# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៣៧

បាលីប្រែ ៥៤

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# បរមត្ថជោតិកា អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# ខុទ្ទកនិកាយ

# សុត្តនិបាត តតិយភាគ

# ៣៧

## បាលីប្រែ ៥៤



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី៣៧
# ខុទ្ទកនិកាយ សុត្តនិបាត
# តតិយភាគ

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## ឧរគវគ្គទី ១

### ឧរគសូត្រទី ១

[ ១ ] *ភិក្ខុណា បន្ទោបង់សេចក្តីក្រោធដែលធ្លលឡើងហើយ ដូចបុគ្គលបន្សាបពិសពស់ ដែលជ្រាបទៅ ដោយឱសថទាំង-ឡាយ ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សកសំណាកចាស់គ្រាំគ្រាចេញ ។ ភិក្ខុណា ផ្តាច់បង់រាគៈ មិនមានសេសសល់ ដូចគេកាត់ផ្កាឈូកដែលដុះក្នុងស្រះ ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សកសំណាកចាស់គ្រាំគ្រាចេញ ។ ភិក្ខុណា បានផ្តាច់បង់តណ្ហា មិនមានសេសសល់ ញុំាងតណ្ហាដែលជាកិលេសជាត ត្រាច់ទៅ អន្ទោលទៅដោយរហ័សឲ្យរីងស្ងួត ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សកសំណាកចាស់គ្រាំគ្រាចេញ ។ ភិក្ខុណា កម្ចាត់មានះ មិនមាន*

សេសសល់ ដូចជំនន់ធំ កម្ចាត់បង់នូវស្ពានបបុស ដែលទុព្វល-
ភាពក្រៃលែង ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូច
ពស់សកសំណកចាស់គ្រាំគ្រាចេញ ។ ភិក្ខុណា កាលស្វែងរក
មិនបាន នូវសារៈក្នុងភពទាំងឡាយ ដូចបុគ្គលស្វែងរកនូវផ្កាឰដ៏
ដើមល្វាទាំងឡាយ ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ
ដូចពស់សកសំណកចាស់គ្រាំគ្រាចេញ ។ សេចក្ដីក្រោធមិនមាន
ក្នុងសន្ដាននៃភិក្ខុណា មួយទៀត ភិក្ខុណា ប្រព្រឹត្តកន្លងនូវបុណ្យ
និងបាប ភិក្ខុនោះ ឈ្មោះថា បានលះបង់ត្រើយខាងអាយ ដូច
ពស់សកសំណកចាស់គ្រាំគ្រាចេញ ។ ភិក្ខុណា កម្ចាត់បង់ ផ្ដាច់
បង់ ឲ្យជ្រះស្រឡះនូវវិតក្កទាំងឡាយ ខាងក្នុងសន្ដានមិនមាន
សេសសល់ ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូច
ពស់សកសំណកចាស់គ្រាំគ្រាចេញ ។ ភិក្ខុណា មិនស្ទុះទៅ មិន
ក្រាញនៅ ប្រព្រឹត្តកន្លងនូវបបញ្ចធម៌ទាំងអស់នេះបាន ភិក្ខុនោះ
ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សកសំណកចាស់
គ្រាំគ្រាចេញ ។ ភិក្ខុណា មិនស្ទុះទៅ មិនក្រាញនៅ ព្រោះដឹង
ច្បាស់ថា ធម្មជាតមានខន្ធជាដើមទាំងអស់នេះ មិនទៀងទាត់ ភិក្ខុ
នោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សកសំណក
ចាស់គ្រាំគ្រាចេញ ។ ភិក្ខុណា មិនស្ទុះទៅ មិនក្រាញនៅ ជាអ្នក

ប្រាសចាកលោភៈ ដោយគិតថា ធម្មជាតមានខន្ធជាដើមទាំងអស់នេះ មិនទៀងទាត់ ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សកសំណកចាស់គ្រាំគ្រាចេញ ។ ភិក្ខុណា មិនស្ទុះទៅ មិនក្រាញនៅ ជាអ្នកប្រាសចាករាគៈ ដោយគិតថា ធម្មជាតមានខន្ធជាដើមទាំងអស់នេះ មិនទៀងទាត់ ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សកសំណកចាស់គ្រាំគ្រាចេញ ។ ភិក្ខុណា មិនស្ទុះទៅ មិនក្រាញនៅ ជាអ្នកប្រាសចាកទោសៈ ដោយគិតថា ធម្មជាតមានខន្ធជាដើមទាំងអស់នេះ មិនទៀងទាត់ ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សកសំណកចាស់គ្រាំគ្រាចេញ ។ ភិក្ខុណា មិនស្ទុះទៅ មិនក្រាញនៅ ជាអ្នកប្រាសចាកមោហៈ ដោយគិតថា ធម្មជាតមានខន្ធជាដើមទាំងអស់នេះ មិនទៀងទាត់ ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សកសំណកចាស់គ្រាំគ្រាចេញ ។ អនុសយក្កិលេសណាមួយ មិនមានដល់ភិក្ខុណា ឬអកុសលមូលដែលភិក្ខុដកចេញហើយ ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សកសំណកចាស់គ្រាំគ្រាចេញ ។ កិលេសដែលកើតអំពីសេចក្តីក្រវល់ក្រវាយណាមួយ ដែលជាបច្ច័យដើម្បីមកកាន់ត្រើយខាងអាយ គឺសក្កាយ មិនមានដល់ភិក្ខុណា ភិក្ខុនោះ

ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សកសំណកចាស់គ្រាំគ្រាចេញ ។ កិលេសដែលកើតអំពីព្រៃ គឺតណ្ហាណាមួយ ជាមូលហេតុដើម្បីចងសត្វទុកក្នុងភព មិនមានដល់ភិក្ខុណា ភិក្ខុនោះឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សកសំណកចាស់គ្រាំគ្រាចេញ ។ ភិក្ខុណា លះបង់នីវរណៈ ៥ ប្រការ ជាអ្នកមិនតានតឹង ចួងសេចក្ដីងឿងឆ្ងល់ ប្រាសចាកសរ គឺកិលេស ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សកសំណកចាស់គ្រាំគ្រាចេញ ។

ឧរគសូត្រទី ១ ចប់

# អដ្ឋកថា
# បរមត្ថជោតិកា
# ខុទ្ទកនិកាយ សុត្តនិបាត

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

## ឧរគវគ្គទី ១

## ឧរគសូត្រ

ខ្ញុំព្រះករុណា ( ពុទ្ធឃោសាចារ្យ ) សូមថ្វាយអភិវាទដល់ព្រះរតនត្រ័យ ដែលឧត្តមជាងវត្ថុដែលគួរថ្វាយបង្គំទាំងឡាយ ហើយនឹងអធិប្បាយអត្ថនៃសុត្តនិបាត ដែលព្រះលោកនាថ ទ្រង់ស្វែងរកផ្លូវនៃការរួចផុតចាកលោក ទ្រង់មានប្រក្រតីលះបង់នូវសេចក្តីវិនាសបន្តិចបន្តួច ទ្រង់បានសម្តែងហើយ ក្នុងគម្ពីរខុទ្ទកនិកាយ ។

សុត្តនិបាតនេះ បានឈមចុះក្នុងគម្ពីរខុទ្ទកនិកាយនោះឯង ព្រោះដូច្នោះខ្ញុំនឹងអធិប្បាយសេចក្តីនៃសុត្តនិបាតនេះ ។

បើមានពាក្យសួរថា ព្រោះហេតុអ្វីគម្ពីរនេះ ចម្រុះទៅដោយគាថារាប់រយប្រកបដោយគេយ្យៈ និងវេយ្យាករណៈ ទើបបានឈ្មោះថាសុត្តនិបាតទៅវិញ ។

ឆ្លើយថា ដែលហៅថា សូត្រ ព្រោះព្រះពុទ្ធត្រាស់ល្អហើយ ព្រោះហូរ

ចេញនូវប្រយោជន៍ទាំងឡាយ ព្រោះជាគ្រឿងជ្រកកោន ព្រោះលម្អិតសេចក្តី និងព្រោះសម្តែងចេញនូវអត្ថទាំងឡាយដោយល្អ និបាតនេះ ដែលព្រះធម្ម-សង្គាហកាចារ្យទាំងឡាយ ប្រមូលចងក្រងព្រះសូត្រទាំងឡាយបែបនោះហើយ សង្ខេបសេចក្តីដោយប្រការយ៉ាងនោះ ដូច្នោះ ទើបបានឈ្មោះថា សុត្តនិបាត ។

ម្យ៉ាងទៀត ព្រះសូត្រទាំងអស់ដោយកំណត់ហើយ ក៏ជាព្រះតម្រាស់របស់ព្រះពុទ្ធដែលជាតាទិបុគ្គល ហើយគម្ពីរនេះ ក៏ជាការចងក្រងព្រះសូត្រទាំងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា **សុត្តនិបាត** ព្រោះមិនមានលក្ខណៈពិសេស ដែលជាគ្រឿងចំណាំឲ្យហៅឈ្មោះដទៃទៅបានឡើយ ។

ក្នុងសុត្តនិបាតនេះ បានទទួលការដាក់ឈ្មោះយ៉ាងនេះ បើពោលដោយវគ្គ ក៏មាន ៥ វគ្គ គឺឧរគវគ្គ ១ ចូឡវគ្គ ១ មហាវគ្គ ១ អដ្ឋកវគ្គ ១ បារាយនវគ្គ ១ ។

បណ្តាវគ្គទាំង ៥ នោះ ឧរគវគ្គ ជាវគ្គដំបូង បើពោលដោយសូត្រហើយ ក្នុងឧរគវគ្គមាន ១២ សូត្រ ក្នុងចូឡវគ្គមាន ១៤ សូត្រ ក្នុងមហាវគ្គមាន ១២ សូត្រ ក្នុងអដ្ឋកវគ្គមាន ១៦ សូត្រ ក្នុងបារាយនវគ្គមាន ១៦ សូត្រ រួមជា ៧០ សូត្រ ។

បណ្តាសូត្រទាំងនោះ ឧរគសូត្រជាសូត្រទី ១ បើពោលដោយប្រមាណនៃបរិយត្តិហើយ ក៏មាន ៨ ភាណវារ តែបើពោលដោយប្រមាណនៃវគ្គ សូត្រ និងបរិយត្តិទាំងនេះ ឧរគសូត្រនេះ មានគាថាដំបូងថា

ភិក្ខុណាបន្ទោបង់សេចក្តីក្រោធ ដែលឆួលឡើងហើយ ដូចបុគ្គល
បន្សាបពិសពស់ដែលជ្រាបទៅ ដោយឱសថទាំងឡាយ ភិក្ខុនោះ
ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សកសំណកចាស់
គ្រាំគ្រាចេញ ។

ព្រោះដូច្នោះ បន្ទាប់អំពីនេះ ដើម្បីនឹងបានអធិប្បាយសេចក្តីនៃគាថា
នោះ ទើបលោកពោលបញ្ហាកម្មនេះថា

គាថានេះ អ្នកណាពោល ពោលក្នុងទីណា ពោលក្នុងកាលណា ពោល
ព្រោះហេតុអ្វី ខ្ញុំនឹងប្រកាសសេចក្តីនេះ ហើយអធិប្បាយអត្ថនៃគាថានោះ ។

សួរថា គាថានេះ អ្នកណាពោល ពោលក្នុងទីណា ពោលក្នុងកាល
ណា ពោលព្រោះហេតុអ្វី ។

ឆ្លើយថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បានទទួលព្យាករក្នុងសម្នាក់
ព្រះពុទ្ធ ២៤ អង្គ ទ្រង់បំពេញបារមីដរាបដល់សោយព្រះជាតិជាព្រះវេស្សន្តរ
ហើយទ្រង់បដិសន្ធិក្នុងតុសិតភព ។ ទ្រង់ចុតិអំពីតុសិតភពនោះហើយ ក៏បដិសន្ធិ
ក្នុងសក្យត្រកូល បានយាងចេញមហាភិនេស្រ្កមណ៍ ទ្រង់សម្រេចសម្ពោ-
ធិញ្ញាណត្រង់មណ្ឌលពោធិព្រឹក្ស ហើយទ្រង់សម្តែងធម្មចក្ក ទ្រង់សម្តែងធម៌
ដើម្បីជាប្រយោជន៍ដល់ទេវតា និងមនុស្សដោយលំដាប់ ។ ក្នុងគាថានេះ ព្រះ
ដ៏មានព្រះភាគអង្គនោះ ទ្រង់ជាសយម្ភូ មិនមានអាចារ្យ ទ្រង់ត្រាស់ដឹងដោយ
ព្រះអង្គឯង បានពោលហើយ ។ គាថានោះ ព្រះដ៏មានព្រះភាគត្រាស់ហើយ

ដើម្បីសម្តែងព្រះធម្មទេសនាដល់ភិក្ខុទាំងឡាយ ដែលនៅក្នុងក្រុងអាឡវី ក្នុងកាលដែលព្រះអង្គទ្រង់បញ្ញត្តកូតគាមសិក្ខាបទ ក្នុងក្រុងអាឡវីនោះ ។

ការវិសជ្ជនាដោយសង្ខេប ក្នុងគាថាទី ១ នេះ មានប្រមាណប៉ុណ្ណោះ ចំណែកការវិសជ្ជនាដោយពិស្តារ អ្នកសិក្សាគប្បីជ្រាបបានដោយអំណាចនៃទូរេនិទាន អវិទូរេនិទាន និងសន្តិកេនិទានដូចតទៅ

ក្នុងនិទានទាំង ៣ យ៉ាងនោះ ឈ្មោះថា **ទូរេនិទាន** បានដល់ កថាដែលពោលដល់រឿងរបស់ព្រះដ៏មានព្រះភាគ តាំងអំពីព្រះពុទ្ធព្រះនាមទីបង្ករ រហូតដល់បច្ចុប្បន្ន ។

ឈ្មោះថា **អវិទូរេនិទាន** បានដល់ កថាដែលពោលដល់រឿងរបស់ព្រះដ៏មានព្រះភាគ តាំងអំពីតុសិតភព រហូតដល់បច្ចុប្បន្ន ។

ដែលឈ្មោះថា **សន្តិកេនទាន** បានដល់ កថាដែលប្រារព្ធរឿងរបស់ព្រះដ៏មានព្រះភាគ តាំងអំពីពោធិមណ្ឌល រហូតដល់បច្ចុប្បន្ន ។

ក្នុងនិទានទាំង ៣ នោះ **អវិទូរេនិទាន** និង **សន្តិកេនិទាន** ចាត់ចូលក្នុង **ទូរេនិទាន** នោះឯង ដូច្នោះ អ្នកសិក្សាគប្បីជ្រាបវិសជ្ជនាក្នុងទីនេះដោយពិស្តារ ដោយអំណាចនៃទូរេនិទានប៉ុណ្ណោះ ។

ការវិសជ្ជនានេះ ខ្ញុំក៏បានពោលហើយ ក្នុងអដ្ឋកថាជាតក ព្រោះដូច្នោះទើបក្នុងទីនេះ មិនបានពោលឲ្យពិស្តារទៀត ព្រោះអ្នកសិក្សាគប្បីជ្រាបដោយន័យពិស្តារ ដែលខ្ញុំពោលហើយ ក្នុងអដ្ឋកថាជាតកនោះឯង ។

ចំណែកសេចក្តីប្លែកគ្នាមានដូចតទៅនេះ ក្នុងគាថាទី ១ នៃអដ្ឋកថាជាតកនោះ រឿងកើតឡើងក្នុងនគរសាវត្ថី ក្នុងព្រះសូត្រនេះ រឿងកើតឡើងក្នុងដែនអាឡវី ដែលព្រះធម្មសង្គាហកាចារ្យពោលថា សម័យនោះ ព្រះដ៏មានព្រះភាគ គង់នៅត្រង់អគ្គាឡវចេតិយ ក្រុងអាឡវី សម័យនោះឯង ពួកភិក្ខុអ្នកក្រុងអាឡវីនាំគ្នាធ្វើនវកម្ម កាប់ឈើឯងខ្លះ ប្រើអ្នកដទៃឲ្យកាប់ខ្លះ កាលភិក្ខុអ្នកស្រុកអាឡវីមួយអង្គកាប់ដើមឈើ ទេវតាដែលអាស្រ័យនៅត្រង់ដើមឈើនោះ បានពោលពាក្យនេះនឹងភិក្ខុនោះថា បពិត្រលោកម្ចាស់ លោកម្ចាស់ត្រូវការធ្វើលំនៅរបស់ខ្លួន កុំកាប់បំផ្លាញទីលំនៅរបស់ខ្ញុំ ភិក្ខុនោះ មិនអើពើនៅតែកាប់នោះឯង ហើយត្រូវដៃកូនទេវតានោះ ។

កាលនោះឯង ទេវតានោះមានសេចក្តីត្រិះរិះដូច្នេះថា អញនឹងសម្លាប់ភិក្ខុនេះក្នុងទីនេះឯង កាលនោះ ទេវតាក៏គិតទៀតថា ការដែលអញសម្លាប់ភិក្ខុរូបនេះឲ្យស្លាប់ក្នុងទីនេះ មិនគួរឡើយ បើដូច្នោះ អញគប្បីក្រាបទូលរឿងនេះដល់ព្រះលោកនាយក ។

កាលនោះឯង ទេវតានោះចូលទៅគាល់ព្រះដ៏មានព្រះភាគដល់ទីប្រថាប់ ហើយបានក្រាបទូលរឿងនេះឲ្យទ្រង់ជ្រាប ។

ព្រះដ៏មានព្រះភាគត្រាស់ថា សាធុ ប្រពៃហើយ ទេវតា ដែលអ្នកមិនផ្តាច់ជីវិតភិក្ខុនោះ ម្នាលទេវតា បើអ្នកផ្តាច់ជីវិតភិក្ខុនេះសោត អ្នកនឹងជួបបាបច្រើន ចូរអ្នកទៅចុះ ដើមឈើក្នុងឱកាសនោះទំនេរ អ្នកចូលទៅអាស្រ័យនៅ

ត្រង់ដើមឈើនោះ ។ កាលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ ដើម្បីកម្ចាត់សេចក្ដីក្រោធ ដែលកើតឡើងហើយដល់ទេវតានោះ ទើបត្រាស់គាថា ( ក្នុងធម្មបទ ) នេះថា

បុគ្គលណា ឃាត់សេចក្ដីក្រោធ ដែលកើតឡើង
ហើយ ដូចសារថីទប់រថដែលកំពុងលឿនបាន ។

បន្ទាប់អំពីនោះ កាលភិក្ខុទាំងឡាយក្រាបទូល ព្រោះហេតុដែលបានស្ដាប់ពួកមនុស្សពោលទោសយ៉ាងនេះថា ហេតុអ្វីហ្ន៎ ពួកសមណសក្យបុត្តកាប់ដើមឈើឯងខ្លះ ប្រើអ្នកដទៃឲ្យកាប់ខ្លះ ពួកសមណសក្យបុត្ត រមែងបៀតបៀនវត្ថុដែលមានជីវិត ដែលមានឥន្ទ្រិយតែមួយ ដូច្នេះហើយ ទើបព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទនេះថា ភិក្ខុធ្វើភូតគាម មានឈើ និងស្មៅជាដើមឲ្យវិនាស ត្រូវអាបត្តិបាចិត្តិយៈ ដូច្នេះ ។ ដើម្បីទ្រង់សម្ដែងធម៌ដល់ភិក្ខុទាំងឡាយដែលមកក្នុងទីនោះ ទើបត្រាស់គាថានេះថា

ភិក្ខុណា បន្ទោបង់សេចក្ដីក្រោធ ដែលធ្លលឡើង
ហើយ ដូចបុគ្គលបន្សាបពិសពស់ ដែលជ្រាបទៅ
ដោយឱសថទាំងឡាយ ដូច្នេះ ។

រឿងដូចគ្នានេះឯង ដល់នូវការសង្គ្រោះក្នុងទីដែលមក ៣ កន្លែង គឺក្នុងវិន័យ ក្នុងធម្មបទ ក្នុងសុត្តនិបាត ដោយប្រការដូច្នេះ ។

ដោយពាក្យប្រមាណប៉ុណ្ណេះ មាតិកានោះ លោកបានតាំងហើយថា

គាថានេះ អ្នកណាពោល ពោលក្នុងទីណា ពោលកាលណា ពោលព្រោះហេតុអ្វី ខ្ញុំនឹងប្រកាសវិធីនេះ ហើយអធិប្បាយអត្ថនៃពាក្យនោះ ។

មាតិកានោះ ឈ្មោះថា ខ្ញុំប្រកាសហើយដោយសង្ខេបផង ដោយពិស្តារផង រៀរតែការអធិប្បាយសេចក្តីប៉ុណ្ណោះក្នុងគាថាមួយនេះមានអធិប្បាយដូច្នេះ

បទថា **យោ** បានដល់ ភិក្ខុណា គឺដូចម្តេច គឺបួសចាកខត្តិយត្រកូលក្តី បួសអំពីព្រាហ្មណត្រកូលក្តី ជាអ្នកបួសថ្មីក្តី ជាមជ្ឈិមភិក្ខុក្តី ជាថេរៈក្តី ។

បទថា **ឧប្បតិតំ** បានដល់ ដែលធ្លាក់ទៅហើយ ដែលទៅហើយ ដែលប្រព្រឹត្តទៅហើយខាងលើៗ មានពាក្យអធិប្បាយថា ដែលកើតឡើងហើយ ។

ធម្មតាសេចក្តីក្រោធដែលកើតឡើងនេះ មានច្រើនប្រភេទ គឺវត្តមាន ១ ភុត្វាបគតៈ ១ ឱកាសកតៈ ១ ភូមិលទ្ធៈ ១ ។

បណ្តាសេចក្តីក្រោធទាំង ៤ ប្រភេទនោះ សេចក្តីដល់ព្រមនៃការកើតឡើងជាដើម ដែលត្រូវបច្ច័យតាក់តែងទាំងអស់ ឈ្មោះថា វត្តមានុប្បន្ន ដែលលោកពោលសំដៅយកថា **ឧប្បន្នា ធម្មា អនុប្បន្នា ធម្មា ឧប្បាទិនោ ធម្មា** ពួកធម៌កើតឡើងហើយ ពួកធម៌មិនទាន់កើតឡើង ពួកធម៌ដែលប្រុងនឹងកើតឡើង ។

កុសល និងអកុសល ពោល គឺភុត្វាបគតៈ ដែលសោយរសនៃអារម្មណ៍ហើយរលត់ទៅ និងសង្ខតៈដ៏សេស ពោល គឺភុត្វាបគតៈ ដែលមិនដល់ខណៈទាំង ៣ មានឧប្បាទក្ខណៈជាដើមហើយរលត់ទៅ ឈ្មោះថា ភុត្វាបគតុប្បន្ន ។

*កុត្វាបគតុប្បន្នៈនេះ គប្បីឃើញបានក្នុងពាក្យថា* **ឯវរូបំ ចាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ** *មានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះ កើតឡើងដូច្នេះ ។ និង ក្នុងសូត្រទាំងឡាយ មានសូត្រថា* **យថា ច ឧប្បន្នស្ស សតិសម្ពោជ្ឈង្គស្ស ភាវនាចារិប្វូរី ហោតិ** *កាលសតិសម្ពោជ្ឈង្គកើតឡើងហើយ ការបំពេញ ភាវនាឲ្យបរិបូណ៌ ក៏រមែងមាន យ៉ាងណា ។*

*កម្មដែលលោកពោលហើយ ដោយន័យជាដើមយ៉ាងនេះថា* **យានិស្ស បុព្វេ ចាបកានិ កម្មានិ កតានិ** *បាបកម្មដែលអ្នកទាំងឡាយបានធ្វើក្នុង កាលមុនមានដែរ ដូច្នេះ ។ សូម្បីជាកម្មដែលកន្លងហើយក៏ឈ្មោះថា ឱកាស-កតុប្បន្នៈ ព្រោះហាមនូវវិបាករបស់កម្មដទៃ ហើយឲ្យឱកាសដល់វិបាករបស់ ខ្លួនតាំងនៅ និងព្រោះវិបាកដែលបានឱកាសហើយយ៉ាងនោះ សូម្បីមិនទាន់ កើតឡើង ក៏កើតឡើងបានយ៉ាងពិតប្រាកដ ក្នុងកាលបានធ្វើឱកាសយ៉ាងនេះ ហើយ ។*

*អកុសលដែលមិនទាន់បានដកឡើង ក្នុងភូមិទាំងឡាយនោះ ឈ្មោះថា ភូមិលទ្ធុប្បន្នៈ ។*

*អ្នកសិក្សាគប្បីជ្រាបអត្ថផ្សេងគ្នានៃភូមិនេះ និងភូមិដែលបានហើយ គឺ ខន្ធ ៥ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជាអារម្មណ៍របស់វិបស្សនា ឈ្មោះ ថា ភូមិ កិលេសជាតដែលសមគួរកើតឡើងក្នុងខន្ធ ៥ ឈ្មោះថា ភូមិលទ្ធៈ ព្រោះហេតុនោះឯង ទើបភូមិនោះ ឈ្មោះថា ជាភូមិដែលបានហើយ ដូច្នោះ*

ទើបលោកហៅថា ភូមិលទ្ធៈ ។

ភូមិលទ្ធៈនោះគប្បីបានក៏ដោយអំណាចនៃអារម្មណ៍ ពិតហើយ កិលេស ទាំងអស់ រមែងកើតឡើងប្រារព្ធខន្ធទាំងឡាយរបស់ព្រះទីណាស្រពទាំងឡាយ ដែលលោកកំណត់ហើយ មានខន្ធក្នុងអតីតជាដើម ដោយអំណាចនៃអា-រម្មណ៍ ដូចកិលេសដែលកើតឡើងដល់ទន្ធមាណព និងសេដ្ឋីបុត្រដែលមាន ឈ្មោះសោរេយ្យៈជាដើម ព្រោះប្រារព្ធខន្ធទាំងឡាយរបស់នាងឧប្បលវណ្ណាថេរី និងរបស់ព្រះមហាកច្ចានៈជាដើម ។ បើអារម្មណ៍នេះគប្បីឈ្មោះថាភូមិលទ្ធៈ ហើយសោត បុគ្គលណាក៏មិនគប្បីលះមូលនៃភពបាន ព្រោះហេតុដែលអា-រម្មណ៍នោះ ដែលបុគ្គលណាម្នាក់មិនគប្បីលះបាន តែគប្បីជ្រាបថា ដែល ឈ្មោះថា ភូមិលទ្ធៈ ក៏ដោយអំណាចនៃវត្ថុ ។ ព្រោះថា ខន្ធទាំងឡាយ ដែលមិនបានកំណត់ហើយដោយវិបស្សនា រមែងកើតឡើងក្នុងវត្ថុណាមួយ កិលេសជាតដែលមានវដ្ដៈជាមូល ក៏រមែងដេកត្រាំក្នុងខន្ធទាំងនោះ រាប់តាំង អំពីបានកើតឡើងក្នុងវត្ថុនោះៗ កិលេសជាតនោះៗ គប្បីជ្រាបថាជាភូមិ-លទ្ធុប្បន្នៈ ព្រោះអត្ថថា លះមិនទាន់បាន កិលេសទាំងឡាយដែលលះមិន ទាន់បាន និងដែលដេកត្រាំរឿយៗ ក្នុងពួកខន្ធណា ( រមែងកើតឡើង ) ដល់ បុគ្គលណា ក្នុងវត្ថុនោះ ខន្ធទាំងនោះឯងរបស់បុគ្គលនោះ ជាទីតាំងរបស់ កិលេសទាំងនោះ មិនមែនខន្ធរបស់បុគ្គលដទៃឡើយ ។ ខន្ធដែលជាអតីត ប៉ុណ្ណោះជាទីតាំងនៃកិលេសទាំងឡាយ ដែលបុគ្គលនោះលះមិនទាន់បាន និង

ដែលដេកត្រាំក្នុងអតីតក្ខន្ធទាំងឡាយ មិនមែនខន្ធដទៃក្រៅអំពីនេះឡើយ ក្នុងខន្ធដែលជាអនាគតជាដើម ក៏ន័យនេះ ។ មួយទៀត ខន្ធដែលជាកាមាវចរប៉ុណ្ណោះ ជាទីតាំងនៃកិលេសទាំងឡាយ ដែលសត្វលះមិនទាន់បាន និងដែលដេកត្រាំក្នុងកាមាវចរក្ខន្ធទាំងឡាយ មិនមែនខន្ធក្រៅអំពីនេះឡើយ ក្នុងខន្ធដែលជារូបាវចរ និងអរូបាវចរ ក៏ន័យនេះដូចគ្នា ។

កិលេសជាត ដែលមានវដ្ដៈជាមូលនោះៗ មាននៅក្នុងខន្ធទាំងឡាយរបស់ព្រះអរិយបុគ្គលណា ក្នុងបណ្ដាសោតាបន្នជាដើម ដែលព្រះអរិយបុគ្គលនោះៗ រមែងលះបានដោយមគ្គនោះៗ ខន្ធទាំងនោះៗ របស់ព្រះអរិយបុគ្គលនោះៗ នឹងរាប់ថាជាភូមិមិនបាន ព្រោះមិនជាទីតាំងនៃកិលេស ដែលមានវដ្ដៈជាមូលនោះឯង ដែលព្រះអរិយបុគ្គលនោះៗ លះបានហើយ ។ តែកម្មដែលធ្វើឯណាមួយ ទោះជាកុសលក្ដី ជាអកុសលក្ដី រមែងមានដល់បុថុជ្ជនបាន ព្រោះកិលេស មានវដ្ដៈជាមូល ដែលបុថុជ្ជនលះមិនទាន់បាន ដោយប្រការទាំងពួង ព្រោះហេតុនោះ ទើបវដ្ដៈរបស់បុថុជ្ជននោះប្រព្រឹត្តទៅព្រោះកិលេសជាបច្ច័យ ។

កិលេសជាត ដែលមានវដ្ដៈជាមូលនោះរបស់បុគ្គលនោះ មិនគួរពោលថា មានក្នុងរូបក្ខន្ធប៉ុណ្ណោះ មិនមានក្នុងខន្ធទាំងឡាយ មានវេទនាខន្ធជាដើម ។បេ។ ឬមិនគួរពោលថា មានក្នុងវិញ្ញាណក្ខន្ធប៉ុណ្ណោះ មិនមានក្នុងខន្ធទាំង-ឡាយ មានរូបក្ខន្ធជាដើម ព្រោះហេតុអ្វី ព្រោះថា កិលេសជាតនោះ ដេកត្រាំ

*រឿយៗ ក្នុងខន្ធទាំង ៥ ដោយមិនវិសេសជាងគ្នា ( គឺដោយមិនប្លែកគ្នា ) សេចក្ដីនេះដូចម្ដេច សេចក្ដីថា កិលេសជាតដែលដេកត្រាំក្នុងខន្ធ ៥ នោះ ប្រៀបដូចរសនៃផែនដីជាដើម ដែលជាប់នៅត្រង់ដើមឈើ ដូច្នោះ ឧបមាដូច កាលដើមឈើធំដុះលើផែនដី អាស្រ័យរសនៃដី និងរសនៃទឹក ចម្រើនដុះ ជាលទ្បើងដោយឫស ដើម មែក ត្រួយ ស្លឹកចាស់ ផ្កា និងផ្លែ ព្រោះអា-ស្រ័យរសដី និងរសទឹកនោះជាបច្ច័យ ធ្វើផ្ទៃមេឃឲ្យពេញ មានការបន្តពូជ ជាដើម ក៏ព្រោះពូជដែលបន្តមកតាំងនៅបាន ដល់កប្បាវសាន រសនៃផែនដី ជាដើមនោះ មិនគួរនឹងពោលថា មាននៅត្រង់ឫសប៉ុណ្ណោះ មិនមាននៅត្រង់ ដើមជាដើម ។បេ។ ឬមិនគួរពោលថា មាននៅត្រង់ផ្លែប៉ុណ្ណោះ មិនមាននៅ ត្រង់ឫសជាដើម ព្រោះហេតុអ្វី ព្រោះរសនៃផែនដីជាដើម ជ្រួតជ្រាបទៅក្នុង ឫសជាដើមរបស់ដើមឈើនោះទាំងអស់នោះឯង ដោយមិនវិសេសជាងគ្នា យ៉ាងណា កិលេសជាត ក៏ដូច្នោះ ។*

*ម្យ៉ាងទៀត ឧបមាដូចបុរសណាម្នាក់ធុញទ្រាន់ក្នុងផ្កា និងផ្លែជាដើមនៃ ដើមឈើនោះ គប្បីដាក់ថ្នាំពិសឈ្មោះមណ្ឌូកកណ្ដកៈ ត្រង់ដើមឈើក្នុងទិស ទាំង ៤ កាលបើដូច្នោះ ដើមឈើនោះបានទទួលសម្ផស្សជាពិសនោះ ពាល់ ត្រូវហើយ ក៏មិនអាចឲ្យការបន្តកើតឡើងបាន ព្រោះមានទឹកចេញតិចជាធម្មតា ទាក់ទងចាករសនៃផែនដី និងរសនៃទឹក ត្រូវថ្នាំពិសគ្របសង្កត់ហើយ យ៉ាង ណា កុលបុត្រដែលនឿយណាយ ក្នុងការប្រព្រឹត្តទៅនៃខន្ធ ក៏ដូច្នោះដូចគ្នា*

ប្រារព្ធចម្រើនមគ្គ ៤ ក្នុងសន្តានរបស់ខ្លួន ដូចការដែលបុរសនោះប្រកបថ្នាំពិសត្រង់ដើមឈើក្នុងទិសទាំង ៤ កាលបើដូច្នោះ ខន្ធសន្តាននោះ របស់កុលបុត្រនោះ ដែលផ្សេងគ្នាដោយកម្មទាំងពួង មានកាយកម្មដែលចូលដល់ត្រឹមតែជាកិរិយាជាដើម ព្រោះកិលេសមានវដ្ដៈជាមូល ត្រូវសម្ផស្ស គឺថ្នាំពិស ក្នុងមគ្គទាំង ៤ នោះគ្របសង្កត់ហើយ ដោយប្រការទាំងពួង ទើបមិនអាចផ្ញើសន្តាន គឺភពថ្មីឲ្យកើតឡើងបាន ព្រោះដល់នូវការមិនកើតឡើងក្នុងភពថ្មីជាធម្មតា បើអស់ការប្រកាន់មាំ រមែងរលត់ទៅតែម្យ៉ាង ព្រោះការរលត់ទៅនៃបុរិមវិញ្ញាណ ដូចភ្លើងព្រៃកើតឡើងហើយ រលត់ទៅ ព្រោះអស់កំញ៉ម ដូច្នោះ អ្នកសិក្សាគប្បីជ្រាបសេចក្ដីផ្សេងគ្នានៃភូមិ និងភូមិលទ្ធៈ ដូចពណ៌នាមក ដូច្នេះ ។ ម្យ៉ាងទៀត ឧប្បន្នៈដទៃទៀត ៤ យ៉ាង គឺសមុទាចារុប្បន្នៈ ១ អារម្មណាធិគ្គហិតុប្បន្នៈ ១ អវិក្ខម្ភិតុប្បន្នៈ ១ អសមុហតុប្បន្នៈ ១ ។

ក្នុងឧប្បន្នទាំង ៤ នោះ ធម្មជាតដែលកើតឡើងក្នុងបច្ចុប្បន្ន ឈ្មោះថាសមុទាចារុប្បន្ន ។

កិលេសជាត សូម្បីកើតឡើងក្នុងចំណែកខាងដើម ក្នុងអារម្មណ៍ដែលមកកាន់គន្លងនៃចក្ខុទ្វារជាដើម លោកហៅថា អារម្មណាធិគ្គហិតុប្បន្ន ព្រោះត្រូវកើតឡើងយ៉ាងពិតប្រាកដក្នុងចំណែកដទៃ ព្រោះហេតុដែលខ្លួនបានទទួលអារម្មណ៍បានហើយនោះឯង ក្នុងសេចក្ដីនេះ មានកិលេសជាតដែលកើតឡើង

ដល់ព្រះមហាតិស្សត្ថេរ ដែលត្រាច់ទៅបិណ្ឌបាតក្នុងកល្យាណគ្រាម ព្រោះការឃើញរូបដែលជាវិសភាគគ្នាជាគុំរូ គប្បីជ្រាបបយោគក្នុងពាក្យទាំងឡាយជាដើមថា **ឧប្បន្នំ កាមវិតក្កំ** កាមវិតក្កកើតឡើងហើយដល់បុគ្គលនោះ ដូច្នេះជាដើម ។

កិលេសជាត ដែលសង្កត់សង្កិនមិនបានដោយអំណាចនៃសមថៈ និងវិបស្សនាណាមួយ សូម្បីមិនមកកាន់ការបន្តនៃចិត្តហើយ ក៏ឈ្មោះថា អវិក្ខម្ភិតុប្បន្ន ព្រោះមិនមានហេតុដែលឃាត់ការកើតឡើងបាន អវិក្ខម្ភិតុប្បន្ននោះ គប្បីឃើញក្នុងអាគតដ្ឋានទាំងឡាយជាដើមថា **អយំបិ ខោ ភិក្ខវេ អានាបានស្សតិសមាធិ ភាវិតោ ពហុលីកតោ សន្តោ ចេវ បណីតោ ច អសេចនកោ ច សុខោ ច វិហារោ ឧប្បន្នុប្បន្នេ ច បាបកេ អកុសលេ ធម្មេ ឋានសោ អន្តរធាបេតិ វូបសមេតិ** ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិនេះឯង ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ជាធម៌ល្អិតផង ជាធម៌ឧត្តមផង ជាធម៌មិនប្រឡូកប្រឡំដោយ ( តណ្ហា និងឧបាទាន ) ផង ជាធម៌ជាគ្រឿងនៅ នាំមកនូវសេចក្តីសុខផង តែងញុំាងអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងហើយៗ ឲ្យសាបសូន្យទៅ ឲ្យស្ងប់រម្ងាប់ដោយហេតុដ៏សមគួរផង ដូច្នេះ ។

ចំណែកកិលេសជាតដែលសង្កត់បានហើយដោយសមថៈ និងវិបស្សនា លោកហៅថា អសមុហតុប្បន្ន ព្រោះអធិប្បាយថា មិនកន្លងការកើតឡើងជា

ធម្មតា ព្រោះកិលេសជាតនោះ មិនទាន់ដកបានដោយអរិយមគ្គ ក្នុងសេចក្ដីនេះ មានកិលេសជាតដែលកើតឡើងដល់ព្រះថេរៈ អ្នកបានសមាបត្តិ ៨ ដែលកំពុងហោះទៅក្នុងអាកាស បានស្ដាប់សំឡេងច្រៀងរបស់ស្ត្រី ដែលកំពុងបេះផ្កាទាំងឡាយ ត្រង់ដើមឈើមានផ្កានាជាយព្រៃ ដែលច្រៀងដោយសំឡេងដ៏ពីរោះ ជាគំរូ ។

អ្នកសិក្សាគប្បីជ្រាបការប្រកបប្រយោគនៃឧប្បន្ននោះ ក្នុងពាក្យទាំងឡាយជាដើមថា **អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ ឋានសោ អន្តរធាបេតិ វូបសមេតិ** ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចម្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យក្រាស់ក្រែលនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងញុំាងអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងហើយៗ ឲ្យវិនាស ឲ្យស្ងប់រម្ងាប់ទៅដោយស្រួលយ៉ាងនេះឯង ដូច្នេះ ។

ឯអារម្មណាធិគ្គហិតុប្បន្ន អវិក្ខម្ភិតុប្បន្ន និងអសមុហតុប្បន្នទាំង ៣ យ៉ាងនេះ គប្បីជ្រាបថា រមែងដល់នូវការសង្គ្រោះដោយភូមិលទ្ធៈនោះឯង ។

កាលកិលេសជាត មានប្រភេទតាមដែលពោលហើយនោះ កើតឡើងហើយយ៉ាងនេះឯង សេចក្ដីក្រោធនេះ ក៏គប្បីជ្រាបថា កើតឡើងហើយដោយអំណាចនៃភូមិលទ្ធុប្បន្ន អារម្មណាធិគ្គហិតុប្បន្ន អវិក្ខម្ភិតុប្បន្ន និងអសមុហតុប្បន្ន ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា បុគ្គលគប្បីកម្ចាត់សេចក្តីក្រោធនោះដោយវិធីយ៉ាងនេះ ព្រោះថា បុគ្គលរមែងអាចកម្ចាត់សេចក្តីក្រោធ ដែលកើតឡើងហើយ ដែលមានប្រភេទតាមដែលពោលមកយ៉ាងនេះ ដោយវិន័យណាមួយបាន ឯកិលេសជាតនេះពោល គឺវត្តមានៈ កុត្វាបកតៈ ឱកាសកតៈ និងសមុទាចារៈកើតឡើងហើយ សេចក្តីព្យាយាមក្នុងកិលេសជាតនេះ រមែងមិនមានផល និងមិនអាចកើតឡើង ព្រោះថា សេចក្តីព្យាយាមក្នុងកិលេស-ជាត គឺសេចក្តីក្រោធដែលជាកុត្វាបគតៈ ឈ្មោះថា មិនមានផល ព្រោះកិលេសជាតនោះរលត់ទៅហើយ ក្នុងវាងនៃសេចក្តីព្យាយាម សូម្បីក្នុងសេចក្តីក្រោធ ដែលជាឱកាសកតៈក៏ដូចគ្នា សេចក្តីព្យាយាមក្នុងកិលេសជាតដែលជាវត្តមានុប្បន្ន និងសមុទាចារុប្បន្ន ក៏មិនអាចធ្វើបាន ព្រោះសេចក្តីសៅហ្មង និងសេចក្តីផូរផង់មិនកើតឡើងព្រមគ្នា ។

ក្នុងបទថា **វិនេតិ** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា

ឈ្មោះថា វិន័យ មាន ២ យ៉ាង ក្នុង ២ យ៉ាងនេះ មួយៗ ចែកជា ៥ យ៉ាង ក្នុង ៥ យ៉ាងនោះ វិន័យនេះ លោកហៅថា **វិនេតិ** ក៏ដោយវិធី ៨ យ៉ាង ។

ព្រោះថា វិន័យនេះមាន ២ យ៉ាង គឺសំវរវិន័យ ១ បហានវិន័យ ១ ក្នុងវិន័យ ២ យ៉ាងនេះ វិន័យមួយៗ ចែកជា ៥ យ៉ាង សូម្បីសំវរវិន័យ ក៏មាន ៥ គឺសីលសំវរៈ ១ សតិសំវរៈ ១ ញាណសំវរៈ ១ ខន្តិសំវរៈ ១

វិរិយសំវរៈ ១ ។

សូម្បីបហានវិន័យក៏មាន ៥ គឺតទង្គប្បហាន ១ វិក្ខម្ភនប្បហាន ១ សមុច្ឆេទប្បហាន ១ បដិបស្សទ្ធិប្បហាន ១ និស្សរណប្បហាន ១ ។

ក្នុងសំវរវិន័យទាំង ៥ យ៉ាងនោះ ការសង្រួមដែលមកហើយក្នុងពាក្យទាំងឡាយជាដើមថា

ពាក្យថា ជាអ្នកសង្រួម គឺជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិតអែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រម ដោយការសង្រួមក្នុងបាតិមោក្ខនេះ ឈ្មោះថា **សីលសំវរៈ** ។

ការសង្រួមដែលមកហើយ ក្នុងពាក្យទាំងឡាយជាដើមថា

រក្សានូវចក្ខុន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ ឈ្មោះថា **សតិសំវរៈ** ។

ការសង្រួមដែលមកហើយ ក្នុងពាក្យទាំងឡាយជាដើមថា

សតិ ជាគ្រឿងទប់ខ្សែតណ្ហាទាំងឡាយនោះ ដែលមាននៅក្នុងលោក តថាគតពោលថា សតិជាគ្រឿងរាំងខ្សែតណ្ហាទាំងឡាយ បុគ្គលគប្បីបិទខ្សែតណ្ហាទាំងនោះ ដោយបញ្ញា ដូច្នេះ ឈ្មោះថា **ញាណសំវរៈ** ។

ការសង្រួមដែលមកហើយ ក្នុងពាក្យទាំងឡាយជាដើមថា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកអត់ធ្មត់នូវត្រជាក់ ក្តៅ ... ដូច្នេះ ឈ្មោះថា **ខន្តិសំវរៈ** ។

ការសង្រួមដែលមកហើយក្នុងពាក្យទាំងឡាយជាដើមថា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនទទួលរ៉ាប់រង លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានតទៅទៀត នូវកាមវិតក្កដែលកើតឡើងហើយ ... ដូច្នេះ ហៅថា **វិរិយសំវរៈ** ។

ការសង្រួមទាំងអស់នេះ លោកហៅថា **សំវរ** ក៏ព្រោះសង្រួមនូវកាយទុច្ចរិត និងវចីទុច្ចរិតជាដើម ដែលគប្បីសង្រួម ហៅថា **វិនយ** ព្រោះកម្ចាត់កាយទុច្ចរិត និងវចីទុច្ចរិតជាដើម ដែលគប្បីកម្ចាត់តាមសមគួរដល់ខ្លួន ។ សំវរវិន័យ គប្បីជ្រាបថា ចែកជា ៥ យ៉ាង យ៉ាងនេះ ។

មួយវិញទៀត ការបន្តសន្តានដែលមិនមានប្រយោជន៍ឯណា ប្រព្រឹត្តទៅក្នុងអង្គនៃវិបស្សនាទាំងឡាយ មាននាមរូបបរិច្ឆេទជាដើម ដោយអំណាចការមិនទាន់លះខ្លួនបានដរាបណា ការលះសន្តានដែលមិនមានប្រយោជន៍នោះៗ ដោយញាណនោះៗ ក៏រមែងមានដរាបនោះ ។

សេចក្តីនេះដូចម្តេច គឺការលះសក្កាយទិដ្ឋិដោយការកំណត់នាមរូប លះអហេតុកទិដ្ឋិ លះវិសមហេតុកទិដ្ឋិ ដោយការកំណត់បច្ច័យ លះសេចក្តីសង្ស័យដោយការឆ្លងផុតសេចក្តីសង្ស័យ ដែលជាចំណែកដទៃនៃការកំណត់បច្ច័យនោះឯង លះការប្រកាន់ថាអញ ថារបស់អញ ដោយការពិចារណាកលាបៈ លះនូវសេចក្តីសម្គាល់ថាមគ្គ ក្នុងធម៌ដែលមិនមែនមគ្គ ដោយការកំណត់មគ្គនិងធម៌ដែលមិនមែនមគ្គ លះឧច្ឆេទទិដ្ឋិ ដោយការឃើញការកើតឡើង លះ

សស្សតទិដ្ឋិ ដោយការឃើញការអស់ទៅ សូន្យទៅ លះនូវការសម្គាល់ថា វត្ថុដែលមិនមានភ័យ ក្នុងវត្ថុដែលមានភ័យ ដោយការឃើញភ័យ លះនូវសេចក្តីសម្គាល់ថា ការត្រេកអរ ដោយការឃើញទោស លះនូវការសម្គាល់ថា ការត្រេកអរក្រៃលែង ដោយការតាមឃើញការនឿយណាយ លះនូវភាពជាបុគ្គលមិនប្រាថ្នាដើម្បីរួចផុត ដោយមុញ្ចិតុកម្យតាញាណ លះនូវការមិនព្រងើយ ដោយឧបេក្ខាញាណ លះនូវធម្មទិដ្ឋិដោយអនុលោមញ្ញាណ លះនូវការកំណត់សង្ខារនិមិត្តដែលផ្ទុយគ្នានឹងព្រះនិព្វាន ដោយគោត្រភូញាណ នេះឈ្មោះថា **តទង្គប្បហាន** ។

ការលះនីវរណៈទាំងឡាយ ដែលឧបចារសមាធិ និងអប្បនាសមាធិកម្ចាត់បាន រហូតដល់ធ្វើខ្លួនមិនឲ្យវិនាសចាកសមាធិនោះ និងប្រព្រឹត្តទៅ និងការលះ ពោល គឺការមិនកើតឡើងនៃបច្ចនិកធម៌ មានវិតក្កជាដើមតាមសមគួរដល់ខ្លួន ឈ្មោះថា **វិក្ខម្ភនប្បហាន** ។

ការលះ ពោល គឺការកាត់ផ្តាច់នូវកងនៃកិលេស ដែលជាចំណែកនៃសមុទយៈ ដែលលោកពោលហើយដោយន័យជាដើមថា ដើម្បីលះទិដ្ឋិតាមកិច្ចរបស់ខ្លួន ក្នុងសន្តានរបស់ខ្លួន ដោយប្រកបដោយអង្គមគ្គនោះៗ ព្រោះបានចម្រើនអរិយមគ្គ ៤ ហើយ ដោយការមិនប្រព្រឹត្តទៅ ដោយឥតសេសសល់ នេះ ឈ្មោះថា **សមុច្ឆេទប្បហាន** ។

ការដែលកិលេសទាំងឡាយស្ងប់រម្ងាប់ទៅ ក្នុងខណៈនៃផល ឈ្មោះថា

**បដិបស្សទ្ធិប្បហាន ។**

*ចំណែកព្រះនិព្វាន ដែលលះសង្ខតធម៌ទាំងពួងបាន ព្រោះរលាស់នូវសង្ខតធម៌ទាំងពួងចេញទៅបាន ឈ្មោះថា* **និស្សរណប្បហាន ។**

*ព្រោះហេតុដែលការលះទាំងអស់នេះ ឈ្មោះថា* **បហាន** *ព្រោះអត្ថថាលះបង់ ឈ្មោះថា* **វិនយ** *ព្រោះអត្ថជាគ្រឿងកម្ចាត់ ដូច្នោះ ទើបហៅថា* **បហានវិនយ ។**

*ម្យ៉ាងទៀត ការលះនេះលោកហៅថា* **បហានវិនយ** *ក៏ព្រោះការមាននៃវិន័យនោះៗ ដោយការលះនូវការប្រព្រឹត្តិកន្លងនោះៗ បាន សូម្បីបហានវិន័យនេះ គប្បីជ្រាបថា ចែកចេញជា ៥ យ៉ាង ដូចពណ៌នាមក ដូច្នេះ ។*

*វិន័យទាំងនេះចាត់ជា ១០ យ៉ាង ព្រោះវិន័យ ១ ចែកជា ៥ ដោយប្រការដូច្នេះ ។*

*ក្នុងវិន័យ ១០ យ៉ាងនោះ វៀរបដិបស្សទ្ធិវិន័យ និងនិស្សរណវិន័យហើយ វិន័យនេះលោកហៅថា* **វិនេតិ** *គឺរមែងកម្ចាត់ដោយបរិយាយនោះៗ ដោយវិន័យ ៨ យ៉ាងដ៏សេស សួរថា រមែងកម្ចាត់ដូចម្តេច ឆ្លើយថា ព្រោះថា បុគ្គលកាលកម្ចាត់កាយទុច្ចរិត និងវចីទុច្ចរិតដោយសីលសំវរៈ ឈ្មោះថារមែងកម្ចាត់សេចក្តីក្រោធ ដែលប្រកបដោយកាយទុច្ចរិត និងវចីទុច្ចរិតនោះ សូម្បីកម្ចាត់នូវអភិជ្ឈា និងទោមនស្សជាដើម ដោយសតិសំវរៈ និងបញ្ញាសំវរៈ ឈ្មោះថា រមែងកម្ចាត់សេចក្តីក្រោធដែលប្រកបដោយទោមនស្ស កាលអត់ធន់*

នូវការរង្គាជាដើម ដោយខន្តិសំវរៈ ឈ្មោះថា រមែងកម្ចាត់សេចក្តីក្រោធ ដែលកើតចាកធាតុនោះៗ បាន ស្មូម្បីកម្ចាត់ព្យាបាទវិតក្ក ដោយវីរិយសំវរៈ ឈ្មោះថា រមែងកម្ចាត់សេចក្តីក្រោធ ដែលប្រកបដោយព្យាបាទវិតក្កនោះបាន ។

តទង្គប្បហាន វិក្ខម្ភនប្បហាន និងសមុច្ឆេទប្បហាន រមែងមានដោយធម៌ពួកណា បុគ្គលលះនូវធម៌នោះៗ ដោយមិនឲ្យធម៌ទាំងនោះប្រព្រឹត្តទៅក្នុងខ្លួន ក៏ឈ្មោះថា រមែងកម្ចាត់សេចក្តីក្រោធ ដែលមានឋានៈជាមួយនឹងធម៌ដែលគប្បីប្រហារដោយអង្គនោះៗ ដែលខ្លួនគប្បីសង្កត់ និងដែលខ្លួនគប្បីលះ ។

ក្នុងទីនេះ ស្មូម្បីវិន័យនឹងកើតឡើងមិនបាន ព្រោះបហានវិន័យក៏ពិតតែការលះរមែងមានដោយធម៌ពួកណា បុគ្គលស្មូម្បីកម្ចាត់ដោយធម៌ទាំងនោះ លោកក៏ហៅថា រមែងកម្ចាត់ដោយបហានវិន័យ ដោយបរិយាយ ។

ចំណែកក្នុងកាលនៃបដិបស្សទ្ធិប្បហាន បុគ្គលនោះលោកហៅថា រមែងកម្ចាត់ធម៌ណាមួយ ដោយធម៌ទាំងឡាយនោះមិនបាន ព្រោះនិស្សរណប្បហាន ជាសភាវធម៌ដែលអ្នកបដិបត្តិមិនគប្បីឲ្យកើតឡើងបាន ព្រោះមិនមានវត្ថុដែលគប្បីលះ ។

ក្នុងវិន័យ ១០ យ៉ាងនេះ វៀរបដិបស្សទ្ធិវិន័យ និងនិស្សរណវិន័យហើយ វិន័យនេះលោកហៅថា រមែងកម្ចាត់បានដោយបរិយាយនោះៗ ដោយវិន័យ ៨ យ៉ាងដ៏សេស ដោយប្រការដូច្នេះ ។

ព្រះដ៏មានព្រះភាគ ត្រាស់ការកម្ចាត់អាឃាត ( ក្នុងអង្គុត្តរនិកាយ

បញ្ចកនិបាត ) ៥ យ៉ាង យ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងដល់ភិក្ខុ ភិក្ខុត្រូវកម្ចាត់បង់ដោយសព្វគ្រប់ ព្រោះអាឃាតប្បដិវិន័យណា អាឃាតប្បដិវិន័យនេះ មាន ៥ យ៉ាង ។ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវចម្រើនមេត្តាចិត្តចំពោះបុគ្គលនោះ ។បេ។ ភិក្ខុត្រូវចម្រើនករុណាចិត្ត ... ភិក្ខុត្រូវចម្រើនឧបេក្ខាចិត្ត ... ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវប្រតិបត្តិនូវការមិនធ្វើទុកក្នុងចិត្ត ដោយស្មារតីចំពោះបុគ្គលនោះ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវតាំងនូវភាពនៃខ្លួនជាអ្នកមានកម្មជារបស់ខ្លួន ចំពោះបុគ្គលនោះថា អ្នកនេះ មានកម្មជារបស់ខ្លួន ជាអ្នកទទួលយកនូវកម្ម មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពំនាក់ អ្នកនេះ នឹងធ្វើកម្មណា ទោះល្អក្តី អាក្រក់ក្តី គង់អ្នកនោះទទួលយកកម្មនោះពុំខានឡើយ ដូច្នេះ ។

ហើយលោកពោលការកម្ចាត់អាឃាត ៥ យ៉ាង ដោយន័យជាដើមយ៉ាងនេះថា

នែអាវុសោទាំងឡាយ គំនុំកើតឡើងដល់ភិក្ខុ ភិក្ខុត្រូវកម្ចាត់បង់ដោយសព្វគ្រប់ ព្រោះអាឃាតប្បដិវិន័យណា អាឃាតប្បដិវិន័យនេះ មាន ៥ យ៉ាង ។ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ក្នុងលោក

នេះ មានបុគ្គលខ្លះ ជាអ្នកមានការប្រព្រឹត្តិដោយកាយមិនបរិសុទ្ធ មានការប្រព្រឹត្តិដោយវាចាដ៏បរិសុទ្ធ ... ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញដោយប្រការយ៉ាងនេះ ដូច្នេះ ។

បុគ្គលនេះ សូម្បីកម្ចាត់អាឃាតណាមួយ ក្នុងបណ្ដាអាឃាត ៥ យ៉ាងនោះ លោកហៅថា **វិនេតិ** ។

ម្យ៉ាងទៀត ព្រោះកាលភិក្ខុរឭកដល់ឱវាទរបស់ព្រះសាស្ដា ( ក្នុងកកចូបមសូត្រ ) យ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ បើពួកចោរ ដែលប្រព្រឹត្តអាក្រក់នាំគ្នា អារអវយវៈតូចធំរបស់អ្នកទាំងឡាយ ដោយរណារដែលមានដងទាំងសងខាង ភិក្ខុណាមួយ ញុំាងចិត្តឲ្យប្រទូស្តចំពោះចោរទាំងអម្បាលនោះ ភិក្ខុនោះ មិនឈ្មោះថា ជាអ្នកធ្វើតាមសាសនារបស់តថាគត ដោយការមិនអត់សង្កត់នោះឡើយ ដូច្នេះ ។

កាលរឭកដល់ឱវាទរបស់ព្រះដ៏មានព្រះភាគ ដែលត្រាស់ ( នៅក្នុងសំយុត្តនិកាយ សគាថវគ្គ ) ទៀតថា

អ្នកណាក្រោធតបនឹងបុគ្គលអ្នកក្រោធ អ្នកនោះឯង រមែងមានសេចក្ដីអាក្រក់ ព្រោះសេចក្ដីក្រោធនោះ បុគ្គលមិនក្រោធតបនឹងបុគ្គលអ្នកក្រោធ ឈ្មោះថា ឈ្នះសង្គ្រាម ដែលគេឈ្នះបានដោយកម្រ អ្នកណាដឹងថា អ្នកដទៃក្រោធនឹងខ្លួន ហើយមាន

ស្មារតីរម្ងាប់សេចក្តីក្រោធបាន អ្នកនោះ ឈ្មោះថា ប្រព្រឹត្តនូវប្រយោជន៍ដល់ជនទាំង ២ នាក់ គឺខ្លួន និងអ្នកដទៃ ដូច្នេះ ។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះ ជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ តែងមកកាន់ស្ត្រីភាព ឬបុរិសភាពដែលមានសេចក្តីក្រោធ ។ ធម៌ ៧ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សត្រូវក្នុងលោកនេះ រមែងប្រាថ្នានូវហេតុយ៉ាងនេះដល់សត្រូវថា ឱហ្ន៎ ចូរឲ្យបុគ្គលនេះ មានវណ្ណៈអាក្រក់ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ សត្រូវរមែងមិនត្រេកអរដល់សត្រូវព្រោះវណ្ណៈទេ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលនេះ ( កាលបើ ) មានសេចក្តីក្រោធ មានសេចក្តីក្រោធគ្របសង្កត់ មានសេចក្តីក្រោធរួបរឹតហើយ បុរសបុគ្គលនោះ ទុកជាងូតស្អាត លាបស្រឡាបល្អបាន កោរសក់ និងពុកមាត់ ហើយស្លៀកសំពត់មានពណ៌សក៏ពិតហើយ ប៉ុន្តែ បុរសបុគ្គលនោះ ឈ្មោះថា មានវណ្ណៈអាក្រក់ ជាអ្នកមានសេចក្តីក្រោធគ្របសង្កត់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ទី ១ ជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬបុរសភាពដែលមានសេចក្តីក្រោធ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវរមែងប្រាថ្នានូវហេតុយ៉ាងនេះដល់សត្រូវថា ឱហ្ន៎ ចូរឲ្យបុគ្គលនេះដេកជាទុក្ខ ... ឱហ្ន៎ ចូរឲ្យបុគ្គលនេះកុំមានប្រយោជន៍ច្រើនឡើយ ... ឱហ្ន៎ ចូរឲ្យបុគ្គលនេះ កុំមានភោគៈ

ឡើយ ... ឱហ្ន៎ ចូរឲ្យបុគ្គលនេះ កុំមានយសឡើយ ... ឱហ្ន៎ ចូរឲ្យបុគ្គលនេះ កុំមានមិត្តឡើយ ... ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវរមែងប្រាថ្នាយ៉ាងនេះ ដល់សត្រូវថា ឱហ្ន៎ ចូរឲ្យបុគ្គលនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ គប្បីចូលទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ រឿងនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ សត្រូវរមែងមិនត្រេកអរដល់សត្រូវ ដោយដំណើរទៅកាន់សុគតិទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែ បុរសបុគ្គលនេះ មានសេចក្តីក្រោធ មានសេចក្តីក្រោធគ្របសង្កត់ មានសេចក្តីក្រោធរួបរឹតហើយ ក៏ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ លុះបុគ្គលដែលមានសេចក្តីក្រោធគ្របសង្កត់នោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ដូច្នេះ ។

កាលពិចារណាទោសក្នុងសេចក្តីក្រោធ ដោយន័យជាដើមយ៉ាងនេះថា
បុគ្គលអ្នកក្រោធ មិនដឹងនូវសេចក្តីចម្រើន បុគ្គលអ្នកក្រោធមិន
ឃើញនូវធម៌ សេចក្តីក្រោធគ្របសង្កត់នូវជនណា សេចក្តីងងឹត
រមែងមានប្រាកដដល់ជននោះ ក្នុងកាលនោះដែរ ដូច្នេះ ។
សត្វទាំងឡាយ ក្រោធហើយ ព្រោះសេចក្តីក្រោធណា តែងទៅ
កាន់ទុគ្គតិ សត្វទាំងឡាយអ្នកឃើញច្បាស់ ដឹងដោយបញ្ញា ដ៏ប្រពៃ

ហើយ រមែងលះបង់សេចក្ដីក្រោធនោះបាន ដូច្នេះ ។

បុគ្គលគួរលះបង់សេចក្ដីក្រោធចេញ គួរលះបង់មានះចេញ គួរកន្លងសញ្ញោជនធម៌ទាំងអស់ចោលចេញ ... ដូច្នេះ ។

សេចក្ដីក្រោធ ជាហេតុឲ្យកើតសេចក្ដីវិនាស សេចក្ដីក្រោធជាហេតុញ៉ាំងចិត្តឲ្យកម្រើក ភ័យកើតឡើងក្នុងសន្ដាន ជនមិនបានដឹងនូវភ័យនោះឡើយ ដូច្នេះ ។

បពិត្រតាបស មានប្រាជ្ញាដូចជាផែនដី សូមលោកម្ចាស់អត់នូវកំហុសម្ដង បណ្ឌិតទាំងឡាយ មិនមានសេចក្ដីក្រោធជាកម្លាំងទេ ដូច្នេះ ។

សេចក្ដីក្រោធ ក៏រមែងដល់នូវការកម្ចាត់ទៅដូច្នោះ បុគ្គលនេះ សូម្បីពិចារណាយ៉ាងនេះហើយ កម្ចាត់នូវសេចក្ដីក្រោធ លោកហៅថា **វិនេតិ** ។

បទថា **កោធំ** បានដល់ អាឃាតដែលកើតអំពីអាឃាតវត្ថុណាមួយក្នុងបណ្ដាអាឃាតវត្ថុ ១៨ គឺអាឃាតវត្ថុ ៩ យ៉ាង ដែលព្រះដ៏មានព្រះភាគត្រាស់ក្នុងព្រះសូត្រដោយន័យថា រមែងកើតអាឃាតឡើងថា ជនឯណោះបានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញជាដើម និងអាឃាតវត្ថុ ៩ យ៉ាងដែលសម្រេចហើយ ដោយន័យផ្ទុយនឹងអាឃាតវត្ថុ ៩ យ៉ាងដំបូងនោះឯងថា ជនឯណោះ មិនបានប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់អញជាដើម ដែលរួមជាអាឃាតវត្ថុ ១៩ មួយអន្លើដោយសេចក្ដីក្រោធ ក្នុងវត្ថុដែលមិនគួរ

មានជង្គត់ និងបន្ទាមុតជាដើម ។

បទថា **វិសដំ** បានដល់ ជ្រាបទៅ ។ បទថា **សប្បវិសំ** បានដល់ ពិសពស់ ។ បទថា **ឥវ** ជាពាក្យឧបមា ។ លោកពោលយ៉ាងនេះថា **សប្បវិសំវ** ព្រោះលុប **ឥ** អក្ខរៈចេញ ។

បទថា **ឱសថេហិ** បានដល់ ដោយថ្នាំទាំងឡាយ លោកអធិប្បាយថា បុគ្គលណារមែងកម្ចាត់ គឺរមែងអត់សង្កត់ បានដល់ រមែងលះ រមែងបន្ទោបង់ រមែងធ្វើឲ្យដល់ទីបំផុតនូវសេចក្តីក្រោធ ដែលកើតឡើងតាមអត្ថដែលពោលហើយ គឺដែលផ្សាយទូទៅក្នុងចិត្តសន្តាន ហើយតាំងនៅ ដោយឧបាយណាមួយ ក្នុងបណ្តាឧបាយគ្រឿងកម្ចាត់ទាំងឡាយ តាមដែលពោលហើយ ដូចគ្រូដែលកម្ចាត់ពិស ដែលត្រូវពស់ខាំ គប្បីកម្ចាត់ពិសពស់ដែលជ្រួតជ្រាបទៅពេញរាងកាយ ហើយតាំងនៅដោយថ្នាំច្រើនប្រភេទ បណ្តាថ្នាំដែលធ្វើដោយឫសឈើ ដើមឈើ សម្បកឈើ ស្លឹក និងផ្កាជាដើមឯណានីមួយ ឬដោយឱសថដែលផ្សំឡើង បានធាប់រួសរាន់ ដូច្នោះ ។

បាទព្រះគាថាថា **សោ ភិក្ខុ ជហាតិ ឱរបារំ** សេចក្តីថា ភិក្ខុនោះកម្ចាត់សេចក្តីក្រោធយ៉ាងនេះ ព្រោះហេតុដែលសេចក្តីក្រោធ លោកលះបានដោយឥតសេសសល់ដោយមគ្គទី ៣ គឺអនាគាមិមគ្គ ដូច្នោះ ភិក្ខុនោះគប្បីជ្រាបថា រមែងលះឱរម្ភាគិយសំយោជនៈ ៥ ប្រការ ដែលហៅថា ត្រើយអាយ និងត្រើយនាយចេញបាន តែកាលពោលដោយមិនប្លែកគ្នាហើយ ពាក្យថា **ឱរំ**

ជាឈ្មោះរបស់ត្រើយ ដូច្នោះ ទើបលោកហៅថា **ឱរបារំ** ព្រោះអធិប្បាយថា ត្រើយអាយ ព្រោះជាច្រាំងនៃសមុទ្រ គឺសង្សារវដ្តទាំងនោះ ។

ម្យ៉ាងទៀត ភិក្ខុណាកម្ចាត់សេចក្តីក្រោធ ដែលកើតឡើងបាន ដូចគ្រូពស់កម្ចាត់ពិសពស់ដែលផ្សាយទៅដោយឱសថ ដូច្នោះ ភិក្ខុនោះកម្ចាត់សេចក្តីក្រោធបានឥតសេសសល់ដោយតតិយមគ្គ ហើយតាំងនៅក្នុងអនាគាមិផល ឈ្មោះថា រមែងលះនូវត្រើយអាយ និងត្រើយនាយបាន ។

ក្នុងបទថា **ឱរបារំ** នោះ អត្តភាពរបស់ខ្លួន ឈ្មោះថា **ឱរំ** គឺត្រើយអាយ អត្តភាពរបស់អ្នកដទៃ ឈ្មោះថា **បារំ** គឺត្រើយនាយ ។

ម្យ៉ាងទៀត អាយតនៈខាងក្នុង ៦ ឈ្មោះថា ត្រើយអាយ អាយតនៈខាងក្រៅ ៦ ឈ្មោះថា ត្រើយនាយ ។

ម្យ៉ាងទៀត មនុស្សលោក ឈ្មោះថា ត្រើយអាយ ទេវលោក ឈ្មោះថា ត្រើយនាយ កាមធាតុ ឈ្មោះថា ត្រើយអាយ រូបធាតុ និងអរូបធាតុ ឈ្មោះថា ត្រើយនាយ កាមភព និងរូបភព ឈ្មោះថា ត្រើយអាយ អរូបភព ឈ្មោះថា ត្រើយនាយ ។ អត្តភាព ឈ្មោះថា ត្រើយអាយ ឧបករណ៍នៃសេចក្តីសុខរបស់អត្តភាព ឈ្មោះថា ត្រើយនាយ ។

ភិក្ខុលះនូវឆន្ទរាគក្នុងត្រើយអាយ និងត្រើយនាយនេះដោយមគ្គទី ៤ យ៉ាងនេះ លោកហៅថា រមែងលះត្រើយអាយ និងត្រើយនាយបាន ក្នុងត្រើយអាយ និងត្រើយនាយនេះ ព្រះអនាគាមីមិនមានឆន្ទរាគឡើយ ក្នុង

អត្តភាពនេះជាដើម ព្រោះលោកលះកាមរាគបានហើយក៏ពិត តែលោកក៏នៅពោលថា រមែងលះនូវត្រើយអាយ និងត្រើយនាយបាន ដោយការលះឆន្ទរាគក្នុងគាថានោះ ព្រោះសង្គ្រោះត្រើយអាយ និងត្រើយនាយទាំងអស់នេះចូលគ្នា ក៏ដើម្បីប្រកាសគុណនៃមគ្គទី ៤ នោះ ដូចមគ្គទី ៣ ជាដើម ។

ឥឡូវនេះ ដើម្បីនឹងប្រកាសសេចក្ដីនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ឧបមាថា ដូចពស់សកសំណកចាស់គ្រាំគ្រាចេញ ដូច្នោះ ។

ក្នុងគាថានោះ មានវិនិច្ឆ័យដូចតទៅនេះ សត្វដែលឈ្មោះថា **ឧរគ** ព្រោះអត្ថវិគ្គហៈថា ទៅដោយទ្រូង ។ ពាក្យថា **ឧរគ** ជាឈ្មោះរបស់ពស់ ។ ពស់នោះមាន ២ ប្រភេទ គឺពស់ដែលមានកាមជារូប ១ ពស់ដែលមានអកាមជារូប ១ ។ ពស់មានកាមជារូបមាន ២ ប្រភេទ គឺពស់ដែលកើតក្នុងទឹក ១ ពស់ដែលកើតលើគោក ១ ។ ពស់ដែលកើតក្នុងទឹក រមែងបានកាមរូបក្នុងទឹកប៉ុណ្ណោះ មិនបានកាមរូបលើគោកឡើយ ដូចសង្ខបាលនាគ-រាជ ក្នុងសង្ខបាលជាតក ។ ពស់ដែលកើតលើគោក រមែងបានកាមរូបលើគោកប៉ុណ្ណោះ មិនបានកាមរូបក្នុងទឹកឡើយ ពស់នោះរមែងសកនូវស្បែកដែលហៅថាសំណក ព្រោះជារបស់ចាស់ ព្រោះតាំងនៅអស់កាលយូរ ទើបសកដោយវិធី ៤ យ៉ាង គឺតាំងនៅក្នុងជាតិកំណើតរបស់ខ្លួន ១ ស្អប់ខ្ពើម ១ ព្រោះអាស្រ័យ ១ ដោយកម្លាំង ១ ។

ជាតិកំណើតរបស់ពស់ ឈ្មោះថា **សជាតិ** បានដល់ មានខ្លួនវែង ព្រោះ

ថា ពស់ទាំងឡាយមិនកន្ទងជាតិកំណើតរបស់ខ្លួន ក្នុងឋានៈទាំង ៥ គឺ ក្នុងកាលកើតឡើង ១ ក្នុងកាលចុតិ ១ ក្នុងកាលកន្ទងនូវនិទ្រាដែលខ្លួនដេកហើយ ១ ក្នុងកាលសេពមេថុនជាមួយនាគី ដែលមានជាតិកំណើតស្មើគ្នា ១ ក្នុងកាលសកសំណាក ១ ។ ព្រោះកាលណាក៏ដោយដែលពស់សកសំណាក កាលនោះ ត្រូវនៅជាពស់ តាំងនៅក្នុងជាតិកំណើតរបស់ខ្លួននោះឯង ក៏រមែងសក ទោះបីតាំងនៅក្នុងជាតិកំណើតរបស់ខ្លួន ក៏ត្រូវរង្កៀស ទើបសក ។

ពស់ដែលឈ្មោះថា ស្អប់ស្រកា គឺកាលណាក៏ដោយ ដែលខ្លួនផុតចាកសំណាកក្នុងឋានៈពាក់កណ្តាល ម្យ៉ាងទៀត មិនផុតចាកសំណាកទៅក្នុងឋានៈពាក់កណ្តាលសំយុងនៅ កាលនោះ ពស់នោះស្អប់ខ្ពើម រមែងសកសំណាកនោះ ។

ពស់នោះ សូម្បីរង្កៀសយ៉ាងនេះ អាស្រ័យចន្លោះឈើខ្លះ ចន្លោះឫសឈើខ្លះ ក្រហែងដីខ្លះ សកនូវសំណាកនោះ ។

ពស់នោះបានអាស្រ័យរវាងដើមឈើជាដើម កាលសក ធ្វើកម្លាំងឲ្យកើតហើយ ធ្វើនូវឧស្សាហ៍ ព្យាយាម ធ្វើកន្ទុយឲ្យវៀច ដកដង្ហើមចូល បើកពពារ សកសំណាកបាន ពស់នោះសកយ៉ាងនេះហើយ ក៏រមែងចៀសទៅបានតាមប្រាថ្នា យ៉ាងណា ភិក្ខុនេះក៏ដូច្នោះដូចគ្នា ប្រាថ្នានឹងលះត្រៃយអាយនិងត្រៃយនាយ រមែងលះទៅដោយអាការ ៤ គឺតាំងនៅ ហើយក្នុងជាតិកំណើតរបស់ខ្លួន ១ ស្អប់ខ្ពើមនូវសំណាក ១ រមែងសកសំណាកព្រោះ

អាស្រ័យ ១ រមែងសកដោយកម្លាំង ១ ។

សីល ឈ្មោះថា ជាតិកំណើតរបស់ភិក្ខុ ព្រោះព្រះបាលីថា តាំងអំពីអាត្មាកើតហើយក្នុងអរិយជាតិ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា នរជនមានប្រាជ្ញា បានតាំងមាំក្នុងសីលហើយជាដើម ។ ភិក្ខុតាំងនៅក្នុងជាតិរបស់ខ្លួននេះ យ៉ាងនេះហើយ ស្អប់ខ្ពើមនូវត្រើយអាយ និងត្រើយនាយមានអត្តភាពរបស់ខ្លួនជាដើម ដែលញ៉ាំងទុក្ខឲ្យកើតឡើង ព្រោះការឃើញទោសក្នុងរឿងនោះៗ ដូចពស់ស្អប់ខ្ពើមនូវស្រកាគ្រាំគ្រារបស់ខ្លួន ដូច្នោះ អាស្រ័យនូវកល្យាណមិត្តទាំងឡាយ ធ្វើនូវកម្លាំង ពោល គឺសេចក្ដីព្យាយាមដែលមានប្រមាណក្រៃលែងឲ្យកើតឡើង ចែកពេលយប់ និងពេលថ្ងៃជា ៦ ចំណែក ហើយព្យាយាម ដោយន័យដែលលោកពោលថា ភិក្ខុក្នុងសាសនានេះ ចូលទៅចង្ក្រមក្នុងវេលាថ្ងៃ សម្អាតចិត្តចាកអាវរណីយធម៌ទាំងឡាយដូច្នេះជាដើម អង្គុយពត់ក្អែន ដូចពស់ធ្វើកន្ទុយរបស់ខ្លួនឲ្យវៀច ដូច្នោះ ភិក្ខុនេះព្យាយាម ព្រោះភាពដែលខ្លួនមានសេចក្ដីព្យាយាមមិនរួញរា ដូចពស់កំពុងដកដង្ហើមចូល ដូច្នោះ ភិក្ខុនេះធ្វើនូវការផ្សាយទៅនៃញាណ ឲ្យកើតឡើង ដូចពស់បើកពពារទៅ ដូច្នោះ រមែងលះត្រើយអាយ និងត្រើយនាយចេញបាន ដូចពស់សកនូវសំណាកដូច្នោះ កាលលះនូវត្រើយអាយ និងត្រើយនាយបានហើយ ភិក្ខុនេះ ជាអ្នកមានភារៈដាក់ចុះហើយ ដូចពស់សកស្រកាហើយដូច្នោះ រមែងឈានទៅកាន់ទិស គឺអនុបាទិសេសនិព្វានធាតុបានតាម

ប្រាថ្នា ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា

*ភិក្ខុណាបន្ទោបង់សេចក្ដីក្រោធ ដែលធ្លលឡើងហើយ ដូចបុគ្គល បន្សាបពិសពស់ដែលជ្រាបទៅ ដោយឱសថទាំងឡាយ ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សកសំណកចាស់ គ្រាំគ្រាចេញ ។*

គាថាទី ១ នេះ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងដោយកំពូល គឺអរហត្ត ដោយប្រការដូច្នេះឯង ។

ឥឡូវនេះ ដល់លំដាប់ពណ៌នាអត្ថនៃគាថាទី ២ ក្នុងគាថាទី ២ នោះ មានមាតិកាដូចគ្នាថា

គាថានេះ អ្នកណាពោល ពោលក្នុងកាលណា ពោលក្នុងទីណា ពោលព្រោះហេតុអ្វី ខ្ញុំនឹងប្រកាសវិធីនេះ ហើយធ្វើការអធិប្បាយសេចក្ដីនៃគាថានោះ ។

បន្តអំពីនេះទៅ ក៏ព្រោះខ្លាចពិស្ដារពេក ក្នុងគាថាទាំងពួង ខ្ញុំនឹងមិនលើកមាតិកាមកសម្ដែងៗ ត្រឹមតែអត្ថនៃគាថានោះៗ ដោយន័យសម្ដែងអត្ថុប្បត្តិហេតុប៉ុណ្ណោះ នឹងធ្វើការអធិប្បាយអត្ថ គឺគាថាទី ២ នេះថា **យោ រាគមុទច្ឆិទា អសេសំ** ជាដើម ។ គាថាទី ២ នោះ មានហេតុកើតឡើងដូចតទៅនេះ

សម័យមួយ ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតវនារាមរបស់

អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង សុវណ្ណការបុត្តម្នាក់ ដែលជាឧបដ្ឋាករបស់ព្រះសារីបុត្តត្ថេរ បានបួសក្នុងសម្នាក់របស់ព្រះថេរៈ ព្រះថេរៈគិតថា អសុភកម្មដ្ឋានសមគួរសម្រាប់ភិក្ខុកំលោះទាំងឡាយ ទើបឲ្យនូវអសុភកម្មដ្ឋានដល់ភិក្ខុកំលោះនោះ ដើម្បីកម្ចាត់រាគៈ ។ ចិត្ត សូម្បីត្រឹមតែសេពក្នុងកម្មដ្ឋាននោះ ក៏មិនកើតដល់ភិក្ខុនោះ លោកក៏ប្រាប់ដល់ព្រះថេរៈថា កម្មដ្ឋាននេះមិនជាឧបការៈដល់ខ្ញុំ ព្រះថេរៈគិតថា កម្មដ្ឋាននេះសមគួរសម្រាប់ភិក្ខុកំលោះទាំងឡាយ ទើបឲ្យកម្មដ្ឋាននោះដដែលទៀត អស់កាល ៤ ខែ កន្លងទៅយ៉ាងនេះ ភិក្ខុនោះមិនបានគុណវិសេសសូម្បីត្រឹមតែមួយ ។ បន្ទាប់អំពីនោះ ព្រះថេរៈបានក្រាបទូលរឿងភិក្ខុនោះ ដល់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលសារីបុត្ត ការដឹងកម្មដ្ឋាន ដែលជាទីសប្បាយដល់ភិក្ខុនោះ មិនមែនវិស័យរបស់អ្នក ភិក្ខុនេះ ជាពុទ្ធវេនេយ្យ ដូច្នេះហើយ ទើបទ្រង់និម្មិតផ្កាឈូកមានពណ៌ដ៏ល្អដោយឫទ្ធិ ទ្រង់ប្រទានក្នុងដៃរបស់ភិក្ខុនោះហើយ ត្រាស់ថា ម្នាលភិក្ខុ ចូរអ្នកយកទងផ្កាឈូកនេះ ដោតលើផ្នូកខ្សាច់ត្រង់ស្រមោលវិហារ ចូរអង្គុយពត់ភ្នែនបែរមុខទៅរកផ្កាឈូកនោះបរិកម្មថា **លោហិតំ លោហិតំ** ។ បានឮថា ភិក្ខុនេះធ្លាប់កើតជាជាងមាស ៥០០ ជាតិជាប់តគ្នា ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា និមិត្តនៃពណ៌ក្រហមសមគួរសម្រាប់ភិក្ខុនោះ ទើបទ្រង់ប្រទានលោហិតកម្មដ្ឋានដល់ភិក្ខុនោះ ភិក្ខុនោះ បានធ្វើតាមព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគ ត្រឹមមួយ

រយៈប៉ុណ្ណោះ ក៏បានសម្រេចឈាន ៤ ក្នុងទីនោះតាមលំដាប់ ប្រារព្ធឈានកីឡាដោយន័យ មានអនុលោម និងបដិលោមជាដើម ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់អធិដ្ឋានថា ចូរផ្កាបទុមនេះស្វិតស្រពោន ភិក្ខុនោះចេញអំពីឈាន ក៏ឃើញផ្កាឈូកនោះក្រៀមស្វិតទៅជាពណ៌ខ្មៅ ទើបបាននូវអនិច្ចសញ្ញាថា រូបដែលល្អល្អះ ត្រូវជរាញាំញីហើយ បន្ទាប់អំពីនោះ លោកបាននាំផ្កាបទុមដែលក្រៀមស្វិតនោះ បង្អោនចូលទៅខាងក្នុង បន្ទាប់មក លោកបានឃើញភពទាំង ៣ ប្រាកដដូចភ្លើងឆេះទូទៅថា ធម៌ណាមិនទៀង ធម៌នោះជាទុក្ខ ធម៌ណាជាទុក្ខ ធម៌នោះ ជាអនត្តា ។

ក្នុងទីមិនឆ្ងាយអំពីភិក្ខុនោះ ដែលជាអ្នកឃើញយ៉ាងនោះ មានស្រះឈូកមួយ ពួកកុមារទាំងឡាយចុះទៅក្នុងស្រះនោះ កាច់ផ្កាឈូកទាំងឡាយហើយនាំមកធ្វើឲ្យជាគំនរ ផ្កាឈូកក្នុងទឹកទាំងនោះ ប្រាកដដល់ភិក្ខុនោះដូចអណ្ដាតភ្លើងឆេះព្រៃបបុស ស្លឹកទាំងឡាយជ្រុះចុះ ក៏ប្រាកដដល់ភិក្ខុនោះដូចធ្លាក់ទៅក្នុងជ្រោះ ចំណែកកំពូលរបស់ផ្កាឈូកដែលចោលលើគោក ស្វិតស្រពោនទៅហើយ ប្រាកដដូចជាត្រូវភ្លើងឆេះ ។ កាលនោះ ភិក្ខុនោះសម្លឹងពិនិត្យធម៌ទាំងពួងតាមក្រសែនៃព្រះធម៌នោះ ភពទាំង ៣ ក៏ប្រាកដជាសភាវៈមិនមានទីពឹង ដូចផ្ទះដែលត្រូវភ្លើងឆេះ ដូច្នោះ ។

បន្ទាប់អំពីនោះ ព្រះដ៏មានព្រះភាគ ទាំងដែលប្រថាប់គង់នៅក្នុងព្រះគន្ធកុដិនោះឯង ក៏ទ្រង់ផ្សាយរស្មីនៃព្រះសរីរៈទៅខាងលើភិក្ខុនោះ រស្មីនោះក៏

គ្របសង្កត់ផ្ទៃមុខរបស់ភិក្ខុនោះពេញកម្លាំង ។ លំដាប់នោះ លោកអាវជ្ជនៈថា នេះអ្វីហ្ន៎ បានឃើញព្រះដ៏មានព្រះភាគហាក់ដូចជាទ្រង់មកប្រថាប់ឈរក្បែរ ទើបក្រោកអំពីអាសនៈ ផ្គងអញ្ជលី ។

កាលនោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបការសប្បាយរបស់ភិក្ខុនោះ កាលទ្រង់សម្តែងធម៌ ទើបបានត្រាស់ឱភាសគាថានេះថា **យោ រាគមុទច្ឆិទា អសេសំ** ជាដើម ។

ក្នុងគាថានោះ កិលេសដែលឈ្មោះថារាគៈ ក៏ដោយអំណាចនៃតម្រេក ពាក្យថា **រាគ** នេះ ជាឈ្មោះនៃតម្រេក គឺកាមគុណ ៥ ។

បទថា **ឧទច្ឆិទា** បានដល់ កាត់ គឺបំបាក់ បានដល់ ធ្វើឲ្យវិនាស ។ ពិតហើយ អ្នកចងគាថាទាំងឡាយ តែងប្រាថ្នាពាក្យដែលជាវត្តមានាវិភត្តថា **ឆិន្ទតិ** សម្រាប់ពាក្យទាំងឡាយដែលជាអតីតកាល ។

បទថា **អសេសំ** បានដល់ មិនមានចំណែកសល់ គឺអស់ទាំងអនុស័យ ។

ពីរបទថា **ភិសបុប្ផំវ សរោរុហំ** សេចក្តីថា ដូចផ្កាឈូកដែលដុះឡើងហើយក្នុងស្រះ ។ បទថា **វិគយ្ហ** បានដល់ ចុះហើយ អធិប្បាយថា ចូលទៅហើយ ។ ពាក្យដ៏សេស ដូចពោលមកហើយខាងដើមនោះឯង ។

សួរថា លោកពោលអធិប្បាយដូចម្តេច ឆ្លើយថា ប្រៀបដូចក្មេងទាំងនេះចុះកាន់ស្រះ កាច់ផ្កាឈូកដែលដុះក្នុងស្រះយ៉ាងណា ភិក្ខុណាឈមចុះកាន់លោកសន្និវាស គឺត្រៃធាតុនេះ ចូលដល់ហើយនូវន័យ មានយ៉ាងនេះជាដើម

ភ្លើងស្មើដោយរាគៈ មិនមាន ខ្ញុំក្តៅដោយកាមរាគ ចិត្តរបស់ខ្ញុំក្តៅក្រហាយណាស់ ពួកជនណា ត្រេកអរដោយអំណាចរាគៈ ពួកជននោះ តែងធ្លាក់ចុះកាន់ខ្សែតណ្ហា ដូចពីងពាងទម្លាក់ខ្លួនចុះកាន់សំណាញ់ ដែលធ្វើហើយដោយខ្លួនឯង ដូច្នេះ ។

ម្នាលអាវុសោ ចុះបុរសបុគ្គលនេះ ជាអ្នកល្មោភ ត្រូវសេចក្តីលោភគ្របសង្កត់ មានចិត្តត្រូវសេចក្តីលោភរួបរឹត រមែងសម្លាប់នូវសត្វមានជីវិតខ្លះ ។

ដូច្នេះហើយ ក៏ដកនូវរាគៈបន្តិចបន្តួច ដោយការពិចារណាទោសរបស់រាគៈ ដោយការសង្រួមទាំងឡាយ មានការសង្រួមសីលជាដើម មានប្រការតាមដែលខ្ញុំពោលហើយ និងដោយការសម្គាល់ថា មិនស្អាតក្នុងវត្ថុទាំង-ឡាយ ទាំងដែលមានវិញ្ញាណ និងមិនមានវិញ្ញាណ ឈ្មោះថា កាត់កិលេសដែលសល់ ដោយអនាគាមិមគ្គ សូម្បីកិលេសដែលនៅសេសសល់ចាកអនាគាមិមគ្គនោះចេញបានដោយអរហត្តមគ្គ ភិក្ខុនោះ ឈ្មោះថា លះត្រើយនាយចេញបាន ដោយប្រការដែលខ្ញុំពោលហើយខាងដើមនោះឯង ដូចពស់លះបង់សំណកដែលចាស់គ្រាំគ្រាទៅ ដូច្នោះ ។ គាថានេះ ព្រះលោកនាយកទ្រង់សម្តែងហើយដោយកំពូល គឺអរហត្ត ដោយប្រការដូច្នេះ ។ ក្នុងទីបំផុតនៃទេសនា ភិក្ខុនោះ តាំងនៅហើយក្នុងអរហត្ត ។

សួរថា គាថាដែលពោលថា **យោ តណ្ហមុទច្ឆិទា** ជាដើម មានហេតុ

*កើតឡើងដូចម្ដេច ឆ្លើយថា ព្រះដ៏មានព្រះភាគគង់នៅក្នុងនគរសាវត្ថី ភិក្ខុមួយរូបដែលនៅត្រង់មាត់ស្រះបោក្ខរណី ឈ្មោះគគ្គរា កំពុងត្រិះរិះក្នុងអកុ-សលវិតក្ក ដោយអំណាចនៃតណ្ហា ព្រះដ៏មានព្រះភាគទ្រង់ជ្រាបអជ្ឈាស្រ័យរបស់លោក ទើបបានភាសិតឱកាសគាថានេះ ។*

*ក្នុងគាថានោះ ឈ្មោះថា* **តណ្ហា** *ព្រោះអត្ថថា គ្រឿងតក់ស្លុតនៃសត្វ អធិប្បាយថា ពួកសត្វរមែងមិនដល់នូវការឆ្អែត ដោយអារម្មណ៍ទាំងឡាយ ពាក្យថា* **តណ្ហា** *នេះ ជាឈ្មោះរបស់កាមតណ្ហា ភវតណ្ហា និងវិភវតណ្ហា ។*

*បទថា* **សរិតំ** *បានដល់ ទៅហើយ គឺប្រព្រឹត្តទៅហើយ មានពាក្យអធិប្បាយថា លិចលង់សត្វលោករហូតដល់ភវគ្គព្រហ្ម ។ បទថា* **សីឃសរំ** *បានដល់ មានប្រក្រតីទៅរហ័ស មានពាក្យអធិប្បាយថា តណ្ហា ដែលមិនពិចារណាដល់ទោស ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងសម្បរាយភព អាចឲ្យដល់ចក្កវាឡដទៃខ្លះ ភវគ្គព្រហ្មខ្លះ ដោយមួយខណៈប៉ុណ្ណោះ ។*

*បុគ្គលណាធ្វើតណ្ហានេះ ដែលជ្រួតជ្រាបទៅយ៉ាងរហ័ស ដោយប្រការទាំងពួងឲ្យរីងស្ងួតទៅបន្តិចម្ដងៗ ដោយការពិចារណាដល់ទោសយ៉ាងនេះថា*

*តណ្ហា ជាធម្មជាតដ៏ទូលាយក្នុងខាងលើ ដែលសត្វបំពេញបាន*
*ដោយក្រ ជាជំណើរដ៏វេះវាម ដោយអំណាចនៃសេចក្ដីប្រាថ្នា*
*ពួកជនណា ជាប់ជំពាក់ដោយតណ្ហានោះ ពួកជននោះ រមែង*
*ទ្រទ្រង់នូវបក្រ ។*

បុរសមានតណ្ហាជាគម្រប់ពីរ អន្ទោលទៅ ( ក្នុងសង្សារវដ្ត )
អស់កាលដ៏វែង រមែងមិនប្រព្រឹត្តកន្លងនូវសង្សារ គឺ ខន្ធ
ធាតុ អាយតនៈ ដែលមានក្នុងអត្តភាពនេះ និងខាងមុខ
និងដូចគាថាថា បពិត្រមហារាជ សត្វលោកមានតែសេចក្តី
ខ្វះខាត មិនចេះឆ្អែត សុទ្ធតែជាខ្ញុំរបស់តណ្ហា ដូច្នេះ ។

និងដោយគុណទាំងឡាយ មានសីលសំវរៈជាដើម មានប្រការដូចខ្ញុំពោលហើយ ហើយកាត់នូវតណ្ហាមិនឲ្យសេសសល់ ដោយអរហត្តមគ្គ ភិក្ខុនោះ ឈ្មោះថា លះនូវត្រើយអាយ និងត្រើយនាយបាន ដោយប្រការទាំងពួងក្នុងខណៈនោះឯង ក្នុងទីបំផុតនៃទេសនា ភិក្ខុនោះ តាំងនៅហើយ ក្នុងអរហត្ត ។

មានពាក្យសួរថា គាថាថា **យោ មានមុទព្វធី** ជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ឆ្លើយថា ព្រះដ៏មានព្រះភាគ គង់នៅក្នុងនគរសាវត្ថី ភិក្ខុមួយរូប នៅត្រង់ឆ្នេរស្ទឹងគង្គា ឃើញស្ពានដើមបបុសដែលគេធ្វើដើម្បីឆ្លងស្ទឹងក្នុងកាលដែលមានទឹកតិចក្នុងរដូវក្តៅ ត្រូវជំនន់ទឹកធំហូរនាំយកទៅហើយ ក៏កើតនូវសេចក្តីសង្វេគឡើងថា សង្ខារទាំងឡាយ មិនទៀង កំពុងឈរ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបអជ្ឈាស្រ័យរបស់លោក ទើបទ្រង់បន្លឺឱភាសគាថានេះ

មានៈ គឺការប៉ោងឡើងនៃចិត្ត ដែលមានជាតិជាដើមជាវត្ថុ ឈ្មោះថា មានៈក្នុងគាថានោះ ។ មានៈនោះមាន ៣ យ៉ាង គឺប្រកាន់ថាអញ ប្រសើរ

ជាងគេ ១ ប្រកាន់ថាអញស្មើគេ ១ ប្រកាន់ថាអញអាក្រក់ជាងគេ ១ ។

ម្យ៉ាងទៀត មានះមាន ៩ យ៉ាង គឺជាអ្នកប្រសើរជាងគេ សម្គាល់ថាប្រសើរជាងគេ ១ ជាអ្នកប្រសើរជាងគេ សម្គាល់ថាស្មើគេ ១ ជាអ្នកប្រសើរជាងគេ សម្គាល់ថាអន់ជាងគេ ១ ជាអ្នកស្មើគេ សម្គាល់ថា ប្រសើរជាងគេ ១ ជាអ្នកស្មើគេ សម្គាល់ថាស្មើគេ ១ ជាអ្នកស្មើគេ សម្គាល់ថាអន់ជាងគេ ១ ជាអ្នកអន់ជាងគេ សម្គាល់ថាប្រសើរជាងគេ ១ ជាអ្នកអន់ជាងគេសម្គាល់ថាស្មើគេ ១ ជាអ្នកអន់ជាងគេ សម្គាល់ថាអន់ជាងគេ ១ ។

មានពាក្យអធិប្បាយថា ភិក្ខុណាសម្លាប់មានះ មានប្រការទាំងពួងនោះ ដោយការពិចារណាឃើញទោសក្នុងមានះនោះ ដោយន័យថា

សត្វទាំងឡាយ ប្រកាន់ហើយ ព្រោះមានះណា តែងទៅកាន់ទុគ្គតិ ។

ដោយសីលសំវរៈជាដើម មានប្រការដូចខ្ញុំពោលហើយ ដែលលះបានបន្តិចម្តងៗ ឈ្មោះថា ដកឡើងនូវមានះ ដែលដូចជាស្ពានដើមបបុស ព្រោះភាពដែលកិលេសទាំងឡាយមិនមានកម្លាំង និងមានកម្លាំងខ្សោយ ដកកិលេសដ៏សេសដោយអរហត្តមគ្គ ដូចគ្នានឹងជំនន់ទឹកធំ ព្រោះលោកុត្តរធម៌ទាំងឡាយមានកម្លាំងក្រៃលែង កាលដកឡើងដោយអំណាចនៃការលះមិនឲ្យសេសសល់ ឈ្មោះថា សម្លាប់នូវមានះ ភិក្ខុនោះ ឈ្មោះថា លះនូវត្រើយអាយ និងត្រើយនាយបានដោយប្រការទាំងពួងក្នុងខណៈនោះឯង ក្នុងទីបំផុតនៃទេសនា ភិក្ខុនោះ តាំងនៅហើយ ក្នុងអរហត្ត ។

*មានពាក្យសួរថា គាថាថា* **យោ ឆាជ្ឈគមា** *ជាដើម មានអត្ថុប្បត្តិ-ហេតុដូចម្តេច ឆ្លើយថា ការកើតឡើងនៃគាថានេះ និង ១២ គាថាដទៃ ដែលជាគាថាបន្តអំពីនេះ ក៏ដូចគ្នានោះឯង គឺសម័យមួយ ព្រះដ៏មានព្រះភាគ គង់នៅក្នុងនគរសាវត្ថី សម័យនោះឯង ព្រាហ្មណ៍ម្នាក់ កាលកូនស្រីរបស់ខ្លួនតាំងនៅក្នុងបឋមវ័យ ដែលអ្នកដទៃគប្បីសូម បានគិតថា អញនឹងប្រដាប់តាក់តែងកូនស្រីរបស់អញដោយផ្កា ដែលមនុស្សអន់មិនធ្លាប់ប្រើប្រាស់ ហើយបញ្ជូនទៅកាន់ត្រកូលស្វាមី ។ ព្រាហ្មណ៍នោះ កាលពិនិត្យមើលពេញក្រុងសាវត្ថីទាំងខាងក្នុង និងខាងក្រៅ ក៏មិនបានឃើញ សូម្បីត្រឹមតែផ្កាណាមួយ ដែលមនុស្សអន់មិនធ្លាប់ប្រើប្រាស់កាលគាត់បានឃើញពួកក្មេងដែលជាកូនព្រាហ្មណ៍ជាច្រើន ដែលជាពួកអ្នកលេងប្រជុំគ្នា គិតថា អញនឹងសួរក្មេងទាំងនេះក្នុងបណ្តាក្មេងជាច្រើន ពិតជាមានអ្នកណាម្នាក់ស្គាល់ពិត ហើយទើបសួរពួកក្មេងដែលជាកូនព្រាហ្មណ៍ទាំងនោះ ។*

*ពួកកូនព្រាហ្មណ៍ទាំងនោះ កាលនឹងចំអកព្រាហ្មណ៍នោះ ទើបពោលថា នៃព្រាហ្មណ៍ ធម្មតាផ្កាល្វា អ្នកណាមួយក្នុងលោកក៏មិនធ្លាប់ប្រដាប់ សូមលោកឲ្យកូនស្រីរបស់លោកប្រដាប់ផ្កាល្វានោះ ។ ក្នុងថ្ងៃទី ២ ព្រាហ្មណ៍ក្រោកឡើងអំពីព្រលឹម ទាំងមិនទាន់បានទទួលទានអាហារ ក៏ទៅកាន់ព្រៃល្វាដែលដុះក្បែរឆ្នេរស្ទឹងអចិរវតី ហើយស្វែងរកដើមល្វាមួយដើមៗ ក៏មិនឃើញត្រឹមតែទងនៃផ្កាល្វា ពេលវេលាកន្លងទៅរហូតដល់ថ្ងៃត្រង់ ។ ថ្ងៃទី ២ ក៏ទៅ*

កាន់ព្រៃល្វានោះ ។ ភិក្ខុមួយរូបអង្គុយសម្រាកពេលថ្ងៃ មនសិការកម្មដ្ឋាន ត្រង់គល់ល្វា ដែលគួរជាទីត្រេកអរមួយដើម ព្រាហ្មណ៍ចូលទៅកាន់ទីដែល ភិក្ខុនោះអង្គុយ មិនចាប់ភ្លឹក អង្គុយមួយសន្ទុះក្រោកឡើងហើយ ឈរមួយ សន្ទុះ គយគន់នូវដើមឈើនោះ ក្នុងវាងមែក និងប្រគាបទាំងពួង ដល់ នូវសេចក្តីលំបាក ។

លំដាប់នោះ ភិក្ខុនោះពោលនឹងព្រាហ្មណ៍នោះថា នែព្រាហ្មណ៍ លោក ស្វែងរកអ្វី ព្រាហ្មណ៍នោះឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំស្វែងរកផ្កាល្វា ភិក្ខុ នោះពោលថា នែព្រាហ្មណ៍ ធម្មតាផ្កាល្វាមិនមានក្នុងលោក ពាក្យពោលនេះ ជាពាក្យកុហក លោកកុំលំបាកឡើយ ។ កាលណោះ ព្រះដ៏មានព្រះភាគទ្រង់ ជ្រាបអធ្យាស្រ័យរបស់ភិក្ខុនោះ ទើបទ្រង់បញ្ចេញរស្មី ហើយបានត្រាស់ឱកាស គាថាទាំងឡាយនេះដល់ភិក្ខុនោះ ដែលមានមានះច្រើន ដែលប្រមូលមកដល់ ព្រមហើយថា **យោ នាជ្ឈគមា ភវេសុ សារំ** ជាដើម អ្នកសិក្សាគួរពោល គាថាគ្រប់ៗ គាថា ។

បណ្តាគាថាទាំងនោះ នឹងពោលដល់គាថាទី ១ មុន ។ បទថា **នាជ្ឈគមា** បានដល់ មិនដល់ គឺមិនជួប ។

បទថា **ភវេសុ** បានដល់ ក្នុងកាមភព រូបភព អរូបភព សញ្ញីភព អសញ្ញីភព នេវសញ្ញីនាសញ្ញីភព ឯកវោការភព ចតុវោការភព និងបញ្ច- វោការភព ។

*បទថា* **សារំ** *បានដល់ ភាវៈដែលទៀង ឬអត្តភាព ។ បទថា* **វិចិនំ** *បានដល់ ស្វែងរកដោយបញ្ញា ។ បទថា* **បុប្ផមិវ ឧទុម្ពរេសុ** *ជាដើម មានអត្ថយោជនាដូច្នេះថា ព្រះយោគាវចរជ្រើសរើសដោយបញ្ញា ក៏មិនជួបសារៈណាមួយក្នុងភពទាំងឡាយ ដូចព្រាហ្មណ៍នេះ កាលស្វែងរកផ្កាល្វាទាំងឡាយ ក៏មិនជួបផ្កាល្វា ដូច្នោះ ព្រះយោគាវចរនោះ ឃើញធម៌ទាំងនោះដោយភាពមិនទៀង និងដោយភាពមិនមែនខ្លួន ព្រោះអត្ថថា មិនមានសារៈ សម្រេចនូវលោកុត្តរធម៌ទាំងឡាយដោយលំដាប់ ឈ្មោះថា លះនូវត្រើយអាយ និងត្រើយនាយបាន ដូចពស់លះបង់សំណាកដែលចាស់គ្រាំគ្រា ដូច្នោះ ។ តែក្នុងគាថាដ៏សេសទាំងឡាយ ខ្ញុំមិនពោលយោជនានៃគាថានោះទេ ពោលចំពោះតែអត្ថដែលប្លែកគ្នាប៉ុណ្ណោះ ។*

*ក្នុងពីរបាទគាថាថា* **យស្សន្តរតោ ន សន្តិ កោបា ឥតិ ភវា ភវតញ្ច វីតិវត្តោ** *នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ អន្តរសព្ទនេះ ប្រាកដក្នុងអត្ថទាំងឡាយជាច្រើន មានអត្ថថា ហេតុ អត្ថថា កណ្តាល និងអត្ថថា ចិត្តជាដើម ។*

*មកក្នុងអត្ថថា ហេតុ ដូចក្នុងប្រយោគជាដើមថា* **នទីតីរេសុ សណ្ឋានេ សភាសុ រថិយាសុ ច ជនា សង្គម្ម មន្តេន្តិ មញ្ច តញ្ច កិមន្តរំ** *ជនទាំងឡាយ មកប្រជុំនិយាយគ្នា ទៀបច្រាំងស្ទឹងទាំងឡាយផង ក្នុងរោងសម្រាប់សម្រាកផង ក្នុងរោងសម្រាប់ប្រជុំគ្នានិយាយផង នាផ្លូវប្រេកផង ហើយ*

និយាយចំពោះខ្ញុំផង ចំពោះលោកផង តើព្រោះហេតុអ្វី ។

មកក្នុងអត្ថថា កណ្ដាល ដូចក្នុងប្រយោគជាដើមថា **ឱរមត្តកេន វិសេសាធិគមេន អន្តរាវោសានំ** អ្នកមានអាយុនេះ ជាអ្នកភ្លេចស្មារតី ដល់នូវការផ្អាកព្យាយាមក្នុងចន្លោះ ។

មកក្នុងអត្ថថា ចិត្ត ដូចក្នុងប្រយោគជាដើមថា

**អនត្ថជននោ កោធោ កោធោ ចិត្តប្បកោបនោ**

**ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ ។**

សេចក្ដីក្រោធ ជាហេតុឲ្យកើតសេចក្ដីវិនាស សេចក្ដីក្រោធ ជាហេតុញ៉ាំងចិត្តឲ្យកម្រើក ភ័យកើតឡើងក្នុងសន្ដានជនមិនបានដឹងនូវភ័យនោះឡើយ ។

តែក្នុងទីនេះ **អន្តរ** សព្ទ ប្រើក្នុងអត្ថថា ចិត្ត ។ បាទគាថាថា **យស្សន្តរតោ ន សន្តិ កោបា** សេចក្ដីថា សេចក្ដីក្រោធ រមែងមិនមានក្នុងចិត្តរបស់បុគ្គលណា ព្រោះសេចក្ដីក្រោធនោះ លោកដកឡើងហើយដោយមគ្គទី ៣ ព្រោះហេតុដែលសម្បត្តិ ឈ្មោះថា **ភវ** វិបត្តិ ឈ្មោះថា **វិភវ** ម្យ៉ាងទៀត សេចក្ដីចម្រើន ឈ្មោះថា **ភវ** សេចក្ដីវិនាស ឈ្មោះថា **វិភវ** ការទៀង ឈ្មោះថា **ភវ** ការដាច់សូន្យ ឈ្មោះថា **វិភវ** បុណ្យឈ្មោះថា **ភវ** បាប ឈ្មោះថា **វិភវ** បើពោលដោយអត្ថហើយ **វិភវ** ក្ដី **អភវ** ក្ដី មានអត្ថដូចគ្នានោះឯង ដូច្នោះ ក្នុងពាក្យថា **ភវាភវតញ្ច វីតិវត្តោ** នេះ

គប្បីជ្រាបអត្ថយ៉ាងនេះថា ភិក្ខុនោះ ឈ្មោះថា កន្ធងនូវសេចក្តីវិនាស និង សេចក្តីចម្រើន មានប្រការជាអនេក ដែលព្រះដ៏មានព្រះភាគត្រាស់ដោយ អំណាចនៃសម្បត្តិ វិបត្តិ សេចក្តីចម្រើន សេចក្តីវិនាស ការទៀង ការដាច់ សូន្យ បុណ្យ និងបាបដោយមគ្គទាំង ៤ ដោយន័យនោះៗ តាមសមគួរ ដល់ហេតុ ។

ក្នុងបទថា **យស្ស វិតក្កា** ជាដើមនេះ មានអធិប្បាយថា ភិក្ខុណាពិចា-រណាឃើញទោសក្នុងវិតក្កនោះៗ ហើយកម្ចាត់ គឺធ្វើឲ្យស្ងប់ បានដល់ ដុត បំផ្លាញនូវវិតក្ក ៩ យ៉ាង គឺកាមវិតក្ក ១ ព្យាបាទវិតក្ក ១ វិហិង្សាវិតក្ក ១ ញាតិវិតក្ក ១ ជនបទវិតក្ក ១ អមរវិតក្ក គឺការត្រិះរិះដល់ការមិនស្លាប់ ១ បរានុទ្ទយតាបដិសំយុត្តវិតក្ក គឺការត្រិះរិះដែលសម្បយុត្តដោយភាពជាអ្នក អាណិតអាសូរអ្នកដទៃ ១ លាភសក្ការសិលោកវិតក្ក គឺការត្រិះរិះដល់ លាភសក្ការៈ និងកេរ្តិ៍ឈ្មោះ ១ អនវញ្ញត្តិបដិសំយុត្តវិតក្ក គឺការត្រិះរិះ ដែលសម្បយុត្តដោយការមិនមើលងាយ ១ ។

ដោយន័យដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ក្នុងសមន្តកទ្ទកសូត្រ គឺសូត្រពោលអំពីសេចក្តីចម្រើនដោយជុំវិញ ដោយការពិចារណាធម៌ ដែល បដិបក្ខគ្នា និងដោយមគ្គខាងក្រោមទាំង ៣ ដែលអាចលះវត្ថុនោះៗ ចេញ បាន ។

អ្នកសិក្សាគប្បីឃើញអត្ថយ៉ាងនេះថា វិតក្កដែលសល់ ដែលភិក្ខុកម្ចាត់

បានហើយយ៉ាងនេះ ធ្វើឲ្យស្ងប់ខាងក្នុង រមែងមិនកើតឡើងទៀត ក្នុងខន្ធ-សន្តានរបស់ខ្លួន ដែលប្រព្រឹត្តទៅខាងក្នុង គឺក្នុងចិត្តជាខាងក្នុង យ៉ាងណា កិលេសដ៏សេសដែលព្រះអរហន្តកាត់បានហើយ ដោយអរហត្តមគ្គ ក៏ដូច្នោះ ព្រោះវត្ថុដែលកាត់បានហើយ លោកហៅថា **កប្បិត** ដែលលោកពោលថា **កប្បិតកេសមស្សុ** ប្រែថា បុគ្គលមានសក់ និងពុកមាត់កោរហើយ ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានេះ **យោ នាច្ចសារី** ជាដើម ដូចតទៅនេះ

ពីរបទថា **យោ នាច្ចសារី** បានដល់ ភិក្ខុណាមិនស្ទុះហួសទៅ ។ បទថា **ន បច្ចសារី** គឺមិនក្រាញនៅ ។

សួរថា លោកអធិប្បាយដូចម្តេច ឆ្លើយថា លោកអធិប្បាយថា ភិក្ខុណាធ្លាក់ទៅក្នុងឧទ្ធច្ចៈដោយការប្រារព្ធព្យាយាមពេក ឈ្មោះថា រមែងស្ទុះទៅ កាលធ្លាក់ទៅក្នុងកោសជ្ជៈ ដោយសេចក្តីព្យាយាមដែលធូរថយពេក ឈ្មោះថា រមែងក្រាញនៅ ម្យ៉ាងទៀត កាលធ្វើខ្លួនឲ្យលំបាកដោយកវតណ្ហា ឈ្មោះថា រមែងស្ទុះទៅ កាលប្រកបកាមសុខដោយកាមតណ្ហា ឈ្មោះថា រមែងក្រាញនៅ ដោយសស្សតទិដ្ឋិ ឈ្មោះថា រមែងស្ទុះហួសទៅ ដោយឧច្ឆេទទិដ្ឋិ ឈ្មោះថា រមែងក្រាញនៅ កាលសោកស្តាយដល់អតីត ឈ្មោះថា រមែងស្ទុះទៅ កាលសង្ឃឹមអនាគត ឈ្មោះថា ក្រាញនៅ ដោយបុព្វន្តានុទិដ្ឋិ ឈ្មោះថា រមែងស្ទុះទៅ ដោយអបរន្តានុទិដ្ឋិ ឈ្មោះថា រមែងក្រាញនៅ

ព្រោះដូច្នោះ ភិក្ខុណាវៀរអន្តធម៌ ២ យ៉ាងនេះបានហើយ បដិបត្តិតាមមជ្ឈិ-មប្បដិបទា ឈ្មោះថា មិនស្ទុះទៅ និងមិនក្រាញនៅ ។

បាទគាថាថា **សព្វំ អច្ចគមា ឥមំ បបញ្ចំ** សេចក្ដីថា ភិក្ខុណាឈានកន្លងគឺច្លងផុត អធិប្បាយថា ឈានកន្លងដោយល្អនូវបបញ្ចធម៌ ៣ យ៉ាង គឺតណ្ហា ១ មានះ ១ និងទិដ្ឋិ ១ ដែលមានវេទនា និងវិតក្កជាដែនកើតទាំងពួងបាន ដោយមជ្ឈិមប្បដិបទា ដែលមានអរហត្តមគ្គជាទីបំផុត ។

ក្នុងគាថាបន្ទាប់អំពីនោះ មានសេចក្ដីប្លែកគ្នាត្រឹមប៉ុណ្ណោះថា **សព្វំ វិតថមិទន្តិ ញត្វា លោកេ** អត្ថនៃគាថានោះថា បទថា **សព្វំ** បានដល់ មិនមានចំណែកសេសសល់ អធិប្បាយថា សព្វយ៉ាង គឺពេញ ។

កាលបើដូច្នេះ ក្នុងគាថានេះ ព្រះដ៏មានព្រះភាគទ្រង់សំដៅយកសង្ខតធម៌ មានខន្ធ អាយតនៈ និងធាតុ ដែលជាលោកិយ ចូលដល់វិបស្សនាប៉ុណ្ណោះ ។

បទថា **វិតថំ** បានដល់ ការប្រែប្រួល មានអធិប្បាយថា ឈ្មោះថា ប្រែប្រួល ព្រោះការមិនកើតដោយប្រការដែលពួកបុគ្គលពាលកាន់យក ដោយអំណាចកិលេសថា ទៀង ស្ថិតស្ថេរ ជាសុខ ស្អាត ឬថា ជាតួខ្លួន ។

បទថា **ឥទំ** សេចក្ដីថា ព្រះដ៏មានព្រះភាគកាលទ្រង់សម្ដែងធម្មជាតមានខន្ធជាដើមទាំងអស់នោះឯង ត្រាស់ដោយភាវៈដែលឃើញប្រចក្ស ។

បទថា **ញត្វា** បានដល់ ជ្រាបដោយមគ្គប្បញ្ញា អធិប្បាយថា ភិក្ខុណា

ជ្រាបធម្មជាត មានខន្ធជាដើមនោះដោយការមិនវង្វេង និងដោយអារម្មណ៍ ។ បទថា **លោភេ** បានដល់ ក្នុងឱកាសលោក ភ្ជាប់សេចក្តីថា ដឹងថា ធម្មជាតមានខន្ធជាដើមទាំងពួងនេះ ជារបស់ប្រែប្រួល ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំង ៤ ខាងមុខអំពីនេះតទៅ

សព្វទាំងនេះ គឺ **វីតលោភោ វីតរាគោ វីតទោសោ វីតមោហោ** មានសេចក្តីប្លែកគ្នា គឺមិនដូចគ្នា ។

ក្នុងបណ្តាទាំង ៤ បទនេះ ដែលឈ្មោះថា លោភ ដោយអំណាចសេចក្តីលោភ ពាក្យថា **លោភ** នេះ ជាពាក្យដែលរួមយកអកុសលធម៌ចំណែកលោភៈទាំងអស់ ជាឈ្មោះនៃអកុសលមូល ឬជា ឈ្មោះនៃវិសមលោភ លោភធម៌នោះ ជួនកាលរមែងកើតឡើងបានក្នុងវត្ថុទាំង ៣ គឺភោគៈ ១ រដ្ឋ ១ ស្រុក ១ ដែលឈ្មោះថា **រាគ** ដោយអំណាចនៃការរំជួល ដែលលោកពោលយ៉ាងនេះថា

> ជួនកាលលោភធម៌ កើតឡើងក្នុងពួកស្រីល្មមជាមាតា ក៏មានលោភធម៌កើតឡើង ក្នុងពួកស្រីល្មមជាបងប្អូនស្រី ក៏មានលោភធម៌ កើតឡើងក្នុងពួកស្រីល្មមជាកូនស្រីក៏មាន ដូច្នេះ ។

ពាក្យថា **រាគ** នេះ ជាឈ្មោះរបស់រាគៈ គឺកាមគុណទាំង ៥ ។

ដែលឈ្មោះថា ទោស ដោយអំណាចនៃការប្រទូស្ត ពាក្យថា ទោស នេះ ជាឈ្មោះរបស់សេចក្តីក្រោធ ដែលខ្ញុំពោលមកហើយខាងដើមនោះឯង ។

ដែលឈ្មោះថា **មោហា** ដោយអំណាចនៃការវង្វេង ពាក្យថា **មោហា** នេះ ជាឈ្មោះនៃការមិនដឹងក្នុងអរិយសច្ច ៤ ។ ក្នុងបណ្ដា លោភៈ រាគៈ ទោសៈ និងមោហៈនោះ ព្រោះហេតុដែលភិក្ខុខ្ពើមលោភៈ ទើបផ្ដើមវិបស្សនាថា ធ្វើម្ដេចហ្ន៎ អាត្មាអញគប្បីកម្ចាត់លោភៈ ដែលប្រាសចាកសេចក្ដីលោភ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងការលះនូវត្រើយអាយ និងត្រើយនាយទាំងពួង ដែលជាឧបាយគ្រឿងលះលោភៈ ដែលជាគ្រឿងសម្ដែងនូវការប្រែប្រួលនៃសង្ខារទាំងឡាយ និងជាអានិសង្សនៃការលះលោភៈ ទើបទ្រង់ត្រាស់គាថានេះ ដល់ភិក្ខុនោះ ។ ក្នុងគាថា ទាំងឡាយខាងមុខអំពីនេះទៅក៏ន័យនេះដូចគ្នា តែអាចារ្យពួកខ្លះពោលថា ភិក្ខុនោះប្រារព្ធវិបស្សនាហើយ ខ្ពើមរអើមនូវធម៌ទាំងនោះ ទើបពោលគាថា មួយរូបមួយគាថាក្នុងព្រះសូត្រនេះ ដោយន័យដែលខ្ញុំពោលហើយនោះឯង អ្នកពេញចិត្តពាក្យណាក៏គប្បីកាន់យកពាក្យនោះ ។ ក្នុងគាថាទាំង ៤ បន្ទាប់អំពីនេះ ក៏ន័យនេះដូចគ្នា តែពណ៌នាសេចក្ដីក្នុងគាថានេះ មានដូច្នេះ

អកុសលធម៌ពួកណា រមែងដេកត្រាំក្នុងសន្ដានទាំងឡាយ ព្រោះអត្ថថា លះមិនទាន់បាន ហេតុនោះ អកុសលធម៌ទាំងនោះ ឈ្មោះថា អនុស័យ ពាក្យថា អនុស័យនេះ ជាឈ្មោះនៃកាមរាគ បដិឃៈ មានះ ទិដ្ឋិ វិចិកិច្ឆា ភវរាគៈ និងអវិជ្ជា ។ ដែលឈ្មោះថាមូល ព្រោះអត្ថថា ជាទីតាំងនៃអាការរបស់ខ្លួន នៃសម្បយុត្តធម៌ទាំងឡាយ ដែលឈ្មោះថាអកុសល ព្រោះអត្ថថា

មិនក្រេម ។ ដែលឈ្មោះថា មូល ព្រោះអត្ថថា ជាទីតាំងនៃសម្បយុត្តធម៌នោះ ដែលឈ្មោះថាអកុសល ព្រោះអត្ថថា មានទោស និងមានវិបាកជាទុក្ខ ។

ពាក្យថា មូល និងអកុសលទាំងពីរយ៉ាងនេះ ជាឈ្មោះនៃលោភៈ ទោសៈ និងមោហៈ ។ ហើយពិត អកុសលមូលទាំងនោះ ព្រះមានព្រះភាគទ្រង់សម្តែងយ៉ាងនេះ ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ លោភៈជាអកុសលផង ជាអកុសលមូលផង ។ អនុស័យទាំងនេះណាមួយ មិនមានដល់ភិក្ខុណា ព្រោះលោកលះបានដោយមគ្គនោះៗ យ៉ាងនេះហើយ អនុស័យទាំងនេះ ក៏ជាអកុសលមូល ដែលភិក្ខុដកឡើងបានហើយ អធិប្បាយថា ដកចេញហើយ ឯពួកអាចារ្យដឹងលក្ខណៈរបស់សត្វ ប្រាថ្នានូវការចុះ ស េ អក្ខរៈសម្រាប់ពាក្យដែលជាបឋមាវិភត្តិ ពហុវចនៈ ។ តែព្រះអដ្ឋកថាចារ្យទាំងឡាយពណ៌នាថា សព្ទថា ស េ ជានិបាត អ្នកគាប់ចិត្តពាក្យណា ក៏គប្បីកាន់យកពាក្យនោះ ។

ក្នុងគាថានេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅ ភិក្ខុនោះ គឺបុគ្គលមានយ៉ាងនេះ ជាព្រះខីណាស្រព ព្រះខីណាស្រពរមែងមិនប្រកាន់មាំ រមែងមិនលះ ព្រះដ៏មានព្រះភាគត្រាស់ថា ព្រះខីណាស្រពកាលលះហើយ ក៏តាំងនៅក៏ពិតតែទោះជាដូច្នោះ ក៏នៅតែត្រាស់ថា ភិក្ខុនោះរមែងលះត្រើយនាយ និងត្រើយអាយចេញបាន ដោយលក្ខណៈនៃពាក្យដែលជាបច្ចុប្បន្ន ក្នុងវិភត្តិដែលជាបច្ចុប្បន្នជិតអតីត ។

ម្យ៉ាងទៀត ភិក្ខុបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ បណ្ឌិតគប្បីជ្រាបថា រមែងលះត្រើយអាយ និងត្រើយនាយ ពោល គឺអាយតនៈខាងក្នុង និងអាយតនៈខាងក្រៅចេញបាន ។

គប្បីជ្រាបការមិនមានអនុស័យ ក្នុងព្រះគាថានោះ ដោយចែកជាពីរចំណែក គឺតាមលំដាប់កិលេស និងតាមលំដាប់មគ្គ ។

កាលពោលតាមលំដាប់កិលេស ការមិនមានកាមរាគានុស័យ និងបដិឃានុស័យ រមែងមានដោយមគ្គទី ៣ ។ ការមិនមាននៃមានានុស័យ រមែងមានដោយមគ្គទី ៤ ការមិនមានទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ រមែងមានដោយមគ្គទី ១ ការមិនមាននៃភវរាគានុស័យ និងអវិជ្ជានុស័យ រមែងមានដោយមគ្គទី ៤ ។

កាលពោលតាមលំដាប់មគ្គ ការមិនមាននៃទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ រមែងមានដោយបឋមមគ្គ ការស្រាលស្តើងនៃកាមរាគានុស័យ និងបដិឃានុស័យ រមែងមានដោយទុតិយមគ្គ ការមិនមាននៃអនុស័យដោយប្រការទាំងពួង រមែងមានដោយតតិយមគ្គ ការមិនមាននៃមានានុស័យ ភវរាគានុស័យ និងអវិជ្ជានុស័យ រមែងមានដោយចតុត្ថមគ្គ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះអនុស័យទាំងពួង ជាអកុសលមូល គឺកាមរាគានុស័យ និងភវរាគានុស័យប៉ុណ្ណោះ ដល់នូវការសង្គ្រោះចូលដោយលោភៈដែលជាអកុសលមូល ។ បដិឃានុស័យ និងអវិជ្ជានុស័យ រមែងដល់នូវការ

រាប់ថា ជាទោសៈ ដែលជាអកុសលមូល ជាមោហៈ ដែលជាអកុសលមូល ចំណែកទិដ្ឋានុស័យ មានានុស័យ និងវិចិកិច្ឆានុស័យ មិនចាត់ជាអកុសលមូលណាមួយឡើយ ។

ម្យ៉ាងទៀត ព្រោះភិក្ខុប្រាថ្នានូវការលះកិលេស ដោយអំណាចនៃការមិនមានអនុស័យ និងដោយអំណាចនៃការដកអកុសលមូលចេញបាន ដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ភិក្ខុណាមិនមានអនុស័យណាមួយ ដកអកុសលមូលបានហើយ ។

ក្នុងបាទព្រះគាថាថា **យស្ស ទរថជា** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូច្នេះ កិលេសដែលកើតឡើងដំបូង ឈ្មោះថា **ទរថ** ព្រោះអត្ថថា ក្តៅ ឯកិលេសដែលកើតបន្ទាប់មក ឈ្មោះថា **ទរថជា** ព្រោះកើតអំពីកិលេសជាគ្រឿងក្រវល់ក្រវាយទាំងនោះ ការប្រកាន់ខ្លួន ឈ្មោះថា **ឱរំ** សមដូចលោកពោលថា

> ម្នាលភិក្ខុទាំងឡាយ ពាក្យថា ត្រើយអាយ ( ប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខ ) នុ៎ះ ជាឈ្មោះនៃសក្កាយ ដូច្នេះ ។

ពាក្យថា **អាគមនាយ** បានដល់ដើម្បីការកើតឡើង ។ បទថា **បច្ចយាសេ** បានដល់ បច្ច័យទាំងនោះឯង ។ លោកពោលអធិប្បាយដូចម្តេច លោកពោលអធិប្បាយថា ភិក្ខុមិនមានកិលេស ដែលមានលក្ខណៈជាហេតុ ឲ្យកើតសេចក្តីក្រវល់ក្រវាយណាមួយ ដែលជាបច្ច័យនៃការប្រកាន់ឧបាទានក្ខន្ធ

ព្រោះហេតុដែលកិលេសទាំងនោះ បុគ្គលលះបានហើយដោយអរិយមគ្គ ភិក្ខុនោះ ឈ្មោះថា លះនូវត្រើយអាយ និងត្រើយនាយចេញបាន ដោយន័យដែលខ្ញុំបានពោលហើយខាងដើមនោះឯង ។

ក្នុងបទថា **យស្ស វនថជា** ជាដើមនេះ បណ្ឌិតគប្បីជ្រាបកិលេសទាំងឡាយដែលកើតអំពីព្រៃ ដូចកិលេសទាំងឡាយ ដែលកើតអំពីសេចក្ដីក្រវល់ក្រវាយ តែក្នុងអត្ថនៃពាក្យមានសេចក្ដីប្លែកគ្នាដូចតទៅ

ធម្មជាតដែលឈ្មោះថា ព្រៃ ក៏ព្រោះអត្ថថា ប្រាថ្នា ឬត្រូវការ អធិប្បាយថា រមែងចង់ គឺរមែងសូម រមែងគប់រក ពាក្យថា **វន** នេះ ជាឈ្មោះនៃតណ្ហា ។ ពិតហើយ តណ្ហានោះ លោកហៅថា **វន** ព្រោះប្រាថ្នា គឺព្រោះហូរចេញមកនៃអារម្មណ៍ទាំងឡាយ តណ្ហា គឺ **វន** រមែងផ្សាយទៅដោយអំណាចដែលមានអារម្មណ៍ជាបរិយុដ្ឋាន ព្រោះហេតុនោះ ទើបតណ្ហាឈ្មោះថា **វនថ** ពាក្យថា **វនថ** នេះ ជាឈ្មោះនៃតណ្ហានុស័យ ។ កិលេសទាំងឡាយ ដែលកើតអំពីព្រៃ គឺតណ្ហា ឈ្មោះថា **វនថជា** តែអាចារ្យពួកខ្លះពោលថា កិលេសទាំងអស់លោកហៅថា **វនថ** ព្រោះអត្ថថា ជាគ្រឿងសាំញ៉ាំ ចំណែកកិលេសដែលកើតឡើងតៗ មក ឈ្មោះថា **វនថជា** ក្នុងទីនេះ លោកបំណងយកអត្ថក្នុងសុកសូត្រត្រឹមប៉ុណ្ណេះ តែអត្ថក្រៅអំពីនេះផ្ទុយគ្នាតាមដែលត្រាស់ក្នុងគាថាធម្មបទ ។

ពីរបទថា **វិនិពន្ធាយ ភវាយ** បានដល់ ដើម្បីការចងសត្វទុកក្នុងភព

ម្យ៉ាងទៀត សេចក្តីថា កាលការចងក្នុងអារម្មណ៍ទាំងឡាយនៃចិត្ត ឬដើម្បីការកើតឡើងតទៅ ហេតុនោះឯង ទើបឈ្មោះថា **ហេតុកប្បា ។**

ពាក្យថា **នីវរណា** ក្នុងបទនេះថា **យោ នីវរណោ** ជាដើម មានវិគ្គហៈថា ដែលឈ្មោះថានីវរណៈ ព្រោះអត្ថវិគ្គហៈថា រមែងធ្វើចិត្តឲ្យក្តៅក្រហាយ អធិប្បាយថា ជាគ្រឿងបិទបាំងចិត្ត ។

បទថា **បហាយ** បានដល់ លះបោល ។ បទថា **បញ្ច** ជាការកំណត់រាប់នីវរណៈទាំងនោះ ភិក្ខុដែលឈ្មោះថា **អនីឃោ** ព្រោះមិនមានសេចក្តីទុក្ខ ដែលឈ្មោះថា **តិណ្ណកថំកថោ** ព្រោះខ្លួនឆ្លងសេចក្តីសង្ស័យបានហើយ ដែលឈ្មោះថា **វិសល្លោ** ព្រោះជាបុគ្គលមានព្រួញទៅប្រាសហើយ សួរថា លោកអធិប្បាយដូចម្តេច ឆ្លើយថា លោកពោលអធិប្បាយថា ភិក្ខុណាឃើញនីវរណៈទាំង ៥ មានកាមឆន្ទៈជាដើម និងឃើញទោសក្នុងនីវរណៈទាំង-ឡាយ ដោយភាពជារបស់ស្មើគ្នា និងដោយវិសេស ដោយន័យដែលព្រះដ៏មានព្រះភាគត្រាស់ក្នុងសមន្តភទ្ទកសូត្រ ទើបលះនីវរណៈទាំងនោះបានដោយមគ្គនោះៗ ឈ្មោះថា ជាបុគ្គលមិនមានទុក្ខ ព្រោះការមិនមាននៃទុក្ខ គឺកិលេសទុក្ខ ព្រោះហេតុដែលខ្លួនលះនីវរណៈទាំងនោះបានហើយនោះឯង ឈ្មោះថា ឆ្លងផុតសេចក្តីសង្ស័យចេញបាន ព្រោះលោកឆ្លងផុតសេចក្តីសង្ស័យ ដែលប្រព្រឹត្តទៅហើយ ដោយន័យជាដើមថា ក្នុងអតីតកាលយូរមកហើយ អញបានកើតហើយឬហ្ន៎ ឈ្មោះថា រលាស់ចោលនូវកូនសរបាន

ព្រោះលោកប្រាសចាកកូនសរទាំង ៥ ដែលលោកពោលថា ក្នុងបណ្តាកូនសរទាំងនោះ កូនសរ ៥ យ៉ាងដូចម្តេច កូនសរ ៥ យ៉ាងនោះ កូនសរ គឺរាគៈ ១ កូនសរ គឺទោសៈ ១ កូនសរ គឺមោហៈ ១ កូនសរ គឺមានះ ១ កូនសរ គឺទិដ្ឋិ ១ ភិក្ខុនោះ ឈ្មោះថា លះនូវត្រើយអាយ និងត្រើយនាយចេញបាន ដោយន័យដែលខ្ញុំពោលហើយខាងដើមនោះឯង ។

ក្នុងព្រះគាថានោះ បណ្ឌិតគប្បីជ្រាបការលះនីវរណៈ ២ យ៉ាងដូចគ្នា គឺដោយលំដាប់កិលេស ១ ដោយលំដាប់នៃមគ្គ ១ ។

កាលពោលតាមលំដាប់កិលេស ការលះកាមឆន្ទនីវរណៈ និងព្យាបាទនីវរណៈ រមែងមានដោយមគ្គទី ៣ ការលះថីនមិទ្ធនីវរណៈ និងឧទ្ធច្ចនីវរណៈ រមែងមានដោយមគ្គទី ៤ ការលះកុក្កុច្ចនីវរណៈ ពោល គឺការក្តៅក្រហាយ ដែលប្រព្រឹត្តទៅហើយដោយន័យជាដើមថា កុសល អាត្មាអញមិនទាន់បានធ្វើហ្ន៎ និងវិចិកិច្ឆានីវរណៈ រមែងមានដោយមគ្គទី ១ ។

តែបើពោលតាមលំដាប់មគ្គ ការលះកុក្កុច្ចនីវរណៈ និងវិចិកិច្ឆានីវរណៈ រមែងមានដោយមគ្គទី ១ ការធ្វើកាមឆន្ទនីវរណៈ និងព្យាបាទនីវរណៈឲ្យស្រាលស្តើង រមែងមានដោយមគ្គទី ២ ការលះកាមឆន្ទនីវរណៈ និងព្យាបាទនីវរណៈ ឲ្យអស់ឥតសេសសល់ រមែងមានដោយមគ្គទី ៣ ការលះថីនមិទ្ធនីវរណៈ និងឧទ្ធច្ចនីវរណៈ រមែងមានដោយមគ្គទី ៤ ដូច្នេះឯង ទើបព្រះមានព្រះភាគត្រាស់ថា

ភិក្ខុណា លះបង់នីវរណៈ ៥ ប្រការ ជាអ្នកមិនតានតឹង ឆ្លង សេចក្តីងឿងឆ្ងល់ ប្រាសចាកសរ គឺកិលេស ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សកសំណកចាស់គ្រាំគ្រាចេញ ដូច្នេះ ។

ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យទេសនាចប់ ដោយកាន់យកកំពូល គឺព្រះអរហត្តនោះឯង ក្នុងទីបំផុតនៃព្រះធម្មទេសនា ភិក្ខុនោះ តាំងនៅហើយក្នុងអរហត្ត ។

អាចារ្យពួកខ្លះពោលថា គាថាណាមួយដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយដល់ភិក្ខុទាំងនោះ ដោយប្រការណាមួយ ភិក្ខុនោះៗ តាំងនៅហើយក្នុងអរហត្ត ក្នុងទីបំផុតនៃគាថានោះៗ ដោយប្រការនោះៗ ដូច្នេះ ។

**អដ្ឋកថាឧរគសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ធនិយសូត្រទី ២

[ ២ ] ( សេដ្ឋីបុត្រឈ្មោះធនិយគោបៈ ពោលថា ) យើងមានបាយចម្អិនហើយ មានទឹកដោះរឹតហើយ ជាអ្នកនៅជាមួយជនបរិស័ទ ទៀបច្រាំងទន្លេមហី ខ្ទមយើងបានប្រក់ហើយ ភ្លើងក៏បង្កាត់ហើយ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

( ព្រះមានព្រះភាគត្រាស់ថា ) តថាគត មិនមានសេចក្ដីក្រោធ ប្រាសចាកសេចក្ដីរឹងត្អឹងហើយ នៅអស់រាត្រីមួយ ក្បែរច្រាំងទន្លេមហី ខ្ទម គឺអត្តភាព មានដំបូលបើកចេញហើយ ភ្លើងរលត់ហើយ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

( ធនិយគោបៈ ពោលថា ) របោមក៏មិនមាន គោទាំងឡាយក៏ដើរទៅក្នុងប្រកដែលមានស្មៅលូតលាស់ល្អ គោទាំងឡាយក៏អត់ធន់នឹងភ្លៀងដែលបង្អុរមក ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

( ព្រះមានព្រះភាគត្រាស់ថា ) ក្បូនតថាគតបានចង ចាត់ចែងស្រេចហើយ តថាគតបានឆ្លងដល់ត្រើយ កម្ចាត់បង់នូវឱឃៈបាន សេចក្ដីត្រូវការដោយក្បូន មិនមានទៀតទេ ម្នាលភ្លៀង

ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

( ធនិយគោបៈ ពោលថា ) ប្រពន្ធរបស់យើង ជាអ្នកស្តាប់បង្គាប់ ជាស្ត្រីមិនឡេះឡោះ ជាទីពេញចិត្ត គួរនៅរួមអស់កាលដ៏វែង យើងមិនដែលឮសម្តីដ៏អាក្រក់តិចតួច របស់ប្រពន្ធនោះឡើយ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

( ព្រះមានព្រះភាគត្រាស់ថា ) ចិត្តរបស់តថាគត ជាធម្មជាតស្តាប់បង្គាប់ ជាចិត្តរួចស្រឡះហើយ តថាគតបានអប់រំហើយ ទូន្មានល្អហើយ អស់កាលដ៏វែង ចំណែកបាប មិនមានដល់តថាគតទៀតទេ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

( ធនិយគោបៈ ពោលថា ) យើងជាអ្នកចិញ្ចឹមជីវិតដោយថ្លៃឈ្នួល ចំពោះខ្លួនឯង ចំណែកខាងកូនទាំងឡាយរបស់យើងមានសេចក្តីមូលមិត្ត ឥតមានរោគទេ យើងមិនដែលឮហេតុអាក្រក់តិចតួចរបស់កូននោះឡើយ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

( ព្រះមានព្រះភាគត្រាស់ថា ) តថាគតមិនមែនជាអ្នកស៊ីឈ្នួលអ្នកណាមួយទេ តថាគតត្រាច់ទៅ ដោយឥតមានជាប់ចំពាក់ក្នុងលោកទាំងមូល សេចក្តីត្រូវការដោយថ្លៃឈ្នួលមិន

មានទេ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

( ធនិយគោបៈ ពោលថា ) គោជំទង់ក៏មាន កូនគោកំពុងបៅដោះក៏មាន មេគោមានគភ៌ និងមេគោកំពុងដោយឈ្មោលក៏មាន គោឈ្មោលជាគោបារបស់យើងក៏មាន ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

( ព្រះមានព្រះភាគត្រាស់ថា ) គោជំទង់ក៏មិនមាន កូនគោកំពុងបៅដោះក៏មិនមាន មេគោមានគភ៌ និងមេគោកំពុងដោយឈ្មោលក៏មិនមាន គោឈ្មោលជាគោបារបស់តថាគតក៏មិនមាន ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

( ធនិយគោបៈ ពោលថា ) បង្គោលស្ទឹង ( សម្រាប់ចងគោ ) យើងបានបោះមិនរង្គៀកទេ ខ្សែព្រួរទាំងឡាយដែលវេញអំពីស្មៅយាប្លងក៏នៅថ្មី មានសណ្ឋាននៅល្អ កូនគោកំពុងបៅដោះ មិនអាចទាញផ្តាច់បានទេ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

( ព្រះមានព្រះភាគត្រាស់ថា ) តថាគតផ្តាច់ចំណង គឺសំយោជនៈចំណែកខាងលើប្រាំ ដូចគោឧសភផ្តាច់នូវចំណងទម្លាយចំណង គឺសំយោជនៈប្រាំខាងក្រោម ដូចដំរីទម្លាយវល្លិ៍ផោម មិនបានចូលទៅកាន់ដំណេកក្នុងគភ៌ទៀតទេ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

ខណៈនោះឯង មហាមេឃបង្អុរភ្លៀង ឲ្យពេញនូវទីទាប និង ទីទួល ធនិយគោបៈបានឮសូរភ្លៀងបង្អុរ ក៏ពោលនូវសេចក្តីនេះ ថា ឱ លាភរបស់យើងមិនមែនតិចទេ ព្រោះយើងបានឃើញ នូវព្រះមានព្រះភាគ បពិត្រព្រះអង្គមានចក្ខុ យើងសូមដល់ ព្រះអង្គជាទីពឹង សូមព្រះមហាមុនីជាសាស្តាចារ្យនៃយើង ។ យើងទាំងឡាយ គឺប្រពន្ធ និងខ្ញុំព្រះអង្គ ជាអ្នកស្តាប់បង្គាប់ សូមប្រព្រឹត្តនូវព្រហ្មចរិយធម៌ ក្នុងសម្នាក់នៃព្រះសុគត សូម ជាអ្នកបានដល់ត្រើយនៃជាតិ និងមរណៈ ធ្វើទីបំផុតនៃទុក្ខ ។

( មារមានចិត្តបាបនិយាយថា ) បុគ្គលមានបុត្រ រមែងត្រេកអរ នឹងបុត្រទាំងឡាយ បុគ្គលមានគោ រមែងត្រេកអរនឹងគោទាំង-ឡាយដូច្នោះដែរ ការត្រេកអររបស់នរជន រមែងមាន ព្រោះ តែឧបធិទាំងឡាយ ( គ្រឿងជាប់ជំពាក់ ) បុគ្គលណាមិនមាន ឧបធិ បុគ្គលនោះ ទើបមិនត្រេកអរ ។

( ព្រះមានព្រះភាគត្រាស់ថា ) បុគ្គលមានបុត្រ រមែងសោក នឹងបុត្រទាំងឡាយ បុគ្គលមានគោ រមែងសោកនឹងគោទាំង ឡាយ ដូច្នោះដែរ ការសោករបស់នរជន រមែងមាន ព្រោះតែ ឧបធិទាំងឡាយ លុះតែបុគ្គលណាមិនមានឧបធិ បុគ្គលនោះ ទើបមិនសោក ។

**ធនិយសូត្រទី ២ ចប់**

# អដ្ឋកថា

## ធនិយសូត្រ

ធនិយសូត្រប្រកបដោយគាថាថា **បក្កោទនោ** ជាដើម ។

ធនិយសូត្រនេះ មានហេតុកើតឡើងដូចម្ដេច ធនិយសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះ

ព្រះដ៏មានព្រះភាគ គង់នៅក្នុងក្រុងសាវត្ថី សម័យនោះ អ្នកចិញ្ចឹមគោ ឈ្មោះធនិយៈ អាស្រ័យនៅត្រង់ឆ្នេរស្ទឹងមហី ។ បុព្វកម្មរបស់ធនិយៈនោះ មានដូច្នេះ

ក្នុងសាសនារបស់ព្រះពុទ្ធ ព្រះនាមកស្សបទសពល នៅប្រាកដនៅឡើយ ធនិយៈនេះបានប្រគេនសលាកភត្ត ២០ សម្រាប់ ដល់ព្រះសង្ឃរាល់ថ្ងៃ អស់ ២ ម៉ឺនឆ្នាំ គាត់ចុតិអំពីជាតិនោះហើយ បានទៅកើតក្នុងទេវលោកទាំងឡាយនោះឯង ធ្វើមួយពុទ្ធន្តរឲ្យអស់ទៅក្នុងទេវលោក លុះដល់កាលរបស់ព្រះដ៏មានព្រះភាគនៃយើង ក៏កើតជាសេដ្ឋីបុត្រ ក្នុងនគរធម្មកោរណ្ឌៈ ដែលជានគរខ្ពស់ក្នុងបព្វតរដ្ឋ នាផ្ទៃកកណ្ដាលនៃវិទេហរដ្ឋ ។ គាត់អាស្រ័យហ្វូងគោចិញ្ចឹមជីវិត ដ្បិតថា គាត់មានគោប្រមាណ ៣ ម៉ឺនក្បាល គាត់រីតទឹកដោះអំពីមេគោ ២៧០០០ ក្បាល ។ ធម្មតាអ្នកចិញ្ចឹមគោទាំងឡាយ មិនបាននៅប្រចាំ ពួកគេនៅត្រង់ទីទួល ៤ ខែ ក្នុងរដូវភ្លៀង ៨ ខែទៀត ពួកគេឲ្យស្មៅនិងទឹកក្នុងទីដែលងាយស្រួលនោះ ហើយទីនោះ ត្រូវជាឆ្នេរស្ទឹង ឬបើមិនដូច្នោះ ត្រង់មាត់ស្រះដែលកើតឯង ។

តមក ក្នុងរដូវភ្លៀង ធនិយៈនេះ បានចេញអំពីស្រុកដែលខ្លួននៅ ទៅស្វែងរកឱកាស ដើម្បីឲ្យគោទាំងឡាយនៅយ៉ាងសប្បាយ ទើបចូលទៅកាន់ឱកាស គឺត្រង់ឆ្នេរស្ទឹងមហាមហី ស្ទឹងនេះ បែកជាពីរខ្សែ មួយខ្សែ ហៅថា កាឡមហី មួយខ្សែ ហៅថា មហាមហី កាលហូរទៅ ក៏មកជួបគ្នាវិញ ហើយបង្កើតបានជាកោះក្នុងរវាងនេះ ទើបគាត់ធ្វើរោងសម្រាប់គោទាំងឡាយ និងទីលំនៅរបស់ខ្លួនត្រង់កោះនោះ ហើយអាស្រ័យនៅ ។ គាត់មានកូនប្រុស ៧ នាក់ កូនស្រី ៧ នាក់ និងកូនប្រសា ៧ នាក់ និងកម្មករជាច្រើន ។

ធម្មតាអ្នកចិញ្ចឹមគោទាំងឡាយ រមែងជ្រាបនិមិត្តនៃភ្លៀង គឺកាលណាបក្សីទាំងឡាយធ្វើសម្បុកលើចុងឈើ ក្តាមទាំងឡាយបិទរន្ធក្បែរស្ទឹង រមែងប្រើរន្ធថ្មីក្បែរទីទួល ក្នុងកាលនោះ អ្នកចិញ្ចឹមគោទាំងឡាយរមែងដឹងថា នឹងមានភ្លៀងជោកជាំ តែកាលណាបក្សីទាំងឡាយ ធ្វើសម្បុកត្រង់ដើមឈើទាបៗ ក្តាមទាំងឡាយបិទរន្ធត្រង់ទីទួល មកកាយរន្ធក្បែរស្ទឹង កាលនោះអ្នកចិញ្ចឹមគោ ក៏រមែងដឹងថា នឹងមានភ្លៀងតិច ។

កាលនោះធនិយៈកំណត់និមិត្តថា នឹងមានភ្លៀងល្អ លុះរដូវភ្លៀងជិតចូលមកដល់ ក៏ចាកចេញអំពីកោះ សាងទីលំនៅរបស់ខ្លួនក្នុងទីដែលទឹកជន់មិនដល់ សូម្បីក្នុងកាលភ្លៀងអស់ ៧ សប្តាហ៍ ត្រង់ត្រើយម្ខាងនៃស្ទឹងមហាមហី សាងរោងគោព័ទ្ធជុំវិញទីលំនៅហើយ ក៏នៅក្នុងទីនោះ ។

កាលនោះ គាត់ធ្វើការត្រៀមវត្ថុ មានឈើ និងស្មៅជាដើមហើយ កាល

កូន និងករិយាទាំងឡាយ មួយអន្លើដោយពួកមនុស្សមកព្រមគ្នា កាលរបស់ទំពា និងរបស់បរិភោគច្រើនប្រការ ដែលខ្លួនបានត្រៀមរៀបរយហើយ ជុំនៃពពកទាំងឡាយ ក៏តាំងឡើងក្នុងទិសទាំង ៤ ដោយជុំវិញ ។

នាយធនិយៈនោះរីតទឹកដោះអំពីមេគោទាំងឡាយ ឲ្យកូនគោទាំងឡាយនៅក្នុងក្រោល ឲ្យបំពក់ភ្លើងគោទាំងឡាយក្នុងទិសទាំង ៤ ឲ្យបរិវារជនគ្រប់គ្នាបរិភោគហើយ ឲ្យធ្វើកិច្ចគ្រប់យ៉ាងហើយ ឲ្យដុតប្រទីបឡើងក្នុងទីនោះៗ ខ្លួនឯងបរិភោគកត្តដោយទឹកដោះស្រស់ ដេកលើមហាសេយ្យនា ឃើញសិរីសម្បត្តិរបស់ខ្លួនហើយ ក៏មានសេចក្តីត្រេកអរ ដេកស្តាប់សំឡេងផ្គរលាន់ដែលមកអំពីទិសខាងមុខ ហើយបន្លឺឧទានថា

យើងមានបាយចម្អិនហើយ មានទឹកដោះរីតហើយ ជាអ្នកនៅជាមួយបរិស័ទ ទៀបច្នេរស្ទឹងមហី ខ្ទមយើងបានប្រក់ហើយ ភ្លើងក៏បង្កាត់ហើយ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

ពណ៌នាសេចក្តីក្នុងគាថាទី ១ ដូចតទៅនេះ

[ ២ ] បទថា **បក្កោទនោ** បានដល់ កត្តដែលចម្អិនហើយ ។ បទថា **ទុទ្ធខីរោ** បានដល់ ទឹកដោះដែលគេរីតអំពីមេគោទាំងឡាយហើយកាន់យក ។ នាយធនិយៈ រមែងសម្តែងខ្លួនឯងដោយពាក្យថា **អហំ** ។

បទថា **អស្មិ** បានដល់ ភាពពិតរបស់ខ្លួន អធិប្បាយថា យើងមានបាយ

ធ្លិនហើយ ទឹកដោះរឹតហើយ ។

សព្ទថា **ឥតិ** សេចក្ដីថា នាយធនិយគោបៈ ពោលហើយយ៉ាងនេះ តែក្នុងគម្ពីរនិទ្ទេស លោកពោលអត្ថនៃ **ឥតិ** សព្ទយ៉ាងនេះថា សព្ទថា **ឥតិ** ប្រើក្នុងការភ្ជាប់បទ ជាការជាប់គ្នានៃបទ ជាការធ្វើបទឲ្យពេញ ជាទីប្រជុំនៃអក្ខរៈ ជាការពីរោះនៃព្យញ្ជនៈ ពាក្យថា **ឥតិ** នេះ ជាឈ្មោះនៃបទចុង **ឥតិ** សព្ទ បណ្ឌិតគប្បីជ្រាប លោកពោលសំដៅយកអត្ថនេះប៉ុណ្ណោះ **ឥតិ** សព្ទដែលប្រកាសអត្ថនោះឯង នៃបទដែលលោកពោលដោយបទខាងដើមថា លោកពោលហើយយ៉ាងនេះ ជាការភ្ជាប់បទដោយបទចុង ដោយន័យយ៉ាងនេះជាដើមថា **ឥតិ មេតេយ្យោ** ឬ **ឥតិ ភគវា** មិនមែនដោយប្រការដទៃឡើយ ។

បទថា **ធនិយោ គោបោ** ជាឈ្មោះរួមរបស់សេដ្ឋីបុត្រនោះ ។ គាត់ឈ្មោះធនិយៈ ព្រោះមានគោដែលមានឧបការៈច្រើន ដោយការឲ្យបញ្ចគោរសដល់សត្វលោកដែលទេវតាពោលដោយពិស្ដារយ៉ាងនេះថា ទ្រព្យស្មើនឹងគោ មិនមាន ដូច្នេះ ។ ក្នុងបណ្ដាទ្រព្យ ៥ យ៉ាង ( វៀរទ្រព្យដែលជាប់តាមខ្លួនទៅបាន មានទាន និងសីលជាដើម ) មានអសង្ហារិមទ្រព្យជាដើម គឺ អសង្ហារិមទ្រព្យ មានស្រែ ចម្ការ និងអារាមជាដើម ១ ទ្រព្យដែលកម្រើកបាន មានគោ និងសេះជាដើម ១ សង្ហារិមទ្រព្យ មានប្រាក់ និងមាសជាដើម ១ ទ្រព្យដែលជាប់ខ្លួន មានសិប្បៈជាដើម ១ ឈ្មោះថា គោបៈ ក៏ព្រោះការ

ចិញ្ចឹមគោទាំងឡាយ ។

បុគ្គលណាចិញ្ចឹមគោរបស់ខ្លួន បុគ្គលនោះ ឈ្មោះថា គោប: ចំណែកបុគ្គលណាចិញ្ចឹមគោឲ្យអ្នកដទៃ ជាអ្នកស៊ីឈ្នួល បុគ្គលនោះឈ្មោះថាគោបាល ឯសេដ្ឋីបុត្រនោះ ជាអ្នកចិញ្ចឹមគោរបស់ខ្លួនប៉ុណ្ណោះ ទើបគេឲ្យឈ្មោះថាគោប: ។

បទថា **អនុតីរេ** គឺទីជិតច្រាំង ។ បទថា **មហិយា** បានដល់ នៃស្ទឹងដែលមានឈ្មោះថា មហាមហី ។

ការនៅរួមគ្នាជាមួយបរិវារជន ដែលសាមគ្គីគ្នា ដែលមានកាប្រព្រឹត្តិឧបការ:គ្នា ឈ្មោះថា មានការនៅដោយព្រមព្រៀងគ្នា នាយធនិយគោប: នេះ មានសភាពដូច្នោះ ព្រោះហេតុនោះ ទើបលោកពោលថា មានការនៅដោយព្រមព្រៀងគ្នា ។

បទថា **ឆន្នា** បានដល់ ធ្វើឲ្យភ្លៀងលិចមិនបានដោយការប្រក់ ដោយគ្រឿងប្រក់ គឺស្មៅ និងស្លឹកឈើទាំងឡាយ ។ ពាក្យថា **កុដិ** នេះ ជាឈ្មោះរបស់ផ្ទះនោះ ។ បទថា **អាហិតោ** គឺនាំមកហើយ ឬសាងហើយ ។ ភ្លើងឈ្មោះថា **គិនិ** លោកហៅថា **គិនិ** ក្នុងឋានៈនោះៗ ។

បទថា **អថ ចេ បត្ថយសី** អធិប្បាយថា កាលបើដូច្នេះ បើអ្នកប្រាថ្នាក្នុងកាលឥឡូវនេះ ។ បទថា **បវស្ស** សេចក្តីថា ចូរស្រោច គឺចូរធ្លាក់ចុះ បានដល់ ចូរបង្អុរធ្លាទឹកចុះមក ។ នាយធនិយ:ហៅភ្លៀងថា **ទេវ** ។

ពណ៌នាពាក្យដោយចំពោះក្នុងគាថានេះ មានប្រមាណត្រឹមប៉ុណ្ណោះ

ឯកិច្ចពណ៌នាអត្ថ មានដូចតទៅនេះ

នាយធនិយគោបៈនេះ ដេកហើយក្នុងផ្ទះ ដែលជាទីដេករបស់ខ្លួនយ៉ាងនេះ ស្តាប់ហើយនូវសំឡេងគ្រហឹមនៃផ្គរ ពោលថា យើងមានបាយសម្រេចហើយ រមែងសម្តែងដល់ការត្រៀមយ៉ាងល្អរបស់ខ្លួន ជាឧបាយដែលនឹងឲ្យរម្ងាប់សេចក្តីទុក្ខកាយ និងជាហេតុនៃសេចក្តីសុខកាយ គាត់កាលពោលថា ទឹកដោះ យើងរីតស្រេចហើយ ឈ្មោះថា រមែងសម្តែងដល់ការចាត់ការល្អរបស់ខ្លួន ដែលជាឧបាយដើម្បីចូលទៅរម្ងាប់ទុក្ខផ្លូវចិត្ត និងជាហេតុនៃសេចក្តីសុខចិត្ត កាលពោលថា គ្រង់ប្រាំងស្ទឹងមហី រមែងសម្តែងដល់សម្បត្តិ គឺទីលំនៅ គាត់ពោលថា ការនៅរួមគ្នា រមែងសម្តែងដល់ការមិនមាននូវសេចក្តីសោក ដែលមានការព្រាត់ប្រាសចាកវត្ថុជាទីស្រឡាញ់ជាហេតុ ក្នុងកាលដូច្នោះ កាលពោលថា យើងប្រក់ខ្ទមហើយ រមែងសម្តែងដល់ការកម្ចាត់ គឺការប្រាសចាកសេចក្តីទុក្ខ ដែលជាទុក្ខផ្លូវកាយ ។

បទថា **អាហិតោ គិនិ** សេចក្តីថា ព្រោះហេតុដែលនាយគោបាលទាំងឡាយបង្កាត់ភ្លើង ៣ ប្រភេទ គឺភ្លើងព័ទ្ធជុំវិញ ភ្លើងដែលមានផ្សែង និងភ្លើងសម្រាប់អាំង ពួកនាយគោបាលទាំងនោះ ក៏បានបង្កាត់ភ្លើងទាំង ៣ ប្រភេទនោះឡើង ក្នុងផ្ទះរបស់នាយធនិយគោបៈនោះ ព្រោះដូច្នោះ គាត់កាលពោលថា ភ្លើងយើងបង្កាត់ហើយ សំដៅដល់ភ្លើងដែលព័ទ្ធជុំវិញ ក្នុងទិសទាំងពួងរមែងសម្តែងដល់ការការពារ នៃការចូលមករបស់សត្វសាហាវ កាលពោល

ថា ភ្លើងយើងបង្កាត់ហើយ សំដៅយកភ្លើងផ្សេងដែលធ្វើដោយវត្ថុទាំងឡាយ មានអាចម៍គោជាដើម ត្រង់កណ្ដាលនៃគោទាំងឡាយ រមែងសម្ដែងដល់ការមិនមានការបៀតបៀននូវគោទាំងឡាយ ដែលកើតអំពីរបោម និងមូសជាដើម កាលពោលថា ភ្លើងយើងបង្កាត់ហើយ សំដៅដល់ភ្លើងសម្រាប់អាំងក្នុងទីដេកទាំងឡាយរបស់ពួកគោបាល រមែងសម្ដែងដល់ការកម្ចាត់អាពាធ ដែលកើតអំពីរងាររបស់ពួកគោបាល គាត់ពោលយ៉ាងនេះ ក៏កើតបីតិ និងសោមនស្សឡើង ព្រោះខ្លួនឯងក្ដី គោទាំងឡាយក្ដី បរិវារជនក្ដី មិនមានអាពាធណាមួយ ដែលមានភ្លៀងជាបច្ច័យ ទើបពោលថា នៃភ្លៀង កាលបើដូច្នេះ បើអ្នកប្រាថ្នា ក៏អញ្ជើញធ្លាក់មកចុះ ។

កាលនាយធនិយៈ ពោលគាថានេះយ៉ាងនេះ ព្រះដ៏មានព្រះភាគ ដែលគង់នៅក្នុងព្រះគន្ធកុដិ ក្នុងជេតពនមហាវិហារ បានស្ដាប់សំឡេងរបស់នាយធនិយៈនោះ ដោយសោតធាតុដែលជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវសោតធាតុរបស់មនុស្ស ។ កាលទ្រង់បានស្ដាប់ហើយ ទ្រង់ប្រមើលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ទ្រង់បានឃើញនាយធនិយៈ មួយអន្លើដោយភរិយារបស់គាត់ ទ្រង់ជ្រាបថា ស្វាមីភរិយាគូនេះ ដល់ព្រមដោយហេតុ បើតថាគតទៅសម្ដែងធម៌ គេទាំងពីរនឹងបួស ហើយសម្រេចអរហត្ត បើតថាគតមិនទៅ ស្អែកនេះ ជនទាំងពីរនឹងវិនាស ព្រោះជំនន់ទឹកធំ ។

ក្នុងខណៈនោះឯង ព្រះសាស្ដាបានយាងទៅកាន់លំនៅរបស់នាយធនិយៈ

តាមផ្លូវអាកាស ដែលមានចម្ងាយ ៧ យោជន៍អំពីក្រុងសាវត្ថី បានប្រថាប់ឈរខាងលើខ្ទមរបស់ធនិយៈ ។ នាយធនិយៈក៏នៅតែពោលគាថានោះរឿយៗ មិនទាន់ចប់ កាលព្រះដ៏មានព្រះភាគយាងមកហើយ ក៏នៅតែពោលនោះឯង ព្រះដ៏មានព្រះភាគកាលទ្រង់ស្តាប់គាថានោះហើយ ដើម្បីសម្តែងថា ជនទាំងឡាយដែលពេញចិត្តហើយ ឬជាអ្នកលះបង់ហើយដោយហេតុមានប្រមាណប៉ុណ្ណោះ ក៏មិនមែន តែរមែងជាយ៉ាងនេះ ទើបទ្រង់ភាសិតគាថាតប ដែលមានព្យញ្ជនៈដូចគ្នា តែផ្សេងគ្នាដោយអត្ថយ៉ាងនេះថា

> តថាគតមិនមានសេចក្តីក្រោធ ប្រាសចាកសេចក្តីរឹងត្អឹងហើយ នៅអស់រាត្រីមួយក្បែរឆ្នេរស្ទឹងមហី ខ្ទម គឺអត្តភាព មានដំបូលបើកចេញហើយ ភ្លើងរលត់ហើយ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

បទទាំងឡាយ មានបទថា **បក្កោធនោ** និងបទថា **អក្កោធនោ** ដោយអត្ថមិនចូលគ្នា គឺមិនដូចគ្នា ដូចត្រើយអាយ និងត្រើយនាយនៃមហាសមុទ្រដូច្នោះ ។ តែព្យញ្ជនៈខ្លះ ក្នុងគាថាទាំងពីរនេះដូចគ្នា ព្រោះដូច្នោះ បទខ្លះក្នុងគាថាទាំងពីរនេះ នឹងដូចដោយព្យញ្ជនៈ ។

ក្នុងគាថាដើមនោះ បណ្ឌិតគប្បីជ្រាបអត្ថនៃបទដ៏សេសដូចគ្នា ដោយន័យដែលខ្ញុំបានពោលហើយ ចំណែកកិច្ចពណ៌នា ទាំងដោយព្យញ្ជនៈ ទាំងដោយអត្ថនៃបទដែលផ្សេងគ្នា មានដូច្នេះ

បទថា **អក្កោធនោ** គឺមានការមិនក្រោធជាសភាវៈ ព្រោះថា សេចក្ដីក្រោធដែលជាអាឃាតវត្ថុ មានប្រការដូចខ្ញុំពោលហើយខាងដើមនោះ សូម្បីតិចតួចកើតឡើងដល់បុគ្គលខ្លះ ធ្វើចិត្តឲ្យក្ដៅក្រហាយ ហើយស្ងប់បាន តែបុគ្គលខ្លះ រមែងធ្វើមុខក្រញូវដោយសេចក្ដីក្រោធណា ដែលកើតឡើងហើយមានកម្លាំងខ្លាំងជាងសេចក្ដីក្រោធដែលតិចតួចនោះ បុគ្គលខ្លះប្រាថ្នានឹងពោលពាក្យគ្រោតគ្រាតដោយសេចក្ដីក្រោធ ដែលមានកម្លាំងខ្លាំងក្លាជាងនោះ ទើបធ្វើហេតុត្រឹមតែញ័រមាត់ ។ ជនមួយពួកទៀត ពោលពាក្យដោយសេចក្ដីក្រោធដែលមានកម្លាំងខ្លាំងក្លាជាងនោះ មួយពួកទៀត ស្វែងរកដំបង និងសស្ត្រាសម្លឹងមើលទិសទាំងឡាយ ដោយសេចក្ដីក្រោធដែលមានកម្លាំងខ្លាំងក្លាជាងនោះ មួយពួកទៀត ចាប់ដំបង និងសស្ត្រាដោយសេចក្ដីក្រោធដែលមានកម្លាំងខ្លាំងក្លាជាងនោះ មួយពួកទៀត កាន់ដំបងជាដើម រត់ចូលទៅដោយសេចក្ដីក្រោធដែលមានកម្លាំងខ្លាំងក្លាជាងនោះ មួយពួកទៀត វាយប្រហារ ២-៣ ដងដោយសេចក្ដីក្រោធ ដែលមានកម្លាំងខ្លាំងក្លាជាងនោះ មួយពួកទៀត សម្លាប់ទាំងញាតិសាលោហិតរបស់ខ្លួន ដោយសេចក្ដីក្រោធដែលមានកម្លាំងខ្លាំងក្លាជាងនោះ មួយពួកទៀត កើតវិប្បដិសារៈឡើងដោយសេចក្ដីក្រោធដែលមានកម្លាំងខ្លាំងក្លាជាងនោះ ហើយសម្លាប់ខ្លួនឯង ដូចអមាត្យអ្នកកាលគាម ក្នុងកោះសីហលៈ ដោយហេតុមានប្រមាណប៉ុណ្ណេះ សេចក្ដីក្រោធ ឈ្មោះថាដល់នូវការចម្រើនឡើងយ៉ាងក្រៃលែង ។

សេចក្តីក្រោធនោះ ព្រះដ៏មានព្រះភាគទ្រង់លះបានហើយ ដោយប្រការទាំងពួង ត្រង់មណ្ឌលពោធិព្រឹក្សនោះឯង មានឫសដាច់ហើយ ធ្វើឲ្យដូចដើមត្នោតកំបុតកដូច្នោះ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា តថាគតជាអ្នកមិនក្រោធ ។

បទថា **វិគតខិលោ** បានដល់ មានកិលេសដូចជង្គត់ទៅប្រាសហើយ ព្រោះថា ព្រះដ៏មានព្រះភាគបានត្រាស់ដល់កិលេស ដូចសសរគោល ៥ នោះ ព្រោះភាពដែលចិត្តជាសភាពរឹងត្អឹង ។ កាលភ្លៀងដែលជាហេតុនៃកុសលមានការស្តាប់ព្រះសទ្ធម្មជាដើម សូម្បីធ្លាក់ស្រោចត្រង់ចិត្ត ដូចជាជង្គត់ ព្រោះកិលេសដូចជង្គត់ពួកណា កុសលក៏មិនដុះឡើង ប្រៀបដូចកាលភ្លៀងធ្លាក់អស់ ៤ ខែ ក្នុងភូមិភាគដែលដូចជង្គត់ សម្ទូងទាំងឡាយក៏ដុះឡើងមិនបានដូច្នោះ កិលេសដូចជាជង្គត់ទាំងនោះ ព្រះដ៏មានព្រះភាគទ្រង់លះបានហើយដោយប្រការទាំងពួង ត្រង់គល់នៃពោធិព្រឹក្សនោះឯង ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា តថាគតមានកិលេសដូចដំបូលប្រាសទៅហើយ ។

ព្រះដ៏មានព្រះភាគអង្គនោះ មានការនៅអស់រាត្រីមួយ ព្រោះដូច្នោះ ទើបទ្រង់ឈ្មោះថា មានការនៅអស់រាត្រីមួយ ។ នាយធនិយៈនោះ ចូលសម្ងំ ៤ ខែ ត្រង់ច្នេរស្ទឹងមហាមហីនោះ យ៉ាងណា ព្រះដ៏មានព្រះភាគ មិនមែនដូច្នោះឡើយ ដ្បិតថា ព្រះដ៏មានព្រះភាគ យាងចូលក្នុងទីនោះ ត្រឹមតែមួយយប់ប៉ុណ្ណោះ ព្រោះទ្រង់ប្រាថ្នាប្រយោជន៍ដល់នាយធនិយៈនោះ ដូច្នោះ ទើប

ព្រះដ៏មានព្រះភាគត្រាស់ថា តថាគតនៅអស់រាត្រីមួយ ។

បទថា **វិវដា** បានដល់ មិនមានដំបូល អត្តភាព ឈ្មោះថា **កុដិ** ព្រោះថា អត្តភាពអាស្រ័យអំណាចនៃប្រយោជន៍នោះៗ លោកហៅថា កាយខ្លះ ហៅថា គុហាខ្លះ ហៅថា ទេហៈខ្លះ ហៅថា សន្ទេហៈខ្លះ ហៅថា នាវាខ្លះ ហៅថា រថខ្លះ ហៅថា វណៈ គឺមុខដំបៅខ្លះ ហៅថា ធជៈ គឺទង់ខ្លះ ហៅថា វម្មិកៈ គឺដំបូកខ្លះ ហៅថា កុដី គឺខ្ទមខ្លះ ហៅថា កុដិកាខ្លះ ។ ក្នុងទីនេះ អត្តភាពព្រះដ៏មានព្រះភាគត្រាស់ហៅថា កុដិ ព្រោះអាស្រ័យឆ្អឹងជាដើមដល់នូវការរាប់ចូលថាជាកាយ ដូចកុដិដែលបានឈ្មោះថា ផ្ទះ ក៏ព្រោះអាស្រ័យដើមឈើជាដើម សមដូចព្រះសារីបុត្តពោលនៅក្នុង ( មហាហត្ថិបទោបមសូត្រ ) ថា

ម្នាលអ្នកទាំងឡាយមានអាយុ អាកាស គឺទីវាលដែលអាស្រ័យគ្រឿងឈើខ្លះ អាស្រ័យវល្លិសម្រាប់ចងខ្លះ អាស្រ័យជីសម្រាប់លាបខ្លះ អាស្រ័យស្បូវប្រក់ខ្លះ ផ្គុំជាមួយគ្នាហើយ ក៏រាប់ហៅថា ផ្ទះបាន យ៉ាងណាមិញ ម្នាលអ្នកទាំងឡាយមានអាយុ អាកាសដែលអាស្រ័យឆ្អឹងខ្លះ អាស្រ័យសរសៃខ្លះ អាស្រ័យសាច់ខ្លះ អាស្រ័យស្បែកខ្លះ រួបរួមជាមួយគ្នាហើយ ទើបហៅថា រូបបាន ដូច្នោះឯង ។

មួយវិញទៀត អត្តភាព ឈ្មោះថា កុដី ក៏ព្រោះជាទីនៅរបស់សត្វ គឺចិត្ត

សមដូចលោកពោលថា

ខម គឺរាងឬផ្ទះនេះ ជាលំនៅរបស់ស្វា ស្វា គឺចិត្ត តែងចូល ទៅក្នុងខម គឺអត្តភាព មានទ្វារ ៥ កាលញាប់ញ័រស្ទុះចុះឡើង តែងត្រាច់ទៅតាមទ្វារ ។

ភ្លៀង គឺកិលេស មានរាគៈជាដើម រមែងលិចស្រោចរឿយៗ ព្រោះសត្វទាំងឡាយ ត្រូវបិទបាំងដោយគ្រឿងបិទបាំង គឺតណ្ហា មានះ និងទិដ្ឋិ សមដូចព្រះដ៏មានព្រះភាគត្រាស់ថា

ភិក្ខុត្រូវអាបត្តិហើយ បិទបាំងអាបត្តិទុក រមែងត្រូវអាបត្តិថ្មីដទៃទៀត ភិក្ខុត្រូវអាបត្តិហើយ បើកអាបត្តិ មិនត្រូវអាបត្តិដទៃទៀតទេ ព្រោះហេតុនោះ កាលបើភិក្ខុ ( ណាមួយ ) ត្រូវអាបត្តិហើយបិទបាំងអាបត្តិទុក ភិក្ខុ ( នោះ ) ត្រូវបើកអាបត្តិចេញ ធ្វើយ៉ាងនេះ ទើបមិនត្រូវអាបត្តិទៀតនោះឡើយ ។

គាថានេះ លោកពោល ២ កន្លែង គឺក្នុងវិនយក្ខន្ធកៈ និងក្នុងថេរគាថា ។

ក្នុងបណ្តាអាគតដ្ឋានទាំង ២ កន្លែងនោះ ក្នុងខន្ធកៈ ព្រះដ៏មានព្រះភាគត្រាស់ព្រោះអាស្រ័យប្រយោជន៍នេះថា ភិក្ខុណាបិទបាំងអាបត្តិ កិលេស និងអាបត្តិទាំងឡាយ រមែងលិចស្រោចចិត្តភិក្ខុនោះរឿយៗ ចំណែកភិក្ខុណា មិនបិទបាំងអាបត្តិ កិលេសទាំងឡាយនិងអាបត្តិទាំងឡាយ រមែងមិនលិចស្រោច

ចិត្តរបស់ភិក្ខុនោះ ។ ក្នុងថេរគាថា លោកពោលថា បុគ្គលណា មានកិលេស ដូចដំបូល មានរាគៈជាដើម ភ្លៀង គឺអាបត្តិ និងកិលេសនោះ រមែងលិច ស្រោចផ្ទះ គឺទុច្ចរិតដែលបិទបាំងរបស់បុគ្គលនោះ ព្រោះការកើតកិលេស មានរាគៈជាដើម ក្នុងអារម្មណ៍ទាំងឡាយ មានឥដ្ឋារម្មណ៍ជាដើម ឬបុគ្គល ណា កាលកិលេសកើតឡើងហើយ រមែងទទួលយក ភ្លៀង គឺកិលេសរមែង លិចស្រោចរឿយៗ នូវខ្ទម គឺអត្តភាពរបស់ភិក្ខុនោះឯង ដែលបិទបាំងដោយ ដំបូល គឺកិលេស ដែលខ្លួនទទួលយក ព្រោះដំបូល គឺកិលេស ដែលបុគ្គល ណាកម្ចាត់ហើយដោយខ្យល់ គឺអរហត្តមគ្គញ្ញាណ ភ្លៀង គឺកិលេស រមែង មិនលិចស្រោចខ្ទម គឺអត្តភាពរបស់បុគ្គលនោះ ដែលមានដំបូល គឺកិលេស ត្រូវបើកហើយ អត្ថនេះ បំណងយកហើយក្នុងទីនេះ ។

ព្រោះថា ព្រះដ៏មានព្រះភាគ ទ្រង់កម្ចាត់គ្រឿងបិទបាំង គឺដំបូលតាម ដែលពោលហើយ ដោយន័យតាមដែលពោលមកហើយនោះឯង ព្រោះហេតុ នោះ ទើបទ្រង់ត្រាស់ថា ខ្ទមមានដំបូលបើកហើយ ។

បទថា **និព្វុតោ** បានដល់ ចូលទៅស្ងប់ហើយ ។ ពិតហើយ សរីរៈ ទាំងអស់នេះក្តៅដោយភ្លើង ១១ កងណា ភ្លើង ១១ កងនោះ ឈ្មោះថា **គិនិ** សមដូចព្រះដ៏មានព្រះភាគត្រាស់ថា ក្តៅព្រោះភ្លើង គឺរាគៈជាដើម ព្រោះហេតុនោះ គប្បីរកមើលសេចក្តីពិស្តារ អំពីសូត្រខាងដើមនោះ ភ្លើង នោះរបស់ព្រះដ៏មានព្រះភាគ រលត់ហើយត្រង់មណ្ឌលនៃពោធិព្រឹក្សនោះឯង

ព្រោះទឹក គឺអរិយមគ្គ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ភ្លើងរលត់ហើយ ។ ព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះ ឈ្មោះថា ទ្រង់ដាស់តឿន គឺទូន្មានប្រៀនប្រដៅនាយធនិយៈ ដែលត្រេកអរដោយវត្ថុមិនគួរត្រេកអរ ដោយទ្រង់លើកយកវត្ថុដទៃឡើងមកសម្ដែងអាងនោះឯង សួរថា សេចក្ដីនេះដូចម្ដេច ឆ្លើយថា ព្រោះព្រះដ៏មានព្រះភាគ កាលត្រាស់ថា តថាគតមិនក្រោធ រមែងសម្ដែងថា ម្នាលធនិយៈ អ្នកត្រេកអរថា អញមានបាយចម្អិនហើយ បាយឆ្អិនដែលបុគ្គលគប្បីដាំដោយការអស់ទៅនៃទ្រព្យ រហូតអស់ជីវិតការ អស់ទ្រព្យជាហេតុឲ្យកើតសេចក្ដីទុក្ខ ក្នុងបណ្ដាទុក្ខទាំងឡាយ មានទុក្ខព្រោះការរក្សាជាដើម កាលបើដូច្នេះ អ្នកឈ្មោះថា ជាអ្នកត្រេកអរដោយទុក្ខ តែតថាគតត្រេកអរថា តថាគតជាអ្នកមិនក្រោធ ទើបឈ្មោះថា ត្រេកអរហើយ ដោយការមិនមានទុក្ខ ទាំងបច្ចុប្បន្ន និងក្នុងសម្បរាយភព ។ ព្រះដ៏មានព្រះភាគកាលត្រាស់ថា តថាគតមិនមានកិលេសដូចសសរគោល រមែងសម្ដែងថា ម្នាលធនិយៈ អ្នកត្រេកអរថា អញរឹតទឹកដោះស្រេចហើយ ទើបគិតថា អញមិនត្រូវធ្វើការងារឡើយ អស់ធុរៈហើយ ទើបត្រេកអរ តែតថាគតពេញចិត្តថា តថាគតមិនមានកិលេសដូចសសរគោល ជាអ្នកសម្រេចកិច្ចហើយ ទើបត្រេកអរ ។

ព្រះដ៏មានព្រះភាគកាលត្រាស់ថា តថាគតនៅត្រង់ប្រាំងស្ទឹងមហីអស់រាត្រីមួយ ឈ្មោះថា រមែងសម្ដែងថា ម្នាលធនិយៈ អ្នកត្រេកអរថា អញនៅ

រួមគ្នាត្រង់ធ្មេញស៊ីធម៌ហើយជាមួយភរិយា កូនប្រុស និងកម្មករ ឈ្មោះថា ត្រេកអរហើយ ដោយការនៅរួមជាប្រចាំអស់ ៤ ខែ ឯការនៅប្រចាំ រមែងមានដោយការពាក់ព័ន្ធក្នុងទីលំនៅ ការពាក់ព័ន្ធដោយទីលំនៅនោះជាទុក្ខ កាលបើដូច្នោះ អ្នក ឈ្មោះថា ជាអ្នកពេញចិត្តដោយទុក្ខនោះឯង ចំណែកតថាគតពេញចិត្តថា តថាគតនៅអស់រាត្រីមួយ ឈ្មោះថា ពេញចិត្ត ដោយការមិននៅប្រចាំ ឯការមិននៅប្រចាំ រមែងមានព្រោះការមិនជាប់ជំពាក់ដោយទីលំនៅ ឯការមិនមានការជាប់ជំពាក់ជាសេចក្តីសុខ ដូច្នោះ ទើបតថាគតជាអ្នកពេញចិត្ត ក្នុងសេចក្តីសុខនោះឯង ។

ព្រះដ៏មានព្រះភាគកាលត្រាស់ថា ខ្ទមមានដំបូលបើកហើយ ឈ្មោះថា រមែងសម្តែងថា ម្នាលធនិយៈ ខ្ទមអ្នកត្រេកអរថា អញប្រក់ខ្ទមហើយ ឈ្មោះថា ត្រេកអរ ព្រោះហេតុដែលផ្ទះបានប្រក់ហើយ កាលបើអ្នកប្រក់ផ្ទះហើយក្តី អ្នកកាលត្រូវជំនន់ទឹកធំទាំង ៤ ដែលកើតឡើងអំពីភ្លៀង គឺកិលេសដែលលិចស្រោចខ្ទម គឺអត្តភាពរបស់អ្នក បានបន្សាត់ទៅ ក៏នឹងដល់នូវសេចក្តីវិនាស កាលបើដូច្នេះ អ្នកក៏គប្បីឈ្មោះថាជាអ្នកត្រេកអរដោយវត្ថុដែលមិនគួរត្រេកអរនោះឯង តែតថាគតត្រេកអរថា ខ្ទមមានដំបូលបើកហើយ ឈ្មោះថា ត្រេកអរដោយភាពដែលខ្ទម គឺអត្តភាពមិនមានដំបូល គឺកិលេស កាលដែលតថាគតបើកខ្ទមហើយយ៉ាងនេះ តថាគតត្រូវជំនន់ទឹកទាំង ៤ ដែលកើតឡើងអំពីភ្លៀង គឺកិលេសដែលលិចស្រោចខ្ទម គឺអត្តភាពរបស់តថាគតនោះ

មិនបានបន្សាត់ទៅ និងមិនដល់នូវសេចក្តីវិនាស កាលបើដូច្នេះ តថាគត ឈ្មោះថា ជាអ្នកគ្រេកអរដោយវត្ថុដែលគួរគ្រេកអរប៉ុណ្ណោះ ។

ព្រះដ៏មានព្រះភាគកាលត្រាស់ថា ភ្លើងរលត់ហើយ រមែងសម្តែងថា ម្នាលធនិយៈ អ្នកត្រេកអរថា អញបានបង្កាត់ភ្លើងហើយ គិតថា អញជាអ្នក មិនបានសាងគ្រឿងការពារអន្តរាយឡើយ ទើបបានសាងគ្រឿងការពារ អន្តរាយហើយ តែតថាគតត្រេកអរថា ភ្លើងរលត់ហើយ ឈ្មោះថា ត្រេកអរ ហើយ ព្រោះតថាគតបានធ្វើគ្រឿងការពារអន្តរាយហើយ ព្រោះមិនមាន គ្រឿងក្តៅក្រហាយអំពីភ្លើង ១១ កង ។

ព្រះដ៏មានព្រះភាគកាលត្រាស់ថា នែភ្លៀង កាលបើដូច្នេះ បើអ្នក ប្រាថ្នាក៏ចូរបង្អុរមកចុះ ឈ្មោះថា ទ្រង់សម្តែងថា ពាក្យនេះ រមែងស្អាត សម្រាប់មនុស្សទាំងឡាយ ដូចតថាគតដែលប្រាសចាកសេចក្តីទុក្ខហើយ ជួប នូវសេចក្តីសុខហើយ ជាអ្នកបានធ្វើកិច្ចទាំងពួងហើយ ព្រោះហេតុនោះ នែ ភ្លៀង បើអ្នកប្រាថ្នា ក៏ចូរបង្អុរមកចុះ ព្រោះបើអ្នកបង្អុរក្តី មិនបង្អុរក្តី សេចក្តីចម្រើន ឬសេចក្តីវិនាស ក៏មិនមានដល់តថាគតឡើយ ចំណែកអ្នក ពោលយ៉ាងនេះ ព្រោះហេតុអ្វី ព្រោះហេតុនោះ ពាក្យណាដែលខ្ញុំពោលថា ព្រះដ៏មានព្រះភាគកាលត្រាស់យ៉ាងនេះ ឈ្មោះថា ទ្រង់ជាស់តឿន គឺទូន្មាន ធនិយគោបៈដែលត្រេកអរដោយវត្ថុដែលមិនគួរត្រេកអរ ដោយនាំវត្ថុដទៃមក ជាគ្រឿងអាងនោះឯង ។ ពាក្យនោះ ឈ្មោះថា ពោលត្រឹមត្រូវ ។

អ្នកចិញ្ចឹមគោឈ្មោះធនិយៈ ទោះបីបានស្តាប់ព្រះគាថា ដែលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះ ក៏មិនពោលថា អ្នកណាពោលគាថា ពេញចិត្តក្រៃលែងដោយភាសិតនេះ បំណងនឹងស្តាប់គាថាបែបនោះទៀត ទើបពោលគាថាបន្តថា **អន្ធកមកសា** ជាដើម ។

បណ្តាបទទាំងនោះ ពាក្យថា **អន្ធក** ជាឈ្មោះនៃរបោម តែអាចារ្យពួកខ្លះពោលថា ពាក្យថា **អន្ធកា** ជាឈ្មោះរបស់សត្វរបោម ដែលមានពណ៌ត្នោតក៏មាន មូសនោះឯង ឈ្មោះថា **មកសា** ។ បទថា **ន វិជ្ជរេ** បានដល់ មិនមាន ។ ភូមិប្រទេសដែលល្អ ក្នុងពាក្យថា **កច្ឆេ** មានពីរប្រភេទ គឺភូមិប្រទេសដែលល្អ ក្នុងទីជិតស្ទឹង ១ ភូមិប្រទេសដែលល្អ ក្បែរភ្នំ ១ ក្នុងទីនេះ ព្រះដ៏មានព្រះភាគ សំដៅយកភូមិប្រទេសដែលល្អ ក្បែរស្ទឹង ។

បទថា **រុឡ្ហតិណេ** បានដល់ ក្នុងស្មៅដែលដុះឡើង ។ បទថា **ចរន្តិ** បានដល់ រមែងរកស៊ី ។ បទថា **វុដ្ឋិម្បិ** បានដល់ ភ្លៀងច្រើនប្រភេទ មានភ្លៀងលាយខ្យល់ជាដើម ។ ភ្លៀងទាំងនោះ ខ្ញុំបានប្រកាសក្នុងអាឡវកសូត្រ តែក្នុងទីនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដៅយកភ្លៀង ដែលធ្លាក់ក្នុងរដូវវស្សា ។ បទថា **សហេយ្យុំ** បានដល់ គប្បីអត់ធន់ ។ ពាក្យដ៏សេស ជាក់ច្បាស់ទាំងអស់ហើយ ។

ក្នុងគាថាទី ៣ នេះ អ្នកសិក្សាគប្បីជ្រាបអធិប្បាយដូចតទៅ របោមនិងមូសឯណា ចោមរោមបឺតឈាមនៃគោទាំងឡាយ រមែងធ្វើឲ្យគោទាំង-

ឡាយដល់នូវសេចក្តីវិនាសមួយរំពេចប៉ុណ្ណោះ ព្រោះហេតុនោះ កាលភ្លៀងធ្លាក់ចុះមកប៉ុណ្ណោះ នាយគោបាលទាំងនោះ ក៏ប្រើធូលី និងមែកឈើសម្លាប់របោម និងមូសទាំងនោះចោល ។ នាយធនិយៈ កាលសម្តែងដល់ការក្រេមនៃគោទាំងឡាយ ព្រោះរបោម និងមូសទាំងនោះមិនមាន និងសម្តែងដល់ការមិនលំបាក ព្រោះបានពោលដល់ការមិនមានអន្តរាយ ក្នុងការដើរផ្លូវឆ្ងាយដោយការត្រាច់ទៅក្នុងទីកដីដែលត្រជាក់ត្រជុំ ដែលមានស្មៅដុះហើយ ឈ្មោះថារមែងសម្តែងថា គោទាំងឡាយរបស់អ្នកដទៃ ប្រាកដដោយការបៀតបៀននៃរបោម និងមូស លំបាកដោយការធ្វើដំណើរផ្លូវឆ្ងាយ ស្គាំងស្គមព្រោះបានស្មៅតិច មិនគប្បីអត់ធន់ សូម្បីភ្លៀងដែលធ្លាក់ចុះមកម្តងបាន យ៉ាងណាគោទាំងឡាយរបស់អញ មិនដូច្នោះឡើយ តែគោទាំងឡាយរបស់អញ គប្បីអត់ធន់ចំពោះភ្លៀងដែលធ្លាក់ចុះមក ទោះបី ២ ដង ៣ ដង ព្រោះមិនមានអន្តរាយដូចពោលមកហើយ ។

លំដាប់នោះ ព្រោះនាយធនិយៈកំពុងនៅត្រង់កណ្តាលកោះ ដែលមានស្ទឹងព័ទ្ធជុំវិញ ឃើញភ័យហើយក៏ចងក្បូន ហើយឆ្លងស្ទឹងមហាមហីដល់ភូមិប្រទេស ដែលត្រជាក់ត្រជុំនោះហើយ ក៏សម្គាល់ថា អញមកល្អ តាំងនៅក្នុងទីផុតភ័យហើយ ទើបបានពោលយ៉ាងនេះ តែគាត់ក៏នៅក្នុងទីដែលមានភ័យនោះឯង ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគពណ៌នាដល់ទីដែលនាយធនិយៈនោះមក និងទីដែលទ្រង់យាងមកថា ប្រសើរជាង និងប្រណីត

ជាងនោះ ទើបត្រាស់គាថានេះថា **ពន្ធា ហិ កិសី** ជាដើម ដែលជាចំណែកស្មើគ្នានៃអត្ថ មិនបានត្រាស់ចំណែកដែលស្មើគ្នានៃព្យញ្ជនៈឡើយ ។

ក្នុង ៤ គាថាទីនេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ក្បួនដែលគេចងធ្វើឲ្យផ្សាយចេញ គឺធ្វើឲ្យទូលាយ គេសន្មតថា **កិសី** តែក្នុងធម្មវិន័យរបស់ព្រះអរិយៈ អរិយមគ្គ លោកហៅថា ក្បូន ។

មគ្គ ១ បជ្ជៈ ១ បថៈ ១ បន្ថៈ ១ អញ្ជសៈ ១ វដុមាយនៈ ១ នាវា ១ ឧត្តរសេតុ ១ កុល្លៈ ១ កិសិ ១ សង្កមៈ ១ អទ្ធានៈ ១ បភវៈ ១ លោកប្រកាសហើយក្នុងទីនោះៗ ( ថា អរិយមគ្គ ) ។

ព្រះដ៏មានព្រះភាគ ទ្រង់ទូន្មានទូវនាយធនិយៈ ដោយន័យមុននោះឯង ដោយគាថានេះគប្បីជ្រាបថា ទ្រង់ត្រាស់ហើយនូវអត្ថនេះ ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលធនិយៈ អ្នកចងក្បូនហើយ ឆ្លងស្ទឹងមហី មកដល់ទីនេះហើយ ឯក្បូនរបស់អ្នក អ្នកក៏នឹងត្រូវចងទៀតនោះឯង ហើយស្ទឹងអ្នកក៏នឹងត្រូវឆ្លងទៀត ទីនោះនឹងជាទីផុតភ័យក៏មិនមែន ។ ចំណែកក្បូនដែលតថាគតធ្វើអង្គអរិយមគ្គឲ្យរួមក្នុងចិត្តមួយ ហើយចងដោយចំណង គឺញាណ ដោយការមិនឃ្លាតកន្លងនូវគ្នានិងគ្នា ព្រោះមិនមានគ្រឿងចងដែលនឹងចងទៀត ព្រោះទៅតាមសភាវៈដែលមានរសតែមួយ ទាក់ទងក្នុងការបរិបូណ៌ ដោយពោធិបក្ខិយធម៌ ៣៧ ឈ្មោះថា ចងល្អ ព្រោះបុគ្គលណាមួយ ក្នុងទេវតា និងមនុស្សមិនអាចនឹងស្រាយបាន ព្រោះមិនមានគ្រឿង

ប្រកបដែលគប្បីចង តថាគតជាអ្នកចងហើយដោយក្បូននោះ ដល់ប្រទេសនៃត្រើយ ដែលតថាគតប្រាថ្នាក្នុងកាលមុនហើយ សូម្បីទៅនឹងទៅដល់ប្រទេសខ្វះប៉ុណ្ណោះ ដូចព្រះសោតាបន្នជាដើមក៏មិនមែន ដោយពិតនោះ តថាគតទៅដល់ត្រើយ គឺអស់ទៅនៃអាសវៈ ឬត្រើយនៃធម៌ទាំងពួង គឺសម្រេចដល់ព្រះនិព្វានដ៏សុខុម ផុតភ័យហើយ ។

ម្យ៉ាងទៀត បទថា **តិណ្ណោ** បានដល់ សម្រេចសព្វញ្ញុតញ្ញាណ ។ បទថា **ឥារគតោ** បានដល់ សម្រេចអរហត្ត ។

បើមានពាក្យសួរថា ទ្រង់កម្ចាត់អ្វី ទើបដល់ត្រើយបាន ឆ្លើយថា ទ្រង់កម្ចាត់ឱឃៈ ៤ យ៉ាង មានកាមោឃៈជាដើម ចងឱឃៈហើយ ឬកន្ទ្រង់ផុតឱឃៈហើយ ទើបដល់ត្រើយបាន ។

ឥឡូវនេះ តថាគតមិនត្រូវការដោយក្បូនទៀតឡើយ ព្រោះមិនមានត្រើយដែលត្រូវឆ្លង ព្រោះហេតុនោះ ការពោលរបស់តថាគតប៉ុណ្ណោះ ត្រឹមត្រូវហើយ នៃភ្លៀង កាលបើដូច្នេះ បើអ្នកប្រាថ្នានឹងធ្លាក់ ក៏ចូរបង្អុរមកចុះ ។

នាយធនិយៈស្តាប់ព្រះតម្រាស់នោះហើយ បានពោលគាថានេះថា **គោបី មម អស្សវា** ជាដើម ។

បណ្តាបទទាំងឡាយនោះ បទថា **គោបី** នាយធនិយៈ សម្តែងដល់ភរិយា ។

បទថា **អស្សវា** បានដល់ ជាអ្នកស្តាប់បង្គាប់ គឺមានប្រក្រតីស្តាប់ពាក្យ

មិនថា ក្នុងកិច្ចការណាមួយឡើយ ។

បទថា **អលោលា** សេចក្តីថា ព្រោះថា មាតុគ្រាម ជាអ្នកឡេះឡោះ ដោយការឡេះឡោះ ៥ ប្រការ គឺ ឡេះឡោះក្នុងអាហារ ១ ឡេះឡោះក្នុងគ្រឿងប្រដាប់ ១ ឡេះឡោះក្នុងបុរសដទៃ ១ ឡេះឡោះក្នុងទ្រព្យ ១ ឡេះឡោះក្នុងការដើរផ្សេង ១ ។ ពិតហើយ មាតុគ្រាម ដោយហោច រមែងបរិភោគកត្តតាមប្រក្រតីខ្លះ រមែងទំពាស៊ីរបស់គួរទំពាដែលមកដល់ដៃខ្លះ បានទ្រព្យ ២ ដងហើយ ផឹកស្រាខ្លះ ព្រោះជាអ្នកឡេះឡោះក្នុងអាហារ មានដោយកត្ត នំ និងស្រាជាដើម ព្រោះឡេះឡោះក្នុងគ្រឿងប្រដាប់ កាលមិនបានគ្រឿងប្រដាប់ដទៃ ដោយហោច សូម្បីបានប្រេងល្វលាយទឹក ក៏រមែងលាបសក់ លាបមុខ ព្រោះហេតុដែលឡេះឡោះក្នុងបុរសដទៃ ដោយហោច សូម្បីតែកូនរបស់ខ្លួន ហៅមកក្នុងប្រទេសដូច្នោះ ( ទីស្ងាត់ ) រមែងគិតដល់ដោយអំណាចអសទ្ធម្មមុន ។ ព្រោះឡេះឡោះក្នុងទ្រព្យ បានស្តេចហង្សហើយ ក៏សាបសូន្យចាករោមមាស ។ ឡេះឡោះក្នុងការដើរផ្សេង ទើបមាតុ-គ្រាម ជាអ្នកច្រើនទៅក្នុងទីផ្សេងៗ មានសួនច្បារជាដើម រមែងធ្វើទ្រព្យទាំងពួងឲ្យវិនាស ។

ក្នុងគាថានោះ នាយធនិយៈ កាលសម្តែងថា សេចក្តីឡេះឡោះណាមួយក៏មិនមានដល់ភរិយារបស់យើង ទើបពោលថា ជាស្រីមិនឡេះឡោះ ។

ពីរបទថា **ទីឃរត្តំ សំវាសិយា** នាយធនិយៈ រមែងសម្តែងថា ភរិយា

របស់យើងនៅរួមគ្នាអស់កាលយូរ តាំងអំពីយើងនៅជាកំលោះ ក៏ចម្រើនឡើងដោយមានចិត្តមួយ រមែងមិនស្គាល់ប្រុសដទៃ ព្រោះការមានចិត្តមួយនោះ ។

ដោយបទថា **មនាបា** នាយធនិយៈ រមែងសម្តែងថា កិរិយារបស់យើង នាងមិនស្គាល់បុរសដទៃយ៉ាងនេះ ឈ្មោះថា រមែងគាប់ចិត្តរបស់យើងនោះឯង ។

ដោយបាទព្រះគាថាថា **តស្សា ន សុណាមិ កិញ្ចិ បាបំ** នាយធនិយៈ រមែងសម្តែងថា យើងមិនបានឮទោសនៃការប្រព្រឹត្តិក្រៅចិត្តណាមួយរបស់កិរិយានោះយ៉ាងនេះថា កិរិយារបស់យើងមានការសើច ឬការនិយាយឡកឡាយជាមួយប្រុសដទៃឈ្មោះនេះ ។

បន្ទាប់អំពីនោះ ព្រះដ៏មានព្រះភាគកាលទ្រង់ទូន្មាននាយធនិយៈ ដែលត្រេកអរដោយកិរិយា ដោយគុណទាំងនេះ ទើបត្រាស់គាថានេះ ដែលដូចគ្នាទាំងដោយអត្ថ និងដូចគ្នាដោយព្យញ្ជនៈថា **ចិត្តំ មម អស្សវំ** ជាដើម ដោយន័យមុននោះឯង ។

បទទាំងឡាយក្នុងគាថាទី ៦ នោះ យល់ងាយទាំងអស់ហើយ តែមានអធិប្បាយដូចតទៅនេះថា

ម្នាលធនិយៈ អ្នកត្រេកអរថា កិរិយារបស់អញជឿស្តាប់ តែកិរិយារបស់អ្នកនោះស្តាប់បង្គាប់ខ្លះ មិនស្តាប់ខ្លះ ចិត្តរបស់អ្នកដទៃដឹងបានលំបាក

ដោយចំពោះចិត្តរបស់មាតុគ្រាម ដ្បិតថា បុរសទាំងឡាយសូម្បីចិញ្ចឹមមាតុ-គ្រាមដោយអាហារ ក៏មិនអាចរក្សាបានឡើយ ព្រោះចិត្ត ជាធម្មជាតរក្សាលំបាកនោះឯង មនុស្សទាំងឡាយដូចអ្នកមិនអាចជ្រាបបានថា ស្ត្រីមានការប្រព្រឹត្តិឡេះឡោះ ឬស្តាប់បង្គាប់ ជាទីស្រឡាញ់ ឬជាទីពេញចិត្ត ជាអ្នកមិនមានអំពើលាមក តែចិត្តរបស់តថាគតស្តាប់បង្គាប់ ធ្វើតាមឱវាទ ប្រព្រឹត្តទៅក្នុងអំណាចរបស់តថាគត តថាគតមិនប្រព្រឹត្តទៅក្នុងអំណាចរបស់ចិត្តនោះការដែលចិត្តរបស់តថាគតនោះស្តាប់បង្គាប់នោះ បានប្រាកដដល់ជនទាំងពួងក្នុងកាលផ្ការភ្លើង និងផ្ការទឹកនៃឆព្វណ្ណរង្សី ប្រព្រឹត្តទៅខាងដើមនៃយមក-ប្បាដិហារ្យ ដ្បិតថា យមកប្បាដិហារ្យនោះ តថាគតចូលតេជោកសិណ ក្នុងកាលនិម្មិតផ្ការភ្លើងឡើង តថាគតចូលអាបោកសិណ ក្នុងកាលនិម្មិតផ្ការទឹកចូលកសិណ មាននីលកសិណជាដើម ក្នុងកាលនិម្មិតពណ៌ខៀវជាដើម ព្រោះថា សូម្បីព្រះពុទ្ធទាំងឡាយ ក៏មិនមានចិត្ត ២ ដួងប្រព្រឹត្តទៅព្រមគ្នា ចិត្ត ១ ដួងប៉ុណ្ណោះ ប្រព្រឹត្តទៅដោយអំណាចយ៉ាងនេះ ដោយភាពជាចិត្តដែលស្តាប់បង្គាប់ ឯចិត្តនោះឯងផុតហើយ ព្រោះផុតចាកការពាក់ព័ន្ធនៃកិលេសទាំងពួង ព្រោះរួចផុតទៅបាន ទើបចិត្តនោះ មិនឡេះឡោះ មិនដូចគ្នានឹងកិរិយារបស់អ្នក ព្រោះថា ចាប់តាំងពីកាលព្រះពុទ្ធ ព្រះនាមទីបង្ករជាដើមមក ចិត្តរបស់តថាគតតាំងមាំដោយល្អ ព្រោះតថាគតបានអប់រំដោយបារមីមានទាន និងសីលជាដើម អស់កាលយូរ មិនដូចកិរិយារបស់អ្នក ចិត្តនេះ

ឈ្មោះថា ទូន្មានល្អហើយ ព្រោះបានបង្ហឹកហើយ ដោយការបង្ហឹកដ៏កំពូល ព្រោះបង្ហឹកល្អហើយនេះឯង ទើបចិត្តលោសចោលនូវការសេពខុសក្នុងទ្វារទាំង ៦ ដោយអំណាចរបស់ខ្លួនបាន ទើបឈ្មោះថា ជាទីពេញចិត្ត ព្រោះប្រព្រឹត្ត ទៅតាមអំណាចនៃបំណងរបស់តថាគតបាន មិនដូចកិរិយារបស់អ្នក ។

ដោយគាថានេះថា **ចាបំ បន មេ ន វិជ្ជតិ** ព្រះដ៏មានព្រះភាគទ្រង់សម្តែង ភាពដែលចិត្តរបស់ខ្លួននោះមិនមានបាប ដូចនាយធនិយៈសម្តែងកិរិយារបស់ ខ្លួន ដែលមិនមានការប្រព្រឹត្តិ មិនជាប្រយោជន៍ ។

ភាពដែលព្រះដ៏មានព្រះភាគជាអ្នកមិនមានបាបនោះ មិនបានកើតឡើង ក្នុងកាលដែលព្រះអង្គ បានជាព្រះសម្មាសម្ពុទ្ធតែម្យ៉ាងឡើយ គប្បីជ្រាបថា បានកើតឡើងដល់ព្រះអង្គ តាំងពីទ្រង់នៅជាយភាវៈ ក្នុងកាលដែលទ្រង់ មានរាគៈជាដើម អស់ ២៩ ឆ្នាំ ។ ពិតហើយ ក្នុងកាលនោះ កាយទុច្ចរិតក្តី វចីទុច្ចរិតក្តី មនោទុច្ចរិតក្តី ដែលវិញ្ញូជនខ្ពើម ដែលសមគួរដល់អ្នកគ្រប់គ្រង ផ្ទះ ក៏មិនធ្លាប់កើតឡើងដល់ព្រះអង្គឡើយ ។ ក្រៅលែងជាងនោះ សូម្បីមារ ជាប់តាមព្រះតថាគតអស់ ៧ ឆ្នាំ គឺជាប់តាមព្រះអង្គ ដែលមិនទាន់ត្រាស់ ដឹង ៦ ឆ្នាំ ត្រាស់ដឹងហើយ ១ ឆ្នាំទៀត ដោយបំណងថា ធ្វើម្តេចហ្ន៎ អញ គប្បីឃើញការប្រព្រឹត្តិអាក្រក់របស់សមណគោតមនោះ សូម្បីប៉ុនចុងរោម ទ្រាយ ។

មារនោះ កាលមិនឃើញការប្រព្រឹត្តិវិនាសរបស់ព្រះតថាគត ក៏កើត

ការនឿយណាយ ទើបបានពោលគាថានេះថា

អាត្មាអញបានជាប់ប្រកិត តាមព្រះមានព្រះភាគ អស់ ៧ ឆ្នាំហើយ មិនបាននូវចន្លោះ គឺទោសរបស់ព្រះសម្ពុទ្ធ អ្នកមានសិរីសោះ ។

ក្នុងពុទ្ធកាល ឧត្តរមាណពបំណងនឹងឃើញការប្រព្រឹត្តិរបស់ព្រះដ៏មានព្រះភាគ ទើបជាប់តាមព្រះអង្គអស់ ៧ ខែ ក៏មិនបានឃើញទោសត្រឹមតែមួយ របស់ព្រះដ៏មានព្រះភាគអង្គនោះ ទើបដាក់នូវការឃើញថា ព្រះដ៏មានព្រះភាគ ជាអ្នកមានការប្រព្រឹត្តិបរិសុទ្ធ ។

វត្ថុដែលព្រះតថាគតមិនរក្សាមាន ៤ ប្រការ សមដូចព្រះដ៏មានព្រះភាគត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ ហេតុទាំងឡាយ ៤ យ៉ាងនេះ តថាគតមិនបាច់រក្សាផង មិនមានការតិះដៀលដោយហេតុ ៣ យ៉ាងផង ។ ហេតុទាំង ៤ យ៉ាង ដែលតថាគតមិនបាច់រក្សា តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ តថាគត មានកាយសមាចារបរិសុទ្ធហើយ កាយទុច្ចរិតរបស់តថាគតមិនមានទេ ដែលតថាគតគួររក្សាថា កុំឲ្យបុគ្គលដទៃដឹងនូវកាយទុច្ចរិតនេះ របស់តថាគតឡើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគត មានវចីសមាចារបរិសុទ្ធហើយ វចីទុច្ចរិតរបស់តថាគតមិនមានទេ ដែលតថាគតគួររក្សា ។បេ។

ម្នាលភិក្ខុទាំងឡាយ តថាគត មានមនោសមាចារបរិសុទ្ធហើយ មនោទុច្ចរិតរបស់តថាគត មិនមានទេ ដែលតថាគតគួររក្សា ។បេ។ ម្នាលភិក្ខុទាំងឡាយ តថាគត មានការចិញ្ចឹមជីវិតបរិសុទ្ធហើយ ការចិញ្ចឹមជីវិតខុសរបស់តថាគត មិនមានទេ ដែលតថាគតគួររក្សាថា កុំឲ្យបុគ្គលដទៃ ដឹងនូវការចិញ្ចឹមជីវិតខុសនេះរបស់តថាគតឡើយ ។ ហេតុទាំង ៤ យ៉ាងនេះ តថាគត មិនបាច់រក្សាទេ ដូច្នេះ ។

ព្រោះហេតុដែលបាបមិនមានដល់ចិត្តរបស់ព្រះតថាគត ក្នុងកាលដែលព្រះអង្គជាព្រះសម្មាសម្ពុទ្ធតែម្យ៉ាងប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុន បាបក៏មិនមានដល់ចិត្តរបស់ព្រះអង្គដូចគ្នា ដូច្នោះ ទើបទ្រង់ត្រាស់ថា ចំណែកបាប មិនមានដល់តថាគតទៀតទេ ។

ព្រះគាថានោះ មានអធិប្បាយថា បុគ្គលណាម្នាក់មិនអាចបានឮបាបនៃចិត្តរបស់តថាគតឡើយ ដូចនាយធនិយៈ មិនអាចបានឮការប្រព្រឹត្តិអាក្រក់របស់ភរិយាខ្លួនដូច្នោះ ព្រោះហេតុនោះ បើអ្នកត្រេកអរហើយដោយគុណទាំងនេះ ក៏គប្បីពោលថា នៃភ្លៀង កាលបើដូច្នេះ បើអ្នកប្រាថ្នា ក៏ចូរបង្អុរមកចុះ ពាក្យនេះ តថាគត ក៏គប្បីពោលដូចគ្នា ។

នាយធនិយៈស្តាប់ពាក្យនោះហើយ ត្រូវការផឹករសរបស់សុភាសិតឲ្យក្រៃលែងឡើងជាងនោះ កាលសម្តែងភាពដែលខ្លួនជាអ្នកជា ទើបពោលថា

**អត្តវេតនភតោហមស្មិ** ជាដើម ។

បណ្តាបទទាំងឡាយនោះ ដោយបទថា **អត្តវេតនភតោ** នាយធនិយៈ សម្តែងថា យើងចិញ្ចឹមខ្លួនឯងប៉ុណ្ណោះដោយអាហារ និងគ្រឿងស្លៀកដណ្តប់ យើងធ្វើការងាររបស់ខ្លួន ទើបមានជីវិត មិនបានទទួលថ្លៃឈ្នួលរបស់អ្នកដទៃ ហើយធ្វើការងារដើម្បីអ្នកដទៃឡើយ បុត្រ និងធីតាទាំងឡាយ ឈ្មោះថា **បុត្តា** បុត្រ និងធីតាទាំងនោះ លោកហៅរួមគ្នាថា បុត្តដូចគ្នា ។

បទថា **សមានិយា** បានដល់ តាំងនៅដោយល្អ គឺមិនបែកគ្នា ។ ដោយបទថា **អរោគា** នាយធនិយៈរមែងសម្តែងថា កូនប្រុស និងកូនស្រីគ្រប់គ្នានោះឯង មិនមានអាពាធ ជាអ្នកមានកម្លាំងរឹងប៉ឹង ។

បាទគាថាថា **តេសំ ន សុណាមិ កិញ្ចិ បាបំ** សេចក្តីថា យើងមិនបានឮអំពើអាក្រក់ណាមួយរបស់កូនប្រុស និងកូនស្រីទាំងនោះថា កូននោះ ឬធីតានេះជាចោរ ឬថា កូនប្រុសទាំងនេះ ប្រព្រឹត្តខុសជាមួយភរិយារបស់អ្នកដទៃ ឬថា កូនប្រុស និងកូនស្រីទាំងឡាយ ជាមនុស្សទ្រុស្តសីល ។

កាលនាយធនិយៈពោលយ៉ាងនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់ទូន្មានធនិយៈនោះ ដោយន័យមុននោះឯង ទើបត្រាស់គាថានេះថា **នាហំ ភតកោ** ជាដើម ។

បទទាំងឡាយសូម្បីក្នុងគាថាទី ៨ នោះយល់បានងាយទាំងអស់ហើយ តែមានអធិប្បាយដូចតទៅនេះថា

អ្នកគិតថា អញជាអ្នកជា ទើបត្រេកអរ តែបើពោលដោយបរមត្ថហើយ អ្នកធ្វើការរបស់ខ្លួន សូម្បីមានជីវិត ក៏ឈ្មោះថានៅជាទាសៈនោះឯង ព្រោះអ្នកជាទាសៈនៃតណ្ហា ទើបអ្នកមិនផុតចាកពាក្យថាជាកូនឈ្នួល សមដូចព្រះរដ្ឋបាលពោលថា សត្វលោកមានតែសេចក្តីខ្វះខាត មិនចេះឆ្អែត សុទ្ធតែជាខ្ញុំរបស់តណ្ហា ដូច្នេះជាដើម ។

បើពោលដោយបរមត្ថ តថាគតមិនមែនជាខ្ញុំបម្រើរបស់អ្នកណា ព្រោះតថាគតមិនមែនជាកូនឈ្នួលរបស់អ្នកដទៃ ឬជាកូនឈ្នួលរបស់ខ្លួនឯង ព្រោះហេតុអ្វី ព្រោះតថាគតរមែងត្រាច់ទៅក្នុងលោកទាំងពួង ដោយភាពជាសព្វញ្ញូ ដែលមិនមានសេចក្តីត្រូវការ ព្រោះថាតថាគតរាប់តាំងអំពីព្រះពុទ្ធ ព្រះនាមថាទីបង្ករ រហូតដល់ត្រាស់ដឹង ក៏ជាអ្នកស៊ីឈ្នួលរបស់សព្វញ្ញុតញ្ញាណរហូតមក តែកាលតថាគតបានសម្រេចសព្វញ្ញុតញ្ញាណហើយ តថាគតក៏ជាអ្នកនៅដោយភាពជាសព្វញ្ញូ ដែលមិនមានសេចក្តីត្រូវការនោះឯង និងដោយសេចក្តីសុខដែលកើតអំពីលោកុត្តរសមាធិ ដូចខ្ញុំរាជការដែលមិនត្រូវការប្រាក់ខែដូច្នោះ ឥឡូវនេះ តថាគតមិនត្រូវការដោយថ្លៃឈ្នួលណា ដែលគប្បីបានទទួល ដូចមនុស្សទាំងឡាយ ដូចអ្នកដែលមិនទាន់លះបដិសន្ធិបាន គប្បីបានទទួល ព្រោះមិនមានកិច្ចណាមួយដែលត្រូវធ្វើក្រៃលែងឡើង ឬកិច្ចត្រឹមតែតិចតួច ។ ព្រះបាលីថា **ភតិយា** ក៏មាន ព្រោះហេតុនោះ បើអ្នកត្រេកអរ ព្រោះឃើញថា ខ្លួនជាអ្នកជា គប្បីពោលថា នៃភ្លៀង បើដូច្នេះ បើអ្នកប្រាថ្នា

ក៏ចូរបង្អុរមកចុះ ពាក្យនេះ តថាគតឯង គប្បីពោលដូចគ្នា ។

នាយធនិយៈស្តាប់ព្រះតម្រាស់នោះហើយក៏មិនឆ្អែត កាលសម្តែងដល់ភាពបរិបូណ៌នៃហ្វូងគោដែលមានឧបការៈ ៥ ប្រភេទរបស់ខ្លួន ដោយពាក្យដែលជាសុភាសិត ទើបពោលគាថានេះថា **អត្ថិ វសា** ជាដើម ។

ក្នុងគាថានោះ គោដែលមិនទាន់បានហ្វឹកទាំងឡាយ ឈ្មោះថា **វសា** ។ កូនគោដែលនៅជំទង់ កំពុងបៅដោះទាំងឡាយ ឈ្មោះថា **ធេនុបា** ម្យ៉ាងទៀត មេគោទាំងឡាយ ដែលឲ្យនូវទឹកដោះ ឈ្មោះថា **ធេនុបា** មេគោទាំងឡាយដែលផើម ឈ្មោះថា **គោធរណិយោ** មេគោទាំងឡាយ ដែលចម្រើនវ័យហើយ ប្រាថ្នាការសម្ព័ន្ធជាមួយគោបាទាំងឡាយ ឈ្មោះថា **បវេណិយោ** ។

ដោយពីរបទថា **ឧសភោបិ គវម្បតី** នាយធនិយៈរមែងសម្តែងថា ហ្វូងគោនោះដែលនាយគោបាលទាំងឡាយ លាងទឹកអំពីព្រលឹម ឲ្យស៊ីស្មៅហើយ ឲ្យនូវគ្រឿងលាប ៥ កន្លែង ពាក់នូវកម្រងផ្កាហើយ ក៏បញ្ជូនទៅដោយពាក្យថា នែបា ចូរអ្នកទៅ ចូរឲ្យគោទាំងឡាយដល់នូវទីរកស៊ី រក្សាហើយចូរនាំមក ឯគោមេហ្វូងនោះ ដែលនាយគោបាលទាំងឡាយបញ្ជូនទៅហើយយ៉ាងនេះ រក្សាគោទាំងឡាយមិនឲ្យទៅកាន់ទីអគោចរ ឲ្យត្រាច់ទៅក្នុងទីគោចរប្រជៀតគ្នាហើយ ចាកភ័យដែលកើតអំពីសត្វកាចទាំងឡាយ មានសីហៈនិងខ្លាធំជាដើម ហើយនាំមក មេហ្វូងគោបែបនេះ មាននៅក្នុងហ្វូងគោរបស់យើង ក្នុងផ្ទះរបស់យើងនេះ ។

កាលនាយធនិយៈពោលហើយយ៉ាងនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់ទូន្មានធនិយៈនោះយ៉ាងនោះ ទើបត្រាស់គាថាផ្ទុយគ្នាថា **នត្ថិ វសា** ជាដើម ។

ក្នុងគាថាទី ១០ នេះ មានអធិប្បាយដូចតទៅនេះ

ក្នុងសាសនារបស់តថាគតទាំងឡាយនេះ មិនមានបរិយុដ្ឋានកិលេស ពោលគឺ **វសា** ព្រោះអត្ថថា មិនទាន់បានហ្វឹក និងព្រោះអត្ថថា ជាគោជំហើយ ឬថា មិនមានអនុសយក្កិលេស ពោលគឺ **ធេនុបា** សំដៅយកកូនគោទាំងឡាយ ព្រោះអត្ថថា ជាទីមក ( មូល ) នៃគោជំទង់ទាំងឡាយ ឬសំដៅយកមេគោទឹកដោះទាំងឡាយ ព្រោះអត្ថថា ហូរចេញ ឬមិនមានបុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ និងអនេញ្ជាភិសង្ខារ ដែលប្រព្រឹត្តទៅជាមួយចេតនា ពោល គឺគោផើម ព្រោះអត្ថថា ទ្រទ្រង់នូវគភ៌ គឺបដិសន្ធិ ឬមិនមានតណ្ហាដែលជាសេចក្តីប្រាថ្នា ពោល គឺបវេណី ព្រោះអត្ថថា ប្រាថ្នាការប្រកប ឬមិនមានអភិសង្ខារវិញ្ញាណ ពោល គឺគោមេហ្វូង ព្រោះអត្ថថា ជាធំ ព្រោះអត្ថថា ដល់មុន ព្រោះអត្ថថា ចម្រើនបំផុត តថាគតនោះ ត្រេកអរហើយក្នុងការមិនមាន ដែលជាការក្សេមចាកយោគៈទាំងពួង តែអ្នកត្រេកអរហើយក្នុងភាពដែលជាទីតាំងនៃទុក្ខ មានសេចក្តីសោកជាដើម ព្រោះហេតុនោះ ការពោលរបស់តថាគត ដែលត្រេកអរហើយ ក្នុងការក្សេមចាកយោគៈទាំងពួងនេះថា នៃភ្លៀង កាលបើយ៉ាងនេះ បើអ្នកប្រាថ្នា ក៏ចូរធ្លាក់មកចុះ ទើបត្រឹមត្រូវហើយ ។

នាយធនិយៈស្តាប់ពុទ្ធភាសិតនោះហើយ ប្រាថ្នានឹងចូលដល់អមតរស

នៃសុភាសិតឲ្យក្រៃលែងជាងនោះ កាលនឹងសម្តែងសម្បត្តិ គឺហ្វូងគោរបស់ខ្លួនត្រង់បង្គោល ទើបពោលថា **ខីលា និខាតា** ជាដើម ។

សសរសម្រាប់ចងគោ ឈ្មោះថា **ខីលា** ។ បទថា **និខាតា** បានដល់ដែលគេបោះចូលក្នុងផែនដី ជាសសរតូច ឬធំ ដែលគេកប់ហើយ ។

បទថា **អសម្បវេធី** គឺមិនញាប់ញ័រ ។ ខ្សែសម្រាប់ចងពិសេស ដែលប្រកបដោយប្រហោក និងចេ្បាះ ដែលគេធ្វើហើយ ឈ្មោះថា **ទាមា** ។

បទថា **មុញ្ជមយា** បានដល់ ធ្វើដោយស្មៅយាប្លង ។ បទថា **នវា** បានដល់ ធ្វើហើយមិនយូរ គឺថ្មីៗ ។

បទថា **សុសណ្ឋានា** បានដល់ មានសណ្ឋានល្អ គឺណែនល្អ បានដល់មានលក្ខណៈល្អ ។ បទថា **ន ហិ សក្ខិន្តិ** បានដល់ នឹងមិនអាចឡើយ ។ បទថា **ធេនុបាបិ ឆេត្តុំ** សេចក្តីថា គោជំទង់ទាំងឡាយក៏មិនអាចទាញឲ្យដាច់បានឡើយ ។

កាលនាយធនិយៈពោលយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបកាលជាទីចាស់ក្លានៃឥន្ទ្រិយរបស់នាយធនិយៈ កាលទ្រង់ទូន្មានដោយន័យមុននោះឯង ទើបត្រាស់គាថាដែលសម្តែងសច្ចៈ ៤ ប្រការថា **ឧសភោរិវ ឆេត្វា** ជាដើម ។

បាគោ គឺគោដែលនាំហ្វូង បានដល់ គោឈ្មោលដែលជាមេហ្វូង ឈ្មោះថា **គោឧសភ** ក្នុងគាថានោះ ។

តែអាចារ្យពួកខ្លះពោលថា គោដែលជាធំក្នុងហ្វូងគោ ១០០ ឈ្មោះថា **គោឧសភ** គោដែលជាធំក្នុងហ្វូងគោមួយពាន់ ឈ្មោះថា **គោវសភ** គោដែលជាធំក្នុងហ្វូងគោមួយសែន ឈ្មោះថា **គោនិសភ** ។ អាចារ្យមួយពួកទៀតពោលថា គោដែលជាធំក្នុងគាមក្ខេត្តមួយ ឈ្មោះថា **គោឧសភ** គោដែលជាធំក្នុងគាមក្ខេត្តពីរ ឈ្មោះថា **គោវសភ** គោដែលមិនជ្រៀតបៀតគ្នាក្នុងគាមក្ខេត្តទាំងពួង ឈ្មោះថា **គោនិសភ** គោទាំងអស់ជាធម៌គ្រឿងឃឹតយូរ ។

ម្យ៉ាងទៀត គោទាំងអស់នេះគប្បីជ្រាបថា គោឧសភៈខ្លះ គោវសភៈខ្លះ គោនិសភៈខ្លះ គប្បីជ្រាបអត្ថថា មិនប៉ុនគ្នា ដូចទេវតាពោលក្នុងទេវតា-សំយុត្តថា យីអើ ព្រះសមណគោតម ជានិសភៈមែនហ្ន៎ជាដើម ។

រ អក្ខរៈ ក្នុងពាក្យថា **ឧសភោរិវ** ជាការភ្ជាប់បទ ។ បទថា **ពន្ធនានិ** បានដល់ គ្រឿងចង គឺខ្សែ និងគ្រឿងចង គឺកិលេស ។ ដំរីឈ្មោះថា **នាគ**។ បទថា **បូតិលតំ** បានដល់ វល្លិ៍ផោម កាយ សូម្បីមានពណ៌ដូចមាស លោកក៏ហៅថា **បូតិកាយោ** ។ ឆ្កែ ទោះបីមានអាយុ ១០០ ឆ្នាំ ក៏លោកហៅថា **កុក្កុរ** គឺកូនឆ្កែ ។ ឆ្កែចចក សូម្បីកើតក្នុងថ្ងៃនោះ លោកក៏ហៅថា **ជរសិគាល** គឺចចកចាស់ យ៉ាងណា វល្លិ៍ផោម សូម្បីនៅស្រស់ ក៏លោកហៅថា **បូតិលតា** គឺវល្លិស្អុយ ព្រោះអត្ថថា មិនមានខ្លឹម ដូច្នោះ ។

បទថា **ទាលយិត្វា** បានដល់ កាត់ហើយ ។ គតិនោះផង ជាទីដេកផង

ឈ្មោះថា **គព្ភសេយ្យំ** ក្នុងពាក្យថា **គព្ភសេយ្យំ** នោះ ។ ជលាពុជកំណើត គប្បីជ្រាបថា លោកពោលដោយ **គព្ភ** សព្ទ កំណើតដ៏សេស គប្បីជ្រាបថា លោកពោលដោយ **សេយ្យ** សព្ទ ។ម្យ៉ាងទៀត កំណើតទាំងនោះ គប្បីជ្រាបថា លោកពោលដោយលើកយក **គព្ភ** សព្ទ មកជាប្រធាន ។

ពាក្យដ៏សេសក្នុងគាថាទី ១២ នេះ បើពោលដោយអត្ថហើយ ក៏យល់បានងាយទាំងអស់ ។

តែក្នុងគាថាទី ១២ នេះ មានពាក្យអធិប្បាយដូចតទៅនេះ

ព្រះដ៏មានព្រះភាគ កាលត្រាស់ថា ម្នាលធនិយៈ អ្នកត្រេកអរដោយចំណង តែតថាគតមិនត្រេកអរដោយចំណង ទើបកាត់សំយោជនៈខាងលើ ៥ ដោយសេចក្ដីព្យាយាមដ៏មានកម្លាំង ពោល គឺអរិយមគ្គទី ៤ ប្រៀបដូចគោឧសភៈធំ ដែលសម្បូរដោយកម្លាំង និងសេចក្ដីព្យាយាម រលាស់នូវខ្សែទាំងឡាយចេញបាន ដូច្នោះ ( តថាគត ) ទម្លាយសំយោជនៈខាងក្រោម ៥ ចេញបានដោយសេចក្ដីព្យាយាមដ៏មានកម្លាំង ពោល គឺអរិយមគ្គខាងក្រោម ៣ ប្រការ ដូចដំរីទម្លាយវល្លិផោមឲ្យដាច់ ហើយទៅ ដូច្នោះ ។

ម្យ៉ាងទៀត តថាគតកាត់ គឺទម្លាយនូវអនុស័យបាន ដូចគោឧសភៈទម្លាយនូវខ្សែបាន ដូច្នោះ តថាគតកាត់ គឺទម្លាយនូវបរិយុដ្ឋានកិលេសចេញបាន ដូចដំរីទម្លាយវល្លិផោម ដូច្នោះ ទើបតថាគតមិនចូលដល់គភ៌ ដែលសត្វគប្បីដេកទៀត តថាគតនោះផុតហើយចាកទុក្ខទាំងពួង ដែលជាទីតាំងនៃជាតិ

ទុក្ខ ទើបសប្បាយ នៃភ្លៀង កាលបើដូច្នេះ បើអ្នកប្រាថ្នានឹងធ្លាក់ ក៏ចូរបង្អុរមកចុះ ព្រោះដូច្នោះ ទើបទ្រង់ត្រាស់ថា បើអ្នកត្រូវការប្រព្រឹត្តឲ្យដូចតថាគត គប្បីកាត់នូវចំណងទាំងឡាយចេញ ។

ក្នុងគាថាទី ១២ នេះ គ្រឿងចងទាំងឡាយ ចាត់ជា សមុទយសច្ច ការដេកក្នុងគភ៌ ចាត់ជា ទុក្ខសច្ច ។

ការមិនចូលដល់ក្នុងពាក្យថា **ន ឧបេស្សំ** នេះ ចាត់ជានិរោធសច្ច ដោយអំណាចនៃឧបាទិសេសនិព្វាន ។ ការកាត់ក្នុងពាក្យថា **ឆេត្វា ទាល-យិត្វា** នេះ ចាត់ជានិរោធសច្ច ដោយអំណាចឧបាទិសេសនិព្វាន គ្រឿងកាត់ និងគ្រឿងទម្លាយ ចាត់ជា មគ្គសច្ច ។

ក្នុងទីបំផុតនៃព្រះគាថា ជនទាំង ៤ គឺធនិយៈ ១ ភរិយា ១ កូនស្រី ២ នាក់ បានស្តាប់គាថា ដែលសម្តែងសច្ចៈ ៤ ប្រការនេះ យ៉ាងនេះហើយ ក៏តាំងនៅក្នុងសោតាបត្តិផល ។ លំដាប់នោះ ធនិយៈឃើញហើយនូវធម្មកាយរបស់ព្រះដ៏មានព្រះភាគដោយបញ្ញាចក្ខុ ដោយសទ្ធាដែលតាំងមាំ ដែលកើតឡើងហើយក្នុងព្រះដ៏មានព្រះភាគជាមូល ដោយការជ្រះថ្លាដែលមិនប្រែប្រួល ជាអ្នកមានហទយៈដែលមានធម្មកាយជាស់តឿនហើយ គិតហើយថា តាំងអំពីអវីចីជាទីបំផុត រហូតដល់ភវគ្គព្រហ្ម វៀរព្រះដ៏មានព្រះភាគ អ្នកដទៃណានឹងបន្លឺសីហនាទដ៏មានកម្លាំងដូច្នេះបាន ព្រះសាស្តារបស់អញ យាងមកហើយហ្ន៎ ដោយការត្រិះរិះថា តថាគតកាត់នូវគ្រឿងចងបានហើយ ការដេក

ក្នុងគភ៌របស់តថាគតមិនមាន ។

បន្ទាប់អំពីនោះ ព្រះដ៏មានព្រះភាគ ទ្រង់បានបញ្ចេញរស្មីនៃព្រះវរកាយ ដែលហាក់បីដូចជាពន្លឺ ដែលស្រោចដោយទឹកមាស លម្អទៅដោយសំណាញ់ ឆព្វណ្ណរង្សី ចូលទៅក្នុងផ្ទះរបស់នាយធនិយៈដោយបំណងថា ឥឡូវនេះ ចូរអ្នកមើលតាមសប្បាយ ។ កាលនោះ ធនិយៈឃើញផ្ទះរបស់ខ្លួនរុងរឿងដោយជុំវិញ បីដូចពន្លឺព្រះចន្ទ និងពន្លឺព្រះអាទិត្យជះចូលទៅខាងក្នុងផ្ទះ ហាក់បីដូចបំភ្លឺដោយប្រទីបមួយពាន់ ដែលឆេះសន្ធោសន្ធៅដោយជុំវិញដូច្នោះ ទើបកើតគំនិតឡើងថា ព្រះដ៏មានព្រះភាគយាងមកហើយ ។

កាលនោះឯង ភ្លៀងក៏ធ្លាក់ចុះ ព្រោះហេតុនោះ ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលថា ភ្លៀងបានធ្លាក់ចុះពេញទាំងទីទាប និងទីទួល ។

បណ្តាបទទាំងនោះ បទថា **និន្នំ** បានដល់ ដែលជាភក់ ។ បទថា **ថលំ** បានដល់ ទីទួល ។ មានពាក្យអធិប្បាយថា ភ្លៀង កាលធ្វើទីទួល និងទីដែលមិនមែនទួលឲ្យពេញស្មើគ្នាទាំងអស់ ធ្លាក់ចុះមកហើយ ។

បទថា **តាវទេវ** សេចក្តីថា ក្នុងខណៈណាព្រះដ៏មានព្រះភាគ ទ្រង់បញ្ចេញរស្មី នាយធនិយៈបញ្ចេញនូវរស្មីនៃចិត្ត ដែលសម្រេចដោយសទ្ធាទៅដោយគិតថា ព្រះសាស្តារបស់អញយាងមកហើយ ខណៈនោះ ភ្លៀងក៏ស្រក់ចុះមក ។ តែអាចារ្យពួកខ្លះពណ៌នាថា ព្រះអាទិត្យបានប្រាកដឡើងក្នុងខណៈនោះដូចគ្នា ។

ក្នុងខណៈដែលនាយធនិយៈពោលពាក្យ ក្នុងខណៈដែលព្រះតថាគតផ្សាយឱកាសទៅ និងក្នុងខណៈដែលព្រះអាទិត្យកំពុងរះឡើងយ៉ាងនេះ នាយធនិយៈស្ដាប់សំឡេងភ្លៀងដែលកំពុងធ្លាក់ ក៏កើតបីតិសោមនស្សឡើង បានក្រាបទូលសេចក្ដីនោះថា ជាលាភរបស់ខ្ញុំព្រះអង្គទាំងឡាយមិនមែនតិចដូច្នោះ ទើបជា ២ គាថា ។

ក្នុង ២ គាថានោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅថា

ព្រោះហេតុដែលនាយធនិយៈ មួយអន្លើដោយបុត្រ និងភរិយាបានឃើញធម្មកាយរបស់ព្រះដ៏មានព្រះភាគ ដោយការបាក់ធ្លុះអរិយមគ្គ ឃើញរូបកាយរបស់ព្រះអង្គ ដោយលោកុត្តរចក្ខុ និងត្រឡប់បាននូវសទ្ធា ដែលជាលោកិយ-សទ្ធា ដូច្នោះ ទើបពោលថា ជាលាភរបស់ខ្ញុំព្រះអង្គមិនមែនតិចហ្ន៎ ដែលខ្ញុំព្រះអង្គបានឃើញព្រះដ៏មានព្រះភាគ ។

បទថា **វត** ក្នុងបទថា **លាភាវត នោ អនប្បកា** នោះ ជានិបាតប្រើក្នុងអត្ថថា ត្រេកអរ ។

បទថា **នោ** គឺខ្ញុំព្រះអង្គទាំងឡាយ ។ បទថា **អនប្បកា** បានដល់ច្រើន ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

ចំណែកក្នុងបទថា **សរណំ តំ ឧបេម** នេះ មានវិនិច្ឆ័យដូច្នេះ ការដល់នូវសរណៈរបស់នាយធនិយៈនោះ សម្រេចហើយ ដោយការត្រាស់ដឹងនូវមគ្គនោះឯងក៏ពិត តែក្នុងពាក្យនោះ នាយធនិយៈនោះ ដល់នូវការយល់ព្រម

នោះឯង ឥឡូវនេះ គាត់ធ្វើការប្រគល់កាយ ថ្វាយខ្លួនដោយវាចា ម្យ៉ាងទៀត ធនិយៈ កាលធ្វើទីពឹង ដោយការប្រគល់ខ្លួនឲ្យប្រាកដដោយអំណាចនៃមគ្គនិង ធ្វើសរណៈ ដែលមិនញាប់ញ័រនោះ ឲ្យប្រាកដដោយវាចាដល់មនុស្សដទៃ ទើបដល់នូវសរណគមន៍ ដោយការបង្អោនដោយដៃទៀត ។

បទថា **ចក្ខុមា** សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **ចក្ខុមា** ព្រោះប្រកបដោយចក្ខុ ៥ គឺមំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុ ១ សមន្តចក្ខុ ១ ពុទ្ធចក្ខុ ១ ។

នាយធនិយៈ កាលក្រាបទូលព្រះដ៏មានព្រះភាគ ទើបក្រាបទូលថា បពិត្រព្រះអង្គមានចក្ខុ ខ្ញុំព្រះអង្គសូមដល់ព្រះអង្គជាទីពឹង ។

ចំណែកបទថា **សត្ថា នោ ហោហិ មហាមុនិ** ធនិយៈទូល ដើម្បីធ្វើ សរណគមន៍ឲ្យបរិបូណ៌ ដោយការចូលដល់ភាពជាសិស្ស ។

បទថា **គោបី ច អហញ្ច អស្សវា ព្រហ្មចរិយំ សុគតេ ចរាមសេ** នេះ នាយធនិយៈធ្វើសរណគមន៍ឲ្យបរិបូណ៌ដោយអំណាចនៃការសមាទាន ។

បណ្តាបទទាំងនោះ បទថា **ព្រហ្មចរិយំ** ជាឈ្មោះនៃមេថុនវិរតិ មគ្គ សមណធម៌ សាសនា និងសទារសន្តោសៈ ។

មេថុនវិរតិ ឈ្មោះថា **ព្រហ្មចរិយ** ដូចក្នុងប្រយោគជាដើមថា **ព្រហ្មចារី** ប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ដូច្នេះ ។

ព្រហ្មចរិយៈ មកក្នុងអត្ថថា មគ្គ ដូចក្នុងប្រយោគជាដើមថា ម្នាល

បញ្ចសិខ: ព្រហ្មចរិយធម៌របស់តថាគតនេះឯង ទើបប្រព្រឹត្តទៅ ដើម្បីនឿយណាយ ដើម្បីប្រាសចាករាគ: ដើម្បីរម្ងាត់ ( កិលេស ) ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វានតែមួយយ៉ាង ។បេ។ គឺអរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ។

ព្រហ្មចរិយ:មកក្នុងអត្ថថា សមណធម៌ ដូចក្នុងប្រយោគជាដើមថា ម្នាលសារីបុត្ត មួយទៀត តថាគតធ្លាប់ប្រព្រឹត្តព្រហ្មចរិយ: ដែលប្រកបដោយអង្គ ៤ ។

ព្រហ្មចរិយ: មកក្នុងអត្ថថា សាសនា ដូចក្នុងប្រយោគជាដើមថា ព្រហ្មចរិយធម៌ ( គឺសាសនា ) របស់តថាគតក៏មាំមួន ផ្សាយទូលាយទៅ ។

ព្រហ្មចរិយ: មកក្នុងអត្ថថា សទារសន្តោស ដូចក្នុងប្រយោគជាដើមថា ពួកយើងមិនប្រព្រឹត្តក្រៅចិត្តភរិយាទេ ទាំងពួកភរិយា ក៏មិនប្រព្រឹត្តកន្លងចិត្តយើង ពួកយើងប្រព្រឹត្តនូវព្រហ្មចរិយធម៌ លើកលែងតែភរិយាទាំងនោះចេញ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង ( ក្នុងត្រកូល ) របស់ពួកយើងមិនស្លាប់ ដូច្នេះ ។

ក្នុងគាថានេះ ធនិយ:សំដៅដល់ព្រហ្មចរិយ: គឺមគ្គខាងលើ ៣ ប្រការ ដែលមានព្រហ្មចរិយ: គឺសមណធម៌ជាប្រធាន ។

បទថា **សុគតេ** បានដល់ ក្នុងសម្នាក់របស់ព្រះសុគត ព្រោះថា ព្រះដ៏មានព្រះភាគ លោកហៅថា **សុគត** ព្រោះទ្រង់យាងទៅដោយល្អ មិនចូល

*ដល់អន្តធម៌ ២ យ៉ាង ព្រោះទ្រង់ប្រកបដោយការសម្រេចអរិយមគ្គដ៏ល្អ និង ព្រោះព្រះអង្គទ្រង់សម្រេចដល់ស្ថានទី ពោល គឺព្រះនិព្វានដ៏ប្រសើរ ។*

*បទថា* **សុគតេ** *នេះ ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថថា ជិត ព្រោះ អធិប្បាយថា ក្នុងសម្នាក់ព្រះសុគត ។*

*បទថា* **ចរាមសេ** *សេចក្តីថា ពួកយើងរមែងប្រព្រឹត្តព្រហ្មចរិយៈ ក្នុង ព្រះសុគតណា អ្នកក៏ចូរប្រព្រឹត្តព្រហ្មចរិយៈនោះ ក្នុងព្រះសុគតនោះ ព្រោះ ហេតុនោះ ទើបធនិយៈពោលការប្រព្រឹត្តិព្រហ្មចរិយៈនោះ ក្នុងព្រះសុគតនេះ ថា* **ចរាមសេ ។**

*តែព្រះអដ្ឋកថាចារ្យពោលថា ពាក្យថា* **សេ** *ជានិបាត ព្រោះថា ពាក្យ ថា* **សេ** *នោះឯង ក្នុងទីនេះ អាចារ្យទាំងឡាយឲ្យនូវពាក្យកំណត់ព្រះបាលីថា* **ចរាមសេ** *សំដៅដល់ការអង្វរ អ្នកគាប់ចិត្តពាក្យណា ក៏គប្បីកាន់យកពាក្យ នោះ ។*

*នាយធនិយៈទូលសូមបព្វជ្ជានឹងព្រះដ៏មានព្រះភាគ ដោយការអាងដល់ ការប្រព្រឹត្តិព្រហ្មចរិយៈយ៉ាងនេះ កាលសម្តែងប្រយោជន៍នៃបព្វជ្ជា ទើបទូល ថា ខ្ញុំព្រះអង្គទាំងឡាយ ជាអ្នកដល់នូវត្រើយនៃជាតិ និងមរណៈ ជាអ្នកធ្វើ ទីបំផុតនៃទុក្ខបាន ។*

*ព្រះនិព្វាន ឈ្មោះថា ត្រើយនៃការកើត និងការស្លាប់ ពួកយើងនឹង ដល់ព្រះនិព្វាននោះ ដោយអរហត្តមគ្គ ។*

បទថា **ឧក្ខស្ស** បានដល់ ទុក្ខក្ខន្ធវដ្ដៈ ។ បទថា **អន្តករា** បានដល់ ធ្វើនូវការមិនមាន ។

បទថា **ភវាមសេ** បានដល់ រមែងជា ។ មួយាងទៀត អធិប្បាយថា ឱហ្ន៍ ពួកយើងគប្បីជា ( អ្នកដល់ទីបំផុតនៃទុក្ខ ) ដូច្នោះ អ្នកសិក្សាគប្បីជ្រាបពាក្យនោះបានដោយន័យដែលខ្ញុំពោលហើយ ក្នុងពាក្យថា **ចរាមសេ** នេះ ។

បានឮថា ជនទាំងពីរ គឺស្វាមី និងភរិយា កាលពោលយ៉ាងនេះហើយ ទើបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយទូលសូមបព្វជ្ជាយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ សូមទ្រង់ឲ្យយើងខ្ញុំទាំងពីរបព្វជ្ជាចុះ ។

កាលណោះ មារមានចិត្តបាប ឃើញជនទាំងពីរ គឺស្វាមី និងភរិយា នោះថ្វាយបង្គំហើយ ក្រាបទូលសូមបព្វជ្ជា គិតថា ស្វាមីភរិយាទាំងពីរនេះ ត្រូវការផុតអំណាចរបស់អញ ណ្ហើយចុះ ឥឡូវនេះ អញនឹងធ្វើអន្តរាយដល់គេទាំងពីរនោះ ដូច្នេះហើយ កាលនឹងសម្ដែងគុណក្នុងការគ្រប់គ្រងផ្ទះ ទើបពោលគាថានេះថា **នន្ទតិ បុត្តេហិ បុត្តិមា** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **នន្ទតិ** បានដល់ ត្រេកអរ គឺរីករាយ ។ បទថា **បុត្តេហិ** បានដល់ កូនប្រុសកូនស្រីទាំងឡាយ ។ ពាក្យថា **បុត្តេហិ** នោះ ជាតតិយាវិភត្តិ ប្រើក្នុងអត្ថថា ជាមួយ ឬប្រើក្នុងអត្ថថា ជាហេតុ មានពាក្យអធិប្បាយថា ត្រេកអរនឹងបុត្រទាំងឡាយ ឬត្រេកអរដោយបុត្រទាំង-

ឡាយ ដែលជាហេតុ ( ឲ្យត្រេកអរ ) ។

បុគ្គលដែលមានកូន ឈ្មោះថា **បុត្តិមា** លោកពោលយ៉ាងនេះដោយ **ឥតិ** សព្ទ ។

ទេវបុត្រដែលទ្រទ្រង់នូវម្កុដផ្កា អង្គណាមួយអង្គ ក្នុងស្ថានសួគ៌ ជាន់វសវត្តិភូមិ ឈ្មោះថា **មារ** ។

មារនោះរមែងធ្វើជនណា ដែលអាចឈានកន្លងឋាន:នោះ រមែងហាមជននោះបាន តែបើជនណាមិនអាចហាមបាន មារនោះក៏ប្រារព្ធនាំនូវការស្លាប់ដល់ជននោះ ព្រោះដូច្នោះ ទើបលោកពោលថា **មារ** ។

បទថា **ធាបិមា** បានដល់ មនុស្សអាក្រក់ ឬមនុស្សមានការប្រព្រឹត្តិអាក្រក់ ពាក្យថា **ធាបិមា** នេះ ជាពាក្យរបស់ព្រះសង្គីតិកាចារ្យទាំងឡាយ ។

ក្នុងគាថាទាំងពួង ពាក្យដ៏សេសក៏ដូច្នេះដូចគ្នា អធិប្បាយថា បុគ្គលមានកូន ត្រេកអរដោយកូនទាំងឡាយ យ៉ាងណា បុគ្គលមានគោ ក៏ត្រេកអរដោយគោទាំងឡាយយ៉ាងនោះ គឺបុគ្គលណាមានគោ បុគ្គលនោះក៏មានគោជាទីស្រឡាញ់ គឺបុគ្គលនោះ រមែងត្រេកអរនឹងគោទាំងនោះ ឬរមែងត្រេកអរដោយគោទាំងឡាយ ដែលជាហេតុឲ្យត្រេកអរនោះដូចគ្នា ។

មារកាលពោលយ៉ាងនេះ ឥឡូវនេះ រមែងអាងដល់ហេតុដែលធ្វើឲ្យប្រយោជន៍នោះសម្រេច ទើបពោលថា **ឧបធីហិ នរស្ស ននុធា** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **ឧបធិ** បានដល់ ឧបធិ ៤ គឺកាមូបធិ ១

ខន្ធូបធិ ១ កិលេសូបធិ ១ អភិសង្ខារូបធិ ១ ។

ពិតហើយ កាមទាំងឡាយ លោកហៅថា **ឧបធិ** ព្រោះអត្ថនៃពាក្យនេះថា **សុខ** ក្នុងអត្ថនេះ ដែលបុគ្គលរមែងចូលទៅតាំងទុក ព្រោះជាទីតាំងនៃសុខ ដែលព្រះដ៏មានព្រះភាគត្រាស់ក្នុងមហាទុក្ខក្ខន្ធសូត្រថា

ម្នាលភិក្ខុទាំងឡាយ សេចក្ដីសុខសោមនស្ស កើតឡើងព្រោះអាស្រ័យកាមគុណទាំង ៥ ប្រការនេះ នេះឯង ជាតម្រេករបស់កាមទាំងឡាយ ដូច្នេះ ។

ខន្ធទាំងឡាយ លោកហៅថា **ឧបធិ** ព្រោះជាទីតាំងនៃទុក្ខ ដែលមានខន្ធជាមូល ។ សូម្បីកិលេសទាំងឡាយ លោកក៏ហៅថា **ឧបធិ** ព្រោះជាទីតាំងនៃទុក្ខក្នុងអបាយ ។ អភិសង្ខារទាំងឡាយ លោកក៏ហៅថា **ឧបធិ** ព្រោះជាទីតាំងនៃទុក្ខក្នុងភព ។

តែក្នុងទីនេះ លោកបំណងយកកាមូបធិ កាមូបធិនោះ មាន ២ យ៉ាង ដោយអំណាចសត្វ និងសង្ខារ ។

ក្នុងឧបធិទាំង ២ យ៉ាងនោះ នឹងពោលដល់ឧបធិដែលទាក់ទងដោយសត្វមុន មារកាលសម្ដែងដល់ឧបធិដែលទាក់ទងដោយសត្វ ទើបពោលថា **បុត្តេហិ គោហិ** ជាដើមហើយ ទើបពោលដល់ហេតុរបស់ឧបធិថា **ឧបធីហិ នរស្ស នន្ទនា** ជាដើម ។

អត្ថនៃគាថានោះថា ព្រោះកាមូបធិទាំងនេះ នាំនូវបីតិ និងសោមនស្ស

*មកឲ្យ ទើបធ្វើឲ្យបុគ្គលត្រេកត្រអាល ព្រោះហេតុនោះ គប្បីជ្រាបពាក្យនេះថា បុគ្គលមានកូន រមែងត្រេកអរដោយកូនទាំងឡាយ បុគ្គលមានគោ រមែងត្រេកអរដោយគោទាំងឡាយដូចគ្នា ខ្លួនអ្នកក៏មានកូន និងមានគោ ព្រោះហេតុនោះ ចូរអ្នកត្រេកអរដោយគោ និងកូនទាំងនោះ កុំត្រឡប់ទៅកាន់បព្វជ្ជាឡើយ ព្រោះការត្រេកអរទាំងនេះ រមែងមិនមានដល់អ្នកបួស កាលបើដូច្នេះ សូម្បីអ្នកប្រាថ្នាផុតទុក្ខ តែក៏ត្រឡប់មានសេចក្ដីទុក្ខ ។ ក្នុងឥឡូវនេះមាររមែងអាងដល់ហេតុដែលធ្វើឲ្យសម្រេចប្រយោជន៍នោះថា* **ន ហិ សោ នន្ទតិ យោ និរុបធិ** *ជាដើម ។ អត្ថនៃគាថានោះថា ព្រោះបុគ្គលណាមិនមានឧបធិទាំងនេះ បុគ្គលនោះ ព្រាត់ប្រាសចាកញាតិទាំងឡាយ ដែលជាទីស្រឡាញ់ មិនមានឧបករណ៍ជាគ្រឿងប្រើប្រាស់ រមែងមិនត្រេកអរ ដូច្នោះខ្លួនអ្នកវៀរឧបធិទាំងនេះចេញ បួសហើយ នឹងបានទទួលទុក្ខ ។*

*កាលនោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា មារមានចិត្តបាបមកហើយដើម្បីធ្វើអន្តរាយដល់ជនទាំងនេះ កាលទ្រង់ទម្លាយនូវវាទៈរបស់មារ ដោយឧបមាដែលមារនាំមកនោះឯង ប្រៀបធៀបដូចបុគ្គលដែលធ្វើផ្លែឈើឲ្យធ្លាក់ដោយផ្លែឈើដូច្នោះ ទើបទ្រង់ត្រឡប់គាថានោះឯង ទ្រង់សម្ដែងថា ឧបធិជាទីតាំងនៃសេចក្ដីសោក ទើបត្រាស់ថា* **សោចតិ បុត្តេហិ** *ជាដើម ។*

*បទទាំងពួងក្នុងគាថានោះ បើពោលដោយបទហើយ ក៏យល់បានងាយទាំងអស់ តែមានពាក្យអធិប្បាយតទៅដូច្នេះ ម្នាលមារមានចិត្តបាប អ្នកកុំ*

ពោលយ៉ាងនេះថា បុគ្គលមានបុត្ត រមែងត្រេកអរដោយបុត្តទាំងឡាយ ដ្បិតថា ការព្រាត់ប្រាស ការវៀរចាករបស់ជាទីស្រឡាញ់ពេញចិត្តទាំងអស់នោះឯង រមែងមាន វិធីនេះ បុគ្គលមិនអាចចៀសផុតបាន ព្រោះថា សត្វទាំង-ឡាយមានហទយៈដែលត្រូវព្រួញ ពោល គឺសេចក្តីសោក មានប្រមាណក្រៃលែងចាក់ទម្លុះហើយ ព្រោះត្រូវព្រាត់ប្រាសចាកបុត្ត និងភរិយាដែលជាទីពេញចិត្តទាំងនោះ និងចាកសត្វ និងទ្រព្យទាំងឡាយ មានគោ សេះឈ្មោល សេះញី ប្រាក់ និងមាសជាដើម ហើយឆ្កួតទៅក៏មាន មានចិត្តរាយមាយទៅ ដល់នូវការស្លាប់ក៏មាន បានទទួលទុក្ខស្មើស្លាប់ក៏មាន ព្រោះហេតុនោះឯង បុគ្គលមានបុត្ត ទើបសោយសោកព្រោះបុត្ត ដោយអំណាចតណ្ហា បុគ្គលរមែងសោកស្តាយព្រោះឧបធិទាំងឡាយ ដូចបុគ្គលមានកូនសោយសោកព្រោះកូនទាំងឡាយ បុគ្គលមានគោ រមែងសោយសោកព្រោះគោទាំងឡាយ ដូច្នោះ ព្រោះហេតុអ្វី ព្រោះបុគ្គលរមែងសោយសោក ព្រោះឧបធិទាំងឡាយ ព្រោះបុគ្គលសោយសោកដោយឧបធិទាំងឡាយ ដូច្នោះនោះឯង បុគ្គលណាមិនមានឧបធិ បុគ្គលនោះ រមែងមិនសោយសោកឡើយ បុគ្គលណា ឈ្មោះថា មិនមានឧបធិ ព្រោះលះនូវការជាប់ជំពាក់ក្នុងឧបធិបាន បុគ្គលនោះ រមែងមានសេចក្តីសន្តោសដោយចីវរៈ ដែលជាគ្រឿងបរិហារកាយ ដោយបិណ្ឌបាត ដែលជាគ្រឿងបរិហារផ្ទៃ នឹងប្រព្រឹត្តដោយវិធីណាមួយ ក៏កាន់យកការសន្តោសប៉ុណ្ណោះប្រព្រឹត្តទៅ ប្រៀបដូចបក្សីមានតែ

បក្សី ។ បេ ។ រមែងជ្រាបបានថា វត្ថុដទៃដើម្បីភាពយ៉ាងនេះ មិនមាន ។ ព្រោះសម្លាប់នូវសេចក្តីសោកបានយ៉ាងនេះ បុគ្គលណា មិនមានឧបធិបុគ្គលនោះ មិនសោយសោក ។

ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យទេសនាចប់ដោយកំពូល គឺអរហត្តយ៉ាងនេះម្យ៉ាងទៀត បុគ្គលណាមិនមានឧបធិ បុគ្គលណាមិនមានកិលេស បុគ្គលនោះរមែងមិនសោកស្តាយ ព្រោះថា ដរាបណានៅមានកិលេស ឧបធិទាំងឡាយឬមូលនៃសេចក្តីសោកទាំងឡាយ ក៏រមែងមានដរាបនោះ ព្រោះលះនូវកិលេសទាំងឡាយចេញបាន សេចក្តីសោកក៏មិនមាន ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ឲ្យទេសនាចប់ដោយកំពូល គឺអរហត្តនោះឯង ដោយប្រការដូច្នេះ ។

ក្នុងទីបំផុតនៃទេសនា នាយធនិយៈ និងភរិយាបានបួសហើយ ។ ព្រះដ៏មានព្រះភាគ បានយាងទៅកាន់វត្តជេតពនតាមអាកាស ។ ជនទាំងពីរនោះកាលបួសហើយ បានធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ពួកគោបាលឲ្យសាងវិហារ ដើម្បីជនទាំងពីរនោះក្នុងទីដែលជាលំនៅ វិហារនោះនៅប្រាកដឈ្មោះថា គោបាលកវិហារ ដល់សព្វថ្ងៃនេះ ។៚

**ធនិយសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ខគ្គវិសាណសូត្រ ទី ៣

[ ៣ ] បុគ្គលដាក់អាជ្ញាចោលចេញ ចំពោះពួកសត្វទាំងអស់ មិនបានបៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយ មិនគប្បីប្រាថ្នានូវបុត្ត តើគប្បីត្រូវការសម្លាញ់អំពីណា គប្បីត្រាច់ទៅតែម្នាកឯង ដូចកុយរមាស ។

សេចក្ដីស្រឡាញ់ រមែងមានដល់បុគ្គល ដែលច្រឡូកច្រឡំ ទុក្ខដែលជាប់តាមចំពោះសេចក្ដីស្រឡាញ់នេះ ក៏រមែងកើតឡើង បុគ្គលឃើញទោសដែលកើតអំពីសេចក្ដីស្រឡាញ់ហើយ គប្បីត្រាច់ទៅតែម្នាក់ឯងដូចកុយរមាស ។

បុគ្គលអ្នកមានចិត្តប្រតិព័ទ្ធ កាលអនុគ្រោះនូវពួកមិត្ត ដែលមានចិត្តល្អ រមែងញ៉ាំងប្រយោជន៍ឲ្យសាបសូន្យ បុគ្គលកាលឃើញនូវភ័យក្នុងការមូលមិត្តគ្នាទុំះហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

សេចក្ដីស្រឡាញ់ចំពោះកូន និងប្រពន្ធ ដូចឫស្សីដែលបែកគុម្ព ចាក់កណ្ដាញ់ បុគ្គលកាលមិនជាប់ជំពាក់ ដូចជាទំពាំងឫស្សី គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

ម្រឹគក្នុងព្រៃ ជាសត្វមិនជាប់ចំណង ទៅរកចំណីតាមចំណង់ចិត្តបាន យ៉ាងណា វិញ្ញូជន កាលបើឃើញសេរីភាព ( យ៉ាង

នោះ ) គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

ការហៅរក រមែងមានដល់ជនស្ថិតនៅក្នុងកណ្តាលនៃសម្លាញ់ គឺការនៅ ការឈរ និងការត្រាច់ចារិក បុគ្គលកាលបើឃើញសេរីភាព ដែល ( ពួកជនពាល ) មិនប្រាថ្នា គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

ការលេង ការត្រេកអរក្នុង ( កាមគុណ ) រមែងមានដល់ជនស្ថិតនៅក្នុងកណ្តាលនៃសម្លាញ់ មួយទៀត សេចក្តីស្រឡាញ់ដ៏ធំទូលាយ រមែងមានក្នុងបុត្តទាំងឡាយ បុគ្គលកាលបើធុញទ្រាន់នឹងការព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលជាអ្នកនៅជាសុខក្នុងទិសទាំង ៤ មិនលំបាក ត្រេកអរដោយបរិក្ខារតាមមាន តាមបាន ជាអ្នកអត់ធន់ចំពោះអន្តរាយទាំងឡាយ ទាំងជាអ្នកមិនតក់ស្លុត គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បព្វជិតពួកខ្លះ ឬគ្រហស្ថអ្នកគ្រប់គ្រងផ្ទះ គេសង្គ្រោះបានដោយកម្រ បុគ្គលមិនមានសេចក្តីខ្វល់ខ្វាយចំពោះបុត្ត នៃបុគ្គលដទៃ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

ធីរបុរិសលះបង់នូវវត្ថុទាំងឡាយ ជាគ្រឿងប្រាកដនូវភាពជា

គ្រហស្ថ កាត់ចំណងរបស់គ្រហស្ថទាំងឡាយ ដូចជារលួសផ្អុង ជម្រុះស្លឹក គប្បីត្រាច់ទៅតែម្នាក់ឯងដូចកុយរមាស ។ បើបុគ្គល បានអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅដោយប្រពៃជាសម្លាញ់ មាន ប្រាជ្ញាខ្ជាប់ខ្ជួន ត្រាច់ទៅជាមួយគ្នា គ្របសង្កត់នូវសេចក្តីអន្តរាយ ទាំងពួងបាន គប្បីមានចិត្តត្រេកអរ មានស្មារតី ត្រាច់ទៅជា មួយសម្លាញ់នោះទៅចុះ ។

បើបុគ្គលរកអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅដោយប្រពៃ ជា សម្លាញ់ មានប្រាជ្ញាខ្ជាប់ខ្ជួនត្រាច់ទៅជាមួយគ្នាពុំបានទេ គប្បី ត្រាច់ទៅតែម្នាក់ឯង ដូចព្រះរាជាលះបង់នូវដែន ដែលព្រះអង្គ ឈ្នះហើយ ឬដូចដំរីឈ្មោះមាតង្គ លះបង់ហ្វូងត្រាច់ទៅ ក្នុងព្រៃ ។

តាមពិត យើងសរសើរនូវការបរិបូណ៌ដោយសម្លាញ់ហើយ តែ សម្លាញ់មានគុណប្រសើរជាង និងសម្លាញ់មានគុណស្មើ បុគ្គល គួរសេពគប់រាប់រក បើ ( កុលបុត្រចង់បានប្រយោជន៍ ) រក សម្លាញ់ទាំងនុ៎ះពុំបានទេ គប្បីជាអ្នកបរិភោគភោជន ដែលមិន មានទោស ហើយត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលឃើញនូវកងមាសទាំងពីរដ៏ភ្លឺផ្លេក ដែលជាងមាសធ្វើ សម្រេចហើយដោយល្អ រណ្តំគ្នាឰដ៏ដៃ គប្បីត្រាច់ទៅតែម្នាក់

ឯង ដូចកុយរមាស ។

ការចរចាដោយវាចាក្តី ការជាប់ចំពាក់ក្តី ជាមួយនឹងកុមារជាគម្រប់ពីរ មានដល់អញយ៉ាងនេះ បុគ្គលកាលបើឃើញនូវភ័យនុ៎ះ តទៅខាងមុខហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

ពិតណាស់ កាមទាំងឡាយដ៏វិចិត្រ មានរសផ្អែម ជាទីរីករាយនៃចិត្ត តែងញាំញីនូវចិត្ត ដោយសភាពដ៏ប្លែកៗ បុគ្គលឃើញទោសក្នុងកាមគុណទាំងឡាយហើយ គប្បីត្រាច់ទៅតែម្នាក់ឯងដូចកុយរមាស ។

ចង្រៃ បូស ឧបទ្រព រោគ កិលេសដូចសរ និងភ័យទាំងនុ៎ះរមែងមានដល់យើង ( ព្រោះកាម ) បុគ្គលកាលបើឃើញភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយហើយ គប្បីត្រាច់ទៅតែម្នាក់ឯងដូចកុយរមាស ។

បុគ្គលគ្របសង្កត់នូវសត្រូវទាំងអស់នុ៎ះ គឺត្រជាក់ ក្តៅ គម្លានសម្រេក ខ្យល់ និងកម្តៅថ្ងៃ របោម និងពស់ហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

ដំរីមានខ្លួន សមរម្យ មាំមួន មានសម្បុរដូចផ្កាឈូក កាលលះបង់នូវហ្វូង ហើយនៅក្នុងព្រៃ គួរដល់អធ្យាស្រ័យ យ៉ាងណា

បុគ្គលគប្បី ត្រាច់ទៅតែម្នាក់ឯងដូចកុយរមាស ( យ៉ាងនោះ ) ។

បុគ្គលបាននូវវិមុត្តិ ប្រព្រឹត្តទៅក្នុងសម័យ គឺលោកិយសមាបត្តិ ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំងនៃបុគ្គល អ្នកត្រេកអរក្នុងពួកទេ បុគ្គលពិចារណាពាក្យរបស់ព្រះពុទ្ធ ជាព្រះអាទិច្ចពន្ធុហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលកន្លងនូវទិដ្ឋិអាក្រក់ ដល់នូវធម៌ទៀង មានមគ្គបានហើយ មិនបាច់មានអ្នកដទៃដឹកនាំ ព្រោះដឹងថា អាត្មាអញ មានញាណកើតហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលមិនជាប់ចិត្តក្នុងអាហារ មិនកុហក មិនមានសេចក្ដីស្រេកឃ្លាន ជាអ្នកមិនលុបគុណគេ កម្ចាត់បង់មោហៈ ដូចជាទឹកចត់ចេញបាន មិនមានទីអាស្រ័យ ( គឺកិលេស ) ក្នុងលោកទាំងមូល គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលគប្បីវៀរនូវសម្លាញ់ដ៏អាក្រក់ ដែលបង្ហាញនូវអំពើមិនជាប្រយោជន៍ អាស្រ័យនៅក្នុងកម្មមិនស្មើ ( គឺទុច្ចរិត ) មិនគប្បីសេពគប់នូវសម្លាញ់ដែលជាប់ចំពាក់ ដែលស្រវឹង ( ក្នុងកាមគុណ ) ដោយខ្លួនឯង គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលគប្បីគប់រក នូវមិត្តជាពហុស្សូត ទ្រទ្រង់នូវធម៌ ប្រកប

ដោយកម្មដ៏ថ្លៃថ្នូរ មានប្រាជ្ញាវាងវៃ លុះដឹងច្បាស់នូវប្រយោជន៍ទាំងឡាយហើយ គប្បីបន្ទោបង់នូវសេចក្តីសង្ស័យចេញ ត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលមិនតាក់តែងនូវការលេងផង ការត្រេកអរផង កាមសុខផង ក្នុងលោក មិនអាឡោះអាល័យ វៀរចាកទី ជាទីស្អិតស្អាង អ្នកពោលពាក្យពិត គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលលះបង់កូនផង ប្រពន្ធផង បិតាផង មាតាផង ទ្រព្យទាំងឡាយផង ស្រូវទាំងឡាយផង ផៅពង្សទាំងឡាយផង កាមទាំងឡាយតាមចំណែករៀងខ្លួនផង គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

កាមគុណនេះជាគ្រឿងជាប់ចំពាក់ សុខក្នុងកាមគុណនេះ មានប្រមាណតិច កាមគុណមានសេចក្តីត្រេកអរតិច ទុក្ខក្នុងកាមគុណនេះ ច្រើនក្រៃលែង បុគ្គលអ្នកមានបញ្ញា ដឹងច្បាស់ថា ការជាប់ចំពាក់ក្នុងកាមគុណនុ៎ះ ដូចជាបួស គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលទម្លាយនូវសំយោជនៈ ដូចត្រីក្នុងទឹក ទម្លាយបង់នូវបណ្តាញ មិនត្រឡប់មក ( រកសំយោជនៈ ) វិញ ដូចជា

ភ្លើងចេះ ( មិនត្រឡប់វិលវិញ ) គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលមានចក្ខុដាក់ចុះ មានជើងមិនរពឹស មានឥន្ទ្រិយគ្រប់គ្រងល្អ មានចិត្តរក្សាទុក មិនជោកជាំ មិនរោលរាល ( ដោយកិលេស ) គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលលះបង់នូវវត្ថុជាគ្រឿងប្រាកដ នូវភាពជាគ្រហស្ថ ដូចដើមបារិច្ឆត្តព្រឹក្ស មានស្លឹកជម្រុះហើយ គប្បីជាអ្នកមានសំពត់កាសាយៈ ចេញបួស ត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលមិនធ្វើសេចក្ដីប្រាថ្នាក្នុងរសទាំងឡាយ ជាអ្នកមិនល្មោភ ( ក្នុងអាហារ ) មិនចិញ្ចឹមអ្នកដទៃ ជាអ្នកត្រាច់ទៅតាមច្រកមិនមានចិត្តជាប់ចំពាក់ក្នុងត្រកូលផ្សេងៗ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលលះបង់នូវនីវរណៈទាំង ៥ បន្ទោបង់នូវឧបក្កិលេស នៃចិត្តទាំងអស់ចេញបាន ជាអ្នកមិនអាស្រ័យ ( ដោយតណ្ហា ) កាត់បង់នូវទោស ដែលកើតអំពីសេចក្ដីស្រឡាញ់ហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គល បានធ្វើនូវសុខ ទុក្ខ និងសោមនស្ស ទោមនស្ស ក្នុងកាលមុន ឲ្យនៅពីក្រោយខ្នងហើយ បាននូវឧបេក្ខាសមថៈ

( ក្នុងចតុត្ថជ្ឈាន ) ដ៏បរិសុទ្ធហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គល មានសេចក្ដីព្យាយាមប្រារព្ធ ដើម្បីដល់នូវព្រះនិព្វាន មានចិត្តមិនរួញរា អ្នកប្រព្រឹត្តមិនខ្ជិលច្រអូស មានសេចក្ដីប្រឹងប្រែងដ៏មាំ ប្រកបដោយកម្លាំងប្រាជ្ញាហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គល មិនលះបង់នូវឈាន ជាធម្មជាតស្ងប់ស្ងាត់ ( ចាកសត្វ និងសង្ខារ ) ជាអ្នកប្រព្រឹត្តធម៌ ដ៏សមគួរក្នុងធម៌ទាំងឡាយ អស់កាលជានិច្ច ពិចារណាឃើញទោសក្នុងភពទាំងឡាយហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គល កាលប្រាថ្នានូវការអស់តណ្ហា ជាអ្នកមិនប្រហែស មិនខ្លួត មិនគ ជាអ្នកមានការចេះដឹង មានស្មារតី មានធម៌ពិចារណាហើយ ជាបុគ្គលទៀង មានសេចក្ដីព្យាយាម គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គល មិនតក់ស្លុត ( ក្នុងលក្ខណៈ មានមិនទៀងជាដើម ) ដូចសីហៈ មិនតក់ស្លុតនឹងសំឡេងទាំងឡាយ មិនបានជាប់ចំពាក់ ( ក្នុងធម៌ទាំងឡាយ មានខន្ធជាដើម ) ដូចខ្យល់មិនជាប់នឹងសំណាញ់ មិនជាប់ ( ដោយតណ្ហា និងលោភៈ )

ដូចឈូក មិនទទឹកដោយទឹក គប្បីត្រាច់ទៅតែម្នាក់ ឯងដូចកុយរមាស ។

បុគ្គល គប្បីអាស្រ័យនូវសេនាសនៈដ៏ស្ងាត់ ដូចជាសីហៈជាស្តេចសត្វ មានកម្លាំងចង្កូម ត្រាច់គ្របសង្កត់ កំហែងនូវពួកម្រឹគ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គល កាលចម្រើនមេត្តាផង ឧបេក្ខាផង ករុណាផង មុទិតាផង ដែលជាហេតុរួចស្រឡះ ( ចាកកិលេស ) ក្នុងកាលគួរមិនថ្នាំងថ្នាក់ចំពោះសត្វលោកទាំងអស់ហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គល លះបង់រាគៈផង ទោសៈផង មោហៈផង ទម្លាយនូវសំយោជនៈទាំងឡាយ មិនតក់ស្លុតក្នុងការក្ស័យជីវិត គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

ពួកមនុស្ស មានប្រយោជន៍ជាហេតុ ទើបគប់រកផង បម្រើផងពួកមិត្តសម្លាញ់ទាំងឡាយ ដែលឥតហេតុ រកបានដោយក្រក្នុងថ្ងៃនេះ ពួកមនុស្ស ( ច្រើនតែ ) មានប្រាជ្ញាចំពោះប្រយោជន៍របស់ខ្លួន ជាអ្នកប្រកបដោយអំពើមិនស្អាត បុគ្គលគប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

**ខគ្គវិសាណសូត្រទី ៣ ចប់**

# អដ្ឋកថា

# ខគ្គវិសាណសូត្រ

## គាថាទី ១

[ ៣ ] ខគ្គវិសាណសូត្រមានពាក្យផ្ដើមថា **សព្វេសុ ភូតេសុ** ដូច្នេះ តើមានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះសូត្រទាំងពួង មានអត្ថុប្បត្តិហេតុ ៤ យ៉ាង គឺព្រោះអធ្យាស្រ័យរបស់ខ្លួន ១ ព្រោះអធ្យាស្រ័យរបស់អ្នកដទៃ ១ ព្រោះការកើតឡើងនៃរឿង ១ ព្រោះអំណាចនៃពាក្យសួរ ១ ។ ពិតហើយ សូត្រទាំងឡាយ មានទ្វយតានុបស្សនាសូត្រជាដើម កើតឡើងព្រោះអធ្យាស្រ័យរបស់ខ្លួន សូត្រទាំងឡាយ មានមេត្តសូត្រជាដើម កើតឡើងព្រោះអធ្យាស្រ័យរបស់អ្នកដទៃ សូត្រទាំងឡាយ មានឧរគសូត្រជាដើម កើតព្រោះអត្ថុប្បត្តិហេតុ សូត្រទាំង-ឡាយមាន វម្មិកសូត្រជាដើម កើតឡើងព្រោះអំណាចនៃពាក្យសួរ ។

ក្នុងសូត្រទាំងនោះ ខគ្គវិសាណសូត្រ កើតឡើងដោយមិនប្លែកគ្នា ព្រោះអំណាចនៃពាក្យសួរ តែដោយប្លែកគ្នា ព្រោះក្នុងខគ្គវិសាណសូត្រនេះ គាថាខ្លះ ព្រះបច្ចេកសម្ពុទ្ធនោះៗ ត្រូវសួរ ទើបពោល គាថាខ្លះ មិនសួរ តែបន្លឺឧទាន ដែលសមគួរដល់ន័យដែលខ្លួនសម្រេចហើយប៉ុណ្ណោះ ព្រោះហេតុនោះ គាថាខ្លះ កើតឡើងព្រោះអំណាចនៃពាក្យសួរ គាថាខ្លះ កើតឡើងព្រោះអធ្យាស្រ័យរបស់អ្នកដទៃ គាថាខ្លះ កើតឡើងព្រោះអធ្យាស្រ័យរបស់

ខ្លួន ។ ក្នុងអត្ថុប្បត្តិហេតុទាំងនោះ អត្ថុប្បត្តិហេតុដោយអំណាចនៃពាក្យសួរ ដោយមិនប៉ែកគ្នានោះ គប្បីជ្រាបយ៉ាងនេះ ចាប់អំពីនេះជាដើម ។

ក្នុងសម័យមួយ ព្រះដ៏មានព្រះភាគ គង់នៅក្រុងសាវត្ថី កាលនោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅកាន់ទីស្ងាត់ ពួនសម្ងំ ក៏កើតបរិវិតក្កក្នុងចិត្ត យ៉ាងនេះថា ការប្រាថ្នា និងអភិនីហាររបស់ព្រះពុទ្ធទាំងឡាយប្រាកដ របស់សាវកទាំងឡាយក៏ប្រាកដដូចគ្នា តែរបស់ព្រះបច្ចេកពុទ្ធទាំងឡាយមិនប្រាកដឡើយ បើដូច្នោះ អញគប្បីចូលទៅគាល់ទូលសួរព្រះដ៏មានព្រះភាគ ។ ព្រះអានន្ទចេញអំពីទីសម្ងំហើយ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ទូលសួររឿងនេះតាមលំដាប់ ។ កាលនោះ ព្រះដ៏មានព្រះភាគ បានត្រាស់បុព្វយោគាវចរសូត្រដល់ព្រះអានន្ទថា ម្នាលអានន្ទ អានិសង្ស ៥ គឺបុគ្គលរមែងសម្រេចអរហត្តផលក្នុងទិដ្ឋធម៌ ព្រោះបុព្វយោគាវចរៈមុននោះឯង បើមិនសម្រេចអរហត្តផលក្នុងទិដ្ឋធម៌ បន្ទាប់មក ក៏សម្រេចអរហត្តផលក្នុងពេលស្លាប់ ។បេ។ តមក កើតជាទេវបុត្រ ក៏សម្រេចអរហត្តផល តមក ក៏ជាខិប្បាភិញ្ញាបុគ្គល ក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធទាំងឡាយ តមក រមែងជាព្រះបច្ចេកសម្ពុទ្ធ ក្នុងកាលចុងក្រោយ ។ កាលត្រាស់ដូច្នេះហើយ ទើបទ្រង់ត្រាស់បន្តថា ម្នាលអានន្ទ ធម្មតាព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ដែលដល់ព្រមដោយអភិនីហា មានបុព្វយោគាវចរធម៌ ព្រោះដូច្នោះ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវកពុទ្ធទាំងឡាយ គប្បីមានកាលប្រាថ្នា និងអភិនីហារ ។

ព្រះអានន្ទទូលថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្ដីប្រាថ្នាជាព្រះពុទ្ធទាំងឡាយយូរប៉ុនណា ព្រះសាស្ដាត្រាស់ថា ម្នាលអានន្ទ ការប្រាថ្នាជាព្រះពុទ្ធទាំងឡាយ យូរដោយការកំណត់យ៉ាងទាបបំផុត ៤ អសង្ខេយ្យ និង ១ សែនកប្ប កំណត់យ៉ាងកណ្ដាល ៨ អសង្ខេយ្យ និង ១ សែនកប្ប កំណត់យ៉ាងខ្ពស់បំផុត ១៦ អសង្ខេយ្យ និង ១ សែនកប្ប ។ ប្រភេទទាំង ៣ នោះ គប្បីដឹងដោយអំណាចនៃព្រះពុទ្ធដែលជាបញ្ញាធិក សទ្ធាធិក និងវិរិយាធិក ។ ពិតហើយ ព្រះពុទ្ធដែលជាបញ្ញាធិក មានសទ្ធាតិច មានបញ្ញាច្រើន ព្រះពុទ្ធដែលជាសទ្ធាធិក មានបញ្ញាជាកណ្ដាល តែមានសទ្ធាច្រើន ព្រះពុទ្ធដែលជាវិរិយាធិក មានសទ្ធា និងបញ្ញាតិច តែមានសេចក្ដីព្យាយាមច្រើន ។

បុគ្គលឲ្យទានដូចគ្នានឹងទាននៃព្រះវេស្សន្តររាល់ៗ ថ្ងៃក្ដី សន្សំបារមី មានសីលជាដើម ដែលសមគួរដល់ញាណនោះក្ដី បើមិនទាន់ដល់ ៤ អសង្ខេយ្យ និង ១ សែនកប្បហើយ ត្រាស់ជាព្រះពុទ្ធក្នុងរវាងនោះ មិនមែនជាឋានៈឡើយ ព្រោះហេតុអ្វី ព្រោះញាណមិនទាន់តាំងគភ៌ មិនទាន់ដល់នូវភាពបរិបូណ៌ មិនទាន់ដល់នូវការចាស់ក្លាដោយជុំវិញ ប្រៀបដូចស្រូវចេញក្ួរមិនបាន ដោយកន្លងទៅ ៣ ខែ ៤ ខែ ឬ ៥ ខែ បើមិនទាន់ដល់កាលនោះៗហើយ បុគ្គលទោះប្រាថ្នាមួយថ្ងៃ ១ សែនដង រាល់ៗ ថ្ងៃក្ដី ស្រោចទឹកមួយថ្ងៃ ១ សែនដងរាល់ៗ ថ្ងៃក្ដី នឹងឲ្យក្ួរចេញមកបានខាងក្នុងមួយបក្ខ ឬ

មួយខែ ទុំះមិនមែនជាបានះឡើយ ព្រោះហេតុអ្វី ព្រោះសម្ពន្ធមិនទាន់ដើម មិនទាន់ដល់នូវការបរិបូណ៌ មិនទាន់ដល់នូវការចាស់ដោយជុំវិញ យ៉ាងណា បុគ្គលឲ្យទានដូចគ្នានឹងទានរបស់ព្រះបាទវេស្សន្តររាល់ៗ ថ្ងៃក្តី សន្សំបារមីធម៌ មានសីលជាដើម ដែលសមគួរដល់ញាណនោះក្តី មិនទាន់ដល់ ៤ អសង្ខេយ្យ និង ១ សែនកប្បហើយ នឹងជាព្រះពុទ្ធក្នុងរវាងនោះ មិនមែនជាបានះឡើយ ព្រោះហេតុអ្វី ព្រោះញាណមិនទាន់តាំងគភ៌ មិនទាន់ដល់នូវភាពបរិបូណ៌ មិនទាន់ដល់ការចាស់ក្លាដោយជុំវិញ ក៏ដូច្នោះដូចគ្នា ព្រោះហេតុនោះគប្បីបំពេញបារមីសព្វកាលតាមដែលពោលហើយនោះឯង ដើម្បីប្រយោជន៍ដល់ការចាស់ក្លាដោយជុំវិញនៃញាណ កាលបុគ្គលប្រាថ្នាភាពជាព្រះពុទ្ធ ដោយកាលមានប្រមាណប៉ុណ្ណេះ ក៏គប្បីប្រាថ្នាសម្បត្តិ ៨ ប្រការ ក្នុងការសាងអភិនីហារពិតហើយ អភិនីហាររមែងសម្រេចបាន ក៏ព្រោះសមោធានធម៌ ៨ ប្រការ គឺភាពជាមនុស្ស ១ ការដល់ព្រមដោយភេទ ១ ហេតុ ១ ការជួបព្រះសាស្តា ១ ការចេញបព្វជ្ជា ១ ការដល់ព្រមនៃគុណ ១ អធិការ ១ ឆន្ទៈ ១ ។

ពាក្យថា អភិនីហារនោះ ជាឈ្មោះនៃមូលបណិធាន ។ ក្នុងសមោធានធម៌ ៨ ប្រការនោះ ពាក្យថា ភាពជាមនុស្ស បានដល់មនុស្សជាតិ ព្រោះថាក្រៅអំពីមនុស្សហើយ បណិធានរបស់បុគ្គលដែលតាំងនៅក្នុងជាតិដ៏សេសទាំងឡាយ សូម្បីជាតិជាទេវតាក៏ដោយ រមែងសម្រេចមិនបាន ព្រោះបុគ្គលដែលតាំងនៅក្នុងមនុស្សជាតិនោះ បើប្រាថ្នាភាពជាព្រះពុទ្ធ បំពេញបុញ្ញកម្ម

ទាំងឡាយ មានទានជាដើមហើយ គប្បីប្រាថ្នាក្នុងភាពជាមនុស្សប៉ុណ្ណោះ បុគ្គលតាំងនៅក្នុងមនុស្សជាតិនោះគប្បីតាំងបណិធាន ព្រោះថា អភិនីហាររមែងសម្រេចយ៉ាងនេះ ។

ពាក្យថា ការដល់ព្រមដោយភេទ បានដល់ ភាពជាបុរស ការប្រាថ្នារបស់ស្ត្រី ខ្ទើយ និងឧភតោព្យញ្ជនកៈ សូម្បីតាំងនៅក្នុងមនុស្សជាតិក៏រមែងសម្រេចមិនបាន ព្រោះថា បុគ្គលដែលតាំងនៅក្នុងមនុស្សជាតិនោះ កាលប្រាថ្នាភាពជាព្រះពុទ្ធ ធ្វើបុញ្ញកម្មទាំងឡាយ មានទានជាដើមហើយ គប្បីប្រាថ្នាក្នុងភាពជាបុរសប៉ុណ្ណោះ បុគ្គលតាំងនៅក្នុងភាពជាបុរសនោះ គប្បីតាំងបណិធាន អភិនីហាររមែងសម្រេចបាន ដោយប្រការដូច្នេះ ។

ពាក្យថា ហេតុ បានដល់ ការដល់ព្រមនូវឧបនិស្ស័យនៃអរហត្ត ។ បុគ្គលណាព្យាយាមក្នុងអត្តភាពនោះ អាចសម្រេចអរហត្តបាន អភិនីហាររមែងសម្រេចដល់បុគ្គលនោះ មិនសម្រេចដល់បុគ្គលក្រៅអំពីនេះឡើយ ដូចសម្រេចដល់សុមេធបណ្ឌិតដូច្នោះ ព្រោះថា សុមេធបណ្ឌិតនេះ បព្វជ្ជាត្រង់បាទមូលរបស់ព្រះពុទ្ធព្រះនាមទីបង្ករ ជាអ្នកអាចសម្រេចអរហត្តក្នុងអត្តភាពនោះបាន ។

ពាក្យថា ការជួបព្រះសាស្តា បានដល់ ការឃើញចំពោះព្រះភក្ត្រព្រះសម្មាសម្ពុទ្ធទាំងឡាយ ព្រោះថា អភិនីហាររមែងសម្រេច ដោយប្រការដូច្នេះ មិនសម្រេចដោយប្រការដទៃឡើយ ដូចសម្រេចដល់សុមេធបណ្ឌិត ដូច្នោះ ព្រោះសុមេធបណ្ឌិតនោះ ឃើញព្រះពុទ្ធព្រះនាមទីបង្ករ ចំពោះព្រះភក្ត្រ

ហើយបានតាំងសេចក្តីប្រាថ្នា ។

ពាក្យថា បព្វជ្ជា បានដល់ ភាពជាអនាគារិក ភាពជាអនាគារិកនោះ ឯង រមែងគួរក្នុងសាសនា ឬក្នុងនិកាយរបស់តាបស និងបរិព្វាជកដែលជា កម្មវាទី និងកិរិយវាទី ដូចគួរដល់សុមេធបណ្ឌិតដូច្នោះ ព្រោះថា សុមេធ-បណ្ឌិតនោះ ជាតាបសឈ្មោះសុមេធ ទើបតាំងបណិធាន ។

ពាក្យថា ការដល់ព្រមនៃគុណ បានដល់ ការបានទូវគុណធម៌ មាន ឈានជាដើម ឯអភិនីហាររមែងសម្រេចដល់បុគ្គលសូម្បីបួសហើយ ដែល ដល់ព្រមដោយគុណប៉ុណ្ណោះ រមែងមិនសម្រេចដល់បុគ្គលក្រៅអំពីនេះ ដូច សម្រេចដល់សុមេធបណ្ឌិតដូច្នោះ ព្រោះថា សុមេធបណ្ឌិតនោះ បានទូវ អភិញ្ញា ៥ និងបានសមាបត្តិ ៨ ហើយ ទើបតាំងបណិធាន ។

ពាក្យថា អធិការ បានដល់ ការធ្វើដ៏ក្រៃលែង អធិប្បាយថា ការ បរិច្ចាគ ។ ពិតហើយ អភិនីហាររមែងសម្រេចដល់បុគ្គលដែលធ្វើនូវការ បរិច្ចាគវត្ថុ មានជីវិតជាដើម ហើយតាំងនូវបណិធានប៉ុណ្ណោះ មិនសម្រេច ដល់បុគ្គលក្រៅអំពីនេះឡើយ ដូចគ្នានឹងការសម្រេចដល់សុមេធបណ្ឌិតដូច្នោះ សុមេធបណ្ឌិតនោះ ធ្វើការបរិច្ចាគជីវិតហើយ តាំងបណិធានយ៉ាងនេះថា

> សូមព្រះពុទ្ធ ព្រមទាំងពួកសិស្ស ជាន់អាត្មាអញ យាងទៅ
> ចុះ សូមកុំជាន់ភក់ឡើយ ការមិនជាន់លើភក់នោះ នឹងជា
> ប្រយោជន៍ដល់អាត្មាអញ ដូច្នេះ ។

ពាក្យថា ឆន្ទៈ បានដល់ ភាពជាអ្នកប្រាថ្នាដើម្បីធ្វើ ភាពជាអ្នកប្រាថ្នាដើម្បីធ្វើនោះរបស់បុគ្គលណាមានកម្លាំង អភិនីហាររមែងសម្រេចដល់បុគ្គលនោះ ឯភាពជាអ្នកប្រាថ្នាដើម្បីធ្វើនោះ គប្បីជ្រាបថា បើបុគ្គលខ្លះគប្បីពោលថា បុគ្គលណាឆេះក្នុងនរកអស់ ៤ អសង្ខេយ្យ និង ១ សែនកប្បហើយ រមែងប្រាថ្នាភាពជាព្រះពុទ្ធដូច្នេះសោត បុគ្គលណាបានស្តាប់ពាក្យនោះហើយ រមែងឧស្សាហ៍ដើម្បីនឹងពោលថា ខ្ញុំ ភាពជាអ្នកប្រាថ្នាដើម្បីធ្វើរបស់បុគ្គលនោះ ឈ្មោះថា មានកម្លាំង ។

ម្យ៉ាងទៀត ភាពជាអ្នកប្រាថ្នាដើម្បីធ្វើនោះ គប្បីជ្រាបថា បើបុគ្គលខ្លះគប្បីពោលថា អ្នកណាដើរឆ្លងសកលចក្កវាឡ ដែលពេញដោយរងើកភ្លើង ដែលប្រាសចាកអណ្តាតហើយ នឹងបានត្រាស់ជាព្រះពុទ្ធសោត អ្នកណាជាន់ឆ្លងសកលចក្កវាឡដែលដេរដាសដោយចម្រូង និងលំពែងហើយ រមែងបានជាព្រះពុទ្ធ បុគ្គលណាហែលឆ្លងសកលចក្កវាឡដែលពេញដោយទឹក រមែងបានជាព្រះពុទ្ធ បុគ្គលណាដើរឆ្លងសកលចក្កវាឡ ដែលដេរដាសដោយគុម្ពឫស្សី ហើយសម្រេចជាព្រះពុទ្ធដូច្នេះសោត បុគ្គលបានស្តាប់ពាក្យនោះហើយ រមែងឧស្សាហ៍ពោលថា ខ្ញុំ ការប្រាថ្នាដើម្បីនឹងធ្វើរបស់បុគ្គលនោះ ឈ្មោះថា មានកម្លាំង ។ សុមេធបណ្ឌិតប្រកបព្រមដោយឆន្ទៈ គឺភាពជាអ្នកប្រាថ្នាដើម្បីនឹងធ្វើបែបនេះ បានតាំងបណិធានហើយ ។

ព្រះពោធិសត្វមានអភិនីហារសម្រេចហើយយ៉ាងនេះឯង រមែងមិនដល់

អភព្វដ្ឋាន ១៨ ប្រការ ។ ពិតហើយ ព្រះពោធិសត្វនោះ ចាប់តាំងពីកាលនោះ មិនជាមនុស្សភ្នែកខ្វាក់អំពីកំណើត ១ មិនជាមនុស្សត្រចៀកថ្លង់អំពីកំណើត ១ មិនជាមនុស្សឆ្កួត ១ មិនជាមនុស្សគ ១ មិនជាមនុស្សក្រិស ១ មិនកើតក្នុងជនជាតិមិលក្ខៈ ១ មិនកើតក្នុងផ្ទៃរបស់ទាសី ១ មិនជាមនុស្សនិយតមិច្ឆាទិដ្ឋិ ១ មិនជាមនុស្សក្លាយភេទ ១ មិនធ្វើអនន្តរិយកម្មឯណានីមួយ ១ មិនកើតរោគឃ្លង់ ១ ក្នុងកំណើតតិរច្ឆានមិនមានអត្តភាពតូចជាងចាបចៀបកប្បាស ១ មិនមានអត្តភាពធំជាងដំរី ១ មិនកើតក្នុងខុប្បិបាសិកប្រេត និងនិជ្ឈាមតណ្ហិកប្រេត ១ មិនកើតក្នុងពួកកាឡកញ្ជិកាសុរទាំងឡាយ ១ មិនកើតក្នុងអវិចីមហានរក ១ មិនកើតក្នុងលោកន្តរិកនរក ១ មិនកើតជាមារក្នុងជាន់កាមាវចរ មិនកើតក្នុងអសញ្ញីក្នុងរូបាវចរ មិនកើតក្នុងសុទ្ធាវាស មិនកើតក្នុងអន្តិមភព ( អរូបភព ) មិនឈានចុះកាន់ចក្កវាឡដទៃ ១ ។

ពុទ្ធភូមិ ៤ គឺឧស្សាហៈ ១ ឧម្មគ្គៈ ១ អវដ្ឋានៈ ១ ហិតចរិយា ១ ព្រះពោធិសត្វ ជាអ្នកដល់ព្រមដោយពុទ្ធភូមិទាំងនោះ ។ ក្នុងពុទ្ធភូមិ ៤ ប្រការនោះ សេចក្តីព្យាយាម ហៅថា **ឧស្សាហៈ** បញ្ញា ហៅថា **ឧម្មគ្គៈ** អធិដ្ឋាន ហៅថា **អវដ្ឋានៈ** មេត្តាភាវនា ហៅថា **ហិតចរិយា ។**

អជ្ឈាស្រ័យ ៦ គឺអជ្ឈាស្រ័យដើម្បីចេញបួស ១ អជ្ឈាស្រ័យដើម្បីបវិវេក ១ អជ្ឈាស្រ័យដើម្បីមិនលោភ ១ អជ្ឈាស្រ័យដើម្បីមិនក្រោធ ១

អធ្យាស្រ័យដើម្បីមិនវង្វេង ១ អធ្យាស្រ័យដើម្បីរលាស់ចេញ ១ រមែងប្រព្រឹត្តទៅដើម្បីបន្ទំពោធិញ្ញាណ ព្រោះព្រះពោធិសត្វទាំងឡាយ ប្រកបដោយអធ្យាស្រ័យទាំងឡាយណា ព្រះពោធិសត្វទាំងឡាយ មានអធ្យាស្រ័យដើម្បីនេក្ខម្ម: ហៅថា មានប្រក្រតីឃើញទោសក្នុងកាម មានអធ្យាស្រ័យដើម្បីបវិវេក ហៅថា មានប្រក្រតីឃើញទោសក្នុងការប្រឡូកប្រឡំ មានអធ្យាស្រ័យដើម្បីការមិនលោភ ហៅថា មានប្រក្រតីឃើញទោសក្នុងលោភ: មានអធ្យាស្រ័យដើម្បីការមិនក្រោធ ហៅថា មានប្រក្រតីឃើញទោសក្នុងទោស: មានអធ្យាស្រ័យដើម្បីការមិនវង្វេង ហៅថា មានប្រក្រតីឃើញទោសក្នុងមោហ: និងមានអធ្យាស្រ័យដើម្បីការរលាស់ចេញ ហៅថា មានប្រក្រតីឃើញទោសក្នុងភពទាំងពួង ។ សុមេធបណ្ឌិតពោធិសត្វ ប្រកបដោយអធ្យាស្រ័យទាំងនេះ ។

សួរថា ការប្រាថ្នាជាព្រះបច្ចេកពុទ្ធទាំងឡាយយូរប៉ុនណា ឆ្លើយថា ការប្រាថ្នាជាព្រះបច្ចេកពុទ្ធទាំងឡាយយូរត្រឹម ២ អសង្ខេយ្យ និង ១ សែនកប្ប បើទាបជាងនោះ មិនជាឋាន: គប្បីជ្រាបហេតុក្នុងការប្រាថ្នាជាព្រះបច្ចេកពុទ្ធ ដោយន័យដែលពោលហើយ ក្នុងបទមុននោះឯង ។ កាលបុគ្គលប្រាថ្នាភាពជាព្រះបច្ចេកពុទ្ធដោយកាល សូម្បីមានប្រមាណប៉ុណ្ណោះ គប្បីប្រាថ្នានូវសម្បត្តិ ៥ ប្រការ ក្នុងការសាងអភិនីហារ ។ ពិតហើយ ព្រះបច្ចេកពុទ្ធទាំងនោះ មានហេតុនៃអភិនីហារទាំងនេះ គឺភាពជាមនុស្ស ១ ការដល់ព្រម

ដោយភេទ ១ ការឃើញបុគ្គលដែលប្រាសចាកអាសវៈ ១ អធិការ ១ ឆន្ទៈ ១ ។ បណ្ដាពាក្យទាំងនោះ ពាក្យថា ការឃើញបុគ្គលដែលប្រាសចាកអាសវៈ បានដល់ ការឃើញព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ សាវកពុទ្ធណាមួយ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

សួរថា ការប្រាថ្នាជាព្រះសាវកទាំងឡាយយូរប៉ុនណា ឆ្លើយថា ការប្រាថ្នាជាអគ្គសាវកទាំងពីរយូរដល់ ១ អសង្ខេយ្យ និង ១ សែនកប្ប ការប្រាថ្នាជាអសីតិមហាសាវក ត្រឹមតែ ១ សែនកប្ប ការប្រាថ្នាជាពុទ្ធមាតា ពុទ្ធបិតា ពុទ្ធុបដ្ឋាក ពុទ្ធោរស យូរដល់ ១ សែនកប្បដូចគ្នា បើទាបជាងនោះ មិនជាឋានៈ ។ ហេតុក្នុងការប្រាថ្នានោះ មានន័យដូចពោលហើយនោះឯង សាវកទាំងអស់ មានអភិនីហារសម្បូរដោយអង្គ ២ យ៉ាង គឺ អធិការ ១ ឆន្ទៈ ១ ប៉ុណ្ណោះ ។

ព្រះពុទ្ធទាំងឡាយ ទ្រង់បំពេញបារមីទាំងឡាយអស់កាលមានប្រភេទតាមដែលពោលហើយ ដោយការប្រាថ្នានេះ ដោយអភិនីហារនេះឯង ។ កាលព្រះពុទ្ធកើតឡើងក្នុងលោក ទ្រង់ក៏កើតក្នុងត្រកូលក្សត្រ ឬត្រកូលព្រាហ្មណ៍ប៉ុណ្ណោះ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ រមែងកើតក្នុងត្រកូលក្សត្រ ព្រាហ្មណ៍ ឬត្រកូលគហបតីណាមួយ ។ ចំណែកអគ្គសាវកទាំងឡាយ រមែងកើតក្នុងត្រកូលក្សត្រ ឬត្រកូលព្រាហ្មណ៍ប៉ុណ្ណោះ ដូចព្រះពុទ្ធទាំងឡាយដែរ ។ ព្រះពុទ្ធទាំងពួង មិនកើតឡើងក្នុងកប្បដែលកំពុងវិនាស ទ្រង់រមែងកើតឡើង

ក្នុងកប្បដែលកំពុងចម្រើន ។ ព្រះបច្ចេកពុទ្ធទាំងឡាយ រមែងកើតក្នុងកាលដែលព្រះពុទ្ធទាំងឡាយមិនទាន់ត្រាស់ដឹងប៉ុណ្ណោះ ។ ព្រះពុទ្ធទាំងឡាយ ត្រាស់ដឹងឯងផង ទូន្មានឲ្យអ្នកដទៃដឹងផង ព្រះបច្ចេកពុទ្ធទាំងឡាយ ត្រាស់ដឹងឯងតែមិនអាចទូន្មានឲ្យអ្នកដទៃដឹង រមែងចាក់ធ្លុះអត្ថរសប៉ុណ្ណោះ មិនចាក់ធ្លុះធម្មរស ព្រោះព្រះបច្ចេកពុទ្ធទាំងនោះ មិនអាចលើកលោកុត្តរធម៌ជាបញ្ញត្តិឡើងសម្តែងបាន ការសម្រេចធម៌ រមែងមានដល់ព្រះបច្ចេកពុទ្ធទាំងនោះ ដូចមនុស្សគយល់សប្តិ និងដូចរសនៃម្ហូបក្នុងក្រុងដែលព្រានព្រៃបានភ្លក្ស ដូច្នោះ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ រមែងសម្រេចធម៌ទាំងអស់ មានឥទ្ធិសមាបត្តិ និងបដិសម្ភិទា មានគុណវិសេសតិចជាងព្រះពុទ្ធទាំងឡាយ តែក្រៃលែងជាងសាវកទាំងឡាយ រមែងញ៉ាំងបុគ្គលដទៃឲ្យបព្វជ្ជា ឲ្យសិក្សានូវអភិសមាចារដោយឧទ្ទេសថា គប្បីដុសខាត់ចិត្ត មិនគប្បីរញ្ជួយ ឬរមែងធ្វើឧបោសថ ដោយហេតុត្រឹមតែពោលថា ថ្ងៃនេះជាថ្ងៃឧបោសថ ហើយកាលធ្វើឧបោសថ រមែងប្រជុំគ្នាធ្វើត្រង់រតនមាលៈ នាគល់មញ្ជូសៈ ត្រង់ភ្នំគន្ធមាទន៍នោះឯង ។

ព្រះដ៏មានព្រះភាគ កាលត្រាស់ការប្រាថ្នា និងអភិនីហារដែលបរិបូណ៌ដោយអាការទាំងពួង របស់ព្រះបច្ចេកពុទ្ធទាំងឡាយ ដល់ព្រះអានន្ទហើយឥឡូវនេះ ដើម្បីទ្រង់សម្តែងព្រះបច្ចេកពុទ្ធទាំងនោះឯង ឲ្យដល់ព្រមដោយការប្រាថ្នានេះ និងអភិនីហារនេះ ទើបត្រាស់ខគ្គវិសាណសូត្រនេះ ដោយន័យជាដើមថា **សព្វេសុ ភូតេសុ និធាយ ទណ្ឌំ** ដូច្នេះ ។ អត្ថុប្បត្តិហេតុនៃខគ្គ-

វិសាណសូត្រ កើតឡើងដោយអំណាចនៃពាក្យសួរ ដោយមិនប្លែកគ្នា ។ ឥឡូវនេះ គប្បីជ្រាបអត្ថុប្បត្តិហេតុដែលប្លែកគ្នា ក្នុងខគ្គវិសាណសូត្រនោះ គប្បីជ្រាបឧប្បត្តិនៃគាថានេះយ៉ាងនេះថា

បានឮថា ព្រះបច្ចេកពុទ្ធនេះ ឈមចុះកាន់បច្ចេកពោធិសត្តភូមិ បំពេញបារមីទាំងឡាយអស់ ២ អសង្ខេយ្យ និង ១ សែនកប្ប បួសក្នុងសាសនារបស់ព្រះដ៏មានព្រះភាគព្រះនាមកស្សបៈ ជាអ្នកនៅក្នុងព្រៃជាវត្ត បំពេញគតបច្ចាគតវត្ត ធ្វើនូវសមណធម៌ ។ បានឮថា ព្រះបច្ចេកពុទ្ធទាំងឡាយមិនបំពេញវត្តនោះហើយ ឈ្មោះថា សម្រេចនូវបច្ចេកពោធិមិនមាន ។ វត្តនោះដូចម្តេច គឺការនាំកម្មដ្ឋានទៅ និងការនាំកម្មដ្ឋានត្រឡប់មក ឈ្មោះថា គតបច្ចាគតវត្ត ខ្ញុំគប្បីពោលគតបច្ចាគតវត្តនោះ ដោយប្រការជាក់ច្បាស់ ។

ភិក្ខុក្នុងសាសនានេះ អង្គខ្លះនាំទៅតែមិននាំត្រឡប់មក អង្គខ្លះនាំត្រឡប់មក តែមិននាំទៅ អង្គខ្លះមិននាំទៅផង មិននាំត្រឡប់មកផង អង្គខ្លះនាំទៅផង នាំត្រឡប់មកផង ។ ក្នុងភិក្ខុទាំងនោះ ភិក្ខុណាក្រោកអំពីព្រលឹម ធ្វើចេតិយង្គណវត្ត និងពោធិយង្គណវត្ត ស្រោចទឹកដើមពោធិ៍ ដងទឹកពេញក្អមទឹកឈរត្រង់រោងទឹកផឹក ធ្វើអាចរិយវត្ត ឧបជ្ឈាយវត្ត សមាទាន ប្រព្រឹត្តវត្តតូច ៨២ វត្ត ធំ ១៤ ភិក្ខុនោះ ធ្វើបរិកម្មរាងកាយ ចូលទៅកាន់សេនាសនៈញុំាងកាលឲ្យកន្លងទៅក្នុងអាសនៈស្ងាត់ រហូតដល់ពេលបិណ្ឌបាត ដឹងវេលាស្លៀកដណ្តប់ ចងវត្តពន្ធចង្កេះ ដណ្តប់ឧត្តរាសង្គ ពាក់សង្ឃាដិ ស្ពាយបាត្រ

មនសិការកម្មដ្ឋាន ដល់លានចេតិយហើយ ថ្វាយបង្គំចេតិយ និងពោធិព្រឹក្ស ដណ្តប់ក្នុងទីជិតស្រុក ឱបបាត្រចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត ភិក្ខុបាន លាភ មានបុណ្យ ចូលទៅយ៉ាងនេះហើយ ដែលឧបាសក ឧបាសិកាធ្វើ សក្ការៈ គោរពហើយ ត្រឡប់ពីត្រកូលឧបដ្ឋាក ឬក្នុងសាលាសម្នាក់ ត្រូវ ឧបាសក ឧបាសិកាសួរបញ្ហានោះៗ ដាក់មនសិការនោះ ដោយការដោះ ស្រាយបញ្ហា និងដោយការវាយមាយក្នុងការសម្តែងធម៌ដល់ឧបាសក ឧបា- សិកាទាំងនោះហើយ ចេញទៅ សូម្បីត្រឡប់មកកាន់វិហារហើយ ត្រូវភិក្ខុ ទាំងឡាយសួរបញ្ហា ហើយពោលដោះស្រាយ សម្តែងធម៌ដល់សេចក្តីខ្វល់ ខ្វាយនោះៗ ត្រូវឃឹតយូរជាមួយភិក្ខុទាំងឡាយយ៉ាងនេះ រហូតដល់អស់បច្ឆា ភត្តខ្លះ បុរិមយាមខ្លះ មជ្ឈិមយាមខ្លះ ត្រូវការប្រព្រឹត្តអាក្រក់គ្រោតគ្រាតផ្លូវ កាយគ្របសង្កត់ រមែងដេកក្នុងបច្ឆិមយាម រមែងមិនមនសិការនូវកម្មដ្ឋាន ភិក្ខុនេះ ហៅថា នាំទៅ តែមិននាំត្រឡប់ ។

ចំណែកភិក្ខុណាច្រើនដោយព្យាធិ ឆាន់អាហារហើយ រមែងមិនរលួយ ទៅដោយប្រពៃ ក្នុងសម័យទៀបភ្លឺ ក្រោកឡើងអំពីព្រលឹម មិនអាចធ្វើវត្ត តាមដែលពោលហើយ ឬដើម្បីមនសិការកម្មដ្ឋាន ប្រាថ្នាបបរ ឬភេសជ្ជៈ ប៉ុណ្ណោះ កាន់បាត្រ និងចីវរចូលស្រុកតាមកាលនោះឯង បានបបរ ឬ ភេសជ្ជៈ ឬភត្តក្នុងស្រុកនោះហើយ ( ធ្វើភត្តកិច្ច ) លាងបាត្រ អង្គុយក្នុង អាសនៈដែលក្រាលហើយ មនសិការកម្មដ្ឋាន សម្រេចគុណវិសេស ឬមិន

សម្រេច ត្រឡប់មកវត្តដោយមនសិការនោះប៉ុណ្ណោះ ភិក្ខុនេះ ហៅថា នាំត្រឡប់ តែមិននាំទៅ ។

ភិក្ខុទាំងឡាយបែបនេះដែរ ធាន់បបរ ប្រារព្ធវិបស្សនាហើយ សម្រេចអរហត្តក្នុងព្រះពុទ្ធសាសនារាប់មិនអស់ ក្នុងស្រុកនោះៗ ក្នុងកោះលង្កា មិនមានអាសនៈណា ដែលភិក្ខុធាន់បបរហើយ មិនសម្រេចអរហត្ត ។

ចំណែកភិក្ខុណា ជាអ្នកនៅដោយសេចក្តីប្រមាទ ដាក់នូវធុរៈ ទម្លាយវត្តគ្រប់យ៉ាង មានចិត្តជាប់ជំពាក់ដោយចេតោខីលធម៌ ៥ យ៉ាង មិនតាមប្រកបមនសិការកម្មដ្ឋាន ចូលស្រុកដើម្បីបិណ្ឌបាតហើយ ត្រូវការឃើតយូរ ព្រោះគ្រហស្ថធ្វើឲ្យឃើតយូរហើយ ជាបុគ្គលទទេត្រឡប់មក ភិក្ខុនេះ ហៅថា មិននាំទៅផង មិននាំត្រឡប់មកផង ។

ចំណែកភិក្ខុណា ក្រោកឡើងអំពីព្រលឹមហើយ បំពេញវត្តសព្វយ៉ាងដោយន័យមុននោះឯង អង្គុយពត់ក្អែនមនសិការកម្មដ្ឋាន រហូតដល់ពេលភិក្ខាចារ ។ ឈ្មោះថា កម្មដ្ឋាន មាន ២ យ៉ាង គឺសព្វត្ថកម្មដ្ឋាន ១ បារិហារិយកម្មដ្ឋាន ១ ។ មេត្តា និងមរណស្សតិ ឈ្មោះថា សព្វត្ថកម្មដ្ឋាន កម្មដ្ឋាននោះ ហៅថា **សព្វត្ថ** ព្រោះជាកម្មដ្ឋានដែលគប្បីប្រាថ្នាក្នុងទីទាំងពួង ឈ្មោះថា មេត្តា គប្បីប្រាថ្នាក្នុងទីទាំងពួង មានអាវាសជាដើម ។ ពិតហើយ ភិក្ខុដែលនៅដោយមេត្តាក្នុងអាវាស រមែងជាទីស្រឡាញ់ ជាទីពេញចិត្តរបស់សព្រហ្មចារីទាំងឡាយ ដែលសព្រហ្មចារីនោះមិនបៀតបៀន ដល់នូវផាសុក

ជាអ្នកនៅដោយមេត្តាក្នុងទេវតាទាំងឡាយ ដែលពួកទេវតារក្សាគ្រប់គ្រង ហើយ រមែងនៅជាសុខ ជាអ្នកនៅដោយមេត្តាក្នុងព្រះរាជា និងមហាមាត្យ របស់ព្រះរាជាជាដើម ដែលលោកទាំងនោះ រាប់អានហើយ រមែងនៅជាសុខ នៅដោយមេត្តាក្នុងស្រុកនិគមជាដើម ដែលមនុស្សទាំងឡាយក្នុងទីទាំងពួង មានទីដែលត្រាច់ទៅដើម្បីភិក្ខាជាដើម ធ្វើនូវសក្ការៈគោរពហើយ រមែងនៅជាសុខ ជាអ្នកលះនូវការប្រាថ្នាក្នុងជីវិត ដោយការចម្រើនមរណានុស្សតិ មិនប្រមាទ ។

កម្មដ្ឋានណា ដែលភិក្ខុគប្បីបរិហារសព្វកាល កាន់យកហើយដោយសមគួរដល់ចរិត ឬចតុធាតុវវដ្ឋានកម្មដ្ឋានណាមួយ ក្នុងបណ្ដាអសុភ ១០ កសិណ ១០ និងអនុស្សតិ ១០ ជាដើម កម្មដ្ឋាននោះ ហៅថា បារិហារិយៈ ព្រោះជាកម្មដ្ឋានដែលភិក្ខុគប្បីបរិហារ គប្បីរក្សា គប្បីចម្រើនសព្វកាល បារិហារិយកម្មដ្ឋាននោះឯង ហៅថា មូលកម្មដ្ឋានដូច្នេះក៏បាន ។ ក្នុងកម្មដ្ឋានទាំង ២ យ៉ាងនោះ ភិក្ខុមនសិការសព្វត្ថកម្មដ្ឋានមុនហើយ មនសិការបារិហារិយកម្មដ្ឋានក្នុងកាលឯក្រោយ ខ្ញុំនឹងសម្ដែងបារិហារិយកម្មដ្ឋាននោះ ដោយចតុធាតុវវដ្ឋានជាប្រធាន ។

ព្រោះថា ភិក្ខុនេះ ពិចារណាកាយតាមដែលស្ថិតនៅ តាមដែលតាំងនៅ ដោយភាពជាធាតុ មនសិការកម្មដ្ឋានខាងដើម កណ្ដាល និងទីបំផុតយ៉ាងនេះថា ធាតុណានីមួយក្នុងបណ្ដាអាការ ២០ ដែលមាននៅក្នុងកាយនេះ ធាតុនោះ

ឈ្មោះថា បឋវីធាតុ ធាតុណាធ្វើកិច្ចជ្រួតជ្រាប ដល់នូវភាពជារបស់ហូរក្នុង ១២ អាការ ធាតុនោះ ឈ្មោះថា អាបោធាតុ ធាតុណាធ្វើនូវកម្តៅ ដល់នូវភាពជាភ្លើងធាតុក្នុងអាការ ៤ ធាតុនោះ ឈ្មោះថា តេជោធាតុ ចំណែកធាតុណាធ្វើនូវការគាំពារ មានលក្ខណៈបក់ទៅមកក្នុង ៦ អាការ ធាតុនោះ ឈ្មោះថា វាយោធាតុ ក្នុងកាយនេះ ធាតុណាដែលមហាភូតរូប ៤ មិនពាល់ត្រូវជាចន្លោះទទេ ធាតុនោះ ឈ្មោះថា អាកាសធាតុ ចិត្តជាតួដឹងនោះ ឈ្មោះថា វិញ្ញាណធាតុ សត្វ ឬបុគ្គលដទៃក្រៅអំពីធាតុ ៦ នោះមិនមាន សត្វឬបុគ្គលនេះ គឺគំនរសង្ខារសុទ្ធៗ ប៉ុណ្ណោះ ដូច្នេះ ដឹងនូវកាលក្រោកឡើងអំពីអាសនៈ ស្លៀកស្បង់ហើយ យុំចីវរទៅកាន់ស្រុកដើម្បីបិណ្ឌបាត ដោយន័យដែលពោលហើយខាងដើមនោះឯង កាលទៅមិនវង្វេង ដូចបុថុជ្ជនល្ងង់ខ្លៅទាំងឡាយ វង្វេងថា ក្នុងការឈានទៅជាដើម ខ្លួនរមែងឈានទៅ ការឈានទៅរបស់ខ្លួនកើតហើយ ដូច្នេះ ឬថា អញឈានទៅមុខ ការឈានទៅអញឲ្យកើតហើយ ដូច្នេះ រមែងទៅដោយមនសិការនូវកម្មដ្ឋាន ដែលបរិបូណ៌ដោយអាការទាំងពួងយ៉ាងនេះថា កាលចិត្តកើតឡើងថា អញនឹងឈានទៅ វាយោធាតុដែលមានកិច្ចកម្រើក ដែលមានចិត្តជាសមុដ្ឋាន រមែងកើតឡើងព្រមនឹងចិត្តនោះ វាយោធាតុនោះ រមែងផ្សាយពេញសរីរៈ មានឆ្អឹង ដែលសន្មតថាកាយ ដែលជាធាតុសន្សំមកចាកបឋវីធាតុជាដើម បន្ទាប់អំពីនោះរាងឆ្អឹងដែលសន្មតថាកាយនេះ ក៏ឈានទៅដោយកិរិយានៃចិត្ត និងការផ្សាយ

ទៅនៃវាយោធាតុ កាលរាងក្អឹងនោះឈានទៅយ៉ាងនេះ ការលើកជើងម្ខាងឡើង ក្នុងបណ្តាធាតុ ៤ តេជោធាតុដែលឧបការៈវាយោធាតុ ក៏មានកម្លាំងក្រៃលែងឡើង ធាតុក្រៅអំពីនេះទន់ខ្សោយ តែក្នុងការលើកជើងឈានទៅដោយការផ្លាស់ជើងទាំងឡាយ វាយោធាតុដែលឧបការៈតេជោធាតុ ក៏មានកម្លាំងក្រៃលែងកើតឡើង ធាតុក្រៅអំពីនេះ ក៏មានកម្លាំងខ្សោយ តែក្នុងការដាក់ចុះ អាបោធាតុឧបការៈ បឋវីធាតុមានកម្លាំងក្រៃលែងកើតឡើង ចំណែកធាតុក្រៅអំពីនេះ ទន់ខ្សោយ ក្នុងការបត់អង្កុញ និងលាតសណ្តូក បឋវីធាតុដែលបានទទួលការឧបការៈអំពីអាបោធាតុ មានកម្លាំងក្រៃលែងកើតឡើង ធាតុក្រៅអំពីនេះ មានកម្លាំងខ្សោយ ធាតុទាំងនោះ រមែងបែកទៅក្នុងទីនោះៗ ឯង មួយអន្លើដោយចិត្តដែលធ្វើខ្លួនឲ្យកើតឡើងនោះៗ ដោយប្រការដូច្នេះ ។ ធាតុដែលកើតឡើងក្នុងប្រការនីមួយៗ ក្នុងប្រការទាំងឡាយ មានការលើកជើងម្ខាងឡើងជាដើមយ៉ាងនេះ គឺក្នុងធាតុទាំង ៤ នោះ បុគ្គលណាម្នាក់ រមែងឈានទៅ ឬការឈានទៅរបស់បុគ្គលណាដូច្នេះ រូបធម៌ដ៏សេស ដែលត្រូវធាតុទាំង ៤ នោះគ្របសង្កត់ ចិត្តដែលញុំាងរូបធម៌នោះឲ្យកើតឡើង និងអរូបធម៌ដ៏សេសដែលសម្បយុត្តដោយចិត្តនោះ រួមសេចក្តីថា រូបធម៌ និងអរូបធម៌ទាំងនោះ រមែងមិនដល់ប្រការដទៃក្នុងប្រការទាំងឡាយ មានការលើកជើងនិងឈានទៅមុខជាដើម បន្ទាប់អំពីការលើកជើងប៉ុណ្ណោះ រមែងបែកធ្លាយទៅក្នុងទីនោះៗ ឯង ។ ព្រោះដូច្នោះ ទើបធាតុទាំងឡាយមិនទៀង ធម៌ណា

មិនទៀង ធម៌នោះ ជាទុក្ខ ធម៌ណា ជាទុក្ខ ធម៌នោះ ជាអនត្តាដូច្នេះ ។

កុលបុត្តទាំងឡាយ ដែលប្រាថ្នាប្រយោជន៍ បួសក្នុងសាសនាហើយ នៅរួមគ្នា ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៣០ ឆ្នាំខ្លះ ៤០ ឆ្នាំខ្លះ ៥០ ឆ្នាំខ្លះ ៦០ ឆ្នាំខ្លះ ៧០ ឆ្នាំខ្លះ ១០០ ឆ្នាំខ្លះ ធ្វើកតិកាវត្តថា អាវុសោទាំងឡាយ អ្នកទាំង-ឡាយ ជាអ្នកមិនមានបំណុល មិនមានភ័យ មិនបានបួសព្រោះហេតុតែជីវិត បួសបំណងនឹងផុតចាកទុក្ខ ព្រោះដូច្នោះ កិលេសកើតហើយក្នុងការទៅ ក៏ចូរសង្កត់សង្កិនក្នុងការទៅនោះឯង កិលេសកើតហើយក្នុងការឈរ ក្នុងការអង្គុយ ក៏ចូរសង្កត់ក្នុងការឈរ និងការអង្គុយនោះឯង កិលេសកើតហើយក្នុងការដេក ក៏ចូរសង្កត់ក្នុងការដេកនោះឯង ។

កុលបុត្រទាំងនោះ ធ្វើកតិកាវត្តយ៉ាងនេះហើយទៅកិក្ខាចារក្នុងវាងផ្លូវ បានកន្លះឧសភៈ កន្លះគាវុត និងមួយគាវុត មានដុំថ្ម ក៏មនសិការកម្មដ្ឋានតាមសញ្ញានោះឯង ហើយទៅ បើក្នុងការទៅកិលេសកើតឡើងដល់បុគ្គលណា បុគ្គលនោះ ត្រូវសង្កត់កិលេសនោះក្នុងការទៅនោះ បើមិនអាចយ៉ាងនោះក៏ឈរ ។ លំដាប់នោះ បុគ្គលដែលមកឯក្រោយក៏ឈរ ភិក្ខុនោះក៏ដាស់តឿនខ្លួនឯងថា ភិក្ខុនេះ ដឹងវិតក្កដែលកើតឡើងដល់អ្នកហើយ អ្នកធ្វើកម្មមិនសមគួរ ដូច្នេះ ទើបចម្រើនវិបស្សនា ឈានចុះកាន់អរិយភូមិក្នុងទីនោះឯង កាលបើមិនអាចយ៉ាងនោះ ក៏អង្គុយ ។ លំដាប់នោះ អ្នកមកឯក្រោយ ក៏អង្គុយដូចគ្នា ។ កាលមិនអាចឈានចុះកាន់អរិយភូមិ សង្កត់កិលេសនោះ

មនសិការកម្មដ្ឋានទៅ រមែងមិនលើកជើងឡើង ដោយចិត្តប្រាសចាកកម្មដ្ឋាន បើលើកឡើង ក៏ត្រូវត្រឡប់មកកាន់ប្រទេសមុននោះឯង ដូចព្រះមហាបុស្ស-ទេវត្ថេរ ដែលនៅត្រង់អាលិន្ទកៈ ក្នុងតម្ពបណ្ណិទ្វីប ដូច្នោះ ។ បានឮថា ព្រះថេរៈនោះ បំពេញគតបច្ចាគតវត្តយ៉ាងនេះអស់ ១៩ ឆ្នាំ បានឮថា សូម្បីពួកមនុស្ស កាលច្រូតស្រូវ និងបោកបែន ធ្វើការក្នុងរវាងផ្លូវ ឃើញព្រះថេរៈទៅយ៉ាងនោះ ក៏និយាយគ្នាថា ព្រះថេរៈនេះត្រឡប់ទៅរឿយៗ គង់វង្វេងផ្លូវ ឬភ្លេចអ្វីហ្ន៎ លោកមិនដាក់ចិត្តក្នុងរឿងនោះ ធ្វើសមណធម៌ដោយចិត្ត ដែលប្រកបដោយកម្មដ្ឋានប៉ុណ្ណោះ ក៏សម្រេចអរហត្តខាងក្នុងវស្សាទី ២០ ក្នុងថ្ងៃដែលសម្រេចអរហត្ត ទេវតាដែលស្ថិតនៅត្រង់ចុងទីចង្ក្រមរបស់ព្រះថេរៈនោះឈរទ្រលប្រទីប ដោយម្រាមដៃទាំងឡាយ មហារាជទាំង ៤ សក្កទេវរាជ និងសហម្បតីព្រហ្ម ក៏បានទៅកាន់ទីបម្រើព្រះតិស្សថេរៈ អ្នកនៅក្នុងព្រៃ ឃើញពន្លឺនោះ ទើបសួរព្រះថេរៈក្នុងថ្ងៃទី ២ ថា ក្នុងចំណែកនៃរាត្រី មានពន្លឺក្នុងសម្នាក់របស់លោកម្ចាស់ នុ៎ះជាពន្លឺអ្វី ព្រះថេរៈមិនដាក់ចិត្ត ពោលពាក្យជាដើមថា ធម្មតាពន្លឺអាចជាពន្លឺប្រទីបក៏បាន ពន្លឺកែវមណីក៏បាន ព្រះតិស្សត្ថេរនោះសួរថា លោកម្ចាស់បិទបាំងឬ ព្រះមហាបុស្សទេវត្ថេរអារាធនា ទើបយល់ព្រម ហើយបានប្រាប់ ។

និងដូចព្រះថេរៈមួយអង្គទៀត ព្រះនាមថា មហានាគត្ថេរ ជាអ្នកនៅក្នុងកាឡវល្លិមណ្ឌប បានឮថា ព្រះថេរៈនោះបំពេញគតបច្ចាគតវត្ត គិតថា អញ

នឹងបូជាមហាបធាន របស់ព្រះដ៏មានព្រះភាគជាលើកដំបូងសិន ហើយអធិដ្ឋានការដើរចង្ក្រមអស់ ៧ ឆ្នាំ បំពេញគតបច្ចាគតវត្តអស់ ១៦ ឆ្នាំទៀត បានសម្រេចអរហត្ត កាលលើកជើងឡើង ដោយចិត្តប្រកបដោយកម្មដ្ឋានយ៉ាងនេះឯង កាលលើកជើងឡើងដោយចិត្តប្រាសចាកកម្មដ្ឋាន ក៏ត្រឡប់ទៅកាន់ទីជិតស្រុក ឈរក្នុងប្រទេសដែលគប្បីរង្កៀសថា មេគោឬហ្ន៎ បព្វជិតឬហ្ន៎ ដណ្តប់សង្ឃាដិ ឱបបាត្រ ដល់ទ្វារស្រុកហើយ ដងទឹកអំពីប្រឡាយ បៀមក្នុងមាត់ ចូលទៅក្នុងស្រុកដោយតាំងចិត្តថា ចូរការរាយមាយក្នុងកម្មដ្ឋានកុំបីមានដល់អញឡើយ សូម្បីដោយហេតុត្រឹមតែពោលនឹងមនុស្សទាំងឡាយដែលចូលមកដើម្បីប្រគេនភិក្ខា ឬថ្វាយបង្គំថា ចូរអ្នកទាំងឡាយមានអាយុវែងដូច្នេះ ។ បើមនុស្សទាំងឡាយ សួរដល់ថ្ងៃថា បពិត្រលោកម្ចាស់ ថ្ងៃនេះជាថ្ងៃ ៧ ឬថ្ងៃ ៨ លោកក៏ខ្ជាក់ទឹកហើយប្រាប់ បើមិនសួរដល់ថ្ងៃ ក្នុងពេលចេញទៅ ក៏ខ្ជាក់ទឹកត្រង់ទ្វារស្រុកហើយទៅ ។

ភិក្ខុ ៥០ រូប ជាអ្នកចាំវស្សាក្នុងកលម្ពតិដ្ឋវិហារ ក្នុងតម្ពបណ្ណិទ្វីបនោះឯង បានឮថា ភិក្ខុទាំងនោះបានធ្វើកតិកាវត្ត ក្នុងវស្សូបនាយិកាឧបោសថថា ពួកយើង បើមិនសម្រេចអរហត្តហើយ នឹងមិននិយាយគ្នា កាលចូលស្រុកដើម្បីបិណ្ឌបាត ក៏បៀមទឹកត្រង់ទ្វារស្រុកហើយចូលទៅ កាលគេសួរដល់ថ្ងៃ ក៏លេបទឹកហើយប្រាប់ បើមិនមានអ្នកណាសួរដល់ថ្ងៃ ក៏ខ្ជាក់ចោលត្រង់ទ្វារស្រុក ហើយត្រឡប់មកវត្ត ។ មនុស្សទាំងឡាយក្នុងទីទាំងនោះ ឃើញស្នាម

ទឹកដែលលោកខ្ជាក់ចោលក៏ដឹងថា ថ្ងៃនេះលោកនិមន្តមកមួយរូប ថ្ងៃនេះមកពីររូប ដូច្នេះហើយ គិតយ៉ាងនេះថា ភិក្ខុទាំងនោះមិននិយាយជាមួយពួកយើងប៉ុណ្ណោះ ឬក៏មិននិយាយរកគ្នានិងគ្នា បើមិននិយាយរកគ្នាសោត មានតែឈ្លោះទាស់ទែងគ្នា ណ្ហើយចុះ ពួកយើងនឹងឲ្យភិក្ខុទាំងនោះសូមខមាទោសគ្នានិងគ្នាដូច្នេះ អ្នកស្រុកទាំងអស់ក៏នាំគ្នាទៅវត្ត កាលភិក្ខុ ៥០ រូប ចាំវស្សាក្នុងវត្តនោះហើយ ភិក្ខុ ២ រូបមិនទៅរួមគ្នាក្នុងទីតែមួយ ។ បណ្តាមនុស្សទាំងនោះបុរសអ្នកមានបញ្ញា ទើបសួរយ៉ាងនេះថា នែអ្នកទាំងឡាយ ឱកាសសម្រាប់អ្នកឈ្លោះគ្នា រមែងមិនយ៉ាងនេះ លានព្រះចេតិយ លានព្រះពោធិព្រឹក្សក៏ស្អាតល្អ អំបោសទាំងឡាយក៏ទុកដាក់ល្អ ទឹកផឹក ទឹកប្រើប្រាស់ក៏តម្កល់ទុកល្អដូច្នេះ មនុស្សទាំងនោះ ក៏នាំគ្នាត្រឡប់អំពីវត្តនោះ ភិក្ខុទាំងនោះ ប្រារព្ធវិបស្សនាក្នុងវស្សានោះឯង ក៏សម្រេចអរហត្ត ធ្វើវិសុទ្ធិបវារណាក្នុងថ្ងៃមហាបវារណា ។

ភិក្ខុគប្បីដូចព្រះមហានាគត្ថេរ ដែលនៅក្នុងកាឡវល្លិមណ្ឌប និងដូចភិក្ខុទាំងឡាយ ដែលចាំវស្សាក្នុងកលម្ពតិត្ថវិហារយ៉ាងនេះ ឈានជើងដោយចិត្តដែលប្រកបដោយកម្មដ្ឋានប៉ុណ្ណោះ ទៅដល់ទីជិតស្រុក បៀមទឹក សង្កេតផ្លូវដើរទៅកាន់ផ្លូវ ដែលមិនមានពួកជនឈ្លោះទាស់ទែងគ្នា មិនមានពួកអ្នកលេងសុរា អ្នកលេងល្បែងភ្នាល់ជាដើម ឬមិនមានពួកសត្វ មានដំរី និងសេះកាចជាដើម កាលទៅបិណ្ឌបាត ត្រង់ផ្លូវនោះ ក៏មិនទៅដោយប្រញាប់

ប្រញាល់ ដូចមនុស្សប្រញាប់ប្រញាល់ ឈ្មោះថា បិណ្ឌបាតិកធុតង្គ ដោយប្រញាប់ប្រញាល់មិនមាន រមែងដើរទៅ មិនញាប់ញ័រ ដូចគ្នានឹងរទេះដែលផ្ទុកទឹកពេញ ដល់ទីពុំរាបស្មើដូច្នោះ ។ ភិក្ខុនោះ ចូលទៅតាមលំដាប់ផ្ទះហើយ រង់ចាំកាល ដែលសមគួរដល់ផ្ទះនោះ ដើម្បីសង្កេតបំណងអ្នកប្រគេនឬមិនបំណងនឹងប្រគេន ទទួលភិក្ខាហើយ អង្គុយក្នុងឱកាសដែលសមគួរមនសិការកម្មដ្ឋាន ចូលទៅតាំងបដិកូលសញ្ញាក្នុងអាហារ ពិចារណាដោយអំណាចនៃឧបមាដោយប្រេងលាបភ្លៅរទេះ សំពត់រុំដំបៅ និងសាច់កូន ឆាន់អាហារដែលប្រកបដោយអង្គ ៨ មិនឆាន់អាហារដើម្បីលេង ដើម្បីស្រវឹង ។បេ។ ឆាន់ហើយ ក៏ធ្វើកិច្ចដោយទឹក បន្ទោបង់សេចក្តីក្រវល់ក្រវាយដោយភត្តមួយអន្ទាំស្វា មនសិការកម្មដ្ឋានក្នុងកាលខាងក្រោយភត្ត អស់បឋមយាមនិងមជ្ឈិមយាម ដូចក្នុងពេលមុនភត្ត ភិក្ខុនេះ ហៅថា នាំទៅ និងនាំត្រឡប់មក ការនាំកម្មដ្ឋានទៅ និងការនាំកម្មដ្ឋានត្រឡប់នោះ ហៅថា គតបច្ចាគតវត្ត ដោយប្រការដូច្នេះ ។

ភិក្ខុកាលបំពេញគតបច្ចាគតវត្តយ៉ាងនេះ បើជាអ្នកដល់ព្រមដោយឧបនិស្ស័យ នឹងសម្រេចអរហត្តក្នុងបឋមវ័យនោះឯង បើមិនសម្រេចក្នុងបឋមវ័យសោត ក៏សម្រេចក្នុងមជ្ឈិមវ័យ បើមិនសម្រេចក្នុងមជ្ឈិមវ័យសោត ក៏នឹងសម្រេចក្នុងមរណសម័យ បើមិនសម្រេចក្នុងមរណសម័យសោត នឹងបានជាទេវបុត្រ ហើយសម្រេច បើមិនជាទេវបុត្រសម្រេចសោត នឹងបានជាព្រះ

បច្ចេកពុទ្ធ ហើយបរិនិព្វាន បើមិនបានជាព្រះបច្ចេកពុទ្ធបរិព្វានសោត នឹងជាបុគ្គលខិប្បាភិញ្ញា ដូចព្រះពាហិយត្ថេរ ឬលោកអ្នកមានបញ្ញាច្រើន ដូចព្រះសារីបុត្តជាដើម ក្នុងសម្នាក់របស់ព្រះពុទ្ធទាំងឡាយ ។

ព្រះបច្ចេកពោធិសត្វនេះ បួសក្នុងសាសនារបស់ព្រះដ៏មានព្រះភាគព្រះនាមកស្សបៈ ជាអ្នកនៅក្នុងព្រៃជាវត្ត បំពេញគតបច្ចាគតវត្តនោះអស់ ២ម៉ឺនឆ្នាំ ធ្វើកាលកិរិយាហើយកើតក្នុងកាមាវចរទេវលោក ចុតិអំពីទេវលោកហើយ បដិសន្ធិក្នុងគភ៌របស់អគ្គមហេសីនៃព្រះបាទពារាណសី ស្រីទាំងឡាយដែលឈ្លាស រមែងដឹងឋានៈដែលខ្លួនមានគភ៌ក្នុងថ្ងៃនោះឯង អគ្គមហេសីនោះក៏ជាស្រីមួយអង្គ បណ្តាស្រីទាំងនោះឯង ព្រោះហេតុនោះ អគ្គមហេសីនោះកាលជ្រាបហើយ ក៏ក្រាបទូលការតាំងគភ៌នោះដល់ព្រះរាជា ។ ការដែលមាតុគ្រាម ត្រូវសត្វមានបញ្ញាកើតក្នុងគភ៌ រមែងបាននូវការបរិហារគភ៌នោះជាធម្មតា ព្រោះហេតុនោះ ទើបព្រះរាជាទ្រង់ប្រទានការបរិហារគភ៌ដល់ព្រះនាង ។ ចាប់តាំងអំពីនោះ ព្រះនាងមិនបានបរិភោគព្រះក្រយាហារខ្លះ ដែលក្តៅខ្លាំង ត្រជាក់ខ្លាំង ជូរខ្លាំង ប្រៃខ្លាំង ហឹរខ្លាំង ល្វីងខ្លាំង ព្រោះកាលមាតាលេបអាហារក្តៅពេក សត្វដែលនៅក្នុងគភ៌ហាក់ដូចជានៅក្នុងលោហកុម្ភី បើលេបអាហារត្រជាក់ពេក ហាក់ដូចជានៅក្នុងលោកន្តរនរក កាលបរិភោគអាហារដែលជូរពេក ប្រៃពេក ហឹរពេក ល្វីងពេក អវយវៈទាំងឡាយរបស់សត្វដែលនៅក្នុងគភ៌ ក៏មានវេទនាខ្លាំងក្លា ដូចត្រូវកាត់ដោយសស្ត្រា ហើយស្រោច

ដោយទឹកជូរជាដើម ព្រោះហេតុនោះ រាជបុរសទាំងឡាយ ទើបឃាត់ព្រះនាងចាកការបង្ក្រម ការឈរ ការអង្គុយ និងការដេកហួសពេលវេលា ដើម្បីកុំឲ្យសត្វនៅក្នុងគភ៌មានទុក្ខព្រោះការកម្រើក ។ ព្រះនាងរមែងបានធ្វើនូវការបង្ក្រមជាដើម លើផែនដី ល្មមប្រមាណ ដើម្បីប្រយោជន៍ដល់នូវការធ្វើកាយឲ្យទន់ ព្រះនាងតែងបាននូវបាយ និងទឹកដែលល្អ សប្បាយ សម្បូរដោយពណ៌ និងក្លិនជាដើម រាជបុរសកាលកំណត់ហើយ ទើបឲ្យព្រះនាងបង្ក្រមហើយក្រោកឡើង ព្រះនាងបានទទួលការបរិហារព្រះគភ៌យ៉ាងនេះ ។ ក្នុងកាលមានព្រះគភ៌ចាស់ ព្រះនាងចូលកាន់ផ្ទះប្រសូត ប្រសូតព្រះឱរសក្នុងពេលទៀបភ្លឺ ដល់ព្រមដោយធញ្ញលក្ខណៈ និងបុញ្ញលក្ខណៈ ដូចគ្នានឹងដុំមនោសិលា ដែលលាបដោយប្រេង ។ បន្ទាប់អំពីនោះ ក្នុងថ្ងៃទី ៥ រាជបុរសទាំងឡាយ ក៏នាំព្រះរាជឱរសនោះ ដែលប្រដាប់តាក់តែងហើយ ថ្វាយដល់ព្រះរាជា ។

ព្រះរាជាត្រេកអរ ទ្រង់ឲ្យកីលៀង ៦៦ នាក់ចិញ្ចឹមរក្សា ព្រះរាជកុមារចម្រើនដោយសម្បត្តិទាំងពួង អស់កាលមិនយូរឡើយ ដល់នូវភាពជាអ្នកដឹងក្តី ព្រះរាជាទ្រង់អភិសេកព្រះរាជកុមារនោះ ដែលមានព្រះជន្មវស្សា ១៦ ឆ្នាំ ប៉ុណ្ណោះក្នុងរាជសម្បត្តិ ទ្រង់ឲ្យអ្នករបាំ ៣ ប្រភេទបម្រើព្រះរាជកុមារនោះ ព្រះរាជឱរសបានអភិសេកហើយ ទ្រង់គ្រងរាជសម្បត្តិ ដោយព្រះនាមថា ព្រហ្មទត្ត ក្នុងព្រះនគរ ២ ម៉ឺនព្រះនគរក្នុងជម្ពូទ្វីបទាំងមូល ។ ក្នុងកាលមុន

ជម្ពូទ្វីបមាននគរដល់ទៅ ៨៤០០០ នគរ ព្រះនគរទាំងនោះ កាលវិនាស ក៏សល់ត្រឹមតែ ៤ ម៉ឺននគរ តែក្នុងកាលដែលមានសេចក្តីវិនាសគ្រប់យ៉ាង ក៏សល់ត្រឹមតែ ២ ម៉ឺននគរ ។ ព្រះបាទព្រហ្មទត្តនោះ ទ្រង់កើតក្នុងកាលដែលមានការវិនាសគ្រប់យ៉ាង ព្រោះហេតុនោះ ព្រះបាទព្រហ្មទត្តនោះ ទ្រង់មានព្រះនគរ ២ ម៉ឺននគរ ប្រាសាទ ២ ម៉ឺន ដំរី ២ ម៉ឺន សេះ ២ ម៉ឺន រថ ២ ម៉ឺន ទាហានថ្មើរជើង ២ ម៉ឺន អ្នករបាំ ២ ម៉ឺន និងអមាត្យ ២ ម៉ឺន ព្រះបាទព្រហ្មទត្តនោះ ទ្រង់សោយរាជសម្បត្តិ ទ្រង់ធ្វើកសិណបរិកម្មយ៉ាងនេះ ទ្រង់ញុំាងអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតឡើង ព្រោះធម្មតាព្រះរាជាដែលបានអភិសេកហើយ គប្បីប្រថាប់គង់ក្នុងទីដែលធ្វើការវិនិច្ឆ័យក្តីដោយពិត ព្រោះហេតុនោះ ថ្ងៃមួយ ទ្រង់សោយព្រះក្រយាហារព្រឹកហើយ ប្រថាប់គង់ក្នុងរោងវិនិច្ឆ័យក្នុងទីនោះៗ មហាជនបានធ្វើសំឡេងខ្លាំង កងរំពង ទ្រង់មានព្រះរាជតម្រិះថា សំឡេងនេះ ជាឧបក្កិលេសនៃសមាបត្តិ ដូច្នេះ ទ្រង់ឡើងកាន់ប្រាសាទ ប្រថាប់គង់ដោយព្រះរាជតម្រិះថា អញនឹងចូលសមាបត្តិ ក៏មិនអាចចូលបាន សមាបត្តិវិនាសហើយ ព្រោះការរាយមាយក្នុងរាជសម្បត្តិ បន្ទាប់អំពីនោះ ព្រះរាជាក៏ទ្រង់ព្រះតម្រិះថា រាជសម្បត្តិប្រសើរ ឬធម៌ប្រសើរ ។ បន្ទាប់អំពីនោះ ទ្រង់ជ្រាបថា សេចក្តីសុខក្នុងរាជសម្បត្តិ មានបន្តិចបន្តួច មានទោសច្រើន ចំណែកសេចក្តីសុខក្នុងសមណធម៌ មានអានិសង្សច្រើនបរិបូណ៌ ដែលឧត្តមបុរសតែងសេពហើយ ត្រាស់បញ្ជាអមាត្យ

ម្នាក់ថា ចូរអ្នកគ្រប់គ្រងរាជសម្បត្តិនេះ ដោយរាជធម៌ដ៏ស្មើ កុំប្រព្រឹត្តអធម៌ ទ្រង់ប្រគល់រាជសម្បត្តិទាំងអស់ យាងឡើងកាន់ប្រាសាទ ប្រថាប់នៅដោយសេចក្តីសុខក្នុងសមាបត្តិ មិនឲ្យបុគ្គលណាម្នាក់ចូលគាល់ ក្រៅអំពីមហាតលិក ដែលថ្វាយទឹកលុបមុខ ឈើស្ទន់ និងក្រយាហារជាដើម ។

តមកកន្លះខែកន្លងផុតទៅ ព្រះមហេសីត្រាស់សួរថា ព្រះរាជាទ្រង់មិនប្រាកដក្នុងទីណាឡើយ មានការយាងទៅឧទ្យាន ការត្រួតពល និងការមើលរបាំជាដើម ទ្រង់យាងទៅឯណា រាជបុរសទាំងឡាយក្រាបទូលរឿងនោះដល់ព្រះនាង ព្រះនាងបញ្ជូនសារដល់អមាត្យថា បើអ្នកទទួលរាជសម្បត្តិហើយ សូម្បីខ្ញុំ ឈ្មោះថា អ្នកទទួលផងដែរ ព្រោះហេតុនោះ ចូរអ្នកមក ចូរសម្រេចការនៅរួមជាមួយខ្ញុំ អមាត្យនោះបិទត្រចៀកទាំងពីរនោះហើយ ទូលបដិសេធថា អាត្មាអញកុំបីឮរឿងបែបនោះ ព្រះនាងក៏បញ្ជូនសារទៅអស់វារៈ ២ ដង ៣ ដង ព្រះនាងគំរាមអមាត្យដែលមិនប្រាថ្នាថា បើអ្នកមិនព្រមធ្វើ យើងនឹងដកអ្នកពីដំណែង ឬនឹងសម្លាប់អ្នកចោល អមាត្យនោះខ្លាច គិតថា ធម្មតាមាតុគ្រាម មានសេចក្តីប្រាថ្នាខ្លាំងក្លា គប្បីឲ្យគេធ្វើយ៉ាងនេះក្នុងកាលខ្លះក៏បាន ដូច្នេះ ក្នុងថ្ងៃមួយ បានទៅក្នុងទីកំបាំង សម្រេចការនៅរួមជាមួយព្រះនាង លើទីបន្ទំដ៏មានសិរី ព្រះនាងសម្បូរដោយបុណ្យ មានសម្ផស្សជាសុខ អមាត្យនោះត្រូវរាគៈ ដែលកើតអំពីផ្សព្វរបស់ព្រះមហេសីនោះ ចាក់ដោតហើយ ក៏បានលួចទៅរឿយៗ ត្រង់ព្រះដំណាក់របស់ព្រះនាង អមាត្យនោះ អស់សេចក្តី

វង្វៀស ចូលទៅដូចជាម្ចាស់របស់ផ្ទះ របស់ខ្លួនដោយលំដាប់ ។

បន្ទាប់អំពីនោះ ពួករាជបុរសក៏ក្រាបទូលដំណើររឿងនោះដល់ព្រះរាជា ព្រះរាជាទ្រង់មិនជឿ ក៏ក្រាបទូលលើកទី ២ ខ្វះ លើកទី ៣ ខ្វះ លំដាប់នោះ ព្រះរាជាប្រថាប់គង់ ទ្រង់ឃើញដោយព្រះអង្គឯង បានត្រាស់ឲ្យប្រជុំអមាត្យ គ្រប់គ្នា ហើយប្រាប់ដល់រឿងដែលប្រព្រឹត្តទៅនោះ អមាត្យទាំងនោះក្រាបទូល ថា អមាត្យនេះ ធ្វើខុសចំពោះព្រះរាជា សមគួរកាត់ដៃ សមគួរកាត់ជើង ដូច្នេះ បានសម្តែងកម្មករណៈទាំងអស់ តាំងអំពីឲ្យដេកលើលំពែងជាដើម ។ ព្រះរាជាត្រាស់ថា យើងគប្បីកើតការបៀតបៀនព្រោះសម្លាប់ ចង និងវាយ អមាត្យនោះ គប្បីមានបាណាតិបាតព្រោះការផ្តាច់ជីវិត និងគប្បីមានអទិន្នាទាន ព្រោះរឹបអូសយកទ្រព្យ ល្មមលះនូវកម្មបែបនេះដែលអមាត្យនេះធ្វើហើយ អញនឹងដោះអមាត្យនេះ ចាករាជសម្បត្តិរបស់អញ ។ អមាត្យទាំងឡាយ បាននិរទេសអមាត្យនោះហើយ ។ អមាត្យនោះកាន់យកទ្រព្យសម្បត្តិ និងបុត្ត ភរិយារបស់ខ្លួនទៅកាន់ប្រទេសដទៃ ព្រះរាជាក្នុងប្រទេសនោះ ទ្រង់ស្តាប់ ហើយត្រាស់សួរថា ឯងមកធ្វើអ្វី អមាត្យនោះក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំប្រាថ្នាបម្រើព្រះអង្គ ។ ព្រះរាជាអង្គនោះ ទ្រង់ទទួលអមាត្យនោះ អមាត្យបានទទួលនូវការទុកព្រះហឫទ័យ ដោយកាលកន្លងទៅបន្តិចបន្តួច បាន ទូលរឿងនោះនឹងព្រះរាជានោះថា បពិត្រមហារាជ ទូលបង្គំឃើញទឹកឃ្មុំដែល មិនមានរមេ បុគ្គលបរិភោគទឹកឃ្មុំនោះក៏មិនមាន ។ ព្រះរាជាទ្រង់ព្រះរាជ-

តម្រិះថា អមាត្យបំណាងនឹងលលេង ទើបពោលរឿងនោះ ហើយទ្រង់មិនស្តាប់ ។ អមាត្យនោះបានឱកាស ពណ៌នាឲ្យល្អជាងមុនហើយទូលម្តងទៀត ព្រះរាជាត្រាស់ថា អ្នកនិយាយអំពីអ្វី អមាត្យទូលថា គឺរាជសម្បត្តិក្នុងនគរពារាណសី ព្រះរាជាត្រាស់ថា ឯងបំណងនាំយើងទៅឲ្យស្លាប់ឬ អមាត្យនោះទូលថា បពិត្រព្រះសម្មតិទេព ទ្រង់កុំត្រាស់យ៉ាងនោះ បើទ្រង់មិនជឿក៏សូមបញ្ជូនមនុស្សទាំងឡាយទៅ ។ ព្រះរាជាអង្គនោះទ្រង់បញ្ជូនមនុស្សទាំង-ឡាយទៅហើយ មនុស្សទាំងនោះទៅហើយ ជីកត្រង់ខ្លោងទ្វារឡើងព្រះដំណាក់របស់ព្រះរាជា ព្រះរាជាទ្រង់ឃើញហើយត្រាស់សួរថា ពួកអ្នកមកដើម្បីអ្វី ពួកមនុស្សទាំងនោះក្រាបទូលថា បពិត្រមហារាជ ពួកខ្ញុំជាចោរ ព្រះរាជាក៏ត្រាស់ឲ្យប្រទានទ្រព្យដល់ពួកចោរទាំងនោះ ហើយឲ្យឱវាទថា ពួកអ្នកកុំធ្វើយ៉ាងនេះទៀត ហើយទ្រង់ដោះលែងទៅ ពួកមនុស្សទាំងនោះ មកទូលដល់ព្រះរាជារបស់ខ្លួននោះ ព្រះរាជានោះទ្រង់សាកល្បងយ៉ាងនោះឯងអស់ ២-៣ ដង ទ្រង់ព្រះរាជតម្រិះថា ព្រះបាទព្រហ្មទត្តជាអ្នកមានសីល ហើយទ្រង់ត្រៀមចតុរង្គសេនា ចូលកាន់ព្រះនគរមួយ ក្នុងរវាងព្រំដែន ទ្រង់បញ្ជូនរាជ-សាសន៍ឲ្យដល់អមាត្យ ក្នុងនគរនោះថា ទ្រង់ឲ្យនគរដល់ទូលបង្គំ ឬក៏ច្បាំង អមាត្យនោះ ក្រាបទូលសេចក្តីនោះ ដល់ព្រះបាទព្រហ្មទត្តថា តើទ្រង់ច្បាំង ឬក៏ឲ្យព្រះនគរ ។ ព្រះរាជាទ្រង់បញ្ជូនទៅថា យើងមិនច្បាំង យើងនឹងឲ្យនគរ ចូរមកក្នុងទីនេះចុះ អមាត្យនោះបានធ្វើយ៉ាងនោះ ។ ចំណែកព្រះរាជា

ដែលជាបដិបក្ខ ទ្រង់ដណ្ដើមព្រះនគរនោះហើយ ក៏បញ្ជូនទូតទៅកាន់នគរដទៃ សូម្បីក្នុងនគរដ៏សេសទាំងឡាយក៏ធ្វើយ៉ាងនោះ អមាត្យទាំងនោះ ទូលដល់ព្រះបាទព្រហ្មទត្តយ៉ាងនោះ ។ ព្រះរាជាត្រាស់ថា មិនគប្បីច្បាំង គប្បីមកក្នុងទីនេះ ទើបមកកាន់ព្រះនគរពារាណសី បន្ទាប់អំពីនោះ អមាត្យទាំងឡាយទូលដល់ព្រះបាទព្រហ្មទត្តថា បពិត្រមហារាជ ពួកទូលបង្គំនឹងច្បាំងជាមួយព្រះរាជាដែលជាសត្រូវនោះ ។ ព្រះរាជាឃាត់ថា បាណាតិបាតនឹងមានដល់យើង អមាត្យទាំងឡាយទូលឲ្យព្រះរាជាយល់ព្រម ដោយឧបាយផ្សេងៗ ថា បពិត្រមហារាជ ពួកទូលបង្គំនឹងចាប់ព្រះរាជាទាំងនោះទាំងរស់ នាំមកក្នុងទីនេះ ហើយទូលថា បពិត្រមហារាជ សូមទ្រង់យាងមក ដូច្នេះ ក៏ផ្ដើមនឹងទៅ ។ ព្រះរាជាត្រាស់ថា បើពួកអ្នកមិននាំសស្ត្រាទៅ មិនសម្លាប់ និងមិនបៀតបៀន យើងនឹងទៅ ។ អមាត្យទាំងឡាយទូលថា បពិត្រព្រះសម្មតិទេព ពួកទូលបង្គំនឹងមិនធ្វើ នឹងសម្ដែងភ័យ ហើយឲ្យព្រះរាជានោះគេចទៅ ដូច្នេះ ទើបត្រៀមចតុរង្គសេនា អុជប្រទីបទាំងឡាយក្នុងឆ្នាំងទាំងឡាយ ហើយទៅក្នុងរាត្រី។ ព្រះរាជាដែលជាបដិបក្ខ ទ្រង់ដណ្ដើមនគរពារាណសីបានក្នុងថ្ងៃនោះ ទ្រង់ព្រះរាជតម្រិះថា ឥឡូវនេះ យើងនឹងយាមកាមដើម្បីអ្វី ដូច្នោះហើយ ទើបឲ្យលើកការយាមកាមក្នុងរាត្រី ទ្រង់ប្រមាទ ផ្ទំលក់ មួយអន្លើដោយពលនិកាយ ។

លំដាប់នោះ អមាត្យទាំងឡាយ នាំព្រះបាទពារាណសីទៅកាន់បន្ទាយ

ព្រះរាជាដែលជាបដិបក្ខ ហើយពន្លត់ប្រទីបក្នុងផ្ទាំងចោល ហើយបានធ្វើសំឡេងនៃកងទ័ពព្រមគ្នា ។ អមាត្យរបស់ព្រះរាជាដែលជាបដិបក្ខឃើញពល មានកម្លាំងច្រើន គិតភ័យចូលគាល់ព្រះរាជារបស់ខ្លួន ហើយធ្វើសំឡេងខ្លាំងថា សូមទ្រង់តើនឡើង សូមសោយទឹកឃ្មុំដែលមិនមានមេ អមាត្យទី ២ ទី ៣ ក៏បានធ្វើយ៉ាងនោះដូចគ្នា ព្រះរាជាដែលជាសត្រូវ តើនឡើងដោយសំឡេងនោះ ទ្រង់ដល់នូវការខ្លាច ការតក់ស្លុត សំឡេងកងរំពងក៏តាំងឡើងរាប់រយ ព្រះរាជាដែលជាបដិបក្ខនោះ ទ្រង់ព្រះរាជតម្រិះថា យើងជឿពាក្យរបស់អ្នកដទៃ ទើបធ្លាក់ដល់កណ្ដាប់ដៃរបស់សត្រូវ ទ្រង់រវើរវាយដល់ពាក្យនោះៗ អស់ ១ យប់ ក្នុងថ្ងៃទី ២ ទើបទ្រង់គិតបានថា ព្រះបាទព្រហ្មទត្តជាព្រះរាជាដែលទ្រទ្រង់ធម៌ នឹងមិនដាក់ទោស អញនឹងទៅសូមខមាទោសព្រះរាជាអង្គនេះ ហើយទើបយាងចូលទៅគាល់ព្រះរាជា ទ្រង់លុតជង្គង់ទាំងពីរចុះ ហើយក្រាបទូលថា បពិត្រមហារាជ សូមទ្រង់អត់ទោសនូវកំហុសរបស់ទូលបង្គំចុះ ព្រះរាជាទ្រង់ឲ្យឱវាទដល់ចោររាជនោះហើយ ត្រាស់ថា សូមទ្រង់ក្រោកឡើង ខ្ញុំអត់ទោសឲ្យទ្រង់ ។ ព្រះរាជាដែលជាបដិបក្ខនោះ លុះព្រះរាជាត្រាស់ប៉ុណ្ណោះ ក៏ដល់នូវការត្រេកអរក្រៃលែង ទ្រង់បានរាជសម្បត្តិក្នុងជនបទជិតខាងព្រំដែនរបស់ព្រះបាទពារាណសី ទាំងពីរអង្គនោះ បានជាសម្លាញ់នឹងគ្នា ។

កាលនោះ ព្រះបាទព្រហ្មទត្ត ទ្រង់ឃើញសេនាទាំងពីរចំណែកត្រេកអររួមគ្នា ទើបទ្រង់ព្រះរាជតម្រិះថា ដំណក់ឈាមសូម្បីត្រឹមតែមួយចម្អេតរុយ ក៏

មិនកើតក្នុងពួកមហាជននេះ ដើម្បីប្រយោជន៍ដល់ការតាមរក្សាចិត្តរបស់អញតែម្នាក់ ឱល្អពិតហ្ន៎ ឱល្អពិតហ្ន៎ សូមសត្វទាំងពួងមានសេចក្តីសុខចុះ កុំបីមានពៀរ កុំបៀតបៀនគ្នា ដូច្នេះហើយ ទ្រង់ញុំាងមេត្តាឈានឲ្យកើត ឡើងទ្រង់ធ្វើមេត្តាឈាននោះឲ្យជាបាទ ពិចារណាសង្ខារទាំងឡាយ ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ទ្រង់ដល់នូវភាពជាសយម្ភូ ។ អមាត្យទាំងឡាយបានប្រជុំគ្នា ក្រាបទូលដល់ព្រះបាទព្រហ្មទត្តនោះ ជាអ្នកមានសេចក្តីសុខដោយមគ្គសុខ ផលសុខ ប្រថាប់គង់លើកដីថា បពិត្រមហារាជ កាលនេះជាកាលដែលទ្រង់ឡើងកាន់ព្រះយាន សូមទ្រង់ធ្វើសក្ការៈដល់ពួកពលដែលឈ្នះ គប្បីព្រះរាជទានអាហារ និងស្បៀងដល់ពួកពលដែលចាញ់ ព្រះបាទព្រហ្មទត្តនោះត្រាស់ថា នែអ្នក យើងមិនមែនព្រះរាជា យើងជាព្រះបច្ចេកពុទ្ធ អមាត្យទាំងឡាយទូលថា ព្រះអង្គត្រាស់អ្វី ព្រះបច្ចេកពុទ្ធទាំងឡាយមិនមែនដូច្នេះឡើយ ព្រះរាជាត្រាស់សួរថា នែអ្នកទាំងឡាយ ព្រះបច្ចេកពុទ្ធទាំងឡាយដូចម្តេច អមាត្យទាំងឡាយក្រាបទូលថា ជម្មតាព្រះបច្ចេកពុទ្ធទាំងឡាយមានសក់ និងពុកមាត់ ប្រមាណ ២ ធ្នាប់ ទ្រទ្រង់នូវបរិក្ខារ ៨ ។ ព្រះរាជាទ្រង់អង្អែលព្រះសីសៈ ដោយព្រះហស្តស្តាំ រំពេចនោះ ឃរាវាសភេទ ក៏អន្តរធានទៅ បព្វជិតភេទក៏មកជំនួស ទ្រង់មានព្រះកេសា និងព្រះមស្សុប្រមាណ ២ ធ្នាប់ ប្រកបដោយបរិក្ខារ ៨ ដូចគ្នានឹងព្រះថេរៈមានវស្សា ១០០ ទ្រង់ចូលចតុត្ថជ្ឈាន ហោះឡើងអំពីកដី ទៅកាន់អាកាស ប្រថាប់គង់លើផ្កា

ឈូក អមាត្យទាំងឡាយថ្វាយបង្គំ ហើយទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់បំពេញកម្មដ្ឋានអ្វី ទ្រង់សម្រេចដូចម្តេច ព្រះបច្ចេកពុទ្ធទ្រង់ឃើញច្បាស់នូវវិបស្សនា ដែលជាហេតុឲ្យទ្រង់បាននូវមេត្តាឈានកម្មដ្ឋាន ហើយសម្រេច ព្រោះដូច្នោះ កាលព្រះបច្ចេកពុទ្ធសម្តែងសេចក្តីនោះ ទើបត្រាស់ឧទានគាថា ព្យាករណគាថា និងគាថានេះថា **សព្វេសុ ភូតេសុ និធាយ ទណ្ឌំ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **សព្វេសុ** បានដល់ ដែលមិនសេសសល់ ។ បទថា **ភូតេសុ** បានដល់ ក្នុងសត្វទាំងឡាយ សេចក្តីសង្ខេបក្នុងគាថានេះត្រឹមប៉ុណ្ណោះ ចំណែកសេចក្តីពិស្តារ ខ្ញុំនឹងពោលក្នុងរតនសុត្តវណ្ណនា ។ បទថា **និធាយ** បានដល់ ដាក់ហើយ ។ បទថា **ទណ្ឌំ** បានដល់ អាជ្ញាផ្លូវកាយ វាចា និងចិត្ត ។ ពាក្យថា **ទណ្ឌំ** នោះ ជាឈ្មោះនៃទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើម ។ ពិតហើយ កាយទុច្ចរិត ឈ្មោះថា **ទណ្ឌ** ព្រោះអត្ថថា ជាហេតុឲ្យដាក់ទោស អធិប្បាយថា បៀតបៀន គឺឲ្យដល់នូវសេចក្តីវិនាស ។ វចីទុច្ចរិត និងមនោទុច្ចរិតក៏ដូចគ្នា ។ ម្យ៉ាងទៀត ការដាក់ទោសដោយការប្រហារនោះឯង ឈ្មោះថា ទណ្ឌៈ អធិប្បាយថា ដាក់ចុះនូវទណ្ឌៈនោះហើយ ដូច្នេះ ។

បទថា **អវិហេឋយំ** បានដល់ មិនបៀតបៀន ។ បទថា **អញ្ញតរម្បិ** បានដល់ បុគ្គលណានីមួយ ។ បទថា **តេសំ** បានដល់ បណ្តាសត្វទាំងពួងនោះ ។ បទថា **ន បុត្តមិច្ឆេយ្យ** សេចក្តីថា មិនគប្បីប្រាថ្នាកូនណាម្នាក់

ឡើយ ក្នុងកូនទាំង ៤ ពួកនេះ គឺកូនកើតអំពីខ្លួន ១ កូនកើតក្នុងខេត្ត ១ កូនចិញ្ចឹម ១ កូនសិស្ស ១ ។ បទថា **កុតោ សហាយំ** សេចក្តីថា គប្បីប្រាថ្នាសម្លាញ់នោះអំពីណា គឺការប្រាថ្នានោះ គប្បីមានអំពីទីណា ។

បទថា **ឯកោ** សេចក្តីថា ជាបុគ្គលម្នាក់ឯងដោយភេទ ពោល គឺបព្វជ្ជាម្នាក់ឯង ដោយអត្ថថា មិនមានសម្លាញ់ ម្នាក់ឯងដោយការលះតណ្ហា ម្នាក់ឯង ដោយអត្ថថា មានកិលេសប្រាសទៅហើយដោយចំណែកមួយ ម្នាក់ឯងដោយអត្ថថា ត្រាស់ដឹងប្រពៃដោយចំពោះនូវបច្ចេកពោធិញ្ញាណតែម្នាក់ឯង ។ ពិតហើយ បុគ្គលប្រព្រឹត្តទៅក្នុងកណ្តាលសមណៈរាប់ពាន់ ក៏ឈ្មោះថា ម្នាក់ឯង ព្រោះកាត់នូវការជាប់ជំពាក់ ជាមួយគ្រហស្ថចេញបាន ម្នាក់ឯងដោយភេទ ពោល គឺបព្វជ្ជាយ៉ាងនេះ ។ ឈ្មោះថា ម្នាក់ឯង ដោយអត្ថថា ឈរម្នាក់ឯង អង្គុយម្នាក់ឯង ដេកម្នាក់ឯង បួរតិរិយាបថម្នាក់ឯង ប្រព្រឹត្តទៅម្នាក់ឯង ម្នាក់ឯង ដោយអត្ថថា មិនមានសម្លាញ់ យ៉ាងនេះ ឈ្មោះថា ម្នាក់ឯងដោយអត្ថថា លះតណ្ហាយ៉ាងនេះថា

បុរសមានតណ្ហាជាគម្រប់ពីរ អន្ទោលទៅ ( ក្នុងសង្សារវដ្ត )
អស់កាលដ៏វែង រមែងមិនប្រព្រឹត្តកន្លងនូវសង្សារ គឺខន្ធ
ធាតុ អាយតនៈ ដែលមានក្នុងអត្តភាពនេះ និងខាងមុខ ។
លុះភិក្ខុដឹងច្បាស់នូវតណ្ហានេះ ថាជាទោស ជាដែនកើត
ព្រមនៃទុក្ខ ហើយជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តី

ប្រកាន់មាំ មានស្មារតីនៅគ្រប់ឥរិយាបថ ដូច្នេះ ។

ឈ្មោះថា ម្នាក់ឯង ដោយអត្ថថា មានកិលេសប្រាសទៅហើយ ដោយចំណែកមួយយ៉ាងនេះថា

កិលេសទាំងពួង ដែលភិក្ខុនោះលះហើយ មានឫសគល់ត្រូវកាត់ហើយ ដូចដើមត្នោត ។បេ។ មានការមិនកើតឡើងតទៅទៀតជាធម្មតា ។

ឈ្មោះថា ម្នាក់ឯង ដោយអត្ថយ៉ាងនេះថា ជាអ្នកមិនមានអាចារ្យ ដឹងឯង ត្រាស់ដឹងប្រពៃចំពោះនូវបច្ចេកពោធិញ្ញាណ បានដោយខ្លួនឯងនោះឯង ម្នាក់ឯង ដោយអត្ថថា ត្រាស់ដឹងប្រពៃចំពោះនូវបច្ចេកពោធិញ្ញាណយ៉ាងនេះ ។ បទថា **ចរេ** បានដល់ ចរិយា ៨ នេះ គឺឥរិយាបថចរិយា ក្នុងឥរិយាបថ ៤ សម្រាប់បុគ្គលដែលដល់ព្រមដោយបណិធិ ១ អាយតនចរិយា ក្នុងអាយតនៈខាងក្នុងសម្រាប់បុគ្គលមានទ្វាររក្សាហើយ ក្នុងឥន្ទ្រិយទាំងឡាយ ១ សតិចរិយា ក្នុងសតិប្បដ្ឋាន ៤ សម្រាប់បុគ្គលដែលនៅដោយការមិនប្រមាទ ១ សមាធិចរិយា ក្នុងចរិយាក្នុងឈាន ៤ សម្រាប់អ្នកតាមប្រកបនូវអធិចិត្ត ១ ញាណចរិយា ក្នុងអរិយសច្ច ៤ សម្រាប់បុគ្គលដែលដល់ព្រមដោយពុទ្ធិ ១ មគ្គចរិយា ក្នុងអរិយមគ្គ ៤ សម្រាប់អ្នកបដិបត្តិប្រពៃ ១ បត្តិចរិយា ក្នុងសាមញ្ញផល ៤ សម្រាប់បុគ្គលត្រាស់ដឹងនូវផល ១ លោកត្ថចរិយា ក្នុងសត្វទាំងឡាយ សម្រាប់ព្រះពុទ្ធទាំងបី ១ ក្នុងព្រះពុទ្ធទាំងបីនោះ ព្រះបច្ចេក-

ពុទ្ធ និងព្រះសាវ័ក មានលោកគួចរិយាដោយចំណែកខ្លះ សមដូចលោក ពោលថា ពាក្យថា **ចរិយា** បានដល់ ចរិយា ៨ គឺឥរិយាបថចរិយាជាដើម គប្បីជ្រាបសេចក្តីពិស្តារ ។ អធិប្បាយថា គប្បីជាអ្នកដល់ព្រមដោយចរិយា ទាំងនោះ ។ ម្យ៉ាងទៀត ចរិយា ៨ ដទៃទៀត គឺបុគ្គលកាលចុះចិត្តស៊ប់ ឈ្មោះថា ប្រព្រឹត្តដោយសទ្ធា ១ កាលផ្គងឡើង ឈ្មោះថា ប្រព្រឹត្តដោយ វិរិយៈ ១ កាលប្រុងប្រយ័ត្ន ឈ្មោះថា ប្រព្រឹត្តដោយសតិ ១ កាលធ្វើមិន ឲ្យរាយមាយ ឈ្មោះថា ប្រព្រឹត្តដោយសមាធិ ១ កាលដឹងច្បាស់ ឈ្មោះថា ប្រព្រឹត្តដោយប្រាជ្ញា ១ កាលដឹងផ្សេងៗ ឈ្មោះថា ប្រព្រឹត្តដោយវិញ្ញាណ ១ បុគ្គលប្រតិបត្តិយ៉ាងនេះ រមែងបាននូវគុណវិសេស ហេតុនោះ ឈ្មោះថា ប្រព្រឹត្តដោយវិសេសចរិយា ១ កុសលធម៌ទាំងឡាយរបស់បុគ្គល ដែល ប្រតិបត្តិយ៉ាងនេះ រមែងប្រព្រឹត្តក្បៀវក្លា ហេតុនោះ ឈ្មោះថា ប្រព្រឹត្តដោយ អាយតនចរិយា ១ ដូច្នេះ ។

បុគ្គលបដិបត្តិយ៉ាងនេះ រមែងសម្រេចដល់គុណវិសេស ព្រោះហេតុ នោះ ទើបឈ្មោះថា ប្រព្រឹត្តដោយចរិយាវិសេស គប្បីជាអ្នកដល់ព្រមដោយ ចរិយាទាំងនោះ ។ កុយរបស់សត្វរមាស ឈ្មោះថា **ខគ្គវិសាណ** ក្នុងបទថា **ខគ្គវិសាណកប្បោ** នេះ ។ ខ្ញុំនឹងប្រកាសអត្ថនៃ **កប្ប** សព្ទដោយពិស្តារ ក្នុងមង្គលសុត្តវណ្ណនា តែក្នុងខគ្គវិសាណសុត្តវណ្ណនានេះ បណ្ឌិតគប្បីជ្រាប អត្ថថា ជាចំណែកប្រៀបធៀប ដូចក្នុងប្រយោគយ៉ាងនេះជាដើមថា **សត្ថុ-**

**ករោម្បន វត ភោ កិរ សាវកេន សទ្ធឹ មន្តយមានា** ពុទ្ធោអើយ យើងបានប្រឹក្សាជាមួយនឹងសាវក ដែលទុកស្មើនឹងព្រះសាស្តាផងតើ អធិប្បាយថា ជាបុគ្គលដូចគ្នានឹងកុយរមាស ។

ពណ៌នាអត្ថតាមបទក្នុងគាថានេះ មានត្រឹមប្រមាណប៉ុណ្ណេះ តែបណ្ឌិតគប្បីជ្រាបដោយអនុសន្ធិនៃការអធិប្បាយយ៉ាងនេះ អាជ្ញាមានប្រការដូចពោលនេះ ដែលបុគ្គលឲ្យប្រព្រឹត្តទៅ គឺមិនដាក់ក្នុងសត្វទាំងឡាយ កាលបើអាជ្ញានោះ ដែលយើងមិនឲ្យប្រព្រឹត្តទៅក្នុងសត្វទាំងឡាយនោះ យើង ឈ្មោះថាដាក់ចុះនូវអាជ្ញាក្នុងសត្វទាំងពួងហើយដោយមេត្តា ដែលជាបដិបក្ខចំពោះអាជ្ញានោះដោយការនាំចូលមកនូវប្រយោជន៍ដល់អ្នកដទៃ និងព្រោះដាក់ចុះនូវអាជ្ញាបានហើយនោះឯង ឈ្មោះថា មិនបៀតបៀនបណ្តាសត្វទាំងនោះ សូម្បីសត្វណាមួយឲ្យលំបាក ដូចសត្វទាំងឡាយ ដែលមិនទាន់ដាក់ចុះនូវអាជ្ញា រមែងបៀតបៀនសត្វទាំងឡាយដោយដំបងខ្លះ ដោយសស្ត្រាខ្លះ បាតដៃខ្លះ ដុំដីខ្លះ ដូច្នោះ អាស្រ័យមេត្តាកម្មដ្ឋាននេះហើយ ពិចារណាវេទនា សញ្ញា សង្ខារ និងវិញ្ញាណក្នុងសត្វទាំងនោះ និងសង្ខតធម៌ដទៃអំពីនោះ តាមក្រសែនៃមេត្តាកម្មដ្ឋាននោះឯង ទើបបានសម្រេចបច្ចេកពោធិញ្ញាណនេះ ពាក្យអធិប្បាយមានប្រមាណប៉ុណ្ណេះ ។

ចំណែកអនុសន្ធិ មានដូច្នេះថា កាលព្រះបច្ចេកពុទ្ធត្រាស់ដូច្នេះហើយ អមាត្យទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ព្រះអង្គយាង

ទៅក្នុងទីណា លំដាប់នោះ ព្រះបច្ចេកពុទ្ធទ្រង់ពិចារណាថា ព្រះបច្ចេកពុទ្ធក្នុងកាលមុន នៅក្នុងទីណា កាលទ្រង់ដឹងហើយ ទើបត្រាស់ថា ទៅត្រង់ភ្នំគន្ធមាទន៍ អមាត្យក៏ក្រាបទូលទៀតថា បពិត្រព្រះអង្គ ឥឡូវនេះ ទ្រង់បោះបង់មិនប្រាថ្នាពួកទូលបង្គំដូច្នេះ ព្រះបច្ចេកសម្ពុទ្ធត្រាស់ថា បុគ្គលមិនគប្បីប្រាថ្នាបុត្ត ។ អធិប្បាយក្នុងគាថានោះដូច្នេះថា ឥឡូវនេះ យើងមិនប្រាថ្នាបុត្ត សូម្បីណាមួយឡើយ ក្នុងបណ្ដាបុត្តដែលកើតអំពីខ្លួនជាដើម គប្បីប្រាថ្នាសម្លាញ់ដូចពួកលោកអំពីណា ព្រោះហេតុនោះ សូម្បីក្នុងពួកអ្នកទាំងឡាយ អ្នកណាត្រូវការទៅជាមួយយើង ឬដូចជាយើង បុគ្គលនោះ គប្បីត្រាច់ទៅតែម្នាក់ឯងដូចកុយរមាស ដូច្នោះ ។

ម្យ៉ាងទៀត ព្រះបច្ចេកពុទ្ធអង្គនោះដែលអមាត្យទាំងនោះទូលថា បពិត្រព្រះអង្គ ឥឡូវនេះ ព្រះអង្គទ្រង់បោះបង់ ទ្រង់មិនប្រាថ្នាពួកទូលបង្គំឡើយ ទើបត្រាស់ថា យើងមិនប្រាថ្នាបុត្ត គប្បីប្រាថ្នាសម្លាញ់អំពីណា ទ្រង់ឃើញគុណនៃការត្រាច់ទៅតែម្នាក់ឯងរបស់ព្រះអង្គ ដោយអត្ថតាមដែលពោលហើយ ទ្រង់ព្រះបាមោជ្ជ ទ្រង់កើតបីតិសោមនស្ស ទើបត្រាស់ឧទានគាថានេះថា គប្បីត្រាច់ទៅម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ព្រះបច្ចេកពុទ្ធ កាលត្រាស់យ៉ាងនេះហើយ កាលមហាជនសម្លឹងមើលនោះឯង ក៏បានហោះឡើងទៅក្នុងអាកាស យាងទៅកាន់ភ្នំគន្ធមាទន៍ ។ ឈ្មោះថា ភ្នំគន្ធមាទន៍នៅរំលងភ្នំ ៧ ក្នុងហិមវន្តប្បទេស គឺចូឡកាលបព៌ត ១

មហាកាលបពិត ១ នាគបលិវេដ្ឋនាបពិត ១ ចន្ទសម្ភរបពិត ១ សុរិយ-សម្ភរបពិត ១ សុវណ្ណបស្សបពិត ១ និងហិមវន្តបពិត ១ ។ ត្រង់ភ្នំគន្ធ-មាទន៍នោះ មានញកមួយ ឈ្មោះថា នន្ទមូលកៈ ជាទីលំនៅរបស់ព្រះបច្ចេក-ពុទ្ធទាំងឡាយ និងមានគុហា ៣ គឺសុវណ្ណគុហា ១ មណិគុហា ១ រជត-គុហា ១ ។ ត្រង់ភ្នំគន្ធមាទន៍នោះ មានដើមឈើឈ្មោះមញ្ជូសកៈ ត្រង់ទ្វារមណិគុហាកម្ពស់ ១ យោជន៍ ទទឹង ១ យោជន៍ ដើមឈើនោះ រីកស្គុសស្គាយ ទាំងក្នុងទឹក ទាំងលើគោក ដោយវិសេស ក្នុងថ្ងៃដែលព្រះបច្ចេកពុទ្ធនិមន្តមកដល់ខាងមុខដើមឈើនោះ មានរោងរតនៈគ្រប់យ៉ាង ក្នុងរោងរតនៈនោះ មានខ្យល់សម្រាប់បោស រមែងបក់ផាត់សំរាម ខ្យល់សម្រាប់កៀរនូវផែនដី រមែងបក់ខ្សាច់ដែលសម្រេចដោយកែវគ្រប់យ៉ាង ឲ្យរាបស្មើ ខ្យល់សម្រាប់ស្រោច រមែងបក់នាំយកទឹកអំពីអនោតត្តស្រះមកស្រោច ខ្យល់សម្រាប់ធ្វើក្លិនក្រអូប រមែងបក់យកក្លិនក្រអូបរបស់ដើមឈើ ដែលមានក្លិនក្រអូបទាំងអស់ មកអំពីភ្នំហិមពាន្ត ខ្យល់សម្រាប់រោយ រមែងបក់យកផ្កាទាំងឡាយមករោយ ខ្យល់សម្រាប់ក្រាល រមែងក្រាលក្នុងទីទាំងពួង ។ ក្នុងថ្ងៃដែលព្រះបច្ចេកពុទ្ធកើតឡើង និងក្នុងថ្ងៃឧបោសថ ព្រះបច្ចេកពុទ្ធទាំងពួង អង្គុយប្រជុំគ្នាក្នុងទីណា អាសនៈទាំងឡាយ ឈ្មោះថា ក្រាលហើយ ក្នុងទីទាំងនោះសព្វកាល នេះជាប្រក្រតីក្នុងភ្នំគន្ធមាទន៍នោះ ព្រះបច្ចេកពុទ្ធដែលត្រាស់ដឹងឯងដោយចំពោះ បាននិមន្តទៅកាន់ភ្នំគន្ធមាទន៍នោះ ប្រថាប់គង់ក្នុងអាសនៈ

ដែលក្រាលហើយ ។

បន្ទាប់អំពីនោះ បើក្នុងពេលនោះ ព្រះបច្ចេកពុទ្ធដទៃ មានព្រះបច្ចេកពុទ្ធទាំងនោះ ក៏ប្រជុំគ្នាក្នុងខណៈនោះ រមែងអង្គុយលើអាសនៈដែលក្រាលហើយ កាលអង្គុយហើយ ក៏ចូលសមាបត្តិណាមួយ ហើយក៏ចេញ បន្ទាប់អំពីនោះ ព្រះសង្ឃត្ថេរ ក៏សួរកម្មដ្ឋានទីងព្រះបច្ចេកពុទ្ធដែលមកថ្មីថា សម្រេចបានដូចម្តេច ដើម្បីជាប្រយោជន៍ដល់ការអនុមោទនារបស់ព្រះបច្ចេកពុទ្ធទាំងពួង សូម្បីក្នុងកាលនោះ ព្រះបច្ចេកពុទ្ធអង្គនោះ ក៏ត្រាស់ឧទានគាថា និងព្យាករណគាថារបស់លោកនោះឯង សូម្បីព្រះដ៏មានព្រះភាគ កាលព្រះអានន្ទទូលសួរ ក៏ត្រាស់គាថានោះទៀតដូចគ្នា ហើយព្រះអានន្ទ ក៏បានពោលម្តងទៀតក្នុងកាលធ្វើសង្គាយនា ព្រោះហេតុនោះ គាថាមួយ បានពោលដល់ទៅ ៤ ដង គឺក្នុងទីដែលព្រះបាទព្រហ្មទត្តត្រាស់ដឹងដោយប្រពៃ នូវព្រះបច្ចេកពោធិញ្ញាណ ១ ត្រង់មញ្ជូសកមាល ១ ក្នុងកាលដែលព្រះអានន្ទទូលសួរ ១ ក្នុងសង្គីតិ-កាល ១ ដោយប្រការដូច្នេះ ។

**គាថាទី ១ ចប់**

# គាថាទី ២

បទថា **សំសគ្គជាតស្ស** ដូច្នេះ តើមានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះបច្ចេកពោធិសត្វនេះ ធ្វើសមណធម៌ដោយន័យមុននោះឯង ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ព្រះនាមកស្សបៈ អស់ ២ ម៉ឺនឆ្នាំ ក្នុងទីបំផុត ធ្វើកសិណបរិកម្ម ញ៉ាំងបឋមជ្ឈានឲ្យកើតឡើង កំណត់នាម និងរូប ធ្វើការពិចារណាលក្ខណៈ មិនទាន់សម្រេចអរិយមគ្គ កើតក្នុងព្រហ្មលោក ។ ចុតិអំពីព្រហ្មលោកនោះ កើតក្នុងគភ៌អគ្គមហេសីនៃព្រះបាទក្រុងពារាណសី បាននូវការបរិហារដោយន័យមុននោះឯង ។ ចាប់តាំងអំពីនោះ កុមារមិនដឹងការប្លែកគ្នាថា នេះស្ត្រី នេះបុរស ព្រោះអាស្រ័យហេតុនោះ ទើបមិនត្រេកអរក្នុងដៃរបស់ស្ត្រីទាំងឡាយ រមែងមិនអត់ធន់សូម្បីត្រឹមតែការអប់ ការងូត ការប្រដាប់ជាដើម បុរសទាំងឡាយប៉ុណ្ណោះ ជាអ្នកថែរក្សាព្រះរាជកុមារនោះ ក្នុងកាលឲ្យបៅដោះ ពួកមេដោះទាំងឡាយ ក៏ពាក់អាវក្លែងភេទជាបុរស ឲ្យសោយទឹកដោះ កុមារនោះ កាលប៉ះក្លិនរបស់ស្ត្រីទាំងឡាយ ក្រោកឡើងយំ ដឹងក្តីហើយ ក៏មិនប្រាថ្នាដើម្បីពាល់ត្រូវស្ត្រីទាំងឡាយ ដោយហេតុនោះ ទើបញាតិទាំងឡាយថ្វាយនាមរបស់ព្រះរាជកុមារនោះថា អនិត្ថិគន្ធៈ ។

កាលព្រះរាជកុមារនោះ មានព្រះជន្មវស្សាបាន ១៦ ព្រះរាជាទ្រង់ព្រះរាជតម្រិះថា យើងនឹងឲ្យកុមារបន្តវង្សត្រកូល ទ្រង់នាំរាជកញ្ញាដែលសមគួរដល់ព្រះរាជកុមារនោះ អំពីត្រកូលផ្សេងៗ ហើយត្រាស់បញ្ជាអមាត្យម្នាក់ថា ចូរអ្នកឲ្យរាជកុមារត្រេកអរ ។ អមាត្យមានបំណងដើម្បីឲ្យព្រះរាជកុមារនោះ

ត្រេកអរដោយឧបាយទាំងឡាយ ឲ្យអ្នករបាំទាំងឡាយ ប្រលោមលួងលោម ប៉ាំងរាំងនទ ក្នុងទីមិនឆ្ងាយអំពីព្រះរាជកុមារនោះ ឲ្យអ្នករបាំច្រៀងរាំ ។ ព្រះរាជកុមារស្តាប់សំឡេងច្រៀង និងប្រគំ ទើបត្រាស់ថា នុ៎ះសំឡេងរបស់អ្នកណា អមាត្យទាំងឡាយទូលថា បពិត្រព្រះសម្មតិទេព នុ៎ះជាសំឡេងរបស់អ្នករបាំទាំងឡាយរបស់ព្រះអង្គ អ្នកមានបុណ្យទាំងឡាយ រមែងមានអ្នករបាំទាំងឡាយបែបនេះ បពិត្រព្រះសម្មតិទេព ទ្រង់មានបុណ្យច្រើន សូមទ្រង់អភិរម្យ ។ ព្រះរាជកុមារ ទ្រង់វាយអមាត្យដោយដំបង ឲ្យដេញចេញទៅ ។ អមាត្យនោះ ក្រាបទូលដល់ព្រះរាជា ។ បានត្រាស់បញ្ជាអមាត្យទៀតថា ចូរអ្នកទៅជាមួយព្រះមាតារបស់កុមារ ហើយឲ្យកុមារត្រេកអរ ។

ព្រះរាជកុមារនោះ ត្រូវមនុស្សទាំងនោះរំខានក្រៃលែង ទើបបានប្រទានមាសដ៏ប្រសើរ ហើយត្រាស់នឹងពួកជាងមាសថា អ្នកទាំងឡាយ ចូរប្រាប់ពួកជាងមាសថា លោកទាំងឡាយ ចូរធ្វើរូបស្ត្រីឲ្យស្អាត ពួកជាងមាសទាំងនោះ ក៏បានធ្វើរូបស្ត្រី ដែលប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ដូចគ្នានឹងវិស្សកម្មនិម្មិត ហើយបង្ហាញដល់ព្រះរាជកុមារ ។ ព្រះរាជកុមារទតហើយ ងក់ក្បាលដោយភាពអស្ចារ្យ បញ្ជូនទៅឲ្យដល់ព្រះមាតា និងព្រះបិតាដោយព្រះតម្រាស់ថា បើទូលបង្គំបានស្រីបែបនេះ នឹងព្រមទទួល ព្រះមាតា និងព្រះបិតាក៏ត្រិះរិះថា កូនរបស់យើងមានបុណ្យច្រើន ទារិកាណាមួយ ដែលធ្លាប់ធ្វើបុណ្យរួមជាមួយបុត្រនោះ នឹងកើតហើយក្នុងលោកពិត ដូច្នេះហើយ

ទើបលើករូបមាសនោះឡើងកាន់រថ ត្រាស់ដល់អមាត្យទាំងឡាយថា ចូរអ្នកទៅចុះ អ្នកគប្បីស្វែងរកទារិកាបែបនេះ ។

អមាត្យទាំងនោះ នាំរូបមាសទៅកាន់ជនបទទាំង ១៦ ទៅកាន់ស្រុកនោះៗ ឃើញប្រជុំជនក្នុងទីណា មានកំពង់ទឹកជាដើម ទើបតាំងរូបមាសធ្វើដូចទេវតា ក្នុងទីនោះៗ ធ្វើការបូជាដោយផ្កា និងគ្រឿងអលង្ការច្រើនប្រភេទ ចងពិដាន ឈរក្នុងទីបំផុតនាចំណែកម្ខាង ដោយគិតថា បើមានអ្នកណាមួយធ្លាប់ឃើញ ធ្លាប់បានឮស្ត្រីដែលមានរូបស្អាតបែបនេះសោត គេនឹងពោលឡើងដូច្នេះហើយ ត្រាច់ទៅក្នុងជនបទទាំងពួង ដោយឧបាយនោះ វៀរមទ្ទរដ្ឋមួយដោយមើលងាយថា មទ្ទរដ្ឋនោះ ជារដ្ឋតូចតាច មិនទៅក្នុងមទ្ទរដ្ឋនោះមុនឡើយ ហើយត្រឡប់ ។ លំដាប់នោះ អមាត្យទាំងនោះ មានការគិតថា ពួកយើងត្រូវទៅកាន់មទ្ទរដ្ឋ សូមព្រះរាជាកុំបីបញ្ជូនពួកយើង ដែលចូលទៅកាន់ក្រុងពារាណសីទៀត ដូច្នេះ ទើបទៅកាន់សាគលនគរ ក្នុងមទ្ទរដ្ឋ ។

ក្នុងសាគលនគរនោះ មានព្រះរាជាព្រះនាមមទ្ទវៈ ព្រះរាជធីតារបស់ព្រះបាទមទ្ទវៈនោះ មានព្រះជន្ម ១៦ ឆ្នាំ មានរូបល្អពន់ពេក នាងវណ្ណទាសីរបស់ព្រះរាជធីតានោះ ក៏ទៅកាន់កំពង់ទឹកដើម្បីប្រយោជន៍ដល់ការដងទឹកងូតឃើញរូបបដិមាមាសនោះ ដែលអមាត្យទាំងឡាយ តម្កល់ក្នុងទីនោះអំពីចម្ងាយក៏ពោលថា ព្រះរាជបុត្រីបញ្ជូនពួកយើងមក ដើម្បីប្រយោជន៍ដល់ទឹក តែបែរជាយាងមកឯង ហើយចូលទៅជិត ពោលថា ស្រីនេះមិនមែនម្ចាស់របស់

ពួកយើង ម្ចាស់របស់ពួកយើងស្អាតក្រៃលែងជាងស្រីនេះ ពួកអមាត្យបាន ស្តាប់ដូច្នេះហើយ ចូលទៅគាល់ព្រះរាជាទូលសូមទារិកា ដោយន័យដែល សមគួរ ព្រះរាជានោះក៏ទ្រង់ព្រះរាជទាន ។ បន្ទាប់អំពីនោះ ពួកអមាត្យបាន បញ្ជូនដំណឹងទូលដល់ព្រះបាទពារាណសីថា រកទារិកាបានហើយ ទ្រង់នឹងយាង មកឯង ឬពួកទូលបង្គំនាំមកដូច្នេះ ព្រះរាជាបញ្ជូនដំណឹងទៅថា កាលយើង ទៅជាការបៀតបៀនជនបទ ពួកលោកប៉ុណ្ណោះ ចូរនាំទារិកានោះមក ។

អមាត្យទាំងឡាយ នាំទារិកាចេញអំពីនគរ បញ្ជូនដំណឹងទៅថ្វាយព្រះ រាជកុមារថា ទារិកាដូចគ្នានឹងរូបមាសរកបានហើយ ។ ព្រះរាជកុមារបានស្តាប់ ដំណឹងនោះ ត្រូវរាគៈគ្របសង្កត់ សាបសូន្យបឋមជ្ឈាន ទ្រង់បញ្ជូនទូតជាទៃៗ ទៅថា ពួកអ្នក ចូរនាំនាងមកឲ្យឆាប់ ពួកអ្នក ចូរនាំនាងមកឲ្យរហ័ស ។

ពួកអមាត្យនោះ ដល់ក្រុងពារាណសីដោយសម្រាកត្រឹមមួយយប់ប៉ុណ្ណោះ ក្នុងទីទាំងពួង ឈរខាងក្រៅព្រះនគរ បញ្ជូនដំណឹងថ្វាយព្រះរាជាថា គប្បីចូល ទៅក្នុងថ្ងៃនេះ ឬមិនទៅ ព្រះរាជាត្រាស់ថា យើងនាំទារិកាមកអំពីត្រកូល ប្រសើរបំផុត ធ្វើមង្គលកិរិយាហើយ នឹងឲ្យចូលមកដោយសក្ការៈធំ ពួកអ្នក ចូរនាំទារិកានោះទៅកាន់ឧទ្យានមុន អមាត្យទាំងនោះ បានធ្វើតាមព្រះរាជឱង្ការ ហើយ ។ ទារិកានោះ ជាស្រីសុខុមាលជាតិក្រៃលែង ទ្រុឌទ្រោមហើយ ព្រោះ ការរលាក់នៃយាន មានរោគខ្យល់កើតឡើង ព្រោះភាពជាអ្នកធ្វើដំណើរឆ្ងាយ ក៏ធ្វើកាលកិរិយាក្នុងយប់នោះឯង ដូចផ្កាឈើដែលស្វិតស្រពោនទៅដូច្នោះ ។

ពួកអមាត្យខ្សឹកខ្សួលថា ពួកយើងវិនាសហើយចាកសក្ការៈ ព្រះរាជាក្តី អ្នកនគរក្តីក៏នាំគ្នាខ្សឹកខ្សួលថា ត្រកូលវង្សវិនាសហើយ កោលាហលធំមានហើយក្នុងព្រះនគរ ។ ព្រះរាជកុមារគ្រាន់តែបានស្តាប់ប៉ុណ្ណោះ ក៏ទ្រង់កើតការសោកសៅធំក្រៃលែង បន្ទាប់អំពីនោះ ព្រះរាជកុមារក៏ប្រារព្ធដើម្បីដកឫសគល់នៃសេចក្តីសោក ទើបទ្រង់ត្រិះរិះថា ធម្មតាសេចក្តីសោកនេះ រមែងមិនមានដល់អ្នកមិនកើត តែរមែងមានដល់អ្នកដែលកើតហើយ ព្រោះហេតុនោះសេចក្តីសោកមាន ព្រោះអាស្រ័យជាតិ ឯជាតិមាន ព្រោះអាស្រ័យអ្វីហ្ន៎ បន្ទាប់អំពីនោះ ទ្រង់មនសិការដោយឧបាយ ដោយអានុភាពនៃការនាក្នុងកាលមុនយ៉ាងនេះថា ជាតិមាន ព្រោះអាស្រ័យភព ទ្រង់ឃើញបដិច្ចសមុប្បាទដោយអនុលោម និងបដិលោម ទ្រង់ពិចារណាសង្ខារទាំងឡាយ ប្រថាប់គង់ក្នុងទីនោះឯង ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ។ អមាត្យទាំង-ឡាយឃើញព្រះរាជកុមារនោះ ទ្រង់មានសេចក្តីសុខ ដោយសេចក្តីសុខដែលកើតអំពីមគ្គផល មានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ប្រថាប់នៅ ទើបផ្គងអញ្ជលីទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់កុំសោយសោកឡើយ ជម្ពូទ្វីបនេះធំធេង ទូលបង្គំនឹងនាំទារិកាដទៃមក ដែលស្អាតជាងនេះ ។ ព្រះរាជកុមារត្រាស់ថា យើងមិនសោកស្តាយ តែអស់សេចក្តីសោកស្តាយហើយ យើងជាព្រះបច្ចេកពុទ្ធ ។ ពាក្យទាំងអស់ បន្ទាប់អំពីនេះ ដូចគ្នានឹងគាថាដំបូង វៀរតែកិច្ចពណ៌នានៃគាថា ។

ក្នុងពណ៌នាគាថា បទថា **សំសគ្គជាតស្ស** បានដល់ ដល់អ្នកកើតនូវការប្រឡូកប្រឡំ ។ ក្នុងគាថានោះ ការប្រឡូកប្រឡំមាន ៥ យ៉ាង គឺ **ទស្សនសំសគ្គ** ប្រឡូកប្រឡំព្រោះការឃើញ ១ **សវនសំសគ្គ** ប្រឡូកប្រឡំព្រោះការស្ដាប់ ១ **កាយសំសគ្គ** ប្រឡូកប្រឡំតាមផ្លូវកាយ ១ **សមុល្លាបនសំសគ្គ** ការប្រឡូកប្រឡំព្រោះការសន្ទនា ១ **សម្ភោគសំសគ្គ** ប្រឡូកប្រឡំព្រោះបរិភោគរួម ១ ។

ក្នុងសំសគ្គៈ ៥ យ៉ាងនោះ រាគៈកើតដោយអំណាចនៃចក្ខុវិញ្ញាណវិថី ព្រោះឃើញនូវគ្នានិងគ្នា ឈ្មោះថា ទស្សនសំសគ្គ ។ ធីតារបស់កុដុម្ពិកៈមានចិត្តស្រឡាញ់ ព្រោះឃើញភិក្ខុកំលោះឈ្មោះទីឃភាណកៈ ដែលនៅក្នុងកល្យាណវិហារ ដែលកំពុងទៅកាន់កាឡទីឃវាបិគាម ដើម្បីបិណ្ឌបាត ក្នុងសីហលទ្វីប មិនបានភិក្ខុកំលោះនោះ ដោយឧបាយណាមួយ ក៏ធ្វើកាលកិរិយា ភិក្ខុកំលោះរូបនោះឯង ឃើញសំពត់ស្លៀករបស់ធីតានោះ ក៏គិតថា អញមិនបាននៅរួមជាមួយនាង ដែលស្លៀកសំពត់បែបនេះ បេះដូងក៏បែក ជាឧទាហរណ៍ ក្នុងទស្សនសំសគ្គៈនេះ ។

រាគៈកើតឡើងដោយអំណាចនៃសោតវិញ្ញាណវិថី ព្រោះស្ដាប់សម្បត្តិមានរូបជាដើម ដែលអ្នកដទៃទាំងឡាយនិយាយ ឬព្រោះខ្លួនបានស្ដាប់សំឡេងសើច សំឡេងចរចា សំឡេងច្រៀង ឈ្មោះថា សវនសំសគ្គៈ ។ ក្នុងសវនសំសគ្គៈនោះ ភិក្ខុកំលោះឈ្មោះតិស្សៈ នៅក្នុងគុហាបញ្ចគ្គឡៈ កំពុង

ហោះតាមអាកាស បានស្តាប់សំឡេងរបស់ធីតាជាងមាស ដែលនៅក្នុងគិរិគាម ទៅកាន់ស្រះឈូក មួយអន្ទើដោយកុមារី ៥ នាក់ ងូតទឹកហើយលើកផ្កាច្រៀងដោយសំឡេងខ្លាំង ក៏សាបសូន្យចាកគុណវិសេសព្រោះកាមរាគដល់នូវសេចក្តីវិនាសជាគំរូ ។

រាគៈកើតព្រោះស្ទាបអវយវៈនៃគ្នានិងគ្នា ឈ្មោះថា កាយសំសគ្គៈ ក្នុងកាយសំសគ្គៈនេះ មានភិក្ខុកំលោះឈ្មោះធម្មភាសកៈជាគំរូ ។ បានឮថា ភិក្ខុកំលោះសម្តែងធម៌ក្នុងមហាវិហារ កាលមហាជនមកក្នុងមហាវិហារនោះ សូម្បីព្រះរាជាក៏យាងទៅព្រមជាមួយអ្នករាជវាំង បន្ទាប់អំពីនោះ រាគៈដ៏ខ្លាំងក្លាបានកើតដល់ព្រះរាជធីតា ព្រោះអាស្រ័យរូប និងសំឡេងរបស់ភិក្ខុកំលោះនោះ និងកើតដល់ភិក្ខុកំលោះរូបនោះ ព្រះរាជាទ្រង់ឃើញហេតុនោះ ទ្រង់កំណត់ហើយ បានព័ទ្ធដោយកំពែង គឺវាំងនន ជនទាំងពីរនោះ ក៏ឱបក្រសោបនូវគ្នានិងគ្នា ជនទាំងឡាយបើកវាំងននមើល ក៏ឃើញជនទាំងពីរដល់នូវការស្លាប់ហើយ ។

រាគៈកើតព្រោះការសន្ទនាប្រាស្រ័យគ្នានិងគ្នា ឈ្មោះថា សមុល្លាបនសំសគ្គៈ ។ រាគៈកើតព្រោះការបរិភោគនឹងភិក្ខុនីទាំងឡាយ ឈ្មោះថា សម្ភោគសំសគ្គៈ ។ ក្នុងសំសគ្គៈទាំងពីរនោះ មានភិក្ខុ និងភិក្ខុនី ដល់នូវអាបត្តិបារាជិកជាគំរូ ។ បានឮថា ក្នុងការឆ្លងមហាវិហារ ឈ្មោះមរិចិវដ្តកៈ ព្រះបាទទុដ្ឋគាមណីអភយមហារាជ ទ្រង់ចាត់ចែងមហាទាន អង្គាសព្រះសង្ឃ

ទាំងពីរចំណែក ក្នុងការធ្វើមហាវិហារនោះ កាលប្រគេនបបរក្តៅ សាមណេរី ដែលថ្មីក្នុងសង្ឃ បានប្រគេនរង្វើលក្អកដល់សាមណេរ ដែលបួសថ្មីក្នុងសង្ឃ ដែលមិនមានជើងបាត្រ បានធ្វើការចរចាប្រាស្រ័យគ្នា លោកទាំងពីរអង្គនោះ ឧបសម្បទាហើយបាន ៦០ វស្សា ទៅកាន់ត្រើយនាយ បានទទួលបុព្វសញ្ញា ព្រោះការចរចាប្រាស្រ័យគ្នានិងគ្នា ក៏កើតស្នេហា ក្នុងវេលានោះឯង ប្រព្រឹត្ត ល្មើសសិក្ខាបទ ត្រូវអាបត្តិបារាជិក ដោយប្រការដូច្នេះ ។

សំសគ្គៈរមែងមានដល់បុគ្គល ដែលប្រឡូកប្រឡំគ្នាដោយសំសគ្គៈណាមួយ ក្នុងសំសគ្គៈ ៥ យ៉ាង រាគៈដែលមានកម្លាំងរមែងកើតឡើង ព្រោះរាគៈក្នុងកាលមុនជាបច្ច័យ ដោយប្រការដូច្នេះ ។ បន្ទាប់អំពីនោះ ទុក្ខនេះ រមែងកើតឡើងតាមការជាប់ជំពាក់ គឺទុក្ខនេះ មានប្រការផ្សេងៗ មានសេចក្តីសោក និងសេចក្តីខ្សឹកខ្សួលជាដើម ទាំងដែលជាទិដ្ឋធម៌ និងសម្បរាយិកភព រមែងកើតឡើង គឺរមែងកើតឡើង រមែងមាន រមែងកើតជាប់តាមសំសគ្គៈនោះឯង ។ ចំណែកអាចារ្យពួកដទៃពោលថា បានដល់ ការបណ្តោយចិត្តក្នុងអារម្មណ៍ បន្ទាប់អំពីនោះ ទុក្ខរមែងកើតឡើងព្រោះការជាប់ជំពាក់ដូច្នេះឯង ។

ព្រះបច្ចេកពុទ្ធនោះ កាលត្រាស់អត្ថគាថានេះ មានប្រភេទនៃអត្ថយ៉ាងនេះហើយ ទើបត្រាស់ថា ទុក្ខ មានសេចក្តីសោកជាដើមនេះ រមែងកើតឡើងតាមការប្រឡូកប្រឡំ អាត្មាអញបានជីកឫសគល់របស់ទុក្ខនោះ ទើបសម្រេចបច្ចេកសម្ពោធិញ្ញាណ កាលត្រាស់យ៉ាងនេះហើយ អមាត្យទាំងនោះក៏ទូលថា

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកទូលបង្គំគប្បីធ្វើដូចម្ដេច លំដាប់នោះ ព្រះបច្ចេកពុទ្ធត្រាស់ថា ពួកអ្នក ឬពួកអ្នកដទៃ អ្នកណាចង់ផុតចាកទុក្ខនេះ អ្នកនោះសម្លឹងឃើញទោស ដែលកើតអំពីការប្រឡូកប្រឡំ គប្បីត្រាច់ទៅម្នាក់ឯង ដូចកុយរមាស ដូច្នោះ ។

ពាក្យថា សម្លឹងឃើញនូវទោស ដែលកើតអំពីការប្រឡូកប្រឡំនេះ គប្បីជ្រាបថា លោកពោលសំដៅយកពាក្យដែលព្រះបច្ចេកពុទ្ធត្រាស់ថា ទុក្ខនេះរមែងកើតឡើងតាមការប្រឡូកប្រឡំ ។ ម្យ៉ាងទៀត គប្បីភ្ជាប់សេចក្ដីយ៉ាងនេះថា ការប្រឡូកប្រឡំ រមែងមានដល់បុគ្គលដែលមានការប្រឡូកប្រឡំកើតឡើងហើយ ដោយការប្រឡូកប្រឡំតាមដែលពោលហើយ ទុក្ខនេះ រមែងកើតឡើងតាមការប្រឡូកប្រឡំ យើងសម្លឹងឃើញទុក្ខនេះ ដែលកើតអំពីការប្រឡូកប្រឡំ ដែលធ្វើនូវការចាក់ដោតជាប់តាមមក ទើបសម្រេចដូច្នេះ ។ គប្បីជ្រាបថា បាទទី ៤ ព្រះបច្ចេកពុទ្ធត្រាស់ហើយ ដោយអំណាចនៃឧទាន ដោយន័យដែលពោលហើយខាងដើមនោះឯង ពាក្យទាំងពួង ក្រៅអំពីនោះ ដូចគ្នាតាមដែលពោលហើយក្នុងគាថាទី ១ នោះឯង ៗ១៚

**សំសគ្គគាថា ចប់**

## គាថាទី ៣

គាថាថា **មិត្តេ សុហជ្ជេ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះបច្ចេកពោធិសត្វនេះ កើតដោយន័យដែលពោលហើយ ក្នុងគាថាដំបូងនោះឯង សោយរាជសម្បត្តិក្នុងនគរពារាណសី ញ៉ាំងបឋមជ្ឈានឲ្យកើតហើយ ទ្រង់ពិចារណាថា សមណធម៌ប្រសើរ ឬរាជសម្បត្តិប្រសើរហ្ន៎ ទ្រង់ប្រគល់រាជសម្បត្តិក្នុងដៃរបស់អមាត្យ ៤ នាក់ ហើយទ្រង់ធ្វើសមណធម៌ អមាត្យទាំងឡាយ សូម្បីព្រះរាជាត្រាស់ថា ចូរអ្នកទាំងឡាយធ្វើដោយធម៌ដោយស្មើ ក៏ទទួលសំណូកធ្វើដោយអធម៌ អមាត្យទាំងនោះមិនបានសំណូកក៏ធ្វើដោយអធម៌ ទទួលសំណូកហើយ ធ្វើម្ចាស់ទ្រព្យទាំងឡាយឲ្យចាញ់ ។ ក្នុងពេលមួយ ធ្វើរាជវល្លភៈម្នាក់ឲ្យចាញ់ រាជវល្លភៈនោះចូលទៅគាល់ជាមួយពួកក្អាក់ងារអ្នកនាំព្រះក្រយារបស់ព្រះរាជា ទូលរឿងទាំងអស់ ក្នុងថ្ងៃទី ២ ព្រះរាជាយាងទៅកាន់ទីវិនិច្ឆ័យដោយព្រះអង្គឯង បន្ទាប់អំពីនោះ ពួកមហាជន បានស្រែកដោយសំឡេងខ្លាំងថា ពួកអមាត្យ ធ្វើម្ចាស់ទ្រព្យឲ្យមិនជាម្ចាស់ទ្រព្យ បានធ្វើសំឡេងខ្លាំងដូចមហាចម្បាំង ។

លំដាប់នោះ ព្រះរាជាទ្រង់ក្រោកចាកអំពីទីវិនិច្ឆ័យ យាងឡើងទៅកាន់ប្រាសាទ ប្រថាប់គង់ដើម្បីចូលសមាបត្តិ តែមិនអាចចូលបាន ព្រោះទ្រង់រាយមាយដោយសំឡេងនោះ ទ្រង់ពិចារណាថា ប្រយោជន៍អ្វីរបស់អញដោយរាជសម្បត្តិ សមណធម៌ប្រសើរជាង ដូច្នេះហើយ ទ្រង់លះបង់សេចក្ដីសុខក្នុងរាជសម្បត្តិ ទ្រង់ញ៉ាំងសមាបត្តិឲ្យកើតឡើងទៀត ទ្រង់ពិចារណាឃើញ

ដោយន័យដែលពោលក្នុងគាថាមុននោះឯង ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេក-ពោធិញ្ញាណ ហើយត្រូវសួរដល់កម្មដ្ឋាន បានត្រាស់គាថានេះថា

បុគ្គលអ្នកមានចិត្តប្រតិព័ទ្ធ កាលអនុគ្រោះនូវពួកមិត្ត ដែលមានចិត្តល្អ រមែងញុំាងប្រយោជន៍ឲ្យសាបសូន្យ បុគ្គលកាលឃើញនូវភ័យក្នុងការមូលមិត្តគ្នាទុំះហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ក្នុងគាថានោះ មនុស្សទាំងឡាយ ឈ្មោះថា មិត្ត ដោយអំណាចនៃការស្រឡាញ់ ឈ្មោះថា សម្លាញ់ ព្រោះភាពជាអ្នកមានចិត្តល្អ ។ បុគ្គលពួកខ្លះ ជាមិត្តប៉ុណ្ណោះ មិនជាសម្លាញ់ ព្រោះភាពជាអ្នកប្រាថ្នាប្រយោជន៍តែម្យ៉ាង ពួកខ្លះ ជាសម្លាញ់ប៉ុណ្ណោះ មិនជាមិត្ត ព្រោះកើតសុខផ្លូវចិត្តក្នុងកិច្ចទាំង-ឡាយ មានការមក ការឈរ ការអង្គុយ និងការចរចាជាដើម ពួកខ្លះ ជាសម្លាញ់ផង ជាមិត្តផង ដោយអំណាចនៃធម៌ទាំងពីរនោះ មិត្តសម្លាញ់ទាំងនោះ មាន ២ ពួក គឺឃរាវាស ១ បព្វជិត ១ ។ ក្នុងពីរពួកនោះ ឃរាវាសមាន ៣ ពួក គឺអ្នកមានឧបការៈ ១ អ្នករួមសុខរួមទុក្ខ ១ អ្នកអនុគ្រោះ ១ ។ បព្វជិតដោយវិសេស គឺជាអ្នកប្រាប់ប្រយោជន៍ ។ មិត្តសម្លាញ់ទាំងនោះប្រកបដោយ អង្គ ៤ យ៉ាងនេះ សមដូចព្រះដ៏មានព្រះភាគត្រាស់ក្នុង ( សិង្គាលកសូត្រ ) ថា

ម្នាលគហបតិបុត្ត មិត្តមានឧបការៈ ជាមិត្តមានសន្ដានល្អ អ្នក

ត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺរក្សាមិត្តដែលធ្វេសប្រហែស ១ រក្សាសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស ១ ជាទីពឹងពំនាក់នៃមិត្តដែលមានសេចក្តីកិតភ័យ ១ កាលបើកិច្ចដែលត្រូវធ្វើកើតឡើងហើយ តែងជួយផ្តល់ភោគៈជាទ្វិគុណជាងទ្រព្យដែលមិត្តត្រូវការនោះ ១ ដូច្នេះ ។

ម្នាលគហបតិបុត្ត មិត្តរួមសុខទុក្ខ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺប្រាប់នូវអាថ៌កំបាំងរបស់ខ្លួនដល់មិត្ត ១ ជួយបិទបាំងនូវអាថ៌កំបាំងរបស់មិត្ត ១ មិនបោះបង់គ្នាក្នុងគ្រាមានវិបត្តិ ១ សូម្បីជីវិតក៏ហ៊ានលះបង់ ដើម្បីប្រយោជន៍ដល់មិត្ត ( ស៊ូប្តូរជីវិត ) ១ ដូច្នេះ ។

ម្នាលគហបតិបុត្ត មិត្តប្រាប់ប្រយោជន៍ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺហាមមិត្តឲ្យឃ្លាតចាកអំពើអាក្រក់ ១ ដឹកនាំឲ្យមិត្តតម្កល់នៅតែក្នុងអំពើល្អ ១ ឲ្យបានឮពាក្យដែលមិនធ្លាប់បានឮ ១ ប្រាប់ផ្លូវស្ថានសួគ៌ ១ ដូច្នេះ ។

ម្នាលគហបតិបុត្ត មិត្តមានសេចក្តីឈឺឆ្អាល ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺជួយព្រួយចិត្តពីព្រោះមិត្តបានសេចក្តីវិនាស ១ ជួយត្រេកអរព្រោះមិត្តបានសេចក្តីចម្រើន ១ ទទឹងទាស់នឹងមនុស្ស ដែលពោលទោសមិត្ត ១ សរសើរតែ

មនុស្សដែលពណ៌នាគុណមិត្ត ១ ដូច្នេះ ។

ព្រោះហេតុនោះ យាវាស លោកបំណាងយកក្នុងទីនេះ តែដោយអត្ថ យាវាស និងបព្វជិតទាំងអស់ ក៏គួរ បានដល់ មិត្តសម្លាញ់ដែលពោលមក ទាំងនោះ ។ បទថា **អនុកម្បាមានោ** សេចក្តីថា អាណិតអាសូរ គឺបំណង ដើម្បីនាំចូលមកនូវសេចក្តីសុខដល់មិត្តសម្លាញ់ទាំងនោះ ។ បទថា **ហាបេតិ អត្ថំ** សេចក្តីថា ញ៉ាំងប្រយោជន៍ ៣ យ៉ាង គឺទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍ឲ្យវិនាស គឺឲ្យវិនាស ម្យ៉ាង ទៀត ញ៉ាំងប្រយោជន៍ ៣ យ៉ាង គឺប្រយោជន៍របស់ខ្លួន ប្រយោជន៍អ្នកដទៃ និងប្រយោជន៍ទាំងពីរយ៉ាងនោះឲ្យវិនាស គឺឲ្យវិនាស ដោយវិធីទាំងពីរ គឺ ដោយការញ៉ាំងវត្ថុដែលបានហើយឲ្យវិនាស និងដោយការមិនឲ្យកើតនូវវត្ថុ ដែលមិនទាន់បាន ។ បទថា **បដិពទ្ធចិត្តោ** សេចក្តីថា បុគ្គលសូម្បីតាំងខ្លួន ក្នុងឋានៈទាបជាងយ៉ាងនេះថា អញ វៀរចាកបុគ្គលនេះ នឹងរស់មិនបាន បុគ្គលនោះ ជាគតិរបស់អញ បុគ្គលនោះ ជាអ្នកនាំរបស់អញ ដូច្នេះ ឈ្មោះ ថា ជាអ្នកមានចិត្តប្រតិព័ទ្ធហើយ តាំងខ្លួនក្នុងឋានៈខ្ពស់ បញ្ចូនទៅថា ជន ទាំងនេះ វៀរអាត្មាអញហើយ រមែងរស់មិនបាន អញ ជាគតិរបស់មនុស្ស ទាំងនោះ ជាអ្នកនាំរបស់មនុស្សទាំងនោះ ឈ្មោះថា ជាអ្នកមានចិត្តប្រតិព័ទ្ធ ហើយដូចគ្នា ជាអ្នកមានចិត្តប្រតិព័ទ្ធហើយយ៉ាងនេះ លោកបំណាងយកក្នុង ព្រះសូត្រនេះ ។

បទថា **ឯតំ ភយំ** លោកពោលសំដៅដល់ភ័យ ដែលញ៉ាំងប្រយោជន៍ឲ្យវិនាសនោះ គឺសេចក្តីវិនាសចាកសមាបត្តិរបស់ខ្លួន ។ បទថា **សន្ថវេ** សេចក្តីថា សន្ថវៈ មាន ៣ យ៉ាង គឺតណ្ហាសន្ថវៈ ១ ទិដ្ឋិសន្ថវៈ ១ មិត្តសន្ថវៈ ១ ។ ក្នុងសន្ថវៈ ៣ យ៉ាងនោះ តណ្ហា មាន ១០៨ ប្រភេទ ឈ្មោះថា តណ្ហាសន្ថវៈ ទិដ្ឋិ ៦២ ឈ្មោះថា ទិដ្ឋិសន្ថវៈ ការអនុគ្រោះមិត្តដោយភាពជាអ្នកមានចិត្តប្រតិព័ទ្ធហើយ ឈ្មោះថា មិត្តសន្ថវៈ មិត្តសន្ថវៈនោះ លោកបំណងយកក្នុងសូត្រនេះ ដ្បិតថា ព្រះបច្ចេកពុទ្ធនោះ សាបសូន្យចាកសមាបត្តិ ក៏ព្រោះមិត្តសន្ថវៈនោះ ដោយហេតុនោះ ទើបព្រះបច្ចេកពុទ្ធត្រាស់ថា យើងឃើញភ័យ គឺការញ៉ាំងប្រយោជន៍ឲ្យវិនាស ក្នុងសន្ថវៈនោះ ទើបសម្រេច ។ ពាក្យដ៏សេស គប្បីជ្រាបថា ដូចគ្នានឹងពាក្យដែលពោលហើយនោះឯង ។

**មិត្តសុហជ្ជគាថា ចប់**

# គាថាទី ៤

គាថាថា **វំសោ វិសាលោ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។ បានឮថា ក្នុងកាលមុន ព្រះបច្ចេកពោធិសត្វ ៣ អង្គ បួសក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ព្រះនាមកស្សបៈ បំពេញគតបច្ចាគតវត្តអស់ ២ ម៉ឺនឆ្នាំ កើតក្នុងទេវលោក ច្យុតចាកទេវលោកនោះហើយ បុគ្គលជាប្រធានកើតក្នុងរាជត្រកូល ក្នុងនគរពារាណសី ក្រៅអំពីនេះ កើតក្នុងរាជត្រកូល ក្នុងបច្ចន្តប្បទេស ស្ដេចទាំងពីរអង្គនោះរៀនកម្មដ្ឋាន លះរាជសម្បត្តិ បួស បានជាព្រះបច្ចេកពុទ្ធដោយលំដាប់ នៅត្រង់ញកភ្នំនន្ទមូលកៈ ។ ក្នុងថ្ងៃមួយ ចេញចាកសមាបត្តិ រឭកថា ពួកយើងធ្វើកម្មអ្វី ទើបសម្រេចដល់លោកុត្តរសុខនេះ ពិចារណា បានឃើញចរិយារបស់ខ្លួន ក្នុងព្រះកស្សបពុទ្ធកាល លំដាប់នោះរឭកទៀតថា ជនទី ៣ នៅឯណា ឃើញជនទី ៣ សោយរាជសម្បត្តិក្នុងនគរពារាណសី រឭកដល់គុណរបស់ប្រធាននោះ គិតថា ដោយប្រក្រតីនោះឯងព្រះរាជាអង្គនោះ ទ្រង់ដល់ព្រមដោយគុណ មានភាពជាអ្នកប្រាថ្នាតិចជាដើម ទ្រង់ទូន្មានពួកយើង ដែលប្រព្រឹត្តអត់ធន់ចំពោះពាក្យពោល ទ្រង់តិះដៀលបាបណេ្ហយចុះ ពួកយើងនឹងសម្ដែងអារម្មណ៍ ហើយដោះព្រះរាជាអង្គនេះ ដូច្នេះហើយ ស្វែងរកឱកាស ថ្ងៃមួយ ឃើញព្រះរាជាអង្គនោះ ទ្រង់ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង កំពុងយាងទៅកាន់ព្រះរាជឧទ្យាន ហើយហោះទៅតាមអាកាស ឈរត្រង់គុម្ពឫស្សី ត្រង់ទ្វារព្រះរាជឧទ្យាន មហាជនកំពុងមើលព្រះរាជា ដោយការមើលព្រះរាជារបស់ខ្លួន ។

បន្ទាប់អំពីនោះ ព្រះរាជាទ្រង់សម្លឹងមើលថា មាននរណាហ្ន៎ខ្វល់ខ្វាយក្នុងការមើលអញ ទ្រង់ឃើញព្រះបច្ចេកពុទ្ធទាំងឡាយ ដំណាលនឹងការឃើញនោះឯង ព្រះរាជាកើតសេចក្តីស្រឡាញ់ក្នុងព្រះបច្ចេកពុទ្ធទាំងនោះ ទើបទ្រង់ចុះអំពីកដំរី យាងទៅរកព្រះបច្ចេកពុទ្ធទាំងនោះ ដោយអាកប្បកិរិយាស្ងប់ស្ងាត់ ហើយត្រាស់សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់មានឈ្មោះអ្វី ព្រះបច្ចេកពុទ្ធទាំងនោះទូលតបថា មហាបពិត្រ ពួកអាត្មាឈ្មោះ **អសជ្ជមាន** ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ឈ្មោះ **អសជ្ជមាន** មានប្រយោជន៍ដូចម្តេច ព្រះបច្ចេកពុទ្ធត្រាស់ថា មហាបពិត្រ ប្រយោជន៍ គឺការមិនជាប់ជំពាក់ បន្ទាប់អំពីនោះ កាលបង្ហាញគុម្ពឫស្សីនោះ ទើបទូលថា មហាបពិត្រ ប្រៀបដូចបុរសមានដាវក្នុងដៃ កាប់ឫសគុម្ពឫស្សីនោះ ដែលចាក់ស្រែះដើម និងមែកដោយប្រការទាំងពួងទាញមក ក៏មិនអាចលើកឡើង យ៉ាងណា ព្រះអង្គត្រូវតណ្ហារឹតរុំស្អេកស្កះទាំងខាងក្នុង និងខាងក្រៅ ជាអ្នកជាប់ជំពាក់រាយមាយទៅ ជាប់នៅក្នុងតណ្ហានោះ ដូច្នោះដូចគ្នា ទំពាំងនេះ សូម្បីនៅកណ្តាលគុម្ពឫស្សីនោះ តែព្រោះមែកមិនកើត ទើបមិនជាប់ជាមួយអ្វីឡើយ បុគ្គលណាក៏អាចកាត់ចុង ឬកាត់គល់ លើកទៅបាន យ៉ាងណា ពួកអាត្មាមិនជាប់ជំពាក់ក្នុងទីណាឡើយ រមែងត្រាច់ទៅក្នុងទិសទាំងពួង ដូច្នោះដូចគ្នា ហើយចូលចតុត្ថជ្ឈាន ក្នុងវេលានោះឯង កាលព្រះរាជាកំពុងមើលនោះ ក៏ហោះទៅកាន់ញកភ្នំនន្ទមូលកៈ ។

បន្ទាប់អំពីនោះ ព្រះរាជាទ្រង់ព្រះរាជតម្រិះថា សូម្បីអញក៏ជាអ្នកមិនជាប់ជំពាក់យ៉ាងនេះ ក្នុងកាលណាហ្ន៎ ហើយប្រថាប់គង់ក្នុងទីនោះឯង ទ្រង់ឃើញច្បាស់ បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ត្រូវសួរដល់កម្មដ្ឋានដោយន័យមុននោះឯង ទើបត្រាស់គាថានេះថា

សេចក្តីស្រឡាញ់ ចំពោះកូន និងប្រពន្ធ ដូចឫស្សីដែលបែកគុម្ព
ចាក់កណ្តាញ់ បុគ្គលកាលមិនជាប់ជំពាក់ ដូចជាទំពាំងឫស្សី
គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ក្នុងគាថានោះ បទថា **វំសោ** បានដល់ ដើមឫស្សី ។ បទថា **វិសាលោ** បានដល់ ទូលំទូលាយ ។ **វ** អក្ខរៈ ចុះក្នុងអត្ថអវធារណៈ ឬជា **ឯវ** អក្ខរៈ ។ **ឯវ** អក្ខរៈ ក្នុងទីនេះ គប្បីឃើញដោយអំណាចសន្ធិ ។ **ឯវ** អក្ខរៈ ភ្ជាប់ជាមួយបទខាងចុងរបស់បទថា **វិសាលោ** ខ្ញុំនឹងប្រកបដោយ **ឯវ** អក្ខរៈនោះក្នុងកាលជាក្រោយ ។ បទថា **យថា** ប្រើក្នុងការប្រៀបធៀប ។ បទថា **វិសត្តោ** បានដល់ ជាប់ហើយ គឺនាំឲ្យស្អេកស្កះ ដេរឲ្យជាប់គ្នា ។ បទថា **បុត្តេសុ ទារេសុ ច** បានដល់ ក្នុងបុត្រ ធីតា និងភរិយា ។ បទថា **យា អបេក្ខា** បានដល់ តណ្ហាឯណា គឺការជាប់ជំពាក់ឯណា ។ បទថា **វំសកឡ្បី-រោវ អសជ្ជមានោ** គឺមិនជាប់ជំពាក់ដូចទំពាំង ។ សេចក្តីនេះមានអធិប្បាយដូចម្តេច គុម្ពឫស្សីចាក់ស្រែះគ្នា យ៉ាងណា ការជាប់ជំពាក់ក្នុងបុត្ត និងភរិយានោះ ឈ្មោះថា ជាប់ជំពាក់ហើយ ព្រោះជាធម៌ចាក់ស្រែះវត្ថុទាំងនោះ ដូច្នោះ

យើងឃើញទោសក្នុងការជាប់ជំពាក់យ៉ាងនេះថា ជាប់ហើយ ដោយការជាប់ជំពាក់នោះ ដូចគុម្ពឫស្សីធំ ដូច្នោះ ហើយកាត់នូវការជាប់ជំពាក់នោះ ដោយមគ្គញាណដែលមិនជាប់ជំពាក់ ដោយអំណាចនៃតណ្ហា មានះ និងទិដ្ឋិក្នុងរូបជាដើមក្តី ក្នុងទិដ្ឋិជាដើមក្តី ក្នុងលោកៈជាដើមក្តី ក្នុងកាមភពជាដើមក្តី ក្នុងកាមរាគជាដើមក្តី ដូចទំពាំងនេះ ទើបសម្រេចបច្ចេកពោធិញាណ ដូច្នេះ បទដ៏សេស គប្បីជ្រាបដោយន័យមុននោះឯង ។

**វំសកឡីរគាថា ចប់**

# គាថាទី ៥

បទថា **មិគោ អរញ្ញម្ហិ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ភិក្ខុមួយរូបជាព្រះយោគាវចរ ក្នុងព្រះសាសនារបស់ព្រះដ៏មានព្រះភាគ ព្រះនាមកស្សបៈ ធ្វើកាលកិរិយាហើយ កើតក្នុងត្រកូលសេដ្ឋីដែលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន ក្នុងនគរពារាណសី បុរសនោះ ជាបុគ្គលក្រាស់ដោយរាគៈ ព្រោះហេតុនោះ ទើបប្រព្រឹត្តកន្លងនូវភរិយាអ្នកដទៃ ធ្វើកាលកិរិយាក្នុងជាតិនោះហើយ កើតក្នុងនរក ឆេះក្នុងនរកនោះហើយ ដោយសេសសល់ផលកម្ម ក៏បដិសន្ធិជាស្រី ក្នុងផ្ទៃរបស់ភរិយាសេដ្ឋី ។ រាងកាយទាំងឡាយ របស់សត្វទាំងឡាយដែលមកអំពីនរក រមែងជារបស់

ក្តៅ ព្រោះហេតុនោះ កិរិយារបស់សេដ្ឋីទ្រង់គភ៌នោះ ដោយផ្ទៃដែលក្តៅ ដល់នូវសេចក្តីលំបាក បានប្រសូតទារិកាតាមកាល ។

ទារិកាចាប់តាំងពីកើតហើយ បានជាទីស្អប់ខ្ពើមនៃមាតាបិតា និងពួកបរិវារជនដ៏សេស ចម្រើនវ័យហើយ មាតាបិតាឲ្យក្នុងត្រកូលណាក៏ជាទីស្អប់របស់ស្វាមី ឪពុកក្មេក និងម្តាយក្មេកក្នុងត្រកូលនោះ ។ ថ្ងៃមួយ គេប្រកាសនក្ខត្តឫក្ស សេដ្ឋីបុត្តកាលមិនប្រាថ្នា ដើម្បីលេងជាមួយធីតារបស់សេដ្ឋីនោះ នាំស្រីពេស្យាលេងកីឡា ។ នាងបានស្តាប់អំពីសម្នាក់របស់ទាសីទាំងឡាយ ទើបចូលទៅរកបុត្រសេដ្ឋី ពោលដោយប្រការផ្សេងៗ ថា បពិត្រអយ្យបុត្រ ធម្មតាស្រី ទោះជាប្អូនស្រីរបស់ព្រះរាជាទាំង ១០ ព្រះអង្គក្តី ជាបុត្រីរបស់ស្តេចចក្កពត្តិក្តី ទោះយ៉ាងនោះ ក៏ជាអ្នកបម្រើស្វាមី បើប្តីមិននិយាយចរចាជាមួយក៏សោយទុក្ខ ដូចត្រូវលើកឡើងកាន់លំពែង បើខ្ញុំគួរដល់ការអនុគ្រោះ ក៏គប្បីអនុគ្រោះ បើមិនគួរដល់ការអនុគ្រោះ ក៏គប្បីបោះបង់ចោល ខ្ញុំនឹងទៅកាន់ត្រកូលញាតិរបស់ខ្លួន សេដ្ឋីបុត្រពោលថា ណ្ហើយចុះ នាងដ៏ចម្រើន នាងកុំសោកឡើយ ចូរត្រៀមការលេង ពួកយើងនឹងលេងនក្ខត្តឫក្ស ។

ធីតាសេដ្ឋីកើតឧស្សាហ៍ ដោយហេតុត្រឹមតែការប្រាស្រ័យ សូម្បីមានប្រការត្រឹមនោះ ទើបគិតថា ស្អែកនេះ អញនឹងលេងនក្ខត្តឫក្ស ហើយចាត់ចែងរបស់ទំពា និងរបស់បរិភោគជាច្រើន ក្នុងថ្ងៃទី ២ សេដ្ឋីបុត្រមិនប្រាប់ទៅលេងក្នុងទីលានកីឡា នាងគិតថា ស្វាមីនឹងនាំទៅក្នុងឥឡូវនេះ ស្វាមីនឹង

នាំទៅក្នុងឥឡូវនេះ អង្គុយចាំមើលផ្លូវ ឃើញថ្ងៃរសៀលហើយ ទើបបញ្ជូនមនុស្សទាំងឡាយទៅតាម មនុស្សទាំងឡាយប្រាប់ថា សេដ្ឋីបុត្រទៅមុនហើយ ទើបនាងកាន់គ្រឿងទំពា និងរបស់បរិភោគ ដែលត្រៀមទាំងអស់នោះឡើងកាន់យាន ប្រារព្ធដើម្បីនឹងទៅកាន់ឧទ្យាន ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធត្រង់ញកភ្នំនន្ទមូលកៈ ចេញអំពីនិរោធក្នុងថ្ងៃទី ៧ លុបមុខ ត្រង់អនោតត្តស្រះ ទំពាឈើស្ទន់ ឈ្មោះនាគលតា អាវជ្ជនៈថា ថ្ងៃនេះ នឹងត្រាច់បិណ្ឌបាតក្នុងទីណាហ្ន៎ ឃើញធីតាសេដ្ឋីនោះហើយ ក៏ដឹងថា ធីតាសេដ្ឋីនេះ ធ្វើសក្ការៈក្នុងអញហើយ កម្មនោះ នឹងដល់នូវការអស់ទៅ ឈរត្រង់ផ្ទៃមនោសិលាដែលមានទំហំ ៦០ យោជន៍ ត្រង់ញកភ្នំនោះ ស្លៀកដណ្តប់ហើយ កាន់បាត្រ ចីវរ ចូលឈាន មានអភិញ្ញាជាបាទ ហោះមកចុះត្រង់ផ្លូវ ដែលសេដ្ឋីធីតានោះ ធ្វើដំណើរឆ្ពោះទៅ ។ ទាសីទាំងឡាយ ឃើញព្រះបច្ចេកពុទ្ធនោះហើយ ក៏ប្រាប់ដល់ធីតាសេដ្ឋី ។

នាងឃើញព្រះបច្ចេកពុទ្ធនោះហើយ ចុះអំពីយានថ្វាយបង្គំដោយគោរព ទទួលបាត្រ ឲ្យពេញដោយខាទនីយៈ និងភោជនីយៈ ដល់ព្រមដោយរសទាំងពួង និងបិទដោយផ្កាឈូក ដាក់ផ្កាឈូកក្រោមបាត្រ កាន់បាច់ផ្កាចូលទៅរកព្រះបច្ចេកពុទ្ធ ប្រគេនបាត្រត្រង់ដៃរបស់លោក ថ្វាយបង្គំហើយ ដៃកាន់បាច់ផ្កា តាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ ខ្ញុំកើតក្នុងជាតិណាមួយ សូមឲ្យបានជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់មហាជនក្នុងជាតិនោះៗ ដូចផ្កានេះចុះ

កាលតាំងសេចក្តីប្រាថ្នាយ៉ាងនេះហើយ ក៏តាំងសេចក្តីប្រាថ្នាទី ២ ថា បពិត្រលោកម្ចាស់ ការនៅក្នុងគភ៌ជាទុក្ខ បដិសន្ធិគប្បីមានដល់ខ្ញុំក្នុងផ្កាឈូកប៉ុណ្ណោះ កុំចាំបាច់អាស្រ័យគភ៌ឡើយ ហើយតាំងសេចក្តីប្រាថ្នាទី ៣ ថា បពិត្រលោកម្ចាស់ មាតុគ្រាម ដែលមហាជនគប្បីរង្កៀស សូម្បីបុត្រីរបស់ស្តេចចក្រពត្តិ ក៏គង់ចុះកាន់ក្នុងអំណាចបុរស ព្រោះដូច្នោះ ខ្ញុំម្ចាស់កុំបីដល់នូវភាពជាស្ត្រី គប្បីជាបុរសចុះ ហើយតាំងសេចក្តីប្រាថ្នាទី ៤ ថា បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់គប្បីកន្លងនូវសង្សារទុក្ខនេះ សម្រេចអរហត្តដែលជាអមតៈ ដែលលោកម្ចាស់បានសម្រេចក្នុងទីបំផុតចុះ កាលធ្វើសេចក្តីប្រាថ្នា ៤ យ៉ាងនេះហើយ យកបាច់ផ្កាឈូកនោះ បូជាព្រះបច្ចេកពុទ្ធ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយធ្វើសេចក្តីប្រាថ្នាទី ៥ ថា សូមឲ្យខ្ញុំមានក្លិន និងពណ៌សម្បុរដូចផ្កាឈូកនេះចុះ ។

លំដាប់នោះ ព្រះបច្ចេកពុទ្ធទទួលបាត្រ និងផ្កាហើយ ឈរក្នុងអាកាស ធ្វើអនុមោទនាដល់ធីតាសេដ្ឋីដោយគាថានេះថា

**ឥច្ឆិតំ បត្ថិតំ តុយ្ហំ ខិប្បមេវ សមិជ្ឈតុ**
**សព្វេ បូរេន្តុ សង្កប្បា ចន្ទោ បណ្ណរសោ យថា ។**

សូមវត្ថុដែលត្រូវការ វត្ថុដែលប្រាថ្នា សម្រេចដល់អ្នកដោយឆាប់រួសរាន់ចុះ សូមការត្រិះរិះទាំងពួង ពេញដល់អ្នក ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត ដូច្នេះ ។

ហើយអធិដ្ឋានថា សូមសេដ្ឋីធីតាឃើញយើងដែលកំពុងទៅចុះ ហើយទៅកាន់ញកក្នុំនទ្ទមូលកៈ ។ បីតិធំកើតហើយដល់សេដ្ឋីធីតា ព្រោះឃើញព្រះបច្ចេកសម្ពុទ្ធនោះ អកុសលកម្មដែលធ្វើក្នុងរវាងកពក៏អស់ទៅ ព្រោះមិនមានឱកាស នាងជាស្រីបរិសុទ្ធ ដូចកាជន៍មាសដែលខាត់ដោយម្សូរអម្ពិលយ៉ាងណា ជនទាំងអស់ក្នុងត្រកូលស្វាមី និងត្រកូលញាតិទាំងពួង ក៏ត្រេកអរចំពោះនាង នាំគ្នាគិតថា ពួកយើងនឹងធ្វើអ្វី ហើយបញ្ជូនពាក្យជាទីស្រឡាញ់ និងគ្រឿងបណ្ណាការមក សេដ្ឋីបុត្តបញ្ជូនមនុស្សទាំងឡាយមកថា ចូរពួកអ្នកនាំសេដ្ឋីធីតាមកឲ្យឆាប់ យើងនឹករឭក បានមកកាន់ឧទ្យានហើយ ។ ចាប់តាំងអំពីនោះ ក៏ស្រឡាញ់ថ្និតថ្នម ដូចលម្អិតខ្លឹមចន្ទន៍ដែលលាបត្រង់ទ្រូង ដូចមុក្តាហារដែលសំយុង និងដូចកម្រងផ្កា ។ នាងតាំងនៅក្នុងជាតិនោះ សោយនូវឥស្សរិយសុខ និងភោគសុខដរាបដល់អស់អាយុ ស្លាប់ហើយទៅកើតក្នុងផ្កាឈូក នាទេវលោកដោយភាពជាបុរស ទេវបុត្រនោះ កាលទៅ ក៏ទៅដោយផ្កាឈូកប៉ុណ្ណោះ កាលឈរក្តី អង្គុយក្តី ដេកក្តី ក៏ឈរ អង្គុយ ដេកលើត្របកឈូកប៉ុណ្ណោះ ទើបទេវតាទាំងឡាយ ថ្វាយនាមទេវបុត្រនោះថា មហាបទុមទេវបុត្ត ។ ទេវបុត្តនោះ អន្ទោលទៅមកក្នុងទេវលោក ៦ ជាន់ប៉ុណ្ណោះ ដោយអានុភាពនោះ ដោយប្រការដូច្នេះ ។

ដោយសម័យនោះ ព្រះបាទក្រុងពារាណសី ទ្រង់មានស្ត្រី ២ ម៉ឺននាក់ សូម្បីព្រះរាជាក៏ទ្រង់មិនមានព្រះឱរស ក្នុងផ្ទៃរបស់ស្រីសូម្បីតែម្នាក់ អមាត្យ

ទាំងឡាយក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាបថា បពិត្រសម្មតិទេព សូមទ្រង់ប្រាថ្នាព្រះរាជឱរស ដែលបន្តសន្តិវង្ស កាលមិនមានព្រះរាជឱរសដែលកើតអំពីព្រះអង្គ សូម្បីព្រះរាជឱរសដែលកើតក្នុងខេត្ត ក៏អាចបន្តសន្តិវង្សបាន ។ ព្រះរាជាទ្រង់ឲ្យស្រីស្នំដ៏សេស វៀរតែអគ្គមហេសី ប្រព្រឹត្តតាមទំនើងចិត្តថា ពួកនាងចូរធ្វើការរាំដោយធម៌ អស់ ៧ ថ្ងៃ សូម្បីយ៉ាងនោះ ក៏មិនបានព្រះរាជឱរស ទើបអមាត្យទាំងឡាយក្រាបទូលទៀតថា បពិត្រមហារាជ ធម្មតាព្រះមហេសីមានបុណ្យ និងមានបញ្ញាជាងស្ត្រីទាំងពួង ដូច្នោះ ព្រះនាង គប្បីបានព្រះរាជឱរសក្នុងព្រះគភ៌របស់ព្រះនាង ។ ព្រះរាជាត្រាស់ប្រាប់សេចក្ដីនោះដល់ព្រះមហេសី ព្រះនាងទូលថា បពិត្រមហារាជ ស្ត្រីណា មានប្រក្រតីពោលពាក្យសច្ចៈ រក្សាសីល ស្រីនោះ គប្បីបានកូន ព្រោះស្រីវៀរចាកហិរិ និងឱត្តប្បៈ នឹងបានកូនមកអំពីណា ។ ព្រះនាងយាងឡើងកាន់ប្រាសាទ សមាទានសីល ៥ ជម្រះសីលឲ្យបរិសុទ្ធរឿយៗ កាលព្រះរាជធីតាជាអ្នកមានសីល ជម្រះសីល ៥ ឲ្យបរិសុទ្ធ លុះមានព្រះហឫទ័យ ប្រាថ្នាព្រះរាជឱរសកើតឡើង អាសនៈរបស់ព្រះសក្កៈ ក៏ញាប់ញ័រ ។

លំដាប់នោះ សក្កទេវរាជទ្រង់ពិចារណាក៏ដឹងសេចក្ដីនោះ ទ្រង់ត្រិះរិះថា អញនឹងឲ្យពរ គឺបុត្តដល់ព្រះរាជធីតាដែលមានសីល ដូច្នេះហើយ ហោះមកប្រថាប់ឈរត្រង់ព្រះភក្ត្ររបស់ព្រះទេវីហើយ ត្រាស់ថា នែព្រះទេវី ព្រះនាងចង់បានអ្វី ព្រះទេវីត្រាស់ថា បពិត្រមហារាជ ខ្ញុំម្ចាស់ប្រាថ្នាព្រះឱរស សក្ក-

ទេវរាជត្រាស់ថា យើងនឹងឲ្យព្រះឱរសដល់ព្រះនាង សូមព្រះនាងកុំគិតថ្វី ឡើយ ដូច្នេះហើយ ក៏យាងទៅកាន់ទេវលោក ទ្រង់ពិចារណាថា ក្នុងទេវលោក នេះ ទេវបុត្តដែលអស់អាយុមានឬហ្ន៎ ទ្រង់ជ្រាបថា មហាបទុមទេវបុត្តនេះ នឹងចុតិអំពីទេវលោកនេះ ហើយកើតក្នុងទេវលោកខាងលើ ដូច្នេះហើយ យាង ទៅកាន់វិមានរបស់មហាបទុមទេវបុត្តនោះ ត្រាស់ថា នែបាមហាបទុម ចូរបា ទៅកាន់មនុស្សលោក ។ ទេវបុត្រនោះទូលថា បពិត្រមហារាជ សូមទ្រង់កុំ ត្រាស់យ៉ាងនេះឡើយ មនុស្សលោក គួរខ្ពើមរអើម សក្កទេវរាជត្រាស់ថា នែ បា មនុស្សធ្វើបុណ្យក្នុងមនុស្សលោកហើយ កើតក្នុងទេវលោកនេះ ចូរបាទៅ ដើម្បីតាំងនៅក្នុងមនុស្សលោកនោះ បំពេញបារមីទាំងឡាយចុះ មហាបទុម- ទេវបុត្រទូលថា បពិត្រមហារាជ ការនៅក្នុងគភ៌ជាទុក្ខ ទូលបង្គំមិនអាចនៅ ក្នុងគភ៌បានទេ សក្កទេវរាជត្រាស់ថា នែបា បានឹងមានប្រយោជន៍អ្វីដោយការ នៅក្នុងគភ៌ ដ្បិតថា បាបានធ្វើកម្មដោយប្រការដែលខ្លួននឹងកើតក្នុងត្របក ឈូកប៉ុណ្ណោះ នែបា ចូរបាទៅចុះ ។

ទេវបុត្រនោះ កាលត្រូវសក្កៈត្រាស់រឿយៗ ក៏ព្រមទទួល ។ លំដាប់ នោះ មហាបទុមទេវបុត្រ ច្យុតចាកទេវលោក កើតក្នុងត្របកឈូក ក្នុងស្រះ បោក្ខរណី ក្បែរព្រះទែនសិលា ក្នុងព្រះរាជឧទ្យាន របស់ព្រះបាទពារាណសីៗ ក្នុងយប់នោះ ព្រះមហេសីព្រះនាងសុបិន្តក្នុងពេលទៀបភ្លឺ ឃើញស្ត្រី ២ ម៉ឺន ចោមរោម យាងទៅកាន់ព្រះរាជឧទ្យាន ហើយបានព្រះរាជឱរស ក្នុងត្របក

ឈូក ក្នុងស្រះបោក្ខរណី ក្បែរព្រះទែនសិលា ព្រះនាងរក្សាសីលក្នុងរាត្រីដែលភ្លឺស្វាង យាងទៅត្រង់ព្រះទែនសិលាយ៉ាងនោះឯង ព្រះនាងឃើញផ្កាឈូកមួយ នៅមិនឆ្ងាយអំពីច្រាំង មិនជ្រៅ ដំណាលគ្នានឹងព្រះនាងឃើញនោះ ព្រះនាងក៏កើតការជាប់ជំពាក់ក្នុងព្រះរាជឱរសក្នុងផ្កាឈូកនោះ ព្រះនាងយាងទៅតាមគាប់ចិត្ត ចាប់ផ្កាឈូកនោះ គ្រាន់តែព្រះនាងចាប់ប៉ុណ្ណោះ ត្របកឈូកទាំងឡាយ ក៏លាចេញ ព្រះនាងឃើញទារកដូចរូបមាសក្នុងត្របកឈូកនោះ កាលឃើញហើយ ព្រះនាងក៏បន្លឺសំឡេងថា យើងបានបុត្តហើយ មហាជនក៏បន្លឺសាធុការ រាប់ពាន់ដល់ព្រះនាង ព្រះនាងក៏បញ្ជូនដំណឹងថ្វាយព្រះរាជាៗទ្រង់ស្តាប់ហើយ ទើបត្រាស់សួរថា បានបុត្តអំពីទីណា កាលទ្រង់ស្តាប់រឿងដែលបានបុត្តហើយ ទើបត្រាស់ថា ឧទ្យាន និងបទុម ក្នុងស្រះបោក្ខរណីជាខេត្តរបស់យើងប៉ុណ្ណោះ ព្រោះដូច្នេះ បុត្រនេះ ឈ្មោះថា បុត្រកើតក្នុងខេត្ត ព្រោះកើតក្នុងខេត្តរបស់យើង ត្រាស់ឲ្យយាងចូលកាន់ព្រះនគរ ទ្រង់ឲ្យស្ត្រីទាំង ២ ម៉ឺននាក់ ធ្វើនាទីជាភីលៀង ស្ត្រីណាម្នាក់ឲ្យព្រះរាជកុមារពេញព្រះហឫទ័យ ទំពានូវខាទនីយៈ ដែលទ្រង់ប្រាថ្នាហើយ ស្ត្រីនោះៗ រមែងបានទ្រព្យមួយពាន់ ។ អ្នកនគរពារាណសី ទាំងមូលកក្រើករំពើក ។ ជនទាំងពួងបញ្ជូនបណ្ណាការរាប់ពាន់ថ្វាយព្រះរាជកុមារៗ ត្រូវមហាជននាំវត្ថុនោះៗ មកទូលថា សូមទ្រង់ទំពារបស់នេះ សូមទ្រង់សោយរបស់នេះ ទ្រង់ក៏នឿយណាយ ដោយភោជន ក៏យាងទៅកាន់ខ្លោងទ្វារ ទ្រង់លេងជាមួយដុំល័ក្ត ។

ក្នុងកាលនោះ ព្រះបច្ចេកពុទ្ធមួយអង្គ អាស្រ័យនគរពារាណសី គង់ឥសិបតនៈ ក្រោកឡើងតាមកាលធ្វើកិច្ចទាំងពួង មានសេនាសនវត្តជាដើម បរិកម្មរាងកាយ និងមនសិការជាដើម ចេញអំពីទីពួនសម្ងំ គិតថា ថ្ងៃនេះនឹងទទួលភិក្ខាក្នុងទីណា ឃើញសម្បត្តិរបស់ព្រះរាជកុមារ ហើយពិចារណាថា ក្នុងកាលមុន កុមារនេះធ្វើកម្មអ្វី ដូច្នេះ ដឹងថា កុមារនេះ បានថ្វាយបិណ្ឌបាតដល់ព្រះបច្ចេកពុទ្ធដូចអាត្មាអញ ហើយតាំងសេចក្តីប្រាថ្នា ៤ យ៉ាង ក្នុងប្រាថ្នា ៤ យ៉ាងនោះ ៣ យ៉ាងសម្រេចហើយ នៅម្យ៉ាងទៀតមិនទាន់សម្រេច អាត្មាអញនឹងឲ្យអារម្មណ៍ដោយឧបាយដល់កុមារនោះ ដូច្នេះហើយ បានទៅកាន់សម្នាក់របស់ព្រះរាជកុមារ ដោយអំណាចនៃភិក្ខាចរិយា ព្រះរាជកុមារទ្រង់ឃើញព្រះបច្ចេកពុទ្ធនោះហើយ ត្រាស់ថា បពិត្រសមណៈ លោកម្ចាស់ កុំមកទីនេះ ដ្បិតថា មនុស្សទាំងនេះ គប្បីពោលដល់លោកម្ចាស់ថា ចូរទំពារបស់នេះ ចូរបរិភោគរបស់នេះ ។ ព្រះបច្ចេកពុទ្ធត្រឡប់អំពីទីនោះ ដោយពាក្យប្រាប់ត្រឹមតែម្តងប៉ុណ្ណោះ ចូលទៅកាន់សេនាសនៈរបស់លោក ។

ចំណែកព្រះរាជកុមារត្រាស់នឹងពួកជនថា សមណៈនេះគ្រាន់តែយើងពោលហើយ ក៏ត្រឡប់ ប្រហែលជាខឹងនឹងយើងឬហ្ន៎ ។ បន្ទាប់អំពីនោះ កាលជនទាំងនោះទូលថា បពិត្រព្រះសម្មតិទេព ធម្មតាបព្វជិតទាំងឡាយមិនមែនជាអ្នកខឹងក្រោធឡើយ ជាអ្នករស់នៅដោយបច្ច័យដែលអ្នកដទៃឲ្យដោយចិត្តជ្រះថ្លា ដូច្នេះ ។ ព្រះរាជកុមារទ្រង់ព្រះតម្រិះថា សមណៈនោះ ពិត

ជាយ៉ាងនោះ ទើបទូលដល់ព្រះមាតា និងព្រះបិតាថា នឹងញុាំងព្រះបច្ចេកពុទ្ធនោះ ឲ្យអភ័យទោស ដូច្នេះហើយ ទ្រង់ឡើងដំរីយានទៅកាន់ព្រៃឥសិបតនៈ ដោយអានុភាពរបស់ព្រះរាជាដែលធំក្រៃលែង ទ្រង់ឃើញនូវហ្វូងម្រឹគ ទើបត្រាស់សួរថា សត្វទាំងនោះ ឈ្មោះអ្វី ពួកអមាត្យទូលថា បពិត្រព្រះអង្គ សត្វទាំងនោះ ឈ្មោះថា ម្រឹគ ព្រះរាជកុមារត្រាស់ថា ម្រឹគទាំងនោះ មានគេពោលថា ចូរទំពារបស់នេះ ចូរបរិភោគរបស់នេះ ចូរភ្លក្សរបស់នេះ ហើយបដិបត្តិមានដែរឬទេ អមាត្យទូលថា បពិត្រព្រះអង្គ មិនមានទេ ទីណាមានស្មៅ និងទឹករកបានងាយ ម្រឹគទាំងឡាយក៏ទៅទីនោះ ។

ព្រះរាជកុមារគិតថា ម្រឹគទាំងនេះ ទោះបីមិនមានអ្នកណារក្សា ក៏នៅក្នុងទីដែលខ្លួនប្រាថ្នាយ៉ាងណា ក្នុងកាលណាហ្ន៎ អញគប្បីនៅយ៉ាងនេះ ដូច្នេះហើយ ទ្រង់កាន់យកហេតុនោះជាអារម្មណ៍ ។

ចំណែកព្រះបច្ចេកពុទ្ធ ដឹងការយាងមករបស់ព្រះរាជកុមារនោះហើយ បោសផ្លូវ និងសេនាសនៈ មួយអន្លើដោយទីចង្ក្រមធ្វើឲ្យរលីង ហើយប្រតិស្ឋានស្នាមជើង ដើរចង្ក្រម ២-៣ ជំហាន បោសឱកាសនៃទីជាទីនៅក្នុងពេលថ្ងៃ និងបណ្ណសាលាធ្វើឲ្យរលីងហើយ ប្រតិស្ឋានស្នាមជើងចូលទៅ តែមិនបង្ហាញស្នាមជើងដែលចេញ ហើយទៅកាន់ទីដទៃ ។ ព្រះរាជកុមារយាងទៅក្នុងទីនោះ ឃើញប្រទេសនោះ ដែលបោសធ្វើឲ្យរលីងហើយ ទ្រង់គិតថា ប្រហែលជាព្រះបច្ចេកពុទ្ធនៅក្នុងទីនោះ ទ្រង់ស្តាប់ពាក្យដែលបរិវារជនទូល

ហើយ ត្រាស់ថា សមណៈនោះ ក្រោកតាំងអំពីព្រឹក ឥឡូវនេះ ឃើញដីរី និងសេះជាដើម ជាន់ឱកាសរបស់ខ្លួន ក៏នឹងក្រោកក្រៃលែង ចូរពួកអ្នក អង្គុយក្នុងទីនេះប៉ុណ្ណោះ ដូច្នេះហើយ យាងចុះអំពីកដីរីមួយព្រះអង្គឯង ប៉ុណ្ណោះ យាងចូលកាន់សេនាសនៈ ឃើញស្នាមជើងក្នុងឱកាសដែលបោស ល្អហើយ តាមកិច្ចវត្ត មានព្រះហឫទ័យជ្រះថ្លាថា សមណៈនេះ ចង្ក្រមក្នុង ទីនេះ ពិតជាមិនគិតដល់ការលក់ដូរជាដើម ប្រហែលជាគិតដល់ប្រយោជន៍ របស់ខ្លួនប៉ុណ្ណោះដោយពិត ទ្រង់ឡើងកាន់ទីចង្ក្រម ទ្រង់ធ្វើវិតក្កដ៏ក្រាស់ឲ្យ ឆ្ងាយ ប្រថាប់គង់លើផ្ទាំងថ្ម ទ្រង់មានឯកគ្គតាចិត្តកើត ហើយយាងចូល កាន់បណ្ណសាលា ទ្រង់ចម្រើនវិបស្សនា សម្រេចនូវបច្ចេកពោធិញ្ញាណ ។ កាល បុរោហិតទូលសួរដល់កម្មដ្ឋានដោយន័យមុននោះឯង ប្រថាប់គង់លើអាកាស ត្រាស់ព្រះគាថានេះថា

> ម្រឹគក្នុងព្រៃ ជាសត្វមិនជាប់ចំណង នៅរកចំណីតាមចំណង់ចិត្ត
> បានយ៉ាងណា វិញ្ញូជន កាលបើឃើញសេរីភាព ( យ៉ាងនោះ )
> គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

បទថា **មិគោ** បានដល់ ម្រឹគពីរប្រភេទ គឺម្រឹគស៊ីស្មៅ ១ ម្រឹកស៊ី ឫសឈើ មើមឈើ ១ ។ ម្យ៉ាងទៀត បទថា **មិគោ** នោះ ជាឈ្មោះរបស់ សត្វជើង ៤ ដែលនៅក្នុងព្រៃទាំងអស់ ។ ម្យ៉ាងទៀត អាចារ្យពួកខ្លះពោល ថា លោកបំណងយកម្រឹគស៊ីឫសឈើ មើមឈើ ។ បទថា **អរញ្ញម្ហិ** បាន ដល់ ក្នុងព្រៃដ៏សេស វៀរស្រុក និងឧបចារៈរបស់ស្រុក ។ ក្នុងគាថានេះ

លោកបំណងយកព្រៃ អធិប្បាយថា ក្នុងឧទ្យាន ។ បទថា **យថា** ជាពាក្យប្រៀបធៀប ។

បទថា **អពទ្ធោ** សេចក្តីថា ដែលបុគ្គលណាម្នាក់ មិនចងហើយដោយវត្ថុទាំងឡាយ មានគ្រឿងចង គឺខ្សែជាដើម ។ បទថា **យេនិច្ឆកំ** សេចក្តីថា ម្រឹគរមែងប្រាថ្នា ដើម្បីទៅក្នុងទិសាភាគណា រមែងទៅរកស៊ីក្នុងទិសាភាគនោះៗ ។ សមដូចព្រះតម្រាស់ដែលព្រះដ៏មានព្រះភាគត្រាស់ក្នុង ( បាសរាសិសូត្រ ) ថា

ម្នាលភិក្ខុទាំងឡាយ ម្រឹគដែលនៅក្នុងព្រៃ ត្រាច់រង្គាត់ទៅក្នុងព្រៃតូចព្រៃធំ តែងដើរទៅឥតរង្កៀស ឈរក៏ឥតរង្កៀស អង្គុយក៏ឥតរង្កៀស សម្រេចការដេកក៏ឥតរង្កៀស ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះម្រឹគនោះ មិនបានប្រទះភ្នែកព្រាន សេចក្តីនេះ មានឧបមាយ៉ាងណាមិញ ភិក្ខុស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈាន ដែលប្រកបដោយវិតក្ក វិចារ មានបីតិ សុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានធ្វើមារឲ្យខ្វាក់ បំបិទភ្នែកមារមិនឲ្យឃើញស្នាមជើងទៅកាន់ទីដែលមារមានចិត្តបាបមើលមិនឃើញ ... ដូច្នេះ ។ គប្បីជ្រាបសេចក្តីនេះ ដោយពិស្តារ ។

បទថា **វិញ្ញូ នរោ** បានដល់ បុគ្គលជាបណ្ឌិត ។ បទថា **សេរិតំ** បានដល់ ការប្រព្រឹត្តិតាមគាប់ចិត្តរបស់ខ្លួន គឺការប្រព្រឹត្តិមិនទាក់ទងជាមួយបុគ្គលដទៃ ។ លោកអធិប្បាយពាក្យនេះថា ម្រឹគក្នុងព្រៃ ដែលបុគ្គលមិនចងហើយ រមែងទៅរកស៊ីតាមសេចក្ដីប្រាថ្នាបាន យ៉ាងណា សូម្បីយើងក៏កាត់នូវគ្រឿងចង គឺតណ្ហាបានយ៉ាងនោះហើយ ក៏គប្បីទៅដូច្នោះ ។ នរជនអ្នកដឹងច្បាស់ គឺបណ្ឌិត សម្លឹងនូវការប្រព្រឹត្តិតាមគាប់ចិត្តរបស់ខ្លួន គប្បីត្រាច់ទៅតែម្នាក់ឯង ។

**មិគអរញ្ញគាថា ចប់**

# គាថាទី ៦

គាថាថា **អាមន្តនា ហោតិ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

អមាត្យទាំងឡាយ បានចូលគាល់ក្នុងសម័យដែលបម្រើធំរបស់ព្រះបាទពារាណសី ក្នុងអមាត្យទាំងនោះ អមាត្យម្នាក់ទូលសូមការទៅក្នុងទីបំផុតចំណែកមួយថា បពិត្រព្រះសម្មតិទេព វត្ថុដែលគប្បីស្ដាប់មានដូច្នេះ ហើយក្រោកទៅ ។ មនុស្សម្នាក់ទៀត ទូលនឹងព្រះរាជាដែលប្រថាប់គង់ ក្នុងទីបម្រើធំទៀត មនុស្សម្នាក់ទៀត ទូលសូមដំរីនឹងព្រះរាជា ដែលប្រថាប់គង់លើកដំរី មនុស្សម្នាក់ទូលសូមសេះនឹងព្រះរាជា ដែលប្រថាប់គង់លើខ្នងសេះ មនុស្ស

ម្នាក់ទូលសូមរថមាសនឹងព្រះរាជា ដែលប្រថាប់គង់ក្នុងរថមាស មនុស្សម្នាក់ទូលសូមវនឹងព្រះរាជា ដែលប្រថាប់គង់ក្នុងវទៅកាន់ឧទ្យាន ព្រះរាជាទ្រង់ចុះអំពីវ ប្រទានឲ្យជនដទៃទូលសូមនឹងព្រះអង្គ ដែលកំពុងត្រាច់ចារិកទៅកាន់ជនបទ ព្រះរាជាទ្រង់ស្តាប់ពាក្យមនុស្សទាំងនោះ ចុះអំពីកដំរី ទៅកាន់ទីមួយកន្លែង ។

ព្រះរាជាទ្រង់ខ្ពើមរអើមដោយអមាត្យទាំងនោះ យ៉ាងនេះហើយ ទ្រង់បួស អមាត្យទាំងឡាយ ចម្រើនដោយឥស្សរិយយស ក្នុងអមាត្យទាំងនោះ អមាត្យម្នាក់ទូលព្រះរាជាថា បពិត្រមហារាជ សូមទ្រង់ព្រះរាជទានជនបទឈ្មោះនោះឲ្យដល់ទូលបង្គំ ព្រះរាជាត្រាស់ថា ជនឈ្មោះនេះគ្រប់គ្រងជនបទនោះ ។ បុរសនោះ មិនអើពើនឹងព្រះតម្រាស់របស់ព្រះរាជា ហើយទូលថា ទូលបង្គំនឹងទៅ នឹងដណ្តើមជនបទនោះគ្រប់គ្រង ដូច្នេះហើយ ទៅក្នុងជនបទនោះ ធ្វើនូវជម្លោះ សូម្បីជនទាំងពីរមកកាន់ព្រះរាជដំណាក់ទៀត ទូលប្រាប់ទោសនៃគ្នានិងគ្នា ព្រះរាជាទ្រង់ព្រះតម្រិះថា អញមិនអាចឲ្យជនទាំងពីរនេះត្រេកអរបាន ទ្រង់ឃើញទោសក្នុងលោភៈនៃអមាត្យទាំងនោះ ទ្រង់ចម្រើនវិបស្សនា ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ទ្រង់បន្លឺឧទាននេះដោយន័យមុននោះឯងថា

ការហៅរក រមែងមានដល់ជនឋិតនៅក្នុងកណ្តាលនៃសម្លាញ់ គឺ
ការនៅ ការឈរ និងការត្រាច់ចារិក បុគ្គលកាលឃើញសេរីភាព

ដែល ( ពួកជនពាល ) មិនប្រាថ្នា គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

អត្ថនៃគាថានោះថា ការប្រឹក្សាដោយប្រការនោះៗ ដោយន័យថា អ្នកចូរស្តាប់វត្ថុនេះរបស់ខ្ញុំ អ្នកចូរឲ្យវត្ថុនេះដល់ខ្ញុំជាដើម ក្នុងទីលំនៅ ពោល គឺទីសម្រាកពេលថ្ងៃ ក្នុងការឈរ ពោល គឺការបម្រើធំ ក្នុងការទៅ ពោល គឺការទៅឧទ្យាន ក្នុងការត្រាច់ចារិក ពោល គឺការត្រាច់ទៅក្នុងជនបទ រមែងមានដល់បុគ្គលដែលតាំងនៅហើយក្នុងកណ្តាលនៃសម្លាញ់ ព្រោះហេតុនោះ យើងនឿយណាយក្នុងការប្រឹក្សា ក្នុងកណ្តាលនៃសម្លាញ់នោះ កាលសម្លឹងឃើញបព្វជ្ជា ដែលមានអានិសង្សច្រើន មានសុខដោយចំណែកមួយ ដែលអរិយជនសេពហើយ សូម្បីយ៉ាងនោះ ក៏ជាបព្វជ្ជាដែលពួកជនពាលទាំងពួងត្រូវសេចក្តីលោភគ្របសង្កត់ហើយ មិនត្រូវការ មិនប្រាថ្នា និងសម្លឹងនូវការប្រព្រឹត្តិតាមគាប់ចិត្ត ដោយការមិនធ្លាក់នៅក្នុងអំណាចរបស់បុគ្គលដទៃ និងដោយអំណាចនៃបុគ្គលដែលរស់នៅដោយធម៌ ដែលពួកបុរសអាក្រក់ មិនប្រាថ្នាហើយ ប្រារព្ធវិបស្សនា បានសម្រេចបច្ចេកពោធិញ្ញាណដោយលំដាប់ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

**អាមន្តគាថា ចប់**

# គាថាទី ៧

គាថាថា **ចិន្តា រតិ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ក្នុងនគរពារាណសី មានព្រះរាជាព្រះនាមឯកបុត្តិកព្រហ្មទត្ត រាជឱរស អង្គនោះ ជាទីស្រឡាញ់ ជាទីពេញព្រះហឫទ័យ ជាបុគ្គលស្មើដោយជីវិត របស់ព្រះអង្គ ទ្រង់បាននាំព្រះរាជឱរស ប្រព្រឹត្តទៅក្នុងឥរិយាបថទាំងពួង ។

ថ្ងៃមួយ កាលទ្រង់យាងទៅកាន់ព្រះរាជឧទ្យាន ទ្រង់មិននាំព្រះរាជឱរស នោះយាងទៅ ។ ព្រះរាជកុមារ អស់ព្រះជន្មដោយព្យាធិដែលកើតឡើង ក្នុង ថ្ងៃនោះឯង អមាត្យទាំងឡាយគិតថា ព្រះហឫទ័យរបស់ព្រះរាជា គប្បីបែក ព្រោះសេចក្តីស្នេហាក្នុងព្រះរាជឱរស ទើបមិនទូលប្រាប់ នាំគ្នាថ្វាយព្រះភ្លើង ព្រះរាជឱរសនោះ ព្រះរាជាទ្រង់ស្រវឹងដោយទឹកច័ណ្ឌ ក្នុងព្រះរាជឧទ្យាន ទើបទ្រង់នឹកមិនឃើញដល់ព្រះរាជឱរស ក្នុងថ្ងៃទី ២ ក្នុងពេលទ្រង់ស្រង់ និងសោយជាដើម ក៏ទ្រង់រឭកមិនបានដូចគ្នា ។ តមក ទ្រង់សោយព្រះ ក្រយាហារ ប្រថាប់គង់ហើយ ទ្រង់រឭកបាន ទើបត្រាស់ថា ចូរនាំបុត្រមក ឲ្យយើង ពួកអមាត្យទូលរឿងនោះ ដោយវិធីដែលសមគួរដល់ព្រះអង្គ ។

តាំងអំពីនោះ ព្រះរាជាត្រូវសេចក្តីសោកគ្របសង្កត់ ប្រថាប់គង់ប៉ុណ្ណោះ ទ្រង់ធ្វើក្នុងព្រះហឫទ័យដោយឧបាយថា កាលវត្ថុនេះមាន វត្ថុនេះក៏មាន ព្រោះ វត្ថុនេះកើត វត្ថុនេះក៏កើត ដូច្នេះ ព្រះអង្គទ្រង់បានពិចារណាបដិច្ចសមុប្បាទ ទាំងអនុលោម និងបដិលោមដោយលំដាប់យ៉ាងនេះ ទ្រង់ឲ្យជាក់ច្បាស់នូវ បច្ចេកពោធិញ្ញាណ ។ បទដ៏សេស ដូចគ្នាតាមដែលពោលហើយ ក្នុង

សំសគ្គគាថានោះឯង វៀរតែអត្ថវណ្ណនានៃគាថា ។

ក្នុងអត្ថវណ្ណនា បទថា **ខិឌ្ឌា** បានដល់ ការលេង ។ ការលេងនោះមានពីរយ៉ាង គឺលេងដោយកាយ ១ លេងដោយវាចា ១ ។ ការលេងយ៉ាងនេះថា រមែងលេងដោយដំរីទាំងឡាយខ្លះ លេងដោយសេះទាំងឡាយខ្លះ លេងដោយរថទាំងឡាយខ្លះ ឈ្មោះថា លេងដោយកាយ ។ ការលេងមានជាដើមយ៉ាងនេះថា ការច្រៀង ការពោលសរសើរ ការលេងស្គរមាត់ ឈ្មោះថា ការលេងដោយវាចា ។ បទថា **រតិ** បានដល់ ការត្រេកអរក្នុងបញ្ចកាមគុណ ។ បទថា **វិបុលំ** សេចក្តីថា ឈ្មោះថា ជ្រួតជ្រាបទូទៅពេញអត្តភាពទាំងមូលដោយឋានៈ រហូតដល់ខួរក្នុងឆ្អឹង ។ ពាក្យដ៏សេស ជាក់ច្បាស់ហើយទាំងអស់ គប្បីជ្រាបការប្រកបអនុសន្ធិក្នុងគាថានេះ ដោយន័យដែលពោលហើយក្នុងសំសគ្គគាថា និងបទទាំងពួងដទៃអំពីនោះ ។

**ខិឌ្ឌារតិគាថា ចប់**

# គាថាទី ៨

គាថាថា **ចាតុទ្ទិសោ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ?

បានឮថា ក្នុងអតីតកាល ព្រះបច្ចេកពោធិសត្វ ៥ អង្គ បួសហើយក្នុងសាសនារបស់ព្រះកស្សបទសពល បំពេញគតបច្ចាគតវត្តអស់ ២ ម៉ឺនឆ្នាំ កើតក្នុងទេវលោក ច្យុតចាកទេវលោកនោះហើយ បណ្ដាព្រះថេរៈទាំង ៥ នោះ ព្រះថេរៈជាប្រធាន កើតជាព្រះរាជាក្នុងនគរពារាណសី ព្រះថេរៈដ៏សេស ៤ អង្គទៀត កើតជាព្រះរាជាធម្មតា ។ ព្រះរាជាទាំង ៤ អង្គនោះរៀនកម្មដ្ឋាន លះរាជសម្បត្តិហើយបួស បានជាព្រះបច្ចេកពុទ្ធតាមលំដាប់នៅក្នុងញកភ្នំនន្ទមូលកៈ ក្នុងថ្ងៃមួយ ចេញអំពីសមាបត្តិហើយ នឹកដល់កម្មរបស់ខ្លួន និងសម្លាញ់ ដោយន័យដែលពោលហើយ ក្នុងវិសកឡិរគាថានោះឯង កាលដឹងហើយ ក៏ស្វែងរកឱកាស ដើម្បីសម្ដែងអារម្មណ៍ដោយឧបាយ ដល់ព្រះបាទក្រុងពារាណសី ។

ព្រះរាជាអង្គនោះ ទ្រង់ភ្ញាក់មួយរាត្រី ៣ ដង ទ្រង់ខ្លាច ស្រែកដោយសំឡេងខុសប្រក្រតី រត់ចូលកាន់រោងធំ ត្រូវបុរោហិតក្រោកឡើងតាមកាលទូលសួរដល់ការផ្ទុំជាសុខ ក៏ត្រាស់ប្រាប់រឿងនោះថា នែអាចារ្យ យើងមានសេចក្ដីសុខអំពីណា ។ ចំណែកបុរោហិតគិតថា រោគនេះ មិនអាចកម្ចាត់ឲ្យដាច់ទៅបានដោយការដាក់ថ្នាំ មានថ្នាំបញ្ចុះជាដើមណាមួយឡើយ តែអញមានឧបាយ ដែលនឹងបានស៊ី ទើបទូលឲ្យព្រះរាជាខ្លាចក្រៃលែងឡើងថា បពិត្រមហារាជ នុ៎ះជាបុព្វនិមិត្តនៃការវិនាសរាជសម្បត្តិ និងអន្តរាយដល់ព្រះជន្ម

ជាដើម ទើបដឹកនាំព្រះរាជាឲ្យធ្វើការបូជាយញ្ញថា សូមទ្រង់រៀបចំដំរី សេះ រថជាដើម មួយអន្ទើដោយប្រាក់ និងមាស មានប្រមាណប៉ុណ្ណេះៗ ជាទក្ខិណា បូជាយញ្ញ ដើម្បីឲ្យអន្តរាយនោះស្ងប់ ដូច្នេះ ។

បន្ទាប់អំពីនោះ ព្រះបច្ចេកពុទ្ធទាំងឡាយ ឃើញសត្វទាំងឡាយចងនាំទៅមួយកន្លែង ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញ ទើបគិតថា ព្រះរាជាកាលទ្រង់ធ្វើកម្មនេះហើយ នឹងដឹកនាំឲ្យត្រាស់ដឹងបានលំបាក ណ្ហើយចុះ ពួកយើងប្រញាប់ទៅដោះព្រះអង្គជាមុន ហើយមកដោយន័យដែលពោលហើយក្នុងវិសកឡ្សីគាថានោះឯង ត្រាច់បិណ្ឌបាត ទៅកាន់ទីលានសម្លាប់សត្វ ក្នុងលានព្រះរាជវាំង ។ ព្រះរាជាប្រថាប់ឈរត្រង់សីហបញ្ជរ ទ្រង់សម្លឹងមើលត្រង់លានព្រះរាជវាំង ទ្រង់ឃើញព្រះបច្ចេកពុទ្ធទាំងនោះ ទ្រង់ក៏កើតសេចក្តីស្នេហា ដំណាលគ្នានឹងការឃើញនោះឯង ។ បន្ទាប់អំពីនោះ ទ្រង់ឲ្យនាំព្រះបច្ចេកពុទ្ធទាំងនោះមក ទ្រង់ឲ្យគង់លើអាសនៈដែលគេក្រាលត្រង់ទីសម្រាប់សំដិលខ្លួន ទ្រង់ឲ្យឆាន់ដោយគោរពហើយ ត្រាស់សួរព្រះបច្ចេកពុទ្ធទាំងឡាយ ដែលធ្វើភត្តកិច្ចស្រេចហើយថា លោកម្ចាស់ទាំងឡាយ ឈ្មោះអ្វី ព្រះបច្ចេកពុទ្ធតបថា មហាបពិត្រ ពួកអាត្មាឈ្មោះថា **ចាតុទ្ទិសា** ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ឈ្មោះថា **ចាតុទ្ទិសា** នេះ មានន័យដូចម្តេច ព្រះបច្ចេកពុទ្ធតបថា មហាបពិត្រ ក្នុងទិសទាំង ៤ ពួកអាត្មាមិនមានភ័យ ឬការតក់ស្លុតនៃចិត្តណាឡើយ ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ភ័យនោះ

រមែងមិនមានដល់លោកម្ចាស់ ព្រោះហេតុអ្វី ព្រះបច្ចេកពុទ្ធទាំងឡាយទូលថា មហាបពិត្រ ព្រោះពួកអាត្មាចម្រើននូវមេត្តា ករុណា មុទិតា ឧបេក្ខា ព្រោះហេតុនោះ ទើបភ័យនោះ មិនមានដល់ពួកអាត្មា ដូច្នេះហើយ ក្រោកចាកអាសនៈទៅកាន់លំនៅរបស់ខ្លួន ។

បន្ទាប់អំពីនោះ ព្រះរាជាទ្រង់ព្រះតម្រិះថា សមណៈទាំងនេះពោលថា ភ័យរមែងមិនមានព្រោះការចម្រើនមេត្តាជាដើម តែពួកព្រាហ្មណ៍ពោលសរសើរការសម្លាប់សត្វច្រើនពាន់ ពាក្យរបស់អ្នកណាហ្ន៎ជាពាក្យពិត ។ លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា សមណៈទាំងឡាយ រមែងពោលវត្ថុដែលបរិសុទ្ធដោយវត្ថុដែលបរិសុទ្ធប៉ុណ្ណោះ ចំណែកពួកព្រាហ្មណ៍ ពោលវត្ថុដែលបរិសុទ្ធដោយវត្ថុដែលមិនបរិសុទ្ធ បុគ្គលណាម្នាក់ មិនអាចលាងវត្ថុដែលមិនបរិសុទ្ធដោយវត្ថុដែលមិនបរិសុទ្ធបានឡើយ ពាក្យរបស់បព្វជិតប៉ុណ្ណោះ ជាពាក្យពិតដូច្នេះ ។

ព្រះរាជានោះទ្រង់ចម្រើនព្រហ្មវិហារទាំង ៤ មានមេត្តាជាដើម ដោយន័យជាដើមថា សូមសត្វទាំងពួងមានសេចក្តីសុខចុះ ត្រាស់បញ្ជាអមាត្យទាំងឡាយ ដោយព្រះហឫទ័យផ្សាយទៅ ប្រកបដោយប្រយោជន៍ថា អ្នកទាំងឡាយ ចូរដោះលែងសត្វទាំងអស់ ចូរឲ្យសត្វទាំងឡាយ បានផឹកនូវទឹកដ៏ត្រជាក់ ស៊ីស្មៅពណ៌ខៀវ និងខ្យល់ត្រជាក់ ចូរបក់សត្វទាំងនោះ អមាត្យទាំងនោះ បានធ្វើយ៉ាងនោះ ។

បន្ទាប់អំពីនោះ ព្រះរាជាទ្រង់ព្រះរាជតម្រិះថា អញផុតហើយចាកបាប-កម្មដោយពាក្យរបស់កល្យាណមិត្តទាំងឡាយ ប្រថាប់គង់ក្នុងទីនោះឯង ទ្រង់ចម្រើនវិបស្សនា ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ កាលអមាត្យទាំងឡាយទូលថា បពិត្រមហារាជ ដល់ពេលសោយព្រះក្រយាហារហើយ សូមទ្រង់សោយ ទើបត្រាស់ព្រះតម្រាស់ទាំងពួងថា យើងមិនមែនព្រះរាជាដោយន័យមុននោះឯង ហើយត្រាស់ឧទានព្យាករណ៍គាថានេះថា

បុគ្គលជាអ្នកនៅជាសុខ ក្នុងទិសទាំង ៤ មិនលំបាក ត្រេកអរ
ដោយបរិក្ខារ តាមមាន តាមបាន ជាអ្នកអត់ធន់ ចំពោះ
អន្តរាយទាំងឡាយ ទាំងជាអ្នកមិនតក់ស្លុត គប្បីត្រាច់ទៅ
តែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ក្នុងគាថានោះ បទថា **ចាតុទ្ទិសោ** បានដល់ នៅតាមសប្បាយក្នុងទិសទាំង ៤ ដែលឈ្មោះថា **ចាតុទ្ទិសោ** ព្រោះអត្ថថា បុគ្គលនោះ ផ្សាយព្រហ្មវិហារភាវនា ទៅគ្រប់ទិសទាំង ៤ ដោយន័យជាដើមថា ផ្សាយអស់ទិស ១ ។ ឈ្មោះថា **អប្បដិឃោ** ព្រោះអត្ថថា មិនបៀតបៀនសត្វទាំង-ឡាយ ឬសង្ខារទាំងឡាយ ។ ដោយភ័យក្នុងទិសទាំងនោះ ទិសណាមួយ ។

បទថា **សន្តុស្សមានោ** សេចក្តីថា ត្រេកអរដោយអំណាចនៃការត្រេកអរ ១២ យ៉ាង ។ បទថា **ឥតរីតរេន** បានដល់ ដោយបច្ច័យខ្ពស់ទាប ។ ក្នុងបាទព្រះគាថាថា **បរិស្សយានំ សហិតា អឆម្ភី** នោះ ឈ្មោះថា **បរិស្សយា**

ដោយអត្ថថា គ្របសង្កត់ ឬញ៉ាំងកាយនិងចិត្តឲ្យវិនាស រមែងគ្របសង្កត់កាយនិងចិត្តទាំងនោះ ធ្វើសម្បត្តិរបស់កាយ និងចិត្តទាំងនោះឲ្យសាបសូន្យ ។ បទថា **បរិស្សយា**នោះ ជាឈ្មោះរបស់អន្តរាយផ្លូវកាយ និងផ្លូវចិត្តដែលជាខាងក្រៅ មានសីហៈ និងខ្លាធំជាដើម និងដែលជាខាងក្នុង មានកាមច្ឆន្ទៈជាដើម ។

ឈ្មោះថា **សហិតា** ព្រោះអត្ថថា គ្របសង្កត់អន្តរាយទាំងនោះ ដោយអធិវាសនខន្តិ និងដោយធម៌ មានវីរិយៈជាដើម អធិប្បាយថា មិនតក់ស្លុតព្រោះមិនមានភ័យដែលធ្វើនូវការរឹងត្អឹង ។ យើងឃើញគុណក្នុងកិច្ចបដិបត្តិយ៉ាងនេះថា បុគ្គលត្រេកអរដោយបច្ច័យតាមមានតាមបាន ដូចសមណៈ ៤ រូបនោះ តាំងនៅក្នុងសន្តោស ដែលជាបទដ្ឋាននៃកិច្ចបដិបត្តិនេះ ឈ្មោះថានៅក្នុងទិសទាំង ៤ ដោយការចម្រើនមេត្តាជាដើម ក្នុងទិសទាំង ៤ និងជាអ្នកមិនក្តៅក្រហាយ ព្រោះមិនធ្វើនូវការបៀតបៀនក្នុងសត្វ និងសង្ខារទាំងឡាយ បុគ្គលនោះ ឈ្មោះថា គ្របសង្កត់នូវអន្តរាយមានប្រការដូចពោលហើយ ព្រោះភាពជាអ្នកនៅក្នុងទិសទាំង ៤ និងឈ្មោះថា ជាអ្នកមិនតក់ស្លុតព្រោះភាពជាអ្នកមិនបៀតបៀន ដូច្នេះហើយ បដិបត្តិដោយឧបាយ ហើយបានសម្រេចនូវបច្ចេកពោធិញ្ញាណ ។

ម្យ៉ាងទៀត យើងដឹងថា បុគ្គលត្រេកអរដោយបច្ច័យ តាមមានតាមបានដូចសមណៈទាំងនោះ ជាអ្នកនៅក្នុងទិសទាំង ៤ ដោយន័យដែលពោលហើយនោះឯង ប្រាថ្នានូវភាពជាបុគ្គលនៅក្នុងទិសទាំង ៤ យ៉ាងនេះហើយ បដិបត្តិ

ដោយឧបាយសម្រេចហើយ ព្រោះហេតុនោះ អ្នកដទៃកាលប្រាថ្នាឋានៈបែប នេះ ជាអ្នកគ្របសង្កត់នូវអន្តរាយ ព្រោះជាអ្នកនៅក្នុងទិសទាំង ៤ និងមិន តក់ស្លុត ព្រោះជាអ្នកមិនក្តៅក្រហាយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយ រមាស ដូច្នោះ ។ បទដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

ចាតុទ្ទិសគាថា ចប់

## គាថាទី ៩

គាថាថា **ឧស្សុង្គហា** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា អគ្គមហេសីរបស់ព្រះបាទក្រុងពារាណសី ព្រះនាងអស់ព្រះ ជន្ម បន្ទាប់អំពីនោះ កាលថ្ងៃដែលជាទីសោយសោកកន្លងទៅហើយ អមាត្យ ទាំងឡាយក្រាបទូលថា ធម្មតាព្រះរាជាទាំងឡាយ ទ្រង់គប្បីប្រាថ្នាព្រះមហេសី ក្នុងកិច្ចនោះៗ ពិតហើយ ទូលបង្គំសូមព្រះវរោកាស សូមទ្រង់នាំព្រះទេវីអង្គ ដទៃមកចុះ ។ ព្រះរាជាត្រាស់ថា បើយ៉ាងនោះ អ្នកចូរដឹងចុះ ។ អមាត្យទាំង នោះស្វែងរក ដឹងថា ព្រះរាជាក្នុងប្រទេសជិតខាង សោយទិវង្គតហើយ ព្រះ ទេវីរបស់ព្រះអង្គគ្រងរាជសម្បត្តិហើយ ព្រះនាងក៏មានព្រះគភ៌ អមាត្យទាំង- ឡាយដឹងថា ព្រះនាងអង្គនេះ សមគួរដល់ព្រះរាជា ដូច្នេះហើយ ទូលសូម ព្រះនាង ។ ព្រះនាងត្រាស់ថា ធម្មតាស្រីមានគភ៌ រមែងមិនជាទីគាប់ចិត្ត

របស់មនុស្សទាំងឡាយ សូមអ្នករង់ចាំទម្រាំខ្ញុំប្រសូតសិន បើរង់ចាំមិនបាន ក៏ចូរស្វែងរកស្រីដទៃចុះ ។ អមាត្យទាំងនោះ ទូលសេចក្ដីនោះដល់ព្រះរាជា ។ ព្រះរាជាត្រាស់ថា បើព្រះនាងមានគភ៌ ក៏មានទៅចុះ ចូរនាំមក អមាត្យទាំងនោះនាំមកហើយ ព្រះរាជាទ្រង់អភិសេកព្រះនាងហើយ ទ្រង់ប្រទានភោគទ្រព្យទាំងអស់ដល់មហេសី ទ្រង់សង្គ្រោះដោយការសង្គ្រោះ មានប្រការផ្សេងៗដល់បរិជនទាំងឡាយរបស់ព្រះនាង ព្រះនាងក៏ប្រសូតព្រះរាជឱរសតាមកាលដ៏សមគួរ ។ ព្រះរាជាទ្រង់ដាក់ព្រះរាជឱរសនោះលើភ្លៅ និងលើព្រះឧរៈគ្រប់ឥរិយាបថ ដូចឱរសរបស់ព្រះអង្គ ។

បន្ទាប់អំពីនោះ បរិវារជនរបស់ព្រះទេវីគិតថា ព្រះរាជាទ្រង់សង្គ្រោះព្រះរាជកុមារពន់ពេក ព្រះរាជហឫទ័យរបស់ទ្រង់ប្រោសប្រាណក្រៃលែងណេហ៍យចុះ ពួកយើងនឹងញុះញង់ព្រះរាជកុមារនោះឲ្យបែកគ្នា ។ លំដាប់នោះទើបទូលព្រះរាជកុមារថា បពិត្រអយ្យបុត្រ ទ្រង់ជាព្រះឱរសរបស់ព្រះរាជាពួកទូលបង្គំ មិនមែនជាឱរសរបស់ព្រះរាជាអង្គនេះទេ សូមទ្រង់កុំស្និទ្ធស្នាលក្នុងព្រះរាជាអង្គនេះឡើយ ។ លំដាប់នោះ ព្រះរាជកុមារដែលព្រះរាជាត្រាស់ថា ម្នាលកូន ចូរកូនមកណេះក្ដី ទ្រង់ចាប់ត្រង់ដៃទាញមកក្ដី ក៏មិនស្និទ្ធស្នាលជាមួយព្រះរាជាដូចក្នុងកាលមុន ព្រះរាជាទ្រង់ពិចារណាថា នុ៎ះ តើមានរឿងអ្វី ទ្រង់ជ្រាបព្រឹត្តិការណ៍នោះហើយ ទ្រង់ព្រះរាជតម្រិះថា អើ ជនទាំងនោះ សូម្បីអញសង្គ្រោះហើយយ៉ាងនេះ គង់ប្រព្រឹត្តគួររង្កៀស ទ្រង់នឿយ

ណាយ ទើបទ្រង់លះរាជសម្បត្តិចេញបួស ។ អមាត្យ និងបរិវារជនជាច្រើនដឹងថា ព្រះរាជាទ្រង់ផ្នួសហើយ ក៏ចេញបួសដែរ ។

មនុស្សទាំងឡាយដឹងថា ព្រះរាជា មួយអន្លើដោយបរិវារជនបួសហើយ ក៏នាំបច្ច័យប្រណីតៗ បញ្ជូនមកប្រគេន ព្រះរាជាឲ្យប្រគេនបច្ច័យ ដែលប្រណីតៗ ដល់បុគ្គលចាស់តាមលំដាប់ ក្នុងបព្វជិតទាំងនោះ បព្វជិតពួកណាបានបច្ច័យល្អ បព្វជិតទាំងនោះ ក៏សប្បាយចិត្ត បព្វជិតដែលបានបច្ច័យមិនល្អ ក៏សម្ដីងទោសថា ពួកយើងធ្វើកិច្ចទាំងពួង មានការបោសបរិវេណជាដើម តែបានកត្តអាក្រក់ និងសំពត់ចាស់ ។ ព្រះរាជាទ្រង់ជ្រាបរឿងនោះហើយ ទ្រង់ព្រះរាជតម្រិះថា ឱហ្ន៎ កាលប្រគេនបច្ច័យតាមលំដាប់អ្នកចាស់ បព្វជិតទាំងឡាយ ក៏សម្ដីងទោស ឱហ្ន៎ បរិស័ទនេះសង្គ្រោះបានលំបាកដូច្នេះហើយ ទ្រង់កាន់យកបាត្រ និងចីវរ តែមួយព្រះអង្គឯង ត្រាច់ចូលទៅក្នុងព្រៃ ប្រារព្ធវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ជនទាំងឡាយដែលមកក្នុងទីនោះ ទូលសួរកម្មដ្ឋាន ទើបត្រាស់ព្រះគាថានេះថា

បព្វជិតពួកខ្លះ ឬគ្រហស្ថអ្នកគ្រប់គ្រងផ្ទះ គេសង្គ្រោះបាន
ដោយកម្រ បុគ្គលមិនមានសេចក្ដីខ្វល់ខ្វាយចំពោះបុត្តនៃបុគ្គល
ដទៃ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

គាថានោះ ដោយអត្ថជាក់ច្បាស់ហើយនោះឯង តែដោយយោជនាមានដូច្នេះ បព្វជិតពួកមួយ ត្រូវសេចក្ដីមិនត្រេកអរគ្របសង្កត់ហើយ សូម្បីបព្វជិត

ទាំងនោះ ក៏សង្គ្រោះបានលំបាក មួយ៉ាងទៀត គ្រហស្ថអ្នកគ្រប់គ្រងផ្ទះ សង្គ្រោះបានលំបាកដូចគ្នា យើងខ្ទើមភាពជាអ្នកសង្គ្រោះបានលំបាកនោះ ប្រារព្ធនូវវិបស្សនា បានសម្រេចហើយ ដូច្នេះ ។ បទដ៏សេស គប្បីជ្រាបដោយន័យមុននោះឯង ។

ទុស្សង្គហគាថា ចប់

## គាថាទី ១០

គាថាថា **ឱរោបយិត្វា** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះរាជាព្រះនាមចតុមាសិកព្រហ្មទត្ត ក្នុងនគរពារាណសី យាងទៅកាន់ព្រះរាជឧទ្យាន ខាងដើមនៃរដូវក្ដៅ ទ្រង់ឃើញដើមរល្លួសម្ផុង ដែលសិប់ទ្រុបដោយស្លឹកពណ៌ខៀវ ក្នុងភូមិភាគដែលគួរជាទីត្រេកអរ ក្នុងព្រះរាជឧទ្យាននោះ ត្រាស់ថា ចូររៀបចំទីដេកឲ្យយើង ត្រង់គល់រល្លួសម្ផុង ទ្រង់ក្រសាលក្នុងព្រះរាជឧទ្យានហើយ ទ្រង់ផ្ទំត្រង់គល់រល្លួសម្ផុងនោះ រហូតដល់ពេលល្ងាច ។ ទ្រង់យាងទៅកាន់ព្រះរាជឧទ្យាន ក្នុងខែកណ្ដាលនៃរដូវក្ដៅទៀត ក្នុងកាលនោះ ដើមរល្លួសម្ផុងក៏ចេញផ្កាហើយ ក្នុងកាលនោះ ទ្រង់ក៏ធ្វើយ៉ាងនោះ ។ ព្រះរាជាយាងទៅកាន់ព្រះរាជឧទ្យាន ក្នុងចុងរដូវក្ដៅទៀត ក្នុងកាលនោះ ដើមរល្លួសម្ផុងក៏ជ្រុះស្លឹកអស់ ដូចជាដើមឈើងាប់ ក្នុងកាល

នោះ ទ្រង់មិនឃើញដើមឈើនោះឡើយ ទ្រង់ត្រាស់ឲ្យរៀបចំទីបន្ទំ ត្រង់គល់រលួសផ្អុននោះឯង តាមដែលទ្រង់ធ្លាប់ប្រព្រឹត្តមកក្នុងកាលមុន ។ អមាត្យទាំងឡាយសូម្បីដឹង ក៏រៀបចំទីបន្ទំត្រង់គល់រលួសផ្អុននោះ ព្រោះខ្លាចថា ព្រះរាជាទ្រង់ត្រាស់បញ្ជាហើយ ។

ព្រះរាជាទ្រង់ក្រសាលក្នុងព្រះរាជឧទ្យាន លុះពេលល្ងាច ទ្រង់ក៏ផ្ទំត្រង់គល់រលួសផ្អុននោះ ទ្រង់ឃើញដើមឈើនោះហើយ ទ្រង់ព្រះរាជតម្រិះថា ក្នុងកាលមុន ដើមឈើនេះ ត្រសុំត្រសាយដោយស្លឹក គួរពេចពិលរមិលមើលក្រៃលែង ដូចសម្រេចដោយកែវមណី ។ បន្ទាប់អំពីនោះ ក៏ជាដើមឈើដែលមានផ្ការីកស្គុសស្គាយ ដូចពន្លកនៃកែវប្រពាល ក្នុងរវាងមែកដែលមានពណ៌ខៀវគួរមើល ដូចមាសដ៏មានសិរី និងខាងក្រោមភូមិភាគនៃដើមរលួសនោះសោតក៏ដេរដាសដោយខ្សាច់ ដូចគ្នានឹងមុក្តាហារ ដេរដាសទៅដោយផ្កាដែលជ្រុះអំពីទង ដូចក្រាលដោយសំពត់កម្ពលក្រហម ថ្ងៃនេះដើមឈើឈ្មោះនេះឈរសល់តែដើម និងមែក ដូចដើមឈើងាប់ ឱដើមឈើនេះ ត្រូវជរាបះខ្ទប់ហើយ រុះរោយទៅ ដូច្នេះហើយ ទ្រង់បានអនិច្ចសញ្ញាថា សូម្បីអនុបាទិន្នកសង្ខារ គង់ត្រូវជរាប៉ះខ្ទប់បាន នឹងពោលថ្វីដល់ឧបាទិន្នកសង្ខារនោះ ហើយទ្រង់ឃើញច្បាស់នូវសង្ខារទាំងពួង តាមទំនងនៃអនិច្ចសញ្ញានោះ ដោយភាពជាទុក្ខ និងដោយភាពជាអនត្តា ទ្រង់ប្រាថ្នាថា ឱហ្ន៎ អញគប្បីប្រាសចាកភេទគ្រហស្ថ ដូចដើមរលួសជ្រុះស្លឹក ដូច្នោះ ទ្រង់ផ្ទំដោយបង្អៀងស្តាំ ត្រង់

ទីបន្ទំនោះឯង ក៏ធ្វើឲ្យជាក់ច្បាស់នូវព្រះបច្ចេកពោធិញ្ញាណដោយលំដាប់ ក្នុងកាលយាងទៅអំពីព្រះរាជឧទ្យាននោះ កាលអមាត្យទាំងឡាយទូលថា បពិត្រមហារាជ កាលនេះ ជាកាលដែលទ្រង់គួរយាងត្រឡប់ ទើបត្រាស់ថា យើងមិនមែនជាព្រះរាជាជាដើម បានត្រាស់គាថាដោយន័យមុននោះឯងថា

ធីរបុរស លះបង់នូវវត្ថុទាំងឡាយ ជាគ្រឿងប្រាកដនូវភាពជាគ្រហស្ថ កាត់ចំណងរបស់គ្រហស្ថទាំងឡាយ ដូចជារលួសផ្អុងជម្រុះស្លឹក គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ក្នុងគាថានោះ បទថា **ឱរោបយិត្វា** សេចក្តីថា បោលហើយ នាំចេញហើយ ។ បទថា **គិហិព្យញ្ជនានិ** សេចក្តីថា សក់ ពុកមាត់ សំពត់សគ្រឿងប្រដាប់ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ស្ត្រី បុត្ត ទាសី ទាសាជាដើមនោះ រមែងសម្តែងភាពជាគ្រហស្ថឲ្យប្រាកដ ព្រោះដូច្នោះ ទើបហៅថា **គិហិព្យញ្ជនានិ** ប្រែថា គ្រឿងប្រាកដនៃគ្រហស្ថ ។

បទថា **សញ្ឆិន្នបត្តោ** សេចក្តីថា មានស្លឹកជ្រុះហើយ ។ បទថា **ឆេត្វាន** បានដល់ កាត់ហើយដោយមគ្គញ្ញាណ ។ បទថា **ធីរោ** បានដល់ ដែលប្រកបព្រមដោយមគ្គវិរិយៈ ។ បទថា **គិហិពន្ធនានិ** បានដល់ គ្រឿងចងគឺកាម ។ ព្រោះកាមទាំងឡាយ ជាគ្រឿងចងរបស់គ្រហស្ថទាំងឡាយ ។

អត្ថតាមបទមានប៉ុណ្ណេះសិន ចំណែកអធិប្បាយមានដូចតទៅនេះ ព្រះរាជាទ្រង់ព្រះតម្រិះយ៉ាងនេះថា ឱហ្ន៎ សូម្បីអញលះហេតុជាគ្រឿងប្រាកដនៃគ្រហស្ថហើយ គប្បីដូចដើមរលួសផ្អុង ដែលមានស្លឹកជ្រុះ ដូច្នោះ ទ្រង់ប្រារព្ធនូវវិបស្សនា សម្រេចហើយ ដូច្នេះ បទដ៏សេស គប្បីជ្រាបដោយន័យមុននោះឯង ។៙

## កោវិឡារគាថា ចប់

## វគ្គទី ១ ចប់

# វគ្គទី ២

## គាថាទី ១១ ទី ១២

គាថាថា **សចេ លភេថ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងអតីតកាល ព្រះបច្ចេកពោធិសត្វ ២ អង្គបួសក្នុងសាសនារបស់ព្រះដ៏មានព្រះភាគព្រះនាមកស្សបៈ បំពេញគតបច្ចាគតវត្តអស់ ២ ម៉ឺនឆ្នាំ ហើយកើតក្នុងទេវលោក ច្យុតចាកទេវលោកនោះហើយ ទេវបុត្រច្បងបដិសន្ធិជាព្រះរាជឱរសរបស់ព្រះបាទពារាណសី ទេវបុត្រប្អូន បដិសន្ធិជាកូនរបស់បុរោហិត ។ ជនទាំងពីរនោះ បដិសន្ធិក្នុងថ្ងៃតែមួយ ប្រសូតចាកគភ៌មាតាក្នុងថ្ងៃតែមួយ ជាសម្លាញ់លេងដីជាមួយគ្នា ។ បុត្របុរោហិត ជាមនុស្សមានបញ្ញា បានទូលព្រះរាជកុមារថា បពិត្រសម្លាញ់ ទ្រង់នឹងបានរាជសម្បត្តិដោយអំណោះតអំពីព្រះបិតា ខ្ញុំនឹងធ្វើជាបុរោហិត ទ្រង់បានទទួលការសិក្សាល្អហើយ គួរគ្រប់គ្រងរាជសម្បត្តិឲ្យជាសុខ មកពួកយើងនឹងរៀនសិល្បសាស្ត្រជាមួយគ្នា បន្ទាប់អំពីនោះ ជនទាំងពីរដែលមានកម្មសន្សំហើយក្នុងជាតិមុន ត្រាច់ស្វែងរកកិក្ខាហារក្នុងគាម និងនិគមជាដើម ទៅកាន់ស្រុកក្នុងជនបទជាយដែន ។

ព្រះបច្ចេកពុទ្ធទាំងឡាយ ចូលទៅកាន់ស្រុកនោះ ក្នុងពេលភិក្ខាចារលំដាប់នោះ មនុស្សទាំងឡាយឃើញព្រះបច្ចេកពុទ្ធហើយ កើតនូវឧស្សាហ៍រមែងក្រាលអាសនៈ បង្អោនខាទនីយៈ ភោជនីយៈដ៏ប្រណីតថ្វាយ រាប់អានបូជា ។ សម្លាញ់ទាំងពីរនោះ មានការគិតយ៉ាងនេះថា មនុស្សមានត្រកូល

ដូចពួកយើងមិនមាន មនុស្សទាំងនេះបើប្រាថ្នា ក៏ឲ្យភិក្ខាដល់ពួកយើង បើមិនប្រាថ្នាក៏មិនឲ្យ តែរមែងធ្វើសក្ការៈបែបនេះ ដល់បព្វជិតទាំងនេះ បព្វជិតទាំងនេះប្រហែលជាចេះសិល្បសាស្ត្រណាមួយពិតប្រាកដ ណ្ហើយចុះ ពួកយើងនឹងរៀនសិប្បៈ ក្នុងសម្នាក់របស់បព្វជិតទាំងនោះ ដូច្នេះ ។

សម្លាញ់ទាំងពីរនោះ កាលមនុស្សទាំងឡាយត្រឡប់ហើយ បានឱកាសទើបអារាធនាថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ទាំងឡាយ ចេះនូវសិប្បៈណា សូមឲ្យពួកខ្ញុំសិក្សាសិប្បៈនោះផង ព្រះបច្ចេកពុទ្ធទាំងឡាយពោលថា អ្នកដែលមិនបានបួស មិនអាចសិក្សាបានទេ ។ សម្លាញ់ទាំងពីរនោះទើបសូមបព្វជ្ជាហើយបួស ។

លំដាប់នោះ ព្រះបច្ចេកពុទ្ធទាំងឡាយ បានប្រាប់អភិសមាចារិកវត្តដល់បព្វជិតទាំងពីរនោះ ដោយន័យជាដើមថា លោកគប្បីស្លៀកយ៉ាងនេះ គប្បីដណ្តប់យ៉ាងនេះ ហើយប្រគល់បណ្ណសាលាឲ្យមួយរូប ១ ខ្នង ដោយពោលថា សេចក្តីត្រេកអរក្រៃលែង ក្នុងភាពជាបុគ្គលម្នាក់ឯង ជាការសម្រេចនៃសិប្បៈនេះ ព្រោះដូច្នោះ គប្បីអង្គុយម្នាក់ឯងប៉ុណ្ណោះ គប្បីចង្ក្រម គប្បីឈរ គប្បីដេកម្នាក់ឯង ។ បន្ទាប់អំពីនោះ បព្វជិតទាំងពីរ ក៏ចូលកាន់បណ្ណសាលារៀងៗ ខ្លួន ហើយអង្គុយ ។ បុត្របុរោហិត បាននូវការតាំងមាំនៃចិត្ត ចាប់តាំងពីអង្គុយហើយបានឈាន ចំណែករាជបុត្ត អផ្សុកមួយស្របក់ប៉ុណ្ណោះក៏មកកាន់សម្នាក់បុត្តបុរោហិតនោះៗ ឃើញព្រះរាជបុត្ត ទើបសួរថា មានរឿងអ្វី

សម្លាញ់ ព្រះរាជកុមារត្រាស់ថា ខ្ញុំអផ្សុក បុត្តបុរោហិតពោលថា បើដូច្នោះ សូមអង្គុយ ។

ព្រះរាជបុត្តនោះ អង្គុយក្នុងទីនោះមួយស្របក់ហើយ ពោលថា សម្លាញ់ បានឮថា ការត្រេកអរក្រៃលែងក្នុងភាពជាបុគ្គលម្នាក់ឯង ជាការសម្រេចនៃសិប្បៈនេះ ។ បុត្តបុរោហិតពោលថា យ៉ាងនោះឯងសម្លាញ់ បើដូច្នោះ ចូរលោកទៅកាន់ឱកាស ដែលខ្លួនអង្គុយនោះឯង យើងនឹងរៀនសេចក្តីសម្រេចនៃសិប្បៈនេះ ព្រះរាជបុត្តនោះទៅហើយ មួយរំពេចប៉ុណ្ណោះក៏អផ្សុកទៀត ទើបមករកអស់វារៈ ៣ ដង ដោយន័យមុននោះឯង ។ បន្ទាប់អំពីនោះ បុត្តបុរោហិត ក៏បញ្ជូនរាជបុត្តត្រឡប់ទៅយ៉ាងនោះ កាលព្រះរាជបុត្តទៅហើយ គិតថា ព្រះរាជបុត្រនេះ ប្រកាសកម្មរបស់ខ្លួន និងរបស់អញ ទើបមកក្នុងទីនេះរឿយៗ ទើបចេញអំពីបណ្ណសាលា ហើយចូលទៅកាន់ព្រៃ ។

ចំណែកព្រះរាជបុត្ត អង្គុយក្នុងបណ្ណសាលារបស់ខ្លួនជាអ្នកអផ្សុកទៀត ដោយមួយរំពេចប៉ុណ្ណោះ ទើបមកកាន់បណ្ណសាលារបស់បុត្តបុរោហិតនោះ រកមើលក្នុងទីផ្សេងៗ ក៏មិនឃើញបុត្តបុរោហិត ទើបគិតថា បុគ្គលណាក្នុងកាលជាគ្រហស្ថ នាំបណ្ណាការមកក៏មិនបានឃើញអញ បុគ្គលនោះ កាលអញមកហើយ ក៏មិនបំណងឲ្យអញឃើញ ចៀសចេញទៅហើយ ។ ឱ ចិត្តឯងមិនខ្មាស ឯងនាំអញមកក្នុងទីនេះអស់វារៈ ៤ ដង ឥឡូវនេះ អញនឹងមិនប្រព្រឹត្តទៅក្នុងអំណាចរបស់ឯង តែនឹងឲ្យឯងប៉ុណ្ណោះ ជាអ្នកនៅក្នុងអំណាច

របស់អញ ដូច្នេះហើយ ចូលទៅកាន់សេនាសនៈរបស់ខ្លួន ប្រារព្ធវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ ហោះទៅកាន់ភ្នំគន្ធមាទនៈ ចំណែកបុត្តបុរោហិត ចេញអំពីបណ្ណសាលា ចូលព្រៃហើយ ប្រារព្ធវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ហើយទៅកាន់ភ្នំគន្ធមាទនៈដូចគ្នា ។

ព្រះបច្ចេកពុទ្ធទាំងពីរអង្គនោះ អង្គុយលើផ្ទាំងថ្មមនោសិលាហើយ បាន ពោលឧទានគាថាទាំងនេះ មួយរូប ១ គាថាថា

បើបុគ្គលបានអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅដោយប្រពៃ ជាសម្លាញ់ មានប្រាជ្ញារក្សាខ្លួន ត្រាច់ទៅជាមួយគ្នា គប្បីសង្កត់នូវសេចក្តី អន្តរាយទាំងពួងបាន គប្បីមានចិត្តត្រេកអរ មានស្មារតី ត្រាច់ ជាមួយសម្លាញ់នោះទៅចុះ ។

បើបុគ្គលរកអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅដោយប្រពៃ ជាសម្លាញ់ មានប្រាជ្ញារក្សាខ្លួន ត្រាច់ទៅជាមួយគ្នាពុំបានទេ គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចជាព្រះរាជាលះបង់នូវដែនដែល ព្រះអង្គឈ្នះ ហើយ ឬដូចដំរីឈ្មោះមាតង្គៈលះបង់ហ្វូង ត្រាច់ទៅក្នុងព្រៃ ដូច្នេះ ។

ក្នុងគាថានោះ បទថា **និបកំ** បានដល់ បណ្ឌិត អ្នកមានប្រាជ្ញារក្សាខ្លួន ដោយប្រក្រតី គឺឈ្លាសក្នុងកសិណបរិកម្មជាដើម ។ បទថា **សាធុវិហារី** បានដល់ ជាអ្នកប្រកបដោយអប្បនាវិហារ ឬឧបចារ ។ បទថា **ធីរំ** បានដល់

ជាអ្នកដល់ព្រមដោយធិតិ ។ ក្នុងគាថានោះ លោកពោលដល់ការដល់ព្រមដោយធិតិដោយអត្ថថា **ធិបក** តែក្នុងអដ្ឋកថានេះ អធិប្បាយថា ជាអ្នកដល់ព្រមដោយធិតិនោះឯង ។ ការប្រឹងប្រែងមិនរួញរា ឈ្មោះថា **ធិតិ** ពាក្យថា ធិតិនោះ ជាឈ្មោះនៃសេចក្តីព្យាយាម ដែលប្រព្រឹត្តទៅហើយ យ៉ាងនេះថា **កាមំ តចោ ច នហារុ ច** ប្រែថា ស្បែក សរសៃ ... សូមឲ្យសល់នៅចុះ ម្យ៉ាងទៀត ឈ្មោះថា **ធីរ** ព្រោះអត្ថថា មានបាបបន្សាត់ហើយ ។

បាទគាថាថា **រាជាវ រដ្ឋំ វិជិតំ បហាយ** សេចក្តីថា ព្រះរាជាដែលជាបរបក្ខ ទ្រង់ជ្រាបថា ដែនដែលឈ្នះហើយ នាំសេចក្តីវិនាសមកឲ្យ ទ្រង់លះរាជសម្បត្តិ ទ្រង់ត្រាច់ទៅតែឯកអង្គយ៉ាងណា បុគ្គលលះសម្លាញ់ ដែលជាបុគ្គលពាលហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូច្នោះ ។

មួយប្រការទៀត បទថា **រាជាវ រដ្ឋំ** សេចក្តីថា ព្រះបាទសុត្តសោម ទ្រង់លះដែនដែលទ្រង់ឈ្នះហើយ ត្រាច់ទៅតែឯកអង្គ យ៉ាងណា ព្រះមហាជនក លះបង់ដែនដែលទ្រង់ឈ្នះហើយ ត្រាច់ទៅតែឯកអង្គ យ៉ាងណា បុគ្គលគប្បីត្រាច់ទៅម្នាក់ឯង យ៉ាងនោះ ។ អត្ថនៃគាថានោះ មានប្រមាណប៉ុណ្ណេះ ពាក្យដ៏សេស គប្បីដឹងបានដោយទំនងដែលពោលហើយ ព្រោះហេតុនោះ ទើបមិនបានអធិប្បាយឲ្យពិស្តារ ។

សហាយវណ្ណនាគាថា ចប់

## គាថាទី ១៣

គាថានេះថា **អទ្ធា បសំសាម** ដូច្នេះ រឿងកើតឡើងតាំងអំពីព្រះបច្ចេកពុទ្ធទាំងឡាយ អង្គុយលើអាសនៈដែលក្រាលហើយត្រង់រាលហាលដូចគ្នា និង អត្ថុប្បត្តិហេតុ ក្នុងចាតុទ្ទិសគាថានោះឯង ។ ចំណែកសេចក្តីប្លែកគ្នា មាន ដូចតទៅនេះថា

ព្រះរាជាអង្គនោះ ទ្រង់តក់ស្លុតក្នុងរាត្រីអស់ ៣ ដងយ៉ាងណា ព្រះរាជាអង្គនេះ មិនដូច្នោះឡើយ ទាំងព្រះអង្គក៏មិនបានរៀបចំយញ្ញ ព្រះរាជាទ្រង់និមន្តព្រះបច្ចេកពុទ្ធទាំងឡាយឲ្យគង់លើអាសនៈ ដែលគេក្រាលត្រង់របៀងហើយ ត្រាស់សួរថា លោកម្ចាស់ទាំងឡាយឈ្មោះអ្វី ព្រះបច្ចេកពុទ្ធតបថា មហាបពិត្រ ពួកអាត្មាឈ្មោះថា **អនវជ្ជភោជន** ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ពាក្យថា **អនវជ្ជភោជន** នេះ មានប្រយោជន៍ដូចម្តេច ព្រះបច្ចេកពុទ្ធត្រាស់ថា មហាបពិត្រ ពួកអាត្មាបានរបស់ល្អក្តី មិនល្អក្តី ក៏មិនបរិភោគដោយអាការខុសប្លែក ។

ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ ទ្រង់ព្រះរាជតម្រិះថា ណ្ហើយចុះ អញនឹងសាកល្បងសមណៈទាំងនេះ តើដូច្នោះមែន ឬមិនមែន ។ ក្នុងថ្ងៃនោះ ទ្រង់អង្គាសដោយបាយចុងអង្ករ មានទឹកជ្រក់ជាគម្រប់ពីរ ព្រះបច្ចេកពុទ្ធទាំងឡាយ ក៏បរិភោគមិនសម្តែងអាការខុសប្លែក ដូចបរិភោគអមតភោជន ព្រះរាជាទ្រង់ព្រះរាជតម្រិះថា សមណៈទាំងនេះ ជាអ្នកមិនសម្តែងអាការខុសប្លែក ព្រោះបានប្តេជ្ញាហើយក្នុងថ្ងៃនេះ អញនឹងដឹងក្នុងថ្ងៃស្អែក ទើបទ្រង់និមន្តដើម្បី

ឆាន់ក្នុងថ្ងៃស្អែក ។ ក្នុងថ្ងៃទី ២ បន្ទាប់អំពីនោះ ក៏ទ្រង់ធ្វើយ៉ាងនោះ ព្រះបច្ចេកពុទ្ធទាំងនោះក៏បរិភោគដូចមុន ។ លំដាប់នោះ ព្រះរាជាទ្រង់ព្រះរាជតម្រិះថា ឥឡូវនេះ អញនឹងថ្វាយវត្ថុដែលល្អជាងនេះសាកមើល ដូច្នេះហើយ ទ្រង់និមន្តទៀត ទ្រង់ធ្វើសក្ការៈធំអស់ពីរថ្ងៃ ទ្រង់អង្គាសដោយខាទនីយៈ ភោជនីយៈដ៏ប្រណីត ព្រះបច្ចេកពុទ្ធទាំងនោះ ក៏ឆាន់មិនមានអាការៈខុសប្លែកដូចមុន ពោលមង្គលថ្វាយព្រះរាជាហើយ ក៏ចៀសចេញទៅ ។

ព្រះរាជាកាលព្រះបច្ចេកពុទ្ធចៀសចេញទៅមិនយូរ ទើបទ្រង់ព្រះរាជតម្រិះថា សមណៈនេះបរិភោគភោជនមិនមានទោស ឱហ្ន៎ អញគប្បីបរិភោគភោជនមិនមានទោស ដូច្នេះហើយ ទ្រង់លះរាជសម្បត្តិ សមាទានបព្វជ្ជា ប្រារព្ធវិបស្សនា បានជាព្រះបច្ចេកពុទ្ធ ទ្រង់ញ៉ាំងអារម្មណ៍របស់ព្រះអង្គឲ្យជាក់ច្បាស់ ក្នុងកណ្តាលជំនុំព្រះបច្ចេកពុទ្ធទាំងឡាយ ត្រង់គល់មញ្ជូសកព្រឹក្ស ត្រាស់ព្រះគាថានេះថា

តាមពិត យើងសរសើរនូវការបរិបូណ៌ដោយសម្លាញ់ហើយ តែ
សម្លាញ់មានគុណប្រសើរជាង និងសម្លាញ់មានគុណស្មើ បុគ្គល
គួរសេពគប់ រាប់រក បើកុលបុត្តចង់បានប្រយោជន៍ រកសម្លាញ់
ទាំងនោះពុំបានទេ គប្បីជាអ្នកបរិភោគភោជនដែលមិនមានទោស
ហើយត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

គាថានោះ ពោលដោយអត្ថនៃបទឆាយយល់ទាំងអស់ហើយ ។ សម្លាញ់

ទាំងឡាយ ដល់ព្រមដោយសីលក្ខន្ធជាដើម ដែលជាអសេក្ខៈតែម្យ៉ាងប៉ុណ្ណោះ ក្នុងបទថា **សហាយសម្បទំ** នេះ គប្បីជ្រាបថា សម្លាញ់ ជាអ្នកដល់ព្រម ។ ចំណែកយោជនាក្នុងបទនេះ មានដូច្នេះថា សម្លាញ់ដែលដល់ព្រមនេះ បាន ពោលហើយ យើងរមែងសរសើរសម្លាញ់ដែលដល់ព្រមនោះពិត អធិប្បាយ ថា យើងសរសើរដោយចំណែកមួយប៉ុណ្ណោះ ។ សេចក្តីនេះដូចម្តេច គឺគប្បី គប់រកសម្លាញ់ដ៏ប្រសើរបំផុត ឬដែលស្មើគ្នា ។ ព្រោះហេតុអ្វី ព្រោះកាល កុលបុត្តគប់រកសម្លាញ់ដែលប្រសើរបំផុត ដោយគុណធម៌ មានសីលជាដើម ជារបស់ខ្លួន ធម៌ទាំងឡាយ មានសីលជាដើម ដែលមិនទាន់កើត រមែងកើត ឡើង ដែលកើតហើយ រមែងដល់នូវសេចក្តីចម្រើន ដុះដាល បរិបូណ៌ កាល គប់រកសម្លាញ់ដែលស្មើគ្នា ធម៌ទាំងឡាយដែលបានហើយ រមែងមិនវិនាស ព្រោះទ្រង់ជ្រាបភាពស្មើគ្នានិងគ្នា និងព្រោះកម្ចាត់សេចក្តីរង្កៀសអំពីកុលបុត្ត ដែលប្រាថ្នាប្រយោជន៍ មិនបានគប់រកសម្លាញ់ដែលប្រសើរបំផុត និងដែល ស្មើគ្នាទាំងនោះ វៀរមិច្ឆាជីវៈ មានការបោកបញ្ឆោតជាដើម បរិភោគភោជន ដែលកើតឡើងដោយធម៌ និងដោយស្មើ និងមិនឲ្យបដិឃានុស័យក្នុងភោជន កើតឡើង ជាអ្នកបរិភោគភោជនមិនមានទោស ត្រាច់ទៅតែម្នាក់ឯង ដូចកុយ រមាស ដូច្នោះ ព្រោះយើងត្រាច់ទៅយ៉ាងនេះ ទើបសម្រេចសម្បត្តិនេះឯង ។

**អនវជ្ជភោជិគាថា ចប់**

# គាថាទី ១៤

គាថាថា **ធិស្វា សុវណ្ណស្ស** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះបាទក្រុងពារាណសីមួយអង្គ យាងចូលទៅកាន់ទីបន្ទំ ក្នុងពេលថ្ងៃក្នុងគិម្ហសម័យ ។ ក្នុងព្រះរាជសម្នាក់របស់ព្រះអង្គ នាងវណ្ណទាសីកំពុងបុកខ្លឹមចន្ទន៍ ក្នុងដៃម្ខាងរបស់នាង មានកងដៃមួយ ក្នុងដៃម្ខាងទៀត មានកងដៃពីរប៉ះខ្ទប់គ្នា កងមួយក្រៅអំពីនេះមិនប៉ះខ្ទប់គ្នា ព្រះរាជាទ្រង់ឃើញហេតុនោះហើយ ទើបទ្រង់សម្លឹងមើលនាងទាសីរឿយៗ ទ្រង់ព្រះតម្រិះថា ការនៅជាពួក រមែងមានការប៉ះគ្នា ការនៅម្នាក់ឯង រមែងមិនមានការប៉ះគ្នាយ៉ាងនេះឯង ។

ដោយសម័យនោះ ព្រះទេវីប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាងប្រថាប់ឈរថ្វាយការបក់ផ្លិត ព្រះនាងព្រះតម្រិះថា ព្រះរាជាប្រហែលជាមានចិត្តប្រតិព័ទ្ធក្នុងនាងវណ្ណទាសី ព្រះនាងឲ្យទាសីនោះចេញទៅ ហើយប្រារព្ធបុកដោយព្រះអង្គឯង ក្នុងព្រះពាហាទាំងសងខាងរបស់ព្រះនាង មានកងដៃមាសជាច្រើនប៉ះខ្ទប់គ្នា ឮសំឡេងយ៉ាងខ្លាំង ព្រះរាជាទ្រង់រង្កៀសក្រៃលែងទាំងដែលកំពុងផ្ទំខាងស្តាំ ទ្រង់ប្រារព្ធវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេក-ពោធិញ្ញាណ ។

ព្រះទេវីកាន់ខ្លឹមចន្ទន៍ យាងចូលទៅគាល់ព្រះរាជាអង្គនោះ ដែលផ្ទំជាសុខ ដោយសេចក្តីសុខដ៏កំពូល ទូលថា បពិត្រមហារាជ ខ្ញុំម្ចាស់នឹងលាបព្រះរាជាត្រាស់ថា កុំឡើយ នាងចូរចេញទៅចុះ ព្រះនាងទូលថា បពិត្រមហា-

រាជ ព្រោះហេតុអ្វី ទើបត្រាស់ថា យើងមិនមែនព្រះរាជា ។ អមាត្យទាំងឡាយស្តាប់ការសន្ទនានោះរបស់ព្រះរាជា និងព្រះទេវីនោះយ៉ាងនោះហើយ ទើបចូលទៅគាល់ ព្រះរាជាដែលអមាត្យទាំងនោះទូលដោយវាទៈថា មហារាជ ទើបត្រាស់ថា នែអមាត្យ យើងមិនមែនព្រះរាជា ។ ពាក្យដ៏សេស ក៏ដូចគ្នានឹងពាក្យដែលពោលហើយក្នុងគាថាដើមនោះឯង ចំណែកគាថាវណ្ណនា មានដូច្នេះថា

បុគ្គល ឃើញនូវកងមាសទាំងពីរដ៏ភ្លឺផ្លេក ដែលជាងមាសធ្វើ
សម្រេចហើយដោយល្អ រណ្តំគ្នាពួដ៏ដៃ គប្បីត្រាច់ទៅតែម្នាក់ឯង
ដូចកុយរមាស ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ទិស្វា** បានដល់ សម្លឹងមើលហើយ ។ បទថា **សុវណ្ណស្ស** បានដល់ មាស ។ បាលីដ៏សេស ( បន្ថែមចូលមក ) ថា **វលយានិ** ។ អត្ថនេះ មានន័យតាមបាលីដ៏សេស ។

បទថា **បភស្សរានិ** បានដល់ ដែលភ្លឺផ្លេកជាប្រក្រតី អធិប្បាយថា មានពន្លឺរុងរឿង ។ បទដ៏សេស ជាបទមានអត្ថងាយយល់ហើយ ។

ចំណែកយោជនាមានដូច្នេះថា យើងសម្លឹងមើលកងដៃមាស ដែលប៉ះខ្ទប់គ្នាក្នុងកដៃ ទើបគិតថា កាលមានការនៅជាក្រុម រមែងមានការប៉ះខ្ទប់គ្នា កាលមានការនៅម្នាក់ឯង មិនប៉ះខ្ទប់គ្នាឡើយ ទើបប្រារព្ធវិបស្សនាបានសម្រេចហើយ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

# គាថាទី ១៥

គាថាថា **ឯវំ ទុតិយេន** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះបាទក្រុងពារាណសីមួយអង្គនៅក្មេង ទ្រង់មានបំណងនឹងបួស ទើបបញ្ជាអមាត្យទាំងឡាយថា ចូរពួកអ្នកទទួលព្រះទេវីហើយគ្រប់គ្រងរាជសម្បត្តិចុះ យើងនឹងបួស ។ អមាត្យទាំងឡាយក្រាបទូលថា បពិត្រមហារាជ រាជសម្បត្តិមិនមានព្រះរាជា ពួកទូលបង្គំមិនអាចរក្សាបាន ព្រះរាជាក្នុងប្រទេសជិតខាងទាំងឡាយ នឹងមកដណ្តើមរាជសម្បត្តិ សូមទ្រង់បង្អង់ ទម្រាំព្រះរាជឱរសមួយអង្គកើតសិន ដូច្នេះហើយ ទូលឲ្យព្រះរាជាទ្រង់យល់ព្រម ។ ព្រះរាជាទ្រង់មានព្រះហឫទ័យទន់ភ្លន់ ទើបព្រមទទួល ។ បន្ទាប់មក ព្រះទេវីក៏មានគភ៌ ព្រះរាជាត្រាស់បញ្ជាអមាត្យទាំងនោះទៀតថា ព្រះទេវីទ្រង់គភ៌ហើយ អ្នកទាំងឡាយ ចូរអភិសេកបុត្តដែលកើតហើយក្នុងរាជសម្បត្តិ គ្រប់គ្រងរាជសម្បត្តិចុះ យើងនឹងបួស ។ ពួកអមាត្យទូលឲ្យព្រះរាជាយល់ព្រមទៀតថា បពិត្រមហារាជ សេចក្តីនោះជាការដឹងបានលំបាកថា ព្រះទេវីប្រសូតព្រះឱរស ឬព្រះធីតា សូមទ្រង់បង្អង់ចាំកាលប្រសូតិសិនចុះ តមក ព្រះទេវីក៏ប្រសូតព្រះឱរស ក្នុងកាលនោះ ព្រះរាជាក៏ត្រាស់ប្រាប់អាមាត្យទាំងឡាយយ៉ាងនោះ ។ ពួកអមាត្យក៏ទូលអង្វរ ឲ្យព្រះរាជាទ្រង់យល់ព្រមទៀត ដោយហេតុជាច្រើនថា បពិត្រមហារាជ សូមទ្រង់បង្អង់សិន ទម្រាំព្រះឱរសមានកម្លាំងរឹងមាំ ។

បន្ទាប់អំពីនោះ កាលព្រះរាជកុមារទ្រង់មានកម្លាំងរឹងមាំហើយ ព្រះរាជាក៏ត្រាស់ឲ្យប្រជុំអមាត្យទាំងឡាយ ហើយត្រាស់ថា កុមារនេះមានកម្លាំង

រឹងប៉ឹងហើយ ចូរពួកអ្នកអភិសេកកុមារនោះ ក្នុងរាជសម្បត្តិចុះ ដូច្នេះ ទ្រង់មិនប្រទានព្រះរាជឱកាសឲ្យដល់អមាត្យ ត្រាស់ឲ្យនាំបរិក្ខារទាំងពួង មានសំពត់កាសាវពស្ត្រជាដើមមកអំពីផ្សារ ទ្រង់បួសក្នុងនគរនោះឯង ហើយយាងចេញទៅ ដូចព្រះបាទមហាជនក ។ បរិវារជនទាំងពួង កន្ទក់កន្ទេញ អនេកប្បការជាប់តាមព្រះរាជា ។ ព្រះរាជាយាងទៅ រហូតដល់ខាងចុងព្រំដែនរបស់ព្រះអង្គ ទ្រង់ធ្វើស្នាមគំនូសដោយឈើច្រត់ ត្រាស់ថា កុំគប្បីឆ្លងគំនូសនេះ ។ មហាជនដេកលើដី យកក្បាលទល់គំនូសខ្សឹកខ្សួលទូលថា បពិត្រអយ្យបុត្ត ឥឡូវនេះ ព្រះរាជាដាក់អាជ្ញាដល់ព្រះអង្គ ទ្រង់នឹងធ្វើដូចម្តេច ហើយឲ្យកុមារនោះយាងឆ្លងស្នាមគំនូសទៅ ។ ព្រះរាជកុមារទ្រង់ស្រែកថា បិតា បិតា ហើយរត់ទៅទាន់ព្រះរាជា។ ទ្រង់ព្រះរាជតម្រិះថា អញគ្រប់គ្រងនូវមហាជននោះ សោយរាជសម្បត្តិ ឥឡូវនេះ អញមិនអាចគ្រប់គ្រងកុមារនេះត្រឹមតែមួយ ឬដូចម្តេច ទ្រង់នាំព្រះរាជកុមារចូលទៅកាន់ព្រៃ ឃើញបណ្ណសាលាដែលព្រះបច្ចេកពុទ្ធក្នុងកាលមុននៅក្នុងព្រៃនោះ ទើបប្រថាប់នៅមួយអន្លើដោយព្រះរាជឱរស ។

លំដាប់នោះ ព្រះរាជកុមារទ្រង់ធ្លាប់ផ្ទំក្នុងទីបន្ទំដ៏ប្រសើរជាដើម តែកាលផ្ទំ ត្រង់កម្រាលស្មៅ ឬលើព្រះទែនដែលត្បាញដោយខ្សែ ត្រូវរងា និងខ្យល់បៀតបៀន ក៏យំទូលថា បពិត្រព្រះបិតា ខ្ញុំរងា បពិត្រព្រះបិតា ខ្ញុំក្តៅ បពិត្រព្រះបិតា រុយរោមខ្ញុំ បពិត្រព្រះបិតា ខ្ញុំឃ្លាន បពិត្រព្រះបិតា ខ្ញុំស្រេក ដូច្នេះ ព្រះរាជាទ្រង់លួងលោមព្រះរាជកុមារនោះ ញុំាងរាត្រីឲ្យឆ្លងទៅ

ក្នុងពេលថ្ងៃ ក៏ត្រូវត្រាច់បិណ្ឌបាត នាំភត្តមកឲ្យព្រះរាជកុមារនោះ ភត្តនោះជាភត្តលាយគ្នា ច្រើនដោយថ្លៅ ស្លួយ និងសម្ងសណ្តែកជាដើម ព្រះរាជកុមារទ្រង់ស្រេកឃ្លាន ក៏សោយភត្តនោះដោយស្រេកឃ្លាន ក្នុងកាលមិនយូរប៉ុន្មានក៏ស្គាំងស្គម ដូចផ្កាឈូកដែលដាក់ហាលថ្ងៃ ដូច្នោះ ។

ចំណែកព្រះបច្ចេកពោធិសត្វ ទ្រង់មិនសម្តែងអាការខុសប្លែកអ្វីឡើយ ទ្រង់សោយដោយកម្លាំងនៃការពិចារណា ។

បន្ទាប់អំពីនោះ ទ្រង់ឲ្យព្រះរាជកុមារយល់ព្រម ត្រាស់ថា នែបា អាហារដ៏ប្រណីត មាននៅក្នុងព្រះនគរ ពួកយើងនឹងទៅក្នុងព្រះនគរនោះ ។ ព្រះរាជ-កុមារទូលថា សាធុ បិតា ។ បន្ទាប់អំពីនោះ ទ្រង់ក៏នាំព្រះរាជកុមារនោះត្រឡប់តាមផ្លូវដែលយាងមកនោះឯង ។

ចំណែកព្រះទេវី មាតារបស់ព្រះរាជកុមារ ព្រះនាងព្រះតម្រិះថា ឥឡូវនេះ ព្រះរាជានាំព្រះរាជកុមារទៅប្រថាប់នៅក្នុងព្រៃ មិនយូរប៉ុន្មាន គង់នឹងត្រឡប់មកក្នុងកាល ២-៣ ថ្ងៃប៉ុណ្ណោះ ទើបព្រះនាងឲ្យព័ទ្ធរបង ក្នុងទីដែលព្រះរាជាគួសដោយឈើច្រត់នោះឯង ហើយប្រថាប់នៅ ។ លំដាប់នោះ ព្រះរាជាប្រថាប់ឈរក្នុងទីមិនឆ្ងាយអំពីរបងនោះ ទ្រង់បញ្ជូនទៅថា នែបា មាតារបស់ឯងអង្គុយក្នុងទីនោះ ចូរបាទៅចុះ ដូច្នេះហើយ ប្រថាប់ឈរទម្រាំព្រះរាជកុមារនោះ យាងដល់ទីនោះដោយព្រះតម្រិះថា បុគ្គលណាម្នាក់ កុំគប្បីបៀតបៀនកុមារនោះ ។ ព្រះរាជកុមារ យាងដល់សម្នាក់របស់ព្រះមាតា បុរស

ដែលរក្សាទាំងឡាយ ឃើញព្រះរាជកុមារនោះហើយ ទូលដល់ព្រះទេវីៗ ទ្រង់មានស្ត្រីអ្នករបាំ ២ ម៉ឺននាក់ ចោមរោមហើយយាងទៅទទួល បានត្រាស់សួរដល់រឿងរ៉ាវរបស់ព្រះរាជា កាលព្រះនាងស្តាប់ថា នឹងយាងមកខាងក្រោយ ទើបទ្រង់បញ្ជូនមនុស្សទាំងឡាយទៅ ចំណែកព្រះរាជា យាងទៅកាន់ទីលំនៅរបស់ព្រះអង្គក្នុងវេលានោះឯង ។ មនុស្សទាំងឡាយ មិនឃើញព្រះរាជា ក៏ត្រឡប់មក បន្ទាប់អំពីនោះ ព្រះទេវីក៏ប្រាសចាកការសង្ឃឹម ព្រះនាងនាំព្រះរាជឱរសត្រឡប់ដល់ព្រះនគរ អភិសេកកុមារនោះ ក្នុងរាជសម្បត្តិ ។

ចំណែកព្រះរាជា យាងដល់លំនៅរបស់ទ្រង់ហើយ ប្រថាប់គង់ក្នុងលំនៅនោះ ទ្រង់ចម្រើនវិបស្សនា ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ត្រាស់ឧទានគាថានេះ ក្នុងកណ្តាលព្រះបច្ចេកពុទ្ធទាំងឡាយ ត្រង់គល់មញ្ជូសកព្រឹក្សថា

ការចរចាដោយវាចាក្តី ការជាប់ជំពាក់ក្តី ជាមួយនឹងកុមារជាគម្រប់ពីរ មានដល់អញយ៉ាងនេះ បុគ្គលកាលបើឃើញនូវភ័យនុ៎ះតទៅខាងមុខហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាសដូច្នេះ ។

គាថានោះ ដោយអត្ថនៃបទងាយយល់ទាំងអស់ហើយ ចំណែកអធិប្បាយក្នុងគាថានោះ មានដូច្នេះថា ការនិយាយរបស់យើងឲ្យព្រះរាជកុមារនោះ ដែលសោយរង៉ា និងក្តៅជាដើម ឲ្យយល់ព្រមជាសម្លាញ់ ការជាប់ជំពាក់ដោយ

អំណាចនៃការជាប់ជំពាក់ គប្បីមានក្នុងការចរចានោះ បើអាត្មាអញ មិនលះបង់ការពោលចរចា និងការជាប់ជំពាក់នោះចេញ បន្ទាប់អំពីនោះ ការដែលអញគប្បីនិយាយចរចាជាមួយព្រះរាជកុមារជាសម្លាញ់ ឬជាប់ជំពាក់ក្នុងអនាគតក៏ដូចជាទីទៅក្នុងបច្ចុប្បន្ន អាត្មាអញកាលសម្លឹងឃើញភ័យក្នុងអនាគតថា ការពោលចរចា និងការជាប់ជំពាក់ទាំងពីរនោះ ជាហេតុធ្វើនូវការអន្តរាយដល់ការសម្រេចគុណវិសេស ដូច្នេះ ទើបលះបង់នូវការចរចា និងការជាប់ជំពាក់នោះ បដិបត្តិដោយឧបាយហើយ ក៏បានសម្រេចបច្ចេកពោធិញ្ញាណ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

**អាយតិភយគាថា ចប់**

## គាថាទី ១៦

គាថាថា **កាមា ហិ ចិត្រា** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងក្រុងពារាណសី សេដ្ឋីបុត្តម្នាក់នៅក្មេង បានតំណែងសេដ្ឋី សេដ្ឋីបុត្តនោះមានប្រាសាទ ៣ ខ្នង សម្រាប់រដូវទាំង ៣ សេដ្ឋីបុត្តនោះ បានទទួលទំនុកបម្រុងដោយសម្បត្តិទាំងពួង ដូចទេវកុមារ ទាំងដែលនៅក្មេង បានប្រឹក្សាជាមួយមាតា និងបិតាថា កូននឹងបួស ។ មាតាបិតា ក៏ឃាត់សេដ្ឋីបុត្តនោះៗ ក៏រំអុកដូចមុននោះឯង មាតា និងបិតា ក៏ឃាត់ទៀតថា

នៃបា បាជាសុខុមាលជាតិ បព្វជ្ជាធ្វើបានលំបាក ដូចជា ការដើរទៅ ដើរមក លើមុខកាំបិតកោរ ដូច្នោះ សេដ្ឋីបុត្តក៏រំអុកដូចមុននោះឯង មាតាបិតាទាំងនោះគិតថា បើកូននេះបួស ពួកយើងនឹងទោមនស្ស បើហាមគេៗ នឹងខូចចិត្តណ្ហើយចុះ ចូរការទោមនស្សមានដល់ពួកយើង កុំបីមានដល់កូនយើងឡើយ ដូច្នេះហើយ ក៏អនុញ្ញាត ។

បន្ទាប់អំពីនោះ សេដ្ឋីបុត្តនោះ មិនគិតដល់បរិជនដែលកំពុងយំសោក ទៅកាន់ព្រៃឥសិបតនៈ បួសក្នុងសម្នាក់នៃព្រះបច្ចេកពុទ្ធទាំងឡាយ សេនាសនៈដ៏ឧឡារ រមែងមិនដល់សេដ្ឋីបុត្តនោះ សេដ្ឋីបុត្តក្រាលកន្ទេលផែងលើគ្រែ ហើយដេក សេដ្ឋីបុត្តធ្លាប់ដេកក្នុងដំណេកដ៏ប្រសើរ ជាទុក្ខក្រៃលែងអស់មួយយប់ ធ្វើបរិកម្មសរីរៈអំពីព្រលឹមហើយ កាន់បាត្រ និងចីវរចូលទៅបិណ្ឌបាត មួយអន្លើដោយព្រះបច្ចេកពុទ្ធទាំងឡាយ ក្នុងព្រះបច្ចេកពុទ្ធទាំងនោះ ព្រះបច្ចេកពុទ្ធជាថេរៈ រមែងបានអាសនៈដ៏ប្រសើរ និងដុំបាយដ៏ប្រសើរ ព្រះបច្ចេកពុទ្ធដែលជានវកៈ បានអាសនៈតាមមានតាមបាន និងភោជនថ្នាក់អន់ ។ សេដ្ឋីបុត្តនោះជាទុក្ខក្រៃលែងដោយភោជនមិនល្អនោះ ។ លុះរំលងទៅ ២-៣ ថ្ងៃប៉ុណ្ណោះក៏ស្គាំងស្គម មានពណ៌សម្បុរសៅហ្មង នឿយណាយក្នុងភាពជាសមណធម៌ ដែលមិនទាន់ដល់ការចាស់ដោយជុំវិញ បន្ទាប់អំពីនោះ ក៏បញ្ជូនទូតទៅប្រាប់ដល់មាតាបិតា ហើយសឹក ។

សេដ្ឋីបុត្តនោះ បានកម្លាំងអស់កាលបន្តិចបន្តួចប៉ុណ្ណោះ ក៏ប្រាថ្នានឹង

បួសទៀត បន្ទាប់អំពីនោះក៏បួស បួសហើយក៏សឹកដោយទំនងនេះឯង ក្នុងវារៈទី ៣ បួសហើយបដិបត្តិប្រពៃ ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ហើយពោលឧទានគាថានេះ ព្យាករគាថានេះឯងក្នុងកណ្ដាលជំនុំព្រះបច្ចេកពុទ្ធទាំងឡាយថា

ពិតណាស់ កាមទាំងឡាយដ៏វិចិត្រ មានរសផ្អែម ជាទីរីករាយនៃចិត្ត តែងញាំញីនូវចិត្តដោយសភាពដ៏ប្លែកៗ បុគ្គលឃើញទោស ក្នុងកាមគុណទាំងឡាយហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ក្នុងគាថានោះ បទថា **កាមា** បានដល់ កាម ២ យ៉ាង គឺវត្ថុកាម ១ កិលេសកាម ១ ។ ក្នុងកាមពីរយ៉ាងនោះ ធម៌ទាំងឡាយ មានរូបជាទីស្រឡាញ់នៃចិត្តជាដើម ឈ្មោះថា វត្ថុកាម ធម៌ទាំងឡាយ ដែលជាប្រភេទនៃរាគៈទាំងអស់ ហៅថា កិលេសកាម ។ ក្នុងគាថានេះ លោកបំណងយកវត្ថុកាម ។ កាមទាំងឡាយ ឈ្មោះថា **ចិត្រា** ដោយអំណាចនៃប្រការច្រើនយ៉ាង មានរូបជាដើម ឈ្មោះថា **មធុរា** ដោយអំណាចនៃការត្រេកអររបស់សត្វលោក ឈ្មោះថា **មនោរមា** ព្រោះអត្ថថា ញុំាងចិត្តរបស់បុថុជ្ជនឲ្យត្រេកអរ ។

បទថា **វិរូបរូបេន** សេចក្ដីថា ដោយរូបប្លែកៗ អធិប្បាយថា ដោយសភាវៈច្រើនយ៉ាង ។ ពិតហើយ កាមទាំងនោះ ឈ្មោះថា ល្អ វិចិត្រដោយអំណាចនៃរូបជាដើម ឈ្មោះថា មានរូបប្លែកៗ ដោយអំណាចនៃពណ៌ មាន

ពណ៌ខៀវជាដើម សូម្បីក្នុងរូបជាដើម សម្តែងការពេញចិត្តដោយរូបប្លែកៗនោះ ឬដោយប្រការទាំងនោះ រមែងញុំាញីចិត្ត គឺមិនឲ្យត្រេកអរក្នុងបព្វជ្ជាដោយប្រការយ៉ាងនោះ ។

បទដ៏សេស ក្នុងគាថានោះ ប្រាកដច្បាស់ហើយ ។ ពាក្យនិគម ដែលបណ្ឌិតប្រកបដោយបទ ២ បទ ឬ ៣ បទ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងគាថាខាងដើមនោះឯង ។

កាមគាថា ចប់

## គាថាទី ១៧

គាថាថា **ឦតី ច** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា បូសបានកើតឡើងដល់ព្រះរាជាក្រុងពារាណសី វេទនាដ៏ខ្លាំងក្លាប្រព្រឹត្តទៅហើយ ពេទ្យទាំងឡាយក្រាបទូលថា វៀរចាកការវះហើយ នឹងមិនមានផាសុក ព្រះរាជាទ្រង់ឲ្យអភ័យដល់ពេទ្យទាំងនោះហើយ ត្រាស់ឲ្យធ្វើការវះកាត់ ពេទ្យទាំងនោះវះកាត់ហើយ នាំយកខ្ទុះ និងឈាមចេញ ធ្វើឲ្យអស់ទុក្ខវេទនា ហើយរុំរបួស ទូលជាស់តៀនដោយប្រពៃ ឲ្យសោយសាច់ និងអាហារដែលសៅហ្មង ។ ព្រះរាជាទ្រង់មានសរីរៈស្គម ព្រោះភោជនសៅហ្មង បូសរបស់ព្រះរាជាក៏ក្រៀម ទ្រង់សម្គាល់ថាជាហើយ ទើបសោយព្រះក្រយាហារ

ដែលមានរសដ៏ប្រសើរ របួសដែលកើតអំពីព្រះក្រយាហារនោះ កម្រើកឡើងម្តងទៀត បូសរបស់ព្រះរាជាក៏ដល់សភាពដូចដើម ទ្រង់ឲ្យធ្វើការវះកាត់យ៉ាងនេះ រហូតអស់វារៈ ៣ ដង ត្រូវពេទ្យទាំងឡាយទូលប្រាប់ត្រណាមហើយ ទ្រង់នឿយណាយ លះរាជសម្បត្តិធំ ទ្រង់បួសចូលព្រៃ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ អស់ឆ្នាំទាំងឡាយ ៧ បានត្រាស់ឧទានគាថានេះថា

ចង្រៃ បូស ឧបទ្រព រោគ កិលេស ដូចសរ និងភ័យទាំងនុ៎ះ
រមែងមានដល់យើង ព្រោះកាម បុគ្គលកាលបើឃើញភ័យនោះ
ក្នុងកាមគុណទាំងឡាយហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូច
កុយរមាស ។ ដូច្នេះហើយ ទើបយាងទៅកាន់ភ្នំនន្ទមូលកៈ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឦតិ** បានដល់ ចង្រៃ ។ ពាក្យថា **ឦតិ** នេះ ជាឈ្មោះនៃហេតុសេចក្តីវិនាស ដែលជាចំណែករបស់អកុសលដែលចរមក ។ ព្រោះហេតុនោះ កាមគុណទាំងនោះ ឈ្មោះថា ចង្រៃ ព្រោះអត្ថថា ជាហេតុនាំមកនូវសេចក្តីវិនាសច្រើនយ៉ាង និងព្រោះជាហេតុឲ្យធ្លាក់ចុះយ៉ាងធ្ងន់ សូម្បីបូស រមែងហូរចេញនូវរបស់មិនស្អាត គឺហើមទុំហើយក៏បែក ព្រោះហេតុនោះ កាមគុណទាំងនោះ ឈ្មោះថា បូស ព្រោះជាទីហូរចេញនូវរបស់មិនស្អាត គឺកិលេស និងព្រោះជារបស់បែក ព្រោះភាពជារបស់ហើមឡើង ហើយទុំ ដោយការកើត ការចាស់ និងការបែកធ្លាយ ។ ឈ្មោះថា

**ឧបទ្ទវោ** ព្រោះអត្ថថា ប្រទូស្ត អធិប្បាយថា ញុំាងនូវសេចក្តីវិនាសឲ្យកើត រមែងញាំញី គឺគ្របសង្កត់ ។ ពាក្យថា **ឧបទ្ទវោ** នោះ ជាឈ្មោះរបស់អាជ្ញាកម្មទាំងឡាយ មានរាជទណ្ឌជាដើម ព្រោះហេតុនោះ សូម្បីកាមគុណទាំងនោះ ឈ្មោះថា **ឧបទ្ទវ** ព្រោះជាហេតុមិនឲ្យឈានចុះកាន់ព្រះនិព្វាន ដែលខ្ជួនមិនទាន់ដឹង ព្រោះជាទីតាំងនៃឧបទ្ទវៈទាំងពួង ក៏ព្រោះកាមគុណទាំងនោះ ញុំាងនូវការក្តៅក្រហាយ គឺកិលេសឲ្យកើតឡើង ញុំាងនូវការមិនមានរោគពោល គឺសីល ឲ្យដល់នូវការឡេះឡោះ រមែងប្លន់ ការមិនមានរោគតាមប្រក្រតីនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **រោគ** ព្រោះអត្ថថា ប្លន់នូវការមិនមានរោគនេះ ឈ្មោះថា **សល្លំ** ព្រោះអត្ថថា តាមចូលទៅខាងក្នុង ព្រោះអត្ថថា ធ្វើនូវការក្តៅក្រហាយខាងក្នុង ព្រោះអត្ថថា ជារបស់ដែលនាំចេញបានដោយលំបាក ឈ្មោះថា **ភយំ** ព្រោះនាំមកនូវភ័យក្នុងទិដ្ឋធម្ម និងក្នុងសម្បរាយិកភព ។ ពីរបទថា **មេ ឯតំ** សន្ធិជា **មេតំ** ប្រែថា របស់យើងនេះ ។ បទដ៏សេស ក្នុងគាថានេះប្រាកដច្បាស់ហើយ សូម្បីពាក្យនិគមក៏គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។

ឰតិគាថា ចប់

# គាថាទី ១៨

គាថាថា **សីតញ្ច** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ?

បានឮថា ក្នុងនគរពារាណសី ព្រះរាជាព្រះនាមសីតាលុកព្រហ្មទត្ត ទ្រង់ផ្នួសហើយ គង់ក្នុងកុដិដែលនៅក្នុងព្រៃ កាលប្រទេសនោះរងា ក៏មានសេចក្ដីរងា កាលក្ដៅក៏មានការក្ដៅ ព្រោះជាប្រទេសតាំងនៅក្នុងទីវាល ភិក្ខាក្នុងគោចរគ្រាម ក៏មិនបានតាមត្រូវការ ទឹកសម្រាប់អ្នកត្រូវការទឹក ក៏រកបានលំបាក សូម្បីខ្យល់ រំបោម សត្វលូន វារ ក៏បៀតបៀន ព្រះរាជាទ្រង់ព្រះរាជតម្រិះដូច្នេះថា ក្នុងទីប្រមាណកន្លះយោជន៍អំពីនេះ មានប្រទេសដែលសម្បូរអន្តរាយ សរីរៈទាំងនោះ រមែងមិនមានក្នុងប្រទេសនោះ ណើ្ហយចុះ អញនឹងទៅក្នុងប្រទេសនោះ កាលនៅជាផាសុក ក៏អាចសម្រេចសុខបាន ។

ព្រះរាជាមានព្រះរាជតម្រិះទៀតថា ធម្មតាបព្វជិតទាំងឡាយមិនគួរធ្លាក់ក្នុងអំណាចបច្ច័យ និងរមែងញ៉ាំងចិត្តបែបនោះឲ្យប្រព្រឹត្តទៅក្នុងអំណាច មិនប្រព្រឹត្តទៅតាមអំណាចចិត្ត អញនឹងមិនទៅ កាលទ្រង់ពិចារណាហើយ ទ្រង់មិនយាងទៅ ទ្រង់ពិចារណាចិត្តដែលកើតហើយយ៉ាងនេះ អស់វារៈ ៣ ដង ហើយយាងត្រឡប់ តាំងអំពីនោះ ក៏គង់នៅក្នុងព្រៃនោះអស់ ៧ ឆ្នាំ ទ្រង់បដិបត្តិប្រពៃ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ ត្រាស់ឧទានគាថានេះថា

បុគ្គលគ្របសង្កត់នូវសត្រូវទាំងអស់ទុំះ គឺត្រជាក់ ក្ដៅ គម្លាន
សម្រេក ខ្យល់ និងកម្ដៅថ្ងៃ រំបោម និងពស់ហើយ គប្បីត្រាច់

ទៅតែម្នាក់ឯង ដូចកុយរមាស ។

ដូច្នេះហើយ ក៏យាងទៅកាន់ញកភ្នំនន្ទមូលកៈ ដូច្នេះ ។

ក្នុងគាថានោះ បទថា **សីតញ្ច** បានដល់ រងាពីរប្រភេទ គឺធាតុខាងក្នុងកម្រើកជាបច្ច័យ ១ ធាតុខាងក្រៅកម្រើកជាបច្ច័យ ១ កម្តៅក៏ដូចគ្នា ។ បទថា **ឌំសា** បានដល់ សត្វល្អិតពណ៌លឿង ។ បទថា **សិរីសបា** សេចក្តីថា ទីឃជាតិពួកណាមួយ ដែលលូនវារទៅ ។ បទដ៏សេស ប្រាកដច្បាស់ហើយ ។ ពាក្យនិគម ក៏គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។

**សីតាលុកគាថា ចប់**

# គាថាទី ១៩

គាថាថា **នាគោវ** ដូច្នេះ មានអត្តុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងនគរពារាណសី ព្រះរាជាមួយព្រះអង្គសោយរាជសម្បត្តិអស់កាល ២០ ឆ្នាំ សោយទិវង្គតហើយ ឆេះក្នុងនរកអស់កាល ២០ ឆ្នាំដូចគ្នា កើតក្នុងកំណើតដំរីក្នុងហិមវន្តប្បទេស មានដងខ្លួនកើតល្អហើយ មានរាងកាយទាំងមូល ពណ៌ដូចផ្កាបទុម បានជាមេហ្វូង ជាដំរីធំ ។ កូនដំរីទាំងឡាយ រមែងទំពានូវមែកឈើដែលស្តេចដំរីនោះកាច់ហើយ ក្នុងពេលចុះកាន់ទឹក ដំរីញីទាំងឡាយ ក៏លាបស្តេចដំរីដោយកក់ ។ រឿងទាំងអស់ ដូចគ្នា

នឹងរឿងរបស់ស្ដេចដំរីបាលិលេយ្យកៈ ។ ស្ដេចដំរីនោះ កាលនឿយណាយចេញចាកអំពីហ្វូង បន្ទាប់អំពីនោះ ហ្វូងដំរីក៏ជាប់តាមស្ដេចដំរីនោះទៀត តាមស្នាមជើង ស្ដេចដំរីចៀសចេញទៅអស់វារៈ ៣ ដង ក៏ត្រូវដំរីជាប់តាមទៀត ទើបគិតថា ឥឡូវនេះ ចៅរបស់អញសោយរាជសម្បត្តិក្នុងនគរពារាណសីហើយចុះ អញគប្បីទៅកាន់ឧទ្យានក្នុងជាតិមុនរបស់អញ ចៅរបស់អញ នឹងរក្សាអញក្នុងឧទ្យាននោះ កាលហ្វូងដំរីដេកលក់ក្នុងរាត្រីហើយ ក៏លះបង់ហ្វូងទៅកាន់ឧទ្យាននោះឯង ។

អ្នករក្សាឧទ្យានឃើញហើយទូលដល់ព្រះរាជាៗ ទ្រង់ព្រះតម្រិះថា យើងនឹងចាប់ដំរី ដូច្នេះហើយ ទ្រង់ចោមរោមដោយសេនាយាងទៅ ដំរីក៏ដើរមករកព្រះរាជានោះឯង ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ដំរីនេះដើរមករកអញ ទើបផ្ទាប់ព្រួញប្រថាប់ឈរ ។ ដំរីឃើញដូច្នោះគិតថា ព្រះរាជានេះនឹងបាញ់អញពិត ទើបពោលដោយវាចាមនុស្សថា ព្រហ្មទត្ត អ្នកកុំបាញ់ខ្ញុំឡើយ ខ្ញុំជាជីតារបស់អ្នក ព្រះរាជាត្រាស់ថា ឯងនិយាយអ្វី ទើបត្រាស់សួរដល់រឿងទាំងអស់ សូម្បីស្ដេចដំរីក៏ប្រាប់រឿងដែលទាក់ទងនឹងរាជសម្បត្តិ ការប្រព្រឹត្តិទៅក្នុងនរក និងក្នុងកំណើតដំរី ចំណែកព្រះរាជាទ្រង់លួងលោមថា កុំខ្លាចឡើយ កុំធ្វើឲ្យអ្នកណាខ្លាចឡើយ ដូច្នេះហើយ ទ្រង់ឲ្យប្រទានអាហារ កម្រាល និងគ្រឿងប្រដាប់ដល់ស្ដេចដំរី ។

ថ្ងៃមួយ ព្រះរាជាយាងទៅប្រថាប់លើកដំរី ទ្រង់ព្រះរាជតម្រិះថា ដំរីនេះ

ធ្លាប់សោយរាជសម្បត្តិអស់ ២០ ឆ្នាំធ្លាក់នរកហើយ កើតក្នុងកំណើតតិរច្ឆាន ដោយសេសសល់វិបាកនៃកម្មនោះឯង កាលមិនអត់ធ្មត់នូវការប្រឡូកប្រឡំ ដោយការនៅរួមគ្នាជាពួក ជាគណៈ ទើបមកក្នុងទីនេះ ឱកាសនៅជាពួក ជាគណៈជាទុក្ខ ចំណែកការនៅម្នាក់ឯងជាសុខ ដូច្នេះ ទើបទ្រង់ប្រារព្ធវិបស្សនា ក្នុងទីនោះឯង ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ។ អមាត្យទាំងឡាយចូលទៅគាល់ព្រះរាជាអង្គនោះ ដែលសោយសុខ ដោយលោកុត្តរសុខ ប្រណម្យដៃទូលថា បពិត្រមហារាជ បានកាលទ្រង់ឡើងយានហើយ លំដាប់នោះ ព្រះបច្ចេកពុទ្ធត្រាស់ថា យើងមិនមែនព្រះរាជា ហើយត្រាស់គាថានេះ ដោយន័យមុននោះឯងថា

ដំរីមានខ្លួនសមរម្យ មាំមួន មានសម្បុរដូចផ្កាឈូក កាលលះបង់
នូវហ្វូងហើយនៅក្នុងព្រៃ គួរដល់អធ្យាស្រ័យយ៉ាងណា បុគ្គល
គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ( យ៉ាងនោះ ) ដូច្នេះ ។

គាថានេះ ដោយអត្ថនៃបទប្រាកដច្បាស់ហើយ តែការប្រកបអធិប្បាយក្នុងគាថានោះ មានដូច្នេះ គាថានោះឯង ប្រាកដច្បាស់ហើយដោយការប្រកបសេចក្តី តែមិនប្រាកដច្បាស់ដោយអំណាចនៃការតាមស្តាប់ អធិប្បាយថា ដំរីនេះ ឈ្មោះថា នាគ ព្រោះអត្ថថា មិនមកកាន់ទីកដីដែលមិនបានបង្ហឹក ព្រោះភាពដែលខ្លួន មានខ្លួនទូន្មានល្អហើយក្នុងសីលទាំងឡាយ ដែលមនុស្សពេញចិត្ត ឬព្រោះភាពដែលខ្លួនមានរាងកាយធំ យ៉ាងណា ក្នុងកាលណាហ្ន៎

អាត្មាអញ ក៏គប្បីជានាគ ព្រោះមិនមកកាន់ទីកដីដែលមិនទាន់បានទូន្មាន ព្រោះភាពដែលខ្លួនទូន្មានល្អហើយ ក្នុងសីលទាំងឡាយ ដែលព្រះអរិយៈពេញចិត្ត ព្រោះមិនធ្វើបាប និងព្រោះមិនត្រឡប់មកកាន់ភាពដូច្នេះទៀត ឬព្រោះភាពដែលខ្លួនមានសរីរៈ គឺគុណធំ ដូច្នេះ ។

ម្យ៉ាងទៀត ដំរីនោះលះបង់ហ្វូង ហើយទៅក្នុងព្រៃតាមគាប់ចិត្តដោយសេចក្ដីសុខដែលត្រាច់ទៅម្នាក់ឯង ដូចកុយរមាស យ៉ាងណា ក្នុងកាលណាហ្ន៎ អាត្មាអញនឹងបាននៅក្នុងព្រៃតាមគាប់ចិត្ត ដោយវិហារសុខ ដោយចំណែកមួយ បានដល់ ដោយសេចក្ដីសុខ ដែលកើតអំពីឈាន គឺនៅក្នុងព្រៃ ដោយប្រការដែលខ្លួននឹងមានសេចក្ដីសុខ ឬតាមដែលយើងប្រាថ្នា ត្រាច់ទៅតែម្នាក់ឯង គឺគប្បីប្រព្រឹត្តដូចកុយរមាស ដូច្នោះ ។

ម្យ៉ាងទៀត ដំរីនោះ ឈ្មោះថា **សញ្ជាតក្ខន្ធោ** ព្រោះមានរាងកាយតាំងឡើងល្អហើយ យ៉ាងណា ក្នុងកាលណាហ្ន៎ អញគប្បីឈ្មោះថា **សញ្ជា-តក្ខន្ធោ** ព្រោះជាអ្នកធំដោយសីលក្ខន្ធ ដែលជាអសេក្ខៈ ដូច្នោះ ។ ម្យ៉ាងទៀត ដំរីនោះ ឈ្មោះថា **បទុមី** ព្រោះមានរាងកាយដូចគ្នានឹងផ្កាឈូក ឬព្រោះកើតហើយក្នុងត្រកូលដំរីបទុម យ៉ាងណា កាលណាហ្ន៎ អាត្មាអញគប្បីឈ្មោះថា **បទុមី** ព្រោះជាអ្នកមានកាយត្រង់ ដូចផ្កាឈូក ឬព្រោះកើតហើយក្នុងផ្កាឈូក គឺអរិយជាតិ ដូច្នោះ ម្យ៉ាងទៀត ដំរីនោះ ឧឡារដោយកម្លាំង និងដោយសម្ទុះជាដើម ក្នុងកាលណាហ្ន៎ អញគប្បីឧឡារដោយគុណ

មានការប្រព្រឹត្តិផ្លូវកាយបរិសុទ្ធជាដើម ឬដោយសីល សមាធិ និងបញ្ញា ជាគ្រឿងចាក់ធ្លុះជាដើម ព្រោះហេតុនោះ អាត្មាអញកាលគិតយ៉ាងនេះ ទើបប្រារព្ធវិបស្សនា បានសម្រេចបច្ចេកពោធិញ្ញាណ ។

**នាគគាថា ចប់**

## គាថាទី ២០

គាថាថា **អដ្ឋាន តំ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះរាជបុត្តរបស់ព្រះបាទពារាណសី ទ្រង់នៅក្មេង មានបំណងទ្រង់ផ្នួស ទើបប្រឹក្សានឹងព្រះមាតាព្រះបិតា តែព្រះមាតាព្រះបិតាហាមឃាត់ ។ ព្រះរាជបុត្តនោះ សូម្បីត្រូវឃាត់ក៏ទ្រង់រំអុកថា ទូលបង្គំនឹងបួស ។ រឿងទាំងអស់ ដូចរឿងសេដ្ឋីបុត្តដែលពោលហើយក្នុងកាលមុន ។ ព្រះមាតាព្រះបិតាអនុញ្ញាតហើយ តែទ្រង់ឲ្យប្តេជ្ញាថា កាលបួសហើយ នៅក្នុងព្រះរាជឧទ្យានប៉ុណ្ណោះ ទ្រង់ធ្វើតាមប្តេជ្ញា ។ ព្រះមាតារបស់ព្រះអង្គ មានស្រីបរិចារ ២ ម៉ឺននាក់ចោមរោមហើយ យាងទៅកាន់ព្រះរាជឧទ្យាន ឲ្យព្រះរាជបុត្តសោយបបរ ឲ្យទំពាខាទនីយៈជាដើម សន្ទនាជាមួយព្រះរាជបុត្តនោះ រហូតដល់ថ្ងៃត្រង់ ព្រះនាងឲ្យពួកបុរសបដិបត្តិហើយ យាងចូលកាន់នគរ ។ ចំណែកព្រះបិតា ក៏យាងមកក្នុងពេលថ្ងៃត្រង់ ទ្រង់ឲ្យព្រះរាជបុត្តសោយហើយ ទ្រង់

ក៏សោយ សន្ទនាជាមួយព្រះរាជបុត្តនោះអស់ ១ ថ្ងៃ លុះដល់ពេលល្ងាច ទ្រង់ចាត់ពួកបុរសបដិបត្តិហើយ យាងចូលកាន់ព្រះនគរ ព្រះរាជបុត្តនោះ មិនស្ងាត់អស់យប់ និងថ្ងៃយ៉ាងនេះ ។

ដោយសម័យនោះឯង ព្រះបច្ចេកពុទ្ធឈ្មោះថា អាទិច្ចពន្ធុ នៅត្រង់ញក ភ្នំនន្ទមូលកៈ លោកអាវជ្ជនៈ បានឃើញព្រះរាជបុត្រនោះថា ព្រះរាជកុមារ នេះ អាចបួស តែមិនអាចកាត់នូវការប្រឡូកប្រឡំបាន បន្ទាប់អំពីនោះ ក៏គិត ថា ព្រះរាជកុមារនេះ នឿយណាយដោយធម្មតារបស់ខ្លួនឬហ្ន៎ ក្នុងលំដាប់ នោះ ក៏ដឹងថា បើទ្រង់នឿយណាយដោយធម្មតា នឹងយឺតយូរក្រៃលែង ណ្ហើយចុះ អាត្មាអញនឹងសម្តែងអារម្មណ៍ដល់កុមារនោះ ទើបមកអំពីផ្ទៃ មនោសិលា ដោយន័យដូចពោលហើយខាងដើមនោះឯង នៅត្រង់ព្រះរាជ-ឧទ្យាន រាជបុរសឃើញហើយទូលព្រះរាជាថា បពិត្រព្រះអង្គ ព្រះបច្ចេកពុទ្ធ ។ ព្រះរាជាមានព្រះហឫទ័យត្រេកអរថា ឥឡូវនេះ កូនរបស់អញមិនអផ្សុក នឹង នៅជាមួយព្រះបច្ចេកពុទ្ធ ទ្រង់ទំនុកបម្រុងព្រះបច្ចេកពុទ្ធដោយគោរព ទ្រង់ និមន្តឲ្យនៅក្នុងព្រះរាជឧទ្យាននោះ ទ្រង់ឲ្យធ្វើវត្ថុទាំងពួង មានបណ្ណសាលា ទីសម្រាកពេលថ្ងៃ និងទីចង្ក្រមជាដើម និមន្តឲ្យនៅ ។ ព្រះបច្ចេកពុទ្ធនៅ ក្នុងព្រះរាជឧទ្យាននោះ ១ ថ្ងៃ បានឱកាសហើយ ទូលសួរព្រះរាជកុមារថា ទ្រង់ជាអ្វី ព្រះរាជកុមារប្រាប់ថា ខ្ញុំជាបព្វជិត ព្រះបច្ចេកពុទ្ធពោលថា ឈ្មោះ ថា បព្វជិតទាំងឡាយ មិនមែនមានសភាពដូច្នេះឡើយ ។ កាលព្រះរាជកុមារ

សួរថា បពិត្រលោកម្ចាស់ បើដូច្នោះ បព្វជិតទាំងឡាយដូចម្តេច អ្វីមិនសមគួរដល់ខ្ញុំ ។ ព្រះបច្ចេកពុទ្ធពោលថា ទ្រង់មិនសម្លឹងមើលវត្ថុមិនសមគួរដល់ព្រះអង្គ ព្រះមាតាយាងមកក្នុងពេលព្រឹក មួយអន្លើដោយស្រី ២ ម៉ឺននាក់ ធ្វើឲ្យព្រះរាជឧទ្យានមិនស្ងាត់ ព្រះបិតាយាងមកក្នុងពេលល្ងាច មួយអន្លើដោយពួកពលជាច្រើន បុរសដែលប្រតិបត្តិទាំងឡាយ មកក្នុងពេលយប់ធ្វើព្រះរាជឧទ្យានមិនឲ្យស្ងាត់ មិនមែនឬ ធម្មតាបព្វជិតទាំងឡាយ មិនមែនដូចទ្រង់ ហើយប្រាប់វិហារមួយកន្លែង ក្នុងហិមវន្តប្បទេសដោយឫទ្ធិ ដល់ព្រះរាជកុមារដែលប្រថាប់ឈរក្នុងទីនោះឯង ។ ព្រះរាជកុមារនោះ ឃើញព្រះបច្ចេកពុទ្ធទាំងឡាយក្នុងវិហារនោះ កំពុងដើរចង្ក្រម កំពុងធ្វើការជ្រលក់និងដេរចីវរជាដើម ទើបត្រាស់ថា លោកម្ចាស់ទាំងឡាយ កុំមកក្នុងទីនេះបព្វជ្ជា លោកម្ចាស់ទាំងឡាយក៏អនុញ្ញាតហើយ ។ ព្រះអទិច្ចពន្ធុបច្ចេកពុទ្ធនោះទូលថា ត្រូវហើយ បព្វជ្ជាអនុញ្ញាតហើយ សមណៈទាំងឡាយ ឈ្មោះថា ចាប់តាំងពីកាលបួសហើយ រមែងបាននូវការរលាស់ចេញចាកភពដើម្បីខ្លួន និងដើម្បីទៅកាន់ប្រទេសដែលខ្លួនត្រូវការ និងប្រាថ្នាហេតុមានប្រមាណប៉ុណ្ណោះ រមែងគួរ ដូច្នេះហើយ ឈរក្នុងអាកាសពោលកន្ទះគាថាថា

បុគ្គលបាននូវវិមុត្តិ ប្រព្រឹត្តទៅក្នុងសម័យ គឺលោកិយសមាបត្តិ
ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំងនៃបុគ្គលអ្នកត្រេកអរ
ក្នុងពួកទេ ។

ដូច្នេះហើយ កាលឱកាសដែលព្រះរាជកុមារទ្រង់ឃើញ ទើបទៅកាន់ញកភ្នំនន្ទមូលកៈ ។

កាលព្រះបច្ចេកពុទ្ធទៅហើយយ៉ាងនេះ ព្រះរាជកុមារនោះ ក៏ចូលទៅកាន់បណ្ណសាលា ទ្រង់ផ្ទំ ចំណែកបុរសដែលរក្សា ធ្វេសប្រហែសថា ឥឡូវនេះ ព្រះរាជកុមារទ្រង់ផ្ទំហើយ តើនឹងយាងទៅណាបាន ទើបដេកលក់អស់ ។ ព្រះរាជកុមារជ្រាបថា អ្នករក្សាទាំងនោះប្រមាទហើយ ទ្រង់ក៏កាន់បាត្រ និងចីវរ យាងចូលកាន់ព្រៃ ទ្រង់ស្ងាត់ក្នុងព្រៃនោះ ទ្រង់ប្រារព្ធវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ យាងចូលកាន់ស្ថានរបស់ព្រះបច្ចេកពុទ្ធ ព្រះបច្ចេកពុទ្ធក្នុងទីនោះទូលសួរថា លោកម្ចាស់សម្រេចបានដូចម្តេច ទើបត្រាស់កន្ទះគាថា ដែលព្រះអាទិច្ចពន្ធុពោលហើយធ្វើឲ្យបរិបូណ៌ថា

បុគ្គលបាននូវវិមុត្តិ ប្រព្រឹត្តទៅក្នុងសម័យ គឺលោកិយសមាបត្តិ
ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំងនៃបុគ្គលអ្នកត្រេកអរ
ក្នុងពួកទេ បុគ្គលពិចារណាពាក្យរបស់ព្រះពុទ្ធ[១] ជាព្រះអាទិច្ច-
ពន្ធុ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ក្នុងគាថានោះមានអត្ថថា បទថា **អដ្ឋាន តំ** សេចក្តីថា ទុំះមិនជាឋានៈដែលនឹងមាន អធិប្បាយថា មិនមែនហេតុ លោកធ្វើការលុបនិគ្គហិតចោល ដូចក្នុងប្រយោគជាដើមថា **អរិយសច្ចានទស្សនំ** ប្រែថា ការឃើញអរិយសច្ច

១- គួរប្រែថា របស់ព្រះបច្ចេកពុទ្ធ ទើបត្រូវតាមន័យរបស់អដ្ឋកថា ។

ទាំងឡាយជាដើម ។ បទថា **សង្គណិការតស្ស** បានដល់ ជាអ្នកត្រេកអរក្រៃលែងហើយដោយគណៈ ។ បទថា **យំ** នោះ ជាតតិយាវិភត្តិ ដូចក្នុងប្រយោគថា **យំ ហិរិយតិ ហិរិយិតព្វេន** ជាដើម ។ បទថា **ផុស្សយេ** សេចក្ដីថា គប្បីសម្រេច ។ បទថា **សាមយិកំ វិមុត្តិំ** បានដល់ លោកិយ-សមាបត្តិ ។ ពិតហើយ លោកិយសមាបត្តិនោះហៅថា **វិមុត្តិ** ដែលមានក្នុងសម័យ ព្រោះផុតចាកអកុសលធម៌ទាំងឡាយ ដែលជាសត្រូវ ក្នុងសម័យដែលបានសមាធិមិនទាន់ស៊ប់ ជាអប្បនានោះឯង ។

ព្រះរាជកុមារត្រាស់ថា អាត្មាអញ ពិចារណានូវពាក្យរបស់ព្រះបច្ចេក-ពុទ្ធ ឈ្មោះថា អាទិច្ចពន្ធុយ៉ាងនេះហើយ កាលដែលបុគ្គលត្រេកអរហើយដោយការប្រឡូកប្រឡំដោយគណៈ គប្បីសម្រេចវិមុត្តិ ដែលមានក្នុងសម័យនោះមិនមែនជាឋានៈ គឺមិនមែនជាហេតុ ដូច្នេះហើយ លះនូវសេចក្ដីត្រេកអរដោយការប្រឡូកប្រឡំដោយគណៈ បដិបត្តិដោយឧបាយ ទើបសម្រេចដូច្នេះបទដ៏សេស មានន័យដូចពោលហើយនោះឯង ។

**អដ្ឋានគាថា ចប់**

**វគ្គទី ២ ចប់**

# វគ្គទី ៣

## គាថាទី ២១

គាថាថា **ទិដ្ឋីវិសូកានិ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះរាជាមួយអង្គក្នុងនគរពារាណសី យាងទៅក្នុងទីកំបាំង ទ្រង់ព្រះតម្រិះថា ក្តៅជាដើម ដែលកម្ចាត់រងាជាដើម មានយ៉ាងណា វិវដ្តៈ ដែលកម្ចាត់វដ្តៈក៏មានដូច្នោះ ឬមិនមានហ្ន៎ ដូច្នេះ ទើបទ្រង់ត្រាស់សួរអមាត្យទាំងឡាយថា ពួកអ្នកស្គាល់វិវដ្តៈឬ អមាត្យទាំងនោះទូលថា ស្គាល់មហារាជ ព្រះរាជាត្រាស់សួរថា វិវដ្តៈនុ៎ះជាអ្វី អមាត្យទាំងឡាយទូលប្រាប់សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិដោយន័យជាដើមថា លោកមានទីបំផុត ។

លំដាប់នោះ ព្រះរាជាទ្រង់ជ្រាបថា អមាត្យទាំងនោះ រមែងមិនដឹង អមាត្យទាំងអស់នេះ ជាមិច្ឆាទិដ្ឋិ ទ្រង់ឃើញភាពដែលអមាត្យទាំងនោះ ជាបុគ្គលជំទាស់ និងយល់មិនត្រឹមត្រូវដោយព្រះអង្គឯងហើយ ទ្រង់ព្រះរាជតម្រិះថា វិវដ្តៈដែលកម្ចាត់វដ្តៈមាន អញគប្បីស្វែងរកវិវដ្តៈនោះ ហើយទ្រង់លះរាជសម្បត្តិបួស ទ្រង់ចម្រើនវិបស្សនា ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេក-ពោធិញ្ញាណហើយ ត្រាស់ឧទានគាថានេះ និងព្យាករណគាថា ក្នុងកណ្តាលជំនុំព្រះបច្ចេកពុទ្ធទាំងឡាយថា

បុគ្គលកន្លងនូវទិដ្ឋិអាក្រក់ ដល់នូវធម៌ទៀង មានមគ្គបានហើយ
មិនបាច់មានអ្នកដទៃដឹកនាំ ព្រោះដឹងថា អាត្មាអញមានញាណ
កើតហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

គាថានោះ មានអត្ថថា បទថា **ទិដ្ឋីវិសូកានិ** បានដល់ ទិដ្ឋិ ៦២ ។ ពិតហើយ ទិដ្ឋិទាំងនោះ ឈ្មោះថា ជាបន្ទា ព្រោះអត្ថថា ចាក់ដោតចំពោះសម្មាទិដ្ឋិក្នុងមគ្គ ព្រោះអត្ថថា ជំទាស់ និងព្រោះអត្ថថា ចាក់ដោត ។ ឈ្មោះថា ទិដ្ឋីវិសូកៈ ព្រោះអត្ថថា ចាក់ដោតចំពោះទិដ្ឋិយ៉ាងនេះ ឬបន្ទា គឺទិដ្ឋិ ទើបឈ្មោះថា **ទិដ្ឋីវិសូកានិ** ។

បទថា **ឧបាតិវត្តោ** គឺឈានកន្លងហើយដោយទស្សនមគ្គ ។ បទថា **បត្តោ និយាមំ** សេចក្តីថា សម្រេចហើយនូវភាពជាបុគ្គលទៀង ព្រោះមិនមានការធ្លាក់ចុះជាធម្មតា និងព្រោះមានការត្រាស់ដឹងប្រពៃជាខាងមុខ ឬសម្រេចបឋមមគ្គ ពោល គឺការទៀងដែលបរិបូណ៌ហើយ ។ ព្រះបច្ចេកពុទ្ធពោលនូវការសម្រេចក្នុងបឋមមគ្គ និងការបានចំពោះនូវបឋមមគ្គនោះ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឥឡូវនេះ ព្រះបច្ចេកពុទ្ធសម្តែងការបានចំពោះនូវមគ្គដ៏សេស ដោយបទនេះថា **បដិលទ្ធមគ្គោ** ដូច្នេះ ។

បទថា **ឧប្បន្នញ្ញាណោម្ហិ** សេចក្តីថា ជាបុគ្គលមានបច្ចេកពុទ្ធញ្ញាណកើតឡើងហើយ ។ ព្រះបច្ចេកពុទ្ធសម្តែងផលដោយបទនេះ ។

បទថា **អនញ្ញនេយ្យោ** សេចក្តីថា ដែលបុគ្គលដទៃមិនគប្បីណែនាំថា ធម៌នេះពិត ធម៌នេះមិនពិត ។ ព្រះបច្ចេកពុទ្ធសម្តែងនូវការដឹងឯងដោយបទនេះ ។

ម្យ៉ាងទៀត បុគ្គលណាកន្លងផុតនូវការមិនមានអ្នកដទៃគប្បីណែនាំ ក្នុង

បច្ចេកពោធិញ្ញាណដែលសម្រេចហើយ ឬកន្លងផុតទិដ្ឋិដែលជាសត្រូវបានហើយ ដោយសមថវិបស្សនាដោយខ្លួនឯង ដល់នូវភាពជាបុគ្គលទៀង ដោយមគ្គខាងដើម មានមគ្គដែលបានចំពោះហើយ ដោយមគ្គដ៏សេសទាំងឡាយ ឬមានញាណកើតហើយដោយផលញ្ញាណ បានសម្រេចហើយ នូវញាណទាំងពួងដោយខ្លួនឯង ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **អនញ្ញនេយ្យោ** ដែលបុគ្គលដទៃមិនគប្បីដឹកនាំ ។ បទដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។

**ទិដ្ឋិវិសូកគាថា ចប់**

## គាថាទី ២២

គាថាថា **និល្លោលុបោ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា វិសូទៈ គឺចុងភៅរបស់ព្រះបាទពារាណសី ចម្អិនព្រះក្រយាហារក្នុងចន្លោះ បង្អែមថ្វាយព្រះក្រយាហារដែលគួរសោយ និងមានរសឆ្ងាញ់ ដោយគិតថា ធ្វើដូចម្តេចហ្ន៎ ការឃើញភោជនដែលជាទីត្រេកអរនៃចិត្ត ជារសដ៏ប្រសើរ ព្រះរាជាគប្បីប្រទានទ្រព្យដល់អញ ។ ដោយក្លិនប៉ុណ្ណោះ ព្រះក្រយាហារនោះ ញ៉ាំងនូវបំណងដែលនឹងសោយឲ្យកើតឡើង ដល់ព្រះរាជា ទើបធ្វើឲ្យទឹកមាត់កើតឡើងក្នុងព្រះឱស្ឋ លុះទ្រង់ដាក់ព្រះក្រយាហារមួយមាត់

ដំបូងចូលក្នុងព្រះឱស្ឋ បសាទសម្រាប់ទទួលរស ៧ ពាន់ ក៏ជ្រួតជ្រាបដូចត្រូវទឹកអម្រឹត ដូច្នោះ ។ អ្នកវិសេស គិតថា ឥឡូវនេះ ព្រះរាជាទ្រង់នឹងព្រះរាជទានដល់អញ ចំណែកព្រះរាជាទ្រង់ព្រះរាជតម្រិះថា អ្នកវិសេសសមគួរដល់សក្ការៈ តែមិនត្រាស់ពាក្យណាមួយ ដោយទ្រង់ព្រះតម្រិះថា កិត្តិសព្ទដែលអាក្រក់ គប្បីល្បីដល់អញ ដែលធ្វើសក្ការៈដល់ចុងភៅថា ព្រះរាជានេះជាអ្នកល្មោភក្នុងរស ។ ចំណែកអ្នកវិសេស គិតថា ព្រះរាជានឹងប្រទានរង្វាន់ក្នុងឥឡូវនេះ រហូតដល់សោយព្រះក្រយាហារស្រេចយ៉ាងនេះ សូម្បីព្រះរាជាក៏មិនត្រាស់ពាក្យណាមួយ ព្រោះទ្រង់ខ្លាចការតិះដៀល ។

លំដាប់នោះ អ្នកវិសេសគិតថា ព្រះរាជានេះមិនមានជិវ្ហាវិញ្ញាណ ក្នុងថ្ងៃទី ២ ក៏នាំព្រះក្រយាហារមិនល្អមកថ្វាយ ព្រះរាជាកាលសោយ សូម្បីទ្រង់ដឹងថា ថ្ងៃនេះអ្នកវិសេសគួរដល់ការសម្លុត គួរដល់ការគំរាម ទ្រង់ពិចារណាដូចក្នុងកាលមុន ក៏មិនត្រាស់អ្វី ព្រោះទ្រង់ខ្លាចការតិះដៀល បន្ទាប់អំពីនោះចុងភៅគិតថា ព្រះរាជាទ្រង់មិនដឹងព្រះក្រយាហារដែលល្អ និងមិនល្អ ដូច្នេះហើយ កាន់យកគ្រឿងប្រកបអាហារដែលខ្លួនសន្សំទាំងអស់ ចម្អិនព្រះក្រយាហារធម្មតាថ្វាយដល់ព្រះរាជា ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ឱហ្ន៎ សេចក្តីលោភ អញបរិភោគអស់ ២ ម៉ឺនឆ្នាំ ក៏មិនបានសូម្បីត្រឹមតែកត្តា ( ដែលល្អ ) ព្រោះសេចក្តីលោភរបស់ចុងភៅនេះ ដូច្នេះហើយ ទ្រង់ខ្ពើមរអើម ទើបទ្រង់លះរាជសម្បត្តិ ទ្រង់ព្រះផ្នួស ចម្រើនវិបស្សនា ទ្រង់ធ្វើជាក់ច្បាស់នូវបច្ចេក-

ពោធិញ្ញាណ ត្រាស់ព្រះគាថានេះ ដោយន័យមុននោះឯងថា

បុគ្គលមិនជាប់ចិត្តក្នុងអាហារ មិនកុហក មិនមានសេចក្តីស្រេក
ឃ្លាន ជាអ្នកមិនលុបគុណគេ កម្ចាត់បង់មោហៈដូចជាទឹកចត់
ចេញបាន មិនមានទីអាស្រ័យ ( គឺកិលេស ) ក្នុងលោក
ទាំងមូល គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **និល្លោលុបោ** បានដល់ ជាអ្នកមិនលោភ ព្រោះបុគ្គលត្រូវចំណង់ក្នុងរសគ្របសង្កត់ហើយ បុគ្គលនោះ រមែងលោភក្រៃពេកនិងលោភរឿយៗ ព្រោះហេតុនោះ ទើបហៅថា **លោលុបោ** ។ ព្រោះដូច្នោះព្រះបច្ចេកពុទ្ធ កាលហាមសេចក្តីលោភនោះ ទើបពោលថា **និល្លោលុបោ** គឺបុគ្គលមិនលោភ ។

ក្នុងបទនេះថា **និក្កុហោ** នេះ បុគ្គលណាមិនមានរឿងបោកបញ្ឆោត ៣ យ៉ាង បុគ្គលនោះហៅថា **និក្កុហោ** ក៏ពិត តែក្នុងគាថានេះ មានអធិប្បាយយ៉ាងនេះថា មិនបោកបញ្ឆោត ព្រោះមិនដល់នូវការវង្វេង ក្នុងភោជនដែលធ្វើឲ្យចិត្តត្រេកអរជាដើម ។

ក្នុងបទថា **និប្បិបាសោ** នេះ ការចង់ផឹក ឈ្មោះថា **បិបាសោ** ។ ឈ្មោះថា **និប្បិបាសោ** ព្រោះមិនមានការស្រេកនោះ អធិប្បាយថា វៀរហើយចាកភាពជាអ្នកប្រាថ្នានឹងបរិភោគ ដោយការល្មោភក្នុងរសល្អ ។

ក្នុងបទថា **និម្មក្ខោ** នេះ ការលុបគុណ មានការញ៉ាំងគុណរបស់អ្នក

ដទៃឲ្យវិនាសជាលក្ខណៈ ឈ្មោះថា **ឆិន្នក្ខោ** ព្រោះមិនមានការលុបគុណនោះ ។ ព្រះបច្ចេកពុទ្ធ ពោលសំដៅដល់ការមិនមានការលុបគុណរបស់ចុងភៅ ក្នុងកាលដែលខ្លួនជាគ្រហស្ថ ។

ក្នុងបទថា **ឆិទ្ទន្តកសាវមោហោ** នេះ ធម៌ ៦ យ៉ាង គឺ ៣ យ៉ាង មាន រាគៈជាដើម និង ៣ យ៉ាង មានកាយទុច្ចរិតជាដើម គប្បីជ្រាបថា **កសាវ** ( ទឹកចត់ ) ដោយអត្ថថា មិនជ្រះថ្លាតាមសេចក្តីពិត និងដោយអត្ថថា ឲ្យលះភាវៈខ្លួន ឲ្យកាន់យកភាវៈដទៃ ដូចលោកពោលក្នុងវិភង្គថា

បណ្តាធម៌ ទាំងនោះ ទឹកចត់ ៣ តើដូចម្តេច ។ ទឹកចត់ គឺរាគៈ ១ ទឹកចត់ គឺទោសៈ ១ ទឹកចត់ គឺមោហៈ ១ នេះ ទឹកចត់ ៣ ។ បណ្តាធម៌ទាំងនោះ ទឹកចត់ ៣ ដទៃទៀត តើដូចម្តេច ។ ទឹកចត់ គឺកាយ ១ ទឹកចត់ គឺវាចា ១ ទឹកចត់ គឺចិត្ត ១ នេះ ទឹកចត់ ៣ ដូច្នេះ ។

ឈ្មោះថា មានបាបធម៌ដូចទឹកចត់ និងមោហៈដែលកម្ចាត់ចេញហើយ ព្រោះកម្ចាត់កសាវៈ ៥ ក្នុងបណ្តាកសាវៈ ៦ នោះ វៀរមោហៈ និងកម្ចាត់មោហៈដែលជាឫសគល់នៃកសាវៈទាំង ៥ នោះទាំងអស់ចេញហើយ ។ ម្យ៉ាងទៀត ឈ្មោះថា មានបាបធម៌ដូចទឹកចត់ និងមោហៈកម្ចាត់ហើយ ព្រោះកម្ចាត់កាយកសាវៈ វចីកសាវៈ និងមនោកសាវៈ ទាំង ៣ យ៉ាងនោះ និងមោហៈចេញហើយ ។ ក្នុងបណ្តាកសាវៈក្រៅអំពីនេះ ព្រោះមិនមានលោភៈ

ជាដើម រាគកសាវៈ ឈ្មោះថា កម្ចាត់ស្រេចហើយ ព្រោះមិនមានការលុប គុណ ទោសកសាវៈ ឈ្មោះថា កម្ចាត់ស្រេចហើយដូចគ្នា ។

បទថា **និរាសយោ** គឺមិនមានតណ្ហា ។ បទថា **សព្វលោកេ** បានដល់ក្នុងលោកទាំងមូល អធិប្បាយថា ជាបុគ្គលវៀរចាកភវតណ្ហានិងវិភវតណ្ហា ក្នុងភពទាំង ៣ ឬក្នុងអាយតនៈ ១២ ។ បទដ៏សេស គប្បីជ្រាបដោយន័យដែលពោលមកហើយនោះឯង ។ម្យ៉ាងទៀត អ្នកសិក្សា កាលពោលបាទទាំង ៣ ហើយ គប្បីធ្វើការភ្ជាប់ក្នុងបាទនេះ យ៉ាងនេះថា គប្បីត្រាច់ទៅតែម្នាក់ឯង ឬយ៉ាងនេះថា គប្បីអាចត្រាច់ទៅម្នាក់ឯង ដូច្នេះ ។

**និល្លោលុបគាថា ចប់**

## គាថាទី ២៣

គាថាថា **ទាឬំ សហាយំ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះរាជាមួយអង្គក្នុងនគរពារាណសី ទ្រង់ធ្វើប្រទក្សិណព្រះនគរ ដោយអានុភាពនៃព្រះរាជាដែលជាធំក្រៃលែង ទ្រង់ឃើញមនុស្សទាំងឡាយជញ្ជូនស្រាចាស់ជាដើម ចេញអំពីជង្រុកមកដាក់ខាងក្រៅ ទើបត្រាស់សួរអមាត្យទាំងឡាយថា នែអមាត្យ នេះជាអ្វី អមាត្យទាំងឡាយក្រាបទូលថា បពិត្រមហារាជ ក្នុងកាលឥឡូវនេះ ស្រូវថ្មីកើតឡើង ទើបមនុស្សទាំង

នេះចោលស្រូវចាស់ ដើម្បីឲ្យជង្រុកទំនេរ សម្រាប់ដាក់ស្រូវថ្មីទាំងនោះ ព្រះរាជាត្រាស់ថា នែអមាត្យ វត្ថុសម្រាប់ស្ងោ និងពលជាដើម បរិបូណ៌ហើយឬ អមាត្យទូលថា បពិត្រព្រះអង្គ បរិបូណ៌ហើយ ព្រះរាជាត្រាស់ថា នែអមាត្យ បើដូច្នោះ ចូរសាងរោងទាន យើងនឹងឲ្យទាន កុំឲ្យស្រូវទាំងនេះវិនាសទៅទទេឡើយ ។

លំដាប់នោះ អមាត្យដែលជាមិច្ឆាទិដ្ឋិម្នាក់ទូលថា បពិត្រព្រះអង្គ ទានដែលឲ្យហើយមិនមានផលទេ ពាលក្តី បណ្ឌិតក្តី សុះទៅ អន្ទោលទៅ នឹងធ្វើទីបំផុតទុក្ខបាន ដូច្នេះហើយ ទូលឃាត់ព្រះរាជានោះ អស់វារៈ ២ ដង សូម្បីលើកទី ៣ ព្រះរាជាក៏ទ្រង់ឃើញមនុស្សទាំងឡាយ ចោមរោមជង្រុក ទើបត្រាស់ពាក្យយ៉ាងនោះដូចគ្នា សូម្បីលើកទី ៣ អមាត្យមិច្ឆាទិដ្ឋិនោះ ក៏ទូលឃាត់ព្រះរាជាអង្គនោះថា បពិត្រមហារាជ ទានបុគ្គលល្ងង់បញ្ញត្តប៉ុណ្ណោះ ដូច្នេះជាដើម ។

ព្រះរាជាទ្រង់ទៀយណាយថា អាត្មាអញមិនបានឲ្យសូម្បីរបស់ខ្លួនឯង ប្រយោជន៍អ្វីដោយសម្លាញ់អាក្រក់ទាំងនេះ ទ្រង់លះរាជសម្បត្តិ បួសហើយ ទ្រង់ចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ហើយទ្រង់តិះដៀលសម្លាញ់អាក្រក់នោះ ទើបត្រាស់ឧទានគាថានេះថា

បុគ្គលគប្បីវៀរនូវសម្លាញ់ដ៏អាក្រក់ ដែលបង្ហាញនូវអំពើមិនជាប្រយោជន៍ អាស្រ័យនៅក្នុងកម្មមិនស្មើ ( គឺទុច្ចរិត ) មិន

គប្បីសេពគប់នូវសម្លាញ់ ដែលជាប់ជំពាក់ ដែលស្រវឹង ( ក្នុងកាមគុណ ) ដោយខ្លួនឯង គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

គាថានោះ មានអត្ថសង្ខេបដូច្នេះថា សម្លាញ់នេះ ឈ្មោះថា អាក្រក់ ព្រោះជាបុគ្គលប្រកបដោយទិដ្ឋិ ១០ យ៉ាង ឈ្មោះថា **អនត្ថទស្សី** ព្រោះអត្ថថា ចង្អុលប្រាប់នូវសេចក្តីវិនាសដល់អ្នកដទៃ និងតាំងនៅក្នុងកម្មដែលមិនស្មើ មានកាយទុច្ចរិតជាដើម កុលបុត្តដែលប្រាថ្នាប្រយោជន៍ គប្បីវៀរសម្លាញ់អាក្រក់នោះ ដែលដឹកនាំក្នុងផ្លូវវិនាស ដែលតាំងនៅក្នុងកម្មមិនស្មើ ។ បទថា **សយំ ន សេវេ** សេចក្តីថា មិនគប្បីសេពដោយអំណាចនៃខ្លួនឯង អធិប្បាយថា បើធ្លាក់នៅក្នុងអំណាចរបស់អ្នកដទៃសោត ខ្លួនឯងនឹងធ្វើអ្វីបាន ។

បទថា **បសុតំ** បានដល់ ដែលវាយមាយទៅ អធិប្បាយថា បុគ្គលដែលជាប់ជំពាក់ហើយក្នុងអារម្មណ៍នោះៗ ដោយអំណាចទិដ្ឋិ ។ បទថា **បមត្តំ** បានដល់ ដែលបណ្តែតបណ្តោយចិត្ត ក្នុងកាមគុណទាំងឡាយ ឬវៀរចាកកុសលភាវនា ។ កុលបុត្តមិនគប្បីសេព គឺមិនគប្បីគប់ មិនគប្បីចូលទៅក្បែរសម្លាញ់នោះ គឺសម្លាញ់មានសភាពបែបនោះ ដោយពិត គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នោះ ។

បាបសហាយគាថា ចប់

# គាថាទី ២៤

គាថាថា **ពហុស្សុតំ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងកាលមុន ព្រះបច្ចេកពោធិសត្វ ៨ អង្គ បួសហើយក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ព្រះនាមកស្សបៈ បំពេញគតបច្ចាគតវត្តហើយ កើតក្នុងទេវលោក រឿងទាំងអស់ដូចគ្នាតាមដែលពោលហើយ ក្នុងអនវជ្ជភោជិគាថានោះឯង ។ ឯការដែលប្លែកគ្នា មានដូច្នេះ

ព្រះរាជា ទ្រង់អារាធនាឲ្យព្រះបច្ចេកពុទ្ធទាំងឡាយអង្គុយហើយ ទើបត្រាស់ថា លោកម្ចាស់ទាំងឡាយឈ្មោះអ្វី ព្រះបច្ចេកពុទ្ធទាំងនោះទូលថា មហាបពិត្រ ពួកអាត្មាឈ្មោះពហុស្សុត ។ ព្រះរាជាទ្រង់មានព្រះហឫទ័យសោមនស្សថា អញក៏មានឈ្មោះសុតព្រហ្មទត្ត រមែងមិនដល់នូវការ ឆ្អែតដោយសុតៈ ណ្ហើយចុះ អញនឹងស្ដាប់ធម្មទេសនា ដែលមានន័យដ៏វិចិត្រក្នុងសម្នាក់របស់ព្រះបច្ចេកពុទ្ធទាំងនោះ ដូច្នេះហើយ ថ្វាយទឹកទក្ខិណោទក ទ្រង់អង្គាសហើយ ក្នុងទីបំផុតនៃភត្តកិច្ច ទ្រង់ទទួលបាត្ររបស់ព្រះសង្ឃត្ថេរ ទ្រង់ថ្វាយបង្គំប្រថាប់គង់ខាងមុខដោយព្រះតម្រាស់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់សម្ដែងធម្មកថាចុះ ព្រះបច្ចេកពុទ្ធទូលថា មហាបពិត្រ សូមមហាបពិត្រ មានសេចក្ដីសុខ សូមលះបង់នូវរាគៈ ហើយក្រោកចៀសចេញទៅ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ព្រះបច្ចេកពុទ្ធអង្គនេះ មិនមែនពហុស្សុត អង្គទី ២ ពិតជាពហុស្សុត ទើបទ្រង់និមន្តដើម្បីឆាន់ក្នុងថ្ងៃស្អែក ដោយព្រះរាជតម្រិះថា អញនឹងស្ដាប់ធម្មទេសនាដ៏វិចិត្រ ក្នុងថ្ងៃស្អែកនេះ ទ្រង់និមន្តព្រះបច្ចេកពុទ្ធ

ទាំងអស់ រហូតដល់អន្តចុងក្រោយ ដោយប្រការយ៉ាងនេះ ព្រះបច្ចេកពុទ្ធទាំងឡាយ សម្ដែងមួយបទឲ្យប្លែកគ្នា ហើយពោលបទដ៏សេស ភ្ជាប់ជាមួយបទដើមថា សូមមហារាជលះបង់ទោសៈ សូមលះបង់មោហៈ សូមអស់នូវគតិ សូមអស់នូវវដ្ដៈ សូមអស់នូវឧបធិ សូមអស់នូវតណ្ហា ដូច្នេះហើយក៏ក្រោកទៅ ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះរាជតម្រិះថា ព្រះបច្ចេកពុទ្ធទាំងនេះពោលថា ពួកអាត្មាជាពហុស្សុត តែព្រះបច្ចេកពុទ្ធទាំងនោះ មិនមានកថាដ៏វិចិត្រ ពាក្យដែលព្រះបច្ចេកពុទ្ធទាំងនោះពោលហើយ នឹងមានប្រយោជន៍អ្វី ទ្រង់ប្រារព្ធហើយ ដើម្បីទ្រង់ពិចារណាអត្ថនៃពាក្យរបស់ព្រះបច្ចេកពុទ្ធទាំងនោះ កាលទ្រង់ពិចារណាថា សូមអស់រាគៈដូច្នេះ ក៏ទ្រង់ជ្រាបថា កាលរាគៈអស់ហើយ ទោសៈក្ដី មោហៈក្ដី កិលេសដទៃទាំងឡាយក្ដី ឈ្មោះថា អស់ហើយផងដែរ ទើបទ្រង់ពេញព្រះរាជហឫទ័យថា សមណៈទាំងនេះ ជាពហុស្សុតដោយត្រង់ ប្រៀបដូចបុរសចង្អុលប្រាប់ផែនដីធំ ឬអាកាសដោយម្រាមដៃ ចំណែកប៉ុនម្រាមដៃមិនមែនជាការសម្ដែងឡើយ តែសេចក្ដីពិត ឈ្មោះថា សម្ដែងផែនដីនិងអាកាសទាំងមូលនោះឯង យ៉ាងណា សមណៈទាំងនេះ កាលចង្អុលបង្ហាញអត្ថមួយអន្ត ១ បទ ក៏ឈ្មោះថា បង្ហាញនូវអត្ថ ដែលប្រមាណមិនបាន ដូច្នោះ ។ បន្ទាប់អំពីនោះ ព្រះរាជាទ្រង់ប្រាថ្នានូវភាពជាពហុស្សុតបែបនោះថា ក្នុងកាលណាហ្ន៎ អញនឹងជាពហុស្សុតយ៉ាងនេះ ទ្រង់លះរាជសម្បត្តិ

បួស ហើយចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញាណ ហើយត្រាស់ឧទានគាថានេះថា

បុគ្គលគប្បីគប់រកនូវមិត្តជាពហុស្សូត ទ្រទ្រង់នូវធម៌ប្រកបដោយកម្មដ៏ថ្លៃថ្នូរ មានប្រាជ្ញាវាងវៃ លុះដឹងច្បាស់នូវប្រយោជន៍ទាំងឡាយហើយ គប្បីបន្ទោបង់នូវសេចក្តីសង្ស័យចេញ ត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ក្នុងគាថានោះ មានអត្ថដោយសង្ខេបដូច្នេះថា បទថា **ពហុស្សុតំ** សេចក្តីថា មិត្តដែលជាពហុស្សូតមាន ២ យ៉ាង គឺពហុស្សូតផ្នែកបរិយត្តិ ជំនាញដោយអត្ថក្នុងព្រះត្រៃបិដក ១ ពហុស្សូតខាងបដិវេធ ព្រោះភាពដែលមគ្គផល វិជ្ជា និងអភិញ្ញាដែលខ្លួនបាក់ធ្លុះហើយ ១ ជាអ្នកមានអាគមមកហើយ ឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ បុគ្គលដែលប្រកបដោយកាយកម្ម វចីកម្ម និងមនោកម្មដ៏ក្រៃលែង ឈ្មោះថា ជាអ្នកក្រៃលែងដោយគុណ ជាអ្នកមានយុត្តប្បដិភាណ ១ ជាអ្នកមានមុត្តប្បដិភាណ ១ ជាអ្នកយុត្តមុត្តប្បដិភាណ ១ ឈ្មោះថា មានបដិភាណ ។ គប្បីជ្រាបអ្នកមានបដិភាណ ៣ យ៉ាង ដោយអំណាចបរិយត្តិ បរិបុច្ឆា និងអធិគម ។

ពិតហើយ បរិយត្តិ តែងជាក់ច្បាស់ដល់មិត្តណា មិត្តនោះ ឈ្មោះថា មានបរិយត្តិប្បដិភាណ ការសាកសួរ រមែងជាក់ច្បាស់ដល់មិត្តណា ជាអ្នកសាកសួរអត្ថ ញាណលក្ខណៈ និងឋានាឋានៈ មិត្តនោះ ឈ្មោះថា មានបរិ-

បុច្ឆាបដិភាណ ធម៌ មានមគ្គជាដើម ដែលមិត្តណាចាក់ធ្លុះហើយ មិត្តនោះឈ្មោះថា មានបដិវេធបដិភាណ ។ បុគ្គលគប្បីគប់មិត្តដែលជាពហុស្សូត ទ្រទ្រង់នូវធម៌ដ៏ក្រៃលែងដោយគុណ មានបដិភាណនោះ គឺមានសភាពបែបនោះ បន្ទាប់អំពីនោះ ស្គាល់ប្រយោជន៍ទាំងឡាយជាច្រើន មានប្រយោជន៍របស់ខ្លួន ប្រយោជន៍អ្នកដទៃ និងប្រយោជន៍ទាំងពីរ ឬដោយទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍ ដោយអានុភាពនៃមិត្តនោះ បន្ទាប់អំពីនោះ កម្ចាត់នូវសេចក្តីសង្ស័យបានហើយ ក្នុងឋានៈជាទីតាំងនៃសេចក្តីសង្ស័យទាំងឡាយ មានក្នុងអតីតកាល អាត្មាអញមានហើយឬហ្ន៎ជាដើម ដូច្នេះហើយ នាំចេញទៅនូវការងឿងឆ្ងល់ឲ្យអស់ទៅ មានកិច្ចទាំងពួង ដែលធ្វើហើយយ៉ាងនេះ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាសដូច្នោះ ។

ពហុស្សុតគាថា ចប់

## គាថាទី ២៩

គាថាថា **ខិឌ្ឌំ រតឹ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ក្នុងក្រុងពារាណសី ព្រះរាជាព្រះនាមវិភូសកព្រហ្មទត្ត សោយយាគូ ឬព្រះក្រយាហារអំពីព្រលឹម ទ្រង់តាក់តែងព្រះកាយដោយគ្រឿងអលង្ការច្រើនប្រភេទ ទ្រង់ឆ្លុះព្រះកាយទាំងមូលត្រង់កញ្ចក់ធំ ទ្រង់យកគ្រឿងអលង្ការដែល

មិនត្រូវការចេញ ឲ្យភ្នាក់ងារតាក់តែងដោយគ្រឿងប្រដាប់ដទៃ ថ្ងៃមួយ កាលទ្រង់ធ្វើយ៉ាងនេះ ក៏ដល់ពេលសោយព្រះក្រយាហារថ្ងៃត្រង់ កាលនោះ ទ្រទ្រង់តាក់តែងមិនទាន់ស្រេចបាច់ឡើយ ទ្រង់ក៏ជូតព្រះសីសៈដោយសំពត់ សោយហើយយាងចូលទីបន្ទំក្នុងពេលថ្ងៃ កាលទ្រង់ក្រោកឡើង ទ្រង់ធ្វើយ៉ាងនោះទៀត ព្រះអាទិត្យក៏អស្តង្គត ក្នុងថ្ងៃទី ២ ក្តី ក្នុងថ្ងៃទី ៣ ក្តី ទ្រង់ក៏ធ្វើយ៉ាងនោះ កាលទ្រង់ខ្វល់ខ្វាយដោយការតាក់តែងយ៉ាងនោះ ក៏កើតរោគឈឺត្រង់ព្រះបិដ្ឋិ ។

ព្រះរាជា ទ្រង់ព្រះរាជតម្រិះថា ឱ អញតាក់តែងដោយកម្លាំងទាំងអស់ ក៏មិនពេញចិត្តក្នុងគ្រឿងអលង្ការដែលសមគួរនេះ ញ៉ាំងការលោភឲ្យកើតឡើង ឈ្មោះថា ការលោភនេះ ធ្វើឲ្យអញដល់អបាយ ណ្ហើយចុះ អញនឹងសង្កត់សង្កិនលោភៈនោះ ដូច្នេះហើយ ទ្រង់លះបង់រាជសម្បត្តិចេញបួសបម្រើននូវវិបស្សនា ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ ទើបត្រាស់ឧទានគាថានេះថា

> បុគ្គលមិនតាក់តែងនូវការលេងផង ការត្រេកអរផង កាមសុខផង ក្នុងលោក មិនអាឡោះអាល័យ វៀរចាកទីជាទីស្អិតស្អាង អ្នកពោលពាក្យពិត គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ការលេង ការត្រេកអរ ក្នុងគាថានោះ បានពោលហើយក្នុងកាលមុន

នោះឯង ។ បទថា **កាមសុខំ** បានដល់ សេចក្ដីសុខក្នុងវត្ថុកាម ។ ពិតហើយ វត្ថុកាមទាំងឡាយ ហៅថា សុខ ព្រោះជាអារម្មណ៍ជាដើមរបស់កាមសុខ ។ ដូចព្រះដ៏មានព្រះភាគត្រាស់ថា តែរូបនេះជាសុខ មានសុខជាប់តាម ដូច្នេះ ។ បុគ្គលមិនពេញចិត្ត គឺមិនធ្វើនូវការល្មមនូវការលេង ការត្រេកអរ និងកាម-សុខនោះ ក្នុងឱកាសលោកនេះយ៉ាងនេះហើយ មិនកាន់យកវត្ថុនោះថា ជាការរុងរឿង ឬមិនកាន់យកវត្ថុនោះ ថាជាសារៈ ។

បទថា **អនបេក្ខមានោ** សេចក្ដីថា មានប្រក្រតីមិនសម្លឹង គឺមិនមានការចង់បាន មិនមានការល្មោភ ដោយការធ្វើនូវការពេញចិត្តនោះ ។ ក្នុងពាក្យថា **វិភូសនដ្ឋានា វិរតោ សច្ចវាទី ឯកោ ចរេ** នេះ គប្បីឃើញអត្ថយ៉ាងនេះថា គ្រឿងប្រដាប់មាន ២ យ៉ាង គឺគ្រឿងប្រដាប់សម្រាប់យកវាស ១ គ្រឿងប្រដាប់សម្រាប់បពា្វជិត ១ គ្រឿងប្រដាប់សម្រាប់យកវាស មានសំពត់សាដក សំពត់ជួតក្បាល ផ្កា និងគ្រឿងក្រអូបជាដើម ចំណែកគ្រឿងប្រដាប់សម្រាប់បពា្វជិត មានគ្រឿងតាក់តែង គឺបាត្រជាដើម គ្រឿងប្រដាប់នោះឯងឈ្មោះថា **វិភូសនដ្ឋាន** វៀរចាកឋានៈនៃការប្រដាប់នោះដោយវិរតិ ៣ យ៉ាង ឈ្មោះថា **សច្ចវាទី** ព្រោះពោលមិនខុសនោះឯង ។

**វិភូសនដ្ឋានគាថា ចប់**

# គាថាទី ២៦

គាថាថា **បុត្តញ្ច ទារំ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះរាជឱរសរបស់ព្រះបាទពារាណសី ទ្រង់អភិសេកហើយក្នុងកាលទ្រង់នៅក្មេងនោះឯង ហើយសោយរាជសម្បត្តិ ។ ទ្រង់សោយសិរីរាជសម្បត្តិ ដូចព្រះបច្ចេកពោធិសត្វដែលពោលហើយ ក្នុងបឋមគាថា ។ ក្នុងថ្ងៃមួយ ទ្រង់ព្រះរាជតម្រិះថា អញសោយរាជសម្បត្តិ រមែងធ្វើទុក្ខដល់ជនច្រើន ប្រយោជន៍អ្វីរបស់អញដោយបាបនេះ ដើម្បីប្រយោជន៍ដល់ការបរិភោគម្នាក់ឯង អញនឹងញុំាងសុខធំឲ្យកើតឡើង ដូច្នេះហើយ ទ្រង់លះរាជសម្បត្តិទ្រង់ចេញបួស ចម្រើនវិបស្សនា ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ បានត្រាស់ឧទានគាថានេះថា

> បុគ្គលលះបង់កូនផង ប្រពន្ធផង បិតាផង មាតាផង ទ្រព្យទាំងឡាយផង ស្រូវទាំងឡាយផង ផៅពង្សទាំងឡាយផង កាមទាំងឡាយតាមចំណែករៀងខ្លួនផង គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធនានិ** បានដល់ រតនៈទាំងឡាយ មានកែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាល ប្រាក់ មាសជាដើម ។ បទថា **ធញ្ញានិ** បានដល់ ពូជ ៧ យ៉ាង មានស្រូវសាលី ស្រូវខ្សាយ ស្រូវដំណើប ស្រងែ ថ្ពៅ ស្កួយ និងស្មៅគែលលក និងអបរណ្ណជាតិដ៏សេស ។

បទថា **ពន្ធវានិ** បានដល់ ផៅពង្ស ៤ ប្រភេទ គឺញាតិ គោត្ត មិត្ត និងសម្លាញ់ដែលរៀនសិប្បៈ ។ បទថា **យថោធិកានិ** បានដល់ ដែលតាំងនៅតាមចំណែករៀងៗខ្លួននោះឯង ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

*បុត្តទារគាថា ចប់*

## គាថាទី ២៧

គាថាថា **សង្គោ ឯសោ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងនគរពារាណសី មានព្រះរាជាមួយអង្គ ព្រះនាមព្រះបាទលោលព្រហ្មទត្ត ។ ព្រះរាជាសោយយាគូ ឬសោយព្រះក្រយាហារអំពីព្រលឹម ទ្រង់ទតអ្នករបាំ ៣ ប្រភេទ ក្នុងប្រាសាទទាំង ៣ ។ ពាក្យថា អ្នករបាំ ៣ ប្រភេទ បានដល់ អ្នករបាំដែលមកអំពីព្រះរាជាក្នុងអតីត ១ អ្នករបាំដែលមកអំពីព្រះរាជាបន្ទាប់មក ១ អ្នករបាំដែលតាំងឡើងក្នុងរជ្ជកាលរបស់ព្រះអង្គ ១ ។ ក្នុងថ្ងៃមួយ ទ្រង់យាងចូលកាន់ប្រាសាទរបស់អ្នករបាំវ័យក្មេង តាំងអំពីព្រលឹម ស្រីអ្នករបាំទាំងឡាយគិតថា ពួកយើងនឹងឲ្យព្រះរាជាទ្រង់ត្រេកអរ ទើបប្រកបការរាំ ការច្រៀង និងការប្រគំដែលគួរឲ្យចាប់ចិត្តក្រៃលែង ដូចស្រីទេពអប្សរ របស់សក្កទេវរាជ ដូច្នោះ ព្រះរាជាទ្រង់មិនពេញព្រះរាជហឫទ័យ

ក្នុងការរាំរបស់អ្នករបាំវ័យក្មេងទាំងឡាយនោះ ទ្រង់មិនអស្ចារ្យ ទើបយាងទៅកាន់ប្រាសាទរបស់អ្នករបាំវ័យកណ្តាល ស្ត្រីអ្នករបាំទាំងឡាយ ក៏បានធ្វើយ៉ាងនោះដូចគ្នា ទ្រង់មិនពេញព្រះរាជហឫទ័យ ក្នុងស្រីវ័យកណ្តាលនោះដូចគ្នា ទើបយាងទៅកាន់ប្រាសាទអ្នករបាំវ័យចាស់ ស្ត្រីអ្នករបាំទាំងនោះ ក៏ធ្វើយ៉ាងនោះដូចគ្នា ។

ព្រះរាជាឃើញការរាំ ដូចគ្នានឹងការលេងគ្រោងឆ្អឹង ព្រោះស្រីអ្នករបាំទាំងនោះជាមនុស្សចាស់ កន្លងទៅ ២-៣ រជ្ជកាលមកហើយ ទ្រង់ស្តាប់សំឡេងច្រៀងក៏មិនពីរោះ ទើបយាងទៅកាន់ប្រាសាទអ្នករបាំវ័យក្មេង ប្រាសាទអ្នករបាំវ័យកណ្តាល ទៅមកៗ យ៉ាងនេះ ក៏ទ្រង់មិនពេញព្រះហឫទ័យក្នុងទីណាឡើយ ទ្រង់ព្រះរាជតម្រិះថា ស្ត្រីអ្នករបាំទាំងនេះ បំណងឲ្យអញត្រេកអរ ដូចពួកទេពអប្សររបស់សក្កទេវរាជ ដូច្នោះ ទើបប្រកបការរាំ ការច្រៀង និងការប្រគំ ពេញសមត្ថភាពគ្រប់យ៉ាង អញមិនពេញចិត្តក្នុងចំណុចណាឡើយ ធ្វើឲ្យលោភៈចម្រើនប៉ុណ្ណោះ ឈ្មោះថា លោភៈនេះ ជាធម៌គប្បីឲ្យទៅកាន់អបាយ ណ្ហើយចុះ អញនឹងសង្កត់លោភៈ ដូច្នេះហើយ ទ្រង់លះរាជសម្បត្តិ ទ្រង់ព្រះផ្នួស ហើយចម្រើនវិបស្សនា ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ទើបបានត្រាស់ឧទានគាថានេះថា

កាមគុណនេះ ជាគ្រឿងជាប់ជំពាក់ សុខក្នុងកាមគុណនេះ មាន
ប្រមាណតិច កាមគុណ មានសេចក្តីត្រេកអរតិច ទុក្ខក្នុងកាម-

*គុណនេះច្រើនក្រៃលែង បុគ្គលអ្នកមានបញ្ញាដឹងច្បាស់ថា ការជាប់ជំពាក់ក្នុងកាមគុណនុ៎ះ ដូចជាបូស គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។*

*គាថានោះមានអត្ថថា បទថា* **សង្គោ ឯសោ** *សេចក្តីថា ព្រះបច្ចេកពុទ្ធសម្តែងការឧបភោគរបស់ខ្លួន ដ្បិតថា កាមនោះ ឈ្មោះថា* **សង្គ** *ព្រោះអត្ថថា សត្វទាំងឡាយជាប់ជំពាក់ក្នុងបញ្ចកាមគុណនោះ ដូចដំរីធ្លាក់នៅក្នុងភក់ ដូច្នោះ ។ បទថា* **បរិត្តមេត្ថ សោខ្យំ** *សេចក្តីថា ក្នុងកាលនៃការបរិភោគបញ្ចកាមគុណនេះ ឈ្មោះថា មានសេចក្តីសុខតិច ព្រោះអត្ថថា លាមក ដោយឲ្យកើតការសម្គាល់ខុស ឬទាក់ទងដោយកាមាវចរធម៌ អធិប្បាយថា មានបន្តិចបន្តួច គឺមានមួយជួរខណៈ ដូចសុខក្នុងការមើលរបាំ ក្នុងកាលមានផ្លេកបន្ទោរ ដូច្នោះ ។ ទោសរបស់កាមទាំងឡាយ គប្បីជ្រាបថា មានសេចក្តីត្រេកអរតិច ដូចដំណក់ទឹក កាលប្រៀបធៀបនឹងសេចក្តីទុក្ខ ដែលព្រះដ៏មានព្រះភាគត្រាស់ក្នុងមហាទុក្ខក្ខន្ធសូត្រ ដោយន័យយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខសោមនស្ស កើតឡើងព្រោះអាស្រ័យកាមគុណទាំង ៥ ប្រការនេះ នេះឯងជាតម្រេករបស់កាមទាំងឡាយ ដូច្នេះ ។ និងត្រាស់ទៀតថា ម្នាលភិក្ខុទាំងឡាយ កុលបុត្តក្នុងលោកនេះ ចិញ្ចឹមជីវិតដោយសេចក្តីប្រឹងប្រែង ដោយសិល្បសាស្ត្រឯណានីមួយ ទោះបីដោយការរាប់ម្រាមដៃទទេក្តី ដោយការរាប់លេខនព្វន្តក្តី ... ដូច្នេះជាដើម ដោយពិត មានទុក្ខ*

ក្រៃលែង គឺច្រើន ដូចគ្នានឹងទឹកក្នុងសមុទ្រទាំង ៤ ព្រោះហេតុនោះ ទើបព្រះបច្ចេកពុទ្ធពោលថា មានការត្រេកអរតិច មានទុក្ខច្រើន ដូច្នេះ ។

បទថា **គណ្ឌោ ឯសោ** សេចក្តីថា បញ្ចកាមគុណនេះ ប្រៀបដូចសន្ទូចដោយអំណាចបង្ហាញឲ្យត្រេកអរហើយ អូសមក ។ បទថា **ឥតិ ញត្វា មតិមា** សេចក្តីថា បុរសបណ្ឌិតដែលមានប្រាជ្ញា ដឹងយ៉ាងនេះហើយ គប្បីលះនូវកាមទាំងឡាយចោល ត្រាច់ទៅម្នាក់ឯង ដូចកុយរមាស ដូច្នោះ ។

សង្គគាថា ចប់

## គាថាទី ២៨

គាថាថា **សន្ទាលយិត្វាន** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងនគរពារាណសី មានព្រះរាជាព្រះនាមអនិវត្តព្រហ្មទត្ត ។ ព្រះរាជាយាងចូលកាន់សង្គ្រាម ទ្រង់បរាជ័យហើយមិនយាងត្រឡប់ ឬទ្រង់ប្រារព្ធរាជកិច្ចដទៃមិនទាន់សម្រេច ក៏មិនត្រឡប់ ព្រោះហេតុនោះ ទើបជនទាំងឡាយហៅទ្រង់យ៉ាងនោះ ។ ថ្ងៃមួយ ទ្រង់យាងទៅកាន់ព្រះរាជឧទ្យាន ។ ដោយសម័យនោះ ភ្លើងឆេះព្រៃ ភ្លើងនោះឆេះស្មៅស្ងួត និងវត្ថុមានស្មៅដែលជ្រុះទៅដីជាដើម រាលទៅមិនត្រឡប់ ព្រះរាជាទ្រង់ឃើញភ្លើងនោះហើយ ទ្រង់ញុំាងនិមិត្តដែលប្រៀបដូចភ្លើងនោះ ឲ្យកើតឡើងថា ភ្លើងព្រៃនេះ យ៉ាង

ណា ភ្លើង ១១ កង ក៏ដូច្នោះដូចគ្នា ចេះសត្វទាំងឡាយមិនវិលត្រឡប់ ញុំាំង ទុក្ខជំឲ្យកើតឡើង ក្នុងកាលណាហ្ន៎ អញមិនគប្បីឲ្យទុក្ខបែបនេះវិលត្រឡប់ គប្បីដុតកិលេសទាំងឡាយដោយភ្លើង គឺអរិយមគ្គញ្ញាណ ដូចភ្លើងនេះ ទៅ មិនត្រឡប់ ។

បន្ទាប់អំពីនោះ ព្រះរាជាយាងទៅមួយស្របក់ ទ្រង់ឃើញអ្នកប្រមង់ កំពុងចាប់ត្រីក្នុងស្ទឹង ត្រីធំមួយជាប់សំណាញ់របស់អ្នកប្រមង់ទាំងនោះ បាន ទម្លាយសំណាញ់គេចទៅ អ្នកប្រមង់ទាំងនោះស្រែកថា ត្រីទម្លាយសំណាញ់ គេចទៅហើយ ។ ព្រះរាជាស្តាប់ពាក្យនោះ ក៏ញុំាំងនិមិត្តដែលឧបមាដូចត្រី នោះ ឲ្យកើតឡើងថា ក្នុងកាលណាហ្ន៎ អញគប្បីទម្លាយសំណាញ់ គឺតណ្ហា និងទិដ្ឋិ ដោយអរិយមគ្គញ្ញាណទៅ មិនជាប់ជំពាក់ ដូច្នេះ ព្រះរាជានោះ ទ្រង់លះបង់រាជសម្បត្តិ ទ្រង់ព្រះផ្នួស ហើយប្រារព្ធវិបស្សនា បានធ្វើឲ្យជាក់ ច្បាស់នូវបច្ចេកពោធិញ្ញាណ ហើយត្រាស់ឧទានគាថានេះថា

> បុគ្គលទម្លាយនូវសំយោជនៈ ដូចត្រីក្នុងទឹកទម្លាយបង់នូវបណ្តាញ
> មិនត្រឡប់មក ( រកសំយោជនៈ ) វិញ ដូចជាភ្លើងចេះ ( មិន
> ត្រឡប់វិលវិញ ) គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស
> ដូច្នេះ ។

ក្នុងបទទី ២ នៃគាថានោះ វត្ថុដែលសម្រេចដោយអំបោះ ហៅថា **ជាលំ** ប្រែថា សំណាញ់ ទឹក ហៅថា **អម្ពុ។** ឈ្មោះថា **អម្ពុចារី** ព្រោះអត្ថថា ហែល

ទៅក្នុងទឹកនោះ ។ បទថា **អម្ពុចារី** នោះ ជាឈ្មោះរបស់ត្រី ត្រីដែលហែលទៅក្នុងទឹក ឈ្មោះថា **សលិលម្ពុចារី** អធិប្បាយថា ដូចត្រីទម្លាយសំណាញ់ក្នុងទឹកនៃនទី ដូច្នោះ ។

ក្នុងបាទទី ៣ ស្ថានទីដែលត្រូវភ្លើងឆេះ ហៅថា **ទឌ្ឍំ** ប្រែថា ដែលឆេះហើយ អធិប្បាយថា ភ្លើងរមែងមិនវិលត្រឡប់ទៅកាន់ទីដែលឆេះហើយ គឺមិនមកក្នុងទីដែលឆេះហើយនុ៎ះដោយពិត យ៉ាងណា បុគ្គលមិនត្រឡប់ទៅកាន់ទីនៃកាមគុណដែលភ្លើង គឺមគ្គញ្ញាណឆេះហើយ គឺមិនមកក្នុងទីនៃកាមគុណនោះពិត ក៏ដូច្នោះ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

សន្ទាលនគាថា ចប់

## គាថាទី ២៩

គាថាថា **ឱក្ខិត្តចក្ខុ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងនគរពារាណសី ព្រះរាជាព្រះនាមចក្ខុលោលព្រហ្មទត្តទ្រង់ចូលចិត្តមើលរបាំ ដូចព្រះបាទលោលព្រហ្មទត្តដែរ ចំណែកសេចក្តីប្លែកគ្នា មានដូច្នេះថា

ព្រះបាទលោលព្រហ្មទត្ត ទ្រង់មិនពេញព្រះរាជហឫទ័យហើយ យាងទៅក្នុងទីនោះៗ តែព្រះបាទចក្ខុលោលព្រហ្មទត្តនេះ ទ្រង់ឃើញអ្នករបាំនោះៗ

ហើយ ទ្រង់ត្រេកអរក្រៃលែង ទ្រង់ធ្វើនូវតណ្ហាឲ្យចម្រើនដោយការទតមើលអ្នករបាំដែលយាងយាស ។ បានឮថា ទ្រង់ឃើញកិរិយារបស់កុដុម្ពិកៈម្នាក់ដែលមកមើលអ្នករាំ ទ្រង់ញ៉ាំងរាគៈឲ្យកើតឡើង បន្ទាប់អំពីនោះ ទ្រង់សង្វេគថា អញញ៉ាំងតណ្ហានេះឲ្យចម្រើនទៀត នឹងពេញក្នុងអបាយ ណ្ហើយចុះ អញនឹងសង្កត់រាគៈនេះ ដូច្នេះហើយ ទ្រង់ព្រះផ្នួស ចម្រើននូវវិបស្សនា ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ កាលទ្រង់តិះដៀលនូវការប្រព្រឹត្តិក្នុងកាលមុនរបស់ព្រះអង្គ ទើបត្រាស់ឧទានគាថានេះ ដើម្បីទ្រង់សម្តែងគុណដែលជាបដិបក្ខចំពោះការប្រព្រឹត្តិនោះថា

*បុគ្គលមានចក្ខុជាក់ចុះ មានជើងមិនរពឹស មានឥន្ទ្រិយគ្រប់គ្រងល្អ មានចិត្តរក្សាទុក មិនជោកជាំ មិនរោលរាលដោយកិលេស គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។*

ក្នុងគាថានោះ បទថា **ឱក្ខិត្តចក្ខុ** បានដល់ មានភ្នែកជាក់ចុះ អធិប្បាយថា បុគ្គលដាក់ទីតទាំង ៧ តាមលំដាប់ហើយ ( តម្រួតឆ្អឹងកឲ្យត្រង់លើគ្នា ) សម្លឹងមើលមួយជួរនឹម ដើម្បីវៀរ និងមើលវត្ថុដែលគួរលះ មិនមែនយកឆ្អឹងចង្កាមកទល់នឹងឆ្អឹងទ្រូង ព្រោះមានចក្ខុជាក់ចុះយ៉ាងនេះ មិនគួរដល់សមណៈ ។

បទថា **ន ច បាទលោលោ** សេចក្តីថា មិនដើររាត់រាយទៅ ដូចបុគ្គលដែលមានជើងខ្វេរ ព្រោះប្រញាប់ចូលទៅក្នុងពួកគណៈ យ៉ាងនេះថា ខ្ញុំជាបុគ្គលទី ២ សម្រាប់មនុស្សទី ១ ទី ៣ សម្រាប់មនុស្សទី ២ ឬវៀរការត្រាច់ទៅយូរ

និងការត្រាច់ទៅ មិនត្រឡប់ ។

បទថា **គុត្តិន្ទ្រិយោ** បានដល់ មានឥន្ទ្រិយរក្សាហើយ ក្នុងឥន្ទ្រិយទាំង ៦ ដោយអំណាចដែលពោលមួយផ្នែក ក្នុងគាថានេះ ។

បទថា **រក្ខិតមានសានោ** សេចក្តីថា មានសៈនោះ ឈ្មោះថា **មាន-សាន** មានសានៈនោះ ដែលបុគ្គលរក្សាហើយ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **រក្ខិតមានសានោ** ប្រែថា មានចិត្តដែលខ្លួនរក្សាហើយ អធិប្បាយថា មានចិត្តដែលខ្លួនរក្សាហើយ ដោយប្រការដែលចិត្តមិនប្រឡាក់ដោយកិលេសទាំងឡាយ ។

បទថា **អនវស្សុតោ** សេចក្តីថា បុគ្គលវៀរចាកការលិចស្រោចរបស់កិលេស ក្នុងអារម្មណ៍នោះៗ ដោយកិច្ចបដិបត្តិនេះ ។

បទថា **អបរិឌយ្ហមានោ** សេចក្តីថា ដែលភ្លើង គឺកិលេសទាំងឡាយមិនដុត ព្រោះវៀរចាកការហូរមកយ៉ាងនេះឯង ឬដែលកិលេសទាំងឡាយមិនលិចស្រោចហើយហើយខាងក្រៅ មិនដុតរោលខាងក្នុង ។ បទដ៏សេសមានន័យដូចពោលហើយនោះឯង ។

**ឧក្ខិត្តបក្ខុគាថា ចប់**

# គាថាទី ៣០

គាថាថា **ឱហារយិត្វា** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងនគរពារាណសី ព្រះរាជាព្រះនាមចាតុមាសិកព្រហ្មទត្ត មួយអង្គទៀត ទ្រង់យាងទៅក្រសាលកីឡា ក្នុងព្រះរាជឧទ្យានរៀងរាល់ ៤ ខែម្ដង ។ ថ្ងៃមួយ ព្រះរាជា កាលយាងចូលព្រះរាជឧទ្យាន ក្នុងកណ្ដាលខែនៃរដូវក្ដៅ ទ្រង់ឃើញរលួសផ្អុង ដូចដើមបារិច្ឆត្តកៈក្នុងស្ថានសួគ៌ ដែលមានប្រគាបចេញផ្ការីកស្គុសស្គាយ លម្អដោយស្លឹក ក្បែរទ្វារនៃព្រះរាជឧទ្យាន ទើបទ្រង់កាច់យកផ្កាមួយហើយ យាងចូលកាន់ព្រះរាជឧទ្យាន ។ បន្ទាប់អំពីនោះ អមាត្យម្នាក់គិតថា ព្រះរាជាទ្រង់ក្ដិចយកផ្កា ទើបឈរលើកដំរីនោះ បេះផ្កាមួយ ដោយឧបាយនោះឯង ពលនិកាយទាំងអស់ ក៏បេះយកដែរ បុគ្គលដែលមិនបានផ្កា បេះយកស្លឹក ដើមនោះ ប្រាសចាកស្លឹក និងផ្កា សល់តែដើមប៉ុណ្ណោះ ។

ក្នុងពេលល្ងាច ព្រះរាជាយាងចេញអំពីព្រះរាជឧទ្យាន ទ្រង់ឃើញដើមឈើនោះ ទ្រង់ព្រះរាជតម្រិះថា ដើមឈើនេះអ្នកណាធ្វើ ក្នុងកាលអញមករីកស្គុសស្គាយដោយផ្កាដ៏ស្អាត ដូចកែវប្រពាល ក្នុងរវាងមែកដែលមានពណ៌ដូចកែវមណី ឥឡូវនេះ ក្លាយជាដើមឈើប្រាសចាកស្លឹក និងផ្កាហើយ ទ្រង់ឃើញដើមឈើមិនចេញផ្កា មានស្លឹកលឿង ជ្រះជេរជាសក្នុងទីមិនឆ្ងាយអំពីដើមឈើនោះឯង កាលទ្រង់ឃើញហើយ ទ្រង់ព្រះតម្រិះដូច្នេះថា ដើមឈើនេះ ជាទីតាំងនៃលោភៈរបស់មហាជន ព្រោះមានមែករីកស្គុសស្គាយដោយ

ផ្កា ព្រោះហេតុនោះ ទើបដល់នូវអន្តរាយត្រឹមមួយជួរខណៈប៉ុណ្ណោះ ចំណែកដើមឈើដទៃ គង់តាំងនៅដដែល ព្រោះមិនជាទីតាំងនៃសេចក្តីលោភ រាជសម្បត្តិនេះ គប្បីជាទីតាំងនៃសេចក្តីលោភ ដូចគ្នានឹងដើមឈើមានផ្កា ចំណែកភាពជាភិក្ខុ មិនគប្បីជាទីតាំងនៃសេចក្តីលោភ ដូចដើមឈើមិនមានផ្កា ព្រោះហេតុនោះ រាជសម្បត្តិនេះ មិនទាន់ត្រូវដណ្តើម ដូចដើមឈើនេះ ដរាបណា អាត្មាអញគប្បីជាអ្នកបិទបាំង ដោយសំពត់កាសាវៈ ដូចដើមរលួសផ្អុងដទៃដែរជាសដោយស្លឹកពណ៌លឿង ហើយបួសដរាបនោះ ។ ព្រះរាជាទ្រង់លះរាជសម្បត្តិ ទ្រង់ព្រះផ្នួស ចម្រើននូវវិបស្សនា ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ហើយត្រាស់ឧទានគាថានេះថា

> បុគ្គលលះបង់នូវវត្ថុជាគ្រឿងប្រាកដនូវភាពជាគ្រហស្ថ ដូចដើមបារិច្ឆត្តព្រឹក្ស មានស្លឹកជម្រុះហើយ គប្បីជាអ្នកមានសំពត់កាសាយៈ ចេញបួស ត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាសដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាសាយវត្ថោ អភិនិក្ខមិត្វា** ដូច្នេះ បណ្ឌិតគប្បីជ្រាបអត្ថយ៉ាងនេះថា ចេញអំពីផ្ទះហើយ ស្លៀកដណ្តប់សំពត់កាសាយៈ ។ បទដ៏សេស គប្បីដឹងដោយន័យដែលពោលហើយនោះឯង ព្រោះដូច្នេះ ទើបមិនបានពោលឲ្យពិស្តារ ៕

**ចារិច្ឆត្តកគាថា ចប់**

**វគ្គទី ៣ ចប់**

# វគ្គទី ៤

## គាថាទី ៣១

គាថាថា **រសេសុ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះបាទពារាណសីមួយអង្គ ទ្រង់ចោមរោមដោយបុត្តអមាត្យទាំងឡាយ ក្នុងព្រះរាជឧទ្យាន ទ្រង់លេងកីឡាក្នុងស្រះបោក្ខរណី ដែលមានផ្ទាំងថ្ម ក្នុងព្រះរាជឧទ្យានអ្នកពិសេសកាន់រសនៃសាច់ទាំងពួង ផ្សំព្រះក្រយាហារ ក្នុងវាំង ( កាល ) ដែលចម្អិនល្អក្រៃលែង ដូចអមតៈហើយ បង្អោនថ្វាយដល់ព្រះរាជា ព្រះរាជាទ្រង់ដល់នូវការជាប់ជំពាក់ក្នុងព្រះក្រយាហារនោះ ទ្រង់មិនប្រទានអ្វីដល់បុគ្គលណាឡើយ សោយតែមួយព្រះអង្គឯងទ្រង់ក្រសាលក្នុងទឹក និងយាងចេញក្នុងពេលងងឹត ក៏ប្រញាប់ប្រញាល់សោយ មិនបានទឹកដល់បរិជនដែលទ្រង់ធ្លាប់សោយជាមួយគ្នា មកអំពីកាលមុន ។

លុះដល់ពេលខាងក្រោយ ទ្រង់រឭកបានថា ឱ អញធ្វើបាប អញជាអ្នកត្រូវចំណង់ក្នុងរសអាហារគ្របសង្កត់ ភ្លេចទឹកដល់ជនទាំងពួង បរិភោគតែម្នាក់ឯង ណ្ហើយចុះ អញនឹងសង្កត់ចំណង់ក្នុងរស ដូច្នេះហើយ ទ្រង់លះរាជសម្បត្តិ ទ្រង់ព្រះផ្នួស ចម្រើនវិបស្សនា ទ្រង់ក៏ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ទ្រង់តិះដៀលបដិបត្តិក្នុងកាលមុនរបស់ព្រះអង្គ ទើបត្រាស់ឧទានគាថានេះ ដែលសម្ដែងដល់បដិបទា ដែលជាបដិបក្ខចំពោះបដិបត្តិក្នុងកាលមុននោះថា

បុគ្គលមិនធ្វើសេចក្តីប្រាថ្នា ក្នុងរសទាំងឡាយ ជាអ្នកមិនល្មោភ ( ក្នុងអាហារ ) មិនចិញ្ចឹមអ្នកដទៃ ជាអ្នកត្រាច់ទៅតាមច្រក មិនមានចិត្តជាប់ចំពាក់ក្នុងត្រកូលផ្សេងៗ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រសេសុ** សេចក្តីថា មិនធ្វើនូវការត្រេកអរ គឺមិនធ្វើការជាប់ក្នុងរសដែលគួរលិទ្ធភក្សទាំងឡាយ មានរសជូរ ផ្អែម ល្វីង ហឹរ ប្រៃ ហាង ចត់ជាដើម មានអធិប្បាយថា មិនញុំាងចំណង់ឲ្យកើតឡើង ។ បទថា **អលោលោ** សេចក្តីថា មិនល្មោះល្មោភក្នុងរសពិសេសទាំងឡាយថា អញនឹងលិទ្ធរសនេះ ។

បទថា **អនញ្ញបោសី** សេចក្តីថា វៀរចាកបុគ្គលដែលមានសទ្ធិវិហារិក ដែលខ្លួនគប្បីចិញ្ចឹមជាដើម អធិប្បាយថា ត្រេកអរហើយ ដោយហេតុត្រឹមតែការសង្រួមផ្លូវកាយ ។ម្យ៉ាងទៀត ព្រះបច្ចេកពុទ្ធសម្តែងថា ក្នុងកាលមុន យើងជាបុគ្គលល្មោះល្មោភក្នុងការធ្វើនូវការជាប់ចំពាក់ក្នុងរសទាំងឡាយ ត្រង់ឧទ្យានហើយ ជាអ្នកចិញ្ចឹមបុគ្គលដទៃ យ៉ាងណា យើងជាបុគ្គលល្មោះល្មោភដោយតណ្ហាណាហើយ ធ្វើនូវសេចក្តីត្រេកអរក្នុងរសទាំងឡាយ ភិក្ខុមិនដូច្នោះ លះតណ្ហានោះ មិនចិញ្ចឹមអ្នកដទៃ ព្រោះអត្តភាពដទៃដែលមានតណ្ហាជាមូល មិនកើតតទៅ ។ ម្យ៉ាងទៀត កិលេស ហៅថា **អញ្ញោ** ព្រោះអត្ថថា កាច់បំបាក់នូវប្រយោជន៍ ។ ក្នុងសេចក្តីនេះ មានអធិប្បាយយ៉ាងនេះថា ភិក្ខុ

ឈ្មោះថា មិនចិញ្ចឹមអ្នកដទៃ ព្រោះមិនចិញ្ចឹមកិលេសទាំងនោះ ។

បទថា **សបទានចារី** សេចក្ដីថា មានប្រក្រតីត្រាច់ទៅដោយការមិនឆ្លងលំដាប់ គឺមានប្រក្រតីត្រាច់ទៅតាមលំដាប់ មិនលះលំដាប់នៃផ្ទះ ចូលទៅកាន់ត្រកូលរបស់បុគ្គលស្ដុកស្ដម្ភ និងត្រកូលរបស់អ្នកក្រីក្រ ដើម្បីបិណ្ឌបាតរឿយៗ ។

បទថា **កុលេ កុលេ អប្បដិពទ្ធចិត្តោ** សេចក្ដីថា ជាអ្នកមានចិត្តមិនជាប់ជំពាក់ដោយអំណាចនៃកិលេស ក្នុងត្រកូលណាមួយ ក្នុងបណ្ដាត្រកូលទាំងឡាយ មានត្រកូលស្ដេចជាដើម ជាបុគ្គលថ្មីជានិច្ច ដូចព្រះចន្ទ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

រសគេធគាថា ចប់

## គាថាទី ៣២

គាថាថា **បហាយ បញ្ចាវរណានិ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះរាជាមួយអង្គក្នុងនគរពារាណសី ទ្រង់បានបឋមជ្ឈាន ទ្រង់លះរាជសម្បត្តិដើម្បីរក្សាឈាន ទ្រង់បួសហើយ ចម្រើនវិបស្សនា ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ដើម្បីសម្ដែងសម្បទាបដិបត្តិរបស់ព្រះអង្គ ទើបត្រាស់ឧទានគាថានេះថា

បុគ្គលលះបង់នូវនីវរណៈទាំង ៥ បន្ទោបង់នូវឧបក្កិលេសនៃចិត្ត
ទាំងអស់ចេញបាន ជាអ្នកមិនអាស្រ័យ ( ដោយតណ្ហា ) កាត់
បង់នូវទោស ដែលកើតអំពីសេចក្ដីស្រឡាញ់ហើយ គប្បីត្រាច់
ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អាវរណានិ** បានដល់ នីវរណៈទាំងឡាយ នោះឯង នីវរណៈទាំងនោះ ដោយអត្ថបានពោលហើយ ក្នុងឧរគសូត្រ នីវរណៈទាំងនោះ ព្រោះរាំងនូវចិត្តដូចពពកជាដើម ដែលបិទបាំងព្រះចន្ទ និងព្រះអាទិត្យ ព្រោះហេតុនោះ ទើបហៅថា ធម៌ជាគ្រឿងរាំងចិត្ត លះនូវនីវរណៈទាំងនោះដោយឧបចារៈ ឬដោយអប្បនា ។

បទថា **ឧបក្កិលេសេ** បានដល់ អកុសលធម៌ទាំងឡាយ ដែលចូលមកបៀតបៀនចិត្ត ឬធម៌ទាំងឡាយ មានអភិជ្ឈាជាដើម ដែលពោលហើយក្នុងសូត្រទាំងឡាយ មានវត្ថោបមសូត្រជាដើម ។

បទថា **ព្យបនុជ្ជ** សេចក្ដីថា បន្ទោបង់ហើយ គឺឲ្យវិនាសហើយ អធិប្បាយថា លះបង់ហើយដោយវិបស្សនាមគ្គ ។

បទថា **សព្វេ** បានដល់ មិនមានសេសសល់ ។ បុគ្គលដល់ព្រមដោយសមថៈ និងវិបស្សនាយ៉ាងនេះ ឈ្មោះថា ទិដ្ឋិមិនអាស្រ័យ ព្រោះភាពដែលទិដ្ឋិនិស្ស័យដែលលោកលះហើយដោយបឋមមគ្គ កាត់នូវទោស គឺការជាប់ជំពាក់ ដែលជាប់តាមត្រៃធាតុបានហើយ ដោយមគ្គដ៏សេសទាំងឡាយ

អធិប្បាយថា កាត់នូវតណ្ហារាគៈបានហើយ ។ ឯការជាប់ជំពាក់នោះឯង ហៅថា ទោស គឺការជាប់ជំពាក់ ព្រោះជាបដិបក្ខចំពោះវត្ថុដែលជាគុណ ។ បទដ៏សេស ងាយយល់ទាំងអស់ហើយ ។

អាវរណគាថា ចប់

## គាថាទី ៣៣

គាថាថា **វិបិដ្ឋិកត្វាន** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះរាជាមួយអង្គក្នុងនគរពារាណសី ទ្រង់បាននូវចតុត្ថជ្ឈានព្រះរាជាទ្រង់លះរាជសម្បត្តិដើម្បីតាមរក្សាឈាន ទ្រង់ព្រះផ្នួស ចម្រើននូវវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ កាលទ្រង់សម្តែងសម្បទានៃបដិបត្តិរបស់ព្រះអង្គ ទើបត្រាស់ឧទានគាថានេះថា

បុគ្គលបានធ្វើនូវសុខទុក្ខ និងសោមនស្សទោមនស្សក្នុងកាលមុន
ឲ្យនៅពីក្រោយខ្នងហើយ បាននូវឧបេក្ខាសមថៈ ក្នុងចតុត្ថជ្ឈាន
ដ៏បរិសុទ្ធហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **វិបិដ្ឋិកត្វាន** សេចក្តីថា ធ្វើទុកខាងក្រោយ គឺចោលហើយ លះបង់ហើយ ។ បទថា **សុខំ ទុក្ខញ្ច** បានដល់ សេចក្តីសុខតាមកាយ និងសេចក្តីមិនសុខផ្លូវកាយ ។ បទថា **សោមនស្សទោមនស្សំ**

បានដល់ សេចក្ដីសុខផ្លូវចិត្ត និងសេចក្ដីមិនសុខផ្លូវចិត្ត ។ បទថា **ឧបេក្ខំ** បានដល់ ឧបេក្ខាក្នុងចតុត្ថជ្ឈាន ។ បទថា **សមថំ** បានដល់ សមថៈក្នុងចតុត្ថជ្ឈាននោះឯង ។ បទថា **វិសុទ្ធំ** សេចក្ដីថា ឈ្មោះថា បរិសុទ្ធហើយ ព្រោះផុតចាកធម៌ដែលជាសត្រូវទាំងឡាយ ៩ យ៉ាង ពោល គឺនីវរណៈ ៥ វិតក្ក វិចារ បីតិ និងសុខ អធិប្បាយថា ប្រាសចាកឧបក្កិលេសហើយ ដូចមាសដែលដេញល្អហើយ ។

យោជនាមានដូច្នេះថា លះសុខនិងទុក្ខ អធិប្បាយថា ទុក្ខក្នុងឧបចារភូមិនៃបឋមជ្ឈាននោះៗ ឯងក្នុងកាលមុន សុខក្នុងឧបចារភូមិនៃតតិយជ្ឈាន ។ មានអធិប្បាយថា លះនូវសោមនស្ស និងទោមនស្សក្នុងកាលមុនបាន ព្រោះនាំ ច អក្ខរៈ ដែលពោលហើយខាងដើម ទៅខាងមុខទៀត ដោយ ច អក្ខរៈនោះ ព្រះបច្ចេកពុទ្ធសម្ដែងថា លះនូវសោមនស្សក្នុងឧបចារៈនៃចតុត្ថជ្ឈាន និងទោមនស្សក្នុងឧបចារៈនៃទុតិយជ្ឈាននោះឯង ។ ពិតហើយ ឧបចារៈនៃចតុត្ថជ្ឈាន និងឧបចារៈនៃទុតិយជ្ឈានទាំងនោះ ជាឋានៈក្នុងការលះសោមនស្ស និងទោមនស្សទាំងនោះដោយអម ។ តែដោយត្រង់ បឋមជ្ឈានជាឋានៈក្នុងការលះទុក្ខ ទុតិយជ្ឈាន ជាឋានៈក្នុងការលះទោមនស្ស តតិយជ្ឈាន ជាឋានៈក្នុងការលះសុខ ចតុត្ថជ្ឈាន ជាឋានៈក្នុងការលះសោមនស្ស ដូចព្រះដ៏មានព្រះភាគត្រាស់ថា ទុក្ខិន្ទ្រិយកើតឡើងក្នុងបឋមជ្ឈាននេះ តែងរលត់ទៅឥតមានសេសសល់ ដូច្នេះជាដើម ។

សេចក្តីទាំងអស់នោះ ខ្ញុំពោលហើយ ក្នុងអដ្ឋកថាធម្មសង្គហៈ ឈ្មោះអដ្ឋសាលិនី ។ ព្រោះបុគ្គលលះទុក្ខ ទោមនស្ស និងសុខក្នុងកាលមុនបាន គឺក្នុងឈានទាំង ៣ មានបឋមជ្ឈានជាដើម ទើបលះសោមនស្សក្នុងចតុត្ថជ្ឈាននោះឯង បានឧបេក្ខាដែលស្ងប់បរិសុទ្ធ ដោយបដិបទានេះ គប្បីត្រាច់ទៅតែម្នាក់ឯង ។ បទដ៏សេស ក្នុងទីទាំងពួង ប្រាកដច្បាស់ហើយ ។

**វិបិដ្ឋិកត្វាគាថា ចប់**

# គាថាទី ៣៤

គាថាថា **អារទ្ធវីរិយោ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះបាទបច្ចន្តរាជមួយអង្គ ទ្រង់មានពលទាហានប្រមាណ ១ ពាន់ ទ្រង់មានព្រះរាជសម្បត្តិតិច តែមានព្រះបញ្ញាច្រើន ថ្ងៃមួយ ព្រះរាជាទ្រង់ព្រះរាជតម្រិះថា អាត្មាអញជាស្តេចក្រីក្រក៏ពិត តែអញមានបញ្ញាអាចដណ្តើមយកជម្ពូទ្វីបទាំងមូលបាន ដូច្នេះហើយ ទ្រង់បញ្ជូនទូតដល់ព្រះបាទសាមន្តរាជថា ខាងក្នុង ៧ ថ្ងៃចូរឲ្យរាជសម្បត្តិដល់យើង ឬក៏ច្បាំង ។ បន្ទាប់អំពីនោះ ទ្រង់ប្រជុំពួកអមាត្យរបស់ទ្រង់ហើយ ត្រាស់ថា យើងមិនបានប្រឹក្សាជាមួយពួកលោក បានធ្វើនូវការរួសរាន់បញ្ជូនទូតយ៉ាងនេះដល់ព្រះរាជាឈ្មោះនោះ តើគប្បីធ្វើដូចម្តេច អមាត្យទាំងឡាយនោះទូលថា បពិត្រមហារាជ ទ្រង់

អាចហៅទូតនោះត្រឡប់ឬ ព្រះរាជាត្រាស់ថា មិនអាច ទូតនោះទៅហើយ អមាត្យទូលថា បើយ៉ាងនោះ ពួកទូលបង្គំត្រូវទ្រង់ឲ្យវិនាសហើយ ព្រោះហេតុនោះ ការស្លាប់ដោយដៃរបស់អ្នកដទៃជាទុក្ខ ណ្ហើយចុះ ពួកទូលបង្គំនឹងសម្លាប់គ្នាឲ្យស្លាប់ ឬសម្លាប់ខ្លួនឯងឲ្យស្លាប់ ឬចងកផឹកថ្នាំពិសឲ្យស្លាប់ ។

ក្នុងអមាត្យទាំងនោះ អមាត្យម្នាក់ៗ បានពណ៌នាសេចក្តីស្លាប់យ៉ាងនេះប៉ុណ្ណោះ បន្ទាប់អំពីនោះ ព្រះរាជាត្រាស់ថា តើមានប្រយោជន៍អ្វីដោយអមាត្យទាំងនេះ នៃលោក យើងមានទាហាន ដូច្នេះ ។ ខណៈនោះ ទាហាន ១ ពាន់នាក់ក្រោកឡើងទូលថា បពិត្រមហារាជ ទូលបង្គំជាទាហាន ។ ព្រះរាជាទ្រង់ព្រះរាជតម្រិះថា អញនឹងពិសោធទាហានទាំងនោះ ដូច្នេះហើយ ទ្រង់ឲ្យត្រៀមជើងថ្ករ ត្រាស់ថា នែអ្នកទាំងឡាយ យើងបានធ្វើការរួសរាន់ឈ្មោះនេះ ពួកអមាត្យជំទាស់ការធ្វើរបស់យើងនោះ ដូច្នោះ យើងនឹងលោតចូលក្នុងជើងថ្ករ តើអ្នកណាខ្លះលោតទៅជាមួយយើង អ្នកណាព្រមលះបង់ជីវិតដើម្បីយើង កាលត្រាស់ដូច្នេះហើយ ពួកទាហាន ៥០០ នាក់ នាំគ្នាក្រោកឡើងទូលថា ទូលបង្គំនឹងលោត ។

លំដាប់នោះ ព្រះរាជាត្រាស់នឹងទាហាន ៥០០ ទៀតថា នែអ្នកទាំង-ឡាយ ឥឡូវនេះ ពួកអ្នកគិតដូចម្តេច ទាហាន ៥០០ នោះក្រាបទូលថា បពិត្រមហារាជ នេះមិនមែនជាការធ្វើរបស់កូនប្រុស នុ៎ះជាការប្រព្រឹត្តិរបស់កូនស្រី សេចក្តីពិត មហារាជបញ្ជូនទូតដល់ព្រះរាជាជាសត្រូវហើយ ពួកទូល

បង្គំនឹងច្បាំងជាមួយព្រះរាជានោះរហូតដល់ស្លាប់ ។ បន្ទាប់អំពីនោះ ព្រះរាជាត្រាស់ថា ពួកអ្នកលះបង់ជីវិតដើម្បីយើង ដូច្នេះហើយ ទ្រង់ឲ្យត្រៀមចតុរង្គិនីសេនា ទ្រង់ចោមរោមដោយទាហាន ១ ពាន់ យាងទៅប្រថាប់គង់ក្នុងជាយដែនរដ្ឋសីមា ។

ចំណែកព្រះបាទបជិរាជ ទ្រង់ស្តាប់ព្រឹត្តិការណ៍នោះហើយ ទ្រង់ត្រេកអរថា អើ ស្តេចតូចតាចនោះ មិនល្មមដល់ទាសៈរបស់យើង ដូច្នេះហើយ ទ្រង់លើកទ័ពទាំងអស់ចេញមកដើម្បីច្បាំង ព្រះបាទខុទ្ទករាជ ទ្រង់ឃើញព្រះបាទបជិរាជនោះ លើកកងទ័ពចេញមកប្រឈមមុខ ទើបត្រាស់នឹងពួកពលនិកាយថា នែបា ពួកយើងមានគ្នាមិនច្រើន ពួកលោកទាំងអស់ ចូររួមគ្នាកាន់ដាវនិងខែល រត់តម្រង់ទៅរកព្រះរាជានេះដោយរហ័ស ទាហានទាំងនោះ បានធ្វើតាមព្រះតម្រាស់ ខណៈនោះ កងទ័ពនោះក៏បែកគ្នាជាពីរពួក បើកឱកាសឲ្យពួកទាហានទាំងនោះ ក៏ចាប់ព្រះរាជាទាំងរស់ ពួកទាហានដទៃក៏គេចទៅ ។ ព្រះបាទខុទ្ទករាជ រត់ទៅខាងមុខដោយព្រះតម្រិះថា នឹងសម្លាប់ព្រះរាជានោះ ព្រះបាទបជិរាជទ្រង់ទូលសូមអភ័យ ជាមួយព្រះបាទខុទ្ទករាជនោះ បន្ទាប់អំពីនោះ ព្រះបាទខុទ្ទករាជ ទ្រង់ឲ្យនូវការមិនមានភ័យ ដល់ព្រះបាទបជិរាជនោះ ទ្រង់ឲ្យព្រះបាទបជិរាជនោះធ្វើនូវសម្បថ ធ្វើឲ្យជាបក្ខពួករបស់ព្រះអង្គហើយ ទ្រង់ផ្តើមដើម្បីចាប់ព្រះរាជាដទៃទាំងរស់ទៀត ទើបយាងទៅជាមួយព្រះបាទបជិរាជនោះ ទ្រង់ប្រថាប់ឈរក្នុងជាយដែន រាជសីមារបស់ព្រះបាទបជិរាជ

( ដទៃ ) នោះ ទ្រង់បញ្ជូនសំបុត្រទៅថា ឲ្យរាជសម្បត្តិដល់យើង ឬមួយក៏ចង់ច្បាំង ព្រះរាជានោះទ្រង់ព្រះរាជតម្រិះថា យើងមិនហ៊ានច្បាំង ទើបទ្រង់ប្រគល់រាជសម្បត្តិ ។ ដោយឧបាយនោះឯង ព្រះរាជាទាំងឡាយណាច្បាំង ព្រះរាជាទាំងនោះក៏ចាញ់ ទើបព្រះរាជាទាំងនោះមិនច្បាំង ប្រគល់រាជសម្បត្តិឲ្យ ព្រះបាទខុទ្ទករាជក៏នាំព្រះរាជាទាំងអស់ ចាប់ព្រះបាទពារាណសីក្រោយគេ ។ ព្រះរាជាអង្គនោះ ទ្រង់មានព្រះរាជា ១០១ អង្គហោមរោម ទ្រង់គ្រប់គ្រងរាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូល ហើយសោយសិរីរាជសម្បត្តិ ។

ក្នុងកាលតមក ព្រះរាជាទ្រង់ព្រះតម្រិះថា ក្នុងកាលមុនអញជាស្តេចក្រីក្រ បានជាធំក្នុងជម្ពូទ្វីបទាំងមូល ដោយបញ្ញាសម្បត្តិរបស់ខ្លួន បញ្ញារបស់អញ ប្រកបដោយលោកិយវីរិយៈ បញ្ញានោះ មិនប្រព្រឹត្តទៅដើម្បីនិព្វិទា មិនប្រព្រឹត្តទៅដើម្បីប្រាសចាករាគៈនោះឯង អញគប្បីស្វែងរកលោកុត្តរធម៌ដោយបញ្ញានេះ ។ លំដាប់នោះ ទើបទ្រង់ប្រទានរាជសម្បត្តិដល់ព្រះបាទក្រុងពារាណសី ទ្រង់បញ្ជូនព្រះរាជបុត្ត និងព្រះមហេសី ត្រឡប់មកកាន់ជនបទស្រេចបាច់ហើយ ទ្រង់សមាទានបព្វជ្ជា ប្រារព្ធវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ កាលទ្រង់សម្តែងវីរិយសម្បត្តិរបស់ព្រះអង្គ ទើបត្រាស់ឧទានគាថានេះថា

បុគ្គលមានសេចក្តីព្យាយាម ប្រារព្ធដើម្បីដល់នូវព្រះនិព្វាន មានចិត្តមិនរួញរា អ្នកប្រព្រឹត្តមិនខ្ជិលច្រអូស មានសេចក្តីប្រឹងប្រែង

ដ៏មាំ ប្រកបដោយកម្លាំងប្រាជ្ញាហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ក្នុងគាថានោះ ឈ្មោះថា **អារទ្ធវីរិយោ** ព្រោះអត្ថថា បុគ្គលនោះប្រារព្ធព្យាយាមហើយ ព្រះបច្ចេកពុទ្ធសម្ដែងនូវសេចក្ដីព្យាយាម មានវីរិយារម្ភៈជាដើមរបស់ខ្លួនដោយបទនេះ ។ និព្វាន ហៅថា **បរមត្ថ** ដើម្បីសម្រេចបរមត្ថប្រយោជន៍ ដោយការសម្រេចនិព្វាននោះ ព្រះបច្ចេកពុទ្ធសម្ដែងផលដែលគប្បីសម្រេចដោយវីរិយារម្ភៈដោយបទនេះ ។

ព្រះបច្ចេកពុទ្ធសម្ដែងភាពដែលចិត្តនិងចេតសិក ដែលវីរិយពលឧបការៈហើយ ជាធម្មជាតមិនរួញរា ដោយបទថា **អលីនចិត្តោ** នេះ សម្ដែងការមិនរួញរានៃកាយ ក្នុងការឈរ ការអង្គុយ និងចង្ក្រមជាដើម ដោយបទថា **អកុសីតវុត្តិ** នេះ សម្ដែងសេចក្ដីព្យាយាមដែលតាំងមាំ ដែលប្រព្រឹត្តទៅហើយយ៉ាងនេះថា **កាមំ តចោ ច ន្ហារុ ច** ស្បែក សរសៃ... សូមឲ្យសល់នៅចុះ ដោយបទថា **ទឡ្ហនិក្កមោ** នេះ ។ បុគ្គលតាំងសេចក្ដីព្យាយាមនោះក្នុងកិច្ចទាំងឡាយ មានការសិក្សាតាមលំដាប់ជាដើម ហៅថា រមែងធ្វើឲ្យជាក់ច្បាស់នូវបរមត្ថសច្ចដោយកាយនោះឯង ។ម្យ៉ាងទៀត សម្ដែងសេចក្ដីព្យាយាម ដែលសម្បយុត្តដោយមគ្គ ដោយបទនេះ ។ ម្យ៉ាងទៀត សេចក្ដីព្យាយាមនោះ ឈ្មោះថា **និក្កម** ព្រោះជាសេចក្ដីព្យាយាមដែលបានហើយដោយការភាវនាដ៏មាំទាំ និងព្រោះសេចក្ដីព្យាយាមដែលចេញចាកធម៌ជា

បដិបក្ខដោយប្រការទាំងពួង ព្រោះហេតុនោះ បុគ្គលដែលដល់ព្រមដោយ សេចក្តីព្យាយាមនោះ ទើបឈ្មោះថា **ឧឡ្ឌនិក្កម** ព្រោះអត្ថថា បុគ្គលនោះ មានការព្យាយាមមាំទាំ ។

បទថា **ថាមពលូបបន្នោ** សេចក្តីថា ដល់ព្រមដោយកម្លាំងកាយ និង កម្លាំងញាណ ក្នុងខណៈនៃមគ្គ ។ ម្យ៉ាងទៀត បុគ្គលណាដល់ព្រមហើយ ដោយកម្លាំងដែលជាថាមៈ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា ដល់ព្រម ហើយដោយថាមពល អធិប្បាយថា ដល់ព្រមហើយដោយកម្លាំងញាណ ។ ព្រះបច្ចេកពុទ្ធ កាលសម្តែងនូវការប្រកបវិបស្សនាញាណ ទើបញ៉ាំងភាពនៃ សេចក្តីព្យាយាមនោះជាប្រធាន ឲ្យសម្រេចដោយឧបាយ ដោយបទនេះ ។ ម្យ៉ាងទៀត គប្បីប្រកបបទទាំង ៣ ដោយអំណាចនៃសេចក្តីព្យាយាមជាខាង ដើម កណ្តាល និងដែលឧក្រិដ្ឋ ។ បទដ៏សេស មានន័យដូចពោលហើយ នោះឯង ។

**អារទ្ធវិរិយគាថា ចប់**

# គាថាទី ៣៥

គាថាថា **បដិសល្លានំ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

គាថានេះ មានអត្ថុប្បត្តិហេតុដូចគ្នានឹងអាវរណគាថានោះឯង ទើបមិនមានការប្លែកគ្នាណាមួយឡើយ តែគប្បីជ្រាបវិនិច្ឆ័យក្នុងអត្ថវណ្ណនា ។

បទថា **បដិសល្លានំ** បានដល់ ការវិលត្រឡប់ចាកសត្វ សង្ខារនោះៗ ហើយពួនសម្ងំ អធិប្បាយថា ការសេពនូវភាពមានខ្លួនតែម្នាក់ឯង ភាពជាអ្នកមានខ្លួនតែម្នាក់ឯង កាយវិវេក ។

ចិត្តវិវេក ហៅថា **ឈាន** ព្រោះដុតនូវធម៌ដែលជាសត្រូវ និងព្រោះចូលទៅសម្ញឹងអារម្មណ៍ និងលក្ខណៈ ក្នុងបទនោះ សមាបត្តិ ៨ ហៅថា **ឈាន** ព្រោះដុតនូវធម៌ដែលជាសត្រូវ មាននីវរណៈជាដើម និងព្រោះចូលទៅសម្ញឹងអារម្មណ៍ ។ ក្នុងគាថានេះ វិបស្សនាមគ្គ និងផល ហៅថា **ឈាន** ព្រោះដុតនូវធម៌ដែលជាសត្រូវ មានសត្តសញ្ញាជាដើម និងព្រោះចូលទៅសម្ញឹងលក្ខណៈនោះៗ ឯង តែក្នុងទីនេះ លោកបំណងយកអារម្មណូបនិជ្ឈានប៉ុណ្ណោះ មិនលះ គឺមិនលះបង់ មិនលែងបោលនូវការពួនសម្ងំក្នុងឈាននោះ ដោយប្រការដូច្នេះ ។

បទថា **ធម្មេសុ** សេចក្ដីថា ក្នុងធម៌មានបញ្ចក្ខន្ធជាដើម ដែលចូលដល់វិបស្សនា ។ បទថា **និច្ចំ** បានដល់ ជានិច្ច រឿយៗ ។

បទថា **អនុធម្មចារី** សេចក្ដីថា ប្រព្រឹត្តវិបស្សនាដែលទៅតាម ព្រោះប្រារព្ធធម៌ទាំងនោះប្រព្រឹត្តទៅ ។ ម្យ៉ាងទៀត លោកុត្តរធម៌ ៩ ឈ្មោះថា **ធម៌**

ធម៌ដែលអនុលោម បានដល់ ធម៌ទាំងនោះ ឈ្មោះថា អនុធម៌ ពាក្យថា **អនុធម្មំ** នោះ ជាឈ្មោះរបស់វិបស្សនា ។ ក្នុងគាថានោះ កាលគួរនឹងពោល **ធម្មានំ និច្ចំ អនុធម្មចារី** ព្រះបច្ចេកពុទ្ធក៏ពោលថា **ធម្មេសុ** ដោយការផ្លាស់វិភត្តិ ដើម្បីងាយស្រួលដល់ការចងគាថា ។

បទថា **អាទីនវំ សម្មសិតា ភវេសុ** សេចក្ដីថា គប្បីជ្រាបការប្រកបសេចក្ដីយ៉ាងនេះថា បុគ្គលពិចារណាឃើញទោស មានការមិនទៀងជាដើមក្នុងភពទាំង ៣ ដោយវិបស្សនា ពោល គឺភាពជាអ្នកប្រព្រឹត្តតាមធម៌នោះ សម្រេចហើយនូវកាយវិវេក និងចិត្តវិវេកនេះ ដោយបដិបទា ពោល គឺ វិបស្សនា ដែលដល់កំពូលយ៉ាងនេះ ព្រោះហេតុនោះ គប្បីពោលថា គប្បីត្រាច់ទៅតែម្នាក់ឯង ។

**បដិសល្លានគាថា ចប់**

## គាថាទី ៣៦

គាថាថា **តណ្ហក្ខយំ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះបាទពារាណសី ទ្រង់ធ្វើប្រទក្សិណព្រះនគរ ដោយរាជានុភាពដ៏ធំ សត្វទាំងឡាយមានហទយៈវិលទៅហើយ ព្រោះលម្អនៃព្រះវរកាយរបស់ព្រះរាជា ទើបទៅខាងមុខខ្លះ ខាងក្រោយខ្លះ ចំហៀងសងខាងខ្លះ ក៏គង់

ត្រឡប់មកសម្លឹងមើលព្រះរាជាអង្គនោះឯង ។ តាមប្រក្រតី សត្វលោកមិនឆ្អែតក្នុងការមើលព្រះសម្ពុទ្ធ និងការមើលព្រះចន្ទពេញវង់ សមុទ្រ និងព្រះរាជា ។

ក្នុងខណៈនោះ សូម្បីកិរិយារបស់កុដុម្ពិកៈម្នាក់ ឡើងកាន់ប្រាសាទជាន់លើ បើកបង្អួចសម្លឹងមើល ព្រះរាជាទ្រង់ឃើញនាងប៉ុណ្ណោះ ទ្រង់ក៏មានព្រះរាជហឫទ័យប្រតិព័ទ្ធ ទើបត្រាស់ប្រាប់អមាត្យថា នែសម្លាញ់ ចូរអ្នកដឹងថា ស្រីនេះ មានប្ដី ឬមិនទាន់មានប្ដី ។ អមាត្យនោះទៅហើយ ត្រឡប់មកទូលថា បពិត្រព្រះអង្គ នាងមានប្ដីហើយ ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះរាជតម្រិះថា ស្រីស្នំ ២ ម៉ឺននាក់ អភិរម្យអញតែម្នាក់ប៉ុណ្ណោះ ដូចពួកទេពអប្សរ ឥឡូវនេះ អញមិនត្រេកអរដោយស្រីទាំងនោះ កើតនូវតណ្ហាក្នុងស្ត្រីរបស់បុរសដទៃ តណ្ហានោះកើតឡើង ក៏នឹងប្រានអញទៅក្នុងអបាយប៉ុណ្ណោះ ដូច្នេះហើយ ទ្រង់ឃើញទោសរបស់តណ្ហាហើយ ទ្រង់ព្រះរាជតម្រិះថា ណ្ហើយចុះ អញនឹងសង្កត់តណ្ហានោះ ទ្រង់លះបង់រាជសម្បត្តិចេញបួស ចម្រើនវិបស្សនា ក៏ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ទើបឧទានគាថានេះថា

បុគ្គលកាលប្រាថ្នានូវការអស់តណ្ហា ជាអ្នកមិនប្រហែស មិនឆ្កួត
មិនគ ជាអ្នកមានការចេះដឹង មានស្មារតី មានធម៌ពិចារណា
ហើយ ជាបុគ្គលទៀង មានសេចក្ដីព្យាយាម គប្បីត្រាច់ទៅតែ

ម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **តណ្ហក្ខយំ** បានដល់ ព្រះនិព្វាន ឬការមិនប្រព្រឹត្តទៅនៃតណ្ហាដែលមានទោស ដែលខ្លួនឃើញហើយយ៉ាងនោះឯង ។ បទថា **អប្បមត្តោ** បានដល់ ដែលមានប្រក្រតីធ្វើជាប់តគ្នាមិនដាច់ ។

បទថា **អនេលមូគោ** បានដល់ មិនជាបុគ្គលគ្លត ។ ម្យ៉ាងទៀត បុគ្គលមិនគ្លត និងបុគ្គលមិនគ ជាបណ្ឌិត អធិប្បាយថា ជាអ្នកឈ្លាសវៃ ។

សុតៈ ដែលឲ្យដល់ហិតសុខ របស់បុគ្គលនោះមាន ព្រោះហេតុនោះបុគ្គលនោះឈ្មោះថា **សុតវា** អធិប្បាយថា ជាអ្នកដល់ព្រមដោយអាគម ។ បទថា **សតីមា** បានដល់ ដែលរឭកដល់កិច្ចទាំងឡាយដែលធ្វើយូរជាដើមបាន ។ បទថា **សង្ខាតធម្មោ** បានដល់ មានធម៌ដែលកំណត់ដឹងហើយដោយការពិចារណាធម៌ ។ បទថា **និយតោ** បានដល់ ដល់នូវការទៀងដោយអរិយមគ្គ ។ បទថា **បធានវា** បានដល់ ដល់ព្រមហើយដោយវិរិយៈ គឺសម្មប្បធាន ។

បាលីនោះ គប្បីប្រកបផ្លាស់ប្តូរលំដាប់ថា បុគ្គលដែលប្រកបព្រមហើយដោយធម៌ទាំងឡាយ មានសេចក្តីមិនប្រមាទជាដើមនោះ មានព្យាយាមដោយព្យាយាម ដែលឲ្យដល់នូវការទៀង ជាបុគ្គលទៀង ដែលដល់នូវការទៀងដោយសេចក្តីព្យាយាមនោះ បន្ទាប់អំពីនោះ មានធម៌ដែលកំណត់ដឹងហើយដោយការសម្រេចអរហត្ត ដោយប្រការដូច្នេះ ។ ព្រះអរហន្ត បានឈ្មោះថា

ជាអ្នកមានធម៌ដែលកំណត់ដឹងហើយ ព្រោះមិនមានធម៌ដែលគប្បីកំណត់ដឹងទៀត ដូចលោកពោលថា ពួកអសេក្ខបុគ្គល អ្នកមានធម៌ពិចារណាហើយ និងពួកសេក្ខបុគ្គលជាច្រើនណាក្នុងសាសនានេះ ដូច្នេះ ។ បទដ៏សេសមានន័យដូចពោលហើយនោះឯង ។

តណ្ហក្ខយគាថា ចប់

## គាថាទី ៣៧

គាថាថា **សីហោវ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះបាទក្រុងពារាណសីមានព្រះរាជឧទ្យាននៅមិនឆ្ងាយ ទ្រង់តើនឡើងអំពីព្រលឹម យាងទៅកាន់ព្រះរាជឧទ្យាន យាងចុះអំពីយានក្នុងរវាងផ្លូវដោយព្រះរាជតម្រិះថា អញទៅកាន់កំពង់ទឹកហើយនឹងលុបមុខ ។ ក្នុងបទេសនោះ រាជសីហ៍ញីកើតកូនហើយទៅរកស៊ី រាជបុរសឃើញកូនរាជសីហ៍នោះហើយទូលថា បពិត្រព្រះអង្គ នេះកូនរាជសីហ៍ ព្រះរាជាទ្រង់ព្រះតម្រិះថា បានឮថា រាជសីហ៍មិនចេះខ្លាចអ្នកណា ទើបឲ្យវាយវត្ថុ មានស្គរជាដើម ដើម្បីសាកល្បងមើលកូនរាជសីហ៍នោះ។ កូនរាជសីហ៍ស្តាប់សំឡេងនោះ ក៏ដេកធ្វើព្រងើយ ព្រះរាជាត្រាស់ឲ្យវាយអស់វារៈ ៣ ដង ក្នុងលើកទី ៣ កូនរាជសីហ៍ក៏អើតក្បាលឡើងសម្លឹងមើលបរិស័ទទាំងអស់ ហើយក៏ដេកវិញ ។

ខណៈនោះ ព្រះរាជាត្រាស់ថា មេរបស់រាជសីហ៍នោះ មិនទាន់ត្រឡប់មកដរាបណា ពួកយើងនឹងទៅដរាបនោះ ។ កាលទ្រង់យាងទៅ ទ្រង់ព្រះរាជតម្រិះថា កូនរាជសីហ៍ សូម្បីកើតក្នុងថ្ងៃនោះ ក៏មិនតក់ស្លុត មិនខ្លាច កាលណាហ្ន៎ អញគប្បីកាត់នូវការខ្លាច ព្រោះតណ្ហា និងទិដ្ឋិ មិនគប្បីតក់ស្លុត មិនគប្បីខ្លាច ទ្រង់តោងយកអារម្មណ៍នោះយាងទៅ ទ្រង់ឃើញខ្យល់មិនជាប់ត្រង់សំណាញ់ទាំងឡាយ ដែលពួកអ្នកប្រមង់ចាប់ត្រីហើយ លាតហាលត្រង់មែកឈើទាំងឡាយ ទ្រង់កាន់យកនិមិត្តនោះទៀតថា កាលណាហ្ន៎ អញគប្បីទម្លាយសំណាញ់ គឺតណ្ហា និងទិដ្ឋិ និងសំណាញ់ គឺមោហៈហើយទៅ មិនជាប់ជំពាក់ដូច្នោះ ។

បន្ទាប់មក ព្រះរាជាយាងចូលទៅកាន់ព្រះរាជឧទ្យាន ប្រថាប់គង់ត្រង់ប្រាំងស្រះបោក្ខរណី ដែលមានផ្កាំងថ្ម ទ្រង់ឃើញឈូកទាំងឡាយត្រូវខ្យល់ហើយវេរង់ទន់ទៅក្នុងទឹក កាលប្រាសចាកខ្យល់ក៏ឈរដូចដើមវិញ មិនទទឹកដោយទឹក ទ្រង់កាន់យកនិមិត្តនោះថា កាលណាហ្ន៎ អញកើតហើយក្នុងលោក មិនគប្បីជាប់ក្នុងលោក តាំងនៅដូចឈូកទាំងនេះ កើតក្នុងទឹកមិនប្រឡាក់ទឹក តាំងនៅ ដូច្នោះ ។

ព្រះរាជាទ្រង់ព្រះរាជតម្រិះរឿយៗ ថា អញមិនគប្បីតក់ស្លុត មិនគប្បីជាប់ មិនគប្បីទទឹក ដូចរាជសីហ៍ ខ្យល់ និងបទុម ដូច្នោះ ហើយទ្រង់លះរាជសម្បត្តិ ចេញបួស ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោ-

ធិញ្ញាណ ទើបត្រាស់ឧទានគាថានេះថា

បុគ្គលមិនតក់ស្លុត ( ក្នុងលក្ខណៈមានមិនទៀងជាដើម ) ដូចសីហៈ មិនតក់ស្លុតនឹងសំឡេងទាំងឡាយ មិនបានជាប់ជំពាក់ ( ក្នុងធម៌ទាំងឡាយ មានខន្ធជាដើម ) ដូចខ្យល់មិនជាប់ និងសំណាញ់មិនជាប់ ( ដោយតណ្ហា និងលោភៈ ) ដូចឈូកមិនទទឹកដោយទឹក គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សីហោ** បានដល់ សីហៈ ៤ ប្រភេទ គឺ តិណសីហៈ នរសីហៈ ( បណ្ឌុសីហៈ ) កាឡសីហៈ កេសរសីហៈ ។ កេសរសីហៈ លោកពោលថា ប្រសើរជាងសីហៈ ៣ ប្រភេទនោះ កេសរសីហៈនោះឯង លោកបំណងយកក្នុងគាថានេះ ។

បទថា **វាតោ** បានដល់ ខ្យល់ច្រើនប្រភេទ ដោយអំណាចនៃខ្យល់ដែលបក់មកអំពីទិសខាងកើតជាដើម ។ បទថា **បទុមំ** បានដល់ បទុមច្រើនប្រភេទដោយអំណាចនៃបទុមក្រហម និងបទុមសជាដើម ។ ក្នុងខ្យល់និងបទុមទាំងនោះ ខ្យល់ឯណាមួយ បទុមឯណាមួយ ក៏គួរទាំងអស់ ។

ក្នុងគាថានោះ ព្រោះការតក់ស្លុតរមែងមាន ព្រោះការស្រឡាញ់ខ្លួន ឯការស្រឡាញ់ខ្លួន គឺការជាប់ជំពាក់ដោយអំណាចតណ្ហា សូម្បីការជាប់ជំពាក់ដោយអំណាចនៃតណ្ហានោះរមែងមាន ព្រោះសេចក្តីលោភដែលសម្បយុត្តដោយទិដ្ឋិ ឬប្រាសចាកទិដ្ឋិ ឯការលោភនោះ គឺតណ្ហានោះឯង ។ ក្នុងគាថា

នោះ ការជាប់ជំពាក់ រមែងមានដោយមោហៈ សម្រាប់បុគ្គលដែលវៀរចាក ការពិចារណា ឯមោហៈ គឺអវិជ្ជា ។ ក្នុងកាលនោះ ការលះតណ្ហា រមែងមានដោយសមថៈ ការលះអវិជ្ជា រមែងមានដោយវិបស្សនា ព្រោះហេតុនោះ បុគ្គលលះនូវការស្រឡាញ់ខ្លួនដោយសមថៈហើយ មិនតក់ស្លុតក្នុងធម៌ មានការមិនទៀងជាដើម ដូចរាជសីហ៍ មិនតក់ស្លុតក្នុងសំឡេងដូច្នោះ លះមោហៈ ដោយវិបស្សនាបញ្ញាហើយ មិនជាប់ជំពាក់ក្នុងធម៌ មានខន្ធ និងអាយតនៈ ជាដើម ដូចខ្យល់មិនជាប់ក្នុងសំណាញ់ ដូច្នោះ លះលោភៈ និងទិដ្ឋិ ដែលសម្បយុត្តដោយលោភៈនោះឯង ដោយសមថៈនោះឯង មិនជាប់ជំពាក់ ដោយសេចក្តីលោភ គឺការត្រេកអរក្នុងភពទាំងពួង ដូចផ្កាឈូកមិនជាប់ ដោយទឹក ដូច្នោះ ។

ក្នុងទីនេះ សីលជាបទដ្ឋានរបស់សមថៈ សមថៈ គឺសមាធិ វិបស្សនា-បញ្ញា ព្រោះហេតុនោះ កាលធម៌ទាំងពីរនោះសម្រេចយ៉ាងនេះហើយ ខន្ធ ទាំង ៣ ក៏ឈ្មោះថា សម្រេចហើយ ។ ក្នុងខន្ធ ៣ យ៉ាងនោះ បុគ្គលជា អ្នកក្លៀវក្លាដោយសីលក្ខន្ធ រមែងមិនតក់ស្លុត ព្រោះភាពដែលខ្លួនបំណង ដើម្បីក្រោធក្នុងអាឃាតវត្ថុទាំងឡាយ ដូចរាជសីហ៍ មិនតក់ស្លុតក្នុងសំឡេង ដូច្នោះ បុគ្គលមានសភាវៈចាក់ធ្លុះហើយដោយបញ្ញាខន្ធ រមែងមិនជាប់ជំពាក់ ក្នុងធម៌ មានខន្ធជាដើម ដូចខ្យល់មិនជាប់ក្នុងសំណាញ់ ដូច្នោះ បុគ្គលដែល មានរាគៈទៅប្រាសហើយដោយសមាធិក្ខន្ធ រមែងមិនជាប់ដោយរាគៈ ដូចឈូក

មិនជាប់ដោយទឹក ដូច្នោះ បុគ្គលមិនតក់ស្លុត មិនជាប់ មិនជំពាក់ដោយអំណាចនៃការលះអវិជ្ជា តណ្ហា និងអកុសលមូល ៣ តាមសេចក្តីពិតដោយសមថវិបស្សនា និងដោយសីលក្ខន្ធ សមាធិក្ខន្ធ និងបញ្ញាខន្ធ បណ្ឌិតគប្បីជ្រាបដោយប្រការដូច្នេះ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

**អសន្តសន្តគាថា ចប់**

## គាថាទី ៣៨

គាថាថា **សីហោ យថា** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះបាទពារាណសីមួយអង្គយាងទៅបង្ក្រាបជាយដែនដែលបះបោរ ទ្រង់លះបង់ផ្លូវ ក្នុងស្រុកធំ និងស្រុកតូច ទ្រង់ជ្រើសរើសផ្លូវដែលជាព្រៃ ព្រោះជាផ្លូវត្រង់ យាងទៅដោយសេនាធំ ។

សម័យនោះ រាជសីហ៍កំពុងដេកអាំងថ្ងៃត្រង់ជើងភ្នំមួយ រាជបុរសឃើញរាជសីហ៍នោះហើយ ទូលព្រះរាជាៗ ទ្រង់ព្រះរាជតម្រិះថា បានឮថា រាជ-សីហ៍ មិនតក់ស្លុតដោយសំឡេង ទើបត្រាស់ឲ្យធ្វើសំឡេងដោយសំឡេងស្គរស័ង្ខ និងស្គរតូចជាដើម រាជសីហ៍ដេកយ៉ាងនោះឯង ទ្រង់ឲ្យបន្លឺសំឡេងលើកទី ២ ក៏ដេកយ៉ាងនោះ ទ្រង់ឲ្យធ្វើសំឡេងលើកទី ៣ រាជសីហ៍ក៏គិតថា សត្រូវរបស់អញមាន ក៏ក្រោកឡើងឈរយ៉ាងសង្ហារដោយជើងទាំង ៤ បន្លឺ

សីហនាទ ពលនិកាយទាំងឡាយ មានហ្វូងដំរីជាដើម បានស្តាប់សំឡេងនោះ ក៏ចុះអំពីពាហនៈ មានដំរីជាដើមរត់ចូលកម្ពោតព្រៃ ពួកដំរី និងពួកសេះ ក៏រត់ទៅកាន់ទិសតូច ទិសធំ សូម្បីដំរីទីនាំងរបស់ព្រះរាជា ក៏នាំព្រះរាជាចូលក្នុងព្រៃគេចទៅ ទ្រង់មិនអាចឲ្យដំរីព្រះទីនាំងឈប់បាន ទ្រង់ក៏តោងមែកឈើសម្រួតចុះមកដី ហើយយាងទៅដោយផ្លូវចង្អៀត ដែលល្មមតែមនុស្សម្នាក់ដើរបាន ដល់លំនៅរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ទើបត្រាស់សួរព្រះបច្ចេកពុទ្ធទាំងឡាយក្នុងទីនោះថា បពិត្រលោកម្ចាស់ លោកម្ចាស់បានស្តាប់សំឡេងខ្លះទេ ព្រះបច្ចេកពុទ្ធពោលថា មហាបពិត្រ អាត្មាបានស្តាប់ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ តើសំឡេងអ្វី ព្រះបច្ចេកពុទ្ធពោលថា ដំបូងសំឡេងស្គរ សំឡេងស័ង្ខជាដើម ខាងក្រោយជាសំឡេងរាជសីហ៍ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ លោកម្ចាស់ខ្លាចដែរឬទេ ព្រះបច្ចេក-ពុទ្ធពោលថា មហាបពិត្រ អាត្មាមិនខ្លាចសំឡេងណាមួយឡើយ ព្រះរាជាត្រាស់ថា តើលោកម្ចាស់អាចធ្វើឲ្យខ្ញុំ កុំឲ្យខ្លាចយ៉ាងនេះបានដែរឬទេ ព្រះបច្ចេកពុទ្ធពោលថា មហាបពិត្រ អាច បើទ្រង់ព្រះផ្នួស ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំនឹងបួស ។

បន្ទាប់អំពីនោះ ព្រះបច្ចេកពុទ្ធទាំងឡាយ ឲ្យព្រះរាជាអង្គនោះទ្រង់បួសហើយ ឲ្យសិក្សាអភិសមាចារិកវត្ត ដោយន័យដែលពោលហើយខាងដើមនោះឯង ។ ព្រះរាជាអង្គនោះ ក៏ទ្រង់ចម្រើនវិបស្សនាដោយន័យតាមដែលពោល

ហើយក្នុងកាលមុននោះឯង ក៏ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ទើបបានត្រាស់ឧទានគាថានេះថា

បុគ្គលគប្បីអាស្រ័យនូវសេនាសនៈដ៏ស្ងាត់ ដូចជាសីហៈជាស្តេចសត្វ មានកម្លាំងចង្កូម ត្រាច់គ្របសង្កត់ កំហែងនូវពួកម្រឹគ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ក្នុងគាថានោះ រាជសីហ៍ជាសត្វមានការអត់ធន់ មានការសម្លាប់សត្វ និងមានសម្ទុះរហ័ស កេសរសីហៈប៉ុណ្ណោះ លោកបំណងយកក្នុងគាថានេះ ។ កម្លាំងនៃចង្កូមរបស់រាជសីហ៍នោះមាន ព្រោះហេតុនោះ ទើបរាជសីហ៍នោះឈ្មោះថា **ទាឋពលី** មានចង្កូមជាកម្លាំង ។

ពីរបទថា **បសយ្ហ អភិភុយ្យ** គប្បីប្រកបព្រមជាមួយសព្ទថា **ចារី** ជា **បសយ្ហចារី អភិភុយ្យចារី** ។ ក្នុងសព្ទពីរនោះ រាជសីហ៍ឈ្មោះថា **បសយ្ហ-ចារី** ព្រោះត្រាច់គ្របសង្កត់ បៀតបៀន ក្តោបក្តាប់ ឈ្មោះថា **អភិភុយ្យចារី** ព្រោះគ្របសង្កត់ឲ្យតក់ស្លុត ធ្វើឲ្យនៅក្នុងអំណាច រាជសីហ៍នោះ ត្រាច់សង្កត់សង្កិនដោយកម្លាំងកាយ ត្រាច់គ្របសង្កត់ដោយតេជៈ ។

ក្នុង ២ សព្ទនោះ បើបុគ្គលណាពោលថា រាជសីហ៍ត្រាច់គ្របសង្កត់នូវអ្វីដូច្នេះសោត បន្ទាប់អំពីនោះ គប្បីធ្វើសាមីវចនៈ ( ឆដ្ឋីវិភត្តិ ) ថា **មិគានំ** ឲ្យជាឧបយោគវចនៈ ( ទុតិយាវចនៈ ) ផ្លាស់ជា **មិគេ បសយ្ហ អភិភុយ្យចារី** ប្រែថា ត្រាច់សង្កត់សង្កិន គ្របសង្កត់នូវម្រឹគទាំងឡាយ ។

បទថា **បន្តានិ** បានដល់ ធ្លាយ ។ បទថា **សេនាសនានិ** បានដល់ទីនៅអាស្រ័យ ។ បទដ៏សេស គប្បីដឹងដោយន័យតាមដែលពោលហើយខាងដើមនោះឯង ព្រោះហេតុនោះ ទើបមិនបានពោល ឲ្យពិស្តារ ។

ទាបពលិគាថា ចប់

## គាថាទី ៣៩

គាថាថា **មេត្តំ ឧបេក្ខំ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះរាជាមួយអង្គ ទ្រង់បានមេត្តាឈាន ទ្រង់ព្រះរាជតម្រិះថា រាជសម្បត្តិធ្វើអន្តរាយចំពោះសុខក្នុងឈាន ទើបទ្រង់លះរាជសម្បត្តិ ហើយទ្រង់រក្សាឈាន ទ្រង់បួសហើយ ទ្រង់ចម្រើនវិបស្សនា ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ បានត្រាស់ឧទានគាថានេះថា

បុគ្គលកាលចម្រើនមេត្តាផង ឧបេក្ខាផង ករុណាផង មុទិតាផង
ដែលជាហេតុរួចស្រឡះ ( ចាកកិលេស ) ក្នុងកាលគួរ មិន
ថ្នាំងថ្នាក់ចំពោះសត្វលោកទាំងអស់ហើយ គប្បីត្រាច់ទៅតែម្នាក់
ឯង ដូចកុយរមាស ដូច្នេះ ។

ក្នុងគាថានោះ ភាពជាអ្នកប្រាថ្នានាំចូលមកនូវហិតសុខ ដោយន័យថា បូរសត្វទាំងឡាយទាំងពួង មានសេចក្តីសុខចុះ ដូច្នេះជាដើម ឈ្មោះថា **មេត្តា**។

ភាពជាបុគ្គលប្រាថ្នា ដើម្បីនាំចេញទៅនូវអហិតទុក្ខ ដោយន័យថា ឱហ្ន៎ ចូរសត្វផុតចាកទុក្ខនេះ ដូច្នេះជាដើម ឈ្មោះថា ករុណា ភាពជាបុគ្គលប្រាថ្នាដើម្បីមិនឲ្យផុតចាកហិតសុខ ដោយន័យថា សត្វដ៏ចម្រើនទាំងឡាយត្រេកអរហ្ន៎ ត្រេកអរល្អពិត ដូច្នេះជាដើម ឈ្មោះថា **មុទិតា** ។ ភាពជាអ្នកព្រងើយកន្តើយក្នុងសុខ និងទុក្ខទាំងឡាយថា សត្វទាំងឡាយ នឹងប្រាកដដោយកម្មរបស់ខ្លួនដូច្នេះ ឈ្មោះថា **ឧបេក្ខា** ។ តែលោកពោលមេត្តា ហើយពោលឧបេក្ខា ហើយពោលមុទិតាក្នុងកាលជាខាងក្រោយ ដោយប្តូរលំដាប់ទាំងនេះ ដើម្បីងាយដល់ការចងគាថា ។

បទថា **វិមុត្តឹ** សេចក្តីថា ធម៌ទាំង ៤ នោះ ឈ្មោះថា **វិមុត្តិ** ព្រោះជាធម៌ផុតហើយចាកធម៌ដែលជាសត្រូវទាំងឡាយរបស់ខ្លួន ព្រោះហេតុនោះ ទើបព្រះបច្ចេកពុទ្ធពោលថា

> បុគ្គលកាលចម្រើនមេត្តាផង ឧបេក្ខាផង ករុណាផង មុទិតាផង
> ដែលជាហេតុរួចស្រឡះ ( ចាកកិលេស ) ក្នុងកាលគួរ ។

ក្នុងគាថានោះ បទថា **អាសេវមានោ** សេចក្តីថា អប់រំនូវធម៌ទាំង ៣ ដោយអំណាចតតិយជ្ឈាន និងចតុត្ថជ្ឈាន អប់រំនូវឧបេក្ខាដោយអំណាចនៃចតុត្ថជ្ឈាន ។

បទថា **កាលេ** សេចក្តីថា បុគ្គលចម្រើនមេត្តាហើយ ចេញអំពីមេត្តានោះ ហើយសេពករុណា ចេញអំពីករុណានោះហើយសេពមុទិតា ចេញអំពី

មុទិតានោះ ឬចេញចាកឈានដែលមិនមានបីតិក្រៅអំពីនេះ ហើយ សេពឧបេក្ខា ហៅថា សេពក្នុងកាល ឬហៅថា សេពក្នុងកាលដែលជាផាសុក ដើម្បីនឹងសេព ។ បទថា **សព្វេន លោកេន អវិរុជ្ឈមានោ** សេចក្តីថា មិនត្រេកអរ ដោយលោកទាំងពួង ក្នុងទិសទាំង ១០ ។ ពិត ហើយ ព្រោះភាពដែលធម៌ទាំងឡាយ មានមេត្តាជាដើម ដែលខ្លួនចម្រើន ហើយ សត្វទាំងឡាយក៏ជាបុគ្គលមិនគួរស្អប់ បដិឃៈ ដែលបង្កនូវសេចក្តីក្រោធក្នុងសត្វទាំងឡាយ រមែងស្ងប់រម្ងាប់ ព្រោះហេតុនោះ ទើបព្រះបច្ចេក-ពុទ្ធពោលថា មិនថ្នាំងថ្នាក់ចំពោះសត្វលោក ដូច្នេះ ។ សេចក្តីសង្ខេបក្នុងគាថានេះ មានប្រមាណប៉ុណ្ណោះ ចំណែកមេត្តាទិកថា ខ្ញុំបានពោលហើយក្នុងអដ្ឋ-កថា ធម្មសង្គហៈ ឈ្មោះអដ្ឋសាលិនី ។ បទដ៏សេស ដូចគ្នានឹងន័យមុននោះឯង ។

អប្បមញ្ញាគាថា ចប់

# គាថាទី ៤០

គាថាថា **រាគញ្ច ទោសញ្ច** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះបច្ចេកពុទ្ធ ឈ្មោះមាតង្គៈ ជាអង្គចុងក្រោយនៃព្រះបច្ចេកពុទ្ធទាំងឡាយ នៅអាស្រ័យនគររាជគ្រឹះ ក្នុងកាលនោះ កាលព្រះ

ពោធិសត្វនៃយើងកើតហើយ ទេវតាទាំងឡាយនាំគ្នាមក ដើម្បីប្រយោជន៍ក្នុងការបូជាព្រះពោធិសត្វ ឃើញមាតង្គបច្ចេកពុទ្ធនោះហើយ ពោលថា លោកនិទ្ទិក្ខ លោកនិទ្ទិក្ខ ព្រះពុទ្ធកើតហើយក្នុងលោក ។

ព្រះបច្ចេកពុទ្ធនោះចេញចាកនិរោធ បានស្តាប់សំឡេងនោះហើយ ឃើញនូវការអស់ទៅនៃជីវិតរបស់ខ្លួននោះឯង ទើបហោះទៅកាន់ភ្នំឈ្មោះមហាបបាតៈក្នុងហិមវន្តប្បទេស ដែលជាទីបរិនិព្វានរបស់ព្រះបច្ចេកពុទ្ធទាំងឡាយនោះ ដាក់គ្រោងឆ្អឹងរបស់ព្រះបច្ចេកពុទ្ធ ដែលបរិនិព្វានហើយក្នុងកាលមុន ក្នុងជ្រោះអន្លុយត្រង់ផ្ទាំងថ្ម បានពោលគាថានេះថា

*បុគ្គលលះបង់រាគៈផង ទោសៈផង មោហៈផង ទម្លាយនូវសំយោជនៈទាំងឡាយ មិនតក់ស្លុតក្នុងការក្ស័យជីវិត គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។*

ក្នុងគាថានោះ រាគៈ ទោសៈ និងមោហៈ ខ្ញុំបានពោលហើយក្នុងខគ្គសូត្រ ។ បទថា **សំយោជនានិ** បានដល់ សំយោជនៈ ១០ ។ ទម្លាយនូវសំយោជនៈទាំងនោះហើយ ដោយមគ្គនោះៗ ។

បទថា **អសន្តសំ ជីវិតសង្ខយម្ហិ** សេចក្តីថា ចុតិ គឺការបែកធ្លាយនៃចិត្ត ហៅថា ការអស់ជីវិត ។ ឈ្មោះថា **អសន្តសំ** ព្រោះលះនូវសេចក្តីប្រាថ្នាក្នុងការអស់ជីវិតនោះហើយ ។

មាតង្គបច្ចេកពុទ្ធអង្គនោះ សម្តែងឧបាទិសេសនិព្វានធាតុដល់ខ្លួនហើយ

បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងកាលចប់គាថា ដោយប្រការដូច្នេះ ។

**ជីវិតសន្ទយគាថា ចប់**

# គាថាទី ៤១

គាថាថា **ភជន្តិ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះរាជាមួយអង្គក្នុងនគរពារាណសី ទ្រង់គ្រប់គ្រងរាជសម្បត្តិដ៏ទូលំទូលាយ មានប្រការដូចពោលហើយក្នុងគាថាដើមនោះឯង ។ ព្រះរាជាទ្រង់ប្រឈួនធ្ងន់ ទុក្ខវេទនាប្រព្រឹត្តទៅ ស្រី ២ ម៉ឺននាក់ នាំគ្នាគក់ប្របាច់ព្រះហស្ត និងព្រះបាទជាដើម ។ អមាត្យទាំងឡាយគិតថា ឥឡូវនេះ ព្រះរាជាអង្គនេះ នឹងមិនរួចជីវិត ណ្ហើយចុះ យើងនឹងស្វែងរកទីពឹងរបស់ខ្លួន ដូច្នេះហើយ ទៅកាន់រាជសម្នាក់របស់ស្តេចដទៃៗ ទូលសូមបម្រើ ។ អមាត្យទាំងនោះ បម្រើក្នុងរាជសម្នាក់នោះៗ ឯង មិនបានអ្វីឡើយ ។

ចំណែកព្រះរាជា ទ្រង់សះស្បើយអំពីប្រឈួនហើយ ត្រាស់សួរថា អមាត្យឈ្មោះនេះ និងឈ្មោះនេះទៅណា បន្ទាប់អំពីនោះ ទ្រង់បានស្តាប់ព្រឹត្តិការណ៍នោះហើយ ទ្រង់គ្រវីសីសៈហើយនៅស្ងៀម ។ អមាត្យទាំងនោះបានឮថា ព្រះរាជាទ្រង់ជាសះស្បើយអំពីប្រឈួនហើយ មិនបានអ្វីឡើយ

ក្នុងសម្នាក់ព្រះរាជាអង្គដទៃនោះ ជួបនូវការវិនាសយ៉ាងក្រៃលែង ទើបត្រឡប់មកវិញ ថ្វាយបង្គំព្រះរាជាហើយ ឈរក្នុងទីបំផុតនាចំណែកម្ខាង ។ អមាត្យទាំងនោះ ត្រូវព្រះរាជាត្រាស់សួរថា នែបា ពួកបាទើបមកអំពីណា ក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេព ពួកទូលបង្គំឃើញទ្រង់ទុព្វលភាពហើយ ទើបទៅកាន់ជនបទឈ្មោះនោះ ព្រោះព្រួយបារម្ភក្នុងការចិញ្ចឹមជីវិត ព្រះរាជាទ្រង់ងក់ព្រះសីសៈហើយ ទ្រង់ព្រះរាជតម្រិះថា ណ្ហើយចុះ យើងគប្បីសាកល្បងអមាត្យទាំងនេះថា តើធ្វើយ៉ាងនេះទៀតដែរឬទេ ។

ព្រះរាជាអង្គនោះ ទ្រង់ក្លែងធ្វើជាជួបនូវទុក្ខវេទនាដ៏ធ្ងន់ ដូចត្រូវប្រឈួនក្នុងកាលមុនកម្រើក ទ្រង់ធ្វើនូវកង្វល់ក្នុងការប្រឈួន ស្រីទាំងឡាយ ក៏ចោមរោមធ្វើកិច្ចគ្រប់យ៉ាងដូចមុននោះឯង អមាត្យទាំងនោះ ក៏នាំជនទាំងនោះ ច្រើនជាងមុន ចៀសចេញទៅយ៉ាងនោះទៀត ទ្រង់ធ្វើដូចគ្នានឹងពោលហើយទាំងអស់ អស់វារៈ ៣ ដងយ៉ាងនេះ អមាត្យទាំងនោះ ក៏ចៀសចេញទៅដូចមុន ។

បន្ទាប់អំពីនោះ ព្រះរាជាទ្រង់ឃើញអមាត្យទាំងនោះ មកហើយក្នុងគ្រាទី ៤ ទ្រង់នឿយណាយថា ឱអមាត្យទាំងនេះ បោះបង់អញដែលជាអ្នកមានជំងឺមិនអាឡោះអាល័យចៀសចេញទៅ ធ្វើនូវអំពើអាក្រក់ហ្ន៎ ដូច្នេះហើយ ទ្រង់លះរាជសម្បត្តិចេញបួស ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ ត្រាស់ឧទានគាថានេះថា

ពួកមនុស្សមានប្រយោជន៍ជាហេតុ ទើបគប់រកផង បម្រើផង ពួកមិត្តសម្លាញ់ទាំងឡាយដែលឥតហេតុ រកបានដោយក្រ ក្នុងថ្ងៃនេះ ពួកមនុស្ស ( ច្រើនតែ ) មានប្រាជ្ញាចំពោះប្រយោជន៍របស់ខ្លួន ជាអ្នកប្រកបដោយអំពើមិនស្អាត បុគ្គលគប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ភជន្តិ** សេចក្តីថា ចូលទៅអង្គុយជិតដោយរាងកាយ ។ បទថា **សេវន្តិ** សេចក្តីថា រមែងបម្រើដោយអញ្ជលិកម្មជាដើម និងដោយភាពជាអ្នកទទួលបម្រើ ។ ហេតុជាប្រយោជន៍របស់មនុស្សទាំងនោះ ព្រោះហេតុនោះ ទើបមនុស្សទាំងនោះ មានហេតុជាប្រយោជន៍ អធិប្បាយថា ហេតុដទៃក្នុងការគប់រក និងការសេពមិនមាន ។ ហេតុរបស់មនុស្សទាំងនោះយ៉ាងនេះ អធិប្បាយថា រមែងសេពព្រោះហេតុនៃខ្លួន ។

បទថា **និក្ការណា ទុល្លភា អជ្ជ មិត្តា** សេចក្តីថា មិត្តទាំងឡាយដែលមិនមានប្រយោជន៍ជាហេតុ ដោយហេតុនៃការបានប្រយោជន៍ យ៉ាងនេះថា អញនឹងបានប្រយោជន៍ខ្លះអំពីមិត្តនេះ ប្រកបដោយភាពជាមិត្តដ៏ប្រសើរ ដែលព្រះដ៏មានព្រះភាគត្រាស់ក្នុងសិង្គាលកសូត្រយ៉ាងនេះថា

មិត្តដែលមានឧបការៈ សម្លាញ់ដែលរួមសុខទុក្ខ មិត្តដែលប្រាប់ប្រយោជន៍ មិត្តដែលមានសេចក្តីឈឺឆ្អាល រកបានដោយកម្រក្នុងសព្វថ្ងៃនេះ ដូច្នេះ ។

បញ្ញារបស់មនុស្សទាំងនោះ តាំងនៅហើយក្នុងខ្លួន មនុស្សទាំងនោះ ឃើញដល់ខ្លួនប៉ុណ្ណោះ មិនឃើញដល់អ្នកដទៃ ព្រោះហេតុនោះ ទើបមនុស្សទាំងនោះ ឈ្មោះថា មានបញ្ញាប្រាថ្នានូវប្រយោជន៍ខ្លួន បានឮថា សព្ទថា **អត្តត្ថបញ្ញា** នេះ ជាបាលីបុរាណ មានអធិប្បាយថា បញ្ញារបស់មនុស្សទាំងនោះ រមែងសម្លឹងឃើញតែប្រយោជន៍ទាំងឡាយ ក្នុងបច្ចុប្បន្នប៉ុណ្ណោះ រមែងមិនសម្លឹងឃើញដល់ប្រយោជន៍ក្នុងអនាគត ។

បទថា **អសុចី** សេចក្តីថា ជាអ្នកប្រកបព្រមហើយដោយកាយកម្ម វចីកម្ម និងមនោកម្មដែលមិនស្អាត គឺមិនប្រសើរ ។ បទដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងកាលមុននោះឯង ។

ខគ្គវិសាណសូត្រនេះ មានគាថា ៤១ អ្នកសិក្សាគប្បីប្រកបតាមសមគួរ ក្នុងគាថាទាំងពួង ដោយន័យរបស់យោជនាដែលខ្ញុំពោលហើយ ក្នុងគាថាកន្លែងខ្លះនោះឯង ហើយគប្បីជ្រាបដោយអនុសន្ធិផង ដោយអត្ថផង ដូចពណ៌នាមកដូច្នេះ តែខ្ញុំមិនបានប្រកបក្នុងគាថាទាំងពួង នាំឲ្យពិស្តារពេកដូច្នេះ ។

**ការណោត្ថគាថា ចប់**

**វគ្គទី ៤ ប្រកបដោយគាថា ១១ ចប់**

**អដ្ឋកថា ខគ្គវិសាណសូត្រ ចប់**

# សុត្តន្តបិដក

## កសិភារទ្វាជសូត្រទី ៤

[ ៤ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងទក្ខិណាគិរិមហាវិហារ ( អាស្រ័យ ) ក្នុងស្រុកព្រាហ្មណ៍ឈ្មោះ ឯកនាឡា ក្នុងដែនមគធៈ ។ សម័យនោះឯង កសិភារទ្វាជព្រាហ្មណ៍ មាន នង្គ័លចំនួន ៥០០ ប្រកបក្នុងកាលសាបព្រោះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ទ្រង់យាងសំដៅទៅត្រង់ កន្លែងការងាររបស់កសិភារទ្វាជព្រាហ្មណ៍ ។ សម័យនោះឯង ការអង្គាស បាយរបស់កសិភារទ្វាជព្រាហ្មណ៍ ក៏កំពុងប្រព្រឹត្តទៅ ។ លំដាប់នោះ ព្រះ មានព្រះភាគ ទ្រង់ចៀងចូលទៅកាន់ទីអង្គាសបាយ ( របស់កសិភារទ្វាជ-ព្រាហ្មណ៍ ) លុះចូលទៅដល់ហើយ ក៏ទ្រង់ឈរនៅក្នុងទីដ៏សមគួរ ។ កសិភារទ្វាជព្រាហ្មណ៍ បានឃើញព្រះមានព្រះភាគកំពុងទ្រង់ឈរនៅដើម្បី បិណ្ឌបាតហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះសមណៈ ខ្ញុំព្រះអង្គភ្ជួររាស់ផង សាបព្រោះផង លុះភ្ជួររាស់សាបព្រោះហើយ ទើប បរិភោគ ។ បពិត្រព្រះសមណៈ ចំណែកព្រះអង្គចូរភ្ជួររាស់សាបព្រោះ លុះ ព្រះអង្គភ្ជួររាស់សាបព្រោះហើយ ចូរបរិភោគចុះ ។

ម្នាលព្រាហ្មណ៍ តថាគតក៏ភ្ជួររាស់ផង សាបព្រោះផង លុះតថាគត ភ្ជួររាស់សាបព្រោះហើយ ទើបបរិភោគដែរ ។ បពិត្រព្រះសមណៈ យើងខ្ញុំ មិនបានឃើញនឹមក្តី នង្គ័លក្តី ផាលក្តី ជន្លួញក្តី សត្វបម្រើក្តីរបស់ព្រះគោតម

ដ៏ចម្រើនសោះ ប៉ុន្តែ ហេតុអ្វី បានជាព្រះគោតមដ៏ចម្រើន និយាយយ៉ាងនេះថា ម្នាលព្រាហ្មណ៍ តថាគតភ្ជួររាស់ផង សាបព្រោះផង លុះភ្ជួររាស់សាបព្រោះហើយ ទើបបរិភោគដែរ ។

លំដាប់នោះ កសិភារទ្វាជព្រាហ្មណ៍បានពោលចំពោះព្រះមានព្រះភាគដោយគាថាដូច្នេះថា

[ ៥ ] ព្រះអង្គប្តេជ្ញាថា ជាអ្នកភ្ជួររាស់ ប៉ុន្តែយើងមិនឃើញនូវការភ្ជួររាស់របស់ព្រះអង្គសោះ យើងសួរនូវការភ្ជួររាស់ សូមព្រះអង្គប្រាប់ឲ្យយើងដឹង នូវការភ្ជួររាស់របស់ព្រះអង្គ ។

( ព្រះអង្គត្រាស់ថា ) តថាគតមានសទ្ធាជាពូជ មានតបធម៌ជាភ្លៀង មានប្រាជ្ញាជានឹមនិងនង្គ័ល តថាគតមានហិរិជាចន្ទោល មានចិត្តជាខ្សែ មានសតិជាផាលនិងជន្ទួញ ។ តថាគតគ្រប់គ្រងកាយ គ្រប់គ្រងវាចា សង្រួមនូវអាហារក្នុងផ្ទៃ ធ្វើនូវការជម្រះ ( នូវស្មៅគឺកិលេស ) ដោយសច្ចៈ តថាគតមានការស្ងប់ស្ងៀមជាគ្រឿងឈប់សម្រាក ។ វិរិយៈរបស់តថាគតជាគ្រឿងនាំទៅនូវធុរៈ ជាហេតុនាំឲ្យបាននូវព្រះនិព្វានដ៏ក្សេមចាកយោគៈ ទៅកាន់ទីដែលគេទៅមិនសោកសៅ ជាទីដែលគេមិនត្រឡប់វិញ ។ ការភ្ជួររាស់ដែលតថាគតភ្ជួររាស់ហើយយ៉ាងនេះ ជាគុណជាតមានផល មិនចេះស្លាប់ទេ បុគ្គលធ្វើនូវការភ្ជួររាស់បែបនុ៎ះ ទើប

រួចបាកទុក្ខទាំងពួង ។

[ ៦ ] គ្រានោះឯង កសិភារទ្វាជព្រាហ្មណ៍ ក៏ដោះបាយដាក់ក្នុងភាជន៍សំរិទ្ធដ៏ធំ បង្អោនចូលទៅថ្វាយព្រះមានព្រះភាគថា សូមព្រះគោតមដ៏ចម្រើនសោយបាយាសចុះ ព្រះគោតមដ៏ចម្រើនក៏ជាអ្នកភ្ជួររាស់ ព្រោះថាព្រះគោតមដ៏ចម្រើន រមែងភ្ជួររាស់ចំពោះការភ្ជួររាស់ដែលមានផលមិនចេះស្លាប់ ។

ភោជនដែលតថាគតពោលហើយ ដោយគាថាជាវត្ថុមិនគួរដល់

ការបរិភោគទេ ម្នាលព្រាហ្មណ៍ នេះមិនមែនជាទំនៀមរបស់ពួក

ជនអ្នកឃើញច្បាស់ ( នូវអាជីវបារិសុទ្ធិ ) ទេ ព្រះពុទ្ធ

ទាំងឡាយ តែងបន្ទោបង់នូវភោជនដែលពោលហើយដោយ

គាថា ម្នាលព្រាហ្មណ៍ កាលបើធម៌មាននៅ ការស្វែងរកនេះ

ជាការប្រព្រឹត្តិចិញ្ចឹមជីវិត ។ អ្នកចូរផ្គត់ផ្គង់ចំពោះលោក អ្នក

ស្វែងនូវគុណធំ បរិបូណ៌ដោយគុណសព្វគ្រប់ មានអាសវៈ

អស់ហើយ ស្ងប់រម្ងាប់ចាកកុក្កុច្ចៈ ដោយវត្ថុដទៃ និងបាយទឹក

ផងចុះ ព្រោះថា ការផ្គត់ផ្គង់នោះ ជាបុញ្ញក្ខេត្តរបស់បុគ្គលអ្នក

ប្រាថ្នាបុណ្យ ។

[ ៧ ] បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នេះ តើខ្ញុំព្រះអង្គឲ្យនូវបាយាសនេះដល់បុគ្គលណាវិញ ។ ម្នាលព្រាហ្មណ៍ តថាគតមិនឃើញបុគ្គលដែលបរិភោគបាយាស ដល់នូវការស្រុះរលាយល្អ ក្នុងលោក ព្រមទាំងទេវលោក

មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសទេ វៀរលែងតែតថាគត ឬសាវកនៃតថាគតចេញ ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរចាក់បាយាសនោះក្នុងទីដែលគ្មានវត្ថុស្រស់ ឬទម្លាក់ទៅក្នុងទឹកដែលគ្មានសត្វទៅចុះ ។ គ្រានោះឯងកសិភារទ្វាជព្រាហ្មណ៍ ក៏ទម្លាក់បាយាសនោះ ទៅក្នុងទឹកដែលគ្មានសត្វ ។ លំដាប់នោះ បាយាសនោះ ដែលព្រាហ្មណ៍ទម្លាក់ចុះទៅក្នុងទឹកហើយ ក៏ឮសំឡេងឆុរៗ ឮ សំឡេងឆាវៗ ហុយផ្សែងទ្រុប ហុយផ្សែងទ្រលោម ។ ដុំដែកដែលឆេះក្តៅ អស់មួយថ្ងៃ ដែលគេដាក់ចុះក្នុងទឹក រមែងឮសំឡេងឆុរៗ ឮសំឡេងឆាវៗ ហុយផ្សែងទ្រុប ហុយផ្សែងទ្រលោម យ៉ាងណាមិញ បាយាសដែលព្រាហ្មណ៍ទម្លាក់ទៅក្នុងទឹក ក៏ឮសំឡេងឆុរៗ ឮសំឡេងឆាវៗ ហុយផ្សែងទ្រុប ហុយផ្សែងទ្រលោម ក៏យ៉ាងនោះដែរ ។

[ ៨ ] គ្រានោះឯង កសិភារទ្វាជព្រាហ្មណ៍ មានចិត្តតក់ស្លុតព្រឺរោម ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបសិរ្សៈទៀបព្រះបាទព្រះមានព្រះភាគ សរសើរព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើន ទ្រង់ប្រកាសដោយអនេកបរិយាយយ៉ាងនេះ ( ភ្លឺច្បាស់ណាស់ ) ដូចមនុស្សផ្ងាររបស់ដែលផ្កាប់ ឬដូចគេបើកបង្ហាញរបស់ដែលបិទបាំង ឬក៏ដូចគេប្រាប់នូវផ្លូវ ដល់អ្នកវង្វេងទិស ពុំ

នោះសោត ដូចគេទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា មនុស្សអ្នកមានចក្ខុទាំងឡាយ ឃើញនូវរូបទាំងឡាយបាន ។ ខ្ញុំព្រះអង្គទុំះ សូមដល់ព្រះគោតមមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផងជាសរណៈ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់នូវសរណៈ ស្មើដោយជីវិតតាំងអំពីថ្ងៃនេះជាដើមទៅ ។ ខ្ញុំព្រះអង្គគប្បីបាននូវបព្វជ្ជា គប្បីបាននូវឧបសម្បទា ក្នុងសម្នាក់នៃព្រះគោតមដ៏ចម្រើន ។ កសិភារទ្វាជព្រាហ្មណ៍ ក៏បាននូវបព្វជ្ជា បាននូវឧបសម្បទា ក្នុងសម្នាក់នៃព្រះមានព្រះភាគ ។ លុះព្រះភារទ្វាជៈដ៏មានអាយុ បានឧបសម្បទាមិនយូរប៉ុន្មាន ក៏ចៀសចេញ ទៅតែម្នាក់ឯង មិនធ្វេសប្រហែស មានសេចក្តីព្យាយាម មានចិត្តស្ទុងទៅកាន់ព្រះនិព្វាន ពួកកុលបុត្តចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន ក៏ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវអនុត្តរធម៌នោះ ដ៏ជាទីបំផុតនៃព្រហ្មចរិយៈ ដោយប្រាជ្ញាដ៏ឧត្តម របស់ខ្លួនឯង ក្នុងអត្តភាពនេះ បានដឹងច្បាស់ថាជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះភារទ្វាជៈដ៏មានអាយុរាប់ថាជាព្រះអរហន្តមួយអង្គដែរ ។

**កសិភារទ្វាជសូត្រទី ៤ ចប់**

# អដ្ឋកថា

## កសិភារទ្វាជសូត្រ

[ ៤-៥ ] កសិភារទ្វាជសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ សូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះដ៏មានព្រះភាគគង់នៅក្នុងព្រាហ្មណគាម ឈ្មោះឯកនាឡា ក្នុងទក្ខិណាគិរីវិហារនៅដែនមគធៈ ទ្រង់ញុំាងបុរេភត្តកិច្ចស្រេចហើយ ក្នុងបណ្ដាពុទ្ធកិច្ច ២ យ៉ាងនេះ គឺបុរេភត្តកិច្ច ១ បច្ឆាភត្តកិច្ច ១ ក្នុងវេលាស្រេចបច្ឆាភត្តកិច្ច ទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ឃើញព្រាហ្មណ៍ឈ្មោះកសិភារទ្វាជៈ ដល់ព្រមដោយឧបនិស្ស័យនៃអរហត្ត ទ្រង់ជ្រាបថា កាលតថាគតទៅក្នុងព្រាហ្មណគាមនោះហើយ កថានឹងប្រព្រឹត្តទៅបន្ទាប់អំពីនោះ ក្នុងពេលចប់គាថា ព្រាហ្មណ៍នោះស្ដាប់ធម្មទេសនា បួសហើយនឹងសម្រេចអរហត្ត ដូច្នេះ ទើបយាងទៅក្នុងព្រាហ្មណគាមនោះ ទ្រង់ញុំាងកថាឲ្យតាំងឡើងហើយ ត្រាស់សូត្រនេះ ។

## បុរេភត្តកិច្ច

ក្នុងព្រះសូត្រនោះ គប្បីមានពាក្យសួរថា បុរេភត្តកិច្ចរបស់ព្រះពុទ្ធទាំងឡាយដូចម្ដេច បច្ឆាភត្តកិច្ចដូចម្ដេច ខ្ញុំនឹងឆ្លើយថា ព្រះដ៏មានព្រះភាគទ្រង់ធ្វើបរិកម្មព្រះសរីរកាយ មានការលុបព្រះភក្ត្រជាដើម ដើម្បីទ្រង់អនុគ្រោះអ្នកឧបដ្ឋាក និងដើម្បីឲ្យព្រះសរីរកាយមានផាសុក ទ្រង់សម្រាកនៅលើអាសនៈដែលស្ងាត់ រហូតដល់ពេលភិក្ខាចារ ទ្រង់ចងវត្ថពន្ធចង្កេះ ឃ្លុំចីវរ កាន់បាត្រ ជួនកាល

យាងទៅមួយអង្គឯង ជួនកាលមានភិក្ខុសង្ឃហែហមរោម យាងទៅកាន់គាម ឬ និគមដើម្បីបិណ្ឌបាត ជួនកាលយាងទៅតាមប្រក្រតី ជួនកាលយាងទៅដោយបាដិហារ្យ ប្រព្រឹត្តទៅសន្ទឹកសន្ទាប់ គឺខ្យល់ស្រទន់បក់ទៅខាងមុខព្រះលោកនាថ ដែលយាងទៅដើម្បីបិណ្ឌបាត ញ៉ាំងផ្ទៃដីឲ្យស្អាត មេឃបង្អុរនូវទឹក ឲ្យធូលីក្នុងផ្លូវស្ងប់ តាំងជាពិដានខាងលើ ខ្យល់ដទៃៗ បក់ផ្កាទាំងឡាយរោយចុះមកលើផ្លូវ ទីដែលទួលក៏ស្រុតចុះ ទីដែលទាបក៏ប៉ោងឡើង ក្នុងសម័យដែលទ្រង់ដាក់ព្រះបាទ ផែនដីក៏រាបស្មើ ឬផ្កាឈូកទាំងឡាយដែលមានសម្ផស្សល្អ បិទបាំងស្នាមព្រះបាទ លុះទ្រង់ដាក់ព្រះបាទខាងស្តាំចុះ ខាងក្នុងសសរខឿន ព្រះឆព្វណ្ណរង្សី ក៏ផ្សាយចេញអំពីព្រះវរកាយ ធ្វើប្រាសាទ និងផ្ទះកំពូលជាដើមឲ្យដូចជាទ្រនាស់មាស ផ្សាយទៅក្នុងទីផ្សេងៗ បណ្តាសេះ ដំរី បក្សីជាដើម តាំងនៅក្នុងទីរៀងៗ ខ្លួននោះឯង ក៏ស្រែកយំពីរោះល្វេងល្វើយ ដូចតូរ្យតន្ត្រី មានស្គរ និងពិណជាដើម ហើយបណ្តាគ្រឿងប្រដាប់កាយរបស់ពួកមនុស្ស ក៏ធ្វើនូវសំឡេងពីរោះដូចគ្នា ។

ដោយសញ្ញានោះ មនុស្សទាំងឡាយក៏ដឹងថា ថ្ងៃនេះព្រះដ៏មានព្រះភាគ យាងទៅបិណ្ឌបាតក្នុងស្រុកនេះ មនុស្សទាំងឡាយក៏ស្លៀកពាក់ស្អាតបាត កាន់នូវគ្រឿងក្រអូប និងផ្កាជាដើម ចេញអំពីផ្ទះដើរទៅតាមផ្លូវ បូជាព្រះដ៏មានព្រះភាគ ដោយគ្រឿងក្រអូប និងផ្កាជាដើមដោយគោរព ទូលថា បពិត្រព្រះអង្គ សូមទ្រង់ឲ្យភិក្ខុ ១០ រូប ដល់រូបខ្ញុំព្រះអង្គ ភិក្ខុ ២០ រូបដល់ខ្ញុំព្រះអង្គ

ភិក្ខុ ១០០ រូបដល់ខ្ញុំព្រះអង្គ ដូច្នេះហើយ ទទួលបាត្រព្រះដ៏មានព្រះភាគ ក្រាលអាសនៈ ទទួលដោយបិណ្ឌបាតដោយគោរព ។

ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ពិចារណាមើលសន្តាន របស់មនុស្សទាំងនោះហើយ ទ្រង់សម្ដែងព្រះធម៌ដោយប្រការ ដែលមនុស្ស ពួកខ្លះតាំងនៅក្នុងសរណគមន៍ ពួកខ្លះតាំងនៅក្នុងសីល ៥ ពួកខ្លះតាំងនៅក្នុង សោតាបត្តិផល សកទាគាមិផល និងអនាគាមិផលឯណានីមួយ ពួកខ្លះបួស ហើយតាំងនៅក្នុងអរហត្តផល ។ កាលទ្រង់អនុគ្រោះជននោះៗ យ៉ាងនេះ ហើយ ទ្រង់ក្រោកចាកអាសនៈ យាងទៅកាន់វិហារ ប្រថាប់គង់លើបវរ-ពុទ្ធាសនៈ ដែលគេក្រាលហើយ ក្នុងរោងមណ្ឌលនោះៗ រង់ចាំភិក្ខុទាំង-ឡាយ ដែលធ្វើភត្តកិច្ចស្រេច បន្ទាប់អំពីនោះ អ្នកឧបដ្ឋាកទូលការសម្រេច ភត្តកិច្ចរបស់ភិក្ខុទាំងឡាយ ឲ្យព្រះដ៏មានព្រះភាគទ្រង់ជ្រាប ។ លំដាប់នោះ ព្រះដ៏មានព្រះភាគក៏យាងចូលព្រះគន្ធកុដិ នេះជាបុរេភត្តកិច្ច ពាក្យណាដែល មិនទាន់បានពោលក្នុងសូត្រនេះ ពាក្យនោះ បណ្ឌិតគប្បីជ្រាបដោយន័យ ដែលពោលហើយ ក្នុងព្រហ្មាយុសូត្រនោះឯង ។

## បច្ឆាភត្តកិច្ច

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើបុរេភត្តកិច្ចស្រេចយ៉ាងនេះហើយ ប្រថាប់គង់ក្នុងទីបម្រើនាព្រះគន្ធកុដិ ទ្រង់លាងព្រះបាទ ប្រថាប់ឈរក្នុងទែន ប្រថាប់ឲ្យឱវាទដល់ភិក្ខុសង្ឃថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បី

ញុំាងប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ ឲ្យដល់ព្រមដោយសេចក្តីមិនប្រមាទចុះ ការកើតឡើងនៃព្រះពុទ្ធ រកបានដោយកម្រ ការបាននូវអត្តភាពជាមនុស្សក៏បានដោយកម្រ ការដល់ព្រមដោយសទ្ធាក៏បានដោយកម្រ បព្វជ្ជាក៏បានដោយកម្រ ការស្តាប់ធម៌ក៏បានដោយកម្រក្នុងលោក បន្ទាប់អំពីនោះ ភិក្ខុទាំងឡាយ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ទូលសួរកម្មដ្ឋានស្រេចហើយ ព្រះដ៏មានព្រះភាគទ្រង់ឲ្យកម្មដ្ឋាន ដោយអំណាចនៃចរិយាដល់ភិក្ខុទាំងឡាយ ភិក្ខុទាំងនោះរៀនកម្មដ្ឋាន អភិវាទព្រះដ៏មានព្រះភាគហើយ ទៅកាន់លំនៅរៀងៗ ខ្លួន ពួកខ្លះ ទៅកាន់ព្រៃ ពួកខ្លះ ទៅកាន់គល់ឈើ ពួកខ្លះ ទៅកាន់ទីទាំងឡាយ មានភ្នំជាដើមឯណានីមួយ ពួកខ្លះ ទៅកាន់ស្ថានចាតុម្មហារាជិកាជាដើម ។បេ។ ពួកខ្លះ ទៅកាន់ស្ថានវសវត្តី ។

បន្ទាប់អំពីនោះ ព្រះដ៏មានព្រះភាគយាងចូលព្រះគន្ធកុដិ បើទ្រង់បំណងមានព្រះសតិសម្បជញ្ញៈ សម្រេចសីហសេយ្យមួយស្របក់ដោយព្រះបង្អៀងស្តាំ កាលមានព្រះវរកាយរឹងប៉ឹងហើយ ទ្រង់ក្រោកឡើង ទ្រង់ប្រមើលមើលសត្វលោកដោយចំណែកទី ២ ។ ក្នុងចំណែកទី ៣ ទ្រង់ប្រថាប់នៅអាស្រ័យគាមគាម ឬនិគមណា ជនទាំងឡាយក្នុងគាម ឬនិគមនោះ ក្នុងបុរេភត្ត ថ្វាយទានក្នុងបច្ឆាភត្ត ស្លៀកល្អដណ្តប់ល្អ កាន់យកផ្កា និងគ្រឿងក្រអូបជាដើមប្រជុំក្នុងវិហារ បន្ទាប់អំពីនោះ ទ្រង់យាងទៅដោយបាដិហារ្យដែលសមគួរដល់បរិស័ទដែលប្រជុំ ប្រថាប់គង់លើបវរពុទ្ធាសនៈ ដែលគេក្រាលល្អហើយក្នុង

ធម្មសភា ទ្រង់សម្ដែងធម៌ដែលសមគួរដល់កាល សមគួរដល់ប្រមាណ កាល ទ្រង់ដឹងកាលហើយ ទើបទ្រង់បញ្ជូនបរិស័ទត្រឡប់ បន្ទាប់អំពីនោះ បើមានបំណងនឹងជម្រះព្រះវរកាយ ក៏ក្រោកចាកពុទ្ធាសនៈ យាងទៅកាន់ឱកាសដែលអ្នកឧបដ្ឋាកត្រៀមទឹក ទ្រង់ទទួលសំពត់ងូតទឹកអំពីដៃរបស់ឧបដ្ឋាក យាងចូលកាន់រោងសម្រាប់ងូតទឹក ចំណែកអ្នកឧបដ្ឋាក នាំពុទ្ធាសនៈមកក្រាលត្រង់បរិវេណព្រះគន្ធកុដិ ព្រះដ៏មានព្រះភាគ កាលទ្រង់ជម្រះនូវព្រះវរកាយហើយ ទ្រង់ស្លៀកសំពត់ពីរជាន់ដែលជ្រលក់ហើយ ទ្រង់ចងវត្ថពន្ធចង្កេះ ទ្រង់ដណ្ដប់សំពត់ឧត្តរាសង្គៈ ហើយយាងទៅក្នុងបរិវេណព្រះគន្ធកុដិនោះ ប្រថាប់គង់មួយព្រះអង្គឯងប៉ុណ្ណោះ សម្ងំមួយសម្ទុះ ។

លំដាប់នោះ ភិក្ខុទាំងឡាយមកអំពីទីនោះៗ មកកាន់ទីបម្រើរបស់ព្រះដ៏មានព្រះភាគ ក្នុងភិក្ខុទាំងនោះ ភិក្ខុពួកខ្លះទូលសួរបញ្ហា ពួកខ្លះទូលសូមនូវកម្មដ្ឋាន ពួកខ្លះទូលសូមស្ដាប់ធម៌ ព្រះដ៏មានព្រះភាគ ទ្រង់ញុំាងបំណងរបស់ភិក្ខុទាំងនោះ ឲ្យសម្រេចរហូតដល់បឋមយាម ក្នុងមជ្ឈិមយាម ទេវតាទាំងឡាយ ក្នុងម៉ឺនលោកធាតុ កាលបានឱកាស ក៏ចូលគាល់ព្រះដ៏មានព្រះភាគ ទូលសួរបញ្ហាតាមបំណង ដោយហោចសូម្បី ៤ អក្ខរៈ ។ ព្រះដ៏មានព្រះភាគ ទ្រង់ឆ្លើយប្រស្នារបស់ទេវតាទាំងនោះ រហូតដល់មជ្ឈិមយាម បន្ទាប់អំពីនោះ ទ្រង់ធ្វើបច្ឆិមយាមឲ្យជា ៤ ចំណែក មួយចំណែក ទ្រង់អធិដ្ឋានចង្ក្រម មួយចំណែក ទ្រង់ចូលកាន់ព្រះគន្ធកុដិ ទ្រង់មានព្រះសតិ-

សម្បជញ្ញៈ សម្រេចសីហសេយ្យ ដោយបង្អៀងស្តាំ ចំណែកទី ៣ ទ្រង់ញ៉ាំងពេលវេលាឲ្យកន្លងទៅដោយផលសមាបត្តិ ចំណែកទី ៤ ទ្រង់ចូលមហាករុណាសមាបត្តិ ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ដើម្បីទ្រង់មើលសត្វដែលមានធូលីក្នុងភ្នែកតិច ឬមានធូលីក្នុងភ្នែកច្រើនជាដើម នេះជាបច្ឆាភត្តកិច្ច ។

ក្នុងទីបំផុតនៃចំណែកទី ៤ ពោល គឺការប្រមើលមើលសត្វលោក នៃបច្ឆាភត្តកិច្ចនេះ យ៉ាងនេះហើយ ទ្រង់ប្រមើលមើលលោកដោយពុទ្ធចក្ខុដើម្បីទ្រង់ឃើញសត្វទាំងឡាយ ដែលមិនបានធ្វើអធិការ និងបានធ្វើអធិការ ក្នុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ក្នុងទាន សីល ឧបោសថកម្មជាដើម ដែលមិនដល់ព្រមដោយឧបនិស្ស័យ ដល់ព្រមដោយឧបនិស្ស័យ ដល់ព្រមដោយឧបនិស្ស័យ គឺអរហត្ត ទ្រង់ឃើញកសិភារទ្វាជព្រាហ្មណ៍ ដល់ព្រមដោយឧបនិស្ស័យ គឺអរហត្ត ទ្រង់ដឹងថា កាលតថាគតទៅកាន់ព្រាហ្មណគាមនោះហើយ កថានឹងប្រព្រឹត្តទៅ បន្ទាប់អំពីនោះ ក្នុងពេលចប់កថា ព្រាហ្មណ៍នោះបួសហើយ នឹងសម្រេចអរហត្ត ដូច្នេះហើយ ទ្រង់យាងទៅក្នុងទីនោះ ទ្រង់ញ៉ាំងកថាឲ្យតាំងឡើងព្រមហើយ បានត្រាស់ព្រះសូត្រនេះ ។

ក្នុងសូត្រនោះ បទថា **ឯវម្មេ សុតំ** ជាដើម ដែលព្រះអានន្ទត្រូវព្រះមហាកស្សបត្ថេរ អ្នកធ្វើធម្មសង្គីតិ ក្នុងមហាសង្គីតិកាលគ្រាដំបូងសួរហើយ ទើបពោលដល់ព្រះអរហន្ត ៥០០ ។ បទថា **អហំ ខោ សមណ កសាមិ ច**

**វប្បាមិ** ច ជាដើម ជាពាក្យកសិភារទ្វាជពោល ។ បទថា **អហម្បិ ខោ ព្រាហ្មណ កសាមិ ច វប្បាមិ ច** ជាដើម ជាព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគ ។ ពាក្យទាំងអស់នោះ រួមបូលគ្នា ហៅថា កសិភារទ្វាជសូត្រ ។

ក្នុងកសិភារទ្វាជសូត្រនេះ **ឯវំ** សុតំ ក្នុងបទថា **ឯវំ** នេះ មានអាការជាអត្ថ មាននិទស្សនៈជាអត្ថ មានអវធារណៈជាអត្ថ ។ ពិតហើយ ព្រះអានន្ទសម្ដែងអត្ថនេះដោយ **ឯវំ** សុតំ ដែលមានអាការជាអត្ថ ធ្វើព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគអង្គនោះ ល្អិតដោយន័យផ្សេងៗ មានអជ្ឈាស្រ័យច្រើនយ៉ាងជាសមុដ្ឋាន ដល់ព្រមដោយអត្ថ និងព្យញ្ជនៈ មានបាដិហារ្យច្រើនយ៉ាងជ្រៅដោយធម៌ អត្ថ ទេសនា និងបដិវេធ មានសភាវៈដែលសត្វទាំងពួងគប្បីកំណត់តាមសមគួរដល់ភាសារៀងៗ ខ្លួន ព្រះតម្រាស់នោះ អ្នកណាអាចដឹងច្បាស់ បានដោយប្រការទាំងពួង ដោយពិត ខ្ញុំបានស្ដាប់មកយ៉ាងនេះ គឺខ្ញុំបានស្ដាប់ហើយដោយ ១ អាការ ។

ព្រះអានន្ទកាលនឹងដោះខ្លួនថា ខ្ញុំមិនមែនសយម្ភូ ព្រះសូត្រនេះខ្ញុំមិនបានធ្វើឲ្យជាក់ច្បាស់ ទើបសម្ដែងលម្អិតព្រះសូត្រទាំងមូល ដែលគប្បីពោលក្នុងឥឡូវនេះ ដោយ **ឯវំ** សុតំ ដែលមាននិទស្សនៈជាអត្ថថា ខ្ញុំបានស្ដាប់មកយ៉ាងនេះ គឺបានស្ដាប់ហើយយ៉ាងនេះ ។

**ឯវំ** សុតំ មានអវធារណៈជាអត្ថ ព្រះអានន្ទកាលសម្ដែងកម្លាំងនៃការចងចាំរបស់ខ្លួន ដែលសមគួរដល់ភាវៈ ដែលព្រះដ៏មានព្រះភាគទ្រង់សរសើរ

ហើយយ៉ាងនេះថា **ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ពហុស្សុតានំ គតិមន្តានំ ធិតិមន្តានំ ឧបដ្ឋាកានំ យទិទំ អានន្ទោ** ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកចេះដឹងច្រើន ពួកភិក្ខុអ្នកមានស្មារតី ពួកភិក្ខុអ្នកមានគតិ ពួកភិក្ខុអ្នកមានប្រាជ្ញា ពួកភិក្ខុជាឧបដ្ឋាក ដែលជាសាវករបស់តថាគត ស្រេចនឹងអានន្ទ ប្រសើរជាងគេ ដូច្នេះ ។

ញុំាងនូវការប្រាថ្នាដើម្បីស្តាប់ ឲ្យកើតដល់សត្វទាំងឡាយថា ខ្ញុំបាន ស្តាប់មកយ៉ាងនេះ ព្រះសូត្រនេះគប្បីឃើញថា មិនខ្វះមិនលើសដោយអត្ថ ឬដោយព្យញ្ជនៈ គឺមិនគប្បីឃើញដោយប្រការដទៃយ៉ាងនេះ ។

ក្នុងបទថា **មេ សុតំ** នេះ **មេ** សព្ទ មាន **មយា** សព្ទជាអត្ថ **សុត** សព្ទ មានសោតទ្វារវិញ្ញាណជាអត្ថ ព្រោះហេតុនោះ ទើបមានអធិប្បាយថា បទថា **ឯវម្មេ សុតំ** សេចក្តីថា ខ្ញុំទ្រទ្រង់ចាំហើយដោយសោតវិញ្ញាណវិថី ដែលមានសោតវិញ្ញាណជាខាងមុខយ៉ាងនេះ ។

បទថា **ឯកំ សមយំ** សេចក្តីថា ក្នុងគ្រាមួយ ។ បទថា **ភគវា** បាន ដល់ ជាអ្នកមានភាគធម៌ អធិប្បាយថា ជាអ្នកមានជោគល្អ ជាអ្នកចែក ។ បទថា **មគធេសុ វិហរតិ** សេចក្តីថា ព្រះរាជកុមារអ្នកជនបទទាំងឡាយ ឈ្មោះថា មគធៈ ជនបទមួយដែលជាលំនៅរបស់ព្រះរាជកុមារទាំងនោះ ក៏ ហៅថា មគធៈ តាមសព្ទដែលពង្រីកចេញ ។ ក្នុងជនបទដែនមគធៈនោះ ។ អាចារ្យមួយពួកពោលយ៉ាងវែងឆ្ងាយ ដោយន័យយ៉ាងនេះថា ព្រះបាទចេតិ-

យរាជពោលពាក្យកុហកត្រូវផែនដីស្រូប ដែលបុរសទាំងឡាយទូលថា សូមទ្រង់កុំចូលកាន់រណ្ដៅ ឬព្រោះបុរសកាលពិចារណា ព្រះរាជាអង្គនោះ ជីកផែនដី ក៏ត្រូវពោលថា អ្នកទាំងឡាយកុំជីករណ្ដៅ ព្រោះហេតុនោះ ទើបឈ្មោះថា មគធៈ អ្នកសិក្សាគាប់ចិត្ត ក្នុងពាក្យណា គប្បីកាន់យកពាក្យនោះចុះ ។

បទថា **វិហរតិ** សេចក្ដីថា ទ្រង់កម្ចាត់ការលំបាកព្រះឥរិយាបថ ១ ដោយព្រះឥរិយាបថដទៃ ទ្រង់បរិហារនូវព្រះអត្តភាពដែលមិនទ្រុឌទ្រោម អធិប្បាយថា ទ្រង់ឲ្យប្រព្រឹត្តទៅ ឬទ្រង់នាំនូវប្រយោជន៍ផ្សេងៗ ដល់សត្វទាំងឡាយ ដោយទិព្វវិហារ ព្រហ្មវិហារ ឬអរិយវិហារ ព្រោះហេតុនោះ ទើបឈ្មោះថា ប្រថាប់នៅ ។ បទថា **ហរតិ** មានអធិប្បាយថា នាំចូលទៅ បង្អោនចូលទៅ ឲ្យកើត ឲ្យកើតឡើង ។ ពិតហើយ ក្នុងកាលណា សត្វទាំងឡាយបដិបត្តិខុសក្នុងកាមទាំងឡាយ បានឮថា ក្នុងកាលនោះព្រះដ៏មានព្រះភាគ ប្រថាប់នៅដោយទិព្វវិហារ ដើម្បីទ្រង់ញ៉ាំងកុសលមូល គឺអលោភៈឲ្យកើតឡើងដល់សត្វទាំងនោះថា ធ្វើម្ដេចហ្ន៎ សត្វទាំងឡាយ ឃើញបដិបត្តិនេះហើយ ញ៉ាំងការពេញចិត្តឲ្យកើតឡើង ក្នុងបដិបត្តិនោះហើយ គប្បីប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ។

ក្នុងកាលណាសត្វទាំងឡាយបដិបត្តិខុសដើម្បីភាពជាធំ ក្នុងកាលនោះប្រថាប់នៅដោយព្រហ្មវិហារ ដើម្បីទ្រង់ញ៉ាំងកុសលមូល គឺអទោសៈឲ្យកើត

ឡើងដល់សត្វទាំងនោះថា ធ្វើម្ដេចហ្ន៎ សត្វទាំងឡាយ ឃើញបដិបត្តិនេះ ញ៉ាំងសេចក្ដីពេញចិត្តឲ្យកើតឡើងក្នុងបដិបត្តិនោះ គប្បីញ៉ាំងទោសៈឲ្យស្ងប់ ដោយអទោសៈ ។

ចំណែកក្នុងកាលណា សត្វទាំងឡាយបួសហើយ ឈ្លោះគ្នាក្នុងរឿងធម៌ ក្នុងកាលនោះ ប្រថាប់នៅដោយអរិយវិហារដើម្បីញ៉ាំងកុសលមូល គឺអមោហៈ ឲ្យកើតឡើងដល់សត្វទាំងនោះថា ធ្វើម្ដេចហ្ន៎ សត្វទាំងឡាយ ឃើញបដិបត្តិ នេះ ញ៉ាំងឆន្ទៈឲ្យកើតឡើងក្នុងបដិបត្តិនេះ គប្បីញ៉ាំងមោហៈឲ្យស្ងប់ដោយ អមោហៈ តែមិនប្រថាប់នៅដោយឥរិយាបថវិហារ ក្នុងកាលណាមួយ ក៏មិន មែន ព្រោះវៀរអរិយវិហារនោះ ក៏មិនមានការបរិហារអត្តភាពឡើយ ។ សេចក្ដីសង្ខេបក្នុងសូត្រនេះ មានប្រមាណត្រឹមប៉ុណ្ណេះ ចំណែកសេចក្ដី ពិស្ដារ ខ្ញុំពោលហើយ ក្នុងមង្គលសុត្តវណ្ណនា ។

បទថា **ទក្ខិណាគិរិស្មឹ** សេចក្ដីថា ភ្នំនោះ បានព័ទ្ធជុំវិញក្រុងរាជគ្រឹះ ជនបទទិសខាងត្បូងនៃភ្នំនោះ ហៅថា ទក្ខិណាគិរី ម្យ៉ាងទៀត បទថា **ទក្ខិណាគិរិ** មានអធិប្បាយថា ក្នុងជនបទនោះ ។ ពាក្យថា ទក្ខិណាគិរី នោះឯង ជាឈ្មោះនៃវិហារក្នុងជនបទនោះ ។

បទថា **ឯកនាឡាយំ ព្រាហ្មណគ្គាមេ** សេចក្ដីថា ពាក្យថា **ឯកនាឡា** ជាឈ្មោះរបស់ស្រុកនោះ ព្រាហ្មណ៍ជាច្រើនអាស្រ័យនៅ ឬការចិញ្ចឹម ព្រាហ្មណ៍នោះ មាននៅក្នុងស្រុកនេះ ព្រោះហេតុនោះ ទើបស្រុកនេះ ហៅថា

ព្រាហ្មណគាម ។

*បទថា* **តេន ខោ បន សមយេន** *សេចក្ដីថា ក្នុងសម័យណា ព្រះដ៏មានព្រះភាគ ទ្រង់ពត់ភ្នែនលើអបរាជិតបល្ល័ង្ក ត្រាស់ដឹងចំពោះនូវសម្មាសម្ពោធិញ្ញាណដ៏កំពូល ទ្រង់ប្រកាសធម្មចក្កដ៏បវរ ទ្រង់អាស្រ័យព្រាហ្មណគាម ឈ្មោះឯកនាឡា ក្នុងដែនមគធៈ ទ្រង់រង់ចាំការចាស់ក្លាដោយជុំវិញនៃឥន្ទ្រិយរបស់ព្រាហ្មណ៍ ទ្រង់គង់នៅក្នុងទក្ខិណាគិរិមហាវិហារដោយសម័យនោះ អធិប្បាយថា ជាហេតុ ។ និបាត ២ យ៉ាងនេះ ក្នុងបទថា* **ខោ បន** *គប្បីឃើញថា គ្រាន់តែបំពេញបទឲ្យពេញ ឬមានការសម្ដែងអធិការដទៃជាអត្ថ ។*

*បទថា* **កសិភារទ្វាជស្ស ព្រាហ្មណស្ស** *សេចក្ដីថា ព្រាហ្មណ៍នោះចិញ្ចឹមជីវិតដោយការធ្វើស្រែ ។ គោត្តរបស់ព្រាហ្មណ៍នោះ ឈ្មោះថា ភារទ្វាជៈ ព្រោះហេតុនោះ ទើបហៅយ៉ាងនោះ ។*

*បទថា* **បញ្ចមត្តានិ** *មានអធិប្បាយថា* **មត្តា** *សព្ទ ក្នុងបទនេះថា* **ភោជនេ មត្តញ្ញុតា** *រមែងប្រព្រឹត្តទៅក្នុងប្រមាណយ៉ាងណា* **មត្តា** *សព្ទ ក្នុងបទនេះថា* **បញ្ចមត្តានិ** *រមែងប្រព្រឹត្តទៅក្នុងប្រមាណយ៉ាងនោះ ព្រោះហេតុនោះ ការប្រកបនង្គ័លប្រមាណ ៥០០ មិនខ្វះមិនលើស បានដល់ ការប្រកបនង្គ័ល ៥០០ ។ បទថា* **បយុត្តានិ** *បានដល់ ត្រូវប្រកបហើយ មានអធិប្បាយថា ប្រកបហើយដោយនង្គ័ល ដែលដាក់លើកទាំងឡាយរបស់*

គោបម្រើទាំងឡាយ ។

បទថា **វប្បកាលេ** បានដល់ ក្នុងពេលសាបព្រោះ អធិប្បាយថា ក្នុងពេលដែលព្រោះពូជ ។ **វប្ប** ក្នុងបទថា **វប្បកាលេ** នោះ មាន ២ យ៉ាង គឺកាលវប្បៈ ១ បំសុវប្បៈ ១ ។ បំសុវប្បៈ លោកបំណងយកក្នុងព្រះសូត្រនេះ ហើយបំសុវប្បៈនោះឯង ជាការវប្បមង្គលក្នុងថ្ងៃដំបូង ។

ក្នុងវប្បមង្គលនោះ មានឧបករណ៍ព្រមដូច្នេះ គឺគោ ៣ ពាន់ក្បាល ត្រូវត្រៀម គោទាំងអស់ពាក់ចង្កូត្រង់ស្នែងដែលធ្វើដោយមាស ក្រចកជើងបំពាក់ដោយប្រាក់ ប្រដាប់ដោយផ្កាពណ៌ស ប្រោះដោយក្លិនក្រអូបក្នុងទី ៥ កន្លែង មាននូវអវយវៈតូចធំគ្រប់បរិបូណ៌ ដល់ព្រមដោយលក្ខណៈគ្រប់យ៉ាង គោខ្លះពណ៌ខ្មៅដូចផ្កាអញ្ចន ពួកខ្លះ សដូចកម្រងប្រាក់ ពួកខ្លះ ក្រហមដូចកែវប្រពាល ពួកខ្លះ ដូចកែវមរកត បុរសអ្នកភ្ជួរមាន ៥០០ នាក់ ស្លៀកសំពត់ថ្មីពណ៌ស ប្រដាប់ដោយកម្រងផ្កា ដាក់នូវម្កុដផ្កាលើចង្កួយស្មាខាងស្តាំ មានចំណែករាងកាយលាបដោយហរតាល និងមនោសិលា ។ អ្នកភ្ជួរចែកជាមួយក្រុម ១០ នង្គ័លទាំងឡាយ មានចន្ទោល នឹម និងជន្លួញស្រោបដោយមាស ក្នុងនង្គ័លទី ១ ទឹមដោយគោ ៨ នង្គ័លដ៏សេសទឹមដោយគោ ៤ គោដ៏សេស នាំមកដូរជាមួយគោដែលនឿយហត់ ។ ក្នុងមួយក្រុមៗ មានរទេះដឹកពូជមួយរទេះ ម្នាក់ភ្ជួរ ម្នាក់ព្រោះ ។

ព្រាហ្មណ៍ឲ្យកោរពុកមាត់អំពីព្រលឹម ងូតទឹក លាបដោយគ្រឿងក្រអូប

យ៉ាងល្អទាំងឡាយ ស្លៀកសំពត់តម្លៃ ៥០០ កហាបណៈ ធ្វើនូវសំពត់តម្លៃ ១០០០ កហាបណៈធៀងស្មា ពាក់ចិញ្ចៀនមួយម្រាម ២ វង់ រួមជា ២០ ចិញ្ចៀន ពាក់កុណ្ឌលមុខសីហៈត្រង់ត្រចៀកទាំងពីរ ជួតឈ្នួតក្បាលប្រោះព្រំយ៉ាងល្អ ពាក់នូវកម្រងមាសត្រង់ក ដែលព្រាហ្មណ៍ចោមរោមហើយ បញ្ជាឲ្យធ្វើការងារ ។ លំដាប់នោះ ព្រាហ្មណីរបស់ព្រាហ្មណ៍នោះ ឲ្យចម្អិនបាយាសដាក់ក្នុងភាជនៈច្រើនរយ លើកដាក់ក្នុងរទេះធំ ងូតដោយទឹកក្រអូប តាក់តែងដោយគ្រឿងអលង្ការសព្វយ៉ាង មានពួកព្រាហ្មណីចោមរោមហើយ ទៅកាន់ទីធ្វើការងារ ។ ផ្ទះរបស់ព្រាហ្មណ៍ ក៏លាបយ៉ាងល្អដោយគ្រឿងក្រអូបទាំងឡាយ ក្នុងទីទាំងពួង មានពលីកម្មដែលធ្វើល្អហើយដោយផ្កាទាំងឡាយត្រង់ស្រែក៏លើកទង់ក្នុងទីនោះៗ ។ បុរសមេការ មួយអន្លើដោយបរិជន និងកម្មករមាន ២៥០០ នាក់ ជនទាំងនោះស្លៀកពាក់ថ្មី និងភោជនទៃបាយាសក៏ត្រៀមហើយសម្រាប់អ្នកធ្វើការទាំងអស់ ។

លំដាប់នោះ ព្រាហ្មណ៍ឲ្យលាងថាសមាសសម្រាប់ដាក់ភោជន ដែលខ្លួនបរិភោគដាក់ពេញដោយបាយាស ផ្សំដោយសប្បិ ទឹកឃ្មុំ ទឹកអំពៅជាដើម ឲ្យធ្វើមង្គលពលីកម្ម ។ ព្រាហ្មណីកាន់ភាជនៈដែលសម្រេចដោយមាស ប្រាក់ សំរឹទ្ធ និងទង់ដែង សម្រាប់អ្នកភ្ជួរស្រែចំនួន ៥០០ អង្គុយកាន់វែកមាស អង្គាសដោយបាយាស ចំណែកព្រាហ្មណ៍ឲ្យធ្វើពលីកម្មស្រេចហើយ ក៏ពាក់ទ្រនាប់ជើងមាសដែលសិតហើយ កាន់ឈើប្រត់មាសដែល

ខាត់ហើយ ដើរប្រាប់ថា ចូរឲ្យបាយាសក្នុងទីនេះ ចូរឲ្យសប្បិក្នុងទីនេះ ចូរឲ្យស្ករក្នុងទីនេះ ។

ក្នុងគ្រានោះ ព្រះដ៏មានព្រះភាគគង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ដឹងការអង្គាសរបស់ព្រាហ្មណ៍ ទ្រង់ព្រះតម្រិះថា នេះជាកាលដើម្បីទូន្មាននូវព្រាហ្មណ៍ដូច្នេះហើយ ទ្រង់ស្លៀកស្បង់ ចងវត្ថពន្ធចង្កេះ ដណ្តប់សង្ឃាដិ ទ្រង់កាន់បាត្រ ចេញចាកព្រះគន្ធកុដិ ដូចនាយសារថីទូន្មានបុរសដ៏កំពូល ដូច្នោះ ដោយហេតុនោះ ទើបព្រះអានន្ទពោលថា គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ដូច្នេះ ។

ក្នុងបទទាំងនោះ និបាតថា **អថ** ចុះបញ្ចាំងដល់ការប្រារព្ធដើម្បីពោលដល់សេចក្តីតទៅ ។ និបាតថា **ខោ** ចុះក្នុងការធ្វើបទឲ្យពេញ ។ បទថា **ភគវា** មានន័យដូចពោលហើយនោះឯង ។ បទថា **បុព្វណ្ហសមយំ** សេចក្តីថា សម័យចំណែកខាងដើមនៃថ្ងៃ អធិប្បាយថា ក្នុងពេលព្រឹក ឬសម័យក្នុងពេលព្រឹកឈ្មោះថា បុព្វណ្ហសម័យ អធិប្បាយថា ខណៈមួយ ក្នុងពេលព្រឹក ។ ជាទុតិយាវិភត្តិ ក្នុងអច្ចន្តសំយោគយ៉ាងនេះ ។ បទថា **និវាសេត្វា** ប្រែថា ទ្រង់ស្លៀកហើយ ។ បទថា **និវាសេត្វា** បានដល់ ទ្រង់ស្លៀកដណ្តប់ហើយ ។ បទថា **និវាសេត្វា** នោះ គប្បីជ្រាបដោយអំណាចនៃការផ្លាស់ប្តូរគ្រឿងស្លៀកដណ្តប់ក្នុងវិហារ ពិតហើយ ព្រះដ៏មានព្រះភាគ ទ្រង់ជាអ្នកមិនស្លៀកស្បង់ក្នុងវេលាមុនកាលអំពីនោះ ក៏មិនមែន ។

បទថា **បត្តចីវរំ អាទាយ** សេចក្ដីថា ទ្រង់កាន់យកបាត្រដោយព្រះហស្ដទាំងពីរ ទ្រង់កាន់ចីវរដោយព្រះវរកាយ អធិប្បាយថា ទទួលហើយទ្រទ្រង់ហើយ អត្ថនៃបទថា **បត្តចីវរំ អាទាយ** នោះ គប្បីជ្រាបយ៉ាងនេះថា បានឮថា បាត្រដែលសម្រេចដោយសិលា មានពណ៌ដូចកែវឥន្ទនីលរមែងមកកាន់ព្រះហស្ដទាំងពីររបស់ព្រះដ៏មានព្រះភាគ ក្នុងកាលទ្រង់បំណងយាងទៅដើម្បីបិណ្ឌបាត ដូចកន្ទង់ចូលត្រង់កណ្ដាលត្របកឈូកទាំងពីរដែលរីកហើយ ដូច្នោះ ។ ទ្រង់ទទួលបាត្រដែលមកហើយ ដោយព្រះហស្ដទាំង ២ និងទ្រទ្រង់ចីវរដែលដណ្ដប់ជាបរិមណ្ឌលហើយ ដោយព្រះវរកាយ ។ ព្រះមានព្រះភាគទ្រង់ទទួលដោយប្រការណាមួយ ហៅថា ទ្រង់កាន់ហើយ ដូចពាក្យថា កាន់ហើយ ក៏យាងចៀសចេញទៅ ដូច្នោះ ។

បទថា **យេន** បានដល់ ដោយផ្លូវណា ។ បទថា **កម្មន្តោ** បានដល់ឱកាសនៃការធ្វើការងារ ។ បទថា **តេន** បានដល់ ដោយផ្លូវនោះ ។ បទថា **ឧបសង្កមិ** បានដល់ យាងទៅហើយ អធិប្បាយថា ការងាររបស់កសិភារទ្វាជព្រាហ្មណ៍ រមែងមានដោយផ្លូវណា យាងទៅហើយ ដោយផ្លូវនោះ ។

សួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបភិក្ខុទាំងឡាយមិនជាប់តាមព្រះដ៏មានព្រះភាគ ខ្ញុំសូមឆ្លើយថា ព្រោះក្នុងកាលណាព្រះដ៏មានព្រះភាគមានបំណងយាងទៅទីណាមួយចំពោះព្រះអង្គឯង ទ្រង់បិទទ្វារក្នុងពេលភិក្ខាចារស្ដេចចូលទៅខាងក្នុងព្រះគន្ធកុដិ បន្ទាប់អំពីនោះ ភិក្ខុទាំងឡាយ ដឹងដោយ

សញ្ញានោះថា ថ្ងៃនេះ ព្រះដ៏មានព្រះភាគ មានបំណងយាងចូលស្រុកតែមួយអង្គឯង ទ្រង់បានឃើញបុគ្គលដែលគួរទូន្មានណាមួយពិត ភិក្ខុទាំងនោះ កាន់បាត្រ និងចីវររបស់ខ្លួន ធ្វើប្រទក្សិណព្រះគន្ធកុដិ ថ្វាយបង្គំហើយ ទៅកាន់ទីភិក្ខាចារ ក្នុងកាលនោះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើហើយយ៉ាងនេះ ព្រោះហេតុនោះ ទើបភិក្ខុទាំងឡាយ មិនដើរតាមព្រះដ៏មានព្រះភាគ ។

បទថា **តេន ខោ បន សមយេន** សេចក្ដីថា ដោយសម័យណា ព្រះដ៏មានព្រះភាគយាងចូលទៅកាន់ទីធ្វើការ ដោយសម័យនោះ ការអង្គាសរបស់ព្រាហ្មណ៍នោះកំពុងប្រព្រឹត្តទៅ អធិប្បាយថា ការចែកចាយភត្តកំពុងប្រព្រឹត្តទៅ ដូចខ្ញុំបានពោលហើយខាងដើមថា ព្រាហ្មណីកាន់យកភាជនៈដែលសម្រេចដោយមាស ប្រាក់ សំរឹទ្ធ និងទង់ដែងសម្រាប់អ្នកភ្ជួរស្រែចំនួន ៥០០ កាន់យកវែកមាសទៅអង្គាសដោយបាយាស ដូច្នេះ ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគចូលទៅដល់ទីអង្គាស សួរថា ព្រោះហេតុអ្វី ឆ្លើយថា ដើម្បីទ្រង់ធ្វើការអនុគ្រោះព្រាហ្មណ៍ ។

មែនពិត ព្រះដ៏មានព្រះភាគយាងចូលទៅកាន់ទីអង្គាស ព្រោះទ្រង់មានបំណងដើម្បីសោយ ដូចបុរសកំព្រាក៏មិនមែន ព្រោះព្រះរាជាសក្យៈ និងកោលិយៈ មួយចំណែកមាន ៨២០០០ អង្គ សុទ្ធតែជាព្រះញាតិរបស់ព្រះដ៏មានព្រះភាគ ព្រះញាតិទាំងនោះ អាចថ្វាយភត្តជានិច្ចដោយសម្បត្តិរបស់ខ្លួនបាន តែព្រះដ៏មានព្រះភាគ ទ្រង់មិនបានបួសដើម្បីប្រយោជន៍ដល់ភត្ត

ឡើយ បណ្ឌិតគប្បីជ្រាបថា ដោយពិត ទ្រង់បរិច្ចាគមហាបរិច្ចាគ ៥ ប្រការ ទ្រង់បំពេញបារមីទាំងឡាយ អស់អសង្ខេយ្យមិនមែនតិច ទ្រង់បួសហើយ ដោយព្រះតម្រិះថា អាត្មាអញផុតហើយ និងឲ្យសត្វផុតផង អាត្មាអញទូន្មានហើយ និងឲ្យអ្នកដទៃទូន្មានផង អាត្មាអញរម្ងត់ហើយ និងឲ្យអ្នកដទៃរម្ងត់ផង ព្រោះហេតុនោះ ដើម្បីញ៉ាំងអ្នកដទៃឲ្យផុត និងឲ្យរលត់ ព្រោះភាពដែលទ្រង់ជាអ្នករួចផុតហើយ និងរម្ងត់ហើយ ទើបទ្រង់ត្រាច់ទៅក្នុងលោក យាងចូលទៅដល់ទីអង្គាស ដើម្បីធ្វើនូវសេចក្ដីអនុគ្រោះដល់ព្រាហ្មណ៍ ។

បទថា **ឯកមន្តំ** ក្នុងបទថា **ឧបសង្កមិត្វា ឯកមន្តំ អដ្ឋាសិ** នោះ ជាការសម្ដែងដល់ការនៃបុំសកលិង្គ អធិប្បាយថា ក្នុងឱកាសមួយ គឺក្នុងចំណែកម្ខាង ។ ឬជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ បានប្រថាប់ឈរក្នុងទីខ្ពស់ល្មមព្រាហ្មណ៍ឃើញបាន គឺក្នុងទីល្មមស្ដាប់បាន ។ កាលប្រថាប់ឈរហើយ ទ្រង់បញ្ចេញពន្លឺព្រះវរកាយ ដូចទ្រង់មាសដែលក្លីក្រៃលែង ជាងពន្លឺព្រះចន្ទ និងព្រះអាទិត្យ រាប់ពាន់ដួង ដោយជុំវិញ ប្រមាណ ៨០ ហត្ថដែលគ្របសង្កត់ហើយ ធ្វើឲ្យជញ្ជាំងរោងសម្រាប់ធ្វើការងារ ដើមឈើ និងដុំដីដែលភ្ជួរហើយជាដើម ហាក់ដូចជាសម្រេចដោយមាស ។

គ្រានោះ មនុស្សទាំងឡាយ បរិភោគបាយាសហើយ ឃើញព្រះសម្មាសម្ពុទ្ធ ប្រថាប់ឈរក្នុងទីសមគួរនាចំណែកម្ខាង ដែលមានព្រះវរកាយប្រដាប់ដោយលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ដែលមានអនុព្យញ្ជនៈ ៨០ ជា

បរិវារ មានព្រះពាហាទាំងគូរុងរឿងដោយពន្លឺមួយព្យាមដោយជុំវិញ មានព្រះរស្មីធ្មៀលធ្មាត់ដោយព្រះកេតុមាលាគួរមើលក្រៃពេក ដូចបាចសាចដោយផ្កាបទុម រុងរឿងដោយព្រះសិរី ដូចពួកផ្កាយព្រិចៗ ដោយសំណាញ់រស្មីធ្វើឲ្យលម្អាមេឃរុងរឿង ដូចព្រះអាទិត្យបញ្ចេញពន្លឺលើកំពូលភ្នំមាស ដូច្នោះលាងដៃ និងជើងហើយ ផ្គងហើយផ្គងទៀតនូវអញ្ជលី បានឈរចោមរោមហើយ ។ កសិភារទ្វាជព្រាហ្មណ៍បានឃើញព្រះដ៏មានព្រះភាគ ប្រថាប់ឈរដើម្បីបិណ្ឌបាត ដែលមនុស្សទាំងនោះចោមរោមហើយយ៉ាងនេះឯង កាលឃើញហើយ ទើបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះសមណៈខ្ញុំព្រះអង្គភ្ជួររាស់ផង សាបព្រោះផង ដូច្នេះ ។

សួរថា ព្រោះហេតុអ្វី ទើបព្រាហ្មណ៍ពោលយ៉ាងនេះ ព្រោះការមិនជ្រះថ្លាក្នុងព្រះដ៏មានព្រះភាគ ដែលគួរជ្រះថ្លាដោយជុំវិញ ដែលដល់ហើយនូវការទូន្មាន និងសមថៈដ៏ឧត្តម ឬព្រោះត្រៀមបាយ បបរ ដល់ជន ២៥០០ ហើយកំណាញ់ដោយភិក្ខាមួយវែក ។

ឆ្លើយថា មិនមែនដោយប្រការទាំងពីរ ដោយពិតនោះ ព្រាហ្មណ៍នោះឃើញជនដែលមិនឆ្អែតដោយការមើលព្រះដ៏មានព្រះភាគហើយ ចោលការងារទើបមានការមិនពេញចិត្តថា ទ្រង់យាងមកដើម្បីធ្វើការងាររបស់អញឲ្យវិនាសព្រោះហេតុនោះ ទើបពោលយ៉ាងនោះ ។ ព្រាហ្មណ៍នោះ ឃើញលក្ខណ-សម្បត្តិរបស់ព្រះដ៏មានព្រះភាគ ទើបមានការត្រិះរិះថា បើសមណៈនេះប្រកប

ការងារទាំងឡាយសោត ក៏នឹងបានដូចជាកែវចូឡាមណីក្នុងសីសៈ ក្នុងជម្ពូទ្វីបទាំងមូល ប្រយោជន៍ប្រភេទណាហ្ន៎របស់សមណៈនោះ នឹងមិនសម្រេច សមណៈនោះ មិនប្រកបការងារទាំងឡាយ ព្រោះភាពដែលខ្លួនជាបុគ្គលខ្ជិលប្រអូស ត្រាច់ដើម្បីបិណ្ឌបាត ក្នុងទីទាំងឡាយ មានវប្បមង្គលកាលជាដើម មកបរិភោគ ត្រាច់ទៅរហូតដល់រាងកាយធាត់ ដោយប្រការដូច្នេះ ។ ដោយហេតុនោះ ទើបកសិភារទ្វាជព្រាហ្មណ៍ក្រាបទូលថា បពិត្រសមណៈ ខ្ញុំព្រះអង្គរមែងភ្ជួរ និងព្រោះ កាលភ្ជួរ និងព្រោះហើយ រមែងបរិភោគ ដូច្នេះ អធិប្បាយថា ការងារទាំងឡាយរបស់ខ្ញុំព្រះអង្គ រមែងមិនវិនាស ទ្រង់ជាបុគ្គលមិនដល់ព្រមដោយលក្ខណៈយ៉ាងនោះ អធិប្បាយថា បពិត្រសមណៈ សូម្បីព្រះអង្គ ។បេ។ សូមបរិភោគ ប្រយោជន៍អ្វី នឹងមិនគប្បីសម្រេចដល់ព្រះអង្គ ដែលដល់ព្រមដោយលក្ខណៈយ៉ាងនេះ ។

ម្យ៉ាងទៀត កសិភារទ្វាជព្រាហ្មណ៍នេះ បានឮមកថា ព្រះរាជកុមារកើតក្នុងសក្យរាជត្រកូល ទ្រង់លះបង់ចក្កពត្តិរាជសម្បត្តិ ទ្រង់ព្រះផ្នួស ព្រោះហេតុនោះ ទើបដឹងក្នុងឥឡូវនេះថា ព្រះរាជកុមារនោះ គឺសមណៈអង្គនេះ កាលធ្វើការតិះដៀលថា បានឮថា ទ្រង់លះបង់ចក្កពត្តិរាជសម្បត្តិ យាងចេញបួសហើយ ក្រាបទូលថា បពិត្រសមណៈ ខ្ញុំព្រះអង្គ ... ដូច្នេះ ។

ម្យ៉ាងទៀត ព្រាហ្មណ៍នេះជាមនុស្សមានបញ្ញាមុតស្រួច មិនក្រាបទូលទ្រគោះព្រះដ៏មានព្រះភាគ តែឃើញរូបសម្បត្តិរបស់ព្រះដ៏មានព្រះភាគហើយ

កាលទ្រឹងពោលសរសើរបញ្ញាសម្បត្តិ ទើបក្រាបទូលយ៉ាងនេះ ដើម្បីឲ្យកថាប្រព្រឹត្តទៅថា បពិត្រសមណៈ ខ្ញុំព្រះអង្គ ដូច្នេះ ។ បន្ទាប់អំពីនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងសេចក្តីដែលព្រះអង្គ ទ្រង់ជាអ្នកស្រែដ៏កំពូលក្នុងលោក ព្រមទាំងទេវលោក ដោយអំណាចនៃវេនេយ្យសត្វ ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគត ... ដូច្នេះ ។

លំដាប់នោះ ព្រាហ្មណ៍កើតគំនិតថា សមណៈនេះត្រាស់ថា តថាគតក៏ភ្ជួរ និងព្រោះ ដូច្នេះ អញមិនឃើញឧបករណ៍សម្រាប់ធ្វើស្រែ មាននឹម និងនង្គ័លជាដើមរបស់សមណៈនេះ សមណៈនេះពោលកុហកឬហ្ន៎ ទើបផ្ចៀងមើលព្រះដ៏មានព្រះភាគ តាំងពីចុងជើងដល់ចុងសក់ ដឹងសម្បត្តិ គឺលក្ខណៈដ៏ប្រសើរ ៣២ យ៉ាងរបស់ព្រះដ៏មានព្រះភាគអង្គនោះ ព្រោះភាពដែលខ្លួនធ្វើការសិក្សាល្អមកហើយក្នុងវិជ្ជាទាយលក្ខណៈ គិតថា ន៎ះ មិនមែនឋានៈមិនមែនឱកាសដែលសមណៈបែបនេះនិយាយកុហក ក្នុងវេលានោះឯង ក៏កើតមានះខ្លាំង លះពាក្យថា **ន ខោ បន បស្សាម ភោតោ គោតមស្ស** ដូច្នេះ ។ ព្រាហ្មណ៍មានបញ្ញាមុតស្រួច ក្រាបទូលយ៉ាងនេះហើយ ក៏ដឹងថា ព្រះសមណៈនេះត្រាស់យ៉ាងនេះ សំដៅដល់អត្ថដ៏ជ្រាលជ្រៅ បំណងនឹងដឹងអត្ថតាមដែលទូលសួរ បានទូលសួរព្រះដ៏មានព្រះភាគដោយគាថា ។ ដោយហេតុនោះ ទើបព្រះអានន្ទពោលថា លំដាប់នោះ កសិភារទ្វាជព្រាហ្មណ៍ បានទូលសួរព្រះដ៏មានព្រះភាគដោយគាថា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **គាថាយ** បានដល់ ដោយពាក្យដែលកំណត់បទនៃអក្ខរៈហើយ ។ បទថា **អជ្ឈភាសិ** សេចក្ដីថា បានពោលហើយ ។ ក្នុងគាថានោះ ព្រាហ្មណ៍កាលទូលសួរដល់ការប្រកបឧបករណ៍ដែលធ្វើស្រែមាននឹម និងនង្គ័លជាដើម ទើបទូលថា **កសិំ** ដូច្នេះ ។ ព្រោះការលើកឡើងពោលដោយបុព្វធម្មសភាគៈ ( វត្ថុដែលស្មើនឹងវត្ថុដែលពោលមកអំពីមុន ) ជាអានុភាពរបស់ព្រះពុទ្ធទាំងឡាយ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគកាលទ្រង់សម្ដែងពុទ្ធានុភាព ទ្រង់បញ្ញត្តដោយសភាវៈដែលជាបុព្វធម្មសភាគៈ ទើបត្រាស់ថា **សទ្ធា ពីជំ** ដូច្នេះ ។

សួរថា ការប្រៀបធៀបដោយបុព្វធម្មសភាគៈ ក្នុងគាថានេះ ព្រះដ៏មានព្រះភាគ ដែលព្រាហ្មណ៍ទូលសួរដល់ការប្រកបនូវឧបករណ៍ ក្នុងការធ្វើស្រែ មាននឹម និងនង្គ័លជាដើម កាលឲ្យព្រាហ្មណ៍ដឹងដោយការប្រៀបធៀបពូជដែលមិនបានទូលសួរ ទើបត្រាស់ថា សទ្ធាជាពូជ កាលបើដូច្នោះ កថានេះ ក៏មិនមានអនុសន្ធិនោះឯង ។

ឆ្លើយថា កថារបស់ព្រះពុទ្ធទាំងឡាយ ឈ្មោះថា មិនមានអនុសន្ធិ មិនមានឡើយ ទាំងមិនលើកយកមកត្រាស់ដោយបុព្វធម្មសភាគៈ ក៏មិនមែន បណ្ឌិតគប្បីជ្រាបអនុសន្ធិក្នុងសូត្រនេះយ៉ាងនេះ ដ្បិតថា ព្រះដ៏មានព្រះភាគ ត្រូវព្រាហ្មណ៍នេះទូលសួរដល់នង្គ័ល ដោយអំណាចគ្រឿងឧបករណ៍ធ្វើស្រែ មាននឹម និងនង្គ័លជាដើម ដោយទ្រង់អនុគ្រោះព្រាហ្មណ៍នោះ មិនឲ្យ

សាបសូន្យចាកប្រយោជន៍ ដោយគិតថា ព្រាហ្មណ៍មិនបានសួរវត្ថុនេះ កាល ទ្រង់សម្ដែងនង្គ័លជាខាងដើម ដើម្បីឲ្យព្រាហ្មណ៍ស្គាល់នង្គ័ល ព្រមទាំងមូល ឧបការៈគ្រឿងឧបករណ៍ និងផល ទើបត្រាស់ថា សទ្ធាជាពូជ មែនហើយ ពូជជាមូលនៃការភ្ជួរ ដោយគប្បីធ្វើក្នុងកាលពូជនោះមាន ដោយមិនគប្បីធ្វើ ក្នុងកាលពូជនោះមិនមាន និងដោយគប្បីធ្វើតាមប្រមាណនៃពូជនោះ កាល ពូជមាន អ្នកស្រែទាំងឡាយ ទើបធ្វើការភ្ជួរ កាលពូជមិនមាន ក៏មិនធ្វើការ ភ្ជួរ ។ អ្នកស្រែទាំងឡាយ ជាអ្នកឈ្លាស រមែងភ្ជួរតាមប្រមាណនៃពូជ មិន ភ្ជួរតិច ដោយគិតថា ស្រូវរបស់យើងកុំវិនាស មិនភ្ជួរច្រើន ដោយគិតថា សេចក្ដីព្យាយាមរបស់ពួកយើង កុំសូន្យទទេ ព្រោះពូជនោះឯងជាមូល ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងនង្គ័លចាប់តាំងអំពី ដើម ទ្រង់លើកបុព្វធម៌នៃការភ្ជួររបស់ព្រះអង្គ ដោយប្រៀបធៀបនឹងពូជ ដែលជាបុព្វធម៌នៃការភ្ជួររបស់ព្រាហ្មណ៍ ទើបត្រាស់ថា សទ្ធាជាពូជ គប្បី ជ្រាបការប្រៀបធៀបដោយបុព្វធម៌ ក្នុងព្រះសូត្រនេះ ដោយប្រការដូច្នេះ ។

ប្រសិនបើមានពាក្យសួរថា ព្រះដ៏មានព្រះភាគត្រាស់ធម៌ដែលព្រាហ្មណ៍ ទូលសួរប៉ុណ្ណោះ ខាងក្រោយមិនត្រាស់ធម៌ដែលព្រាហ្មណ៍មិនទូលសួរ ព្រោះ ហេតុអ្វី ឆ្លើយថា ព្រោះព្រះអង្គមានឧបការៈដល់ព្រាហ្មណ៍ និងព្រោះព្រះអង្គ ជាអ្នកអាចក្នុងការភ្ជាប់ព្រះធម៌ ព្រាហ្មណ៍នេះក៏មានបញ្ញា តែខ្វះសទ្ធា ព្រោះ ខ្ជួនកើតក្នុងត្រកូលមិច្ឆាទិដ្ឋិ មនុស្សដែលខ្វះសទ្ធា មានតែបញ្ញា មិនបដិបត្តិ

ក្នុងវត្ថុដែលមិនមែនជាវិស័យរបស់ខ្លួន តាមសទ្ធារបស់បុគ្គលពួកដទៃ រមែងមិនសម្រេចគុណវិសេស ឯសទ្ធាដែលមានកម្លាំងខ្សោយរបស់ព្រាហ្មណ៍នោះ សូម្បីមានលក្ខណៈ ត្រឹមតែការជ្រះថ្លា ព្រោះមិនមានការផ្សាយឡើងនៃកិលេសតាមកាល ដែលប្រព្រឹត្តទៅព្រមជាមួយបញ្ញាដែលមានកម្លាំង រមែងមិនធ្វើនូវការសម្រេចប្រយោជន៍ ដូចគោទឹមក្នុងនឹមជាមួយដំរី ព្រោះហេតុនោះ ទើបសទ្ធាជាឧបការៈដល់ព្រាហ្មណ៍នោះ អត្ថនេះ គប្បីត្រាស់ខាងក្រោយ ដែលព្រះដ៏មានព្រះភាគ ទ្រង់ញ៉ាំងព្រាហ្មណ៍នោះ ឲ្យតាំងនៅក្នុងសទ្ធា ត្រាស់ហើយមុន ព្រោះភាពជាឧបការៈដល់ព្រាហ្មណ៍នោះ យ៉ាងនេះ ព្រោះភាពដែលទ្រង់ជាបុគ្គលឈ្លាសក្នុងទេសនា ដូចត្រាស់ក្នុងទីដទៃថា **សទ្ធា ពន្ធតិ ធាថេយ្យំ** សទ្ធារមែងចងនូវស្បៀង **សទ្ធា ទុតិយា បុរិសស្ស ហោតិ** សទ្ធាជាទីពីររបស់បុរស **សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ** សទ្ធាជាទ្រព្យដ៏ប្រសើររបស់បុរសក្នុងលោកនេះ **សទ្ធាយ តរតិ ឱឃំ** បុគ្គលឆ្លងអន្លង់បានដោយសទ្ធា **សទ្ធាហត្ថោ មហានាគោ** ព្រះសម្ពុទ្ធជាមហានាគ ទ្រង់មានសទ្ធាជាប្រមោយ **សទ្ធេា ខោ ភិក្ខវេ អរិយសាវកោតិ** ច ម្នាលភិក្ខុទាំងឡាយ អរិយសាវក មានសទ្ធាជា ( សសរគោល ) ដូច្នេះ ។ ភ្លៀងមានឧបការៈដល់ពូជនោះ ភ្លៀងនោះ ទ្រង់ត្រាស់ក្នុងលំដាប់នៃសទ្ធានោះហើយ ទើបជាការសមគួរ អត្ថនេះ គួរត្រាស់ក្នុងខាងក្រោយ តែត្រាស់មុន ព្រោះភាពដែលទ្រង់ជាអ្នកអាចភ្ជាប់នូវធម៌ ដោយប្រការដូច្នេះ ។ ឯធម៌ដទៃ មាន

ចន្ទោលទន្តុ័ល និងខ្សែរជាដើម ក៏មានវិធីយ៉ាងនេះ ។

ក្នុងព្រះសូត្រនេះ សទ្ធាមានការជ្រះថ្លា មួយអន្ទើដោយលក្ខណៈ ឬមានការឈមចុះជាលក្ខណៈ មានការស្ទុះទៅជាកិច្ច មានការបង្អោនចិត្តជឿជាបច្ចុប្បដ្ឋាន ឬមានការមិនផ្សាយឡើងតាមកាលជាបច្ចុប្បដ្ឋាន មានសោតាបត្តិយង្គៈជាបទដ្ឋាន ឬមានធម៌គួរជឿជាបទដ្ឋាន ជាការជ្រះថ្លារបស់ចិត្ត ដូចការថ្លារបស់វត្ថុ មានកពក់ ឬទឹកជាដើម ជាទីផ្សួរផង់នៃសម្បយុត្តធម៌ទាំងឡាយ ដូចកែវមណីញ៉ាំងទឹកឲ្យថ្លា ជាទីផ្សួរផង់នៃទឹក ដូច្នោះ ។

បទថា **ពីជំ** បានដល់ ពូជ ៥ ប្រភេទ គឺមូលពីជៈ ខន្ធពីជៈ ផលពីជៈ អគ្គពីជៈ និងពីជពីជៈជាគម្រប់ ៥ ។ ពូជទាំងអស់នោះ ដល់នូវការរាប់ថាជាពូជប៉ុណ្ណោះ ព្រោះអត្ថថា ដុះឡើង ដូចលោកពោលថា ទុំះឈ្មោះថា ពូជ ព្រោះអត្ថថា ដុះឡើង ។ ក្នុងពូជទាំងនោះ ពូជដែលកើតអំពីឫស នៃការភ្ជួររបស់ព្រាហ្មណ៍ រមែងធ្វើកិច្ចពីរយ៉ាង គឺថ្នាំងក្រោមតាំងនៅដោយឫស ថ្នាំងលើចេញពន្លកយ៉ាងណា សទ្ធាជាឫសនៃការភ្ជួររបស់ព្រះដ៏មានព្រះភាគ ថ្នាំងក្រោមតាំងនៅដោយឫស គឺសីល ថ្នាំងលើចេញពន្លក គឺសមថៈ និងវិបស្សនា ដូច្នោះ ។

ម្យ៉ាងទៀត ពូជនោះ ស្រូបរសដី រសទឹកដោយឫស រមែងចម្រើនដោយមែក ដើម្បីទទួលការចាស់ដោយជុំវិញនៃធញ្ញជាតិយ៉ាងណា សទ្ធានេះក៏ដូច្នោះ ទទួលនូវរស គឺសមថៈ និងវិបស្សនាដោយឫស គឺសីល រមែង

ចម្រើនដោយមែក គឺអរិយមគ្គ ដើម្បីទទួលនូវការចាស់ដោយជុំវិញនៃអរិយផល ។

ម្យ៉ាងទៀត ពូជនោះ តាំងនៅក្នុងដីល្អ ដល់នូវការចម្រើន លូតលាស់ បរិបូណ៌ដោយឫស ពន្លក ស្លឹក មែក ដើម និងត្រួយ ញ៉ាំងទឹកដោះឲ្យកើតឡើង ហើយសម្រេចជាកួរស្រូវសាលី ដែលពេញដោយផ្លែមិនមែនតិច យ៉ាងណា សទ្ធានេះ ក៏ដូច្នោះ តាំងនៅក្នុងចិត្តសន្តានហើយ ដល់នូវសេចក្តីចម្រើនដុះដាល បរិបូណ៌ដោយសីលវិសុទ្ធិ ចិត្តវិសុទ្ធិ ទិដ្ឋិវិសុទ្ធិ កង្ខាវិតរណវិសុទ្ធិ មគ្គាមគ្គញាណទស្សនវិសុទ្ធិ និងបដិបទាញាណទស្សនវិសុទ្ធិ ញ៉ាំងទឹកដោះ គឺញាណទស្សនវិសុទ្ធិឲ្យកើតឡើងហើយ រមែងឲ្យសម្រេចនូវអរហត្តផល ដែលពេញដោយបដិសម្ភិទាមិនមែនតិច ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **សទ្ធា ពីជំ** ដូច្នេះ ។

ក្នុងសេចក្តីនោះ គប្បីមានពាក្យសួរថា កាលកុសលធម៌ជាង ៥០ កើតរួមគ្នា ព្រោះហេតុអ្វី ទើបព្រះដ៏មានព្រះភាគត្រាស់ថា សទ្ធាជាពូជ ឆ្លើយថា ព្រោះសទ្ធាធ្វើកិច្ចជាពូជ មែនហើយ ក្នុងធម៌ទាំងនោះ វិញ្ញាណប៉ុណ្ណោះ រមែងធ្វើកិច្ចដឹងច្បាស់ យ៉ាងណា សទ្ធារមែងធ្វើកិច្ចជាពូជដូច្នោះ ព្រោះសទ្ធានោះ ជាឫសគល់នៃកុសលទាំងពួង ដូចលោកពោលក្នុង ( កីដាគិរិសូត្រ ) ថា

ម្នាលភិក្ខុទាំងឡាយ កុលបុត្រក្នុងសាសនានេះ មានសទ្ធា ទើប

ចូលទៅរក កាលបើចូលទៅរកហើយ ទើបចូលទៅអង្គុយជិត លុះចូលទៅអង្គុយជិតហើយ ទើបផ្ទៀងនូវសោតប្បសាទ លុះផ្ទៀងនូវសោតប្បសាទហើយ ទើបស្តាប់ធម៌ លុះស្តាប់ធម៌ហើយ ទើបចងចាំធម៌ ( នោះ ) កាលបើចងចាំធម៌ ( នោះ ) ហើយ ទើបពិចារណារកសេចក្តី លុះពិចារណារកសេចក្តីនៃធម៌នោះហើយ ធម៌ទាំងឡាយ តែងគួរដល់កិរិយាលៃលកមើល កាលបើមានការលៃលកមើលហើយ ឆន្ទៈក៏កើតឡើង បុគ្គលនោះលុះមានឆន្ទៈកើតហើយ ទើបព្យាយាម លុះព្យាយាមហើយ រមែងស្ទង់មើល លុះស្ទង់មើលហើយ រមែងតម្កល់ទុក មានចិត្តបញ្ជូនទៅ ( កាន់ព្រះនិព្វាន ) ធ្វើឲ្យជាក់ច្បាស់នូវបរមត្ថសច្ចដោយនាមកាយ ទាំងបានចាក់ធ្លុះឃើញច្បាស់នូវបរមត្ថសច្ចនោះដោយប្រាជ្ញា ដូច្នេះ ។

ធម៌ណា រមែងដុតអកុសលធម៌ទាំងឡាយ និងកាយ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **តប** គឺការព្យាយាម ។ ពាក្យថា **តប** នោះជាឈ្មោះនៃឥន្ទ្រិយសំវរៈ វីរិយៈ ធុតង្គ និងការបំពេញទុក្ករកិរិយា ឥន្ទ្រិយសំវរៈ លោកបំណងយកក្នុងព្រះសូត្រនេះ ។ បទថា **វុដ្ឋិ** បានដល់ ភ្លៀងច្រើនយ៉ាង មានភ្លៀងក្នុងរដូវវស្សា និងភ្លៀងខ្យល់ជាដើម ។ ភ្លៀងក្នុងរដូវវស្សា លោក

បំណាំងយកក្នុងព្រះសូត្រនេះ ។ ពូជដែលភ្លៀងក្នុងរដូវវស្សាអនុគ្រោះល្អហើយ សម្បូរដែលមានពូជជាមូលរបស់ព្រាហ្មណ៍ រមែងដុះដាលមិនក្រៀមស្ងួត រមែងដល់នូវការសម្រេច យ៉ាងណា សទ្ធាដែលឥន្ទ្រិយសំវរៈអនុគ្រោះល្អហើយ និងធម៌ទាំងឡាយ មានសីលជាដើម ដែលមានសទ្ធាជាមូលរបស់ព្រះដ៏មានព្រះភាគ រមែងដុះ រមែងមិនក្រៀមស្ងួត រមែងដល់នូវសេចក្ដីសម្រេច ដូច្នោះ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **តបោ វុដ្ឋិ** ដូច្នេះ ។

**មេ** សព្ទ ដែលព្រះដ៏មានព្រះភាគត្រាស់ក្នុងបទថា **បញ្ញា មេ** នេះ អ្នកសិក្សាគប្បីប្រកបក្នុងបទទាំងនោះថា **សទ្ធា មេ ពីជំ តបោ មេ វុដ្ឋិ** ប្រែថា សទ្ធារបស់តថាគតជាពូជ សេចក្ដីព្យាយាមរបស់តថាគតជាភ្លៀង ដូច្នេះ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងអ្វីដោយបទនេះ ទ្រង់សម្ដែងថា ម្នាលព្រាហ្មណ៍ កាលពូជដែលអ្នកព្រោះហើយ បើមានភ្លៀងជាការល្អ បើមិនមានភ្លៀង ទឹកក៏អ្នកត្រូវស្រោច យ៉ាងណា កាលចន្ទោលនង្គ័ល គឺហិរិ នឹម និងនង្គ័ល គឺបញ្ញា តថាគតធ្វើរួមគ្នាជាមួយខ្សែ គឺចិត្ត ទឹមដោយគោ គឺសេចក្ដីព្យាយាម ចាក់ដោយជន្ទញ គឺសតិ ព្រោះនូវពូជ គឺសទ្ធាក្នុងស្រែ គឺចិត្តសន្តានរបស់ខ្លួន ឈ្មោះថា ការមិនមានភ្លៀង រមែងមិនមាន គឺសេចក្ដីព្យាយាមជានិច្ចរបស់តថាគតនេះ ជាភ្លៀង ។

ឈ្មោះថា បញ្ញា ព្រោះអត្ថវិគ្គហៈថា ជាគ្រឿងដឹងច្បាស់របស់បុគ្គល

ឬបុគ្គលរមែងដឹងច្បាស់ ។ បញ្ញានោះមានច្រើនយ៉ាង មានកាមាវចរៈជាដើម មគ្គប្បញ្ញា មួយអន្លើដោយវិបស្សនា ទ្រង់បំណាងយកក្នុងគាថានេះ ។ បទថា **យុគនង្គលំ** បានដល់ នឹម និងនង្គ័ល ឈ្មោះថា **យុគនង្គលំ** ប្រែថា នឹម និងនង្គ័ល ។ នឹម និងនង្គ័លរបស់ព្រាហ្មណ៍មាន យ៉ាងណា បញ្ញាទាំងពីររបស់ព្រះដ៏មានព្រះភាគ ក៏មានយ៉ាងនោះ ។

ក្នុងគាថានោះ នឹមជាគ្រឿងអាស្រ័យរបស់ចន្ទោលនង្គ័ល រមែងនៅខាងមុខ តជាមួយចន្ទោលនង្គ័ល ជាទីតរបស់ខ្សែទាំងឡាយ រមែងទ្រទ្រង់នូវការទៅរួមគ្នានៃគោបម្រើទាំងឡាយ យ៉ាងណា បញ្ញាក៏ដូច្នោះ ជាគ្រឿងអាស្រ័យរបស់ធម៌ទាំងឡាយ មានហិរិជាប្រធាន ដូចដែលត្រាស់ថា ធម៌ទាំងអស់ មានបញ្ញាជាវិសេស ដូច្នេះ ។ និងពុទ្ធដីកាមួយកន្លែងទៀតថា

អ្នកឈ្លាសវៃទាំងឡាយ ពោលថា ប្រាជ្ញាជាគុណជាតដ៏ប្រសើរបំផុត ដូចស្តេចនៃផ្កាយ ( ព្រះចន្ទ្រ ) ដ៏ប្រសើរជាងផ្កាយទាំងឡាយ ដូច្នេះ ។

ហើយបញ្ញាជាអ្នកនាំមុខនៃកុសលធម៌ទាំងឡាយ ព្រោះអត្ថថា ជាប្រធាន ដូចត្រាស់ថា

ទុកជាសីលក្តី សិរីក្តី ធម៌របស់សប្បុរសក្តី ក៏ប្រព្រឹត្តទៅតាមបុគ្គលអ្នកមានប្រាជ្ញា ដូច្នេះ ។

បញ្ញា ឈ្មោះថា ជាធម្មជាតទាក់ទង ដូចចន្ទោលនង្គ័ល ព្រោះមិនកើតឡើងដោយប្រាសចាកហិរិ ជាទីតោងនៃខ្សែទាំងឡាយ ដោយនិស្សយ-ប្បច្ច័យនៃខ្សែ គឺសមាធិ ពោល គឺចិត្ត រមែងទ្រទ្រង់នូវការទៅរួមគ្នានៃគោ គឺសេចក្តីព្យាយាម ព្រោះបដិសេធការប្រារព្ធសេចក្តីព្យាយាមខ្ជាំង និងធូរថយពេក ។

នង្គ័លប្រកបដោយផាលហើយ រមែងទម្លាយដី ក្នុងពេលភ្ជួរ រមែងទម្លាយនូវពូជដែលមានឫស យ៉ាងណា បញ្ញាដែលប្រកបដោយសតិក៏ដូច្នោះ រមែងទម្លាយនូវដុំនៃអារម្មណ៍ ដែលមានកិច្ចប្រជុំបន្តនៃធម៌ទាំងឡាយ ក្នុងវេលា ( ចម្រើន ) វិបស្សនា រមែងទម្លាយនូវការបន្តនៃកិលេសមូលទាំងអស់ បញ្ញាដែលប្រកបដោយសតិនោះឯង ជាលោកុត្តរតែម្យ៉ាង ឯបញ្ញាក្រៅអំពីនេះ គប្បីជាលោកិយ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **បញ្ញា មេ យុគនង្គលំ** ដូច្នេះ ។

ឈ្មោះថា ហិរិ ព្រោះអត្ថវិគ្គហៈថា ជាគ្រឿងខ្មាសរបស់បុគ្គល ឬបុគ្គលរមែងខ្មាសឯង គឺខ្ពើមនូវការប្រព្រឹត្តិទៅនៃអកុសល ឱត្តប្បៈ ឈ្មោះថាកាន់យកហើយដោយ **ហិរិ** សព្ទនោះ ដោយភាពជាធម៌មិនទៅរួមគ្នា ។ បទថា **ឦសា** បានដល់ ដុំឈើដែលទ្រទ្រង់នូវនឹម និងនង្គ័ល ។ ប្រៀបដូចចន្ទោលនង្គ័លរបស់ព្រាហ្មណ៍ រមែងទ្រទ្រង់នូវនឹម និងនង្គ័ល យ៉ាងណា ហិរិរបស់ព្រះដ៏មានព្រះភាគក៏ដូច្នោះ ឈ្មោះថា រមែងទ្រទ្រង់នូវនឹម និងនង្គ័ល ពោល គឺលោកិយប្បញ្ញា និងលោកុត្តរប្បញ្ញា ព្រោះកាលហិរិមិនមាន បញ្ញា

ក៏មិនមាន នឹម និងនង្គ័ល ដែលទាក់ទងដោយចន្ទោល រមែងធ្វើកិច្ចបាន មិនញាប់ញ័រ មិនធូរថយ យ៉ាងណា បញ្ញាដែលទាក់ទងដោយហិរិ ក៏ដូច្នោះ រមែងធ្វើកិច្ចដែលមិនឲ្យញាប់ញ័រ មិនធូរថយ មិនឃ្លៀងឃ្លាត ដោយការមិនមានហិរិ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **ហិរិ ឦសា** ដូច្នេះ ។

ឈ្មោះថា **មនោ** ដោយអត្ថវិគ្គហៈថា រមែងដឹង ពាក្យថា **មនោ** នោះ ជាឈ្មោះរបស់ចិត្ត សមាធិដែលប្រកបព្រមជាមួយចិត្តនោះ ដោយចិត្តជាប្រធាន ទ្រង់បំណាងយកក្នុងគាថានេះ ។ បទថា **យោត្តំ** បានដល់ ចំណង គឺខ្សែ ។ ខ្សែនោះមាន ៣ យ៉ាង គឺខ្សែដែលចងនឹមនឹងចន្ទោល ១ ខ្សែដែលចងគោទាំងឡាយនឹងនឹម ១ ខ្សែចងគោទាំងឡាយនឹងសារថី ១ ។ ក្នុងខ្សែ ៣ យ៉ាងនោះ ខ្សែរបស់ព្រាហ្មណ៍ធ្វើចន្ទោល នឹម និងគោទាំងឡាយឲ្យជាប់គ្នា រមែងញុំាងកិច្ចរបស់ខ្លួនឲ្យសម្រេចយ៉ាងណា សមាធិរបស់ព្រះដ៏មានព្រះភាគ ចងធម៌ គឺហិរិ បញ្ញា និងវិរិយៈទាំងអស់នោះឯង ឲ្យមានអារម្មណ៍តែមួយ ដោយភាពជាធម៌មិនរាយមាយ រមែងញុំាងកិច្ចរបស់ខ្លួនឲ្យសម្រេច ដូច្នោះ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **មនោ យោត្តំ** ដូច្នេះ ។

ឈ្មោះថា **សតិ** ព្រោះអត្ថវិគ្គហៈថា ជាគ្រឿងរឭករបស់បុគ្គល ឬបុគ្គលរឭកដល់រឿង ដែលធ្វើយូរហើយជាដើមបានដោយខ្លួនឯង ។ សតិនោះ មានការមិនវង្វេងជាលក្ខណៈ ។ ធម្មជាតណា រមែងឲ្យដីបែក ព្រោះ

ហេតុនោះ ធម្មជាតនោះ ឈ្មោះថា **ផាល** បុគ្គលរមែងចាក់ដោយវត្ថុនោះ ព្រោះហេតុនោះ វត្ថុនោះ ឈ្មោះថា **ចាចនំ** ជន្ទួញនោះ ហៅថា **ចាចនំ** ក្នុងគាថានេះ ។ ពាក្យថា **ចាចនំ** នោះ ជាឈ្មោះរបស់វត្ថុសម្រាប់ចាក់ ។ ផាល និងជន្ទួញ ឈ្មោះថា **ផាលចាចនំ ។** ផាល និងជន្ទួញរបស់ព្រាហ្មណ៍ យ៉ាងណា សតិដែលប្រកបដោយវិបស្សនា និងប្រកបដោយមគ្គរបស់ព្រះដ៏មានព្រះភាគ ក៏យ៉ាងនោះ ។

ក្នុងសេចក្តីនោះ ផាលរមែងតាមរក្សានង្គ័ល និងទៅខាងមុខរបស់នង្គ័លនោះ យ៉ាងណា សតិ ក៏ដូច្នោះ ជាទីទៅរបស់កុសលធម៌ទាំងឡាយ រឭកព្រម ឬឲ្យអារម្មណ៍ទាំងឡាយប្រាកដឡើង ឈ្មោះថា រមែងរក្សានង្គ័ល គឺបញ្ញា ។ ពិតហើយ សតិ លោកហៅថា **អារក្ខា** ដូចក្នុងប្រយោគជាដើមថា ភិក្ខុនៅដោយភាពជាអ្នកមានចិត្តរក្សាស្មារតី ដូច្នេះ និងរមែងនាំមុខបញ្ញានោះ ដោយអំណាចការមិនវង្វេង ព្រោះបញ្ញារមែងដឹងច្បាស់នូវធម៌ទាំង-ឡាយ មានសតិសន្សំហើយ រមែងមិនដឹងច្បាស់នូវធម៌ទាំងឡាយ មានការមិនមានសតិជាដើម ដូចជន្ទួញបង្ហាញនូវភ័យ គឺការចាក់ដល់គោទាំងឡាយ រមែងមិនឲ្យឈប់ និងរមែងឃាត់ការចេញក្រៅគន្លង យ៉ាងណា សតិក៏ដូច្នោះ សម្តែងនូវភ័យក្នុងអបាយដល់គោ គឺវិរិយៈ រមែងមិនឲ្យលិចក្នុងការខ្ជិលប្រអូស រមែងហាមនូវអគោចរទាំងឡាយ ពោល គឺកាមគុណ កាលហាមហើយ រមែងឲ្យប្រកបក្នុងកម្មដ្ឋាន និងរមែងហាមការទៅក្រៅគន្លង ព្រោះ

ហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **សតិ មេ ផាលបាចនំ** ដូច្នេះ ។

បទថា **កាយគុត្តោ** សេចក្តីថា គ្រប់គ្រងកាយដោយសុចរិត ៣ ។ បទថា **វចីគុត្តោ** សេចក្តីថា គ្រប់គ្រងដោយវចីសុចរិត ៤ យ៉ាង ។ បាតិមោក្ខសំវរសីល ត្រាស់ហើយដោយពាក្យមានប្រមាណប៉ុណ្ណេះ ក្នុងបទថា **អាហារេ ឧទរេ យតោ** នេះ ជាអ្នកសង្រួម គឺសង្រួមព្រមហើយ អធិប្បាយថា មិនមានឧបក្កិលេសក្នុងបច្ច័យ ៤ យ៉ាង ព្រោះបច្ច័យទាំងអស់ ទ្រង់សង្គ្រោះហើយដោយអាហារជាប្រធាន ។ អាជីវបារិសុទ្ធិសីល ត្រាស់ហើយដោយបទនេះ ។ បទថា **ឧទរេ យតោ** សេចក្តីថា សង្រួម គឺសង្រួមព្រមហើយក្នុងផ្ទៃ គឺបរិភោគមានកំណត់ អធិប្បាយថា ដឹងប្រមាណក្នុងអាហារ ។ បច្ចយបដិសេវនសីល ត្រាស់ហើយដោយភាពជាអ្នកដឹងប្រមាណក្នុងភោជនជាប្រធាន ដោយបទនេះ ។

ព្រះដ៏មានព្រះភាគទ្រង់សម្តែងអ្វីដោយបទនោះ ទ្រង់សម្តែងថា ម្នាលព្រាហ្មណ៍ អ្នកព្រោះពូជហើយរមែងស្រះបន្ទា យកឈើធ្វើរបង ឬព័ទ្ធដោយកំពែងដើម្បីរក្សាស្រូវដោយរបងនោះ ហ្វូងគោ ក្របី និងម្រឹគ កាលមិនបានការចូលទៅ រមែងមិនដណ្តើមស៊ីស្រូវរបស់អ្នកយ៉ាងណា តថាគតក៏ដូច្នោះព្រោះនូវពូជ គឺសទ្ធានោះហើយ ធ្វើនូវការព័ទ្ធរបង ៣ យ៉ាង ដែលសម្រេចអំពីការគ្រប់គ្រងកាយ វាចា និងអាហារដើម្បីរក្សាស្រូវ គឺកុសលដែលមានប្រការផ្សេងៗ ដោយការព័ទ្ធនោះ ហ្វូងគោ ក្របី និងម្រឹគ គឺអកុសលធម៌

មានរាគៈជាដើម កាលមិនបានការចូលទៅ រមែងមិនដណ្ដើមស៊ីនូវស្រូវ គឺ កុសលដែលមានប្រការផ្សេងៗ របស់តថាគត ដូច្នេះ ។

ក្នុងបទថា **សច្ចំ ករោមិ និទ្ទានំ** នេះ ការកាត់ ការច្រូត ការដកឡើង ឈ្មោះថា ការដកស្មៅ ដោយសច្ចៈ គឺមិនពោលឲ្យខុសដោយទ្វារទាំងពីរ ។ ពាក្យថា **សច្ចំ** នោះជាទុតិយាវិភត្តិ គប្បីជ្រាបថា ប្រើក្នុងអត្ថនៃតតិយាវិភត្តិ ។ អត្ថក្នុងបទថា **សច្ចំ ករោមិ និទ្ទានំ** នោះ មានដូច្នេះថា **សច្ចេន ករោមិ និទ្ទានំ** ។ មានអធិប្បាយដូចម្ដេច មានអធិប្បាយថា អ្នកភ្ជួរស្រែខាងក្រៅ ហើយ រមែងធ្វើនូវការដកស្មៅដែលបៀតបៀននូវសម្ទូងដោយដៃ ឬដោយ កណ្ដៀវ យ៉ាងណា តថាគតក៏ដូច្នោះ ភ្ជួរស្រែដែលមានខាងក្នុងហើយ រមែង ធ្វើនូវការដកស្មៅ គឺការពោលឲ្យឃ្លាតចាកសំឡេងពិត ដែលបៀតបៀននូវ សម្ទូង គឺកុសលដោយសច្ចៈ ។ ម្យ៉ាងទៀត ញាណសច្ចៈ ដែលហៅថា យថាភូតញ្ញាណ គប្បីជ្រាបថា សច្ចៈក្នុងបទថា **សច្ចំ ករោមិ និទ្ទានំ** នេះ ។ អ្នកសិក្សាគប្បីប្រកបសេចក្ដីយ៉ាងនេះថា តថាគតធ្វើនូវការដកស្មៅទាំង-ឡាយ មានអត្តសញ្ញាជាដើម ដោយសច្ចៈនោះ ។

ម្យ៉ាងទៀត បទថា **និទ្ទានំ** បានដល់ ការកាត់ ការច្រូត អធិប្បាយថា ការដក ។ កាលបើយ៉ាងនោះ អ្នករមែងឲ្យទោសៈ ឬកម្មករធ្វើនូវការដកថា ចូរអ្នកដកស្មៅទាំងឡាយ គឺឲ្យធ្វើនូវការកាត់ ការច្រូត ការដកនូវស្មៅទាំង-ឡាយ យ៉ាងណា តថាគតរមែងធ្វើនូវសច្ចៈ ដូច្នោះ ។ ការពោលដោយ

ទុតិយាវិកត្តិនោះឯង ក៏គួរ ។

ម្យ៉ាងទៀត បទថា **សច្ចំ** បានដល់ ទិដ្ឋិសច្ចៈ ។ ការពោលដោយទុតិយាវិកត្តិនោះឯង យ៉ាងនេះថា តថាគតរមែងធ្វើនូវការជកនោះ គឺរមែងធ្វើកិច្ចដែលគប្បីកាត់ គប្បីប្រូត គប្បីជកឡើងដូច្នេះ ក៏គួរ ។

ក្នុងបទថា **សោរច្ចំ មេ បមោចនំ** នេះ សីលនោះយ៉ាងនេះថា ការមិនល្មើសផ្លូវកាយ ការមិនប្រព្រឹត្តកន្លងផ្លូវវាចានោះឯង ហៅថា **សោរច្ច** ការស្ងប់ស្ងៀម សីលនោះ មិនបំណងយកក្នុងគាថានេះ សីលនោះ បានពោលហើយដោយន័យជាដើមថា គ្រប់គ្រងកាយ តែអរហត្តផលដែលលោកបំណងហើយ ព្រោះថា អរហត្តផលនោះ ហៅថា **សោរច្ច** ព្រោះព្រះដ៏មានព្រះភាគទ្រង់ត្រេកអរហើយក្នុងនិព្វានដែលជាសុន្ទរៈ ។ បទថា **បមោចនំ** បានដល់ជាគ្រឿងលះនូវការប្រកប ។

សេចក្ដីនេះ មានអធិប្បាយដូចម្ដេច មានអធិប្បាយថា ការឈប់របស់អ្នកមិនទាន់ជាការឈប់ឡើយ ព្រោះអ្នកគប្បីប្រកបក្នុងពេលល្ងាច ក្នុងថ្ងៃទី ២ ឬក្នុងឆ្នាំខាងមុខទៀត យ៉ាងណា ការឈប់របស់តថាគតមិនដូច្នោះឡើយ ព្រោះឈ្មោះថា ការឈប់ក្នុងរវាងរបស់តថាគតមិនមាន ដ្បិតថា តថាគតបានប្រកបគោ គឺវីរិយៈទាំងឡាយ ក្នុងនង្គ័ល គឺបញ្ញា ចាប់តាំងពីកាលនៃព្រះទសពលព្រះនាមទីបង្ករ ភ្ជួរនូវការភ្ជួរធំអស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប មិនទាន់ឈប់ ដរាបណាតថាគតនៅមិនបានត្រាស់ដឹងប្រពៃដោយ

ចំពោះនូវសម្មាសម្ពោធិញ្ញាណ ក្នុងកាលណាអរហត្តផល ដែលមានគុណទាំងអស់ជាបរិវារ បានកើតឡើងហើយដល់តថាគត ដែលញ៉ាំងកាលទាំងអស់នោះឲ្យអស់ទៅហើយ អង្គុយលើអបរាជិតបល្ល័ង្កទៀបគល់ពោធិព្រឹក្សក្នុងកាលនោះ ការឈប់នោះរបស់តថាគត បានឈប់ហើយ ដោយការសម្រេចនូវការស្ងប់រម្ងាប់នៃការក្រវល់ក្រវាយទាំងអស់ និងមិនជាកិច្ចដែលគប្បីប្រកបទៀតក្នុងកាលឥឡូវនេះ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគទ្រង់សំដៅដល់អត្ថនោះ ត្រាស់ថា **សោរច្ចំ មេ បមោចនំ** ដូច្នេះ ។

ក្នុងបទថា **វីរិយំ មេ ធុរធោរយ្ហំ** នោះ បទថា **វីរិយំ** បានដល់ បធាន គឺសេចក្ដីព្យាយាមដែលពោលហើយ ដោយន័យជាដើមថា ប្រារព្ធព្យាយាមតាមផ្លូវកាយ ឬផ្លូវចិត្ត ។ ការនាំធុរៈទៅដើម្បីធុរៈ ឈ្មោះថា **ធុរធោរយ្ហំ** អធិប្បាយថា រមែងនាំធុរៈទៅ ។ ដូចនង្គ័លរបស់ព្រាហ្មណ៍ ត្រូវវត្ថុនាំធុរៈទៅដើម្បីធុរៈ ( គោ ) អូសមកទម្លាយនូវផែនដី បំបែកនូវពូជ ដែលមានឫសទាំងអស់ទៅ យ៉ាងណា នង្គ័ល គឺបញ្ញានៃព្រះដ៏មានព្រះភាគ ក៏ដូច្នោះទាញមកដោយសេចក្ដីព្យាយាម ទម្លាយនូវផែនដី តាមដែលពោលហើយ និងបំបែកកិលេសសន្តានទាំងឡាយឲ្យអស់ទៅ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **វីរិយំ មេ ធុរធោរយ្ហំ** ដូច្នេះ ។

ម្យ៉ាងទៀត កាលនាំទៅនូវធុរៈដែលមានក្នុងកាលមុន ឈ្មោះថា **ធុរា** កាលនាំទៅនូវមូលធុរៈ ឈ្មោះថា **ធោរយ្ហា** ធុរាផង ធុរយ្ហាផង ឈ្មោះថា

**ធុរធោរយ្ហំ** ។ ក្នុងសេចក្ដីនោះ វត្ថុនាំធុរៈទៅដើម្បីធុរៈ មានគោ ៤ ជាប្រភេទ ដែលភ្ជួរក្នុងនង្គ័លនីមួយៗ របស់ព្រាហ្មណ៍ កាលនាំទៅរមែងញ៉ាំងការទម្លាយឫសស្មៅ ដែលកើតហើយ និងមិនទាន់កើត និងសម្បត្តិ គឺសម្ទូងឲ្យសម្រេច យ៉ាងណា នាំធុរៈទៅដើម្បីធុរៈ មានការព្យាយាម គឺសម្មប្បធាន ៤ ដែលជាប្រភេទរបស់ព្រះដ៏មានព្រះភាគ ក៏ដូច្នោះ កាលនាំទៅ រមែងញ៉ាំងការទម្លាយអកុសលមូលដែលកើតឡើង និងមិនទាន់កើតឡើង និងសម្បត្តិ គឺកុសលឲ្យសម្រេច ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **វីរិយំ មេ ធុរធោរយ្ហំ** ដូច្នេះ ។

ក្នុងបទថា **យោគក្ខេមាធិវាហនំ** នេះ និព្វាន ហៅថា **យោគក្ខេម** ព្រោះនិព្វានជាធម៌ក្សេមចាកយោគៈទាំងឡាយ សេចក្ដីព្យាយាមនោះ ឈ្មោះថា **អធិវាហន** ព្រោះអត្ថវិគ្គហៈថា ដែលបុគ្គលសម្រេចហើយរមែងនាំទៅ ឬរមែងនាំទៅចំពោះមុខ ការនាំទៅដល់ដែនក្សេមចាកយោគៈ ឈ្មោះថា **យោគក្ខេមាធិវាហនំ** ព្រះដ៏មានព្រះភាគទ្រង់សម្ដែងអ្វីដោយបទនោះ ទ្រង់សម្ដែងថា វត្ថុនាំធុរៈទៅដើម្បីធុរៈ ( គោ ) របស់អ្នក រមែងនាំទៅចំពោះមុខ កាន់ទិសខាងកើត ឬទិសណាមួយ ក្នុងទិសទាំងឡាយ មានទិសខាងលិចជាដើម យ៉ាងណា វត្ថុនាំធុរៈទៅដើម្បីធុរៈ ( សេចក្ដីព្យាយាម ) របស់តថាគត ក៏ដូច្នោះ រមែងត្រូវនាំឲ្យបែរមុខឆ្ពោះទៅកាន់ព្រះនិព្វាន កាលនាំទៅយ៉ាងនេះ ឈ្មោះថា **អនិវត្តន្តំ** ។ វត្ថុនាំធុរៈទៅដើម្បីធុរៈ នាំនង្គ័លរបស់

អ្នកទៅដល់ទីបំផុតស្រែហើយ ត្រឡប់មកវិញ យ៉ាងណា ឯសេចក្ដីព្យាយាមរបស់តថាគត ឈ្មោះថា មិនវិលត្រឡប់មក ចាប់តាំងអំពីព្រះពុទ្ធព្រះនាមទីបង្ករ ដូច្នោះ ។

ម្យ៉ាងទៀត ព្រោះកិលេសទាំងឡាយ ដែលមគ្គនោះៗ លះហើយមិនគប្បីលះទៀត ដូចស្មៅទាំងឡាយដែលនង្គ័លរបស់អ្នកកាត់ផ្ដាច់ហើយ គប្បីកាត់ក្នុងសម័យដទៃទៀត ព្រោះហេតុនោះ សេចក្ដីព្យាយាមនោះ ដើម្បីលះនូវកិលេសទាំងឡាយ ដែលតាំងនៅក្នុងឋានៈតែមួយជាមួយនិងទិដ្ឋិ ដោយអំណាចនៃបឋមមគ្គ លះនូវកិលេសទាំងឡាយគ្រោតគ្រាត ដោយអំណាចមគ្គទី ២ លះនូវកិលេសទាំងឡាយដែលល្អិតដោយអំណាចមគ្គទី ៣ លះនូវកិលេសទាំងអស់ដោយអំណាចមគ្គទី ៤ ឈ្មោះថា **អនុវត្តន្តំ** ដូច្នេះ ។

ម្យ៉ាងទៀត បទថា **គច្ឆតិ អនិវត្តន្តំ** សេចក្ដីថា ជាការវៀរចាកការត្រឡប់ គឺរមែងទៅ ។ បទថា **តំ** បានដល់ វត្ថុនាំធុរៈទៅដើម្បីធុរៈនោះ ។ គប្បីជ្រាបការកាត់បទក្នុងពាក្យនេះយ៉ាងនេះ ។ វត្ថុនាំធុរៈទៅដើម្បីធុរៈរបស់អ្នកនោះ កាលទៅយ៉ាងនេះ រមែងមិនដល់ស្ថានទីដែលអ្នកភ្ជួរទៅហើយ មិនសោក ប្រាសចាកសេចក្ដីសោក ប្រាសចាកតម្រេក មិនសោកស្ដាយ ឯសេចក្ដីព្យាយាមនោះ រមែងដល់ស្ថានទីនោះ ។

បទថា **យត្ថ គន្ត្វា ន សោចតិ** សេចក្ដីថា វត្ថុនាំធុរៈទៅដើម្បីធុរៈគឺវិរិយៈនោះ ដែលជន្ទួញ គឺសតិជាស់តឿនទៅហើយ រមែងដូចគ្នានឹងអ្នក

ស្រែដែលមិនសោក ប្រាសចាកសេចក្តីសោក ប្រាសចាកតម្រេក មិនសោកស្តាយ ក្នុងស្ថានទីណា សេចក្តីព្យាយាមនោះ រមែងដល់ស្ថានទីនោះ ពោលគឺអមតមហានិព្វាន ដែលជាការដកឡើងនូវសរ គឺសេចក្តីសោកទាំងអស់ ។

ឥឡូវនេះ ព្រះដ៏មានព្រះភាគកាលទ្រង់ធ្វើពាក្យនិគម ទើបត្រាស់ព្រះគាថានេះថា

> ការភ្ជួររាស់ដែលតថាគត ភ្ជួររាស់ហើយយ៉ាងនេះ ជាគុណជាត
> មានផលមិនចេះស្លាប់ទេ បុគ្គលធ្វើនូវការភ្ជួររាស់បែបនុ៎ះ ទើប
> រួចចាកទុក្ខទាំងពួង ដូច្នេះ ។

គាថានោះ មានអត្ថដោយសង្ខេបដូច្នេះថា ម្នាលព្រាហ្មណ៍ ចូរអ្នកមើលការភ្ជួរស្រែនោះ មានសទ្ធាជាពូជ កាលសេចក្តីព្យាយាមជាភ្លៀងអនុគ្រោះហើយ តថាគតធ្វើនឹម និងនង្គ័លដែលសម្រេចហើយដោយបញ្ញា និងចន្ទោលដែលសម្រេចហើយដោយហិរិ ឲ្យជាប់តគ្នាដោយខ្សែដែលសម្រេចហើយអំពីចិត្ត ជន្ទួញ ផាល គឺសតិ ក្នុងនង្គ័ល គឺបញ្ញា ចាប់នូវជន្ទួញ គឺសតិ គ្រប់គ្រងដោយការគ្រប់គ្រងកាយ វាចា និងអាហារ ធ្វើនូវការដកស្មៅដោយសច្ចៈ ធ្វើនូវការស្ងប់ស្ងៀម ជាគ្រឿងបញ្ឈប់កិលេស សេចក្តីព្យាយាម ជាវត្ថុនាំធុរៈទៅដើម្បីធុរៈ នាំទៅរហូតដល់ដែនក្សេមចាកយោគៈ មិនវិលត្រឡប់មកភ្ជួរទៀតឡើយ ឲ្យដល់សាមញ្ញផល ៤ ដែលជាទីបំផុតនៃកសិកម្ម ។

បទថា **សា ហោតិ អមតប្ផលា** សេចក្តីថា ការភ្ជួរនេះ មានផលជាអមតៈ ។ និព្វាន ហៅថា **អមត** អធិប្បាយថា ការភ្ជួរស្រែមាននិព្វានជាអានិសង្ស ឯការភ្ជួរនោះ រមែងមានផលជាអមតៈ សម្រាប់តថាគតម្នាក់ឯងប៉ុណ្ណោះ ក៏មិនមែន តែដោយពិត បុគ្គលណាមួយ ក្សត្រក្តី ព្រាហ្មណ៍ក្តី វេស្សៈក្តី សូទ្រៈក្តី គ្រហស្ថក្តី បព្វជិតក្តី រមែងភ្ជួរស្រែនោះ មនុស្សទាំងអស់នោះ កាលភ្ជួរស្រែនោះហើយ រមែងផុតចាកទុក្ខទាំងពួង គឺរមែងផុតចាកវដ្តទុក្ខ ទុក្ខទុក្ខ សង្ខារទុក្ខ វិបរិណាមទុក្ខទាំងពួង ព្រះដ៏មានព្រះភាគទ្រង់ធ្វើនិព្វានជាទីបំផុតដោយកំពូល គឺ អរហត្ត ទ្រង់ញ៉ាំងទេសនាឲ្យដល់ព្រមដល់ព្រាហ្មណ៍ ដោយប្រការដូច្នេះ ។

លំដាប់នោះ ព្រាហ្មណ៍ស្តាប់ទេសនា ដែលមានអត្ថជ្រាលជ្រៅហើយ បានជ្រាបថា អាត្មាអញបរិភោគផលនៃការភ្ជួរស្រែហើយ រមែងមានការស្រេកឃ្លានក្នុងថ្ងៃដទៃនោះឯង តែការភ្ជួរស្រែរបស់សមណៈនេះ មានផលជាអមតៈ បុគ្គលបរិភោគផលនៃការភ្ជួរស្រែនោះ រមែងផុតចាកទុក្ខទាំងពួងដូច្នេះ ជ្រះថ្លាហើយ ប្រារព្ធហើយ ដើម្បីធ្វើអាការនៃបុគ្គលជ្រះថ្លា ដើម្បីថ្វាយបាយាស ព្រោះហេតុនោះ ទើបព្រះអានន្ទត្ថេរពោលថា លំដាប់នោះឯង កសិភារទ្វាជៈ ដូច្នេះជាដើម ។

[ ៦ ] បណ្តាបទទាំងនោះ បទថា **មហតិយា** បានដល់ ថាសធំ ។ បទថា **កំសបាតិយា** បានដល់ ក្នុងថាសមាស គឺក្នុងថាសមាសរបស់ខ្ទួន

ដែលមានតម្លៃមួយសែនកហាបណៈ ។ បទថា **វេឡ្លិតា** បានដល់ ជួសហើយ អធិប្បាយថា កៀរទម្លាក់ហើយ ។ បទថា **ភគវតោ ឧបនាមេសិ** សេចក្តីថា ធ្វើឲ្យវិចិត្រដោយសប្បិ ទឹកឃ្មុំ និងទឹកអំពៅជាដើម ដណ្តប់ដោយសំពត់ លើកឡើងហើយ បង្អោនថ្វាយដល់ព្រះតថាគតដោយគោរព ។ សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា សូមព្រះសមណគោតមសោយនូវបាយាសចុះ ព្រោះទ្រង់ជាអ្នកស្រែ ។ បន្ទាប់អំពីនោះ បានពោលដល់ហេតុដែលឲ្យសម្រេចភាពជាអ្នកស្រែថា រមែងភ្ជួរស្រែដែលមានផលជាអមតៈ អធិប្បាយថា ព្រោះរមែងភ្ជួរស្រែដែលមានផលមិនស្លាប់ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់ថា **គាថាភិគីតម្មេ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **គាថាភិគីតំ** បានដល់ ច្រៀងដោយគាថាទាំងឡាយ អធិប្បាយថា ពោលគាថាទាំងឡាយ ហើយបានមក ។ បទថា **មេ** បានដល់ **មយា** ប្រែថា ដែលតថាគត ។ បទថា **អភោជនេយ្យំ** សេចក្តីថា មិនគួរបរិភោគ ។ បទថា **សម្បស្សតំ** សេចក្តីថា ជាអ្នកឃើញនូវអាជីវៈបរិសុទ្ធដោយប្រពៃ ឬជាអ្នកឃើញដោយជុំវិញ ឈ្មោះថា ជាអ្នកឃើញដោយជុំវិញ អធិប្បាយថា ព្រះពុទ្ធទាំងឡាយ ។ បទថា **នេស ធម្មោ** សេចក្តីថា ពាក្យថា តថាគតគួរបរិភោគភោជនដែលច្រៀងបានមក នេះមិនមែនធម៌ គឺនុ៎ះមិនមែនជាការប្រព្រឹត្ត ព្រោះហេតុអ្វី ព្រោះពុទ្ធទាំងឡាយទ្រង់រមែងហាមភោជនដែលច្រៀងបានមក គឺទ្រង់រមែងបដិសេធ រមែងមិនសោយ ។

សួរថា ព្រះដ៏មានព្រះភាគទ្រង់ច្រៀងនូវគាថា ដើម្បីបាយាសដែលជាហេតុឲ្យត្រាស់យ៉ាងនេះឬ ឆ្លើយថា ទ្រង់មិនច្រៀងគាថាដើម្បីប្រយោជន៍ដល់បាយាសនោះ តែដោយពិត ភោជនដែលទ្រង់ប្រថាប់ឈរក្នុងទីជិតស្រែអំពីព្រលឹម ទ្រង់មិនបានភិក្ខាសូម្បីមួយវែកឡើយ ប្រកាសគុណរបស់ព្រះពុទ្ធទាំងពួង បានមកនេះ ដូចគ្នានឹងភោជនដែលអ្នកច្រៀង និងអ្នករាំទាំងឡាយ ច្រៀងនិងរាំបានមក ព្រោះហេតុនោះ ទើបត្រាស់ថា ដែលច្រៀងបានមក ។ ក្នុងភោជនបែបនោះ រមែងមិនគួរដល់ព្រះពុទ្ធទាំងឡាយ ព្រោះហេតុនោះ ទើបត្រាស់ថា តថាគតមិនគួរបរិភោគភោជន ។ ភោជននោះ មិនសមគួរដល់អ្នកប្រាថ្នាតិច ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់អនុគ្រោះជនឯក្រោយ ទើបត្រាស់ថា តថាគតមិនគួរបរិភោគភោជនដែលច្រៀងបានមក ។ ព្រះពុទ្ធទាំងឡាយទ្រង់បដិសេធលាភដែលកើតឡើងដោយគុណរបស់ខ្លួន ដែលអ្នកដទៃប្រកាសហើយក្នុងទីណាមួយ ដូចយជិការកូនស្នូនឆ្មាំង ដែលមានសេចក្តីប្រាថ្នាតិច ដូច្នោះ ។

សួរថា ព្រះដ៏មានព្រះភាគទ្រង់ដល់ព្រមដោយភាពជាអ្នកប្រាថ្នាតិចដល់ទីបំផុតហើយ ទ្រង់នឹងត្រេកអរលាភដែលកើតឡើងហើយ ដោយការប្រកាសគុណរបស់ព្រះអង្គ ដោយព្រះអង្គឯងបានដូចម្តេច ព្រោះព្រះដ៏មានព្រះភាគ ត្រាស់ពាក្យទុំសមហើយនោះឯងក្នុងកាល ។ ឆ្លើយថា ដោយពាក្យមានប្រមាណប៉ុណ្ណោះ ទ្រង់កាលដោះខ្លួនចាកពាក្យតំណិះដំណៀលរបស់

សត្វលោកថា ព្រះសមណគោតមធ្វើព្រាហ្មណ៍ ដែលមិនជ្រះថ្លា មិនបំណង នឹងឲ្យ ឲ្យជាអ្នកប្រាថ្នាដើម្បីថ្វាយ ដោយការត្រាស់គាថា ហើយទ្រង់ទទួល ភោជន ធម្មទេសនារបស់ព្រះគោតមនេះ មានអាមិសជាហេតុ ដូច្នេះហើយ ទ្រង់សម្តែងទេសនា បារិសុទ្ធិ ឥឡូវនេះ កាលទ្រង់សម្តែងអាជីវៈបរិសុទ្ធ ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ កាលបើធម៌មាននៅ ការស្វែងរកនេះ ជាការ ប្រព្រឹត្តចិញ្ចឹមជីវិត ដូច្នេះ ។

អត្ថនៃព្រះតម្រាស់នោះថា ម្នាលព្រាហ្មណ៍ កាលអាជីវៈបារិសុទ្ធិធម៌ ឬសុចរិតធម៌ ១០ យ៉ាង ឬចារិតធម៌របស់ព្រះពុទ្ធទាំងឡាយមាននៅ គឺ មានព្រម ជាប់តាមព្រម ប្រព្រឹត្តទៅ ការស្វែងរក គឺការត្រាច់ស្វែងរក ដ៏ស្អាត ដោយចំណែកមួយ ដូចលាបាតដៃក្នុងអាកាស នេះជាការប្រព្រឹត្តិ គឺ ជាការប្រព្រឹត្តប្រចាំជីវិតរបស់ព្រះពុទ្ធទាំងឡាយ ។

កាលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ ព្រាហ្មណ៍កើតទោមនស្ស ថា ព្រះគោតមទ្រង់បដិសេធបាយាសរបស់អញ បានឮថា ភោជននោះ មិនគួរ កាលបើដូច្នេះ អញរមែងមិនបានថ្វាយវត្ថុដទៃដល់ព្រះអង្គឡើយ និង គិតបន្តទៀតថា ព្រះសមណគោតមគប្បីទទួលរបស់ដទៃទេដឹង ដូច្នេះ ព្រះ ដ៏មានព្រះភាគទ្រង់ជ្រាបដូច្នោះ ទ្រង់ត្រិះរិះថា តថាគតកំណត់ពេលដើម្បី ភិក្ខាចារហើយទើបមក ដោយគិតថា នឹងញុំាងព្រាហ្មណ៍នេះឲ្យជ្រះថ្លាដោយ កាល មានប្រមាណប៉ុណ្ណោះ តែព្រាហ្មណ៍នេះបានធ្វើនូវទោមនស្ស ឥឡូវនេះ

ព្រាហ្មណ៍ ញុំាងចិត្តឲ្យករម្រើកក្នុងតថាគត ដោយទោមនស្សនោះហើយ មិនអាចចាក់ធ្លុះនូវធម៌ប្រសើរ គឺអមតៈ កាលញុំាងមនោរថដែលព្រាហ្មណ៍ប្រាថ្នាឲ្យពេញដើម្បីឲ្យការជ្រះថ្លា កើតដល់ព្រាហ្មណ៍ ទើបត្រាស់ថា **អញ្ញេន ច កេវលិនំ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កេវលិនំ** សេចក្ដីថា ជាអ្នកបរិបូណ៌ហើយដោយគុណទាំងពួង គឺប្រាសចាកយោគៈទាំងអស់ហើយ ។ ឈ្មោះថា **មហេសី** ព្រោះស្វែងរកគុណទាំងឡាយ មានសីលក្ខន្ធជាដើមដ៏ធំ ឈ្មោះថា **ខីណាសវំ** ព្រោះភាពជាបុគ្គលមានអាសវៈទាំងពួងអស់ហើយ ឈ្មោះថា **កុក្កុច្ចវូបសន្តំ** ព្រោះភាពដែលព្រះខីណាស្រពមានសេចក្ដីឃ្លើសឃ្លងទាំងពួង មានការឃ្លើសឃ្លងដៃជើងជាដើមស្ងប់ហើយ ។ បទថា **ឧបដ្ឋហស្សុ** សេចក្ដីថា ចូរអ្នកអង្គាស ចូរអ្នករាប់អាន ។ កាលចិត្តព្រាហ្មណ៍កើតយ៉ាងនេះហើយ ទ្រង់ត្រាស់បរិយាយប៉ុណ្ណោះ តែមិនត្រាស់ថា ចូរអ្នកនាំមក ដូច្នេះ ។ បទដ៏សេសក្នុងគាថានេះ មានអត្ថងាយ យល់ទាំងអស់ហើយ ។

[ ៧ ] លំដាប់នោះ ព្រាហ្មណ៍គិតថា បាយាសនេះអញនាំមកដើម្បីព្រះដ៏មានព្រះភាគ អញមិនគួរឲ្យបាយាសនោះ ដល់បុគ្គលណាម្នាក់ តាមការគាប់ចិត្តរបស់ខ្លួន ដូច្នេះហើយ ក្រាបទូលថា ខ្ញុំព្រះអង្គគួរឲ្យបាយាសនេះ ដល់អ្នកណា បន្ទាប់អំពីនោះ ព្រះដ៏មានព្រះភាគទ្រង់ដឹងបាយាសនោះថា បាយាសនេះ មានការមិនរលួយជាធម្មតាដល់អ្នកដទៃ វៀរតែព្រះតថាគត

និងសាវ័ករបស់តថាគត ទើបត្រាស់ថា **ឆ ទ្វាហានំ** ដូច្នេះ ។

ក្នុងបទទាំងនោះ ទ្រង់កាន់យកទេវតាជាន់កាមាវចរទាំង ៥ ដោយព្រះតម្រាស់ថា **សទេវកេ** ទ្រង់កាន់យកទេវតាជាន់កាមាវចរទី ៦ ដោយព្រះតម្រាស់ថា **សមារកេ** ទ្រង់កាន់យករូបាវចរព្រហ្ម ដោយព្រះតម្រាស់ថា **សព្រហ្មកេ** ចំណែកទេវតាជាន់អរូបាវចរព្រហ្ម មិនគួរសង្គ្រោះចូលក្នុងបទថា គប្បីបរិភោគ ទ្រង់កាន់យកសមណព្រាហ្មណ៍ដែលជាសត្រូវ ឬសត្រូវចំពោះសាសនា និងទ្រង់កាន់យកសមណព្រាហ្មណ៍ដែលមានបាបស្ងប់ហើយ ឬមានបាបបន្សាត់ហើយ ដោយព្រះតម្រាស់ថា **សស្សមណព្រាហ្មណី** ទ្រង់កាន់យកសត្វលោក ដោយពាក្យថា **បជា** ទ្រង់កាន់យកសម្មតិទេព និងមនុស្សដ៏សេសដោយព្រះតម្រាស់ថា **សទេវមនុស្ស** ។ ដោយប្រការដូច្នេះ ក្នុងព្រះសូត្រនេះគប្បីជ្រាបថា ឱកាសលោក ទ្រង់កាន់យកដោយព្រះតម្រាស់ ៣ យ៉ាង សត្វលោក ដោយអំណាចនៃ **បជា** ទ្រង់កាន់យកដោយព្រះតម្រាស់ ២ យ៉ាង ដោយប្រការដូច្នេះ ។ សេចក្តីសង្ខេប មានប្រមាណប៉ុណ្ណេះ ចំណែកសេចក្តីពិស្តារ ខ្ញុំនឹងពណ៌នាក្នុងអាឡវកសូត្រ ។

សួរថា បាយាសនេះ ដែលបុគ្គលណាក្នុងលោក ព្រមទាំងទេវលោកជាដើមបរិភោគហើយ នឹងមិនគប្បីឲ្យរលួយបានដោយជុំវិញ ព្រោះហេតុអ្វី ឆ្លើយថា ព្រោះដាក់ឱជៈដែលល្អិតក្នុងបាយាសដែលគ្រោតគ្រាត ។ ពិតយ៉ាងនោះ ទេវតាទាំងឡាយដាក់ឱជៈក្នុងបាយាសនេះ ដែលគ្រាន់តែព្រាហ្មណ៍

ឧទ្ទិសចំពោះព្រះដ៏មានព្រះភាគនោះឯង ដូចក្នុងបាយាសរបស់នាងសុជាតា ក្នុងសូករមទ្ទវៈរបស់នាយចុន្ទ ដែលកំពុងផ្សំក្នុងដុំបាយ ដែលព្រះដ៏មានព្រះភាគទ្រង់ទទួលហើយ ក្នុងស្រុកវេរញ្ជា និងក្នុងស្លាអំពៅ ដែលសល់ក្នុងក្អមរបស់ព្រះកច្ចានៈ ក្នុងកេសជ្ជកុន្ទកៈ ដូច្នោះ ។

បាយាសនោះរមែងមិនរលួយសម្រាប់ទេវតាទាំងឡាយ ព្រោះដាក់ឱជៈដែលល្អិត ក្នុងរបស់ដែលគ្រោតគ្រាត ព្រោះទេវតាទាំងឡាយមានរាងកាយល្អិតសុខុម អាហាររបស់មនុស្សដែលគ្រោតគ្រាត រមែងមិនរលួយដោយប្រពៃដល់ទេវតាទាំងនោះ រមែងមិនរលួយដល់មនុស្សទាំងឡាយ ព្រោះមនុស្សទាំងឡាយ មានរាងកាយគ្រោតគ្រាត ទិព្វឱជៈដ៏ល្អិត រមែងមិនរលួយដោយប្រពៃដល់មនុស្សទាំងនោះ ។ តែសម្រាប់ព្រះតថាគត រមែងរលួយតាមភ្លើងធាតុប្រក្រតី រមែងរលួយដោយប្រពៃ ។ អាចារ្យពួកខ្លះពោលថា តាមអំណាចនៃកម្លាំងកាយ និងកម្លាំងញាណ សម្រាប់ព្រះខីណាស្រពដែលជាសាវករបស់ព្រះតថាគតរមែងរលួយ ដោយកម្លាំងសមាធិ និងដោយភាពជាអ្នកស្គាល់ប្រមាណ ។ រមែងមិនរលួយសម្រាប់បុគ្គលក្រៅអំពីនេះ ទោះបីមានឫទ្ធិ ។ ម្យ៉ាងទៀត ហេតុក្នុងរឿងនេះជាអចិន្តេយ្យ ជាវិស័យរបស់ព្រះពុទ្ធ ។

បទថា **តេនហិ ត្វំ** មានអធិប្បាយថា ព្រោះតថាគតមិនឃើញបុគ្គលដទៃ បាយាសនោះ មិនគួរដល់តថាគត កាលមិនគួរដល់តថាគត ក៏មិនគួរដល់សាវករបស់តថាគត ព្រោះហេតុនោះ ម្នាលព្រាហ្មណ៍ ... ។ បទថា

**អប្បហារិតេ** សេចក្តីថា ក្នុងស្មៅខៀវបន្តិចបន្តួច ឬក្នុងស្មៅខៀវដែលដុះបន្តិចបន្តួច ដូចជាលើថ្មជាដើម ។ បទថា **អប្បាណកេ** សេចក្តីថា ក្នុងអន្លង់ទឹកធំដែលប្រាសចាកសត្វ ឬវៀរចាកសត្វដែលគប្បីស្លាប់ ព្រោះហេតុនៃការចាក់បាយាសនោះ ។ បទថា **អប្បាណកេ** នោះ ត្រាស់ដើម្បីប្រយោជន៍ដល់ការអនុគ្រោះស្មៅ និងសត្វទាំងឡាយ មួយអន្លើដោយសត្វដែលអាស្រ័យស្មៅ ។

បទថា **ចិច្ចិដាយតិ ចិដិចិដាយតិ** សេចក្តីថា រមែងមានសំឡេងយ៉ាងនោះ ។ បទថា **សំធូមាយតិ** បានដល់ ផ្សែងដោយជុំវិញ ។ បទថា **សម្បធូមាយតិ** បានដល់ ផ្សែងមានប្រមាណយ៉ាងក្រៃលែងនោះឯង សួរថា ផ្សែងមានយ៉ាងនោះ ព្រោះហេតុអ្វី ឆ្លើយថា ព្រោះអានុភាពរបស់ព្រះដ៏មានព្រះភាគ មិនមែនព្រោះអានុភាពនៃទឹក ឬបាយាស ព្រាហ្មណ៍ ទេវតា ឬយក្ខជាទេឡើយ សេចក្តីពិត ព្រះដ៏មានព្រះភាគ ទ្រង់អធិដ្ឋានយ៉ាងនោះ ដើម្បីជម្រុសសង្វេគដល់ព្រាហ្មណ៍ ។

បទថា **សេយ្យថាបិ ផាល** នោះ ជាការសម្តែងបទប្រៀបធៀប ។ ពាក្យត្រឹមប៉ុណ្ណោះឯងថា **យថា ផាលោ** ជាការត្រាស់ហើយ ។ ព្រាហ្មណ៍សង្វេគ ប្រព្រឹត្តទៅតាមផ្លូវចិត្ត មានរាងកាយព្រឺរោមព្រឺស្បែក បានឮថា រោមទាំង ៩៩០០០ រណ្តៅក្នុងរាងកាយរបស់ព្រាហ្មណ៍ បះឡើងដូចដៃកែវដែលសម្រេចអំពីកែវមណី ដែលគេបោះត្រង់ជញ្ជាំងមាស ដូច្នោះ ។ បទ

ដ៏សេស ប្រាកដជាក់ច្បាស់ហើយនោះឯង ។ ឯព្រាហ្មណ៍ក្រាបចុះទៀបបាទាទាំងគូ កាលសរសើរព្រះធម្មទេសនារបស់ព្រះដ៏មានព្រះភាគ ទើបក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតម ភាសិតរបស់ទ្រង់ជាក់ច្បាស់ពេកណាស់ បពិត្រព្រះគោតម ភាសិតរបស់ព្រះអង្គជាក់ច្បាស់ពេកណាស់ ដូច្នេះ ។

[ ៨ ] **អភិក្កន្ត** សព្ទ ក្នុងព្រះសូត្រនេះ ប្រើក្នុងការសរសើរ ចំណែកពណ៌នាអត្ថនៃ **អភិក្កន្ត** សព្ទនោះ ជាក់ច្បាស់ដោយពិស្តារក្នុងអដ្ឋកថានៃមង្គលសូត្រ ។ គប្បីជ្រាបថា ព្រោះ **អភិក្កន្ត** សព្ទ ប្រើក្នុងអត្ថនៃការសរសើរ ដូច្នោះ ទើបអធិប្បាយបានថា សាធុ សាធុ ព្រះគោតមដ៏ចម្រើន ។

អភិក្កន្ត សព្ទនេះ គប្បីជ្រាបថា ព្រាហ្មណ៍បានពោលដល់ទៅពីរដងដោយអំណាចការជ្រះថ្លា និងដោយអំណាចការសរសើរក្នុងព្រះធម្មទេសនានេះ ដោយលក្ខណៈនេះថា

> អ្នកប្រាជ្ញគប្បីពោលត្រួតព្រោះការខ្លាច ព្រោះការក្រោធ ព្រោះការសរសើរ ព្រោះការរួសរាន់ កោលាហល ព្រោះអស្ចារ្យ ព្រោះត្រេកអរ ព្រោះសេចក្តីសោក និងព្រោះសេចក្តីជ្រះថ្លា ។

ម្យ៉ាងទៀត បទថា **អភិក្កន្តំ** បានដល់ គួរស្រឡាញ់ពន់ពេក គួរប្រាថ្នាពន់ពេក គួរពេញចិត្តពន់ពេក អធិប្បាយថា ល្អក្រៃលែង ។ ក្នុងអត្ថនេះព្រាហ្មណ៍សរសើរទេសនាដោយ **អភិក្កន្ត** សព្ទ ១ សរសើរសេចក្តីជ្រះថ្លា

របស់ខ្លួនដោយអភិក្កន្តសព្ទ ១ ។ អធិប្បាយក្នុង **អភិក្កន្ត** សព្ទនោះ ដូច្នេះ ថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះធម្មទេសនារបស់ព្រះគោតមល្អក្រៃលែង ការជ្រះថ្លារបស់ខ្ញុំព្រះអង្គ ព្រោះអាស្រ័យព្រះធម្មទេសនារបស់ព្រះគោតម ដ៏ចម្រើន ល្អក្រៃលែង ឬសរសើរព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគនោះ ឯង សំដៅដល់ប្រយោជន៍ទីមួយៗ ២ យ៉ាង គឺព្រះតម្រាស់របស់ព្រះគោតម ដ៏ចម្រើន ល្អក្រៃលែង ព្រោះញុំាងទោសៈឲ្យវិនាស ល្អក្រៃលែង ព្រោះ សម្រេចគុណ ។ម្យ៉ាងទៀត អ្នកសិក្សាគប្បីប្រកបដោយបទទាំងឡាយយ៉ាង នេះថា ព្រោះឲ្យកើតសទ្ធា ព្រោះឲ្យកើតបញ្ញា ។ ព្រោះមានអត្ថ ព្រោះមាន ព្យញ្ជនៈ ព្រោះបទរាក់ ព្រោះអត្ថជ្រៅ ព្រោះពីរោះដល់ត្រចៀក ព្រោះចូល ដល់ក្នុងចិត្ត ព្រោះមិនលើកខ្លួន ព្រោះមិនសង្កត់សង្កិនអ្នកដទៃ ព្រោះត្រជាក់ ដោយករុណា ព្រោះផូរផង់ដោយបញ្ញា ព្រោះមានផ្លូវមកដែលគប្បីត្រេកអរ ព្រោះកម្ចាត់ការស្រេវឹង ព្រោះមានសុខក្នុងកាលស្តាប់ ព្រោះមានប្រយោជន៍ កាលពិចារណាជាដើម សូម្បីខាងមុខអំពីនោះ ក៏សរសើរទេសនានោះឯង ដោយឧបមា ៤ យ៉ាង ។

បណ្តាបទទាំងនោះ បទថា **និក្កុជ្ជិតំ** សេចក្តីថា របស់ដែលផ្កាប់ ឬ របស់ដែលមានមាត់ផ្កាប់ ។ បទថា **ឧក្កុជ្ជេយ្យ** បានដល់ ធ្វើមាត់ឲ្យផ្ងារឡើង ។ បទថា **បដិច្ឆន្នំ** បានដល់ ដែលវត្ថុទាំងឡាយ មានស្មៅជាដើមបិទបាំង ហើយ ។ បទថា **វិវរេយ្យ** បានដល់ បើកបង្ហាញ ។ បទថា **មូឡ្ហស្ស** បាន

ដល់ អ្នកវង្វេងទិស ។ បទថា **មគ្គំ អាចិក្ខេយ្យ** សេចក្ដីថា ចាប់ត្រង់ដើមដៃហើយ ប្រាប់ថា នុ៎ះផ្លូវ ។ បទថា **អន្ធការេ** បានដល់ ដែលមានងងឹតប្រកបដោយអង្គ ៤ គឺយប់ ១៤ នៃកាឡបក្ខ ១ កណ្ដាលយប់ ១ ព្រៃជ្រៅក្រាស់ ១ ពពកច្រើន ១ ។ អត្ថនៃបទមានប្រមាណប៉ុណ្ណេះ ចំណែកការប្រកប មានអធិប្បាយដូច្នេះថា

បពិត្រព្រះគោតម ទ្រង់ញ៉ាំងខ្ញុំព្រះអង្គដែលបែរខ្នងដាក់ព្រះសទ្ធម្ម ជាអ្នកធ្លាក់ក្នុងអសទ្ធម្ម ឲ្យចេញអំពីអសទ្ធម្ម ប្រៀបដូចផ្ងាររបស់ដែលផ្កាប់ ទ្រង់បើកព្រះសាសនាដែលបិទដោយព្រៃក្រាស់ គឺមិច្ឆាទិដ្ឋិ ចាប់តាំងអំពីព្រះសាសនារបស់ព្រះដ៏មានព្រះភាគកស្សបៈអន្តរធានទៅ ប្រៀបដូចបើករបស់ដែលបិទ ។ ទ្រង់ប្រាប់ផ្លូវសួគ៌ និងផ្លូវនិព្វានដល់ខ្ញុំព្រះអង្គ ដែលបដិបត្តិផ្លូវអាក្រក់ ផ្លូវខុស ប្រៀបដូចប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ទ្រង់ប្រកាសនូវធម៌ដោយអនេកបរិយាយ ព្រោះទ្រង់សម្ដែងដោយបរិយាយទាំងនោះ ដោយអុជប្រទីប គឺធម្មទេសនា ដែលកម្ចាត់ងងឹត គឺមោហៈ ដែលបិទបាំងនូវធម៌នោះ ដល់ខ្ញុំព្រះអង្គ ដែលលិចក្នុងងងឹត គឺមោហៈ មិនឃើញនូវរូបរតនៈមានពុទ្ធរតនៈជាដើម ប្រៀបដូចអុជប្រទីបប្រេងក្នុងទីងងឹត ដូច្នោះ ។

ម្យ៉ាងទៀត តាមមតិខ្លះ ព្រោះធម៌នេះ ដូចគ្នានឹងផ្ងាររបស់ដែលផ្កាប់ដោយការឃើញទុក្ខ និងដោយការលះវិបល្លាសក្នុងវត្ថុដែលមិនស្អាត ថាស្អាត ដូចបើករបស់ដែលបិទ ដោយឃើញសមុទយៈ និងដោយការលះ

វិបល្លាសក្នុងទុក្ខ ថាជាសុខ ដូចគ្នានឹងប្រាប់ផ្លូវដល់បុគ្គលវង្វេងដោយការ ឃើញនិរោធ និងដោយការលះវិបល្លាសក្នុងវត្ថុដែលមិនទៀង ថាទៀង ដូចគ្នានឹងអុជប្រទីបក្នុងទីងងឹត ដោយការឃើញមគ្គ និងដោយការលះវិបល្លាសក្នុងអនត្តា ថាជាអត្តា ព្រោះហេតុនោះ ទើបឈ្មោះថា ប្រកាសហើយយ៉ាងនេះថា ប្រៀបដូចផ្ងាររបស់ដែលផ្កាប់ ។បេ។ ឬអុជប្រទីបក្នុងទីងងឹត ដោយបំណងថា បុគ្គលមានចក្ខុ នឹងឃើញរូបបាន ដូច្នោះ ។

ព្រោះក្នុងសូត្រនេះ ទ្រង់ប្រកាសសីលក្ខន្ធដោយសទ្ធា សេចក្តីព្យាយាម និងការគ្រប់គ្រងកាយជាដើម ទ្រង់ប្រកាសបញ្ញាខន្ធដោយបញ្ញា ទ្រង់ប្រកាសសមាធិក្ខន្ធដោយហិរិ និងចិត្តជាដើម ទ្រង់ប្រកាសនិរោធដោយធម៌ដែលជាដែនក្សេមចាកយោគៈ ព្រោះហេតុនោះ ទើបទ្រង់ប្រកាសខន្ធ ៣ អរិយសច្ច ២ ដោយសង្ខេបថា អរិយមគ្គ និងនិរោធ ដោយប្រការដូច្នេះ ទ្រង់ប្រកាសនូវអរិយសច្ច ៤ ក្នុងព្រះសូត្រនោះ ដោយបដិបក្ខថា មគ្គជាបដិបក្ខចំពោះសមុទយៈ និរោធជាបដិបក្ខចំពោះទុក្ខដោយបរិយាយពីរ ដូចពោលហើយនេះ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា ទ្រង់ប្រកាសដោយអនេកបរិយាយ ។

ក្នុងបទថា **ឯសាហំ** ជាដើម **ឯសោ** និង **អហំ** ឈ្មោះថា **ឯសាហំ** ។ បទថា **សរណំ គច្ឆាមិ** សេចក្តីថា ព្រាហ្មណ៍ក្រាបចុះទៀបបាទាទាំងគូដល់ដោយសរណគមន៍ ដរាបដល់អស់ជីវិត ។ ឥឡូវនេះ កាលសមាទានទើបក្រាបទូលដោយវាចា ។ ឬដល់នូវព្រះពុទ្ធប៉ុណ្ណោះជាសរណៈ ដរាបដល់

អស់ជីវិត ។ ឥឡូវនេះ ធ្វើនូវព្រះពុទ្ធនោះឲ្យជាខាងដើម ទើបក្រាបទូល ដើម្បីដល់ព្រះធម៌ និងព្រះសង្ឃដ៏សេស ។

បទថា **អជ្ជតគ្គេ** បានដល់ ធ្វើថ្ងៃនេះឲ្យជាខាងដើម ។ ឬ **អជ្ជទគ្គេ** ក៏មាន **ទ** អក្ខរៈ គ្រាន់តែធ្វើការភ្ជាប់បទ ។ អធិប្បាយថា ធ្វើថ្ងៃនេះ ឲ្យជាថ្ងៃខាងដើម ។ បុគ្គលដល់នូវសរណៈដរាបដល់អស់ជីវិត ឈ្មោះថា **ចាណុ-បេតំ** អធិប្បាយថា ជីវិតរបស់ខ្ញុំព្រះអង្គនៅមានដរាបណា សូមព្រះគោតមចាំ គឺជឹងខ្ញុំព្រះអង្គ ថាជាឧបាសក ដែលដល់នូវសរណៈដរាបដល់អស់ជីវិត គឺដល់នូវសរណៈ ដោយសរណៈ ៣ មិនមានសាស្ដាដទៃជាសរណៈ ដរាបនោះ បដិបត្តិសមគួរដល់សុតៈ ដែលព្រាហ្មណ៍នេះសម្ដែងហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

ម្យ៉ាងទៀត ព្រាហ្មណ៍នេះសម្ដែងសម្បត្តិរបស់ព្រះសាស្ដាដោយពាក្យថា **និក្កុជ្ជិតំ** ជាដើម សម្ដែងសម្បត្តិរបស់សិស្ស ដោយបទជាដើមថា **ឯសាហំ** នេះ ឬសម្ដែងការបាននូវបញ្ញាដោយបទនោះ សម្ដែងការបាននូវសទ្ធាដោយបទនេះ ។ ឥឡូវនេះ មានបំណងដើម្បីធ្វើកិច្ចដែលបុគ្គលមានបញ្ញាបាននូវសទ្ធាហើយគប្បីធ្វើ ទើបទូលសូមព្រះដ៏មានព្រះភាគយ៉ាងនេះថា **លភេយ្យាហំ** ។ ព្រាហ្មណ៍មានចិត្តជ្រះថ្លាក្រៃលែងក្នុងបព្វជ្ជានោះ ដោយឥទ្ធិឫទ្ធិជាដើមរបស់ព្រះដ៏មានព្រះភាគ ទើបក្រាបទូលសូមបព្វជ្ជាដោយសទ្ធាថា សូម្បីព្រះដ៏មានព្រះភាគ ទ្រង់លះចក្រពត្តិរាជសម្បត្តិហើយ ទ្រង់

បព្វជ្ជា នឹងពោលថ្វីដល់អាត្មាអញ កាលប្រាថ្នានូវភាពជាអ្នកធ្វើបរិបូណ៌ ក្នុងបព្វជ្ជានោះ ទើបទូលសូមឧបសម្បទាដោយបញ្ញា ។ បទដ៏សេស ប្រាកដជាក់ច្បាស់ហើយ ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឯកោ វូបកដ្ឋោ** ជាដើម ព្រះការទ្វាជ: ជាបុគ្គលតែឯងដោយកាយវិវេក ឬចេញចាកពួកដោយចិត្តវិវេក មិនប្រមាទ ដោយការមិនបណ្តែតបណ្តោយសតិក្នុងកម្មដ្ឋាន មានសេចក្តីព្យាយាម ដោយសេចក្តីព្យាយាម ពោល គឺសេចក្តីព្យាយាមតាមផ្លូវកាយនិងផ្លូវចិត្ត មានចិត្តតែមួយ ដោយការមិនឃើញដល់កាយ និងជីវិត នៅដោយការប្តូរឥរិយាបថណាមួយ ។ បទថា **នចិរស្សេវ** ពោលសំដៅដល់បព្វជ្ជា ។ បទថា **កុលបុត្តា** បានដល់ កុលបុត្ត ២ យ៉ាង គឺជាតិកុលបុត្ត ១ អាចារ-កុលបុត្ត ១ ។ កុលបុត្តនោះ បំណងយកទាំងពីរយ៉ាង ។ បទថា **អគារស្មា** បានដល់ ចាកផ្ទះ ។ ការងារក្នុងការចិញ្ចឹមរបស់កុដុម្ពិក: មានការធ្វើស្រែនិងចិញ្ចឹមគោរបស់អ្នកគ្រប់គ្រងផ្ទះជាដើម ហៅថា ប្រយោជន៍របស់អ្នកគ្រប់គ្រងផ្ទះនោះ កិច្ចក្នុងការគ្រប់គ្រងផ្ទះ រមែងមិនមានក្នុងបព្វជ្ជានោះ ព្រោះហេតុនោះ ទើបព្វជ្ជានោះ ឈ្មោះថា **អនគារិយ** ។ ពាក្យថា **អនគារិយ** នេះជាឈ្មោះរបស់បព្វជ្ជា ។ បទថា **បព្វជន្តិ** សេចក្តីថា ចូលទៅ ចូលទៅ ជិត ។ បទថា **តទនុត្តរំ** គឺ **តំ អនុត្តរំ** ។ បទថា **ព្រហ្មចរិយបរិយោសានំ** បានដល់ ទីបំផុតនៃមគ្គព្រហ្មចរិយ: អធិប្បាយថា អរហត្តផល ។ ពិតហើយ

កុលបុត្តទាំងឡាយ រមែងបួសដើម្បីប្រយោជន៍ដល់អរហត្តផលនោះ ។ បទថា **ទិដ្ឋេវ ធម្មេ** បានដល់ ក្នុងអត្តភាពនោះឯង ។ បទថា **សយំ អភិញ្ញា សច្ឆិកត្វា** សេចក្តីថា ដឹងច្បាស់ដោយបញ្ញា ដោយខ្លួនឯងប៉ុណ្ណោះ គឺដឹងដោយមិនមានអ្នកដទៃជាបច្ច័យ ។ បទថា **ឧបសម្បជ្ជ វិហាសិ** សេចក្តីថា សម្រេចហើយ ឬឲ្យដល់ព្រមហើយ ។ ព្រះអានន្ទសម្តែងភូមិនៃការពិចារណារបស់ការទ្វាជភិក្ខុនោះ ដោយបទនេះថា បុគ្គលនៅយ៉ាងនេះហើយ ក៏បានដឹងច្បាស់ថា ជាតិអស់ហើយ ។បេ។

សួរថា ជាតិណារបស់ការទ្វាជភិក្ខុនោះអស់ហើយ និងបានដឹងច្បាស់នូវជាតិនោះដូចម្តេច ។

ឆ្លើយថា អតីតជាតិរបស់ភិក្ខុនោះ មិនអស់ ព្រោះបានអស់ហើយក្នុងអតីតនោះឯង ជាតិក្នុងអនាគតក៏មិនអស់ហើយ ព្រោះមិនមានការព្យាយាមជាតិបច្ចុប្បន្នក៏មិនអស់ ព្រោះជាតិនៅមាន តែជាតិណាមានខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ ក្នុងឯកកភព ចតុកភព និងបញ្ចវោការភពគប្បីកើតឡើង ព្រោះភាពដែលមគ្គមិនទាន់អប់រំហើយ ជាតិនោះឈ្មោះថា អស់ហើយ ដោយដល់នូវការមិនកើតឡើងជាធម្មតា ព្រោះភាពដែលមគ្គបានអប់រំហើយ ។ ភិក្ខុនោះពិចារណានូវកិលេសដែលលះហើយដោយមគ្គភាវនា ដឹងថា កម្មមាន ព្រោះមិនមានកិលេស ទើបមិនមានបដិសន្ធិតទៅ ឈ្មោះថា រមែងដឹងជាតិនោះ ។

បទថា **វុសិតំ** សេចក្តីថា នៅចប់ហើយ គឺធ្វើហើយ នៅចប់ដោយជុំ

វិញហើយ អធិប្បាយថា ធ្វើហើយ ប្រព្រឹត្តហើយ ឲ្យចប់ហើយ ។ បទថា **ព្រហ្មចរិយំ** បានដល់ មគ្គព្រហ្មចរិយៈ ។ បទថា **កតំ ករណីយំ** សេចក្ដីថា កិច្ច ១៦ ឲ្យចប់ហើយដោយអំណាចនៃបរិញ្ញា បហាន សច្ឆិកិរិយា និងភាវនា ដោយមគ្គ ៤ ក្នុងសច្ចៈ ៤ ។ បទថា **នាបរំ ឥត្ថត្តាយ** សេចក្ដីថា មគ្គភាវនាដើម្បីភាពយ៉ាងនេះ គឺដើម្បីភាពជាសោឡសកិច្ច ឬដើម្បីការអស់កិលេស មិនមានទៀតក្នុងឥឡូវនេះ ។

ម្យ៉ាងទៀត បទថា **ឥត្ថត្តាយ** សេចក្ដីថា ដឹងច្បាស់ថា ខន្ធសន្តានដទៃចាកខន្ធសន្តានដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ននេះ មានប្រការយ៉ាងនេះ ដោយភាពយ៉ាងនេះមិនមាន តែខន្ធ ៥ នេះ បានកំណត់ដឹងហើយ តាំងនៅដូចដើមឈើ មានឫសដាច់ហើយ ដូច្នោះ ។ បទថា **អញ្ញតរោ** បានដល់ រូប ១ ។ បទថា **អរហតំ** សេចក្ដីថា ព្រះភារទ្វាជៈ បានជាព្រះអរហន្តក្នុងបណ្ដាសាវកដែលជាអរហន្តទាំងឡាយ ។ បានឮថា នេះជាអធិប្បាយក្នុងកសិភារទ្វាជសូត្រនេះឯង ។

**អដ្ឋកថា កសិភារទ្វាជសូត្រ ចប់**

# សុត្តន្តបិដក

## ចុន្ទសូត្រទី ៥

[ ៩ ] ( ចុន្ទកម្មារបុត្ត ក្រាបទូលសួរព្រះមានព្រះភាគថា ) ខ្ញុំព្រះអង្គ សូមទូលសួរព្រះអង្គ ជាអ្នកប្រាជ្ញ មានបញ្ញាច្រើន ជាព្រះពុទ្ធ ជាម្ចាស់នៃធម៌ ប្រាសចាកតណ្ហា ដ៏ឧត្តមជាងសត្វជើងពីរ ប្រសើរជាងសារថីទាំងឡាយ តើពួកសមណៈក្នុងលោកនេះ មានប៉ុន្មាន សូមព្រះអង្គសម្ដែងប្រាប់ នូវពួកសមណៈនោះឲ្យទាន ។

( ព្រះមានព្រះភាគត្រាស់ថា ម្នាលចុន្ទ ) សមណៈមានត្រឹមតែ ៤ ពួក មិនមានដល់គម្រប់ ៥ ទេ កាលបើអ្នកសួរបញ្ជាក់ហើយ តថាគតនឹងប្រាប់នូវសមណៈទាំងនោះ ដល់អ្នក គឺសមណៈឈ្នះកិលេសដោយមគ្គ ១ សមណៈសម្ដែងប្រាប់នូវមគ្គ ១ សមណៈរស់នៅក្នុងមគ្គ ១ សមណៈប្រទូស្តនូវមគ្គ ១ ។

( ចុន្ទកម្មារបុត្តទូលសួរថា ) ព្រះពុទ្ធទាំងឡាយ តែងសម្ដែងនូវសមណៈណា ថាជាសមណៈឈ្នះកិលេសដោយមគ្គ សមណៈដុតបំផ្លាញនូវកិលេសដោយមគ្គ ជាបុគ្គលប្រឹងមិនបាន រស់នៅក្នុងមគ្គ ខ្ញុំសួរហើយ សូមព្រះអង្គសម្ដែងប្រាប់ឲ្យទាន មួយទៀត សូមព្រះអង្គប្រាប់នូវសមណៈ អ្នកប្រទូស្ត

នូវមគ្គ ដល់ខ្ញុំព្រះអង្គ ។

( ព្រះមានព្រះភាគត្រាស់ថា ) សមណៈណាកន្លងផុតនូវសេចក្ដីសង្ស័យ ប្រាសចាកសរគឺកិលេស ត្រេកអរក្នុងព្រះនិព្វាន មិនជាប់ជំពាក់ដោយតណ្ហា ជាអ្នកណែនាំសត្វលោកព្រមទាំងទេវលោក ព្រះពុទ្ធទាំងឡាយ សម្ដែងនូវសមណៈបែបនោះ ថាជាអ្នកឈ្នះកិលេសដោយមគ្គ ។ សមណៈណាក្នុងសាសនានេះ ដឹងនូវព្រះនិព្វាន ថាជាគុណជាតឧត្ដមក្រៃលែង ហើយសម្ដែងចែកនូវនិព្វានធម៌ ក្នុងលោកនេះ អ្នកប្រាជ្ញទាំងឡាយ ហៅសមណៈ ដែលជាអ្នកកាត់បង់នូវសេចក្ដីសង្ស័យ ជាអ្នកប្រាជ្ញមិនមានសេចក្ដីញាប់ញ័រនោះ ថាជាអ្នកសម្ដែងប្រាប់មគ្គ ថាជាសមណៈទី ២ នៃភិក្ខុទាំងឡាយ ។ សមណៈណាមានស្មារតីសង្រួមហើយ សេពនូវគន្លងមិនមានទោស រស់នៅក្នុងមគ្គ ជាផ្លូវនៃធម៌គឺព្រះនិព្វាន ដែលព្រះពុទ្ធសម្ដែងប្រពៃហើយ អ្នកប្រាជ្ញទាំងឡាយ ហៅសមណៈនោះថាជាអ្នករស់នៅក្នុងមគ្គ ជាសមណៈទី ៣ នៃភិក្ខុទាំងឡាយ ។ សមណៈណាធ្វើនូវភេទ របស់ពួកអ្នកមានវត្តល្អ ឲ្យជាគ្រឿងបិទបាំង ជាអ្នកស្ទុះស្ទា អ្នកប្រទូស្តត្រកូល មានឫកពាឃ្នើសឃ្នង មានកលមាយា មិនសង្រួម ពោលពាក្យឡេះឡោះ

ប្រព្រឹត្តបន្ទំ សមណៈនោះ ឈ្មោះថា ជាអ្នកទ្រុស្តនូវមគ្គ ។ គ្រហស្ថណាជាអ្នកចេះដឹង ជាអរិយសាវ័ក ប្រកបដោយប្រាជ្ញា ស្គាល់ច្បាស់នូវសមណៈទាំងនុ៎ះ សទ្ធារបស់គ្រហស្ថនោះ រមែង មិនសាបសូន្យទេ ព្រោះដឹងថា ពួកសមណៈទាំងអស់ មិន ដូច្នោះទេ ព្រោះឃើញដូច្នេះ គប្បីប្រៀបនូវសមណៈមិន អាក្រក់ ឲ្យស្មើដោយសមណៈអាក្រក់ ឬគប្បីប្រៀបនូវសមណៈ បរិសុទ្ធ ឲ្យស្មើដោយសមណៈមិនបរិសុទ្ធ ដូចម្ដេចកើត ។

ចុន្ទសូត្រទី ៥ ចប់

# អដ្ឋកថា

## ចុន្ទសូត្រ

[ ៩ ] ចុន្ទសូត្រមានពាក្យផ្ដើមថា **បុច្ឆាមិ មុនឹ បហុតបញ្ញំ** ដូច្នេះ ។ សូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ដោយសង្ខេបក្នុងឧប្បត្តិ ៤ យ៉ាង គឺព្រោះអជ្ឈាស្រ័យរបស់ខ្លួន ១ ព្រោះអជ្ឈាស្រ័យរបស់អ្នកដទៃ ១ ព្រោះអត្ថុប្បត្តិហេតុ ១ ព្រោះការសាកសួរ ១ សូត្រនេះ កើតឡើងដោយអំណាចនៃការសាកសួរ ។

ចំណែកដោយពិស្ដារ ក្នុងសម័យមួយ ព្រះដ៏មានព្រះភាគទ្រង់ចារិកទៅ

កាន់ដែនមល្លៈ មួយអន្លើដោយភិក្ខុសង្ឃជាច្រើន យាងដល់នគរបាវា ។ បានឮថា ក្នុងកាលនោះ ព្រះដ៏មានព្រះភាគ គង់នៅក្នុងអម្ពវ័នរបស់នាយចុន្ទកម្មារបុត្ត ជិតនគរបាវា ។ ចាប់តាំងអំពីនេះទៅ គប្បីឲ្យពិស្តារដោយន័យដែលមកហើយក្នុងសូត្រថា

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅកាន់លំនៅរបស់នាយចុន្ទកម្មារបុត្ត ព្រមដោយភិក្ខុសង្ឃ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ដូច្នេះ ។

កាលព្រះដ៏មានព្រះភាគប្រថាប់គង់ មួយអន្លើដោយភិក្ខុសង្ឃយ៉ាងនោះហើយ នាយចុន្ទកម្មារបុត្តកាលអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន បានបង្អោនភាជនមាសទាំងឡាយ ដល់ភិក្ខុទាំងឡាយ ដើម្បីទទួលព្យញ្ជនៈ និងសូបៈជាដើម ។

កាលសិក្ខាបទទ្រង់មិនទាន់បញ្ញត្ត ភិក្ខុខ្លះទទួលដោយភាជនមាស ភិក្ខុខ្លះមិនទទួល ចំណែកព្រះដ៏មានព្រះភាគ ទ្រង់មានភាជនៈតែម្យ៉ាងប៉ុណ្ណោះ គឺបាត្រសេលមយៈរបស់ព្រះអង្គ ។ ព្រះពុទ្ធទាំងឡាយ ទ្រង់មិនទទួលភាជនៈទី ២ ។ ក្នុងភិក្ខុទាំងនោះ ភិក្ខុអាក្រក់មួយរូប ដាក់ភាជន៍មាសតម្លៃមួយពាន់ដើម្បីប្រយោជន៍ដល់គោជនរបស់ខ្លួនក្នុងថង់សោ ដោយថេយ្យចិត្ត ។ នាយចុន្ទអង្គាសហើយ លាងដៃ និងជើង នមស្ការព្រះដ៏មានព្រះភាគ សម្លឹងមើល

ភិក្ខុសង្ឃ បានឃើញភិក្ខុនោះ តែធ្វើដូចជាមិនឃើញ មិនបានពោលអ្វីនឹងភិក្ខុនោះ ដោយគោរពក្នុងព្រះមានព្រះភាគ និងក្នុងព្រះថេរៈទាំងឡាយថា អើ ពួកមិច្ឆាទិដ្ឋិកុំបីមានពាក្យតិះដៀលបាន គាត់ចង់ដឹងថា សមណៈទាំងឡាយជាអ្នកប្រកបដោយសំវរៈឬហ្ន៎ ឬសមណៈបែបនេះ មានសំវរៈបែកហើយ ក្នុងពេលល្ងាច ចូលទៅគាល់ព្រះមានព្រះភាគ ហើយទូលសួរថា **បុច្ឆាមិ មុនឹ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុច្ឆាមិ** មានន័យដូចពោលហើយក្នុង ( ចូឡនិទ្ទេស ) នោះឯង ដោយន័យជាដើមថា

ត្រង់ពាក្យថា សួរ បានដល់ សំណួរ ៣ គឺអទិដ្ឋជោតនាបុច្ឆា ( សំណួរជាគ្រឿងបំភ្លឺហេតុ ដែលមិនទាន់បានឃើញ ) ១ ... ដូច្នេះ ។

បទថា **មុនឹ** នោះ មានន័យដូចពោលហើយក្នុង ( មហានិទ្ទេស ) នោះឯង ដោយន័យជាដើមថា

ពាក្យថា មុនិ អធិប្បាយថា ការដឹង លោកហៅថា មោនៈ បានដល់ បញ្ញាការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការសន្សំធម៌ ការយល់ឃើញត្រូវ មុនិ ប្រកបព្រមដោយការដឹងនោះ ឈ្មោះថា អ្នកដល់នូវមោនៈ ។ មោនេយ្យៈ មាន ៣ គឺ កាយមោនេយ្យៈ ១ ... ដូច្នេះ ។

សេចក្តីសង្ខេបក្នុងគាថានេះ ដូច្នេះ ។ បទថា **បុច្ឆាមិ** សេចក្តីថា

នាយចុន្ទកម្មារបុត្ត កាលធ្វើឱកាសហើយ ទើបទូលហៅព្រះមានព្រះភាគ ថាជាមុនី ។ បទថា **បហុតបញ្ញំ** ជាដើម ជាពាក្យពោលសរសើរ ។ នាយចុន្ទកម្មារបុត្ត សរសើរព្រះមានព្រះភាគនោះថា ជាមុនីដោយបទទាំងនោះ ។ ក្នុងបទទាំងនោះ បទថា **បហុតបញ្ញំ** បានដល់ មានបញ្ញាបរិបូណ៌ ។ ភាពដែលគប្បីដឹងដល់ទីបំផុត គប្បីជ្រាបថាភាពដែលព្រះមានព្រះភាគនោះ មានបញ្ញាបរិបូណ៌ ។ បទថា **ឥតិ ចុន្ទោ កម្មារបុត្តោ** នេះ មានន័យដូចពោលហើយ ក្នុងធនិយសូត្រនោះឯង ។ ខាងមុខអំពីនេះ ខ្ញុំមិនពោលពាក្យមានប្រមាណប៉ុណ្ណោះ លះបង់ន័យដែលពោលហើយទាំងអស់ នឹងពណ៌នាន័យដែលមិនទាន់ពោលប៉ុណ្ណោះ ។

បទថា **ពុទ្ធំ** បានដល់ ព្រះសម្មាសម្ពុទ្ធ ក្នុងព្រះពុទ្ធទាំង ៣ ។ បទថា **ធម្មស្សាមឹ** សេចក្តីថា ឈ្មោះថា ជាម្ចាស់នៃធម៌ គឺជាអ្នកមានធម៌ជាឥស្សរៈ ជាធម្មរាជា ជាអ្នកប្រព្រឹត្តតាមអំណាចធម៌ ព្រោះភាពដែលទ្រង់ឲ្យនូវមគ្គធម៌កើតឡើង ដូចបិតារបស់បុត្ត ជាអាចារ្យរបស់ពួកសិប្បាយតនៈជាដើមដែលខ្លួនឲ្យកើតហើយ សមដូចលោកពោលក្នុង ( គោបកមោគ្គល្លានសូត្រ ) ថា

> ម្នាលព្រាហ្មណ៍ ព្រោះថា ព្រះមានព្រះភាគអង្គនោះ ជាអ្នកបង្កើតផ្លូវដែលមិនទាន់កើតឡើង ជាអ្នករៀបចំផ្លូវដែលមិនទាន់រៀបចំ ជាអ្នកប្រាប់ផ្លូវដែលគេមិនដែលប្រាប់ ជាអ្នកស្គាល់ផ្លូវ

ដីនផ្លូវ ឈ្មោះថាអ្នកផ្លូវ ពួកសាវកក្នុងកាលឥឡូវនេះ គ្រាន់តែជាអ្នកដើរតាមផ្លូវ ប្រកបតាមក្រោយប៉ុណ្ណោះទេតើ ដូច្នេះ ។

បទថា **វីតតណ្ហំ** បានដល់ ជាអ្នកប្រាសចាកកាមតណ្ហា ភវតណ្ហា និងវិភវតណ្ហាហើយ ។ បទថា **ទិបទុត្តមំ** បានដល់ ឧត្តមជាងសត្វជើងពីរទាំងឡាយ ។ ក្នុងបទនោះ ព្រះមានព្រះភាគទ្រង់មិនមែនឧត្តមជាងសត្វជើងពីរ តែម្យ៉ាងប៉ុណ្ណោះក៏ពិត តែជាអ្នកឧត្តមជាងសត្វទាំងឡាយដែលមិនមានជើង មានជើងពីរ ។បេ។ ឬនេវសញ្ញីនាសញ្ញីទាំងអស់ ដោយពិត ហៅថាជាអ្នកឧត្តមជាងសត្វជើងពីរនោះឯង ដោយអំណាចការកំណត់យ៉ាងខ្ពស់ ។ ព្រោះសត្វជើងពីរ ឈ្មោះថា ឧត្តមជាងសត្វទាំងពួង ព្រោះស្តេចចក្រពត្តិក្តី មហាសាវកក្តី ព្រះបច្ចេកពុទ្ធជាដើមក្តី កើតក្នុងសត្វជើងពីរប៉ុណ្ណោះ កាលពោលថា បុគ្គលឧត្តមជាងសត្វទាំងនោះ ព្រះមានព្រះភាគ លោកហៅថាឧត្តមជាងសត្វទាំងពួងដូចគ្នា ។

បទថា **សារថីនំ បវរំ** សេចក្តីថា ឈ្មោះថាសារថី ព្រោះអត្ថវិគ្គហៈថាឲ្យស្ទុះទៅ ។ ពាក្យថា សារថីនោះ ជាឈ្មោះរបស់អ្នកទូន្មានដំរីជាដើម ។ ព្រះដ៏មានព្រះភាគទ្រង់ជាបុគ្គលប្រសើរជាងសារថីទាំងឡាយ ព្រោះទ្រង់អាចទូន្មានបុរសដែលគួរទូន្មានទាំងឡាយ ដោយការទូន្មានដ៏កំពូល ដូចព្រះតម្រាស់ក្នុង ( សឡាយតនវិភង្គសូត្រ ) ថា

ម្នាលភិក្ខុទាំងឡាយ ដំរីគួរទូន្មានដែលទម័កដំរីបានទូន្មានហើយ

រមែងស្ទុះទៅកាន់ទិសតែមួយៗ គឺទិសខាងកើតក្តី ខាងលិចក្តី ខាងជើងក្តី ខាងត្បូងក្តី ។ ម្នាលភិក្ខុទាំងឡាយ សេះគួរទូន្មាន ដែលទមកសេះបានទូន្មានហើយ រមែងស្ទុះទៅកាន់ទិសតែមួយៗ គឺទិសខាងកើតក្តី ខាងលិចក្តី ខាងជើងក្តី ខាងត្បូងក្តី ។ ម្នាលភិក្ខុទាំងឡាយ គោគួរទូន្មានដែលទមកគោ បានទូន្មានហើយ រមែងស្ទុះទៅកាន់ទិសតែមួយៗ គឺទិសខាងកើតក្តី ខាងលិចក្តី ខាងជើងក្តី ខាងត្បូងក្តី ។ ម្នាលភិក្ខុទាំងឡាយ ឯបុរសគួរទូន្មាន ដែលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធបានទូន្មានហើយ រមែងស្ទុះទៅកាន់ទិសទាំង ៨ បាន គឺបុគ្គលបានទូវរូបជ្ឈានតែងមើលឃើញនូវរូបទាំងឡាយ នេះជាទិសទី ១ ។បេ។ ក៏បានដល់នូវសញ្ញាវេទយិតនិរោធ ប្រព្រឹត្តនៅគ្រប់ឥរិយាបថទាំង ៤ នេះជាទិសទី ៨ ដូច្នេះ ។

បទថា **គតិ** បានដល់ សួរដល់ប្រភេទនៃអត្ថ ។ បទថា **លោកេ** បានដល់ ក្នុងសត្វលោក ។ បទថា **សមណា** ជាការសម្តែងលម្អិតអត្ថដែលគប្បីសួរ ។ បទថា **ឥង្ឃ** ជានិបាត ចុះក្នុងអត្ថសំណូមពរ ។ បទថា **តថិង្ឃ** កាត់បទជា **តេ ឥង្ឃ** ប្រែថា អញ្ជើញ ត្រាស់ប្រាប់សមណៈទាំងនោះ ។ បទថា **ព្រូហិ** សេចក្តីថា ត្រាស់ប្រាប់ គឺសូមត្រាស់ ។

កាលនាយចុន្ទទូលយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគទ្រង់ឃើញនាយ

ចុន្ទកម្មារបុត្ត មិនសួរបញ្ហារបស់គ្រហស្ថដោយន័យជាដើមថា បពិត្រព្រះអង្គ កុសលដូចម្តេច អកុសលដូចម្តេច សួរនូវបញ្ហារបស់សមណៈ កាលទ្រង់ឮពាក្យក៏ដឹងថា នាយចុន្ទកម្មារបុត្តនេះ សួរសំដៅដល់ភិក្ខុអាក្រក់នោះ កាលទ្រង់សម្តែងភាពដែលភិក្ខុនោះ មិនជាសមណៈ ព្រោះត្រឹមតែជាសមណៈដោយវោហារ ទើបត្រាស់ថា **ចតុរោ សមណា** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចតុរោ** ជាការកំណត់ចំនួន ។ បទថា **សមណា** សេចក្តីថា ជួនកាលព្រះដ៏មានព្រះភាគត្រាស់ដល់តិរ្ថិយទាំងឡាយដោយវាទៈថាសមណៈ ដូចព្រះតម្រាស់ថា

គប្បីប្រកាន់នូវវត្តសមាទាន សេចក្តីភ្ញាក់ផ្អើលដោយទិដ្ឋិ និងទិដ្ឋមង្គល សុតមង្គល មុតមង្គល ជារបស់ពួកតិរ្ថិយសមណៈ និងព្រាហ្មណសមណៈជាច្រើនដែរឬទេ ដូច្នេះ ។ ជួនកាល ត្រាស់ដល់បុថុជ្ជនទាំងឡាយដូចព្រះតម្រាស់ថា

ម្នាលភិក្ខុទាំងឡាយ អ្នកផងតែងស្គាល់ច្បាស់នូវអ្នកទាំងឡាយថាជាសមណៈៗ ។

ជួនកាល ត្រាស់ដល់ព្រះសេក្ខៈ ដូចព្រះតម្រាស់ថា

ម្នាលភិក្ខុទាំងឡាយ សមណៈ ( ទី ១ ) ( គឺសោតាបន្ន ) មានតែក្នុងសាសនានេះ សមណៈទី ២ ( គឺសកទាគាមី ) ក៏មានតែក្នុងសាសនានេះ ដូច្នេះ ។

ជូនកាល ត្រាស់ដល់ព្រះខីណាស្រពទាំងឡាយ ដូចព្រះតម្រាស់ថា ( តថាគតហៅបព្វជិតនោះថា ) ជាសមណៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដូច្នេះ ។

ជូនកាលត្រាស់ដល់ព្រះអង្គនោះឯង ដូចត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ ពាក្យថា សមណៈ ( អ្នកស្ងប់រម្ងាប់ ) នេះ ជាឈ្មោះរបស់តថាគត ដូច្នេះ ។ តែក្នុងទីនេះ ត្រាស់ដល់ព្រះអរិយៈទាំងអស់ និងបុថុជ្ជនដែលមានសីលដោយបទទាំង ៣ ។ ដោយបទទី ៤ ទ្រង់សង្គ្រោះដល់ភិក្ខុក្រៅអំពីនេះ មិនជាសមណៈ មានតែសំពត់ពណ៌លឿងព័ទ្ធព័ន្ធក ថាជាសមណៈ ដោយហេតុត្រឹមតែវោហារប៉ុណ្ណោះ ហើយទើបត្រាស់ថា **ចតុរោ សមណា** ដូច្នេះ ។

បទថា **ន បញ្ចមត្ថិ** សេចក្ដីថា ឈ្មោះថា សមណៈទី ៥ មិនមានក្នុងធម្មវិន័យនេះ ដោយហេតុត្រឹមតែវោហារ ដោយហេតុត្រឹមតែបដិញ្ញា ។ បទថា **តេ តេ អាវិករោមិ** សេចក្ដីថា តថាគតនឹងធ្វើសមណៈទាំង ៤ នោះឲ្យប្រាកដដល់អ្នក ។ បទថា **សក្ខិបុដ្ឋោ** សេចក្ដីថា ត្រូវសួរដល់មុខហើយ ។

បទថា **មគ្គជិនោ** សេចក្ដីថា បុគ្គលឈ្នះកិលេសទាំងពួងដោយមគ្គ ។ បទថា **មគ្គទេសកោ** បានដល់ ជាអ្នកសម្ដែងមគ្គដល់ជនដទៃ ។ បទថា **មគ្គេ ជីវតិ** សេចក្ដីថា ក្នុងព្រះសេក្ខៈទាំង ៧ សេក្ខៈណាមួយ ឈ្មោះថា ជាអ្នកនៅក្នុងមគ្គ ដែលជាលោកុត្តរ ព្រោះការនៅក្នុងមគ្គ ដែលមិនទាន់ដល់

ទីបំផុត ឯបុថុជ្ជនអ្នកមានសីល ឈ្មោះថា ជាអ្នករស់នៅក្នុងមគ្គ ដែលជាលោកិយ ឬគប្បីជ្រាបថា បុថុជ្ជនអ្នកមានសីល ឈ្មោះថា រស់នៅក្នុងមគ្គ ព្រោះរស់នៅដោយមគ្គនិមិត្តដែលជាលោកុត្តរ ។

បទថា **យោ ច មគ្គទូសី** សេចក្តីថា សមណៈទ្រុស្តសីល ជាមិច្ឆាទិដ្ឋិ ឈ្មោះថា ជាអ្នកប្រទូស្តមគ្គ ព្រោះបដិបត្តិជំទាស់នឹងមគ្គ ។

នាយចុន្ទ កាលមិនអាចដឹងច្បាស់នូវសមណៈ ៤ ដែលព្រះដ៏មានព្រះភាគទ្រង់លើកឡើងសម្តែងដោយសង្ខេបថា សមណៈ ៤ ពួកនេះ យ៉ាងនេះថា ក្នុងសមណៈទាំងនេះ សមណៈដែលឈ្នះដោយមគ្គឈ្មោះនេះ សមណៈដែលប្រទូស្តមគ្គឈ្មោះនេះ ដូច្នេះ ដើម្បីនឹងទូលសួរទៀត ទើបទូលថា **កម្មគ្គជិនំ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **មគ្គេ ជីវតិ មេ** សេចក្តីថា សមណៈនោះជាអ្នកនៅក្នុងមគ្គ បពិត្រព្រះមានព្រះភាគខ្ញុំព្រះអង្គសួរហើយ សូមទ្រង់ត្រាស់ប្រាប់សមណៈនោះដល់ខ្ញុំព្រះអង្គ ។ បទដ៏សេស ប្រាកដច្បាស់ហើយនោះឯង ។

ឥឡូវនេះ ព្រះដ៏មានព្រះភាគកាលទ្រង់សម្តែងពង្រីកសមណៈទាំង ៤ ដល់ព្រាហ្មណ៍នោះ ដោយ ៤ គាថា ទើបត្រាស់ថា **យោ តិណ្ណកថង្កថោ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **តិណ្ណកថង្កថោ វិសល្លោ** នោះ មានន័យដូចពោលហើយក្នុងឧរគសូត្រនោះឯង ចំណែកសេចក្តីដែលប្លែកគ្នា មានដូច្នេះថា

ព្រោះសមណៈ គឺព្រះពុទ្ធទ្រង់បំណាងយកថា សមណៈអ្នកឈ្នះកិលេសទាំងពួងដោយមគ្គ ដោយគាថានេះ ព្រោះដូច្នោះបណ្ឌិតគប្បីជ្រាបថា ឈ្មោះថា សមណៈអ្នកឆ្លងសេចក្ដីសង្ស័យបានហើយ ព្រោះទ្រង់ឆ្លងនូវការមិនដឹងក្នុងធម៌ទាំងពួងដ៏សមគួរ គួរសង្ស័យបានហើយ ដោយសព្វញ្ញុតញ្ញាណ ។ សមណៈទាំងឡាយ មានសោតាបន្នជាដើម មានព្រះបច្ចេកពុទ្ធជាទីបំផុត សូម្បីឆ្លងសេចក្ដីសង្ស័យបានហើយ ដោយន័យដែលពោលហើយ ក្នុងបទមុន តែដោយបរិយាយ ឈ្មោះថា មិនទាន់ឆ្លងសេចក្ដីសង្ស័យនោះឯង ព្រោះអំណាចញាណដែលមិនទើសទាក់ក្នុងវិស័យទាំងឡាយ មានសកទាគាមិវិស័យជាដើម មានពុទ្ធវិស័យជាទីបំផុត ។ ចំណែកព្រះដ៏មានព្រះភាគជាសមណៈដែលឆ្លងសេចក្ដីសង្ស័យបានហើយ ដោយប្រការទាំងពួង ។

បទថា **និព្វានាភិរតោ** បានដល់ ត្រេកអរចំពោះហើយក្នុងនិព្វាន ។ អធិប្បាយថា មានចិត្តបង្អោនហើយ ក្នុងនិព្វានសព្វកាល ដោយអំណាចនៃផលសមាបត្តិ ។ ព្រះមានព្រះភាគទ្រង់ជាបុគ្គលបែបនោះ សមដូចទ្រង់ត្រាស់ក្នុងមហាសច្ចកសូត្រថា

> ម្នាលអគ្គិវេស្សនៈ តថាគតនោះឯង តែងនៅអស់កាលជានិច្ចដោយផលសមាធិណា កាលបើចប់គាថានោះហើយ តថាគតក៏តម្រង់ ទប់ទល់ តម្កល់ចិត្តខាងក្នុង ធ្វើឲ្យជាចិត្តមានអារម្មណ៍តែមួយ ក្នុងសមាធិនិមិត្តដែលមានហើយ អំពីមុននោះឯងដោយ

ផលសមាធិនោះ ដូច្នេះ ។

បទថា **អនានុគិទ្ធោ** សេចក្តីថា ជាអ្នកមិនមានតម្រេកនូវធម៌ណា មួយ ដោយតម្រេក គឺតណ្ហា ។

បទថា **លោកស្ស សទេវកស្ស នេតា** សេចក្តីថា ជាអ្នកនាំលោក ព្រមទាំងទេវលោក គឺឲ្យដល់ដោយការសម្តែងធម៌ ដោយសមគួរដល់ អាសយៈ និងអនុសយៈ ហើយឲ្យដល់នូវការចាក់ធ្លុះសច្ចៈ ដល់ទេវតា និង មនុស្សទាំងឡាយ ដែលមិនមានប្រមាណ ក្នុងសូត្រទាំងឡាយដ៏ច្រើន មាន បាភយនសូត្រ និងមហាសមយសូត្រជាដើម អធិប្បាយថា ឲ្យឆ្លង គឺឲ្យ ដល់នូវត្រើយនាយ ។

បទថា **តាទី** សេចក្តីថា បុគ្គលបែបនោះ មានប្រការតាមដែលពោល ហើយ ឬជាបុគ្គលមិនប្រែប្រួលដោយលោកធម៌ទាំងឡាយ ។ បទដ៏សេស ក្នុងគាថានេះ ប្រាកដហើយនោះឯង ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងពន្រឹកសមណៈ គឺព្រះពុទ្ធ ថាជា សមណៈដែលឈ្នះកិលេសទាំងពួងដោយមគ្គ ដោយគាថានេះយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ពន្រឹកសមណៈដែលជាទីណាស្រេព ទើបត្រាស់ថា **បរមំ** ដូច្នេះ ។

ក្នុងគាថានោះ និព្វាន ឈ្មោះថា **បរមំ** អធិប្បាយថា ប្រសើរ ឧត្តម ជាងធម៌ទាំងពួង ។ បទថា **បរមន្តិ យោធ ញត្វា** សេចក្តីថា ភិក្ខុណាក្នុង

សាសនានេះ ដឹងថានិព្វាននោះជាធម៌ក្រៃលែង ដោយបច្ចវេក្ខណញ្ញាណ ។

បទថា **អក្ខាតិ វិភជតិ ឥធេវ ធម្មំ** សេចក្តីថា រមែងប្រាប់និព្វានធម៌ គឺធ្វើនិព្វានធម៌ឲ្យប្រាកដដល់អ្នកដទៃ ព្រោះភាពដែលនិព្វានធម៌ ជាធម៌ដែលខ្ញុំនបាក់ចុះហើយថា នេះនិព្វាន រមែងចែកនូវមគ្គធម៌ថា នេះសតិប្បដ្ឋាន ៤ ។បេ។ នេះមគ្គមានអង្គ ៨ ដ៏ប្រសើរដូច្នេះ ឬរមែងប្រាប់ធម៌ទាំងពីរ ដោយសម្តែងយ៉ាងសង្ខេបដល់ឧគ្ឃដិតញ្ញូបុគ្គល រមែងចែកដោយសម្តែងយ៉ាងពិស្តារដល់វិបចិតញ្ញូបុគ្គល ដើម្បីប្រាប់ និងចែកយ៉ាងនេះ បន្លឺនូវសីហនាទថា ធម៌នេះ មានក្នុងសាសនានេះប៉ុណ្ណោះ មិនមាននៅខាងក្រៅសាសនានេះឡើយ ឈ្មោះថា រមែងប្រាប់ និងរមែងចែក ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ភិក្ខុណា ក្នុងសាសនានេះ រមែងប្រាប់ រមែងចែកនូវធម៌ក្នុងធម្មវិន័យនេះឯង ។

បទថា **តំ កង្ខច្ឆិទំ មុនឹ អនេជំ** សេចក្តីថា ព្រះពុទ្ធទាំងឡាយ ត្រាស់ភិក្ខុទី ២ ដែលកាត់សេចក្តីសង្ស័យដោយការបាក់ចុះនូវសច្ចៈ ៤ និងដោយការកាត់នូវសេចក្តីសង្ស័យរបស់អ្នកដទៃ ដោយទេសនាដែលជាមុនី ដោយការដល់ព្រមដោយមោនេយ្យៈ ដែលមិនញាប់ញ័រ ព្រោះមិនមានតណ្ហាពោលគឺ **ឯជា** នុ៎ះ គឺបែបនោះថា **ទុតិយំ ភិក្ខុនមាហុ មគ្គទេសឹ** ដូច្នេះ ។

ព្រះដ៏មានព្រះភាគ ទ្រង់ញុំាងមគ្គដែលមិនទាន់កើត ឲ្យកើតហើយដោយព្រះអង្គឯង ជាអ្នកសម្តែងមគ្គដ៏កំពូលដោយទេសនាហើយ ទ្រង់សម្តែងពង្រីក

សមណៈដែលជាទីណាស្រេពថា សមណៈអ្នកសម្ដែងមគ្គ ដែលសមគួរដល់សាសនារបស់ខ្លួន ទីងញ៉ាំងសាសនាឲ្យរុងរឿង ដូចទូត ដូចរាជលេខារបស់ព្រះរាជា ដោយគាថានេះយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងពន្រឹកសមណៈដែលជាសេក្ខៈ និងសមណៈដែលជាបុថុជ្ជនមានសីល ទើបត្រាស់ថា **យោ ធម្មបទេ** ដូច្នេះ ។

ពណ៌នាបទ ក្នុងបទទាំងនោះ ប្រាកដច្បាស់ហើយ តែន័យនៃវណ្ណនាក្នុងគាថានេះ មានដូច្នេះ

ភិក្ខុណា កាលបទធម៌ ដែលព្រះពុទ្ធទាំងឡាយទ្រង់សម្ដែងល្អហើយ ព្រោះជាបទនៃធម៌ គឺព្រះនិព្វាន ព្រោះទ្រង់សម្ដែងមិនអាស្រ័យអន្តធម៌ទាំង ២ ឬទ្រង់សម្ដែងហើយដោយប្រការផ្សេងៗ មានសតិប្បដ្ឋានជាដើម ដ៏សមគួរដល់អាសយៈ ដែលជាបុគ្គលដល់ព្រមដោយមគ្គ ឈ្មោះថា ជាអ្នកនៅក្នុងមគ្គ ព្រោះជាអ្នកមានមគ្គកិច្ច ដែលកិលេសមិនទាន់រំហើយ ជាអ្នកសង្រួមហើយ ដោយសីលសំវរៈ មានសតិ ដោយសតិដែលតម្កល់ល្អហើយ ក្នុងកាយជាដើម ឬរឭកបាននូវកិច្ចដែលធ្វើហើយ ក្នុងកាលដ៏យូរជាដើមបានសេពនូវបទដែលមិនមានទោស ពោល គឺពោធិបក្ខិយធម៌ ៣៧ ប្រការព្រោះជាបទមិនមានទោស ដោយមិនមានទោសសូម្បីតិចតួច និងជាបទដោយការៈ ជាកោដ្ឋាសៈ ដោយការសេពភាវនា ចាប់តាំងអំពីគន្ត្រញាណព្រះពុទ្ធទាំងឡាយ ត្រាស់ភិក្ខុទី ៣ នោះថា ជាអ្នកនៅដោយមគ្គ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់ត្រាស់ពន្យល់សមណៈដែលជាសេក្ខៈ និងសមណបុថុជ្ជនដែលមានសីលថា ជាអ្នកនៅក្នុងមគ្គដោយគាថាយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងពន្យល់សមណៈត្រឹមតែវោហារ ដែលមានសំពត់ពណ៌លឿងព័ទ្ធព័ន្ធកនោះ ទើបត្រាស់ថា **ឆទនំ កត្វាន** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឆទនំ កត្វាន** សេចក្តីថា ធ្វើនូវការសមគួរ គឺកាន់យកភេទ អធិប្បាយថា ទ្រទ្រង់នូវភេទ ។ បទថា **សុព្វតានំ** បានដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវកពុទ្ធ ។ ពិតហើយ វត្តរបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវក រមែងល្អ ព្រោះហេតុនោះ លោកទាំងនោះ មានព្រះពុទ្ធជាដើម ហៅថា **សុព្វតា** ។

បទថា **បក្ខន្ទី** សេចក្តីថា ស្ទុះទៅ គឺចូលទៅខាងក្នុង ។ ពិតហើយ បុគ្គលអ្នកទ្រុស្តសីល ធ្វើនូវភេទរបស់អ្នកមានវត្តល្អ ឲ្យបើកនូវគ្រឿងបិទបាំង ដើម្បីបិទបាំងភាពដែលខ្លួនជាអ្នកទ្រុស្តសីល ដូចការបិទបាំងដោយវត្ថុមានស្លឹកឈើជាដើម ដើម្បីបិទបាំងនូវលាមកដូច្នោះ រមែងស្ទុះទៅក្នុងកណ្តាលភិក្ខុថា សូម្បីអញក៏ជាភិក្ខុ កាលបុគ្គលនោះប្រគេនលាភថា ភិក្ខុមានវស្សាប្រមាណប៉ុណ្ណេះ គប្បីទទួលលាភនេះ រមែងស្ទុះទៅដើម្បីទទួលថា អាត្មាក៏មានវស្សាប៉ុណ្ណេះ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ធ្វើនូវភេទនៃព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវកដែលមានវត្តល្អ ឲ្យជាគ្រឿងបិទបាំងហើយ ប្រព្រឹត្តទៅ ដូច្នេះ ។

បុគ្គលណារមែងប្រទូស្តនូវការជ្រះថ្លា ដែលកើតអំពីត្រកូល សូម្បីទាំង ៤ មានខត្តិយត្រកូលជាដើម ដោយការប្រព្រឹត្តិដែលមិនសមគួរ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **កុលទូសកោ** ជាអ្នកទ្រុស្តត្រកូល ។ បទថា **បគព្ភោ** សេចក្តីថា ជាអ្នកប្រកបព្រមហើយដោយការឃ្នើសឃ្នងកាយ ៨ ឋានៈ ឃ្នើសឃ្នងវាចា ៤ ឋានៈ និងឃ្នើសឃ្នងចិត្តច្រើនឋានៈ សេចក្តីសង្ខេបក្នុងសូត្រនេះ មានប្រមាណប៉ុណ្ណេះ ចំណែកសេចក្តីពិស្តារ ខ្ញុំនឹងពណ៌នាក្នុងមេត្តាសុត្តវណ្ណនា ។

ឈ្មោះថា **មាយាវី** ព្រោះជាអ្នកប្រកបព្រមហើយដោយមាយាដែលបិទបាំងកម្មដែលខ្លួនធ្វើហើយ ជាលក្ខណៈ ឈ្មោះថា **អសញ្ញតោ** ព្រោះមិនមានការសង្រួមសីល ឈ្មោះថា **បលាបោ** ព្រោះដូចគ្នានឹងអង្កាម ប្រៀបដូចអង្កាមដែលវៀរអង្ករខាងក្នុង តែប្រាកដដូចស្រូវដែលមានគ្រាប់ល្អ ខាងក្រៅ យ៉ាងណា បុគ្គលខ្លះក្នុងសាសនានេះក៏ដូច្នោះ វៀរចាកនូវគុណសារៈមានសីលជាដើមខាងក្នុង តែប្រាកដដូចសមណៈដោយភេទសមណៈ ដែលជាគ្រឿងបិទបាំងនូវវត្តដ៏ល្អខាងក្រៅដូច្នោះ សមណៈនោះហៅថា សមណៈអង្កាម ព្រោះដូចគ្នានឹងអង្កាមយ៉ាងនោះ ។

ក្នុងអានាបានស្សតិសូត្រ សូម្បីកល្យាណបុថុជ្ជន ក៏ទ្រង់ត្រាស់ថា ជាអង្កាមយ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះស្ងាត់ ( មិនមានអង្កាម ) ហើយ ម្នាល

ភិក្ខុទាំងឡាយ បរិស័ទនេះស្អាតចាកការបរបា ( មិនមានអង្កាម ) ហើយ ស្ថិតនៅក្នុងធម៌ដែលជាខ្លឹមសារដ៏បរិសុទ្ធដូច្នេះ ត្រាស់ថា ជាបុគ្គលអង្កាម ។ ចំណែកក្នុងសូត្រនេះ និងក្នុងកបិលសូត្រ បុគ្គលត្រូវបារាជិក ទ្រង់ត្រាស់ថា

គប្បីបណ្តេញនូវពួកបុគ្គល ដែលដូចជាសំដីស្រូវ មិនមែនជាសមណៈ ប្រកាន់ថា ខ្លួនជាសមណៈចេញ ដូច្នេះ ។

បទថា **បដិរូបេន ចរំ ស មគ្គទូសី** សេចក្តីថា បុគ្គលនោះ ធ្វើនូវភេទនៃព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវកដែលមានវត្តល្អឲ្យជាគ្រឿងបិទបាំងហើយនោះ ប្រព្រឹត្តវត្តបដិរូប ឬដោយអាចារត្រឹមតែខាងក្រៅ ដោយប្រការដែលជនរមែងដឹងអាត្មាអញ តាមដែលប្រព្រឹត្តថា ភិក្ខុនេះ នៅក្នុងព្រៃជាវត្ត សមាទានរុក្ខមូលជាវត្ត កាន់យកនូវសំពត់បង្សុកូលជាវត្ត ត្រាច់បិណ្ឌបាតជាវត្ត ជាអ្នកប្រាថ្នាតិច ជាអ្នកសន្តោសដូច្នេះ គប្បីជ្រាបថា ជាសមណៈដែលប្រទូស្តមគ្គ ព្រោះប្រទូស្តក្នុងលោកុត្តរមគ្គរបស់ខ្លួន និងព្រោះប្រទូស្តសុគតិមគ្គរបស់អ្នកដទៃ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលទ្រង់ពន្យល់សមណៈ ដែលគ្រាន់តែហៅដោយវោហារ ជាអ្នកទ្រុស្តសីលថា ជាសមណៈដែលប្រទូស្តមគ្គដោយគាថានេះ ដោយប្រការដូច្នេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងភាពដែលសមណៈទាំងនោះ ជាអ្នកមិនចូលគ្នានិងគ្នា ទើបត្រាស់ថា **ឃតេ ច បដិវិជ្ឈ** ដូច្នេះ ។

គាថានោះមានអត្ថថា បុគ្គលណា ជាគ្រហស្ថក្តី ជាក្សត្រក្តី ជាព្រាហ្មណ៍ក្តី ណាមួយជ្រាបច្បាស់ គឺដឹងទូទៅ ធ្វើឲ្យជាក់ច្បាស់នូវសមណៈ ៤ នោះ ដោយលក្ខណៈតាមដែលពោលហើយ ឈ្មោះថា **សុតវា** ព្រោះបានស្តាប់លក្ខណៈរបស់សមណៈ ៤ នេះ ដោយត្រឹមតែស្តាប់ ឈ្មោះថា **អរិយសាវកោ** ព្រោះភាពដែលលក្ខណៈនោះឯង បានស្តាប់ហើយក្នុងសម្នាក់របស់ព្រះអរិយៈទាំងឡាយ ឈ្មោះថា **សបញ្ញោ** ព្រោះដឹងច្បាស់នូវសមណៈទាំងនោះឯងថា ភិក្ខុរូបនេះ និងភិក្ខុរូបនេះ មានលក្ខណៈយ៉ាងនេះ ហើយដឹងថា សមណៈនេះ ជាសមណៈប្រទូស្តមគ្គ ដែលត្រូវត្រាស់ដល់ហើយក្នុងកាលខាងក្រោយ យ៉ាងណា សមណៈទាំងអស់ក្រៅអំពីនេះ មិនមែនដូច្នេះឡើយ ។ ឃើញហើយយ៉ាងនេះ គឺឃើញភិក្ខុអាក្រក់នោះ សូម្បីធ្វើអាក្រក់យ៉ាងនេះ ។

ក្នុងគាថានោះ មានយោជនាដូច្នេះថា ព្រះអរិយសាវក ជាអ្នកបានស្តាប់ មានបញ្ញាជ្រាបច្បាស់សមណៈទាំងនោះ កាលគ្រហស្ថនោះ ដឹងដោយបញ្ញានោះថា សមណៈទាំងអស់ មិនមែនដូច្នោះ យ៉ាងនេះហើយ ព្រោះឃើញយ៉ាងនេះ សទ្ធារមែងមិនវិនាស គឺព្រោះឃើញភិក្ខុអាក្រក់ធ្វើកម្មអាក្រក់យ៉ាងនេះហើយ មិនញុំាងសទ្ធាឲ្យវិនាស គឺមិនឲ្យសាបសូន្យ មិនឲ្យសទ្ធាអន្តរាយ ដូច្នេះ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងភាពដែលសមណៈទាំងនោះ ជា

អ្នកមិនចូលគ្នានិងគ្នា ដោយគាថាដូច្នេះហើយ ឥឡូវនេះ កាលសរសើរអរិយសាវកដែលឃើញហើយយ៉ាងនេះ ដឹងនូវសមណៈទាំងអស់ថា មានសភាពដូច្នោះ ទើបត្រាស់ថា **កច្ចិញ្ហិ ទុដ្ឋេន** ដូច្នេះ ។

គាថាវចនៈនោះ មានការសម្ពន្ធថា ព្រះអរិយសាវកដែលបានស្តាប់រឿងដែលប្រកបហើយនោះឯង គឺឃើញភិក្ខុធ្វើនូវអំពើអាក្រក់រូបខ្លះ ដូច្នេះហើយ ដឹងនូវសមណៈទាំងអស់នោះថាដូច្នោះឯង ព្រោះហេតុអ្វី ព្រោះឃើញដូច្នេះ គប្បីប្រៀបនូវសមណៈមិនអាក្រក់ ឲ្យស្មើដោយសមណៈអាក្រក់ ឬគប្បីប្រៀបនូវសមណៈបរិសុទ្ធ ឲ្យស្មើដោយសមណៈមិនបរិសុទ្ធដូចម្តេចកើត ។

គាថានោះមានអត្ថថា ព្រោះព្រះអរិយសាវកអ្នកស្តាប់ មានបញ្ញាគប្បីធ្វើសមណៈមិនអាក្រក់ក្រៅអំពីនេះ ឲ្យស្មើដោយសមណៈ ដែលប្រទូស្តមគ្គដែលមានទោសប្រទូស្តដោយសីលវិបត្តិ គប្បីធ្វើសមណៈដែលបរិសុទ្ធ ដូច្នោះ ឲ្យស្មើដោយសមណៈដែលមិនបរិសុទ្ធ ដោយកាយសមាចារជាដើម ដែលជាសមណ ត្រឹមតែជាវោហារចុងក្រោយ បានដូចម្តេច គឺគប្បីដឹងថា ដូចគ្នាបានដូចម្តេច ។

ក្នុងកាលចប់ព្រះសូត្រ ព្រះដ៏មានព្រះភាគមិនត្រាស់មគ្គ ឬផលដល់ឧបាសក ព្រោះឧបាសកនោះលះការសង្ស័យបានហើយ ដូច្នោះឯង ។០៚

**អដ្ឋកថា ចុន្ទសូត្រ ចប់**

# សុត្តន្តបិដក

## បរាភវសូត្រទី ៦

[ ១០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ទេវតា ១ អង្គ កាលដែលរាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏រុងរឿង ញ៉ាំងវត្តជេតពនជុំវិញទាំងអស់ ឲ្យភ្លឺស្វាងហើយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយស្ថិតនៅក្នុងទីសមគួរ ។ លុះទេវតានោះ ស្ថិតនៅក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគដោយគាថា ដូច្នេះថា

[ ១១ ] យើងទាំងឡាយ មកដើម្បីសួរព្រះគោតមដ៏ចម្រើន
( ដោយគិតថា ) យើងទាំងឡាយ សូមសួរអំពីបុរសបុគ្គល
ដែលមានសេចក្តីវិនាស ចុះអ្វីជាប្រធាននៃសេចក្តីវិនាស ។

( ព្រះមានព្រះភាគត្រាស់ថា ) បុរសដែលចម្រើន ជា
បុគ្គល គឺបណ្ឌិតដឹងបានដោយងាយ បុរសដែលវិនាស ជា
បុគ្គល គឺបណ្ឌិតដឹងបានដោយងាយដែរ បុគ្គលអ្នកប្រាថ្នាធម៌
រមែងចម្រើន អ្នកស្អប់ធម៌ រមែងវិនាស ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នោះជាសេចក្តី
វិនាសទី ១ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែងនូវ
ហេតុទី ២ អ្វីជាប្រធាននៃសេចក្តីវិនាស ។

បុគ្គលមានពួកអសប្បុរស ជាទីស្រឡាញ់ មិនធ្វើសេចក្តីស្រឡាញ់ ចំពោះពួកសប្បុរស ពេញចិត្តចំពោះធម៌របស់ពួកអសប្បុរស នុ៎ះជាប្រធាននៃសេចក្តីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នុ៎ះជាសេចក្តីវិនាសទី ២ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែងនូវហេតុទី ៣ អ្វីជាប្រធាននៃសេចក្តីវិនាស ។

ជនអ្នកដេកលក់ច្រើនក្តី និយាយច្រើនក្តី មិនខ្មីឃ្មាតក្តី ខ្ជិលច្រអូសក្តី ប្រាកដតែខាងក្រោធក្តី នុ៎ះជាប្រធាននៃសេចក្តីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នុ៎ះជាសេចក្តីវិនាសទី ៣ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែងនូវហេតុទី ៤ អ្វីជាប្រធាននៃសេចក្តីវិនាស ។

បុគ្គលជាអ្នកស្តុកស្តម្ភ តែមិនចិញ្ចឹមមាតាក្តី បិតាក្តី ដែលចាស់មានវ័យកន្លងហើយ នុ៎ះជាប្រធាននៃសេចក្តីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នុ៎ះជាសេចក្តីវិនាសទី ៤ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែងនូវហេតុទី ៥ អ្វីជាប្រធាននៃសេចក្តីវិនាស ។

បុគ្គលបញ្ឆោតព្រាហ្មណ៍ក្តី សមណៈក្តី ឬអ្នកសូមដទៃក្តី ដោយពាក្យកុហក នុ៎ះជាប្រធាននៃសេចក្តីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នុ៎ះជាសេចក្ដីវិនាសទី ៥ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្ដែងនូវហេតុទី ៦ អ្វីជាប្រធាននៃសេចក្ដីវិនាស ។

បុរសបុគ្គល មានទ្រព្យជាគ្រឿងត្រេកអរច្រើន មានប្រាក់សម្បូរភោជន បរិភោគនូវភោជនមានរសឆ្ងាញ់ តែម្នាក់ឯងនុ៎ះជាប្រធាននៃសេចក្ដីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នុ៎ះជាសេចក្ដីវិនាសទី ៦ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្ដែងនូវហេតុទី ៧ អ្វីជាប្រធាននៃសេចក្ដីវិនាស ។

ជនដែលរឹងត្អឹង ដោយអាងជាតិក្ដី រឹងត្អឹងដោយអាងទ្រព្យក្ដី រឹងត្អឹងដោយអាងគោត្រត្រកូលក្ដី ហើយមើលងាយញាតិរបស់ខ្លួន នុ៎ះជាប្រធាននៃសេចក្ដីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នុ៎ះជាសេចក្ដីវិនាសទី ៧ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្ដែងនូវហេតុទី ៨ អ្វីជាប្រធាននៃសេចក្ដីវិនាស ។

ជនជាអ្នកលេងស្រីក្ដី លេងសុរាក្ដី លេងល្បែងភ្នាល់ក្ដី រមែងញ៉ាំងទ្រព្យដែលខ្លួនបានហើយ បានហើយ ឲ្យវិនាសទៅនុ៎ះជាប្រធាននៃសេចក្ដីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នុ៎ះជាសេចក្ដី

វិនាសទី ៨ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសំដែងនូវហេតុទី ៩ អ្វីជាប្រធាននៃសេចក្ដីវិនាស ។

ជនមិនត្រេកអរនឹងប្រពន្ធរបស់ខ្លួន ទៅខូចចំពោះពួកស្រីពេស្យា ឬខូចចំពោះប្រពន្ធនៃបុគ្គលដទៃ នុ៎ះជាប្រធាននៃសេចក្ដីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នុ៎ះជាសេចក្ដីវិនាសទី ៩ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសំដែងនូវហេតុទី ១០ អ្វីជាប្រធាននៃសេចក្ដីវិនាស ។

បុរសមានវ័យកន្លងហើយ នាំយកស្ត្រី ( ក្មេង ) ដែលមានដោះក្បំ ដូចជាផ្លែទន្លាប់ រមែងដេកមិនលក់ ព្រោះសេចក្ដីប្រចណ្ឌ ចំពោះស្ត្រីនោះ នុ៎ះជាប្រធាននៃសេចក្ដីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នុ៎ះជាសេចក្ដីវិនាសទី ១០ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសំដែងនូវហេតុទី ១១ អ្វីជាប្រធាននៃសេចក្ដីវិនាស ។

បុរសបុគ្គល តាំងស្ត្រីអ្នកលេងខ្ជះខ្ជាយ ឬបុរសបែបនោះដែរ ក្នុងឋានៈជាធំ នុ៎ះជាប្រធាននៃសេចក្ដីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នុ៎ះជាសេចក្ដីវិនាសទី ១១ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសំដែងនូវហេតុទី ១២ អ្វីជាប្រធាននៃសេចក្ដីវិនាស ។

បុគ្គលដែលកើតក្នុងខត្តិយត្រកូល មានភោគៈតិច តែមានសេចក្តីប្រាថ្នាធំ ទៅប្រាថ្នារាជ្យសម្បត្តិ នុ៎ះជាប្រធាននៃសេចក្តីវិនាស ។

បុគ្គលជាបណ្ឌិត បរិបូណ៌ដោយការឃើញដ៏ប្រសើរ ពិចារណាឃើញច្បាស់ នូវសេចក្តីវិនាសទាំងនុ៎ះ ក្នុងលោក បណ្ឌិតនោះ រមែងគប់រកនូវលោក ដែលមានសេចក្តីសុខដ៏ក្សេមក្សាន្ត ។

បរាភវសូត្រទី ៦ ចប់

# អដ្ឋកថា

## បរាភវសូត្រ

[ ១០ ] បរាភវសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះ ។ សូត្រនេះមានអត្ថុប្បត្តិហេតុដូចម្តេច ។ បានឮថា ទេវតាទាំងឡាយ ស្តាប់មង្គលសូត្រហើយ មានបរិវិតក្កថា ព្រះដ៏មានព្រះភាគត្រាស់សេចក្តីចម្រើន និងសួស្តីដល់សត្វទាំងឡាយ ក្នុងមង្គលសូត្រ ត្រាស់តែសេចក្តីចម្រើនដោយចំណែកមួយប៉ុណ្ណោះ មិនត្រាស់ដល់សេចក្តីវិនាសឡើយ ណ្ហើយចុះឥឡូវនេះ សត្វទាំងឡាយរមែងសាបសូន្យ រមែងវិនាសដោយហេតុនៃសេចក្តី

វិនាសណា ពួកយើងនឹងទូលសួរដល់ហេតុនៃសេចក្ដីវិនាសនោះ នៃសត្វទាំងនោះ ។

លំដាប់នោះ ក្នុងថ្ងៃទី ២ បន្ទាប់អំពីថ្ងៃដែលត្រាស់មង្គលសូត្រ ទេវតាទាំងឡាយក្នុងម៉ឺនចក្កវាឡ បំណងនឹងស្ដាប់ព្រះសូត្រ ពោលដោយសេចក្ដីវិនាស ប្រជុំគ្នាក្នុងចក្កវាឡនេះ និម្មិតអត្តភាពតូចៗ ១០ អត្តភាពខ្លះ ២០ អត្តភាពខ្លះ ៣០ អត្តភាពខ្លះ ៤០ អត្តភាពខ្លះ ៥០ អត្តភាពខ្លះ ៦០ អត្តភាពខ្លះ ៧០ អត្តភាពខ្លះ ៨០ អត្តភាពខ្លះ ដោយឱកាសទីបំផុតនៃចុងរោមទ្រាយ ១ បានឈរចោមរោមព្រះមានព្រះភាគ ដែលគង់លើបវរពុទ្ធាសនៈ ដែលក្រាលហើយ រុងរឿងគ្របសង្កត់ទេវតា មារ និងព្រហ្មទាំងពួង ដោយសិរីនិងតេជៈ បន្ទាប់អំពីនោះ ទេវបុត្តមួយអង្គ ត្រូវសក្កទេវិន្ទត្រាស់ប្រើមកហើយ ទូលសួរប្រស្នាដែលទាក់ទងនឹងសេចក្ដីវិនាសជាមួយព្រះមានព្រះភាគ លំដាប់នោះ ព្រះមានព្រះភាគត្រាស់សូត្រនេះ ដោយអំណាចនៃការសួរ ។

បណ្ដាបទទាំងនោះ បទថា **ឯវម្មេ សុតំ** ជាដើម ព្រះអានន្ទពោល ។ គាថាក្នុងលំដាប់មួយដោយន័យជាដើមថា **បរាភវន្តំ បុរិសំ** ទេវបុត្តពោល ។ គាថាលំដាប់មួយទៀត ដោយន័យជាដើមថា **សុវិជានោ ភវំ ហោតិ** និងគាថាចុងក្រោយ ព្រះមានព្រះភាគត្រាស់ពាក្យទាំងអស់សរុបចូលគ្នាហើយ ហៅថា **បរាភវសូត្រ** ។

បណ្ដាបទទាំងនោះ ក្នុងបទថា **ឯវម្មេ សុតំ** ជាដើម ពាក្យណាគប្បី

ពោល ពាក្យទាំងអស់នោះ ខ្ញុំពោលហើយក្នុងមង្គលសូត្រ ។

[ ១១ ] ចំណែកក្នុងបទជាដើមថា **បរាភវន្តំ បុរិសំ** បានដល់ អ្នកវិនាស អ្នកសាបសូន្យ អ្នកអន្តរធាន ។ បទថា **បុរិសំ** បានដល់ សត្វ គឺអ្នកកើតឯណានីមួយ ។

បទថា **មយំ បុច្ឆាម គោតមំ** សេចក្តីថា ទេវបុត្តនោះ បង្ហាញខ្លួនជាមួយទេវតាដ៏សេសទាំងឡាយ ទូលហៅព្រះមានព្រះភាគដោយគោត្ត ។ បទថា **ភគវន្តំ បុដ្ឋុមាគម្ម** សេចក្តីថា ខ្ញុំព្រះអង្គមកអំពីចក្កវាឡនោះៗ ដោយបំណងថា នឹងទូលសួរព្រះមានព្រះភាគ ទេវបុត្តសម្តែងសេចក្តីអើពើដោយបទនេះ ។

បទថា **កឹ បរាភវតោ មុខំ** សេចក្តីថា សូមទ្រង់ត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គទាំងឡាយដែលមកហើយយ៉ាងនេះថា អ្វីជាផ្លូវ គឺជាទ្វារ ជាកំណើត ជាហេតុនៃបុគ្គលវិនាស ដែលធ្វើឲ្យខ្ញុំព្រះអង្គគប្បីស្គាល់បុគ្គលវិនាស ។ ទេវបុត្តទូលសួរហេតុនៃសេចក្តីវិនាសរបស់បុគ្គលវិនាស ដែលពោលក្នុងបទនេះថា **បរាភវន្តំ បុរិសំ** ដោយបទនេះ ។ ព្រោះកាលដឹងហេតុនៃសេចក្តីវិនាសហើយ ក៏អាចដឹងបុគ្គលដែលវិនាសខ្លះបាន ដោយអំណាចហេតុសាមញ្ញនោះ ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ដែលជាបដិបក្ខដើម្បីធ្វើឲ្យប្រាកដដោយល្អដល់ទេវបុត្តនោះ កាលទ្រង់សម្តែងផ្លូវនៃសេចក្តី

វិនាសដោយទេសនា មានបុគ្គលាធិដ្ឋាន ទើបត្រាស់ថា **សុវិជានោ ភវំ** ដូច្នេះ ។

គាថានោះ មានអត្ថថា បុគ្គលនេះចម្រើន គឺវឌ្ឍនា មិនវិនាស បុគ្គលនោះជាអ្នកដឹងបានងាយ គឺអាចជ្រាបច្បាស់ដោយងាយ គឺដោយមិនលំបាក ចំណែកបុគ្គលនេះ ជាអ្នកវិនាស ព្រោះអត្ថថា រមែងវិនាស គឺរមែងអន្តរាយ គឺរមែងអន្តរធាន ដែលពួកអ្នកសួរផ្លូវនៃសេចក្តីវិនាស របស់អ្នកវិនាសនោះ នឹងតថាគត បុគ្គលនោះក៏ដឹងបានងាយ ។ សេចក្តីនេះដូចម្តេច បុគ្គលអ្នកប្រាថ្នាធម៌ ជាអ្នកចម្រើន គឺរមែងប្រាថ្នា ចូលចិត្ត ប្រាថ្នានឹងស្តាប់ បដិបត្តិនូវធម៌ គឺកុសលកម្មបថ ១០ បុគ្គលនោះ ឈ្មោះថា ជាអ្នកដឹងបានងាយ ព្រោះឃើញ និងស្តាប់បដិបទានោះហើយ គប្បីដឹងបាន ។ បុគ្គលខ្ពើមនូវធម៌ក្រៅអំពីនេះ ជាអ្នកវិនាស រមែងខ្ពើម គឺរមែងមិនចូលចិត្ត មិនប្រាថ្នា មិនស្តាប់ មិនបដិបត្តិធម៌នោះឯង ជាអ្នកខ្ពើមនូវធម៌នោះ ជាអ្នកដឹងបានងាយ ព្រោះឃើញនូវបដិបត្តិខុសនោះហើយ គប្បីដឹងបាន ។

ក្នុងគាថានោះ អ្នកសិក្សាគប្បីជ្រាបយ៉ាងនេះថា ព្រះដ៏មានព្រះភាគកាលទ្រង់សម្តែងធម៌ដែលជាបដិបក្ខដោយអត្ថ ទ្រង់ក៏សម្តែងភាពជាអ្នកប្រាថ្នាធម៌ សម្តែងផ្លូវនៃសេចក្តីចម្រើនហើយ ទ្រង់សម្តែងភាពជាអ្នកខ្ពើមធម៌ ថាជាផ្លូវនៃសេចក្តីវិនាស ។ លំដាប់នោះ ទេវតានោះត្រេកអរក្រៃលែង នូវភាសិតរបស់ព្រះដ៏មានព្រះភាគ ទើបទូលថា **ឥតិ ហេតំ** ដូច្នេះ ។

អត្ថនៃពាក្យនោះដូច្នេះថា ព្រោះហេតុនោះឯងខ្ញុំដឹងច្បាស់ គឺចងចាំនូវសេចក្ដីនេះ ដោយប្រការដែលព្រះដ៏មានព្រះភាគ ត្រាស់ហើយនោះឯងថា ការវិនាសនោះជាទី ១ គឺការវិនាសនោះមានការស្អប់ធម៌ ជាលក្ខណៈ ជាប្រការទី ១ អធិប្បាយថា ពួកខ្ញុំជាអ្នកមកហើយដើម្បីដឹងច្បាស់នូវផ្លូវនៃសេចក្ដីវិនាសពួកណា ក្នុងផ្លូវនៃសេចក្ដីវិនាសទាំងនោះ នេះជាផ្លូវនៃសេចក្ដីវិនាសទី ១ ។

ក្នុងពាក្យនោះ មានវិគ្គហៈថា សត្វទាំងឡាយរមែងវិនាសដោយហេតុនោះ ព្រោះដូច្នោះ ទើបហេតុនោះឈ្មោះថា **បរាភវោ** ប្រែថា សេចក្ដីវិនាស ។ សត្វទាំងឡាយ រមែងវិនាសព្រោះអ្វី ក៏ព្រោះហេតុដែលជាផ្លូវ គឺជាហេតុនៃសេចក្ដីវិនាស ព្រោះថា ការផ្សេងគ្នានៅក្នុងសេចក្ដីនេះ មានត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ តែដោយអត្ថ ពាក្យថា វិនាស ឬថា ផ្លូវនៃសេចក្ដីវិនាស មិនមានការផ្សេងគ្នាឡើយ ។

ទេវបុត្តគិតថា អញត្រេកអរថា អញដឹងច្បាស់នូវផ្លូវរបស់អ្នកវិនាសនេះយ៉ាងនេះហើយ បំណងនឹងដឹងសេចក្ដីដទៃក្រៅអំពីនោះ ទើបទូលថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្ដែងនូវហេតុទី ២ អ្វីជាប្រធាននៃសេចក្ដីវិនាស ។ តអំពីនេះទៅ អ្នកសិក្សាគប្បីជ្រាបអត្ថទី ៣-៤ ជាដើម ដោយន័យនេះឯង គប្បីជ្រាបអត្ថក្នុងចំណែកព្យាករណ៍ថា សត្វនោះៗ ប្រកបព្រមហើយ ដោយផ្លូវនៃសេចក្ដីវិនាសនោះៗ សត្វមួយមិនរួមជាមួយសត្វទាំងពួង

សត្វទាំងពួងក៏មិនរួមជាមួយសត្វមួយ ព្រោះហេតុនោះ ទើបទ្រង់ព្យាករ ដល់ផ្លូវនៃសេចក្តីវិនាសទាំងឡាយ មានបែបផ្សេងៗ គ្នា ដោយទេសនា មានបុគ្គលាធិដ្ឋានប៉ុណ្ណោះ ដោយន័យជាដើមថា **អសន្តស្ស បិយា ហោន្តិ** បុគ្គលមានពួកអសប្បុរសជាទីស្រឡាញ់ ដូច្នេះ ដើម្បីទ្រង់សម្តែងផ្លូវនៃការ វិនាសនោះៗ នៃសត្វទាំងនោះ ។ ក្នុងគាថានោះ មានអត្ថវណ្ណនាដោយ សង្ខេបដូច្នេះថា គ្រូទាំង ៦ ឬបុគ្គលពួកដទៃដែលប្រកបព្រមដោយកាយកម្ម វចីកម្ម និងមនោកម្មដែលមិនស្ងប់ ឈ្មោះថា អសប្បុរស អសប្បុរសនោះ ជាទីស្រឡាញ់របស់បុគ្គលនោះ ដូចអចេលកកោរក្ខត្តិយៈជាដើម ជាទី ស្រឡាញ់នៃមនុស្សទាំងឡាយ មានស្តេចសុនក្ខត្តៈជាដើម ។

ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវក ឬបុគ្គលដទៃដែលប្រកបហើយដោយ កាយកម្ម វចីកម្ម មនោកម្មដែលស្ងប់ហើយ ឈ្មោះថា សប្បុរស មិនធ្វើ សប្បុរសទាំងនោះឲ្យជាទីស្រឡាញ់ អធិប្បាយថា មិនធ្វើសប្បុរសទាំងនោះ ឲ្យជាទីស្រឡាញ់ ជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្តរបស់ខ្លួន ។

សេចក្តីផ្សេងគ្នានៃពាក្យក្នុងគាថានេះ គប្បីជ្រាបថា ទ្រង់ធ្វើហើយដោយ អំណាចនៃវេនេយ្យសត្វ ម្យ៉ាងទៀត បទថា **សន្តេ ន កុរុតេ បិយំ** អធិប្បាយ ថា មិនធ្វើសប្បុរសទាំងឡាយ គឺមិនសេពសប្បុរសទាំងឡាយ ដូចលោក អ្នកចេះសព្ទទាំងឡាយពណ៌នាថា ក្នុងអត្ថនេះថា ធ្វើព្រះរាជាឲ្យជាទីស្រឡាញ់ អត្ថ ក៏គឺរមែងសេពព្រះរាជា ។

បទថា **បិយំ** សេចក្ដីថា ស្រឡាញ់ ត្រេកអរ បាមោជ្ជ ។ ទិដ្ឋិ ៦២ ឬអកុសលកម្មបថ ១០ ឈ្មោះថា ធម៌របស់អសប្បុរស រមែងពេញចិត្ត រមែងចូលចិត្ត រមែងប្រាថ្នា រមែងសេពនូវធម៌របស់អសប្បុរសនោះ ។

ឋានៈ ៣ យ៉ាង គឺភាពជាអ្នកមានអសប្បុរសជាទីស្រឡាញ់ ១ ភាពជាអ្នកមានសប្បុរសមិនជាទីស្រឡាញ់ ១ គាប់ចិត្តក្នុងធម៌របស់អសប្បុរស ១ ទ្រង់ត្រាស់ថា ជាផ្លូវនៃសេចក្ដីវិនាសដោយគាថានេះ ដោយប្រការដូច្នេះ ។ បុគ្គលប្រកបដោយឋានៈ ៣ យ៉ាងនោះរមែងវិនាស គឺរមែងអន្តរាយ រមែងមិនដល់នូវសេចក្ដីចម្រើនក្នុងលោកនេះ ឬលោកខាងមុខ ព្រោះហេតុនោះទើបហៅថា ជាផ្លូវនៃសេចក្ដីវិនាស ។ ចំណែកសេចក្ដីពិស្ដារក្នុងគាថានេះ ខ្ញុំនឹងពោលក្នុងអត្ថនៃគាថាថា ការមិនសេពគប់បុគ្គលពាល ១ ការសេពគប់បុគ្គលជាបណ្ឌិត ១ ដូច្នេះ ។

បុគ្គលណាដើរក្ដី អង្គុយក្ដី ឈរក្ដី ដេកក្ដី រមែងលក់នោះឯង បុគ្គលនោះ ឈ្មោះថា **និទ្ទាសីលី** ។ បុគ្គលតាមប្រកបសេចក្ដីត្រេកអរក្នុងការប្រឡូកប្រឡំ គឺត្រេកអរក្នុងកាមគុណ ឈ្មោះថា **សភាសីលី** ។ បទថា **អនុដ្ឋាតា** បានដល់ ជាអ្នកវៀរចាកតេជះនៃសេចក្ដីព្យាយាម ជាអ្នកមិនក្រោកឡើងជាប្រក្រតី ។ ជាគ្រហស្ថ ត្រូវអ្នកដទៃដាស់តឿន មិនប្រាថ្នាការងាររបស់គ្រហស្ថ ជាបព្វជិត ក៏មិនប្រាថ្នា ការងាររបស់បព្វជិត ។

បទថា **អលសោ** សេចក្ដីថា បុគ្គលមានសេចក្ដីខ្ជិលច្រអូស ជាម្ចាស់

ផ្ទះ ត្រូវការនោកន្ទុយគ្រប់សង្កត់ដោយចំណែកមួយ បើឈរក៏ឈរក្នុងទីឈរ នោះឯង អង្គុយហើយ អង្គុយក្នុងទីអង្គុយនោះឯង រមែងមិនសម្រេចឥរិយាបថដទៃ ដោយឧស្សាហ៍របស់ខ្លួន ។ ក្នុងរឿងនេះ មានរឿងភ្លើងឆេះព្រៃ ក៏នៅតែខ្ជិលច្រអូស ជាឧទាហរណ៍ ។ ក្នុងទីនេះ ជាការកំណត់យ៉ាងឧក្រិដ្ឋ ។

ការខ្ជិលច្រអូស សូម្បីកំណត់ដោយថោកទាបជាងនោះ ក៏គប្បីជ្រាបថា ខ្ជិលច្រអូសដូចគ្នា ។

សេចក្តីក្រោធជាគ្រឿងប្រាកដរបស់មនុស្សនោះ ដូចទង់ជាគ្រឿងប្រាកដរបស់រថ ដូចផ្សែងជាគ្រឿងប្រាកដរបស់ភ្លើង ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **កោធបញ្ញាណោ** បុគ្គលដែលជាទោសចរិត ក្រោធងាយ មានចិត្តដូចមុខដំបៅ រមែងមានសភាពដូច្នោះ ។

ឋានៈ ៥ គឺគាប់ចិត្តក្នុងការដេក ១ គាប់ចិត្តក្នុងការជជែក ១ មិនព្យាយាម ១ ខ្ជិលច្រអូស ១ សេចក្តីក្រោធ ១ ព្រះដ៏មានព្រះភាគត្រាស់ថា ជាផ្លូវនៃការវិនាសដោយគាថានេះ ព្រោះបុគ្គលដល់ព្រមដោយឋានៈ ៥ យ៉ាងនោះ ជាគ្រហស្ថ ក៏មិនដល់នូវសេចក្តីចម្រើនរបស់គ្រហស្ថ ជាបព្វជិត ក៏មិនដល់នូវសេចក្តីចម្រើនរបស់បព្វជិត រមែងវិនាសតែម្យ៉ាង រមែងវិនាសតែមួយចំណែកពិត ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាស ។

ស្រីអ្នកឲ្យកើត គប្បីជ្រាបថា មាតា ប្រុសអ្នកឲ្យកើតនោះឯង គប្បីជ្រាបថា បិតា ឈ្មោះថា **ជិណ្ណកំ** ព្រោះភាពជាអ្នកមានសរីរៈយុរយារ ឈ្មោះ

ថា **គតយោព្វនំ** ព្រោះឈានកន្លងនូវភាពជាកំលោះ ក្រមុំ គឺមានវ័យ ៨០ ឆ្នាំ ឬ ៩០ ឆ្នាំ ជាអ្នកមិនអាចធ្វើនូវការងារទាំងឡាយដោយខ្លួនឯង ។ បទថា **បហុសន្តោ** សេចក្តីថា ជាអ្នកអាច គឺមានការសម្រេចហើយ ជាអ្នកនៅយ៉ាងសប្បាយ ។ បទថា **ន ភរតិ** គឺមិនចិញ្ចឹម ការមិនចិញ្ចឹម គឺការមិនមើលថែ ការមិនទំនុកបម្រុងមាតាបិតា ត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាសតែម្យ៉ាងប៉ុណ្ណោះ ដោយគាថានេះ ។ ព្រោះបុគ្គលប្រកបព្រមដោយការមិនចិញ្ចឹមមាតាបិតានោះ រមែងមិនសម្រេចដល់អានិសង្សក្នុងការចិញ្ចឹម មាតាបិតាដែលត្រាស់ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) ថា

ការបម្រើចំពោះមាតាបិតាទាំងឡាយនោះ បណ្ឌិតទាំងឡាយ តែងសរសើរបុគ្គលនោះ ក្នុងលោកនេះដោយពិត លុះលះលោកនេះទៅ រមែងរីករាយក្នុងស្ថានសួគ៌ ដូច្នេះ ។

បុគ្គលមិនចិញ្ចឹមមាតាបិតា ដល់នូវសេចក្តីនិន្ទា និងការតិះដៀលថា មាតាបិតាមិនចិញ្ចឹម នឹងចិញ្ចឹមបុគ្គលណាហ្ន៎ នឹងដល់នូវទុគ្គតិ ឈ្មោះថារមែងវិនាសនោះឯង ព្រោះហេតុនោះ ទើបត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាស ។

បុគ្គលរមែងបោកបញ្ឆោត បុគ្គលដែលជាព្រាហ្មណ៍ ព្រោះជាអ្នកបន្សាត់បាបទាំងឡាយហើយ ឈ្មោះថា សមណៈ ព្រោះជាអ្នកស្ងប់ហើយ ឬព្រាហ្មណ៍ដែលជាអ្នកកើតក្នុងត្រកូលព្រាហ្មណ៍ សមណៈដែលចូលដល់បព្វជ្ជា ឬបុគ្គលអ្នកសូមណាមួយដទៃអំពីនោះ ដោយមុសាវាទ ព្រោះហេតុ

នោះ បុគ្គលបវារណាថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ពោលដល់បច្ច័យ ត្រូវសមណៈ ឬព្រាហ្មណ៍សូមហើយ ឬទទួលពាក្យហើយ ឲ្យតិចខាងក្រោយ ពោលឲ្យឃ្លាងឃ្លាតនឹងសមណៈព្រាហ្មណ៍នោះ ។

ការបោកបញ្ឆោតព្រាហ្មណ៍ជាដើម ដោយមុសាវាទ ត្រាស់ថា ជាផ្លូវនៃសេចក្ដីវិនាសតែម្យ៉ាងប៉ុណ្ណោះ ដោយគាថានេះ ព្រោះបុគ្គលដល់ព្រមដោយការបោកបញ្ឆោតនោះ រមែងដល់នូវការទិន្នទុក្ខក្នុងលោកនេះ ដល់នូវទុគ្គតិក្នុងសម្បរាយភព និងវិបត្តិចាកបំណងសូម្បីក្នុងសុគតិ សមដូចព្រះតម្រាស់ថា

ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីលហើយ តែងមានកិត្តិសព្ទដ៏អាក្រក់ខ្ចរខ្ចាយទៅ ។ ម្យ៉ាងទៀត ទ្រង់ត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្ដេចខ្លះ ។ គឺជាអ្នកនិយាយពាក្យកុហក ១ ដូច្នេះ ។

ម្នាលសារីបុត្រ បុគ្គលពួកខ្លះ ក្នុងលោកនេះ ចូលទៅរកសមណៈឬព្រាហ្មណ៍ ហើយបវារណាថា បពិត្រលោកដ៏ចម្រើន ចូរលោកប្រាប់ ( សូម ) ដោយបច្ច័យចុះ បុគ្គលនោះបវារណាដោយបច្ច័យណាមែន តែមិនឲ្យបច្ច័យនោះទេ បុគ្គលនោះ បើច្យុតអំពីលោកនោះទៅ មកកើតក្នុងលោកនេះ បុគ្គលនោះ ប្រកបការជំនួញណា ជំនួញរបស់បុគ្គលនោះ រមែងខាត

ទុន ទៅជាប្រក្រតី ។ ម្នាលសារីបុត្រ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ។បេ។ បុគ្គលនោះ បវារណាដោយបច្ច័យណា ក៏ឲ្យបច្ច័យនោះតាមបំណងមែន បុគ្គលនោះ បើច្យុតអំពីលោកនោះទៅ បានមកកើតក្នុងលោកនេះ បុគ្គលនោះ ប្រកបជំនួញណា ជំនួញរបស់បុគ្គលនោះ រមែងមានចំណេញដូចបំណង ដូច្នេះ ។

បុគ្គលដល់នូវការនិន្ទាជាដើមយ៉ាងនេះ ឈ្មោះថា រមែងវិនាស ព្រោះហេតុនោះ ទើបត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាស ។

បទថា **បហុតវិត្តោ** បានដល់ មានមាស ប្រាក់ និងកែវមណីច្រើន ។ បទថា **សហិរញ្ញោ** បានដល់ មានកហាបណៈ ។ បទថា **សភោជនោ** គឺដល់ព្រមដោយរបស់ស៊ី គឺសូបព្យញ្ជនៈច្រើន ។ បទថា **ឯកោ ភុញ្ជតិ** សេចក្តីថា មិនឲ្យរបស់បរិភោគដែលឆ្ងាញ់ សូម្បីដល់កូនរបស់ខ្លួន រមែងបរិភោគក្នុងឱកាសកំបាំង ព្រោះហេតុនោះ ទើបឈ្មោះថា បរិភោគរបស់ឆ្ងាញ់តែម្នាក់ឯង ។

សេចក្តីកំណាញ់ក្នុងរបស់បរិភោគ ព្រោះភាពជាអ្នកជាប់ជំពាក់ក្នុងរបស់បរិភោគ ត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាសតែម្យ៉ាងប៉ុណ្ណោះ ដោយគាថានេះ ព្រោះបុគ្គលដល់ព្រមដោយសេចក្តីកំណាញ់ក្នុងរបស់បរិភោគនោះ ដល់នូវហេតុទាំងឡាយ មានការនិន្ទា ការតិះដៀល ទុគ្គតិជាដើម ឈ្មោះថា រមែងវិនាសនោះឯង ព្រោះហេតុនោះ ទើបត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាស ។

គប្បីប្រកបបទទាំងអស់តាមទំនងព្រះសូត្រ ដោយន័យដែលពោលហើយនោះឯង តែឥឡូវនេះ ខ្ញុំខ្វាចពិស្តារពេក មិនសម្ដែងន័យដោយយោជនាទាំងឡាយ នឹងពោលត្រឹមអត្ថប៉ុណ្ណោះ ។

បុគ្គលណាញ៉ាំងមានះឲ្យកើតឡើងថា អាត្មាអញជាអ្នកដល់ព្រមដោយជាតិ ជាអ្នកតម្កើងខ្លួនព្រោះមានះ ជាបុគ្គលបំប៉ោងខ្លួន ដូចស្នប់ពេញដោយខ្យល់ដូច្នោះ រមែងមិនឱនលំទោនចំពោះបុគ្គលណាម្នាក់នោះ បុគ្គលនោះឈ្មោះថា មានះព្រោះជាតិ ។ ការមានះព្រោះទ្រព្យ និងមានះព្រោះគោត្ត ក៏ន័យនេះ ។ បទថា **សញ្ញាតិ មតិ មញ្ញោតិ** សេចក្ដីថា រមែងមើលងាយសូម្បីញាតិរបស់ខ្លួនព្រោះជាតិ ដូចស្ដេចសក្យៈទាំងឡាយ មើលងាយវិឌូឌភៈដូច្នោះ និងរមែងមើលងាយព្រោះទ្រព្យថា បុគ្គលនេះកំព្រាលំបាក ដូច្នេះរមែងមិនធ្វើសូម្បីត្រឹមតែសាមីចិកម្ម ញាតិទាំងឡាយនោះ រមែងប្រាថ្នាសេចក្ដីវិនាសប៉ុណ្ណោះដល់បុគ្គលនោះ ឋានះមាន ៤ យ៉ាង ដោយវត្ថុមានតែម្យ៉ាងដោយលក្ខណៈ ត្រាស់ថា ជាផ្លូវនៃសេចក្ដីវិនាស ដោយគាថានេះ ។ បទថា **ឥត្ថីធុត្តោ** សេចក្ដីថា ជាអ្នកត្រេកត្រអាលក្នុងស្រីទាំងឡាយ ឲ្យនូវទ្រព្យដែលមានទាំងអស់ហើយ សង្គ្រោះស្រីដទៃៗ ។ ម្យ៉ាងទៀត បុគ្គលចោលនូវរបស់ដែលមាននៃខ្លួនទាំងអស់ហើយ ប្រកបនូវការផឹកសុរា ឈ្មោះថា **សុរាធុត្តោ** បុគ្គលចោលសូម្បីតែសំពត់ស្លៀក ហើយប្រកបនូវការលេងល្បែងភ្នាល់ ឈ្មោះថា **អក្ខធុត្តោ** បុគ្គលដែលដល់ព្រមដោយឋានៈទាំង ៣

គប្បីជ្រាបថា បំផ្លាញទ្រព្យដែលខ្លួនរកមកបាន ព្រោះញុំាំងទ្រព្យឯណាមួយ ដែលរកបានមកនោះឲ្យវិនាស បុគ្គលយ៉ាងនេះ រមែងវិនាសតែម្យ៉ាង ដោយហេតុនោះ ឋានៈ ៣ យ៉ាងនោះ ព្រះមានព្រះភាគត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាសរបស់បុគ្គលនោះ ដោយគាថានេះ ។

បទថា **សេហិ ទារេហិ** បានដល់ ដោយកិរិយារបស់ខ្លួន ។ បុគ្គលណាមិនសន្តោសដោយកិរិយារបស់ខ្លួន ប្រទូស្តក្នុងស្រីពេស្យា ឬក្នុងកិរិយារបស់អ្នកដទៃ បុគ្គលនោះឈ្មោះថា រមែងវិនាសដោយចំណែកមួយ ព្រោះការបន្ថែមឲ្យនូវទ្រព្យដល់ស្រីពេស្យា ព្រោះសេពកិរិយាអ្នកដទៃ និងព្រោះកម្មករណៈមានរាជទណ្ឌជាដើម ដោយហេតុនោះ ទើបឋានៈ ២ យ៉ាងនោះ ត្រាស់ថាជាផ្លូវនៃសេចក្តីវិនាសរបស់បុគ្គលនោះ ដោយគាថានេះ ។

បទថា **អតីតយោព្វនោ** សេចក្តីថា បុរសកន្លងនូវវ័យក្មេង អាយុ ៨០ ឬ ៩០ ឆ្នាំហើយ នាំមក គឺបម្រើ ។ បទថា **តិម្ពរុត្ថនឹ** បានដល់ ស្រីវ័យក្មេងមានដោះដូចផ្លែទន្លាប់ គឺស្រីវ័យក្មេង ។ បទថា **តស្សា ឥស្សា ន សុបតិ** សេចក្តីថា ការត្រេកអរនឹងការសង្វាសជាមួយប្រុសចាស់ទាំងឡាយ រមែងមិនជាទីគាប់ចិត្តរបស់ស្រីវ័យក្មេង បុរសចាស់ កាលរក្សាកិរិយាក្មេងនោះ ព្រោះភាពជាអ្នកហួងហែងថា ស្រីនេះ កុំគប្បីប្រាថ្នាប្រុសកំលោះដទៃឡើយ ឈ្មោះថា រមែងដេកមិនលក់ ប្រុសចាស់ត្រូវកាមរាគ និងការជាប់ជំពាក់ដុតរោល មិនប្រកបការងារខាងក្រៅ ឈ្មោះថា រមែងវិនាសដោយ

ចំណែកមួយ ដោយហេតុនោះ ការដេកមិនលក់ ព្រោះការជាប់ជំពាក់តែម្យ៉ាង ប៉ុណ្ណោះ ទើបទ្រង់ត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាស របស់បុរសចាស់នោះ ដោយគាថានេះ ។

បទថា **សោណ្ឌី** សេចក្តីថា ជាអ្នករវើ្សរវោ្សះ គឺជាអ្នកជាប់ចិត្តក្នុងត្រី សាច់ និងទឹកស្រវឹងជាដើម ។ បទថា **វិកិរណី** បានដល់ មានប្រក្រតីចាយទ្រព្យខ្ជះខ្ជាយដើម្បីប្រយោជន៍ដល់ត្រីសាច់ និងទឹកស្រវឹងទាំងនោះជាដើម ឲ្យវិនាស ដូចបាចធូលី ដូច្នោះ ។ បទថា **បុរិសំ វាបិ តាទិសំ** សេចក្តីថា បុគ្គលណាតាំងបុរសបែបនោះក្នុងភាពជាធំ គឺឲ្យវត្ថុ មានត្រាប្រថាប់ជាដើម ហើយ ឲ្យធ្វើសេចក្តីខ្វល់ខ្វាយក្នុងឃរាវាស ក្នុងការងារ ឬក្នុងវោហារ មានការជួញដូរជាដើម បុគ្គលនោះ កាលដល់នូវការអស់ទ្រព្យ ព្រោះទោសរបស់បុរសនោះ ឈ្មោះថា រមែងវិនាសតែម្យ៉ាង ដោយហេតុនោះ ការតាំងស្រី ឬបុរសបែបនោះក្នុងភាពជាធំ ទ្រង់ត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាសតែម្យ៉ាងប៉ុណ្ណោះ របស់បុគ្គលនោះ ដោយគាថានេះ ។

ឈ្មោះថាមានភោគទ្រព្យតិច ព្រោះមិនមានភោគទ្រព្យទាំងឡាយដែលសន្សំទុក និងព្រោះមិនមានផ្លូវចម្រើននៃភោគទ្រព្យ ។ បទថា **មហាតណ្ហោ** សេចក្តីថា ជាអ្នកដល់ព្រមហើយដោយការប្រាថ្នាធំ ក្នុងភោគទ្រព្យច្រើន គឺមិនសន្តោសដោយភោគទ្រព្យ តាមដែលខ្លួនរកមកបាន ។

បទថា **ខត្តិយេ ជាយតេ កុលេ** សេចក្តីថា កើតក្នុងត្រកូលក្សត្រ ។

បទថា **សោ ច រដ្ឋំ បត្ថយតិ** សេចក្ដីថា បុគ្គលនោះ ប្រាថ្នារាជទាយាទ ដែលខ្លួនមិនគួរបាន ឬរបស់អ្នកដទៃព្រោះភាពជាអ្នកប្រាថ្នា ក្នុងការប្រាថ្នារាជសម្បត្តិ គឺព្រោះការប្រាថ្នាធំនោះដោយមិនមែនឧបាយ គឺថា ដោយខុសលំដាប់ បុគ្គលនោះ កាលប្រាថ្នាយ៉ាងនោះ ឲ្យនូវភោគទ្រព្យតិចនោះ ដល់មនុស្សទាំងឡាយ មានទាហានជាដើម កាលមិនបានសម្រេចដល់រាជសម្បត្តិ ឈ្មោះថា រមែងវិនាសតែម្យ៉ាង ដោយហេតុនោះ ការប្រាថ្នារាជសម្បត្តិនោះ ទើបទ្រង់ត្រាស់ថា ជាផ្លូវនៃសេចក្ដីវិនាស របស់បុគ្គលនោះ តែម្យ៉ាងប៉ុណ្ណោះ ដោយគាថានេះ ។

ខាងមុខអំពីនេះ បើទេវតានោះគប្បីទូលសួរថា បពិត្រព្រះដ៏មានព្រះភាគ សូមទ្រង់ត្រាស់ប្រាប់បុគ្គលវិនាសទី ១៣ ។បេ។ បពិត្រព្រះមានព្រះភាគ សូមទ្រង់ត្រាស់ប្រាប់បុគ្គលដែលវិនាសទី ១ សែនដូច្នេះសោតព្រះមានព្រះភាគ គប្បីត្រាស់ប្រាប់បុគ្គលវិនាសទាំងនោះ តែទេវតាគិតថា ប្រយោជន៍អ្វីដោយបុគ្គលវិនាសទាំងនេះ ដែលទូលសួរហើយ ការធ្វើសេចក្ដីចម្រើនតែមួយគាថាក្នុងសូត្រនេះ ក៏មិនមាន ដូច្នេះ កាលមិនដាក់ចិត្តស្ដាប់ផ្លូវនៃសេចក្ដីវិនាសទាំងនោះ ទូលសួរត្រឹមប៉ុណ្ណោះហើយ មានវិប្បដិសារៈនៅស្ងៀម ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ជ្រាបអធ្យាស្រ័យរបស់ទេវតានោះហើយ កាលទ្រង់ប្រមូលទេសនា ទើបត្រាស់គាថានេះថា

**ឯតេ បរាភវេ លោកេ ។**

ក្នុងបទទាំងនោះ បទថា **បណ្ឌិតោ** បានដល់ ដែលដល់ព្រមដោយការពិចារណាដោយជុំវិញ ។ បទថា **សមវេក្ខិយ** បានដល់ ពិចារណាហើយដោយបញ្ញាចក្ខុ ។ បទថា **អរិយោ** បានដល់ មិនមែនដោយមគ្គ មិនមែនដោយផល ឈ្មោះថា **អរិយ** ព្រោះអត្ថថា មិនប្រព្រឹត្តទៅក្នុងវត្ថុដែលមិនគួរប្រព្រឹត្ត ពោល គឺការវិនាសនោះ ។ បណ្ឌិតគប្បីឃើញការវិនាសទាំងឡាយហើយ វៀរដោយទស្សនៈណា និងដោយបញ្ញាណា ឈ្មោះថា ដល់ព្រមដោយការឃើញ ព្រោះភាពជាអ្នកដល់ព្រមហើយ ដោយទស្សនៈ និងបញ្ញានោះ ។

បទថា **ស លោកំ ភជតេ សិវំ** បានដល់ បណ្ឌិតនោះ គឺបណ្ឌិតបែបនោះ រមែងគប់រក គឺរមែងជិតស្និទ្ធ អធិប្បាយថា ចូលទៅកាន់លោកដែលក្សេម គឺទេវលោក ដែលជាឧត្តមក្ខេត្ត មិនមានឧបទ្រវៈ ។

ក្នុងកាលចប់ទេសនា ទេវតាទាំងឡាយ ស្តាប់ផ្លូវនៃសេចក្តីវិនាសទាំងឡាយហើយ តាំងចិត្តមាំដោយឧបាយ សមគួរដល់សេចក្តីសង្វេគដែលកើតឡើង សម្រេចសោតាបត្តិផល សកទាគាមិផល និងអនាគាមិផល ហួសនឹងរាប់ ដូចព្រះតម្រាស់ត្រាស់ថា

ទេវតាទាំងឡាយដែលសម្រេចមគ្គផលក្នុងសូត្រនោះ គឺមហាសមយសូត្រ មង្គលសូត្រ សមចិត្តសូត្រ រាហុលោវាទសូត្រ ធម្មចក្កសូត្រ បរាភវសូត្រ និងទេវតាសមសូត្រ មិនមានតិច គឺប្រមាណមិនបាន ចំណែកធម្មាភិ-

សម័យក្នុងការប្រារព្ធសូត្រនេះ ក៏ហួសគណនារាប់ ដូច្នេះ ។ល។

**អដ្ឋកថា បរាភវសូត្រ ចប់**

# សុត្តន្តបិដក

## វសលសូត្រទី ៧

[ ១២ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ យាងទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ សម័យនោះឯង អគ្គិកភារទ្វាជ-ព្រាហ្មណ៍ ( ព្រាហ្មណ៍ឈ្មោះភារទ្វាជៈ អ្នកបង្កាត់ភ្លើង ) កំពុងបង្កាត់ភ្លើង ផ្គូផ្គងគ្រឿងបូជាក្នុងលំនៅ ។ លំដាប់នោះ ព្រះមានព្រះភាគ ត្រាច់ទៅកាន់លំដាប់ច្រក ( ផ្ទះ ) ដើម្បីបិណ្ឌបាត ចៀងចូលទៅត្រង់លំនៅរបស់អគ្គិក-ភារទ្វាជព្រាហ្មណ៍ ។ អគ្គិកភារទ្វាជព្រាហ្មណ៍ បានឃើញព្រះមានព្រះភាគយាងមកអំពីចម្ងាយ លុះឃើញហើយ ក៏ពោលទ្រគោះទៅរកព្រះមានព្រះភាគថា នែស្រមណ៍កំណោរ ចូរអ្នកឈប់ក្នុងទីនេះសិន នែសមណៈ ចូរអ្នកឈប់ក្នុងទីនេះសិន នែអ្នកថោកទាប ចូរអ្នកឈប់ក្នុងទីនេះសិន ។

កាលដែលអគ្គិកភារទ្វាជព្រាហ្មណ៍ និយាយយ៉ាងនេះហើយ ព្រះមាន

ព្រះភាគត្រាស់តបនឹងអគ្គិកភារទ្វាជព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍ អ្នកស្គាល់បុគ្គលថោកទាប ឬធម៌ដែលធ្វើឲ្យថោកទាបដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំមិនទាន់ស្គាល់បុគ្គលថោកទាប ឬធម៌ដែលធ្វើឲ្យថោកទាបទេ សូមព្រះគោតមដ៏ចម្រើន សម្តែងធម៌ដែលជាហេតុ ឲ្យខ្ញុំស្គាល់បុគ្គលថោកទាប ឬធម៌ដែលធ្វើឲ្យថោកទាបផង ។ ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយល្អចុះ តថាគតនឹងសម្តែងប្រាប់ ។ អគ្គិកភារទ្វាជព្រាហ្មណ៍ ទទួលស្តាប់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ សម្តែងសេចក្តីនុ៎ះថា

[ ១៣ ] បុគ្គលណា មានសេចក្តីក្រោធ ចងសេចក្តីក្រោធទុក ( គំនុំ ) ជាបុគ្គលបាប លុបគុណគេ ប្រាសចាកសម្មាទិដ្ឋិ មានមាយា អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណាក្នុងលោកនេះ បៀតបៀនទូវសត្វ ដែលមានកំណើតម្តង ឬមានកំណើតពីរដង ឬបុគ្គលណា មិនមានសេចក្តីអាណិតចំពោះសត្វ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណាសម្លាប់ ឬឡោម រឹបជាន់នូវអ្នកស្រុក ឬអ្នកនិគម ដែលអ្នកផងដឹងច្បាស់ថា ជាអ្នកសង្កត់សង្កិនគេ អ្នក

ចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណាកាន់យកទ្រព្យក្នុងស្រុក ឬក្នុងព្រៃ ដែលបុគ្គលប្រកាន់ថាជារបស់អញ ជាទ្រព្យដែលគេមិនឲ្យ ដោយអាការលួច អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណាបុលទ្រព្យគេ យកមកប្រើប្រាស់ ហើយគេចកែថា ( អញ ) មិនជំពាក់បំណុលអ្នកទេ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណាសម្លាប់អ្នកផង ដែលដើរក្នុងផ្លូវ ដោយប្រាថ្នាទ្រព្យរបស់ណាមួយ ដណ្តើមយកទ្រព្យរបស់ណាមួយ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណាគេសួរជាបន្ទាល់ និយាយកុហក ព្រោះហេតុនៃខ្លួនក្តី ព្រោះហេតុនៃបុគ្គលដទៃក្តី ព្រោះហេតុនៃទ្រព្យក្តី អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណាប្រព្រឹត្តខុច ចំពោះប្រពន្ធរបស់ពួកញាតិ ឬសំឡាញ់ដោយការកំហែង ឬដោយការស្រឡាញ់ស្មគ្រចិត្ត អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ជាអ្នកស្តុកស្តម្ភ តែមិនចិញ្ចឹមមាតា ឬបិតាដែលចាស់ជរា មានវ័យកន្លងហើយ អ្នកចូរដឹងបុគ្គលនោះថា

ជាបុគ្គលថោកទាប ។

បុគ្គលណា ប្រហារមាតា ឬបិតា បងប្អូនប្រុស បងប្អូនស្រី ឬម្ដាយក្មេក ឬក៏ជេរប្រទេចដោយវាចា អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា កាលដែលគេសួរចំពោះហេតុមានប្រយោជន៍ ហើយពន្យល់ប្រាប់ហេតុ ដែលគ្មានប្រយោជន៍ បង្ហាញដោយពាក្យបិទបាំង អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា បានធ្វើបាបកម្មហើយប្រាថ្នាថា អ្នកផងកុំគប្បីដឹងនូវអញ បុគ្គលណាមានការងារបិទបាំង អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ទៅកាន់ត្រកូលញាតិមិត្តដទៃ ទាំងបានបរិភោគភោជនដ៏ស្អាត ហើយមិនបានបូជាគេ ដែលមកកាន់ផ្ទះរបស់ខ្លួនវិញ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា បញ្ឆោតព្រាហ្មណ៍ក្ដី សមណៈក្ដី ឬអ្នកសូមឯទៀតក្ដី ដោយពាក្យកុហក អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ជេរសមណៈ ឬព្រាហ្មណ៍ ដោយវាចាក្ដី មិនឲ្យភោជនក្នុងវេលាភត្តកាល ដែលគួរទំនុកបម្រុងក្ដី អ្នកចូរ

ដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណាក្នុងលោកនេះ ត្រូវមោហៈរួបរឹតហើយ កាល ស្វែងរកចំពោះទ្រព្យណាមួយ ក៏និយាយបោកប្រាស់ ដោយពាក្យមិនពិត ( នឹងស្ត្រី ) អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា លើកតម្កើងខ្លួនឯង ឬបន្តុះបង្អាប់ពួកជនដទៃ តែខ្លួនជាអ្នកសាបសូន្យ ( ចាកគុណវុឌ្ឍិ ) ព្រោះការតម្កើង និងការបន្តុះបង្អាប់របស់ខ្លួន អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា កោងកាចក្តី ទ្រឹស្តិស្មូរក្តី មានសេចក្តីប្រាថ្នាអាក្រក់ក្តី កំណាញ់ក្តី អំនួតក្តី មិនអៀនខ្មាសក្តី មិនខ្លាចបាបក្តី អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ជេរប្រទេចព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធ ឬបរិព្វាជក ឬក៏គ្រហស្ថ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា មិនមែនជាអរហន្តទេ តែប្តេជ្ញា ( ខ្លួន ) ថាជាអរហន្ត បុគ្គលនោះជាចោរក្នុងលោក ព្រមទាំងព្រហ្មលោក នេះឯងជាបុគ្គលថោកទាបបំផុត ។

បុគ្គលថោកទាបទាំងនេះឯង តថាគតបានប្រកាសហើយ បុគ្គលមិនមែនថោកទាបព្រោះជាតិ មិនមែនជាព្រាហ្មណ៍ព្រោះជាតិទេ បុគ្គលថោកទាបព្រោះកម្ម ជាព្រាហ្មណ៍ក៏ព្រោះកម្ម ។

អ្នកទាំងឡាយ ចូរដឹងនូវសេចក្តីនោះ ដោយពាក្យនេះចុះ ដូចឧទាហរណ៍នេះឯង កូនរបស់មនុស្សចណ្ឌាល មានឈ្មោះប្រាកដថា សោបាកមាតង្គៈ មាតង្គកុមារនោះ បាននូវយសដ៏ប្រសើរ ដែលគេបានដោយក្រក្រៃលែង ពួកក្សត្រ ព្រាហ្មណ៍ជាច្រើន តែងមកកាន់ទីបម្រើ របស់កុមារនោះ ។

មាតង្គកុមារនោះ ឡើងកាន់យាន គឺសមាបត្តិ ៨ អាចឲ្យទៅកាន់ទេវលោក ប្រាសចាកធូលី គឺកិលេស ជាផ្លូវធំ នឿយណាយនឹងកាមរាគហើយ ទៅកើតក្នុងព្រហ្មលោក ។

ជាតិ មិនមែនឃាត់មាតង្គៈនោះ ចាកការកើតក្នុងព្រហ្មលោកទេ ។ ពួកព្រាហ្មណ៍ជាផៅពង្សព្រោះមន្ត កើតក្នុងត្រកូលអ្នករៀនមន្ត ពួកព្រាហ្មណ៍ទាំងនោះ រមែងប្រាកដក្នុងបាបកម្មទាំងឡាយរឿយៗ ទុគ្គតិដែលអ្នកផងគួរតិះដៀល ក្នុងបច្ចុប្បន្នក៏មាន ក្នុងបរលោកក៏មាន ( ព្រោះបាបកម្មជាបច្ច័យ ) ។

ជាតិ មិនមែនឃាត់ពួកព្រាហ្មណ៍ទាំងនោះ ចាកទុគ្គតិ ឬចាកការតិះដៀលទេ ។ បុគ្គលមិនមែនថោកទាប ព្រោះជាតិ

មិនមែនជាព្រាហ្មណ៍ព្រោះជាតិទេ បុគ្គលជាកទាប ព្រោះកម្ម
ជាព្រាហ្មណ៍ ក៏ព្រោះកម្មដែរ ។

[ ១៤ ] ព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ អគ្គិកភារទ្វាជ-ព្រាហ្មណ៍ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ធម៌ដែលព្រះគោតមដ៏ចម្រើនទ្រង់សម្ដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ ដូចគេផ្ងារនូវរបស់ដែលផ្កាប់ ឬដូចគេបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចគេប្រាប់ផ្លូវ ដល់អ្នកវង្វេងផ្លូវ ពុំនោះសោត ដូចគេបំភ្លឺប្រទីបប្រេង ក្នុងទីងងឹត ដោយគិតថា មនុស្សអ្នកមានចក្ខុ មើលឃើញរូបទាំងឡាយបាន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់នូវសរណគមន៍ ស្មើដោយជីវិត ចាប់ដើមអំពីថ្ងៃនេះទៅ ។

**វសលសូត្រទី ៧ ចប់**

# អដ្ឋកថា

## វសលសូត្រ

[ ១២ ] វសលសូត្រនេះ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ ។ វសលសូត្រ មានអត្ថុប្បត្តិហេតុដូចម្ដេច ។ ព្រះដ៏មានព្រះភាគ គង់នៅក្នុងវិហារជេតពន អារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតនគរសាវត្ថី ទ្រង់ប្រមើលមើលនូវលោកដោយពុទ្ធចក្ខុ ក្នុងពេលស្រេចកត្តកិច្ចជាដើម ដោយន័យដែលពោលហើយ ក្នុងកសិភារទ្វាជសូត្រនោះឯង ។ ទ្រង់ឃើញអគ្គិកភារទ្វាជព្រាហ្មណ៍ ដែលដល់ព្រមដោយឧបនិស្ស័យនៃសរណៈ និងសិក្ខាបទ ទ្រង់ជ្រាបថា កាលតថាគតទៅក្នុងទីនោះហើយ ការសន្ទនានឹងប្រព្រឹត្តទៅ បន្ទាប់អំពីនោះ ក្នុងទីបំផុតនៃការសន្ទនា ព្រាហ្មណ៍នោះស្ដាប់ធម្មទេសនាហើយ នឹងដល់សរណៈ សមាទានសិក្ខាបទទាំងឡាយ ។ ហើយបានយាងទៅក្នុងនិវេសន៍ របស់អគ្គិកភារទ្វាជព្រាហ្មណ៍នោះ កាលការសន្ទនាប្រព្រឹត្តទៅហើយ ព្រាហ្មណ៍បានទូលសូមឲ្យទ្រង់សម្ដែងធម៌ ទើបត្រាស់ព្រះសូត្រនេះ ។

បណ្ដាបទទាំងនោះ បទថា **ឯវម្មេ សុតំ** ជាដើម ខ្ញុំនឹងពណ៌នាក្នុងមង្គលសូត្រ ។ បទថា **អថខោ ភគវា បុព្វណ្ហសមយំ** ជាដើម អ្នកសិក្សាគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងកសិភារទ្វាជសូត្រនោះឯង ។ ក្នុងពាក្យថា **តេន ខោ បន សមយេន អគ្គិកភារទ្វាជស្ស** នោះ ពាក្យណាមួយដែលមិនធ្លាប់ពោល ខ្ញុំនឹងពោលពាក្យនោះៗ ឯង ។

ព្រាហ្មណ៍រមែងបូជា គឺបម្រើភ្លើង ព្រោះធ្វើយ៉ាងនេះ ទើបប្រាកដដោយឈ្មោះថា **អគ្គិកៈ** ប្រាកដដោយគោត្រថា **ភារទ្វាជៈ** ព្រោះហេតុនោះ ទើបលោកពោលថា **អគ្គិកភារទ្វាជ** ។

បទថា **និវេសនេ** បានដល់ ជិតផ្ទះ បានឮថា ក្បែរទ្វារនិវេសន៍របស់ព្រាហ្មណ៍នោះ មានរោងបូជាភ្លើងត្រង់រវាងថ្នល់ ។ បន្ទាប់អំពីនោះ កាលគួរនឹងពោលថា **និវេសនទ្វារេ** តែពោលថា **និវេសនេ** ព្រោះបទ នោះទាក់ទងក្នុងនិវេសន៍នោះឯង ។ បទថា **និវេសនេ** ជាសត្តមីវិភត្តិ ក្នុងអត្ថថា ជិត អធិប្បាយថា ជិតនិវេសន៍ ។

បទថា **អគ្គិ បជ្ជលិតោ ហោតិ** សេចក្តីថា ភ្លើងតាំងនៅក្នុងចង្ក្រានបានទូវកំញ៉ម និងខ្យល់ក្នុងទីបំផុតនៃឧស ឬក្នុងទីជិត ក៏ឆេះមានអណ្តាតឡើងខាងលើ ។ បទថា **អាហុតី បគ្គហិតា** សេចក្តីថា ព្រាហ្មណ៍ងូតទឹកជម្រះសីសៈហើយ តាក់តែងបាយាស សប្បិ ទឹកឃ្មុំ ទឹកអំពៅជាដើមដោយសក្ការៈធំ វត្ថុឯណានីមួយគួរបូជាភ្លើង វត្ថុនោះ ហៅថា **អាហុតី** ។

បទថា **សបទានំ** បានដល់ តាមលំដាប់ផ្ទះ ។ ពិតហើយ ព្រះដ៏មានព្រះភាគយាងបិណ្ឌបាត ចៀងចូលទៅក្នុងត្រកូលខ្ពស់ និងត្រកូលទាបដើម្បីប្រយោជន៍ដល់ការអនុគ្រោះជនទាំងពួង ដោយការសន្តោសក្នុងអាហារ ដោយហេតុនោះ ទើបលោកពោលថា ទ្រង់ត្រាច់បិណ្ឌបាតតាមលំដាប់ច្រក ។

សួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី ព្រាហ្មណ៍ឃើញព្រះមានព្រះភាគ

ដែលទ្រទ្រង់ដល់ព្រមហើយដោយអាការទាំងពួង ទ្រង់គួរជ្រះថ្លាដោយជុំវិញ ប្រែជាមិនជ្រះថ្លា ព្រោះហេតុអ្វី ទើបព្រាហ្មណ៍ពោលពាក្យគ្រោតគ្រាត ជាមួយព្រះដ៏មានព្រះភាគទៅវិញ ។

ឆ្លើយថា បានឮថា ព្រាហ្មណ៍នេះមានទិដ្ឋិយ៉ាងនេះថា ការឃើញសមណៈ ក្នុងមង្គលកិច្ចទាំងឡាយជាអពមង្គល ព្រោះហេតុនោះ លុះដឹងថា សមណៈ ត្រងោល កាឡកិណ្ណី ចូលមកកាន់ផ្ទះរបស់អញក្នុងពេលដែលមហាព្រហ្ម បរិភោគ ទើបមិនញ៉ាំងចិត្តឲ្យជ្រះថ្លា ដល់នូវការអាក់អន់ កាលអាក់អន់ ហើយ ក៏ទោមនស្ស ទើបបន្លឺវាចាដែលមិនពេញចិត្តថា សមណៈកំណោរ ចូរឈប់ ដូច្នេះជាដើម ។

ព្រោះក្នុងទីនោះ ព្រាហ្មណ៍ទាំងឡាយមានទិដ្ឋិថា បុគ្គលត្រងោលជាបុគ្គល មិនបរិសុទ្ធ ព្រោះហេតុនោះ កាលវង្វៀសថា បុគ្គលត្រងោលមិនបរិសុទ្ធ ដោយហេតុនោះ ទើបជាបុគ្គលដែលទេវតា និងព្រាហ្មណ៍មិនបូជា ទើបទូល ថា នែសមណៈកំណោរ ។ ឬវង្វៀសថា សមណៈនេះជាបុគ្គលប្រាកដច្បាស់ ព្រោះមានក្បាលត្រងោល ទើបមិនគួរមកកាន់ប្រទេសនេះ និងវង្វៀសភាពជា សមណៈថា សូម្បីជាសមណៈ ក៏មិនសរសើរសេចក្ដីសៅហ្មងផ្លូវកាយ ដូច្នេះ ទើបទូលថា នែសមណៈ ។

ព្រាហ្មណ៍នេះ ពោលដោយអំណាចនៃការជេរតែម្យ៉ាងក៏មិនមែន ថែម ទាំងវង្វៀសថា បុគ្គលថោកថយបួសហើយ ត្រេកអរដោយការបរិភោគរួមនឹង

មួយបុគ្គលថោកថយទាំងនោះ សមណៈនេះ អាក្រក់ក្រៃលែងជាបុគ្គលថោកថយ ទើបទូលថា នៃសមណៈថោកទាប ឬសម្គាល់ថា បាបរមែងមានដល់បុគ្គលថោកទាប ដោយការមើលការបូជា និងការស្ដាប់មន្ត ទើបទូលយ៉ាងនេះ ។

ព្រះដ៏មានព្រះភាគ សូម្បីត្រូវព្រាហ្មណ៍ក្រាបទូលយ៉ាងនោះ កាលទ្រង់ប្រកាសភាពដែលព្រះអង្គមានព្រះគុណជាអសាធារណជាដើម ជាមួយសត្វទាំងពួង ដោយពណ៌សម្បុរ ព្រះភក្ត្រផូរផង់នោះឯង ដោយព្រះសូរសៀងដ៏ពីរោះ ដោយព្រះហឫទ័យ ពោរពេញដោយសេចក្ដីអនុគ្រោះ និងត្រជាក់មកលើព្រាហ្មណ៍ ទើបត្រាស់ថា **ជានាសិ បន ត្វំ ព្រាហ្មណ** ប្រែថា ម្នាលព្រាហ្មណ៍ អ្នកស្គាល់បុគ្គលថោកទាបឬ ។ លំដាប់នោះ ព្រាហ្មណ៍ដឹងភាពដែលព្រះដ៏មានព្រះភាគមានព្រះភក្ត្រផូរផង់ ព្រោះមាននូវព្រះហឫទ័យស្មើជាដើម ស្ដាប់ព្រះសូរសៀងដ៏ពីរោះ ដែលទ្រង់បន្លឺដោយព្រះហឫទ័យអនុគ្រោះ និងត្រជាក់ ក៏មានហទយៈ ដែលទឹកអម្រឹតនោះស្រោចហើយ មានចិត្តជារបស់ខ្លួន មានឥន្ទ្រិយផូរផង់ លះនូវមានះបាន លះនូវវាចាដែលមិនគួរពោល ដូចគ្នានឹងអាសិរពិសដែលមានជាតិនោះៗ ជាសភាវៈ សម្គាល់ថា អញពោលដល់ជាតិអាក្រក់ ថាជាបុគ្គលថោកទាប ដោយបរមត្ថមិនមែនជាបុគ្គលថោកទាបឡើយ ហើយភាពដែលជាតិអាក្រក់ក៏មិនមាន មានតែធម៌ដែលធ្វើឲ្យជាបុគ្គលថោកទាប ទើបក្រាបទូលថា **ន ខោ អហំ ភោ គោតម**

*ប្រែថា បពិត្រព្រះគោតម ខ្ញុំមិនស្គាល់បុគ្គលថោកទាប ។ ការដែលបុគ្គលដល់ព្រមដោយហេតុ សូម្បីជាបុគ្គលគ្រោតគ្រាត ព្រោះមិនបាននូវបច្ច័យ តែលុះបានបច្ច័យ ក៏ជាបុគ្គលទន់ភ្លន់នោះជាធម្មតា ។*

## សាធុ សព្ទ

*បណ្ដាបទទាំងនោះ បទថា* **សាធុ** *នេះ រមែងប្រាកដក្នុងអត្ថជាដើមថា* **អាយាចន** *គឺការសូម ១* **សម្បដិច្ឆន្ន** *គឺការទទួល ១* **សម្បហំសន** *គឺការត្រេកអរ ១* **សុន្ទរ** *គឺត្រង់ ១* **ទឡ្ហិកម្ម** *គឺការធ្វើឲ្យមាំទាំ ១ ។*

**សាធុ** *សព្ទ ប្រាកដក្នុងការសំណូមពរ ដូចក្នុងប្រយោគជាដើមថា* **សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ** *បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមឱកាស សូមព្រះដ៏មានព្រះភាគ សម្តែងធម៌ដោយសង្ខេបដល់ខ្ញុំព្រះអង្គ ដូច្នេះជាដើម ។*

*ប្រាកដក្នុងអត្ថព្រមទទួល ដូចក្នុងប្រយោគជាដើមថា* **សាធុ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា** *ភិក្ខុនោះទទួលពាក្យថា សាធុព្រះអង្គ ហើយរីករាយអនុមោទនាភាសិតរបស់ព្រះមានព្រះភាគ ដូចេ្នះជាដើម ។*

*ប្រាកដក្នុងអត្ថថា ត្រេកអរ ដូចក្នុងប្រយោគជាដើមថា* **សាធុ សាធុ សារីបុត្ត** *ប្រពៃហើយ ប្រពៃហើយ សារីបុត្ត ដូចេ្នះជាដើម ។*

*ប្រាកដក្នុងអត្ថថា ល្អ ដូចក្នុងប្រយោគជាដើមថា*

**សាធុ ធម្មរុចី រាជា សាធុ បញ្ញាណវា នរោ**
**សាធុ មិត្តានមទ្ទុព្ភោ បាបស្សាករណំ សុខំ ។**

*ព្រះរាជា ជាអ្នកគាប់ចិត្តដោយធម៌ ទើបល្អ ជនមានប្រាជ្ញា ទើបល្អ ការមិនប្រទូស្តមិត្ត ទើបល្អ កិរិយាមិនធ្វើបាប ទើបសុខ ។*

*ប្រាកដក្នុងអត្ថថា ធ្វើឲ្យមាំទាំ ដូចក្នុងប្រយោគជាដើមថា* **តំ សុណាហិ សាធុកំ មនសិករោហិ** *ចូរអ្នកស្តាប់នូវប្រការនោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ ។ តែក្នុងទីនេះ* **សាធុ** *សព្ទ ប្រាកដក្នុងអត្ថថា សំណូមពរ ។*

*បទថា* **តេនហិ** *ជាការសម្តែងអធិប្បាយនូវការសំណូមពរនោះ អធិប្បាយថា បើអ្នកបំណាននឹងដឹង ឬជាការពោលដល់ហេតុ ។ គប្បីជ្រាបការភ្ជាប់បទនោះចូលជាមួយបទដទៃយ៉ាងនេះថា ព្រោះអ្នកត្រូវការដឹង ព្រោះហេតុនោះ ម្នាលព្រាហ្មណ៍ ចូរអ្នកស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អ តថាគតនឹងពោលដល់អ្នក ដោយប្រការដែលអ្នកដឹង ដូច្នេះ ។*

*ក្នុងបទទាំងនោះ បទថា* **សុណាហិ** *ជាការឃាត់ដល់ការរាយមាយនៃសោតិន្ទ្រិយ ។ បទថា* **សាធុកំ មនសិករោហិ** *ជាការឃាត់នូវការរាយមាយនៃមនិន្ទ្រិយ ព្រោះប្រកបធ្វើឲ្យមាំទាំក្នុងមនសិការ ។ ក្នុងពាក្យទាំងពីរនោះ ពាក្យដើម ជាការឃាត់ដល់ការកាន់យកព្យញ្ជនៈដែលខុស ពាក្យក្រោយ ជាការឃាត់ដល់ការប្រកាន់អត្ថដែលខុស ព្រះដ៏មានព្រះភាគ ទ្រង់ប្រកប*

ព្រាហ្មណ៍ក្នុងការស្តាប់ធម៌ដោយពាក្យដើម ទ្រង់ប្រកបក្នុងកម្មទាំងឡាយ មានការទ្រទ្រង់ និងការពិចារណាអត្ថនៃធម៌ទាំងឡាយ ដែលស្តាប់ហើយ ដោយពាក្យក្រោយ និងដោយពាក្យដើម ទ្រង់សំដែងថា ធម៌នេះមានព្យញ្ជនៈ ព្រោះហេតុនោះ អ្នកគប្បីស្តាប់ ។ ដោយពាក្យក្រោយ ទ្រង់សំដែងថា ធម៌នេះ មានអត្ថ ព្រោះហេតុនោះ អ្នកគប្បីមនសិការ ។

ម្យ៉ាងទៀត ទ្រង់ប្រកបសាធុកបទ ចូលជាមួយបទទាំងពីរ ។ កាលទ្រង់សំដែងអត្ថនោះថា ព្រោះធម៌នេះ ជ្រាលជ្រៅដោយធម៌ និងជ្រាលជ្រៅដោយទេសនា ព្រោះហេតុនោះ អ្នកគប្បីស្តាប់ឲ្យល្អ ព្រោះជាធម៌ជ្រៅដោយអត្ថ និងជ្រៅដោយបដិវេធ ព្រោះហេតុនោះ ចូរអ្នកដាក់ចិត្តឲ្យល្អ ដូច្នេះ ទើបត្រាស់ថា **សុណាហិ សាធុកំ មនសិករោហិ** បន្ទាប់អំពីនោះ ទ្រង់លួងលោមព្រាហ្មណ៍នោះ ដែលរួញរាថា អញនឹងបានទីពឹងក្នុងធម៌ដែលជ្រាលជ្រៅយ៉ាងនេះដូចម្តេច ទើបត្រាស់ថា **ភាសិស្សាមិ** ដូច្នេះ ។ ក្នុងពាក្យនោះ គប្បីជ្រាបការខ្វល់ខ្វាយយ៉ាងនេះថា អ្នកនឹងដឹងដោយប្រការណា តថាគតនឹងពោលដោយន័យដែលរាក់ដោយបទ និងព្យញ្ជនៈដែលល្អ ដោយប្រការនោះ ។ បន្ទាប់អំពីនោះ អគ្គិកភារទ្វាជព្រាហ្មណ៍ ជាអ្នកមានសេចក្តីខ្វល់ខ្វាយហើយ ក៏ទូលទទួលអធិប្បាយថា ទទួលហើយ គឺទទួលចំពោះព្រះដ៏មានព្រះភាគថា ករុណាព្រះអង្គ បែរមុខស្តាប់ដោយបដិបត្តិតាមធម៌ដែលទ្រង់សំដែង លំដាប់នោះ ព្រះដ៏មានព្រះភាគបានត្រាស់ពាក្យនេះ គឺ

ត្រាស់ប្រាប់ពាក្យនេះដល់ព្រាហ្មណ៍នោះ ។ បទ មានយ៉ាងនេះថា **កោធនោ ឧបនាហី** ជាដើម ត្រាស់សំដៅដល់ធម៌ដែល គប្បីប្រាប់ក្នុងឥឡូវនេះ ។

[ ១៣ ] ក្នុងបទទាំងនោះ បទថា **កោធនោ** បានដល់ បុគ្គលក្រោធជាប្រក្រតី ។ បទថា **ឧបនាហី** បានដល់ ជាអ្នកប្រកបព្រមដោយសេចក្តីក្រោធ ដោយធ្វើសេចក្តីក្រោធនោះឯងឲ្យមាំទាំ ។ បុគ្គលណា រមែងលាងគឺលុបនូវគុណទាំងឡាយរបស់អ្នកដទៃ ព្រោះហេតុនោះ ទើបបុគ្គលនោះឈ្មោះថា **មក្ខី** គឺជាអ្នកលុបគុណ បុគ្គលនោះអាក្រក់ផង លុបគុណផង ឈ្មោះថា **ចាបមក្ខី** ។

បទថា **វិបន្នទិដ្ឋិ** បានដល់ មានសម្មាទិដ្ឋិវិនាសហើយ ឬប្រកបដោយមិច្ឆាទិដ្ឋិ ១០ យ៉ាងដែលវិបត្តិ គឺខុសហើយ ។ បទថា **មាយាវី** បានដល់ ដែលប្រកបព្រមដោយមាយា មានការបិទបាំងទោសដែលមានក្នុងខ្លួនជាលក្ខណៈ ។ បទថា **តំ ជញ្ញា វសលោ ឥតិ** សេចក្តីថា ចូរអ្នកដឹងបុគ្គលនោះ គឺបែបនោះថា ជាបុគ្គលថោកទាប ព្រោះហៀរចេញ ព្រោះហូរចេញ ព្រោះផ្សាយទៅនៃធម៌អាក្រក់ទាំងនោះ ។ ដ្បិតថា ធម៌អាក្រក់ទាំងអស់ កើតហើយក្នុងសីសៈព្រាហ្មណ៍ ពិតហើយ ព្រាហ្មណ៍នេះ ដោយបរមត្ថ ជាបុគ្គលថោកទាបនោះឯង មិនបានហៅអ្នកដទៃត្រឹមតែការពេញចិត្តរបស់ខ្លួនឡើយ ។

ក្នុងគាថានេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើការសង្កត់សេចក្តីក្រោធរបស់

ព្រាហ្មណ៍នោះ ដោយបទដើមប៉ុណ្ណោះ ដោយប្រការដូច្នេះហើយ ព្រោះកាល ទ្រង់សម្ដែងធម៌ មានសេចក្ដីក្រោធជាដើម ដោយបុគ្គលាធិដ្ឋានថា បុគ្គលមាន សេចក្ដីក្រោធជាធម្មតា ទើបទ្រង់សម្ដែងបុគ្គលថោកទាប និងធម៌ទាំងឡាយ ដែលធ្វើឲ្យជាបុគ្គលថោកទាប ដោយបរិយាយមួយសិន កាលទ្រង់សម្ដែង យ៉ាងនោះ ទ្រង់មិនធ្វើការសន្ទត់សន្ទិនអ្នកដទៃ និងមិនលើកព្រះអង្គថា អ្នក តថាគត ទ្រង់តាំងព្រាហ្មណ៍នោះក្នុងភាពថោកទាប ហើយព្រះអង្គក្នុងភាព ជាព្រាហ្មណ៍ដោយធម៌នោះឯង គឺដោយការត្រឹមត្រូវជានិច្ច ។

ឥឡូវនេះ កាលទ្រង់បដិសេធនូវទិដ្ឋិរបស់ព្រាហ្មណ៍ទាំងឡាយថា បុគ្គល សូម្បីធ្វើនូវបាណាតិបាត និងអទិន្នាទានជាដើមក្នុងកាលខ្លះ ក៏នៅជាព្រាហ្មណ៍ នោះឯង កាលទ្រង់សម្ដែងទោសក្នុងទិដ្ឋិនោះថា សត្វទាំងឡាយពួកណាប្រកប ដោយអកុសលធម៌ទាំងនោះ ក្នុងបណ្ដាអកុសលធម៌ មានការបៀតបៀនជាដើម កាលមិនឃើញទោស រមែងប្រកាន់នូវធម៌ទាំងនោះ ធម៌ទាំងនោះអាក្រក់សម្រាប់ សត្វទាំងនោះ ទើបជាធម៌ធ្វើឲ្យបុគ្គលថោកទាប ទើបបានត្រាស់គាថាយ៉ាង នេះថា **ឯកជំ វា ទ្វិជំ វា** ដើម្បីទ្រង់សម្ដែងបុគ្គលថោកទាប និងធម៌ទាំង-ឡាយដែលធ្វើឲ្យជាបុគ្គលថោកទាប ដោយបរិយាយទាំងឡាយដទៃទៀត ។

បណ្ដាបទទាំងនោះ បទថា **ឯកជំ** បានដល់ សត្វដែលកើតក្នុងកំណើត ដ៏សេស វៀរសត្វដែលកើតក្នុងស៊ុត សត្វដែលកើតក្នុងកំណើតនោះ រមែង កើតម្ដងប៉ុណ្ណោះ ។

បទថា **ទ្វិជំ** បានដល់ សត្វដែលកើតក្នុងស៊ុត ពិតហើយ សត្វដែលកើតក្នុងស៊ុតនោះរមែងកើត ២ ដង គឺចាកផ្ទៃរបស់មេម្តង ញាស់ពីស៊ុតម្តង ។ បានដល់ សត្វដែលកើតម្តង ឬពីរដងនោះ ។

បទថា **យោធ ចាណំ** សេចក្តីថា បុគ្គលណាក្នុងលោកនេះបៀតបៀនសត្វ ។ បទថា **វិហឹសតិ** សេចក្តីថា ផ្តាច់ជីវិតដោយប្រយោគដែលតាំងឡើងអំពីចេតនាដែលប្រព្រឹត្តទៅតាមកាយទ្វារ ឬដែលតាំងឡើងចាកចេតនាដែលប្រព្រឹត្តទៅតាមវចីទ្វារ ។ បាលីថា រមែងបៀតបៀនសត្វទាំងឡាយ ដូច្នេះក៏មាន ។ អ្នកសិក្សាគប្បីជ្រាបការសម្ពន្ធក្នុងបទនោះយ៉ាងនេះថា បុគ្គលណាក្នុងលោកនេះ រមែងបៀតបៀនសត្វទាំងឡាយ មានប្រភេទយ៉ាងនេះ គឺសត្វដែលកើតម្តង ឬកើតពីរដង ។ ត្រាស់ការមិនមានការអាណិតអាសូរដោយចិត្ត ដោយបទនេះថា **យស្ស ចាណេ ទយានត្ថិ** ។

បទដ៏សេសក្នុងគាថានេះ និងក្នុងគាថាទាំងឡាយក្រៅអំពីនេះ មានន័យដូចពោលហើយនោះឯង ព្រោះខ្ញុំមិនពោលបទមានប្រមាណប៉ុណ្ណោះ បន្ទាប់អំពីនេះទៅ នឹងរៀនទូវបទទាំងឡាយដែលមានអត្ថងាយយល់ ធ្វើនូវកិច្ចពណ៌នាបទ ដែលមិនទាន់បានពណ៌នាប៉ុណ្ណោះ ។

បទថា **ហន្តិ** គឺរមែងសម្លាប់ រមែងឲ្យវិនាស ។ បទថា **ឧបរុន្ធតិ** គឺប្រើបក្ខពួកឈរចោមរោមព័ទ្ធជុំវិញ ។ បទថា **ឩគរានិ** ដូច្នេះ គប្បីសង្គ្រោះចូលក្នុងបទនេះថា **គាមានិ និគមានិ ច** ដោយ **ច** សព្ទ ។ បទថា

**ឆិន្នាមាកោ សមញ្ញាតោ** បានដល់ មានកេរ្តិ៍ឈ្មោះ ដែលបុគ្គលដឹងហើយក្នុងលោកថា បៀតបៀនអ្នកស្រុក អ្នកនិគម និងអ្នកនគរ ដោយការបៀតបៀន គឺប្លន់ ។

បទថា **គាមេ វា យទិ វារញ្ញេ** សេចក្តីថា ស្រុកក្តី និគមក្តី នគរក្តី ទាំងអស់ មួយអន្លើដោយបរិវេណ ឈ្មោះថា ស្រុក ក្នុងគាថានេះ វៀរស្រុកនោះ ដ៏សេស ឈ្មោះថា ព្រៃ ។ ទ្រព្យដែលអ្នកដទៃហួងហែង ដែលសត្វដទៃគ្រប់គ្រង មិនទាន់បានលះបង់ ទោះជាសត្វក្តី ជាទ្រព្យក្តី ក្នុងស្រុកឬក្នុងព្រៃនោះ ។

បទថា **ថេយ្យា អទិន្នំ អាទិយតិ** សេចក្តីថា លួចទ្រព្យដែលអ្នកដទៃទាំងនោះមិនបានឲ្យ មិនបានអនុញ្ញាតដោយថេយ្យចិត្ត គឺញុំាងការកាន់យករបស់ខ្លួនឲ្យសម្រេច ដោយប្រយោគណាមួយ គឺដោយអវហារណាមួយ ។

បទថា **ឥណមាទាយ** សេចក្តីថា បុគ្គលដាក់ទ្រព្យណាមួយរបស់ខ្លួនហើយខ្ចីបំណុលមកដោយការប្រចាំទ្រព្យ ឬមិនបញ្ចាំទ្រព្យណាមួយ ខ្ចីបំណុលមកដោយការឲ្យការប្រាក់ថា ខ្ញុំនឹងឲ្យការប្រាក់ប្រមាណប៉ុណ្ណេះ ដោយកាលប្រមាណប៉ុណ្ណេះ ឬដោយធ្វើសញ្ញាថា កម្រៃណានឹងមានអំពីទ្រព្យនេះ កម្រៃនោះ នឹងជាដើមទុនរបស់ខ្ញុំ និងរបស់អ្នកផងដែរ ឬថា កម្រៃត្រូវបែងចែកគ្នាទាំងពីរចំណែក ហើយគេចទៅ ។ បទថា **ឆ ហិ តេ ឥណមត្ថិ** សេចក្តីថា បុគ្គលដែលម្ចាស់បំណុលនោះទារថា ចូរឲ្យបំណុលនេះដល់ខ្ញុំ ទាំងដែលនៅ

ក្នុងផ្ទះ ក៏ឈ្មោះថា គេចទៅ ដោយការពោលយ៉ាងនេះថា បំណុលរបស់អ្នក មិនមានឡើយ អ្នកណាជាសាក្សីថា ខ្ញុំខ្ចីអ្នក ។

បទថា **កិញ្ចិក្ខកម្យតា** សេចក្តីថា ព្រោះត្រូវការទ្រព្យណាមួយប៉ុណ្ណោះ សូម្បីមានប្រមាណតិច ។ បទថា **បន្ថស្មឹ វជតំ ជនំ** សេចក្តីថា ស្ត្រី និង បុរសណាមួយដែលកំពុងដើរផ្លូវ ។ បទថា **ហន្ត្វា កិញ្ចិក្ខមាទេតិ** សេចក្តីថា សម្លាប់ហើយ ឬវាយហើយ ដណ្តើមយកទ្រព្យនោះ ។

បទថា **អត្តហេតុ** បានដល់ ព្រោះហេតុនៃជីវិតរបស់ខ្លួន ។ ព្រោះហេតុនៃអ្នកដទៃក៏ដូចគ្នា ។ បទថា **ធនហេតុ** បានដល់ ព្រោះហេតុនៃទ្រព្យរបស់ខ្លួន ឬទ្រព្យរបស់អ្នកដទៃ ។ **ច** អក្ខរៈ ក្នុងបទទាំងពួង មានការកំណត់ជាអត្ថ ។ បទថា **សក្ខិបុដ្ឋោ** សេចក្តីថា ត្រូវសួរថា អ្នកដឹងវត្ថុណា ចូរពោលដល់វត្ថុនោះ ។ បទថា **មុសា ព្រូហិ** សេចក្តីថា កាលដឹងក៏ពោលថាមិនដឹង ឬកាលមិនដឹង ក៏ពោលថាដឹង គឺរមែងធ្វើបុគ្គលដែលជាម្ចាស់ទ្រព្យ មិនឲ្យជាម្ចាស់ទ្រព្យ ធ្វើបុគ្គលមិនជាម្ចាស់ទ្រព្យ ឲ្យជាម្ចាស់ទ្រព្យ ។

បទថា **ញាតីនំ** បានដល់ ជាសាច់ញាតិ ។ បទថា **សខីនំ** បានដល់ បុគ្គលជាសម្លាញ់ ។ បទថា **ទារេសុ** បានដល់ ក្នុងភរិយាទាំងឡាយ ដែលអ្នកដទៃគ្រប់គ្រង ។ បទថា **បដិទិស្សតិ** សេចក្តីថា រមែងប្រាកដដោយបដិកូល អធិប្បាយថា ប្រាកដថា ប្រព្រឹត្តកន្លង ។ បទថា **សហសា** បានដល់ ស្រីមិនត្រូវការដោយចាប់បង្ខំ ។ បទថា **សម្បិយេន** សេចក្តីថា បុគ្គល

ដែលកិរិយាទាំងនោះ របស់បុគ្គលទាំងនោះត្រូវការ ហើយខ្លួនឯងក៏ត្រូវការ អធិប្បាយថា ដោយអំណាចនៃសេចក្តីស្រឡាញ់របស់បុគ្គលទាំងពីរ ។

បុគ្គលជាទីតាំងនៃមេត្តាយ៉ាងនេះថា **មាតរំ វា បិតរំ វា** ។ បុគ្គលជាទីតាំងនៃករុណាយ៉ាងនេះ **ជិណ្ណកំ គតយោព្វនំ** ។ បទថា **បហុសន្តោ ន ភរតិ** សេចក្តីថា ជាអ្នកដល់ព្រមដោយប្រយោជន៍ ដល់ព្រមដោយឧបករណ៍ ក៏មិនចិញ្ចឹម គឺមិនបីបាច់ថែរក្សា ។

បទថា **សស្សុំ** បានដល់ ម្តាយក្មេក ។ បទថា **ហន្តិ** សេចក្តីថា ប្រហារដោយបាតដៃ ឬដោយដុំដី ឬដោយវត្ថុដទៃណាមួយ ។ បទថា **រោសេតិ** បានដល់ ញុំាងសេចក្តីក្រោធឲ្យកើតដល់បុគ្គលនោះដោយវាចា គឺដោយពាក្យគ្រោតគ្រាត ។

បទថា **អត្ថំ** បានដល់ ប្រយោជន៍ណាមួយ ក្នុងបណ្តាសន្ទិដ្ឋិកប្រយោជន៍ សម្បរាយិកប្រយោជន៍ និងបរមត្ថប្រយោជន៍ ។ បទថា **បុច្ឆិតោ សន្តោ** សេចក្តីថា ត្រូវសួរហើយ ។ បទថា **អនត្ថមនុសាសតិ** សេចក្តីថា រមែងប្រាប់វត្ថុដែលមិនជាប្រយោជន៍នោះឯងដល់បុគ្គលនោះ ។ បទថា **បដិច្ឆន្នេន មន្តេតិ** សេចក្តីថា កាលប្រាប់វត្ថុដែលជាប្រយោជន៍ រមែងប្រាប់ដោយពាក្យដែលស្រពិចស្រពិល មានអត្ថមិនប្រាកដដោយប្រការដែលបុគ្គលនោះ មិនដឹង ឬជាអាចារ្យលាក់បាំងនូវចំណេះដឹង បង្រៀនឲ្យចេះក្នុងកាលយូរ បង្រៀនឲ្យមានចំណែកនៅសល់ ។

បទថា **យោ កត្វា** សេចក្តីថា សេចក្តីប្រាថ្នាលាមកក្នុងចំណែកខាងដើមនៃមាយា បានពោលហើយក្នុងអដ្ឋកថា កាលប្រាថ្នា មកហើយយ៉ាងនេះថា បុគ្គលពួកខ្លះក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត តម្កល់ទុកនូវសេចក្តីប្រាថ្នាដ៏លាមកព្រោះបិទបាំងនូវអំពើទុច្ចរិតនោះ ជាហេតុប្រាថ្នាថា ពួកជននីមួយ កុំដឹងនូវអាត្មាអញឡើយ ។ ឈ្មោះថា **បដិច្ឆន្នកម្មន្តោ** ព្រោះអត្ថថា មានការងារបិទបាំង ដោយធ្វើឲ្យអ្នកដទៃមិនដឹង និងដោយការមិនបើកផ្សាយនូវការងារដែលធ្វើហើយ ។

បទថា **បរកុលំ** បានដល់ ត្រកូលញាតិ ឬត្រកូលមិត្ត ។ បទថា **អាគតំ** សេចក្តីថា រមែងមិនតបស្នងបុគ្គលនោះដែលមកហើយកាន់ផ្ទះរបស់ខ្លួន ដែលខ្លួនធ្លាប់បានបរិភោគអាហារមកហើយ ដោយវត្ថុទាំងឡាយមានទឹកនិងភោជនជាដើម អធិប្បាយថា រមែងមិនឲ្យ ឬឲ្យតែអាហារដែលអាក្រក់ ។

បទថា **យោ ព្រាហ្មណំ វា** មានន័យដូចបានពោលហើយ ក្នុងបរាភវសូត្រនោះឯង ។

បទថា **ភត្តកាលេ ឧបដ្ឋិតេ** សេចក្តីថា កើតហើយ ប្រាកដហើយក្នុងកាលនៃភោជន បាលីថា **ឧបដ្ឋិតំ** ដូច្នេះក៏មាន អធិប្បាយថា ដែលមកហើយក្នុងកាលនៃភត្តអំពីព្រលឹម ។ បទថា **រោសេតិ វាចា ន ច ទេតិ** អធិប្បាយថា បុគ្គលមិនគិតថា សមណៈ ឬព្រាហ្មណ៍នេះ ប្រាថ្នាប្រយោជន៍

ដល់អញ មិនមកដើម្បីប្រាប់ឲ្យអញធ្វើបុណ្យ រមែងជេរដោយពាក្យគ្រោតគ្រាតដែលមិនសមគួរ ដោយហោចមិនឲ្យត្រឹមតែសមណៈ ឬព្រាហ្មណ៍នោះជួបមុខ នឹងពោលថ្វីដល់ការឲ្យភោជន ។

បទថា **អសតំ យោធ បព្រូតិ** សេចក្តីថា បុគ្គលក្នុងលោកនេះពោលនូវពាក្យដែលមិនមានដោយប្រការដែលនិមិត្តទាំងឡាយប្រាកដថា វត្ថុនេះនិងវត្ថុនេះ នឹងមានដល់អ្នកក្នុងថ្ងៃឈ្មោះនោះ បាលីថា **អសន្តំ** ដូច្នេះក៏មានអធិប្បាយថា រឿងមិនពិត ។ បទថា **បព្រូតិ** សេចក្តីថា រមែងពោលដូចអ្នកលេងបោកបញ្ឆោតកិរិយារបស់អ្នកដទៃ ឬទាសីរបស់អ្នកដទៃថា ក្នុងស្រុកឈ្មោះនោះ ខ្ញុំមានសម្បត្តិប្រចាំផ្ទះបែបនេះ ចូរមក ទៅក្នុងស្រុកនោះជាមួយគ្នា នាងនឹងជាម្ចាស់ផ្ទះរបស់ខ្ញុំ ខ្ញុំនឹងឲ្យសម្បត្តិនេះដល់នាង ។ បទថា **និជិ-គីសានោ** សេចក្តីថា ត្រូវការ គឺស្វែងរក អធិប្បាយថា ដែលបំណងនឹងបោកបញ្ឆោត កាន់យកទ្រព្យណាមួយ គេចទៅ ។

បទថា **យោ ចត្តានំ** សេចក្តីថា បុគ្គលណាលើកខ្លួន ។ បទថា **សមុក្កំសេ** សេចក្តីថា រមែងលើកខ្លួនដោយមានះទាំងឡាយ មានជាតិជាដើម គឺតាំងខ្លួនក្នុងឋានៈខ្ពស់ ។ បទថា **បរេ ច មវជានតិ** សេចក្តីថា រមែងមើលងាយអ្នកដទៃ គឺធ្វើឲ្យទាបដោយមានះទាំងឡាយ មានជាតិជាដើមនោះ ។ **ម** អក្ខរៈ ធ្វើនូវការភ្ជាប់បទ ។ បទថា **និហីនោ** សេចក្តីថា បុគ្គលសាបសូន្យចាកគុណ ឬដល់នូវភាពថោកទាប ។ បទថា **សេន មានេន** សេចក្តីថា

ដោយមានះរបស់ខ្លួន ពោល គឺលើកខ្លួន សង្កត់សង្កិនបុគ្គលនោះ ។

បទថា **រោសកោ** បានដល់ ជាបុគ្គលកោងកាចក្នុងអ្នកដទៃដោយកាយនិងវាចា ។ បទថា **កទរិយោ** បានដល់ ជាអ្នកកំណាញ់ខ្លាំង ។ បទថា **កទរិយោ** នោះ ជាឈ្មោះរបស់បុគ្គលដែលហាមអ្នកដទៃ ដែលឲ្យទានដល់អ្នកដទៃ ឬអ្នកធ្វើបុណ្យណាម្នាក់ ។ បទថា **ទាបិច្ឆោ** បានដល់ ដល់ព្រមដោយការប្រាថ្នា និងលើកតម្កើងនូវគុណដែលខ្លួនមិនមាន ។ បទថា **មច្ឆរី** បានដល់ ប្រកបដោយសេចក្តីកំណាញ់ មានកំណាញ់អាវាសជាដើម ។ បទថា **សឋោ** បានដល់ ប្រកបព្រមដោយការអួតអាង មានការប្រកាសគុណដែលខ្លួនមិនមានជាលក្ខណៈ ឬពោលនូវពាក្យមិនត្រង់ មិនបំណងនឹងធ្វើដោយពាក្យថា ខ្ញុំនឹងធ្វើជាដើម ។ ហិរិ មានការខ្ពើមបាបជាលក្ខណៈ មិនមានដល់បុគ្គលនោះ ឱត្តប្បៈ មានការខ្លាចបាបជាលក្ខណៈ មិនមានដល់បុគ្គលនោះ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **អហិរិកោ** និង **អនោត្តប្បី** ។

បទថា **ពុទ្ធំ** បានដល់ ព្រះសម្មាសម្ពុទ្ធ ។ បទថា **បរិភាសតិ** សេចក្តីថា តិះដៀលដោយពាក្យថា មិនជាសព្វញ្ញូជាដើម ។ និងរមែងតិះដៀលព្រះសាវកដោយពាក្យថា អ្នកបដិបត្តិអាក្រក់ជាដើម ។ បទថា **បរិព្វាជកំ គហដ្ឋំវា** នោះ ជាវិសេសនៈរបស់សាវកៈប៉ុណ្ណោះ អធិប្បាយថា បព្វជិតដែលជាសាវករបស់ព្រះសម្ពុទ្ធ ឬគ្រហស្ថដែលប្រគេនបច្ច័យ ។ បុរាណាចារ្យទាំងឡាយ រមែងត្រូវការអត្ថក្នុងគាថានេះ យ៉ាងនេះថា រមែងតិះដៀលបរិព្វាជក

ខាងក្រៅ ឬគ្រហស្ថណាមួយ ដោយទោសដែលមិនពិត ។

បទថា **អនរហំ សន្តោ** សេចក្តីថា បុគ្គលមិនជាខីណាស្រព ។ បទថា **អរហំ បដិជានតិ** សេចក្តីថា ប្តេជ្ញាថា យើងជាព្រះអរហន្ត គឺរមែងបន្ទឺវាចា រមែងកៀគរដោយកាយ រមែងប្រាថ្នា រមែងទទួលដោយចិត្ត ដោយប្រការដែលបុគ្គលទាំងឡាយដឹងថា បុគ្គលនេះជាព្រះអរហន្ត ។ បទថា **ចោរោ** បានដល់ ចោរ ។ ព្រះដ៏មានព្រះភាគត្រាស់ដោយអំណាចពាក្យដែលជាឧក្រិដ្ឋថា ក្នុងលោក ព្រមទាំងព្រហ្មលោក អធិប្បាយថា ក្នុងលោកទាំងពួង ។

ពិតហើយ ក្នុងផ្លូវលោក ពួកអ្នកលួចទ្រព្យ រមែងលួចទ្រព្យអ្នកដទៃដោយកាត់ទីត ប្លន់ស្រុក ប្លន់ផ្ទះមួយខ្នង និងស្កាត់ផ្លូវជាដើម ហៅថា ចោរ ក្នុងផ្លូវសាសនា ពួកបព្វជិតប្លន់បច្ច័យជាដើម អំពីសម្បត្តិរបស់បរិស័ទជាដើម ក៏ហៅថា ចោរ សមដូចព្រះដ៏មានព្រះភាគត្រាស់ថា

> ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ មានភិក្ខុជាមហាចោរ ៥ ពួក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាមហាចោរ ៥ ពួកនោះដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីត្រិះរិះរបស់មហាចោរខ្លះ ដែលមានក្នុងលោកនេះថា បើដល់វេលាណាអញបានបរិសទ្យ ១ រយ ឬ ១ ពាន់ចោមរោមជាគ្នាហើយ នឹងលើកចូលទៅក្នុងស្រុក និគម រាជធានី ហើយនឹងវាយសំពង ផ្តាច់ជីវិតពួកអ្នកស្រុកទាំងនោះ ដោយខ្លួន

ឯង ឬប្រើអ្នកដទៃឲ្យផ្តាច់ជីវិត ដុតភេលអ្នកស្រុកទាំងនោះ ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យដុតភេល ។ លុះដល់សម័យជាខាងក្រោយមក មហាចោរនោះបានបរិសទ្យ ១ រយ ឬ ១ ពាន់ ចោមរោលជាគ្នាហើយ ក៏លើកចូលទៅក្នុងស្រុក និគម រាជធានី វាយសំពងផ្តាច់ជីវិតអ្នកស្រុកទាំងនោះដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យផ្តាច់ជីវិត ដុតភេលអ្នកស្រុកទាំងនោះដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យដុតភេល យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីត្រិះរិះរបស់ភិក្ខុបាបខ្លះ ដែលមានក្នុងសាសនានេះ ក៏យ៉ាងនោះដែរ ( ត្រិះរិះ ) ថា បើដល់កាលណា អញបានបរិសទ្យ ១ រយ ឬ ១ ពាន់ ចោមរោមជាគ្នាហើយ នឹងត្រាច់ទៅកាន់ចារិក ក្នុងស្រុក និគម រាជធានី ក៏នឹងបាននូវចីវរ បិណ្ឌ-បាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ដែលពួកគ្រហស្ថក្តី ពួកបព្វជិតក្តី ធ្វើសក្ការគោរពរាប់អានបូជាកោតក្រែង ។ លុះដល់សម័យខាងក្រោយមក ភិក្ខុបាបនោះបានបរិសទ្យ ១ រយ ឬ ១ ពាន់ចោមរោមជាគ្នាហើយ ក៏ត្រាច់ទៅកាន់ចារិកក្នុងស្រុក និគម រាជធានី បានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ដែលពួកគ្រហស្ថ

ក្តី បព្វជិតក្តី ធ្វើសក្ការគោរពរាប់អាន បូជាក្រោតក្រែង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ ហៅថា មហាចោរទី ១ ដែលមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត ក្នុងសាសនានេះ មានភិក្ខុបាបខ្លះ រៀនសូត្រធម្មវិន័យ ដែលតថាគតបានសម្តែងហើយ ដុតកម្តៅខ្លួនឯងចោល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ ហៅថា មហាចោរទី ២ ដែលមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត ក្នុងសាសនានេះ មានភិក្ខុបាបខ្លះ ពោលចោទភិក្ខុដែលប្រព្រឹត្តធម៌ប្រសើរដ៏ស្អាត ដែលកំពុងប្រព្រឹត្តធម៌ប្រសើរ ដ៏បរិសុទ្ធ ចោទដោយការប្រព្រឹត្តមិនប្រសើររកមូលគ្មាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ ហៅថា មហាចោរទី ៣ មានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំង-ឡាយ ហេតុដទៃមានតទៅទៀត ក្នុងសាសនានេះ មានភិក្ខុបាបខ្លះ សង្គ្រោះផ្គាប់ផ្គុនគ្រហស្ថ ដោយគ្រឿងគរុភណ្ឌរបស់សង្ឃ ឬគ្រឿងគរុបរិក្ខារ គ្រឿងគរុភណ្ឌ គឺអ្វីខ្លះ គ្រឿងគរុភណ្ឌនោះ គឺគុម្ពផ្កា និងដើមឈើ ១ ទីដែលសម្រាប់ដាំគុម្ពផ្កា និងដើមឈើ ១ កុដិ ១ ទីដែលសម្រាប់សង់កុដិ ១ គ្រែ ១ តាំង ១ ពូក ១ ខ្នើយ ១ ផ្ទាំង

លោហៈ ១ ស្ពាន់លោហៈ ១ ក្អមលោហៈ ១ ផើងលោហៈ ១ កាំបិត ១ ពូថៅ ១ ដីង ១ ចប ១ ពន្លាក ( ឬ ដែកកណ្តារ ) ១ វល្លិប្រវែងមួយលូកឡើងទៅ ១ ឫស្សីប្រវែង ៨ ធ្នាប់ឡើងទៅ ១ ស្មៅជំណោកទន្សាយ ១ ស្មៅយាប្លង ១ ស្មៅធម្មតា ១ ដីស្អិត ១ គ្រឿងធ្វើទឹងឈើ ១ គ្រឿងធ្វើទឹងដី ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ ហៅថាមហាចោរទី ៤ មានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមានមិនប្រាកដក្នុងខ្លួន ភិក្ខុនេះ ជាមហាចោរទី ៥ ជាចោរធំបំផុត ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហេតុអ្វី បានជាតថាគតពោលដូច្នោះ ម្នាលភិក្ខុទាំងឡាយ ពីព្រោះដុំបាយរបស់ជនអ្នកនៅក្នុងដែន គឺភិក្ខុនោះឯង លួចយកមកបរិភោគ ។[១]

ក្នុងចោរ ៥ ពួកនោះ ចោរផ្លូវលោក រមែងលួចវត្ថុ និងធញ្ញជាតិជាដើម

១- ក្នុងអដ្ឋកថា លោកប្រើបេយ្យាលច្រើនកន្លែងធ្វើឲ្យសេចក្តីដាច់ ក្នុងទីនេះ យើងមិនប្រើបេយ្យាលឡើយ ។

ដែលជាផ្លូវលោកប៉ុណ្ណោះ ក្នុងសាសនា ក្នុងបណ្តាចោរដែលពោលហើយ ចោរទី ១ រមែងលួចត្រឹមតែបច្ច័យ មានចីវរជាដើម មានសភាពបែបនោះប៉ុណ្ណោះ ចោរទី ២ រមែងលួចបរិយត្តិធម៌ ចោរទី ៣ រមែងលួចព្រហ្មចរិយៈរបស់អ្នកដទៃ ចោរទី ៤ រមែងលួចគរុភណ្ឌដែលជារបស់សង្ឃ ចោរទី ៥ រមែងលួចទាំងគុណទាំងទ្រព្យ ដែលជាលោកិយ និងលោកុត្តរ មានឈាន សមាធិ សមាបត្តិ មគ្គ និងផល មួយអន្លើដោយបច្ច័យ មានចីវរជាដើម ដែលជាលោកិយ ដូចដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពីព្រោះដុំបាយរបស់ជនអ្នកនៅក្នុងដែន គឺភិក្ខុនោះឯងលួចយកមកបរិភោគ ។

ក្នុងចោរ ៥ ពួកនោះ ព្រះដ៏មានព្រះភាគត្រាស់ថា ជាចោរក្នុងលោក ព្រមទាំងព្រហ្មលោក ដូច្នេះ ទ្រង់សំដៅដល់មហាចោរទី ៥ នេះ ព្រោះមហាចោរទាំងនោះ ព្រះដ៏មានព្រះភាគត្រាស់ថា ជាកំពូលមហាចោរ ព្រោះលួចលោកិយទ្រព្យ និងលោកុត្តរទ្រព្យយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាពោលអួតឧត្តរិមនុស្សធម្មដែលមិនមានមិនប្រាកដក្នុងខ្លួន ភិក្ខុនេះ ជាមហាចោរទី ៥ ជាចោរធំបំផុតក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ព្រោះហេតុនោះ ទើបទ្រង់ប្រកាសភិក្ខុនោះ ក្នុងគាថានេះ ដោយកំណត់យ៉ាងឧក្រិដ្ឋថា ក្នុងលោក ព្រមទាំងព្រហ្មលោក ។

សព្ទថា **ខោ** ក្នុងបទនេះថា **ឯសោ ខោ វិសេសោ** មានអវធារណៈ

ជាអត្ថ ដោយ **ខោ** សព្ទនោះ ទ្រង់កំណត់ថា បុគ្គលនោះឯង ជាបុគ្គលថោកទាប គឺអាក្រក់បំផុត ក្នុងបណ្តាអ្នកថោកទាបទាំងឡាយ ។ ព្រោះហេតុអ្វី ព្រោះហួរចេញនូវថេយ្យធម៌ ( ធម៌សម្រាប់ចោរ ) ក្នុងវត្ថុដ៏ប្រសើរ បុគ្គលនោះ មិនលះបង្គាប់នោះដរាបណា បុគ្គលនោះក៏សម្រេចហើយនូវធម៌ ដែលធ្វើឲ្យថោកទាប ជាបុគ្គលថោកទាបដរាបនោះ ។

បទថា **ឯតេ ខោ វសលា** សេចក្តីថា ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងបរិយាយដល់បុគ្គលថោកទាប ៣៣ ពួក ឬ ៣៤ ពួកដែលត្រាស់យ៉ាងនេះថា ក្នុងគាថាទី ១ មាន ៥ ពួក មានសេចក្តីក្រោធជាដើម ដោយអំណាចនៃអាសយវិបត្តិ ឬមាន ៦ ពួក ដោយចែកបាបមក្ខីបុគ្គលជា ២ យ៉ាង ក្នុងគាថាទី ២ មានមួយ គឺបុគ្គលបៀតបៀនសត្វដោយអំណាចនៃបយោគវិបត្តិ ក្នុងគាថាទី ៣ មានមួយ គឺបុគ្គលសម្លាប់អ្នកស្រុក និងអ្នកនិគម ដោយអំណាចនៃបយោគវិបត្តិប៉ុណ្ណោះ ក្នុងគាថាទី ៤ មានមួយ ដោយអំណាចថេយ្យាវហារ ក្នុងគាថាទី ៥ មានមួយ ដោយអំណាចនៃការគេចកែបំណុល ក្នុងគាថាទី ៦ មានមួយ គឺសម្លាប់អ្នកដើរផ្លូវ ដោយអំណាចបសយ្ហាវហារ ក្នុងគាថាទី ៧ មានមួយ ដោយអំណាចនៃបុគ្គលដែលជាសាក្សីកោង ក្នុងគាថាទី ៨ មានមួយ ដោយអំណាចនៃការទ្រុស្តមិត្ត ក្នុងគាថាទី ៩ មានមួយ ដោយអំណាចនៃអកតញ្ញូ ក្នុងគាថាទី ១០ មានមួយ ដោយអំណាចនៃបុគ្គលធ្វើសេចក្តីវិនាស និងបៀតបៀន ក្នុងគាថាទី ១១ មានមួយ ដោយ

អំណាចនៃការបោកបញ្ឆោតអ្នកដទៃ ក្នុងគាថាទី ១២ មានពីរ ដោយអំណាច នៃបុគ្គលដែលបិទបាំងកម្ម និងការឆោរ ក្នុងគាថាទី ១៣ មានមួយ ដោយ អំណាចនៃបុគ្គលអកតញ្ញូចក្នា ក្នុងគាថាទី ១៤ មានមួយ ដោយអំណាច នៃការបោកបញ្ឆោត ក្នុងគាថាទី ១៥ មានមួយ ដោយអំណាចនៃការបៀត បៀន ក្នុងគាថាទី ១៦ មានមួយ ដោយអំណាចនៃការបោកបញ្ឆោត ក្នុង គាថាទី ១៧ មានពីរ ដោយអំណាចការលើកខ្លួន និងសង្កត់សង្កិនអ្នកដទៃ ក្នុងគាថាទី ១៨ មាន ៧ មានកោងកាចជាដើម ដោយអំណាចនៃបយោគ វិបត្តិ និងអាសយវិបត្តិ ក្នុងគាថាទី ១៩ មានពីរ ដោយអំណាចនៃការ តិះដៀល ក្នុងគាថាទី ២០ មានមួយ ដោយអំណាចនៃអគ្គមហាចោរ ដូច្នេះ ហើយ ទើបទ្រង់ត្រាស់ថា បុគ្គលថោកទាបទាំងនេះឯង តថាគតបានប្រកាស ហើយ ។

អត្ថនៃព្រះតម្រាស់នោះ មានដូច្នេះថា បុគ្គលថោកទាបទាំងនោះ ដែល តថាគតពោលក្នុងកាលមុន ដោយសង្ខេបយ៉ាងនេះថា ម្នាលព្រាហ្មណ៍ អ្នក ស្គាល់បុគ្គលថោកទាបឬ បុគ្គលថោកទាបទាំងនោះ តថាគតប្រកាសហើយ ដោយពិស្តារ ។

ម្យ៉ាងទៀត បុគ្គលថោកទាបទាំងនោះ តថាគតពោលហើយដោយអំណាច បុគ្គលថោកទាបទាំងនោះឯង តថាគតប្រកាសហើយដោយអំណាចនៃធម៌ ។

ម្យ៉ាងទៀត បុគ្គលថោកទាបពួកណា តថាគតប្រកាសហើយដល់អ្នក

បុគ្គលថោកទាបទាំងនោះ តថាគតពោលហើយ ដោយអំណាចនៃអរិយធម៌ មិនបានពោលដោយអំណាចនៃជាតិឡើយ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងបុគ្គលថោកទាបយ៉ាងនេះ ដោយន័យជាដើមថា អ្នកច្រើនដោយសេចក្ដីក្រោធ អ្នកចងសេចក្ដីក្រោធដូច្នេះ ឥឡូវនេះ កាលទ្រង់បដិសេធទិដ្ឋិដែលព្រាហ្មណ៍ប្រកាន់មាំក្រៃលែងដោយសក្កាយទិដ្ឋិ ទើបត្រាស់ថា បុគ្គលមិនមែនថោកទាប ព្រោះជាតិ ។

អត្ថនៃគាថានោះថា ដោយបរមត្ថ បុគ្គលមិនជាមនុស្សថោកទាបព្រោះជាតិ មិនជាព្រាហ្មណ៍ព្រោះជាតិ តែជាបុគ្គលថោកទាបព្រោះកម្ម ជាព្រាហ្មណ៍ព្រោះកម្ម ជាបុគ្គលថោកទាបព្រោះហូរចេញមកនូវកម្មមិនបរិសុទ្ធ ជាព្រាហ្មណ៍ព្រោះបន្សាត់នូវកម្មដែលមិនបរិសុទ្ធ ដោយកម្មដ៏បរិសុទ្ធ ឬព្រោះអ្នកសម្គាល់មនុស្សអាក្រក់ថាជាបុគ្គលថោកទាប មនុស្សប្រសើរថាជាព្រាហ្មណ៍ព្រោះហេតុនោះ បុគ្គលជាមនុស្សថោកទាបព្រោះកម្មអាក្រក់ ជាព្រាហ្មណ៍ព្រោះកម្មប្រសើរដោយហេតុនេះ កាលទ្រង់ញុំាងព្រាហ្មណ៍ឲ្យដឹងអត្ថយ៉ាងនេះ ទើបត្រាស់យ៉ាងនោះ ។

ឥឡូវនេះ ដើម្បីទ្រង់ញុំាងអត្ថនោះឲ្យសម្រេច ដោយការសម្ដែងពន្លឹក ទើបត្រាស់ ៣ គាថាយ៉ាងនេះថា **តទមិនាបិ ជានាថ** ដូច្នេះ ។ ក្នុងគាថាទាំងនោះ ២ គាថា មាន ៤ បទ ១ គាថា មាន ៦ បទ ។

អត្ថនៃគាថាទាំងនោះថា ពាក្យណា តថាគតពោលហើយថា បុគ្គល

មិនមែនថោកទាបព្រោះជាតិជាដើម ចូរអ្នកដឹងសេចក្ដីនោះតាមដែលតថាគត សម្ដែងនេះ អធិប្បាយថា ពាក្យដែលតថាគតពន្យល់នេះ រមែងមានដោយប្រការណា គឺដោយការដូចគ្នាឯណា ចូរអ្នកដឹងសេចក្ដីនោះ ដោយប្រការនេះ ។ បើមានពាក្យសួរថា ឧបមាដូចម្ដេច ឆ្លើយថា កូនរបស់មនុស្សចណ្ឌាល មានឈ្មោះប្រាកដថា សោបាកមាតង្គៈ ។បេ។ ហើយទៅកើតក្នុងព្រហ្មលោកជាឧទាហរណ៍ ។ បុត្ររបស់មនុស្សចណ្ឌាល ឈ្មោះថា ចណ្ឌាល-បុត្រ បុគ្គលណាបានរបស់ដែលឆ្អិនហើយ ដើម្បីប្រយោជន៍ដល់ការទំពាស៊ីរបស់ខ្លួន ហើយចម្អិនទូវរបស់ឆ្អិនទាំងនោះទៀត ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **សោបាក** អ្នកបរិភោគរបស់ដែលខ្លួនចម្អិន ឈ្មោះថា **មាតង្គ** បានដល់ ដែលមានឈ្មោះយ៉ាងនោះ ។

បទថា **វិស្សុតោ** សេចក្ដីថា ប្រាកដហើយដោយជាតិអាក្រក់ រស់នៅហើយ នឹងមានឈ្មោះយ៉ាងនេះ ។ បទថា **សោ** សេចក្ដីថា ភ្ជាប់ចូលជាមួយបទមុនថា មាតង្គៈនោះបានយសដ៏ឧត្ដម គឺសម្រេចព្រមហើយនូវយស គឺកិត្តិយស ការសរសើរគួរអស្ចារ្យ ដ៏ឧត្ដម ប្រសើរក្រៃលែង ។ បទថា **យំ សុទុល្លភំ** សេចក្ដីថា ដែលបុគ្គលកើតហើយ ក្នុងត្រកូលខ្ពស់ ក៏បានដោយលំបាក ដែលបុគ្គលកើតក្នុងត្រកូលអាក្រក់ ក៏បានដោយលំបាក ។ អធិប្បាយថា ពួកក្សត្រ ពួកព្រាហ្មណ៍ជាច្រើន មកកាន់ទីបម្រើរបស់មាតង្គៈនោះ បុគ្គលបានដល់នូវយសយ៉ាងនេះ គឺពួកក្សត្រ ពួកព្រាហ្មណ៍ និងពួកមនុស្ស

ក្នុងជម្ពូទ្វីបដទៃច្រើន មានវេស្សៈ និងសូទ្រៈ ក៏មកកាន់ទីបម្រើដោយច្រើន ដើម្បីបម្រើមាតង្គៈនោះ ។

អធិប្បាយថា មាតង្គៈនោះ ដល់ព្រមដោយការខ្ទីឃ្មាត ព្យាយាមយ៉ាងនេះ ឡើងកាន់យាន គឺសមាបត្តិ ៨ ដែលឈ្មោះថា **វិរជំ** ព្រោះប្រាសចាកធូលី គឺកិលេស ឈ្មោះថា **មហាបថំ** ព្រោះបុគ្គលធំ មានព្រះពុទ្ធជាដើមបដិបត្តិហើយ ដែលដឹងថាយានទៅកាន់ព្រហ្មលោក ព្រោះជាយានអាចឲ្យដល់ទេវលោក ពោល គឺព្រហ្មលោក ខ្ជាក់ចោលនូវកាមរាគបាន ដោយបដិបត្តិនោះ ស្លាប់ហើយ បានចូលដល់ព្រហ្មលោក ជាតិសូម្បីអាក្រក់យ៉ាងនោះ ក៏មិនហាមការកើតក្នុងព្រហ្មលោក អ្នកសិក្សាគប្បីជ្រាបអត្ថនេះយ៉ាងនេះថា

បានឮថា ក្នុងអតីតកាល មហាបុរសធ្វើនូវប្រយោជន៍ដល់សត្វ ដោយឧបាយនោះៗ កើតក្នុងត្រកូលចណ្ឌាល ដែលចិញ្ចឹមជីវិតដោយអាហារដែលខ្លួនឲ្យផ្អិនឯង មហាបុរសនោះមានឈ្មោះថា មាតង្គៈ មានរូបរាងមិនគួរមើល អាស្រ័យនៅក្នុងខ្ទមដែលប្រក់ដោយស្បែកសត្វ ខាងក្រៅនគរ ដើររកកិច្ចខាងក្នុងនគរចិញ្ចឹមជីវិត ។

ថ្ងៃមួយ កាលពួកមនុស្សឃោសនានក្ខត្តឫក្ស ទាក់ទងដោយសុរាក្នុងនគរនោះ ពួកអ្នកលេងនាំគ្នាលេងជាមួយបរិវាររបស់ខ្លួន ធីតារបស់ព្រាហ្មណ៍មហាសាលម្នាក់ អាយុប្រហែល ១៥ ឬ ១៦ ឆ្នាំ មានរូបល្អគួរគយគន់

គួរជ្រះថ្លា ដូចទេវកញ្ញា គិតថា អញនឹងលេងតាមសមគួរដល់ត្រកូលវង្ស របស់ខ្លួន ទើបដឹកសម្ភារៈដែលទាក់ទងក្នុងការលេង មានរបស់ទំពា របស់បរិភោគជាដើម គ្រប់គ្រាន់ ដាក់ក្នុងរទេះទាំងឡាយ ឡើងកាន់យាន ដែលទឹមដោយសេះពណ៌សសុទ្ធ ទៅកាន់ទីលេងក្នុងឧទ្យានដោយបរិវារធំ នាងមានឈ្មោះថា ទិដ្ឋមង្គលិកា ។ បានឮថា នាងមិនប្រាថ្នាឃើញរូបដែលមិនស្អាត ដោយគិតថា ជាអព្វមង្គល ដោយហេតុនោះ ទើបមានឈ្មោះថា ទិដ្ឋ-មង្គលិកា ។

ក្នុងកាលនោះ មាតង្គៈក្រោកឡើងតាមកាលនោះឯង ស្លៀកសំពត់ចាស់ ចងស្លឹកត្នោតត្រង់ដៃ កាន់ភាជន៍ចូលកាន់នគរ ឃើញមនុស្សទាំងឡាយហើយ ក៏គោះផាងត្នោតអំពីចម្ងាយ លំដាប់នោះ នាងទិដ្ឋិមង្គលិកា ដែលបុរសទាំងឡាយកំពុងដេញមនុស្ស ដែលអាក្រក់ខាងមុខៗ ថា ចូរពួកអ្នកក្រោកចេញទៅ ចូរក្រោកចេញទៅ បានឃើញមាតង្គៈត្រង់កណ្តាលទ្វារនគរ ទើបពោលថា នុ៎ះជានរណា មាតង្គៈឆ្លើយថា ខ្ញុំជាកូនចណ្ឌាល ឈ្មោះមាតង្គៈ ។ នាងគិតថា មនុស្សទាំងឡាយមិនឃើញមនុស្សបែបនេះ សេចក្តីចម្រើន នឹងមានមកអំពីណា ទើបឲ្យនាំយានត្រឡប់ ។ មនុស្សទាំងឡាយខឹងក្រោធ ពោលថា ពួកយើងទៅកាន់ឧទ្យានហើយ គប្បីបានវត្ថុ មានខាទនីយៈ និងភោជនី-យាហារ យ៉ាងណា អន្តរាយនៃវត្ថុមានរបស់ទំពា និងរបស់បរិភោគជាដើម នោះរបស់ពួកយើង ត្រូវមាតង្គៈធ្វើហើយ ទើបពោលថា ពួកយើង ចូរចាប់

មនុស្សចណ្ឌាល ប្រហារដោយដុំដីទាំងឡាយ ដឹងថា ស្លាប់ហើយ ក៏ចាប់ជើងអូសទៅបោះចោលត្រង់ចំណែកម្ខាង លុបដោយសំរាមហើយទៅ ។ មាតង្គៈបាននូវស្មារតីហើយ ក្រោកឡើងសួរមនុស្សទាំងឡាយថា នៃអ្នកទាំងឡាយឈ្មោះថា ទ្វារ ជារបស់ទូទៅដល់មនុស្សទាំងពួង ឬធ្វើសម្រាប់តែពួកព្រាហ្មណ៍ប៉ុណ្ណោះ មនុស្សទាំងឡាយពោលថា មិនមែនធ្វើដើម្បីពួកព្រាហ្មណ៍ប៉ុណ្ណោះឡើយ ទ្វារ ជារបស់ទូទៅដល់មនុស្សទាំងពួង ។ មាតង្គៈគិតថា មនុស្សទាំងឡាយ ឲ្យអញ ដែលចូលទៅតាមទ្វារ ដែលទូទៅដល់ជនទាំងពួងហើយ ញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅដោយកិច្ចាចារ ឲ្យដល់នូវសេចក្ដីវិនាស ដល់នូវសេចក្ដីលំបាកនេះ ព្រោះនាងទិដ្ឋមង្គលិកាជាហេតុ ទើបត្រាច់ទៅតាមវិថី ប្រាប់ដល់មនុស្សទាំងឡាយ ហើយដេកត្រង់ទ្វារផ្ទះរបស់ព្រាហ្មណ៍ ដោយគិតថា បើអញមិនបាននាងទិដ្ឋមង្គលិកា អញមិនក្រោកឡើងឡើយ ។

ព្រាហ្មណ៍បានឮថា មាតង្គៈដេកត្រង់ទ្វារផ្ទះ ទើបពោលថា អ្នកទាំងឡាយ ចូរឲ្យកាកណិក ១ ដល់គេ យកប្រេងល្ងលាបខ្លួនហើយ ឲ្យគេទៅចុះ ។ មាតង្គៈនោះមិនប្រាថ្នាកាកណិកៈនោះ ទើបពោលថា បើខ្ញុំមិនបាននាងទិដ្ឋមង្គលិកាហើយ នឹងមិនក្រោកឡើង ។ បន្ទាប់អំពីនោះ ព្រាហ្មណ៍ពោលថា ចូរឲ្យ ២ កាកណិក ចូរមាតង្គៈបរិភោគនំ ១ កាកណិក យកប្រេងល្ងលាបខ្លួន ១ កាកណិក ហើយឲ្យគេទៅចុះ ។ មាតង្គៈមិនត្រូវការ

កាកណិកនោះ នៅតែពោលដូចដើមនោះឯង ព្រាហ្មណ៍ឮហើយ ក៏ប្រាប់ថា ចូរឲ្យមួយមាសក មួយបាទ កន្លះកហាបណៈ ២ កហាបណៈ ៣ កហាបណៈ រហូតដល់ ១០០ កហាបណៈ មាតង្គៈក៏មិនត្រូវការ នៅតែពោលដូចមុននោះឯង កាលពួកជនកំពុងអង្វរនោះឯង ព្រះអាទិត្យក៏អស្តង្គត ។

លំដាប់នោះ ព្រាហ្មណីក៏ចុះអំពីប្រាសាទ ឲ្យព័ទ្ធវាំងននចូលទៅរកមាតង្គៈនោះហើយអង្វរថា នែបាមាតង្គៈ ចូរបាអត់ទោសឲ្យទិដ្ឋមង្គលិកាចុះ ចូរទទួល ១ ពាន់កហាបណៈ ២ ពាន់កហាបណៈ ៣ ពាន់កហាបណៈ រហូតដល់ ១ សែនកហាបណៈ មាតង្គៈក៏នៅតែដេកស្ងៀមនោះឯង កាលថ្ងៃទី ៤ ទី ៥ កន្លងទៅយ៉ាងនេះហើយ ជនទាំងឡាយ មានខត្តិយរាជកុមារជាដើម ឲ្យបណ្ណាការសូម្បីច្រើនហើយ កាលមិនបាននាងទិដ្ឋមង្គលិកា ទើបមកខ្សឹមប្រាប់មាតង្គៈថា ធម្មតាបុរសទាំងឡាយ ធ្វើនូវសេចក្តីព្យាយាមច្រើនឆ្នាំ ទើបដល់នូវសេចក្តីប្រាថ្នា អ្នកកុំនឿយណាយឡើយ អ្នកនឹងបាននាងទិដ្ឋមង្គលិកា ដោយកាលកន្លងទៅពីរបីថ្ងៃទៀតប៉ុណ្ណោះ មាតង្គៈក៏ដេកស្ងៀមយ៉ាងនោះឯង ។

លំដាប់នោះ ក្នុងថ្ងៃទី ៧ ពួកមនុស្សដែលស្និទ្ធស្នាលនៅជុំវិញផ្ទះ ក្រោកឡើងពោលថា ចូរលោកឲ្យមាតង្គៈក្រោកឡើង ចូរឲ្យទារិកា កុំឲ្យពួកយើងទាំងឡាយវិនាសឡើយ ។ បានឮថា ជនទាំងនោះមានទិដ្ឋិយ៉ាងនេះថា មនុស្សចណ្ឌាលដេកស្លាប់យ៉ាងនេះ ក្នុងទ្វារផ្ទះរបស់អ្នកណា ពួកមនុស្សដែលនៅ

ក្នុងផ្ទះជុំវិញ ៧ ខ្នង មួយអន្លើដោយផ្ទះបុគ្គលនោះ ក៏ក្លាយជាមនុស្សចណ្ឌាលផងដែរ ។ បន្ទាប់អំពីនោះ ព្រាហ្មណ៍ និងព្រាហ្មណីឲ្យនាងទិដ្ឋមង្គលិកាស្លៀកសំពត់ចាស់ពណ៌ខៀវ ឲ្យវត្ថុទាំងឡាយ មានត្រឡោក និងថ្នាំងជាដើម នាំនាងដែលកំពុងយំ ទៅកាន់សម្នាក់របស់មាតង្គៈនោះហើយ ពោលថា ចូរអ្នកទទួលទារិកាក្រោកឡើងទៅចុះ ទារិកានោះឈរក្បែរ ពោលថា ចូរក្រោកឡើង ។ មាតង្គៈពោលថា ចូរចាប់ដៃខ្ញុំឲ្យក្រោកឡើង ហើយពោលថា ពួកយើងមិនបានទៅខាងក្នុងនគរ ចូរមក នាំខ្ញុំទៅកាន់ខ្ទមស្បែកខាងក្រៅព្រះនគរ នាងបានដឹកដៃនាំទៅកាន់ខ្ទមស្បែក អាចារ្យអ្នកពោលជាតកពោលថា ឲ្យជិះលើខ្នង ។ កាលនាំទៅហើយ ទើបយកប្រេងលាបរាងកាយរបស់មាតង្គៈនោះ ឲ្យងូតដោយទឹកក្តៅ ហើយដាំបបរឲ្យ ។ មាតង្គៈគិតថា ព្រាហ្មណកញ្ញានេះ កុំបីវិនាសឡើយ ហើយមិនធ្វើសម្ពពដោយជាតិ លុះមានកម្លាំងត្រឹមកន្លះខែ ក៏ពោលថា ខ្ញុំនឹងទៅព្រៃ នាងកុំក្តៅក្រហាយចិត្តថាយឺតយូរប្រើនឡើយ ហើយប្រាប់មនុស្សក្នុងផ្ទះថា ពួកអ្នកកុំលះបង់នាង ហើយចេញអំពីផ្ទះបួសជាតាបស ធ្វើកសិណបរិកម្ម ដោយកាលមិនយូរប៉ុន្មាន ក៏ញុំាំងសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតឡើង គិតថា ឥឡូវនេះ អញនឹងធ្វើជាទីពឹងដល់នាងទិដ្ឋមង្គលិកា ទើបហោះមកតាមអាកាសចុះត្រង់ទ្វារនគរ ឲ្យដំណឹងដល់នាងទិដ្ឋមង្គលិកា ។ នាងស្តាប់ហើយគិតថា ប្រហែលជាញាតិរបស់អញណាមួយបួសហើយ ដឹងថា អញមានទុក្ខ មកសួរសុខទុក្ខ ដូច្នេះ ទើបទៅ ដឹងថាមាតង្គៈនោះហើយ

ក្រាបចុះទៀបបាទាពោលថា លោកម្ចាស់ធ្វើខ្ញុំឲ្យអស់ទីពឹង លោកម្ចាស់មក ដើម្បីប្រយោជន៍អ្វី ។ មហាបុរសពោលថា នែទិដ្ឋមង្គលិកា នាងកុំជាទុក្ខថ្វី ឡើយ ខ្ញុំនឹងឲ្យអ្នកជម្ពូទ្វីបទាំងមូលធ្វើសក្ការៈដល់នាង ហើយពោលពាក្យ នេះថា ទៅចុះ ចូរនាងធ្វើការប្រកាសថា មហាព្រហ្មជាប្តីរបស់ខ្ញុំ មិនមែន មាតង្គៈ មហាព្រហ្មនោះ នឹងហែកព្រះចន្ទមកកាន់សម្នាក់របស់ខ្ញុំក្នុងថ្ងៃទី ៧ ។ នាងពោលថា បពិត្រលោកម្ចាស់ ខ្ញុំជាធីតារបស់ព្រាហ្មណមហាសាល ដល់ នូវភាពជាមនុស្សចណ្ឌាល ព្រោះបាបកម្មរបស់ខ្លួន ខ្ញុំមិនអាចពោលយ៉ាង នោះបានទេ មហាបុរសពោលថា នាងមិនដឹងអានុភាពរបស់មាតង្គៈ ដូចយើង ទើបសម្តែងបាដិហារ្យច្រើនយ៉ាងឲ្យនាងជឿ បញ្ជូននាងទៅយ៉ាងនោះហើយ ក៏ទៅកាន់លំនៅរបស់ខ្លួន នាងបានធ្វើយ៉ាងនោះ ។

ពួកមនុស្សក៏នាំគ្នាសម្លឹងទោសសើចថា ទិដ្ឋមង្គលិកានេះ ដល់នូវភាព ជាចណ្ឌាលហើយ ព្រោះបាបកម្មរបស់ខ្លួន នឹងធ្វើមាតង្គៈនោះឲ្យជាមហាព្រហ្ម ទៀត ។ នាងមានមានះក្រៃលែងនោះឯង ទើបត្រាច់ប្រកាសពេញព្រះនគរ រាល់ៗ ថ្ងៃថា ចាប់អំពីនេះទៅ មហាព្រហ្មនឹងមកក្នុងថ្ងៃទី ៦ ទី ៥ ទី ៤ ទី ៣ ក្នុងថ្ងៃស្អែកនេះ ក្នុងថ្ងៃនេះ ។ មនុស្សទាំងឡាយស្តាប់ដំណឹងដែលនាង ប្រកាសហើយគិតថា ជួនកាលអាចមានយ៉ាងនេះ ទើបធ្វើមណ្ឌបត្រង់ទ្វារផ្ទះ រៀងៗ ខ្លួន រៀបចំទឹកខ្ទែង ចងរាំងននទ តាក់តែងទារិកាដែលចម្រើនដោយ វ័យ អង្គុយមើលមេឃថា កាលមហាព្រហ្មយាងមក នឹងថ្វាយកញ្ញាទាន ។

លំដាប់នោះ មហាបុរស កាលព្រះចន្ទរះឡើងក្នុងលម្អ ក្នុងថ្ងៃ ១៥ កើត ក៏ហែកព្រះចន្ទចេញមក ប្រាកដរូបជាមហាព្រហ្មដល់មហាជនដែលកំពុងមើល មហាជនយល់ថា ព្រះចន្ទពីរកើតឡើងហើយ បន្ទាប់អំពីនោះ ឃើញមហាព្រហ្មមកដោយលំដាប់ ដល់នូវការសម្រេចថា នាងទិដ្ឋមង្គលិកានិយាយពិត នេះជាមហាព្រហ្មនោះឯង មកដោយគេទរបស់មាតង្គៈក្នុងកាលមុន ដើម្បីទូន្មាននាងទិដ្ឋមង្គលិកា ។ មហាបុរសនោះ កាលមហាជនកំពុងមើលយ៉ាងនោះ ក៏ចុះទៅកាន់លំនៅរបស់នាងទិដ្ឋមង្គលិកានោះឯង ។

ក្នុងកាលនោះ នាងមានរដូវ មហាបុរសនោះក៏ស្ទាបត្រង់ផ្ចិតរបស់នាងដោយម្រាមដៃ គភ៌ក៏តាំងឡើងដោយការស្ទាបនោះ បន្ទាប់អំពីនោះ ទើបពោលថា គភ៌របស់នាងដល់ព្រមហើយ កាលបុត្រកើត ចូរនាងអាស្រ័យបុត្រនោះចិញ្ចឹមជីវិត កាលមហាជនកំពុងសម្លឹងមើលនោះឯង ក៏ចូលទៅក្នុងព្រះចន្ទវិញ ពួកព្រាហ្មណ៍នាំគ្នាពោលថា នាងទិដ្ឋមង្គលិកាជាបជាបតីរបស់មហាព្រហ្ម ជាមាតារបស់ពួកយើង ទើបមកអំពីទីនោះៗ ទ្វារនគរទាំងមូលក៏ចង្អៀត ដោយអំណាចនៃពួកមនុស្ស ។ បុគ្គលប្រាថ្នាដើម្បីធ្វើសក្ការៈនោះ ពួកព្រាហ្មណ៍ទាំងនោះ បានតាំងនាងក្នុងគំនរប្រាក់ ឲ្យងូតទឹក តាក់តែងលើកឡើងកាន់រថ ធ្វើប្រទក្សិណព្រះនគរដោយសក្ការៈធំ សាងមណ្ឌបត្រង់កណ្ដាលនគរ តាំងនាងក្នុងតំណែងបជាបតីរបស់ព្រហ្ម ឲ្យនៅក្នុងមណ្ឌបនោះថា សូមឲ្យនាងនៅក្នុងមណ្ឌបនេះសិន ទម្រាំពួកយើងធ្វើឱកាស គឺទីលំនៅ

សមគួរដល់នាង ។

នាងប្រសូតបុត្រត្រង់មណ្ឌបនោះឯង ក្នុងថ្ងៃបរិសុទ្ធ ពួកព្រាហ្មណ៍ឲ្យនាង ព្រមទាំងបុត្រងូតទឹក កក់សក់ ហើយដាក់ឈ្មោះថា មណ្ឌព្យកុមារ ព្រោះកើតក្នុងមណ្ឌប ។ ចាប់តាំងអំពីនោះ ពួកព្រាហ្មណ៍ចោមរោមកុមារនោះថា ជាបុត្ររបស់ព្រហ្ម បណ្ណាការច្រើនសែនប្រការមកអំពីទីនោះ ព្រាហ្មណ៍ទាំងនោះរក្សាកុមារ ។ ជនដែលមកហើយ មិនបានសួរសុខទុក្ខកុមារដោយរហ័ស ។ កុមារអាស្រ័យការចម្រើនដោយលំដាប់ ប្រារព្ធនឹងឲ្យទាន តែកុមារមិនឲ្យទានដល់មនុស្សកំព្រា និងអ្នកដំណើរ ដែលដល់ព្រមដោយសេចក្តីសង្ឃឹម គឺឲ្យដល់ព្រាហ្មណ៍ប៉ុណ្ណោះ ។

មហាបុរសរឭកថា កូនរបស់អញឲ្យទានឬហ្ន៎ ឃើញកុមារកំពុងឲ្យទានដល់ព្រាហ្មណ៍ទាំងឡាយ ទើបគិតថា អញនឹងធ្វើដោយប្រការដែលកុមារនេះឲ្យទានដល់មនុស្សទាំងអស់ ទើបដណ្តប់ចីវរ កាន់បាត្រមកតាមអាកាស ឈរត្រង់ទ្វារផ្ទះរបស់កុមារនោះ កុមារឃើញមហាបុរសហើយខឹងក្រោធថា សមណៈនេះជាមនុស្សថោកទាប មានភេទគួរខ្ពើមយ៉ាងនេះ មកអំពីណា ដូច្នេះហើយពោលគាថានេះថា

អ្នកមកអំពីទីណា បានជាមានប្រដាប់ស្លៀកពាក់អាក្រក់ លាមក
ដូចជាបិសាចលើអាចម៍ដី ពាក់នូវកំណាត់សំពត់ ដែលគេចោល
លើគំនរសំរាមព្ធដ៏ក ខ្ទនអ្នកជាបុគ្គលផ្តេសផ្តាស មិនមែនជា

ទក្ខិណេយ្យបុគ្គលទេ ។

ពួកព្រាហ្មណ៍ពោលថា ចូរចាប់ ចូរចាប់ ហើយចាប់មហាបុរសនោះ វាយឲ្យដល់នូវសេចក្តីវិនាស ឲ្យដល់នូវសេចក្តីលំបាក មហាបុរសនោះហោះតាមអាកាសទៅឈរខាងក្រៅនគរ ។

ទេវតាទាំងឡាយក្រោធហើយ ចាប់កកុមារយកជើងឡើងលើ ក្បាលចុះក្រោម ។ កុមារនោះមានភ្នែកមិនប៉ប្រិច មានទឹកមាត់ហូរចេញអំពីមាត់ដកដង្ហើម ឃ្រុ ឃ្រុ សោយនូវទុក្ខវេទនា ។ នាងទិដ្ឋមង្គលិកាស្តាប់ហើយសួរថា មានអ្នកណាមកឬ ពួកជនទាំងនោះឆ្លើយថា មានបព្វជិតមួយរូបមក នាងសួរថា តើបព្វជិតនោះទៅណា ជនទាំងនោះឆ្លើយថា ទើបទៅទីឯណោះ នាងទៅទីនោះហើយ អង្វរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់អត់ទោសដល់ទាសៈរបស់លោកម្ចាស់ ដូច្នេះហើយ ក្រាបចុះទៀបបាទារបស់មហាបុរស ។

ដោយសម័យនោះ មហាបុរសត្រាច់បិណ្ឌបាតបានបបរ កំពុងហុតបបរអង្គុយក្នុងទីនោះ ឲ្យបបរដែលសល់បន្តិចបន្តួចដល់នាងទិដ្ឋមង្គលិកា ពោលថា ចូរទៅចុះ ចូរកូរបបរនេះក្នុងផ្តាំងទឹក ហើយបន្តក់ភ្នែក ត្រចៀក ប្រមុះ និងប្រោះព្រំរាងកាយទាំងមូលរបស់មនុស្សពិការទាំងឡាយ អ្នកពិការទាំងឡាយ នឹងជាសះស្បើយ នាងបានធ្វើយ៉ាងនោះ បន្ទាប់អំពីនោះ កាលកុមារមានរាងកាយប្រក្រតីហើយ ទើបពោលថា នែបាមណ្ឌព្យ: ពួកយើងនឹងឲ្យ

មហាបុរសនោះអត់ទោស ហើយនាំកូន និងព្រាហ្មណ៍ទាំងពួង ឲ្យក្រាបចុះទៀបបាទមូលរបស់មហាបុរសនោះ ហើយឲ្យសូមខមាទោស ។

មហាបុរសទូន្មានថា គប្បីឲ្យទានដល់ជនទាំងពួង ពោលធម្មកថាហើយទៅកាន់លំនៅរបស់ខ្លួន គិតថា នាងទិដ្ឋមង្គលិកា យើងបានទូន្មានប្រាកដហើយក្នុងស្រីទាំងឡាយ មណ្ឌព្យកុមារ ប្រាកដហើយក្នុងបុរសទាំងឡាយ ឥឡូវនេះ អញគប្បីទូន្មានអ្នកណា បន្ទាប់អំពីនោះ បានឃើញជាតិមន្តតាបស ដែលអាស្រ័យពន្ធុមតីនគរ នៅត្រង់ប្រាំងនៃកុម្ភវតីនទី តាបសនោះគិតថា អាត្មាអញជាបុគ្គលប្រសើរដោយជាតិ និងមិនបរិភោគទឹកដែលអ្នកដទៃទាំងឡាយបរិភោគហើយ ទើបទៅបោះទីអាស្រ័យខាងលើទឹក មហាបុរសសម្រេចការនៅលើភូមិភាគរបស់តាបសនោះ ក្នុងកាលដែលតាបសនោះបរិភោគទឹក ក៏ទំពាឈើស្ទន់ខ្ជាក់ចោលទៅក្នុងស្ទឹង តាបសឃើញឈើស្ទន់នោះត្រូវទឹកបន្សាត់ទៅ ក៏គិតថា អ្នកណាចោលឈើស្ទន់នេះ ទើបដើរប្រាស់ខ្សែទឹក ឃើញមហាបុរសហើយ សួរថា ឯងជាអ្នកណា មហាបុរសឆ្លើយថា ខ្ញុំឈ្មោះមាតង្គៈជាមនុស្សចណ្ឌាល តាបសនោះពោលថា ចូរចៀសចេញទៅ កុំមកនៅលើទឹក មហាបុរសទទួលថា សាធុ ហើយក៏ស្នាក់នៅខាងក្រោមទឹក ឈើស្ទន់ក៏អណ្តែតប្រាស់ក្រសែ មកកាន់សម្នាក់តាបសៗ បានទៅទៀត ពោលថា ចេញទៅមនុស្សចណ្ឌាល ចូរកុំនៅក្នុងទីក្រោមទឹក ចូរនៅលើទឹកប៉ុណ្ណោះ មហាបុរសទទួលថា សាធុ ទើបធ្វើតាមពាក្យប្រាប់ ហើយក៏ធ្វើដូចមុនទៀត

តាបសក្រោធថា កុំធ្វើយ៉ាងនោះទៀត ទើបផ្ដាសាមហាបុរសថា ក្នុងពេលព្រះអាទិត្យរះឡើង ក្បាលរបស់លោក ចូរបែកជា ៧ ភាគ ចំណែកមហាបុរសពោលថា សាធុ តែខ្ញុំនឹងមិនឲ្យព្រះអាទិត្យរះឡើង ទើបឃាត់ព្រះអាទិត្យមិនឲ្យរះ ។

បន្ទាប់អំពីនោះ រាត្រីក៏មិនអស់ទៅ ងងឹតក៏កើតឡើង អ្នកនគរពន្ធុមតីខ្លាចហើយ នាំគ្នាទៅកាន់សម្នាក់របស់តាបស សួរថា លោកអាចារ្យ ពួកខ្ញុំនឹងមានការផុតភ័យឬហ្ន៎ ហើយអ្នកនគរទាំងនោះ ក៏សម្គាល់តាបសនោះថាជាព្រះអរហន្ត តាបសនោះក៏ប្រាប់រឿងទាំងអស់ដល់អ្នកនគរទាំងនោះ ទើបពួកអ្នកនគរ ចូលទៅរកមហាបុរសអង្វរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់លែងនូវព្រះអាទិត្យ មហាបុរសពោលថា បើព្រះអរហន្តរបស់ពួកអ្នកមកសូមខមាទោសអាត្មាៗ នឹងលែង ។

ពួកមនុស្សទៅហើយពោលនឹងតាបសថា មកលោកដ៏ចម្រើន សូមលោកម្ចាស់សូមខមាទោសមាតង្គបណ្ឌិត កុំឲ្យពួកខ្ញុំវិនាស ព្រោះហេតុនៃការទាស់ទែងរបស់ពួកលោកម្ចាស់ឡើយ តាបសនោះពោលថា យើងមិនសូមខមាទោសចណ្ឌាលឡើយ ។ មនុស្សទាំងឡាយពោលថា លោកម្ចាស់ឲ្យពួកខ្ញុំវិនាស ហើយនាំគ្នាចាប់ដៃ និងជើង នាំទៅកាន់សម្នាក់របស់មហាបុរសៗពោលថា បើតាបសក្រាបទៀបបាតជើងរបស់យើង ហើយសូមខមាទោសយើងនឹងអត់ទោសឲ្យ មនុស្សទាំងឡាយពោលថា ចូរធ្វើយ៉ាងនេះ តាបស

ពោលថា យើងមិនថ្វាយបន្ទំចណ្ឌាល មនុស្សទាំងឡាយពោលថា លោកម្ចាស់មិនថ្វាយបង្គំតាមការពេញចិត្តរបស់លោកម្ចាស់ឬ ដូច្នេះហើយ ទើបចាប់ដៃជើង ពុកមាត់ និងកជាដើម ឲ្យដេកទៀបបាតជើងរបស់មហាបុរស ។

មហាបុរសពោលថា យើងអត់ទោសឲ្យតាបសនេះ តែមិនលែងព្រះអាទិត្យ ព្រោះអនុគ្រោះដល់តាបសនោះឯង ព្រោះកាលព្រះអាទិត្យរះឡើងប៉ុណ្ណោះ ក្បាលរបស់តាបសនេះនឹងបែកជា ៧ ភាគ ទើបមនុស្សទាំងឡាយពោលថា បពិត្រលោកម្ចាស់ ឥឡូវនេះ គប្បីធ្វើដូចម្តេច មហាបុរសពោលថា បើដូច្នោះ ចូរពួកអ្នកដាក់ដុំដីស្អិតលើក្បាលរបស់តាបស និងឲ្យនៅក្នុងទឹកជម្រៅប្រមាណត្រឹមក យើងនឹងលែងព្រះអាទិត្យ លុះលែងព្រះអាទិត្យហើយ ដុំដីស្អិតនឹងបែកជា ៧ ភាគ ធ្លាក់ចុះមក តាបសខ្លាចហើយនឹងគេចទៅ ពួកមនុស្សឃើញហើយ ទើបពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់មើលអានុភាពរបស់សមណៈ ដូច្នេះហើយ ពោលរឿងទាំងអស់ឲ្យពិស្តារ តាំងអំពីចោលឈើស្ទន់ជាដើម ជ្រះថ្លាក្នុងមហាបុរសនោះ ពោលថា សមណៈបែបនេះ មិនមាន ។

ចាប់តាំងអំពីនោះ គ្រហស្ថ និងបព្វជិតទាំងឡាយ មានក្សត្រ និងព្រាហ្មណ៍ជាដើម ក្នុងជម្ពូទ្វីបទាំងមូល ក៏បានទៅកាន់ទីបម្រើរបស់មាតង្គបណ្ឌិត តាបសនោះតាំងនៅតាមសមគួរដល់អាយុហើយ ព្រោះកាយបែកធ្លាយ កើតក្នុងព្រហ្មលោក ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **តទមិនាបិ ជានាថ**

។បេ។ **ព្រហ្មលោកូបបត្តិយា** ដូច្នេះ ។

ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យសម្រេចថា បុគ្គលមិនថោកទាបព្រោះជាតិ តែថោកទាបព្រោះកម្មដូច្នេះយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីឲ្យអត្ថសម្រេចយ៉ាងនេះថា មិនជាព្រាហ្មណ៍ព្រោះជាតិ តែជាព្រាហ្មណ៍ព្រោះកម្មដូច្នេះ ទើបត្រាស់ថា **អជ្ឈាយកកុលេ ជាតា ។បេ។ទុគ្គច្វា គរហាយ វា** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អជ្ឈាយកកុលេ** បានដល់ កើតក្នុងត្រកូលព្រាហ្មណ៍ អ្នកស្វាធ្យាយមន្ត ។ បាលីថា **អជ្ឈាយិកកុលេ ជាតា** ដូច្នេះក៏មានអធិប្បាយថា កើតក្នុងត្រកូលព្រាហ្មណ៍ដែលស្វាធ្យាយមន្ត និងមិនត្រូវរង្កៀស ។ មន្តទាំងឡាយជាផៅពង្សរបស់ព្រាហ្មណ៍ទាំងនោះ ព្រោះហេតុនោះទើបព្រាហ្មណ៍ទាំងនោះ ឈ្មោះថា **មន្តពន្ធវា** ជាអ្នកវាយមន្ត គឺវាយវេទ អធិប្បាយថា មានវេទជាទីអាស្រ័យ ។

បទថា **តេ ច បាបេសុ កម្មេសុ អភិណ្ហមុបទិស្សរេ** សេចក្ដីថា ព្រាហ្មណ៍ទាំងនោះ កើតក្នុងត្រកូលយ៉ាងនេះហើយ សូម្បីជាពួកវាយមន្ត ក៏ប្រាកដរឿយៗ ក្នុងបាបកម្មទាំងឡាយ មានបាណាតិបាតជាដើម កាលបើយ៉ាងនោះ ក៏គប្បីតិះដៀលក្នុងបច្ចុប្បន្ននោះឯង ភពខាងមុខក៏ជាទុគ្គតិ អធិប្បាយថា ពួកជនទាំងនោះ កាលប្រាកដយ៉ាងនេះ ក្នុងអត្តភាពនេះ ក៏គប្បីត្រូវមាតា និងបិតាតិះដៀលយ៉ាងនេះថា ជននេះ មិនមែនជាកូនរបស់ពួកយើង ពួកវាធ្វើអាក្រក់ ជាផេះ ជាធ្យូងរបស់ត្រកូល ចូរបណ្ដេញវាទៅ ដូច្នេះក៏មាន ត្រូវ

ព្រាហ្មណ៍ទាំងឡាយតិះដៀលយ៉ាងនេះថា ជនទាំងនេះជាគហបតិ ពួកគេមិនមែនព្រាហ្មណ៍ ពួកអ្នកកុំឲ្យពួកគេចូលទៅក្នុងពិធីទាំងឡាយ មានទីបូជាយញ្ញនិងទីថ្វាយថាសបាយដោយសទ្ធាជាដើម កុំគប្បីសន្ទនាជាមួយពួកគេ ដូច្នេះក៏មាន ត្រូវមនុស្សដទៃតិះដៀលយ៉ាងនេះថា ជនទាំងនេះធ្វើកម្មអាក្រក់ ជនទាំងនេះមិនមែនព្រាហ្មណ៍ ដូច្នេះក៏មាន ភពខាងមុខរបស់ជនទាំងនោះ ក៏ជាទុគ្គតិ គឺបរលោកនៃជនទាំងនោះជាទុគ្គតិមាននរកជាដើម បាលីថា **សម្បរាយេ** ដូច្នេះក៏មាន អធិប្បាយថា ក្នុងបរលោក ពួកជនទាំងនេះ ក៏កើតក្នុងទុគ្គតិ គឺកើតក្នុងកំណើតជាទុក្ខ បានដល់ ដល់នូវសេចក្តីទុក្ខនោះឯង ។

បទថា **ន នេ ជាតិ និវារេតិ ទុគ្គច្ចា គរហាយ វា** សេចក្តីថា ជាតិនោះ សូម្បីខ្ពស់យ៉ាងនោះ លោកសន្មតិជាតិណាថាជាសារៈ ជាតិនោះរមែងមិនឃាត់ពួកព្រាហ្មណ៍ ដែលប្រកបក្នុងបាបកម្មទាំងឡាយនោះ ចាកទុគ្គតិ មានប្រការដូចបានពោលហើយ ក្នុងបទនេះថា ភពខាងមុខក៏នឹងជាទុគ្គតិ ឬចាកការនិន្ទា មានប្រការដូចពោលហើយ ក្នុងបទថា គប្បីត្រូវតិះដៀលក្នុងបច្ចុប្បន្ននោះឯង ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងភាពដែលព្រាហ្មណ៍ទាំងឡាយកើតក្នុងត្រកូលស្វាធ្យាយមន្ត ក៏គង់ថោកទាបក្នុងបច្ចុប្បន្ននោះឯង ដោយអំណាចនៃកម្ម មានការត្រូវតិះដៀលជាដើម កាលទ្រង់សម្តែងការមិនមាននៃជាតិ-ព្រាហ្មណ៍ក្នុងភពខាងមុខ ដោយការដល់នូវទុគ្គតិ ទ្រង់ញ៉ាំងអត្ថនេះថា មិន

មែនជាព្រាហ្មណ៍ព្រោះជាតិទេ ជាព្រាហ្មណ៍ ក៏ព្រោះកម្ម ដូច្នេះ ឲ្យសម្រេច យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សមោធានអត្ថទាំងពីរ ទើបត្រាស់ថា

បុគ្គលមិនមែនថោកទាប ព្រោះជាតិ មិនមែនជាព្រាហ្មណ៍ ព្រោះជាតិទេ បុគ្គលថោកទាប ព្រោះកម្ម ជាព្រាហ្មណ៍ ក៏ព្រោះកម្មដែរ ។

[ ១៤ ] បទដ៏សេស មានន័យដូចពោលហើយ ក្នុងកសិភារទ្វាជ-សូត្រនោះឯង ឬដោយពិសេស គប្បីជ្រាបការប្រកបយ៉ាងនេះនៃបទទាំង-ឡាយថា **និក្កុជ្ជិតំ វា** ក្នុងគាថានេះថា

ព្រះគោតម ទ្រង់លើកខ្ញុំព្រះអង្គដែលបែរខ្នងឲ្យកម្ម ជាអ្នកធ្លាក់ក្នុងជាតិវាទ ឡើងអំពីទិដ្ឋិថា ជាតិជាហេតុឲ្យបុគ្គលជាព្រាហ្មណ៍ និងជាបុគ្គលថោកទាប ដូចបុគ្គលផ្ងារបស់ដែលផ្កាប់ ដូច្នោះ ទ្រង់បើកកម្មវាទដែលជាតិវាទបិទបាំង ដូចបុគ្គលបើកវត្ថុដែលបិទ ដូច្នោះ ទ្រង់ប្រាប់ផ្លូវត្រង់ដែលមិនលាយឡំដោយភាពដែលជាតិជាហេតុឲ្យជាព្រាហ្មណ៍ និងឲ្យជាបុគ្គលថោកទាប ដូចបុគ្គលប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ដូច្នោះ ទ្រង់ប្រកាសធម៌ហើយដោយអំណាចអនេកបរិយាយ ព្រោះជាធម៌ដែលទ្រង់ប្រកាសហើយ ដោយបរិយាយទាំងនោះដល់ខ្ញុំព្រះអង្គដោយត្រង់ រមែងបំភ្លឺក្នុងការលើករឿងមាតង្គៈជាដើម មកជាឧទាហរណ៍ ដូចបុគ្គលអុជប្រទីបក្នុងទីងងឹតដូច្នោះ ៕ល៚

**អដ្ឋកថា វសលសូត្រ ចប់**

# សុត្តន្តបិដក

## មេត្តសូត្រទី ៨

[ ១៥ ] កិច្ចណាដែលអរិយបុគ្គល បានត្រាស់ដឹងនូវចំណែកនៃធម៌ ដ៏ស្ងប់រម្ងាប់ គឺព្រះនិព្វាន ( បានធ្វើហើយ ) កិច្ចនោះ កុលបុត្តអ្នកឈ្លាសក្នុងប្រយោជន៍គួរធ្វើ ( កុលបុត្តនោះ ) គួរជាអ្នកអាចហ៊ានផង មានកាយវាចាត្រង់ផង មានចិត្តត្រង់ល្អផង ជាបុគ្គលប្រដៅងាយផង មានសភាពទន់ភ្លន់ផង មិនមានមានះដ៏ក្រៃលែងផង ។ ជាអ្នកសន្តោសផង គេចិញ្ចឹមងាយផង មិនមានកិច្ចកង្វល់ផង ប្រព្រឹត្តស្រាលព្រមផង មានឥន្ទ្រិយស្ងប់ផង មានប្រាជ្ញាចាស់ផង មិនច្នាំច្នងផង មិនជាប់ជំពាក់ក្នុងត្រកូលទាំងឡាយផង ។ វិញ្ញូជនទាំងឡាយ គប្បីតិះដៀលនូវជនទាំងឡាយដទៃ ដោយកម្មណា មិនគួរប្រព្រឹត្តធ្វើនូវកម្មនោះ ដែលជាកម្មលាមក សូម្បីតិចតួច ( ហើយគប្បីផ្សាយមេត្តាចិត្ត ចំពោះពួកសត្វថា ) សូមឲ្យពួកសត្វទាំងពួង មានសេចក្តីសុខ មានសេចក្តីក្សេមក្សាន្ត មានខ្លួនដល់នូវសេចក្តីសុខចុះ ពួកសត្វដែលមានជីវិត ឥតមានសេសសល់ ទោះសត្វជាអ្នកមានសេចក្តីតក់ស្លុត គឺនៅមានតណ្ហាក្តី ជាអ្នកមាំមួន គឺឥតមានតណ្ហាក្តី ពួកសត្វដែលមានកាយវែងក្តី ធំក្តី មានកាយយ៉ាងកណ្តាលក្តី ខ្លីក្តី ស្គមក្តី ធាត់ក្តី ពួកសត្វដែល

យើងឃើញក្តី មិនឃើញក្តី ពួកសត្វដែលនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី កើតរួចហើយក្តី កំពុងស្វែងរកកំណើតក្តី សូមឲ្យសត្វទាំងអស់ ( នោះ ) មានខ្លួនដល់នូវសេចក្តីសុខចុះ ។ សត្វដទៃមិនគួរកំហែងបៀតបៀនសត្វដទៃឡើយ មិនគួរមើលងាយគេតិចតួច ក្នុងទីណាមួយឡើយ មិនគួរប្រាថ្នានូវសេចក្តីទុក្ខ ដល់គ្នានិងគ្នា ដោយសេចក្តីក្រេវក្រោធ ដោយសេចក្តីចង្អៀតចង្អល់ចិត្តឡើយ ។ មាតាថ្នមរក្សាបុត្ត ដែលកើតអំពីខ្លួន ជាបុត្រតែមួយដោយអាយុ គឺថា សូម្បីជីវិតក៏ហ៊ានលះបង់ ក្នុងការរក្សានូវបុត្តបាន យ៉ាងណាមិញ បុគ្គលគួរចម្រើនមេត្តាចិត្ត មិនមានប្រមាណ ចំពោះពួកសត្វទាំងពួង ក៏យ៉ាងនោះឯង ។ បុគ្គលគួរចម្រើនមេត្តាចិត្ត មិនមានប្រមាណ ជាធម៌មិនចង្អៀត មិនមានពៀរ មិនមានសត្រូវ ទៅក្នុងលោកទាំងអស់ ទាំងខាងលើខាងក្រោម ទាំងទទឹង គឺត្រង់កណ្តាលផង ( បុគ្គលអ្នកចម្រើនមេត្តាចិត្តនោះ ) ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ជាអ្នកមានសេចក្តីងោកងក់ទៅប្រាសហើយ គឺជាអ្នកមិនដេកលក់អស់កាលត្រឹមណា គួរតម្កល់នូវមេត្តានុស្សតិនុ៎ះ ( អស់កាលត្រឹមនោះ ) ។ បណ្ឌិតទាំងឡាយ ពោលនូវជំណើរនុ៎ះ ថាជាព្រហ្មវិហារ ក្នុងសាសនានេះ ។ ( បុគ្គលដែលមានមេត្តាព្រហ្មវិហារ )

មិនអាស្រ័យនូវទិដ្ឋិ ជាអ្នកមានសីល ប្រកបដោយទស្សន-សម្បត្តិ គឺសោតាបត្តិមគ្គ បន្ទោបង់នូវសេចក្តីត្រេកអរក្នុងកាមទាំងឡាយ ដោយសកទាគាមិមគ្គ និងអនាគាមិមគ្គ រមែងមិនមកកាន់គព្ភសេយ្យាសន៍ គឺថា មិនមកកើតក្នុងគភ៌ទៀតឡើយ ។

មេត្តសូត្រទី ៨ ចប់

# អដ្ឋកថា

## មេត្តសូត្រ

[ ១៥ ] មេត្តសូត្រ មានពាក្យផ្តើមដោយគាថា **ករណីយ មត្ថកុសលេន** ដូច្នេះ សូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។ បានឮថា ភិក្ខុទាំងឡាយត្រូវទេវតាទាំងឡាយ ដែលនៅក្បែរភ្នំហិមពាន្ត ធ្វើកលឲ្យខ្លាចហើយមកកាន់នគរសាវត្ថី ចូលកាន់សម្នាក់របស់ព្រះដ៏មានព្រះភាគ ព្រះសាស្តាទ្រង់បានត្រាស់សូត្រនេះ ដើម្បីប្រយោជន៍ការពារ និងដើម្បីជាប្រយោជន៍ដល់កម្មដ្ឋាន ដល់ភិក្ខុទាំងនោះសេចក្តីសង្ខេប មានប្រមាណប៉ុណ្ណោះសិន ចំណែកសេចក្តីពិស្តារ មានដូចតទៅនេះ

សម័យមួយ ព្រះដ៏មានព្រះភាគ កាលថ្ងៃចូលវស្សាខិតចូលមកដល់ទ្រង់គង់ក្នុងនគរសាវត្ថី ។ សម័យនោះ ភិក្ខុអ្នកនគរផ្សេងៗ ជាច្រើន រៀននូវ

កម្មដ្ឋានក្នុងសម្នាក់របស់ព្រះដ៏មានព្រះភាគហើយ មានបំណងដើម្បីចាំវស្សាក្នុងទីនោះៗ ទើបចូលទៅគាល់ព្រះដ៏មានព្រះភាគ បានឮថា ក្នុងទីនោះ ព្រះដ៏មានព្រះភាគត្រាស់កម្មដ្ឋាន ដែលអនុគ្រោះដល់ចរិតចំនួន ៨៤០០០ ប្រភេទ ដោយន័យនេះ គឺអសុភកម្មដ្ឋាន ១១ យ៉ាង ដោយអំណាចសវិញ្ញាណកៈ និងអវិញ្ញាណកៈ សម្រាប់បុគ្គលដែលជារាគចរិតទាំងឡាយ កម្មដ្ឋាន មានមេត្តាជាដើម ៤ យ៉ាង សម្រាប់បុគ្គលទោសចរិតទាំងឡាយ កម្មដ្ឋានទាំងឡាយមានមរណានុស្សតិកម្មដ្ឋានជាដើម សម្រាប់បុគ្គលមោហចរិតទាំងឡាយ កម្មដ្ឋានទាំងឡាយ មានអនាបានស្សតិ និងបឋវីកសិណជាដើម សម្រាប់បុគ្គលវិតក្ក-ចរិតទាំងឡាយ កម្មដ្ឋានទាំងឡាយ មានពុទ្ធានុស្សតិកម្មដ្ឋានជាដើម សម្រាប់បុគ្គលសទ្ធាចរិតទាំងឡាយ កម្មដ្ឋាន មានចតុធាតុវវដ្ឋានជាដើម សម្រាប់បុគ្គលដែលជាពុទ្ធិចរិតទាំងឡាយ ។

កាលនោះ ភិក្ខុប្រមាណ ៥០០ រូប រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះដ៏មានព្រះភាគហើយ ស្វែងរកសេនាសនៈដែលជាទីសប្បាយ និងគោចរគាមបានឃើញភ្នំមួយ ដែលជាប់គ្នានឹងភ្នំហិមពាន្ត ត្រង់ចុងដែនដោយលំដាប់មានផ្ទាំងថ្មដេរដាសដោយកែវផលិក និងកែវមណីពណ៌ខៀវ ប្រដាប់ដោយដងព្រៃខៀវស្រងាត់ មានម្លប់ក្រាស់ត្រជាក់ មានផ្ទៃដីក្រាលដោយខ្សាច់ ដូចគ្នានឹងកម្រងកែវមុក្តា និងបន្ទះប្រាក់ ព័ទ្ធដោយជលាល័យដ៏ស្អាត សាបត្រជាក់ល្អ ។ លំដាប់នោះឯង ភិក្ខុទាំងនោះ បានស្នាក់នៅត្រង់ភ្នំនោះមួយយប់

កាលរាត្រីអស់ហើយ ធ្វើបរិកម្មសរីរៈស្រេច ចូលទៅបិណ្ឌបាតត្រង់ស្រុកមួយ ដែលមិនឆ្ងាយអំពីភ្នំនោះ ស្រុកនោះប្រកបដោយត្រកូល ចូលទៅកាន់ផ្ទះដែលកុះករ ប្រមាណ ១ ពាន់ត្រកូល ។

ក្នុងស្រុកនោះ មនុស្សទាំងឡាយ មានសទ្ធាជ្រះថ្លា លុះឃើញភិក្ខុទាំងនោះក៏កើតបីតិ និងសោមនស្ស ព្រោះការឃើញបព្វជិតក្នុងបច្ចន្តជនបទ រកបានដោយកម្រ ញុំាងភិក្ខុទាំងនោះឲ្យឆាន់ហើយ សាកសួរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយនៅក្នុងស្រុកនេះឯងអស់កាល ៣ ខែ កាលអារាធនាហើយ ក៏ធ្វើកុដិសម្រាប់ប្រារព្ធព្យាយាម ៥០០ រៀបចំគ្រឿងឧបករណ៍គ្រប់យ៉ាង មានគ្រែ តាំង ឆ្នាំងទឹកផឹក ទឹកប្រើប្រាស់ជាដើម ទុកក្នុងកុដិនោះ ក្នុងថ្ងៃទី ២ ភិក្ខុទាំងឡាយចូលទៅកាន់ស្រុកដទៃដើម្បីបិណ្ឌបាត មនុស្សទាំងឡាយក្នុងស្រុកនោះ ក៏ទំនុកបម្រុងយ៉ាងនោះ អារាធនាឲ្យនៅចាំវស្សា ភិក្ខុទាំងឡាយឃើញថា មិនមានអន្តរាយ ទើបទទួលនិមន្ត ចូលទៅកាន់ដងព្រៃនោះ ប្រារព្ធសេចក្តីព្យាយាមអស់យប់ និងថ្ងៃទាំងពួង វាយជួងប្រាប់យាម ជាអ្នកច្រើនទៅដោយយោនិសោមនសិការ អង្គុយអាស្រ័យគល់ឈើ ។

រុក្ខទេវតាទាំងឡាយប្រាសចាកតេជះ ព្រោះតេជះរបស់ភិក្ខុអ្នកមានសីលទាំងឡាយ ចុះអំពីវិមានរៀងៗ ខ្លួន ហើយនាំកូនទាំងឡាយ ត្រាច់ទៅក្នុងទីផ្សេងៗ ដូចកាលឱកាសក្នុងផ្ទះរបស់អ្នកស្រុកទាំងឡាយ ត្រូវព្រះរាជា ឬមហាមាត្យរបស់ព្រះរាជាគ្រប់គ្រងហើយ អ្នកស្រុកទាំងឡាយ ចេញអំពីផ្ទះ

ទៅក្នុងទីដទៃចាំមើលអំពីចម្ងាយថា កាលណាហ្ន៎ ព្រះរាជានឹងទៅ យ៉ាងណា ទេវតាទាំងឡាយក៏ដូច្នោះ លះបង់វិមានរៀងៗ ខ្លួនត្រាច់ទៅក្នុងទីផ្សេងៗ សម្លឹងមើលអំពីចម្ងាយថា កាលណាហ្ន៎ លោកម្ចាស់ទាំងឡាយនឹងទៅ បន្ទាប់អំពីនោះ ក៏គិតយ៉ាងនេះថា ភិក្ខុទាំងឡាយចាំវស្សាអស់ ៣ ខែពិត ពួកយើងមិនអាចនាំកូនទាំងឡាយចុះមកយូរដល់ម៉្លេះ ណ្ហើយចុះ ពួកយើងនឹងបង្ហាញអា-រម្មណ៍ដែលគួរខ្លាចដល់ភិក្ខុទាំងឡាយ ទេវតាទាំងនោះ បានទិម្មិតរូបយក្ខទាំងឡាយដ៏គួរខ្លាច ក្នុងកាលភិក្ខុទាំងឡាយធ្វើសមណធម៌ក្នុងរាត្រី ឈរនៅខាងមុខ និងស្រែកដោយសំឡេងគួរខ្លាច ។

កាលភិក្ខុទាំងឡាយកំពុងឃើញនូវរូបទាំងនោះ និងស្តាប់សំឡេងទាំងនោះ ហទយៈក៏ញាប់ញ័រ ហើយភិក្ខុទាំងឡាយ ក៏មានពណ៌សម្បុរសៅហ្មង កើតរោគស្គមលឿង ដោយហេតុនោះ ទើបភិក្ខុទាំងនោះមិនអាចធ្វើចិត្តឲ្យជាឯកគ្គតាបាន កាលភិក្ខុទាំងនោះមានចិត្តមិនមានអារម្មណ៍តែមួយ និងតក់ស្លុតរឿយៗ ព្រោះខ្លាចអារម្មណ៍នោះ ក៏មិនមានស្មារតី បន្ទាប់អំពីនោះ ទេវតាទាំងឡាយ ក៏ប្រកបអារម្មណ៍ទាំងឡាយ មានក្លិនស្អុយជាដើមដល់ភិក្ខុដែលមិនមានស្មារតីទាំងនោះ ខួរក្បាលរបស់ភិក្ខុទាំងនោះ ហាក់ដូចជាត្រូវគ្របសង្កត់ដោយក្លិនស្អុយនោះ វេទនាក្នុងក្បាលដ៏ខ្លាំងក្លា បានកើតឡើងហើយ ភិក្ខុទាំងឡាយ មិនប្រាប់ព្រឹត្តិការណ៍នោះដល់គ្នានិងគ្នាឡើយ ។

ថ្ងៃមួយ កាលភិក្ខុទាំងឡាយប្រជុំគ្នា ក្នុងពេលបម្រើព្រះថេរៈ ព្រះសង្ឃត្ថេរក៏ពោលថា អាវុសោទាំងឡាយ កាលពួកលោកចូលកាន់ដងព្រៃនេះ ត្រឹមតែថ្ងៃបន្តិចបន្តួច ពណ៌សម្បុរក៏បរិសុទ្ធក្រៃលែង សស្អាត ហើយឥន្ទ្រិយទាំងឡាយ ក៏ថ្លូវផង់ តែឥឡូវនេះ លោកទាំងឡាយក៏ស្គាំងស្គម ពណ៌សម្បុរក៏សៅហ្មង កើតនូវរោគស្គមលឿង ក្នុងព្រៃនេះ លោកទាំងឡាយមានសេចក្តីមិនសប្បាយដូចម្តេចឬ បន្ទាប់អំពីនោះ ភិក្ខុមួយរូបពោលថា បពិត្រលោកម្ចាស់ ក្នុងពេលយប់ ខ្ញុំឃើញ និងស្តាប់អារម្មណ៍ដែលគួរខ្លាច យ៉ាងនេះមួយ យ៉ាងនេះមួយ និងធំនូវក្លិនយ៉ាងនេះ ដោយហេតុនោះ ទើបចិត្តរបស់ខ្ញុំមិនតាំងមាំ ភិក្ខុទាំងអស់ ក៏ប្រាប់ព្រឹត្តិការណ៍នោះ ដោយឧបាយនោះដូចគ្នា ព្រះសង្ឃត្ថេរពោលថា អាវុសោទាំងឡាយ ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតការចាំវស្សាពីរជង ឯសេនាសនៈនេះរបស់ពួកយើង មិនជាទីសប្បាយមកអាវុសោ ពួកយើងទៅកាន់សម្នាក់របស់ព្រះដ៏មានព្រះភាគ ហើយទូលសួរសេនាសនៈដទៃដែលជាទីសប្បាយ ភិក្ខុទាំងនោះទទួលថា សាធុ ហើយទុកដាក់សេនាសនៈ កាន់បាត្រ និងចីវរ មិនលាអ្នកស្រុកក្នុងត្រកូលទាំងឡាយ ព្រោះជាអ្នកមិនប្រឡូកប្រឡំ ចារិកទៅកាន់ក្រុងសាវត្ថី ។ ភិក្ខុទាំងនោះ ទៅកាន់ក្រុងសាវត្ថីដោយលំដាប់ ហើយទៅកាន់សម្នាក់របស់ព្រះមានព្រះភាគ ។

ព្រះដ៏មានព្រះភាគទ្រង់ឃើញភិក្ខុនោះហើយ ទើបត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតបានបញ្ញត្តសិក្ខាបទថា ភិក្ខុមិនគប្បីត្រាច់ចារិកខាងក្នុងវស្សាហើយ អ្នកទាំងឡាយត្រាច់ចារិកដើម្បីអ្វី ភិក្ខុទាំងនោះទូលរឿង

ទាំងអស់ដល់ព្រះដ៏មានព្រះភាគៗ ទ្រង់ពិចារណា ក៏ទ្រង់មិនឃើញសេនាសនៈដែលជាទីសប្បាយសម្រាប់ភិក្ខុទាំងនោះ ដោយហោច សូម្បីត្រឹមតែទីដែលដាក់តាំងជើង ៤ ក្នុងជម្ពូទ្វីបទាំងមូល កាលទ្រង់ពិចារណាហើយ ទើបត្រាស់នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ សេនាសនៈដែលជាទីសប្បាយរបស់ពួកអ្នកមិនមាន ចូរពួកអ្នកនៅក្នុងទីនោះឯង គប្បីអស់ទៅនៃអាសវៈបាន ទៅចុះភិក្ខុទាំងឡាយ ចូរពួកអ្នកអាស្រ័យសេនាសនៈនោះចុះ បើពួកអ្នកប្រាថ្នាការមិនមានភ័យដល់ទេវតាទាំងឡាយ ចូររៀនព្រះបរិត្តនេះ ព្រោះបរិត្តនេះជាគ្រឿងការពារ និងជាកម្មដ្ឋានរបស់ពួកអ្នក ដូច្នេះហើយ ទើបត្រាស់ព្រះសូត្រនេះ ។

អាចារ្យដទៃពោលថា ព្រះដ៏មានព្រះភាគកាលត្រាស់ដូច្នេះថា ទៅចុះភិក្ខុទាំងឡាយ ចូរពួកអ្នកអាស្រ័យសេនាសនៈនោះឯង ទើបត្រាស់ថា ភិក្ខុនៅព្រៃ គប្បីជ្រាបការឃុំគ្រង គឺមេត្តា ២ បរិត្ត ២ អសុភ ២ មរណស្សតិ ២ និងការពិចារណាមហាសង្វេគវត្ថុ ៨ គឺជាតិ ជរា ព្យាធិ មរណៈ និងអបាយទុក្ខ ៤ ឈ្មោះថា មហាសង្វេគវត្ថុ ៨ ដោយអំណាចធ្វើក្នុងពេលល្ងាច និងពេលព្រឹក ។ គប្បីជ្រាបមហាសង្វេគវត្ថុ ៨ គឺជាតិ ជរា ព្យាធិ មរណៈ ជាគម្រប់ ៤ អបាយទុក្ខជាគម្រប់ ៥ ទុក្ខ មានវដ្តៈជាមូលក្នុងអតីត ១ ទុក្ខមានវដ្តៈជាមូលក្នុងអនាគត ១ ទុក្ខ មានការស្វែងរកអាហារជាមូលក្នុងបច្ចុប្បន្ន ១ ព្រះដ៏មានព្រះភាគ កាលត្រាស់ប្រាប់ការរក្សាយ៉ាងនេះហើយ

ទើបត្រាស់ព្រះសូត្រនេះដល់ភិក្ខុទាំងនោះ ដើម្បីមេត្តា ដើម្បីការពារ និង ដើម្បីឈាន ដែលមានវិបស្សនាជាបាទ ដូច្នេះ ។

ក្នុងគាថាទាំងនោះ គាថាទី ១ ថា **ករណីយមត្ថកុសលេន** មាន ពណ៌នាតាមបទយ៉ាងនេះមុន ។ បទថា **ករណីយំ** បានដល់ ប្រយោជន៍ដែល គួរធ្វើ អធិប្បាយថា គួរដល់ការធ្វើ ។ បដិបទា ឈ្មោះថា ប្រយោជន៍ ឬ ប្រយោជន៍របស់ខ្លួនឯណានីមួយ ទាំងអស់នោះ ហៅថា ប្រយោជន៍ ព្រោះ ជាប្រយោជន៍ដែលកុលបុត្រគប្បីចូលដល់ ឈ្មោះថា ព្រោះជាប្រយោជន៍ ដែលកុលបុត្រគួរបានទទួល ។ បុគ្គលឈ្លាសក្នុងប្រយោជន៍ ឈ្មោះថា **អត្ថកុសល** អធិប្បាយថា អ្នកឈ្លាសក្នុងប្រយោជន៍ ។

បទថា **យំ** ជាបឋមាវិភត្តិ អនិយមសព្វនាម ។ បទថា **តំ** ជាទុតិយា-វិភត្តិ និយមសព្វនាម ។ ឬបទថា **យន្តំ** ទាំងពីរ ក៏ជាបឋមាវិភត្តិ ។ បទថា **សន្តំ បទំ** ជាទុតិយាវិភត្តិ ។ ក្នុងបទទាំងពីរនោះ ឈ្មោះថា **សន្តំ** ក៏ព្រោះ ដោយលក្ខណៈ ឈ្មោះថា **បទំ** ព្រោះជាធម៌ដែលកុលបុត្តគប្បីដល់ ។ បទ ថា **សន្តំ បទំ** នោះ ជាឈ្មោះរបស់ព្រះនិព្វាន ។ បទថា **អភិសមេច្ច** បាន ដល់ ប្រាថ្នា ឈ្មោះថា **សក្កោ** ព្រោះអត្ថវិគ្គហៈថា អាចហ៊ាន អធិប្បាយថា ជាអ្នកអាច ជាអ្នកមានសមត្ថភាព ។

បទថា **ឧជូ** បានដល់ ប្រកបដោយការស្មោះត្រង់ ។ ឈ្មោះថា **សុហុជុ** ព្រោះអត្ថថា ស្មោះត្រង់ដោយល្អ ។ ឈ្មោះថា **សុវចោ** ព្រោះអត្ថថា ប្រដៅ

ងាយ ។ បទថា **អសុប្បូ** ប្រែថា គប្បីជា ។ បទថា **មុទុ** បានដល់ ជាអ្នកប្រកបដោយការទន់ភ្លន់ ។ បុគ្គលមិនលើកតម្កើងខ្លួន ឈ្មោះថា **អនតិមានី ។**

ក្នុងគាថានេះ មានកិច្ចពណ៌នាអត្ថយ៉ាងនេះថា ក្នុងបាទគាថានេះថា **ករណីយមត្ថកុសលេន យន្តំ សន្តំ បទំ អភិសមេច្ច** កិច្ចដែលគួរធ្វើក៏មាន កិច្ចដែលមិនគួរធ្វើក៏មាន ក្នុងកិច្ច ២ យ៉ាងនោះ ដោយសង្ខេប សិក្ខា ៣ ជាកិច្ចដែលគួរធ្វើ កិច្ច មានជាដើមយ៉ាងនេះថា សីលវិបត្តិ ទិដ្ឋិវិបត្តិ អាចារ-វិបត្តិ អាជីវវិបត្តិ ជាកិច្ចមិនគួរធ្វើ ។ មួយ៉ាងទៀត កុលបុត្តអ្នកឈ្លាសក្នុងប្រយោជន៍ក៏មាន កុលបុត្តដែលឈ្លាសក្នុងវត្ថុមិនជាប្រយោជន៍ក៏មាន ក្នុងកុលបុត្តពីរពួកនោះ កុលបុត្តណា បួសក្នុងសាសនានេះហើយ មិនប្រកបខ្លួនដោយប្រពៃ ជាអ្នកមានសីលដាច់ សម្រេចការចិញ្ចឹមជីវិតដោយអាស្រ័យអនេសនៈ ២១ យ៉ាង គឺឲ្យឫស្សី ឲ្យស្លឹក ឲ្យផ្កា ឲ្យផ្លែឈើ ឲ្យឈើស្ទន់ ឲ្យទឹកលុបមុខ ឲ្យគ្រឿងងូត ឲ្យលម្អិត ឲ្យដីស្អិត ពោលកៀគរដើម្បីឲ្យគេស្រឡាញ់ ពោលលាយលេងលាយមែន ដូចសម្ដៅសណ្ដែកបាយ ភាពជាបុគ្គលទទួលចិញ្ចឹមក្មេង ទទួលបម្រើគ្រហស្ថ ធ្វើវេជ្ជកម្ម ធ្វើទូតកម្ម ការទៅដូចបុគ្គលថោកថយ ការឲ្យលាភដើម្បីទាក់លាភ ការទស្សន៍ទាយទឹកដី ទស្សន៍ទាយនក្ខត្តឫក្ស ទស្សន៍ទាយអវយវៈ និងត្រាច់ទៅក្នុងអគោចរ ៦ យ៉ាង គឺទីស្រីពេស្យា ស្រីមេម៉ាយ ក្រមុំចាស់ ខ្ទើយ ភិក្ខុនី រានស្រា និងនៅប្រឡូកប្រឡំដោយព្រះរាជា អមាត្យរបស់ព្រះរាជា តិរ្ថិយ ប្រឡូកប្រឡំដោយ

គ្រហស្ថមិនសមគួរ ឬរមែងសេពគប់ ចូលទៅរកត្រកូលទាំងឡាយដែលមិនមានសទ្ធា មិនជ្រះថ្លា ជេរ បរិភាស ប្រាថ្នានូវការវិនាស ប្រាថ្នាចំពោះវត្ថុដែលមិនជាប្រយោជន៍ មិនផាសុក និងមិនក្សេមចាកយោគដល់ភិក្ខុទាំងឡាយ ។បេ។ ឧបាសិកាទាំងឡាយ កុលបុត្តនេះ ឈ្មោះថា ជាអ្នកឈ្លាសក្នុងវត្ថុដែលមិនជាប្រយោជន៍ ។

ចំណែកកុលបុត្តណាបួសក្នុងសាសនានេះហើយ ប្រកបខ្លួនដោយប្រពៃលះអានេសនៈ ជាអ្នកប្រាថ្នាដើម្បីតាំងនៅក្នុងចតុប្បារិសុទ្ធិសីល បំពេញនូវបាតិមោក្ខសំវរៈដោយសទ្ធាជាគោល បំពេញនូវឥន្ទ្រិយសំវរៈ ដោយសតិជាគោល បំពេញនូវអាជីវបារិសុទ្ធិ ដោយវីរិយៈជាគោល បំពេញនូវបច្ចយ-ប្បដិសេវនា ដោយបញ្ញាជាគោល កុលបុត្តនេះ ឈ្មោះថា ជាអ្នកឈ្លាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត កុលបុត្តណា ជម្រះបាតិមោក្ខសំវរៈ ដោយអំណាចនៃការជម្រះអាបត្តិ ៧ កង ឥន្ទ្រិយសំវរៈ ដោយអំណាចការមិនកើតឡើងនៃឧប-ក្កិលេសទាំងឡាយ មានអភិជ្ឈាជាដើម ក្នុងអារម្មណ៍ដែលមកប៉ះខ្ទប់ក្នុងទ្វារទាំង ៦ ជម្រះអាជីវបារិសុទ្ធិ ដោយការគប់រកព្រះសម្ពុទ្ធ អនុពុទ្ធសាវ័ក និងបុរសដែលជាបណ្ឌិត ដែលអ្នកប្រាជ្ញសរសើរហើយ ដោយការវៀរចាកនូវអនេសនៈ ជម្រះនូវបច្ចយប្បដិសេវនៈ ដោយអំណាចនៃការពិចារណាតាមដែលពោលហើយ និងជម្រះសម្បជញ្ញៈ ដោយអំណាចនៃការពិចារណាវត្ថុ

ដែលមានប្រយោជន៍ជាដើម ក្នុងការប្តូរឥរិយាបថទាំង ៤ កុលបុត្តនេះ ឈ្មោះថា ជាអ្នកឈ្លាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត កុលបុត្តណា ដឹងថា សីលបរិសុទ្ធបាន ព្រោះអាស្រ័យញាណ ដូចសំពត់ស្មោកគ្រោក រមែងស្អាតបានព្រោះអាស្រ័យទឹកស្អាត កញ្ចក់ផ្ទូរផង់បាន ព្រោះអាស្រ័យផេះ មាសបរិសុទ្ធបាន ព្រោះអាស្រ័យស្នប់ដូច្នោះ លាងដោយទឹក គឺញាណ ឈ្មោះថា ញ៉ាំងសីលឲ្យបរិសុទ្ធ និងជាអ្នកមិនប្រមាទ រមែងរក្សាសីលក្ខន្ធរបស់ខ្លួន ដូចសត្វត្រដេវវិចរក្សាស៊ុត មេចាមរីរក្សារោមកន្ទុយ ស្ត្រីមានកូនតែមួយ រក្សាកូនជាទីស្រឡាញ់ និងបុរសមានភ្នែកម្ខាង រក្សាភ្នែកម្ខាងដូច្នោះ ពិចារណាទាំងពេលល្ងាច ទាំងពេលព្រឹក រមែងមិនឃើញទោសមានប្រមាណតិច កុលបុត្តនេះ ឈ្មោះថា ជាអ្នកឈ្លាសក្នុងប្រយោជន៍ ។

កុលបុត្តណាតាំងនៅក្នុងសីល ជាគ្រឿងធ្វើមិនឲ្យក្តៅក្រហាយ ផ្គងនូវបដិបទា ជាគ្រឿងសង្កត់នូវកិលេស កាលផ្គងបដិបទានោះហើយ រមែងធ្វើកសិណបរិកម្ម កាលធ្វើកសិណបរិកម្មហើយ រមែងញ៉ាំងសមាបត្តិទាំងឡាយឲ្យកើត កុលបុត្រនេះ ឈ្មោះថា ជាអ្នកឈ្លាសក្នុងប្រយោជន៍ ។

កុលបុត្តណា ចេញចាកសមាបត្តិ ពិចារណាសង្ខារទាំងឡាយហើយសម្រេចអរហត្ត កុលបុត្តនេះ ជាបុគ្គលក្រៃលែង នៃកុលបុត្តអ្នកឈ្លាសក្នុងប្រយោជន៍ទាំងឡាយ ។

ក្នុងគាថានោះ ភិក្ខុទាំងនេះជាអ្នកឈ្លាសក្នុងប្រយោជន៍ ដែលពណ៌នាហើយ តាំងអំពីការតាំងនៅក្នុងសីល ជាគ្រឿងធ្វើមិនឲ្យក្តៅក្រហាយ ឬតាំងអំពីការផ្គងបដិបទា ជាគ្រឿងសង្កត់សង្កិននូវកិលេស ភិក្ខុទាំងនោះ លោកបំណងថា ជាអ្នកឈ្លាសក្នុងប្រយោជន៍ ក្នុងអត្ថនេះ ភិក្ខុទាំងនោះ ក៏យ៉ាងនោះ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់សំដៅដល់ភិក្ខុទាំងនោះ ត្រាស់ដោយទេសនាដែលមានបុគ្គលម្នាក់ជាទីតាំងថា **ករណីយមត្ថកុស-លេន**។បន្ទាប់អំពីនោះ ទើបត្រាស់ថា **យន្តំ សន្តំ បទំ អភិសមេច្ច** ដល់ភិក្ខុទាំងនោះ ដែលកើតសេចក្តីសង្ស័យថា គប្បីបំពេញដូចម្តេច មានអធិប្បាយដូច្នេះថា បទណាដែលកុលបុត្រត្រូវការសម្រេចដោយអំណាចការចាក់ធ្លុះ គួរធ្វើ បទនោះ គឺនិព្វានដ៏ស្ងប់ ដែលព្រះពុទ្ធ និងព្រះអនុពុទ្ធទាំងឡាយសរសើរហើយ ។

ក្នុងគាថានោះ បទដែលពោលហើយ តាំងអំពីដើមនៃគាថាបទនេះថា **យំ** រមែងអនុលោមតាមអធិការថា **ករណីយំ** ។

បទថា **តំ សន្តំ បទំ អភិសមេច្ច** គប្បីជ្រាបថា អត្ថនេះ មានបាលីមិនគ្រប់ ព្រោះដូច្នោះ ទើបពោលថា **វិហរិតុកាមេន** បុគ្គលត្រូវការដើម្បី...នៅ ។

ម្យ៉ាងទៀត ក្នុងបទថា **សន្តំ បទំ អភិសមេច្ច** នេះ គប្បីជ្រាបអធិប្បាយយ៉ាងនេះថា កុលបុត្តអ្នកឈ្លាសក្នុងប្រយោជន៍ ដឹងនូវបទនិព្វានថា ស្ងប់

ដោយលោកិយប្បញ្ញា ដោយអំណាចនៃការស្តាប់ជាដើម ជាបុគ្គលប្រាថ្នា ដើម្បីសម្រេចបទនិព្វាននោះ គប្បីធ្វើកិច្ចដែលអនុលោមតាមអធិការថា គប្បីបំពេញ ។

ម្យ៉ាងទៀត កាលត្រាស់ថា **ករណីយមត្ថកុសលេន** ទើបត្រាស់ថា **យន្តំ សន្តំ បទំ អភិសមេច្ច** ដល់ភិក្ខុទាំងឡាយដែលគិតថាបំពេញដូចម្តេច ។ អ្នកសិក្សាគប្បីជ្រាបអធិប្បាយបទនោះថា កុលបុត្តត្រាស់ដឹងនូវបទស្ងប់ ដោយលោកិយប្បញ្ញា គប្បីធ្វើប្រយោជន៍ណា គប្បីបំពេញប្រយោជន៍នោះ ។ មានអធិប្បាយថា គប្បីបំពេញប្រយោជន៍ដែលគួរធ្វើ គឺជារបស់គួរធ្វើនោះឯង ។

សួរថា ប្រយោជន៍នោះគឺអ្វី ឆ្លើយថា ក្រៅអំពីឧបាយជាគ្រឿងសម្រេចសន្តិបទនោះ គប្បីមានប្រយោជន៍ដទៃដូចម្តេច សន្តិបទនោះបានពោលហើយដោយបទដើម ដែលសម្តែងដល់ត្រៃសិក្ខា មានអត្ថថា សមគួរដល់ការធ្វើក៏ពិត តែខ្ញុំបានពោលហើយ ក្នុងកិច្ចពណ៌នាអត្ថនៃបទនោះថា ប្រយោជន៍គួរធ្វើក៏មាន ប្រយោជន៍មិនគួរធ្វើក៏មាន ប្រយោជន៍ពីរយ៉ាងនោះ ។ ដោយសង្ខេបត្រៃសិក្ខាជាប្រយោជន៍គួរធ្វើ តែព្រោះទ្រង់សម្តែងដោយសង្ខេប ភិក្ខុទាំងនោះពួកខ្លះក៏ដឹង ពួកខ្លះក៏មិនដឹង បន្ទាប់អំពីនោះ ទ្រង់សម្តែងប្រយោជន៍ដែលភិក្ខុនៅព្រៃជាវត្ត គប្បីធ្វើដោយវិសេស ឲ្យពិស្តារ ដើម្បីឲ្យភិក្ខុដែលមិនទាន់ដឹងបានដឹង ទើបត្រាស់កន្លះគាថានេះថា ជាអ្នកអាចហ៊ានផង មានកាយវាចាត្រង់ផង មានចិត្តត្រង់ល្អផង ជាបុគ្គលប្រដៅងាយផង មានសភាពទន់ភ្លន់

ផង មិនមានមានះដ៏ក្រៃលែងផង ដូច្នេះ ។

សេចក្តីនេះមានអធិប្បាយដូចម្តេច កុលបុត្រដែលនៅព្រៃជាវត្ត បំណាន់នឹងត្រាស់ដឹងសន្តិបទ ឬត្រាស់ដឹងសន្តិបទនោះដោយលោកិយប្បញ្ញា បដិបត្តិដើម្បីសម្រេចសន្តិបទនោះ មិនអាល័យក្នុងកាយ និងជីវិត ដោយការដល់ព្រមដោយសេចក្តីព្យាយាម អង្គទី ២ និងអង្គទី ៤ អាចបដិបត្តិក្នុងការចាក់ធ្លុះសច្ចៈក្នុងកិច្ចទាំងឡាយ មានកសិណបរិកម្ម និងការសមាទានវត្តជាដើម ឯក្នុងកិច្ចទាំងឡាយ មានការអប់បាត្រ និងដេរចីវររបស់ខ្លួនក៏ដូចគ្នា ឯក្នុងកិច្ចដទៃបែបនោះ ដែលជាករណីយកិច្ចតូចធំរបស់សព្រហ្មចារី ក៏គប្បីជាអ្នកអាចហ៊ានជាអ្នកព្យាយាម មិនខ្ជិលច្រអូស ជាអ្នកអាច ។ លុះគប្បីជាអ្នកអាចហ៊ាន ក៏គប្បីជាអ្នកត្រង់ ដោយការដល់ព្រមដោយសេចក្តីព្យាយាមទី ៣ លុះគប្បីជាអ្នកត្រង់ ក៏ត្រូវមិនដល់នូវការពេញចិត្តដោយភាពជាអ្នកត្រង់ម្តង គប្បីជាអ្នកត្រង់ដោយល្អ ដោយការធ្វើមិនធូរថយដរាបដល់អស់ជីវិត ឬជាអ្នកត្រង់ព្រោះមិនអួត ជាអ្នកត្រង់ដោយល្អ ព្រោះជាអ្នកមិនមានមាយា ជាអ្នកត្រង់ដោយការលះនូវការវៀចតាមផ្លូវកាយ និងវាចា ជាបុគ្គលទៀងត្រង់ល្អដោយការលះនូវការវៀចផ្លូវចិត្ត ឬជាអ្នកត្រង់ដោយការមិនបាចសាចនូវគុណដែលមិនមាន ជាបុគ្គលត្រង់ល្អ ដោយការមិនទទួលលាភ ដែលកើតឡើងដោយគុណដែលមិនមាន គប្បីជាអ្នកត្រង់ និងជាអ្នកត្រង់ដោយល្អ ដោយអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈានដោយ សិក្ខា ២ ខាងដើម និងសិក្ខាទី ៣

និងដោយសេចក្ដីព្យាយាម និងការតាំងចិត្តដ៏បរិសុទ្ធ ។

ម្យ៉ាងទៀត គប្បីជាអ្នកត្រង់ និងជាអ្នកត្រង់ដោយល្អតែម្យ៉ាងក៏មិនមែន ក៏ត្រូវជាអ្នកប្រដៅងាយទៀតផង ។ ពិតហើយ បុគ្គលណា ត្រូវគេពោលថា លោកមិនគួរធ្វើវត្ថុនេះ រមែងពោលថា លោកឃើញអ្វី លោកឮអ្វី លោកជាអ្វីនឹងខ្ញុំ ជាឧបជ្ឈាយ៍ ជាអាចារ្យ ជាសម្លាញ់ ជាមិត្តរួមបរិភោគឬ ឬធ្វើឲ្យលំបាកដោយភាពជាអ្នកនៅស្ងៀម ឬទទួលហើយមិនធ្វើតាម បុគ្គលនោះរមែងនៅក្នុងទីឆ្ងាយនៃការសម្រេចគុណវិសេស ។

ចំណែកបុគ្គលណាត្រូវទូន្មាន រមែងពោលថា សាធុលោកម្ចាស់ លោកម្ចាស់ពោលល្អក្រៃលែង ឈ្មោះថា ទោសរបស់ខ្លួន ឃើញបានដោយលំបាក លោកឃើញយ៉ាងនោះហើយ គប្បីអាស្រ័យសេចក្ដីករុណា ពោលជាស់តឿនខ្ញុំទៀត យូរៗ ទើបខ្ញុំបានទទួលឱវាទអំពីសម្នាក់របស់លោក នឹងបដិបត្តិតាមពាក្យប្រៀនប្រដៅបុគ្គលនោះ ជាអ្នកនៅក្នុងទីជិតនៃការសម្រេចគុណវិសេស ។ ព្រោះដូច្នោះ បុគ្គលទទួលពាក្យរបស់អ្នកដទៃហើយធ្វើយ៉ាងនេះ គប្បីជាអ្នកប្រដៅងាយ គប្បីជាអ្នកទន់ភ្លន់ ដូចជាបុគ្គលប្រដៅងាយ ។

បទថា **មុទុ** សេចក្ដីថា កុលបុត្តត្រូវគ្រហស្ថទាំងឡាយ ប្រើក្នុងកិច្ចទាំងឡាយ មានការទៅជាទូត និងការទៅដូចបុគ្គលថោកទាបជាដើម មិនគួរធ្វើនូវការរារែកក្នុងកិច្ចនោះ ត្រូវជាបុគ្គលរឹងប៉ឹង តែគប្បីជាបុគ្គលទន់ភ្លន់ក្នុងបដិបទា និងក្នុងការប្រព្រឹត្តិព្រហ្មចរិយៈទាំងមូល ជាបុគ្គលគួរដល់ការទូន្មាន

ក្នុងកិច្ចនោះៗ ដូចមាសដែលជាងរម្លាយល្អហើយ ដូច្នោះ ។

ម្យ៉ាងទៀត បទថា **មុខ** បានដល់ គប្បីជាអ្នកមិនមានមុខក្រញូវ គឺជាអ្នកមានមុខរីក ចរចាពីរោះ ស្គាល់បដិសណ្ឋារៈ ជាអ្នកចូលជិតបានងាយ ដូចវត្ថុដែលតាំងល្អហើយ ដូច្នោះ កុលបុត្តគប្បីជាអ្នកទន់ភ្លន់តែម្យ៉ាង ក៏មិនមែនគប្បីជាអ្នកមិនមានមានះដ៏ក្រៃលែង គឺមិនមើលងាយអ្នកដទៃទាំងឡាយ ដោយអតិមានះ វត្ថុ មានជាតិ និងគោត្រជាដើម គប្បីជាអ្នកនៅដោយចិត្តស្មើ ដូចក្មេងចណ្ឌាល ដូចព្រះសារីបុត្តត្ថេរ ដូច្នោះ ។

ព្រះដ៏មានព្រះភាគ កាលត្រាស់ប្រយោជន៍ខ្លះ ដែលគួរធ្វើសម្រាប់ភិក្ខុដែលនៅព្រៃជាវត្តដោយពិសេស ជាអ្នកប្រាថ្នាដើម្បីត្រាស់ដឹងនូវសន្តិបទ ឬបដិបត្តិដើម្បីសម្រេចនូវសន្តិបទនោះ យ៉ាងនេះហើយ ទ្រង់បំណងនឹងត្រាស់ប្រយោជន៍ ដែលគួរធ្វើក្រៃលែងជាងនោះទៀត ទើបត្រាស់គាថាទី ២ ថា **សន្តុស្សកោ ច** ដូច្នេះ ។

ក្នុងគាថានោះ កុលបុត្ត ឈ្មោះថាជាអ្នកសន្តោស ព្រោះអត្ថវិគ្គហៈថា ត្រេកអរដោយសន្តោស ១២ យ៉ាង មានប្រភេទដែលពោលហើយ ក្នុងគាថានេះថា **សន្តុដ្ឋី ច កតញ្ញុតា ។** ម្យ៉ាងទៀត កុលបុត្តឈ្មោះថា **តុស្សកោ** ព្រោះអត្ថវិគ្គហៈថា រមែងពេញចិត្ត កុលបុត្តជាអ្នកសន្តោស ព្រោះអត្ថ ( ៣ យ៉ាង ) ថា **សកេន តុស្សកោ** ពេញចិត្តដោយរបស់ខ្លួន ១ **សន្តេន តុស្សកោ** ពេញចិត្តដោយរបស់មាន ១ **សមេន តុស្សកោ** ពេញចិត្តដោយ

របស់ស្មើ ១ ។

ក្នុង ៣ យ៉ាងនោះ បច្ច័យ ៤ ដែលខ្លួនទទួលហើយ លើកឡើងក្នុងមណ្ឌលនៃឧបសម្បទាយ៉ាងនេះថា អាស្រ័យភោជន គឺដុំបាយដែលរកបានមកដោយកម្លាំងស្មង ឈ្មោះថា របស់ខ្លួន កុលបុត្តមិនសម្តែងអាការខុសប្លែកក្នុងពេលទទួល និងពេលបរិភោគ ជាអ្នកនៅដោយបច្ច័យ ៤ នោះ ល្អក្តីមិនល្អក្តី ដែលគេឲ្យដោយគោរព ឬមិនគោរពក្តី ហៅថា **សកេន តុស្សកោ** ។

វត្ថុណាដែលខ្លួនបានហើយ ជារបស់មាននៃខ្លួន របស់នោះ ឈ្មោះថា របស់មាន កុលបុត្តត្រេកអរដោយរបស់មាននោះឯង គឺមិនប្រាថ្នារបស់ដទៃចាករបស់មាននោះ លះបង់នូវភាពជាអ្នកប្រាថ្នាច្រើន ហៅថា **សន្តេន តុស្សកោ** ។

ការលះនូវការពេញចិត្ត និងការមិនពេញចិត្ត ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ឈ្មោះថា ស្មើ កុលបុត្តពេញចិត្តក្នុងអារម្មណ៍ទាំងពួង ដោយស្មើនោះ ហៅថា **សមេន តុស្សកោ** ។

ឈ្មោះថា **សុភរោ** ព្រោះអត្ថវិគ្គហៈថា បុគ្គលដែលគេចិញ្ចឹមដោយងាយ អធិប្បាយថា ចិញ្ចឹមដោយងាយ ពិតហើយ ភិក្ខុណា សម្តែងភាពជាអ្នកមុខក្រញូវ និងភាពជាអ្នកមិនពេញចិត្តក្នុងបិណ្ឌបាត ដែលគេដាក់បាយស្រូវសាលី សាច់ និងបាយជាដើមពេញបាត្រប្រគេន ឬមើលងាយបិណ្ឌបាតនោះ ក្នុងទីចំពោះមុខជនទាំងឡាយថា ពួកអ្នកឲ្យអ្វី រមែងឲ្យដល់សាមណេរ

និងគ្រហស្ថជាដើម ភិក្ខុនោះ ឈ្មោះថា ចិញ្ចឹមក្រ ។ មនុស្សទាំងឡាយ ឃើញភិក្ខុនោះ រមែងវៀរអំពីចម្ងាយថា ភិក្ខុចិញ្ចឹមក្រ យើងមិនអាចទំនុកបម្រុងបាន ។

ចំណែកកុលបុត្តបានបិណ្ឌបាតណាមួយ សៅហ្មងក្តី ប្រណីតក្តី តិចក្តី ច្រើនក្តី មានចិត្តជារបស់ខ្លួន មានមុខថ្លូរថង់ ញុំាងជីវិតឲ្យប្រព្រឹត្តទៅ កុលបុត្តនោះ ឈ្មោះថា ចិញ្ចឹមងាយ មនុស្សទាំងឡាយ ឃើញកុលបុត្តនោះហើយ ស្រាកស្រាន្តចិត្តក្រៃលែងថា លោកម្ចាស់របស់ពួកយើង ចិញ្ចឹមងាយ រមែងត្រេកអរដោយរបស់សូម្បីតិចតួច ពួកយើងប៉ុណ្ណោះ នឹងទំនុកបម្រុងលោកម្ចាស់អង្គនោះ ដូច្នេះហើយ ធ្វើនូវបដិញ្ញាដើម្បីចិញ្ចឹម ។ កុលបុត្តមានសភាពយ៉ាងនេះ ទ្រង់បំណងថា ជាអ្នកចិញ្ចឹមងាយ ក្នុងគាថានេះ ។

ឈ្មោះថា **អប្បកិច្ចោ** ព្រោះវិគ្គហៈថា កុលបុត្តនោះមានកិច្ចតិច គឺមិនខ្វល់ខ្វាយក្នុងកិច្ចច្រើនយ៉ាង មានភាពជាអ្នកត្រេកអរក្នុងការងារ ត្រេកអរក្នុងការនិយាយ និងត្រេកអរក្នុងការប្រឡូកប្រឡំជាដើម ។ មួយប្រការទៀត មានអធិប្បាយថា កុលបុត្តនោះ វៀរចាកកិច្ច មានការកសាងក្នុងវិហារទាំងមូល ការបង្រៀនពួកសង្ឃ និងសាមណេរ ញោមវត្តជាដើម ធ្វើនូវកិច្ចរបស់ខ្លួន មានការកោរសក់ កាត់ក្រចក អប់បាត្រ និងដេរចីវរជាដើម ឈ្មោះថា ជាអ្នកមានកិច្ច គឺសមណធម៌ជាទីទៅខាងមុខ ។

ឈ្មោះថា **សល្លហុកវុត្តិ** ព្រោះអត្ថថា កុលបុត្តនោះ មានការប្រព្រឹត្តិ

ស្រាល ភិក្ខុអ្នកមានបរិក្ខារច្រើនរូបខ្លះ ចៀសទៅកាន់ទិស ក៏ឲ្យមហាជនជញ្ជូនបាត្រ ចីវរ សំពត់ក្រាលដេក ប្រេង ទឹកអំពៅជាដើម ដែលមានចំនួនច្រើន ដោយទូលលើក្បាលខ្លះ កណ្តៀតខ្លះជាដើម ចៀសចេញទៅ យ៉ាងណា កុលបុត្តណាមិនមានសភាពដូច្នោះ ជាអ្នកមានបរិក្ខារតិច ប្រើចំពោះតែសមណបរិក្ខារ ៨ មានបាត្រ និងចីវរជាដើមប៉ុណ្ណោះ ក្នុងពេលចៀសទៅកាន់ទិស ក៏កាន់យកប៉ុណ្ណោះចៀសចេញទៅ ដូចបក្សីមានតែស្លាបទៅដូច្នោះ ។ កុលបុត្តមានសភាពយ៉ាងនេះ លោកបំណងយកថា ជាអ្នកមានការប្រព្រឹត្តិស្រាល ក្នុងគាថានេះ ។

ឈ្មោះថា **សន្តិន្ទ្រិយោ** ព្រោះអត្ថថា កុលបុត្តនោះ មានឥន្ទ្រិយទាំង-ឡាយស្ងប់ហើយ អធិប្បាយថា មានឥន្ទ្រិយដែលមិនរាយមាយ ដោយអំណាចនៃរាគៈជាដើម ក្នុងអារម្មណ៍ទាំងឡាយ មានឥដ្ឋារម្មណ៍ជាដើម ។

បទថា **និបកោ** បានដល់ ជាអ្នកដឹងច្បាស់ គឺជាអ្នកមានការដឹង បានដល់ ជាអ្នកមានបញ្ញា អធិប្បាយថា ជាអ្នកដល់ព្រមហើយដោយបញ្ញា ជាគ្រឿងតាមរក្សាសីល ដោយបញ្ញាជាគ្រឿងពិចារណាចីវរជាដើម និងដោយបញ្ញាកំណត់ដឹងនូវសប្បាយ ៧ មានអាវាសសប្បាយជាដើម ។ ឈ្មោះថា **អប្បគព្ភោ** ព្រោះអត្ថថា កុលបុត្តមិនមានការគ្នាំគ្នង អធិប្បាយថា វៀរចាកការគ្នាំគ្នងកាយ ដែលមានឋានៈ ៨ និងការគ្នាំគ្នងវាចា ដែលមានឋានៈ ៤ និងគ្នាំគ្នងចិត្ត មានច្រើនឋានៈ ។

ការធ្វើដែលមិនសមគួរផ្លូវកាយក្នុងការចូលទៅរកសង្ឃ គណៈ បុគ្គល រោងឆាន់ រោងភ្លើង កំពង់ទឹក ផ្លូវបិណ្ឌបាត និងក្នុងចន្លោះស្រុក ឈ្មោះថា ការខ្នាំខ្នងដោយកាយ មាន ៨ ឋានៈ គឺភិក្ខុបវខ្វះក្នុងសាសនានេះ អង្គុយ ត្របោមក្បាលជង្គង់ ឬអង្គុយបញ្ឈរជង្គង់ក្នុងកណ្តាលសង្ឃយ៉ាងនេះជាដើម ។ ក្នុងកណ្តាលគណៈក៏ដូចគ្នា ពាក្យថា ក្នុងកណ្តាលគណៈ បានដល់ ក្នុងការ ប្រជុំបរិស័ទ ៤ ។ ក្នុងបុគ្គលដែលចាស់ជាងក៏យ៉ាងនោះ ។

ក្នុងរោងឆាន់ រមែងមិនឲ្យអាសនៈដល់ភិក្ខុ ដែលជាថេរៈទាំងឡាយ រមែងបៀតបៀនភិក្ខុថ្មីទាំងឡាយដោយអាសនៈ ។ ក្នុងរោងភ្លើង ក៏យ៉ាងនោះ ក្នុងរោងភ្លើងនោះ មិនសូមអនុញ្ញាតព្រះថេរៈទាំងឡាយ ធ្វើកិច្ចទាំងឡាយមាន បង្កាត់ភ្លើងជាដើម ។ ក្នុងកំពង់ទឹក លោកពោលថា គប្បីផ្លូតតាមលំដាប់អ្នក មកមុនមកក្រោយ ដោយមិនធ្វើការកំណត់ថា ខ្ញុំចាស់ ។ ភិក្ខុបវខ្វះមិនអើពើ ក្នុងរឿងនោះ សូម្បីមកក្រោយក៏ចុះទឹកមុន បៀតបៀនដល់ភិក្ខុចាស់ និងភិក្ខុ ដែលបួសថ្មី ។

ចំណែកក្នុងផ្លូវបិណ្ឌបាត ក៏ដើរទៅខាងមុខភិក្ខុចាស់ទាំងឡាយ ដើម្បី អាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ បិណ្ឌបាតដ៏ប្រសើរ យកដៃប៉ះដៃ ចូលទៅ មុនភិក្ខុចាស់ទាំងឡាយ ក្នុងកាលចូលទៅក្នុងចន្លោះស្រុក រមែងធ្វើការលេង ផ្លូវកាយដោយភិក្ខុក្មេងទាំងឡាយ ដូច្នេះជាដើម ។

កាលបន្ទីវាចាដែលមិនសមគួរក្នុងសង្ឃ គណៈ បុគ្គល និងក្នុងចន្លោះ

ស្រុក ឈ្មោះថា ការគ្គាំគ្គងដោយវាចា មាន ៤ ឋានៈ គឺភិក្ខុរូបខ្លះ ក្នុងសាសនានេះ មិនសូមអនុញ្ញាត សម្ដែងធម៌ក្នុងកណ្ដាលសង្ឃ ។ ក្នុងគណៈនិងក្នុងបុគ្គលដែលចាស់ជាង មានប្រការដូចពោលហើយក្នុងកាលមុន ។ ភិក្ខុរូបខ្លះ ត្រូវមនុស្សទាំងឡាយសួរបញ្ហាក្នុងកណ្ដាលសង្ឃនោះ មិនសូមអនុញ្ញាតភិក្ខុដែលចាស់ជាង ឆ្លើយនូវបញ្ហា ចំណែកក្នុងចន្លោះស្រុក ពោលពាក្យយ៉ាងនេះថា ក្នុងទីឈ្មោះនេះ មានអ្វី មានបបរ ឬរបស់ទំពា របស់ធាន់ អ្នកនឹងឲ្យអ្វីដល់អាត្មាក្នុងថ្ងៃនេះ អាត្មានឹងទំពាអ្វី ធាន់អ្វី ផឹកអ្វី ដូច្នេះជាដើម ។

ការមិនដល់អជ្ឈាចារ ដោយកាយ និងវាចាក្នុងឋានៈនោះៗ ត្រិះរិះដល់វត្ថុដែលមិនសមគួរ មានប្រការផ្សេងៗ មានកាមវិតក្កជាដើម ដោយចិត្តតែម្យ៉ាង ឈ្មោះថា ការគ្គាំគ្គងចិត្ត មានឋានៈច្រើនយ៉ាង ។

បទថា **កុលេសុ អននុគិទ្ធោ** សេចក្ដីថា មិនជាប់ជំពាក់ក្នុងត្រកូលទាំងឡាយដែលខ្លួនចូលទៅរកដោយការចង់បានក្នុងបច្ច័យ ឬដោយអំណាចនៃការប្រឡូកប្រឡំជាមួយគ្រហស្ថដែលមិនសមគួរ អធិប្បាយថា មិនសោកផង មិនត្រេកអរផង មិនសុខក្នុងត្រកូលដែលមានសេចក្ដីសុខ មិនទុក្ខក្នុងត្រកូលដែលមានសេចក្ដីទុក្ខ មិនដល់នូវការប្រកបដោយខ្លួនឯង ក្នុងករណីយកិច្ចទាំងឡាយដែលកើតឡើង ។ ក្នុងគាថានេះ ពាក្យថា **អស្ស** បានពោលហើយក្នុងបទថា **សុវចោ អស្ស** គប្បីប្រកបពាក្យនោះ មួយអន្លើដោយបទទាំងពួង

យ៉ាងនេះថា **សន្ទុស្សកោ ច អស្ស សុភរោ ច អស្ស** ដូច្នេះ ។

ព្រះដ៏មានព្រះភាគ កាលត្រាស់ប្រាប់កិច្ចដែលគួរធ្វើ សូម្បីក្រៃលែងជាងនោះ ដល់ភិក្ខុដែលនៅព្រៃដោយពិសេស បំណងដើម្បីត្រាស់ដឹងនូវសន្តិបទ ឬប្រាថ្នាដើម្បីបដិបត្តិ ដើម្បីសម្រេចសន្តិបទយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់បំណងដើម្បីត្រាស់ប្រាប់កិច្ចដែលមិនគួរធ្វើ ទើបត្រាស់កន្លះគាថានេះថា

**ន ច ខុទ្ទំ សមាចរេ កិញ្ចិ យេន វិញ្ញូ បរេ ឧបវទេយ្យុំ។**

វិញ្ញូជនទាំងឡាយ គប្បីតិះដៀលនូវជនទាំងឡាយដទៃ ដោយកម្មណា មិនគួរប្រព្រឹត្តនូវកម្មនោះ ដែលជាកម្មលាមក សូម្បីតិចតួច ។

គាថានោះ មានសេចក្ដីថា ការធ្វើប្រយោជន៍ដែលគួរធ្វើយ៉ាងនេះ មិនគប្បីប្រព្រឹត្តទុច្ចរិតផ្លូវកាយ ផ្លូវវាចា និងផ្លូវចិត្ត ដែលហៅថា តិចតួច គឺលាមក ។ មានអធិប្បាយថា កាលមិនប្រព្រឹត្តទុច្ចរិត មិនមែនត្រឹមតែទុច្ចរិតគ្រោតគ្រាតតែម្យ៉ាង មិនគប្បីប្រព្រឹត្តទុច្ចរិតប្រមាណតិចតួច ។ បន្ទាប់អំពីនោះ ទ្រង់សម្ដែងទោសដែលគប្បីឃើញឯង ក្នុងការប្រព្រឹត្តិទុច្ចរិតនោះថា ជាហេតុឲ្យអ្នកប្រាជ្ញពួកដទៃតិះដៀលបាន ។

ក្នុងគាថានេះ ព្រោះបុគ្គលពាលដទៃមិនជាប្រមាណ ព្រោះថាបុគ្គលពាលទាំងនោះ រមែងធ្វើវត្ថុដែលមិនមានទោស ឲ្យមានទោសខ្លះ រមែងធ្វើវត្ថុដែលមានទោសតិច ឲ្យមានទោសច្រើនខ្លះ ឯអ្នកប្រាជ្ញទាំងឡាយប៉ុណ្ណោះ ទើបយក

ជាប្រមាណ ព្រោះអ្នកប្រាជ្ញទាំងនោះ ពិចារណាហើយ គិតហើយ រមែង ពោលតិះដៀលដល់បុគ្គលដែលគួរតិះដៀល រមែងពោលសរសើរដល់បុគ្គល ដែលគួរសរសើរ ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **វិញ្ញូ បរេ** ប្រែថា អ្នកប្រាជ្ញដទៃ ដូច្នេះ ។

ព្រះដ៏មានព្រះភាគ កាលត្រាស់ឧបចារៈនៃកម្មដ្ឋាន មានប្រយោជន៍ដែល គួរធ្វើ និងមិនគួរធ្វើជាដើមដល់អ្នកនៅព្រៃជាវត្តដោយពិសេស បុគ្គលប្រាថ្នា ដើម្បីត្រាស់ដឹងនូវសន្តិបទ ឬប្រាថ្នាដើម្បីបដិបត្តិសម្រេចសន្តិបទនោះ ដល់ ភិក្ខុទាំងឡាយ បុគ្គលប្រាថ្នាដើម្បីនឹងរៀនកម្មដ្ឋានទាំងអស់ដោយមានភិក្ខុដែល នៅព្រៃជាវត្តជាប្រធាន ដោយ ២ គាថាកន្លះនេះយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីកម្ចាត់ និងដើម្បីការពារភ័យអំពីទេវតានោះ និងដើម្បីកម្មដ្ឋាន ដោយ អំណាចឈាន ដែលជាបាទនៃវិបស្សនាសម្រាប់ភិក្ខុទាំងនោះ ទើបទ្រង់ផ្តើម ត្រាស់មេត្តកថា ដោយន័យជាដើមថា **សុខិនោ វា ខេមិនោ ហោន្តុ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុខិនោ** បានដល់ មានការដល់ព្រមដោយ សេចក្តីសុខ ។ បទថា **ខេមិនោ** បានដល់ មានសេចក្តីក្សេម អធិប្បាយថា ជាអ្នកមិនមានភ័យ មិនមានឧបទ្រព ។ បទថា **សព្វេ** បានដល់ ដែលមិន មានសេសសល់ ។ បទថា **សត្តា** បានដល់ សត្វដែលមានជីវិតទាំងឡាយ ។ បទថា **សុខិតត្តា** បានដល់ ជាអ្នកមានចិត្តជាសុខ ។

ក្នុងគាថានេះ សត្វមានជីវិតទាំងឡាយ អ្នកសិក្សាគប្បីជ្រាបថា មាន

សុខដោយសុខផ្លូវកាយ មានខ្លួនដល់នូវសេចក្ដីសុខដោយសុខផ្លូវចិត្ត ឬមានសេចក្ដីក្សេម ដោយសុខទាំងពីរនោះ ឬដោយការផុតភ័យ និងឧបទ្រពទាំងពួង ។

សួរថា ព្រោះហេតុអ្វីទើបត្រាស់យ៉ាងនេះ ឆ្លើយថា ព្រោះដើម្បីសម្ដែងអាការនៃមេត្តាភាវនា ។ ពិតហើយ ព្រះយោគាវចរគប្បីចម្រើនមេត្តាដូច្នេះថា ចូរសត្វទាំងឡាយ ជាអ្នកមានសេចក្ដីសុខចុះ ឬថា ចូរមានសេចក្ដីក្សេមចុះ ឬថា ចូរមានខ្លួនដល់នូវសេចក្ដីសុខចុះ ។

កាលទ្រង់សម្ដែងមេត្តាភាវនាដោយសង្ខេប តាំងអំពីឧបចារសមាធិរហូតដល់ទីបំផុតនៃអប្បនាសមាធិយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្ដែងមេត្តាភាវនានោះដោយពិស្ដារ ទើបត្រាស់ ២ គាថាថា **យេ កេចិ** ដូច្នេះ ។

ម្យ៉ាងទៀត ចិត្តរបស់កុលបុត្តណា សន្សំហើយក្នុងអារម្មណ៍ផ្សេងៗ រមែងមិនតាំងនៅក្នុងឯកត្តារម្មណ៍ ដោយអារម្មណ៍ខាងដើមឡើយ តែស្ទុះទៅតាមប្រភេទនៃអារម្មណ៍ ហើយតាំងនៅតាមលំដាប់នោះឯង ព្រោះដូច្នោះ ដើម្បីទ្រង់ញុំាងចិត្តរបស់កុលបុត្តនោះ ដែលជាប់ហើយជាប់ទៀតនូវអារម្មណ៍ទាំងឡាយ មានទុកៈ និងតិកៈ មានការតក់ស្លុត និងមិនតក់ស្លុតជាដើម ឲ្យតាំងមាំបាន ទើបត្រាស់ ២ គាថាថា **យេ កេចិ** ជាដើម ។

មួយប្រការទៀត ព្រោះអារម្មណ៍ជាក់ច្បាស់ដល់កុលបុត្តណា ចិត្តរបស់កុលបុត្តនោះ តែងតាំងមាំយ៉ាងល្អក្នុងអារម្មណ៍នោះ ព្រោះដូច្នោះ ទ្រង់បំណង

ដើម្បីញ៉ាំងចិត្តរបស់កុលបុត្តនោះ ឲ្យតាំងមាំក្នុងអារម្មណ៍នោះ ទើបត្រាស់ ២ គាថានេះថា **យេ កេចិ** ដែលសម្តែងប្រភេទនៃអារម្មណ៍ ដែលជាទុកៈ និងតិកៈ មានការតក់ស្លុត និងមិនតក់ស្លុតជាដើម ដល់ភិក្ខុទាំងនោះ ។

ក្នុងគាថានេះ ទ្រង់សម្តែងទុកៈ ៤ គឺពួក ២ នៃសត្វដែលតក់ស្លុត និងមិនតក់ស្លុត ពួក ២ នៃសត្វដែលឃើញ និងមិនឃើញ ពួក ២ នៃសត្វដែលនៅឆ្ងាយ និងនៅជិត ពួក ២ នៃភូត និងសម្ភវេសី និងតិកៈ ៣ គឺតិកៈនៃសត្វវែង សត្វខ្លី និងសត្វកណ្តាល តិកៈនៃសត្វធំ សត្វតូច និងសត្វកណ្តាល តិកៈនៃសត្វធាត់ សត្វតូច និងកណ្តាល ដោយ ៦ ពាក្យ មានវែងជាដើម ដោយមានអត្ថនៃពាក្យថា កណ្តាល ក្នុងតិកៈ ៣ ពួក និងអត្ថនៃពាក្យថា តូចក្នុងតិកៈ ២ ពួក ។

ក្នុងបទទាំងនោះ បទថា **យេ កេចិ** ជាពាក្យពោលដែលមិនមានចំណែកសេសសល់ ។ សត្វទាំងឡាយដែលមានបាណៈ គឺមានខ្យល់ដង្ហើមនោះឯង ឈ្មោះថា **បាណភូតា** ។ ម៉្យាងទៀត ឈ្មោះថា **បាណា** ព្រោះអត្ថថា រមែងដកដង្ហើម ។ ទ្រង់កាន់យកសត្វមានខន្ធ ៥ ទាំងឡាយ ដែលទាក់ទងដោយខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដោយបទថា **បាណា** នេះ ។

ឈ្មោះថា **ភូតា** ព្រោះអត្ថថា កើត ។ ទ្រង់កាន់យកសត្វ មានខន្ធ ១ និងខន្ធ ៤ ដោយបទថា **ភូតា** នេះ ។ បទថា **អត្ថិ** បានដល់ មានប្រាកដ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងសត្វទាំងឡាយដែលគប្បីសង្គ្រោះ

ដោយទុកៈ និងតិកៈរួមចូលគ្នាដោយព្រះតម្រាស់នេះថា **យេ កេចិ បាណភូតត្ថិ** យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់សម្តែងសត្វទាំងអស់នោះ សង្គ្រោះចូលដោយទុកៈនេះថា **តសា វា ថាវរា វា អនវសេសា** ដូច្នេះ ។

ក្នុងគាថានោះ ឈ្មោះថា **តសា** ព្រោះអត្ថថា សត្វទាំងឡាយរមែងតក់ស្លុត ។ ពាក្យថា **តសា** នោះ ជាឈ្មោះនៃសត្វទាំងឡាយ ដែលមានតណ្ហា និងមានភ័យ ។ ឈ្មោះថា **ថាវរា** ព្រោះអត្ថថា រមែងតាំងនៅ ។ បទថា **ថាវរា** នោះ ជាឈ្មោះរបស់ព្រះអរហន្តទាំងឡាយ ដែលលះការប្រព្រឹត្តិទៅនៃតណ្ហាហើយ ។ ឈ្មោះថា **អនវសេសា** ព្រោះអត្ថថា សត្វទាំងនោះមិនមានចំណែកសេសសល់ អធិប្បាយថា ទាំងអស់ ។

ពាក្យណាដែលត្រាស់ហើយ ក្នុងទីបំផុតនៃគាថាទី ២ ពាក្យទាំងអស់នោះ អ្នកសិក្សាគប្បីភ្ជាប់ជាមួយទុកៈ និងតិកៈថា សត្វមានជីវិតពួកឯណានីមួយមាន ជាសត្វតក់ស្លុត ឬជាសត្វមាំទាំ មិនមានសេសសល់ ចូរសត្វទាំងអស់នោះ ជាអ្នកមានខ្លួនដល់នូវសេចក្តីសុខចុះ បែបនេះរហូតដល់សត្វទាំងឡាយដែលកើតហើយ ឬដែលកំពុងស្វែងរកទីកើត សូមសត្វទាំងអស់នេះ ជាអ្នកមានខ្លួនដល់នូវសេចក្តីសុខចុះ ។

ឥឡូវនេះ គប្បីជ្រាបអធិប្បាយក្នុងបទទាំង ៦ ថា **ទីឃា វា** ជាដើម ដែលសម្តែងដល់តិកៈទាំង ៣ មានវែង ខ្លី កណ្តាល ។ បទថា **ទីឃា** បានដល់ មានអត្តភាពវែង មាននាគ ត្រី និងទន្សោងជាដើម អត្តភាពរបស់សត្វ

ទាំងឡាយ មាននាគជាដើមក្នុងមហាសមុទ្រ មានប្រមាណច្រើនរយព្យាមខ្លះ អត្តភាពរបស់សត្វទាំងឡាយ មានត្រី និងទន្សោងជាដើម មានប្រមាណច្រើនយោជន៍ខ្លះ ។

បទថា **មហន្តា** បានដល់ មានអត្តភាពធំក្នុងសមុទ្រ មានអណ្តើកជាដើម លើគោក មានដំរី និងនាគជាដើម ក្នុងអមនុស្សទាំងឡាយ មានទានវៈជាដើម ដូចព្រះមានព្រះភាគត្រាស់ថា រាហុធំលើសពួកសត្វដែលមានអត្តភាព ដូច្នេះ ពិតហើយ ខ្លួនរបស់រាហូនោះ កម្ពស់ ៤៨០០ យោជន៍ ប្រវែងដៃប្រមាណ ១២០០ យោជន៍ ចន្លោះចិញ្ចើម ៥០ យោជន៍ ថ្នាំងម្រាមដៃ ៥០ យោជន៍ បាតដៃទំហំ ២០០ យោជន៍ ។

បទថា **មជ្ឈិមា** បានដល់ អត្តភាពរបស់សេះ គោ ក្របី និងជ្រូកជាដើម ។ បទថា **រស្សកា** បានដល់ សត្វទាំងឡាយដែលមានប្រមាណទាបជាងសត្វដែលវែង និងកណ្តាល មានខ្លួនទាបជាដើម ក្នុងជាតិនោះៗ ។

បទថា **អណុកា** បានដល់ សត្វទាំងឡាយដែលមានអត្តភាពល្អិត កើតក្នុងទឹកជាដើម មិនជាអារម្មណ៍របស់មំសចក្ខុ តែជាវិស័យរបស់ទិព្វចក្ខុ ឬសត្វទាំងឡាយ មានសុចជាដើម ។ម៉្យាងទៀត សត្វទាំងឡាយណា មានប្រមាណទាបជាងសត្វដែលធំ ឬកណ្តាល និងជាងសត្វធាត់ ឬកណ្តាលក្នុងជាតិនោះៗ សត្វទាំងនោះ គប្បីជ្រាបថា **អណុកា** ( ល្អិត ) ។

បទថា **ថូលា** បានដល់ សត្វទាំងឡាយដែលមានអត្តភាពមូល មាន

ត្រី អណ្ដើក ខ្យង និងខ្ចៅជាដើម ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងសត្វទាំងឡាយ ដោយមិនមានចំណែកសេសសល់ដោយតិកៈទាំង ៣ យ៉ាងនេះហើយ ឥឡូវនេះ ទើបត្រាស់ដើម្បីទ្រង់សម្ដែងសត្វទាំងនោះ សង្គ្រោះដោយទុកៈទាំង ៣ យ៉ាងនេះថា **ទិដ្ឋា វា យេ ច អទិដ្ឋា** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទិដ្ឋា** បានដល់ ដែលធ្លាប់ឃើញដោយអំណាចដែលមកកាន់គន្លងចក្ខុរបស់ខ្លួន ។ បទថា **អទិដ្ឋា** បានដល់ តាំងនៅក្នុងសមុទ្រដទៃ ភ្នំដទៃ និងចក្កវាឡដទៃជាដើម ។

ទ្រង់សម្ដែងសត្វទាំងឡាយដែលនៅក្នុងទីឆ្ងាយ និងក្នុងទីជិត និងអត្តភាពរបស់ខ្លួនដោយទុកៈនេះថា **យេ ច ទូរេ វសន្តិ អវិទូរេ** ។ សត្វទាំងនោះគប្បីជ្រាបដោយអំណាចនៃសត្វមិនមានជើង និងសត្វជើងពីរ ឯសត្វទាំងឡាយក្នុងកាយរបស់ខ្លួន ហៅថា នៅក្នុងទីជិត នៅក្នុងកាយខាងក្រៅ ហៅថា នៅក្នុងទីឆ្ងាយ ម្យ៉ាងទៀត នៅខាងក្នុងឧបចារៈ ហៅថា នៅក្នុងទីជិត នៅខាងក្រៅ ឧបចារៈ ហៅថា នៅក្នុងទីឆ្ងាយ នៅខាងក្នុងវិហារ គាម ជនបទ ទ្វីប ចក្កវាឡ ហៅថា នៅក្នុងទីជិត នៅក្នុងចក្កវាឡដទៃ ហៅថា នៅក្នុងទីឆ្ងាយ ។

បទថា **ភូតា** បានដល់ កើតហើយ គឺកើតឡើងហើយ ។ សត្វពួកណាកើតហើយនោះឯង រមែងមិនដល់នូវការរាប់ថា នឹងមានទៀត ពាក្យថា **ភូតា** នោះ ជាឈ្មោះរបស់សត្វទាំងនោះ ដែលជាព្រះខីណាស្រព ។

ឈ្មោះថា **សម្ភវេសី** ព្រោះអត្ថថា សត្វទាំងឡាយរមែងស្វែងរកទីកើត ពាក្យថា **សម្ភវេសី** នោះជាឈ្មោះរបស់សេក្ខៈ និងបុថុជ្ជនទាំងឡាយដែលជាអ្នកស្វែងរកទីកើតជាបន្ត ព្រោះជាបុគ្គលលះនូវភវសំយោជនៈមិនទាន់បាន ។

សត្វទាំងឡាយដែលកើតអំពីស៊ុត និងកើតអំពីគភ៌ ក្នុងបណ្តាកំណើតទាំង ៤ ដែលមិនទាន់ទម្លាយសម្បកស៊ុត និងមិនទាន់ទម្លាយស្បូនចេញមកដរាបណា ឈ្មោះថា **សម្ភវេសី** ដរាបនោះ ។ សត្វទាំងឡាយដែលទម្លាយសម្បកស៊ុត និងទម្លាយស្បូនចេញមកខាងក្រៅឈ្មោះថា **ភូត**។ សត្វទាំង-ឡាយដែលកើតអំពីញើសក្អែល និងឧបបាតិកសត្វ ឈ្មោះថា **សម្ភវេសី** ក្នុង ខណៈនៃបឋមចិត្ត ចាប់ពីខណៈចិត្តជួងទី ២ ឈ្មោះថា **ភូត** ឬកើតដោយឥរិយាបថណា មិនទាន់ផ្លាស់ឥរិយាបថដទៃដរាបណា ឈ្មោះថា **សម្ភវេសី** ដរាបនោះ បន្ទាប់អំពីនោះទៅ ឈ្មោះថា **ភូត**។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងមេត្តាភាវនា ក្នុងសត្វទាំងឡាយដោយអំណាចនៃការប្រាថ្នាដើម្បីដល់នូវហិតសុខ ដល់ភិក្ខុទាំងនោះ ដោយប្រការផ្សេងៗ ដោយ ២ គាថាកន្ទះថា **សុខិនោ វា** យ៉ាងនេះជាដើមហើយឥឡូវនេះ កាលទ្រង់សម្តែងមេត្តាភាវនានោះ ដោយអំណាចនៃការប្រាថ្នាដើម្បីមិនឲ្យជួបនូវអហិតទុក្ខ ទើបត្រាស់ថា **ន បរោ បរំ និកុព្វេថ** នេះជាបាលីបុរាណ ។ ឥឡូវនេះ គេតែងសូត្រថា **បរញ្ហិ** ដូច្នេះក៏មាន តែមិនប្រពៃ ។

បណ្តាបទទាំងនោះ បទថា **បរោ** បានដល់ ជនដទៃ ។ បទថា **បរំ**

បានដល់ នូវជនដទៃ ។ បទថា **ន និក្ខមេយ្យ** គឺមិនគប្បីសង្កត់សង្កិន ។ បទថា **នាតិមញ្ញេយ្យ** គឺមិនគប្បីមើលងាយ មើលថោក ។ បទថា **កត្ថចិ** បានដល់ ក្នុងទីទាំងឡាយ មានឱកាស គាម ខេត្ត កណ្តាលញាតិ ឬកណ្តាលបុត្រជាដើម ។ បទថា **នំ** បានដល់ បុគ្គលនោះ ។

បទថា **កិញ្ចិ** បានដល់ នូវបុគ្គលណាម្នាក់ ទោះជាក្សត្រក្តី ព្រាហ្មណ៍ក្តី គ្រហស្ថក្តី បព្វជិតក្តី អ្នកមានក្តី អ្នកក្រក្តីជាដើម ។

បទថា **ព្យារោសនា បដិឃសញ្ញា** សេចក្តីថា ដោយសេចក្តីក្រេវក្រោធ ដោយខុសប្រក្រតីផ្លូវកាយ និងផ្លូវវាចា និងដោយការអាក់អន់ ព្រោះខុសប្រក្រតីផ្លូវចិត្ត ។ កាលគួរត្រាស់ថា **ព្យារោសនាយ បដិឃសញ្ញាយ** ទ្រង់ក៏ត្រាស់ថា **ព្យារោសនា បដិឃសញ្ញា** ដូចកាលគួរពោលថា **សម្មទញ្ញាយ វិមុត្តា** ក៏ពោលថា **សម្មទញ្ញា វិមុត្តា** និងកាលគួរពោលថា **អនុបុព្វសិក្ខាយ អនុបុព្វកិរិយាយ អនុបុព្វបដិបទាយ** ក៏ពោលថា **អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វបដិបទា** ។

បទថា **នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ** សេចក្តីថា មិនគប្បីប្រាថ្នាទុក្ខដល់គ្នានិងគ្នា មានអធិប្បាយដូចម្តេច អធិប្បាយថា មិនគប្បីចម្រើនមេត្តាដោយអំណាចនៃមនសិការជាដើមថា ចូរមានសេចក្តីសុខ មានសេចក្តីក្សេមចុះ តែម្យ៉ាងប៉ុណ្ណោះ តែគប្បីចម្រើនមនសិការយ៉ាងនេះថា ធ្វើម្តេចហ្ន៎ បុគ្គលដទៃពួកខ្លះ កុំគប្បីសង្កត់សង្កិនបុគ្គលដទៃណាមួយ ដោយពាក្យក្រោធទាំងឡាយ

មានការបោកបញ្ឆោតជាដើម និងមិនគប្បីមើលងាយបុគ្គលដទៃណាមួយ ក្នុងប្រទេសណាមួយ ដោយរឿងមានះ មានជាតិជាដើម គឺមិនគប្បីប្រាថ្នានូវទុក្ខដល់គ្នានិងគ្នា ព្រោះការក្រេវក្រោធ ឬការថ្នាំងថ្នាក់ ។

កាលទ្រង់សម្តែងមេត្តាភាវនាដោយអត្ថ ដោយអំណាចនៃការប្រាថ្នាដើម្បីការមិនជួបនូវអហិតទុក្ខយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងនូវមេត្តាភាវនានោះឯង ដោយពាក្យឧបមា ទើបត្រាស់ថា **មាតា យថា និយំ បុត្តំ** ដូច្នេះ ។

គាថានោះ មានសេចក្តីថា មាតាគប្បីថ្នមថែរក្សាបុត្តទោល ដែលកើតក្នុងខ្លួន គឺបុត្តដែលកើតអំពីទ្រូង បានដល់ កូនតែមួយនោះដោយអាយុ គឺលះបង់អាយុរបស់ខ្លួន ដើម្បីការពារនូវសេចក្តីទុក្ខដែលមកដល់បុត្តនោះ ថ្នមថែរក្សាបុត្តនោះ យ៉ាងណា កុលបុត្តគប្បីចម្រើនមេត្តា ដែលមានក្នុងចិត្តនេះ ក្នុងសត្វទាំងពួង គឺគប្បីញ៉ាំងមេត្តាឲ្យកើត ឲ្យចម្រើនរឿយៗ និងគប្បីចម្រើនមេត្តានោះដោយអំណាចនៃសត្វមិនមានប្រមាណក្នុងអារម្មណ៍ ឬគប្បីចម្រើនមេត្តានោះមិនមានប្រមាណ ដោយអំណាចនៃការផ្សាយទៅ មិនមានចំណែកសេសសល់ ក្នុងសត្វសូម្បីម្នាក់ ដូច្នោះ ។

កាលទ្រង់សម្តែងមេត្តាភាវនា ដោយអាការទាំងពួង យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងការចម្រើនមេត្តាភាវនានោះឯង ទើបត្រាស់ថា **មេត្តញ្ច សព្វលោកស្មឹ** ដូច្នេះ ។

ក្នុងគាថានោះ ឈ្មោះថា មិត្ត ព្រោះអត្ថវិគ្គហៈថា រមែងស្រឡាញ់ និងការពារ អធិប្បាយថា រមែងជាប់ជំពាក់ ព្រោះជាអ្នកមានអធ្យាស្រ័យអនុគ្រោះ និងរមែងរក្សាចាកការជួបនូវវត្ថុ ដែលមិនជាប្រយោជន៍ ។ ភាវៈនៃមិត្ត ឈ្មោះថា **មេត្តា** ។

បទថា **សព្វំ** បានដល់ មិនមានចំណែកសល់ ។ បទថា **លោកស្មឹ** បានដល់ ក្នុងសត្វលោក ។ វត្ថុដែលមានក្នុងចិត្ត ឈ្មោះថា **មានស** ។ **មានស** នោះ ត្រាស់យ៉ាងនេះ ក៏ព្រោះជាធម៌ដែលសម្បយុត្តដោយចិត្ត ។ បទថា **ភាវយេ** គឺគប្បីឲ្យចម្រើន ។ ឈ្មោះថា **អបរិមាណំ** ព្រោះមេត្តានោះ មិនមានប្រមាណ មេត្តានោះ ទ្រង់ត្រាស់យ៉ាងនេះ ព្រោះមានសត្វមិនមានប្រមាណជាអារម្មណ៍ ។

បទថា **ឧទ្ធំ** បានដល់ ខាងលើ ទ្រង់កាន់យកអរូបភពដោយបទនោះ ។ បទថា **អធោ** បានដល់ ខាងក្រោម ទ្រង់កាន់យកកាមភពដោយបទនោះ ។ បទថា **តិរិយំ** បានដល់ ក្នុងកណ្តាល ទ្រង់កាន់យករូបភពដោយបទនោះ ។

បទថា **អសម្ពាធំ** បានដល់ វៀរចាកការចង្អៀតចង្អល់ អធិប្បាយថា មានព្រំដែនទម្លាយហើយ សត្រូវ ( បច្ចត្ថិក ) ហៅថា ព្រំដែន អធិប្បាយថា ប្រព្រឹត្តទៅហើយ ក្នុងព្រំដែននោះ ។

បទថា **អវេរំ** បានដល់ ប្រាសចាកពៀរ អធិប្បាយថា វៀរចាកការប្រាកដនៃវេរចេតនា ក្នុងចន្លោះៗ ។

បទថា **អសបត្តំ** បានដល់ ប្រាសចាកសត្រូវ ។ ពិតហើយ បុគ្គលដែលមានមេត្តាជាគ្រឿងនៅ រមែងជាទីស្រឡាញ់របស់មនុស្សទាំងឡាយ ជាទីស្រឡាញ់របស់អមនុស្សទាំងឡាយ រមែងមិនមានសត្រូវណាមួយ ដោយហេតុនោះ មានសៈនោះរបស់បុគ្គលនោះ ហៅថា **អសបត្តំ** ព្រោះភាពជាអ្នកប្រាសចាកសត្រូវហើយ ។ ពាក្យថា **បច្ចត្ថិក** និង **សបត្ត** នោះ ជាវេវចនៈនៃគ្នានិងគ្នា នេះជាពណ៌នាអត្ថតាមលំដាប់បទ ។

ពណ៌នាអត្ថដែលបំណងក្នុងគាថានេះ មានដូច្នេះ មេត្តាមានក្នុងចិត្តនោះ ដែលព្រះដ៏មានព្រះភាគត្រាស់ថា កុលបុត្តគប្បីចម្រើនមេត្តាក្នុងចិត្ត ដែលមិនមានប្រមាណក្នុងសត្វទាំងពួងយ៉ាងនេះ កុលបុត្តគប្បីចម្រើនមេត្តា ដែលមិនមានប្រមាណ ដែលមានក្នុងចិត្តនេះ ក្នុងលោកទាំងពួង គឺគប្បីឲ្យចម្រើនបានដល់ គប្បីឲ្យដល់នូវសេចក្តីចម្រើន ដុះដាល បរិបូណ៌ ។ គប្បីចម្រើនដូចម្តេច គឺគប្បីចម្រើនទាំងខាងលើ ខាងក្រោម និងទទឹង បានដល់ ខាងលើដល់ភវគ្គព្រហ្ម ខាងក្រោម ដល់អវីចី ខាងទទឹង សព្វទិសដ៏សេស ឬការផ្សាយមេត្តាដែលមានក្នុងចិត្ត ដែលមិនមានចំណែកសល់ ខាងលើ ទៅកាន់អរូបព្រហ្ម ខាងក្រោម ទៅកាន់កាមធាតុ ខាងទទឹង ទៅកាន់រូបធាតុ កាលចម្រើនយ៉ាងនេះ គប្បីចម្រើនធ្វើមេត្តាដែលមានក្នុងចិត្តនោះ មិនឲ្យចង្អៀតចង្អល់ មិនមានពៀរ មិនមានសត្រូវ ដោយប្រការដែលមេត្តាមានក្នុងចិត្ត ជាធម្មជាតមិនចង្អៀតចង្អល់ មិនមានពៀរ និងមិនមានសត្រូវ ។

ម្យ៉ាងទៀត មេត្តាដែលមានក្នុងចិត្ត ដែលមិនមានប្រមាណនោះ ដល់ហើយនូវការនាសម្បទា មិនចង្អៀតចង្អល់ក្នុងលោកទាំងពួង ដោយអំណាចនៃឱកាសលោក មិនមានពៀរ ដោយការកម្ចាត់នូវការចង្អៀតចង្អល់ដែលខ្លួនមានក្នុងសត្វដទៃ និងមិនមានសត្រូវ ដោយការកម្ចាត់នូវការចង្អៀតចង្អល់ដែលសត្វដទៃមានក្នុងខ្លួន គប្បីចម្រើន គឺគប្បីឲ្យចម្រើនមេត្តា ដែលមានក្នុងចិត្ត ដែលមិនមានប្រមាណនោះ មិនចង្អៀតចង្អល់ មិនមានពៀរ មិនមានសត្រូវក្នុងលោកទាំងមូល ដោយកំណត់ ៣ យ៉ាង គឺខាងលើ ខាងក្រោម និងខាងទទឹង ។

កាលទ្រង់សម្តែងការចម្រើនមេត្តាភាវនាយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងនូវការមិនមានកំណត់ នូវឥរិយាបថដល់កុលបុត្ត អ្នកតាមប្រកបភាវនានោះ ទើបត្រាស់ថា **តិដ្ឋំ ។បេ។ អធិដ្ឋេយ្យ** ដូច្នេះ ។

គាថានោះ មានអត្ថថា កាលកុលបុត្តចម្រើនមេត្តា ដែលមានក្នុងចិត្តនោះយ៉ាងនេះហើយ មិនធ្វើនូវការកំណត់ឥរិយាបថ ដូចក្នុងប្រយោគជាដើមថា ភិក្ខុនោះអង្គុយពត់ភ្នែន តាំងកាយឲ្យត្រង់ តម្កល់សតិចំពោះមុខ ដូច្នេះធ្វើនូវការបន្ទោបង់នូវការនឿយហត់ក្នុងឥរិយាបថដទៃៗ តាមសប្បាយ ឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី គប្បីជាអ្នកប្រាសចាកនូវការងងុយដរាបណា ក៏គប្បីតាំងសតិក្នុងមេត្តាឈាននេះដរាបនោះ ។

ម្យ៉ាងទៀត កាលត្រាស់សរសើរមេត្តាភាវនាយ៉ាងនេះហើយ ឥឡូវនេះ

កាលទ្រង់សម្ដែងភាពជាអ្នកជំនាញ ទើបត្រាស់ថា **តិដ្ឋញ្ចរំ** ដូច្នេះ ។ កុលបុត្តដែលដល់នូវភាពជាអ្នកជំនាញ ឈរក្ដី ដើរក្ដី រមែងជាអ្នកប្រាថ្នាដើម្បីតាំងសតិក្នុងមេត្តាឈានតាមឥរិយាបថ ។

ម្យ៉ាងទៀត បទថា **តិដ្ឋំ ចរំ និសិន្នោ** បានដល់ ឥរិយាបថទាំងឡាយមានការឈរជាដើម រមែងមិនធ្វើអន្តរាយដល់កុលបុត្តនោះ ដោយពិត កុលបុត្តនោះ រមែងជាអ្នកប្រាថ្នានឹងតម្កល់សតិក្នុងមេត្តាឈាននោះដោយឥរិយាបថដរាបណា រមែងជាអ្នកប្រាសចាកនូវការងោកងុយ តាំងមេត្តាសតិដរាបនោះភាពជាអ្នកមានប្រក្រតីប្រព្រឹត្តយឺតយូរក្នុងមេត្តាឈាននោះ មិនមានដល់កុលបុត្តនោះ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ( បុគ្គលអ្នកចម្រើនមេត្តាចិត្តនោះ ) ទោះឈរក្ដី ដើរក្ដី អង្គុយក្ដី ដេកក្ដី ជាអ្នកមានសេចក្ដីងោកងក់ទៅប្រាសហើយ គឺជាអ្នកមិនដេកលក់អស់កាលត្រឹមណា គួរតម្កល់នូវមេត្តានុស្សតិនុ៎ះ ( អស់កាលត្រឹមនោះ ) ។

គាថានោះ មានអធិប្បាយដូច្នេះ មេត្តាដែលត្រាស់ថា បុគ្គលគួរចម្រើនមេត្តាចិត្ត មិនមានប្រមាណ ជាធម៌មិនចង្អៀត មិនមានពៀរ មិនមានសត្រូវទៅក្នុងលោកទាំងអស់ ដូច្នេះ កុលបុត្តគប្បីចម្រើនមេត្តានោះ ដោយប្រការដែលគប្បីតម្កល់ស្មារតីនោះបាន ក្នុងឥរិយាបថទាំងឡាយ មានការឈរជាដើម ដោយឥរិយាបថឯណានីមួយ ឬដោយប្រការដែលគប្បីតម្កល់ស្មារតីនោះបាន ដរាបមិនប្រកាន់ក្នុងឥរិយាបថទាំងឡាយ មានការឈរជាដើម គប្បី

ជាអ្នកបំណាំងតម្កល់ស្មារតីក្នុងមេត្តាឈាននោះ ។

កាលទ្រង់សម្ដែងភាពជាបុគ្គលជំនាញ ក្នុងការចម្រើនមេត្តាយ៉ាងនេះ ទ្រង់ប្រកបកុលបុត្តក្នុងមេត្តាវិហារនោះថា **ឯតំ សតឹ អធិដ្ឋេយ្យ** ដូច្នេះហើយ ឥឡូវនេះ កាលទ្រង់សរសើរវិហារធម៌នោះ ទើបត្រាស់ថា **ព្រហ្មមេតំ វិហារំ ឥធមាហុ** ប្រែថា បណ្ឌិតទាំងឡាយពោលនូវដំណើរនុ៎ះ ថាជាព្រហ្មវិហារក្នុងសាសនានេះ ដូច្នេះ ។

គាថានោះ មានអត្ថថា មេត្តាវិហារនេះ ដែលព្រះដ៏មានព្រះភាគ ទ្រង់ពណ៌នាហើយ ផ្ដើមអំពីពាក្យថា **សុខិនោ វា ខេមិនោ ហោន្តុ** រហូតដល់ពាក្យថា **ឯតំ សតឹ អធិដ្ឋេយ្យ** បណ្ឌិតទាំងឡាយ ពោលមេត្តាវិហារនោះថាជាព្រហ្មវិហារ គឺពោលថា ធម៌ជាគ្រឿងនៅដ៏ប្រសើរបំផុត ក្នុងធម្មវិន័យរបស់ព្រះអរិយៈនេះ ព្រោះជាធម៌ប្រាសចាកទោសក្នុងទិព្វវិហារ ព្រហ្មវិហារ អរិយ-វិហារ និងឥរិយាបថវិហារទាំង ៤ និងព្រោះជាធម៌ធ្វើប្រយោជន៍ដល់ខ្លួនខ្លះ ដល់សត្វទាំងឡាយដទៃខ្លះ ព្រោះដូច្នោះ កុលបុត្តឈរក្ដី ដើរក្ដី អង្គុយក្ដី ដេកក្ដី ជានិច្ចកាល មិនប្រមូស គប្បីជាអ្នកប្រាសចាកងងុយដរាបណា ក៏គប្បីតាំងសតិនោះដរាបនោះ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងមេត្តាភាវនាដោយប្រការផ្សេងៗ ដល់ភិក្ខុទាំងនោះយ៉ាងនេះហើយ ឥឡូវនេះ ព្រោះមេត្តាជាធម៌ជិតចំពោះអត្ត-ទិដ្ឋិ ព្រោះជាធម៌មានសត្វជាអារម្មណ៍ ព្រោះដូច្នោះ កាលទ្រង់សម្ដែងការ

សម្រេចអរិយភូមិ ធ្វើមេត្តាឈាននោះឯង ឲ្យជាបាទដល់ភិក្ខុទាំងនោះដោយមុខ គឺការរៀតរៀននូវការប្រកាន់ ទើបត្រាស់ គឺឲ្យទេសនាចប់ ដោយព្រះគាថានេះថា **ទិដ្ឋិញ្ច អនុបគម្ម** ដូច្នេះ ។

គាថានោះ មានអត្ថថា មេត្តាឈានវិហារនេះ ដែលព្រះដ៏មានព្រះភាគទ្រង់ពណ៌នាហើយថា បណ្ឌិតទាំងឡាយ ពោលនូវដំណើរនុ៎ះ ថាជាព្រហ្មវិហារក្នុងសាសនានេះ ។ ឯកុលបុត្តចេញអំពីមេត្តាឈានវិហារនោះហើយ កំណត់រូបធម៌ កំណត់អរូបធម៌ តាមទំនងដែលកំណត់ជាដើម នូវធម៌ មានវិតក្ក វិចារជាដើម ក្នុងមេត្តាឈានវិហារនោះ និងមិនចូលទៅអាស្រ័យទិដ្ឋិក្នុងគំនរនៃសង្ខារសុទ្ធៗ ដោយការកំណត់នាម និងរូបយ៉ាងនេះថា បុគ្គលមិនគប្បីបាននូវសត្វ ក្នុងគំនរនៃសង្ខារនេះ ជាអ្នកមានសីល ដោយលោកុត្តរសីល ដោយលំដាប់ ដល់ព្រមហើយដោយទស្សនៈ ពោល គឺសម្មាទិដ្ឋិក្នុងសោតាបត្តិមគ្គ ដែលសម្បយុត្តដោយលោកុត្តរសីល បន្ទាប់អំពីនោះ ការត្រេកអរក្នុងវត្ថុកាមទាំងឡាយនេះ ដែលជាកិលេសកាម មិនទាន់លះបាន គប្បីនាំចេញនូវការត្រេកអរក្នុងកាមទាំងឡាយនោះ ដោយសកទាគាមិមគ្គ និងអនាគាមិមគ្គ និងដោយការលះមិនមានចំណែកសេសសល់ ដោយអានុភាពនៃមគ្គទាំងពីរនោះ កាលនាំចេញហើយ គឺស្ងប់រម្ងាប់ហើយ រមែងមិនដល់ភាពជាសត្វដេកក្នុងគភ៌ទៀត ដោយពិតនោះឯង គឺរមែងមិនដល់នូវការដេកក្នុងគភ៌ទៀត ដោយចំណែកមួយនោះឯង គឺកើតក្នុងសុទ្ធាវាសទាំងឡាយ

ហើយសម្រេចនូវអរហត្ត បរិនិព្វានក្នុងស្ងួវាសនោះឯង ។

ព្រះដ៏មានព្រះភាគ កាលទ្រង់ញ៉ាំងទេសនាឲ្យចប់យ៉ាងនេះហើយ ទើបត្រាស់នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ចូរពួកអ្នកទៅ ចូរនៅក្នុងដងព្រៃនោះ ហើយកាន់យកសូត្រនេះ ចូរគោះជួងប្រជុំគ្នាក្នុងថ្ងៃដែលជាថ្ងៃស្តាប់ធម៌ទាំង ៨ នៃខែ ធ្វើនូវធម្មកថា សាកសួរ អនុមោទនា សេព ចម្រើន ធ្វើឲ្យច្រើននូវកម្មដ្ឋាននេះឯង អមនុស្សទាំងឡាយ នឹងមិនសម្តែងអារម្មណ៍ដែលគួរខ្លាចដល់អ្នកទាំងឡាយ នឹងជាអ្នកប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីអនុគ្រោះដោយពិត ដូច្នោះ ។

ភិក្ខុទាំងនោះ ទទួលពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា សាធុ ក្រោកចាកអាសនៈ អភិវាទព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ទៅកាន់ដងព្រៃនោះហើយ ធ្វើតាមពាក្យប្រៀនប្រដៅនោះ ទេវតាទាំងឡាយគិតថា ព្រះដ៏មានព្រះភាគ ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីអនុគ្រោះដល់ពួកយើង កើតបីតិ និងសោមនស្ស បោសសេនាសនៈឯង រៀបចំទឹកក្តៅ ធ្វើនូវការច្របាច់ខ្នង ច្របាច់ជើង ត្រៀមនូវការរក្សា ភិក្ខុទាំងនោះ ចម្រើនមេត្តាយ៉ាងនោះឯង ធ្វើមេត្តានោះឲ្យជាបាទ ប្រារព្ធវិបស្សនាគ្រប់រូប សម្រេចអរហត្តដែលជាអគ្គផលខាងក្នុង ៣ ខែនោះឯង ធ្វើវិសុទ្ធិបវារណា ក្នុងថ្ងៃមហាបវារណាដូច្នេះឯង ។

កុលបុត្តធ្វើនូវប្រយោជន៍ដែលគួរធ្វើ ដែលព្រះតថាគតជាអ្នក
ឈ្លាសក្នុងប្រយោជន៍ ជាធំក្នុងធម៌ ត្រាស់ហើយយ៉ាងនេះ

កាលធ្វើហើយ គប្បីបានសោយនូវការស្ងប់នៃចិត្តដ៏ក្រៃលែង ជនអ្នកមានបញ្ញាបរិបូណ៌ទាំងឡាយ រមែងបានត្រាស់ដឹងចំពោះសន្តិបទ ព្រោះដូច្នោះ វិញ្ញូជនប្រាថ្នាដើម្បីត្រាស់ដឹងនូវសន្តិបទនោះ ដែលជាអមតៈ គួរអស្ចារ្យ ដែលព្រះអរិយៈប្រាថ្នាហើយ គប្បីធ្វើប្រយោជន៍ដែលគួរធ្វើ មានសីល សមាធិ និងបញ្ញាដែលបរិសុទ្ធ មិនមានមន្ទិលរឿយៗ ដូច្នេះឯង ។ល។

**អដ្ឋកថា មេត្តសូត្រ ចប់**

# សុត្តន្តបិដក

## ហេមវតសូត្រ

[ ១៦ ] *( សាតាគិរយក្សពោលថា ) ថ្ងៃនេះ ជាថ្ងៃឧបោសថទី ១៥ រាត្រីទិព្វប្រាកដហើយ ណ្ហើយចុះ យើងទាំងឡាយនឹងទៅគាល់ព្រះគោតមជាសាស្តា មានព្រះនាមមិនថោកថយ ។*

*( ហេមវតយក្សសួរថា ) ព្រះហឫទ័យ ( របស់ព្រះគោតម ) តាំងនៅល្អ នឹងធឹងក្នុងសត្វទាំងអស់ទេឬ តម្រិះរបស់ព្រះអង្គ បានធ្វើឲ្យស្ទាត់ជំនាញ ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ហើយឬ ។*

*( សាតាគិរយក្សពោលថា ) ព្រះហឫទ័យរបស់ព្រះគោតមនោះ តាំងនៅល្អ នឹងធឹងក្នុងពួកសត្វទាំងអស់ មួយទៀត តម្រិះព្រះអង្គ បានធ្វើឲ្យស្ទាត់ជំនាញក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ហើយ ។*

*( ហេមវតយក្សសួរថា ) ព្រះគោតម មិនកាន់យកវត្ថុដែលគេមិនបានឲ្យទេឬ ព្រះអង្គសង្រួមក្នុងពួកសត្វឬ ឆ្ងាយចាកសេចក្តីប្រមាទឬ មិនបោះបង់ចោលឈានទេឬ ។*

*( សាតាគិរយក្ខពោលថា ) ព្រះគោតមនោះ មិនកាន់យកវត្ថុ ដែលគេមិនបានឲ្យទេ មួយទៀត ព្រះអង្គសង្រួមក្នុងពួកសត្វ ទាំងឆ្ងាយចាកសេចក្តីប្រមាទហើយ ជាព្រះពុទ្ធ មិន*

ប្បោះបង់ឈានចោលឡើយ ។

( ហេមវតយក្សសួរថា ) ព្រះសមណគោតម មិនពោលពាក្យកុហកទេឬ មានគន្លងនៃពាក្យមិនអស់ទេឬ ( មិនពោលផរុសវាចា ) មិនពោលពាក្យញុះញង់ទេឬ មិនពោលពាក្យឥតប្រយោជន៍ទេឬ ។

( សាតាគិរយក្សពោលថា ) ព្រះសមណគោតមនោះមិនពោលពាក្យកុហកទេ មួយទៀត មានគន្លងនៃពាក្យមិនចេះអស់ ទាំងមិនចេះពោលពាក្យញុះញង់ទេ តែងពោលពាក្យមានប្រយោជន៍ដោយបញ្ញា ។

( ហេមវតយក្សសួរថា ) ព្រះពុទ្ធ មិនត្រេកអរក្នុងកាមទេឬ ព្រះហឫទ័យមិនល្អក់ទេឬ ព្រះអង្គកន្លងបង់នូវមោហៈហើយឬ មានបញ្ញាចក្ខុក្នុងធម៌ទាំងឡាយឬ ។

( សាតាគិរយក្សពោលថា ) ព្រះពុទ្ធនោះ មិនត្រេកអរក្នុងកាមទាំងឡាយទេ ទាំងព្រះហឫទ័យសោត ក៏មិនល្អក់ ព្រះអង្គកន្លងបង់នូវមោហៈទាំងអស់ ជាព្រះពុទ្ធ មានបញ្ញាចក្ខុក្នុងធម៌ទាំងឡាយ ។

( ហេមវតយក្សសួរថា ) ព្រះពុទ្ធ បរិបូណ៌ដោយវិជ្ជាឬ មានចរណៈដ៏បរិសុទ្ធប្រពៃឬ អាសវៈទាំងឡាយរបស់ព្រះអង្គ

អស់ហើយឬ ការកើតក្នុងភពថ្មីទៀត មិនមានទេឬ ។

( សាតាគិរយក្សពោលថា ) ព្រះគោតមបរិបូណ៌ដោយវិជ្ជា ទាំងមានចរណៈដ៏បរិសុទ្ធប្រពៃ អាសវៈទាំងអស់ របស់ព្រះអង្គអស់ហើយ ភពថ្មីរបស់ព្រះអង្គមិនមានទៀតឡើយ ។ ព្រះហឫទ័យរបស់ព្រះមុនីបរិបូណ៌ដោយកម្មផង ដោយគន្លងនៃពាក្យផង ណ្ហើយចុះ យើងនឹងទៅគាល់ព្រះគោតម ដែលបរិបូណ៌ដោយវិជ្ជា និងចរណៈ ។

អ្នកចូរមក យើងនឹងទៅគាល់ព្រះគោតម ដែលមានព្រះជង្ឃាដូចជាស្មងនៃសត្វរមាំង មានព្រះកាយស្គម ជាអ្នកប្រាជ្ញ មានអាហារតិច មិនឡេះឡោះ ជាអ្នកស្ងប់ស្ងៀម ដុតកម្តៅកិលេសក្នុងព្រៃ ។

យើងនឹងចូលទៅគាល់ ហើយសួរនូវការរួចចាកអន្ទាក់នៃមច្ចុចំពោះព្រះអង្គជាអ្នកប្រសើរ ត្រាច់ទៅតែម្នាក់ឯងដូចជាសត្វសីហៈ មិនអាឡោះអាល័យក្នុងកាមទាំងឡាយ ។ យើងនឹងសួរនូវព្រះគោតម ជាអ្នកប្រាប់ចង្អុលបង្ហាញ ជាអ្នកដល់នូវត្រើយនៃធម៌ទាំងពួង ជាព្រះពុទ្ធកន្លងបង់នូវពៀរ និងភ័យ ។

( ហេមវតយក្សសួរថា ) សត្វលោក កើតឡើងព្រោះអ្វី ធ្វើសេចក្តីស្និទ្ធស្នាលព្រោះអ្វី សត្វលោកប្រកាន់នូវអ្វី សត្វ

លោកលំបាកព្រោះអ្វី ។

( ព្រះមានព្រះភាគត្រាស់ថា ម្នាលហេមវតៈ ) សត្វលោកកើតឡើងព្រោះវត្ថុ ៦ ធ្វើសេចក្តីស្និទ្ធស្នាលព្រោះវត្ថុ ៦ សត្វលោកប្រកាន់មាំនូវវត្ថុ ៦ សត្វលោកលំបាកព្រោះវត្ថុ ៦ ។

ខ្ញុំព្រះអង្គនឹងសួរនូវផ្លូវជាទីនាំទៅ សូមព្រះអង្គប្រាប់ការប្រកាន់មាំ ដែលនាំឲ្យសត្វលោកលំបាក តើដូចម្តេច សត្វលោកតែងរួចស្រឡះចាកទុក្ខ ដោយប្រការដូចម្តេច ។

កាមគុណ ៥ មានមនោជាគម្រប់ ៦ ក្នុងលោក ដែលតថាគតសម្តែងហើយ សត្វលោកកម្ចាត់បង់ហើយនូវឆន្ទៈ ក្នុងកាមគុណនុ៎ះ តែងរួចស្រឡះចាកទុក្ខយ៉ាងនេះឯង ។ ផ្លូវជាទីនាំទៅនូវសត្វលោកនុ៎ះ តថាគតបានប្រាប់ហើយដល់អ្នកទាំងឡាយតាមពិត តថាគតនឹងប្រាប់នូវផ្លូវនុ៎ះដល់អ្នកទាំងឡាយ សត្វលោក តែងរួចស្រឡះចាកទុក្ខយ៉ាងនេះ ។

ក្នុងលោកនេះ នរណាហ្ន៎ឆ្លងអន្លង់បួនបាន ក្នុងលោកនេះ នរណាហ្ន៎ឆ្លងនូវសមុទ្រ គឺសង្សារបាន នរណាហ្ន៎ មិនលិចចុះក្នុងជម្រៅ គឺសង្សារ ដែលមិនមានទីពឹង មិនមានទីតោង ។

បុគ្គលបរិបូណ៌ដោយសីល មានបញ្ញា មានចិត្តជាសមាធិ ជាអ្នកសម្គាល់នូវត្រៃសិក្ខាក្នុងសន្តាន មានស្មារតីសព្វកាល

រមែងឆ្លងអន្លង់ដែលឆ្លងបានដោយក្រ ( បុគ្គលណា ) វៀរចាកកាមសញ្ញា កន្លងផុតសំយោជនៈទាំងអស់ មានសេចក្តីត្រេកអរក្នុងភពអស់ហើយ បុគ្គលនោះ មិនលិចចុះក្នុងទីជ្រៅគឺសង្សារ ។ អ្នកទាំងឡាយ ចូរមើលបុគ្គលនោះ មានប្រាជ្ញាជ្រាលជ្រៅ ឃើញនូវប្រយោជន៍ដ៏ល្អិត មិនមានកង្វល់ មិនជាប់ជំពាក់ក្នុងកាមភព ផុតស្រឡះចាកកិលេសទាំងពួង អ្នកស្វែងរកប្រយោជន៍ដ៏ធំ ចំពោះកុសលកម្មទាំងឡាយក្នុងផ្លូវដ៏ជាទិព្វ អ្នកទាំងឡាយ ចូរមើលបុគ្គលនោះ ជាអ្នកមានឈ្មោះមិនថយថោក ឃើញនូវប្រយោជន៍ដ៏ល្អិត ឲ្យនូវប្រាជ្ញា មិនជាប់ក្នុងសេចក្តីអាឡោះអាល័យក្នុងកាម ជាអ្នកប្រាជ្ញ ដឹងហេតុសព្វគ្រប់ ស្វែងរកប្រយោជន៍ដ៏ធំចំពោះ កុសលកម្មទាំងឡាយក្នុងផ្លូវដ៏ប្រសើរ ។

ឱហ្ន៎ ថ្ងៃនេះ យើងបានឃើញល្អ ជាពេលភ្លឺស្វាងល្អ ជាពេលនៃអរុណល្អ ពួកយើងបានឃើញព្រះសម្ពុទ្ធ ដែលព្រះអង្គឆ្លងអន្លង់បានហើយ មិនមានអាសវៈ ។ ពួកយក្សទាំងមួយពាន់នាក់នេះ ជាអ្នកមានឫទ្ធិ មានយស ទាំងអស់គ្នា បានដល់នូវព្រះសម្ពុទ្ធនោះជាសរណៈ ព្រះអង្គជាសាស្តាដ៏ប្រសើររបស់យើងខ្ញុំទាំងឡាយ ។ យើងខ្ញុំទាំងនោះ នឹងត្រាច់ទៅកាន់

ស្រុកតូច ស្រុកធំ ភ្នំតូច ភ្នំធំ ក្រាបថ្វាយបង្គំព្រះសម្ពុទ្ធផង នូវសភាពដ៏ល្អរបស់ព្រះធម៌ផង ។

*ហេមវតសូត្រទី ៩ ចប់*

# អដ្ឋកថា

## ហេមវតសូត្រ

[ ១៦ ] ហេមវតសូត្រមានពាក្យផ្ដើមថា **អជ្ជ បណ្ណរសោ** ដូច្នេះ ។ សូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច មានអត្ថុប្បត្តិហេតុដោយអំណាចនៃពាក្យសួរ ។ ពិតហើយ ព្រះដ៏មានព្រះភាគត្រូវហេមវតយក្ខទូលសួរ ទើបត្រាស់ថា **ឆសុ លោកោ សមុប្បន្នោ** ដូច្នេះជាដើម ។

ក្នុងសូត្រនោះ បទថា **អជ្ជ បណ្ណរសោ** ជាដើម សាតាគិរយក្ខជាអ្នកពោលពាក្យថា **ឥតិ សាតាគិរោ** ជាដើម ព្រះសង្គីតិកាចារ្យទាំងឡាយជាអ្នកពោល ។ បទថា **កច្ចិ មនោ** ជាដើម ហេមវតយក្ខជាអ្នកពោល ។ បទថា **ឆសុ លោកោ** ជាដើម ព្រះដ៏មានព្រះភាគទ្រង់ជាអ្នកត្រាស់ ពាក្យទាំងអស់នោះរួមចូលគ្នា ហៅថា **ហេមវតសូត្រ** ។ អាចារ្យពួកខ្លះពោលថា **សាតាគិរសូត្រ** ដូច្នេះក៏មាន ក្នុងសូត្រនោះ គាថាថា **អជ្ជ បណ្ណរសោ** ជាដើម មានអត្ថុប្បត្តិហេតុដូច្នេះថា

ក្នុងកទ្ទកប្បនេះឯង មនុស្សទាំងឡាយបានធ្វើសរីរកិច្ច ដោយការបូជាយ៉ាងធំដល់ព្រះដ៏មានព្រះភាគ សម្មាសម្ពុទ្ធព្រះនាមកស្សបៈ ទ្រង់កើតក្នុងសម័យមនុស្សទាំងឡាយអាយុ ២ ម៉ឺនឆ្នាំ ទ្រង់តម្កល់ព្រះជន្មាយុបាន ១ ម៉ឺន ៦ ពាន់ឆ្នាំហើយ បរិនិព្វាន ។ ព្រះធាតុទាំងឡាយរបស់ព្រះដ៏មានព្រះភាគព្រះនាមកស្សបៈអង្គនោះ មិនខ្ចាត់ខ្ចាយ តាំងនៅជាដុំតែមួយដូចដុំមាសដូច្នោះ ព្រោះជាធម្មតារបស់ព្រះពុទ្ធ ដែលមានព្រះជន្មាយុយឺនយូរទាំងឡាយ ចំណែកព្រះសម្ពុទ្ធដែលមានព្រះជន្មាយុតិច ជនជាច្រើនមិនទាន់ឃើញ ទ្រង់ក៏បរិនិព្វានមុន ព្រោះដូច្នោះ ទើបទ្រង់អធិដ្ឋានថា ចូរព្រះធាតុទាំងឡាយបែកជាបំណែក ដោយទ្រង់អនុគ្រោះថា ជនទាំងឡាយក្នុងទីនោះៗ សូម្បីធ្វើការបូជាព្រះធាតុហើយ នឹងជួបនូវគំនរបុណ្យ ដោយហេតុនោះ ព្រះធាតុទាំង-ឡាយរបស់ព្រះពុទ្ធ ដែលមានព្រះជន្មាយុតិចប៉ុណ្ណោះ ទើបបែកខ្ទេកទៅដូចកម្ទេចនៃមាស ដូចជាព្រះធាតុទាំងឡាយ របស់ព្រះដ៏មានព្រះភាគនៃយើងដូច្នោះ ។

មនុស្សទាំងឡាយ បានធ្វើផ្ទះបញ្ចុះព្រះធាតុរបស់ព្រះដ៏មានព្រះភាគអង្គនោះ ឲ្យមានកន្លែងតែមួយប៉ុណ្ណោះ ឲ្យប្រតិស្ឋានព្រះចេតិយដោយចំណែកនៃកម្ពស់ និងជុំវិញ ១ យោជន៍ ។ ព្រះចេតិយនោះមានទ្វារ ៤ ទ្វារនីមួយៗឆ្ងាយអំពីគ្នា ១ គាវុត ព្រះបាទកឹកិរាជ ទ្រង់សាងមួយមុខ ព្រះឱរសរបស់ព្រះអង្គព្រះនាមបឋវិន្ធរៈ ទ្រង់សាងមួយមុខ អមាត្យដែលជាធំជាងសេនាបតី

ទាំងឡាយសាងមួយមុខ អ្នកជនបទ មានសេដ្ឋីជាប្រធានសាងមួយមុខ ។ ឥដ្ឋមួយដុំសម្រេចដោយមាស និងសម្រេចដោយរតនៈផ្សេងៗ ប្រៀបធៀបដោយតម្លៃនៃមាស មួយដុំមានតម្លៃ ១ សែនកហាបណៈ ។ មនុស្សទាំងនោះបានប្រើហរតាល និងមនោសិលាទាំងឡាយជំនួសដីឥដ្ឋ និងប្រើប្រេងក្រអូបជំនួសទឹក ប្រតិស្ឋានចេតិយនោះ ។

កាលព្រះចេតិយប្រតិស្ឋានយ៉ាងនេះហើយ កុលបុត្តពីរនាក់ជាសម្លាញ់នឹងគ្នា ចេញបួសក្នុងសម្នាក់មហាសាវកទាំងឡាយ ។ ពិតហើយ មហាសាវកទាំងឡាយរបស់ព្រះពុទ្ធ ដែលមានព្រះជន្មាយុវែងប៉ុណ្ណោះ រមែងឲ្យបព្វជ្ជា ឲ្យឧបសម្បទា ឲ្យនិស្ស័យ សាវកទាំងឡាយក្រៅអំពីនេះ មិនបានឡើយ ។ បន្ទាប់អំពីនោះ កុលបុត្តទាំងនោះសួរថា បពិត្រលោកម្ចាស់ ក្នុងសាសនាមានធុរៈប៉ុន្មាន ព្រះថេរៈពោលថា ធុរៈមាន ២ យ៉ាង គឺវាសធុរៈ ១ បរិយត្តិធុរៈ ១ ក្នុងធុរៈ ២ យ៉ាងនោះ កុលបុត្តដែលបួសហើយ នៅក្នុងសម្នាក់របស់អាចារ្យ និងឧបជ្ឈាយ៍អស់ ៥ ឆ្នាំ បំពេញវត្ត និងបដិបត្តិ ធ្វើបាតិមោក្ខនិងសូត្រក្នុងភាណវារ ២-៣ សូត្រ ឲ្យស្ទាត់ជំនាញហើយ រៀនកម្មដ្ឋានចូលកាន់ព្រៃដោយមិនមានអាល័យក្នុងត្រកូល ឬគណៈ បន្តព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត នេះឈ្មោះថា **វាសធុរៈ** ។ ចំណែកកុលបុត្តរៀន ១ នូវនិកាយ ២ និកាយ ឬ ៥ និកាយ តាមកម្លាំងរបស់ខ្លួន គប្បីតាមប្រកបសាសនាឲ្យបរិសុទ្ធល្អដោយបរិយត្តិ និងដោយអត្ថ នេះហៅថា **បរិយត្តិធុរៈ** ។

លំដាប់នោះ កុលបុត្តទាំងនោះពោលថា បណ្ដាធុរៈពីរយ៉ាង វាសធុរៈប៉ុណ្ណោះប្រសើរ ។ គិតថា ពួកយើងនៅក្មេង នឹងបំពេញវាសធុរៈកាលឯចាស់ យើងនឹងបំពេញបរិយត្តិធុរៈជាមុន ទើបប្រារព្ធបរិយត្តិ ។ ភិក្ខុទាំងពីរ ដោយប្រក្រតីជាអ្នកមានបញ្ញា ក្នុងកាលមិនយូរប៉ុន្មាន ក៏មានការដឹងដែលធ្វើហើយក្នុងពុទ្ធវចនៈទាំងមូល និងជាអ្នកឈ្លាសក្នុងការវិនិច្ឆ័យក្នុងវិន័យក្រៃលែង ភិក្ខុទាំងពីរនោះព្រោះអាស្រ័យបរិយត្តិ ក៏មានបរិវារកើតឡើង ព្រោះអាស្រ័យបរិវារទើបមានលាភ ភិក្ខុមួយរូបមានភិក្ខុ ៥០០ ជាបរិវារ ភិក្ខុទាំងនោះសម្ដែងនូវសាសនារបស់ព្រះសាស្ដា ដូចពុទ្ធកាលទៀត ។

ក្នុងកាលនោះ ភិក្ខុ ២ រូប គឺធម្មវាទីភិក្ខុ ១ អធម្មវាទីភិក្ខុ ១ នៅក្នុងវត្តក្បែរស្រុក ព្រះអធម្មវាទីជាភិក្ខុកាច គ្រោតគ្រាត មាត់រឹង អជ្ឈាចាររបស់អធម្មវាទីនោះ ប្រាកដដល់ព្រះធម្មវាទីក្រៅអំពីនេះ ។ ព្រះធម្មវាទីជាស់តឿនព្រះអធម្មវាទីនោះថា អាវុសោ កម្មរបស់លោកនេះមិនសមគួរដល់សាសនា អធម្មវាទីភិក្ខុជំទាស់ថា លោកឃើញអ្វី លោកឮអ្វី ព្រះធម្មវាទីពោលថា វិនយធរទាំងឡាយនឹងដឹង បន្ទាប់អំពីនោះ អធម្មវាទីភិក្ខុដឹងថា បើព្រះវិនយធរទាំងឡាយវិនិច្ឆ័យរឿងនេះសោត ទីពឹងរបស់អញក្នុងសាសនា នឹងមិនមានពិត បំណងនឹងធ្វើជាបក្ខពួករបស់ខ្លួន ទើបកាន់យកបរិក្ខារទាំងឡាយចូលទៅរកព្រះថេរៈពីររូបនោះ ប្រគេនសមណបរិក្ខារ ប្រារព្ធដើម្បីនៅ គឺសូមនិស្ស័យចំពោះព្រះថេរៈទាំងនោះ ហើយបានធ្វើការទំនុកបម្រុងដល់ព្រះថេរៈទាំងនោះ

ដូចបំណាង ដើម្បីបំពេញវត្ត និងបដិបត្តិដោយគោរព ។

បន្ទាប់អំពីនោះ ថ្ងៃមួយ ព្រះអធម្មវាទីទៅកាន់ទីបម្រើ ថ្វាយបង្គំហើយ សូម្បីព្រះថេរៈទាំងនោះអនុញ្ញាតឲ្យទៅ ក៏នៅតែឈរនោះឯង ទើបព្រះថេរៈទាំងឡាយសួរអធម្មវាទីភិក្ខុនោះថា មានអ្វីគប្បីនិយាយឬ អធម្មវាទីភិក្ខុនោះពោលថា បពិត្រលោកម្ចាស់ មាន ខ្ញុំឈ្មោះគ្មានីងភិក្ខុមួយរូប ព្រោះអាស្រ័យអជ្ឈាចាររបស់ខ្ញុំ បើភិក្ខុនោះមកទីនេះ ប្រាប់រឿងនោះសោត សូមកុំវិនិច្ឆ័យតាមវិនិច្ឆ័យ ព្រះថេរៈទាំងឡាយពោលថា ការមិនវិនិច្ឆ័យរឿងដែលកើតតាមដែលគួរវិនិច្ឆ័យមិនគួរ អធម្មវាទីភិក្ខុនោះពោលថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ ធ្វើការវិនិច្ឆ័យយ៉ាងនោះ ខ្ញុំនឹងមិនមានទីពឹងក្នុងសាសនា អំពើអាក្រក់នោះ លើកលែងឲ្យដល់ខ្ញុំចុះ សូមលោកម្ចាស់ទាំងឡាយកុំវិនិច្ឆ័យរឿងនោះ ព្រះវិនយធរទាំងនោះ ត្រូវអធម្មវាទីបៀតបៀន ទើបព្រមទទួល អធម្មវាទីភិក្ខុនោះទទួលបដិញ្ញារបស់ព្រះវិនយធរទាំងនោះហើយ ទៅកាន់អាវាសនោះទៀតពោលថា រឿងទាំងអស់ ខ្ញុំចាត់ចែងស្រេចបាច់ហើយ ក្នុងសម្នាក់របស់ព្រះវិនយធរទាំងឡាយ មើលងាយព្រះធម្មវាទីនោះខ្លាំងឡើង ពោលពាក្យទ្រគោះ ។

ព្រះធម្មវាទីគិតថា អធម្មវាទីនេះមានទីពឹងអាស្រ័យ ទើបចេញទៅរកភិក្ខុមួយពាន់រូប ដែលជាបរិវាររបស់ព្រះថេរៈទាំងឡាយ ពោលថា អាវុសោទាំងឡាយ ព្រះថេរៈគួរវិនិច្ឆ័យរឿងដែលកើតឡើងតាមធម៌មិនមែនឬ ឬឲ្យ

រំពឹកមិនបាន ឲ្យសម្តែងការល្មើសដល់គ្នានិងគ្នាហើយ គប្បីធ្វើនូវសាមគ្គី ព្រះថេរៈទាំងនេះមិនវិនិច្ឆ័យរឿងឡើយ មិនធ្វើនូវសាមគ្គី នុ៎ះមានរឿងអ្វី ចំណែកភិក្ខុទាំងនោះស្តាប់ហើយក៏នៅស្ងៀម ដោយគិតថា រឿងទាំងនេះ អាចារ្យទាំងឡាយដឹងហើយ មិនមែនឬ បន្ទាប់អំពីនោះ អធម្មវាទីភិក្ខុបានឱកាស ទើបបៀតបៀនព្រះធម្មវាទីនោះថា ក្នុងកាលមុនលោកពោលថា ព្រះវិនយធរទាំងឡាយនឹងដឹងឥឡូវនេះ ចូរលោកប្រាប់រឿងនោះ ដល់ព្រះវិនយធរទាំងនោះហើយពោលថា លោកចាញ់ហើយ ចាប់អំពីថ្ងៃនេះទៅ កុំមកកាន់អាវាសនេះដូច្នេះ ក៏ចៀសចេញទៅ ។ បន្ទាប់អំពីនោះ ព្រះធម្មវាទីចូលទៅរកព្រះថេរៈទាំងឡាយ ពោលថា លោកម្ចាស់ទាំងឡាយ មិនពិចារណាដល់សាសនា ពិចារណាតែបុគ្គលថា លោកចូរបម្រើពួកយើង ចូរឲ្យពួកយើងត្រេកអរ មិនរក្សាព្រះសាសនា តែរក្សាបុគ្គល តាំងអំពីថ្ងៃនេះជាដើមទៅ លោកម្ចាស់ទាំងឡាយមិនគួរពិចារណានូវវិនិច្ឆ័យ ព្រះដ៏មានព្រះភាគព្រះនាមកស្សបៈ ទ្រង់រម្លត់ខន្ធបរិនិព្វានហើយក្នុងថ្ងៃនេះ ដូច្នេះហើយ ស្រែកយំដោយសំឡេងខ្លាំងខ្សឹកខ្សួលថា សាសនារបស់ព្រះសាស្តា វិនាសហើយ ក៏ចៀសចេញទៅ ។

លំដាប់នោះឯង ភិក្ខុទាំងនោះសង្វេគ កើតសេចក្តីរង្កៀសថា ពួកយើងរក្សាបុគ្គល បោះបោលរតនៈ គឺសាសនាចូលក្នុងជ្រោះ លោកទាំងនោះដល់ហើយ ប្រកបហើយដោយការរង្កៀសនោះឯង ពួកលោកធ្វើកាលកិរិយាហើយ មិនអាចកើតក្នុងស្ថានសួគ៌ អាចារ្យមួយរូបកើតក្នុងហេមវតបព៌ត ក្នុងហិមវន្ត-

ប្បទេស ជាយក្ខឈ្មោះហេមវតៈ អាចារ្យមួយរូបទៀត កើតក្នុងសាតបព៌ត ក្នុងមជ្ឈិមប្បទេស ជាយក្ខឈ្មោះសាតាគិរៈ ចំណែកភិក្ខុទាំងនោះ ជាបរិវារ របស់អាចារ្យទាំងពីរនោះ បដិបត្តិតាមអាចារ្យទាំងនោះ មិនអាចកើតក្នុង ស្ថានសួគ៌ កើតជាយក្ខបរិវាររបស់យក្ខទាំងពីរនោះ ឯគ្រហស្ថទាំងឡាយ ដែលប្រគេនបច្ច័យដល់ភិក្ខុទាំងនោះ កើតក្នុងទេវលោក ។

ហេមវតយក្ខ និងសាតាគិរយក្ខ ជាយក្ខមានអានុភាពច្រើនក្នុងចំណោម សេនាបតីយក្ខទាំង ២៨ រូប ។ ធម្មតាសេនាបតីយក្ខទាំងឡាយ គឺទេវតា ទាំងឡាយប្រជុំគ្នាក្នុងកគលវតិមណ្ឌប លើផ្ទៃមនោសិលាក្នុងហិមវន្តប្បទេស ដើម្បីវិនិច្ឆ័យធម៌ មួយខែ ៨ ថ្ងៃ ។ សេនាបតីយក្ខទាំងឡាយ គប្បីប្រជុំគ្នា ត្រង់មណ្ឌបនោះ ក្នុងខណៈនោះ សាតាគិរយក្ខ និងហេមវតយក្ខជួបគ្នាត្រង់ សមាគមនោះ ចាំបានហើយ សួរដល់ទីកើតរបស់ខ្លួនថា នែសម្លាញ់ ឯងកើត ក្នុងទីណា ឯងកើតក្នុងទីណា ជាអ្នកក្តៅក្រហាយថា នែសម្លាញ់ ពួកយើង វិនាសហើយ ក្នុងកាលមុនពួកយើងធ្វើសមណធម៌អស់ ២ ម៉ឺនឆ្នាំ អាស្រ័យ សម្លាញ់អាក្រក់ម្នាក់ កើតក្នុងកំណើតយក្ខ ទាយកអ្នកឲ្យបច្ច័យទាំងឡាយរបស់ ពួកយើង កើតក្នុងកាមាវចរទេវតា ។ លំដាប់នោះ សាតាគិរយក្ខពោលនឹង ហេមវតយក្ខនោះថា នែលោកនិរទុក្ខ ធម្មតាហិមវន្តល្បីថា មានភាពអស្ចារ្យ បើឯងឃើញ ឬឮនូវភាពអស្ចារ្យណាមួយ គប្បីប្រាប់ដល់គ្នាផង ចំណែក ហេមវតយក្ខក៏ពោលថា អើអ្នកនិរទុក្ខ ធម្មតាមជ្ឈិមប្បទេសល្បីថា មានភាព

អស្ចារ្យ បើឯងឃើញ ឬពួនូវភាពអស្ចារ្យណាមួយ គប្បីប្រាប់ដល់គ្នាផង ។

កាលសម្លាញ់ទាំងពីរនោះធ្វើកតិកានឹងគ្នាហើយ មិនលះហេតុនោះយ៉ាងនេះ ពុទ្ធន្តរមួយក៏កន្លងទៅ មហាប្រឹថពីក៏ដុះឡើងប្រមាណមួយយោជន៍ ៣ គាវុត ។

ក្នុងកាលនោះ ព្រះពោធិសត្វនៃយើង មានបណិធានដែលខ្លួនធ្វើហើយ ទៀបបាទមូលរបស់ព្រះពុទ្ធទីបង្ករ បំពេញបារមីទាំងឡាយ រហូតដល់កើតជាវេស្សន្តរហើយ កើតក្នុងជាន់តុសិត តាំងនៅក្នុងជាន់តុសិតនោះដរាបដល់អស់អាយុ កាលទេវតាទាំងឡាយអារាធនា ដោយន័យដែលពោលហើយក្នុងធម្មបទនិទាននោះឯង សម្លឹងមើលមហាវិលោកនៈ ៥ យ៉ាង ប្រាប់ដល់ទេវតាទាំងឡាយ កាលបុព្វនិមិត្ត ៣២ ប្រការប្រព្រឹត្តទៅ បានបដិសន្ធិក្នុងលោកនេះ ញ៉ាំងលោកធាតុមួយម៉ឺនឲ្យញាប់ញ័រ យក្ខទាំងនេះ ទោះបីឃើញបុព្វនិមិត្តទាំងនោះ ក៏មិនដឹងថា កើតព្រោះហេតុនេះ អាចារ្យពួកខ្លះពោលថា មិនបានឃើញ ព្រោះយក្ខទាំងនោះរវល់តែលេង ។ ក្នុងការប្រសូតិ ការចេញអភិនិស្ក្រមណ៍ និងការត្រាស់ដឹងក៏ន័យនេះ ។

កាលព្រះដ៏មានព្រះភាគត្រាស់ហៅបញ្ចវគ្គិយ ប្រកាសធម្មចក្កដ៏ប្រសើរ មានបរិវដ្ត ៣ មានអាការ ១២ ឲ្យប្រព្រឹត្តទៅក្នុងកាលប្រកាសធម្មចក្ក បណ្ដាសម្លាញ់ទាំងពីរនោះ សាតាគិរយក្ខប៉ុណ្ណោះ បានឃើញមហាប្រឹថពីញាប់ញ័របុព្វនិមិត្ត និងបាដិហារ្យ និងដឹងហេតុនៃការកើតឡើងនៃវត្ថុទាំងនោះ មួយអន្លើ

ដោយបរិស័ទ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ស្តាប់ធម្មទេសនា តែក៏មិនសម្រេចគុណវិសេសអ្វីឡើយ ។ ព្រោះហេតុអ្វី ព្រោះយក្ខនោះ ស្តាប់ធម៌ រវល់តែគិតដល់ហេមវតយក្ខ សម្លឹងមើលបរិស័ទថា សម្លាញ់របស់យើងមកហើយឬ កាលមិនឃើញ ទើបមានចិត្តរាយមាយថា សម្លាញ់របស់អញមិនបានស្តាប់ព្រះធម្មទេសនារបស់ព្រះដ៏មានព្រះភាគ ដែលមានបដិភាណវិចិត្រយ៉ាងនេះ ក៏នឹងល្ងង់ខ្លៅ ព្រះដ៏មានព្រះភាគ កាលព្រះអាទិត្យអស្តង្គតហើយ ក៏មិនបញ្ចប់ព្រះធម្មទេសនា ។ ខណៈនោះ សាតាគិរយក្ខគិតថា អញនឹងទៅនាំសម្លាញ់ ហើយមកជាមួយសម្លាញ់នោះស្តាប់ធម្មទេសនា បាននិមិត្តយានទាំងឡាយ មានសេះ ដំរី និងគ្រុឌជាដើម ដែលយក្ខ ៥០០ ចោមរោមហើយ មានមុខទៅកាន់ហិមវន្តប្បទេស ។

ខណៈនោះ ហេមវតយក្ខ ព្រោះហេតុដែលបុព្វនិមិត្ត ៣២ ប្រការ ក្នុង ( កាល ) បដិសន្ធិ ប្រសូត អភិនិក្ខ្រមណ៍ ត្រាស់ដឹង និងបរិនិព្វាននោះឯងបាត់ទៅ មិនតាំងនៅបានយូរ តែក្នុងកាលប្រកាសធម្មចក្ក ហេតុការណ៍ទាំងនោះ មានពិសេសតាំងនៅបានយូរ ព្រោះហេតុនោះ ទើបហេមវតយក្ខឃើញការប្រាកដនៃភាពអស្ចារ្យនោះ ក្នុងហិមវន្តប្បទេស គឺឃើញថា តាំងពីអញកើតមក ភ្នំនេះ មិនធ្លាប់ជាទីត្រេកអរយ៉ាងនេះ ក្នុងកាលណាឡើយ ណ្ហើយចុះ ឥឡូវនេះ អញនឹងនាំសម្លាញ់របស់អញ មកមើលសិរីនៃផ្កាទាំងនេះជាមួយសម្លាញ់នោះ ទើបបែរមុខមកកាន់មជ្ឈិមប្បទេស ។ យក្ខទាំងពីរ

នោះ មកជួបគ្នាខាងលើក្រុងរាជគ្រឹះ បានសួរដល់ហេតុក្នុងការមកនៃគ្នានិងគ្នា ហេមវតយក្ខពោលថា នែអ្នកនិរទុក្ខ តាំងពីយើងកើតមក ភ្នំនេះមិនធ្លាប់ជាទីត្រេកអរ ដោយដើមឈើទាំងឡាយ ដែលរីកស្គុសស្គាយដោយផ្កាពុំជូកាលយ៉ាងនេះឡើយ ព្រោះហេតុនោះ ទើបខ្ញុំមកដោយគិតថា នឹងសរសើរសិរីនៃផ្កាជាមួយឯង សាតាគិរយក្ខពោលថា នែអ្នកនិរទុក្ខ ឯងដឹងហេតុការណ៍ ដែលជាហេតុឲ្យកើតបាដិហារ្យ ឲ្យផ្ការីកពុំជូកាលដែរឬ ហេមវតៈពោលថា នែអ្នកនិរទុក្ខ ខ្ញុំមិនដឹងឡើយ សាតាគិរយក្ខពោលថា នែអ្នកនិរទុក្ខ បាដិហារ្យនេះ មិនមែនកើតក្នុងហិមវន្តតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត កើតក្នុងម៉ឺនលោកធាតុ ព្រះសម្មាសម្ពុទ្ធទ្រង់កើតហើយក្នុងលោក ទ្រង់ប្រកាសធម្មចក្កឲ្យប្រព្រឹត្តទៅក្នុងថ្ងៃនេះ ដោយហេតុនោះ ទើបបាដិហារ្យកើតឡើង ។

សាតាគិរយក្ខ ពោលដល់ការកើតនៃព្រះពុទ្ធ ដល់ហេមវតយក្ខយ៉ាងនេះហើយ បំណងនាំយកហេមវតយក្ខនោះ មកកាន់សម្នាក់របស់ព្រះដ៏មានព្រះភាគ ទើបពោលគាថានេះ អាចារ្យពួកខ្លះពោលថា កាលព្រះដ៏មានព្រះភាគគង់នៅក្នុងគោតមកចេតិយ ទើបសាតាគិរយក្ខនេះ ពោលយ៉ាងនេះថា **អជ្ជ បណ្ណរសោ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អជ្ជ** បានដល់ យប់ និងថ្ងៃ នេះជាថ្ងៃ ១៥ តាមបក្ខគណនា ជាថ្ងៃឧបោសថ ព្រោះជាថ្ងៃគប្បីនៅចាំ ឬក្នុងឧបោសថទាំង

៣ ថ្ងៃនេះជាឧបោសថទី ១៥ មិនមែនឧបោសថទី ១៤ មិនមែនសាមគ្គីឧបោសថ ។ ព្រោះ **ឧបោសថ** សព្ទ រមែងប្រព្រឹត្តទៅក្នុងអត្ថច្រើនយ៉ាង មានបាតិមោក្ខុទ្ទេស អង្គ ៨ ឧបវាសបញ្ញត្តិ និងថ្ងៃជាដើម ។

ពិតហើយ **ឧបោសថ** សព្ទ ប្រព្រឹត្តទៅក្នុងបាតិមោក្ខុទ្ទេស ដូចក្នុងប្រយោគជាដើមថា **អាយាមាវុសោ កប្បិន ឧបោសថំ គមិស្សាម** មកអាវុសោកប្បិន ពួកយើងនឹងទៅកាន់ឧបោសថ ដូច្នេះ ។

ប្រព្រឹត្តទៅក្នុងអង្គ ៨ មានចេតនាវៀរចាកបាណាតិបាតជាដើម ដូចក្នុងប្រយោគជាដើមថា **ឯវំ ខោ អដ្ឋង្គសមន្នាគតោ វិសាខេ ឧបោសថោ ឧបវុត្ថោ** ម្នាលវិសាខា ឧបោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ ដូច្នេះ ។

ប្រព្រឹត្តទៅ ក្នុងឧបវាសៈ ដូចក្នុងប្រយោគជាដើមថា **សុទ្ធស្ស វេ សទា ផគ្គុ សុទ្ធស្សុបោសថោ សទា** ផគ្គុណឫក្សតែងមានសព្វៗ កាលដល់បុគ្គលដែលបរិសុទ្ធ ឧបោសថតែងមានសព្វៗ កាល ដល់បុគ្គលដែលបរិសុទ្ធ ដូច្នេះ ។

ប្រព្រឹត្តទៅក្នុងបញ្ញត្តិ ក្នុងប្រយោគជាដើមថា **ឧបោសថោ នាម នាគរាជា** ស្តេចដំរីឈ្មោះឧបោសថ ដូច្នេះ ។

ប្រព្រឹត្តទៅក្នុងថ្ងៃ ដូចក្នុងប្រយោគជាដើមថា **តទហុបោសថេ បណ្ណរសេ សីសនហាតស្ស ឧបោសថិកស្ស ឧបរិបាសាទវរគតស្ស** កក់ព្រះ

កេសា សមាទានឧបោសថ ហើយស្តេចទៅខាងលើប្រាសាទដ៏ប្រសើរ ក្នុងថ្ងៃទី ១៥ ដែលជាថ្ងៃឧបោសថនោះ ដូច្នេះ ។ ព្រោះហេតុនោះ សាតាគិរយក្ខយាត់អត្ថដ៏សេស កំណត់ថ្ងៃពេញបូណ៌មី ១៥ កើត នៃខែអាសាឍប៉ុណ្ណោះ ទើបពោលថា ថ្ងៃនេះជាថ្ងៃឧបោសថទី ១៥ ដូច្នេះ អធិប្បាយថា កាលរាប់ថ្ងៃយ៉ាងនេះថា ថ្ងៃទី ២ ជាថ្ងៃបាដិបទ ថ្ងៃនេះជាថ្ងៃឧបោសថទី ១៥ ដូច្នេះ ។

ឈ្មោះថា **ទិព្វា រត្តិ** ព្រោះអត្ថថា មានភាពជាទិព្វ វត្ថុដែលជាទិព្វទាំងឡាយ មានក្នុងរាត្រីនេះ ព្រោះហេតុនោះ ទើបរាត្រីនោះ ឈ្មោះថាជាទិព្វ ។ រាត្រីដែលជាទិព្វនោះដូចម្តេច ពិតហើយ ក្នុងរាត្រីនោះ ជម្ពូទ្វីបទាំងមូល ប្រដាប់ហើយដោយពន្លឺនៃរាងកាយ សំពត់ អាភរណៈ និងវិមានរបស់ទេវតាទាំងឡាយ ដែលមកប្រជុំអំពីម៉ឺនលោកធាតុ និងពន្លឺនៃព្រះចន្ទ ដែលរៀរគ្រឿងសៅហ្មង មានពពកជាដើម និងតាក់តែងជាពិសេសដោយពន្លឺនៃព្រះវរកាយរបស់ព្រះដ៏មានព្រះភាគ ដែលជាវិសុទ្ធិទេពយ៉ាងក្រៃលែង ដោយហេតុនោះ ទើបសាតាគិរយក្ខពោលថា រាត្រីទិព្វប្រាកដហើយ ដូច្នេះ ។

សាតាគិរយក្ខ កាលញុំាងនូវសេចក្តីជ្រះថ្លានៃចិត្ត ឲ្យកើតដល់សម្លាញ់ ដោយការអាងដល់ពណ៌នាគុណ នៃរាត្រីយ៉ាងនេះហើយ ពោលដល់ការកើតឡើងនៃព្រះពុទ្ធ ទើបពោលថា ណ្ហើយចុះ យើងទាំងឡាយនឹងទៅគាល់ព្រះគោតមជាសាស្តា មានព្រះនាមមិនថោកថយ ដូច្នេះ ។

ក្នុងគាថានោះ ឈ្មោះថា **អនោមនាមំ** ព្រោះអត្ថថា ទ្រង់មានព្រះនាម

ដោយព្រះគុណទាំងឡាយ ដែលមិនថោកថយ គឺមិនអាក្រក់ បរិបូណ៌ ដោយអាការទាំងពួង ។ ពិតហើយ ទ្រង់មានព្រះនាមដោយព្រះគុណទាំងឡាយ ដែលមិនថោកថយថា **ពុទ្ធោ** ដោយន័យជាដើមថា ព្រះនាមថា ព្រះពុទ្ធ ព្រោះហេតុព្រះអង្គត្រាស់ដឹងសច្ចៈទាំងឡាយ ព្រះនាមថា ព្រះពុទ្ធ ព្រោះហេតុព្រះអង្គញ៉ាំងពួកសត្វឲ្យត្រាស់ដឹង ដូច្នេះ ។ និងទ្រង់មានព្រះនាមដោយព្រះគុណមិនថោកថយ ដោយន័យជាដើមថា មួយទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះហេតុទ្រង់កាច់បំបាក់ចោលនូវភគៈ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះហេតុទ្រង់កាច់បំបាក់ចោលនូវទោសៈ ដូច្នេះ ។ ក្នុងព្រះគុណទាំងឡាយ មាន **អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ** ជាដើមក៏ន័យនេះ ។ ឬព្រះអង្គទ្រង់ទូន្មានទេវតា និងមនុស្សទាំងឡាយ ក្នុងប្រយោជន៍ទាំងឡាយ មានទិដ្ឋធម្មិកត្ថប្រយោជន៍ជាដើមថា ចូរលះវត្ថុនេះ ចូរសមាទានប្រព្រឹត្តវត្ថុនេះ ព្រោះដូច្នោះ ទើបទ្រង់ជាព្រះសាស្តា ម្យ៉ាងទៀត បុគ្គលជាព្រះសាស្តាដោយន័យដែលពោលហើយ ក្នុង ( មហា ) និទ្ទេសថា ពាក្យថា ព្រះសាស្តា គឺព្រះមានព្រះភាគជាអ្នកនាំពួក ។ នាយពួក ញ៉ាំងពួកទាំងឡាយឲ្យឆ្លងផុតវាលំបាក ... ជាដើម ។ ទ្រង់ជាព្រះសាស្តា មានព្រះនាមមិនថោកថយនោះ ។

សព្ទថា **ហន្ទ** ជានិបាត ចុះក្នុងអត្ថថា អាភជនា ។ បទថា **បស្សាម** ជាការពោលដល់បច្ចុប្បន្នកាល សង្គ្រោះចូលជាមួយហោមវតយក្ខនោះជាមួយ

នឹងខ្ជួន ។ បទថា **គោតមំ** បានដល់ មានគោត្រថាគោតម ។ សេចក្តីនេះ មានអធិប្បាយដូចម្តេច មានអធិប្បាយថា អ្នកកុំសង្ស័យថា ជាព្រះសាស្តា ឬមិនមែនជាព្រះសាស្តា គឺលះចោលនូវសេចក្តីសង្ស័យ មកពួកយើងទៅគាល់ព្រះគោតម ។

កាលសាតាគិរយក្ខពោលយ៉ាងនេះហើយ ហេមវតយក្ខគិតថា សាតា-គិរយក្ខនេះ កាលពោលថា បុគ្គលជាព្រះសាស្តាមានព្រះនាមមិនថោកថយឈ្មោះថា ប្រកាសនូវភាពដែលព្រះគោតមនោះជាសព្វញ្ញូ ហើយសព្វញ្ញូទាំងឡាយរកបានដោយក្រក្នុងលោក លោកត្រូវបុគ្គលប្តេជ្ញាថាជាសព្វញ្ញូ ដូចគ្នានឹងបូរណៈជាដើមនោះឯងទម្លាយហើយ បើព្រះគោតមនោះជាសព្វញ្ញូសោតនឹងជាអ្នកដល់នូវលក្ខណៈរបស់តាទិបុគ្គលពិត ដោយហេតុនោះ អញនឹងពិចារណាព្រះគោតមនោះយ៉ាងនេះ កាលនឹងសួរដល់លក្ខណៈនៃបុគ្គលនឹងធឹងទើបពោលថា **កច្ចិ មនោ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កច្ចិ** ជាពាក្យសួរ ។ បទថា **មនោ** បានដល់ ចិត្ត ។ បទថា **សុបណិហិតោ** សេចក្តីថា តាំងមាំហើយដោយល្អ គឺមិនញាប់ញ័រ បានដល់ មិនឃ្លៀងឃ្លាត ។ បទថា **សព្វភូតេសុ** បានដល់ ក្នុងភូតទាំងពួង ។ បទថា **តាទិនោ** បានដល់ ជាអ្នកដល់នូវលក្ខណៈ ជាបុគ្គលនឹងធឹងនោះឯង ។ ឬគាថានេះ ជាពាក្យសួរប៉ុណ្ណោះថា នឹងធឹងក្នុងសត្វទាំងអស់ទេឬ ដូច្នេះ ។

បទថា **ឥដ្ឋេ អនិដ្ឋេ ច** សេចក្តីថា ក្នុងអារម្មណ៍បែបនោះ ។ បទថា **សង្កប្បា** បានដល់ វិតក្ក ។ បទថា **វសីកតា** បានដល់ ទៅកាន់អំណាច ។ មានអធិប្បាយដូចម្តេច មានអធិប្បាយថា ឯងពោលដល់ព្រះសាស្តាណា ព្រះហឫទ័យរបស់ព្រះសាស្តារបស់ឯងនោះ ដល់នូវលក្ខណៈនៃតាទិបុគ្គលល្អហើយក្នុងសត្វទាំងពួងឬ ឬប្រាកដដូចតាំងល្អហើយ ដរាបមិនទាន់បានបច្ច័យ ដែលជាគ្រឿងឲ្យញាប់ញ័រឬ ព្រះសាស្តារបស់ឯងនោះ ជាតាទិបុគ្គលដោយព្រះហឫទ័យស្មើក្នុងសត្វទាំងពួងនោះឬ ឯការត្រិះរិះដោយអំណាចនៃរាគៈ និងទោសៈទាំងឡាយណា គប្បីកើតឡើងក្នុងអារម្មណ៍ទាំងឡាយដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា ព្រះសាស្តារបស់ឯងនោះ ទ្រង់ធ្វើសេចក្តីត្រិះរិះទាំងនោះ ឲ្យនៅក្នុងអំណាចហើយឬ ឬរមែងបណ្តោយតាមអំណាចនៃវិតក្កទាំងនោះ ក្នុងកាលខ្លះ ។

បន្ទាប់អំពីនោះ សាតាគិរយក្ខ រមែងដឹងសព្វញ្ញុគុណទាំងអស់ ព្រោះភាពដែលព្រះដ៏មានព្រះភាគ ទ្រង់ជាអ្នកជំនាញវិសេសក្នុងភាពជាសព្វញ្ញូ ទើបពោលថា **មនោ ចស្ស សុបណិហិតោ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **សុបណិហិតោ** សេចក្តីថា ទ្រង់តាំងទុកល្អហើយ គឺស្មើដោយផែនដី ព្រោះអត្ថថា មិនត្រេកអរ មិនប្រទូស្ត ដូចភ្នំសិនេរុ ព្រោះអត្ថថា មិនញាប់ញ័រដោយតាំងមាំល្អហើយ ដូចសសរខឿន ព្រោះអត្ថថា មារ ៤ ពួក និងពួកនៃមេលទ្ធិធ្វើឲ្យញាប់ញ័រមិនបាន ។

ការដែលហទយៈរបស់ព្រះដ៏មានព្រះភាគ តាំងនៅក្នុងភាពជាព្រះសព្វញ្ញូ ព្រោះព្រះអង្គ ទ្រង់ដល់ព្រមដោយអាការទាំងពួងតាំងមាំល្អហើយ មិនញាប់ញ័រក្នុងឥឡូវនេះមិនជាអស្ចារ្យឡើយ តែដែលអស្ចារ្យ គឺទ្រង់ជាតិរិច្ឆានក្នុងកាលមានរាគៈជាដើម កើតក្នុងត្រកូលស្ដេចដំរីឆទ្ទន្ត ត្រូវមុតដោយព្រួញដែលលាបដោយថ្នាំពិស ក៏មិនញាប់ញ័រ មិនប្រទូស្តក្នុងអ្នកសម្លាប់នោះ ទាំងឲ្យចម្រើននូវភ្លុកទាំងឡាយរបស់ខ្លួន ( កាត់ភ្លុករបស់ខ្លួន ) ឲ្យដល់អ្នកសម្លាប់នោះទៀតផង ។ ម្យ៉ាងទៀត កាលទ្រង់ជាមហាកបិ ត្រូវគប់ក្បាលដោយថ្មធំ ក៏នៅតែប្រាប់ផ្លូវដល់អ្នកគប់នោះឯង ម្យ៉ាងទៀត ក្នុងកាលជាវិធុរបណ្ឌិត ត្រូវចាប់ត្រង់ជើងទាំងពីរ បោះទៅក្នុងជ្រោះកាឡបព៌ត ដែលមានជម្រៅ ៦០ យោជន៍ ក៏នៅតែសម្ដែងធម៌ ដើម្បីប្រយោជន៍ដល់យក្ខនោះទៀត ព្រោះហេតុនោះ សាតាគិរយក្ខពោលប្រពៃនោះឯងថា **មនោ ចស្ស សុបណិហិតោ** ដូច្នេះ ។

បទថា **សព្វភូតេសុ តាទិនោ** សេចក្ដីថា ព្រះហឫទ័យរបស់ព្រះអង្គដែលទ្រទ្រង់ដល់លក្ខណៈរបស់តាទិបុគ្គលនោះឯង តាំងមាំល្អហើយ ក្នុងសត្វទាំងពួង មិនមែនអស់កាលដែលមិនទាន់បានបច្ច័យ ។ ក្នុងគាថានោះ អ្នកសិក្សាគប្បីជ្រាបនូវលក្ខណៈរបស់តាទិបុគ្គល នៃព្រះដ៏មានព្រះភាគដោយអាការ ៥ យ៉ាង ដូចព្រះសារីបុត្តពោលថា ពាក្យថា ជាអ្នកនឹងធឹង បានដល់ ព្រះអរហន្ត លោកនឹងធឹង ដោយអាការ ៥ យ៉ាង គឺលោកនឹងធឹងក្នុង

ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ១ លោកនឹងធឹង ព្រោះជាអ្នកលះបង់ហើយ ១ លោកនឹងធឹង ព្រោះជាអ្នកឆ្លងហើយ ១ លោកនឹងធឹង ព្រោះជាអ្នករួចហើយ ១ លោកនឹងធឹង ព្រោះការសម្តែងចេញនូវហេតុនោះ ១ ។

លោកនឹងធឹង ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ តើដូចម្តេច ។ ព្រះអរហន្តលោកនឹងធឹងក្នុងលាភ ដូច្នេះជាដើម អ្នកសិក្សាគប្បីកាន់យកដោយន័យ ដែលពោលហើយ ក្នុង ( មហា )និទ្ទេស ។

ធម៌ទាំងឡាយ មានលាភជាដើម អ្នកសិក្សាគប្បីកាន់យកដោយន័យដែលឲ្យពិស្តារហើយ ក្នុងមហាអដ្ឋកថានៃ ( មហា ) និទ្ទេសនោះ ។ គាថានេះជាពាក្យសួរប៉ុណ្ណោះថា ព្រះសាស្តារបស់ឯងនោះ ជាអ្នកនឹងធឹងក្នុងសត្វទាំងពួងឬ ក្នុងវិកប្បនេះ មានអធិប្បាយថា ព្រះសាស្តានៃយើងទាំងឡាយឈ្មោះថា ជាអ្នកនឹងធឹង ព្រោះទ្រង់មានព្រះហឫទ័យស្មើក្នុងសត្វទាំងពួង ។

ពិតហើយ ព្រះដ៏មានព្រះភាគអង្គនេះ ទ្រង់មានព្រះហឫទ័យស្មើក្នុងសត្វទាំងពួង ព្រោះទ្រង់ប្រាថ្នាក្នុងការនាំសុខចូលមក និងព្រោះទ្រង់ប្រាថ្នាដើម្បីនាំទុក្ខចេញទៅ គឺក្នុងព្រះអង្គ ទ្រង់មានព្រះហឫទ័យយ៉ាងណា ក្នុងសត្វដទៃក៏យ៉ាងនោះ ក្នុងព្រះមាតាមហាមាយាយ៉ាងណា ក្នុងនាងចិញ្ចមាណវិកាក៏យ៉ាងនោះ ក្នុងព្រះបិតាសុទ្ធោទនៈយ៉ាងណា ក្នុងព្រះបាទសុប្បពុទ្ធក៏យ៉ាងនោះ ក្នុងព្រះរាហុលឱរសយ៉ាងណា ក្នុងអ្នកសម្លាប់ទាំងឡាយមានទេវទត្ត ធនបាល និងអង្គុលីមាលជាដើមក៏យ៉ាងនោះ ទ្រង់ជាតាទិបុគ្គលក្នុងលោក

និងទេវលោក ព្រោះហេតុនោះ សាតាគិរយក្ខពោលប្រាប់ពោនោះឯងថា នឹងធឹង ក្នុងពួកសត្វទាំងអស់ ដូច្នេះ ។

អត្ថក្នុងគាថានេះថា **អថោ ឥដ្ឋេ អនិដ្ឋេ ច** អ្នកសិក្សាគប្បីឃើញយ៉ាងនេះ អារម្មណ៍ណាមួយ គួរប្រាថ្នាក្តី មិនគួរប្រាថ្នាក្តី ការត្រិះរិះដោយអំណាចនៃរាគៈ និងទោសៈពួកណា គប្បីកើតឡើងក្នុងអារម្មណ៍នោះ ដោយប្រការទាំងពួង ទ្រង់ធ្វើនូវការត្រិះរិះទាំងនោះឲ្យនៅក្នុងអំណាចហើយ ព្រោះភាពដែលកិលេសទាំងឡាយ មានរាគៈជាដើម ព្រះអង្គទ្រង់លះបានហើយដោយមគ្គដ៏កំពូល រមែងមិនប្រព្រឹត្តទៅក្នុងអំណាចនៃការត្រិះរិះទាំងនោះ ក្នុងកាលណាមួយ ។ មែនពិត ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់មានព្រះតម្រិះមិនល្អក់កករ មានព្រះហឫទ័យដែលផុតល្អហើយ មានព្រះបញ្ញាផុតល្អហើយ ។ ក្នុងគាថានេះ សាតាគិរយក្ខពោលការមិនមានអយោនិសោមនសិការ ព្រោះព្រះដ៏មានព្រះភាគ ទ្រង់មានព្រះហឫទ័យតាំងទុកល្អហើយ ទ្រង់នឹងធឹងក្នុងសត្វទាំងពួង នឹងក្នុងឥដ្ឋារម្មណ៍ អនិដ្ឋារម្មណ៍ទាំងឡាយ គប្បីមានក្នុងអារម្មណ៍ណា អារម្មណ៍នោះ លោកពោលជាពីរយ៉ាង ដោយចែកជាសត្វ និងសង្ខារ ។ ពោលដល់ការលះកិលេស ព្រោះទ្រង់ជំនាញក្នុងសេចក្តីត្រិះរិះ ដោយការមិនមានការធ្វើទុកក្នុងចិត្តក្នុងអារម្មណ៍នោះ ។ ពោលដល់សេចក្តីបរិសុទ្ធិតាមមនោសមាចារ ព្រោះទ្រង់មានព្រះហឫទ័យតាំងទុកល្អហើយ ពោលដល់សេចក្តីបរិសុទ្ធិផ្លូវកាយសមាចារ ព្រោះទ្រង់នឹងធឹងក្នុងសត្វទាំងពួង និងពោល

ដល់សេចក្តីបរិសុទ្ធិខាងវចីសមាចារ ព្រោះភាពដែលទ្រង់ជំនាញក្នុងការត្រិះរិះ ព្រោះវាចាមានវិតក្កជាមូល ។ មួយវិញទៀត គប្បីជ្រាបថា សាតាគិរយក្ខ ពោលដល់ការមិនមានទោសទាំងពួង មានលោភៈជាដើម ព្រោះព្រះអង្គទ្រង់មានព្រះហឫទ័យតាំងទុកល្អហើយ ពោលដល់ការកើតឡើងនៃគុណ មានមេត្តាជាដើម ព្រោះទ្រង់ជាអ្នកនឹងធឹងក្នុងសត្វទាំងពួង ពោលដល់ឫទ្ធិរបស់ព្រះអរិយៈ មានភាពជាអ្នកសម្គាល់ក្នុងរបស់បដិកូល ថាមិនបដិកូលជាដើម ដោយភាពដែលទ្រង់ជំនាញក្នុងការត្រិះរិះ និងពោលដល់ភាពដែលទ្រង់ជាសព្វញ្ញូ ព្រោះឫទ្ធិដែលជាអរិយៈនោះ ។

ហេមវតយក្ខ សួរដល់ភាពដែលព្រះអង្គជាតាទិបុគ្គល ដោយអំណាចនៃមនោទ្វារនោះឯង ក្នុងបទមុនយ៉ាងនេះហើយ សាកល្បងសាតាគិរយក្ខ ដែលអះអាងនូវភាពជាតាទិបុគ្គលនោះ ឥឡូវនេះ ដើម្បីធ្វើឲ្យមាំទាំ កាលសួរដល់សេចក្តីបរិសុទ្ធិតាមកាយទ្វារ វចីទ្វារ និងមនោទ្វារ ដោយអំណាចនៃទ្វារទាំង ៣ ឬដោយសង្ខេបក្នុងបទមុន កាលសាកល្បង សាតាគិរយក្ខ ដើម្បីធ្វើឲ្យមាំទាំនោះឯង ទើបពោលថា **កច្ចិ អទិន្នំ** ដូច្នេះ ។

ក្នុងគាថានោះ ហេមវតយក្ខសួរដល់ចេតនា វៀរចាកការកាន់យកទ្រព្យដែលអ្នកដទៃមិនបានឲ្យមុន ដើម្បីប្រយោជន៍ដល់ការងាយស្រួល ក្នុងការចងគាថា ។

បទថា **អារា បមាទម្ហា** សេចក្តីថា ហេមវតយក្ខសួរដល់ចេតនាវៀរ

ចាកអព្រហ្មចរិយៈ ដោយភាពជាអ្នកឆ្ងាយចាកការបណ្តោយចិត្តក្នុងកាមគុណទាំង ៥ ឬតែងសូត្រថា **អារា បមត្តម្ហា** ដូច្នេះក៏មាន អធិប្បាយថា ឆ្ងាយចាកមាតុគ្រាម ។

ហេមវតយក្ខសួរដល់ភាពដែលព្រះអង្គ ទ្រង់មានកម្លាំងក្នុងការវៀរចាកកាយទុច្ចរិត ៣ យ៉ាងនោះឯង ដោយបទនេះថា **ឈានំ ន រិញ្ចតិ ។** ព្រោះវិរតិរបស់បុគ្គលដែលប្រកបដោយឈាន រមែងមានកម្លាំង ។

លំដាប់នោះ សាតាគិរយក្ខ ព្រោះព្រះដ៏មានព្រះភាគទ្រង់វៀរចាកនូវអទិន្នាទានជាដើម ក្នុងបច្ចុប្បន្នតែម្យ៉ាងក៏មិនមែន សូម្បីក្នុងអតីតកាល ទ្រង់ក៏វៀរចាកអទិន្នាទានជាដើម អស់កាលយូរ ទើបទ្រង់បានទទួលមហាបុរិសលក្ខណៈនោះៗ ដោយអានុភាពនៃវិរតិនោះឯង ហើយលោក ព្រមទាំងទេវលោកពោលសរសើរព្រះអង្គដោយន័យថា ព្រះសមណគោតម ទ្រង់វៀរចាកអទិន្នាទានជាដើម ព្រោះដូច្នោះ កាលបន្លឺសីហនាទដោយវាចាដ៏ពីរោះ ទើបពោលថា **ន សោ អទិន្នំ អាទិយតិ** ដូច្នេះ ។ បទនោះដោយ អត្ថប្រាកដច្បាស់ហើយ ក្នុងបាទទី ៣ នៃគាថានេះ បាលីមានពីរយ៉ាង គឺ **បមាទម្ហា បមត្តម្ហា។** បទថា **ឈានំ ន រិញ្ចតិ** ក្នុងបាទទី ៤ នោះឯង សេចក្តីថា ទ្រង់មិនធ្វើឈានឲ្យទទេ គឺសូន្យ អ្នកសិក្សាគប្បីជ្រាបអត្ថថា ទ្រង់មិនលះ ។

ហេមវតយក្ខ ស្តាប់ការបរិសុទ្ធិនៃកាយទ្វារយ៉ាងនេះហើយ ឥឡូវនេះកាលនឹងសួរដល់សេចក្តីបរិសុទ្ធិក្នុងវចីទ្វារ ទើបពោលថា **កច្ចិ មុសា ន**

**ភណាតិ** ដូច្នេះ ។

ក្នុងគាថានោះឈ្មោះថា **ខីណា** ព្រោះអត្ថថា រមែងអស់ទៅ អធិប្បាយថា រមែងបៀតបៀន រមែងគ្របសង្កត់ ។ គន្លងនៃវាចាឈ្មោះថា **ព្យប្បថោ** គន្លងនៃវាចារបស់បុគ្គលនោះអស់ហើយ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **ខីណាព្យប្បថ** ប្រែថា ដែលមានគន្លងនៃវាចាអស់ហើយ ។ ហេមវតយក្ខបដិសេធគន្លងនៃវាចាអស់ហើយនោះ ដោយ **ន** អក្ខរៈ ទើបសួរថា មានគន្លងនៃពាក្យមិនអស់ទេឬ អធិប្បាយថា មានព្រះវាចាគ្រោតគ្រាត ។ បាលីថា **ឆាខីណាព្យបថោ** ក៏មាន ។ អធិប្បាយថា មានព្រះវាចាអស់ហើយ ពិតហើយ ពាក្យគ្រោតគ្រាតអស់ទៅក្នុងហទយៈទាំងឡាយរបស់បុគ្គលដទៃ តាំងនៅ អធិប្បាយថា ព្រះគោតមនោះ មិនមានព្រះវាចានឹងធឹងទេឬ ។

បទថា **វិភូតិ** បានដល់ សេចក្តីវិនាស ។ ពាក្យណារមែងប្រកាស ឬរមែងធ្វើនូវសេចក្តីវិនាស ព្រោះហេតុនោះ ពាក្យនោះឈ្មោះថា **វិភូតិក** ប្រែថា ពាក្យដែលធ្វើនូវសេចក្តីវិនាស **វិភូតក** នោះឯង ឈ្មោះថា **វេភូតិក** ឬហៅថា **វេភូតិយំ** ដូច្នេះក៏មាន ពាក្យថា **វេភូតិយំ** នោះ ជាឈ្មោះនៃពាក្យញុះញង់ ពិតហើយ ពាក្យញុះញង់នោះ រមែងធ្វើនូវសេចក្តីវិនាសដល់សត្វទាំងឡាយ ដោយការទម្លាយគ្នានិងគ្នា ចាកគ្នានិងគ្នា ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

លំដាប់នោះ សាតាគិរយក្ខ ព្រោះព្រះដ៏មានព្រះភាគទ្រង់វៀរចាកមុសា-

វាទជាដើម ក្នុងបច្ចុប្បន្នតែម្យ៉ាងក៏មិនមែន ក្នុងអតីតកាល ក៏ទ្រង់វៀរចាកនូវមុសាវាទជាដើមអស់កាលយូរ និងទ្រង់បានមហាបុរិសលក្ខណៈនោះៗ ដោយអានុភាពនៃវិរតិនោះឯង លោក ព្រមទាំងទេវលោក ក៏ពោលសរសើរព្រះគោតមនោះថា ព្រះសមណគោតមទ្រង់វៀរចាកមុសាវាទ ព្រោះដូច្នោះ កាលបន្លឺសីហនាទដោយវាចាដ៏ពីរោះ ទើបពោលថា **មុសា ច សោ ន ភណាតិ** ដូច្នេះ ។

ក្នុងគាថានោះ បទថា **មុសា** បានដល់ ពាក្យដែលពោលវត្ថុប្រាកដជាដើម ឲ្យឃ្លៀងឃ្លាតដល់អ្នកដទៃ ។ ព្រះអង្គមិនត្រាស់ពាក្យកុហកនោះ ។ ក្នុងបាទទី ២ បាលីថា **ន ខីណាព្យប្បថោ** ដោយអំណាចនៃអត្ថបែបទីមួយ បាលីថា **ណាខីណាព្យប្បថោ** ដោយអំណាចនៃអត្ថបែបទី ២ ក្នុងបាទទី ៤ បញ្ញាហៅថា **មន្តា** ។ ព្រះដ៏មានព្រះភាគទ្រង់កំណត់ដោយបញ្ញា ទើបត្រាស់តែពាក្យដែលជាប្រយោជន៍តែម្យ៉ាង គឺពាក្យដែលមិនប្រាសចាកប្រយោជន៍ មិនត្រាស់នូវពាក្យរោយរាយ ដ្បិតថា ពាក្យដែលឥតប្រយោជន៍ មានការមិនដឹងជាខាងមុខ រមែងមិនមានដល់ព្រះពុទ្ធទាំងឡាយ ព្រោះដូច្នោះ ទើបពោលថា **មន្តា អត្ថំ សោ ភាសតិ** ដូច្នេះ ។ បទដ៏សេស ក្នុងគាថានេះប្រាកដច្បាស់ហើយ ។

ហេមវតយក្ខបានស្តាប់សេចក្តីបរិសុទ្ធិតាមវចីទ្វារយ៉ាងនេះហើយ ឥឡូវនេះ កាលសួរដល់សេចក្តីបរិសុទ្ធិតាមមនោទ្វារ ទើបពោលថា **កច្ចិ ន រជ្ជតិ**

**កាមេសុ** ដូច្នេះ ។

ក្នុងគាថានោះ ពាក្យថា **កាម** បានដល់ កិលេសកាម និងវត្ថុកាម ។ ហេមវតយក្ខកាលសួរថា ព្រះគោតមទ្រង់មិនត្រេកអរដោយកិលេសកាម ក្នុងកាមទាំងនោះទេឬ ឈ្មោះថា សួរដល់ភាពដែលទ្រង់មិនមានអភិជ្ឈាលុ កាលសួរថា ព្រះហឫទ័យមិនល្អក់ទេឬ ឈ្មោះថា រមែងសួរដល់ភាពដែលទ្រង់មិនមានព្យាបាទ សំដៅដល់ការល្អក់ដោយព្យាបាទ កាលសួរថា ព្រះអង្គកន្លងបង់នូវមោហៈហើយឬ ឈ្មោះថា រមែងសួរដល់ភាពដែលទ្រង់មានសម្មាទិដ្ឋិ ព្រោះទ្រង់ឈានកន្លងមោហៈ ដែលជាហេតុឲ្យបុគ្គលវង្វេងហើយកាន់យកមិច្ឆាទិដ្ឋិ កាលសួរថា មានបញ្ញាចក្ខុក្នុងធម៌ទាំងឡាយឬ ឈ្មោះថា រមែងសួរដល់ភាពដែលទ្រង់ជាព្រះសព្វញ្ញូ ដោយអំណាចនៃញាណចក្ខុ ដែលមិនជាប់ជំពាក់ក្នុងធម៌ទាំងពួង ឬដោយអំណាចនៃចក្ខុទាំង ៥ ក្នុងធម៌ទាំងឡាយដែលជាវិស័យនៃចក្ខុទាំង ៥ ព្រោះគិតថា ទ្រង់មិនជាសព្វញ្ញូ ដោយគ្រាន់តែបរិសុទ្ធ តាមទ្វារទាំង ៣ ប៉ុណ្ណោះ ។

លំដាប់នោះ សាតាគិរិយក្ខ ព្រោះព្រះដ៏មានព្រះភាគទ្រង់មិនសម្រេចអរហត្ត ក៏ឈ្មោះថា មិនត្រេកអរក្នុងកាមទាំងឡាយ មិនមានព្រះហឫទ័យល្អក់កករ ដោយព្យាបាទ ព្រោះជាអ្នកមានកាមរាគ និងព្យាបាទដែលទ្រង់លះបានហើយ ដោយអនាគាមិមគ្គ និងឈ្មោះថា ទ្រង់កន្លងនូវមោហៈ ព្រោះភាពដែលមោហៈបិទបាំងសច្ចៈ ដែលមានមិច្ឆាទិដ្ឋិជាបច្ច័យ ដែលទ្រង់លះបាន

ហើយ ដោយសោតាបត្តិមគ្គនោះឯង ទ្រង់ត្រាស់ដឹងសច្ចៈទាំងឡាយដោយព្រះអង្គឯង ទើបទ្រង់បានព្រះនាមដែលមានវិមោក្ខជាទីបំផុតថា **ពុទ្ធោ** និងទ្រង់បាននូវចក្ខុទាំងឡាយតាមដែលពោលហើយ ព្រោះដូច្នោះ កាលនឹងពោលប្រកាសភាពបរិសុទ្ធតាមមនោទ្វារ និងភាពជាសព្វញ្ញូដល់ហេមវតយក្ខនោះ ទើបពោលថា **ន សោ រជ្ជតិ កាមេសុ** ដូច្នេះ ។

ហេមវតយក្ខបានស្តាប់សេចក្តីបរិសុទ្ធក្នុងទ្វារទាំង ៣ និងភាពជាសព្វញ្ញូរបស់ព្រះដ៏មានព្រះភាគយ៉ាងនេះហើយ ត្រេកអរ រីករាយ មានគន្ធនៃពាក្យមិនទើសទាក់ដោយបញ្ញា ដែលស្ទាត់ជំនាញហើយក្នុងពហុសច្ចៈ ក្នុងអតីតជាតិ បំណងនឹងស្តាប់សព្វញ្ញុគុណទាំងឡាយដែលគួរអស្ចារ្យ ទើបពោលថា ព្រះពុទ្ធបរិបូណ៌ដោយវិជ្ជាឬ ។

ក្នុងគាថានោះ ហេមវតយក្ខសួរដល់ទស្សនសម្បត្តិ ដោយបទនេះថា ព្រះពុទ្ធបរិបូណ៌ដោយវិជ្ជាឬ សួរដល់គមនសម្បត្តិដោយបទនេះថា មានចរណៈដ៏បរិសុទ្ធប្រពៃឬ ក៏ពោល ច អក្ខរៈ ព្រោះធ្វើឲ្យជាទីឃៈ ក្នុងបទថា **សំសុទ្ធចារណោ** នេះ ដោយអំណាចនៃឆន្ទលក្ខណៈ អធិប្បាយថា **សំសុទ្ធចរណោ**។ សួរដល់ការសម្រេចនិព្វានធាតុទី ១ ដែលសន្មតថា ជាការអស់ទៅនូវអាសវៈ ដែលគប្បីសម្រេចដោយទស្សនសម្បត្តិ និងគមនសម្បត្តិនោះ ដោយបទនេះថា អាសវៈទាំងឡាយរបស់ព្រះអង្គអស់ហើយឬ ។ សួរដល់ភាពដែលព្រះអង្គទ្រង់អាចសម្រេចនិព្វានធាតុទី ២ ឬភាពដែលព្រះអង្គទ្រង់ជ្រាប

នូវសម្បត្តិ គឺត្រេកអរក្រៃលែង តាំងនៅដោយបច្ចវេក្ខណញ្ញាណ ដោយបទនេះថា ការកើតក្នុងភពថ្មីទៀត មិនមានទេឬ ។

បន្ទាប់អំពីនោះ ព្រោះអវិជ្ជា ៣ យ៉ាងនោះ ដែលទ្រង់ត្រាស់ហើយក្នុងសូត្រទាំងឡាយ មានភយភេរវសូត្រជាដើម ដោយន័យថា តថាគតនោះរឭកជាតិដែលបានអាស្រ័យនៅពីមុន ជាអនេកជាតិជាដើម ។ វិជ្ជា ៨ យ៉ាងនោះ ដែលត្រាស់ក្នុងសូត្រទាំងឡាយ មានអម្ពដ្ឋសូត្រ[១] ជាដើម ដោយន័យជាដើមថា ភិក្ខុនោះ កាលបើចិត្តតាំងមាំបរិសុទ្ធផូរផង់មិនមានទីទួល គឺកិលេស ។បេ។ ក៏ទាញនាំបង្អោនទៅ ដើម្បីញាណទស្សនៈជាដើម ព្រះដ៏មានព្រះភាគទ្រង់ចូលដល់ដោយវិជ្ជានោះ ដែលដល់ព្រមដោយអាការគ្រប់យ៉ាង និងចរណៈ ១៥ ប្រភេទនោះ ដែលព្រះដ៏មានព្រះភាគទ្រង់លើកឡើងសម្ដែងយ៉ាងនេះថា បពិត្រមហានាម អរិយសាវក ក្នុងសាសនានេះ ជាអ្នកបរិបូណ៌ដោយសីល ជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ជាអ្នកស្គាល់ប្រមាណក្នុងភោជន ជាអ្នកប្រកបនូវការភ្ញាក់រឭក ជាអ្នកប្រកបដោយសប្បុរិសធម៌ទាំង ៧ ប្រការ ជាអ្នកបានដូចប្រាថ្នានូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ថ្លៃថ្លា ជាហេតុនៃកិរិយានៅជាសុខ ក្នុងបច្ចុប្បន្ន ជាអ្នកបានដោយមិនលំបាក បានដោយងាយ ដូច្នេះ ។ ដូច្នេះហើយ ទ្រង់សម្ដែងពង្រីកក្នុង ( សេក្ខប្បដិបទា )

---

១- ក្នុងអម្ពដ្ឋសូត្រ ពុទ្ធដីកានេះ មិនមាន ព្រោះលោកចង្អុលបង្ហាញឲ្យមើលក្នុងសាមញ្ញផលសូត្រ ។

សូត្រ ដោយន័យជាដើមថា បពិត្រមហានាម ចុះអរិយសាវក ជាអ្នកបរិបូណ៌ ដោយសីល តើដូចម្តេច ដូច្នេះ ។ ចរណៈនោះ របស់ព្រះដ៏មានព្រះភាគ បរិសុទ្ធក្រៃលែង ព្រោះទ្រង់លះឧបក្កិលេសទាំងអស់ អាសវៈទាំង ៤ មាន កាមាសវៈជាដើមទាំងអស់នេះ ប្រព្រឹត្តទៅជាមួយបរិវារ ដែលប្រព្រឹត្តទៅជា មួយវាសនារបស់ព្រះដ៏មានព្រះភាគ អស់ទៅហើយ ព្រោះទ្រង់ជាព្រះ ខីណាស្រព ដោយវិជ្ជា និងចរណសម្បទានេះ ទ្រង់ពិចារណាក្នុងកាលនោះ ថា កពច្ចិរបស់ព្រះអង្គមិនមានទៀតឡើយ ដូច្នេះ ព្រោះហេតុនោះ សាតា- គិរយក្ខមានហឫទ័យ ដែលគន្ធនៃវាចាឲ្យកើតឧស្សាហ៍ព្រមហើយ ក្នុងកាល ដែលព្រះដ៏មានព្រះភាគទ្រង់ជាសព្វញ្ញូ កាលទទួលនូវគុណទាំងនោះ ទើប ពោលថា **វិជ្ជាយ ចេវ សម្បន្នោ** ដូច្នេះ ។

បន្ទាប់អំពីនោះ ហេមវតយក្ខអស់នូវសេចក្តីសង្ស័យក្នុងព្រះដ៏មានព្រះ ភាគថាៗ ទ្រង់ជាព្រះសម្មាសម្ពុទ្ធ ដូច្នេះ ក្នុងអាកាសនោះឯង សរសើរព្រះ ដ៏មានព្រះភាគ និងសរសើរសាតាគិរយក្ខថា **សម្បន្នំ មុនិនោ ចិត្តំ** ដូច្នេះ ។

គាថានោះមានអត្ថថា ព្រះហឫទ័យរបស់ព្រះគោតមដែលជាមុនី ដល់ ព្រមហើយ អធិប្បាយថា ដល់ព្រមហើយ ដោយភាពដែលទ្រង់ជាតាទិ- បុគ្គល ដែលសាតាគិរយក្ខពោលក្នុងបទនេះថា ព្រះហឫទ័យ ( របស់ព្រះ គោតម ) តាំងនៅល្អ ដល់ព្រមហើយដោយកាយកម្ម ដែលសាតាគិរយក្ខ ពោលក្នុងបទនេះថា ព្រះគោតមនោះ មិនកាន់យកវត្ថុដែលគេមិនបានឲ្យទេ

និងដល់ព្រមហើយដោយមនោកម្ម ដែលសាតាគិរយក្ខពោលក្នុងបទនេះថា ព្រះពុទ្ធនោះ មិនត្រេកអរក្នុងកាមទាំងឡាយទេ ដល់ព្រមហើយដោយវចីកម្ម ដែលជាផ្លូវនៃវាចា ដែលសាតាគិរយក្ខពោលហើយ ក្នុងបទនេះថា ព្រះសមណគោតមនោះ មិនពោលពាក្យកុហកទេ ។

ហេមវតយក្ខសម្ដែងថា ព្រះហឫទ័យដល់ព្រមហើយយ៉ាងនេះ ឈ្មោះថា ដល់ព្រមហើយដោយវិជ្ជា និងចរណៈ ព្រោះភាពដែលព្រះអង្គទ្រង់ដល់ព្រមហើយដោយវិជ្ជាសម្បទា និងចរណសម្បទាដ៏កំពូល អ្នកសរសើរព្រះគោតមនោះដោយគុណទាំងឡាយនេះដោយធម៌ ដោយន័យជាដើមថា ព្រះហឫទ័យរបស់ព្រះអង្គតាំងមាំល្អហើយ គឺអ្នកសរសើរព្រះគោតមនោះ ដោយសភាវៈ ដោយសេចក្ដីពិតនោះឯង មិនបានសរសើរ ដោយហេតុត្រឹមតែមានសទ្ធាតែម្យ៉ាងឡើយ ។

បន្ទាប់អំពីនោះ ចំណែកសាតាគិរិយក្ខ កាលនឹងសរសើរហេមវតយក្ខនោះដោយបរិយាយថា នៃអ្នកនិទ្ទិក្ខ សេចក្ដីនោះអ្នកដឹងល្អហើយ កាលសរសើរហើយយ៉ាងនេះ ទើបពោលថា ព្រះហឫទ័យរបស់ព្រះមុនីបរិបូណ៌ដោយកម្មផង ដោយគន្លងនៃពាក្យផង ណ្ហើយចុះ យើងនឹងទៅគាល់ព្រះគោតម ដែលបរិបូណ៌ដោយវិជ្ជា និងចរណៈ ដូច្នេះ ។ កាលពោលយ៉ាងនេះហើយ កាលនឹងសរសើរហេមវតយក្ខនោះ ក្នុងការគាល់ព្រះដ៏មានព្រះភាគទៀត ទើបពោលថា ណ្ហើយចុះ យើងនឹងទៅគាល់ព្រះគោតម ដែលបរិបូណ៌ដោយវិជ្ជា

និងចរណៈ ដូច្នេះ ។

លំដាប់នោះហេមវតយក្ខ កាលសរសើរព្រះដ៏មានព្រះភាគដោយកម្លាំងនៃពាហុសច្ចៈក្នុងជាតិមុន ដោយព្រះគុណដែលខ្លួនគាប់ចិត្តក្រៃលែង ទើបពោលថា ចូរអ្នកមក យើងនឹងទៅគាល់ព្រះគោតម ដែលមានព្រះជង្ឃាដូចជាស្នងនៃរមាំង ... ដូច្នេះ ។

គាថានោះមានអត្ថថា ស្នងទាំងឡាយរបស់ព្រះគោតមនោះ ដូចគ្នានឹងស្នងសត្វទ្រាយ ព្រោះហេតុនោះ ទើបព្រះគោតមនោះព្រះនាម **ឯណិជង្ឃោ** ។ ពិតហើយ ស្នងទាំងឡាយរបស់ព្រះសម្ពុទ្ធទាំងឡាយ មូលស្រឡូនទៅដោយលំដាប់ ដូចស្នងនៃសត្វទ្រាយ ខាងមុខ មិនមានសាច់ ខាងក្រោយ ប៉ោងឡើងដូចពោះក្រពើ ព្រះពុទ្ធទាំងឡាយជាអ្នកស្គម គឺមិនធាត់ដូចបុរសដទៃ ព្រោះដល់ព្រមដោយអវយវៈតូចធំបែបនោះ ក្នុងទីដែលគួរវែង ខ្លី ស្មើ និងមូល ឬឈ្មោះថា **កីសា** ព្រោះភាពដែលព្រះអង្គកម្ចាត់នូវកិលេសដោយបញ្ញា ឈ្មោះថា **ធីរា** ព្រោះទ្រង់កម្ចាត់សត្រូវខាងក្នុង និងខាងក្រៅ ឈ្មោះថា **អប្បាហារា** ព្រោះទ្រង់សោយតែម្តង ហើយសោយមានកំណត់ មិនមែនមានព្រះក្រយាហារតិច ព្រោះទ្រង់សោយ ២ ឬ ៣ ពំនូត សមដូចព្រះដ៏មានព្រះភាគត្រាស់ថា

ម្នាលឧទាយិ ចំណែកតថាគតវិញ ជួនណា បរិភោគអាហារពេញស្មើដោយបាត្រនេះក៏មាន បរិភោគអាហារច្រើនជាងនោះទៅក៏មាន ។ ម្នាលឧទាយិ

បើពួកសាវក ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈ គោរព ហើយនៅអាស្រ័យ ( នឹងតថាគត ) ដោយគិតថា ព្រះសមណគោតម ព្រះអង្គមានអាហារតិចផង សរសើរបែបភាពរបស់បុគ្គលអ្នកមានអាហារតិចផង សមតាមពាក្យអ្នកថាមែន ម្នាលឧទាយិ ពួកសាវកណារបស់តថាគត ដែលមានអាហារត្រឹមមួយកូនផ្តិលខ្លះ មានអាហារកន្លះកូនផ្តិលខ្លះ មានអាហារមួយសម្បកផ្លែព្នៅខ្លះ មានអាហារកន្លះសម្បកផ្លែព្នៅខ្លះ ពួកសាវកទាំងនោះ សមជាមិនធ្វើសក្ការៈ គោរព រាប់អាន បូជា តថាគតដោយធម៌នេះទេ ... ដូច្នេះ ។

ឈ្មោះថា **អលោលុបំ** ព្រោះមិនមានចន្ទ្រាគក្នុងអាហារ ទ្រង់សោយព្រះក្រយាហារដែលប្រកបដោយអង្គ ៨ ឈ្មោះថា **មុនឹ** ព្រោះដល់ព្រមដោយមោនេយ្យៈ ។ ឈ្មោះថា **វនស្មឹ ឈាយន្តំ** ព្រោះទ្រង់ជាអនាគារិកៈ និងព្រោះមានព្រះហឫទ័យបង្អោនមកកាន់វិវេក ដោយហេតុនោះ ទើបហេមវតយក្ខពោលថា ចូរអ្នកមក យើងនឹងទៅគាល់ព្រះគោតម ដែលមានព្រះជង្ឃាដូចជាស្មងនៃសត្វរមាំង ... ដូច្នេះ ។

កាលពោលយ៉ាងនេះហើយ ទើបពោលគាថានេះថា **សីហំវេកចរំ** ព្រោះភាពជាអ្នកប្រាថ្នានឹងស្តាប់ធម៌ ក្នុងសម្នាក់របស់ព្រះដ៏មានព្រះភាគ អង្គនោះទៀត ។

គាថានោះមានអត្ថថា បទថា **សីហំ វ** សេចក្តីថា ដូចគ្នានឹងកេសរសីហៈ

ព្រោះអត្ថថា ចូលជិតបានដោយលំបាក ព្រោះអត្ថថា អត់ធន់ និងព្រោះអត្ថថា ផុតភ័យ ឈ្មោះថា **ឯកចរំ** ព្រោះមិនមានតណ្ហា ដែលហៅថាតណ្ហាជាសម្លាញ់ ឈ្មោះថា **ឯកចរំ** ព្រោះព្រះពុទ្ធពីរអង្គ មិនកើតព្រមគ្នាក្នុងលោកធាតុតែមួយ អ្នកសិក្សាគប្បីជ្រាបសេចក្ដីនោះ ដោយន័យដែលពោលហើយក្នុងខគ្គវិសាណសូត្រ ។

បទថា **ឆាតំ** បានដល់ មិនទៅមិនមកកាន់ភពថ្មី ។ ម្យ៉ាងទៀត ឈ្មោះថា **ឆាតំ** ព្រោះអត្ថថា មិនធ្វើបាបខ្វះ មានកម្លាំងខ្វះ បានដល់ បុគ្គលប្រសើរនោះ ។

បទថា **កាមេសុ អនបេក្ខិនំ** បានដល់ មិនមានការជាប់ជំពាក់ ព្រោះមិនមានឆន្ទរាគក្នុងកាមទាំងពីរយ៉ាង ។

បទថា **ឧបសង្កម្ម បុច្ឆាម មច្ចុបាសប្បមោចនំ** សេចក្ដីថា ពួកយើងចូលទៅគាល់ព្រះគោតមនោះ ដែលជាអ្នកស្វែងរកគុណធំបែបនោះ ទូលសួរដល់ធម៌ជាគ្រឿងផុតចាកអន្ទាក់មារ ជាវដ្ដៈ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ បានដល់ វិវដ្ដនិព្វាន គឺទូលសួរដល់ឧបាយជាគ្រឿងផុតចាកអន្ទាក់មារ ពោលគឺទុក្ខ និងសមុទយៈ ។ ហេមវតយក្ខពោលគាថានេះ សំដៅដល់សាតាគិរិយក្ខ បរិស័ទរបស់សាតាគិរិយក្ខ និងបរិស័ទរបស់ខ្លួន ។

ដោយសម័យនោះ នក្ខត្តឫក្សប្រចាំខែអាសាឍបានប្រកាសហើយក្នុងនគររាជគ្រឹះ កាលនោះ ឧបាសិកាឈ្មោះកាឡីកុររឃរិកា ក្នុងនគររាជគ្រឹះ

ដែលប្រដាប់តាក់តែងដោយជុំវិញ ដូចសោយនូវសិរីក្នុងទេវនគរ ឡើងកាន់ប្រាសាទ បើកបង្អួច កំពុងបន្ទោបង់ការចាញ់គក៏ ឈរក្នុងប្រទេសជាទីទទួលខ្យល់ ដើម្បីយកខ្យល់អាកាស បានស្តាប់ការសន្ទនាដែលប្រកបដោយពុទ្ធគុណនោះ របស់សេនាបតីយក្ខទាំងនោះអំពីខាងដើម កណ្តាល និងទីបំផុត កាលស្តាប់ហើយ ក៏កើតបីតិ មានពុទ្ធគុណជាអារម្មណ៍ថា ព្រះពុទ្ធទាំងឡាយទ្រង់ដល់ព្រមដោយព្រះគុណផ្សេងៗ យ៉ាងនេះ សង្កត់នីវរណៈដោយបីតិនោះ ឈរក្នុងប្រទេសនោះឯង តាំងនៅក្នុងសោតាបត្តិផល ។

ព្រោះហេតុនោះឯង ព្រះដ៏មានព្រះភាគទ្រង់តាំងនាងក្នុងតំណែងឯតទគ្គៈថា ពួកឧបាសិកាអ្នកជ្រះថ្លា តាមពាក្យដែលឮតៗ គ្នា ស្រេចនឹងកាឡីឧបាសិកាកុររឃរិកា ។

សេនាបតីយក្ខទាំងនោះ មានយក្ខមួយពាន់ជាបរិវារ មកដល់ឥសិបតនៈក្នុងសម័យមជ្ឈិមយាម ចូលទៅគាល់ព្រះដ៏មានព្រះភាគដែលគង់ពត់ភ្នែន ដែលទ្រង់ប្រកាសធម្មចក្កឲ្យប្រព្រឹត្តទៅ ថ្វាយបង្គំ សរសើរ ក្រាបទូលឲ្យព្រះដ៏មានព្រះភាគទ្រង់ធ្វើឱកាសដោយគាថានេះថា **អក្ខាតារំ បវត្តារំ** ដូច្នេះ ។

គាថានោះ មានអត្ថថា ឈ្មោះថា **អក្ខាតារំ** ដោយពាក្យកំណត់សច្ចៈទាំងឡាយដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ ក៏សេចក្តីទុក្ខនេះឯង ហៅថា អរិយសច្ច ក្នុងធម៌ ប្រព្រឹត្តក្នុងភូមិ វៀរតណ្ហា ឈ្មោះថា **បវត្តារំ** ដោយញ៉ាំងកិច្ចញ្ញាណ និងកតញ្ញាណ ឲ្យប្រព្រឹត្តទៅក្នុងសច្ចៈទាំង

នោះ ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ ពន្លឺកើតឡើងហើយ ដល់តថាគតថា ទុក្ខនោះ ហៅថា អរិយសច្ច ដែលតថាគតគប្បីកំណត់ដឹង ឬឈ្មោះថា **អក្ខាតារំ** ដោយការត្រាស់ដោយវោហារក្នុងធម៌ទាំងឡាយ ដោយប្រការដែលបុគ្គលគប្បីពោល ។ ឈ្មោះថា **បវត្តារំ** ទ្រង់សម្តែងធម៌ទាំងនោះ ដោយសមគួរដល់សត្វ ឬឈ្មោះថា **អក្ខាតារំ** ដោយសម្តែងដល់ឧគ្ឃដិតញ្ញូបុគ្គល និងវិបចិតញ្ញូបុគ្គល ឈ្មោះថា **បវត្តារំ** ដោយឲ្យវេនេយ្យសត្វអនុវត្តតាម ឬឈ្មោះថា **អក្ខាតារំ** ដោយឧទ្ទេស ។ ឈ្មោះថា **បវត្តារំ** ដោយចែក ដោយពោលដល់ ដោយប្រការនោះៗ ។ ឬឈ្មោះថា **អក្ខាតារំ** ដោយពោលកំណត់ពោធិបក្ខិយធម៌ទាំងឡាយ ឈ្មោះថា **បវត្តារំ** ដោយការប្រព្រឹត្តិទៅ ក្នុងចិត្តសន្តានរបស់សត្វទាំងឡាយ ។ ឬឈ្មោះថា **អក្ខាតារំ** ដោយការត្រាស់ប្រាប់សច្ចៈទាំងឡាយ ដោយបរិវដ្ដៈ ៣ ដោយសង្ខេប ឈ្មោះថា **បវត្តារំ** ដោយការត្រាស់សច្ចៈទាំងឡាយដោយពិស្តារ គឺឈ្មោះថា **បវត្តារំ** ដោយការប្រកាសព្រះធម្មចក្ក ដែលឲ្យពិស្តារហើយ ដោយន័យនៃបដិសម្ភិទាយ៉ាងនេះថា ព្រោះសទ្ធិន្ទ្រិយជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ។

បទថា **សព្វធម្មានំ** បានដល់ នៃធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បទថា **ចារគុំ** សេចក្តីថា ទ្រង់ដល់នូវត្រើយដោយអាការ ៦ គឺអភិញ្ញា ១ បរិញ្ញា ១ បហាន ១ ភាវនា ១ សច្ឆិកិរិយា ១ សមាបត្តិ ១ ។ ពិតហើយ

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ដឹងក្រៃលែងនូវធម៌ទាំងពួងដល់ហើយ ព្រោះដូច្នោះ ទើបឈ្មោះថា **អភិញ្ញាចារគូ** គឺទ្រង់ដល់នូវត្រើយដោយអភិញ្ញា ទ្រង់កំណត់ដឹងនូវឧបាទានក្ខន្ធ ៥ ដល់ហើយ ព្រោះដូច្នោះ ទើបឈ្មោះថា **បរិញ្ញាចារគូ** គឺទ្រង់ដល់នូវត្រើយ គឺបរិញ្ញា ។ ទ្រង់លះបង់នូវកិលេសទាំងពួងដល់ហើយ ព្រោះដូច្នោះ ទើបឈ្មោះថា **បហានចារគូ** គឺទ្រង់ដល់នូវត្រើយដោយបហាន ទ្រង់ចម្រើនមគ្គ ៤ ដល់ហើយ ព្រោះដូច្នោះ ទើបឈ្មោះថា **ភាវនាចារគូ** គឺទ្រង់ដល់ត្រើយដោយភាវនា ។ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវនិរោធដល់ហើយ ព្រោះដូច្នោះ ទើបឈ្មោះថា **សច្ចិកិរិយាចារគូ** គឺទ្រង់ដល់នូវត្រើយ ដោយសច្ចិកិរិយា ទ្រង់ចូលសមាបត្តិទាំងពួងដល់ហើយ ព្រោះដូច្នោះ ទើបឈ្មោះថា **សមាបត្តិចារគូ** គឺទ្រង់ដល់នូវត្រើយដោយសមាបត្តិ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ដោយប្រការដូច្នេះ ។

បទថា **ពុទ្ធំ វេរភយាតីតំ** សេចក្តីថា ឈ្មោះថាត្រាស់ដឹងហើយ ព្រោះភាពដែលព្រះអង្គទ្រង់ភ្ញាក់ហើយ ចាកការដេកលក់ គឺការមិនដឹង គឺទ្រង់ត្រាស់ដឹងប្រយោជន៍ទាំងឡាយ ដោយន័យដែលពោលហើយ ក្នុងសរណវណ្ណនា ឈ្មោះថា ទ្រង់កន្លងនូវពៀរ និងភ័យបានហើយ ព្រោះភាពដែលព្រះអង្គកន្លងនូវបញ្ចវេរបានហើយ ។ សេនាបតីយក្ខ កាលសរសើរព្រះដ៏មានព្រះភាគយ៉ាងនេះហើយ ទើបទ្រង់ឲ្យធ្វើឱកាសថា យើងនឹងសួរនូវព្រះគោតម ដូច្នេះ ។

លំដាប់នោះ ហេមវតយក្ខដែលក្រៃលែងជាងយក្ខទាំងនោះដោយតេជះ

បញ្ហា និងប្រយោជន៍ កាលទូលសួរបញ្ហាដែលគួរសួរតាមតម្រូវការហើយ ទើបពោលគាថានេះថា **កិស្មឹ លោកោ** ដូច្នេះ ។

ក្នុងបាទដើមនៃគាថានោះ បទថា **កិស្មឹ** ជាសត្តមីវិភត្តិ ប្រើក្នុងលក្ខណៈភាវៈដោយភាវៈ ( លក្ខណវត្ថុ ) កាលអ្វីកើត ទើបលោកកើតឡើង នេះជាអធិប្បាយក្នុងគាថានេះ ហេមវតយក្ខ ទូលសួរសំដៅដល់សត្វលោក និងសង្ខារលោក ។

បទថា **កិស្មឹ កុព្វតិ សន្ថវំ** សេចក្ដីថា លោករមែងធ្វើនូវការជិតស្និទ្ធដោយអំណាចតណ្ហា និងទិដ្ឋិ ថាអញ ថារបស់អញក្នុងអ្វី ។ ពាក្យថា **កិស្មឹ** ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថអធិករណៈ ។ បទថា **កិស្ស លោកោ** ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថទុតិយាវិភត្តិ ។ ក្នុងគាថានេះ មានសេចក្ដីអធិប្បាយថា លោករមែងដល់នូវការរាប់ថា លោកប្រកាន់អ្វី ។

បទថា **កិស្មឹ លោកោ** ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថនៃលក្ខណវត្ថុ និងអធិករណៈ ដោយភាវៈ ។ អធិប្បាយក្នុងគាថានេះដូច្នេះថា កាលអ្វីមានព្រោះហេតុអ្វី ទើបលោកក្ដៅក្រហាយ គឺត្រូវបៀតបៀន ត្រូវឈឺចុកចាប់ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ព្រោះកាលអាយតនៈខាងក្នុង និងខាងក្រៅទាំង ៦ កើតឡើង ទើបសត្វលោកកើតឡើង សង្ខារលោកក៏កើតឡើងដោយអំណាចនៃទ្រព្យ និងធញ្ញជាតិជាដើម និងព្រោះសត្វលោករមែងធ្វើនូវការជិតស្និទ្ធ ២ យ៉ាង ក្នុងអាយតនៈ ៦ នោះឯង ក្នុងសង្ខារលោកនេះ ឬ

កាលប្រកាន់អាយតនៈ គឺចក្ខុ ថាអញ របស់អញ ឬប្រកាន់អាយតនៈដទៃក្នុងបណ្ដាអាយតនៈដ៏សេស រមែងប្រកាន់ដូចព្រះតម្រាស់ថា បុគ្គលណានិយាយយ៉ាងនេះថា ភ្នែកជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេជាដើម ព្រោះលោកទាំងពីរប្រកាន់អាយតនៈ ៦ នោះឯង រមែងដល់នូវការរាប់ថា លោក ព្រោះកាលមានអាយតនៈ ៦ នោះឯង សត្វលោករមែងក្ដៅក្រហាយព្រោះទុក្ខប្រាកដ ដូចព្រះដ៏មានព្រះភាគត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ កាលបើដៃមានការកាន់ និងការដាក់ចុះរមែងប្រាកដ កាលបើជើងមាន ការឈានទៅមុខ និងឈានថយក្រោយ ក៏រមែងប្រាកដ កាលបើសន្លាក់ទាំងឡាយមានការបត់ចូល និងលាចេញ ក៏រមែងប្រាកដ កាលបើពោះមានសេចក្ដីស្រេកឃ្លាន ក៏រមែងប្រាកដ ។ ម្នាលភិក្ខុទាំងឡាយពិតយ៉ាងនេះឯង កាលបើចក្ខុមាន សេចក្ដីសុខ និងទុក្ខជាខាងក្នុង ក៏កើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យជាដើម ។

ម្យ៉ាងទៀត កាលមានគ្រឿងទ្រទាំងនោះ សង្ខារលោកដែលត្រូវបៀតបៀន ក៏រមែងក្ដៅក្រហាយ ដូចព្រះដ៏មានព្រះភាគត្រាស់ថា ចក្ខុដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ខ្ទាំងខ្ទប់ហើយក្ដី ដូច្នេះ ។ ឬដូចពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ចក្ខុរមែងបៀតបៀនចំពោះរូបទាំងឡាយជាទីគាប់ចិត្ត និងមិនជាទីគាប់ចិត្ត ដូច្នេះជាដើម ។ ម្យ៉ាងទៀត លោកទាំង

ពីរ រមែងក្តៅក្រហាយ ព្រោះអាយតនៈខាងក្នុង និងអាយតនៈខាងក្រៅ ដែលជាហេតុទាំងនោះឯង ដូចព្រះដ៏មានព្រះភាគត្រាស់ថា ចក្ខុរមែងជាប់ក្នុងរូបទាំងឡាយ ដែលពេញចិត្ត និងមិនពេញចិត្ត ដូច្នេះ និងព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចក្ខុជារបស់ក្តៅ រូបជារបស់ក្តៅ ... ក្តៅ ដោយអ្វី តថាគតពោលថា ក្តៅដោយភ្លើង គឺរាគៈជាដើម ។ ព្រោះដូច្នោះ កាលទ្រង់វិសជ្ជនាបញ្ហានោះ ដោយអំណាចនៃអាយតនៈខាងក្នុង និងខាងក្រៅ ៦ ទើបត្រាស់ថា **ឆសុ លោកោ សមុប្បន្នោ** ដូច្នេះ ។

លំដាប់នោះ យក្ខនោះកំណត់មិនល្អនូវបញ្ហាដែលខ្លួនទូលសួរ ដោយអំណាចនៃវដ្តៈដែលព្រះដ៏មានព្រះភាគទ្រង់វិសជ្ជនាយ៉ាងសង្ខេប ដោយអំណាចនៃអាយតនៈ ៦ មានបំណងដើម្បីដឹងនូវអត្ថនោះ និងប្រការដែលផុយចំពោះអត្ថនោះ កាលទូលសួរវដ្តៈ និងវិវដ្តៈដោយសង្ខេបប៉ុណ្ណោះ ទើបទូលថា **កតមន្តំ** ដូច្នេះ ។

ក្នុងគាថានោះ ឈ្មោះថា **ឧបាទាន** ព្រោះអត្ថថា ដែលសត្វគប្បីចូលទៅប្រកាន់មាំ ពាក្យថា ឧបាទាននោះ ជាឈ្មោះរបស់ទុក្ខសច្ចនោះឯង ។

បាទគាថាថា **យត្ថ លោកោ វិហញ្ញតិ** សេចក្តីថា ហេមវតយក្ខដែលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះថា សត្វលោកលំបាកព្រោះវត្ថុ ៦ ឈ្មោះថា ទ្រង់ទទួលពាក្យឆ្លើយថា សត្វលោកលំបាកព្រោះឧបាទាន ៦ ទើបទូលសួរដល់ទុក្ខសច្ច ដោយសង្ខេបប៉ុណ្ណោះ ដោយកន្ទះគាថាយ៉ាងនេះថា ការ

ប្រកាន់មាំដែលនាំឲ្យសត្វលោកលំបាក តើដូចម្តេច ។ ចំណែកសមុទយសច្ច ក៏ឈ្មោះថា ព្រះដ៏មានព្រះភាគទ្រង់កាន់យកហើយ ដោយភាពជាហេតុនៃទុក្ខសច្ចនោះឯង ។

ហេមវតយក្ខទូលសួរដល់មគ្គសច្ច ដោយកន្លះគាថានេះថា សត្វលោកតែងរួចស្រឡះចាកទុក្ខដោយប្រការដូចម្តេច ។ ពិតហើយ ព្រះអរិយសាវកកំណត់ដឹងទុក្ខ លះសមុទយៈ ធ្វើឲ្យជាក់ច្បាស់នូវនិរោធ និងចម្រើនមគ្គរមែងចេញចាកលោកដោយមគ្គសច្ច ព្រោះដូច្នោះ ទើបមគ្គសច្ចនោះ ហៅថា **និយ្យានំ** ប្រែថា ធម៌ជាគ្រឿងនាំចេញ ។ បទថា **កថំ** បានដល់ ដោយប្រការណា ។ បទថា **ទុក្ខា បមុញ្ចតិ** សេចក្តីថា បុគ្គលនឹងសម្រេចដល់ការផុតចាកវដ្តទុក្ខដែលពោលថា ឧបាទាន ។ ហេមវតយក្ខទូលសួរដល់មគ្គសច្ចដោយសន្ទើបប៉ុណ្ណោះ ក្នុងគាថានេះ ដោយប្រការដូច្នេះ ចំណែកនិរោធសច្ច ឈ្មោះថា ទ្រង់កាន់យកហើយ ដោយភាពជាវិស័យរបស់មគ្គ-សច្ចនោះឯង ។

ព្រះដ៏មានព្រះភាគ កាលយក្ខទូលសួរបញ្ហាដោយអំណាចនៃសច្ចៈ ៤ ដែលទ្រង់សម្តែងហើយ និងដែលទ្រង់មិនបានសម្តែង ដោយសរុបយ៉ាងនេះហើយ កាលទ្រង់វិសជ្ជនាដោយន័យនោះឯង ទើបត្រាស់ថា **បញ្ច កាមគុណា** ដូច្នេះ ។

ក្នុងគាថានោះ អាយតនៈ ៥ ដែលជាអារម្មណ៍របស់ចិត្តនោះ ឈ្មោះថា

ទ្រង់កាន់យកហើយដោយគោចរសព្ទ ពោល គឺកាមគុណ ៥ ក្នុងចិត្តជាគម្រប់ ៦ នៃអាយតនៈទាំងនោះ ព្រោះដូច្នោះ អាយតនៈទាំងនោះ ឈ្មោះថា **មនោឆដ្ឋា** ដូច្នេះ ។ បទថា **បវេទិតា** បានដល់ ប្រកាសឲ្យដឹងហើយ ។ ធម្មាយតនៈដែលជាអារម្មណ៍របស់ចិត្តនោះ ឈ្មោះថា ទ្រង់កាន់យកហើយដោយសព្ទ គឺមនាយតនៈទី ៦ ក្នុងបណ្ដាអាយតនៈខាងក្នុង ក្នុងគាថានេះ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់វិសជ្ជនាបញ្ហានេះថា ឧបាទានដូចម្ដេចយ៉ាងនេះ កាលហេមវតយក្ខទូលសួរទៀត ទើបទ្រង់ប្រកាសទុក្ខសច្ចដោយអំណាចនៃអាយតនៈ ១២ តែព្រោះគំនរនៃវិញ្ញាណទាំង ៧ លោកកាន់យកហើយដោយមនោសព្ទ ក្នុងបណ្ដាអាយតនៈទាំង ៦ នោះ អាយតនៈ ៥ យ៉ាងមានចក្ខាយតនៈជាដើម ដែលជាវត្ថុនៃវិញ្ញាណធាតុទាំងនោះ ឈ្មោះថា លោកកាន់យកហើយដោយសព្ទ គឺវិញ្ញាណធាតុ ៥ ខាងដើម ធម្មាយតនៈ ដែលជាវត្ថុ និងជាអារម្មណ៍នៃមនោធាតុ និងមនោវិញ្ញាណធាតុទាំងនោះ ដែលលោកកាន់យកហើយដោយសព្ទ គឺមនោធាតុ និងមនោវិញ្ញាណធាតុ ព្រោះដូច្នោះ ទើបទ្រង់ប្រកាសទុក្ខសច្ច ដោយអំណាចនៃអាយតនៈ ១២ ដោយប្រការដូច្នេះ ។

ឯកទេសនៃមនាយតនៈ និងធម្មាយតនៈដែលជាលោកុត្តរ លោកមិនបានសង្គ្រោះក្នុងទីនេះ ព្រោះលោកសម្ដែងសំដៅដល់អាយតនៈ ដែលជាហេតុឲ្យលោកលំបាក ។

បទថា **ឯត្ថ ឆន្ទំ វិរាជេត្វា** សេចក្ដីថា បុគ្គលកំណត់អាយតនៈទាំងនោះហើយក្នុងទុក្ខសច្ច មានអាយតនៈ ១២ ជាដើម ដោយប្រការនោះៗ គឺដោយខន្ធ ដោយធាតុ ដោយនាមរូប លើកឡើងកាន់ត្រៃលក្ខណ៍ ឃើញជាក់ច្បាស់ ប្រាសចាក គឺនាំចេញ បានដល់ កម្ចាត់នូវការពេញចិត្ត គឺតណ្ហាក្នុងកាមគុណ ៥ នេះ ដោយវិបស្សនា មានអរហត្តមគ្គជាទីបំផុត បានដោយប្រការទាំងពួង ។

បទថា **ឯវំ ទុក្ខា បមុច្ចតិ** សេចក្ដីថា រមែងផុតចាកវដ្ដទុក្ខនោះដោយប្រការដូច្នេះ ។ បញ្ហានេះថា **និយ្យានំ បុច្ឆិតោ ព្រូហិ កថំ ទុក្ខា បមុច្ចតិ** ដូច្នេះ ឈ្មោះថា ទ្រង់វិសជ្ជនាហើយដោយកន្លះគាថានេះ ដោយប្រការដូច្នេះ ។ មគ្គសច្ច ក៏ឈ្មោះថា ទ្រង់ប្រកាសហើយ សមុទយសច្ច និងនិរោធសច្ច គប្បីជ្រាបថា ឈ្មោះថា ទ្រង់ប្រកាសហើយ ព្រោះសង្គ្រោះដោយន័យមុននោះឯង ។

ទ្រង់ប្រកាសទុក្ខសច្ចដោយកន្លះគាថា សមុទយសច្ចដោយឆន្ទ និរោធ-សច្ចដោយពាក្យថា កម្ចាត់បង់ ក្នុងបទថា **វិរាជេត្វា** ដូច្នេះ មគ្គសច្ចដោយព្រះបាលីថា **វិរាគា វិមុច្ចតិ** ឬទ្រង់ប្រកាសមគ្គសច្ចដោយនិទស្សនៈ ដែលអាស្រ័យ **ឯវំ** សព្ទ ទ្រង់ប្រកាសនិរោធសច្ចដោយការផុតចាកទុក្ខថា សត្វលោកតែងរួចស្រឡះចាកទុក្ខ ដោយព្រះបាលីថា **ទុក្ខនិរោធំ** ព្រោះដូច្នោះសច្ចៈ ៤ គប្បីជ្រាបថា ទ្រង់ប្រកាសហើយក្នុងគាថានេះ ដោយប្រការដូច្នេះ ។

ទ្រង់ប្រកាសធម្មជាតជាគ្រឿងចេញចាកលោក ដោយលក្ខណៈ ដោយគាថាដែលសម្រេចសច្ចៈ ៤ យ៉ាងនេះហើយ កាលទ្រង់ប្រមូលនិយ្យានធម៌នោះដោយការជំនាញផ្នែកនិរុត្តិរបស់ព្រះអង្គ ទើបត្រាស់ថា **ឯតំ លោកស្ស និយ្យានំ** ដូច្នេះ ។

ក្នុងគាថានោះ បទថា **ឯតំ** ជាការសម្ដែងលម្អិតដល់បទដែលពោលហើយក្នុងបទមុន ។ បទថា **លោកស្ស** បានដល់ លោកធាតុទាំង ៣ ។ បទថា **យថាតថំ** បានដល់ មិនខុស ។

បទថា **ឯតំ វោ អហាមក្ខាមិ** សេចក្ដីថា បើអ្នកទាំងឡាយគប្បីសួរតថាគតមួយពាន់ដង តថាគតនឹងប្រាប់សេចក្ដីនេះដល់អ្នកទាំងឡាយ គឺមិនប្រាប់បទដទៃ ព្រោះហេតុអ្វី ព្រោះបុគ្គលរមែងផុតចាកទុក្ខបានដោយអាការយ៉ាងនេះ អធិប្បាយថា មិនមែនដោយប្រការដទៃ ។ម្យ៉ាងទៀត តថាគតក៏ប្រាប់សេចក្ដីនេះដល់អ្នកទាំងឡាយ សូម្បីចេញទៅហើយម្ដង ២ ដង និង ៣ ដង ដោយនិយ្យានធម៌នេះ អធិប្បាយថា តថាគតនឹងប្រាប់និយ្យានធម៌នោះឯង ដើម្បីសម្រេចគុណវិសេសជាន់ខ្ពស់ ព្រោះហេតុអ្វី ព្រោះបុគ្គលរមែងផុតចាកទុក្ខដ៏សេស និងមិនមានចំណែកសេសសល់ ដោយអាការយ៉ាងនេះ ។

ព្រះដ៏មានព្រះភាគទ្រង់ញ៉ាំងទេសនាឲ្យចប់ដោយកំពូល គឺអរហត្ត ក្នុងពេលចប់ទេសនា សេនាបតីយក្ខទាំងពីរ ក៏តាំងនៅហើយក្នុងសោតាបត្តិផលមួយអន្លើដោយយក្ខ ១ ពាន់ ។

លំដាប់នោះ ហេមវតយក្ខដោយប្រក្រតី ជាអ្នកជូន់ក្នុងធម៌ ឥឡូវនេះ តាំងនៅហើយក្នុងអរិយភូមិ មិនទាន់ឆ្អែតដោយល្អ ដើម្បីទូលសួរសេក្ខភូមិ និងអសេក្ខភូមិនឹងព្រះដ៏មានព្រះភាគ ដោយទេសនាដែលមានបដិភាណដ៏វិចិត្រ របស់ព្រះដ៏មានព្រះភាគ ទើបពោលគាថាថា **កោសូធ តរតិ ឱឃំ** ដូច្នេះ ។

ក្នុងគាថានោះ ហេមវតយក្ខទូលសួរដល់សេក្ខភូមិថា អ្នកណាឆ្លងឱឃៈ ៤ បាន ដោយបទនេះថា **កោសូធ តរតិ ឱឃំ** ។ ដោយមិនប្លែកគ្នា ព្រោះពាក្យថា **អណ្ណវំ** បានដល់ អន្លង់ទឹកដែលមានប្រមាណធំផង ជ្រៅផង ម្យ៉ាងទៀត **អណ្ណវំ** ដូចលោកពោលថា ធំជាង ជ្រៅជាងនោះឯង ឈ្មោះថា **អណ្ណវំ** គឺសង្សារវដ្ត ។ **អណ្ណវ** គឺសង្សារវដ្តនេះ ដោយជុំវិញក៏ធំ មិនមានទីបំផុត ខាងក្រោមក៏ជ្រៅមិនមានទីតាំង ខាងលើក៏ជ្រៅ ព្រោះមិនមានទីតោង ព្រោះដូច្នោះ ទើបហេមវតយក្ខទូលសួរដល់អសេក្ខភូមិថា ក្នុងលោកនេះ អ្នកណាហ្ន៎ ឆ្លងអន្លង់ ៤ បាន អ្នកណាមិនលិចចូលក្នុង **អណ្ណវ** ដ៏មានជម្រៅនោះ មិនមានទីពឹង មិនមានទីតោង ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ព្រោះភិក្ខុណាមិនធ្វើការកន្លងល្មើស ព្រោះហេតុនៃជីវិត ដល់ព្រមដោយសីលគ្រប់កាល និងមានបញ្ញា ដោយបញ្ញាដែលជាលោកិយ និងលោកុត្តរ តាំងមាំល្អហើយដោយឧបចារសមាធិ និងអប្បនាសមាធិ មគ្គ ផល ខាងក្រោមគ្រប់ឥរិយាបថ លើកឡើងកាន់ត្រៃលក្ខណ៍ មានប្រក្រតីគិតនូវធម៌ខាងក្នុង ដែលនាំចេញចាកទុក្ខដោយវិបស្សនា និងដល់

ព្រមហើយដោយសតិ គឺដោយមិនប្រមាទ ដែលនាំមកនូវការធ្វើជាប់ត ភិក្ខុនោះរមែងឆ្លងឱឃៈនេះ ដែលឆ្លងបានដោយលំបាក ដោយមិនមានចំណែកសល់ ដោយមគ្គទី ៤ ព្រោះដូច្នោះ កាលទ្រង់វិសជ្ជនាសេក្ខភូមិ ទើបត្រាស់គាថាដែលបញ្ចូលត្រៃសិក្ខានេះថា **សព្វទា សីលសម្បន្នោ** ដូច្នេះ ។

ក្នុងគាថានេះ សិក្ខា ៣ មួយអន្លើដោយឧបការៈ និងអានិសង្ស ព្រះមានព្រះភាគត្រាស់ហើយ គឺអធិសីលសិក្ខា ត្រាស់ដោយសីលសម្បទា អធិចិត្តសិក្ខា ត្រាស់ដោយសតិ និងសមាធិ អធិបញ្ញាសិក្ខា ត្រាស់ដោយបញ្ញា គឺការគិតដល់ធម៌ខាងក្នុង ។ ពិតហើយ សិក្ខាទាំងឡាយ មានលោកិយប្បញ្ញា និងសតិជាឧបការៈ មានសាមញ្ញផលជាអានិសង្ស ។

កាលទ្រង់សម្តែងសេក្ខភូមិ ដោយ ១ គាថាយ៉ាងនេះហើយ ឥឡូវនេះ កាលសម្តែងអសេក្ខភូមិ ទើបត្រាស់គាថាទី ២ ។

គាថានោះ មានសេចក្តីថា បទថា **វិរតោ កាមសញ្ញាយ** សេចក្តីថា បុគ្គលវៀរចាកកាមសញ្ញាណាមួយដោយសមុច្ឆេទវិរតិ ដែលសម្បយុត្តដោយមគ្គទី ៤ ដោយប្រការទាំងពួង បាលីថា **វិរតោ** ដូច្នេះក៏មាន ។ ក្នុងបាលីនោះ ពាក្យថា **កាមសញ្ញាយ** ជាសត្តមីវិភត្តិ តែក្នុងសគាថវគ្គ បាលីជា **កាមសញ្ញាសុ** ដូច្នេះក៏មាន ។ ឈ្មោះថា កន្លងនូវសំយោជនៈទាំងពួង ព្រោះកន្លងនូវសំយោជនៈ ១០ ដោយមគ្គទាំង ៤ ឬកន្លងនូវសំយោជនៈ ខាងលើដោយមគ្គទី ៤ ប៉ុណ្ណោះ ឈ្មោះថា **នន្ទិភវបរិក្ខីណោ** ព្រោះមានការត្រេកអរ

ពោល គឺតណ្ហាដែលនាំឲ្យត្រេកអរក្នុងវត្ថុនោះៗ និងភព ៣ អស់ហើយ ។

បទថា **សោ** បានដល់ ភិក្ខុដែលជាទីណាស្រពបែបនោះ រមែងមិនលិចចុះក្នុងអន្លង់ គឺសង្សារវដ្តដ៏ជ្រៅ ព្រោះចូលដល់ផលនៃនិព្វានធាតុ មានបញ្ចក្ខន្ធនៅសេសសល់ ព្រោះអស់នូវការត្រេកអរ និងមិនមានបញ្ចក្ខន្ធសេសសល់ ហើយដល់នូវការត្រេកអរក្រៃលែង ។

លំដាប់នោះ ហេមវតយក្ខសម្លឹងមើលសម្លាញ់ និងយក្ខបរិស័ទ កើតបីតិ និងសោមនស្ស សរសើរព្រះដ៏មានព្រះភាគ ដោយគាថាយ៉ាងនេះថា **គម្ភីរបញ្ញំ** ជាដើម ថ្វាយបង្គំហើយ មួយអន្លើដោយសម្លាញ់ និងបរិស័ទទាំងអស់ ធ្វើប្រទក្សិណហើយ ទៅកាន់លំនៅរបស់ខ្លួន ។

គាថាទាំងនោះ មានអត្ថពណ៌នាដូច្នេះ បទថា **គម្ភីរបញ្ញំ** សេចក្តីថាទ្រង់ដល់ព្រមដោយព្រះបញ្ញាដ៏ជ្រាលជ្រៅ ។ **គម្ភីរបញ្ញា** ក្នុងគាថានោះគប្បីជ្រាបដោយន័យដែលពោលហើយក្នុងបដិសម្ភិទា ( មគ្គ ) នោះឯង ។ ពិតហើយ ក្នុងបដិសម្ភិទា ( មគ្គ ) នោះ លោកពោលជាដើមថា ដែលឈ្មោះថា **គម្ភីរបញ្ញា** ព្រោះអត្ថថា ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងខន្ធដ៏ជ្រាលជ្រៅ ដូច្នេះ ។

បទថា **និបុណត្ថទស្សឹ** សេចក្តីថា ទ្រង់សម្តែងអត្ថនៃបញ្ហាទាំងឡាយដែលជនទាំងឡាយ មានក្សត្រ និងបណ្ឌិតជាដើមដែលជាបុគ្គលសុខុម តាក់តែងហើយ ឬដែលទ្រង់សម្តែងអត្ថដ៏សុខុម ដោយទ្រង់សម្តែងហេតុទាំងឡាយ

ដ៏ល្អិតនៃអត្ថទាំងឡាយ ដែលបុគ្គលដទៃចាក់ធ្លុះបានលំបាក ។

ឈ្មោះថា **អកិញ្ចនំ** ព្រោះមិនមានកង្វល់ មានរាគៈជាដើម ឈ្មោះថា **កាមភវេ អសត្តំ** ព្រោះទ្រង់មិនជាប់ក្នុងកាមទាំង ២ និងក្នុងភព ៣ ឈ្មោះថា **សព្វធិ វិប្បមុត្តំ** ព្រោះមិនមានការជាប់ជំពាក់ដោយឆន្ទរាគ ក្នុងអារម្មណ៍ទាំងពួង មានខន្ធជាដើម ។

បទថា **ទិព្វេ បថេ កមមានំ** សេចក្តីថា ទ្រង់ប្រព្រឹត្តទៅក្នុងផ្លូវដែលជាទិព្វ មានសមាបត្តិ ៨ ជាដើម ដោយអំណាចនៃការចូល ។ ក្នុងគាថានោះ ព្រះដ៏មានព្រះភាគ ទ្រង់យាងទៅក្នុងផ្លូវដែលជាទិព្វ ក្នុងពេលនោះក៏ពិត តែហេមវតយក្ខពោលយ៉ាងនោះ ក៏ព្រោះទ្រង់មានការអាច ដែលនឹងឈានទៅដែលសំដៅដល់ការឈានទៅក្នុងកាលមុន ឬព្រោះទ្រង់មានការជំនាញដែលបានហើយក្នុងផ្លូវដែលជាទិព្វនោះ ម្យ៉ាងទៀត លោកពោលពាក្យនេះ ដោយការឈានទៅក្នុងវិហារធម៌រាប់រយយ៉ាង ដែលជាផ្លូវនៃព្រះអរហន្តទាំងឡាយដែលជាវិសុទ្ធិទេព ។ ឈ្មោះថា **មហេសឹ** ព្រោះទ្រង់ស្វែងរកគុណទាំងឡាយដ៏ធំ ។

ក្នុងគាថាទី ២ ហេមវតយក្ខបានសម្តែងពង្រីក និបុណត្ថទស្សិសព្ទទៀត ព្រោះធ្វើអធិប្បាយថា ខ្ញុំបានប្រារព្ធនូវការសរសើរដោយបរិយាយដទៃ ម្យ៉ាងទៀត អធិប្បាយថា ទ្រង់សម្តែងអត្ថល្អិតល្អន់ ។

បទថា **បញ្ញាទទំ** បានដល់ ទ្រង់ឲ្យនូវបញ្ញា ព្រោះត្រាស់បដិបទាដែល

ប្រព្រឹត្តទៅដើម្បីបានបញ្ញា ។

បទថា **កាមាលយេ អសត្តំ** បានដល់ មិនជាប់ជំពាក់ហើយក្នុងអាល័យ ២ យ៉ាង ដោយអំណាចនៃតណ្ហា និងទិដ្ឋិក្នុងកាមទាំងឡាយ ។

បទថា **សព្វវិទុំ** បានដល់ ទ្រង់ដឹងនូវធម៌ទាំងពួង អធិប្បាយថា ទ្រង់ជាសព្វញ្ញូ ។

បទថា **សុមេធំ** សេចក្ដីថា ទ្រង់ដល់ព្រមដោយមេធា ពោលគឺបញ្ញាបារមី ដែលជាផ្លូវនៃភាពជាព្រះសព្វញ្ញូនោះ ។

បទថា **អរិយេ បថេ** សេចក្ដីថា ក្នុងមគ្គដែលប្រកបដោយអង្គ ៨ ឬក្នុងផលសមាបត្តិ ។

បទថា **កមមានំ** បានដល់ ទ្រង់ឈមចុះដោយព្រះបញ្ញា គឺត្រង់ឈានទៅ ព្រោះទ្រង់ដឹងនូវលក្ខណៈនៃមគ្គហើយ ទ្រង់សម្ដែង ឬគប្បីឈានទៅដោយកម្លាំងនៃការឈានទៅ ពោល គឺមគ្គភាវនា ៤ យ៉ាង ព្រោះទ្រង់ចូលផលសមាបត្តិបានគ្រប់ៗ ខណៈ ។

បទថា **សុទិដ្ឋំ វត នោ អជ្ជ** សេចក្ដីថា ថ្ងៃនេះយើងទាំងឡាយឃើញល្អហើយ អធិប្បាយថា ការឃើញ ។

បទថា **សុប្បភាតំ សុហុដ្ឋិតំ** សេចក្ដីថា ថ្ងៃនេះ ពួកយើងឃើញល្អហើយ ឬក្នុងថ្ងៃនេះ ការស្អាតរបស់ពួកយើងល្អហើយ ភ្លឺហើយ បានដល់ជាក់ច្បាស់ហើយ ថ្ងៃនេះ ពួកយើងតម្កល់ល្អហើយហ្ន៎ គឺតាំងឡើងល្អហើយ

ព្រោះមិនមានអន្តរាយ ព្រោះហេតុអ្វី ព្រោះហេមវតយក្ខប្រកាសនូវបារមោជ្ជ ប្រាវព្ទសម្បត្តិ គឺលាភរបស់ខ្លួនថា ពួកយើងបានឃើញព្រះសម្មាសម្ពុទ្ធ យើងទាំងឡាយបានឃើញព្រះសម្មាសម្ពុទ្ធហើយ ។

បទថា **ឥទ្ធិមន្តោ** សេចក្តីថា ប្រកបព្រមហើយដោយឫទ្ធិ ដែលកើតអំពីកម្មវិបាក ។ បទថា **យសស្សិនោ** សេចក្តីថា ដល់ព្រមហើយដោយលាភដ៏ប្រសើរ និងបរិវារដ៏ប្រសើរ ។ បទថា **សរណំ យន្តិ** សេចក្តីថា យក្ខទាំងឡាយដល់នូវសរណៈដោយមគ្គហើយក៏ពិត តែទោះជាដូច្នោះ ហេមវតយក្ខរមែងបន្លឺវាចា ដើម្បីសម្តែងភាពដែលខ្លួនជាព្រះសោតាបន្ន និងដើម្បីសម្តែងការជ្រះថ្លា ។

បទថា **គាមា គាមំ** សេចក្តីថា ចាកទេវគាម ទៅកាន់ទេវគាម ។ បទថា **នគា នគំ** បានដល់ ចាកទេវបពិត ទៅកាន់ទេវបពិត ។

បទថា **នមស្សមានា សម្ពុទ្ធំ ធម្មស្ស ច សុធម្មតំ** អធិប្បាយថា ខ្ញុំព្រះអង្គទាំងឡាយនឹងសរសើរ ខ្ញុំព្រះអង្គសូមនមស្ការនូវភាពដែលទ្រង់ត្រាស់ដឹងល្អ និងភាពដែលព្រះធម៌ជាធម៌ល្អដោយន័យជាដើមថា **ឥតិ បិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ... ស្វាក្ខាតោ ភគវតា ធម្មោ ...** និងការបដិបត្តិល្អនៃសង្ឃដោយន័យជាដើមថា **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ដូច្នេះហើយ ជាអ្នកប្រកាសធម៌ត្រាច់ទៅ ។ បទដ៏សេស ក្នុងគាថានេះ ងាយយល់ទាំងអស់ហើយ ៕ ០ ៕

# សុត្តន្តបិដក

## អាឡវកសូត្រទី ១០

[ ១៧ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងលំនៅរបស់អាឡវកយក្ស ក្បែរក្រុងអាឡវី ។ គ្រានោះឯង អាឡវកយក្ស ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ពោលនឹងព្រះមានព្រះភាគដូច្នេះថា នែសមណៈ ចូរចេញទៅ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ប្រពៃហើយ អាវុសោ ហើយក៏ស្តេចចេញទៅ ។ អាឡវកយក្សពោលថា នែសមណៈ ចូរចូលមកវិញ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ប្រពៃហើយ អាវុសោ ហើយក៏ស្តេចចូលមក ។ អាឡវកយក្សពោលនឹងព្រះមានព្រះភាគដូច្នេះទៀត ជាគម្រប់ ២ ដងថា នែសមណៈ ចូរចេញទៅ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ប្រពៃហើយ អាវុសោ រួចក៏ស្តេចចេញទៅ ។ អាឡវកយក្សពោលថា នែសមណៈ ចូរចូលមកវិញ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ប្រពៃហើយ អាវុសោ ហើយក៏ស្តេចចូលមក ។ អាឡវកយក្សនោះពោលនឹងព្រះមានព្រះភាគដូច្នេះទៀត ជាគម្រប់ ៣ ដងថា នែសមណៈ ចូរចេញទៅ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ប្រពៃហើយ អាវុសោ ហើយក៏ស្តេចចេញទៅ ។ អាឡវកយក្សពោលថា នែសមណៈ ចូរចូលមកវិញ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ប្រពៃហើយ អាវុសោ ហើយក៏ស្តេចចូលមកវិញ ។ អាឡវកយក្សពោលនឹងព្រះមានព្រះភាគដូច្នេះទៀត ជាគម្រប់ ៤ ដងថា នែសមណៈ ចូរចេញទៅ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាល

អាវុសោ តថាគតនឹងមិនចេញទៅទេ អំពើណាដែលអ្នកត្រូវធ្វើ ចូរអ្នកធ្វើអំពើនោះចុះ ។ នៃសមណៈ ខ្ញុំនឹងសួរប្រស្នាចំពោះលោក បើលោកមិនដោះស្រាយឲ្យយើងទេ យើងនឹងធ្វើចិត្តលោកឲ្យរវើរវាយ ឬហែកហឫទ័យរបស់លោក ឬក៏ចាប់ជើងគ្រវែងចោលទៅត្រើយម្ខាងទន្លេគង្គា ។ ម្នាលអាវុសោ តថាគតមិនឃើញអ្នកណាដែលធ្វើចិត្តនៃតថាគត ឲ្យរវើរវាយបាន ឬហែកហឫទ័យ ឬក៏ចាប់ជើងគ្រវែងចោលទៅត្រើយម្ខាងទន្លេគង្គា ក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសឡើយ ម្នាលអាវុសោ អ្នកប្រាថ្នានឹងសួរយ៉ាងណា ចូរសួរមកចុះ ។ គ្រានោះឯង អាឡវកយក្ស បានពោលនឹងព្រះមានព្រះភាគដោយគាថាដូច្នេះ

[ ១៨ ] ក្នុងលោកនេះ អ្វីជាទ្រព្យដ៏ប្រសើររបស់បុរស អ្វីដែលគេប្រព្រឹត្តល្អហើយ តែងនាំសេចក្តីសុខមកឲ្យ អ្វីមានរសឆ្ងាញ់ពីសាជាងរសទាំងឡាយ បណ្ឌិតហៅជីវិតនៃអ្នករស់នៅបែបណា ថាជាជីវិតប្រសើរ ។

( ព្រះមានព្រះភាគត្រាស់ថា ) ក្នុងលោកនេះ សទ្ធាជាទ្រព្យដ៏ប្រសើររបស់បុរស ធម៌ដែលគេប្រព្រឹត្តល្អហើយ តែងនាំសេចក្តីសុខមកឲ្យ ពាក្យសត្យ មានរសឆ្ងាញ់ពីសាជាងរសទាំងឡាយ បណ្ឌិតហៅជីវិតនៃអ្នករស់នៅដោយបញ្ញា ថាជា

ជីវិតប្រសើរ ។

បុគ្គលឆ្លងអន្លង់បានដោយអ្វី ឆ្លងមហាសមុទ្របានដោយអ្វី កន្លងសេចក្តីទុក្ខបានដោយអ្វី បរិសុទ្ធបានដោយអ្វី ។

បុគ្គលឆ្លងអន្លង់បាន ដោយសទ្ធា ឆ្លងមហាសមុទ្របានដោយសេចក្តីមិនប្រមាទ កន្លងសេចក្តីទុក្ខបានដោយព្យាយាម បរិសុទ្ធបានដោយប្រាជ្ញា ។

បុគ្គលបាននូវប្រាជ្ញាដោយអ្វី បាននូវទ្រព្យដោយអ្វី ដល់នូវសេចក្តីសរសើរដោយអ្វី ចងនូវមិត្តទាំងឡាយបានដោយអ្វី បុគ្គលចេញចាកលោកនេះ ទៅកាន់លោកខាងមុខ ហើយមិនសោយសោកក្នុងលោកខាងមុខដោយអ្វី ។

បុគ្គលជឿធម៌របស់ព្រះអរហន្ត ស្តាប់ដោយគោរព ជាអ្នកមិនប្រមាទ មានបញ្ញាពិចារណា រមែងបាននូវប្រាជ្ញា ដើម្បីដល់ព្រះនិព្វាន បុគ្គលមានការងារដ៏សមគួរ មានធុរៈ មានព្យាយាមប្រឹងប្រែង រមែងបាននូវទ្រព្យ បុគ្គលដល់នូវសេចក្តីសរសើរដោយសច្ចៈ បុគ្គលកាលឲ្យ រមែងចងនូវមិត្តទាំងឡាយបាន ។

ធម៌ទាំង ៤ នេះ គឺសច្ចៈ ១ ធម្មៈ ( បញ្ញា ) ១ ធីតិ ( ព្យាយាម ) ១ ចាគៈ ( ការបរិច្ចាគ ) ១ របស់បុគ្គលណា

មានសទ្ធានៅគ្រប់គ្រងផ្ទះ បុគ្គលនោះឯង រមែងមិនសោយសោក ក្នុងលោកខាងមុខ ។

អញ្ជើញអ្នកទៅសួរពួកសមណព្រាហ្មណ៍ជាច្រើន ដទៃទៀតចុះ បើមានធម៌ដទៃទៀតក្នុងលោកនេះ ឲ្យក្រៃលែងជាងសច្ចៈ ទមៈ ចាគៈ ខន្តិទៅទៀត ។

ឥឡូវនេះ ខ្ញុំចាំបាច់សួរពួកសមណព្រាហ្មណ៍ជាច្រើនធ្វើអ្វីទៀត ( ព្រោះ ) ក្នុងថ្ងៃនេះ ខ្ញុំដឹងប្រយោជន៍ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខច្បាស់ហើយ ព្រះពុទ្ធទ្រង់ស្ដេចមកកាន់ដែនអាឡវី ដើម្បីគង់នៅជាប្រយោជន៍ដល់ខ្ញុំព្រះអង្គហើយ ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គដឹងច្បាស់ហើយថា ទានដែលបុគ្គលឲ្យហើយចំពោះព្រះសម្ពុទ្ធណា ថាជាទានមានផលច្រើន ខ្ញុំព្រះអង្គនឹងត្រាច់ទៅអំពីស្រុក ទៅកាន់ស្រុក អំពីបុរី ទៅកាន់បុរី សូមថ្វាយបង្គំនូវព្រះសម្ពុទ្ធ ( នោះ ) ផង នូវសភាពដ៏ល្អរបស់ព្រះធម៌ផង ។

អាឡវកសូត្រទី ១០ ចប់

# អដ្ឋកថា

## អាឡវកសូត្រ

[ ១៧ ] អាឡវកសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះ សូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។ អត្ថុប្បត្តិហេតុនៃអាឡវកសូត្រនោះ នឹងជាក់ច្បាស់ ដោយន័យរបស់អត្ថវណ្ណនានោះឯង ។ ក្នុងអត្ថវណ្ណនា បទថា **ឯវម្មេ សុតំ ឯកំ សមយំ ភគវា** នោះ មានអត្ថដែលពោលហើយនោះឯង ។ ក្នុងបទថា **អាឡវិយំ វិហរតិ អាឡវកស្ស យក្ខស្ស ភវនេ** នេះ មានពាក្យសួរថា អាឡវី គឺអ្វី ហើយព្រះដ៏មានព្រះភាគគង់នៅក្នុងលំនៅរបស់អាឡវកយក្ខនោះ ព្រោះហេតុអ្វី ខ្ញុំនឹងឆ្លើយនូវពាក្យសួរដូចតទៅ

ពាក្យថា **អាឡវី** នោះ ជារដ្ឋក៏ ជានគរក៏ ទាំងពីរយ៉ាងនោះ ក៏គួរ ក្នុងសូត្រនេះ ព្រះដ៏មានព្រះភាគសូម្បីគង់នៅក្នុងទីជិតអាឡវីនគរ ក៏ហៅថា គង់នៅក្នុងក្រុងអាឡវី និងក្នុងទីជិត គឺក្នុងទីមិនឆ្ងាយអំពីនគរនោះ ប្រមាណ ១ គាវុត ទីលំនៅនោះក៏ហៅថា ព្រះដ៏មានព្រះភាគប្រថាប់នៅក្នុងក្រុងអាឡវីប្រថាប់នៅជិតនគរអាឡវី ។ ទីលំនៅនោះមានក្នុងក្រុងអាឡវី ។

បានឮថា ព្រះរាជាព្រះនាមអាឡវកៈ ទ្រង់លះបង់អ្នករបាំ និងគ្រឿងឧបភោគផ្សេងៗ យាងទៅបរបាញ់សត្វរៀងរាល់ ៧ ថ្ងៃ ដើម្បីការពារចោរ ដើម្បីកំចាត់បច្ចាមិត្ត ដើម្បីកំញើញបដិរាជា និងដើម្បីធ្វើសេចក្តីព្យាយាម ។ ក្នុងថ្ងៃមួយ ទ្រង់បានធ្វើកតិកាជាមួយពួកពលថា ម្រឹគគេចទៅត្រង់មុខអ្នកណា ម្រឹគនោះ ត្រូវជាភារៈរបស់បុគ្គលនោះប៉ុណ្ណោះ ។ កាលនោះ ម្រឹគបានគេចទៅត្រង់មុខព្រះរាជា

អន្តនោះឯង ។ ព្រះរាជាទ្រង់សម្បូរដោយសម្ទុះ ទ្រង់ចាប់ធ្នូដេញតាមម្រឹគនោះ តែមួយព្រះអង្គឯង អស់ចម្ងាយផ្លូវ ៣ យោជន៍ ម្រឹគទ្រាយទាំងឡាយមានកម្លាំងរហ័សត្រឹម ៣ យោជន៍ប៉ុណ្ណោះ ។

លំដាប់នោះ ព្រះរាជាទ្រង់សម្លាប់ម្រឹគនោះដែលខ្សោយកម្លាំង ចុះទឹកហើយឈរ កាត់ម្រឹគនោះជាពីរកំណាត់ ទ្រង់មិនត្រូវការសាច់ តែដើម្បីដោះនូវការចោទប្រកាន់ថា ព្រះរាជាមិនអាចសម្លាប់ម្រឹគនោះបាន ទើបទ្រង់រែកសាច់យាងមក ។ ទ្រង់ឃើញដើមជ្រៃធំ មានស្លឹកខៀវក្រាស់ក្នុងទីមិនឆ្ងាយអំពីព្រះនគរ ទ្រង់យាងចូលគាន់គល់ជ្រៃនោះ ដើម្បីបន្ទោបង់នូវការនឿយហត់ក្នុងដើមជ្រៃនោះ មានយក្ខឈ្មោះអាឡវកៈ បានពរអំពីសម្នាក់ព្រះបាទវេស្សវណមហារាជ ឲ្យស៊ីសត្វទាំងឡាយដែលចូលទៅកាន់បរិវេណ ដែលស្រមោលត្រង់ម្លប់ដើមជ្រៃនោះ ផ្សាយទៅដល់ក្នុងពេលថ្ងៃត្រង់ អាស្រ័យនៅ យក្ខនោះ ឃើញព្រះរាជានោះ ក៏ចូលមកដើម្បីទំពាស៊ី ព្រះរាជាទ្រង់ធ្វើកតិកានឹងយក្ខនោះថា ចូរលែងខ្ញុំ ខ្ញុំត្រូវលែងនឹងបញ្ជូនមនុស្ស និងថាសអាហាររាល់ៗ ថ្ងៃ ។ យក្ខទូលថា ទ្រង់រវល់ស្រវឹងដោយរាជូបភោគ ទ្រង់នឹងភ្លេច ចំណែកខ្ញុំនឹងមិនបានស៊ីមនុស្ស ដែលមិនចូលមកកាន់លំនៅ និងមនុស្សដែលមិនបានអនុញ្ញាត ខ្ញុំត្រូវបរិភោគទ្រង់ ទើបរស់នៅបាន ដូច្នេះទើបមិនលែង ។ ព្រះរាជាទ្រង់យល់ព្រមថា បើខ្ញុំមិនបញ្ជូនមនុស្សមកក្នុងថ្ងៃណា ចូរអ្នកចាប់ខ្ញុំស៊ីក្នុងថ្ងៃនោះ យក្ខនោះលែងហើយ ទើបចៀសចេញទៅ

ទ្រង់បែរមុខទៅកាន់ព្រះនគរ ។

វេលាពេលបោះព្រះពន្លារង់ចាំផ្លូវ ឃើញព្រះរាជាហើយ ទូលថា បពិត្រមហារាជ ទ្រង់នឿយហត់យ៉ាងនេះ ព្រោះខ្លាចហេតុត្រឹមតែការមិនសមព្រះកិត្តិយសឬ ទើបសម្ដែងការទទួល ព្រះរាជាត្រាស់ប្រាប់ព្រឹត្តិការណ៍នោះ យាងទៅកាន់ព្រះនគរ សោយព្រះក្រយាហារព្រឹកហើយ ត្រាស់ហៅអ្នករក្សាព្រះនគរមកប្រាប់រឿងនោះ អ្នករក្សាព្រះនគរទូលថា បពិត្រព្រះសម្មតិទេព ទ្រង់កំណត់កាលឬ ព្រះរាជាត្រាស់ថា យើងមិនបានកំណត់កាលឡើយ អ្នករក្សានគរទូលថា បពិត្រព្រះសម្មតិទេព ទ្រង់ធ្វើមិនប្រពៃ ព្រោះអមនុស្សទាំង-ឡាយរមែងបានកាលដែលកំណត់ហើយប៉ុណ្ណោះ តែបើទ្រង់មិនកំណត់កាល ជនបទនឹងមានសេចក្ដីលំបាក ណ្ហើយចុះ ព្រះអង្គទ្រង់ធ្វើយ៉ាងនេះក៏ពិត តែសូមទ្រង់ខ្វល់ខ្វាយតិច សោយនូវរាជសម្បត្តិចុះ ទូលបង្គំនឹងធ្វើវត្ថុដែលគួរធ្វើក្នុងរឿងនេះ ។

អ្នករក្សានគរនោះ ក្រោកឡើងតាមកាលនោះឯងទៅកាន់គុក ពោលសំដៅដល់អ្នកទោសទាំងឡាយ ដែលត្រូវសម្លាប់ថា អ្នកណាត្រូវការជីវិត អ្នកនោះចូរចេញមក ដូច្នេះហើយ ទទួលយកអ្នកទោសដែលចេញមកមុនគេឲ្យងូតទឹក និងឲ្យបរិភោគហើយ បញ្ជូនទៅថា ចូរឯងឲ្យថាសអាហារនេះដល់យក្ខ យក្ខនិម្មិតអត្តភាពដែលគួរតក់ស្លុត ហើយទំពាស៊ីអ្នកទោសនោះ ដោយគ្រាន់តែគេចូលមកខាងក្នុងគល់ឈើនោះឯង ដូចស៊ីមើមជំឡូង បានឮថា ដោយ

អានុភាពរបស់យក្ខ សរីរៈទាំងមូល មានសរសៃសក់ជាដើម របស់មនុស្ស ទាំងឡាយ ដូចគ្នានឹងជុំនវនីត បុរសដែលទៅដើម្បីឲ្យអ្នកទោសកាន់កត្តឲ្យ ដល់យក្ខ ឃើញយក្ខនោះហើយខ្លាច ទើបប្រាប់ដល់មិត្តសម្លាញ់ ។

ចាប់តាំងអំពីនោះ មនុស្សទាំងឡាយចោទគ្នានិងគ្នាថា ព្រះរាជាចាប់ចោរ ឲ្យដល់យក្ខ បានវៀរចាកចោរកម្ម ដោយសម័យដទៃអំពីនោះ គុកទាំងឡាយ ក៏ទទេ ព្រោះចោរក្នុងកាលមុនអស់ទៅ ចោរថ្មីទាំងឡាយមិនមាន លំដាប់នោះ អ្នករក្សាព្រះនគរ ក៏ទូលដល់ព្រះរាជា ។ ព្រះរាជាឲ្យចោលថង់ព្រះរាជទ្រព្យ ត្រង់ច្រកនៃព្រះនគរទាំងឡាយដោយទ្រង់បំណងថា គង់មានអ្នកណារើសយក ទ្រព្យដោយការចង់បានខ្លះ ក៏មិនមានអ្នកណាពាល់ត្រូវទ្រព្យនោះ សូម្បីដោយ ជើង អ្នករក្សានគរនោះកាលមិនបានចោរទាំងឡាយ ទើបប្រាប់ដល់អមាត្យ ទាំងឡាយ អមាត្យទាំងឡាយក៏ទូលថា ពួកទូលបង្គំនឹងបញ្ជូនមនុស្សចាស់ តាមលំដាប់ត្រកូល មួយត្រកូលម្នាក់ៗ ទៅឲ្យ ព្រោះដោយប្រក្រតី មនុស្ស ចាស់ទាំងនោះ ក៏ជិតស្លាប់ដែរហើយ ។ ព្រះរាជាឃាត់ថា មនុស្សទាំងឡាយ នឹងធ្វើការជំទាស់ថា ព្រះរាជាបញ្ជូនឪរបស់ពួកយើង តារបស់ពួកយើងឲ្យ ទៅស្លាប់ ពួកអ្នកកុំគាប់ចិត្តក្នុងសេចក្ដីនោះឡើយ ។ ពួកអមាត្យក្រាបទូល ថា បពិត្រព្រះសម្មតិទេព បើយ៉ាងនោះ ពួកទូលបង្គំនឹងបញ្ជូនទារកដែលនៅ ដេកផ្ងារ ព្រោះទារកបែបនោះ មិនមានការជាប់ជំពាក់ថា ម៉ែរបស់អញ ឪ របស់អញ ព្រះរាជាទ្រង់ក៏អនុញ្ញាត ។ អមាត្យទាំងនោះ ក៏បានធ្វើយ៉ាងនោះ

ពួកមាតារបស់ទារកក្នុងព្រះនគរ ក៏នាំពួកទារក និងស្ត្រីមានគភ៌ ចៀសចេញទៅ ឲ្យទារកទាំងឡាយធំធាត់ក្នុងជនបទដទៃហើយ ទើបនាំត្រឡប់មក យ៉ាងនេះរហូតអស់ ១២ ឆ្នាំ ។

បន្ទាប់អំពីនោះ ថ្ងៃមួយ ពួកអមាត្យ ដើររកពេញព្រះនគរក៏មិនបានកូនក្មេងត្រឹមតែម្នាក់ ទើបទូលដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព ក្នុងព្រះនគរមិនមានទារក មានតែអាឡវកកុមារ ព្រះរាជឱរសរបស់ព្រះអង្គ ខាងក្នុងបុរី ។ ព្រះរាជាត្រាស់ថា កូនរបស់យើង រមែងជាទីស្រឡាញ់ យ៉ាងណាបុគ្គលជាទីស្រឡាញ់ក្រៃលែងជាងខ្លួន រមែងមិនមានដល់សត្វលោក ដូច្នោះទៅចុះ ចូរឲ្យអាឡវកកុមារនោះហើយ រក្សាជីវិតរបស់យើង ។ ដោយសម័យនោះ ព្រះរាជមាតារបស់អាឡវកកុមារ ឲ្យព្រះឱរសងូតទឹកហើយ ប្រដាប់តាក់តែង ពាក់ធ្នូតដែលធ្វើដោយសំពត់សម្បកឈើ ឲ្យផ្ទំលើភ្លៅ ប្រថាប់គង់ហើយ ។ រាជបុរសទាំងឡាយទៅក្នុងទីនោះ តាមព្រះតម្រាស់របស់ព្រះរាជាបានមកយកព្រះរាជកុមារនោះអំពីព្រះមាតានោះ ដែលកំពុងខ្សឹកខ្សួល មួយអន្លើដោយកីលៀង ១៦០០០ នាក់ ចៀសចេញទៅ ដោយពោលថា ព្រះរាជកុមារនឹងក្លាយជាចំណីរបស់យក្ខ ក្នុងថ្ងៃស្អែកនេះ ។

សម័យនោះ ព្រះដ៏មានព្រះភាគទ្រង់តើនឡើងក្នុងបច្ចូសសម័យ ទ្រង់ចូលមហាករុណាសមាបត្តិក្នុងព្រះគន្ធកុដិ ត្រង់ជេតពនមហាវិហារ កាលទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ឃើញឧបនិស្ស័យអនាគាមិផល

របស់អាឡវកកុមារ និងការសម្រេចសោតារបស់យក្ខ និងក្នុងកាលចប់ទេសនា សត្វ ៨៤០០០ បាននូវធម្មចក្ខុ ព្រោះដូច្នោះ កាលរាត្រីអស់ហើយ ទ្រង់ធ្វើបុរេកត្តកិច្ចស្រេចហើយ តែទ្រង់ធ្វើបច្ឆាកត្តកិច្ចមិនទាន់សម្រេច ។ កាលថ្ងៃឧបោសថនៃកាឡបក្ខប្រព្រឹត្តទៅ ព្រះអាទិត្យរះឡើងហើយ ទ្រង់តែមួយអង្គឯង មិនមានសម្លាញ់ កាន់នូវបាត្រ និងចីវរ យាងទៅអស់ចម្ងាយផ្លូវ ៣ យោជន៍ អំពីក្រុងសាវត្ថី ដោយព្រះបាទនោះឯង ទ្រង់ចូលទៅកាន់លំនៅរបស់យក្ខនោះ ដោយហេតុនោះ ទើបលោកពោលថា ក្នុងលំនៅរបស់អាឡវកយក្ខ ។

សួរថា ព្រះដ៏មានព្រះភាគគង់នៅត្រង់គល់ជ្រៃ ដែលជាលំនៅរបស់អាឡវកយក្ខ ឬក្នុងទីលំនៅដែលជាទីនៅប៉ុណ្ណោះ ។

ឆ្លើយថា ក្នុងទីលំនៅប៉ុណ្ណោះ ព្រោះថា យក្ខទាំងឡាយ រមែងឃើញទីលំនៅរបស់ខ្លួនដោយប្រការណា សូម្បីព្រះដ៏មានព្រះភាគ ក៏គង់នៅដោយប្រការនោះ ទ្រង់យាងទៅក្នុងទីនោះ ឈរត្រង់ទ្វារលំនៅ ។ ក្នុងកាលនោះ អាឡវកយក្ខ ទៅកាន់សមាគមនៃយក្ខ ក្នុងហិមវន្តប្បទេស បន្ទាប់អំពីនោះ យក្ខឈ្មោះគទ្រភៈ ជាអ្នករក្សាទ្វាររបស់អាឡវកយក្ខ ចូលទៅរកព្រះដ៏មានព្រះភាគ ថ្វាយបង្គំហើយ ទូលថា បពិត្រព្រះអង្គ ទ្រង់យាងមកក្នុងវិកាលឬ ព្រះសាស្តាត្រាស់ថា ម្នាលគទ្រភៈ យ៉ាងនោះឯង តថាគតមកហើយ បើអ្នកមិនទើសទាល់ តថាគតស្នាក់នៅក្នុងលំនៅរបស់អាឡវកយក្ខមួយរាត្រី គទ្រភៈ

ទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនទើសទាល់ទេ តែអាឡវកយក្ខនោះយោរយៅ គ្រោតគ្រាត មិនធ្វើកិច្ច មានការសំពះជាដើម សូម្បីតែឪពុកម្តាយរបស់ខ្លួន សូមទ្រង់កុំគាប់ចិត្តនៅក្នុងទីនេះឡើយ ព្រះសាស្តាត្រាស់ថា ម្នាលគទ្រភៈ តថាគតដឹងថា យក្ខនោះកាច តែអន្តរាយណាមួយមិនមានដល់តថាគតទេ បើអ្នកមិនទើសទាល់ តថាគតស្នាក់នៅមួយយប់ចុះ ។

គទ្រភយក្ខ បានទូលពាក្យនេះនឹងព្រះសាស្តាលើកទី ២ ថា បពិត្រព្រះអង្គ អាឡវកយក្ខដូចគ្នានឹងអំបែងក្តៅ មិនដឹងថាមាតាបិតា សមណព្រាហ្មណ៍ ឬធម៌ឡើយ រមែងខ្ទេះបេះដូងរបស់ពួកមនុស្សដែលមកក្នុងទីនេះ បោះចោលខ្លះ រមែងហែកបេះដូងខ្លះ ចាប់ជើងគ្រវែងទៅត្រើយសមុទ្រដទៃ ឬចក្កវាឡដទៃខ្លះ ។

សូម្បីក្នុងលើកទី ២ ព្រះសាស្តាក៏នៅតែត្រាស់ថា ម្នាលគទ្រភៈ តថាគតដឹង បើអ្នកមិនទើសទាល់ តថាគតស្នាក់នៅមួយយប់ចុះ ។

ក្នុងលើកទី ៣ គទ្រភយក្ខ បានទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គ អាឡវកយក្ខដូចគ្នានឹងអំបែងត្រូវភ្លើង រមែងមិនដឹងថា មាតាបិតា ឬសមណព្រាហ្មណ៍ ឬធម៌ រមែងធ្វើនូវការខ្ទេះហទយៈរបស់ពួកមនុស្សដែលមកក្នុងទីនេះ បោះចោលខ្លះ ហែកបេះដូងខ្លះ ចាប់ជើងបោះទៅកាន់ត្រើយសមុទ្រដទៃ ឬចក្កវាឡដទៃខ្លះ ។

ក្នុងលើកទី ៣ ព្រះដ៏មានព្រះភាគក៏នៅតែត្រាស់ថា ម្នាលគទ្រភៈ

តថាគតដឹង បើអ្នកមិនទើសទាល់ តថាគតស្នាក់នៅត្រឹមមួយរាត្រី គទ្រភយក្ខពោលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនទើសទាល់ឡើយ តែយក្ខនោះ គប្បីសម្លាប់ខ្ញុំព្រះអង្គ ដែលមិនប្រាប់ដល់ខ្លួន ហើយអនុញ្ញាត បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងប្រាប់ដល់យក្ខនោះ ព្រះសាស្តាត្រាស់ថា ម្នាលគទ្រភៈ ចូរអ្នកប្រាប់តាមសប្បាយចុះ ។ គទ្រភៈទូលថា បពិត្រព្រះអង្គ បើយ៉ាងនោះ សូមទ្រង់ដឹង ដូច្នេះ អភិវាទព្រះដ៏មានព្រះភាគហើយ មានមុខទៅកាន់ហិមវន្តប្បទេស។ ទ្វារនៃលំនៅក៏បើកឯងដល់ព្រះដ៏មានព្រះភាគ ។

ព្រះដ៏មានព្រះភាគ យាងចូលខាងក្នុងលំនៅ គង់ក្នុងរតនបល្ល័ង្កដែលជាទិព្វ ដែលអាឡវកយក្ខនោះសោយសិរីក្នុងថ្ងៃទាំងឡាយ មានថ្ងៃមង្គលជាដើមដែលកំណត់ហើយ ទ្រង់បញ្ចេញពន្លឺដូចមាស ។ ស្រីទាំងឡាយរបស់យក្ខ ឃើញព្រះដ៏មានព្រះភាគនោះហើយ មកថ្វាយបង្គំព្រះដ៏មានព្រះភាគអង្គុយចោមរោម ព្រះដ៏មានព្រះភាគត្រាស់បកិណ្ណកធម្មកថាដល់ស្រីទាំងនោះដោយន័យជាដើមថា ក្នុងកាលមុនពួកនាងបានឲ្យទាន សមាទានសីល បូជាបុគ្គលដែលគួរបូជា ទើបបានដល់នូវសម្បត្តិនេះ សូម្បីក្នុងឥឡូវនេះ ចូរនាងធ្វើយ៉ាងនោះឯង កុំឲ្យការប្រណែន និងការកំណាញ់គ្របសង្កត់ដល់គ្នានិងគ្នាឡើយ ស្រីទាំងនោះ ស្តាប់ព្រះសូរសៀងដ៏ពីរោះរបស់ព្រះដ៏មានព្រះភាគហើយឲ្យសាធុការអស់ពាន់ដង អង្គុយចោមរោមព្រះដ៏មានព្រះភាគនោះឯង ចំណែកគទ្រភយក្ខទៅកាន់ហិមវន្តប្បទេស ប្រាប់ដល់អាឡវកយក្ខថា បពិត្រលោក

និរទុក្ខ សូមលោកជ្រាបថា ព្រះដ៏មានព្រះភាគគង់ក្នុងវិមានរបស់លោក អាឡវកយក្ខនោះ បានធ្វើសញ្ញាដល់គទ្រភៈថា នៅឲ្យស្ងៀម យើងនឹងដឹងកិច្ចដែលគួរធ្វើ ។ បានឮថា អាឡវកយក្ខនោះ ខ្មាសហើយ ដោយមានះរបស់បុរស ព្រោះដូច្នោះ ទើបឃាត់ថា អ្នកណាមួយក្នុងចំណោមបរិស័ទ កុំបីបានឮ ។

ក្នុងកាលនោះ សាតាគិរយក្ខ និងហេមវតយក្ខបបួលគ្នាថា ពួកយើងថ្វាយបង្គំព្រះដ៏មានព្រះភាគត្រង់វត្តជេតពនហើយ សឹមទៅកាន់សមាគមយក្ខមួយអន្លើដោយបរិវារ ទៅតាមអាកាសដោយយានផ្សេងៗ ឯយក្ខទាំងឡាយមិនមានផ្លូវក្នុងអាកាសគ្រប់អន្លើ មានតែផ្លូវក្នុងទីដែលជាផ្លូវលើវិមានមាសទាំងឡាយ ដែលតាំងនៅក្នុងអាកាស ចំណែកវិមានរបស់អាឡវកយក្ខ តាំងនៅលើដី ព័ទ្ធដោយកំពែងដែលរក្សាល្អហើយ មានទ្វារ ប៉ម និងខ្លោងទ្វារដែលរៀបចំយ៉ាងល្អ ខាងលើបិទដោយសំណាញ់សំរឹទ្ធិ ដូចគ្នានឹងហិបកម្ពស់ ៣ យោជន៍ ផ្លូវរមែងមានលើវិមាននោះ យក្ខទាំងនោះ មកកាន់ប្រទេសនោះហើយ មិនអាចទៅបាន ។ ពិតហើយ បុគ្គលណាម្នាក់ មិនអាចទៅដោយចំណែកខាងលើនៃឱកាស ដែលព្រះពុទ្ធទាំងឡាយគង់នៅ រហូតដល់ភវគ្គ-ព្រហ្ម ។ យក្ខនោះគិតថា នេះអ្វីហ្ន៎ ឃើញព្រះដ៏មានព្រះភាគហើយ ចុះមកដូចដុំដី ដែលគេបោះទៅក្នុងអាកាស ដូច្នោះ ថ្វាយបង្គំហើយ ស្តាប់ធម៌ ធ្វើប្រទក្សិណទូលថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គទៅកាន់សមាគមយក្ខ សរសើរ

រតនៈ ៣ ហើយទៅកាន់យក្ខសមាគម ។ អាឡវកយក្ខ ឃើញសាតាគិរយក្ខ និងហេមវតយក្ខហើយ ពោលថា ចូរឯងអង្គុយក្នុងទីនេះ ហើយថយឲ្យឱកាស យក្ខទាំងពីរនោះប្រកាសដល់អាឡវកយក្ខថា នែសម្លាញ់អាឡវកៈ ការដែលព្រះដ៏មានព្រះភាគគង់នៅក្នុងលំនៅរបស់ឯង ជាលាភរបស់ឯង ទៅចុះអាវុសោ ចូរអង្គុយជិតព្រះដ៏មានព្រះភាគ ដូច្នេះ ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងទីនោះឯងយ៉ាងនេះ មិនបានគង់នៅត្រង់គល់ជ្រៃ ដែលជាលំនៅរបស់អាឡវកយក្ខឡើយ ព្រោះហេតុនោះ ទើបព្រះអានន្ទពោលថា សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងលំនៅរបស់អាឡវកយក្ខ ក្បែរក្រុងអាឡវី ដូច្នេះ ។

គ្រានោះឯង អាឡវកយក្ខ ។បេ។ បានពោលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា នែសមណៈ ចូរចេញទៅ ។ សួរថា ព្រោះហេតុអ្វី ទើបអាឡវកយក្ខនេះទូលយ៉ាងនោះ ខ្ញុំនឹងឆ្លើយ ព្រោះភាពដែលអាឡវកយក្ខបំណងនឹងជេរ ក្នុងសេចក្តីនេះ គប្បីជ្រាបសម្ពន្ធតាំងអំពីដើមយ៉ាងនេះថា ព្រោះសទ្ធាកថា ធ្វើបានលំបាកដល់បុគ្គលដែលមិនមានសទ្ធា ដូចសីលកថាជាដើម ធ្វើបានលំបាកដល់បុគ្គលទាំងឡាយ ដែលទ្រុស្តសីលជាដើម ព្រោះដូច្នោះ អាឡវកយក្ខនេះ បានស្តាប់ការសរសើរព្រះដ៏មានព្រះភាគ អំពីសម្នាក់របស់យក្ខទាំងនោះហើយ ជាអ្នកមានដួងហទយៈក្តៅរោលរាល ដោយសេចក្តីក្រោធអំពីខាងក្នុង ដូចអំបិលបោះទៅក្នុងភ្លើង ដូច្នោះ ទើបពោលថា

បុគ្គលដែលចូលទៅកាន់លំនៅរបស់ខ្ញុំ ដែលឈ្មោះថាព្រះដ៏មានព្រះភាគនោះ គឺនរណា ។

យក្ខទាំងនោះ កាលពោលដោយន័យជាដើមថា អាវុសោ អ្នកមិនស្គាល់ព្រះដ៏មានព្រះភាគ ជាសាស្តារបស់ពួកយើង ដែលតាំងនៅក្នុងតុសិតភពហើយ ទ្រង់ប្រមើលមើលមហាវិលោកនៈ ៥ ទេឬ រហូតដល់ទ្រង់ប្រកាសធម្មចក្កឲ្យប្រព្រឹត្តទៅ ពោលដល់បុព្វនិមិត្ត ៣២ យ៉ាងក្នុងកាលទាំងឡាយ មានបដិសន្ធិជាដើម ហើយជាស់តឿនថា អាវុសោ ឯងមិនឃើញអស្ចារ្យទាំងនេះទេឬ អាឡវកយក្ខនោះ សូម្បីឃើញហើយក៏ពោលថា មិនឃើញ ព្រោះអំណាចនៃសេចក្តីក្រោធ ទើបយក្ខទាំងពីរពោលថា អាវុសោអាឡវកៈ ឯងឃើញឬមិនឃើញ ប្រយោជន៍អ្វីដោយឯង ដែលឃើញ ឬមិនឃើញ ឯងនឹងធ្វើអ្វីដល់ព្រះសាស្តារបស់យើង ដែលឯងជួបព្រះដ៏មានព្រះភាគនោះហើយ នឹងប្រាកដដូចកូនគោ ដែលទើបកើតក្នុងថ្ងៃនេះ ប្រាកដក្នុងទីជិតគោឧសភៈ ដែលមានគ្រឿងប្រដាប់ត្រង់បូក ដូចកូនដំរីចូលទៅជិតដំរីចុះប្រេង ដូចចចកចាស់នៅក្នុងទីជិតរាជសីហ៍ស្តេចម្រឹគ ដែលមានរាងកាយដ៏ល្អ ប្រដាប់ដោយកេសរដ៏ស្អាត ដូចក្អែកបាក់ស្លាប ចូលទៅជិតស្តេចគ្រុឌដែលមានរាងកាយធំដល់ ១៥០ យោជន៍ដូច្នោះ ចូរឯងទៅ ចូរធ្វើវត្ថុដែលឯងគប្បីធ្វើចុះ ។

កាលយក្ខទាំងពីរពោលយ៉ាងនេះហើយ អាឡវកយក្ខក្រោធ ក្រោកឡើងជាន់ផ្ទាំងមនោសិលាដោយជើងខាងឆ្វេង ជាន់កំពូលភ្នំកៃលាសប្រមាណ ៦០

យោជន៍ដោយជើងខាងស្តាំ ពោលថា ឥឡូវនេះ ចូរមើល តើសាស្តារបស់ពួកអ្នកមានអានុភាពច្រើន ឬយើងជាអ្នកមានអានុភាពច្រើន ។ កំពូលភ្នំកៃលាសនោះ ក៏ខ្ទាតកម្ទេចមកដូចដុំដែក ដែលត្រូវវាយខ្ទាយចេញមកដូច្នោះ អាឡវកយក្ខនោះ ឈរក្នុងទីនោះស្រែកលាន់រំពងថា យើង គឺអាឡវកៈ សំឡេងក៏ផ្សាយទៅពេញជម្ពូទ្វីប ។

បានឮថា សំឡេង ៤ ប្រភេទ បានឮពេញជម្ពូទ្វីប គឺសំឡេងដែលបុណ្ណកយក្ខសេនាបតីឈ្នះព្រះបាទធនញ្ជយកោរព្យ ដោយការភ្នាល់ ទះដៃប្រកាសថា យើងឈ្នះហើយ ១ សំឡេងដែលសក្កទេវរាជ កាលសាសនាព្រះដ៏មានព្រះភាគ ព្រះនាមកស្សបៈកំពុងវិនាស ទ្រង់ធ្វើវិស្សកម្មទេវបុត្រឲ្យជាសុនខប្រកាសទូទៅថា យើងនឹងខាំស៊ីភិក្ខុអាក្រក់ ភិក្ខុនីអាក្រក់ ឧបាសក ឧបាសិកា និងមនុស្សទាំងឡាយដែលជាអធម្មវាទី ១ សំឡេងដែលមហាបុរសក្នុងកាលក្សត្រ ៧ អង្គចូលដណ្តើមព្រះនគរបានហើយ ព្រោះហេតុនៃនាងបភាវតី ទើបបានលើកនាងបភាវតីដាក់លើកដំរីទៅជាមួយខ្លួន ចេញអំពីព្រះនគរហើយ ប្រកាសក្នុងកុសជាតកថា យើង គឺសីហស្សរកុសមហារាជ ១ សំឡេងដែលអាឡវកយក្ខ ឈរលើកំពូលភ្នំកៃលាសប្រកាសថា យើង គឺជាអាឡវកៈ ១ ។

ក្នុងកាលនោះ សំឡេងនោះ ក៏ដូចគ្នានឹងសំឡេងដែលយក្ខឈរត្រង់ទ្វារក្នុងជម្ពូទ្វីបទាំងមូល ប្រកាសកងរំពង និងសូម្បីហិមវន្តប្បទេសដែលមានទំហំ

៣ ពាន់យោជន៍ ក៏ញាប់ញ័រដោយអានុភាពរបស់យក្ខ អាឡវកយក្ខនោះធ្វើជាខ្យល់ឲ្យបក់ទៅ ដោយគិតថា យើងនឹងឲ្យសមណៈគេចទៅដោយខ្យល់នេះឯង ខ្យល់ មានខ្យល់ទិសខាងកើតជាដើមនោះតាំងឡើងហើយ អាចកាច់បំបាក់ភ្នំទាំងឡាយ ដែលមានប្រមាណកន្លះយោជន៍ ២ យោជន៍ ៣ យោជន៍ ដកនូវឫស និងគល់ឈើ ដើមឈើក្នុងព្រៃជាដើម តម្រង់ទៅកាន់អាឡវីនគរ ធ្វើទីទាំងឡាយ មានរោងដំរីជាដើមឲ្យខ្ទាត់ខ្ទាយ បក់នូវដំបូល និងឥដ្ឋឲ្យអណ្តែតទៅក្នុងអាកាស ព្រះដ៏មានព្រះភាគទ្រង់អធិដ្ឋានថា ភ័យនេះ កុំបីមានដល់សត្វណាមួយ ខ្យល់នោះ បក់ដល់ព្រះទសពលហើយ ក៏មិនអាចធ្វើសូម្បីត្រឹមតែជាយចីវរឲ្យកម្រើកបាន ។

បន្ទាប់អំពីនោះ អាឡវកយក្ខធ្វើនូវភ្លៀងធំឲ្យធ្លាក់ចុះដោយគិតថា យើងនឹងឲ្យទឹកលិចសមណៈស្លាប់ ភ្លៀងទាំងឡាយ ដែលតាំងឡើងដោយដុំពពករាប់រយរាប់ពាន់ជាដើម តាំងឡើងហើយក៏ធ្លាក់ចុះមកដោយរហ័សរបស់ក្រសែទឹកភ្លៀង ផែនដីក៏ធ្លុះជាដុំៗ បន្ទាប់អំពីនោះ មហាមេឃខាងលើនៃព្រៃ ក៏មិនអាចធ្វើត្រឹមតែតំណក់ទឹកឲ្យសើមត្រង់ចីវររបស់ព្រះទសពលបាន ។

បន្ទាប់អំពីនោះ អាឡវកយក្ខធ្វើភ្លៀងថ្មឲ្យធ្លាក់ចុះមក កំពូលភ្នំធំៗ ទន្ទិចគ្នាបែកផ្សែង ឆេះជាភ្លើង ធ្លាក់មកតាមអាកាស ដល់ព្រះទសពលហើយ ក៏ក្លាយជាលម្អិតទិព្វ និងកម្រងផ្កាទិព្វ បន្ទាប់អំពីនោះ ក៏ធ្វើភ្លៀងគ្រឿងប្រហារឲ្យធ្លាក់ចុះមក អាវុធទាំងឡាយដែលមានមុខម្ខាង ដែលមានមុខពីរខាង មាន

ដាវ លំពែង និងកាំបិតកោរជាដើម ក៏ទន្ទិច គឺបែកជាផ្សែង ឆេះជាភ្លើងធ្លាក់មកតាមអាកាស ដល់ព្រះទសពលហើយ ក៏ក្លាយជាផ្កាទិព្វ បន្ទាប់អំពីនោះ ក៏ធ្វើភ្លៀងរងើកភ្លើងឲ្យធ្លាក់ចុះមក រងើកភ្លើងមានពណ៌ដូចផ្កាចារ ក៏ធ្លាក់មកតាមអាកាស បានក្លាយជាផ្កាទិព្វរាយរាយ ទៀបព្រះបាទារបស់ព្រះទសពល បន្ទាប់អំពីនោះ ក៏ធ្វើភ្លៀងផេះធ្លាក់មកតាមអាកាស ក៏ក្លាយជាលម្អិតខ្លឹមចន្ទន៍ធ្លាក់ចុះទៀបបាទមូលរបស់ព្រះទសពល ។ បន្ទាប់អំពីនោះ ក៏ធ្វើភ្លៀងខ្សាច់ឲ្យធ្លាក់ចុះមក ជាខ្សាច់ល្អិតក្រៃលែង ក្លាយជាផ្សែង ឆេះជាអណ្ដាតភ្លើង មកតាមអាកាស ក៏ក្លាយជាផ្កាធ្លាក់ចុះ ទៀបបាទមូលរបស់ព្រះទសពល បន្ទាប់អំពីនោះ ក៏ធ្វើភ្លៀងភក់ឲ្យធ្លាក់ចុះមក ភ្លៀងភក់នោះក៏ក្លាយជាផ្សែង ឆេះជាភ្លើង មកតាមអាកាស ក៏ក្លាយជាគ្រឿងក្រអូបដែលជាទិព្វ ធ្លាក់ចុះទៀបបាទមូលរបស់ព្រះទសពល បន្ទាប់អំពីនោះ ក៏បណ្ដាលឲ្យកើតជាងងឹតអន្ធការ ដោយបំណងថា អញនឹងឲ្យសមណៈខ្លាច ហើយគេចទៅ ការងងឹតនោះ ដូចគ្នានឹងការងងឹតដែលប្រកបដោយអង្គ ៤ ដល់ព្រះទសពលហើយ ក៏អន្តរធានទៅ ដូចត្រូវកម្ចាត់ដោយពន្លឺនៃព្រះអាទិត្យ ដូច្នោះ ។

យក្ខកាលមិនអាចឲ្យព្រះដ៏មានព្រះភាគគេចទៅដោយខ្យល់ ភ្លៀង ភ្លៀងថ្ម ភ្លៀងគ្រឿងប្រហារ ភ្លៀងរងើកភ្លើង ភ្លៀងផេះ ភ្លៀងខ្សាច់ ភ្លៀងភក់ និងភ្លៀងងងឹត ៩ យ៉ាង យ៉ាងនេះហើយ ខ្លួនឯងក៏ចូលទៅរកព្រះដ៏មានព្រះភាគដោយសេនាប្រកបដោយអង្គ ៤ ដេរដាសទៅដោយពួកភូតបិសាច ដែល

មានរូបជាច្រើនប្រការ មានដៃកាន់គ្រឿងប្រហារច្រើនប្រភេទ គណៈភូតទាំងនោះ ធ្វើវត្ថុដែលប្លែកច្រើនប្រការ ដូចមកអំពីខាងលើព្រះដ៏មានព្រះភាគ ដោយវាចាថា អ្នកទាំងឡាយ ចូរចាប់ អ្នកទាំងឡាយ ចូរសម្លាប់ ។

ម្យ៉ាងទៀត ភូតទាំងនោះក៏មិនអាចចូលទៅជិត ព្រះដ៏មានព្រះភាគបានឡើយ ដូចរុយមិនអាចចូលជិតដុំដែកដែលក្តៅ កាលបើដូច្នោះ មារត្រង់ពោធិមណ្ឌល ត្រឡប់ទៅក្នុងខណៈដែលខ្ទួមកប៉ុណ្ណោះ យ៉ាងណា ភូតបិសាចទាំងនេះ មិនត្រឡប់យ៉ាងនោះឡើយ ធ្វើនូវការវឹកវរផ្សេងៗ ប្រមាណកន្លះយប់ អាឡវកយក្ខ កាលមិនអាចធ្វើព្រះដ៏មានព្រះភាគឲ្យញាប់ញ័របាន ដោយការសម្តែងវត្ថុដែលគប្បីខ្លាចជាអនេក ក្នុងកាលកន្លះរាត្រីកន្លងទៅហើយយ៉ាងនេះ ទើបគិតថា បើដូច្នោះ អញគប្បីលែងទុស្សាវុធ ដែលបុគ្គលណាម្នាក់ឈ្នះមិនបាន ។

បានឮថា អាវុធដែលប្រសើរបំផុតក្នុងលោក មាន ៤ គឺវជិរាវុធរបស់ព្រះឥន្ទ្រ ១ គទាវុធរបស់ព្រះបាទវេស្សវ័ណ ១ នយនាវុធរបស់ស្តេចយម ១ ទុស្សាវុធរបស់អាឡវកយក្ខ ១ ។

បានឮថា សក្កទេវរាជពិរោធហើយ គប្បីលែងវជិរាវុធតម្រង់ក្នុំសិនេរុសោត វជិរាវុធនោះ ក៏មុតភ្នំសិនេរុដែលមានកម្ពស់ ១ សែន ៦ ម៉ឺន ៨ ពាន់យោជន៍ ធ្លុះរហូតដល់ខាងក្រោម ។

គទាវុធរបស់ព្រះបាទវេស្សវ័ណ កាលដែលនៅជាបុថុជ្ជន បំបែកក្បាល

របស់យក្ខរាប់ពាន់ហើយ ត្រឡប់មកក្នុងដៃដូចដើម ។

កាលស្តេចយមខឹងក្រោធហើយ គ្រាន់តែសម្លឹងមើល កុម្ភណ្ឌច្រើនពាន់ក៏ឆេះជាផេះផង់ ដូចស្មៅ និងស្លឹកឈើដាក់លើអំបែងក្តៅ ដូច្នោះ ។

អាវឡវកក្រោធ បើលែងទុស្សាវុធទៅក្នុងអាកាសសោត ភ្លៀងក៏រាំងអស់ ១២ ឆ្នាំ បើលែងទៅលើផែនដីសោត ដើមឈើ និងស្មៅទាំងពួងក៏ងាប់អស់មិនដុះឡើងទៀតឡើយ អស់កាល ១២ ឆ្នាំ បើលែងទៅក្នុងសមុទ្រសោត ទឹកទាំងអស់ក៏គប្បីរីងស្ងួត ដូចតំណក់ទឹកដាក់លើអំបែងក្តៅដូច្នោះ បើលែងតម្រង់ភ្នំព្រះសិនេរុសោត ភ្នំក៏នឹងខ្ចាត់ខ្ចាយជាលម្អិតតូចធំ ។

អាឡវកយក្ខនោះ លែងនូវទុស្សាវុធដែលមានអានុភាពយ៉ាងនេះ ចាប់លើកឡើង ទេវតាក្នុងម៉ឺនលោកធាតុ ក៏ប្រញាប់មកប្រជុំគ្នាដោយគិតថា ថ្ងៃនេះ ព្រះដ៏មានព្រះភាគទ្រង់ទូន្មានអាឡវកៈ ពួកយើងនឹងស្តាប់ធម៌ក្នុងទីនោះ ទេវតាទាំងឡាយមិនប្រាថ្នាឃើញការច្បាំងក៏ប្រជុំគ្នា អាកាសទាំងមូលក៏ពេញដោយទេវតា ដោយប្រការដូច្នេះ អាឡវកយក្ខត្រាច់ទៅខាងលើ ក្នុងទីជិតព្រះដ៏មានព្រះភាគហើយ លែងនូវវត្ថាវុធៗ នោះ ក៏ធ្វើសំឡេងខ្លាំងគួរតក់ស្លុតក្នុងអាកាស ដូចរន្ទះ ក្លាយជាផ្សែង ឆេះជាភ្លើង មកដល់ព្រះដ៏មានព្រះភាគក្លាយជាសំពត់ជូតព្រះបាទា ធ្លាក់ទៀបបាទមូល ដើម្បីញាំញីនូវមានះរបស់យក្ខ ។ អាឡវកយក្ខឃើញហេតុនោះហើយ ក៏អស់តេជះ អស់មានះ ដូចគោឧសភៈ ដែលមានស្នែងបាក់ហើយ ដូចពស់ដែលដកចង្កូមហើយ ដូច្នោះ

ជាអ្នកមានទង់ គឺមានះដែលត្រូវដកហើយ គិតថា សូម្បីទុស្សព្រុជក៏មិនធ្វើឲ្យសមណៈខ្លាចបាន ព្រោះហេតុអ្វីហ្ន៎ បានឃើញហេតុនេះថា សមណៈប្រកបដោយមេត្តាវិហារធម៌ ណ្ហើយចុះ អញធ្វើឲ្យសមណៈនោះក្រោធហើយ នឹងបំផ្លាញមេត្តាដូច្នេះ ។ ទើបព្រះអានន្ទពោលសេចក្តីនេះដោយភ្ជាប់គ្នាថា **អថខោ អាឡវកោ យក្ខោ យេន ភគវា ។បេ។ និក្ខម សមណ** ដូច្នេះ ។

ក្នុងបាលីនោះ មានអធិប្បាយដូច្នេះថា ព្រោះអ្នកដែលខ្ញុំមិនបានអនុញ្ញាតហើយ ចូលទៅកាន់លំនៅរបស់ខ្ញុំ អង្គុយក្នុងកណ្តាលមាតុគ្រាម ដូចម្ចាស់ផ្ទះ ការបរិភោគវត្ថុដែលមិនបានឲ្យ និងការប្រឡូកប្រឡំដោយស្រីមិនសមគួរដល់សមណៈ មិនមែនឬ ព្រោះដូច្នោះ បើអ្នកតាំងនៅក្នុងសមណធម៌ ក៏ចូរទៅចុះ ។ ចំណែកអាចារ្យពួកខ្លះពោលថា អាឡវកយក្ខនេះ បានពោលពាក្យទាំងនេះ និងពាក្យគ្រោតគ្រាតដទៃហើយនោះឯង ទើបទូលពាក្យនេះ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា អាឡវកយក្ខជាបុគ្គលរឹងត្អឹង ដែលបុគ្គលណាម្នាក់មិនអាចទូន្មានដោយការរឹងត្អឹងបាន អាឡវកយក្ខនេះ កាលបុគ្គលធ្វើរឹងត្អឹង គេគប្បីកាចក្រៃលែង ជាអ្នករឹងត្អឹងខ្លាំងឡើង ដូចលាបប្រមាត់ត្រង់ច្រមុះឆ្កែកាច ដូច្នោះ តែអាចទូន្មានបានដោយការទន់ភ្លន់ ទើបទ្រង់ទទួលពាក្យរបស់អាឡវកយក្ខនោះ ដោយពាក្យជាទីស្រឡាញ់ថា សាធុ ដូច្នេះហើយ ទ្រង់ក៏ចុះចេញ ដោយហេតុនោះ ទើបព្រះអានន្ទពោលថា **សាធាវុសោតិ ភគវា និក្ខមិ** ដូច្នេះ ។

បន្ទាប់អំពីនោះ អាឡវកយក្ខ ជាអ្នកមានចិត្តទន់ភ្លន់ថា សមណៈនេះប្រដៅងាយហ្ន៎ ចេញទៅដោយពាក្យពោលត្រឹមតែម្តងប៉ុណ្ណោះ ការចេញទៅយ៉ាងនេះជាសុខ អញច្បាំងជាមួយសមណៈនេះអស់មួយយប់ ដោយហេតុដែលមិនសមគួរ ដូច្នេះហើយ ទើបគិតថា ឥឡូវនេះ អញអាចឈ្នះបានសមណៈនេះចេញទៅព្រោះភាពជាអ្នកប្រដៅងាយឬហ្ន៎ ឬព្រោះសេចក្តីក្រោធណ្ហើយចុះ អញនឹងសាកល្បងសមណៈនេះ ទើបពោលថា មកសមណៈលំដាប់នោះ ព្រះដ៏មានព្រះភាគ កាលត្រាស់ពាក្យដែលគួរស្រឡាញ់ទៀតដើម្បីទ្រង់ធ្វើចិត្តដែលទន់ភ្លន់ឲ្យមាំទាំថា ជាអ្នកប្រដៅងាយ ទើបត្រាស់ថាសាធុ ហើយចូលទៅ ។ អាឡវកយក្ខ កាលសាកល្បងភាពដែលព្រះដ៏មានព្រះភាគទ្រង់ជាអ្នកប្រដៅងាយនោះរឿយៗ ទើបពោលថា ចូរចេញទៅ ចូរចូលមក ក្នុងលើកទី ២ ខ្ញុំ ក្នុងលើកទី ៣ ខ្ញុំ ព្រះដ៏មានព្រះភាគក៏ទ្រង់ធ្វើយ៉ាងនោះ បើទ្រង់មិនធ្វើយ៉ាងនោះ ចិត្តរបស់អាឡវកយក្ខរឹងត្អឹងដោយប្រក្រតី ក៏រឹងរឹតតែរឹងត្អឹងឡើង មិនគប្បីជាភាជនៈដើម្បីទទួលធម្មកថា ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើវត្ថុ ដែលយក្ខនោះបាននិយាយដើម្បីឲ្យយក្ខយំ ដោយការយំ គឺកិលេស ព្រមទទួល ដូចមាតាឲ្យ ឬធ្វើវត្ថុដែលបុត្តត្រូវការ ដើម្បីឲ្យបុត្រនោះយំ ព្រមទទួល ដូច្នោះ ដូចមេដោះឲ្យរបស់ណាមួយដល់ទារកមិនបៅដោះ ពោលលួងលោមហើយ រមែងឲ្យបៅបានយ៉ាងណា ព្រះដ៏មានព្រះភាគ ក៏ដូច្នោះដូចគ្នា ទ្រង់ពោលលួងលោមដោយ

ត្រាស់ពាក្យដែលយក្ខប្រាថ្នា ដើម្បីឲ្យយក្ខនោះបានបៅដោះ គឺលោកុត្តរធម៌ ទើបត្រាស់យ៉ាងនេះ ដូចបុរសដែលត្រូវការឲ្យនូវមធុរស ៤ យ៉ាងពេញក្នុងឃ្លោក ទើបឲ្យជម្រះខាងក្នុងរបស់ឃ្លោកនោះឲ្យស្អាត យ៉ាងណា ព្រះដ៏មានព្រះភាគក៏ដូច្នោះដូចគ្នា ទ្រង់ញ៉ាំងមធុរស ៤ យ៉ាង គឺលោកុត្តរធម៌ឲ្យពេញក្នុងចិត្តរបស់យក្ខ ទើបទ្រង់ធ្វើនូវការយាងចេញទៅ និងចូលមកអស់វារៈ ៣ ដង ដើម្បីជម្រះមន្ទិល គឺសេចក្ដីក្រោធខាងក្នុងនៃយក្ខនោះ ។

គ្រានោះ អាឡវកយក្ខញ៉ាំងចិត្តអាក្រក់ឲ្យកើតឡើងថា សមណៈនេះជាអ្នកប្រដៅងាយ ត្រូវអញពោលថា ចូរចេញ ក៏ចេញ អញពោលថា ចូរមក ក៏ចូល បើដូច្នោះ អញនឹងធ្វើសមណៈនេះឲ្យលំបាកមួយយប់ទល់ភ្លឺយ៉ាងនេះឯង ហើយចាប់ជើងទាំងពីរ បោះទៅត្រើយម្ខាងស្ទឹងគង្គា ដូច្នេះ ទើបពោលលើកទី ៤ ថា ចូរចេញទៅសមណៈ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបហេតុនោះ ទើបត្រាស់ថា **ន ខ្វាហំ** ដូច្នេះ ទ្រង់ជ្រាបថា កាលតថាគតពោលយ៉ាងនេះហើយ យក្ខស្វែងរកវត្ថុដែលគួរធ្វើឲ្យក្រៃលែងជាងនោះ និងសម្គាល់បញ្ហាដែលគប្បីសួរ សេចក្ដីនោះ នឹងជាការងាយស្រួលដល់ធម្មកថា ទើបត្រាស់ថា **ន ក្វាហំ តំ** ជាដើម ។

ក្នុងបទទាំងនោះ សព្ទថា **ន** ប្រើក្នុងការបដិសេធ ។ សព្ទថា **ខោ** ប្រើក្នុងអវធារណៈ ។ បទថា **អហំ** បានដល់ ការសម្ដែងដល់ខ្លួន ។ បទថា **តំ** ជាការពោលដល់ហេតុ ។ ដោយហេតុនោះ អ្នកសិក្សាគប្បីឃើញអត្ថក្នុងទីនេះ យ៉ាងនេះថា ព្រោះអ្នកគិតយ៉ាងនេះ ព្រោះហេតុនោះ តថាគតនឹងមិន

ចេញ អ្នកចូរធ្វើវត្ថុដែលអ្នកគប្បីធ្វើចុះដូច្នេះ ។

បន្ទាប់អំពីនោះ អាឡវកយក្ខ ព្រោះក្នុងកាលមុនបានសួរបញ្ហានឹងតាបស ឬបរិព្វាជកដែលមានឫទ្ធិ មកកាន់វិមានរបស់ខ្លួន ក្នុងពេលទៅក្នុងអាកាស យ៉ាងនេះថា វិមាននេះជាវិមានមាស ឬវិមានប្រាក់ និងវិមានកែវមណីណាមួយ យើងនឹងចូលទៅកាន់វិមាននោះ ដូច្នេះហើយ ទើបបៀតបៀនតាបស និងបរិព្វាជកទាំងនោះ ដែលមិនអាចឆ្លើយបាន ដោយធ្វើចិត្តឲ្យរវើរវាយជាដើម ។ សួរថា បៀតបៀនដូចម្តេច ឆ្លើយថា អមនុស្សទាំងឡាយ រមែងធ្វើចិត្តឲ្យរាយមាយដោយអាការ ២ យ៉ាង គឺដោយការបង្ហាញរូបគួរខ្លាច ឬដោយការប្រចាប់បេះដូង យក្ខនេះដឹងថា បុគ្គលមានឫទ្ធិទាំងឡាយ រមែងខ្លាច ដោយការបង្ហាញរូបដែលគួរខ្លាច ហើយនិម្មិតអត្តភាពល្អិត ដោយអំណាចឫទ្ធិរបស់ខ្លួន ចូលទៅខាងក្នុងអ្នកមានឫទ្ធិទាំងនោះ ហើយប្រចាប់ហទយៈ បន្ទាប់អំពីនោះ តំណនៃចិត្តក៏មិនប្រាកដ កាលតំណនៃចិត្តនោះមិនប្រាកដ បុគ្គលមានឫទ្ធិនោះ ក៏ក្លាយជាឆ្កួត ឬមានចិត្តអណ្តែតអណ្តូង ។ ដោយប្រការនេះ យក្ខក៏ពុះទ្រូងរបស់បុគ្គលដែលរាយមាយនោះយ៉ាងនេះខ្លះ ហើយចាប់ជើងជនទាំងនោះ គ្រវែងទៅត្រង់ត្រើយនាយនៃស្ទឹងគង្គាខ្លះ ដោយគិតថា បុគ្គលមានឫទ្ធិបែបនេះ កុំមកកាន់លំនៅរបស់អញទៀតឡើយ ព្រោះហេតុនោះ ទើបរឭកដល់បញ្ហាទាំងនោះ ហើយគិតថា បើដូច្នោះ អញគប្បីបៀតបៀនសមណៈនេះយ៉ាងនេះ ទើបពោលថា **បញ្ហន្តំ សមណ** ជាដើម ។

សួរថា បញ្ហាទាំងនោះ យក្ខនោះបានមកអំពីណា ឆ្លើយថា បានឮថា មាតា និងបិតារបស់អាឡវកយក្ខនោះ ចូលទៅរកព្រះដ៏មានព្រះភាគ ព្រះនាមកស្សបៈ បានរៀន ៨ ប្រស្នា មួយអន្លើដោយចម្លើយ បានឲ្យអាឡវកៈរៀនបញ្ហានោះតាំងពីនៅក្មេង អាឡវកយក្ខនោះ ដោយកាលវេលាកន្លងទៅ ក៏ភ្លេចនូវចម្លើយ បន្ទាប់អំពីនោះ ក៏ប្រើជាតិហិង្គុ ចារឹកអក្សរលើជំបារមាស ដោយគិតថា បញ្ហានេះ ចូរកុំវិនាសឡើយ រក្សាក្នុងវិមាន ពុទ្ធប្បញ្ហានោះ ជាពុទ្ធវិស័យយ៉ាងនេះឯង ។

ព្រះដ៏មានព្រះភាគទ្រង់ស្តាប់ដូច្នោះហើយ ព្រោះបុគ្គលណាម្នាក់ មិនអាចធ្វើអន្តរាយនៃលាភ ដែលបរិច្ចាគដល់ព្រះដ៏មានព្រះភាគទាំងឡាយ ឬអន្តរាយនៃជីវិត ឬការទម្លាយនូវសព្វញ្ញុតញ្ញាណ និងរស្មីមួយព្យាម ដូច្នេះ កាលទ្រង់សម្តែងពុទ្ធានុភាព ដែលមិនទូទៅក្នុងលោកនោះ ទើបត្រាស់ថា **ន ខ្វាហន្តំ អាវុសោ បស្សាមិ សទេវកេ លោកេ** ជាដើម ។

បណ្តាបទទាំងនោះ ព្រះដ៏មានព្រះភាគ ត្រាស់សេចក្តីសង្ខេបដោយការសម្តែងត្រឹមតែអត្ថ នៃបទទាំងនោះ ដោយន័យជាដើមថា ទ្រង់កាន់យកកាមាវចរទេវតា ៥ ជាន់ ដោយពាក្យថា **សទេវកេ** ។ មិនត្រាស់សេចក្តីពិស្តារដោយលំដាប់នៃការប្រកបតាមអនុសន្ធិ ខ្ញុំនឹងពោលសេចក្តីពិស្តារនោះ ។ កាលទេវតាទាំងពួង សូម្បីទ្រង់កាន់យកហើយ ដោយការកំណត់យ៉ាងខ្ពស់ ដោយពាក្យថា **សទេវកេ** កាលពួកទេវតាប្រជុំក្នុងទីនោះ ទេវតាពួកណាមាន

សេចក្តីសង្ស័យថា វសវត្តីមារមានអានុភាពច្រើន ជាធំក្នុងកាមាវចរទាំង ៦ ជាន់ ត្រេកអរក្នុងធម៌ដែលជាសត្រូវ ស្អប់នូវធម៌ មានការឆោរឃោកទាប មារនោះមិនគប្បីធ្វើនូវការរាយមាយនៃចិត្តជាដើម ដល់ព្រះដ៏មានព្រះភាគអង្គនោះឬហ្ន៎ ដូច្នេះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **សមារកេ** ដើម្បីការពារនូវសេចក្តីសង្ស័យរបស់ទេវតាទាំងនោះ ។

បន្ទាប់អំពីនោះ ទេវតាពួកណាមានសេចក្តីសង្ស័យថា ព្រហ្មមានអានុភាពច្រើន រមែងធ្វើចក្កវាឡមួយពាន់ឲ្យភ្លឺដោយម្រាមដៃមួយ ដោយម្រាមដៃ ២ ។បេ។ ក្នុងម៉ឺនចក្កវាឡ សោយសុខក្នុងឈាន និងសមាបត្តិដ៏កំពូល ព្រហ្មនោះ មិនគប្បីធ្វើឬ ដើម្បីការពារសេចក្តីសង្ស័យរបស់ទេវតាទាំងនោះ ទើបត្រាស់ថា **សព្រហ្មកេ** ។

លំដាប់នោះ ទេវតាពួកណាមានសេចក្តីសង្ស័យថា សមណព្រាហ្មណ៍បុថុជ្ជន ជាសត្រូវ ជាបច្ចាមិត្តចំពោះសាសនា ដល់ព្រមដោយកម្លាំង មានមន្តជាដើម សូម្បីសមណព្រាហ្មណ៍ដែលជាបុថុជ្ជននោះ មិនគប្បីធ្វើឬ ដើម្បីទ្រង់ការពារសេចក្តីសង្ស័យរបស់ទេវតាទាំងនោះ ទើបត្រាស់ថា **សស្សមណព្រាហ្មណិយា** ។

កាលទ្រង់សម្តែងការមិនមានអ្នកណា ក្នុងឋានៈខ្ពង់ខ្ពស់យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់សំដៅដល់សម្មតិទេព និងមនុស្សដ៏សេសទាំងឡាយ ដោយពាក្យថា **សទេវមនុស្សាយ** ហើយទ្រង់សម្តែងការមិនមានអ្នកណា សូម្បីក្នុង

សត្វដ៏សេស ដោយអំណាចនៃការកំណត់យ៉ាងខ្ពស់ ព្រោះហេតុនោះអ្នកសិក្សាគប្បីជ្រាបលំដាប់នៃការប្រកបអនុសន្ធិក្នុងទីនេះ ដោយប្រការដូច្នេះ ។

ព្រះដ៏មានព្រះភាគ ទ្រង់បដិសេធសេចក្ដីលំបាកនៃព្រះហឫទ័យដល់យក្ខនោះយ៉ាងនេះហើយ កាលទ្រង់ញុំាងឧស្សាហ៍ឲ្យកើតក្នុងការសួរបញ្ហា ទើបត្រាស់ថា ម្នាលអាវុសោ អ្នកប្រាថ្នានឹងសួរយ៉ាងណា ចូរសួរមកចុះ ដូច្នេះ ។

ព្រះបាលីនោះ មានអត្ថថា ចូរសួរ បើបំណងនឹងសួរ តថាគតមិនមានការទើសទាល់ក្នុងការសួរបញ្ហា ។ ម្យ៉ាងទៀត ទ្រង់ប្រាថ្នាដល់សព្វញ្ញុបវារណា ដែលមិនទូទៅដល់ព្រះបច្ចេកពុទ្ធ អគ្គសាវកពុទ្ធ និងមហាសាវកពុទ្ធទាំងឡាយថា បើអ្នកបំណងនឹងសួរក៏ចូរសួរ តថាគតនឹងឆ្លើយបញ្ហារបស់អ្នកទាំងអស់ពិតហើយ សូម្បីអ្នកទាំងនោះពោលថា ចូរសួរចុះ យើងខ្ញុំស្ដាប់ហើយនឹងដឹងតែព្រះពុទ្ធទាំងឡាយត្រាស់ថា ម្នាលអាវុសោ មួយទៀត បើអ្នកឯងចង់សួរក៏សួរចុះ ។ ឬថា បពិត្រវាសវៈ មហារាជមានព្រះហឫទ័យប្រាថ្នានឹងសួរនូវប្រស្នាណា ចូរសួរនូវប្រស្នានោះ ចំពោះតថាគតចុះ ដូច្នេះ រមែងបវារណាដល់សព្វញ្ញុបវារណា ដល់ទេវតា និងមនុស្សទាំងឡាយ ដោយន័យជាដើមថា

អ្នកទាំងឡាយ តថាគតបើកឱកាសឲ្យហើយ ចូរសួរនូវសេចក្ដីសង្ស័យទាំងអស់របស់ពាវរីព្រាហ្មណ៍ផង របស់អ្នកផង របស់ពួកជនទាំងអស់ផង ចូរប្រាថ្នាទុកក្នុងចិត្តនូវហេតុណាមួយចុះ

ដូច្នេះ ។

កាលដែលព្រះដ៏មានព្រះភាគទ្រង់សម្រេចពុទ្ធភូមិហើយ គប្បីបរិវណា នូវបរិវណានោះ មិនអស្ចារ្យឡើយ តែដែលអស្ចារ្យ គឺព្រះពោធិសត្វសូម្បី ប្រព្រឹត្តទៅក្នុងបទេសញ្ញាណ ក្នុងពោធិសត្តភូមិ ពួកឥសីទាំងឡាយសំណូមពរ យ៉ាងនេះថា

បពិត្រកោណ្ឌញ្ញៈ សូមលោកឆ្លើយនូវប្រស្នាទាំងឡាយ ឥសី ទាំងឡាយមានសភាពដ៏ល្អ អាពធនាលោក បពិត្រកោណ្ឌញ្ញៈ ការដោះប្រស្នានុ៎ះ ជាទំនៀមតែងមានក្នុងពួកមនុស្ស ប្រស្នាណា មកកាន់សេចក្តីចម្រើន ប្រស្នានុ៎ះ ជាភារៈរបស់លោក ដូច្នេះ ។

ត្រាច់ទៅកាន់ជម្ពូទ្វីបទាំងមូលអស់ ៣ ដង ក៏មិនបានជួបអ្នកឆ្លើយនូវ បញ្ហាបាន មានអាយុ ៧ ឆ្នាំអំពីកំណើត កំពុងលេងដីលើថ្នល់ កាលព្រាហ្មណ៍ ដែលប្រព្រឹត្តសុចរិតសួរហើយ ក្នុងកាលដែលព្រះពោធិសត្វ នៅជាសរភង្គ- តាបស និងក្នុងសម្ភវជាតក យ៉ាងនេះថា

លោកដ៏ចម្រើនទាំងឡាយ ខ្ញុំធ្វើឱកាសឲ្យហើយ ចូរសួរនូវ ប្រស្នាណានីមួយ ដែលលោកទាំងឡាយប្រាថ្នាហើយដោយចិត្ត ចុះ ព្រោះថា ខ្ញុំដឹងនូវលោកនេះ និងលោកខាងមុខ ដោយ ខ្លួនឯង នឹងឆ្លើយនូវប្រស្នានោះៗ ប្រាប់លោកទាំងឡាយបាន ដូច្នេះ ។

បានបវារណានូវសព្វញ្ញុបវារណាយ៉ាងនេះថា បើដូច្នោះ អ្នកឈ្មោះសូរ (និយាយ) យ៉ាងណា ខ្ញុំនឹងប្រាប់អ្នកយ៉ាងនោះ ព្រះរាជានឹងទ្រង់ជ្រាបនូវប្រស្នានោះ ទោះបីព្រះអង្គធ្វើតាមក្តី មិនធ្វើតាមក្តីដូច្នេះ ។

កាលសព្វញ្ញុបវារណា ដែលព្រះដ៏មានព្រះភាគ ទ្រង់បវារណាហើយដល់អាឡវកយក្ខយ៉ាងនេះហើយ លំដាប់នោះឯង អាឡវកយក្ខបានទូលសួរព្រះដ៏មានព្រះភាគដោយគាថាថា **កឹសូធ វិត្តំ** ដូច្នេះ ។

[ ១៨ ] បណ្តាបទទាំងនោះ បទថា **កឹ** ជាពាក្យសួរ សព្ទថា **សុ** ជានិបាត ប្រើក្នុងហេតុគ្រាន់តែធ្វើបទឲ្យពេញ ។ បទថា **ឥធ** បានដល់ ក្នុងលោកនេះ ។ បទថា **វិត្តំ** បានដល់ ឈ្មោះថា ទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត ព្រោះអត្ថថា ធ្វើនូវការត្រេកអរ ។ ពាក្យថា **វិត្តំ** នោះ ជាឈ្មោះនៃទ្រព្យ ។

បទថា **សុចិណ្ណំ** បានដល់ ធ្វើល្អហើយ ។ បទថា **សុខំ** បានដល់ សេចក្តីសុខផ្លូវកាយ និងសុខផ្លូវចិត្ត ។ បទថា **អាវហាតិ** សេចក្តីថា រមែងនាំមក នាំមកឲ្យ អធិប្បាយថា រមែងឲ្យ រមែងឲ្យដល់ ។

សព្ទថា **ហវេ** ជានិបាត ចុះក្នុងអត្ថថា រឹងមាំ ។ បទថា **សាធុតរំ** បានដល់ ញុំាងប្រយោជន៍ឲ្យសម្រេចយ៉ាងក្រៃលែង ។ បាលីថា **សាទុតរំ** ដូច្នេះក៏មាន ។ បទថា **រសានំ** បានដល់ ជាងធម៌ទាំងឡាយដែលសម្គាល់ហើយ ថាជារស ។

បទថា **កថំ** បានដល់ ដោយប្រការណា ។ ជីវិតរបស់បុគ្គលរស់នៅ

ដូចម្ដេច ឈ្មោះថា **កថំជីវិជីវិតំ** តែលោកហៅតាមទាសិកៈ ដើម្បីងាយស្រួលដល់ការចងគាថា ឬបាលីថា **កថំជីវិ ជីវិតំ** អធិប្បាយថា បណ្ដាបុគ្គលដែលរស់នៅមានជីវិតដូចម្ដេច ។ បទដ៏សេសក្នុងគាថានេះ ប្រាកដច្បាស់ហើយ ។

អាឡវកយក្ខទូលសួរ ៤ បញ្ហាថា អ្វីជាទ្រព្យដ៏ប្រសើររបស់បុរសក្នុងលោកនេះ អ្វីដែលបុគ្គលប្រព្រឹត្តល្អហើយ នាំសេចក្ដីសុខមកឲ្យ អ្វីជារសប្រសើរជាងរសទាំងឡាយ អ្នកប្រាជ្ញទាំងឡាយបានពោលជីវិតរបស់បុគ្គលដូចម្ដេច ថាប្រសើរបំផុតដោយគាថានេះ ដោយប្រការដូច្នេះ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ឆ្លើយដល់អាឡវកយក្ខនោះដោយន័យដែលព្រះទសពល ព្រះនាមកស្សបៈទ្រង់តបហើយ ទើបត្រាស់គាថានេះថា **សទ្ធីធ វិត្តំ** ដូច្នេះ ។

ក្នុងគាថានោះ មានអធិប្បាយថា ទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត ដែលមានប្រាក់ និងមាសជាដើម រមែងនាំមកនូវឧបភោគសុខ គឺរមែងការពារនូវទុក្ខ មានការស្រេកឃ្លានជាដើម រមែងញ៉ាំងនូវការលំបាកនោះឯងឲ្យស្ងប់ ជាហេតុនៃការបានមកនូវរតនៈ មានកែវមុក្ដាជាដើម និងរមែងនាំមកនូវលោកិយ-សុខយ៉ាងណា សូម្បីសទ្ធាដែលជាលោកិយ និងលោកុត្តរក៏ដូច្នោះ រមែងនាំមកនូវវិបាកសុខដែលជាលោកិយ និងលោកុត្តរតាមសេចក្ដីពិត គឺការពារទុក្ខមានជាតិ ជរាជាដើម ដល់អ្នកបដិបត្តិដោយធុរៈ គឺសទ្ធា រមែងញ៉ាំងនូវភាពក្រក្នុងគុណឲ្យស្ងប់រម្ងាប់ ជាហេតុបានមកនូវរតនៈ មានសតិសម្ពោជ្ឈង្គជាដើម

ហើយព្រះដ៏មានព្រះភាគត្រាស់ថា ជាទ្រព្យ ជាគ្រឿងត្រេកអរនៃចិត្ត ព្រោះធ្វើវិគ្គហៈថា រមែងនាំមកនូវការបន្តក្នុងលោក តាំងព្រះបាលីថា

បុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីល ស្កប់ស្កល់ ដោយយស និងភោគសម្បត្តិ គប់រកប្រទេសណាៗ គេតែងបូជា ក្នុងប្រទេសនោះៗ ។

ព្រោះទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត គឺសទ្ធានោះជាប់តាមខ្លួនទៅ មិនទូទៅដល់អ្នកដទៃ ជាហេតុនៃសម្បត្តិទាំងពួង ជាហេតុនៃទ្រព្យគ្រឿងត្រេកអរនៃចិត្ត មានប្រាក់ និងមាសជាដើម ដែលជាលោកិយ ព្រោះបុគ្គលមានសទ្ធាប៉ុណ្ណោះ ធ្វើនូវបុណ្យទាំងឡាយ មានទានជាដើម រមែងសម្រេចដល់ទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត ចំណែកទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត របស់បុគ្គលដែលមិនមានសទ្ធា រមែងមានដើម្បីសេចក្តីវិនាសប៉ុណ្ណោះ ព្រោះហេតុនោះទើបទ្រង់ត្រាស់ថា **សេដ្ឋំ** ។

បទថា **បុរិសស្ស** ជាការសម្តែងកំណត់យ៉ាងឧក្រិដ្ឋ ព្រោះដូច្នោះ អ្នកសិក្សាគប្បីជ្រាបថា សទ្ធារបស់បុរសតែម្យ៉ាង ជាទ្រព្យគ្រឿងត្រេកអរនៃចិត្តដ៏ប្រសើរបំផុតក៏មិនមែន សទ្ធារបស់ស្ត្រីជាដើមក៏ជាទ្រព្យដ៏ប្រសើរដូចគ្នា ។

បទថា **ធម្មោ** បានដល់ ធម៌ គឺកុសលកម្មបថ ១០ ឬធម៌ គឺទាន សីល និងភាវនា ។ បទថា **សុចិណ្ណោ** គឺធ្វើល្អហើយ ប្រព្រឹត្តល្អហើយ ។ បទថា **សុខមាវហាតិ** សេចក្តីថា រមែងនាំមកនូវសុខរបស់មនុស្ស ដូចសុខរបស់

សោណសេដ្ឋីបុត្ត និងរដ្ឋបាលជាដើម ទិព្វសុខ ដូចសុខរបស់ទេវតា មានសក្កទេវរាជជាដើម និងក្នុងទីបំផុត រមែងនាំមកនូវនិព្វានសុខ ដូចសុខរបស់ព្រះអរិយៈទាំងឡាយ មានព្រះមហាបទុមជាដើម ។

បទថា **សច្ចំ** សេចក្តីថា **សច្ច** សព្ទ នេះ រមែងប្រាកដក្នុងអត្ថច្រើនប្រការ គឺរមែងប្រាកដក្នុងវាចាសច្ចៈ វិរតិសច្ចៈ ទិដ្ឋិសច្ចៈ ព្រាហ្មណសច្ចៈ បរមត្ថសច្ចៈ អរិយសច្ចៈជាដើម ។

ប្រាកដក្នុងវាចាសច្ចៈ ដូចក្នុងប្រយោគជាដើមថា **សច្ចំ ភណេ ន កុជ្ឈេយ្យ** បុគ្គលគួរពោលពាក្យពិត ១ មិនគួរក្រោធ ១ ដូច្នេះ ។

ប្រាកដក្នុងវិរតិសច្ចៈ ដូចក្នុងប្រយោគជាដើមថា **សច្ចេ ឋិតា សមណព្រាហ្មណា** ជ សមណៈ និងព្រាហ្មណ៍ដែលតាំងនៅក្នុងសច្ចៈ ដូច្នេះ ។

ប្រាកដក្នុងទិដ្ឋិសច្ចៈ ដូចក្នុងប្រយោគជាដើមថា **កស្មា នុ សច្ចានិ វទន្តិ នានា បវាទិយាសេ កុសលាវទានា** ព្រោះហេតុអ្វីហ្ន៎ បានជាសមណព្រាហ្មណ៍ទាំងឡាយ ដែលពោលលើកខ្លួនថា ជាអ្នកឈ្លាសវៃ ជាអ្នកពោលតាមបំណងរបស់ខ្លួន តែងពោលសច្ចៈផ្សេងៗ គ្នា ... ដូច្នេះ ។

ប្រាកដក្នុងព្រាហ្មណសច្ចៈ ដូចក្នុងប្រយោគជាដើមថា **ចត្តារិមានិ ភិក្ខវេ ព្រាហ្មណា សច្ច** ម្នាលបរិព្វាជកទាំងឡាយ សច្ចៈរបស់ពួកព្រាហ្មណ៍នេះមាន ៤ ... ដូច្នេះ ។

ប្រាកដក្នុងបរមត្ថសច្ចៈ ដូចក្នុងប្រយោគជាដើមថា **ឯកំ ហិ សច្ចំ ន**

**ទុតិយំ មត្ថិ** សច្ចៈមានតែ ១ មិនមានទី ២ ... ដូច្នេះ ។

ប្រាកដក្នុងអរិយសច្ចៈ ដូចក្នុងប្រយោគជាដើមថា **ចតុន្នំ សច្ចានំ កុសលា** សច្ចៈ ៤ មានកុសលប៉ុន្មាន ដូច្នេះ ។

តែក្នុងទីនេះ ជនទាំងឡាយរមែងធ្វើទឹកជាដើម ឲ្យប្រព្រឹត្តទៅក្នុងអំណាចបាន រមែងឆ្លងទៅកាន់ត្រើយនៃជាតិ ជរា និងមរណៈបាន ដោយអានុភាពនៃសច្ចៈឯណា សច្ចៈនោះ លោកបំណងយកវាថាសច្ចៈ ដែលរួមបរមត្ថសច្ចៈ គឺព្រះនិព្វាន ឬវិរតិសច្ចៈទុកខាងក្នុង ដូចលោកពោលថា

បុគ្គលរមែងទប់ទឹកដោយសច្ចវាចា បណ្ឌិតទាំងឡាយ រមែងកម្ចាត់ពិសបានដោយសច្ចៈ ទេវតាទាំងឡាយ បង្អុរនូវទឹកដោះដោយសច្ចៈ បណ្ឌិតទាំងឡាយតាំងនៅក្នុងសច្ចៈ រមែងប្រាថ្នានូវព្រះនិព្វាន ។

រសឯណាទីមួយ មាននៅលើផែនដី សច្ចៈ ជារសល្អក្រៃលែងជាងរសទាំងឡាយនោះ ពួកសមណៈ និងព្រាហ្មណ៍ ដែលតាំងនៅក្នុងសច្ចៈ រមែងឆ្លងទៅកាន់ត្រើយនៃជាតិ និងមរណៈបាន ដូច្នេះ ។

បទថា **សាធុតរំ** បានដល់ ផ្អែមជាង ប្រណីតជាង ។ បទថា **រសានំ** សេចក្តីថា ធម៌គួរលិទ្ធិភក្សណាមួយ ដោយន័យជាដើមថា **មូលរសោ ខន្ធរសោ** រសមើម រសដើម ដូច្នេះ ។ ធម៌ មានការពោលទោសដោយគន្ធនៃ

រស គឺវាចា និងការបន្ទឺសំឡេងដ៏សេសជាដើមឯណាមួយ ដោយន័យជាដើម ថា **អនុជានាមិ ភិក្ខវេ សព្វំ ផលរសំ** ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតទឹកផ្លែឈើគ្រប់យ៉ាង ដូច្នេះ ។ **អរសរូបោ ភវំ គោតមោតិ ។បេ។ យេ តេ ព្រាហ្មណ រូបរសា សទ្ទរសា** ព្រះគោតមដ៏ចម្រើន ជាមនុស្ស សោះកក្រោះ ឥតរសជាតិទេតើ ។បេ។ ម្នាលព្រាហ្មណ៍ ពិតហើយ មាន ហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតមជាមនុស្សសោះកក្រោះ ឥតរសជាតិ ដែលគេថានុ៎ះ ត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះរសជាតិ គឺ រូប សំឡេង ... ដូច្នេះ ។ **អនាបត្តិ រសរសេ** វារៈដែលមិនត្រូវអាបត្តិ គឺ សម្ងមានរសដ៏ក្រៃលែង ដូច្នេះ ។ **អយំ ធម្មវិនយោ ឯករសោ វិមុត្តិរសោ** ធម្មវិន័យនេះ មានរសតែមួយ គឺវិមុត្តិរស ដូច្នេះ ។ **ភាគី វា ភគវា អត្ថរសស្ស ធម្មរសស្ស** មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែក អត្ថរស ធម្មរស ដូច្នេះ ។ សច្ចៈ ល្អជាងរសទាំងនោះ គឺសច្ចៈនោះឯង ល្អជាង គឺប្រពៃជាង ប្រសើរជាង ឧត្តមជាងរសទាំងនោះ ។

មែនហើយ រសទាំងឡាយ មានរសកើតអំពីឫសជាដើម ចម្រើនសរីរៈ និងនាំមកនូវសុខ ដែលប្រកបដោយសង្កិលេស ។ ក្នុងសច្ចរស រស គឺ វិរតិសច្ចៈ និងសច្ចវាចា រមែងចម្រើនចិត្តដោយសមថៈ និងវិបស្សនាជាដើម រមែងនាំមកនូវសុខដែលប្រកបដោយសង្កិលេស វិមុត្តិរស ឈ្មោះថា ញ៉ាំង ប្រយោជន៍ឲ្យសម្រេច ព្រោះជាធម៌ដែលលោកអប់រំហើយ ដោយបរមត្ថ-

សច្ចរស និងឈ្មោះថា ជាអត្ថរស និងធម្មរស ព្រោះអាស្រ័យអត្ថ និងធម៌ដែលជាឧបាយឲ្យសម្រេចបរមត្ថសច្ចរសនោះ ប្រព្រឹត្តទៅដូច្នេះឯង ។

បទថា **បញ្ញាជីវី** អ្នកសិក្សាគប្បីឃើញអត្ថយ៉ាងនេះថា ក្នុងបុគ្គលខ្វាក់មានភ្នែកតែម្ខាង និងបុគ្គលមានភ្នែកសងខាងទាំងឡាយ បុគ្គលមានភ្នែកសងខាងនេះ ជាគ្រហស្ថត្រេកអរដោយបញ្ញានូវបដិបទាសម្រាប់គ្រហស្ថ មានការឧស្សាហ៍ធ្វើការងារ ដល់នូវសរណៈ ចែកនូវទាន សមាទានសីល និងឧបោសថកម្មជាដើម ឬជាបព្វជិតត្រេកអរដោយបញ្ញា នូវបដិបទាសម្រាប់បព្វជិតពោល គឺសីលដែលធ្វើនូវការមិនក្តៅក្រហាយ ឬដោយចិត្តវិសុទ្ធិជាដើម ដ៏ក្រៃលែងជាងនោះ ហើយញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ អ្នកប្រាជ្ញទាំងឡាយពោលជីវិតដែលរស់នៅដោយបញ្ញា របស់បុគ្គលនោះ ឬជីវិតដែលរស់នៅដោយបញ្ញា របស់បុគ្គលដែលជាអ្នករស់នៅដោយបញ្ញានោះថា ប្រសើរបំផុត ។

យក្ខបានស្តាប់បញ្ហាទាំង ៤ ដែលព្រះដ៏មានព្រះភាគ ទ្រង់ឆ្លើយយ៉ាងនេះ មានចិត្តជារបស់ខ្លួន កាលទូលសួរបញ្ហាទាំង ៤ ដ៏សេស ទើបពោលគាថាថា **កថំសុ តរតិ ឱឃំ** បុគ្គលរមែងឆ្លងឱឃៈបានដូចម្តេច ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់វិសជ្ជនាដល់យក្ខនោះ ដោយន័យមុននោះឯង ទើបត្រាស់ថា **សទ្ធាយ តរតិ ឱឃំ** បុគ្គលរមែងឆ្លងឱឃៈបានដោយសទ្ធា ។

ក្នុងគាថានោះ មានអធិប្បាយដូច្នេះថា បុគ្គលណាឆ្លងឱឃៈទាំង ៤ បាន

បុគ្គលនោះរមែងឆ្លងអន្លង់ គឺសង្សារវដ្តៈ រមែងឆ្លងនូវវដ្តទុក្ខៈ រមែងបរិសុទ្ធ ចាកមន្ទិល គឺកិលេសវដ្តៈក៏ពិត តែបុគ្គលមិនមានសទ្ធា មិនជឿនូវការឆ្លងឱឃៈ រមែងស្ទុះទៅ រមែងប្រមាទដោយការបណ្តែតបណ្តោយចិត្តក្នុងបញ្ចកាមគុណ ឈ្មោះថា រមែងមិនឆ្លងអន្លង់ គឺសង្សារបាន ព្រោះខ្វនជាប់ និងជំពាក់ក្នុង កាមគុណទាំង ៥ នោះ ជាអ្នកខ្ជិលច្រអូស រមែងនៅជាទុក្ខ សៅហ្មងដោយ អកុសលធម៌ទាំងឡាយ បុគ្គលមិនមានបញ្ញាកាលមិនដឹងផ្លូវបរិសុទ្ធ ក៏រមែង មិនបរិសុទ្ធ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគទ្រង់សម្តែងធម៌ដែលជា បដិបក្ខចំពោះការមិនមានសទ្ធាជាដើមនោះ ទើបត្រាស់គាថានេះ ។

ដោយគាថានោះ ព្រះដ៏មានព្រះភាគ ត្រាស់យ៉ាងនេះហើយ ព្រោះ សទ្ធិន្ទ្រិយ ជាបទដ្ឋាននៃសោតាបត្តិយង្គៈ ព្រោះហេតុនោះ ទើបព្រះដ៏មាន ព្រះភាគ ទ្រង់ប្រកាសនូវការឆ្លងទិដ្ឋោឃៈ គឺសោតាបត្តិមគ្គ និងសោតាបន្ន ដោយបទនេះថា បុគ្គលឆ្លងអន្លង់បានដោយសទ្ធា ព្រោះព្រះសោតាបន្នដល់ ព្រមហើយ ដោយសេចក្តីមិនប្រមាទ ពោល គឺការធ្វើជាប់តមិនដាច់ ដោយ ការបម្រើនូវកុសលធម៌ ត្រេកអរក្នុងមគ្គទី ២ រមែងឆ្លងអន្លង់ គឺសង្សារ ដែលជាទីតាំងនៃភវោឃៈ ដែលឆ្លងមិនបានដោយសោតាបត្តិមគ្គ វៀរចំណែក ដែលសេសសល់ តែងមកកាន់លោកនេះម្តងប៉ុណ្ណោះ ព្រោះហេតុនោះ ទើប ទ្រង់ប្រកាសនូវការឆ្លងភវោឃៈ គឺសកទាគាមិមគ្គ និងសកទាគាមី ដោយ បទនេះថា រមែងឆ្លងមហាសមុទ្របាន ដោយសេចក្តីមិនប្រមាទ ព្រោះសក-

ទាគាមីត្រេកអរក្នុងមគ្គទី ៣ រមែងឆ្លងបានដោយសេចក្ដីព្យាយាម នូវទុក្ខ ដែលជាទីតាំងនៃកាមោឃៈ និងដែលសម្គាល់ថា កាមោឃៈដែលឆ្លងមិនបាន ដោយសកទាគាមិមគ្គ ព្រោះហេតុនោះ ទើបទ្រង់ប្រកាសនូវការឆ្លងកាមោឃៈ គឺអនាគាមិមគ្គ និងអនាគាមីដោយបទនេះថា កន្លងសេចក្ដីទុក្ខបានដោយ ព្យាយាម ។ ព្រោះអនាគាមីត្រេកអរក្នុងមគ្គប្បញ្ញាទី ៤ ដែលបរិសុទ្ធដោយ ចំណែកមួយ ដោយបញ្ញាដែលបរិសុទ្ធដែលប្រាសចាកកក់ គឺកាម លះនូវ មន្ទិលយ៉ាងល្អិត ពោល គឺអវិជ្ជាដែលលះមិនបានដោយអនាគាមិមគ្គ ព្រោះ ហេតុនោះ ទើបទ្រង់ប្រកាសនូវការឆ្លងអវិជ្ជោឃៈ គឺអហរត្តមគ្គ និងព្រះអរហន្ត ដោយបទនេះថា បរិសុទ្ធបានដោយប្រាជ្ញា ។ ក្នុងទីបំផុតនៃគាថានេះ ដែល ត្រាស់ដោយកំពូល គឺអរហត្ត យក្ខក៏តាំងនៅក្នុងសោតាបត្តិផល ។

ឥឡូវនេះ អាឡវកយក្ខកាន់យកបទថា បញ្ញា ដែលត្រាស់ក្នុងគាថានេះ ថា រមែងបរិសុទ្ធបានដោយបញ្ញានោះឯង កាលនឹងទូលសួរបញ្ហាដែលប្រឡូក ប្រឡំដោយលោកិយ និងលោកុត្តរ ដោយបដិភាណរបស់ខ្លួន ទើបពោល គាថា ៦ បទនេះថា **កថំ សុ លភតេ បញ្ញំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **កថំ សុ** ជាការសួរដល់ការប្រកបប្រយោជន៍ ក្នុងទីទាំងពួងនោះឯង ។ អាឡវកយក្ខនេះដឹងអត្ថ មានបញ្ញាជាដើម ទើបទូល សួរដល់ការប្រកបនូវអត្ថនោះថា បុគ្គលរមែងបាននូវបញ្ញាដូចម្ដេច គឺដោយ ការប្រកបដូចម្ដេច ដោយការណ៍ដូចម្ដេច ក្នុងទ្រព្យជាដើមក៏ន័យនេះ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងនូវការបាននូវបញ្ញា ដោយហេតុ ៤ យ៉ាង ដល់អាឡវកយក្ខនោះ ទើបត្រាស់ថា **សទ្ទហានោ** ជាដើម ។

គាថានោះមានអធិប្បាយថា ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវកពុទ្ធ ដែលជាអរហន្ត សម្រេចនិព្វានដោយធម៌ណាក្នុងបុព្វភាគ មានកាយទុច្ចរិត ជាដើម ក្នុងអបរភាគ មានពោធិបក្ខិយធម៌ ៣៧ ប្រការជាដើម បុគ្គលជឿនូវធម៌នោះ គឺធម៌របស់ព្រះអរហន្តទាំងឡាយ រមែងបាននូវបញ្ញាដែលជាលោកិយ និងលោកុត្តរ ដើម្បីសម្រេចនិព្វាននោះ ក៏រមែងបាននូវបញ្ញាដែលជាលោកិយ និងលោកុត្តរ ដោយហេតុត្រឹមតែសទ្ធាប៉ុណ្ណោះ ក៏មិនមែន ព្រោះបុគ្គលកើតសទ្ធាហើយ រមែងចូលទៅរក កាលចូលទៅរក រមែងអង្គុយជិត កាលអង្គុយជិត រមែងផ្ទៀងនូវសោតៈ កាលផ្ទៀងនូវសោតៈ រមែងស្តាប់ធម៌ ព្រោះហេតុនោះ ការស្តាប់ដោយល្អ ចាប់តាំងអំពីចូលទៅរក រហូតដល់ការស្តាប់ធម៌ រមែងបាននូវបញ្ញា ។

សេចក្តីនេះមានអធិប្បាយដូចម្តេច មានអធិប្បាយថា កាលជឿនូវធម៌នោះហើយ ចូលទៅរកអាចារ្យ និងឧបជ្ឈាយ៍តាមកាល ចូលទៅអង្គុយជិតដោយការធ្វើវត្តក្នុងកាលណា អាចារ្យ និងឧបជ្ឈាយ៍ មានចិត្តដែលការចូលទៅអង្គុយជិតឲ្យត្រេកអរហើយ បំណងនឹងពោលពាក្យណាមួយ ក្នុងកាលនោះ ក៏ផ្ទៀងសោតៈដោយភាពជាអ្នកប្រាថ្នានឹងស្តាប់ ហើយស្តាប់ រមែងបាននូវបញ្ញា ស្តាប់

ដោយល្អយ៉ាងនេះ ជាអ្នកមិនប្រមាទដោយការមិនទៅប្រាសចាកសតិ និងមានបញ្ញាជាគ្រឿងបំភ្លឺដោយភាពជាអ្នកដឹងសុភាសិត និងទុព្ភាសិតនោះឯង រមែងបាននូវបញ្ញា បុគ្គលក្រៅពីនេះ រមែងមិនបាននូវបញ្ញា ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **អប្បមត្តោ វិចក្ខណោ** ព្រោះបុគ្គលបដិបត្តិបដិបទា ដែលប្រព្រឹត្តទៅដើម្បីបាននូវបញ្ញា ដោយសទ្ធាយ៉ាងនេះហើយស្តាប់ឧបាយដែលជាគ្រឿងនាំឲ្យដល់នូវបញ្ញា ដោយការស្តាប់ដោយល្អ គឺដោយគោរព មិនវង្វេងក្នុងវត្ថុដែលកាន់យកហើយ ដោយការមិនប្រមាទ និងកាន់យកវត្ថុមិនធូរថយ មិនលើស និងមិនខុសដោយភាពជាអ្នកមានបញ្ញាជាគ្រឿងបំភ្លឺ រមែងធ្វើឲ្យទូលំទូលាយ ឬផ្ទៀងនូវសោតៈដោយការស្តាប់ដោយល្អ រមែងស្តាប់ធម៌ដែលជាហេតុបានចំពោះនូវបញ្ញា កាលស្តាប់ដោយការមិនប្រមាទហើយ រមែងទ្រទ្រង់នូវធម៌ រមែងពិចារណាអត្ថនៃធម៌ទាំងឡាយ ដែលចងចាំ ដោយភាពជាអ្នកមានបញ្ញាជាគ្រឿងបំភ្លឺ ក្នុងលំដាប់នោះ រមែងធ្វើឲ្យជាក់ច្បាស់នូវបរមត្ថដោយលំដាប់ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគត្រូវអាឡវកយក្ខទូលសួរថា បុគ្គលបាននូវប្រាជ្ញាដោយអ្វី កាលទ្រង់សម្តែងហេតុទាំង ៤ នេះ ទើបត្រាស់គាថានេះថា **សទ្ទហានោ ។បេ។ វិចក្ខណោ ។**

ឥឡូវនេះ កាលទ្រង់វិសជ្ជនាបញ្ហា ៣ ដទៃអំពីនោះ ទើបត្រាស់គាថានេះថា **បដិរូបការី ។**

ក្នុងគាថានោះ បុគ្គលណាមិនធ្វើនូវប្រយោជន៍ទាំងឡាយ មានកាលៈ-

ទោសៈជាដើមឲ្យវិនាសទៅ រមែងធ្វើឧបាយជាគ្រឿងបាននូវទ្រព្យដែលជាលោកិយ និងលោកុត្តរតាមសមគួរ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **បដិរូបការី** ប្រែថា ធ្វើសមគួរ ។

បទថា **ធុរវា** បានដល់ ជាអ្នកមិនបោះបង់ធុរៈ ដោយអំណាចនៃសេចក្ដីព្យាយាម ដែលប្រព្រឹត្តទៅក្នុងចិត្ត ។

បទថា **ឧដ្ឋាតា** បានដល់ ដល់ព្រមដោយសេចក្ដីព្យាយាម គឺមានការប្រឹងប្រែងមិនដាក់ធុរៈ ដោយអំណាចសេចក្ដីព្យាយាមផ្លូវកាយ ដោយន័យក្នុង (សិង្គាលកសូត្រ ) ជាដើមថា ជនណាម្នាក់ ធ្វើនូវកិច្ចរបស់បុរសមិនអើពើនូវត្រជាក់ និងក្ដៅ ក្រៃលែងជាងស្មៅ ដូច្នេះជាដើម ។

បទថា **វិន្ទតេ ធនំ** សេចក្ដីថា រមែងបាននូវលោកិយទ្រព្យ ដូចចូឡ-កន្តេវាសី បានទ្រព្យចំនួន ២ សែនកហាបណៈ ដោយកណ្ដុរស្លាប់មួយ ក្នុងកាលមិនយូរប៉ុន្មាន និងបានលោកុត្តរទ្រព្យ ដូចមហាតិស្សត្ថេរ បួសឯចាស់ដូច្នោះ ។

ព្រះថេរៈនោះគិតថា អញនៅដោយឥរិយាបថ ៣ ធ្វើវត្តក្នុងកាលថីនមិទ្ធៈមកគ្របសង្កត់ ធ្វើរង្វេលស្លឹកឈើឲ្យសើមហើយដាក់លើក្បាល ចុះទៅក្នុងទឹក ប្រមាណត្រឹម-ក ឃាត់នូវថីនមិទ្ធៈ បានសម្រេចអរហត្តក្នុងកាល ១២ ឆ្នាំ ។

បទថា **សច្ចេន** សេចក្ដីថា បុគ្គលរមែងបាននូវសំឡេងយ៉ាងនេះថា

បុគ្គលពោលពាក្យសច្ចៈ ពោលពាក្យពិត ដោយវចីសច្ចៈខ្លះ ជាព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរិយសាវក ដោយបរមត្ថសច្ចៈខ្លះ ។

បទថា **ទទំ** សេចក្ដីថា កាលឲ្យវត្ថុណានីមួយដែលគេត្រូវការ ដែលគេប្រាថ្នា រមែងចងនូវមិត្តបាន គឺរមែងឲ្យដល់ព្រម រមែងធ្វើមិត្ត ឬឲ្យនូវវត្ថុដែលឲ្យដោយលំបាក រមែងចងមិត្តបាន ឬសង្គហវត្ថុទាំង ៤ អ្នកសិក្សាគប្បីជ្រាបថា ទ្រង់កាន់យកហើយដោយមាតិកាថា **ទាន** អធិប្បាយថា រមែងធ្វើភាពជាមិត្តដោយសង្គហវត្ថុទាំងនោះ ។ កាលទ្រង់វិសជ្ជនាបញ្ហាទាំង ៤ ដោយន័យដែលលាយឡំគ្នា ទាំងលោកិយ និងលោកុត្តរ ដែលទូទៅដល់គ្រហស្ថ និងបព្វជិតយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់វិសជ្ជនាបញ្ហាទី ៥ ដោយអំណាចនៃគ្រហស្ថនេះថា **ស វេ បេច្ច ន សោចតិ** នេះ ទើបត្រាស់ថា **យស្សេតេ** ដូច្នេះ ។

គាថានោះ មានអត្ថថា បុគ្គលណាឈ្មោះថាមានសទ្ធា ព្រោះជាបុគ្គលប្រកបដោយសទ្ធា ដែលញ៉ាំងកល្យាណធម៌ទាំងពួងឲ្យកើតឡើង ដែលត្រាស់ក្នុងបទនេះថា **សទ្ធស្ស ឃរមេសិនោ** បុគ្គលគ្រប់គ្រងផ្ទះ គឺជាគ្រហស្ថអ្នកបរិភោគកាម ស្វែងរក ស្វះស្វែងរកកាមគុណ ៥ មានធម៌ ៤ គឺសច្ចៈមានប្រការដែលត្រាស់ក្នុងពាក្យនេះថា បុគ្គលដល់នូវសេចក្ដីសរសើរដោយសច្ចៈ ធម៌ដែលត្រាស់ដោយឈ្មោះថា បញ្ញា កើតអំពីការស្ដាប់ដោយល្អក្នុងពាក្យនេះថា ស្ដាប់ដោយគោរពរមែងបាននូវបញ្ញា **ធិតិ** ដែលត្រាស់ដោយ

ឈ្មោះថា **ធុរ** និងដោយឈ្មោះថា **ឧដ្ឋាន** ក្នុងពាក្យនេះថា មានធុរៈ មានព្យាយាម ប្រឹងប្រែង និងចាគៈ មានប្រការដែលត្រាស់ក្នុងពាក្យនេះថា បុគ្គលកាលឲ្យរមែងចងមិត្តទាំងឡាយបាន បុគ្គលនោះឯង រមែងមិនសោយសោកក្នុងលោកខាងមុខ គឺបុគ្គលនោះឯង ទៅអំពីលោកនេះ ទៅកាន់បរលោក រមែងមិនសោយសោក ដូច្នេះ ។

ព្រះដ៏មានព្រះភាគ កាលវិសជ្ជនាបញ្ហាទី ៥ យ៉ាងនេះហើយ កាលទ្រង់ដាស់តឿនយក្ខនោះ ទើបត្រាស់ថា **ឥង្ឃ អញ្ញេបិ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឥង្ឃ** ជានិបាត ចុះក្នុងអត្ថថា ដាស់តឿន ។

បទថា **អញ្ញេបិ** សេចក្តីថា អញ្ជើញអ្នកសាកសួរធម៌ទាំងឡាយ ជាមួយសមណព្រាហ្មណ៍ដ៏ច្រើនដទៃចុះ ឬចូរសាកសួរព្រាហ្មណ៍ពួកដទៃជាច្រើនដែលប្តេជ្ញាថាជាសព្វញ្ញូ មានបូរណៈជាដើម ។

ក្នុងគាថានេះ អ្នកសិក្សាគប្បីជ្រាបនូវពណ៌នាអត្ថ ការដល់ព្រម និងយោជនាដោយសង្ខេបថា បើហេតុនៃការបាននូវកិត្តិយសក្រៃលែងជាងសច្ចៈ មានប្រការដែលតថាគតពោលហើយក្នុងបទនេះថា បុគ្គលដល់នូវសេចក្តីសរសើរដោយសច្ចៈក្តី ហេតុនៃការបាននូវលោកិយប្បញ្ញា និងលោកុត្តរប្បញ្ញាក្រៃលែងជាងទមៈ ដែលតថាគតពោលហើយដោយអំណាចនៃបញ្ញាដែលកើតអំពីការស្តាប់ដោយល្អ ក្នុងបទថា ជាអ្នកស្តាប់ដោយល្អ រមែងបាននូវបញ្ញាក្តី ហេតុនៃការចងមិត្តក្រៃលែងជាងចាគៈ មានប្រការដែលតថាគត

ពោលហើយក្នុងបទនេះថា បុគ្គលកាលឲ្យរមែងចងមិត្តទាំងឡាយបានក្តី ហេតុនៃការបានលោកិយទ្រព្យ និងលោកុត្តរទ្រព្យក្រៃលែងជាងខន្តិ ពោល គឺសេចក្តីព្យាយាមដែលដល់នូវភាពជាអ្នកមានឧស្សាហ៍ ដោយអត្ថថា អត់ធន់ចំពោះភារៈច្រើន ដែលតថាគតពោលដោយឈ្មោះថា **ធុរៈ** និងដោយឈ្មោះថា **ឧដ្ឋានៈ** ព្រោះអាស្រ័យអំណាចនៃប្រយោជន៍នោះៗ ក្នុងបទនេះថា មានធុរៈមានព្យាយាមប្រឹងប្រែងក្តី ហេតុនៃការលះចាកលោកនេះ ទៅកាន់លោកដទៃហើយ មិនមានសេចក្តីសោកក្រៃលែងជាងធម៌ ៤ នេះ ដែលតថាគតពោលយ៉ាងនេះថា សច្ចៈ ១ ធម្ម (បញ្ញា) ១ ធិតិ (ព្យាយាម) ១ ចាគៈ (ការបរិច្ចាគ) ១ ក្តី មានក្នុងលោកនេះសោត អញ្ជើញអ្នកសាកសួរសមណព្រាហ្មណ៍ជាច្រើនដទៃមើលចុះ ។ តែដោយពិស្តារ អ្នកសិក្សាគប្បីចែកតែមួយបទដោយន័យនៃការលើកអត្ថឡើង និងលើកបទឡើង អធិប្បាយថា គប្បីជ្រាបពណ៌នាអត្ថ ។

កាលព្រះដ៏មានព្រះភាគ ត្រាស់យ៉ាងនេះហើយ យក្ខទូលថា ឥឡូវនេះខ្ញុំចាំបាច់សួរពួកសមណព្រាហ្មណ៍ជាច្រើនធ្វើអ្វីទៀត ព្រោះសេចក្តីសង្ស័យដែលគប្បីសួរសមណព្រាហ្មណ៍ដទៃ ដែលខ្ញុំលះបានហើយ កាលនឹងធ្វើជនដទៃ ដែលមិនទាន់ដឹងហេតុនៃការមិនទូលសួរព្រះដ៏មានព្រះភាគនោះ ឲ្យជ្រាប ទើបទូលថា (ព្រោះ) ក្នុងថ្ងៃនេះ ខ្ញុំដឹងប្រយោជន៍ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខច្បាស់ហើយ ដូច្នេះ ។

ក្នុងបទទាំងនេះ បទថា **អជ្ជ** អធិប្បាយថា រាប់តាំងអំពីថ្ងៃនេះជាដើមទៅ ។ បទថា **បជានាមិ** សេចក្តីថា ជ្រាបច្បាស់ដោយប្រការតាមដែលពោលហើយ ។ បទថា **យោ ចត្ថោ** សេចក្តីថា យក្ខសម្តែងប្រយោជន៍ក្នុងបច្ចុប្បន្ន ដែលព្រះដ៏មានព្រះភាគត្រាស់ដោយន័យជាដើមថា ជាអ្នកស្តាប់ដោយល្អ រមែងបានទូវបញ្ញា ដោយពាក្យមានប្រមាណប៉ុណ្ណេះ សម្តែងប្រយោជន៍ក្នុងភពខាងមុខ ដែលធ្វើកាលដែលលះលោកនេះទៅហើយ មិនមានសេចក្តីសោក ដែលត្រាស់ថា **យស្សេតេ ចតុរោ ធម្មា** ក្នុងបទនេះថា **សម្បរាយិកោ** ។ ពាក្យថា **អត្ថោ** នោះ ជាឈ្មោះរបស់ហេតុ ។

ពិតហើយ **អត្ថ** សព្ទនេះ រមែងប្រព្រឹត្តទៅក្នុងអត្ថនៃបាលី ការប្រាប់ សេចក្តីចម្រើន ទ្រព្យ ប្រយោជន៍ ហេតុ ។

មកក្នុងអត្ថថា បាលី ដូចក្នុងប្រយោគជាដើមថា **សាត្ថំ សព្យញ្ជនំ** ប្រែថា បរិបូណ៌ដោយអត្ថ ( បាលី ) និងព្យញ្ជនៈ ដូច្នេះ ។

មកក្នុងអត្ថថា ការប្រាប់ ដូចក្នុងប្រយោគជាដើមថា **អត្ថោ មេ គហបតិ ហិរញ្ញសុវណ្ណេន** ប្រែថា ម្នាលគហបតី យើងត្រូវការដោយប្រាក់និងមាស ដូច្នេះ ។

មកក្នុងអត្ថថា សេចក្តីចម្រើន ដូចក្នុងប្រយោគជាដើមថា **ហោតិ សីលវតំ អត្ថោ** ប្រែថា សេចក្តីចម្រើនតែងមានដល់ពួកជនអ្នកមានសីល ដូច្នេះ ។

មកក្នុងអត្ថថា ទ្រព្យ ដូចក្នុងប្រយោគជាដើមថា **ពហុជ្ជនោ ភជតិ អត្ថហេតុ** ប្រែថា ជនជាច្រើនតែងគប់រក ព្រោះហេតុតែប្រយោជន៍ ( ទ្រព្យ ) ដូច្នេះ ។

មកក្នុងអត្ថថា ប្រយោជន៍ ដូចក្នុងប្រយោគជាដើមថា **ឧភិន្នមត្ថំ ចរតិ** ប្រែថា ប្រព្រឹត្តនូវប្រយោជន៍ ដល់ជនទាំង ២ នាក់ ដូច្នេះ ។

ប្រព្រឹត្តទៅក្នុង ហេតុ ដូចក្នុងប្រយោគជាដើមថា **អត្ថេ ជាតេ ច បណ្ឌិតំ** ប្រែថា ក្នុងកាលអាថ៌កំបាំង ( ហេតុ ) កើតឡើង គេប្រាថ្នានូវបណ្ឌិត ដូច្នេះ ។ ក្នុងទីនេះ រមែងប្រព្រឹត្តទៅក្នុងហេតុ ព្រោះហេតុនោះ អ្នកសិក្សា គប្បីជ្រាបអត្ថដោយសង្ខេប ក្នុងទីនេះយ៉ាងនេះថា ហេតុនៃការបាននូវបញ្ញាជាដើម ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នណា និងហេតុនៃភាពដែលលះលោកនេះទៅហើយ មិនមានសេចក្តីសោកស្តាយ ប្រព្រឹត្តទៅក្នុងភពខាងមុខថ្ងៃនេះ ខ្ញុំបានជ្រាបច្បាស់នូវហេតុនោះដោយខ្លួនឯង ដោយន័យដែលព្រះដ៏មានព្រះភាគត្រាស់ហើយនោះឯង ឥឡូវនេះ ខ្ញុំគប្បីសាកសួរសមណព្រាហ្មណ៍ជាច្រើនធ្វើអ្វីទៀត យក្ខទូលថា ខ្ញុំព្រះអង្គដឹងច្បាស់នូវប្រយោជន៍ ដែលប្រព្រឹត្តទៅក្នុងភពខាងមុខយ៉ាងនេះហើយ កាលនឹងសម្តែងភាពដែលញាណនោះ មានភពជាមូល ទើបក្រាបទូលថា **អត្ថាយ វត មេ ពុទ្ធោ** ។

ក្នុងបទនោះ បទថា **អត្ថាយ** សេចក្តីថា ដើម្បីប្រយោជន៍ ឬដើម្បីការដឹង ។ បទថា **យត្ថ ទិន្នំ មហប្ផលំ** សេចក្តីថា ទានដែលបុគ្គលឲ្យហើយ

ក្នុងទក្ខិណេយ្យបុគ្គលដ៏ប្រសើរណា ដោយការបរិច្ចាគ ដែលត្រាស់ក្នុងបទនេះថា **យស្សេត្ថ ចតុរោ ធម្មា** ជាទានដែលមានផលច្រើនជាង ខ្ញុំព្រះអង្គជ្រាបច្បាស់នូវទក្ខិណេយ្យបុគ្គលដ៏ប្រសើរនោះ ចំណែកពួកកេចិអាចារ្យពោលថា អាឡវកយក្ខទូលយ៉ាងនេះ សំដៅដល់ព្រះសង្ឃ ។

អាឡវកយក្ខ សម្តែងនូវការសម្រេចប្រយោជន៍របស់ខ្លួន ដោយគាថានេះយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្តែងបដិបត្តិប្រយោជន៍ដល់អ្នកដទៃទើបក្រាលទូលថា **សោ អហំ វិចរិស្សាមិ** អត្ថនៃគាថានោះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងហេមវតសូត្រនោះឯង ។

ការចប់គាថានេះ ១ រាត្រីភ្លឺស្វាង ១ ការឲ្យសំឡេងសាធុការតាំងឡើង ១ ការនាំអាឡវកកុមារមកកាន់លំនៅរបស់យក្ខ ១ មានហើយក្នុងខណៈតែមួយនោះឯង ដោយប្រការដូច្នេះ ។ រាជបុរសទាំងឡាយ ស្តាប់សំឡេងសាធុការហើយ គិតថា សំឡេងសាធុការបែបនេះ វៀរព្រះពុទ្ធទាំងឡាយហើយ រមែងមិនលាន់ឡើងដល់ជនដទៃ ព្រះដ៏មានព្រះភាគយាងមកឬហ្ន៎ បានឃើញរស្មីនៃព្រះវរកាយរបស់ព្រះដ៏មានព្រះភាគហើយ មិនឈរខាងក្រៅដូចកាលមុនអស់សេចក្តីសង្ស័យ ចូលទៅខាងក្នុងនោះឯង បានឃើញព្រះដ៏មានព្រះភាគគង់ក្នុងលំនៅរបស់យក្ខ និងឃើញយក្ខឈរផ្គងអញ្ជលី កាលឃើញហើយ បានពោលនឹងយក្ខថា បពិត្រមហាយក្ខ ព្រះរាជកុមារនេះ នាំមកដើម្បីពលីកម្មសម្រាប់លោក សូមលោកទំពា សូមលោកពិសាព្រះរាជកុមារ

នេះ ឬធ្វើតាមគាប់ចិត្តចុះ ដូច្នេះ ។

អាឡវកយក្ខនោះ ខ្មាសហើយ ព្រោះអំណាចខ្លួនជាព្រះសោតាបន្ន ហើយត្រូវអ្នកដទៃពោលយ៉ាងនេះ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគ ដោយត្រង់ ។ លំដាប់នោះ ទើបទទួលព្រះកុមារនោះហើយដោយដៃទាំងពីរ ហើយថ្វាយដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គ កុមារនេះ គេបញ្ជូនមកដល់ខ្ញុំព្រះអង្គៗ សូមថ្វាយកុមារនេះដល់ទ្រង់ ព្រះពុទ្ធទាំងឡាយទ្រង់ជាអ្នកអនុគ្រោះ សូមទ្រង់ទទួលទារកនេះដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ព្រះកុមារនេះ ហើយពោលគាថានេះថា

> បពិត្រព្រះអង្គ ទ្រង់មានព្រះហឫទ័យរីក មានព្រះហឫទ័យល្អ ខ្ញុំព្រះអង្គសូមថ្វាយព្រះរាជកុមារនេះ ដែលមានបុញ្ញលក្ខណៈរាប់រយ មានអវយវៈទាំងពួងបរិបូណ៌ ដល់ព្រមដោយ ( អនុ ) ព្យញ្ជនៈ ដល់ព្រះអង្គ បពិត្រព្រះអង្គ ទ្រង់មានចក្ខុ សូមទ្រង់ទទួលព្រះរាជកុមារនេះ ដើម្បីជាប្រយោជន៍ ដល់សត្វលោក ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់ទទួលព្រះរាជកុមារហើយ កាលទ្រង់ទទួលបានត្រាស់គាថាជាគ្រឿងរក្សា ដើម្បីទ្រង់ធ្វើមង្គលដល់យក្ខ និងកុមារ ។ យក្ខឲ្យព្រះរាជកុមារនោះ ដល់នូវសរណៈ និងញុំាងគាថាឲ្យពេញដោយបាទទី ៤ អស់វារៈ ៣ ដងថា

សូមព្រះរាជកុមារនេះ មានអាយុវែង ម្នាលយក្ខ ចូរអ្នកមានសេចក្ដីសុខ អ្នកទាំងពីរ ចូរកុំបីមានរោគបៀតបៀន តាំងនៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីចម្រើន ដល់សត្វលោកចុះ ។ សូម កុមារនេះ ដល់នូវព្រះពុទ្ធ ។បេ។ ព្រះធម៌ ។បេ។ និងព្រះសង្ឃ ជាជាសរណៈដូច្នេះ ។

ព្រះដ៏មានព្រះភាគ ទ្រង់ប្រទានព្រះរាជកុមារដល់ពួករាជបុរសទាំងឡាយថា ចូរពួកអ្នកញ៉ាំងព្រះរាជកុមារនេះឲ្យចម្រើនធំធាត់ ហើយឲ្យដល់តថាគតវិញ ។ ដោយប្រការដូច្នេះ ទើបព្រះរាជកុមារនោះ មានព្រះនាម ហត្ថកអាឡវកកុមារ ព្រោះព្រះកុមារនោះ មកអំពីដៃរាជបុរសជាដើម ទៅកាន់ដៃរបស់យក្ខ មកអំពីដៃរបស់យក្ខ ទៅកាន់ព្រះហស្ថរបស់ព្រះដ៏មានព្រះភាគ មកអំពីព្រះហស្ថរបស់ព្រះដ៏មានព្រះភាគ ទៅកាន់ដៃរាជបុរសទាំងឡាយវិញ ។

ជនទាំងឡាយ មានអ្នកស្រែ និងអ្នកធ្វើការក្នុងព្រៃជាដើម បានឃើញរាជបុរសទាំងឡាយ នាំព្រះរាជកុមារនោះត្រឡប់មក មានសេចក្ដីខ្លាចក៏សួរថា យក្ខមិនត្រូវការព្រះរាជកុមារ ព្រោះនៅតូចពេកឬ រាជបុរសទាំងឡាយបានប្រាប់រឿងទាំងអស់ថា អ្នកទាំងឡាយកុំខ្លាច ព្រះដ៏មានព្រះភាគទ្រង់ធ្វើនូវសួស្ដីហើយ បន្ទាប់អំពីនោះ ពួកអ្នកអាឡវីនគរ ក៏បែរមុខទៅរកផ្លូវយក្ខដោយសំឡេងកោលាហលតែមួយថា សាធុ សាធុ ។

ចំណែកយក្ខ កាលភិក្ខាចាររបស់ព្រះដ៏មានព្រះភាគមិនទាន់ដល់ ក៏កាន់

បាត្រ ចីវរ មកដល់កណ្ដាលផ្លូវហើយត្រឡប់ កាលនោះ ព្រះដ៏មានព្រះភាគ យាងបិណ្ឌបាតក្នុងព្រះនគរ ទ្រង់ធ្វើភត្តកិច្ចហើយ ប្រថាប់គង់លើបវរពុទ្ធាសនៈ ដែលក្រាលហើយ ត្រង់គល់ឈើដែលស្ងាត់មួយក្បែរទ្វារនគរ បន្ទាប់អំពីនោះ ព្រះរាជា មួយអន្លើដោយពួកមហាជន និងអ្នកនគរទាំងឡាយប្រជុំគ្នា ចូលទៅគាល់ព្រះដ៏មានព្រះភាគ ថ្វាយបង្គំចោមរោមហើយ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់ទូន្មានយក្ខកាចបែបនេះដូចម្ដេច ព្រះដ៏មានព្រះភាគត្រាស់អាឡវកសូត្រនោះឯង ចាប់តាំងពីការផ្ដើមច្បាំងជាដើមនោះថា យក្ខនេះ បណ្ដាលឲ្យភ្លៀងធ្លាក់ ៩ ប្រភេទបែបនេះ បានធ្វើវត្ថុដែលគួរខ្លាចយ៉ាងនេះ បានសួរបញ្ហាយ៉ាងនេះ តថាគតបានឆ្លើយហើយយ៉ាងនេះដល់យក្ខ ក្នុងកាលចប់គាថា សត្វ ៨៤០០០ ក៏បាននូវធម្មាភិសម័យ ។

បន្ទាប់អំពីនោះ ព្រះរាជា និងអ្នកនគរបានធ្វើលំនៅឲ្យដល់យក្ខ ក្នុងទីជិតភពរបស់ស្ដេចវេស្សវណមហារាជ ញុំាងពលីកម្មដែលដល់ព្រមដោយសក្ការៈ មានផ្កា និងគ្រឿងក្រអូបជាដើម ឲ្យប្រព្រឹត្តទៅជានិច្ចហើយ ដោះលែងព្រះរាជកុមារនោះ ដែលទ្រង់សម្រេចនិតិកាវៈហើយថា ព្រះរាជកុមារអាស្រ័យព្រះដ៏មានព្រះភាគ ទើបបានជីវិត សូមយាងទៅ សូមទ្រង់អង្គុយជិតព្រះដ៏មានព្រះភាគនោះឯង និងភិក្ខុសង្ឃ ។ ព្រះរាជកុមារនោះ យាងចូលទៅអង្គុយជិតព្រះដ៏មានព្រះភាគ និងភិក្ខុសង្ឃ ក្នុងកាលមិនយូរប៉ុន្មាន ក៏តាំងនៅក្នុងអនាគាមិផល ទ្រង់រៀនព្រះពុទ្ធវចនៈទាំងអស់ ជាអ្នកមានឧបាសក ៥០០

ជាបរិវារ ហើយព្រះដ៏មានព្រះភាគ ទ្រង់តាំងព្រះរាជកុមារនោះក្នុងតំណែង ឯតទគ្គថា ពួកឧបាសកអ្នកសង្គ្រោះបរិសទ្យ ដោយសង្គហវត្ថុ ៤ ប្រការ ស្រេចនឹងហត្ថកអាឡវកៈ ។ល។

**អដ្ឋកថា អាឡវកសូត្រទី ១០ ចប់**

# សុត្តន្តបិដក

## វិជយសូត្រទី ១១

[ ១៩ ] ថាបើបុគ្គលដើរក្តី ឈរក្តី អង្គុយក្តី ដេកក្តី រមែងបត់ចូល លាចេញ នេះជាការកម្រើកកាយ ។

កាយប្រកបដោយឆ្អឹង និងសរសៃទាំងឡាយ គ្របដណ្តប់ដោយស្បែក និងសាច់ បិទបាំងដោយសម្បុរថ្ងៃ មិនប្រាកដតាមពិត ។

កាយពេញដោយពោះវៀនផង ពេញដោយអាហារថ្មីផង ដោយដុំថ្លើមផង ដោយក្រពះនោមផង ដោយបេះដូងផង ដោយសួតផង ដោយទាចផង ដោយក្រពះបាយផង ដោយទឹកសំបោរផង ដោយទឹកមាត់ផង ដោយញើសផង ដោយខ្លាញ់ខាប់ផង ដោយឈាមផង ដោយទឹករំអិលផង ដោយទឹកប្រមាត់ផង ដោយខ្លាញ់រាវផង ។

មួយទៀត វត្ថុមិនស្អាត រមែងហូរចេញតាមរន្ធទាំង ៩ របស់កាយនោះសព្វកាល គឺព្រៀកភ្នែក ហូរចេញអំពីភ្នែក មូលត្រចៀក ហូរចេញអំពីត្រចៀក ទឹកសំបោរហូរចេញអំពីប្រមុះ ជួនណា ចេញតាមមាត់ ប្រមាត់ និងស្លេស្ម ក៏ខ្ជាក់ចេញតាមមាត់ដែរ ញើស និងក្អែល ហូរចេញអំពីកាយ ។

មួយទៀត កាយនោះ មានក្បាលប្រហោង ពេញដោយខួរ

ក្នុងក្បាល ជនពាលត្រូវអវិជ្ជារួបរឹតហើយ រមែងសម្គាល់កាយនោះថាល្អ ។ កាលណាកាយនោះស្លាប់ទៅ ដេកនៅហើមប៉ោងមានពណ៌ខៀវ ត្រូវគេបោះបោលទៅក្នុងព្រៃស្មសានហើយ កាលណោះ ជនទាំងឡាយជាញាតិក៏លែងរមិល ស្វាន ចចក ឆ្កែ ដង្កូវ ជញ្ជ្រូងស៊ីកាយស្លាប់នោះ ចំណែកពួកសត្វដទៃមានក្អែក ត្មាតជាដើម ក៏ចឹកស៊ីនូវកាយស្លាប់នោះដែរ ។

ភិក្ខុណាក្នុងសាសនានេះ ជាអ្នកមានបញ្ញា បានស្តាប់នូវពុទ្ធវចនៈហើយ ភិក្ខុនោះរមែងកំណត់ដឹងនូវកាយនោះ ព្រោះឃើញច្បាស់តាមពិត ។ សរីរៈរស់នេះយ៉ាងណា សរីរៈស្លាប់នុ៎ះ ក៏យ៉ាងនោះ សរីរៈស្លាប់នុ៎ះយ៉ាងណា សរីរៈរស់នេះ ក៏យ៉ាងនោះ ភិក្ខុគប្បីរំសាយនូវសេចក្តីប្រាថ្នាក្នុងកាយ ទាំងខាងក្នុង ទាំងខាងក្រៅ ក្នុងសាសនានេះ ភិក្ខុនោះមានបញ្ញាប្រាសចាកឆន្ទរាគ ដល់នូវបទ គឺព្រះនិព្វាន ជាធម្មជាតមិនស្លាប់ ចេញចាកវានៈ គឺតណ្ហា ជាធម្មជាតស្ងប់ មិនច្យុត ។ កាយ មានជើងពីរនេះ មិនស្អាត មានក្លិនអាសោចិ៍ ពេញដោយសាកសពផ្សេងៗ ហូរចេញអំពីរន្ធនោះៗ ។

បុគ្គលណា មានកាយមានសភាពដូច្នេះ ហើយលើកតម្កើងខ្លួនឯង មើលងាយបុគ្គលដទៃ ( បុគ្គលនោះ ) គ្មានធម្មជាត

អ្វីក្រៅអំពីការមិនឃើញ ( នូវអរិយសច្ចៈទេ ) ។

វិជយសូត្រទី ១១ ចប់

# អដ្ឋកថា

## វិជយសូត្រ

[ ១៩ ] វិជយសូត្រ មានពាក្យផ្តើមថា **ចរំ វា យទិ វា តិដ្ឋំ** ដូច្នេះ ហៅថា **កាយវិច្ឆន្ទនិកសូត្រ** ដូច្នេះក៏មាន សូត្រនេះ មានអត្ថុប្បត្តិហេតុ ដូចម្តេច ។

បានឮថា សូត្រនេះ ត្រាស់ក្នុងឋានៈ ២ យ៉ាង ព្រោះដូច្នោះ វិជយ-សូត្រនេះ មានអត្ថុប្បត្តិហេតុ ២ យ៉ាង ។

ក្នុងសូត្រនោះ ស្ត្រីដែលមានឈ្មោះថា នន្ទា មាន ៣ នាក់ គឺនន្ទា ដែលជាប្អូនស្រីរបស់អានន្ទត្ថេរ ១ អភិរូបនន្ទា ជាបុត្រីរបស់ព្រះបាទខេមក-សក្យៈ ១ នន្ទាដែលជាជនបទកល្យាណី ១ ( នន្ទាជនបទកល្យាណីនេះ ) បួសហើយដោយបព្វជ្ជាសម្រាប់មាតុគ្រាម ដែលព្រះដ៏មានព្រះភាគ យាងដល់ក្រុងកបិលពស្តុដោយលំដាប់ ទ្រង់ទូន្មានស្តេចសក្យៈទាំងឡាយ ទ្រង់ឲ្យស្ត្រីទាំងឡាយ មាននាងនន្ទាជាដើមបព្វជ្ជា ទ្រង់អនុញ្ញាតហើយ ។ ដោយសម័យនោះ ព្រះដ៏មានព្រះភាគ គង់ក្នុងក្រុងសាវត្ថី នាងអភិរូបនន្ទា មានរូបស្អាត

ក្រៃលែង គួរគយគន់ គួរជ្រះថ្លា ដោយហេតុនោះ ទើបញាតិទាំងឡាយដាក់ឈ្មោះថា អភិរូបនន្ទា ។ ចំណែកនាងនន្ទា ដែលជាជនបទកល្យាណី មិនឃើញស្រីដទៃ ដែលមានរូបស្អាតស្មើនឹងខ្លួន នាងទាំងពីរនោះ ស្រវឹងហើយដោយរូបមទៈ គិតថា ព្រះដ៏មានព្រះភាគទ្រង់តិះដៀលនូវរូប ទ្រង់និន្ទារូប ទ្រង់សម្តែងទោសក្នុងរូបដោយអនេកបរិយាយ មិនទៅកាន់ទីបម្រើព្រះដ៏មានព្រះភាគ ទាំងមិនប្រាថ្នាដើម្បីនឹងឃើញ ។

បើមានពាក្យសួរថា នាងមិនជ្រះថ្លាយ៉ាងនេះ ព្រោះហេតុអ្វី ទើបបព្វជា ឆ្លើយថា សច្ចកុមារ ជាស្វាមីរបស់ព្រះនាងអភិរូបនន្ទា បានធ្វើកាលកិរិយាដោយប្រក្រតីក្នុងថ្ងៃនោះឯង ដោយហេតុនោះ ទើបមាតា និងបិតាឲ្យនាងដែលមិនមានបំណងនឹងបួស បួសហើយ ។

ចំណែកនន្ទាជនបទកល្យាណី កាលព្រះនន្ទសម្រេចអរហត្តហើយ ក៏អស់សង្ឃឹមថា ស្វាមីរបស់អញ មហាបជាបតីព្រះមាតា និងព្រះញាតិដទៃៗ បួសហើយ នាងវៀរចាកព្រះញាតិទាំងឡាយ កាលមិនបាននូវការសុខសាន្តផ្លូវចិត្តក្នុងយកវាសដែលជាទុក្ខ ក៏បព្វជា មិនមែនបួសដោយសទ្ធាឡើយ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ដឹងនូវការចាស់ក្លាដោយជុំវិញនៃញាណរបស់នាងទាំងពីរនោះ ទើបត្រាស់ប្រាប់នាងមហាបជាបតីថា ភិក្ខុនីទាំងអស់ ចូរមកទទួលឱវាទតាមលំដាប់ ។ លំដាប់នោះ ស្ត្រីទាំងពីរនោះ កាលដល់វារៈរបស់ខ្លួន ក៏បញ្ជូនភិក្ខុនីដទៃទៅជំនួស បន្ទាប់អំពីនោះ ព្រះដ៏មាន

ព្រះភាគត្រាស់ថា ដល់វារៈអ្នកណា អ្នកនោះគប្បីមក មិនត្រូវបញ្ជូនកិក្ខុនីដទៃទៅជំនួសឡើយ ។ ថ្ងៃមួយ នាងអភិរូបនន្ទាបានទៅទទួលឱវាទ ព្រះដ៏មានព្រះភាគក៏ញ៉ាំងនាងឲ្យសង្វេគដោយរូបដែលទ្រង់និម្មិត ឲ្យតាំងនៅក្នុងអរហត្តដោយលំដាប់ ដោយគាថាក្នុងធម្មបទថា ដែលកុសលាកុសលកម្មធ្វើហើយឲ្យជានគររបស់ឆ្អឹងទាំងឡាយ និងដោយថេរីគាថាទាំងនេះថា

**អាតុរំ អសុចឹ បូតឹ បស្ស នន្ទេ សមុស្សយំ**
**ឧគ្ឃរន្តំ បគ្ឃរន្តំ ពាលានំ អភិបត្ថិតំ ។**[១]

ម្នាលនាងនន្ទា នាងចូរមើល ( រាងកាយនេះ ) មានជំងឺជានិច្ច មិនស្អាត ជារបស់ស្អុយ ហូរចូល ហូរចេញនូវរបស់មិនស្អាត ដែលពួកបុគ្គលពាលប្រាថ្នាក្រៃលែង ។

**អនិមិត្តញ្ច ភាវេហិ មានានុសយមុជ្ជហ**
**តតោ មានាភិសមយា ឧបសន្តា ចរិស្សសិ ។**

ចូរនាងចម្រើននូវអនិមិត្ត ចូរលះបោលនូវមានានុស័យ នាងនឹងបានស្ងប់រម្ងាប់ ព្រោះបានលះនូវមានះនោះដូច្នេះ ។

ថ្ងៃមួយ ពួកអ្នកក្រុងសាវត្ថី ក្នុងបុរេភត្ត ថ្វាយទាន សមាទាន ឧបោសថ

១- បិដកខ្មែរ បាទទី ៣ និងបាទទី ៤ ជា អសុភាយ ចិត្តំ ភាវេហិ ឯកគ្គំ សុសមាហិតំ ។

ស្បៀកល្អ ដណ្តប់ល្អ កាន់វត្ថុមានផ្កាកម្រង និងគ្រឿងក្រអូបជាដើមទៅកាន់វត្ត ជេតពន ដើម្បីប្រយោជន៍ដល់ការស្តាប់ធម៌ ក្នុងពេលចប់នៃការស្តាប់ធម៌ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ចូលកាន់ព្រះនគរ សូម្បីភិក្ខុនីសង្ឃស្តាប់ធម្មកថាហើយ ក៏ទៅកាន់សម្នាក់របស់ភិក្ខុនី មនុស្ស និងភិក្ខុនីទាំងឡាយក្នុងក្រុងសាវត្ថីនោះ សុទ្ធតែនាំគ្នាសរសើរព្រះដ៏មានព្រះភាគ ។

លោកសន្និវាសមាន ៤ យ៉ាង បុគ្គលឃើញព្រះសម្មាសម្ពុទ្ធហើយ ឈ្មោះថាមិនជ្រះថ្លា មិនមាន ពិតហើយ បុគ្គលទាំងឡាយដែលកាន់យករូបជាប្រមាណ ឃើញព្រះរូបរបស់ព្រះដ៏មានព្រះភាគ វិចិត្រដោយលក្ខណៈ និងអនុព្យញ្ជនៈ មានព្រះកេតុមាលារុងរឿង មានរស្មីប្រមាណមួយព្យាម ដូចជាអលង្ការដែលមានប្រយោជន៍ល្អព្រម ដែលកើតឡើងដល់ ( សត្វ ) លោកដូច្នោះ រមែងជ្រះថ្លា ។

បុគ្គលកាន់យកសំឡេងជាប្រមាណ ស្តាប់សំឡេង កិត្តិសព្ទក្នុងជាតកច្រើនរយ ប្រកបដោយអង្គ ៨ ទ្រង់បន្លឺចេញយ៉ាងពីរោះ ដូចសត្វករវិក ដូចសំឡេងនៃព្រហ្ម រមែងជ្រះថ្លា ។

ចំណែកបុគ្គលដល់នូវការសៅហ្មងជាប្រមាណ ឃើញនូវការសៅហ្មងដោយចីវរជាដើម ឬសៅហ្មងដោយកាលបំពេញទុក្ករកិរិយា រមែងជ្រះថ្លា ។

បុគ្គលកាន់យកធម៌ជាប្រមាណ ពិចារណាធម្មក្ខន្ធណាមួយ បណ្តាធម្ម-ក្ខន្ធទាំងឡាយ មានសីលក្ខន្ធជាដើម រមែងជ្រះថ្លា ព្រោះដូច្នោះ ទើបពោល

សរសើរព្រះដ៏មានព្រះភាគក្នុងទីទាំងពួង ។

នាងនន្ទាជនបទកល្យាណី សូម្បីដល់សម្នាក់របស់ភិក្ខុនីហើយ បានស្តាប់បុគ្គលទាំងនោះ កំពុងពោលសរសើរព្រះដ៏មានព្រះភាគ ដោយអនេកបរិយាយ បំណងនឹងចូលទៅគាល់ព្រះដ៏មានព្រះភាគ ទើបប្រាប់ដល់ភិក្ខុនីទាំងឡាយ ពួកភិក្ខុនីនាំនាងទៅគាល់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគ ទ្រង់ដឹងការមករបស់នាងមុននោះឯង ទ្រង់និម្មិតស្ត្រីដែលមានអាយុប្រមាណ ១៥ ឬ ១៦ ឆ្នាំ ដែលគួរមើលក្រៃលែង ឈរបក់ផ្លិតអំពីខាងក្រោយដោយឫទ្ធិរបស់ព្រះអង្គ កាលទ្រង់កម្ចាត់ការស្រើងក្នុងរូបដោយរូបនោះឯង ដូចបុរសត្រូវការដោះបន្លាដោយបន្លា និងត្រូវការដកស្នៀតដោយស្នៀតដូច្នោះ នាងនន្ទា ចូលទៅគាល់មួយអន្លើដោយភិក្ខុនីទាំងឡាយ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងរវាងភិក្ខុនីសង្ឃ ឃើញរូបសម្បត្តិរបស់ព្រះដ៏មានព្រះភាគ តាំងពីចុងព្រះបាទដល់ចុងព្រះកេសា និងឃើញរូបនិម្មិតនោះ ដែលឈរក្បែរព្រះដ៏មានព្រះភាគ គិតថា ឱស្ត្រីនេះ រូបស្អាត លះនូវសេចក្តីស្រើងក្នុងរូបរបស់ខ្លួន មានអត្តភាពដែលត្រេកអរក្រៃលែង ក្នុងរូបរបស់ស្ត្រីនោះ ។

បន្ទាប់អំពីនោះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងស្ត្រីនោះ ធ្វើឲ្យមានអាយុប្រមាណ ២០ ឆ្នាំ ព្រោះថា មាតុគ្រាម មានអាយុ ១៦ ឆ្នាំប៉ុណ្ណោះ រមែងស្អាត លើសអំពីនោះមិនស្អាត លំដាប់នោះ នាងនន្ទាឃើញការសាបសូន្យនៃរូបរបស់ស្ត្រីនោះ ក៏មានឆន្ទរាគក្នុងរូបថយចុះ បន្ទាប់អំពីនោះ ព្រះដ៏មានព្រះ

ភាគសម្តែងស្ត្រីយ៉ាងនេះ គឺស្ត្រីនៅមិនទាន់ប្រសូត ស្ត្រីកូនមួយ ស្ត្រីកណ្តាលមនុស្ស ស្ត្រីចាស់ រហូតដល់ស្ត្រីមានអាយុ ១០០ ឆ្នាំ ខ្នងកោង មានដៃកាន់ឈើច្រត់ មានខ្លួនដួលចុះហើយ ទ្រង់សម្តែងការស្លាប់របស់ស្ត្រីនោះហើយ ធ្វើសាកសពឲ្យហើមប៉ោងជាដើម ដែលសត្វទាំងឡាយ មានក្អែកជាដើមចោមរោមចឹកស៊ី និងមានក្លិនស្អុយ គួរខ្ពើម គួរបដិកូលដល់នាងនន្ទា ដែលកំពុងមើលនោះឯង នាងនន្ទាឃើញមាតុគ្រាមនោះ ក៏មានអនិច្ចសញ្ញាប្រាកដឡើងថា កាយនេះទូទៅទាំងអស់ ដល់អាត្មាអញ និងដល់អ្នកដទៃយ៉ាងនេះឯង សូម្បីទុក្ខសញ្ញា និងអនត្តសញ្ញា ក៏ប្រាកដឡើងដោយទំនងអនិច្ចសញ្ញានោះ កពទាំង ៣ ប្រាកដឡើង មិនជាទីពឹងអាស្រ័យ ដូចផ្ទះត្រូវភ្លើងឆេះដូច្នោះ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ដឹងថា ចិត្តរបស់នាងនន្ទាស្ទុះទៅក្នុងកម្មដ្ឋាន ទើបត្រាស់គាថាទាំងនេះ ដោយអំណាចនៃសប្បាយដល់នាងថា

ម្នាលនាងនន្ទា នាងចូរមើល ( រាងកាយនេះ ) មានជំងឺជានិច្ច មិនស្អាត ជារបស់ស្អុយ ហូរចូល ហូរចេញនូវរបស់មិនស្អាត ដែលពួកបុគ្គលពាលប្រាថ្នាក្រៃលែង សរីរៈរបស់ស្រីនេះយ៉ាងនេះ សរីរៈរបស់នាងក៏យ៉ាងនោះ សរីរៈរបស់នាងយ៉ាងណា សរីរៈរបស់ស្រីនេះក៏យ៉ាងនោះ នាងចូរមើលធាតុទាំងឡាយដោយភាពជារបស់សូន្យ ចូរកុំត្រឡប់មកកាន់លោកនេះទៀត ចូរខ្ជាក់ចោលនូវការពេញចិត្តក្នុងភព ជាអ្នកស្ងប់រម្ងាប់

ត្រាច់ទៅ ។

ក្នុងកាលចប់គាថា នាងនន្ទាតាំងនៅក្នុងសោតាបត្តិផល លំដាប់នោះ ព្រះដ៏មានព្រះភាគ កាលត្រាស់វិបស្សនាកម្មដ្ឋាន ដែលមានសុញ្ញតាជាបរិវារ ដើម្បីសម្រេចមគ្គខាងលើដល់នាង ទើបត្រាស់សូត្រនេះ នេះជាអត្ថុប្បត្តិហេតុទី ១ ។

ក្នុងអត្ថុប្បត្តិហេតុទី ២ បានពោលក្នុងគាថាធម្មបទថា ព្រះដ៏មានព្រះភាគ គង់នៅក្នុងក្រុងរាជគ្រឹះ ធីតារបស់នាងសាលវតីគណិកា ឈ្មោះសិរិមា ដែលមានសមុដ្ឋានបានពោលពិស្តារក្នុងចីវរក្ខន្ធកៈ ដែលជាប្អូនស្រីរបស់ពេទ្យជីវកនោះ បាននូវតំណែងនោះ ដោយកន្ទ្រង់អំពីមាតា មើលងាយបុណ្ណកសេដ្ឋីធីតា សូមខមាទោសដល់ព្រះមានព្រះភាគ ស្តាប់ព្រះធម្មទេសនា បានជាសោតាបន្ន ញុំាងនិច្ចភត្ត ៨ សម្រាប់ឲ្យប្រព្រឹត្តទៅ ក្នុងរឿងនៃគាថានេះថា បុគ្គលគប្បីផ្ចាញ់មនុស្សក្រោធ ដោយសេចក្តីមិនក្រោធ ភិក្ខុដែលទទួលនិច្ចភត្តមួយរូប ប្រារព្ធដល់នាងសិរិមានោះ ក៏កើតរាគៈ និងមិនអាចធ្វើអាហារកិច្ច ដេកអត់អាហារ ។ ភិក្ខុនោះដេកយ៉ាងនោះឯង នាងសិរិមាក៏ស្លាប់ទៅកើតជាព្រះទេវីរបស់ស្តេចសុយាម ក្នុងយាមាភព ។

ក្នុងខណៈនោះ ព្រះដ៏មានព្រះភាគ ទ្រង់មានភិក្ខុសង្ឃចោមរោមហើយ នាំភិក្ខុនោះយាងទៅមើលសរីរៈរបស់នាងសិរិមានោះ ដែលព្រះរាជាទ្រង់ហាមនូវការដុតសពរបស់នាង ហើយរក្សានៅក្នុងព្រៃខ្មោច មហាជន និងព្រះរាជា

ក៏ទៅមើលយ៉ាងនោះ ក្នុងជនចំនួននោះមនុស្សទាំងឡាយពោលថា ក្នុងកាលមុន ការមើលនាងសិរិមាដោយទ្រព្យ ១០០៨ ( កហាបណៈ ) ក៏ឃើញបានដោយលំបាក ឥឡូវនេះ ក្នុងថ្ងៃនេះ បុគ្គលដែលប្រាថ្នានឹងមើលនាង សូម្បីដោយមួយកាកណិក ក៏មិនមាន ។ ចំណែកសិរិមាទេវកញ្ញា កាលរថ ៥០០ ចោមរោមហើយ ក៏ទៅក្នុងទីនោះ ។ ព្រះដ៏មានព្រះភាគ ត្រាស់សូត្រនេះ ដើម្បីសម្ដែងធម៌ដល់ជនទាំងឡាយ ដែលប្រជុំគ្នាក្នុងទីនោះ ដោយគាថាធម្មបទថា ចូរអ្នកមើលអត្តភាព ( នោះ ) ដែលកុសលាកុសលកម្ម ធ្វើវិចិត្រហើយ ដើម្បីទ្រង់ទូន្មានដល់ភិក្ខុនោះ នេះជាអត្ថុប្បត្តិហេតុទី ២ នៃព្រះសូត្រនេះ ។

បណ្ដាបទទាំងនោះ បទថា **ចរំ វា** សេចក្ដីថា ទៅដោយការនាំរូបកាយទាំងមូលទៅ ដោយបែរមុខចំពោះទិសដែលគប្បីទៅ ។ បទថា **យទិ វា តិដ្ឋំ** សេចក្ដីថា ឈរដោយមិនមានការលើករូបកាយនោះឯង ។ បទថា **និសិន្នោ ឧទ វា សយំ** សេចក្ដីថា អង្គុយដោយភាពដែលរូបកាយនោះបត់ចំណែកខាងក្រោម និងលើកឡើងនូវចំណែកខាងលើ ឬដេកដោយសណ្ដូក ទៅខាងទទឹង ។

បទថា **សម្មិញ្ជេតិ បសារេតិ** សេចក្ដីថា បត់ចូល និងលាចេញនូវសន្ទាក់នោះៗ ។ បទថា **ឯសា កាយស្ស ឥញ្ជនា** សេចក្ដីថា ទាំងអស់នោះជាការកម្រើក បានដល់ ឃាត គឺឃាតទៅរបស់កាយដែលមានវិញ្ញាណនេះ ។

បុគ្គលណាដែលឈ្មោះថាត្រាច់ទៅ ឬលាចេញទៅក្នុងទីនេះ មិនមានឡើយ ម្យ៉ាងទៀត កាលចិត្តកើតឡើងថា អញនឹងដើរ វាយោធាតុដែលមានចិត្តនោះជាសមុដ្ឋាន រមែងផ្សាយទៅកាន់រាងកាយ កាយនោះក៏មានការនាំទៅ បែរមុខចំពោះទិសដែលគប្បីទៅ គឺការកើតឡើងក្នុងរវាងចំណែក ក៏រមែងមានដោយហេតុនោះ ទើបហៅថា **ចរំ** ។

ម្យ៉ាងទៀត កាលចិត្តកើតឡើងថា អញឈរ វាយោធាតុដែលមានចិត្តនោះជាសមុដ្ឋាន ក៏រមែងផ្សាយទៅកាន់រាងកាយ រាងកាយនោះ ក៏មានការលើកឡើងដោយចិត្តនោះ គឺប្រាកដនៃរូបដោយឋានៈដែលខ្ពស់ រមែងមានព្រោះហេតុនោះ ទើបហៅថា **តិដ្ឋំ** ។

ម្យ៉ាងទៀត កាលចិត្តកើតឡើងថា អញនឹងអង្គុយ វាយោធាតុដែលមានចិត្តជាសមុដ្ឋាន រមែងផ្សាយទៅកាន់រាងកាយ រាងកាយនោះ ក៏មានការបត់ចូលនូវចំណែកខាងក្រោម និងការលើកឡើងនូវចំណែកខាងលើដោយចិត្តនោះ គឺការប្រាកដនៃរូប រមែងមានដោយភាវៈយ៉ាងនោះ ។ ដោយហេតុនោះ ទើបហៅថា **និសិន្នោ** ។

ម្យ៉ាងទៀត កាលចិត្តកើតឡើងថា អញនឹងដេក វាយោធាតុដែលមានចិត្តនោះជាសមុដ្ឋាន រមែងផ្សាយទៅកាន់រាងកាយ រាងកាយនោះ រមែងលាចេញតាមទទឹងដោយចិត្តនោះ គឺការប្រាកដនៃរូបដោយភាវៈយ៉ាងនោះ ដោយហេតុនោះ ទើបហៅថា **សយំ** ។

ការដែលអ្នកមានអាយុនេះរូបណាមួយដែលមានឈ្មោះយ៉ាងនេះ ដើរ ឈរ អង្គុយ ឬដេកយ៉ាងនេះ លោកហៅថា បត់ចូល លាចេញ ដោយអំណាចនៃការលុតជង្គង់ និងលាចេញនូវសន្ទាក់នោះៗ ក្នុងឥរិយាបថនោះៗ ព្រោះកាលចិត្តគិតនឹងបត់ចូល ឬលាចេញកើតឡើង ការកម្រើកនោះ រមែងមានដោយន័យតាមដែលពោលហើយនោះឯង ព្រោះហេតុនោះ ទុំះជាការកម្រើករបស់កាយ បុគ្គលដទៃក្នុងទីនេះ មិនមានឡើយ សូន្យចាកសត្វ ឬបុគ្គលដែលកំពុងដើរ ឬលាចេញ តែក្នុងទីនេះ មានបរមត្ថតែម្យ៉ាង គឺភាពដែលវាយោធាតុផ្សេងគ្នា រមែងមានព្រោះអាស្រ័យចិត្តដែលផ្សេងគ្នា ការកម្រើកនៃកាយរមែងមានផ្សេងៗ ព្រោះភាពដែលវាយោធាតុផ្សេងគ្នាដូច្នេះ ។

ដោយគាថានេះ ព្រោះព្រះដ៏មានព្រះភាគគង់នៅក្នុងឥរិយាបថមួយ ការបៀតបៀនកាយក៏មានដោយការប្រកប និងដើម្បីកម្ចាត់នូវការបៀតបៀនកាយនោះ ទើបទ្រង់ធ្វើនូវការផ្លាស់ប្តូរឥរិយាបថ ព្រោះហេតុនោះ ទើបទ្រង់សម្តែងទុក្ខលក្ខណៈ ដែលឥរិយាបថបិទបាំង ដោយបទថា **ចរំ វា** ជាដើម ។ ម្យ៉ាងទៀត ការត្រាស់ប្រភេទនៃការត្រាច់ទៅជាដើមទាំងអស់នោះ ព្រោះមិនមានការឈរជាដើមក្នុងវេលាដើរថា ទុំះជាការកម្រើករបស់កាយ ឈ្មោះថា ទ្រង់សម្តែងអនិច្ចលក្ខណៈដែលសន្តតិបិទបាំង និងកាលការដល់ព្រមនោះប្រព្រឹត្តទៅហើយ ក៏ត្រាស់បដិសេធសត្វថា ទុំះជាការកម្រើករបស់កាយ ឈ្មោះថា ទ្រង់សម្តែងអនត្តលក្ខណៈ ដែលអត្តសញ្ញា និងឃនៈបិទបាំង ។

កាលត្រាស់សុញ្ញតាកម្មដ្ឋាន ដោយការសម្ដែងត្រៃលក្ខណ៍ យ៉ាងនេះហើយ ទើបទ្រង់ប្រារព្ធគាថាថា កាយប្រកបហើយដោយឆ្អឹង និងសរសៃទាំងឡាយ ដើម្បីទ្រង់សម្ដែងអសុភទាំងដែលមានវិញ្ញាណ និងមិនមានវិញ្ញាណ ។

គាថានោះ មានសេចក្ដីថា ទុះជាការកម្រើករបស់កាយណា កាយនេះប្រកបហើយដោយឆ្អឹង និងសរសៃ ព្រោះភាពដែលកាយនេះប្រកបហើយដោយឆ្អឹងជាង ៣០០ កំណាត់ និងដោយសរសៃ ៩០០ ដែលខ្ញុំប្រកាសហើយដោយប្រភេទនៃពណ៌ សណ្ឋាន ទិស ឱកាស និងការកំណត់ និងដោយអព្យាបារន័យ ក្នុងកាលពណ៌នាដល់អាការ ៣២ យ៉ាង ក្នុងវិសុទ្ធិមគ្គ ព្រោះដូច្នោះអ្នកសិក្សាគប្បីជ្រាបថា ពាសដោយស្បែក បូកដោយសាច់ ព្រោះភាពដែលកាយនេះពាសដោយស្បែក មានស្បែកម្រាមជើង និងស្បែកម្រាមដៃជាដើម និងដោយសាច់ មានសាច់ ៩០០ ដុំ ដែលខ្ញុំប្រកាសហើយ ក្នុងវិសុទ្ធិមគ្គនោះឯង មានក្លិនស្អុយ គួរខ្ពើម គួរបដិកូលក្រៃលែង ។

ក្នុងសេចក្ដីនេះ អ្នកសិក្សាគប្បីជ្រាបដូចម្ដេច បើស្បែកនេះ ត្រូវបកចេញអំពីរាងកាយទាំងមូល របស់មជ្ឈិមបុរស ក៏នឹងមានប្រមាណប៉ុនគ្រាប់ពុទ្រារាងកាយនេះបើមិនត្រូវបិទបាំងដោយស្បែក ដែលល្អិតដូចស្លាបរុយ ក៏នឹងដូចជញ្ជាំងផ្ទះមិនបិទបាំងដោយរន្ធពណ៌ខៀវជាដើម តែកាយនេះ បិទបាំងដោយស្បែក សូម្បីល្អិតយ៉ាងនោះ ដែលបុគ្គលពាល ប្រាសចាកបញ្ញាចក្ខុ រមែង

មិនឃើញតាមសេចក្តីពិត ។

ស្បែករបស់រាងកាយនោះ ដែលគេលាបដោយគ្រឿងរក្សាស្បែក រាប់ថា គួរខ្ពើម និងគួរបដិកូលយ៉ាងក្រៃលែង ។ សាច់ច្រើនរយដុំ លោកពោលហើយថា សាច់មាន ៩០០ ដុំ បូកលាបហើយក្នុងរាងកាយ ជារបស់ស្អុយដូចបន្ទន់ដែលជេរជាសដោយហ្វូងដង្កូវដូច្នោះ ។

ដោយប្រភេទដែលស្បែកស្រោបក្តី ដូចមានគាថាថា

សរសៃ ៩០០ នៅក្នុងរាងកាយ ដែលមានបណ្តោយ
មួយព្យាម ចងនូវគ្រោងឆ្អឹង ដូចផ្ទះដែលចងដោយវល្លិ៍
ដូច្នោះ បូកលាបដោយសាច់ក្តី ។

ឆ្អឹង ៣០០ កំណាត់ដែលសរសៃចងតម្រៀបគ្នាតាមលំដាប់ ជារបស់ស្អុយ មានក្លិនស្អុយក្តី ដែលពាលបុថុជ្ជនមិនបានឃើញតាមសេចក្តីពិត ។

ព្រោះបណ្ឌិត មិនប្រកាន់ស្បែកជាដើមនោះ ប្រើភ្នែក គឺបញ្ញា ចាក់ធ្លុះនូវសាកសពខាងក្នុង និងរបស់មិនស្អាត មានក្លិនស្អុយ គួរខ្ពើម និងបដិកូលក្រៃលែង មានប្រការផ្សេងៗ មិនប្រាកដដល់ ( សត្វ ) លោកទាំងអស់ ព្រោះភាពដែលកាយបិទបាំងដោយសម្បុរថ្លៃ ដែលស្មើដូចស្លាបរុយ ដែលត្រូវខ្ចប់ដោយស្បែក ដែលលាបដោយគ្រឿងលាប គប្បីឃើញកាយយ៉ាងនេះថា ពេញដោយពោះវៀន អាហារថ្មី ។បេ។ ប្រមាត់ ខ្លាញ់រាវ ដូច្នេះ ។

បណ្តាបទទាំងនោះ កាយពេញដោយពោះវៀន ឈ្មោះថា **អន្តបូរោ**

ពេញដោយអាហារ ឈ្មោះថា **ឧទរបូរោ ។** ពាក្យថា **ឧទរំ** នោះ ជាឈ្មោះរបស់អាហារថ្មី ។ ពិតហើយ អាហារថ្មីនោះ ហៅថា **ឧទរំ** ដោយឈ្មោះរបស់ទីតាំង ។ បទថា **យកបេឡស្ស** បានដល់ មានដុំថ្លើម ។ បទថា **វត្ថិនោ** បានដល់ ទឹកមូត្រ ។ មូត្រនោះ ហៅថា **វត្ថិ** សំដៅដល់ទីតាំង ។ បទថា **បូរោ** បានដល់ ធ្វើពេញទំហឹង ព្រោះដូច្នោះ គប្បីប្រកបយ៉ាងនេះថា ពេញដោយដុំថ្លើម ពេញដោយមូត្រ ។ ក្នុងបេះដូងជាដើមក៏ន័យនេះ ។ បទថា **អន្ត** ជាដើម អ្នកសិក្សាគប្បីជ្រាបដោយអំណាចនៃពាក្យដែលពោលហើយ ក្នុងវិសុទ្ធិមគ្គ ដោយប្រភេទនៃពណ៌ សណ្ឋាន ទិស ឱកាស និងបរិច្ឆេទ និងដោយអព្យាបារន័យ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងសាកសពខាងក្នុងថា ក្នុងកាយនេះ វត្ថុដែលគួរកាន់យក ដូចជាកែវមុក្តា និងកែវមណីណាមួយ ក៏មិនមានឡើយដោយពិត កាយនេះ ពេញទៅដោយរបស់មិនស្អាតទាំងអស់ ឥឡូវនេះកាលទ្រង់សម្តែងសាកសពខាងក្នុងនោះឯង ធ្វើឲ្យប្រាកដដូចសាកសពខាងក្រៅ ទើបសង្គ្រោះនូវវត្ថុដែលត្រាស់ហើយកាលមុន និងដែលមិនទាន់ត្រាស់ចូលជាមួយគ្នា ទើបត្រាស់ ២ គាថាថា **អថស្ស នវហិ សោតេហិ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **អថ** ជាការសម្តែងពន្រឹកបរិយាយដទៃ អធិប្បាយថា ចូរអ្នកមើលរបស់មិនស្អាត ដោយបរិយាយដទៃទៀត ។ បទថា **អស្ស** បានដល់ កាយនេះ ។ បទថា **នវហិ សោតេហិ** បានដល់

ប្រឡង់ត្រចៀក ២ រន្ធត្រចៀក ២ រន្ធច្រមុះ ២ មាត់ ១ ទ្វារលាមក ១ និងទ្វារមូត្រ ១ ។ បទថា **អសុចី សវតិ** សេចក្តីថា របស់ដែលមិនស្អាត មានក្លិនស្អុយ និងគួរខ្ពើមក្រៃលែង មានប្រការផ្សេងៗ ប្រាកដហើយដល់លោកទូទៅ រមែងហូរចេញ គឺរមែងហៀរចេញ រមែងហូរចេញទៅ ។ គន្ធជាតិ មានក្រស្នា និងខ្លឹមចន្ទន៍ ឬរតនជាតិ មានកែវមណី និងកែវមុក្តាជាដើមណាមួយ ក៏មិនមែនហូរចេញមកឡើយ ។ បទថា **សព្វទា** សេចក្តីថា របស់ដែលមិនស្អាតនោះឯង រមែងប្រាកដដល់បុគ្គលដែលឈរក្តី ដើរក្តី សព្វកាល គឺក្នុងពេលយប់ខ្លះ ពេលថ្ងៃខ្លះ ពេលព្រឹកខ្លះ ពេលល្ងាចខ្លះ ។

បើមានពាក្យសួរថា របស់មិនស្អាតនោះគឺអ្វី ឆ្លើយថា គឺពពឹកត្រចៀកហូរអំពីត្រចៀកជាដើម ។ ពិតហើយ ពពឹកត្រចៀកដូចគ្នានឹងសាច់ដែលបកស្បែកចេញហើយ រមែងហូរចេញអំពីប្រឡង់ត្រចៀកទាំងពីរនៃកាយនោះ ។ អាចម៍ត្រចៀកដូចគ្នានឹងដុំធូលី រមែងហូរចេញអំពីរន្ធត្រចៀកទាំងពីរ ។ អាចម៍ច្រមុះ ដូចគ្នានឹងខ្ទុះ រមែងហូរចេញអំពីរន្ធច្រមុះទាំងពីរ ។ បុគ្គលរមែងខ្ជាក់ចោលតាមមាត់ ។

បើមានពាក្យសួរថា ខ្ជាក់ចោលនូវអ្វី ឆ្លើយថា ជួនកាល ខ្ជាក់ចោលនូវទឹកប្រមាត់ អធិប្បាយថា ក្នុងកាលណាទឹកប្រមាត់រាវកម្រើក ក៏រមែងខ្ជាក់នូវទឹកប្រមាត់ក្នុងកាលនោះ ។

បទថា **សេម្ហំ ច** សេចក្តីថា រមែងខ្ជាក់នូវទឹកប្រមាត់តែម្យ៉ាងក៏មិនមែន

សូម្បីស្លេស្មដែលជាដុំ ដែលមានប្រមាណមួយបាត្រណា តាំងនៅក្នុងពោះ រមែងខ្ជាក់ស្លេស្មនោះក្នុងកាលខ្លះ ។ ស្លេស្មនោះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងវិសុទ្ធិមគ្គ ដោយពណ៌ជាដើម ដោយ ៥ សព្ទថា **សេម្ហំ ៥** ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងថា រមែងខ្ជាក់នូវស្លេស្ម និងរបស់មិនស្អាតដទៃ មានអាហារថ្មី និងឈាមជាដើមបែបនោះ ។

ព្រះដ៏មានព្រះភាគ ទ្រង់ជាកាលញ្ញូ បុគ្គលញ្ញូ និងបរិសញ្ញូ កាលទ្រង់សម្តែងនូវការខ្ជាក់របស់ដែលមិនស្អាតចាកទ្វារទាំង ៧ យ៉ាងនេះហើយ បន្ទាប់អំពីនោះ ទ្រង់មិនពាល់ត្រូវនូវទ្វារទាំងពីរ ដោយព្រះតម្រាស់ពិសេស កាលទ្រង់សម្តែងនូវការហូរចេញរបស់មិនស្អាត ចាកកាយទាំងអស់ដោយបរិយាយដទៃទៀត ទើបត្រាស់ថា **កាយម្ហា សេទជល្លិកា** ។

បណ្តាបទទាំងនោះ បទថា **សេទជល្លិកា** បានដល់ ញើស និងទឹកប្រៃមានផ្កាអំបិល និងញើសក្អែលនៃរាងកាយជាដើម ។ គប្បីសម្ព័ន្ធពាក្យនេះជាមួយ ពាក្យថា **សវតិ សព្ពទា** ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងភាពដែលកាយនេះ ជារបស់មិនស្អាតដោយអំណាចនៃមន្ទិល ចាកអាហារដែលបរិភោគ និងផឹកជាដើម កាលអាហារដែលបរិភោគ និងផឹកជាដើមចំហុយដោយភ្លើង ដែលកើតអំពីកម្ម ក៏ប្រាកដឡើងហើយហូរចេញដោយប្រភេទ មានពពឹកភ្នែកចេញអំពីភ្នែក ហើយប្រឡាក់អវយវៈ មានភ្នែកជាដើម ហើយជាប់ខាងក្រៅ ដូចកាលគេចម្អិនកត្ត

ពពុះអង្គុរ និងកំណកទឹក ក៏ប្រាកដជាមួយពពុះទឹក ហើយប្រឡាក់មាត់ផ្ទាំង ហៀរចេញមកក្រៅដូច្នោះ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងភាព ដែលកាយនោះជារបស់មិនស្អាត ព្រោះភាពដែលសីសៈ ដែលសន្មតថា ជាឧត្តមមង្គលក្នុងលោក ដែលមនុស្សទាំងឡាយកាន់យក ដោយភាពជារបស់ប្រសើរក្រៃលែង មិនធ្វើនូវការថ្វាយបង្គំដល់បុគ្គលដែលគួរថ្វាយបង្គំទាំងឡាយ នុ៎ះជារបស់មិនមានខ្លឹមសារ និងភាពជារបស់មិនស្អាត ទើបត្រាស់គាថានេះថា **អថស្ស សុសិរំ សីសំ ។**

ក្នុងបទទាំងនោះ បទថា **សុសិរំ** បានដល់ ឱកាសទទេ ។ បទថា **មត្ថលុង្គស្ស បូរិតំ** សេចក្ដីថា ពេញដោយខួរក្បាល ដូចឃ្មោកពេញដោយតក្កៈ ដូច្នោះ ។ ខួរក្បាលនេះ អ្នកសិក្សាគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងវិសុទ្ធិមគ្គនោះឯង ។

បទថា **សុភតោ ណំ មញ្ញតិ ពាលោ** សេចក្ដីថា បុគ្គលពាលចូលចិត្តគិតក្នុងវត្ថុដែលគិតអាក្រក់ រមែងសម្គាល់កាយនេះ ដែលពេញដោយសាកសពមានប្រការផ្សេងៗ យ៉ាងនេះថា ស្អាត គឺរមែងសម្គាល់ដោយការសម្គាល់ គឺតណ្ហា ទិដ្ឋិ មានះទាំង ៣ ថាល្អ ស្អាត គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ព្រោះហេតុអ្វី ព្រោះបុគ្គលពាលត្រូវអវិជ្ជារឹតរួតហើយ គឺត្រូវមោហៈដែលបិទបាំងសច្ចៈទាំង ៤ រឹតរួតហើយ គឺជាស់តឿនហើយ ឲ្យប្រព្រឹត្តទៅហើយ ឲ្យកាន់យកហើយថា ចូរប្រកាន់យ៉ាងនេះ ចូរកាន់យកយ៉ាងនេះ ចូរ

សម្គាល់យ៉ាងនេះ អធិប្បាយថា ចូរអ្នកឃើញ ថាកាយជារបស់ស្អាត ជរាប ដែលអវិជ្ជាជាហេតុមិនគួរត្រេកអរបាន ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងអសុភដោយអំណាចនៃកាយ មានវិញ្ញាណគ្រប់គ្រងជាដើមយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងអសុភដោយអំណាចនៃកាយដែលមានវិញ្ញាណគ្រប់គ្រង ឬព្រោះកាយសូម្បីជាកាយស្តេចចក្រពត្តិ ក៏ពេញដោយសាកសព តាមដែលពោលហើយដូចគ្នា ព្រោះហេតុនោះ ដើម្បីសម្តែងអសុភក្នុងការមានសម្បត្តិ ដោយប្រការទាំងពួងហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងនូវការមានវិបត្តិ ទើបត្រាស់គាថាថា **យទា ច សោ មតោ សេតិ** ដូច្នេះ ។

គាថានោះ មានអត្ថថា កាយមានយ៉ាងនេះឯង កាលណាបុគ្គលនោះស្លាប់ ព្រោះប្រាសចាកអាយុ ភ្លើងធាតុ និងវិញ្ញាណ ហើមប៉ោងដូចស្បង់ដែលពេញដោយខ្យល់ដូច្នោះ មានពណ៌ខៀវ ព្រោះពណ៌សម្បុរវិនាស ត្រូវបោលក្នុងព្រៃ ព្រោះត្រូវបោះបោលដូចអង្កត់ឧសមិនមានប្រយោជន៍ ដូច្នោះ ក្នុងកាលនោះ ញាតិទាំងឡាយមិនអាឡោះអាល័យដោយចំណែកមួយថា ឥឡូវនេះ គេមិនក្រោកឡើងទៀតឡើយ ។

ក្នុងគាថានោះ ទ្រង់សម្តែងការមិនទៀងដោយបទថា **មតោ** ទ្រង់សម្តែងភាពដែលកាយមិនក្រោកឡើងដោយបទថា **សេតិ** ទ្រង់ប្រកបក្នុងការលះនូវសេចក្តីស្រើនក្នុងជីវិត និងកម្លាំងដោយបទទាំងពីរនោះ ទ្រង់សម្តែងវិបត្តិ ក្នុង

សណ្ឋានដោយបទថា **ឧទ្ធុមាតកោ** ទ្រង់សម្តែងវិបត្តិក្នុងគ្រឿងលាបស្បែក ដោយបទថា **វិនីលកោ** ព្រោះទ្រង់ប្រកបក្នុងការលះនូវសេចក្តីស្រវឹងក្នុងរូប និងក្នុងការលះមានះ ព្រោះអាស្រ័យការស្អាតនៃពណ៌សម្បុរ ដោយបទទាំងពីរនោះ ទ្រង់សម្តែងការមិនមានរបស់ដែលគប្បីកាន់យកដោយបទថា **អបវិទ្ធោ** ទ្រង់សម្តែងភាពជាកាយដែលគប្បីខ្ពើម ដែលមិនគួរនៅខាងក្នុងដោយបទថា **សុសានស្មឹ** ទ្រង់ប្រកបក្នុងការលះនូវការប្រកាន់ថា របស់អញ និងក្នុងការលះសុភសញ្ញា ដោយបទទាំងពីរនោះ ទ្រង់សម្តែងការមិនមានកិរិយាឆ្លើយឆ្លងដោយបទថា **អនបេក្ខា ហោន្តិ ញាតយោ** ទ្រង់ប្រកបនូវការលះសេចក្តីស្រវឹងក្នុងបរិវារដោយបទនោះ ។

កាលទ្រង់សម្តែងអសុភ ដោយអំណាចកាយដែលមិនមានវិញ្ញាណគ្រប់គ្រង ដែលមិនទាន់បែកធ្លាយដោយគាថានេះយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងដោយអំណាចនៃកាយបែកធ្លាយ ទើបត្រាស់គាថាថា **ខាទន្តិ នំ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យេ ចញ្ញេ** សេចក្តីថា សត្វទាំងឡាយដែលបរិភោគសាកសពដទៃ មានក្អែក និងស្ការជាដើម រមែងទំពាស៊ីកាយនោះ បទដ៏សេស ងាយយល់ទាំងអស់ហើយ ។

កាលទ្រង់សម្តែងកាយ ដោយអំណាចនៃសុញ្ញតាកម្មដ្ឋាន ដោយន័យជាដើមថា **ចរំ វា** ដោយអំណាចនៃអសុភ សម្រាប់កាយដែលមានវិញ្ញាណ

គ្រប់គ្រង ដោយន័យជាដើមថា កាយប្រកបដោយឆ្អឹង និងសរសៃទាំងឡាយ ដោយអំណាចនៃអសុភ សម្រាប់កាយដែលមិនមានវិញ្ញាណគ្រប់គ្រង ដោយន័យជាដើមថា កាលណាកាយនោះ ស្លាប់ទៅ ដេកនៅយ៉ាងនេះហើយ ទ្រង់ប្រកាសការប្រព្រឹត្តិរបស់បុថុជ្ជន ដែលជាបុគ្គលពាល និងទ្រង់សម្តែងវដ្ដៈ ដោយមានអវិជ្ជាជាប្រធានដោយពាក្យនេះថា ជនពាលត្រូវអវិជ្ជារួបរឹតហើយ រមែងសម្គាល់កាយនេះថាល្អ ក្នុងកាយនេះ ដែលសូន្យចាកការទៀង សេចក្ដីសុខ និងតួខ្លួនដែលមិនស្អាត ដោយចំណែកមួយ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្ដែងនូវការប្រព្រឹត្តិរបស់បណ្ឌិត ក្នុងកាយនោះ និងវិវដ្ដៈ ដោយមានបរិញ្ញាជាប្រធាន ទើបទ្រង់ប្រារព្ធថា **សុត្វាន ពុទ្ធវចនំ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុត្វាន** បានដល់ ពិចារណាដោយឧបាយ ។ បទថា **ពុទ្ធវចនំ** បានដល់ ពុទ្ធវចនៈ ដែលធ្វើការកំណត់ដឹងកាយ ។ បទថា **ភិក្ខុ** បានដល់ ព្រះសេក្ខៈ ឬបុថុជ្ជន ។ បទថា **បញ្ញាណវា** សេចក្ដីថា វិបស្សនា ហៅថា **បញ្ញាណ** ដែលប្រកបដោយវិបស្សនានោះ ព្រោះការប្រព្រឹត្តិទៅហើយ ក្នុងប្រការមានការមិនទៀងជាដើម ។

បទថា **ឥធ** គឺក្នុងសាសនានេះ ។ បទថា **សោ ខោ នំ បរិជានាតិ** សេចក្ដីថា ភិក្ខុនោះ កំណត់ដឹងកាយនេះដោយបរិញ្ញា ៣ ។ សេចក្ដីនេះដូចម្ដេច គឺដូចឈ្មួញអ្នកឈ្លាសមើលទំនិញថា នេះផង នេះផង ប្រៀបធៀបថា កាលទិញទំនិញដោយទ្រព្យប៉ុណ្ណោះឯង នឹងមានចំណេញប៉ុណ្ណោះ កាលធ្វើយ៉ាង

នោះហើយ កាន់យកដើមទុន និងចំណេញទៀតលក់នូវទំនិញនោះ យ៉ាងណា ភិក្ខុនោះក៏ដូចគ្នា កាលសម្លឹងមើលដោយចក្ខុ គឺញាណថា ចំណែកទាំងនេះ មានធ្អឹង និងសរសៃជាដើម និងមានសក់ រោមជាដើម ឈ្មោះថា កំណត់ដឹងដោយញាតបរិញ្ញា កាលប្រៀបធៀបថា ធម៌នោះមិនទៀង ជាទុក្ខ ជាអនត្តា ឈ្មោះថា កំណត់ដឹងដោយតីរណបរិញ្ញា កាលប្រៀបធៀបយ៉ាងនេះហើយ ដល់នូវអរិយមគ្គ ឈ្មោះថា កំណត់ដឹងដោយបហានបរិញ្ញា ព្រោះលះឆន្ទរាគក្នុងកាយនោះ ឬកាលឃើញដោយអំណាចនៃអសុភនៃកាយដែលមានវិញ្ញាណគ្រប់គ្រង ឬមិនមានវិញ្ញាណគ្រប់គ្រង ឈ្មោះថា កំណត់ដឹងដោយញាតបរិញ្ញា កាលឃើញដោយអំណាចនៃការមិនទៀងជាដើម ឈ្មោះថា កំណត់ដឹងដោយតីរណបរិញ្ញា នាំឆន្ទរាគចេញអំពីកាយនោះ លះកាយនោះដោយអរហត្តមគ្គ ឈ្មោះថា កំណត់ដឹងដោយបហានបរិញ្ញា ។

បើមានពាក្យសួរថា ព្រោះហេតុអ្វី ភិក្ខុនោះរមែងកំណត់យ៉ាងនេះ ឆ្លើយថា ព្រោះរមែងឃើញតាមសេចក្តីពិត អធិប្បាយថា ព្រោះឃើញតាមសេចក្តីពិត កាលប្រយោជន៍នោះសម្រេចដោយបទថា **បញ្ញាណវា** ជាដើមនោះឯង ព្រោះបញ្ញាណវត្ត រមែងមានដល់ភិក្ខុនោះ ព្រោះស្តាប់ពុទ្ធវចនៈ និងព្រោះកាយនេះប្រាកដដល់ជនទាំងពួង ដែលភិក្ខុមិនស្តាប់ពុទ្ធវចនៈហើយ ក៏មិនអាចកំណត់ដឹងបានព្រោះដូច្នោះព្រះដ៏មានព្រះភាគ ដើម្បីទ្រង់សម្តែងហេតុនៃញាណរបស់ភិក្ខុនោះឯង និងភាពដែលភិក្ខុនោះ ជាអ្នកមិនអាចឃើញរូបខាងក្រៅ

ទាំងឡាយអំពីកាយនេះយ៉ាងនេះហើយ ទើបត្រាស់ថា **សុត្វាន ពុទ្ធវចនំ** ដូច្នេះ ។

ព្រះដ៏មានព្រះភាគ ទ្រង់ប្រារព្ធនន្ទាភិក្ខុនី និងភិក្ខុដែលមានចិត្តវិបល្លាសហើយនោះ ទើបត្រាស់ថា **ភិក្ខុ** ដោយញុំាងទេសនាឲ្យប្រព្រឹត្តទៅ ដោយជាបរិស័ទដ៏ប្រសើរ និងដោយសម្តែងភិក្ខុភាវៈ ដល់ជនទាំងឡាយដែលដល់នូវបដិបត្តិក្នុងកាយនោះ ។

ឥឡូវនេះ ដើម្បីទ្រង់សម្តែងប្រការដែលភិក្ខុកំពុងឃើញ រមែងឃើញតាមសេចក្តីពិត ក្នុងបាទគាថានេះថា **យថាភូតញ្ហិ បស្សតិ** ទើបត្រាស់ថា សរីរៈរស់នេះយ៉ាងណា សរីរៈស្លាប់នុ៎ះក៏យ៉ាងនោះ សរីរៈស្លាប់នុ៎ះយ៉ាងណា សរីរៈរស់នេះក៏យ៉ាងនោះ ដូច្នេះ ។

គាថានោះ មានអត្ថថា សរីរៈនេះ មានវិញ្ញាណគ្រប់គ្រង និងជារបស់ដែលមិនស្អាត រមែងដើរ រមែងឈរ រមែងអង្គុយ រមែងដេក ព្រោះមិនទាន់ប្រាសចាកអាយុ ភ្លើងធាតុ និងវិញ្ញាណ យ៉ាងណា សរីរៈសូម្បីមិនមានវិញ្ញាណគ្រប់គ្រងនោះ ដេកក្នុងព្រៃខ្មោចក្នុងឥឡូវនេះ ក្នុងកាលមុនក៏មានហើយ ព្រោះមិនប្រាសចាកធម៌ទាំងនោះ ក៏ដូច្នោះ ។

ម្យ៉ាងទៀត សរីរៈដែលស្លាប់ហើយក្នុងឥឡូវនេះ រមែងមិនដើរ រមែងមិនឈរ មិនអង្គុយ មិនសម្រេចការដេក ព្រោះប្រាសចាកធម៌ទាំងនោះយ៉ាងណា សរីរៈសូម្បីមានវិញ្ញាណគ្រប់គ្រងនេះ ព្រោះប្រាសចាកធម៌ទាំងនោះ

នឹងប្រព្រឹត្តទៅ ដូច្នោះ ។

ម្យ៉ាងទៀត សរីរៈមានវិញ្ញាណគ្រប់គ្រងនេះ មិនទាន់ដេកស្លាប់ក្នុងព្រៃខ្មោច ក្នុងឥឡូវនេះ មិនដល់នូវភាពជារបស់ហើមប៉ោងជាដើម យ៉ាងណា សូម្បីសរីរៈរបស់បុគ្គលស្លាប់ហើយ ក្នុងឥឡូវនេះ ក្នុងកាលមុនក៏បានរស់នៅហើយ ដូច្នោះ ។

ម្យ៉ាងទៀត សរីរៈដែលស្លាប់ហើយ មិនមានវិញ្ញាណគ្រប់គ្រង និងជារបស់មិនស្អាត ដេកនៅក្នុងព្រៃខ្មោច និងដល់នូវភាពជារបស់ហើមប៉ោងជាដើម យ៉ាងណា សរីរៈសូម្បីមានវិញ្ញាណគ្រប់គ្រងនេះ ក៏នឹងដល់សភាពដូច្នោះ ។

ក្នុងបទទាំងនោះ បទថា **យថា ឥទំ តថា ឯតំ** សេចក្តីថា ភិក្ខុ កាលធ្វើភាពដែលសរីរៈដែលស្លាប់ហើយ ជារបស់ស្មើនឹងខ្លួន រមែងលះទោសៈខាងក្រៅបាន ។ បទថា **យថា ឯតំ តថា ឥទំ** សេចក្តីថា កាលធ្វើនូវភាពដែលខ្លួនជាអ្នកស្មើដោយសរីរៈដែលស្លាប់ហើយ រមែងលះនូវតម្រេកខាងក្នុងបាន គឺកាលដឹងច្បាស់នូវអាការដែលធ្វើសរីរៈទាំងពីរឲ្យស្មើគ្នា រមែងលះនូវមោហៈក្នុងសរីរៈទាំងពីរនោះបាន ។

ព្រះដ៏មានព្រះភាគ ទ្រង់ជម្រះការលះអកុសលមូល ក្នុងចំណែកខាងដើមនោះឯង ដោយការឃើញតាមសេចក្តីពិតយ៉ាងនេះហើយ ព្រោះភិក្ខុបដិបត្តិក្នុងការលះអកុសលមូលនោះ រមែងជាអ្នកអាចសម្រេចអរហត្តមគ្គ ខ្ជាក់នូវឆន្ទរាគទាំងពួងដោយលំដាប់ ព្រោះដូច្នោះ ទើបត្រាស់ថា ភិក្ខុគប្បីរំសាយ

នូវសេចក្តីប្រាថ្នាក្នុងកាយ ទាំងខាងក្នុង ទាំងខាងក្រៅ ដូច្នេះ ។ បាលីដ៏សេសថា **ឯវំ បដិបន្នោ ភិក្ខុ អនុបុព្វេន** សេចក្តីថា ភិក្ខុបដិបត្តិហើយយ៉ាងនេះ រមែងខ្ចាក់ចោលនូវការពេញចិត្តក្នុងកាយ ទាំងខាងក្នុង និងខាងក្រៅ ដោយលំដាប់ដូច្នេះ ។

កាលទ្រង់សម្តែងសេក្ខភូមិយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងអសេក្ខភូមិ ទើបត្រាស់ថា **ឆន្ទរាគវិរត្តោ សោ** ដូច្នេះ ។

គាថានោះ មានសេចក្តីថា ភិក្ខុនោះ មានការដឹងច្បាស់ដោយអរហត្តមគ្គញាណ រមែងសម្រេចផលក្នុងលំដាប់នៃមគ្គ ក្នុងកាលនោះ ហៅថា មិនត្រេកអរហើយដោយឆន្ទរាគ ព្រោះភាពដែលឆន្ទរាគៈដែលភិក្ខុនោះលះហើយដោយប្រការទាំងពួង និងហៅថា បានសម្រេចបទដែលទ្រង់ពណ៌នាហើយថា ឈ្មោះថា **អមតំ** ព្រោះមិនមានការស្លាប់ ឬព្រោះអត្ថថា ប្រណីត ឈ្មោះថា **សន្តិ** ព្រោះស្ងប់នូវសង្ខារទាំងពួង ឈ្មោះថា **និព្វានំ** ព្រោះមិនមានគ្រឿងរួបរឹត គឺតណ្ហា ឈ្មោះថា **អមច្ចុតំ** ព្រោះមិនមានការឃ្លាតទៅ ។

ម្យ៉ាងទៀត ភិក្ខុនោះ មានការដឹងច្បាស់ដោយអរហត្តមគ្គញាណ តាំងនៅក្នុងផលក្នុងលំដាប់នៃមគ្គ គប្បីជ្រាបថា មិនត្រេកអរហើយដោយឆន្ទរាគ និងបានសម្រេចបទ មានប្រការដែលពោលហើយ ។ ដោយបទថា **អជ្ឈគា** នោះ ទ្រង់សម្តែងថា ឆន្ទរាគនេះ ដែលភិក្ខុនោះលះបានហើយ និងនិព្វាននេះដែលភិក្ខុនេះបានហើយ ដូច្នេះ ។

កាលត្រាស់អសុភកម្មដ្ឋាន មួយអន្ទើដោយការសម្រេចដោយអំណាចនៃកាយ ដែលមានវិញ្ញាណគ្រប់គ្រង និងមិនមានវិញ្ញាណគ្រប់គ្រងយ៉ាងនេះហើយ កាលទ្រង់តិះដៀលការនៅដោយសេចក្ដីប្រមាទ ទើបធ្វើអន្តរាយដល់អានិសង្សជាច្រើនយ៉ាងនេះ ដោយទ្រង់សម្ដែងដោយសង្ខេបទៀត ទើបត្រាស់ ២ គាថាថា **ទិចានកោយំ** ដូច្នេះជាដើម ។

ក្នុងគាថានោះ កាយទាំងឡាយសូម្បីមិនមានជើងជាដើម ជារបស់មិនស្អាតនោះឯង តែក្នុងគាថានេះ ដោយអំណាចនៃការធ្វើក្រៃលែង ឬដោយអំណាចនៃការកំណត់យ៉ាងខ្ពស់ ឬព្រោះកាយដទៃសូម្បីជារបស់មិនស្អាត តែបុគ្គលផ្សំដោយរសប្រៃ និងរសជូរជាដើមហើយ នាំទៅធ្វើជាអាហាររបស់មនុស្សទាំងឡាយបាន ចំណែកកាយរបស់មនុស្ស មិនដូច្នោះឡើយ ព្រោះហេតុនោះ កាលទ្រង់សម្ដែងមនុស្សដែលមានភាវៈមិនស្អាតក្រៃលែង ទើបត្រាស់ថា **ទិចានកោ** ដូច្នេះ ។

បទថា **អយំ** បានដល់ ទ្រង់សម្ដែងកាយមនុស្ស ។ បទថា **ទុគ្គន្ធោ បរិហីរតិ** សេចក្ដីថា កាយនេះមានក្លិនស្អុយ ដែលបុគ្គលតាក់តែងដោយផ្កា និងគ្រឿងក្រអូបទាំងឡាយ ថែរក្សា ។ បទថា **នានាកុណបបរិបូរោ** បានដល់ ពេញដោយសាកសពច្រើនប្រការ មានសរសៃសក់ជាដើម ។

បទថា **វិស្សវន្តោ តតោ តតោ** សេចក្ដីថា កាយនេះធ្វើនូវការព្យាយាមរបស់មនុស្សទាំងឡាយ សូម្បីព្យាយាមបិទបាំងដោយផ្កា និងគ្រឿង

គ្រអូបជាដើមក៏ឥតផល ហូរចេញនូវរបស់មិនស្អាតទាំងឡាយ មានស្លេស្ម និងសម្បោរជាដើមអំពីទ្វារទាំង ៩ និងកំណកញើសអំពីរណ្ដៅរោមទាំងឡាយ ។ ឥឡូវនេះ ចូរអ្នកមើលក្នុងកាយនេះថា កាយនេះ បុគ្គលពាលទោះប្រុសក្តី ស្រីក្តី គប្បីសម្គាល់លើកខ្លួនឯង គឺសម្គាល់លើកខ្លួនឯងដោយការសម្គាល់ គឺតណ្ហា ទិដ្ឋិ និងមានះ ដោយន័យជាដើមថា អញ របស់អញ ទៀង ឬតាំងខ្លួនក្នុងឋានៈខ្ពស់ គប្បីមើលងាយអ្នកដទៃដោយជាតិជាដើម នឹងមានអ្វីក្រៅពីការមិនឃើញអរិយសច្ចៈ គឺវៀរចាកការមិនឃើញដោយអរិយមគ្គហើយ នឹងមានអ្វីដទៃ គឺគប្បីមានតែការលើកខ្លួន និងការមើលងាយអ្នកដទៃយ៉ាងនេះ សម្រាប់បុគ្គលនោះ ។

ក្នុងកាលចប់ទេសនា នាងនន្ទាភិក្ខុនីបានដល់នូវសេចក្ដីសង្វេគថា ឱហ្ន៎ អញជាបុគ្គលពាល ប្រព្រឹត្តខ្លួនប៉ុណ្ណោះ មិនមកកាន់ទីបម្រើរបស់ព្រះដ៏មានព្រះភាគ ដែលទ្រង់ញ៉ាំងព្រះធម្មទេសនាផ្សេងៗ ឲ្យប្រព្រឹត្តទៅយ៉ាងនេះ កាលសង្វេគយ៉ាងនេះហើយ ពិចារណានូវធម្មទេសនានោះ បានធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ខាងក្នុង ២ ឬ ៣ ថ្ងៃ ដោយកម្មដ្ឋាននោះឯង ។ បានឮថា ក្នុងឋានៈទី ២ ក្នុងពេលចប់ទេសនា សត្វ ៨៤០០០ បាននូវធម្មាភិសម័យ ។ សិរិមាទេវកញ្ញា បានសម្រេចអនាគាមិផល ចំណែកភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផលនោះឯង ។៚

**អដ្ឋកថា វិជយសូត្រ ចប់**

# សុត្តន្តបិដក

## មុនិសូត្រ

[ ២០ ] ភ័យកើតអំពីសេចក្ដីស្និទ្ធស្នាល ធូលី គឺរាគៈជាដើម កើតអំពីលំនៅ គឺរូបនិមិត្តជាដើម ការមិនមានលំនៅ និងការមិនមានសេចក្ដីស្និទ្ធស្នាលនុ៎ះឯង ជាការឃើញរបស់មុនី ( អ្នកប្រាជ្ញ ) ។

បុគ្គលណាបានផ្ដាច់បង់នូវកិលេសដែលកើតហើយ មិនបណ្ដុះកិលេសដែលកំពុងកើត មិនប្រមូលមក ( នូវបច្ច័យ ) នៃកិលេសនោះ អ្នកប្រាជ្ញហៅបុគ្គលនោះ ថាជាបុគ្គលមានប្រយោជន៍ ប្រសើរក្នុងចំណោមអ្នកប្រាជ្ញទាំងឡាយ កំពុងប្រព្រឹត្ត បុគ្គលនោះស្វែងរក ( នូវខន្ធ មានសីលក្ខន្ធជាដើម ) បានឃើញហើយនូវចំណែកនៃសន្តិភាព ។

បុគ្គលណាពិចារណាឃើញទីកើត ( នៃកិលេស ) ទាំងឡាយ ហើយលះបង់ពូជ មិនប្រមូលមកនូវជ័រ គឺតណ្ហា និងទិដ្ឋិ បុគ្គលនោះឯងជាមុនី ឃើញនូវទីបំផុតនៃការអស់ជាតិ លះបង់នូវអកុសលវិតក្ក មិនដល់នូវគតិរាប់ ( ថាជាអ្នកត្រេកអរឬប្រទូស្តឡើយ ) ។

បុគ្គលណាដឹងច្បាស់នូវលំនៅ គឺភពទាំងអស់ មិនប្រាថ្នាលំនៅទាំងនោះទៀត សូម្បីលំនៅណាមួយ បុគ្គលនោះ ជាមុនី

មានសេចក្តីប្រាថ្នាទៅប្រាសហើយ ជាអ្នកលែងប្រាថ្នា មិនប្រមូលមក ( នូវកម្មជាកុសល ឬអកុសល ) ព្រោះជាអ្នកដល់នូវត្រើយ គឺព្រះនិព្វាន ។

អ្នកប្រាជ្ញទាំងឡាយដឹងច្បាស់នូវបុគ្គលនោះ អ្នកគ្របសង្កត់នូវធម៌ទាំងពួង ដឹងច្បាស់នូវធម៌ទាំងពួង មានបញ្ញាល្អ មិនជាប់ក្នុងពួកធម៌ទាំងពួង លះបង់នូវធម៌ទាំងពួង រួចស្រឡះព្រោះអស់ទៅនៃតណ្ហា ថាជាមុនី ។

អ្នកប្រាជ្ញទាំងឡាយដឹងច្បាស់នូវបុគ្គលនោះ អ្នកមានកម្លាំង គឺប្រាជ្ញា ប្រកបដោយសីលវត្ត មានចិត្តតម្កល់មាំត្រេកអរក្នុងឈាន មានស្មារតី រួចចាកធម៌ជាគ្រឿងជាប់ មិនរឹងរូស មិនមានអាសវៈ ថាជាមុនី ។

អ្នកប្រាជ្ញទាំងឡាយដឹងច្បាស់នូវបុគ្គលនោះ ជាបុគ្គលឯកត្រាច់ទៅ ជាអ្នកស្ងៀមមិនប្រមាទ មិនញាប់ញ័រក្នុងសេចក្តីនិន្ទា និងសរសើរ ដូចជាសត្វសីហៈមិនតក់ស្លុត ព្រោះសំឡេងមិនជាប់ក្នុងសំណាញ់ គឺតណ្ហា និងទិដ្ឋិ ដូចជាខ្យល់មិនជាប់ក្នុងសំណាញ់ មិនប្រឡាក់ដោយលោក ព្រោះគ្រឿងប្រឡាក់ គឺតណ្ហា និងទិដ្ឋិ ដូចផ្កាឈូកមិនប្រឡាក់ដោយទឹក ជាអ្នកដឹកនាំគេ មនុស្សដទៃមិនគប្បីនាំទៅបាន ថាជាមុនី ។

ជនទាំងឡាយដទៃ តែងពោលនូវវាចាមានទីបំផុត ដោយជុំវិញ ចំពោះវត្ថុណា បុគ្គលណា ( មិនដល់នូវសេចក្តីត្រេកអរ ឬតូចចិត្តក្នុងវត្ថុនោះ ) ដូចជាសសរដែលបុគ្គលដាំចុះក្នុងកំពង់សម្រាប់ងូត អ្នកប្រាជ្ញទាំងឡាយដឹងច្បាស់នូវបុគ្គលនោះ អ្នកមានរាគៈទៅប្រាសហើយ មានឥន្ទ្រិយតម្កល់មាំល្អហើយ ថាជាមុនី ។ បុគ្គលណាមានខ្លួនស្ថិតនៅត្រង់ដូចជាខ្នារ កាលពិចារណាឃើញការពុំរាបសា និងការរាបសា តែងខ្ពើមកម្មទាំងឡាយដ៏លាមក អ្នកប្រាជ្ញទាំងឡាយដឹងបុគ្គលនោះ ថាជាមុនី ។

បុគ្គលណាមានខ្លួនសង្រួមហើយ មិនធ្វើបាប ទោះនៅក្មេងក្តី កណ្តាលក្តី ជាមុនីមានខ្លួនវៀរចាកបាបហើយ ជាបុគ្គលមិនមានការបៀតបៀន មិនប្រទូស្តនូវបុគ្គលណាមួយ អ្នកប្រាជ្ញទាំងឡាយ រមែងដឹងច្បាស់នូវបុគ្គលនោះ ថាជាមុនី ។

បុគ្គលណាចិញ្ចឹមជីវិតដោយបុគ្គលដទៃឲ្យ បាននូវដុំបាយណា ទោះថ្នាំងក្តី កណ្តាលក្តី សេសសល់ក្តី មិនសរសើរ មិនបន្ទុះបង្អាប់ អ្នកប្រាជ្ញទាំងឡាយ ដឹងច្បាស់នូវបុគ្គលនោះ ថាជាមុនី ។

បុគ្គលណាមិនជាប់នៅក្នុងវ័យណាមួយ អ្នកប្រាជ្ញទាំងឡាយ ដឹងច្បាស់នូវបុគ្គលនោះ ដែលជាអ្នកស្ងៀម ប្រព្រឹត្ត

វៀរមេថុនធម្ម វៀរស្រឡះចាកសេចក្តីស្រវឹង និងសេចក្តីប្រមាទ រួបួតចាកចំណង គឺកិលេស ថាជាមុនី ។

អ្នកប្រាជ្ញទាំងឡាយដឹងច្បាស់នូវបុគ្គលនោះ អ្នកឃើញនូវបរមត្ថ ព្រោះដឹងច្បាស់នូវលោក ប្រព្រឹត្តកន្លងនូវអន្លង់ និងសមុទ្រ មិនញាប់ញ័រ កាត់ផ្តាច់នូវគ្រឿងចាក់ស្រែះ មិនអាស្រ័យនូវតណ្ហា និងទិដ្ឋិ មិនមានអាសវៈ ថាជាមុនី ។

ជនទាំងពីរនាក់មានការនៅ និងការចិញ្ចឹមជីវិតឆ្ងាយគ្នា មិនស្មើគ្នាទេ គឺគ្រហស្ថជាអ្នកចិញ្ចឹមប្រពន្ធ ១ អ្នកបួសមិនប្រកាន់ខ្លួន ជាអ្នកមានវត្តល្អ ១ គ្រហស្ថមិនបានសង្រួមក្នុងការបៀតបៀនជីវិតសត្វដទៃ មុនីសង្រួមរក្សានូវពួកសត្វអស់កាលជានិច្ច ។ ដូចជាសត្វក្ងោកមានកខៀវ ហើរតាមអាកាស មិនដល់នូវសម្ទុះរបស់ហង្សក្នុងកាលណាៗ ឡើយ គ្រហស្ថក៏យ៉ាងនោះដែរ នឹងធ្វើតាមភិក្ខុជាមុនីអ្នកស្ងប់ស្ងាត់ អ្នកចម្រើនឈានក្នុងព្រៃមិនបាន ។

**មុនិសូត្រទី ១២ ចប់**

**ឧរគវគ្គទី ១ ចប់**

**ឧទ្ទាននៃឧរគវគ្គនោះ គឺ**

និយាយអំពីការប្រៀបដោយសត្វពស់ ១ ធនិយគោបាល ១ បុគ្គលប្រៀបដោយកុយរមាស ១ កសិភារទ្វាជព្រាហ្មណ៍ ១ ចុន្ទ ១ សេចក្ដីវិនាស ១ បុគ្គលថោកទាប ១ មេត្តា ១ ហេមវតយក្ស ១ អាឡវកយក្ស ១ អំពីការលះ ១ មុនី ១ រួមជា ១២ ហៅថា ឧរគវគ្គ ។

# អដ្ឋកថា

## មុនិសូត្រ

[ ២០ ] មុនិសូត្រផ្ដើមដោយគាថា **សន្ថវាតោ ភយំ ជាតំ** ដូច្នេះ ។

សូត្រនេះមានអត្ថុប្បត្តិហេតុដូចម្ដេច សូត្រទាំងអស់នោះឯង មិនមានអត្ថុប្បត្តិហេតុដូចគ្នា ពិតហើយ ក្នុងមុនិសូត្រនេះ ៤ គាថាខាងដើម មានអត្ថុប្បត្តិហេតុយ៉ាងនេះមុន ។ បានឮថា កាលព្រះដ៏មានព្រះភាគ គង់នៅក្នុងក្រុងសាវត្ថី ស្រីទុគ៌តម្នាក់ ជាស្រីមេម៉ាយប្ដីស្លាប់ ទើបឲ្យកូនបួសក្នុងសម្នាក់ភិក្ខុទាំងឡាយ សូម្បីខ្លួនឯងក៏បួសក្នុងសម្នាក់ភិក្ខុនីទាំងឡាយ ក្នុងវត្តដែលជាស្រុកភូមិរបស់ខ្លួន ជនទាំងពីរចូលវស្សាក្នុងក្រុងសាវត្ថី បំណងនឹងសួរសុខទុក្ខគ្នានិងគ្នារឿយៗ មាតាបានរបស់ណាមួយ ក៏នាំទៅឲ្យបុត្តៗ បានរបស់ណាមួយ ក៏នាំមកឲ្យមាតាគប់រកគ្នា ទាំងល្ងាច ទាំងព្រឹក ចែករបស់ដែល

បានហើយ ឲ្យដល់គ្នានិងគ្នា ត្រេកអរក្នុងការសួរសុខទុក្ខ អស់នូវសេចក្ដីរន្ធៀស ។ ជនទាំងពីរ ប្រឡូកប្រឡំគ្នា ព្រោះឃើញគ្នារឿយៗ យ៉ាងនេះ ក៏មានការស្និទ្ធស្នាលព្រោះការប្រឡូកប្រឡំ មានឱកាស ព្រោះការស្និទ្ធស្នាល មានចិត្តត្រូវរាគៈចូលមកបៀតបៀន បព្វជិតសញ្ញា និងមាតុបុត្តសញ្ញា ក៏អន្តរធានទៅ បន្ទាប់អំពីនោះ ក៏ធ្វើនូវការកន្លងព្រំដែន សេពនូវអសទ្ធម្ម ដល់នូវការមិនមានយស នាំគ្នាសឹក ហើយគ្រប់គ្រងផ្ទះ ។

ភិក្ខុទាំងឡាយ ក្រាបទូលដល់ព្រះដ៏មានព្រះភាគ ព្រះពុទ្ធអង្គទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មោឃបុរស រមែងដឹងឬហ្ន៎ថា មាតាមិនត្រេកអរក្នុងបុត្ត ឬបុត្តមិនមានតម្រេកក្នុងមាតា ដូច្នេះហើយ ទ្រង់ញុំាងភិក្ខុទាំងឡាយឲ្យសង្វេគដោយសូត្រដ៏សេសជាដើមថា តថាគតពិចារណារកមិនឃើញនូវរូបដទៃ សូម្បីតែរូបមួយ ... ហើយត្រាស់ថា ព្រោះហេតុនោះឯង ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីវៀរមាតុគ្រាម ដូចវៀរពិសដ៏ពន្លឹក វៀរនូវខ្លាញ់ ដ៏ក្ដៅ និងវៀរនូវទឹកទន់ដែង ដូច្នោះ ។

រួចហើយទ្រង់ភាសិត ៤ គាថា ដែលគប្បីបង្អោនចូលមកក្នុងខន្ធថា ភ័យកើតអំពីសេចក្ដីស្និទ្ធស្នាល ដើម្បីទ្រង់សម្ដែងធម៌ដល់ភិក្ខុទាំងឡាយ ។

ក្នុងគាថានោះ សន្ថវៈក្នុងកាលមុនពោលជា ៣ យ៉ាង គឺតណ្ហា ទិដ្ឋិ និងមិត្ត ក្នុងទីនេះបំណងយកតណ្ហាសន្ថវៈ និងទិដ្ឋិសន្ថវៈ សំដៅដល់សន្ថវៈនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ

ចូរមើល ភ័យកើតឡើងអំពីសន្ថវៈរបស់មោឃបុរសនោះ ភ័យនោះជាភ័យកើតអំពីកិលេសដ៏មានកម្លាំង ព្រោះតណ្ហា មានភាពជាអ្នកប្រាថ្នាដើម្បីឃើញគ្នារឿយៗ របស់ភិក្ខុនោះ ដែលជាហេតុឲ្យភិក្ខុនោះមិនអាចតាំងនៅបានប្រព្រឹត្តខុសក្នុងមាតា ឬជាមហាភ័យ មានការតិះដៀលខ្លួនជាដើម ដែលជាហេតុឲ្យលះបង់សាសនា សឹកទៅ ដូច្នោះ ។

បទថា **និកេតា** បានដល់ ប្រភេទនៃអារម្មណ៍ ដែលពោលដោយន័យជាដើមថា ម្នាលគហបតី បុគ្គលដែលហៅថា មានការអន្ទោលទៅរកកន្លែងស្នាក់ ព្រោះការផ្សាយទៅ និងការជាប់ជំពាក់នៃកិលេស ដែលកើតឡើងក្នុងកន្លែងស្នាក់ គឺរូបនិមិត្ត ។

បទថា **ជាយតេ រជោ** សេចក្តីថា ធូលី គឺរាគៈ ទោសៈ និងមោហៈ រមែងកើត ។ សេចក្តីនេះ មានអធិប្បាយដូចម្តេច មានអធិប្បាយថា ភ័យកើតអំពីសេចក្តីស្និទ្ធស្នាល កើតដល់ភិក្ខុនោះតែម្យ៉ាងក៏មិនមែន ដោយពិតនោះ ភ័យនោះ មានអាសវៈជាអារម្មណ៍ ហៅថា **និកេតៈ** ព្រោះអត្ថថា ជាទីនៅរបស់កិលេសទាំងឡាយ ឥឡូវនេះ ធូលីរមែងកើតអំពីភ័យនោះ គឺកើតអំពីទីលំនៅច្រើនឡើង ព្រោះភាពដែលភិក្ខុនោះ ជាអ្នកទម្លាយសំវរៈ ព្រោះភាពជាបុគ្គលកន្លងនូវព្រំដែន ដែលជាហេតុឲ្យបុគ្គលនោះ មានចិត្តសៅហ្មង ដល់នូវសេចក្តីវិនាស ដល់នូវសេចក្តីលំបាក ម្យ៉ាងទៀត គប្បីប្រកបពីរបទនោះយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរមើល ដូចភ័យ

កើតឡើងអំពីការស្និទ្ធស្នាលរបស់មោឃបុរសនោះ និងដូចធូលីកើតអំពីអារម្មណ៍ជាទីតាំងនៃកិលេសដល់បុថុជ្ជនទាំងពួង ដូច្នោះ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់តិះដៀលនូវការឃើញរបស់បុថុជ្ជនដោយអត្ថមុននោះ ដោយប្រការទាំងពួងហើយ កាលទ្រង់សរសើរនូវការឃើញរបស់ព្រះអង្គ ទើបត្រាស់អត្ថក្រោយថា **អនិកេតំ** ដូច្នេះ ។

ក្នុងគាថានោះ គប្បីជ្រាបអនិកេតៈ ដោយបដិសេធនិកេតៈ តាមដែលពោលហើយ ។ អសន្ថវៈ ដោយបដិសេធសន្ថវៈ ពាក្យទាំងពីរនោះជាឈ្មោះរបស់ព្រះនិព្វាន ។ បទថា **ឯតំ វេ មុនិទស្សនំ** សេចក្តីថា ការមិនមានអារម្មណ៍ដែលជាទីតាំងនៃកិលេស និងការមិនស្និទ្ធស្នាលនេះឯង ដែលមុនីបានឃើញហើយ ។ ក្នុងគាថានោះ និបាតថា **វេ** គប្បីឃើញក្នុងអត្ថដែលគួរអស្ចារ្យក្នុងចិត្ត ។ អធិប្បាយថា កាលមាតា និងបុត្តបដិបត្តិខុស ដោយអំណាចអារម្មណ៍ដែលជាទីតាំងនៃកិលេស និងការស្និទ្ធស្នាល អារម្មណ៍ដែលជាទីតាំងនៃកិលេស និងការស្និទ្ធស្នាលនេះឯង ដែលមុនីឃើញហើយថា ឱ មិនធ្លាប់មានដូច្នេះ ជាការដែលសម្រេចហើយ ដោយ **វេ** និបាតនោះ ។ ម្យ៉ាងទៀត ការឃើញរបស់មុនី ព្រោះហេតុនោះ ទើបឈ្មោះថា មុនីទស្សនៈ ឈ្មោះថា ទស្សនៈ ជារបស់គួរ ជារបស់គាប់ចិត្ត អធិប្បាយថា រមែងគួរ និងរមែងគាប់ចិត្ត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ២ បទថា **យោ ជាតមុច្ឆិជ្ជ** សេចក្តីថា

បុគ្គលណាព្យាយាមដោយប្រការដែលនឹងលះអកុសល ដែលកើតឡើងហើយ កាត់នូវកិលេសដែលកើតហើយ គឺមានហើយ កើតឡើងហើយក្នុងវត្ថុណាមួយនោះឯង ដោយញ៉ាំងគុណឲ្យកើតក្នុងវត្ថុនោះ និងកិលេសដែលមិនទាន់មកហើយណា ហៅថា កំពុងកើត ដោយលក្ខណៈកំពុងប្រព្រឹត្តទៅក្នុងទីជិតដែលកំពុងប្រព្រឹត្តទៅ ព្រោះភាពជាកិលេស បែរមុខដើម្បីកើតឡើងដោយការប្រជុំនៃបច្ច័យមានសភាពបែបនោះ មិនគប្បីបណ្តុះនូវកិលេសនោះ ឲ្យកើតឡើងទៀត អធិប្បាយថា ព្យាយាមដោយប្រការដែលមានការមិនកើតឡើងនៃអកុសល ដែលមិនទាន់កើត ឈ្មោះថា មិនគប្បីឲ្យកិលេសកើតឡើង ។

សួរថា មិនគប្បីឲ្យកិលេសកើតដូចម្តេច ឆ្លើយថា មិនគប្បីឲ្យកិលេសនោះហូរចូលទៅ គឺមិនគប្បីឲ្យបច្ច័យ ដែលជាហេតុឲ្យកិលេសនោះកើតហូរចូលទៅ មិនគប្បីរួមចូល មិនគប្បីបណ្តុះកិលេសនោះឲ្យកើតឡើងទៀត ដោយធ្វើឲ្យខ្សោយកម្លាំងក្នុងការងើបឡើងយ៉ាងនេះ ។

ម្យ៉ាងទៀត អ្នកសិក្សាគប្បីជ្រាបការប្រកប ក្នុងគាថានេះយ៉ាងនេះថា ព្រោះកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងអនាគតក្តី ក៏កាត់ដោយមគ្គភាវនា ដោយការមិនមានក្នុងអនាគត ដែលជាបច្ចុប្បន្នក្តី រមែងមិនបណ្តុះដោយការមិនមានកិលេសនោះ ដែលជាអនាគតក្តី រមែងមិនឲ្យហូរចូលទៅកាន់ការបន្តនៃចិត្ត ដោយការទម្លាយនូវសមត្ថភាពនៃការកើត ដូច្នោះ បុគ្គលណា

កាត់នូវកិលេសដែលកើតហើយ ដោយអរិយមគ្គភាវនា មិនគប្បីបណ្តុះកិលេសឲ្យកើតឡើង កាលកិលេសនោះកើតឡើង ក៏មិនគប្បីឲ្យកិលេសដែលជាអនាគតហូរចូលទៅ បណ្ឌិតទាំងឡាយ ពោលបុគ្គលនោះថា ជាបុគ្គលមានប្រយោជន៍ ប្រសើរក្នុងចំណោមអ្នកប្រាជ្ញទាំងឡាយ កំពុងប្រព្រឹត្ត បុគ្គលនោះ ស្វែងរក ( នូវខន្ធ មានសីលក្ខន្ធជាដើម ) បានឃើញហើយនូវចំណែកនៃសន្តិភាព ។

បទថា **ឯកំ** សេចក្តីថា ឈ្មោះថា **ឯក** ព្រោះប្រាសចាកកិលេស ឬឈ្មោះថា **ឯក** ព្រោះអត្ថថា ប្រសើរបំផុត ។ បទថា **មុនិនំ** បានដល់ ជាមុនី ឬជាឯកក្នុងមុនីទាំងឡាយ ។ បទថា **ចរន្តំ** សេចក្តីថា ត្រាច់ទៅដោយភាពបរិបូណ៌ដោយអាការទាំងពួង ដោយលោកត្ថចរិយា និងដោយចរិយាដ៏សេសទាំងឡាយ ។

បទថា **អទក្ខិ** សេចក្តីថា បានឃើញហើយ ។ បទថា **សោ** សេចក្តីថា ពុទ្ធមុនី ដែលត្រាស់ថា បុគ្គលដែលកាត់នូវកិលេសដែលកើតហើយឈ្មោះថា មិនគប្បីដាំឲ្យកើតឡើងទៀត ព្រោះភាពជាអ្នកអាចក្នុងការមិនដាំនិងក្នុងការមិនឲ្យហូរចូលទៅ កាលកិលេសនោះកើត ក៏មិនគប្បីឲ្យហូរចូលទៅ ។ បទថា **សន្តិបទំ** បានដល់ ចំណែកនៃសេចក្តីស្ងប់ អ្នកសិក្សាគប្បីជ្រាបអត្ថយ៉ាងនេះថា បុគ្គលស្វែងរកគុណធំ បានឃើញអច្ចន្តសន្តិក្នុងលោកដែលតាមឃើញយ៉ាងនេះថា ប្រសើរបំផុត ក្នុងបណ្តាសម្មតិសន្តិ និងតទង្គសន្តិ

និងអបច្ចន្តសន្តិ ទាំង ៣ ដែលតំណាងឲ្យទិដ្ឋិ ៦២ វិបស្សនា និងនិព្វាន ។ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៣ បទថា **សង្ខាយ** បានដល់ រាប់ហើយ កំណត់ហើយ ពិចារណាហើយ ដឹងតាមសេចក្តីពិតហើយ អធិប្បាយថា កំណត់ដឹងហើយដោយទុក្ខបរិញ្ញា ។

បទថា **វត្ថូនិ** សេចក្តីថា ទីតាំងនៃកិលេសទាំងឡាយ មានខន្ធ អាយតនៈ និងធាតុ ដែលជាទីតាំងឲ្យបុគ្គលនេះ ជាប់នៅក្នុងលោកយ៉ាងនេះ ។ បទថា **បមាយ ពីជំ** សេចក្តីថា ពូជ គឺអភិសង្ខារវិញ្ញាណនៃវត្ថុទាំងនោះសម្លាប់ គឺបៀតបៀន ទម្លាយនូវពូជនោះ អធិប្បាយថា លះដាច់ហើយដោយសមុច្ឆេ-ទប្បហាន ។

បទថា **សិនេហមស្ស នានុប្បវេច្ឆេ** សេចក្តីថា ដោយហេតុដែលពូជនោះសើមដោយជ័រ គឺតណ្ហា និងទិដ្ឋិ ដូច្នោះ ពូជដែលពោលមកហើយនោះ គប្បីដុះជាវត្ថុតាមដែលពោលហើយនោះ ដោយអំណាចនៃបដិសន្ធិតទៅ មិនធ្វើជ័រនៃពូជនោះឲ្យហូរចូលទៅ អធិប្បាយថា មិនធ្វើជ័រនោះឲ្យហូរចូលទៅដោយមគ្គភាវនា ដែលជាបដិបក្ខចំពោះជ័រនៃពូជនោះ ។

បទថា **ស វេ មុនិ ជាតិក្ខយន្តទស្សី** សេចក្តីថា ពុទ្ធមុនីនោះ បែបនោះ ឈ្មោះថា មានប្រក្រតីឃើញទីបំផុតនៃការវិនាសទៅនៃជាតិ ព្រោះភាពដែលនិព្វាន ដែលជាទីបំផុតនៃជាតិ និងមរណៈ ដែលមុនីឃើញហើយដោយនិព្វានសច្ឆិកិរិយា លះនូវវិតក្កចេញហើយ រមែងមិនចូលដល់ការរាប់ គឺអកុ-

*សលវិតក្ក ៩ ប្រភេទដោយសច្ចភាវនាទាំង ៤ នេះ សម្រេចសឧបា-ទិសេសនិព្វានធាតុ ធ្វើលោកត្តចរិយា ឈ្មោះថា មិនចូលដល់ការរាប់ថាជាទេវតា ឬមនុស្ស ដោយការសម្រេចអនុបាទិសេសនិព្វានធាតុ ព្រោះការអស់ទៅនៃចរិមវិញ្ញាណដោយលំដាប់ ម្យ៉ាងទៀត គប្បីឃើញអត្ថក្នុងគាថានេះយ៉ាងនេះថា បុគ្គលដែលមិនទាន់បរិនិព្វាននោះឯង រមែងចូលដល់ការរាប់ថាបុគ្គលនេះត្រេកអរហើយ ឬត្រូវកិលេសប្រទូស្តហើយ ព្រោះមិនទាន់លះវិតក្កមានកាមវិតក្កជាដើម យ៉ាងណា លះវិតក្កចេញហើយ មិនចូលដល់នូវការរាប់ ដូច្នោះ ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៤ បទថា* **អញ្ញាយ** *សេចក្តីថា ដឹងហើយដោយន័យមានមិនទៀងជាដើម ។ បទថា* **សព្វានិ** *បានដល់ មិនមានចំណែកសល់ ។ បទថា* **និវេសនានិ** *បានដល់ ភពទាំងឡាយ មានកាមភពជាដើម ព្រោះសត្វទាំងឡាយរមែងអាស្រ័យនៅក្នុងភពទាំងនោះ ព្រោះហេតុនោះ ទើបហៅថា ភពដែលជាទីអាស្រ័យនៅ ។*

*បទថា* **អនិកាមយំ អញ្ញតរម្បិ តេសំ** *សេចក្តីថា មិនប្រាថ្នាភពដែលជាទីអាស្រ័យនៅទាំងនោះ សូម្បីភពមួយ ព្រោះឃើញទោសយ៉ាងនេះ ពុទ្ធ-មុនីនោះ គឺបែបនោះ ឈ្មោះថា ប្រាសចាកតម្រេក ព្រោះភាពជាអ្នកប្រាសចាកតម្រេក គឺតណ្ហាហើយ និងឈ្មោះថា មិនត្រេកអរហើយ ព្រោះភាពជាបុគ្គលប្រាសចាកតម្រេកនោះឯងដោយកម្លាំង គឺមគ្គភាវនា មិនដូចបុគ្គលពួក*

មួយ ដែលមិនទាន់ប្រាសចាកតម្រេកសោះ តែប្តេជ្ញាថា អាត្មាអញប្រាស
ចាកតម្រេកហើយ ដូច្នេះ ។

បទថា **ឆាយូហាតី** សេចក្តីថា មិនធ្វើកុសល ឬអកុសលដែលជាហេតុ
កើតនៃភព ដែលជាទីអាស្រ័យនៅនោះៗ ព្រោះហេតុអ្វី ព្រោះជាអ្នកដល់នូវ
ត្រើយនាយហើយ អធិប្បាយថា ព្រោះមុនីបែបនោះជាអ្នកដល់នូវត្រើយនៃ
ភពដែលជាទីអាស្រ័យនៅទាំងពួង គឺព្រះនិព្វានហើយ ។

កាលទ្រង់តិះដៀលការឃើញរបស់បុថុជ្ជនហើយ ទ្រង់សរសើរការឃើញ
របស់ព្រះអង្គដោយគាថាទី ១ ដោយប្រការដូច្នេះហើយ ទ្រង់សរសើរការ
សម្រេចសន្តិបទរបស់ព្រះអង្គ ព្រោះការមិនមានកិលេសទាំងឡាយ ដែល
បុថុជ្ជនមិនទាន់ស្ងប់រម្ងាប់ដោយ ២ គាថា ទ្រង់សរសើរនូវការលះវិតក្ក មិន
ចូលដល់ការរាប់របស់ព្រះអង្គ ដោយសច្ចការនាទាំង ៤ ក្នុងទីតាំងនៃកិលេស
ដែលបុថុជ្ជនមិនទាន់លះវិតក្ក ហើយចូលដល់នូវការរាប់យ៉ាងនោះៗ ដោយ
គាថាទី ៣ ទ្រង់សរសើរការមិនបង្កនូវកម្មរបស់ព្រះអង្គបន្តទៅទៀត ព្រោះមិន
មានតណ្ហាក្នុងភពដែលជាទីអាស្រ័យនៅ ដែលបុថុជ្ជនប្រាថ្នាក្រៃលែង ទើប
សាងនូវកម្មព្រោះភវតណ្ហា ដោយគាថាទី ៤ ទ្រង់បញ្ចប់ទេសនា ក្នុងការ
កើតឡើងដំបូង ដោយកំពូល គឺអរហត្ត ដោយគាថាទាំង ៤ នោះឯង ។

គាថាថា **សព្វាភិភុំ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

មហាបុរសធ្វើមហាភិនិស្ក្រមណ៍ហើយ ទ្រង់សម្រេចសព្វញ្ញុតញ្ញាណ

ដោយលំដាប់ យាងទៅកាន់ក្រុងពារាណសី ដើម្បីប្រយោជន៍ដល់ការញ៉ាំង ធម្មចក្រឲ្យប្រព្រឹត្តទៅ ទ្រង់ជួបឧបកាជីវកក្នុងរវាងចន្លោះពោធិមណ្ឌល និង តំបន់គយា ដែលឧបកាជីវកទូលសួរដោយន័យជាដើមថា អាវុសោ ឥន្ទ្រិយ ទាំងឡាយរបស់លោកផូរផង់ ទើបត្រាស់ថា តថាគតជាបុគ្គលគ្របសង្កត់នូវ ធម៌ទាំងពួង ដូច្នេះជាដើម ឧបកាជីវកទូលថា អើអាវុសោ ងក់ក្បាលហើយ ដើរបញ្ច្រាសផ្លូវហួសទៅ កាលដល់មាគវិកគាម ( ស្រុកព្រាន ) មួយកន្លែង ក្នុងវង្គជនបទដោយលំដាប់ ប្រធានព្រានម្រឹគឃើញឧបកាជីវកនោះ ក៏គិតថា ឱ សមណៈប្រាថ្នាតិច មិនស្លៀកសំពត់ សមណៈនេះជាព្រះអរហន្តក្នុង លោក ហើយនាំទៅកាន់ផ្ទះ អង្គាសដោយរសសាច់ មួយអន្ទើដោយបុត្ត ភរិយា ថ្វាយបង្គំឲ្យបរិភោគហើយ និមន្តថា បពិត្រលោកម្ចាស់ សូមលោក នៅក្នុងទីនេះឯង ខ្ញុំនឹងទំនុកបម្រុងដោយបច្ច័យ រៀបចំទីលំនៅឲ្យឧបកាជីវក ក៏នៅក្នុងទីនោះ ។

ព្រានម្រឹគ កាលម្រឹគទាំងឡាយមិនគេចឆ្ងាយ ដើម្បីត្រាច់ទៅក្នុងបទេស ដែលត្រជាក់ សម្បូរទៅដោយទឹកក្នុងគិម្ហកាល កាលនឹងទៅក្នុងបទេសនោះ ទើបប្រាប់កូនស្រីឈ្មោះឆាវា[1] ថា ចូរនាងទំនុកបម្រុងព្រះអរហន្តរបស់ពួក យើងដោយគោរព ហើយទៅជាមួយកូនប្រុស និងប្អូនប្រុសទាំងឡាយ ។ នាង ឆាវា ជាស្ត្រីដែលគួរមើល ដល់ព្រមដោយចំណែកនៃសរីរៈ ក្នុងថ្ងៃទី ២

១- ក្នុងទីខ្លះ ឈ្មោះនាងនាវា ក៏មាន ។

ឧបកាជីវកមកកាន់ផ្ទះឃើញទារិកានោះ ចូលអន្លុងយជិតដើម្បីអង្គាស ត្រូវរាគៈគ្របសង្កត់ មិនអាចបរិភោគ កាន់ភាជនកត្តទៅកាន់លំនៅ ដាក់ភាជនកត្តក្នុងចំណែកម្ខាង គិតថា បើអញបាននាងចាវ៉ា អញនឹងរស់នៅ បើមិនបាននឹងស្លាប់ ដូច្នេះ ជាអ្នកប្រាសចាកអាហារ ដេក ។ ក្នុងថ្ងៃទី ៧ ព្រានម្រឹគត្រឡប់មក សួរធីតា ដល់ព្រឹត្តិការណ៍របស់ឧបកាជីវក នាងពោលថា មកតែមួយថ្ងៃប៉ុណ្ណោះ ហើយមិនឃើញមកទៀត ព្រានម្រឹគគិតថា អញនឹងចូលទៅរកឧបកាជីវកនោះសាកសួរមើល ទាំងមិនទាន់ផ្លាស់សំលៀកបំពាក់មកក្នុងខណៈនោះឯង ស្ទាបជើង សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់មិនផាសុកឬ ឧបកាជីវកមានរាងកាយទន់ខ្សោយ បម្រះននៀល ទៅមកនោះឯង ព្រានម្រឹគពោលថា សូមលោកម្ចាស់និយាយចុះ ខ្ញុំអាចធ្វើវត្ថុណា នឹងធ្វើវត្ថុទាំងអស់នោះ ។ ឧបកាជីវកពោលថា បើបាននាងចាវ៉ា នឹងមានជីវិត បើមិនបានខ្ញុំស្លាប់ក្នុងទីនេះឯងប្រសើរជាង មាគវិកៈពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ចេះសិប្បៈអ្វីខ្លះឬ ឧបកាជីវកពោលថា ខ្ញុំមិនចេះឡើយ មាគវិកៈពោលថា បពិត្រលោកម្ចាស់ លោកមិនចេះសិប្បៈអ្វីសោះ មិនអាចតម្កល់ក្នុងឃរាវាសបាន ។ ឧបកាជីវកនោះពោលថា ខ្ញុំមិនចេះសិប្បៈអ្វីមែនតែខ្ញុំអាចរែកសាច់របស់អ្នកលក់ដូរ ។ ចំណែកព្រានម្រឹគពោលថា ពួកយើងពេញចិត្តនូវការលក់សាច់នោះឯង ទើបឲ្យសំពត់សាច់ក្រាស់ នាំទៅកាន់ផ្ទះប្រគល់ធីតាឲ្យ ព្រោះអាស្រ័យការនៅរួមរបស់ជនទាំងនោះ កូនក៏កើតឡើង

គាត់ក៏ដាក់ឈ្មោះកូននោះថា សុភទ្ទ នាងចាវាពោលបន្អាប់ឧបកៈ ដោយចម្រៀងបំពេកូន ឧបកៈនោះ មិនអត់ធន់ចំពោះពាក្យចំអន់នោះ ទើបពោលថា នែស្រីស្អាត អញនឹងទៅកាន់សម្នាក់របស់អនន្តជិនៈ ជាសម្លាញ់របស់អញ ហើយបែរមុខទៅកាន់មជ្ឈិមប្បទេស ចៀសចេញទៅ ។

សម័យនោះ ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពនមហាវិហារ ជិតក្រុងសាវត្ថី លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំង-ឡាយជាមុនថា ម្នាលភិក្ខុទាំងឡាយ បើមានអ្នកមកសួរថា ព្រះអនន្តជិនៈ អ្នកទាំងឡាយគប្បីបង្ហាញតថាគត ដល់បុគ្គលនោះ ។ ចំណែកឧបកៈ មកកាន់ក្រុងសាវត្ថីដោយលំដាប់នោះឯង ឈរត្រង់កណ្តាលវិហារសួរថា សម្លាញ់របស់ខ្ញុំឈ្មោះអនន្តជិនៈមានក្នុងវិហារនេះ តើលោកនៅឯណា ភិក្ខុទាំងឡាយនាំឧបកៈទៅកាន់សម្នាក់ព្រះមានព្រះភាគៗ ទ្រង់សម្តែងធម៌ដ៏សមគួរដល់ឧបកៈនោះ ក្នុងទីបំផុតនៃទេសនា ឧបកៈតាំងនៅក្នុងអនាគាមិផល ។

ភិក្ខុទាំងឡាយ ស្តាប់ព្រឹត្តិការណ៍ក្នុងកាលមុន របស់ឧបកៈនោះហើយ ញុំាងវាចាឲ្យតាំងឡើងថា ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងធម៌ដល់សមណៈអាក្រាត ប្រាសចាកសិរី ព្រះដ៏មានព្រះភាគទ្រង់ដឹងការតាំងឡើងនៃវាចានោះ យាងចេញអំពីព្រះគន្ធកុដិ គង់លើពុទ្ធាសនៈ ដោយបាដិហារ្យដែលសមគួរដល់ខណៈនោះ ត្រាស់ហៅថាភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនារឿងអ្វីហ្ន៎ ភិក្ខុទាំងនោះក្រាបទូលរឿង

ទាំងអស់ បន្ទាប់អំពីនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនសម្តែងធម៌ព្រោះមិនមានហេតុ មិនមានបច្ច័យ ធម្មទេសនារបស់តថាគត ប្រាសចាកមន្ទិល បុគ្គលណាម្នាក់ មិនអាចឃើញទោសក្នុងធម្មទេសនានោះម្នាលភិក្ខុទាំងឡាយ ឧបកៈបានជាអនាគាមី ក្នុងឥឡូវនេះព្រោះឧបនិស្ស័យនៃធម្មទេសនានោះ ទ្រង់បានភាសិតគាថានេះ ដែលសម្តែងភាពដែលព្រះអង្គទ្រង់មានទេសនា ដែលមិនមានមន្ទិល ។

គាថានោះ មានសេចក្តីថា ឈ្មោះថា **សព្វាភិភុំ** ព្រោះភាពដែលទ្រង់ជាបុគ្គល ដែលធម៌ទាំងនោះ មិនគ្របសង្កត់ ដោយការលះឆន្ទរាគៈក្នុងខន្ធ អាយតនៈ និងធាតុទាំងពួង ដែលមានអាសវៈ និងព្រោះភាពដែលព្រះអង្គទ្រង់គ្របសង្កត់នូវធម៌ទាំងនោះ ដោយព្រះអង្គឯង ឈ្មោះថា **សព្វវិទុំ** ព្រោះភាពដែលធម៌ទាំងនោះ និងធម៌សព្វយ៉ាងដទៃៗ ដែលទ្រង់ដឹងច្បាស់ដោយអាការទាំងពួង ឈ្មោះថា **សុមេធំ** ព្រោះភាពដែលទ្រង់ដល់ព្រមហើយដោយបញ្ញាដ៏ល្អ ដែលអាចក្នុងការសម្តែងនូវធម៌ទាំងពួង ឈ្មោះថា **សព្វេសុ ធម្មេសុ អនូបលិត្តំ** ព្រោះមិនមានការជាប់ គឺតណ្ហា និងទិដ្ឋិទាំងឡាយ ដែលជាហេតុឲ្យបុគ្គលចូលទៅជាប់ក្នុងធម៌ទាំងពួង មានខន្ធដែលប្រកបដោយអាសវៈជាដើម ឈ្មោះថា **សព្វញ្ជហំ** ព្រោះភាពដែលទ្រង់មិនមានឆន្ទរាគៈ ក្នុងធម៌សព្វយ៉ាងនោះ និងព្រោះទ្រង់លះនូវធម៌ទាំងអស់នោះតាំងនៅ ឈ្មោះថា **តណ្ហក្ខយេ វិមុត្តំ** អធិប្បាយថា បង្អោនទៅក្រៃលែង

ហើយ ព្រោះភាពដែលព្រះអង្គទ្រង់បង្អោនទៅហើយដោយពិសេស ក្នុងនិព្វាន ដែលជាទីអស់តណ្ហា ដោយចិត្តដែលបង្អោនទៅក្នុងឧបធិវិវេក ។

បទថា **តំ វាបិ ធីរា មុនិ វេទយន្តិ** សេចក្តីថា សត្វដែលជាអ្នកប្រាជ្ញទាំងឡាយ រមែងប្រកាស គឺដឹងបុគ្គលនោះថាជាមុនី ។

ព្រះដ៏មានព្រះភាគ ទ្រង់ញុំាងព្រះអង្គឲ្យជាក់ច្បាស់ថា អ្នកទាំងឡាយចូរមើលមុនី ជាបុគ្គលប្រសើរក្រៃលែងជរាបណា ទេសនារបស់មុនីដ៏ប្រសើរក្រៃលែងជរាបនោះ នឹងមានមន្ទិលអំពីណា ។ ពិតហើយ **វា** សព្ទ ក្នុងបទថា **តំ វាបិ ធីរា** នេះមានការជាក់ច្បាស់ជាអត្ថ ចំណែកអាចារ្យពួកខ្លះពោលថា ឧបកៈសូម្បីឃើញព្រះតថាគតក្នុងកាលនោះមិនជឿថា ព្រះតថាគតជាពុទ្ធមុនី ភិក្ខុទាំងឡាយ ញុំាងវាចាឲ្យតាំងឡើងយ៉ាងនេះហើយ បន្ទាប់អំពីនោះ ព្រះដ៏មានព្រះភាគកាលទ្រង់សម្តែងថា ជឿក្តី មិនជឿក្តី តែអ្នកប្រាជ្ញទាំងឡាយប្រកាសបុគ្គលនោះថាជាមុនី ទើបត្រាស់គាថានេះឯង ។

គាថាថា **បញ្ញាពលំ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

គាថានេះ ត្រាស់ប្រារព្ធដល់ព្រះរេវតត្ថេរ ក្នុងគាថានោះ បណ្ឌិតគប្បីជ្រាបបព្វជ្ជា ចាប់តាំងអំពីដើមរបស់ព្រះរេវតត្ថេរ ការសម្រេចគុណវិសេសរបស់លោក ដែលបួសហើយនៅត្រង់ព្រៃគគីរ ដោយន័យដែលពោលហើយក្នុងគាថា ( ធម្មបទ ) នេះថា **គាមេ វា យទិ វារញ្ញេ** និងការយាងទៅ យាងត្រឡប់ អំពីព្រៃគគីរនោះរបស់ព្រះដ៏មានព្រះភាគ កាលព្រះដ៏មាន

ព្រះភាគយាងត្រឡប់ហើយ ភិក្ខុចាស់មួយរូបភ្លេចស្បែកជើង ទើបត្រឡប់មក ឃើញស្បែកជើង ព្យួរត្រង់ដើមគគីរ ដល់ក្រុងសាវត្ថី កាលនាងវិសាខាឧបាសិកាសួរថា បពិត្រលោកម្ចាស់ ឱកាសដែលជាលំនៅរបស់ព្រះរេវតត្ថេរ ជាទីត្រេកអរឬ កាលពោលបៀតបៀន ភិក្ខុទាំងឡាយដែលសរសើរ ទើបពោលថា អើឧបាសិកា ភិក្ខុទាំងនោះ និយាយកុហកកួមិបទេសមិនស្អាត សៅហ្មងក្រៃលែង ព្រៃគគីរនោះសោត ក៏ទាបខ្ពស់ ។ ភិក្ខុនោះ ឆាន់អាគន្តុកភត្តរបស់នាងវិសាខាហើយ សម្ដីងទោសភិក្ខុទាំងឡាយ ដែលប្រជុំត្រង់រោងមូលខាងក្រោយភត្ត ពោលថា អាវុសោ របស់ដែលគប្បីត្រេកអរក្នុងសេនាសនៈរបស់ព្រះរេវតៈ ពួកលោកឃើញហើយឬ ។

ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបហេតុការណ៍នោះ ទើបយាងចេញអំពីព្រះគន្ធកុដិ ដល់កណ្ដាលបរិស័ទ ដោយបាដិហារ្យដែលសមគួរដល់ខណៈនោះគង់លើពុទ្ធាសនៈ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ពាក្យកើតឡើងប្រារព្ធព្រះរេវតត្ថេរៗ ជានវកម្មយ៉ាងនេះ នឹងធ្វើសមណធម៌ក្នុងកាលណា ។ ព្រះសម្ពុទ្ធត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រេវតៈមិនបានជានវកម្ម រេវតៈជាអរហន្តខីណាស្រព ។ ទ្រង់ប្រារព្ធព្រះរេវតៈនោះហើយ ទើបត្រាស់គាថានេះ ដើម្បីសម្ដែងធម៌ដល់ភិក្ខុទាំងនោះ ។

គាថានោះ មានអត្ថថា ឈ្មោះថា **បញ្ញាពលំ** ព្រោះភាពជាអ្នកប្រកប

ដោយកម្លាំង គឺបញ្ញា ដែលសម្រេចការធ្វើកិលេសឲ្យខ្សោយកម្លាំង និងការលះកិលេស មានការសម្តែងឫទ្ធិ និងការអធិដ្ឋានជាដើម ឈ្មោះថា **សីល-វត្តូបបន្នំ** ព្រោះជាបុគ្គលប្រកបហើយដោយបារិសុទ្ធិសីល ៤ និងធុតង្គវត្ត ឈ្មោះថា **សមាហិតំ** បានដល់ មានចិត្តតាំងមាំដោយមគ្គសមាធិ ផល-សមាធិ និងឥរិយាបថសមាធិ ឈ្មោះថា **ឈានរតំ** ព្រោះភាពជាអ្នកត្រេកអរហើយដោយឈាន មានឧបចារជ្ឈាន និងអប្បនាជ្ឈាន ឬត្រេកអរហើយក្នុងឈាន ឈ្មោះថា **សតិមំ** ព្រោះភាពជាអ្នកដល់នូវការបរិបូណ៌ដោយសតិ ឈ្មោះថា **សង្គា បមុត្តំ** ព្រោះភាពជាអ្នករួចផុតចាកគ្រឿងជាប់ជំពាក់ គឺរាគៈជាដើម ឈ្មោះថា **អខិលំ អនាសវំ** ព្រោះមិនមានកិលេសដូចសសរគោល ៥ យ៉ាង និងមិនមានអាសវៈ ៤ យ៉ាង ។

បទថា **តំ វាបិ ធីរា មុនិ វេទយន្តិ** សេចក្តីថា ម្យ៉ាងទៀត សត្វទាំង-ឡាយដែលជាបណ្ឌិតរមែងប្រកាស សូម្បីបុគ្គលនោះ ជាអ្នកប្រកបដោយគុណ គឺបញ្ញាជាដើម ដែលប្រាសចាកទោស គឺគ្រឿងជាប់ជំពាក់ជាដើម ថាជាមុនី ព្រះដ៏មានព្រះភាគទ្រង់សរសើរព្រះរេវតត្ថេរថា អ្នកទាំងឡាយ ចូរមើលវិណាសវមុនីនេះជាបុគ្គលប្រសើរបំផុត មុនីនោះ គប្បីឃើញថាជានវកម្ម ឬនឹងធ្វើសមណធម៌ក្នុងកាលណាដូចម្តេច ព្រោះមុនីនោះ ញ៉ាំងវិហារធម៌នោះឲ្យចប់ហើយដោយកម្លាំង គឺបញ្ញា មិនមែនឲ្យចប់ដោយការធ្វើនវកម្មឡើយ មុនីនោះ ធ្វើកិច្ចស្រេចហើយ នឹងមិនធ្វើសមណធម៌ក្នុងឥឡូវនេះ ។ **វា** សព្ទ

ក្នុងគាថានេះ មានការធ្វើឲ្យជាក់ច្បាស់ជាអត្ថដូច្នេះឯង ។

គាថាថា **ឯកំ ចរន្តំ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

កាលព្រះដ៏មានព្រះភាគ យាងដល់ក្រុងកបិលពស្ដុតាមលំដាប់តាំងអំពីពោធិមណ្ឌល កាលសមាគមនៃព្រះបិតា និងឱរសប្រព្រឹត្តទៅ ព្រះដ៏មានព្រះភាគជាបុគ្គលដែលព្រះបាទសុទ្ធោទនៈទ្រង់ព្រះបាមោជ្ជ ត្រាស់នូវព្រះតម្រាស់ជាដើមយ៉ាងនេះថា បពិត្រព្រះអង្គ កាលនៅជាគ្រហស្ថ ទ្រង់ស្លៀកសំពត់ទាំងឡាយ មានសំពត់កាសីជាដើម ដែលអប់ក្នុងហិបគ្រឿងក្រអូប ឥឡូវនេះ ទ្រង់ស្លៀកសំពត់បំសុកូលទាំងឡាយ ដែលកាត់ហើយបានដូចម្ដេច កាលទ្រង់ទូន្មានព្រះរាជា ទើបត្រាស់ពាក្យជាដើមថា

បពិត្រព្រះបិតា ទ្រង់ត្រាស់ដល់សំពត់កាសីដែលត្បាញផ្ទាំងណា
សំពត់បំសុកូលល្អជាងសំពត់កាសីនោះ សំពត់បំសុកូលនោះ
តថាគតប្រាថ្នាក្រៃលែង ដូច្នេះ ។

កាលទ្រង់សម្ដែងសភាវៈរបស់ព្រះអង្គ ក្រៃលែងជាងលោកធម៌ទាំងឡាយ ទើបត្រាស់គាថា ៧ បទនេះ ដើម្បីទ្រង់សម្ដែងធម៌ដល់ព្រះរាជា ។

គាថានោះ មានអត្ថថា ឈ្មោះថា **ឯកំ** ព្រោះម្នាក់ឯងដោយគុណទាំង-ឡាយ ពោល គឺបព្វជ្ជាជាដើម ឈ្មោះថា **ចរន្តំ** ព្រោះត្រាច់ទៅដោយចរិយាទាំងឡាយ មានឥរិយាបថជាដើម ឈ្មោះថា **មុនិ** ព្រោះដល់ព្រមដោយមោនេយ្យធម៌ ឈ្មោះថា **អប្បមត្តំ** ព្រោះមិនមានសេចក្ដីប្រមាទ ក្នុងឋានៈ

ទាំងពួង ឈ្មោះថា **អវេជមានំ** ព្រោះមិនញាប់ញ័រដោយអំណាចនៃការមិនត្រេកអរ និងការត្រេកអរ ព្រោះនិន្ទា និងសរសើរទាំងនេះ គឺនិន្ទា មានការជេរ និងការនិន្ទាជាដើម និងការសរសើរ មានការសរសើរគុណជាដើម លោកធម៌ ៨ យ៉ាង គប្បីជ្រាបថា ត្រាស់ហើយក្នុងគាថានេះ ដោយមាននិន្ទា និងការសរសើរជាប្រធាន ។

ឈ្មោះថា **អសន្តសន្តំ** ព្រោះមិនចូលដល់ការខុសប្រក្រតី ព្រោះលោកធម៌ទាំង ៨ ឬព្រោះមិនមានការតក់ស្លុត ក្នុងសេនាសនៈស្ងាត់ ដូចរាជសីហ៍មិនតក់ស្លុតព្រោះសំឡេង មានសំឡេងស្គរជាដើម ឈ្មោះថា **អសជ្ជមានំ** ព្រោះមិនជាប់ក្នុងសំណាញ់ គឺតណ្ហា និងទិដ្ឋិ ដោយមគ្គទាំង ៤ ឬថា ឈ្មោះថា **អសជ្ជមានំ** ព្រោះមិនជាប់ជំពាក់ដោយការមិនត្រេកអរ និងការត្រេកអរក្នុងលោកធម៌ ៨ ដូចខ្យល់មិនជាប់ក្នុងសំណាញ់ មានសំណាញ់ដែលធ្វើដោយអំបោះជាដើម ឈ្មោះថា **អលិម្បមានំ** ព្រោះលះបានហើយនូវការជាប់ គឺតណ្ហា និងទិដ្ឋិដែលជាហេតុឲ្យសត្វទាំងឡាយជាប់នៅក្នុងលោក ដូចផ្កាឈូក សូម្បីកើតក្នុងទឹក តែមិនជាប់ក្នុងទឹក ឈ្មោះថា **នេតារំ** ព្រោះទ្រង់ជាអ្នកនាំដោយមគ្គនោះ ព្រោះញ៉ាំងមគ្គជាគ្រឿងឲ្យដល់និព្វានឲ្យកើតឡើងហើយ ឈ្មោះថា **នេតារំ អញ្ញេសំ** ព្រោះភាពដែលព្រះអង្គទ្រង់សម្តែងមគ្គដល់ទេវតា និងមនុស្សពួកដទៃ តែព្រះអង្គមិនមានបុគ្គលណាម្នាក់ ដែលគប្បីសម្តែងមគ្គនាំទៅបាន អ្នកប្រាជ្ញ រមែងប្រកាសបុគ្គលនោះ ថាជាមុនី ព្រះ

ដ៏មានព្រះភាគទ្រង់ប្រកាសព្រះអង្គឲ្យជាក់ច្បាស់ ដូចពណ៌នាមកនេះ ។ បទដ៏សេស ក្នុងគាថានេះ មានន័យដូចពោលហើយនោះឯង ។

គាថាថា **យោ ឱឃបាណោ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដឹងឯងដោយចំពោះ គ្រាដំបូងទ្រង់មានលាភសក្ការៈធំឲ្យប្រព្រឹត្តទៅហើយ ដែលមិនអាចប្រមាណបាន ព្រោះអាស្រ័យអភិនីហារគុណ មានបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ ដែលទ្រង់បំពេញអស់ ៤ អសង្ខេយ្យ និងមួយសែនកប្ប ព្រះគុណដែលទ្រង់បំពេញបារមីទាំងឡាយហើយ ទ្រង់កើតក្នុងតុសិតភព ព្រះគុណដែលទ្រង់ប្រថាប់ក្នុងតុសិតភពនោះ ព្រះមហាវិលោកនគុណ ការឈានចុះកាន់ព្រះគភ៌ ការនៅក្នុងព្រះគភ៌ ការយាងចេញចាកព្រះគភ៌ ការឈានព្រះបាទ ការសម្លឹងមើលទិស ការបន្លឺដូចព្រហ្ម ការចេញមហាភិនិស្ក្រមណ៍ មហាបធាន ការត្រាស់ដឹង ការប្រកាសធម្មចក្រ មគ្គញ្ញាណ ៤ ញាណដែលមិនកម្រើកក្នុងបរិញ្ញា ៨ ទសពលញ្ញាណ ញាណដែលកំណត់គតិ ៥ ពុទ្ធញ្ញាណ ១៤ គឺអសាធារណញ្ញាណ ៦ ពុទ្ធញ្ញាណដែលមិនទូទៅដល់សាវ័ក ៨ ញាណកំណត់ពុទ្ធគុណ ១៨ បច្ចវេក្ខណញ្ញាណ ១៩ ព្រះគុណរាប់សែន មានញាណវត្ថុ ៧៧ ជាដើម តិរ្ថិយទាំងឡាយមិនអត់ធន់ចំពោះលាភសក្ការៈ ដែលមិនមានប្រមាណនោះ ទើបប្រើចិញ្ចមាណវិកាឲ្យបង្កនូវការអាប់យសដល់ព្រះដ៏មានព្រះភាគ ក្នុងកណ្ដាលបរិស័ទ ៤ ដោយន័យដែលពោលហើយក្នុងគាថា

( ធម្មបទ ) នេះថា **ឯកំ ធម្មំ អតីតស្ស** ដូច្នេះ ភិក្ខុទាំងឡាយសន្ទនាគ្នា ព្រោះការអាប់យសនោះ ជាបច្ច័យថា ការអាប់យសឈ្មោះនេះ កើតឡើង ហើយដល់ព្រះដ៏មានព្រះភាគ ទ្រង់មិនមានព្រះហឫទ័យដទៃឡើយ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបរឿងនោះហើយ យាងចេញអំពីព្រះគន្ធកុដិ ដល់កណ្តាលបរិស័ទ ដោយបាដិហារ្យ ដែលសមគួរដល់ខណៈនោះ គង់លើពុទ្ធាសនៈ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ភិក្ខុទាំងនោះក្រាបទូលរឿងទាំងអស់ហើយ ។ បន្ទាប់អំពីនោះ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះពុទ្ធទាំងឡាយ ឈ្មោះថា ជាតាទិបុគ្គលក្នុងលោកធម៌ទាំង ៨ ដូច្នេះហើយ ត្រាស់គាថានេះ ដើម្បីប្រយោជន៍ដល់ការសម្តែងធម៌ដល់ភិក្ខុទាំងនោះ ។

គាថានោះ មានអត្ថថា ពួកត្រកូលខ្ពស់ក្តី ពួកត្រកូលទាបក្តី ត្រដុសខ្ទនត្រង់សសរ ៤ ជ្រុង ឬ ៨ ជ្រុង ដែលកប់ដើម្បីប្រយោជន៍ដល់ការដុសខ្ទនត្រង់កំពង់ទឹក គឺកំពង់សម្រាប់ជាទីងូតទឹករបស់មនុស្សទាំងឡាយ សសរនឹងស្រុតចុះ ឬផុសឡើងព្រោះការដុះខ្ទននោះមិនមាន យ៉ាងណា បុគ្គលណាមិនដល់នូវការត្រេកអរ ឬមិនត្រេកអរក្នុងរឿងដែលអ្នកដទៃពោលវាចា ដោយអំណាចការសរសើរ ឬការតិះដៀល ព្រោះភាពជាតាទិបុគ្គល ដូចសសរដែលមានត្រង់កំពង់ទឹកសម្រាប់ងូតក៏ដូច្នោះដូចគ្នា ។ សេចក្តីនេះ មានអធិប្បាយដូចម្តេច មានអធិប្បាយថា បុគ្គលដទៃ ទោះជាតិរ្ថិយ ឬពួកដទៃពោលវាចា

ខ្ពស់ដោយអំណាចការសរសើរ ឬវាចាទាបដោយអំណាចនៃការតិះដៀលជាទីបំផុតក្នុងរឿងណា បុគ្គលណាមិនដល់នូវការត្រេកអរ ឬមិនត្រេកអរក្នុងរឿងនោះ ដូចជាសសរដែលនៅត្រង់កំពង់ទឹក ជាទីចុះងូតទឹក ព្រោះភាពជាអ្នកមិនញាប់ញ័រ ដូច្នោះ ។

បទថា **តំ វីតរាគំ សុសមាហិតិន្ទ្រិយំ** សេចក្តីថា បុគ្គលនោះឈ្មោះជាប្រាសចាករាគៈ ព្រោះមិនមានរាគៈក្នុងឥដ្ឋារម្មណ៍ និងឈ្មោះថាមានឥន្ទ្រិយតាំងមាំល្អហើយ ព្រោះមិនមានទោសៈ និងមោហៈ ព្រោះអនិដ្ឋារម្មណ៍ ឬមានឥន្ទ្រិយតាំងមាំដោយល្អហើយ អធិប្បាយថា មានឥន្ទ្រិយរក្សាហើយ គឺមានឥន្ទ្រិយដែលគ្រប់គ្រងហើយ ។ ព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសព្រះអង្គថា អ្នកប្រាជ្ញ រមែងប្រកាសបុគ្គលនោះថាជាមុនី គឺរមែងប្រកាសថា ជាពុទ្ធមុនី ចិត្តរបស់ពុទ្ធមុនីនោះ និងជាប្រការដទៃយ៉ាងណាបាន ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

គាថាថា **យោ វេ ឋិតត្តោ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ធីតាសេដ្ឋីម្នាក់ក្នុងក្រុងសាវត្ថី ចុះអំពីប្រាសាទ ទៅកាន់រោងត្បាញសំពត់ក្នុងប្រាសាទខាងក្រោម ឃើញមនុស្សទាំងឡាយកំពុងស៊ិកខ្នារ កាន់យកនិមិត្តដែលប្រៀបដូចខ្នារនោះ ដោយភាពដែលខ្នារនោះជាធម្មជាតិត្រង់ថា ឱហ្ន៎ សត្វទាំងឡាយលះនូវការវៀចផ្លូវកាយ និងផ្លូវវាចា គប្បីជាអ្នកមានចិត្តត្រង់ដូចខ្នារ សូម្បីនាងឡើងកាន់ប្រាសាទហើយ ក៏អង្គុយគិតដល់

និមិត្តនោះរឿយៗ កាលនាងបដិបត្តិហើយយ៉ាងនេះ មិនយូរប៉ុន្មាន អនិច្ចលក្ខណៈក៏ប្រាកដ ទុក្ខលក្ខណៈ និងអនត្តលក្ខណៈ ក៏ប្រាកដដោយទំនងនោះដូចគ្នា ។

លំដាប់នោះ ភពទាំង ៣ ក៏ប្រាកដដល់នាងដូចត្រូវភ្លើងឆេះ ព្រះដ៏មានព្រះភាគ ទ្រង់ដឹងនាងដែលកំពុងឃើញច្បាស់យ៉ាងនោះ គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់បញ្ចេញរស្មី នាងឃើញរស្មីនោះ គិតថា នេះជាអ្វីហ្ន៎ ក៏ឃើញព្រះដ៏មានព្រះភាគហាក់ដូចគង់ក្បែរៗ ក្រោកឡើងឈរផ្គងអញ្ជលី ។ គ្រានោះព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា នាងមានសប្បាយ ទើបត្រាស់គាថានេះដោយអំណាចនៃព្រះធម្មទេសនា ។

គាថានោះ មានអត្ថថា បុគ្គលណាឈ្មោះថា **ឋិតត្តោ** ព្រោះមិនមានសេចក្តីចម្រើន និងសេចក្តីវិនាស ព្រោះជាអ្នកមានចិត្តជាឯកគ្គតា និងព្រោះភាពជាអ្នកមានវិមុត្តិមិនកម្រើក និងព្រោះមិនមានការចូលទៅកាន់រវាងភពព្រោះភាពជាអ្នកអស់នូវជាតិ និងសង្សារហើយ ឈ្មោះថា **តសរំវ ឧជ្ជុ** ព្រោះលះនូវការវៀចផ្លូវកាយ វាចា និងចិត្តបានហើយ ឬព្រោះមិនមានការលុះនូវអគតិ ឈ្មោះថា **ជិគុច្ឆតិ កម្មេហិ បាបកេហិ** គឺខ្ពើមនូវកម្មទាំងឡាយដែលជាបាប ដូចប្រឡាក់លាមក និងមូត្រដូច្នោះ ព្រោះភាពជាអ្នកដល់ព្រមដោយហិរិ និងឱត្តប្បៈ អធិប្បាយថា រមែងខ្មាស ពិតហើយ ការញែកប្រយោគតតិយាវិភត្តិ ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ រមែងប្រើបានក្នុងសព្ទសាស្ត្រ ។

បទថា **វិមំសមានោ វិសមំ សមញ្ច** សេចក្តីថា ពិចារណាឃើញ គឺពិចារណាកម្មដែលមិនស្មើ មានការមិនស្មើផ្លូវកាយជាដើម និងកម្មដែលស្មើ មានការស្មើផ្លូវកាយជាដើមដោយមគ្គប្បញ្ញា ដោយឲ្យសម្រេចបហានកិច្ច និងភាវនាកិច្ច អ្នកប្រាជ្ញរមែងប្រកាសបុគ្គលនោះ ដែលជាអ្នកអស់អាសវៈហើយជាជាមុនី ។ សេចក្តីនេះ មានអធិប្បាយដូចម្តេច មានអធិប្បាយថា បុគ្គលណាពិចារណាឃើញនូវកម្មទាំង ៤ ដែលមិនស្មើ និងស្មើ ដោយមគ្គប្បញ្ញាដោយន័យតាមដែលពោលហើយ ជាបុគ្គលដែលតម្កល់ខ្លួន បុគ្គលនោះ ជាអ្នកត្រង់ដូចខ្នារយ៉ាងនេះ មិនដល់នូវការកន្លងល្មើសណាមួយ ឈ្មោះថា ខ្ពើមនូវកម្មអាក្រក់ អ្នកប្រាជ្ញរមែងប្រកាសបុគ្គលនោះ ថាជាមុនី ព្រោះព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងមុនីដែលជាខីណាស្រពថា មានភាពដូច្នេះ ទើបត្រាស់គាថាដោយកំពូល គឺអរហត្ត ក្នុងទីបំផុតនៃទេសនា ធីតាសេដ្ឋីតាំងនៅក្នុងសោតាបត្តិផល អ្នកសិក្សាគប្បីឃើញអត្ថនៃ វា សព្ទ ក្នុងគាថានេះប្រើក្នុងវិកប្ប ឬសមុច្ចយៈ ។

បទថា **យោ សញ្ញតត្តោ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កាលព្រះដ៏មានព្រះភាគគង់នៅក្នុងក្រុងអាឡវី ជាងតម្បាញម្នាក់ក្នុងនគរអាឡវី ប្រើធីតាអាយុ ៧ ឆ្នាំថា នែនាង ម្សៀមិញ ខ្នារនៅសល់ នាងការអំបោះឲ្យគ្រប់គ្រាន់ហើយ គប្បីទៅកាន់រោងតម្បាញឲ្យឆាប់កុំយឺតយូរឡើយ ។ នាងទទួលពាក្យថា សាធុ ។ ជាងតម្បាញនោះ ទៅកាន់

រោងតម្បាញហើយ ឈរជ្រើសរើសសរសៃអំបោះ ។ ក្នុងថ្ងៃនោះ ព្រះដ៏មានព្រះភាគ ចេញអំពីមហាករុណាសមាបត្តិ ហើយត្រួតមើលលោក ទ្រង់ឃើញឧបនិស្ស័យនៃសោតាបត្តិផលរបស់ទារិកានោះ និងធម្មាភិសម័យរបស់សត្វ ៨៤០០០ ក្នុងកាលចប់ទេសនា ទ្រង់បដិបត្តិសរីរៈអំពីព្រលឹម ហើយកាន់បាត្រ និងចីវរយាងទៅកាន់ព្រះនគរ ។ មនុស្សទាំងឡាយឃើញព្រះដ៏មានព្រះភាគហើយ គិតថា ក្នុងថ្ងៃនេះ គប្បីមាននរណាដែលទ្រង់អនុគ្រោះពិត ទើបព្រះដ៏មានព្រះភាគយាងចូលទៅអំពីព្រលឹម ហើយនាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ ព្រះសាស្តាទ្រង់ឈរត្រង់ផ្លូវ ដែលទារិកាកំពុងទៅកាន់សម្នាក់របស់បិតា ។

អ្នកនគរទាំងឡាយបោសសម្អាតបទេសនោះ ពង្រាបផែនដី រោយនូវផ្កា ចងពិតាន ក្រាលអាសនៈ ព្រះដ៏មានព្រះភាគទ្រង់គង់លើអាសនៈ ដែលក្រាលហើយ ពួកមហាជនឈរចោមរោមហើយ ។ ទារិកានោះ ដល់បទេសនោះហើយ ឃើញព្រះដ៏មានព្រះភាគដែលមហាជនចោមរោមហើយ ថ្វាយបង្គំ ដោយបញ្ចង្គប្រតិស្ឋាន ព្រះដ៏មានព្រះភាគត្រាស់ហៅទារិកានោះមកហើយត្រាស់ថា នែទារិកា នាងមកអំពីណា ទារិកាតបថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់មិនដឹងឡើយ ព្រះសាស្តាត្រាស់ថា តើនាងទៅណា ទារិកាតបថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់មិនដឹងឡើយ ព្រះសាស្តាត្រាស់ថា នាងមិនដឹងទេឬ ទារិកាតបថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់ដឹង ព្រះសាស្តាត្រាស់ថា នាងដឹងឬ ទារិកា

តបថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់មិនដឹងឡើយ ។

មនុស្សទាំងឡាយស្តាប់ពាក្យនោះហើយ ក៏ពោលទោសថា មើលចុះអ្នកទាំងឡាយ ទារិកានេះមកអំពីផ្ទះរបស់ខ្លួន ត្រូវព្រះដ៏មានព្រះភាគត្រាស់សួរ ក៏ទូលថា ខ្ញុំម្ចាស់មិនដឹង កាលកំពុងទៅកាន់រោងតម្បាញក៏ទូលថា មិនដឹង ព្រះសាស្តាត្រាស់សួរថា នាងមិនដឹងឬ ក៏ទូលថាដឹង ព្រះសាស្តាត្រាស់សួរថា នាងដឹងឬ ក៏ទូលថាមិនដឹង រមែងធ្វើវាចាទាំងពួងឲ្យទាស់គ្នានោះឯង ។

ព្រះដ៏មានព្រះភាគ ទ្រង់បំណងធ្វើសេចក្តីនោះឲ្យប្រាកដដល់មនុស្សទាំងឡាយ ទើបត្រាស់ថា តថាគតសួរដូចម្តេច នាងឆ្លើយដូចម្តេច នាងក្រាបទូលព្រះដ៏មានព្រះភាគអង្គនោះថា បពិត្រព្រះដ៏មានព្រះភាគ បុគ្គលណាម្នាក់មិនដឹងខ្ញុំម្ចាស់ថាមកអំពីផ្ទះ ទៅកាន់រោងតម្បាញក៏មិនមែន ដោយពិត ទ្រង់ត្រាស់សួរខ្ញុំម្ចាស់ដោយអំណាចបដិសន្ធិថា នាងមកអំពីណា ត្រាស់សួរដោយអំណាចចុតិថា នាងនឹងទៅណា ខ្ញុំម្ចាស់មិនដឹងថាមកអំពីណា មកអំពីនរក ឬមកអំពីទេវលោក ព្រោះខ្ញុំម្ចាស់មិនដឹងថា នឹងទៅទីណា ទៅនរក ឬទេវលោក ព្រោះដូច្នេះ ទើបខ្ញុំម្ចាស់ទូលថា មិនដឹង បន្ទាប់អំពីនោះ ព្រះដ៏មានព្រះភាគ ទ្រង់សំដៅដល់មរណៈ ទើបត្រាស់សួរខ្ញុំម្ចាស់ថា មិនដឹងឬ ខ្ញុំម្ចាស់ដឹងថា សត្វទាំងឡាយត្រូវស្លាប់ពិត ដោយហេតុនោះ ទើបទូលថា ដឹង បន្ទាប់អំពីនោះ ទ្រង់សួរដល់កាលមរណៈ ទើបត្រាស់សួរខ្ញុំម្ចាស់ថា នាងដឹងឬ ខ្ញុំម្ចាស់មិនដឹងថា នឹងស្លាប់ក្នុងកាលណា ថ្ងៃនេះ ឬថ្ងៃស្អែក ដោយហេតុ

នោះ ទើបទូលថា មិនដឹងដូច្នេះ ។

ព្រះដ៏មានព្រះភាគ ទ្រង់អនុមោទនាបញ្ហាដែលទារិកានោះវិសជ្ជនាហើយថា សាធុ សាធុ ។ ចំណែកពួកមហាជន បានឲ្យសាធុការមួយពាន់ដងថា ទារិកានេះជាបណ្ឌិត ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា ទារិកាមានសប្បាយ កាលទ្រង់សម្តែងព្រះធម៌ ទើបត្រាស់គាថានេះថា

លោកិយមហាជននេះ ជាមនុស្សងងឹត បណ្តាជនទាំងនេះ ជនតិចគ្នា ដែលឃើញច្បាស់ ( នូវខន្ធាទិលោកនេះ ដោយអំណាចអនិច្ចលក្ខណៈជាដើម ) ជនតិចគ្នា ដែលទៅកាន់ស្ថានសួគ៌ ដូចសត្វស្លាប ( ដែលជាប់សំណាញ់របស់ព្រានហើយ ) តិចណាស់ ដែលរួចអំពីសំណាញ់ ដូច្នោះ ។

ក្នុងកាលចប់គាថា ទារិកានោះតាំងនៅក្នុងសោតាបត្តិផល សត្វ ៨ ម៉ឺន ៤ ពាន់ បានលុះក្នុងធម្មាភិសម័យ ។

ទារិកានោះ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ទៅកាន់សម្នាក់បិតាៗ ឃើញនាងក៏ក្រោធថា ហេតុអ្វីមកយឺត ទើបដាក់ខ្នារយ៉ាងខ្លាំង ខ្នារហោះទៅទម្លុះពោះរបស់ទារិកា ទារិកាធ្វើកាលកិរិយាក្នុងទីនោះឯង ។ បុរសនោះឃើញហើយពិចារណាថា អញមិនបានប្រហារធីតារបស់អញដោយពិត ខ្នារខ្ទាតមកដោយកម្លាំង ទម្លុះពោះរបស់ធីតានេះ នាងនៅរស់ឬហ្ន៎ ដឹងថា កូនស្លាប់ហើយ គិតថា មនុស្សទាំងឡាយ ដឹងថា អញសម្លាប់ធីតា គប្បី

ពោលទោស ដោយហេតុនោះ ព្រះរាជាក៏គប្បីដាក់អាជ្ញាយ៉ាងធ្ងន់ ណ្ហើយចុះអញទឹងរត់ទៅមុន ។

បុរសនោះរត់គេចទៅព្រោះខ្លាចអាជ្ញា ដល់ឱកាសដែលជាលំនៅរបស់ភិក្ខុទាំងឡាយ ដែលរៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះដ៏មានព្រះភាគ ហើយនៅព្រៃ ។ បុរសនោះចូលទៅរកភិក្ខុទាំងនោះ ថ្វាយបង្គំហើយសូមបព្វជ្ជា ភិក្ខុទាំងនោះឲ្យបុរសនោះបួសហើយ ឲ្យនូវតចបញ្ចកកម្មដ្ឋាន ដែលមានស្បែកជាទីបំផុត លោករៀនកម្មដ្ឋាននោះ ប្រារព្ធសេចក្ដីព្យាយាម មិនយូរប៉ុន្មានក៏សម្រេចអរហត្ត ភិក្ខុទាំងនោះ ជាអាចារ្យ និងជាឧបជ្ឈាយ៍របស់លោក ។ លំដាប់នោះ ក្នុងថ្ងៃមហាបវារណា ភិក្ខុទាំងអស់នោះឯង បានទៅកាន់សម្នាក់របស់ព្រះដ៏មានព្រះភាគ ដោយគិតថា នឹងបវារណាដោយវិសុទ្ធិបវារណា ។

ព្រះដ៏មានព្រះភាគ កាលទ្រង់បវារណាចេញវស្សាហើយ មានភិក្ខុសង្ឃចោមរោម ចារិកទៅកាន់គាម និងនិគមជាដើម យាងទៅកាន់ក្រុងអាឡវីដោយលំដាប់ មនុស្សទាំងឡាយក្នុងដែនអាឡវីនោះ និមន្តព្រះដ៏មានព្រះភាគហើយ ធ្វើទានទាំងឡាយ ឃើញភិក្ខុនោះហើយនាំគ្នាបៀតបៀនថា លោកសម្លាប់កូនស្រីហើយ ឥឡូវនេះ មកដើម្បីសម្លាប់អ្នកណា ដូច្នេះជាដើម ភិក្ខុទាំងឡាយបានស្ដាប់ដូច្នោះហើយ ដល់ពេលបម្រើ ចូលទៅគាល់ព្រះដ៏មានព្រះភាគហើយ ទូលរឿងនោះដល់ព្រះដ៏មានព្រះភាគៗ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះមិនបានសម្លាប់ធីតាៗ នោះស្លាប់ តាមកម្មរបស់ខ្លួន កាល

ទ្រង់ប្រកាសភាពដែលភិក្ខុនោះជាមុនីទីណាសវៈ ដែលមនុស្សទាំងឡាយដឹងបានដោយលំបាក ទើបត្រាស់គាថានេះ ដើម្បីសម្តែងធម៌ដល់ភិក្ខុទាំងឡាយ ។

គាថានោះមានសេចក្តីថា បុគ្គលណាសង្រួមខ្លួនដោយការសង្រួមសីលក្នុងកម្មទ្វារទាំង ៣ រមែងមិនធ្វើបាប មានការបៀតបៀនជាដើមដោយកាយ ឬដោយវាចា ឬដោយចិត្ត ជាកំលោះ គឺតាំងនៅក្នុងវ័យក្មេង ឬជាបុគ្គលកណ្តាល គឺតាំងនៅក្នុងវ័យកណ្តាល ជាព្រះថេរៈតាំងនៅក្នុងបច្ឆិមវ័យដោយន័យនោះឯង មិនធ្វើនូវបាបនោះក្នុងកាលណាមួយ ព្រោះហេតុអ្វី ព្រោះមានខ្លួនសង្រួមហើយ អធិប្បាយថា ព្រោះមានចិត្តឆ្ងាយចាកបាបទាំងពួង ដោយវិរតិដ៏កំពូល ។

ឥឡូវនេះ គប្បីជ្រាបយោជនា និងអធិប្បាយនៃបទទាំងនេះថា **មុនិ អរោសនេយ្យោ ន សោ រោសេតិ កិញ្ចិ** ដូច្នេះ ។

បុគ្គលនោះជាមុនីទីណាស្រេព មិនក្រោធឆាយ គឺជាបុគ្គលមិនគួរប្រទូស្តគឺទ្រគោះ បៀតបៀនដោយកាយ ឬដោយវាចា ដោយន័យយ៉ាងនេះថា អ្នកសម្លាប់កូនស្រី ឬថា ជាជាងតម្បាញ ព្រោះលោកមិនប្រទូស្តដល់បុគ្គលណាមួយ គឺមិនពោលអាក្រក់ណាមួយ មិនទ្រគោះ មិនបៀតបៀនថា យើងមិនបានសម្លាប់ធីតារបស់យើង អ្នកសម្លាប់ ឬអ្នកដូចគ្នានឹងអ្នកសម្លាប់ជាដើម ព្រោះដូច្នោះ បុគ្គលនោះ បុគ្គលមិនគប្បីប្រទូស្តដោយពិត ជាបុគ្គលដែលបុគ្គលគប្បីសំពះនោះឯង ដោយន័យដែលពោលហើយថា ចូរឈប់ចុះនាគ

ចូរឈប់ចុះនាគ ចូរទមស្គារដល់នាគ ដូច្នេះ ។ នាគទុកឲ្យនៅចុះ អ្នកកុំបៀតបៀននាគឡើយ ចូរអ្នកថ្វាយបង្គំនាគចុះ ។

ក្នុងបាទគាថាថា **តំ វាបិ ធីរា មុនិ វេទយន្តិ** នេះ គប្បីជ្រាបការចែកបទយ៉ាងនេះថា អ្នកប្រាជ្ញប៉ុណ្ណោះរមែងប្រកាសបុគ្គលនោះថាជាមុនី ក្នុងបាទគាថានោះមានអធិប្បាយថា បុគ្គលពាលទាំងនោះមិនដឹងបុគ្គលនោះថា បុគ្គលនេះមិនគួរប្រទូស្តដូច្នេះ រមែងប្រទូស្ត ចំណែកមនុស្សពួកណាជាអ្នកប្រាជ្ញ មនុស្សដែលជាអ្នកប្រាជ្ញទាំងនោះឯង រមែងប្រកាសបុគ្គលនោះថាជាមុនី គឺរមែងដឹងថា បុគ្គលនេះជាមុនីខីណាស្រព ដូច្នេះ ។

គាថាថា **យទគ្គតោ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងក្រុងសាវត្ថីមានព្រាហ្មណ៍ម្នាក់ ឈ្មោះបញ្ចគ្គទាយក កាលសម្ទួងទាំងឡាយសម្រេច រមែងឲ្យទានដ៏ប្រសើរ ៥ ប្រការ គឺខេត្តគ្គទាន ១ រាសគ្គទាន ១ កោដ្ឋគ្គទាន ១ កុម្ភិអគ្គទាន ១ ភោជនគ្គទាន ១ ។ ក្នុងអគ្គទាន ៥ យ៉ាងនោះ ព្រាហ្មណ៍ជាអ្នកឃើញយ៉ាងនេះថា បុគ្គលមានបញ្ញាណា ឲ្យនាំមកនូវកួរស្រូវសាលី ស្រូវជំណើប ស្រងែដែលទុំ ព្រាហ្មណ៍រៀបចំបបរ បាយាស អំបុកជាដើម ឲ្យអគ្គទាន បុគ្គលនោះរមែងបាននូវផលដ៏ប្រសើរ ហើយឲ្យទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន នេះឈ្មោះថា ខេត្តគ្គទានរបស់ព្រាហ្មណ៍នោះ ។

កាលស្រូវទាំងឡាយសម្រេចហើយ ប្រូតហើយ បែនហើយ កាន់យក

ធញ្ញៈដ៏ប្រសើរឲ្យទានយ៉ាងនោះឯង ឈ្មោះថាកសគ្គទានរបស់ព្រាហ្មណ៍នោះ ។

ព្រាហ្មណ៍ញុំាងជង្រុកទាំងឡាយឲ្យពេញដោយធញ្ញជាតិទាំងនោះ កាន់យកធញ្ញៈទាំងឡាយ ដែលនាំចេញលើកទីមួយ ក្នុងការបើកជង្រុកហើយឲ្យទានយ៉ាងនោះឯង ឈ្មោះថា កោដ្ឋគ្គទានរបស់ព្រាហ្មណ៍នោះ ។

កត្តណាមួយចម្អិនក្នុងផ្ទះរបស់ព្រាហ្មណ៍នោះ ព្រាហ្មណ៍មិនទាន់ឲ្យកត្តដ៏ប្រសើរអំពីកត្តនោះដល់បព្វជិតដែលមកដល់ហើយ ដោយហោចសូម្បីក្មេងទាំងឡាយ ក៏មិនបរិភោគឡើយ នេះឈ្មោះថា កុម្ភិអគ្គទាន ។

ក្នុងកាលបរិភោគរបស់ខ្លួន ព្រាហ្មណ៍មិនឲ្យកត្ត ដែលមនុស្សបង្អោនមកគ្រាដំបូងដល់សង្ឃ ក្នុងកាលមុនកត្ត ឬឲ្យដល់យាចកដែលមកដល់ក្នុងកាលក្រោយកត្ត ព្រោះមិនមានសង្ឃជាដើមនោះ ដោយហោចមិនឲ្យហើយដល់ក្មេងទាំងឡាយ ក៏មិនបរិភោគ នេះឈ្មោះថា ភោជនគ្គទានរបស់ព្រាហ្មណ៍នោះ ។ ទើបព្រាហ្មណ៍នោះត្រូវកំណត់ថា បញ្ចគ្គទាយក យ៉ាងនេះឯង ។

ថ្ងៃមួយ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលលោកដោយពុទ្ធចក្ខុ ក្នុងសម័យទៀបភ្លឺ ទ្រង់ឃើញឧបនិស្ស័យនៃសោតាបត្តិមគ្គរបស់ព្រាហ្មណ៍នោះនិងព្រាហ្មណី ទ្រង់បដិបត្តិសរីរៈ យាងចូលព្រះគន្ធកុដិអំពីព្រលឹម ភិក្ខុទាំង-ឡាយឃើញព្រះគន្ធកុដិបិទក៏ដឹងថា ថ្ងៃនេះព្រះដ៏មានព្រះភាគមានបំណងយាងទៅកាន់ស្រុកតែមួយព្រះអង្គឯង ក្នុងពេលភិក្ខាចារ ធ្វើប្រទក្សិណព្រះគន្ធកុដិចូលទៅដើម្បីបិណ្ឌបាត ចំណែកព្រះដ៏មានព្រះភាគ ក្នុងពេលព្រាហ្មណ៍

បរិភោគ យាងចេញអំពីព្រះគន្ធកុដិ ចូលទៅកាន់ក្រុងសាវត្ថី មនុស្សទាំង-ឡាយឃើញព្រះដ៏មានព្រះភាគប៉ុណ្ណោះ ក៏ដឹងថា ព្រះដ៏មានព្រះភាគ ទ្រង់អនុគ្រោះសត្វណាមួយដោយពិតប្រាកដ ដោយហេតុនោះ ព្រះដ៏មានព្រះភាគ យាងចូលទៅមួយព្រះអង្គឯង ទើបមិនចូលគាល់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ដល់ការនិមន្ត ។ សូម្បីព្រះដ៏មានព្រះភាគ ក៏យាងដល់ទ្វារផ្ទះរបស់ព្រាហ្មណ៍ដោយលំដាប់ ប្រថាប់ឈរ ។

សម័យនោះ ព្រាហ្មណ៍អង្គុយបរិភោគភោជន ចំណែកព្រាហ្មណីរបស់ព្រាហ្មណ៍នោះឈរបក់ផ្លិត នាងឃើញព្រះដ៏មានព្រះភាគគិតថា បើព្រាហ្មណ៍នេះឃើញសោត ក៏គប្បីទទួលបាត្រ ថ្វាយភោជនទាំងអស់ អញនឹងពិបាកដាំភោជនសាថ្មី ក៏កើតការមិនជ្រះថ្លា និងសេចក្តីកំណាញ់ ទើបយកផ្លិតស្លឹកត្នោតមកបាំង មិនឲ្យព្រាហ្មណ៍មើលឃើញព្រះដ៏មានព្រះភាគៗ ដឹងហេតុនោះ ទើបបញ្ចេញរស្មីអំពីព្រះសរីរៈ ព្រាហ្មណ៍ឃើញពន្លឺពណ៌មាសហើយ កំណត់ថា នេះអ្វីហ្ន៎ បានឃើញព្រះដ៏មានព្រះភាគប្រថាប់ឈរត្រង់ទ្វារ ចំណែកព្រាហ្មណីគិតថា ព្រះដ៏មានព្រះភាគ ព្រាហ្មណ៍នោះឃើញហើយ ទើបដាក់ផ្លិតស្លឹកត្នោតចុះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ព្រះដ៏មានព្រះភាគទ្រង់ដឹងធម៌ដែលជាសប្បាយរបស់ព្រាហ្មណីនោះ ដែលថ្វាយបង្គំហើយ កំពុងឈរ ទើបត្រាស់គាថានេះថា

បុគ្គលណា មិនមានសេចក្តីប្រកាន់ក្នុងនាម និងរូបថាជារបស់អញ

ដោយប្រការទាំងពួង មួយទៀត បុគ្គលណាមិនសោកស្តាយ ព្រោះនាម និងរូបដែលមិនមាន បុគ្គលនោះឯង តថាគត ហៅថា ភិក្ខុ ដូច្នេះ ។

ក្នុងពេលចប់គាថានោះ នាងក៏បានតាំងនៅក្នុងសោតាបត្តិផល ចំណែកព្រាហ្មណ៍ទូលនិមន្តព្រះដ៏មានព្រះភាគ ឲ្យចូលទៅខាងក្នុងផ្ទះ និមន្តឲ្យគង់លើអាសនៈ ថ្វាយទក្ខិណោទក ថ្វាយភោជនដែលគេរៀបចំដើម្បីខ្លួនថា បពិត្រព្រះអង្គ ទ្រង់ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរក្នុងលោក ព្រមទាំងទេវលោក សូមទ្រង់ទទួលភោជននោះរបស់ខ្ញុំព្រះអង្គ ដែលប្រតិស្ឋានក្នុងបាត្ររបស់ទ្រង់ចុះ ព្រះដ៏មានព្រះភាគទ្រង់ទទួលសោយហើយ ដើម្បីអនុគ្រោះដល់ព្រាហ្មណ៍នោះ ទ្រង់ធ្វើកត្តកិច្ចស្រេចហើយ ទ្រង់ដឹងធម៌ដែលជាសប្បាយរបស់ព្រាហ្មណ៍ ទើបត្រាស់គាថានេះ ។

គាថានោះមានអត្ថថា បុគ្គលណាបាននូវដុំបាយ អំពីចំណែកដ៏ប្រសើរ ព្រោះជាដុំបាយដែលដួសមកអំពីឆ្នាំងនោះឯង អំពីចំណែកកណ្តាល ព្រោះជាដុំបាយដែលដួសមកអំពីឆ្នាំង ដែលសល់ពាក់កណ្តាលហើយ កាន់យកអំពីចំណែកដែលសល់នោះ ឬអំពីចំណែកដែលសល់ ព្រោះជាដុំបាយដែលដួសមកអំពីឆ្នាំងដែលសល់ប្រមាណមួយវែក ឬពីរវែក ហើយកាន់យកអំពីចំណែកដែលសល់នោះ ។

បទថា **បរទត្តូបជីវី** បានដល់ បព្វជិត ពិតហើយ បព្វជិតនោះ រៀរ

ទឹក និងឈើស្ងួនហើយ រមែងចូលទៅអាស្រ័យអាហារដែលសល់ដែលអ្នកដទៃឲ្យ ដើម្បីរស់នៅ ព្រោះដូច្នោះ ទើបហៅថា **បរទត្តូបជីវី** ។

បទថា **នាលំ ថុតុំ នាបិ និបច្ចវាទី** សេចក្ដីថា បានដុំបាយអំពីចំណែកដែលល្អក្ដី មិនអាចពោលសរសើរខ្លួន ឬទាយក ព្រោះភាពជាអ្នកលះសេចក្ដីត្រេកអរហើយ បានអំពីចំណែកដែលសល់ ក៏មិនគួរធ្វើឲ្យទាយកថោកថយ ហើយពោលពាក្យដែលមិនជាទីស្រឡាញ់ទាំងឡាយ ដោយន័យជាដើមថា ទាយកនេះឲ្យដុំបាយអ្វីដូច្នេះ ព្រោះជាបុគ្គលលះនូវការប្រទូស្តបានហើយ ។

បទថា **តំ វាបិ ធីរា មុនិ វេទយន្តិ** បានដល់ អ្នកប្រាជ្ញប៉ុណ្ណោះ រមែងប្រកាសបុគ្គលនោះដែលលះនូវការត្រេកអរ និងការមិនត្រេកអរបានហើយថាជាមុនី ព្រះដ៏មានព្រះភាគទ្រង់សម្ដែងគាថាដោយកំពូល គឺអរហត្តដល់ព្រាហ្មណ៍ ដោយប្រការដូច្នេះ ក្នុងពេលចប់គាថា ព្រាហ្មណ៍តាំងនៅក្នុងសោតាបត្តិផល ។

គាថាថា **មុនឹ ចរន្តំ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា សេដ្ឋីបុត្រម្នាក់ក្នុងក្រុងសាវត្ថី ទំនុកបម្រុងដោយសម្បត្តិទាំងពួង នៅក្នុងប្រាសាទ ៣ ដោយអំណាចនៃរដូវ ជាកំលោះ បំណងនឹងបួសបន្ទាប់អំពីនោះ ទើបអង្វរមាតាបិតា ហើយបួសសឹកៗ អស់វារៈ ៣ ដង លើកទី ៤ ក៏សម្រេចអរហត្តដោយន័យដែលពោលហើយ ក្នុងឧប្បត្តុប្បត្តិហេតុនៃ

រឿងក្នុងគាថានេះថា **កាមា ហិ ចិត្រា** ក្នុងខគ្គវិសាណសូត្រ ភិក្ខុទាំងឡាយពោលនឹងភិក្ខុនោះតាមការស្និទ្ធស្នាលក្នុងកាលមុនថា អាវុសោ ដល់សម័យដើម្បីសឹកហើយឬ ភិក្ខុនោះពោលថា អាវុសោ ឥឡូវនេះ ខ្ញុំមិនគួរសឹកឡើយ ភិក្ខុទាំងឡាយស្តាប់ដូច្នោះហើយ ទើបទូលដល់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពិតដូច្នោះឯង ឥឡូវនេះបុត្តតថាគតមិនគួរសឹកទេ កាលធ្វើភាពដែលភិក្ខុនោះជាមុនីទីណាស្រេចឲ្យជាក់ច្បាស់ ទើបត្រាស់គាថានេះ ។

គាថានោះមានអត្ថថា ឈ្មោះថា **មុនី** ព្រោះដល់ព្រមដោយមោនេយ្យ-ធម៌ ឈ្មោះថា **ចរន្តំ** ព្រោះត្រាច់ទៅដោយភាពជាបុគ្គលម្នាក់ឯង ឬដោយចរិយាចំណែកខ្លះ ក្នុងចរិយាទាំងឡាយមានប្រការដូចពោលហើយខាងដើម ឈ្មោះថា **វិរតំ មេថុនស្មា** ដោយវិរតិដ៏កំពូល ព្រោះមិនដាក់ចិត្តក្នុងមេថុន-ធម្មដូចក្នុងកាលមុន ។

ការសម្ពន្ធនៃបាទទី ២ បើមានពាក្យសួរថា មុនីត្រាច់ទៅប្រាសចាកការត្រេកអរក្នុងមេថុនដូចម្តេច ឆ្លើយថា បុគ្គលណាមិនជាប់ជ្រប់ក្នុងរូបនៃស្រីណាម្នាក់ដែលកំពុងនៅក្មេង គឺបុគ្គលណា មិនវង្វេងក្នុងរូបនៃស្រី ដែលវ័យក្មេងស្អាត កំពុងប្រព្រឹត្តទៅដោយមេថុនរាគៈ ដូចក្នុងកាលមុន ។

ម្យ៉ាងទៀត ក្នុងគាថានេះ មានអត្ថយ៉ាងនេះថា បុគ្គលណាមិនជាប់ជ្រប់ដោយរាគៈ ក្នុងការនៅក្មេងរបស់ខ្លួន ឬរបស់អ្នកដទៃណាម្នាក់យ៉ាងនេះថា

អាត្មាអញទៅកំលោះ ឬស្រីនេះទៅក្រមុំ អញនឹងសេពកាមសិន វៀរចាកសេចក្តីត្រេកអរក្នុងមេថុនតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន ដោយពិត វៀរហើយចាកការស្រវឹង មានការស្រវឹងព្រោះជាតិជាដើម និងវៀរចាកសេចក្តីប្រមាទ ពោល គឺការបណ្តោយសតិក្នុងកាមគុណ ៥ ព្រោះភាពជាអ្នកវៀរហើយចាកការស្រវឹង និងការប្រមាទ នឹងរួចផុតចាកគ្រឿងចង គឺកិលេសទាំងពួងយ៉ាងនេះ ។

បុគ្គលណាម្នាក់ជាអ្នកវៀរហើយដោយវិរតិ សូម្បីជាលោកិយយ៉ាងណា បុគ្គលនេះមិនមែនដូច្នេះឡើយ រួចផុតហើយ វៀរហើយដូចម្តេច អធិប្បាយថា វៀរហើយដោយវិរតិដែលជាលោកុត្តរ ព្រោះភាពដែលភិក្ខុនេះ ជាអ្នករួចផុតហើយចាកគ្រឿងចង គឺកិលេសទាំងពួង ។ បទថា **តំ វាបិ ធីរា** សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់សម្តែងថា អ្នកប្រាជ្ញប៉ុណ្ណោះរមែងប្រកាសបុគ្គលនោះថាជាមុនី អ្នកទាំងឡាយមិនគប្បីពោលភិក្ខុនោះ ដោយហេតុនោះ អ្នកទាំងឡាយ ចូរពោលភិក្ខុនោះ ថាជាមុនីយ៉ាងនេះឯង ។

គាថាថា **អញ្ញាយ លោកំ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគគង់នៅក្នុងនគរកបិលពស្តុ សម័យនោះឯង ព្រះញាតិទាំងឡាយបានធ្វើមង្គល ៣ ប្រការ គឺអាភរណមង្គល ១ អភិសេកមង្គល ១ អាវាហមង្គល ១ ដល់នន្ទរាជកុមារ ។ ព្រះដ៏មានព្រះភាគ ទ្រង់ក៏ត្រូវគេនិមន្តចូលរួមក្នុងមង្គលនោះ យាងដល់ទីមង្គល មួយអន្លើដោយភិក្ខុ ៥០០

សោយព្រះក្រយាស្រេចហើយ យាងចេញទៅ ទ្រង់ប្រទានបាត្រក្នុងដៃរបស់នន្ទកុមារ ព្រះនាងជនបទកល្យាណី ឃើញនន្ទរាជកុមារយាងចេញទៅ ទើបត្រាស់ថា សូមអយ្យបុត្រប្រញាប់ត្រឡប់មក នន្ទរាជកុមារនោះ កាលមិនអាចទូលថា សូមព្រះដ៏មានព្រះភាគទ្រង់ទទួលបាត្រចុះ ដោយគោរពក្នុងព្រះអង្គ ក៏យាងទៅកាន់វិហារនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ឈរត្រង់បរិវេណព្រះគន្ធកុដិត្រាស់ថា ម្នាលនន្ទ ចូរនាំបាត្រមក កាលទទួលហើយក៏ត្រាស់ថា នន្ទ បួសឬ ព្រះរាជកុមារកាលមិនអាចបដិសេធ ដោយសេចក្ដីគោរពចំពោះព្រះដ៏មានព្រះភាគ ក៏ទូលថា ខ្ញុំព្រះអង្គបួស ព្រះដ៏មានព្រះភាគទ្រង់ឲ្យនន្ទ-រាជកុមារបួសហើយ ។

នន្ទនោះរពូកដល់វាចារបស់ជនបទកល្យាណីរឿយៗ ក៏អផ្សុក ភិក្ខុទាំងឡាយទូលរឿងនោះដល់ព្រះដ៏មានព្រះភាគ ព្រះអង្គមានបំណងនឹងកម្ចាត់នូវការមិនត្រេកអររបស់ព្រះនន្ទ ទើបត្រាស់ថា ម្នាលនន្ទ អ្នកធ្លាប់ទៅកាន់ស្ថានសួគ៌ជាន់តាវត្តិង្សដែរឬទេ ព្រះនន្ទទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនធ្លាប់ទៅឡើយ ។ បន្ទាប់អំពីនោះ ព្រះដ៏មានព្រះភាគ ទ្រង់ក៏នាំនន្ទភិក្ខុនោះទៅកាន់ស្ថានសួគ៌ជាន់តាវត្តិង្សដោយអានុភាពរបស់ព្រះអង្គ ហើយប្រថាប់ឈរត្រង់ទ្វារវេជយន្តប្រាសាទ សក្កទេវរាជទ្រង់ជ្រាបការយាងមករបស់ព្រះដ៏មានព្រះភាគ ដែលពួកទេពអប្សរចោមរោមហើយ ទ្រង់ចុះអំពីប្រាសាទស្រីទេពអប្សរទាំងនោះ ក៏ធ្លាប់ប្រគេនប្រេងលាបជើងដល់សាវ័កទាំងឡាយ

របស់ព្រះដ៏មានព្រះភាគព្រះនាមកស្សបៈ ជាអ្នកមានជើងពណ៌ដូចជើងព្រាប ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ត្រាស់ហៅនន្ទភិក្ខុថា ម្នាលនន្ទ អ្នកឃើញទេពអប្សរ ៥០០ ដែលមានជើងពណ៌ដូចជើងព្រាបទាំងនេះដែរឬទេ អ្នកសិក្សាគប្បីធ្វើរឿងនេះឲ្យពិស្តារ ។ ពាក្យថា និមិត្ត និងអនុព្យញ្ជនៈរបស់មាតុគ្រាមដែលបុគ្គលគប្បីកាន់យកនោះ មិនមានក្នុងពុទ្ធវចនៈទាំងអស់ តែក្នុងទីនេះ ព្រះដ៏មានព្រះភាគទ្រង់បំណាំងនឹងទម្លាយរាគៈរបស់នន្ទភិក្ខុ ដូចគ្រូពេទ្យបំណាំងនឹងកម្ចាត់ទោសរបស់អ្នកក្តៅក្រហាយដូច្នោះ ព្រោះទ្រង់ឈ្លាសក្នុងឧបាយកោសល ទើបទ្រង់អនុញ្ញាតឲ្យព្រះនន្ទនោះកាន់យកនិមិត្ត និងអនុ-ព្យញ្ជនៈ ដូចសារថីទូន្មាននូវបុរសដ៏កំពូល ដូច្នោះ បន្ទាប់អំពីនោះ ព្រះដ៏មានព្រះភាគទ្រង់ដឹងថា នន្ទភិក្ខុត្រេកអរក្រៃលែងក្នុងព្រហ្មចរិយៈ ព្រោះហេតុនៃស្រីទេពអប្សរ ទ្រង់ត្រាស់ប្រាប់ភិក្ខុទាំងឡាយថា ចូរដាស់តឿននន្ទដោយវាទៈថា កូនឈ្នួល ។ នន្ទនោះ កាលភិក្ខុទាំងនោះដាស់តឿន កើតនូវការខ្មាសហើយ មនសិការដោយឧបាយបដិបត្តិហើយ មិនយូរប៉ុន្មាន ក៏ធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ទេវតាដែលអាស្រ័យនៅត្រង់ដើមឈើ ក្បែរទីបំផុតនៃទីចង្រ្កមរបស់នន្ទភិក្ខុនោះ បានទូលរឿងនោះដល់ព្រះដ៏មានព្រះភាគ ញាណក៏បានកើតឡើងដល់ព្រះដ៏មានព្រះភាគ ភិក្ខុទាំងឡាយ កាលមិនដឹងក៏នៅតែដាស់តឿននន្ទភិក្ខុយ៉ាងនោះឯង ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ឥឡូវនេះ ពួកអ្នកមិនគប្បីដាស់តឿននន្ទយ៉ាងនោះទៀតឡើយ កាល

ទ្រង់សម្តែងភាពដែលនទួភិក្ខុនោះ ជាមុទីទីណាស្រេព ទើបត្រាស់គាថានេះ ដើម្បីសម្តែងធម៌ដល់ភិក្ខុទាំងនោះ ។

គាថានោះមានអត្ថថា បុគ្គលស្គាល់ គឺដឹងហើយ កំណត់ហើយនូវលោក មានខន្ធលោកជាដើម ដោយការកំណត់ទុក្ខសច្ច ឃើញបរមត្ថប្រយោជន៍ ដោយការធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ឆ្លងផុត គឺឈានកន្លងនូវឱឃៈ ៤ យ៉ាងដោយការលះសមុទយៈ និងឆ្លងផុតសមុទ្ទ គឺអាយតនៈ មានចក្ខុជាដើម ដោយការអត់ធន់ចំពោះកម្លាំង នៃការស្រេវឹងក្នុងរូបជាដើម ព្រោះជាបុគ្គល លះនូវសមុទយៈបានហើយ ជាបុគ្គលនឹងធឹង ដោយការដល់នូវលក្ខណៈ ជាតាទិបុគ្គលនេះថា ជាអ្នកនឹងធឹង ព្រោះមានគុណលក្ខណៈនោះ ដោយមគ្គភាវនា ។

អ្នកសិក្សាជ្រាបអត្ថ និងអធិប្បាយក្នុងគាថានេះយ៉ាងនេះថា គំនរនៃកិលេស មានកាមរាគៈជាដើមនោះឯង នេះឈ្មោះថា **ឱឃំ** ព្រោះអត្ថថា ហូរទៅ ឈ្មោះថា **សមុទ្ទំ** ព្រោះអត្ថថាផ្សាយឡើង ដោយបរិយាយនៃគតិដែលគួរខ្ពើម ឆ្លងផុតគំនរកិលេសនោះ គឺឱឃៈ និងសមុទ្ទដោយលះសមុទយៈ ព្រោះភាពជាបុគ្គលឆ្លងផុតឱឃៈបានហើយ ឈ្មោះថា **តាទី** ព្រោះភាពជាអ្នកមិនដល់នូវការខុសប្រក្រតីក្នុងវាចា ដែលអ្នកទាំងឡាយពោលយ៉ាងនេះ ក្នុងឥឡូវនេះ ។

ពាក្យថា **តំ ឆិន្នគន្ថំ អសិតំ អនាសវំ** នេះ ជាពាក្យពោលសរសើរ

ព្រះនន្ទនោះ អធិប្បាយថា ឈ្មោះថា កាត់កិលេសជាគ្រឿងរួបរឹតជាប់ហើយ ព្រោះភាពដែលគន្ថៈ ៤ យ៉ាង ត្រូវកាត់បានហើយដោយសច្ចភាវនាទាំង ៤ នេះ ឈ្មោះថា ដែលទិដ្ឋិ ឬតណ្ហាអាស្រ័យមិនបានហើយ ព្រោះភាពដែលទិដ្ឋិ ឬតណ្ហាមិនអាស្រ័យហើយ ក្នុងទីណាមួយ ឈ្មោះថា មិនមានអាសវៈ ព្រោះមិនមានអាសវៈទាំង ៤ ។

បទថា **តំ វាបិ ធីរា មុនិ វេទយន្តិ** សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់សម្តែងថា អ្នកប្រាជ្ញរមែងប្រកាសបុគ្គលនោះថា ជាមុនីទីណាស្រេច តែអ្នកទាំងឡាយមិនត្រូវប្រកាស រមែងពោលថា ជាមុនីយ៉ាងនេះឯង ។

គាថាថា **អសមា ឧភោ** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ភិក្ខុមួយរូបអាស្រ័យបច្ចន្តគាមក្នុងដែនកោសល នៅក្នុងព្រៃ ។ ព្រានម្រឹគក្នុងស្រុកនោះ ទៅកាន់ឱកាសដែលជាលំនៅរបស់ភិក្ខុនោះ ចាប់ម្រឹគទាំងឡាយ កាលចូលទៅកាន់ព្រៃ ឃើញព្រះថេរៈចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត កាលមកអំពីព្រៃក៏ឃើញព្រះថេរៈកំពុងចេញអំពីស្រុក ក៏កើតសេចក្តីស្រឡាញ់ក្នុងព្រះថេរៈ ដោយការឃើញរឿយៗ យ៉ាងនេះ ប្រគេនបិណ្ឌបាតដែលមានរសដល់ព្រះថេរៈ ក្នុងពេលដែលខ្លួនបានសាច់ច្រើន មនុស្សទាំងឡាយពោលទោសថា ភិក្ខុនេះ រមែងប្រាប់ដល់ព្រានថា ក្នុងប្រទេសឈ្មោះនោះ ម្រឹគទាំងឡាយ រមែងឈរ ដើរ ផឹកទឹកដែលគួរផឹក បន្ទាប់អំពីនោះ ព្រានក៏សម្លាប់ម្រឹគទាំងឡាយ ដោយហេតុនោះ ទើបជនទាំងពីរសេហាការ

គ្នាចិញ្ចឹមជីវិត ។

លំដាប់នោះ ព្រះដ៏មានព្រះភាគយាងចារិកទៅកាន់ជនបទ បានយាងទៅកាន់ជនបទនោះ ភិក្ខុទាំងឡាយចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ស្តាប់ព្រឹត្តិការណ៍នោះហើយ ទូលដល់ព្រះដ៏មានព្រះភាគ ព្រះអង្គកាលទ្រង់សម្តែងភាពដែលភិក្ខុនោះ ជាមុនីទីណាស្រេព ដែលមិនសម្រេចការចិញ្ចឹមជីវិតរួមជាមួយព្រាន ទើបត្រាស់គាថានេះ ដើម្បីសម្តែងធម៌ដល់ភិក្ខុទាំងនោះ ។

គាថានោះមានសេចក្តីថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ និងព្រាននោះ ជនទាំងពីរមិនស្មើគ្នា មនុស្សទាំងឡាយ រមែងពោលពាក្យណាថា មានការចិញ្ចឹមជីវិតរួមគ្នា ពាក្យនោះខុសទេ ព្រោះហេតុអ្វី ព្រោះមានទីលំនៅ និងការរស់នៅឆ្ងាយគ្នា ទីលំនៅ និងការរស់នៅរបស់ជនទាំងពីរនោះ នៅឆ្ងាយគ្នា ព្រោះហេតុនោះ ទើបជនទាំងពីរនោះ ឈ្មោះថា **ទូរវិហារវុត្តិនោ ។**

បទថា **វិហារោ** បានដល់ ឱកាសដែលជាលំនៅ ។ ឱកាសដែលជាលំនៅរបស់ភិក្ខុមានក្នុងព្រៃ របស់ព្រានមានក្នុងស្រុក ។ បទថា **វុត្តិ** បានដល់ មានការរស់នៅ ។ ការរស់នៅរបស់ភិក្ខុ គឺការត្រាច់ទៅដើម្បីភិក្ខា តាមប្រកក្នុងស្រុក ឯរបស់ព្រាន គឺសម្លាប់ម្រឹគ និងបក្សីក្នុងព្រៃ ។

ប្រការមួយទៀត គ្រហស្ថចិញ្ចឹមកូនប្រពន្ធ ព្រោះហេតុនោះ ព្រាននោះរមែងចិញ្ចឹមកូនប្រពន្ធដោយកម្មនោះ ចំណែកភិក្ខុទីណាស្រេពនោះ មិនប្រកាន់ថា ជារបស់អញ មានវត្តល្អ គឺវៀរចាកការប្រកាន់ថា ជារបស់អញ ដោយ

តណ្ហា និងទិដ្ឋិ ក្នុងកូនប្រពន្ធទាំងឡាយ ឈ្មោះថា មានវត្តល្អ ព្រោះជាអ្នកមានវត្តស្អាត និងជាអ្នកមានវត្តប្រសើរ ។

ម្យ៉ាងទៀត គ្រហស្ថមិនសង្រួម ព្រោះបៀតបៀនសត្វដទៃ ព្រានទោះជាគ្រហស្ថ ឈ្មោះថា មិនសង្រួមនូវកាយ វាចា និងចិត្ត ព្រោះបៀតបៀនសត្វដទៃ គឺចូលទៅផ្តាច់ជីវិតិន្ទ្រិយរបស់សត្វទាំងនោះ មុនីសង្រួមជានិច្ច រក្សាសត្វមានជីវិត ចំណែកភិក្ខុក្រៅពីនេះជាមុនីទីណាស្រេព សង្រួម គឺប្រុងស្មារតីជានិច្ចដោយកាយ វាចា និងចិត្ត រក្សាសត្វមានជីវិត កាលបើដូច្នេះ ជនទាំងពីរមានការចិញ្ចឹមជីវិតរួមគ្នាដូចម្តេចកើត ដូច្នេះ ។

គាថាថា **សិខី យថា** ដូច្នេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

កាលព្រះដ៏មានព្រះភាគ គង់នៅក្នុងក្រុងកបិលពស្តុ ការសន្ទនាបានកើតឡើងដល់សក្យៈទាំងឡាយថា បុគ្គលសម្រេចសោតាមុន រមែងជាបុគ្គលចាស់ជាងអ្នកសម្រេចសោតាក្រោយដោយធម៌ ព្រោះដូច្នោះ ភិក្ខុដែលសម្រេចសោតាខាងក្រោយ គប្បីធ្វើកិច្ចទាំងឡាយ មានការអភិវាទជាដើមដល់គ្រហស្ថដែលសម្រេចសោតាមុន ភិក្ខុដែលសមាទានបិណ្ឌបាតជាវត្តមួយរូប ស្តាប់ការសន្ទនានោះ ទើបក្រាបទូលដល់ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់សំដៅថា ជាតិកើតក៏មួយបែប ភេទជាវត្ថុដែលបុគ្គលគប្បីបូជា ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើអនាគាមីជាគ្រហស្ថសោត អនាគាមីដែលជាគ្រហស្ថនោះគប្បីធ្វើកិច្ចទាំងឡាយ មានការអភិវាទជាដើមដល់សាមណេរដែលបួសក្នុង

ថ្ងៃនេះ កាលទ្រង់សម្ដែងគុណវិសេសរបស់ភិក្ខុ ដែលសម្រេចសោតាបន្ន ខាងក្រោយមានគុណធំក្រៃលែងជាងគ្រហស្ថ ដែលសម្រេចសោតាមុនទៅទៀត ទើបត្រាស់គាថានេះ ដើម្បីសម្ដែងធម៌ដល់ភិក្ខុទាំងឡាយ ។

គាថានោះមានអត្ថថា ក្ងោកហើរទៅក្នុងអាកាស ហៅថាមានសិរ ព្រោះមានភាវៈដែលសិរកើតត្រង់ក្បាល និងមានផ្ចិតកពណ៌ខៀវត្រង់ក ដូចដុំកែវមណី ក្ងោកនោះរមែងមិនដល់ចំណែកទី ១៦ ដោយសម្ទុះរបស់សុវណ្ណហង្ស ក្នុងបណ្ដាហរិតហង្ស តម្ពហង្ស ខីរសង្ស កាឡហង្ស បាកហង្ស និងសុវណ្ណ-ហង្ស ។ សូម្បីសុវណ្ណហង្ស រមែងហើរទៅមួយពាន់យោជន៍ ក៏មានដោយត្រឹមតែមួយសម្ទុះ ចំណែកក្ងោកក្រៅអំពីនេះ មិនប្រាកដថា អាចហើយទៅសូម្បីមួយយោជន៍ តែហង្ស និងក្ងោកទាំងពីរ ក៏ជាសត្វគួរមើល ព្រោះភាពជាសត្វគួរមើលយ៉ាងណា គ្រហស្ថសូម្បីសម្រេចសោតាមុន ក៏ដូច្នោះរមែងជាបុគ្គលដែលគួរមើលដោយមគ្គទស្សនៈក៏ពិត តែគ្រហស្ថនោះ ធ្វើតាមភិក្ខុដែលជាអ្នកសម្រេចសោតាខាងក្រោយក្ដី ជាអ្នកមានភាវៈដែលទៀងត្រង់គួរមើលដោយមគ្គទស្សនៈក្ដី ដោយជវៈ ( សម្ទុះ ) មិនបាន សួរថាដោយជវៈណា ឆ្លើយថា ដោយជវៈ គឺវិបស្សនា ញាណក្នុងមគ្គខាងលើ ព្រោះញាណនោះរបស់គ្រហស្ថ ជារបស់យឺតយូរ ព្រោះជាញាណដែលសាំញុំ ដោយការសាំញុំ មានបុត្ត និងភរិយាជាដើម ចំណែកញាណរបស់ភិក្ខុជារបស់រហ័ស ព្រោះការសាំញុំនោះ ត្រូវកាត់បន្ថយហើយ អត្ថនេះព្រះ

*ដ៏មានព្រះភាគ ទ្រង់សម្តែងហើយដោយបទនេះថា* **មុនិនោ វិវិត្តស្ស វនស្មឹ ឈាយតោ ។** *ភិក្ខុដែលជាសេក្ខមុនី ស្ងាត់ដោយកាយវិវេក និងចិត្តវិវេក សម្ងំនៅក្នុងព្រៃជានិច្ច ដោយលក្ខណារម្មណូបនិជ្ឈានវិវេក ឯឈានបែបនេះ របស់គ្រហស្ថនឹងមានអំពីណា អធិប្បាយក្នុងគាថានេះ មានប្រមាណ ប៉ុណ្ណេះឯង ។*

**អដ្ឋកថា មុនិសូត្រ ចប់**

**ឧរគវគ្គទី ១ ចប់**

# សុត្តន្តបិដក

# ចូឡវគ្គទី ២

## រតនសូត្រ

[ ២១ ] ពួកភូតណា ស្ថិតនៅលើផែនដីក្តី ពួកភូតណា ស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំក្នុងទីនេះ សូមពួកសត្វទាំងអស់នោះ មានចិត្តល្អ មួយទៀត ចូរស្តាប់នូវភាសិតដោយគោរព ។ ព្រោះហេតុនោះ អ្នកទាំងឡាយ ជាភូតទាំងអស់ ចូរស្តាប់ ចូរធ្វើនូវមេត្តាចិត្តក្នុងពពួកសត្វជាមនុស្សជាតិ ពួកមនុស្សណា នាំនូវពលិកម្ម ក្នុងវេលាថ្ងៃ ឬវេលាយប់ ព្រោះហេតុនោះ សូមអ្នកទាំងឡាយ កុំប្រហែស ចូររក្សានូវមនុស្សទាំងនោះ ។ ទ្រព្យជាទីគាប់ចិត្តណាមួយ ក្នុងលោកនេះ ឬក្នុងលោកដទៃ រតនវត្ថុដ៏ឧត្តមណា ក្នុងស្ថានសួគ៌ក្តី ( ទ្រព្យ និង រតនវត្ថុទាំងនោះ ) ស្មើដោយព្រះតថាគតមិនមានឡើយ រតនៈគឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

ព្រះសក្យមុនីមានព្រះហឫទ័យតម្កល់មាំ បានត្រាស់ដឹងហើយនូវព្រះធម៌ណា ជាគ្រឿងក្ស័យកិលេស ប្រាសចាករាគៈ ជាធម៌មិនស្លាប់ ជាធម៌ឧត្តម របស់អ្វីមួយ ស្មើដោយព្រះធម៌

នោះ មិនមានឡើយ រតនៈ គឺព្រះធម៌នេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

ព្រះពុទ្ធដ៏ប្រសើរ ទ្រង់សរសើរនូវសមាធិណា ថាជាសមាធិស្អាត បណ្ឌិតទាំងឡាយ ពោលនូវសមាធិណា ថាជាធម៌ឲ្យនូវផលដោយលំដាប់ សមាធិដទៃ ស្មើដោយសមាធិនោះ មិនមានឡើយ រតនៈ គឺព្រះធម៌នេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

បុគ្គលទាំងឡាយណា ៨ ពួក ដែលសប្បុរសទាំងឡាយសរសើរហើយ បើរាប់ជាគូបាន ៤ គូ បុគ្គលទាំងឡាយនោះ ជាសាវករបស់ព្រះសុគត លោកគួរដល់ទក្ខិណាទាន ទានទាំងឡាយ ដែលបុគ្គលឲ្យហើយ ចំពោះបុគ្គលទាំងនោះ ជាទានមានផលច្រើន រតនៈ គឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

អរិយបុគ្គលទាំងឡាយណា ក្នុងសាសនានៃព្រះគោតម ប្រកបត្រូវល្អហើយ មានចិត្តខ្ជាប់ខ្ជួន មិនមានសេចក្តីប្រាថ្នា អរិយបុគ្គលទាំងឡាយនោះ ដល់ហើយនូវព្រះអរហត្តផល ហើយចូលទៅកាន់ព្រះនិព្វាន បាននូវការរលត់កិលេសដោយទទេ គឺឥតមានទិញដូរឡើយ ហើយសោយ ( នូវផល )

រតនៈ គឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

សសរខឿន ដែលគេបោះភ្ជាប់នឹងផែនដី ជារបស់មិនកម្រើកដោយខ្យល់ព្យុះ ដែលបក់មកអំពីទិសទាំង ៤ យ៉ាងណាមិញ បុគ្គលណាពិចារណាឃើញជាក់នូវអរិយសច្ចទាំងឡាយ តថាគតហៅអ្នកនោះ ថាជាសប្បុរស ( មិនញាប់ញ័រ ) ក៏យ៉ាងនោះដែរ រតនៈ គឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

អរិយបុគ្គលទាំងឡាយណា ធ្វើឲ្យជាក់ច្បាស់នូវអរិយ-សច្ច ដែលព្រះតថាគតមានប្រាជ្ញាដ៏ជ្រៅ សម្ដែងល្អហើយ អរិយបុគ្គលទាំងនោះ ទុកជាប្រមាទដ៏លើសលន់ក៏ដោយ អរិយបុគ្គលទាំងនោះ នឹងមិនកាន់យកនូវភពជាគម្រប់ ៨ ( គឺមិនកើតទៀតហួសពី ៧ ជាតិឡើយ ) រតនៈ គឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

ធម៌ ៣ គឺសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ឬការប្រព្រឹត្តិតាមណាមួយ ដែលសោតាបន្នបុគ្គលនោះបានលះបង់ហើយ ជាមួយនឹងទស្សនសម្បត្តិ គឺសោតាបត្តិមគ្គ មួយវិញទៀត សោតាបន្នបុគ្គល បានរួចស្រឡះចាកអបាយទាំង ៤

ហើយ មិនគួរធ្វើនូវអភិឋាន ៦ គឺអនន្តរិយកម្ម ៥ និងការ ផាកចិត្តទៅកាន់សាសនាដទៃឡើយ រតនៈ គឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

ទុកជាសោតាបន្នបុគ្គលនោះ ធ្វើនូវបាបកម្មដោយកាយ វាចា ឬក៏ដោយចិត្ត ( ព្រោះសេចក្តីភ្លាំងភ្លាត់ ) សោតាបន្នបុគ្គល នោះ មិនគួរបិទបាំងនូវបាបកម្មនោះឡើយ ព្រោះភាពនៃបុគ្គល ដែលឃើញផ្លូវនៃព្រះនិព្វានហើយ ជាបុគ្គលមិនគួរបិទបាំងនូវ បាបកម្ម ដែលព្រះពុទ្ធទាំងឡាយសម្តែងហើយ រតនៈ គឺព្រះសង្ឃ នេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តី កើតមាន ។

គុម្ពឈើក្នុងព្រៃមានត្រួយលូតលាស់ ក្នុងខាងដើមគិម្ហ- រដូវ គឺខែក្តៅយ៉ាងណាមិញ ព្រះពុទ្ធបានសម្តែងហើយ នូវធម៌ ដ៏ប្រសើរ ជាធម៌អាចញុំាងសត្វទាំងឡាយ ឲ្យដល់នូវព្រះនិព្វាន ដើម្បីប្រយោជន៍ដ៏ឧត្តម ក៏យ៉ាងនោះឯង រតនៈ គឺព្រះពុទ្ធនេះ ឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចនេះ សូមសួស្តីកើត មាន ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរ ទ្រង់ជ្រាបនូវធម៌ដ៏ ប្រសើរ ទ្រង់ប្រទាននូវធម៌ដ៏ប្រសើរ ទ្រង់នាំមកនូវធម៌ដ៏ប្រសើរ

ព្រះអង្គប្រសើរ មិនមានអ្នកណាជាង ទ្រង់សម្តែងនូវធម៌ដ៏ប្រសើរ រតនៈ គឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

កម្មចាស់អស់ហើយ កម្មថ្មីរមែងមិនកើតប្រាកដ អរិយ-បុគ្គលទាំងឡាយណា មានចិត្តនឿយណាយ ក្នុងភពតទៅ អរិយបុគ្គលទាំងនោះ មានពូជអស់ហើយ មានឆន្ទៈ គឺសេចក្តីប៉ុនប៉ងក្នុងចិត្តមិនដុះឡើងឡើយ ជាអ្នកមានប្រាជ្ញាតែងរលត់ទៅ ដូចជាប្រទីប ( ដែលរលត់ ) រតនៈ គឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

ពួកភូតណា ស្ថិតនៅលើផែនដីក្តី ពួកភូតណាស្ថិតនៅពួដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ យើងទាំងឡាយ សូមនមស្ការនូវព្រះពុទ្ធ ទ្រង់បានត្រាស់មកហើយដូចគ្នា ដែលទេវតានិងមនុស្សបូជាហើយ សូមសួស្តីកើតមាន ។

ពួកភូតណា ស្ថិតនៅលើផែនដីក្តី ពួកភូតណា ស្ថិតនៅពួដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ យើងទាំងឡាយសូមនមស្ការនូវព្រះធម៌ ដែលមានមកហើយដូចគ្នា ដែលទេវតា និងមនុស្សបូជាហើយ សូមសួស្តីកើតមាន ។

ពួកភូតណា ស្ថិតនៅលើផែនដីក្តី ពួកភូតណា ស្ថិតនៅលើអាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ យើងទាំងឡាយសូមនមស្ការនូវព្រះសង្ឃ ដែលមានមកហើយដូចគ្នា ដែលទេវតា និងមនុស្សបូជាហើយ សូមសួស្តីកើតមាន ។

**រតនសូត្រទី ១ ចប់**

# អដ្ឋកថា

# ចូឡវគ្គទី ២

## រតនសូត្រ

[ ២១ ] ក្នុងរតនសូត្រទី ១ នៃវគ្គទី ២ មានពាក្យផ្ដើមថា **យានីធ ភូតានិ** ដូច្នេះ ។ សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះថា

បានឮថា ក្នុងអតីតកាល ឧបទ្រពទាំងឡាយ មានទុព្ភិក្ខភ័យជាដើម កើតឡើងហើយ ក្នុងក្រុងវេសាលី ស្ដេចលិច្ឆវីទាំងឡាយ បានទៅកាន់នគររាជគ្រឹះ ទូលអារាធនាព្រះមានព្រះភាគមកកាន់នគរវេសាលី ដើម្បីឲ្យភ័យទាំងនោះស្ងប់ ។ ព្រះមានព្រះភាគ ដែលស្ដេចលិច្ឆវីនិមន្តមកហើយយ៉ាងនេះ បានត្រាស់ព្រះសូត្រនេះ ដើម្បីឲ្យឧបទ្រពទាំងឡាយស្ងប់ នេះ គឺសេចក្ដីសង្ខេបក្នុងរតនសូត្រនេះ ។

បុរាណាចារ្យទាំងឡាយ បានពណ៌នាដល់ការកើតឡើងនៃព្រះសូត្រនេះ ចាប់តាំងពីកកើតនគរវេសាលី គប្បីជ្រាបអត្ថុប្បត្តិហេតុនៃរតនសូត្រនោះដូចតទៅនេះ

បានឮមកថា គភ៌តាំងឡើងក្នុងផ្ទៃអគ្គមហេសីរបស់ព្រះរាជាក្នុងនគរពារាណសី ព្រះនាងជ្រាបការដែលគភ៌នោះតាំងឡើងហើយ ទើបបានក្រាបទូលដល់ព្រះរាជាៗ ទ្រង់បានព្រះរាជទានការបរិហារគភ៌ ព្រះនាងមានព្រះគភ៌

ដែលមនុស្សទាំងឡាយថែរក្សាដោយប្រពៃ ក្នុងកាលដែលគភ៌ចាស់ ព្រះនាង ក៏យាងឡើងកាន់ផ្ទះប្រសូត ។ ស្រីមានបុណ្យទាំងឡាយ តែងប្រសូតបុត្តក្នុង វេលាទៀបភ្លឺ ព្រះនាងជាស្រីម្នាក់ ក្នុងបណ្តាស្រីមានបុណ្យទាំងនោះ ព្រោះ ហេតុនោះ ក្នុងវេលាទៀបភ្លឺ ព្រះនាងក៏ប្រសូតដុំសាច់មួយដុំ ដូចគ្នានឹង ដុំល័ក្ត មានពណ៌ដូចផ្កាចប្បារ ។ បន្ទាប់អំពីនោះ ព្រះមហេសីព្រះតម្រិះថា ការខូចកិត្តិយសគប្បីកើតឡើងដល់អញចំពោះមុខព្រះរាជា ព្រោះថា ទេវីដទៃ ប្រសូតព្រះឱរសដូចគ្នានឹងដុំមាស អគ្គមហេសីប្រសូតដុំសាច់ ដូច្នេះ ។ ព្រោះ ខ្លាចវិនាសកិត្តិយសនោះ ទើបព្រះនាងឲ្យដាក់ដុំសាច់នោះ ក្នុងភាជន:មួយ គ្របដោយភាជន:មួយ ប្រថាប់ត្រា ហើយឲ្យយកទៅបណ្តែតក្នុងស្ទឹងគង្គា គ្រាន់តែមនុស្សទាំងឡាយ បណ្តែតភាជន:នោះប៉ុណ្ណោះ ទេវតាទាំងឡាយ ក៏តាមថែរក្សា ។ ទេវតាទាំងឡាយបានចារឹកបន្ទះមាសដោយហិង្គុលជាតិ ចង ត្រង់ភាជន:នោះថា វត្ថុនេះកើតអំពីគភ៌អគ្គមហេសី របស់ព្រះបាទពារាណសី បន្ទាប់អំពីនោះ ភាជន:នោះមិនមានអន្តរាយ អំពីរលកជាដើមឡើយ បាន អណ្តែតតាមខ្សែទឹកស្ទឹងគង្គានោះ ។

សម័យនោះ តាបសម្នាក់អាស្រ័យនាយគោបាល ក្បែរឆ្នេរស្ទឹងគង្គា ចុះកាន់ស្ទឹងនោះអំពីព្រលឹម បានឃើញភាជន:នោះកំពុងអណ្តែតមក បាន កាន់យកហើយ ដោយសម្គាល់ថា ជារបស់បង្សុកូល បន្ទាប់អំពីនោះ ឥសី នោះបានឃើញបន្ទះអក្សរនោះ និងស្នាមត្រាត្រង់ភាជន:នោះ បើកចេញហើយ

បានឃើញដុំសាច់នោះ ។ លុះឃើញហើយ ឥសីនោះគិតថា នេះជាគភ៌ ព្រោះដុំសាច់នេះមិនមានក្លិនស្អុយ ទើបនាំដុំសាច់នោះទៅកាន់អាស្រម ទុកក្នុងទីដ៏បរិសុទ្ធ ។ លុះកន្លងទៅបានកន្លះខែ ដុំសាច់នោះក៏បែកជា ២ តាបសឃើញដុំសាច់នោះហើយ ក៏រក្សាឲ្យល្អជាងមុន ។ បន្ទាប់អំពីនោះ កន្លងទៅបានកន្លះខែទៀត ដុំសាច់នីមួយៗ ក៏ចេញជាបញ្ចសាខា ដើម្បីជាប្រយោជន៍ដល់ដៃ ជើង និងក្បាល ។ តាបសនោះឃើញហើយ រឹងរឹតតែរក្សាទុកក្រៃលែងឡើង បន្តអំពីនោះកន្លះខែទៀត ដុំសាច់មួយក៏ក្លាយជាទារក ដូចគ្នានឹងដុំមាស ដុំសាច់មួយទៀត ក៏កើតជាទារិកា ដូចគ្នានឹងដុំមាស តាបសកើតសេចក្តីស្នេហាដូចបុត្ត ក្នុងក្មេងទាំង ២ នោះ ទឹកដោះបានកើតឡើងត្រង់មេដៃរបស់តាបស ។ តាំងអំពីនោះមក កាលតាបសបានទឹកដោះ និងកត្ត កាលនោះក៏ដាន់កត្ត ទុកទឹកដោះឲ្យទារកទាំង ២ ពៅ ។ របស់ណាមួយ ចូលទៅក្នុងពោះរបស់ក្មេងទាំង ២ នោះ របស់ទាំងអស់រមែងប្រាកដហាក់ដូចដាក់ក្នុងភាជនៈកែវមណី ដូច្នោះ ( គឺមើលធ្លុះ ) ។ ក្មេងទាំងនោះ ជាអ្នកមិនមានស្បែកដោយអាការយ៉ាងនេះ ។ អាចារ្យពួកខ្លះពោលថា ស្បែករបស់ក្មេងទាំង ២ នោះ ជាប់គ្នានិងគ្នា ដូចដេរដូច្នោះ ទើបក្មេងទាំង ២ ប្រាកដឈ្មោះថា លិច្ឆវី ព្រោះជាអ្នកមិនមានស្បែក ឬព្រោះមានស្បែកជាប់គ្នាដោយប្រការដូច្នេះ ។ តាបសចិញ្ចឹមទារកទាំង ២ ចូលទៅក្នុងស្រុកដើម្បីបិណ្ឌបាតយឺតយូរ ត្រឡប់មកក៏យឺតយូរ ពួកនាយគោបាលជ្រាបដល់

បលិពោធរបស់តាបសនោះ ទើបប្រាប់ថា បពិត្រលោកម្ចាស់ ការចិញ្ចឹមក្មេង ជាកង្វល់របស់បព្វជិតទាំងឡាយ សូមលោកម្ចាស់ឲ្យក្មេងទាំង ២ ដល់ពួកខ្ញុំៗ នឹងចិញ្ចឹម សូមលោកម្ចាស់ធ្វើសមណធម៌ចុះ តាបសទទួលថា សាធុ ។

នាយគោបាលទាំងឡាយ បានជម្រះផ្លូវឲ្យស្មើ ក្នុងថ្ងៃទី ២ រោយផ្កា លើកទង់ជ័យ និងទង់ផ្កាលា ទៅកាន់អាស្រមដោយតន្ត្រីទាំងឡាយ ។ តាបសពោលថា ក្មេងទាំង ២ ជាសត្វមានបុណ្យច្រើន ចូរពួកអ្នកចិញ្ចឹមឲ្យចម្រើនដោយយកចិត្តទុកដាក់ កាលក្មេងទាំង ២ ធំហើយ ចូរធ្វើអាវាហវិវាហៈជាមួយគ្នា ពួកអ្នកធ្វើឲ្យព្រះរាជាពេញទ្រះហឫទ័យ ដោយការថ្វាយបញ្ចគោរសរួចចូរកាន់យកទីណាមួយ នាំគ្នាសាងនគរ ចូរអភិសេកកុមារក្នុងព្រះនគរដូច្នេះហើយ ទើបប្រគល់ទារកទាំង ២ ដល់ពួកគោបាល ។ ពួកគោបាលទាំងនោះទទួលថា សាធុ ដូច្នេះហើយ នាំទារកទាំង ២ ទៅចិញ្ចឹម ក្មេងទាំង ២ ចម្រើនវ័យឡើងហើយ លេងជាមួយទារកដទៃ ប្រើដៃខ្លះ ជើងខ្លះ វាយកូនរបស់នាយគោបាលដទៃៗ ក្នុងទីដែលឈ្លោះគ្នា ពួកក្មេងទាំងនោះយំ កាលឪពុកម្តាយសាកសួរថា ហេតុអ្វីក៏ឯងយំ ក៏ឆ្លើយថា កូនអត់ម៉ែអត់ឪទាំង ២ ដែលតាបសចិញ្ចឹមវាយពួកខ្ញុំ ។

លំដាប់នោះ មាតាបិតារបស់ក្មេងក៏ពោលថា ក្មេង ២ នាក់នេះ បៀតបៀនក្មេងដទៃ ធ្វើឲ្យក្មេងដទៃដល់នូវសេចក្តីទុក្ខ ពួកយើងមិនគួរសង្គ្រោះក្មេង

បែបនេះ ពួកយើងគួរលះបង់ ។ បានឮថា តាំងពីកាលនោះមក ទឹកដីត្រង់ទីនោះក៏មានឈ្មោះថា **វជ្ជី** ដែលមានផ្ទៃដីប្រមាណ ១០០ យោជន៍ ។ តាំងពីនោះមក នាយគោបាលទាំងឡាយ ធ្វើឲ្យព្រះរាជាសព្វព្រះហឫទ័យហើយកាន់យកដីមួយកន្លែងនោះ សាងព្រះនគរឡើងក្នុងទីនោះឯង ហើយអភិសេកព្រះរាជកុមារដែលមានវស្សា ១៦ ក្នុងតំណែងព្រះរាជា ហើយពួកនាយគោបាលបានធ្វើកតិកាហាមឃាត់ទារិកា និងព្រះរាជានោះថា មិនគប្បីនាំទារិកាអំពីខាងក្រៅមក មិនគប្បីឲ្យទារិកាក្នុងទីនេះដល់បុគ្គលណាម្នាក់ ។ ព្រោះការនៅរួមគ្នាលើកដំបូងរបស់ព្រះរាជា និងព្រះរាជនីនោះ ក៏ប្រសូតបានទារក ២ អង្គ ស្រី ១ ប្រុស ១ ទារកកើត ២ ម្តងៗ រហូតដល់ ១៦ ដង ។ បន្ទាប់អំពីនោះ ជនទាំងឡាយបានព័ទ្ធព្រះនគរ មួយកន្លែងនោះ ដើម្បីឲ្យក្មេងនោះចម្រើនឡើងជាលំដាប់ កាន់យកសួនឧទ្យានជាទីត្រេកអរ ទីលំនៅ បរិវារ និងសម្បត្តិ ដោយកំពែង ៣ ជាន់ ដែលឃ្លាតគ្នាចម្ងាយ ៣ គាវុត ព្រោះនគរនោះពង្រីកចេញបណ្តើរៗ ទើបបានឈ្មោះថា **វេសាលី** នេះជារឿងរបស់នគរវេសាលី ។

តែនគរវេសាលីនេះ ក្នុងសម័យដែលព្រះមានព្រះភាគទ្រង់កើតឡើងហើយ ជានគរស្តុកស្តម្ភបរិបូណ៌ ក្នុងនគរវេសាលីនោះ មានព្រះរាជា ៧៧០៧ អង្គ សូម្បីឧបរាជ សេនាបតី និងនាយឃ្លាំងជាដើម ក៏មានចំនួនប៉ុណ្ណោះដូចគ្នា សមដូចព្រះធម្មសង្គាហកាចារ្យពោលក្នុងវិន័យមហាវគ្គថា *សម័យ*

នោះឯង ក្រុងវេសាលីក៏ស្តុកស្តម្ភ ទូលាយ មានជនច្រើន មានមនុស្សមីរដេរដាស មានអាហារ ផ្ទះកំពូល ចំណីក៏សម្បូណ៌ មានប្រាសាទ ៧ ពាន់ ៧ រយ ៧ ប្រាសាទ មានផ្ទះកំពូល ៧ ពាន់ ៧ រយ ៧ ផ្ទះ មានសួនច្បារ ៧ ពាន់ ៧ រយ ៧ សួនច្បារ មានស្រះបោក្ខរណី ៧ ពាន់ ៧ រយ ៧ ស្រះ ។

ដោយសម័យដទៃ នគរវេសាលីមានភិក្ខាហាររកបានលំបាក ភ្លៀងរាំងសម្ងួនវិនាស ជាដំបូងអ្នកក្រីក្រស្លាប់មុន មនុស្សទាំងឡាយចោលសាកសពអ្នកក្រីក្រទាំងនោះខាងក្រៅនគរ ព្រោះក្លិនសាកសពរបស់អ្នកដែលស្លាប់ទាំង-ឡាយ ពួកអមនុស្សទាំងឡាយក៏ចូលក្នុងនគរ តាំងពីកាលនោះមក មនុស្សស្លាប់ច្រើនជាបន្តបន្ទាប់ ព្រោះភាពបដិកូលនោះ អហិវាតករោគ ក៏កើតឡើងដល់សត្វទាំងឡាយ កាលនគរវេសាលីត្រូវទុព្ភិក្ខភ័យ អមនុស្សភ័យ និងរោគភ័យ ៣ ប្រការ ប្រទូស្តហើយ ដូចពោលមកនេះ អ្នកនគរទាំងឡាយក៏ចូលទៅក្រាបទូលព្រះរាជាថា បពិត្រមហារាជ ភ័យ ៣ ប្រការកើតឡើងហើយក្នុងព្រះនគរ ក្នុងកាលមុនរាប់អំពីនេះទៅ រហូតដល់ ៧ ជួររាជត្រកូល ភ័យបែបនេះ មិនធ្លាប់កើតឡើង តែបានកើតឡើងហើយ ក្នុងកាលឥឡូវនេះ ប្រហែលជាទ្រង់មិនតាំងនៅក្នុងធម៌ ។

ព្រះរាជាត្រាស់ឲ្យមហាជនប្រជុំគ្នាត្រង់សណ្ឋាគារ ហើយទើបត្រាស់ថា ចូរពួកអ្នកជួយពិនិត្យមើលថា តើខ្ញុំមិនតាំងនៅក្នុងធម៌ប្រការណាមួយ ជន

ទាំងពួងពិចារណាបវេណីសព្វយ៉ាង ក៏មិនបានជួបកំហុសគ្គងណាមួយ បន្ទាប់អំពីនោះ មហាជនក៏មិនឃើញកំហុសរបស់ព្រះរាជា ទើបនាំគ្នាគិតថា ភ័យនេះ គប្បីស្ងប់បានដូចម្ដេច ក្នុងបណ្ដាមនុស្សទាំងនោះ មនុស្សពួកខ្លះ ស្នើថា បើគ្រូទាំង ៦ បានប្រាកដហើយ ភ័យមុខជានឹងស្ងប់ក្នុងកាលដែលគ្រូទាំង ៦ ដាក់ជើងចុះ គឺជាន់នគរវេសាលីប៉ុណ្ណោះ ។ មនុស្សពួកខ្លះ ស្នើថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ព្រះមានព្រះភាគអង្គនោះ ទ្រង់សម្ដែងធម៌ ដើម្បីជាប្រយោជន៍ដល់សត្វទាំងពួង ទ្រង់មានឫទ្ធិច្រើន មានអានុភាពច្រើន ក្នុងកាលទ្រង់ដាក់ព្រះបាទចុះ ភ័យទាំងពួងគប្បីស្ងប់បាន ព្រោះហេតុនោះ មនុស្សទាំងនោះក៏ពេញចិត្ត ពោលថា ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ គង់នៅក្នុងទីណា កាលពួកយើងបញ្ជូនសារយាងទ្រង់មក ទ្រង់គប្បីមកឬហ្ន៎ ។ លំដាប់នោះ មនុស្សមួយពួកទៀតនិយាយថា ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់តែងករុណាចំពោះសត្វលោក រឿងអ្វីដែលថាទ្រង់មិនមក ឥឡូវនេះ ទ្រង់គង់នៅក្នុងនគររាជគ្រឹះ ហើយព្រះបាទពិម្ពិសារ ក៏ទ្រង់ឧបដ្ឋាកព្រះអង្គ ជួនកាលព្រះបាទពិម្ពិសារមិនឲ្យព្រះអង្គ យាងមកក៏ថាបាន មនុស្សទាំងនោះក៏ពោលថា បើដូច្នោះ ចូរអ្នកទាំងឡាយ ឲ្យព្រះរាជាយល់ព្រមសិន ហើយនាំព្រះមានព្រះភាគមក ។

ស្ដេចលិច្ឆវី ២ អង្គ បានថ្វាយគ្រឿងបណ្ណាការជាច្រើន មួយអន្លើដោយពលនិកាយដ៏ធំ បញ្ជូនទៅកាន់សម្នាក់ព្រះរាជាថា សូមពួកទ្រង់ឲ្យស្ដេចពិម្ពិសារ

អនុញ្ញាតហើយ នាំព្រះមានព្រះភាគមក ។ ជនទាំងនោះទៅហើយ ថ្វាយគ្រឿងបណ្ណាការដល់ព្រះរាជា ចន្លុលបង្ហាញឲ្យទ្រង់ជ្រាបការប្រព្រឹត្តិទៅនោះ ហើយទូលថា បពិត្រមហារាជ សូមទ្រង់បញ្ជូនព្រះមានព្រះភាគទៅកាន់នគររបស់ពួកខ្ញុំ ។ ព្រះរាជាទ្រង់មិនទទួល គ្រាន់តែត្រាស់ថា សូមទ្រង់ទាំងឡាយដឹងឯងចុះ ជនទាំងនោះក្រាបទូលថា សាធុ ហើយចូលទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ ទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ភ័យ ៣ ប្រការ កើតឡើងហើយក្នុងនគររបស់ពួកខ្ញុំព្រះអង្គ បើព្រះមានព្រះភាគយាងទៅសោត សួស្តីគប្បីមានដល់ពួកខ្ញុំព្រះអង្គទាំងឡាយ ។

លំដាប់នោះ ព្រះសាស្តាទ្រង់ពិចារណាហើយ ទ្រង់ក៏ទទួល ដោយទ្រង់ដឹងច្បាស់ថា កាលតថាគតសម្តែងរតនសូត្រក្នុងនគរវេសាលីហើយ ការរក្សាគឺអាជ្ញានឹងផ្សាយទៅអស់សែនកោដិចក្រវាល ក្នុងកាលចប់ព្រះសូត្រ ធម្មាភិសម័យនឹងមានដល់សត្វ ៨៤០០០ ។

លំដាប់នោះ ព្រះបាទពិម្ពិសារ ទ្រង់ឮថា ព្រះសាស្តាទទួលហើយ ក៏ឲ្យប្រកាសក្នុងព្រះនគរថា ព្រះមានព្រះភាគ ទ្រង់ទទួលការនិមន្ត យាងទៅកាន់នគរវេសាលីហើយ ទើបចូលទៅគាល់ព្រះសាស្តា ហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់ទទួលការយាងទៅនគរវេសាលីឬ ព្រះសាស្តាត្រាស់ថា ថ្វាយព្រះពរមហាបពិត្រ ។ ព្រះបាទពិម្ពិសារក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ សូមទ្រង់បង្អង់សិន ទម្រាំខ្ញុំព្រះអង្គរៀបចំផ្លូវស្រេចបាច់ ។

កាលនោះឯង ព្រះបាទពិម្ពិសារ ទ្រង់ពង្រាបផែនដីក្នុងទីប្រមាណ ៥ យោជន៍ ក្នុងរវាងនគររាជគ្រឹះ និងស្ទឹងគង្គាឲ្យស្មើ ហើយឲ្យសាងវិហារក្នុងទីមួយយោជន៍មួយកន្លែង ហើយឲ្យក្រាបទូលកាលដល់ព្រះមានព្រះភាគ ។ ព្រះសុគត ចោមរោមដោយភិក្ខុប្រមាណ ៥០០ យាងទៅហើយ ព្រះរាជាទ្រង់រោយផ្កា ដែលមានពណ៌ ៥ អស់ចម្ងាយផ្លូវ ៥ យោជន៍ ត្រឹមជង្គង់ ឲ្យលើកទង់ជ័យ និងទង់ផ្លាលា តម្កល់ក្អមទឹកដែលពេញ និងលើកដើមចេកជាដើម ទ្រង់ឲ្យលើកស្វេតច្ឆត្រ ២ ជាន់សម្រាប់ព្រះមានព្រះភាគ និងមួយជាន់សម្រាប់ភិក្ខុមួយរូបៗ ធ្វើនូវការបូជាដោយផ្កា និងគ្រឿងក្រអូបជាដើម ជាមួយបរិវាររបស់ព្រះអង្គ ទ្រង់និមន្តឲ្យព្រះសាស្តា គង់នៅក្នុងវិហារនីមួយៗ ហើយទ្រង់ថ្វាយមហាទាន ហើយនាំទៅកាន់ស្ទឹងគង្គា អស់កាល ៥ ថ្ងៃ ។

ព្រះបាទពិម្ពិសារទ្រង់តាក់តែងនាវា ដោយគ្រឿងប្រដាប់គ្រប់យ៉ាងត្រង់ប្រាំងស្ទឹងគង្គានោះ ហើយទ្រង់បញ្ជូនព្រះរាជសារដល់ព្រះរាជាក្រុងវេសាលីថា ព្រះសាស្តាយាងមកហើយ សូមពួកទ្រង់ត្រៀមរៀបចំផ្លូវ សូមធ្វើការទទួលព្រះមានព្រះភាគ ។ ស្តេចលិច្ឆវីទាំងឡាយ ទ្រង់ព្រះតម្រិះថា ពួកយើងនឹងធ្វើការបូជាទ្វេដង ដូច្នេះហើយ ឲ្យធ្វើផ្លូវប្រមាណ ៣ យោជន៍ ក្នុងរវាងក្រុងវេសាលី និងស្ទឹងគង្គាឲ្យស្មើ ហើយត្រៀមស្វេតច្ឆត្រ ៤ ជាន់ដើម្បីព្រះមានព្រះភាគ ស្វេតច្ឆត្រ ២ ជាន់សម្រាប់ភិក្ខុមួយរូបៗ កាលនឹងធ្វើការបូជា ទើបមកប្រថាប់ឈរត្រង់ច្រាំងស្ទឹងគង្គា ។ ព្រះបាទពិម្ពិសារ ទ្រង់ឲ្យធ្វើ

ទូក ២ មានមណ្ឌប ប្រដាប់ដោយកម្រងផ្កាជាដើម ឲ្យក្រាលពុទ្ធាសនៈសម្រេចដោយរតនៈទាំងពួងលើទូកនោះ ។ ព្រះមានព្រះភាគ គង់លើពុទ្ធាសនៈនោះ សូម្បីភិក្ខុ ៥០០ ក៏ឡើងទូក អង្គុយក្នុងទីសមគួរ ព្រះរាជាកាលតាមជូនដំណើរព្រះមានព្រះភាគ បានចុះទៅក្នុងទឹកប្រមាណត្រឹមក ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនៅត្រង់ប្រាំងស្ទឹងនេះឯង ទម្រាំទ្រង់យាងមក ហើយត្រឡប់ ។

ទេវតាទាំងឡាយខាងលើដល់អកនិដ្ឋកព្រហ្ម បានធ្វើការបូជា ។ នាគទាំងឡាយ មានពួកនាគឈ្មោះកម្ពលស្សតរជាដើម ដែលនៅអាស្រ័យបាតស្ទឹងគង្គា ធ្វើហើយនូវការបូជា ។ ព្រះសាស្តាយាងតាមស្ទឹងគង្គាអស់ចម្ងាយផ្លូវមួយយោជន៍ ក៏ចូលដល់ដែនដីក្រុងវេសាលី ដោយការបូជាដ៏ធំក្រៃលែងបន្ទាប់អំពីនោះ ស្តេចលិច្ឆវីទាំងឡាយ កាលធ្វើការបូជាទ្វេគុណនៃការបូជាដែលព្រះបាទពិម្ពិសារនោះធ្វើហើយ ទ្រង់ទទួលព្រះមានព្រះភាគក្នុងទឹកប្រមាណត្រឹមក ខណៈនោះឯង មហាមេឃក៏ចាប់ផ្តើមងងឹត ខ្សែផ្ទេកបន្ទោរជាលប្រវាត់ផ្គរគំរាមទាំង ៤ ទិស គ្រាន់តែព្រះសាស្តាដាក់ព្រះបាទដំបូងត្រង់ស្ទឹងគង្គាប៉ុណ្ណោះ ភ្លៀងបោក្ខរព័ស៌ក៏ធ្លាក់ មនុស្សពួកណាត្រូវការសើម ក៏សើម មិនត្រូវការទទឹក ក៏មិនទទឹក ទឹកប្រមាណស្មើក្បាលជង្គង់ ស្មើភ្លៅ ស្មើចង្កេះ ស្មើក ហូរទៅក្នុងទីទាំងពួង សាកសពទាំងអស់ ត្រូវទឹកហូរនាំទៅកាន់ស្ទឹងគង្គា ផ្ទៃដីក៏បរិសុទ្ធ ។

ស្ដេចលិច្ឆវីទាំងឡាយឲ្យព្រះមានព្រះភាគគង់នៅ រាល់ៗ កន្ទះយោជន៍ ថ្វាយមហាទាន ធ្វើសក្ការបូជាទ្វេគុណអស់វេលា ៣ ថ្ងៃ នាំព្រះសាស្ដាមកកាន់ក្រុងវេសាលី ។ កាលព្រះមានព្រះភាគយាងដល់ក្រុងវេសាលីហើយ សក្កទេវរាជ មានពួកទេវតាចោមរោមយាងមកហើយ ។ ព្រោះទេវតាមានសក្តិធំប្រជុំគ្នា ពួកអមនុស្សក៏គេចទៅដោយច្រើន ។ ព្រះមានព្រះភាគប្រថាប់ឈរត្រង់ទ្វារព្រះនគរ ហៅព្រះអានន្ទមកហើយ ត្រាស់ថា ម្នាលអានន្ទ ចូរអ្នករៀនរតនសូត្រនេះ ហើយកាន់ឧបករណ៍នៃពលីកម្ម មួយអន្លើដោយលិច្ឆវីកុមារទាំងឡាយ ត្រាច់ទៅក្នុងរវាងកំពែង ៣ ជាន់នៃនគរវេសាលី ចូរធ្វើនូវព្រះបរិត្ត ដូច្នេះហើយ បានត្រាស់រតនសូត្រ ។

មានពាក្យសួរថា ព្រះសូត្រនេះ អ្នកណាពោលយ៉ាងនេះ ពោលកាលណា ពោលក្នុងទីណា ពោលព្រោះហេតុអ្វី ការវិសជ្ជនាបញ្ហា បុរាណាចារ្យទាំងឡាយ បានពណ៌នាដោយពិស្ដារ ចាប់តាំងពីរឿងនគរវេសាលី ។

ក្នុងថ្ងៃដែលព្រះមានព្រះភាគ យាងមិនទាន់ដល់នគរវេសាលីនោះឯង ព្រះអានន្ទបានរៀនរតនសូត្រនេះ ដែលព្រះមានព្រះភាគត្រាស់ដើម្បីកម្ចាត់ឧបទ្រវទាំងនោះ ត្រង់ទ្វារនគរវេសាលី សូធ្យដើម្បីការពារ ប្រើបាត្ររបស់ព្រះមានព្រះភាគដងទឹក ត្រាច់ប្រោះព្រំព្រះនគរ ។ កាលព្រះថេរៈពោលថា **យង្កិញ្ចិ** ប៉ុណ្ណោះ ពួកអមនុស្សទាំងឡាយ ដែលអាស្រ័យគំនរសំរាម និងបទេសនៃជញ្ជាំងផ្ទះជាដើម ដែលមិនទាន់គេចទៅក្នុងកាលមុន ក៏នាំគ្នាគេច

ទៅតាមទ្វារធំទាំង ៤ ។ ទ្វារទាំង ៤ មិនគ្រប់គ្រាន់ បន្ទាប់អំពីនោះ អមនុស្ស ពួកខ្លះ កាលមិនបានទីទំនេរដើម្បីចេញតាមទ្វារទាំងឡាយ ក៏ផ្ទោះកំពែងរត់ទៅ កាលពួកអមនុស្សទៅហើយ រោគរបស់មនុស្សទាំងឡាយក៏ស្ងប់ មនុស្សទាំង នោះ ចេញអំពីផ្ទះរបស់ខ្លួនបូជាព្រះថេរៈ ដោយគ្រឿងក្រអូប និងផ្កាគ្រប់ ប្រភេទជាដើម មហាជនបានប្រើគ្រឿងក្រអូបទាំងពួង លាបសណ្ឋាគារត្រង់ កណ្ដាលនគរ ធ្វើពិតានដែលប្រកបដោយរតនៈ ប្រដាប់ដោយគ្រឿងអលង្ការ សព្វយ៉ាង ឲ្យក្រាលពុទ្ធាសនៈក្នុងសណ្ឋាគារនោះហើយ បាននាំព្រះមាន ព្រះភាគមក ។ ព្រះមានព្រះភាគយាងចូលកាន់សណ្ឋាគារ គង់លើពុទ្ធាសនៈ ដែលគេក្រាលហើយ ឯភិក្ខុសង្ឃ រួមទាំងព្រះរាជាទាំងឡាយ មួយអន្លើដោយ ពួកមនុស្ស ក៏បានអង្គុយក្នុងឱកាសសមគួរ សូម្បីសក្កទេវរាជក៏អង្គុយជាមួយ នឹងទេវបរិស័ទក្នុងទេវលោកទាំង ២ ទេវតាពួកដទៃ ក៏បានអង្គុយដោយទេវ-បរិស័ទដូចគ្នា ឯព្រះអានន្ទត្ថេរត្រាច់ទៅកាន់នគរវេសាលី សព្វអន្លើហើយ ធ្វើការរក្សា ហើយត្រឡប់មកជាមួយអ្នកនគរវេសាលី អង្គុយចុះហើយក្នុង ចំណែកម្ខាង ក្នុងសណ្ឋាគារនោះ ព្រះមានព្រះភាគបានត្រាស់រតនសូត្រនោះ ឯង ដល់ទេវតា និងមនុស្សទាំងពួង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១ ថា **យានីធ ភូតានិ** ដូចតទៅនេះ

បណ្ដាបទទាំងនោះ បទថា **យានិ** សេចក្ដីថា ភូតពួកណា មានសក្តិ តិចក្តី ច្រើនក្តី ។

បទថា **ភូតេ** បានដល់ ក្នុងបទេសនេះ លោកពោលសំដៅដល់ទីប្រជុំគ្នាក្នុងខណៈនោះ ។

បទថា **ភូតានិ** នេះ **ភូត** សព្ទ ប្រើក្នុងអត្ថច្រើនយ៉ាង គឺរបស់ដែលពិត បញ្ចក្ខន្ធ រូបទាំង ៤ ព្រះខីណាស្រព សត្វទាំងពួង ដើមឈើ ពួកសត្វខាងក្រោមចាតុម្មហារាជិកា ។

មកក្នុងអត្ថថា របស់ដែលពិត ដូចក្នុងប្រយោគជាដើមថា **ភូតស្មឹ ចាចិត្តិយំ** ភិក្ខុណាមួយ ប្រាប់ឧត្តរិមនុស្សធម្មដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយៈ ព្រោះឧត្តរិមនុស្សធម្មនោះ ភិក្ខុមានពិតមែន ។

មកក្នុងអត្ថថា បញ្ចក្ខន្ធ ដូចក្នុងប្រយោគជាដើមថា **ភូតមិទន្តិ ភិក្ខវេ សមនុបស្សថ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញនូវខន្ធបញ្ចកៈនេះដែលកើតឡើងហើយឬទេ ។

មកក្នុងអត្ថថា រូប ៤ យ៉ាង មានបឋវីធាតុជាដើម ដូចក្នុងប្រយោគជាដើមថា **ចត្តារោ ខោ ភិក្ខុ មហាភូតា ហេតុ** ម្នាលភិក្ខុ មហាភូតទាំង ៤ ជាហេតុ មហាភូតទាំង ៤ ជាបច្ច័យ ដូច្នេះជាដើម ។

មកក្នុងអត្ថថា ព្រះខីណាស្រព ដូចក្នុងប្រយោគជាដើមថា **យោ ច កាលឃសោ ភូតោ** បុគ្គលណា ជាអ្នកទំពាស៊ីនូវពេលវេលា ដូច្នេះ ។

មកក្នុងអត្ថថា សត្វទាំងពួង ដូចក្នុងប្រយោគជាដើមថា **សព្វេវ និក្ខិបិស្សន្តិ ភូតា លោកេ សមុស្សយំ** សត្វទាំងឡាយនេះឯង តែងលះបង់

រាងកាយក្នុងលោក ដូច្នេះ ។

មកក្នុងអត្ថថា ដើមឈើជាដើម ដូចក្នុងប្រយោគជាដើមថា **ភូតគាមបាតព្យតាយ បាចិត្តិយំ** ភិក្ខុធ្វើភូតគាម មានឈើ និងស្មៅជាដើមឲ្យវិនាស ត្រូវអាបត្តិបាចិត្តិយៈ ដូច្នេះ ។

មកក្នុងអត្ថថា ពួកសត្វ ខាងក្រោមទេវតាជាន់ចាតុម្មហារាជ ដូចក្នុងប្រយោគជាដើមថា **ភូតេ ភូតតោ សញ្ជានាតិ** បុថុជ្ជនសម្គាល់នូវពួកសត្វថាជាសត្វពិត ដូច្នេះ ។

ក្នុងរតនសូត្រនេះ បណ្ឌិតគប្បីឃើញថា **ភូត** សព្ទ សំដៅដល់អមនុស្សទាំងឡាយដោយចំពោះ ។ បទថា **សមាគតានិ** បានដល់ ប្រជុំព្រមគ្នាហើយ ទេវតាទាំងឡាយដែលកើតហើយនាផែនដី ឈ្មោះថា **ភុម្មានិ ។ វា** សព្ទ ប្រើក្នុងវិកប្បត្ថ ប្រែថា ឬ ដោយអត្ថថា កំណត់ ព្រោះហេតុនោះទើបព្រះមានព្រះភាគធ្វើវិកប្បតែមួយយ៉ាងនេះថា ភុម្មទេវតាទាំងឡាយពួកណា ឬភូតទាំងឡាយពួកណា ដែលប្រជុំគ្នាហើយ ក្នុងទីនេះ ហើយត្រាស់ថា **យានិ វ អន្តលិក្ខេ** ដើម្បីធ្វើវិកប្បទី ២ យ៉ាងទៀត អធិប្បាយថា ភូតទាំងឡាយណាកើតហើយក្នុងអាកាស ភូតទាំងនោះមកប្រជុំគ្នាហើយក្នុងទីនេះ ។

ពាក្យថា **ភូត** នេះ ភូតទាំងឡាយដែលកើតហើយតាំងអំពីយាមា រហូតដល់អកនិដ្ឋកភព គប្បីជ្រាបថាជាភូតក្នុងអាកាស ព្រោះកើតក្នុងវិមាន ដែលប្រាកដក្នុងអាកាស ។ ភូតទាំងឡាយដែលស្ថិតនៅត្រង់ដើមឈើ និងវល្លិ

ជាដើម ទាបជាងអាកាសនោះ តាំងអំពីភ្នំសិនេរុ រហូតដល់ភូតដែលនៅលើផែនដី និងដែលកើតហើយនៅលើផែនដី ភូតទាំងអស់នោះ គប្បីជ្រាបថា ជាភូតដែលនៅលើផែនដី ព្រោះកើតហើយលើផែនដី និងក្នុងទីទាំងឡាយមានដើម ឈើ វល្លិ និងភ្នំជាដើម ដែលទាក់ទងដោយផែនដី ។ ព្រះមានព្រះភាគ ទ្រង់វិកប្ប គឺកំណត់អមនុស្សភូតទាំងអស់ ដោយ ២ បទថា **ភុម្មានិ វា យានិ វា អន្តលិក្ខេ** ហើយកំណត់ដោយ ១ បទទៀត ត្រាស់ថា **សព្វេវ ភូតា សុមនា ភវន្តុ ។**

បទថា **សព្វេ** បានដល់ មិនមានចំណែកសល់ សព្ទថា **ឯវ** ប្រើក្នុងអត្ថនៃអវធារណៈ អធិប្បាយថា មិនវៀរសូម្បីតែមួយសព្ទ អមនុស្សទាំងឡាយ ឈ្មោះថា **ភូត ។**

ពីរបទថា **សុមនា ភវន្តុ** បានដល់ ចូរជាអ្នកមានចិត្តដល់នូវសេចក្ដីសុខ គឺជាអ្នកមានបីតិ និងសោមនស្សកើតហើយ ។

ពីរសព្ទថា **អថោបិ** ជានិបាតទាំង ២ ពាក្យ ប្រើក្នុងអត្ថនៃវាក្យបទវិកប្បត្ថ ដើម្បីប្រកបក្នុងកិច្ចដទៃ ។

បីបទថា **សក្កច្ច សុណន្តុ ភាសិតំ** សេចក្ដីថា សូមឲ្យភូតទាំងពួងតាំងចិត្ត គឺធ្វើទុកក្នុងចិត្ត បានដល់ ប្រមូលមកដោយចិត្តទាំងអស់ ចូរស្ដាប់ទេសនារបស់តថាគត ដែលនាំសម្បត្តិជាទិព្វ និងលោកុត្តរសុខមកឲ្យ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់កំណត់ភូតសត្វទាំងឡាយ ដោយពាក្យ

ដែលកំណត់មិនពិតប្រាកដថា **យានីធ ភូតានិ សមាគតានិ** យ៉ាងនេះ ហើយ ទើបទ្រង់កំណត់ដោយពីរបទដទៃទៀតថា **ភុម្មានិ វា យានិ វ អន្ត-លិក្ខេ** បន្ទាប់អំពីនោះ ទ្រង់ធ្វើឲ្យដូចគ្នាទៀតថា **សព្វេវ ភូតា** ហើយទ្រង់ប្រកបក្នុងអាសយសម្បត្តិ ដោយពាក្យនេះថា **សុមនា ភវន្តុ** ហើយទ្រង់ប្រកបក្នុងបយោគសម្បត្តិ ដោយពាក្យនេះថា **សក្កច្ច សុណន្តុ ភាសិតំ** ។ ម្យ៉ាងទៀត ទ្រង់ប្រកបក្នុងយោនិសោមនសិការសម្បត្តិ និងក្នុងឃោស-សម្បត្តិយ៉ាងនោះ ទ្រង់ប្រកបក្នុងអត្តសម្មាបណិធិសម្បត្តិ និងសប្បុរិសូប-និស្សយសម្បត្តិ និងទ្រង់ប្រកបក្នុងសមាធិសម្បត្តិ បញ្ញាសម្បត្តិ និងហេតុ-សម្បត្តិយ៉ាងនោះ ទើបពោលគាថានេះ ។

បទថា **តស្មាហិ ភូតា** ជាដើម ជាគាថាទី ២ ។ ក្នុងបណ្ដាបទទាំងនោះ បទថា **តស្មា** ជាពាក្យប្រាប់ហេតុ បទថា **ភូតា** ជាពាក្យអញ្ជើញ ។

បទថា **និសាមេថ** ប្រែថា ចូរស្ដាប់ ។ បទថា **សព្វេ** បានដល់ មិនមានចំណែកសេសសល់ លោកបានអធិប្បាយដូចម្ដេច លោកបានអធិប្បាយថា ព្រោះហេតុដែលអ្នកទាំងឡាយបានលះទិព្វស្ថាន និងឧបភោគសម្បត្តិ បរិភោគសម្បត្តិ បានមកប្រជុំគ្នាក្នុងទីនេះ ដើម្បីស្ដាប់ធម៌ មិនមែនមកដើម្បីមើលអ្នករបាំសម្ដែងនូវការរាំឡើយ ព្រោះដូច្នោះ សូមភូតទាំងឡាយស្ដាប់ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ត្រាស់ថា **សុមនា ភវន្តុ** និង **សក្កច្ច សុណន្តុ** ព្រះដ៏មានព្រះភាគទ្រង់ឃើញថា ទេវតាទាំងនោះ ជាអ្នកមានចិត្តល្អ

និងឃើញថា ទេវតាទាំងនោះបំណងនឹងស្តាប់ដោយគោរព ទើបត្រាស់ថា ព្រោះហេតុដែលអ្នកទាំងឡាយ ប្រកបដោយអត្តសម្មាបណិធិ យោនិសោ-មនសិការ និងអាសយសុទ្ធិ ដោយភាពជាអ្នកមានចិត្តល្អ ទាំងប្រកបដោយបយោគសុទ្ធិទាំងឡាយ ដោយមានសប្បុរិសូបនិស្សយៈ និងបរតោឃោសៈជាបទដ្ឋាន ព្រោះការស្តាប់ដោយគោរព ដូច្នោះឯង ចូរភូតទាំងពួង តាំងចិត្តស្តាប់ ។

ម្យ៉ាងទៀត ពាក្យណាដែលព្រះមានព្រះភាគ ត្រាស់ក្នុងទីបំផុតនៃគាថាដំបូងថា **ភាសិតំ** ព្រះមានព្រះភាគទ្រង់មិនអាងដល់ពាក្យនោះដោយភាពជាហេតុ ទើបត្រាស់ថា ធម្មតាភាសិតរបស់តថាគត បុគ្គលបានដោយលំបាកក្រៃលែង ព្រោះខណៈដែលវៀរចាកខណៈទាំងពួង ជាខណៈដែលរកបានដោយក្រផង ជាពាក្យមានអានិសង្សជាអនេកផង ព្រោះប្រព្រឹត្តទៅដោយបញ្ញាគុណ និងករុណាគុណ តែតថាគតត្រូវពោលពាក្យនោះ ទើបពោលថា **សុណន្តុ ភាសិតំ** ទើបជាពាក្យអធិប្បាយ ពាក្យដែលជាគាថានេះថា **តស្មា ហិ ភូតា និសាមេថ សព្វេ** ដូច្នេះ ។

ព្រះមានព្រះភាគទ្រង់ប្រកបហេតុនោះយ៉ាងនេះហើយ ទើបទ្រង់ប្រកបភូតឲ្យតាំងចិត្តស្តាប់ភាសិតរបស់ព្រះអង្គ ទ្រង់បានផ្តើមដើម្បីនឹងត្រាស់ពាក្យដែលគួរស្តាប់ថា **មេត្តំ ករោថ មានុសិយា បជាយ** ដូច្នេះ ។

អត្ថនៃគាថានោះថា ពួកសត្វ គឺមនុស្សនេះដែលឧបទ្រវទាំង ៣ ប្រទូស្ត

ហើយ ចូរអ្នកទាំងឡាយចូលទៅតាំងមេត្តា គឺមិត្តភាព បានដល់ ភាពជាអ្នកមានអធ្យាស្រ័យឧបការៈក្នុងពួកសត្វដែលជាមនុស្សនោះ ។ តែអាចារ្យពួកខ្លះពោលថា **មានុសិយំ បជំ** ( នូវពួកមនុស្ស ) ពាក្យនោះ មិនត្រឹមត្រូវ ព្រោះមិនមែនជាសត្តមីវិភត្តិ ហើយអាចារ្យពួកដទៃក៏ពណ៌នាអត្ថណា អត្ថនោះក៏មិនត្រូវ តែក្នុងគាថានេះ មានពាក្យអធិប្បាយថា តថាគតមិនហៅយ៉ាងនោះ ព្រោះកម្លាំងនៃភាពជាធំថា ជាព្រះពុទ្ធឡើយ តែជម៉ណាជាប្រយោជន៍ ឧបការៈដល់អ្នកទាំងឡាយផង ដល់ពួកមនុស្សផង តថាគត ក៏បានពោលវត្ថុនោះថា អ្នកទាំងឡាយ ចូរផ្សាយមេត្តាចិត្តក្នុងពួកមនុស្ស ដូច្នេះ ។

ក្នុងពាក្យថា **មេត្តំ ករោថ មានុសិយា បជាយ** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

ជនពួកណា ផ្សាយមេត្តាចិត្ត ដោយអំណាចនៃព្រះសូត្រទាំងឡាយជាដើម យ៉ាងនេះថា

បើបុគ្គលមានចិត្តមិនបានប្រទូស្តសត្វណាមួយ ឈ្មោះថា ជាប់មេត្តា កុសលក៏រមែងកើតមាន ដោយហេតុនោះ ចំណែកព្រះអរិយៈមានចិត្តអនុគ្រោះសត្វទាំងឡាយទាំងពួង តែងធ្វើបុណ្យច្រើន ពួកស្តេចណាដែលប្រាកដដូចជាឥសី បានឈ្នះនូវផែនដីដែលពាសពេញដោយមនុស្សសត្វ កាលឲ្យទាន ប្រព្រឹត្តរឿយៗ ( ដោយសង្គហវត្ថុ ៤ ប្រការ ) គឺយាសវៃ ក្នុងការ

ទំនុកបម្រុងជញ្ជាតិ ១ ឈ្លាសវៃក្នុងការទំនុកបម្រុងមនុស្ស ១ ការចងចិត្តមនុស្ស ១ ពោលពាក្យជាទីស្រឡាញ់ ១ មិនបាច់ប្រើរនុកទ្វារផ្ទះឡើយ ។

និងដោយអំណាចនៃអានិសង្សរបស់មេត្តា ១១ យ៉ាង មេត្តារបស់ជនទាំងនោះ គប្បីជ្រាបថា មានប្រយោជន៍ បុគ្គលផ្សាយមេត្តាក្នុងទេវតាពួកណា ដោយអំណាចនៃអត្ថទាំងឡាយ មានជាដើមយ៉ាងនេះថា បុរសដែលមានទេវតាអនុគ្រោះហើយ រមែងជួបប្រទះនូវសេចក្ដីចម្រើនសព្វកាល ដូច្នេះ មេត្តារបស់ជនទាំងនោះ គប្បីជ្រាបថា មានប្រយោជន៍ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងលក្ខណៈនៃមេត្តាចិត្ត ២ យ៉ាងដូចពោលមកហើយនោះថា មានប្រយោជន៍យ៉ាងនេះ ទើបត្រាស់ថា **មេត្តំ ករោថ មានុសិយា បជាយ** ប្រែថា អ្នកទាំងឡាយ ចូរផ្សាយមេត្តាចិត្តទៅក្នុងពួកមនុស្ស ដូច្នេះ ឥឡូវនេះ កាលសម្ដែងឧបការៈ ទើបត្រាស់ថា

ពួកមនុស្សណា នាំនូវពលិកម្ម ក្នុងវេលាថ្ងៃ ឬវេលាយប់ ព្រោះហេតុនោះ សូមអ្នកទាំងឡាយ កុំប្រហែស ចូររក្សានូវមនុស្សទាំងនោះ ។

អត្ថនៃគាថានោះថា មនុស្សទាំងឡាយណាសាងរូបទេវតាដោយចិត្រកម្ម និងបដិមាកម្មជាដើម ចូលទៅកាន់ចេតិយ និងដើមឈើទាំងឡាយ ហើយធ្វើពលិកម្មក្នុងពេលថ្ងៃ ឧទ្ទិសទេវតាទាំងឡាយក្ដី ធ្វើពលិកម្មក្នុងពេលយប់ ខាងរនោចជាដើមក្ដី ឬថ្វាយសលាកភត្តជាដើម ហើយធ្វើពលិកម្មក្នុងពេល

ថ្ងៃ ដោយការឧទ្ទិសចំណែកបុណ្យឲ្យដល់អារក្ខទេវតា រហូតដល់ព្រហ្មក្តី និង ឲ្យមានការស្តាប់ធម៌ជាដើមអស់យប់ ដោយការលើកឆត្រ និងអុជប្រទីប បូជាផ្កា ហើយធ្វើពលីកម្មក្នុងវេលាយប់ ដោយការឧទ្ទិសនូវចំណែកបុណ្យក្តី មនុស្សទាំងនោះដែលពួកអ្នកមិនគប្បីរក្សាបានដូចម្តេច ព្រោះថា មនុស្សទាំង នោះ ធ្វើពលីកម្មឧទ្ទិសដល់ពួកអ្នកប៉ុណ្ណោះ ទាំងពេលថ្ងៃ និងពេលយប់ យ៉ាងនេះ ។

ពាក្យថា **តស្មា ហិ នេ** សេចក្តីថា ព្រោះដូច្នោះ អ្នកទាំងឡាយ ចូររក្សា គឺចូរគ្រប់គ្រងមនុស្សទាំងនោះ ព្រោះហេតុនៃពលីកម្ម ពួកអ្នក ចូរ កម្ចាត់នូវវត្ថុដែលមិនជាប្រយោជន៍របស់មនុស្សទាំងនោះ ហើយនាំវត្ថុដែល ជាប្រយោជន៍មកឲ្យ ពួកអ្នក ចូរជាបុគ្គលមិនប្រមាទ តាំងនូវភាពជាអ្នក កតញ្ញូនោះ ក្នុងចិត្តជានិច្ចចុះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងភាពដែលមនុស្សទាំងឡាយ មាន ឧបការៈចំពោះទេវតាទាំងឡាយយ៉ាងនេះហើយ ទើបទ្រង់ផ្តើមដើម្បីប្រកប សច្ចវាចា ដោយន័យជាដើមថា **យង្កិញ្ចិ វិត្តំ** ដើម្បីការចូលទៅស្ងប់នូវឧប- ទ្រពរបស់មនុស្សទាំងឡាយនោះ ដើម្បីស្តាប់ធម៌របស់ទេវតា និងមនុស្ស ទាំងឡាយ ដោយទ្រង់ប្រកាសពុទ្ធគុណជាដើម ។

ក្នុងបទទាំងនោះ បទថា **យង្កិញ្ចិ** បានដល់ វត្ថុណាមួយដែលមិនមាន ចំណែកសេសសល់ ដោយអំណាចនៃការកំណត់មិនពិតប្រាកដ គឺវត្ថុណា

មួយដែលបានរៅហារក្នុងវត្ថុនោះៗ ។

ទ្រព្យ ឈ្មោះថា **វិត្តំ** ព្រោះអត្ថថា ធ្វើនូវការត្រេកអរនៃចិត្តឲ្យកើតឡើង ។

ដោយពាក្យថា **ឥធ វា** នេះ ព្រះមានព្រះភាគទ្រង់សម្ដែងដល់មនុស្ស-លោក ។ បទថា **ហុរំ វា** ព្រះមានព្រះភាគ ទ្រង់សម្ដែងដល់លោកដ៏សេសក្រៅអំពីមនុស្សលោកនោះ ។ បទថា **ហុរំ វា** នោះ គប្បីជ្រាបថាសំដៅដល់លោកទាំងអស់ វៀរមនុស្សលោក ព្រោះទ្រង់ត្រាស់បន្តថា **សគ្គេសុ វា** សំដៅដល់ លោកដ៏សេស មាននាគ និងគ្រុឌជាដើម ព្រោះលោកបានពោលខាងដើម វៀរមនុស្សលោក និងស្ថានសួគ៌ ។ ដោយបទទាំង ២ នេះ វត្ថុណាជាគ្រឿងប្រើប្រាស់ ជាគៀងប្រដាប់ ឬបរិភោគរបស់មនុស្សទាំងឡាយ មានមាសប្រាក់កែវមុក្តា កែវមណី កែវពិទូរ្យ កែវប្រពាលកែវទទឹម និងកែវឆ្នូតជាដើម ឬទ្រព្យជាគ្រឿងត្រេកអរឯណារបស់នាគ និងគ្រុឌជាដើម ដែលកើតហើយក្នុងវិមានកែវ លើផែនដី ដែលដេរដាសទៅដោយខ្សាច់មុក្តា និងខ្សាច់កែវក្នុងភពទាំងឡាយ ដែលមានទទឹងជាង ១០០យោជន៍ វត្ថុនោះ ព្រះមានព្រះភាគទ្រង់សម្ដែងហើយយ៉ាងនេះ ។

ពាក្យថា **សគ្គេសុ វា** បានដល់ ទេវលោកជាន់កាមាវចរ និងរូបាវចរទាំងឡាយ ។ ទេវតាទាំងនោះ ឈ្មោះថា **សគ្គ** ព្រោះអត្ថថា ឃ្លាតទៅ គឺរមែងទៅដោយកម្មដ៏ល្អគួត ។

ម្យ៉ាងទៀត ដែលឈ្មោះថា **សត្ត** ព្រោះអត្ថថា ជាទីកន្លែងដ៏ប្រសើរ ដោយល្អ ដូច្នេះក៏មាន ។

បទថា **យំ** បានដល់ ទ្រព្យឯណាដែលមានម្ចាស់ក្តី មិនមានម្ចាស់ក្តី ។ ក្នុងបទថា **រតនំ** នេះ មានអត្ថវិគ្គហៈថា វត្ថុណារមែងនាំមក គឺរមែងនាំមកនូវការត្រេកអរ បានដល់ រមែងញ៉ាំងការត្រេកអរឲ្យកើត ឲ្យចម្រើន ហេតុនោះ ទើបវត្ថុនោះ ឈ្មោះថា **រតន** ។ វត្ថុណាមួយ ដែលបុគ្គលធ្វើការបូជា មានតម្លៃច្រើន ថ្លឹងមិនបាន ឃើញបានដោយលំបាក និងមិនមែនជារបស់ដែលសត្វថោកថយបរិភោគ ពាក្យនេះ ជាឈ្មោះរបស់រតនៈនោះ សមដូចព្រះមានព្រះភាគត្រាស់ថា

> វត្ថុដែលបុគ្គលធ្វើនូវការកោតក្រែង មានតម្លៃច្រើន ថ្លឹងថ្លែងមិនបាន ឃើញបានលំបាក និងមិនមែនរបស់ដែលសត្វថោកថយបរិភោគ ព្រោះហេតុនោះ ទើបហៅថា **រតន** ដូច្នេះ ។

ពាក្យថា **បណីតំ** បានដល់ ប្រសើរបំផុត គឺមានតម្លៃខ្ពស់ បានដល់ មិនមែនមានតម្លៃតិច គឺជាទីពេញចិត្ត ។

ដោយបទដែលជាព្រះគាថានេះ រតនៈណាដែលមានម្ចាស់ក្នុងស្ថានសួគ៌ទាំងឡាយ មានវិមានដែលសម្រេចដោយរតនៈទាំងពួង ដែលមានប្រមាណច្រើនរយយោជន៍ជាអនេក ដូចជាសុធម្មសភា និងវេជយន្តប្រាសាទជាដើមក្តី រតនៈណាដែលមិនមានម្ចាស់នៅក្នុងវិមានទទេ ក្នុងកាលសត្វទាំងឡាយធ្វើនូវ

អបាយភូមិឲ្យពេញ ព្រោះវៀរចាកពុទ្ធុប្បាទកាល ឬថា រតនៈឯណាដែលជា រតនៈមិនមានម្ចាស់ ដែលនៅត្រង់ផែនដី មហាសមុទ្រ និងព្រៃហិមពាន្តជាដើម រតនៈនោះ ឈ្មោះថា ព្រះមានព្រះភាគសម្តែងហើយ ។

បទថា **ន** ក្នុងបាទគាថានេះថា **ន នោ សមំ អត្ថិ តថាគតេន** ដូច្នេះ ប្រើក្នុងអត្ថបដិសេធ ។

សព្ទថា **នោ** ប្រើក្នុងអត្ថអវធារណៈ។ បទថា **សមំ** បានដល់ ស្មើ ។ បទថា **អត្ថិ** បានដល់ មាន ។ បទថា **តថាគតេន** បានដល់ ដោយព្រះពុទ្ធ លោកអធិប្បាយដូចម្តេច លោកពោលអធិប្បាយថា ព្រះមានព្រះភាគ ទ្រង់ប្រកាសទ្រព្យ និងរតនៈនេះ ។ ក្នុងពាក្យថា **ឧត្តម** និង **រតនៈ** នេះ រតនៈឯណាមួយដែលស្មើដោយពុទ្ធរតនៈមិនមាន ។

ពិតហើយ រតនៈនោះ ឈ្មោះថា **រតន** ព្រោះអត្ថថា ដែលបុគ្គលធ្វើនូវការកោតក្រែង គឺអ្វី គឺចក្ករ័តន៍ និងមណីរ័តន៍របស់ស្តេចចក្រពត្តិ កាលរតនៈកើតឡើងហើយ មហាជនមិនធ្វើការបូជាក្នុងទីដទៃ បុគ្គលណានឹងកាន់យកផ្កា និងគ្រឿងក្រអូបជាដើមទៅកាន់យក្ខដ្ឋាន និងភូតដ្ឋាន មិនមាន ។ បុគ្គលទាំងអស់ នឹងធ្វើនូវការកោតក្រែងបូជានូវចក្ករ័តន៍ និង មណីរ័តន៍ប៉ុណ្ណោះ ប្រាថ្នានូវពរនោះៗ វត្ថុដែលគេប្រាថ្នាហើយ និងប្រាថ្នាហើយ ណាមួយ រមែងសម្រេចរតនៈបាន ។ រតនៈនោះ ដែលស្មើដោយពុទ្ធរតនៈ មិនមាន បើឈ្មោះថា រតនៈ ព្រោះអត្ថថា បុគ្គលធ្វើនូវការកោតក្រែងហើយ

សោត ព្រះតថាគតប៉ុណ្ណោះ ចាត់ជារតនៈ ។

ពិតហើយ កាលព្រះតថាគតកើតឡើងហើយ ទេវតា និងមនុស្សដែលមានសក្តិធំពួកណាមួយ មានទេវតា និងមនុស្សទាំងនោះ មិនបានធ្វើនូវការកោតក្រែងក្នុងទីដទៃឡើយ ទាំងមិនព្រមបូជានូវវត្ថុដទៃណា ពិតហើយ សហម្បតីព្រហ្មបូជាព្រះតថាគតដោយកម្រងរតនៈប៉ុនភ្នំសិនេរុ ទេវតា និងមនុស្សដទៃ មានព្រះបាទពិម្ពិសារ ព្រះបាទកោសល និងអនាថបិណ្ឌិកជាដើម ក៏បូជាព្រះតថាគតតាមកម្លាំង ព្រះបាទអសោកមហារាជទ្រង់លះរាជសម្បត្តិ ៩៦ កោដិ ឲ្យសាងព្រះវិហារ ៨៤០០០ កន្លែង ពេញជម្ពូទ្វីប ឧទ្ទិសដល់ព្រះមានព្រះភាគ សូម្បីបរិនិព្វានហើយ នឹងពោលទៅថ្វីដល់ជនដទៃដែលធ្វើសេចក្តីកោតក្រែង មួយប្រការទៀត ការធ្វើនូវការកោតក្រែង និងការគោរពរមែងប្រព្រឹត្តទៅចំពោះទីប្រសូតិ ទីត្រាស់ដឹង ទីសម្តែងធម្មចក្ក ទីបរិនិព្វាន ឬបដិមាកម្ម និងចេតិយដ្ឋានជាដើមរបស់ព្រះកស្សបសម្ពុទ្ធដែលបរិនិព្វានទៅហើយ ដូចគ្នានឹងធ្វើការបូជា សម្តែងសេចក្តីគោរពចំពោះព្រះមានព្រះភាគ ឈ្មោះថា រតនៈដែលស្មើដោយព្រះតថាគតមិនមាន ព្រោះអត្ថថា ដែលបុគ្គលធ្វើការបូជាយ៉ាងនេះ ។

ម្យ៉ាងទៀត រតនៈនោះ បានឈ្មោះថា **រតន** ព្រោះអត្ថថា មានតម្លៃច្រើន ដូចគ្នានឹងសំពត់ដែលធ្វើក្នុងដែនកាសី ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សំពត់កាសិក ទោះចាស់ មានពណ៌ល្អ មានសម្ផស្ស

ក៏ស្រួល ទាំងមានតម្លៃក៏ច្រើន ដូច្នេះ ។ សំពត់កាសិកពស្ត្រ ដែលស្មើដោយពុទ្ធរ័តន៍ មិនមាន ។ បើសំពត់កាសិកពស្ត្រនោះ ឈ្មោះថាជារតនៈ ព្រោះអត្ថថា មានតម្លៃច្រើនសោត ព្រះតថាគតក៏ជារតនៈ ដ្បិតថា ព្រះតថាគត តែងទទួលសំពត់បង្សុកូលរបស់ជនពួកណា សំពត់បង្សុកូលនោះរបស់ជនទាំងនោះ មានផលច្រើន មានអានិសង្សច្រើន ដូចគ្នានឹងសំពត់របស់ព្រះបាទអសោកមហារាជ ។ សំពត់របស់ព្រះបាទអសោកមហារាជនោះ នឹងគប្បីជារតនៈបាន ព្រោះជាសំពត់ដែលមានតម្លៃច្រើន រតនៈដែលស្មើដោយព្រះតថាគត មិនមាន ព្រោះអត្ថថា មានតម្លៃច្រើនយ៉ាងនេះ ។ ក្នុងរឿងនៃរតនៈនេះ គប្បីជ្រាបដល់សុត្តបទ ដែលលើកមកសម្តែងឲ្យឃើញថា វាចាដែលពោលថា មានតម្លៃច្រើននោះ មិនខុស ដូចព្រះតម្រាស់ក្នុង ( អង្គុត្តរនិកាយតិកនិបាត ) ថា

> ប្រសិនបើបុគ្គលនោះ ទទួលចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខាររបស់ពួកជនណា ការទទួលនោះរមែងមានផលច្រើន មានអានិសង្សច្រើនដល់ពួកជននោះ បានជាតថាគតពោលយ៉ាងនេះ ព្រោះបុគ្គលនោះមានតម្លៃច្រើន ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកនោះ មានតម្លៃច្រើន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ដូច្នេះ ។

ឈ្មោះថា រតនៈ ស្មើដោយព្រះតថាគត រមែងមិនមាន ព្រោះអត្ថថា មានតម្លៃច្រើនយ៉ាងនេះ ។ ម្យ៉ាងទៀត រតនៈ សូម្បីបានឈ្មោះថា **រតន** ព្រោះអត្ថថា ប្រឹងមិនបាន គឺដូចម្តេច គឺចក្ករ័តន៍ដែលកើតឡើងដល់ស្តេចចក្រពត្តិ ដែលមានដុំសម្រេចដោយកែវឥន្ទនីល មានកាំ ១០០០ សម្រេចដោយរតនៈ ៧ ប្រការ មានខ្នងកង់សម្រេចដោយកែវប្រពាល មានទីតសម្រេចដោយមាសដែលមានកាំរលោង នៅលើកាំគ្រប់ៗ ១០ កាំ ដែលគេធ្វើដើម្បីឲ្យត្រូវខ្យល់ ហើយលាន់ឮនូវសំឡេង មានសំឡេងដូចតន្ត្រីប្រកបដោយអង្គ ៥ ដែលបន្លឺបានពីរោះ ដូច្នោះ នៅសងខាងនៃដុំ មានមុខសីហៈ ២ នៅខាងក្នុងមានរន្ធដូចរូបកង់រទេះ ដូច្នោះ បុគ្គលដែលធ្វើ ឬឲ្យធ្វើនូវចក្ក-រ័តន៍នោះមិនមាន ចក្ករ័តន៍នោះប្រាកដឡើង ដោយឧតុដែលមានកម្មជាបច្ច័យ ។

ព្រះរាជាទ្រង់បំពេញចក្កពត្តិវត្ត ១០ ប្រការ ទ្រង់កក់ព្រះសីសៈក្នុងថ្ងៃ ១៥ ដែលជាថ្ងៃឧបោសថ ទ្រង់រក្សាឧបោសថ យាងទៅកាន់ខាងលើប្រាសាទដ៏ប្រសើរ គង់រឭកដល់សីលទាំងឡាយ បានឃើញចក្ករ័តន៍ដែលតាំងឡើងដូចព្រះចន្ទពេញវង់ និងដូចព្រះអាទិត្យ ដូច្នោះ ដែលបុគ្គលរមែងបានឮនូវសំឡេងតាំងអំពី ១២ យោជន៍ មានពណ៌ប្រាកដតាំងអំពី ៣ យោជន៍ដែលមហាជនកើតកោលាហលយ៉ាងក្រៃលែងថា ប្រហែលជាមានព្រះចន្ទ ឬព្រះអាទិត្យរះឡើងជាគម្រប់ ២ ដូច្នេះប្រាកដ បានអណ្តែតមកខាងលើព្រះនគរប្រាកដក្នុងទិសខាងកើតនៃរាជបុរី មិនខ្ពស់ពេក មិនទាបពេក អណ្តែតប្រាកដ

ហាក់មិនញាប់ញ័រក្នុងទីដែលសមគួរ ដើម្បីឲ្យមហាជនបូជាដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម ។

ហត្ថីរ័តន៍ដែលកើតឡើងតាមស្តេចចក្រពត្តិអង្គនោះ ជាដំរីស មានជើងក្រហម ជាសត្វរឹងប៉ឹង មានឫទ្ធិ ទៅក្នុងអាកាសបាន កើតអំពីត្រកូលឧបោ-សថ ឬត្រកូលឆទ្ទន្ត បើមកអំពីត្រកូលឧបោសថ ជាដំរីមេហ្វូង បើមកអំពីដំរីឆទ្ទន្ត ជាកូនដំរីដែលកើតក្រោយគេ មានការសិក្សាអប់រំល្អ គួរដល់ការទូន្មាន ដំរីនោះនាំបរិស័ទទៅអស់ ១២ យោជន៍ ប្រទក្សិណជុំវិញជម្ពូទ្វីប នាំគ្នាមកកាន់រាជធានីរបស់ខ្លួនក្នុងកាលមុនអាហារព្រឹកនោះឯង ។

អស្សរ័តន៍ ដែលកើតតាមព្រះរាជានោះ ក៏ជាសេះស ជើងក្រហម ក្បាលខ្មៅ រោមដូចស្មៅយាប្លង មកអំពីត្រកូលសេះវលាហក ពាក្យដ៏សេសក្នុងរឿងសេះនេះ គប្បីជ្រាបដូចគ្នានឹងដំរីនោះឯង ។

មណីរ័តន៍កើតតាមព្រះរាជានោះ កែវមណីនោះជាកែវពិទូរ្យ ភ្លឺល្អរុងរឿងដូចថ្ងៃ ល្អទាំង ៨ ជ្រុង ដូចគ្នានឹងដុំរទេះ មកអំពីភ្នំវេបុល្ល កែវមណីនោះឡើងកាន់កំពូលទង់របស់ព្រះរាជាហើយ រមែងភ្លឺទៅក្នុងទីងងឹត ដែលប្រកបដោយអង្គ ៤ បានមួយយោជន៍ដោយជុំវិញ ពួកមនុស្សទាំងឡាយសម្គាល់ថា ជាពេលថ្ងៃ ហើយប្រកបការងារទាំងឡាយ ដោយហោចរមែងឃើញបានសូម្បីតែស្រមោចខ្មៅ និងស្រមោចក្រហម ។

ឥត្ថីរ័តន៍កើតតាមស្តេចចក្រពត្តិ ជាអគ្គមហេសីដោយប្រក្រតី ឬក៏មក

អំពីឧត្តរកុរុទ្វីប ឬក៏មកអំពីត្រកូលមទ្ទរាជ វៀរចាកទោស ៦ ប្រការ មានខ្ពស់ពេកជាដើម មានពណ៌សម្បុរល្អក្រៃលែងជាងមនុស្ស តែមិនដល់ពណ៌សម្បុរដែលជាទិព្វ ក្នុងពេលព្រះរាជារងា កាយព្រះនាងក៏ក្តៅ ក្នុងពេលព្រះរាជាក្តៅ ព្រះកាយរបស់នាងក៏ត្រជាក់ មានសម្ផស្សទន់ដូចសំឡីដែលគេផ្ចិតអស់ ៧ ដង មានក្លិនខ្លឹមចន្ទន៍ផ្សាយចេញអំពីព្រះកាយ មានក្លិនឧប្បលផ្សាយចេញអំពីព្រះឱស្ឋ ប្រកបដោយគុណជាអនេក មានការក្រោកឡើងមុនជាដើម ។

គហបតិរ័តន៍ ដែលកើតឡើងតាមស្តេចចក្រពត្តិនោះ ជាសេដ្ឋីធ្វើនូវការងារតាមប្រក្រតីរបស់ព្រះរាជា ព្រោះគ្រាន់តែចក្ករ័តន៍កើតឡើងហើយទិព្វចក្ខុក៏កើតឡើង ព្រោះមានទិព្វចក្ខុហើយ ក៏ឃើញកំណប់ទ្រព្យដែលមានម្ចាស់ខ្លះ មិនមានម្ចាស់ខ្លះ ក្នុងទីប្រមាណមួយយោជន៍ដោយជុំវិញ គហបតី-កែវចូលទៅគាល់ព្រះរាជាហើយ បវារណាថា បពិត្រព្រះសម្មតិទេព សូមទ្រង់មានសេចក្តីខ្វល់ខ្វាយតិច ទូលបង្គំនឹងធ្វើកិច្ចដែលត្រូវធ្វើដោយទ្រព្យដើម្បីព្រះអង្គ ។

បរិនាយករ័តន៍ដែលកើតតាមស្តេចចក្រពត្តិនោះ ដែលជារាជឱរសច្បងរបស់ព្រះរាជា លុះមានចក្ករ័តន៍កើតឡើង ក៏មានបញ្ញា និងបដិភាណក្រៃលែងបរិនាយកកែវនោះ កំណត់ដឹងចិត្តរបស់បរិស័ទប្រមាណ ១២ យោជន៍ដោយចិត្តរបស់ខ្លួន ទាំងអាចធ្វើនូវការសង្កត់សង្កិន និងការលើកតម្កើង ចូលទៅ

គាល់ព្រះរាជា ហើយទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ជាអ្នកខ្វល់ខ្វាយតិច ទូលបង្គំគ្រប់គ្រងរាជសម្បត្តិដើម្បីព្រះអង្គ ។

រតនៈបែបនេះ ក៏ឈ្មោះថា រតនៈ ដូចព្រះអដ្ឋកថាចារ្យពោលថា មិនមានបុគ្គលណាថ្លឹងថ្លៃងបាន មានតម្លៃមិនអាចថ្លឹងដោយជញ្ជីង ឬកាត់ថ្លៃថាមានតម្លៃ ១ រយ ១ ពាន់ ឬ ១ កោដិ ។ រតនៈណាមួយ ក្នុងបណ្ដារតនៈទាំងនេះ ដែលស្មើដោយពុទ្ធរ័តន៍មិនមាន បើរតនៈដទៃណាគប្បីជារតនៈ ព្រោះអត្ថថា បុគ្គលថ្លឹងមិនបានហើយសោត ព្រះតថាគតនោះឯង ក៏ចាត់ជារតនៈ ដ្បិតថា ព្រះតថាគត ដែលមិនមានបុគ្គលណាអាចថ្លឹងដោយសីល សមាធិ ឬដោយគុណណាមួយ មានបញ្ញាគុណជាដើមបានឡើយ កាលកំណត់ថា ព្រះតថាគតនោះ មានគុណប៉ុណ្ណេះ បុគ្គលដែលស្មើ ឬដែលនឹងប្រៀបធៀបបាន ជាមួយព្រះតថាគតនេះមាន ព្រោះដូច្នោះ រតនៈ ស្មើដោយព្រះតថាគតមិនមាន ព្រោះអត្ថថា មិនមានអ្នកដទៃថ្លឹងថ្លៃងបានដូចពណ៌នាមក ដូច្នេះ ។

ម្យ៉ាងទៀត រតនៈណា ឈ្មោះថាជារតនៈ ព្រោះអត្ថថា ដែលបុគ្គលឃើញបានដោយលំបាក ដូចស្ដេចចក្រពត្តិ និងរតនៈរបស់ព្រះអង្គ មានចក្ក-រ័តន៍ជាដើម ដែលប្រាកដថា ឃើញបានលំបាក រតនៈនោះដែលស្មើដោយពុទ្ធរ័តន៍ មិនមាន បើឈ្មោះថា រតនៈ ព្រោះអត្ថថា ដែលបុគ្គលឃើញបានលំបាកហើយសោត ព្រះតថាគតក៏ចាត់ជារតនៈ រតនៈរបស់ស្ដេចចក្រពត្តិជាដើម ឬរតនៈដទៃជាអនេក ដែលកើតក្នុងកប្បមួយ ដែលស្មើនឹងពុទ្ធរ័តន៍

នឹងមានមកអំពីណា ព្រោះលោកសាបសូន្យទទេចាកព្រះតថាគត ដល់ទៅមួយអសង្ខេយ្យកប្ប ( ក៏មាន ) ដូច្នោះ ព្រះតថាគតនោះ ឈ្មោះថាឃើញបានលំបាក ព្រោះទ្រង់កើតឡើងក្នុងកាលខ្លះប៉ុណ្ណោះ សមដូចព្រះមានព្រះភាគត្រាស់ក្នុងកាលបរិនិព្វានថា

ម្នាលអានន្ទ ពួកទេវតាពោលទោសថា ពួកយើងមកអំពីចម្ងាយ ដើម្បីឃើញព្រះតថាគតៗ ជាព្រះអរហន្តសម្មាសម្ពុទ្ធកើតឡើងក្នុងលោក មានម្ដងៗ ក្នុងបច្ឆិមយាម នៃរាត្រីថ្ងៃនេះឯង បរិនិព្វាន នឹងមានដល់ព្រះតថាគត ក៏ភិក្ខុមានសក្តិធំនេះ មកឈររាំងនៅចំព្រះភក្ត្រនៃព្រះមានព្រះភាគ ពួកយើងមិនបានឃើញព្រះតថាគត ក្នុងបច្ឆិមកាលឡើយ ដូច្នេះ ។

រតនៈ ស្មើដោយព្រះតថាគត មិនមាន ព្រោះអត្ថថា បុគ្គលឃើញបានដោយក្រយ៉ាងនេះ ។

ម្យ៉ាងទៀត សូម្បីរតនៈដែលឈ្មោះថា ជារតនៈ ព្រោះអត្ថថា ដែលសត្វមិនថោកថយបរិភោគ គឺអ្វី គឺចក្ករ័តន៍ជាដើមរបស់ស្ដេចចក្រពត្តិ ព្រោះថា ចក្ករ័តន៍ជាដើមនោះ មិនបានកើតឡើងដើម្បីការបរិភោគរបស់ជនទាំង-ឡាយ ដែលមានទ្រព្យមួយសែនកោដិក្ដី របស់ជនទាំងឡាយ ដែលនៅលើប្រាសាទដ៏ប្រសើរ ៧ ជាន់ក្ដី របស់បុរសដែលថោកថយ កើតក្នុងត្រកូលទាប មានមនុស្សចណ្ឌាល ជាងផែង ព្រានជាងឈើ ជាងរថ អ្នកចាក់សំរាម

ដោយហេតុសូម្បីការយល់សប្តិ ។ តែចក្ករ័តន៍នោះ ជារបស់គួរបរិភោគនៃសត្វដែលមិនថោកថយប៉ុណ្ណោះ ព្រោះកើតឡើងដើម្បីការបរិភោគរបស់ស្តេចចក្រពត្តិ ដែលជាឧភតោសុជាតិ ដែលបំពេញចក្កពត្តិវត្ត ១០ ប្រការបរិបូណ៌ប៉ុណ្ណោះ ។ ចក្ករ័តន៍ជាដើមនោះ ស្មើដោយពុទ្ធរ័តន៍ មិនមាន បើឈ្មោះថារតនៈ ព្រោះអត្ថថា សត្វ ដែលមិនថោកថយបរិភោគហើយសោត ព្រះតថាគតនោះឯង ក៏ចាត់ជារតនៈ ព្រោះថា ព្រះតថាគត ឈ្មោះថា មិនគួរដល់ការបរិភោគរបស់សត្វទាំងឡាយដែលថោកថយ ដែលមិនមានឧបនិស្ស័យរបស់គ្រូទាំង ៦ មានបូរណកស្សបៈជាដើម ដែលមានទិដ្ឋិវិបរិត និងរបស់មនុស្សដទៃបែបនេះ ដោយហេតុសូម្បីការយល់សប្តិ តែព្រះតថាគតជាអ្នកគួរដល់ការបរិភោគនៃជនទាំងឡាយ ដែលមានឧបនិស្ស័យដល់ព្រម ជាអ្នកអាចសម្រេចជាព្រះអរហន្ត ក្នុងទីបំផុតនៃគាថាដែលប្រកបដោយបទ ៤ ដែលមាននិព្វេធិកញ្ញាណទស្សនៈ មានព្រះពាហិយទារុចីរិយៈជាដើម និងរបស់ព្រះមហាសាវ័កដែលកើតក្នុងត្រកូលធំដទៃ ព្រោះថា អរិយសាវ័កប៉ុណ្ណោះញុំាំងការបរិភោគនោះឲ្យសម្រេចដោយអនុត្តរិយៈទាំងឡាយ មានទស្សនានុត្តរិយៈ សវនានុត្តរិយៈ បារិចរិយានុត្តរិយៈជាដើម ឈ្មោះថា បានបរិភោគនូវព្រះតថាគត រតនៈដែលស្មើដោយព្រះតថាគត មិនមាន ព្រោះអត្ថថា សត្វ ដែលមិនថោកថយបរិភោគ ដូច្នេះ ។

រតនៈណា ដែលឈ្មោះថា រតនៈ ព្រោះអត្ថថា ធ្វើការត្រេកអរឲ្យកើត

ដោយមិនប្លែកគ្នា ដូចគ្នានឹងចក្ករ័តន៍របស់ស្តេចចក្កពត្តិ ។ ពិតហើយ ស្តេចចក្រពត្តិគ្រាន់តែទតឃើញចក្ករ័តន៍ប៉ុណ្ណោះ ក៏ទ្រង់មានព្រះហឫទ័យត្រេកអរចក្ករ័តន៍នោះ ឈ្មោះថា ធ្វើនូវការត្រេកអរឲ្យកើតដល់ស្តេចចក្កពត្តិយ៉ាងនេះ ។

សេចក្តីដទៃនៅមានទៀត ស្តេចចក្កពត្តិទ្រង់ចាប់ឃ្នោកមាសដោយព្រះហស្តឆ្វេង ហើយទ្រង់ប្រោះចក្ករ័តន៍ដោយព្រះហស្តស្តាំ ដោយទ្រង់អធិដ្ឋានថា ចូរចក្ករ័តន៍ដ៏ប្រសើរវិលទៅ ចូរចក្ករ័តន៍ដ៏ប្រសើរមានជ័យជម្នះ ដូច្នេះ បន្ទាប់អំពីនោះ ចក្ករ័តន៍ក៏បញ្ចេញសំឡេងពីរោះដូចតន្ត្រីប្រកបដោយអង្គ ៥ ទៅកាន់អាកាសទិសខាងកើត ស្តេចចក្កពត្តិក៏ទៅតាមចក្ករ័តន៍នោះ ដែលហោះទៅ មិនខ្ពស់ពេក មិនទាបពេក គឺទាបជាងដើមឈើដែលខ្ពស់ៗ និងខ្ពស់ជាងដើមឈើដែលទាបៗ មួយអន្លើដោយសេនាទាំងឡាយ ដែលប្រកបដោយអង្គ ៤ ដែលមានក្បួនព័ទ្ធទំហំប្រមាណ ១២ យោជន៍ ដោយអានុភាពនៃចក្ករ័តន៍ ទ្រង់ទទួលគ្រឿងបណ្ណាការ មានផ្លែឈើ ផ្កា និងត្រួយឈើជាដើម ត្រង់ដើមឈើទាំងឡាយ និងទ្រង់ទទួលគ្រឿងបណ្ណាការអំពីដៃរបស់ជនទាំងឡាយ ដែលកាន់បណ្ណាការមកថ្វាយហើយ ទ្រង់ទូន្មានព្រះរាជាដែលជាសត្រូវ ដែលយាងមកហើយ ដោយការកោតក្រែងក្រៃលែងយ៉ាងនេះថា បពិត្រមហារាជ សូមទ្រង់យាងមក ដូច្នេះ ដោយន័យថា ទ្រង់ទាំងឡាយកុំសម្លាប់សត្វ ដូច្នេះជាដើម ហើយយាងទៅ ។ ព្រះរាជា ទ្រង់ប្រាថ្នាសោយឬប្រាថ្នានឹងសម្រាកពេលថ្ងៃ ក្នុងទីណា ចក្ករ័តន៍ ក៏ចុះអំពីអាកាសក្នុងទីនោះ

ប្រតិស្ឋានត្រង់ភូមិភាគដែលស្មើ ដែលគួរដល់ការធ្វើកិច្ចទាំងពួង មានទឹកជាដើម ដូចស្ទុះមកលើផែនដីដោយភ្លៅ ដូច្នោះ ។ កាលព្រះរាជាទ្រង់ប្រាថ្នានឹងយាងទៅទៀត ចក្ករ័តន៍ក៏បន្លឺសំឡេងពីរោះ ដោយន័យមុននោះឯង ដែលបរិស័ទប្រមាណ ១២ យោជន៍ បានស្តាប់សំឡេងហើយ ក៏នាំគ្នាទៅតាមអាកាស ចក្ករ័តន៍រមែងចុះកាន់នូវ មហាសមុទ្រទិសខាងកើតដោយលំដាប់ កាលចក្ករ័តន៍នោះចុះកាន់មហាសមុទ្រ ទឹកប្រមាណមួយយោជន៍ ក៏ចៀសចេញទៅ ដូចមានជញ្ជាំងរាំង មហាជនរមែងឃើញរតនៈទាំង ៧ ប្រការតាមលំដាប់ ។ ព្រះរាជាទ្រង់ចាប់ឃ្លោកមាសអធិដ្ឋានថា ចូររាជសីមារបស់អញ ប្រព្រឹត្តទៅចាប់អំពីទីនេះ ដូច្នេះហើយ ក៏ប្រើទឹកប្រោះព្រំ ហើយយាងត្រឡប់ ។ ពួកសេនាខាងមុខចក្ករ័តន៍ ក៏មកនៅខាងក្រោយ ព្រះរាជានៅត្រង់កណ្តាល ។ ឯទីដែលចក្ករ័តន៍ អណ្តែតឡើងហើយ ទឹកក៏ពេញវិញ ។ ចក្ករ័តន៍ រមែងទៅកាន់មហាសមុទ្រទិសខាងត្បូង ទិសខាងលិច និងទិសខាងជើង ដោយឧបាយនេះ ។

ចក្ករ័តន៍ទៅកាន់ទិសទាំង ៤ ហើយហោះទៅកាន់អាកាសប្រមាណ ៣០០ យោជន៍ ព្រះរាជាទ្រង់គង់លើចក្ករ័តន៍នោះ ទ្រង់បាននូវជ័យជម្នះដែលទ្រង់ឈ្នះហើយ ដោយអានុភាពរបស់ចក្ករ័តន៍ ទ្រង់ទតចក្រវាលនីមួយៗ ដែលប្រដាប់ដោយទ្វីបធំ ៤ និងទ្វីបតូច ២០០០ ហាក់បីដូចទតគុម្ពឈូកដែលមានផ្ការីកស្គុសស្គាយយ៉ាងនេះ គឺបុព្វវិទេហទ្វីប ១ ដែលមានបរិ-

មណ្ឌល ៧០០០ យោជន៍ ល្អដោយទ្វីបតូច ៥០០ ឧត្តរកុរុទ្វីប ១ ដែលមានបរិមណ្ឌល ៨០០០ យោជន៍ ប្រដាប់ដោយទ្វីបតូច ៥០០ អមរគោយានទ្វីប ១ ដែលមានបរិមណ្ឌល ៧០០០ យោជន៍ ប្រដាប់ដោយទ្វីបតូច ៥០០ ជម្ពូទ្វីប ១ មានបរិមណ្ឌល ១០០០០ យោជន៍ ប្រដាប់ដោយទ្វីបតូច ៥០០ កាលព្រះរាជានោះទ្រង់ទតយ៉ាងនោះ សេចក្តីត្រេកអរមិនមែនតិចក៏បានកើតឡើង ចក្ករ័តន៍នោះ ធ្វើនូវការត្រេកអរឲ្យកើតឡើងដល់ព្រះរាជាដូចពណ៌នាមកយ៉ាងនេះ ។ សូម្បីចក្ករ័តន៍នោះ ដែលស្មើដោយពុទ្ធរ័តន៍ មិនមានបើចក្ករ័តន៍ ឈ្មោះថា **រតន** ព្រោះអត្ថថា ឲ្យកើតសេចក្តីត្រេកអរសោតព្រះតថាគត ក៏ឈ្មោះថា រតនៈដូចគ្នា ។

ចក្ករ័តន៍នោះ នឹងធ្វើអ្វីបាន ព្រោះថា ការត្រេកអររបស់ស្តេចចក្រពត្តិដែលកើតឡើងហើយអំពីរតនៈទាំងពួង មានចក្ករ័តន៍ជាដើម រមែងមិនចូលដល់នូវការរាប់សូម្បីនូវចំណែកនៃការត្រេកអរដែលជាទិព្វ ព្រះតថាគតតែងញ៉ាំងសេចក្តីត្រេកអរក្នុងបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន និងបញ្ចមជ្ឈាន ញ៉ាំងការត្រេកអរក្នុងអាកាសានញ្ចាយតនជ្ឈាន វិញ្ញាណញ្ចាយតនជ្ឈាន អាកិញ្ចញ្ញាយតនជ្ឈាន នេវសញ្ញានាសញ្ញាយតនជ្ឈាន ញ៉ាំងសេចក្តីត្រេកអរក្នុងសោតាបត្តិមគ្គ សោតាបត្តិផល សកទាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ អរហត្តផល ឲ្យកើតដល់ទេវតា និងមនុស្សទាំងឡាយ ដែលទទួលឱវាទរបស់ព្រះអង្គ មានចំនួន

រាប់មិនអស់ ក្រៃលែងជាង និងប្រណីតជាងការត្រេកអរដែលជាទិព្វនោះ ។ រតនៈដែលស្មើដោយព្រះតថាគត មិនមាន ព្រោះអត្ថថា ញុំាងសេចក្តីត្រេកអរឲ្យកើត ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ឈ្មោះថា **រតន** មាន ២ យ៉ាង គឺសវិញ្ញាណករតនៈ ១ អវិញ្ញាណករតនៈ ១ ក្នុង ២ យ៉ាងនោះ ចក្ករ័តន៍ និងកែវមណី ឬរតនៈដទៃណា ដែលមិនមានឥន្ទ្រិយ មានមាស និងប្រាក់ជាដើម ឈ្មោះថា អវិញ្ញាណករតនៈ រតនៈមានដំរីជាដើម មានបរិនាយកជាទីបំផុត ឬរតនៈដទៃឯណាដែលមានឥន្ទ្រិយ ឈ្មោះថា **សវិញ្ញាណករតន** ។ ក្នុងអវិញ្ញាណករតនៈ និងសវិញ្ញាណករតនៈទាំង ២ នេះ ដែលពោលមកនេះ សវិញ្ញាណករតនៈ លោកពោលថា ប្រសើរ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះរតនៈមានមាស ប្រាក់ កែវមណី និងកែវមុក្តាជាដើម ដែលមិនមានវិញ្ញាណ ត្រូវគេនាំមកប្រើដើម្បីជាគ្រឿងប្រដាប់នៃរតនៈទាំងឡាយ ដែលមានវិញ្ញាណ មានហត្ថិរ័តន៍ជាដើម ។

សវិញ្ញាណករតនៈក៏មាន ២ យ៉ាង គឺតិរច្ឆានរតនៈ ១ មនុស្សរតនៈ ១ ក្នុង ២ យ៉ាងនោះ មនុស្សរតនៈ លោកពោលថា ជារតនៈប្រសើរ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះតិរច្ឆានរតនៈត្រូវនាំមកបម្រើមនុស្សរតនៈ សូម្បីមនុស្សរតនៈក៏មាន ២ យ៉ាង គឺឥត្ថីរតនៈ ១ បុរិសរតនៈ ១ ក្នុង ២ យ៉ាងនោះ បុរិសរតនៈ លោកពោលថា ប្រសើរ សួរថា ព្រោះហេតុអ្វី

ព្រោះថា ឥត្ថីរតនៈដល់នូវភាវៈជាអ្នកបម្រើរបស់បុរិសរតនៈ ។

បុរិសរតនៈមាន ២ គឺអគារិករតនៈ ១ អនាគារិករតនៈ ១ ក្នុង ២ យ៉ាងនោះ អនាគារិករតនៈ លោកពោលថា ប្រសើរ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះក្នុងបណ្តាអគារិករតនៈទាំងឡាយ សូម្បីស្តេចចក្កពត្តិ ក៏គង់ថ្វាយបង្គំអនាគារិករតនៈ ដោយបញ្ចង្គប្រតិស្ឋាន ទ្រង់ចូលទៅឧបដ្ឋាក និងចូលទៅអង្គុយជិត ដើម្បីបានសម្រេចទិព្វសម្បត្តិ និងមនុស្សសម្បត្តិ ហើយសម្រេចនិព្វានសម្បត្តិក្នុងទីបំផុត ។

អនាគារិករតនៈ ក៏មាន ២ យ៉ាង គឺអរិយរតនៈ ១ បុថុជ្ជនរតនៈ ១ យ៉ាងនេះ ។

សូម្បីអរិយរតនៈក៏មាន ២ យ៉ាង គឺសេក្ខរតនៈ ១ អសេក្ខរតនៈ ១ សូម្បីអសេក្ខរតនៈក៏មាន ២ យ៉ាង គឺសុក្ខវិបស្សករតនៈ ១ សមថយានិករតនៈ ១ ។

សូម្បីសមថយានិករតនៈក៏មាន ២ យ៉ាង គឺសាវកបារមីប្បត្តរតនៈ ១ សាវកបារមីអប្បត្តរតនៈ ១ ។

ក្នុងបណ្តាសាវកបារមីរតនៈទាំង ២ យ៉ាងនោះ សាវកបារមីប្បត្តរតនៈ លោកពោលថា ប្រសើរ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះលោកបានសម្រេចសាវកបារមីដែលមានគុណច្រើន បច្ចេកពុទ្ធរតនៈ លោកពោលថា ប្រសើរជាងសាវកបារមីប្បត្តរតនៈ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះ

បច្ចេកពុទ្ធរតនៈមានគុណច្រើន សាវកទាំងឡាយទោះបី ១០០ អង្គ អម្បាល ព្រះសារីបុត្រ និងព្រះមោគ្គល្លាន មិនចូលដល់សូម្បីចំណែកទី ១០០ ឬទី ១០០០ នៃគុណទាំងឡាយរបស់ព្រះបច្ចេកពុទ្ធមួយអង្គ សម្មាសម្ពុទ្ធរតនៈ លោកពោលថា ក្រៃលែងជាងបច្ចេកពុទ្ធរតនៈ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមាននូវគុណច្រើន បើព្រះបច្ចេកពុទ្ធទាំងឡាយអង្គុយពត់ភ្នែនពេញជម្ពូទ្វីប មិនចូលដល់ការរាប់ មិនចូលដល់មួយចម្រៀកនៃគុណទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធមួយអង្គ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាតថា

ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ដែលឥតជើងក្តី មាន ជើង ២ ក្តី មានជើង ៤ ក្តី មានជើងច្រើនក្តី មានរូបក្តី គ្មានរូបក្តី មានសញ្ញាក្តី គ្មានសញ្ញាក្តី មិនមែនជាមិនមានសញ្ញាក្តី ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរលើសជាងពួកសត្វទាំងនោះដូច្នេះ ។

រតនៈដែលស្មើដោយតថាគតរតនៈ រមែងមិនមានដោយបរិយាយណាមួយយ៉ាងនេះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ន នោ សមំ អត្ថិ តថាគតេន** ( ទ្រព្យ និងរតនវត្ថុទាំងនោះ ) ស្មើដោយព្រះតថាគតមិនមានឡើយ ។

ព្រះមានព្រះភាគ កាលត្រាស់ដល់ភាពដែលពុទ្ធរ័តន៍ មិនស្មើដោយរតនៈដទៃយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីការចូលទៅស្ងប់នូវឧបទ្រពដែលកើតឡើងដល់ពួកសត្វទាំងនោះ ព្រះមានព្រះភាគ ទ្រង់មិនអាស្រ័យជាតិ អាស្រ័យគោត្ត អាស្រ័យការកើតឡើងនៃត្រកូល និងអាស្រ័យភាពជាបុគ្គលមានពណ៌សម្បុរស្អាតជាដើមឡើយ តែទ្រង់អាស្រ័យភាពដែលពុទ្ធរ័តន៍ ជារតនៈដែលមិនមានប្រមាណ ដោយគុណទាំងឡាយ មានសីលក្ខន្ធ និងសមាធិក្ខន្ធជាដើម ក្នុងលោក តាំងអំពីអវីចីនរក រហូតដល់ភវគ្គព្រហ្មជាទីបំផុត ទើបទ្រង់ប្រកបសច្ចវាចាថា

**ឥទម្បិ ពុទ្ធេ រតនំ បណីតំ ឯតេន សច្ចេន សុវត្ថិ ហោតុ** រតនៈគឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

អត្ថនៃព្រះគាថានោះថា ទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត ឬរតនៈឯណានីមួយ ដែលមានក្នុងលោកនេះ ឬក្នុងលោកដទៃ ឬក្នុងស្ថានសួគ៌ទាំងឡាយ ពុទ្ធរ័តន៍នេះ ឈ្មោះថា ប្រណីត ព្រោះមិនស្មើដូចទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត ឬរតនៈនោះ ដោយគុណទាំងឡាយនោះៗ បើពាក្យដែលពោលនេះជាពាក្យពិតសោត ដោយសច្ចៈនេះ សួស្តី ចូរកើតមាន គឺចូរសេចក្តីល្អកើតមាន បានដល់ ការមិនមានរោគ ការមិនមានឧបទ្រវៈ ចូរមានដល់សត្វទាំងឡាយនេះ ។ ក្នុងសេចក្តីនេះ មានពាក្យអធិប្បាយថា ចក្ខុឈ្មោះថាជារបស់សូន្យ សូន្យចាកភាពជារបស់ខ្លួន ឬចាកភាពដែលទាក់ទងនឹងខ្លួន ដូច

ក្នុងប្រយោគទាំងឡាយយ៉ាងនេះថា ម្នាលអានន្ទ ចក្ខុហ្នឹងឯងសូន្យចាកខ្លួន ឬចាកបរិក្ខាររបស់ខ្លួន ដូច្នេះ ។ តែកាលកាន់យកដោយប្រការក្រៅអំពីនេះ ចក្ខុក៏មិនសម្រេច ដោយពាក្យថា ខ្លួន ឬចាកបរិក្ខាររបស់ខ្លួន យ៉ាងណា ពាក្យដែលពោលថា **រតនំ បណីតំ** គប្បីជ្រាបអត្ថនេះថា ភាពជារតនៈដែលប្រណីត គឺរតនៈ គឺភាពដែលឧត្តម តែបើកាន់យកដោយប្រការក្រៅអំពីនេះ ព្រះមានព្រះភាគ ក៏មិនសម្រេចថាជារតនៈឡើយ ដូច្នោះ ព្រោះថា ក្នុងទីណាមិនមានរតនៈ ទីនោះ ក៏មិនទាន់ថាជារតនៈបាន តែក្នុងទីណា មានភាពជារតនៈ ដែលដល់នូវការសម្មន្នគ្នាដោយវិធីណាមួយ ពោល គឺប្រយោជន៍ មានការធ្វើសេចក្ដីគោរពជាដើម ទីនោះ ក៏រមែងប្រាកដថា ជារតនៈបាន សំដៅដល់ភាពជារតនៈ ព្រោះដូច្នោះ ទើបសម្រេចជារតនៈបាន ព្រោះការមាននៃរតនៈនោះ ។

ម្យ៉ាងទៀត ដោយសព្ទថា **ឥទម្បិ ពុទ្ធេ រតនំ** គប្បីជ្រាបអត្ថក្នុងពាក្យយ៉ាងនេះថា ដោយហេតុនេះ ព្រះពុទ្ធ ចាត់ថាជារតនៈ ក៏ដោយព្រះគាថាមានប្រមាណស្មើនឹងព្រះតម្រាស់ ដែលព្រះមានព្រះភាគត្រាស់ហើយនេះ សួស្ដីកើតហើយដល់រាជត្រកូល ភ័យក៏ស្ងប់ហើយ ដោយគាថានេះ អាជ្ញាអមនុស្សទាំងឡាយ ក្នុងមួយសែនកោដិចក្កវាឡ បានទទួលហើយ ។

ព្រះមានព្រះភាគ កាលត្រាស់សច្ចវាចាដោយពុទ្ធគុណយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងត្រាស់ដោយធម្មគុណ គឺព្រះនិព្វាន ទើបទ្រង់ផ្ដើមពាក្យថា

**ខយំ វិរាគំ** ជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះដូចតទៅនេះថា ព្រោះកិលេសទាំងឡាយមានរាគៈជាដើមអស់ទៅហើយ គឺអស់ទៅដោយជុំវិញហើយ ព្រោះធ្វើនូវព្រះនិព្វានឲ្យជាក់ច្បាស់ ឬព្រោះព្រះនិព្វាននោះ ជាធម្មជាតត្រឹមតែមិនកើតឡើងអស់ទៅសូន្យទៅនៃកិលេស មានរាគៈជាដើម ព្រោះនិព្វាននោះ មិនប្រកបដោយរាគៈជាដើម ទាំងដោយសម្បយោគ ទាំងដោយអារម្មណ៍ ឬព្រោះកាលព្រះនិព្វាននោះ ដែលព្រះអរិយបុគ្គលធ្វើឲ្យជាក់ច្បាស់ហើយ កិលេសទាំងឡាយ មានរាគៈជាដើម ក៏ប្រាសចេញទៅដោយចំណែកមួយ គឺខ្ទាក់ទៅខ្ទាត់ខ្ចាយទៅ ដូច្នោះ ទើបនិព្វាននោះ លោកហៅថា **ខយំ** ព្រោះជាទីអស់ទៅ និងហៅថា **វិរាគំ** ព្រោះខ្ទាក់នូវកិលេស ។

ម្យ៉ាងទៀត ព្រោះការកើតឡើងនៃព្រះនិព្វាននោះ មិនប្រាកដ ការវិនាសទៅក៏មិនប្រាកដ ភាពជាទៃនៃព្រះនិព្វាននោះ ឈ្មោះថា តាំងមាំហើយក៏មិនប្រាកដ ដូច្នោះ ព្រះនិព្វាននោះ លោកហៅថា **អមតំ** ព្រោះអត្ថវិគ្គហៈថា មិនកើត មិនចាស់ និងមិនស្លាប់ ។ ព្រះនិព្វាននោះ ឈ្មោះថា **បណីតំ** ព្រោះអត្ថថា ឧត្តម និងព្រោះអត្ថថា មិនក្តៅ ។

ពីរបទថា **យទជ្ឈគា** សេចក្តីថា ព្រះសក្យមុនីទ្រង់សម្រេចហើយ គឺទ្រង់ស្ងប់ហើយ ទ្រង់បានហើយ ទ្រង់ធ្វើឲ្យជាក់ច្បាស់ហើយនូវព្រះធម៌ណាដោយកម្លាំងនៃញាណរបស់ព្រះអង្គ ។

បទថា **សក្យមុនី** បានដល់ ឈ្មោះថា **សក្យៈ** ព្រោះប្រសូតក្នុងសក្យត្រកូល ឈ្មោះថា **មុនី** ព្រោះទ្រង់ប្រកបដោយមោនេយ្យធម៌ មុនី គឺសក្យៈនោះឯង ឈ្មោះថា **សក្យមុនី** ។

បទថា **សមាហិតោ** បានដល់ មានចិត្តតាំងមាំដោយអរិយមគ្គសមាធិ ។ បទថា **ន តេន ធម្មេន សមត្ថិ កិញ្ចិ** សេចក្ដីថា ធម្មជាតណាមួយដែលស្មើដោយព្រះធម៌ ដែលបានឈ្មោះថា **ខយំ** ជាដើមនោះ ដែលព្រះសក្យមុនីទ្រង់សម្រេចហើយ មិនមាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងសូត្រដទៃថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មានជាសង្ខតធម៌ក្ដី អសង្ខតធម៌ក្ដី វិរាគធម៌ប្រាកដជាប្រសើរជាងពួកធម៌ទាំងនោះ ដូច្នេះ ។

ព្រះមានព្រះភាគ កាលត្រាស់ភាពដែលនិព្វានធម៌ជាធម៌ដែលមិនស្មើដោយធម៌ដទៃយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីការចូលទៅស្ងប់នៃឧបទ្រវដែលកើតឡើងហើយដល់សត្វទាំងឡាយនោះ ទ្រង់អាស្រ័យភាពដែលធម្មរ័តន៍គឺព្រះនិព្វានជារតនៈមិនមានរតនៈដទៃស្មើ ដោយគុណទាំងឡាយ មានខយធម៌ វិរាគធម៌ អមតធម៌ និងបណីតធម៌ ទើបទ្រង់ប្រកបសច្ចវាចាថា

**ឥទម្បិ ធម្មេ រតនំ បណីតំ ឯតេន សច្ចេន សុវត្ថិ ហោតុ** រតនៈគឺព្រះធម៌នេះឯង ជារតនៈដ៏ឧត្ដម ។ ដោយពាក្យសច្ចៈនេះ សូមសួស្ដីកើតមាន ។

អត្ថនៃគាថានោះ បណ្ឌិតគប្បីជ្រាបដោយន័យដែលខ្ញុំបានពោលហើយ

ក្នុងគាថាមុននោះឯង អាជ្ញានៃគាថានេះ ដែលអមនុស្សទាំងឡាយក្នុងមួយសែនកោដិចក្រវាលបានទទួលហើយ ។

ព្រះមានព្រះភាគ កាលត្រាស់សច្ចវាចាដោយធម្មគុណ គឺព្រះនិព្វាន យ៉ាងនេះហើយ ក្នុងឥឡូវនេះ កាលត្រាស់ធម្មគុណ គឺមគ្គ ទើបទ្រង់ផ្តើមថា **យម្ពុទ្ធសេដ្ឋោ** ជាដើម ។

ក្នុងគាថានោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ព្រះមានព្រះភាគ ទ្រង់ព្រះនាម **ពុទ្ធ** ដោយន័យថា ព្រះអង្គទ្រង់ត្រាស់ដឹងនូវសច្ចៈទាំងឡាយ ដូច្នេះជាដើម ឈ្មោះថា **សេដ្ឋោ** ព្រោះអត្ថថា ទ្រង់ជាបុគ្គលឧត្តម ឬជាបុគ្គលគួរសរសើរ ព្រះពុទ្ធអង្គនោះផង ជាបុគ្គលប្រសើរផង ព្រោះហេតុនោះ ទើបឈ្មោះថា **ពុទ្ធសេដ្ឋោ**។

ម្យ៉ាងទៀត ព្រះសម្មាសម្ពុទ្ធ ឈ្មោះថា **សេដ្ឋោ** ក្នុងបណ្តាព្រះពុទ្ធទាំងឡាយ គឺព្រះអនុពុទ្ធ និងព្រះបច្ចេកពុទ្ធ ព្រោះហេតុនោះ ទើបឈ្មោះថា **ពុទ្ធសេដ្ឋោ** ។ ព្រះពុទ្ធជាបុគ្គលប្រសើរបំផុតអង្គនោះ រមែងលើកតម្កើង គឺរមែងសរសើរ បានដល់ រមែងប្រកាសនូវធម៌ណា ក្នុងទីនោះៗ ដោយន័យជាដើមយ៉ាងនេះថា មគ្គដែលប្រកបដោយអង្គ ៨ ដ៏ក្សេមក្សាន្តជាងមគ្គទាំង-ឡាយ សម្រាប់ដើរទៅកាន់ព្រះនិព្វាន ឈ្មោះអមតៈ ដូច្នេះ ។ និងពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសម្មាសមាធិ ដែលឥតទោស ព្រមទាំងបច្ច័យ ព្រមទាំងបរិវារ ដូច្នេះ ។

បទថា **សុចឹ** បានដល់ ដ៏វេងបំផុត ព្រោះធ្វើនូវការកាត់មន្ទិល គឺកិលេស ។

បាទគាថាថា **សមាធិមានន្តរិកញ្ញមាហុ** សេចក្ដីថា បណ្ឌិតទាំងឡាយពោលសមាធិណា ថាជាសមាធិដែលឲ្យផលតាមលំដាប់ ព្រោះឲ្យផលក្នុងលំដាប់នៃការប្រព្រឹត្តិទៅរបស់ខ្លួន យ៉ាងពិតប្រាកដនោះឯង កាលមគ្គសមាធិកើតឡើងហើយ រមែងមិនមានអន្តរាយណាមួយដែលនឹងហាមការកើតឡើងនៃផលរបស់មគ្គសមាធិនោះ ដូចព្រះតម្រាស់ក្នុងបុគ្គលបញ្ញត្តិថា

> បុគ្គលនេះជាអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតបត្តិផល ទុកជាវេលាភ្លើងឆេះកប្បនឹងមាន បើបុគ្គលនេះមិនទាន់ធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលដរាបណា ភ្លើងក៏មិនគប្បីឆេះកប្បដរាបនោះដែរ នេះហៅថា បុគ្គលជាឋិតកប្បី ដូច្នេះ ។

បាទគាថាថា **សមាធិនា តេន សមោ ន វិជ្ជតិ** សេចក្ដីថា រូបាវចរ-សមាធិ ឬអរូបាវចរសមាធិណាមួយ ដែលស្មើដោយសមាធិ ដែលឲ្យផលក្នុងលំដាប់ ( មគ្គសមាធិ ) ដ៏ស្អាត ដែលព្រះពុទ្ធប្រសើរបំផុត ទ្រង់សរសើរហើយនោះ រមែងមិនមាន សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះសូម្បីលោកកើតហើយក្នុងព្រហ្មលោកនោះ ព្រោះហេតុដែលបានចម្រើននូវរូបាវចរសមាធិនិងអរូបាវចរសមាធិទាំងនោះហើយ ក៏នៅមកកើតក្នុងអបាយភូមិទាំងឡាយមាននរកជាដើមទៀតបាន ព្រោះព្រះអរិយបុគ្គលជាអ្នកកើបកន្ទ្រាក់ការកើតក្នុង

ភពទាំងឡាយបាន ព្រោះលោកបានចម្រើនអប់រំអរហត្តសមាធិនេះហើយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងសូត្រដទៃថា ម្នាលភិក្ខុទាំង-ឡាយ ពួកសង្ខតធម៌ ធម៌ដែលបច្ច័យតាក់តែងទាំងប៉ុន្មាន មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ប្រាកដជាប្រសើរជាងពួកសង្ខតធម៌ទាំងនោះជាដើម ។

ព្រះមានព្រះភាគ កាលត្រាស់ភាពដែលអានន្តរិកសមាធិ គឺអរហត្តមគ្គ-សមាធិ ជាសមាធិដែលមិនស្មើជាមួយនឹងសមាធិដទៃយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យធម៌ដែលជាធម្មរតនៈ គឺមគ្គជារតនៈដែលមិនស្មើដោយន័យមុននោះឯង ទើបទ្រង់ប្រកបសច្ចវាចាថា **ឥទម្បិ ធម្មេ** ដូច្នេះជាដើម ។

អត្ថនៃព្រះគាថានោះ ដែលបណ្ឌិតគប្បីជ្រាបដោយន័យដែលខ្ញុំពោលហើយខាងដើមនោះឯង អាជ្ញានៃព្រះគាថានេះ ដែលអមនុស្សទាំងឡាយក្នុងមួយសែនកោដិចក្រវាលបានទទួលហើយ ។

ព្រះមានព្រះភាគ កាលត្រាស់សច្ចវាចាដោយធម្មគុណ គឺមគ្គយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់បំណងនឹងត្រាស់សច្ចវាចាដោយសង្ឃគុណ ទើបត្រាស់ថា **យេ បុគ្គលា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **យេ** ជានិក្ខេបបទ ដែលកំណត់ពិតប្រាកដ ។ បទថា **បុគ្គលា** បានដល់ សត្វទាំងឡាយ ។ បទថា **អដ្ឋ** ជាការកំណត់រាប់ចំនួនបុគ្គលទាំងនោះ ។ ពិតហើយ អរិយបុគ្គលនោះមាន ៨ ពួក គឺបុគ្គលដែលបដិបត្តិ ៤ ពួក និងបុគ្គលដែលតាំងនៅហើយក្នុងផល ៤ ពួក ។

ពីរបទថា **សតំ បសដ្ឋា** សេចក្តីថា ដែលសប្បុរសទាំងឡាយ គឺព្រះសម្ពុទ្ធ ព្រះបច្ចេកពុទ្ធ សាវកទាំងឡាយ ដែលទេវតា និងមនុស្សទាំងឡាយដទៃសរសើរហើយ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះព្រះអរិយបុគ្គល ៨ ពួកនោះ ប្រកបដោយគុណ មានសីលដែលកើតព្រមគ្នាជាដើម ដ្បិតថា ព្រះអរិយបុគ្គលទាំងនោះ មានគុណច្រើនប្រការ មានសីល សមាធិ បញ្ញា ដែលកើតរួមគ្នាជាដើម ដូចផ្កាទាំងឡាយ មានផ្កាចម្ប៉ា ផ្កាពិកុល និងផ្កាកុសុមជាដើម ដែលមានគុណច្រើនយ៉ាង មានពណ៌ និងក្លិនដែលកើតព្រមគ្នាជាដើម ព្រោះហេតុនោះ ទើបព្រះអរិយបុគ្គលទាំងនោះ ជាទីស្រឡាញ់ពេញចិត្ត និងជាបុគ្គលដែលសប្បុរសទាំងឡាយសរសើរ ដូចផ្កាដែលសម្បូរដោយពណ៌ និងក្លិនជាដើម រមែងជាទីស្រឡាញ់ពេញចិត្តនៃទេវតា និងមនុស្សទាំងឡាយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **យេ បុគ្គលា អដ្ឋសតំ បសដ្ឋា។**

ម្យ៉ាងទៀត បទថា **យេ** ជានិគ្គហបទដែលមិនកំណត់ពិតប្រាកដ ។ បទថា **បុគ្គលា** បានដល់ សត្វទាំងឡាយ ។ បទថា **អដ្ឋសតំ** បានដល់ការកំណត់គុណរបស់ព្រះអរិយបុគ្គលទាំងនោះថា មាន ១០៨ ។ ពិតហើយ ព្រះអរិយបុគ្គល ៨ ពួកនោះ រួមជា ៥៤ ពួក គឺព្រះសោតាបន្ន ៣ ពួក គឺ ឯកពីជី ១ កោលំកោលៈ ១ សត្តក្ខត្តុបរមៈ ១ ។

ព្រះសកទាគាមី ៣ ពួក គឺលោកអ្នកដែលបានសម្រេចផលហើយក្នុង

កាមភព រូបភព អរូបភព ។ ព្រះសោតាបន្ន និងព្រះសកទាគាមីទាំងអស់នោះ រួមជា ២៤ ពួក ដោយអំណាចនៃបដិបទា ៤ ( ព្រះសោតាបន្ន ១២ និងព្រះសកទាគាមី ១២ ) ។

ព្រះអនាគាមីមាន ២៤ ពួក គឺអនាគាមី ៥ ពួក ក្នុងអវិហាភូមិ គឺ អន្តរាបរិនិព្វាយី ១ ឧបហច្ចបរិនិព្វាយី ១ សសង្ខារបរិនិព្វាយី ១ អសង្ខារ-បរិនិព្វាយី ១ និងឧទ្ធំសោតោអកនិដ្ឋគាមី ១ ។ ក្នុងអតប្បាភូមិ សុទស្សាភូមិ សុទស្សីភូមិក៏ដូចគ្នា តែក្នុងអកនិដ្ឋកភូមិ មាន ៤ ពួក វៀរឧទ្ធំសោតោ ។

ព្រះអរហន្ត ២ ពួក គឺសុក្ខវិបស្សក: ១ សមថយានិក ១ និងលោកអ្នកដែលតាំងនៅក្នុងមគ្គ ៤ ពួក រួមជា ៥៤ ពួក ។ ព្រះអរិយបុគ្គលទាំង ៥៤ ពួកនោះ យក ២ គុណ ដោយអំណាចនៃសទ្ធាធុរៈ និងបញ្ញាធុរៈ ទើបជាព្រះអរិយបុគ្គល ១០៨ ពួក ពាក្យដ៏សេស មានន័យដូចខ្ញុំពោលហើយនោះឯង ។

បាទគាថាថា **ចត្តារិ ឯតានិ យុគានិ ហោន្តិ** សេចក្តីថា ព្រះអរិយ-បុគ្គលទាំងអស់នោះ ដែលលោកសម្តែងថា ៨ ពួក ឬ ១០៨ ពួក ដោយពិស្តារ តែដោយសង្ខេបមាន ៤ គូ គឺបុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ ១ រហូតដល់បុគ្គលតាំងនៅក្នុងអរហត្តមគ្គ និងតាំងនៅក្នុងអរហត្តផលជាគូ ១ ។

បទថា **តេ** ក្នុងពាក្យថា **តេ ទក្ខិណេយ្យា** ជាការពង្រីកការកំណត់

ដល់ព្រះអរិយបុគ្គលតាមដែលលោកមិនកំណត់ខាងដើម ។

បុគ្គលទាំងឡាយណា ដែលលោកពោលដោយពិស្តារថា មាន ៨ ពួក ឬ ១០៨ ពួក តែដោយសង្ខេបមាន ៤ គូ ដូច្នេះ បានដល់ ព្រះអរិយបុគ្គលទាំងនេះ ។

ព្រះអរិយបុគ្គលទាំងឡាយ ឈ្មោះថា **ទក្ខិណេយ្យា** ព្រោះអត្ថវិគ្គហៈថា រមែងគួរដល់ទក្ខិណា ។ ទេយ្យធម៌ដែលបុគ្គលជឿនូវកម្ម និងជឿផលរបស់កម្មឲ្យដោយមិនពិចារណាដល់ហេតុទាំងឡាយ មានយ៉ាងនេះជាដើមថា បុគ្គលនេះនឹងធ្វើវេជ្ជកម្មនេះដល់អាត្មាអញ នឹងធ្វើការបម្រើអញ ដូច្នេះ ឈ្មោះថា **ទក្ខិណា** ។ បុគ្គលទាំងឡាយដែលប្រកបដោយគុណ មានសីលជាដើម ឈ្មោះថា រមែងគួរដល់ទក្ខិណានោះ ។ ព្រះអរិយបុគ្គលទាំងនេះ មានសភាពដូច្នោះ ។ ព្រោះហេតុនោះ ទើបព្រះអរិយបុគ្គលនោះ លោកហៅថា **ទក្ខិណេយ្យា** ។

ពីរបទថា **សុគតស្ស សាវកា** សេចក្ដីថា ព្រះមានព្រះភាគទ្រង់ព្រះនាម **សុគតោ** ព្រោះព្រះអង្គប្រកបដោយការយាងទៅល្អ ព្រោះទ្រង់យាងដល់ឋានៈដែលល្អ ព្រោះទ្រង់យាងទៅល្អ និងព្រោះទ្រង់ត្រាស់ដោយល្អនោះឯង បុគ្គលទាំងនោះ រមែងស្ដាប់នូវពាក្យប្រៀនប្រដៅរបស់ព្រះសុគតនោះ ព្រោះហេតុនោះ ទើបជនទាំងនោះ ឈ្មោះថា **សាវក** ។

មនុស្សដទៃ រមែងស្ដាប់ពាក្យប្រៀនប្រដៅរបស់ព្រះសុគតក៏ពិត តែ

ស្តាប់ហើយ មិនបានធ្វើកិច្ចដែលខ្លួនគប្បីធ្វើឡើយ តែសាវកទាំងឡាយនេះ ស្តាប់ហើយ ធ្វើតាមធម្មានុធម្មប្បដិបត្តិដែលគួរធ្វើ សម្រេចហើយ នូវមគ្គ និងផលទាំងឡាយ ព្រោះហេតុនោះ ទើបលោកហៅថា **សាវក** ។

បាទគាថាថា **ឯតេសុ ទិន្នានិ មហប្ផលានិ** សេចក្តីថា ទានទាំងឡាយ សូម្បីតិចដែលបុគ្គលឲ្យហើយ ក្នុងសាវករបស់ព្រះសុគតទាំងឡាយនេះ ឈ្មោះថា មានផលច្រើន ព្រោះទក្ខិណាទានចូលដល់សេចក្តីបរិសុទ្ធិខាង បដិគ្គាហក ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ត្រង់កណ្តាលនៃអគ្គ-ប្បសាទសូត្រថា ម្នាលភិក្ខុទាំងឡាយ សង្ឃក្តី គណៈក្តី ទាំងប៉ុន្មាន សង្ឃ សាវកនៃតថាគត បើរាប់ជាគូបាន ៤ គូ បើរាប់រៀងជាបុរស បុគ្គលមាន ៨ នេះជាសង្ឃសាវករបស់ព្រះដ៏មានព្រះភាគ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួក សត្វណាជ្រះថ្លាក្នុងព្រះសង្ឃ ពួកសត្វនោះ ឈ្មោះថា ជ្រះថ្លាក្នុងព្រះសង្ឃដ៏ ប្រសើរ ផលដ៏ប្រសើរតែងមានដល់ពួកសត្វអ្នកជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ដូច្នេះ ។

ព្រះមានព្រះភាគ កាលត្រាស់ដល់គុណនៃសង្ឃរតនៈដោយអំណាច បុគ្គលដែលតាំងនៅក្នុងមគ្គ និងផលទាំងពួងយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់ អាស្រ័យគុណនោះ ប្រកបសច្ចវាចាថា **ឥទម្បិ សង្ឃេ** ដូច្នេះជាដើម ។

អត្ថនៃព្រះគាថានោះ គប្បីជ្រាបដោយន័យដែលខ្ញុំពោលហើយខាងដើម នោះឯង អាជ្ញានៃព្រះគាថាទាំងនេះ ដែលអមនុស្សទាំងឡាយក្នុងមួយសែន

កោដិចក្រវាលទទួលហើយ ព្រះមានព្រះភាគត្រាស់សច្ចវាចាដោយគុណនៃសង្ឃរតនៈ ដោយអំណាចនៃបុគ្គលដែលតាំងនៅក្នុងមគ្គ និងតាំងនៅក្នុងផល យ៉ាងនេះហើយ ឥឡូវនេះ បន្ទាប់អំពីនោះ ទ្រង់ប្រារព្ធសច្ចវាចាដោយគុណនៃព្រះខីណាស្រពទាំងឡាយ ដែលសោយសេចក្ដីសុខកើតអំពីផលសមាបត្តិពួកខ្លះប៉ុណ្ណោះ ទើបត្រាស់ថា **យេ សុប្បយុត្តា** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **យេ** ជាពាក្យលើកឡើងសម្ដែងដោយមិនកំណត់ ។ បទថា **សុប្បយុត្តា** បានដល់ ប្រកបហើយដោយល្អ ។ អធិប្បាយថា ព្រះអរិយបុគ្គលទាំងនោះ លះអនេសនៈ មានបែបផ្សេងៗ អាស្រ័យការចិញ្ចឹមជីវិតដ៏បរិសុទ្ធ ផ្ដើមប្រកបខ្លួនក្នុងវិបស្សនា ។

ម្យ៉ាងទៀត បទថា **សុប្បយុត្តា** បានដល់ ប្រកបដោយកាយប្បយោគនិងវចីបយោគដ៏បរិសុទ្ធ ។ ដោយបទថា **សុប្បយុត្តា** នោះ ព្រះមានព្រះភាគទ្រង់សម្ដែងដល់សីលក្ខន្ធរបស់ព្រះអរិយបុគ្គលទាំងនោះ ។

ពីរបទថា **មនសា ទឡ្ហេន** សេចក្ដីថា ដោយចិត្តដែលមាំទាំ អធិប្បាយថា ដោយចិត្តដែលប្រកបដោយសមាធិមាំទាំ ដោយបទថា **មនសា ទឡ្ហេន** នេះ ព្រះមានព្រះភាគ ទ្រង់សម្ដែងដល់សមាធិក្ខន្ធរបស់ព្រះអរិយបុគ្គលទាំងនោះ ។

បទថា **និក្កាមិនោ** សេចក្ដីថា ជាបុគ្គលដែលមិនអាល័យក្នុងកាយនិងជីវិត គឺបុគ្គលធ្វើការឈានចេញចាកកិលេសទាំងពួង ដោយសេចក្ដីព្យា-

យាមដែលជាបញ្ញាធុរៈ ។ ដោយបទថា **ឆិន្នាមិនោ** នេះ ព្រះមានព្រះភាគ សម្តែងដល់បញ្ញាខន្ធ ដែលដល់ព្រមដោយសេចក្តីព្យាយាម របស់ព្រះអរិយបុគ្គលទាំងនោះ ។

បទថា **គោតមសាសនម្ហិ** សេចក្តីថា ក្នុងសាសនារបស់ព្រះតថាគត ព្រះនាមគោតមដោយគោត្តនោះឯង ។ បទថា **គោតមសាសនម្ហិ** នោះ ព្រះមានព្រះភាគ ទ្រង់សម្តែងដល់ការមិនមានការធ្វើនូវការឈានចេញចាកកិលេសទាំងឡាយ ព្រោះការមិនមាននៃគុណ មានការព្យាយាមល្អជាដើម នៃបុគ្គលទាំងឡាយដែលធ្វើសេចក្តីព្យាយាម ដើម្បីការមិនស្លាប់ មានប្រការផ្សេងៗ ខាងក្រៅសាសនារបស់ព្រះសមណគោតមនេះ ។

បទថា **តេ** ជាពាក្យសម្តែងដល់ព្រះអរិយបុគ្គល ដែលព្រះអង្គបានសម្តែងខាងដើម ។ ក្នុងបទថា **បត្តិបត្តា** នេះ មានវិគ្គហៈដូច្នេះថា ដែលឈ្មោះថា **បត្តិ** ព្រោះអត្ថវិគ្គហៈថា ដែលបុគ្គលគប្បីសម្រេច ។ ព្រះអរិយ-បុគ្គលទាំងនោះ ឈ្មោះថា **បត្តិ** បានដល់ គួរសម្រេច ព្រះអរិយបុគ្គលទាំងនោះសម្រេចផលណាហើយ ជាអ្នកក្សេមចាកយោគៈដោយចំណែកមួយ ។

បទថា **បត្តិបត្តា** នោះ ជាឈ្មោះនៃអរហត្តផល ។ ព្រះអរិយបុគ្គលសម្រេចនូវអរហត្តផលនោះ ព្រោះហេតុនោះ ទើបព្រះអរិយបុគ្គលទាំងនោះឈ្មោះថា **បត្តិបត្តា** ។

បទថា **អមតំ** បានដល់ ព្រះនិព្វាន ។ បទថា **វិគយ្ហ** បានដល់ ឈម

ចុះហើយដោយអំណាចនៃអារម្មណ៍ ។ បទថា **លទ្ធា** បានដល់ បានហើយ ។ បទថា **មុធា** បានដល់ ដោយមិនវិនាស គឺមិនធ្វើឲ្យវិនាសទៅ សូម្បីត្រឹមតែមួយកាកណិក ។

បទថា **និព្វុតឹ** បានដល់ នូវផលសមាបត្តិជាទីស្ងប់រម្ងាប់សេចក្ដីក្រវល់ក្រវាយនៃកិលេស ។

បទថា **ភុញ្ជមានា** គឺសោយ ។ លោកពោលអធិប្បាយដូចម្ដេច លោកអធិប្បាយថា ព្រះអរិយបុគ្គលទាំងឡាយណា ឈ្មោះថា **សុប្បយុត្តា** ព្រោះជាអ្នកប្រកបហើយដោយសីល ។ ឈ្មោះថា **មនសា ទឡ្ហេន** ព្រោះដែលសម្បូរដោយសមាធិ ។ ឈ្មោះថា **និក្កាមិនោ** ព្រោះដល់ព្រមដោយបញ្ញាក្នុងសាសនារបស់ព្រះគោតមនេះ ព្រះអរិយបុគ្គលទាំងឡាយនោះ ឈមចុះហើយកាន់អមតៈ ដោយសម្មាបដិបទានេះ បានហើយនូវការរលត់ ដែលដឹងថា ផលសមាបត្តិ ដោយមិនទទេៗ សោយផល ជាបុគ្គល ឈ្មោះថា បានសម្រេចអរហត្តផលដែលគួរសម្រេច ។

ព្រះមានព្រះភាគ កាលទ្រង់ត្រាស់គុណនៃព្រះសង្ឃរតនៈ ដោយភាពនៃបុគ្គលដែលជាខីណាស្រពសោយនូវសេចក្ដីសុខ ដែលកើតអំពីផលសមាបត្តិនោះឯង យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបប្រកបសច្ចវាចាថា **ឥទម្បិ សង្ឃេ** ជាដើម ។

អត្ថនៃគាថានោះ គប្បីជ្រាបដោយន័យដែលខ្ញុំពោលទុកខាងដើមនោះ

ឯង ។

អាជ្ញានៃគាថានេះ ដែលអមនុស្សទាំងឡាយ ក្នុងមួយសែនកោដិចក្រវាលបានទទួលហើយ ។

ព្រះមានព្រះភាគ កាលត្រាស់សច្ចៈដែលមានព្រះសង្ឃជាទីតាំង ដោយគុណនៃព្រះខីណាស្រពបុគ្គលទាំងឡាយយ៉ាងនេះហើយ ឥឡូវនេះ បំណងត្រាស់ដល់គុណរបស់ព្រះសោតាបន្ន ដែលប្រចក្សដល់ជនជាច្រើននោះ ទើបត្រាស់ពាក្យថា **យថិន្ទខីលោ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **យថា** ជាពាក្យឧបមា ។ បទថា **ឥន្ទ-ខីលោ** នេះ ជាឈ្មោះនៃសសរក្រាក់ដែលគេជីកបោះទៅក្នុងដី ជម្រៅ ៨ ហត្ថ ឬ ១០ ហត្ថ ត្រង់កណ្ដាលទ្វារ ដើម្បីរាំងទ្វារព្រះនគរ ។

បទថា **បឋវឹ** បានដល់ ផែនដី ។ បទថា **សិតោ** បានដល់ កប់ខាងក្នុងដី ។ បទថា **សិយា** ប្រែថា គប្បីជា ។

ពីរបទថា **ចតុព្ភិ វាតេភិ** បានដល់ គឺព្រោះខ្យល់ដែលមកអំពីទិសទាំង ៤ ។ បទថា **អសម្បកម្បិយោ** បានដល់ មិនអាចឲ្យញាប់ញ័រ ឬនឹងឲ្យកម្រើកបាន ។ បទថា **តថូបមំ** បានដល់ មានឧបមាយ៉ាងនោះ ។ បទថា **សប្បុរិសំ** បានដល់ បុរសដ៏ប្រសើរ ។ បទថា **វទាមិ** ប្រែថា តថាគតពោល ។

បាទព្រះគាថាថា **យោ អរិយសច្ចានិ អវេច្ច បស្សតិ** សេចក្ដីថា

បុគ្គលណាឈមចុះដោយបញ្ញា ឃើញនូវអរិយសច្ច ៤ ។ អរិយសច្ចក្នុងព្រះគាថានោះ គប្បីជ្រាបដោយន័យដែលខ្ញុំពោលហើយក្នុងវិសុទ្ធិមគ្គ ។

តែក្នុងទីនេះ មានសេចក្តីសង្ខេបដូចតទៅនេះ សសរខឿនដែលគេកប់ដីគប្បីមិនញាប់ញ័រ ព្រោះខ្យល់ដែលមកអំពីទិសទាំង ៤ បាន ព្រោះមានគល់ចាក់ចូលជ្រៅ យ៉ាងណា បុគ្គលណាពិចារណាឃើញអរិយសច្ចទាំងឡាយ ព្រះតថាគតហៅបុគ្គលនោះថា សប្បុរសដែលមានឧបមាដូច្នោះ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបុគ្គលនេះ ជាអ្នកមិនញាប់ញ័រដោយខ្យល់ គឺពាក្យសម្តីរបស់តិរ្ថិយទាំងឡាយ ដូចសសរខឿនមិនញាប់ញ័រដោយខ្យល់ដែលមកអំពីទិសទាំង ៤ ដូច្នោះ គឺជាបុគ្គលដែលអ្នកដទៃមិនអាចឲ្យញាប់ញ័រ ឬដើម្បីឲ្យឃ្លាតចាកការឃើញនេះបាន ព្រោះហេតុនោះ ក្នុងព្រះសូត្រដទៃ ព្រះមានព្រះភាគ ក៏ត្រាស់ក្នុងសំយុត្តនិកាយ មហាវារវគ្គថា

ម្នាលភិក្ខុទាំងឡាយ ដូចសសរដែកក្តី សសរគោលក្តី ដែលមានរណ្តៅដ៏ជ្រៅ គេដាំស៊ប់សួនល្អឥតមានកម្រើក ឥតមានញាប់ញ័រ បើទុកជាភ្លៀងលាយដោយខ្យល់ដ៏ខ្លាំង មកអំពីទិសខាងកើត ក៏មិនធ្វើសសរនោះឲ្យកម្រើក មិនធ្វើឲ្យរញ្ជួយ មិនធ្វើឲ្យញាប់ញ័រ បើទុកជាខ្យល់បក់មកអំពីទិសខាងលិចក្តី ។បេ។ អំពីខាងជើងក្តី ភ្លៀងដែលលាយដោយខ្យល់ដ៏ខ្លាំង មកអំពីទិសខាងត្បូងក្តី ក៏មិនធ្វើឲ្យសសរនោះ កម្រើករញ្ជួយញាប់ញ័រឡើយ ។ ដំណើរនោះ

ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះរណ្ដៅជ្រៅ ព្រោះសសរគេដាំស៊ប់សួនល្អ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈ ឬព្រាហ្មណ៍ឯណានីមួយ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខ ។បេ។ ដឹងច្បាស់តាមសេចក្ដីពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរម្ងត់ទុក្ខ សមណៈ ឬព្រាហ្មណ៍ទាំងនោះ មិនក្រឡេកមើលមុខសមណៈ ឬព្រាហ្មណ៍ដទៃថា លោកដ៏ចម្រើននេះ កាលបើដឹង ក៏ដឹងដោយពិត កាលបើឃើញ ក៏ឃើញដោយពិត ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បានឃើញនូវអរិយសច្ច ៤ ដោយប្រពៃ ដូច្នេះ ។

ព្រះមានព្រះភាគ កាលត្រាស់គុណនៃរតនៈ ដោយអំណាចរបស់ព្រះ-សោតាបន្ន ដែលមនុស្សជាច្រើនឃើញបានប្រចក្សប៉ុណ្ណោះ យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបប្រកបសច្ចវាចាថា **ឥទម្បិ សង្ឃេ** ដូច្នេះ ។

អត្ថនៃគាថានោះ គប្បីជ្រាបដោយន័យដែលខ្ញុំពោលទុកហើយខាងដើមនោះឯង អាជ្ញានៃគាថានេះ អមនុស្សក្នុងមួយសែនកោដិចក្រវាល ក៏ទទួលហើយ ។

ព្រះមានព្រះភាគ កាលត្រាស់សច្ចៈដែលមានព្រះសង្ឃជាទីតាំងដោយគុណរបស់ព្រះសោតាបន្ន ដោយមិនប្លែកគ្នាយ៉ាងនេះហើយ ឥឡូវនេះ ទើប

ត្រាស់ថា ព្រះសោតាបន្ន ៣ ពួកនោះ គឺឯកពីជី ១ កោលំកោលៈ ១ សត្តក្ខត្តុបរមៈ ១ ។ ដូចព្រះតម្រាស់ ( ក្នុងបុគ្គលប្បញ្ញត្តិ ) ថា

បុគ្គលខ្លះ ក្នុងលោកនេះ ដល់នូវសោតៈ ព្រោះអស់ទៅនៃសញ្ញោជនៈ ៣ មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ បុគ្គលនោះ កើតក្នុងភព ជារបស់មនុស្សតែម្តងទៀត ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខនេះហៅថា បុគ្គលជាឯកពីជី ។ បុគ្គលនោះ ស្ទុះទៅ អន្ទោលទៅកាន់ត្រកូល ២ ឬ ៣ ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខ នេះហៅថា បុគ្គលជាកោលំកោលៈ ។ បុគ្គលនោះ ស្ទុះទៅ អន្ទោលទៅក្នុងទេវតា និងមនុស្សអស់វារៈ ៧ ដង ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខ នេះហៅថា បុគ្គលជាសត្តក្ខត្តុំបរមៈ ដូច្នេះ ។

ទ្រង់បំណាងត្រាស់ដល់គុណរបស់ព្រះសោតាបន្ន ដែលជាសត្តក្ខត្តុបរមៈ ជាអ្នកតិចជាងសោតាបន្ន ៣ ពួកនោះ ទើបទ្រង់ផ្តើមពាក្យថា **យេ អរិយសច្ចានិ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **យេ អរិយសច្ចានិ** មានន័យដូចខ្ញុំពោលហើយនោះឯង ។

បទថា **វិភាវយន្តិ** សេចក្តីថា កម្ចាត់ងងឹត គឺកិលេសដែលបិទបាំងនូវសច្ចៈដោយឱភាស គឺបញ្ញា ធ្វើនូវការជាក់ច្បាស់របស់ខ្លួនឲ្យប្រាកដ ។

*បទថា* **គម្ភីរបញ្ញេន** *បានដល់ ទ្រង់មានបញ្ញាដែលប្រតិស្ឋាន ដែលបុគ្គលមិនគប្បីបានដោយញាណរបស់លោក ព្រមទាំងទេវលោក ព្រោះទ្រង់មានបញ្ញាមិនអាចប្រមាណបាន មានពាក្យអធិប្បាយថា ទ្រង់ជាសព្វញ្ញូ ។*

*បទថា* **សុទេសិតានិ** *សេចក្តីថា ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយដោយល្អ ដោយន័យទាំងឡាយនោះៗ មានដោយសង្ខេប ដោយពិស្តារសកល និងដោយបន្រ្ទបបន្រ្ទមជាដើម ។*

*បាទគាថាថា* **កិញ្ចាបិ តេ ហោន្តិ ភុសប្បមត្តា** *សេចក្តីថា បុគ្គលដែលធ្វើឲ្យជាក់ច្បាស់នូវអរិយសច្ចហើយនោះ ជួនកាល ដល់នូវឋានៈជាទីតាំងនៃសេចក្តីប្រមាទ ដូចទេវរាជ ឬស្តេចចក្រពត្តិជាដើម ជាអ្នកប្រមាទយ៉ាងក្រៃលែងក៏ពិត តែព្រះអរិយបុគ្គលពួកណា តាំងនៅហើយ ដោយការរម្ងត់អភិសង្ខារវិញ្ញាណ ដោយសោតាបត្តិមគ្គញាណ គប្បីធ្វើនាមរូបឲ្យកើតឡើងក្នុងសង្សារវដ្ត ដែលមិនមានទីបំផុតខាងដើម អស់ ៧ ជាតិ មិនធ្វើភពទី ៨ ឲ្យកើតឡើង ព្រោះរម្ងត់នាមរូបទាំងនោះចេញបាន ព្រោះនាមរូបដល់នូវការតាំងនៅមិនបាន តែបានចម្រើនវិបស្សនាក្នុងភពទី ៧ នោះឯង ក៏បានសម្រេចអរហត្ត ។*

*ព្រះមានព្រះភាគ កាលត្រាស់គុណរបស់សង្ឃរតនៈ ដោយអំណាចនៃព្រះសោតាបន្នដែលជាសត្តក្ខត្តុបរមៈយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់បានអាស្រ័យគុណនោះឯង ទ្រង់ប្រកបសច្ចវាចាថា* **ឥទម្បិ សង្ឃេ** *ដូច្នេះ ។*

អត្ថនៃបាទគាថានោះ គប្បីជ្រាបដោយន័យដែលខ្ញុំពោលហើយខាងដើមនោះឯង អាថ្មានៃគាថានោះ អមនុស្សមួយសែនកោដិចក្រវាល បានទទួលហើយ ។

ព្រះមានព្រះភាគត្រាស់សច្ចៈ ដែលមានព្រះសង្ឃជាទីតាំងដោយគុណ គឺការមិនកើតទៀតក្នុងភពទី ៨ របស់ព្រះសោតាបន្ន ដែលជាសត្តក្ខត្តុបរមៈ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីត្រាស់ដល់គុណរបស់ព្រះសោតាបន្ននោះឯង ជាបុគ្គលដែលត្រូវកើតអស់ ៧ ភពថា ពិសេសជាងបុគ្គលទាំងឡាយដទៃ ដែលលះនូវការប្រកាន់មាំក្នុងភពមិនបាន ទើបទ្រង់ផ្តើមថា **សហាវស្ស** ដូច្នេះជាដើម ។

ក្នុងគាថានោះ សព្ទថា **សហាវ** បានដល់ ព្រមនោះឯង ។ បទថា **អស្ស** បានដល់ ព្រះសោតាបន្នពួកណានីមួយ ក្នុងបណ្តាសោតាបន្នទាំង ៣ ពួក ដែលព្រះមានព្រះភាគត្រាស់ហើយថា ព្រះសោតាបន្នទាំងនោះ តែងមិនកាន់យកភពទី ៨ ដើម្បីកើតឡើយ ។

បទថា **ទស្សនសម្បទាយ** បានដល់ ដោយការដល់ព្រមជាមួយនឹងសោតាបត្តិមគ្គ ពិតហើយ សោតាបត្តិមគ្គ លោកហៅថា **ទស្សន** ព្រោះឃើញនូវព្រះនិព្វានមុនព្រះអរិយៈគ្រប់ពួក ព្រោះការដល់ព្រមនៃកិច្ច ដែលលោកឃើញព្រះនិព្វាន ហើយគប្បីធ្វើ ភាពដែលសោតាបត្តិមគ្គនោះប្រាកដក្នុងខ្លួន ឈ្មោះថា **ទស្សនសម្បទាយ** ព្រមដោយទស្សនសម្បទានោះឯង ។

បទថា **សុ** ក្នុងគាថានេះថា **តយស្សុ ធម្មា ជហិតា ភវន្តិ** ជានិបាត ប្រើក្នុងអត្ថធ្វើបទឲ្យពេញ ដូចពាក្យថា **សុ** ក្នុងប្រយោគទាំងឡាយ មាន ប្រយោគជាដើមថា **ឥទំសុ មេ សារិបុត្ត មហាវិកដភោជនស្មិំ ហោតិ** ម្នាលសារីបុត្ត នេះឯង ជាវត្តខាងភោជនយ៉ាងចម្លែកធំរបស់តថាគត ។

ក្នុងបយោគនេះ មានអត្ថត្រឹមប៉ុណ្ណេះថា ព្រោះព្រះសោតាបន្នោះលះ គឺលះបង់នូវធម៌ ៣ ប្រការចេញបាន មួយអន្លើដោយទស្សនសម្បទានោះ ដើម្បីសម្តែងដល់ធម៌ ដែលព្រះសោតាបន្នលះបានហើយក្នុងឥឡូវនេះ ទើប ព្រះមានព្រះភាគត្រាស់ថា **សក្កាយទិដ្ឋិ វិចិកិច្ឆិតញ្ច សីលព្វតំ វាបិ យទត្ថិ កិញ្ចិ** ធម៌ ៣ គឺសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ឬការប្រព្រឹត្តិ តាមណាមួយ ។

ក្នុងគាថានេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា ទិដ្ឋិមានវត្ថុ ២០ ក្នុង កាយដែលមាន បានដល់ ក្នុងកាយ ពោល គឺឧបាទានក្ខន្ធ ៥ ឈ្មោះថា **សក្កាយទិដ្ឋិ** ម្យ៉ាងទៀត សូម្បីទិដ្ឋិដែលមាននៅក្នុងកាយ ក៏ឈ្មោះថា សក្កា-យទិដ្ឋិ អធិប្បាយថា ទិដ្ឋិដែលមាននៅក្នុងកាយ មានប្រការដូចពោល ហើយ ។ ម្យ៉ាងទៀត ដែលឈ្មោះថា **សក្កាយទិដ្ឋិ** ព្រោះអត្ថថា ជាទិដ្ឋិក្នុង កាយដែលមាននោះឯង អធិប្បាយថា ទិដ្ឋិប្រព្រឹត្តទៅយ៉ាងនេះថា តួខ្លួន ពោល គឺរូបក្ខន្ធជាដើម ក្នុងកាយដែលមាន មានប្រការដូចពោលហើយ ឈ្មោះថា **សក្កាយទិដ្ឋិ**។

ទិដ្ឋិគ្រប់ប្រការ ឈ្មោះថា ព្រះសោតាបន្ននោះលះបានហើយ ព្រោះលោកលះសក្កាយទិដ្ឋិនោះបានហើយនោះឯង ឯសក្កាយទិដ្ឋិនោះឯង ជាឫសគល់នៃទិដ្ឋិទាំងពួងនោះ ។

បញ្ញា លោកហៅថា **ចិកិច្ឆិតំ** ( គុណជាតិជាគ្រឿងព្យាបាល ) ព្រោះចូលទៅស្ងប់ព្យាធិ គឺកិលេសទាំងពួង បញ្ញាជាអ្នកព្យាបាលនោះ ទៅប្រាសធម្មជាតនេះ ឬធម្មជាតនេះ ទៅប្រាសចាកបញ្ញាដែលជាអ្នកព្យាបាលនោះ ព្រោះហេតុនោះ ទើបធម្មជាតនោះ ឈ្មោះថា **វិចិកិច្ឆិតំ** ។ បទថា **វិចិកិច្ឆិតំ** នោះ ជាឈ្មោះនៃសេចក្តីសង្ស័យក្នុងវត្ថុ ៨ ប្រការ តាមដែលពោលដោយន័យថា សេចក្តីសង្ស័យក្នុងព្រះសាស្តា ដូច្នេះជាដើម ។ ព្រោះសោតាបន្នលះនូវសេចក្តីសង្ស័យនោះចេញបាន ទើបសេចក្តីសង្ស័យគ្រប់យ៉ាង ឈ្មោះថា លោកលះបានហើយ ព្រោះសេចក្តីសង្ស័យនោះ ជាមូលនៃសេចក្តីសង្ស័យទាំងពួង ។

សីលច្រើនប្រការ មានគោសីល និងកុក្កុរសីលជាដើម និងវត្ត មានគោវត្ត និងកុក្កុរវត្ត ( ការប្រព្រឹត្តិដូចសត្វឆ្កែ ) ជាដើម ដែលមកហើយក្នុងសូត្រទាំងឡាយ មានយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ខាងក្រៅសាសនានេះ មានទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុសមានសភាពយ៉ាងនេះណាថា សេចក្តីបរិសុទ្ធិព្រោះសីល សេចក្តីបរិសុទ្ធព្រោះវត្ត ... ដូច្នេះ លោកហៅថា **សីលព្វត** ។ ព្រោះលះសីល និងវត្តនោះ

បាន តបៈដែលមិនស្ងាប់ទាំងពួង មានទត្តិយតបៈ ( តបៈរបស់មនុស្សអាក្រាត ) និងមុណ្ឌិយតបៈ ( តបៈរបស់មនុស្សក្បាលត្រងោល ) ជាដើម ក៏ព្រះសោតាបន្នលះបាន ។ ព្រោះថា សីលវត្តនោះ ជាឫសគល់នៃសីលវត្តទាំងពួង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងទីបំផុតនៃពាក្យទាំងពួងថា **យទត្ថិ កិញ្ចិ** ។ បណ្ឌិតគប្បីជ្រាបថា សក្កាយទិដ្ឋិ ក្នុងពាក្យថា **សក្កាយទិដ្ឋិ វិចិកិច្ឆិតញ្ច សីលព្វតំ វាបិ** នេះ ព្រះសោតាបន្នលះបាន ដោយការដល់ព្រមនៃការឃើញទុក្ខ លះវិចិកិច្ឆាចេញបាន ដោយការដល់ព្រមនៃការឃើញសមុទយៈ លះសីលព្វតបរាមាសចេញបាន ដោយការឃើញព្រះនិព្វានដោយមគ្គ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងការលះកិលេសវដ្ដនៃព្រះសោតា-បន្នបុគ្គលយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងនូវការលះវិបាកវដ្ដក្នុងកាលកិលេសវដ្ដនៅមាន ទើបត្រាស់ថា **ចតូហបាយេហិ ច វិប្បមុត្តោ** ជាដើម ។

ក្នុងព្រះគាថានោះ នរក សត្វតិរច្ឆាន បិត្តិវិស័យ និងអសុរកាយ ឈ្មោះថា អបាយ ៤ អធិប្បាយថា ព្រះអរិយបុគ្គលនេះ សូម្បីកើតក្នុងភព ៧ ក៏ផុតហើយចាកអបាយ ៤ នោះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងដល់ការដែលព្រះសោតាបន្ននោះលះវិបាកវដ្ដបានហើយ ឥឡូវនេះ កាលទ្រង់សម្ដែងដល់ការលះកម្មវដ្ដ ដែល

ជាឫសគល់របស់វិបាកវដ្តនេះ ទើបត្រាស់ថា **ឆ ចាភិឋានានិ អភព្វោ កាតុំ** ដូច្នេះ ។

កម្មដែលគ្រោតគ្រាត ឈ្មោះថា **អភិឋាន** ព្រះសោតាបន្ននេះ ជាអ្នកមិនធ្វើអភិឋានទាំងនោះ ។ អភិឋាន ៦ នេះ អ្នកសិក្សាគប្បីជ្រាបថា បានដល់ កម្ម គឺមាតុឃាត ១ បិតុឃាត ១ អរហន្តឃាត ១ លោហិតុប្បាទ ១ សង្ឃភេទ ១ និងការចូលសាសនាដទៃ ១ ដែលព្រះមានព្រះភាគត្រាស់ក្នុងអង្គុត្តរនិកាយ ឯកនិបាតថា

ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ គប្បីផ្តាច់បង់ជីវិតមាតា ដោយហេតុឯណា ហេតុនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ ។ គឺថា ហេតុនុ៎ះ មិនដែលមានឡើយ ដូច្នេះជាដើម ។

សូម្បីព្រះអរិយបុគ្គល ដែលដល់ព្រមដោយទិដ្ឋិ មិនសម្លាប់សូម្បីត្រឹមស្រមោចខ្មៅ ស្រមោចក្រហម ក៏ពិត តែអភិឋាន ៦ នោះ ព្រះមានព្រះភាគត្រាស់ដើម្បីតិះដៀលភាពជាបុថុជ្ជន ព្រោះថា បុថុជ្ជន រមែងធ្វើនូវអភិឋានដែលមានទោសច្រើនយ៉ាងនេះ ព្រោះខ្លួនមិនទាន់ដល់ព្រមដោយទិដ្ឋិ ។ តែបុគ្គលដល់ព្រមដោយទិដ្ឋិ មិនគួរធ្វើអភិឋានទាំងនោះ ។

**អភព្វោ** សព្វ ក្នុងបាទគាថាថា **ឆ ចាភិឋានានិ អភព្វោ កាតុំ** នេះ ជាការសម្តែងដល់ការមិនធ្វើអភិឋាន ៦ ក្នុងវាងភព ។ ពិតហើយ ក្នុង

អន្តរភព ព្រះអរិយបុគ្គលទាំងនេះ ទោះបីមិនដឹងថា ខ្លួនជាអរិយសាវក ក៏មិនធ្វើអភិឋានទាំង ៦ ឬធ្វើបញ្ចវេរ ៥ មានការសម្លាប់សត្វជាដើម គឺមិនធ្វើឋានៈ ៦ មួយអន្ទើដោយការចូលសាសនាដទៃ អាចារ្យពួកខ្លះ ពោលថា អភិឋាន ៦ ដូច្នេះក៏មាន ។ ក្នុងសេចក្តីនេះ មានរឿងក្មេងអ្នកស្រុក ជាអរិយសាវិកា ចាប់តែត្រីងាប់ជាដើមជាគំរូ ។

ព្រះមានព្រះភាគ កាលត្រាស់ដល់គុណរបស់អរិយសាវក ដែលកើតហើយអស់ ៧ ជាតិដែលជាសង្ឃរតនៈ ដោយអំណាចនៃភាពជាបុគ្គលមានគុណវិសេសជាងបុគ្គលទាំងឡាយ ដែលលះនូវការប្រកាន់មាំក្នុងភពមិនបាន យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវាចាថា **ឥទម្បិ សង្ឃេ** ដូច្នេះ ។

អត្ថនៃព្រះគាថានោះ គប្បីជ្រាបដោយន័យដែលខ្ញុំបានពោលហើយខាងដើមនោះឯង អាជ្ញានៃគាថានេះ ដែលអមនុស្សក្នុងមួយសែនកោដិចក្រវាលបានទទួលហើយ ។

ព្រះមានព្រះភាគ កាលត្រាស់សច្ចៈដែលមានព្រះសង្ឃជាទីតាំងនៃព្រះអរិយបុគ្គលដែលកើតហើយអស់ ៧ ភព ដោយអំណាចជាអ្នកមានគុណវិសេសជាងបុគ្គលទាំងឡាយ ដែលលះនូវការប្រកាន់មាំក្នុងភពមិនបាន យ៉ាងនេះហើយ ឥឡូវនេះ បំណងនឹងត្រាស់ដល់បុគ្គល ដែលដល់ព្រមដោយទស្សនៈ សូម្បីនៅដោយសេចក្តីប្រមាទដោយគុណ គឺការមិនបិទបាំង

វត្ថុដែលខ្លួនបានធ្វើហើយថា ព្រះសោតាបន្នដែលដល់ព្រមដោយទស្សនៈ មិនមែនជាបុគ្គលមិនគួរធ្វើអភិឋាន ៦ តែម្យ៉ាងឡើយ តែលោកធ្វើបាបណាមួយសូម្បីតិចតួច ក៏មិនបិទបាំងបាបនោះ ដូច្នេះ ទើបទ្រង់ផ្ដើមថា **កិញ្ចាបិ សោ កម្មំ ករោតិ បាបកំ** ដូច្នេះជាដើម ។

អត្ថនៃបាទព្រះគាថានោះថា ព្រះអរិយបុគ្គលនោះ ជាអ្នកដល់ព្រមដោយទស្សនៈ អាស្រ័យការនៅដោយសេចក្ដីប្រមាទ ព្រោះការភ្លេចភ្លាំងសតិ ក៏គង់វៀរការកន្លងល្មើស ដោយចេតនាដែលជាលោកវជ្ជៈ ដែលព្រះមានព្រះភាគត្រាស់សំដៅយកថា ពួកសាវ័កនៃតថាគត សូម្បីមានហេតុដល់ជីវិត ក៏មិនហ៊ានប្រព្រឹត្តកន្លងសិក្ខាបទនោះឡើយ រមែងធ្វើនូវបាបកម្មដទៃ មានកុដិការសហសេយ្យា ដែលព្រះពុទ្ធទ្រង់រង្កៀស ពោល គឺកន្លងល្មើសសិក្ខាបទដែលជាបណ្ណត្តិវជ្ជៈ ( មានការដេកក្នុងកុដិតែមួយជាមួយអនុបសម្បន្ន លើស ៣ រាត្រី ឬក្នុងកុដិមួយជាមួយមាតុគ្រាមសូម្បីមួយរាត្រី ) ដោយកាយ ឬធ្វើបាបកម្ម មានការឈានកន្លងល្មើសសិក្ខបទ ដែលជាបទសោធម្ម ( ការបង្រៀនធម៌ដល់អនុបសម្បន្ន ដោយពោលព្រមគ្នា ) ឧត្តរិឆប្បញ្ចវាចាធម្មទេសនា ( ការសម្ដែងធម៌ដល់មាតុគ្រាម ដែលមិនមានបុរសជាសម្គាល់ លើស ៥-៦ ម៉ាត់ ការពោលរោយរាយ និងការពោលញុះញង់ជាដើម ដោយវាចា ឬធ្វើបាបកម្ម មានការមិនពិចារណា ហើយប្រើប្រាស់ជាដើម ក្នុងការត្រេកអរដោយមាស និងប្រាក់ជាដើម ដែលជាហេតុឲ្យកើតលោកៈ

ទោសៈ និងការប្រើប្រាស់ចីវរជាដើម ព្រះអរិយបុគ្គលទាំងនោះ មិនបិទបាំងកម្មទាំងនោះ ព្រះអរិយបុគ្គលនោះដឹងថា កម្មនេះ ជារបស់មិនគួរ ខ្លួនមិនគួរធ្វើ សូម្បីបិទបាំងមួយស្របក់ ក៏បើកផ្ចារក្នុងសាស្តា ឬក្នុងសព្រហ្មចារី រមែងសម្តែងតាមធម៌ក្នុងខណៈនោះឯង ឬសង្រួមក្នុងវត្ថុដែលគួរសង្រួមយ៉ាងនេះថា អញនឹងមិនធ្វើទៀតឡើយ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះសោតាបន្នបុគ្គលនោះ មិនគួរបិទបាំងនូវបាបកម្មនោះឡើយ ព្រោះភាពនៃបុគ្គលដែលឃើញផ្លូវព្រះនិព្វានហើយ ជាបុគ្គលមិនគួរបិទបាំងនូវបាបកម្ម ដែលព្រះពុទ្ធទាំងឡាយសម្តែងហើយ អធិប្បាយថា ព្រះមានព្រះភាគត្រាស់ថា បុគ្គលដល់ព្រមដោយទស្សនៈ បុគ្គលមានបទ គឺព្រះនិព្វាន ដែលខ្លួនឃើញហើយ ធ្វើនូវបាបកម្មបែបនោះ មិនគួរបិទបាំងនូវកម្មនោះ ។

សួរថា ព្រះមានព្រះភាគត្រាស់ដូចម្តេច ឆ្លើយថា ព្រះមានព្រះភាគត្រាស់ក្នុងកោសម្ពិយសូត្រថា

ម្នាលភិក្ខុទាំងឡាយ ដូចជាកុមារក្មេង ជាកូនខ្ចី នៅដេកផ្ងារនៅឡើយ ប៉ះពាល់រងើកភ្លើងដោយដៃក្តី ដោយជើងក្តី ក៏ដកមកវិញជាប្រញាប់ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ ធម្មតារបស់បុគ្គលដែលប្រកបដោយទិដ្ឋិ គឺការចេញចាកអាបត្តិមានសភាពយ៉ាងណា ភិក្ខុក៏គង់ត្រូវអាបត្តិមានសភាពយ៉ាងនោះខ្លះដែរ តែថា ភិក្ខុ

នោះសម្តែង បើក ធ្វើឲ្យច្បាស់ឡើង នូវអាបត្តិនោះ ក្នុងសម្នាក់សាស្តា ឬក្នុងពួកសព្រហ្មចារី បុគ្គលជាអ្នកប្រាជ្ញដោយធាប់របស លុះសម្តែង បើក ធ្វើឲ្យច្បាស់ឡើងហើយ ក៏ដល់នូវកិរិយាសង្រួមតទៅ យ៉ាងនោះដែរ ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងគុណរបស់ព្រះសង្ឃរតនៈ ដែលដល់ព្រមដោយទស្សនៈ នៅដោយសេចក្តីប្រមាទ ដោយគុណ គឺការមិនបិទបាំងកម្មដែលខ្លួនធ្វើ យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯងទើបទ្រង់ប្រកបសច្ចវាចាថា **ឥទម្បិ សង្ឃេ** ដូច្នេះ ។

អត្ថនៃព្រះគាថានោះ អ្នកសិក្សាគប្បីជ្រាបដោយន័យដែលពោលហើយខាងដើមនោះឯង អាជ្ញានៃគាថានេះ ដែលអមនុស្សទាំងឡាយក្នុងមួយសែនកោដិចក្រវាលបានទទួលហើយ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងសច្ចៈដែលមានព្រះសង្ឃជាទីតាំងនៃបុគ្គលទាំងឡាយ ដែលទាក់ទងក្នុងសង្ឃ ដោយការប្រកាសគុណនោះៗ យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យបរិយត្តិធម៌ ដែលព្រះអង្គទ្រង់សម្តែងគុណនៃព្រះរតនត្រ័យ ទ្រង់សម្តែងដោយសង្ខេបក្នុងទីនេះ និងដោយពិស្តារក្នុងទីដទៃ បំណាន់នឹងពោលសច្ចៈដែលមានព្រះពុទ្ធជាទីតាំង ទើបទ្រង់ផ្តើមទៀតថា **វនប្បគុម្ពេ យថា ផុស្សិតគ្គេ** ជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះដូច្នេះ ពួកនៃឈើទាំងឡាយ ដែល

តាំងនៅហើយ គឺតាំងឡើងហើយ ដោយការដុះយ៉ាងក្រាស់ ឈ្មោះថា **វនំ**។ គុម្ពឈើដែលចម្រើនដោយឫស ខ្ទឹម ស្រាយ ក្រមុំ មែក ស្លឹក ឈ្មោះថា **បគុម្ពោ**។

គុម្ពឈើក្នុងព្រៃ ឈ្មោះថា **វនប្បគុម្ពោ** ព្រះមានព្រះភាគត្រាស់ថា **វនប្បគុម្ពោ** នេះ ( ជាសត្តមីវិភត្តិ ) ថា **វនប្បគុម្ពេ**។ កាលបើដូច្នេះ បុគ្គលណាម្នាក់ក៏អាចពោលបានថា **វនសណ្ឌោ** ( ដងព្រៃ ) ដូចពាក្យទាំងឡាយ មានពាក្យជាដើមថា **អត្ថិ សវិតក្កសវិចារេ អត្ថិ អវិតក្ក-អវិចារមត្តេ សុខេ ទុក្ខេ ជីវេ** ដូច្នេះ ។

បទថា **យថា** ជាពាក្យឧបមា ។ ត្រួយរបស់ដើមឈើនោះរីកហើយ ហេតុនោះ ទើបដើមឈើនោះ ឈ្មោះថា **ផុស្សិតគ្គេ** អធិប្បាយថា មានការកើតហើយត្រង់មែកតូច-ធំគ្រប់មែក ។

បទថា **ផុស្សិតគ្គោ** នោះ ព្រះមានព្រះភាគត្រាស់ហៅថា **ផុស្សិតគ្គេ** ដោយន័យដែលខ្ញុំពោលហើយខាងដើមនោះឯង ។

បាទព្រះគាថាថា **គិម្ហានមាសេ បឋមស្មឹ គិម្ហេ** បានដល់ ក្នុងខែ ១ បណ្តាខែទាំង ៤ ក្នុងរដូវក្តៅ បើបុគ្គលណាម្នាក់ពោលថា ក្នុងខែណា ក៏ត្រូវពោលថា ក្នុងខែចេត្រ ដែលផ្តើមរដូវក្តៅដំបូង ។ ពិតហើយ ខែចេត្រនោះ លោកហៅថា **បឋមគិម្ហោ** និងថា **ពាលវសន្តោ** ( រដូវស្លឹកឈើលាស់ )។ បទបន្តអំពីនោះ អត្ថប្រាកដជាក់ច្បាស់ហើយទាំងអស់ ។

បទថា **បឋមគិម្ហេ** នេះ ក្នុងគាថានេះ មានការប្រមូលមកជាអត្ថ គុម្ពឈើដែលបានបរិយាយនាមថា គុម្ពឈើខ្ចីដែលមានមែក ត្រួយរីកស្គុសស្គាយ ក្នុងព្រៃដែលក្រាស់ដោយដើមឈើផ្សេងៗ ក្នុងរដូវស្លឹកឈើលាស់ដែលឈ្មោះថា **បឋមគិម្ហ** ចាត់ថា ជាព្រៃដែលស្អាតក្រៃលែង យ៉ាងណា ព្រះមានព្រះភាគ ទ្រង់បានសម្តែងបរិយត្តិធម៌ដ៏ប្រសើរដែលឲ្យដល់ព្រះនិព្វាន ដោយទ្រង់បានសម្តែងផ្លូវឲ្យដល់ព្រះនិព្វាន មិនមែនសម្តែងព្រោះហេតុនៃលាភ ឬព្រោះហេតុនៃសក្ការៈជាដើមឡើយ តែទ្រង់ជាអ្នកមានព្រះហឫទ័យប្រកបដោយឧស្សាហ៍ និងអាណិតអាសូរក្រៃលែង ទ្រង់បានសម្តែងដោយមហាករុណាតែម្យ៉ាង ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខក្រៃលែង ដល់សត្វទាំងឡាយ មានឧបមាដូច្នោះ ព្រោះភាពនៃព្រះធម៌របស់ព្រះអង្គ ជាធម៌ដ៏មានសិរី គឺល្អក្រៃលែង ដោយផ្កាដែលមានប្រយោជន៍ច្រើនប្រការ មានខន្ធអាយតនៈជាដើម ឬមានសតិប្បដ្ឋាន និងសម្មប្បធានជាដើម ឬមានសីលក្ខន្ធសមាធិក្ខន្ធជាដើមដូច្នោះដូចគ្នា ។ ក្នុងពាក្យថា **បរមំ ហិតាយ** នេះ ជាអនុនាសិក ( និគ្គហិតចេញសំឡេងត្រង់ច្រមុះ ) ព្រះមានព្រះភាគ ទ្រង់ត្រាស់ដើម្បីងាយស្រួលដល់ការចងគាថា តែអត្ថមានដូច្នេះថា ព្រះមានព្រះភាគ ទ្រង់បានសម្តែងនូវធម៌ដ៏ប្រសើរ ដើម្បីព្រះនិព្វានដែលមានប្រយោជន៍យ៉ាងក្រៃលែង ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងបរិយត្តិធម៌ ដូចគ្នានឹងគុម្ពឈើក្នុង

ព្រៃដែលមានត្រួយ គឺផ្ការីកស្គុសស្គាយយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យនូវគុណនោះឯង ទ្រង់ប្រកបសច្ចវាចាដែលមានព្រះពុទ្ធជាទីតាំងថា **ឥទម្បិ ពុទ្ធេ** ដូច្នេះ ។

អត្ថនៃគាថានោះ គប្បីជ្រាបដោយន័យដែលពោលហើយខាងដើម តែគប្បីប្រកបបទ ១ យ៉ាងនេះថា ពុទ្ធរតនៈ ពោល គឺព្រះបរិយត្តិធម៌ មានប្រការតាមដែលពោលហើយនេះ ជារតនៈប្រណីត អាជ្ញានៃគាថានេះដែលអមនុស្សទាំងឡាយ ក្នុងមួយសែនកោដិចក្រវាល បានទទួលហើយ ។

ព្រះមានព្រះភាគ កាលត្រាស់សច្ចៈ ដែលមានព្រះពុទ្ធជាទីតាំងដោយបរិយត្តិធម៌យ៉ាងនេះហើយ ឥឡូវនេះ បំណងនឹងត្រាស់ដោយលោកុត្តរធម៌ ទើបទ្រង់ផ្តើមថា **វរោ វរញ្ញូ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **វរោ** សេចក្តីថា ដែលជនទាំងឡាយ អ្នកមានអធិមុត្តិដ៏ប្រណីតប្រាថ្នាហើយថា ឱហ្ន៎ សូមឲ្យពួកយើងគប្បីដូច្នេះ ។ ម្យ៉ាងទៀត ឈ្មោះថា **វរោ** ព្រោះប្រកបដោយគុណដ៏ប្រសើរ អធិប្បាយថា ជាបុគ្គលឧត្តម គឺប្រសើរលើសលប់ ។

បទថា **វរញ្ញូ** បានដល់ ទ្រង់ដឹងព្រះនិព្វាន ពិតហើយ ព្រះនិព្វានឈ្មោះថា **វរញ្ញូ** ព្រោះអត្ថថា ឧត្តមជាងធម៌ទាំងពួង ព្រះសម្មាសម្ពុទ្ធអង្គនេះទ្រង់ជ្រាបព្រះនិព្វាននោះដោយព្រះអង្គឯង ត្រង់មណ្ឌលនៃពោធិព្រឹក្ស ។

បទថា **វរទោ** សេចក្តីថា ទ្រង់ប្រទានធម៌ដ៏ប្រសើរដែលជាចំណែកនៃ

ធម៌ជាគ្រឿងចាក់ធ្លុះ ឬដែលជាចំណែកនៃវាសនាដល់ភិក្ខុទាំងឡាយ មាន បញ្ចវគ្គិយ កទូវគ្គិយ និងជដិលទាំងឡាយជាដើម និងដល់ទេវតា មួយអន្ទើដោយមនុស្សទាំងឡាយដទៃ ។

បទថា **វរាហរោ** សេចក្តីថា ព្រះសម្មាសម្ពុទ្ធ សត្វលោកហៅថា ទ្រង់នាំមកនូវធម៌ដ៏ប្រសើរ ព្រោះទ្រង់នាំមគ្គដ៏ប្រសើរមក ។ ពិតហើយ ព្រះមានព្រះភាគអង្គនោះបំពេញបារមី ៣០ តាំងអំពីព្រះពុទ្ធព្រះនាមទីបង្ករ ទ្រង់នាំមកនូវមគ្គដ៏ប្រសើរដែលជារបស់បុរាណ ដែលព្រះសម្មាសម្ពុទ្ធទាំងឡាយក្នុងកាលមុនទ្រង់យាងទៅហើយ ព្រោះហេតុនោះ ទើបសត្វលោកហៅថា **វរាហរោ** ដូច្នេះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **វរោ** ព្រោះបានចំពោះនូវសព្វញ្ញុតញ្ញាណ ឈ្មោះថា **វរញ្ញូ** ព្រោះទ្រង់ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ឈ្មោះថា **វរទោ** ព្រោះទ្រង់ប្រទានសុខ ដែលកើតអំពីវិមុត្តិដល់សត្វទាំងឡាយ ឈ្មោះថា **វរាហរោ** ព្រោះនាំបដិបទាដ៏ឧត្តមមកឲ្យព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **អនុត្តរោ** ព្រោះមិនមានបុគ្គលណាក្រៃលែងជាង ដោយលោកុត្តរគុណទាំងឡាយនេះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **វរោ** ព្រោះធ្វើឲ្យបរិបូណ៌ក្នុងឧបសមាធិដ្ឋាន ឈ្មោះថា **វរញ្ញូ** ព្រោះធ្វើឲ្យបរិបូណ៌ក្នុងបញ្ញាធិដ្ឋាន ឈ្មោះថា **វរទោ** ព្រោះធ្វើឲ្យបរិបូណ៌ក្នុងចាគាធិដ្ឋាន ឈ្មោះថា **វរា-**

**ហរោ** ព្រោះធ្វើឲ្យបរិបូណ៌ក្នុងសច្ចាធិដ្ឋាន ( នេះ ) ឈ្មោះថា ទ្រង់នាំមកនូវមគ្គសច្ចដ៏ប្រសើរ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **វរោ** ព្រោះជាទីតាំងនៃបុណ្យ ឈ្មោះថា **វរញ្ញូ** ព្រោះជាទីតាំងនៃបញ្ញា ឈ្មោះថា **វរទោ** ព្រោះទ្រង់ប្រទានឧបាយនោះៗ ដល់ជនទាំងឡាយដែលត្រូវការភាពជាពុទ្ធៈ ឈ្មោះថា **វរាហរោ** ព្រោះទ្រង់នាំមកនូវឧបាយនោះៗ ដល់ជនទាំងឡាយដែលត្រូវការជាព្រះបច្ចេកពុទ្ធ ឈ្មោះថា **អនុត្តរោ** ព្រោះមិនមាននរណាស្មើក្នុងគុណនោះៗ ឬព្រោះទ្រង់មិនមានអាចារ្យ ឬទ្រង់ជាអាចារ្យរបស់ជនដទៃ ឈ្មោះថា **ធម្មវរំ អទេសយិ** ព្រោះទ្រង់សម្តែងធម៌ប្រសើរ ដែលប្រកបដោយគុណមានភាពជាស្វាក្ខាតធម៌ជាដើម ដើម្បីគុណនោះៗ ដល់ជនទាំង-ឡាយ ដែលត្រូវការជាសាវ័ក ពាក្យដ៏សេសមានន័យដូចខ្ញុំពោលហើយនោះឯង ដូច្នេះ ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់ព្រះអង្គដោយលោកុត្តរធម៌ ៩ យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវាចាដែលមានព្រះពុទ្ធជាទីតាំងថា **ឥទម្បិ ពុទ្ធេ** ដូច្នេះ ។

អត្ថនៃព្រះគាថានោះ អ្នកសិក្សាគប្បីជ្រាបដោយន័យដែលខ្ញុំបានពោលខាងដើមនោះឯង តែក្នុងទីនេះ គប្បីជ្រាបយោជនាយ៉ាងនេះថា ព្រះមានព្រះភាគអង្គនេះ ទ្រង់ជ្រាបលោកុត្តរធម៌ ៩ ដ៏ប្រសើរណា ទ្រង់បានប្រទាននូវ

លោកុត្តធម៌ ៩ ដ៏ប្រសើរណា ទ្រង់បាននាំមកនូវព្រះលោកុត្តរធម៌ ៩ ដ៏ប្រសើរណា និងបានសម្តែងលោកុត្តរធម៌ ៩ ដ៏ប្រសើរណា ពុទ្ធរតនៈនេះ ជារតនៈដ៏ប្រណីត ។ អាជ្ញានៃគាថានេះដែលអមនុស្សទាំងឡាយ ក្នុងមួយសែនកោដិចក្រវាល បានទទួលហើយ ។

ព្រះមានព្រះភាគ ទ្រង់អាស្រ័យបរិយត្តិធម៌ និងលោកុត្តរធម៌ ត្រាស់សច្ចៈដែលមានព្រះពុទ្ធជាទីតាំង ២ គាថាយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណ គឺការសម្រេចអនុបាទិសេសនិព្វាននៃលោកទាំងឡាយ ដែលបានស្តាប់ព្រះបរិយត្តិធម៌នោះហើយ និងបានបដិបត្តិតាមក្រសែនៃធម៌ដែលបានស្តាប់មកហើយ ក៏បានសម្រេចលោកុត្តរធម៌ ៩ ប្រការ បំណងត្រាស់សច្ចវាចា ដែលមានព្រះសង្ឃជាទីតាំងទៀត ទើបទ្រង់ផ្តើមថា **ខីណំ បុរាណំ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខីណំ** បានដល់ អស់ជុំវិញហើយ ឬបានកាត់ផ្តាច់ហើយ ។

បទថា **បុរាណំ** បានដល់ របស់ចាស់ ។ បទថា **នវំ** បានដល់ ដែលកើតក្នុងបច្ចុប្បន្ន ។ បទថា **នត្ថិ សម្ភវំ** បានដល់ ការប្រាកដ មិនមាន ។ បទថា **វិរត្តចិត្តា** បានដល់ ជាអ្នកមានចិត្តប្រាសចាករាគៈ ។

ពីរបទថា **អាយតិកេ ភវស្មឹ** បានដល់ ក្នុងភពថ្មី ក្នុងអនាគតកាល ។ បទថា **តេ** សេចក្តីថា លោកពួកណាមានកម្មចាស់អស់ហើយ កម្មថ្មីក៏មិន

មាន លោកពួកណា មានចិត្តប្រាសចាកភាគៈក្នុងភពថ្មីតទៅ លោកទាំងនោះ ឈ្មោះថា ភិក្ខុខីណាស្រព ។

បទថា **ខីណាពីជា** បានដល់ មានពូជកាត់ផ្តាច់ហើយ ។ បទថា **អវិរូឡ្ហិឆន្ទា** គឺវៀរចាកការពេញចិត្ត ដែលចម្រើនឡើង ។ បទថា **និព្វន្តិ** បានដល់ រមែងរលត់ ។ បទថា **ធីរា** បានដល់ អ្នកដល់ព្រមដោយបញ្ញា ។ ពីរបទថា **យថាយម្បទីបោ** បានដល់ ប្រៀបដូចប្រទីប ។

មានពាក្យសួរថា លោកអធិប្បាយដូចម្តេច ឆ្លើយថា លោកអធិប្បាយទុកថា កម្មណាដែលជាបុរាណកម្ម បានដល់ កម្មក្នុងអតីតដែលកើតដល់សត្វទាំងឡាយ ហើយរលត់ទៅ ឈ្មោះថា ផលមិនអស់ហើយនោះឯង ព្រោះអាចនាំបដិសន្ធិមក ព្រោះមិនទាន់លះនូវជ័រ គឺតណ្ហាបាន កម្មចាស់នោះរបស់សត្វពួកណា ឈ្មោះថា អស់ហើយ ព្រោះមិនអាចឲ្យវិបាកជាបន្តបាន ព្រោះជ័រ គឺតណ្ហា បានរីងស្ងួតទៅដោយអំណាចអរហត្តមគ្គញាណ ប្រៀបដូចពូជដែលភ្លើងឆេះហើយ ដូច្នោះ ហើយកម្មឯណារបស់សត្វទាំងនោះ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ដោយអំណាចនៃការបូជាព្រះពុទ្ធជាដើម ហៅថា កម្មថ្មី ឯកម្មថ្មីនោះរបស់ជនពួកណា ឈ្មោះថា មិនមានសម្ភព ព្រោះមិនអាចឲ្យផលបន្តបាន ព្រោះលះតណ្ហាហើយនោះឯង ប្រៀបដូចផ្កាដែលរួចផុតចាកទងហើយ ដូច្នោះ ជនពួកណា ឈ្មោះថា មានចិត្តប្រាសចាកតម្រេកក្នុងភពតទៅបានហើយ ព្រោះលះតណ្ហានោះឯង ជនទាំងឡាយនោះ ឈ្មោះថា

ជាភិក្ខុទីណាស្រេព ឈ្មោះថា មានពូជអស់ហើយ ព្រោះអស់នូវបដិសន្ធិ-វិញ្ញាណ ដែលព្រះមានព្រះភាគត្រាស់ក្នុងគាថានេះថា **កម្មំ ខេត្តំ វិញ្ញាណំ ពីជំ** កម្មជាស្រែ វិញ្ញាណ ជាពូជ ដូច្នេះជាដើម ព្រោះការអស់ទៅនៃកម្មនោះឯង ។ សូម្បីការពេញចិត្តដោយអំណាចតណ្ហា ពោល គឺតណ្ហាក្នុងភពថ្មីដែលចម្រើនឡើង យ៉ាងណា មានហើយក្នុងកាលមុន ព្រោះតណ្ហាដែលចម្រើនឡើងនោះ ដែលខ្ញុំនគប្បីលះបានដោយការលះសមុទយៈនោះឯង ទើបព្រះអរិយបុគ្គលពួកនោះ ឈ្មោះថា ជាអ្នកមានការពេញចិត្តមិនចម្រើនឡើង ព្រោះមិនមានសម្ភវៈ ( ការកើត ) ក្នុងពេលចុតិ ដូចក្នុងកាលមុន ទើបឈ្មោះថា ជាអ្នកប្រាជ្ញ ព្រោះដល់ព្រមដោយបញ្ញា តែងរម្ងត់បាន ព្រោះការរលត់នៃវិញ្ញាណចុងក្រោយ ដូចប្រទីបដែលរលត់ទៅ ដូច្នោះ បានដល់រម៉ែងកន្លងនូវបញ្ញត្តិយ៉ាងនេះថា ជារូប ឬជាអរូបទៀត ។

បានឮមកថា សម័យនោះ ក្នុងបណ្តាប្រទីបទាំងឡាយដែលគេដុតដើម្បីបូជាទេវតាប្រចាំនគរ ប្រទីបមួយរលត់ទៅ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់ប្រទីបដែលរលត់ទៅនោះ ទើបត្រាស់ថា **យថាយម្បទីបោ។**

ព្រះមានព្រះភាគ កាលត្រាស់ដល់គុណនៃការសម្រេចអនុបាទិសេស-និព្វានធាតុរបស់ព្រះអរិយបុគ្គលទាំងឡាយ ដែលបានស្តាប់បរិយត្តិធម៌ដែលព្រះមានព្រះភាគត្រាស់ ២ គាថាដំបូងនោះហើយ បដិបត្តិតាមក្រសែនៃធម៌ដែលខ្ញុំនបានស្តាប់មកហើយនោះឯង បានសម្រេចលោកុត្តរធម៌ទាំង ៩ ប្រការ

យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះយ៉ាងនោះឯង ដើម្បីទ្រង់ប្រកបសច្ចវាចា ដែលមានព្រះសង្ឃជាទីតាំង ទើបត្រាស់ទេសនាថា **ឥទម្បិ សង្ឃេ** ដូច្នេះ ។

អត្ថនៃគាថានោះ គប្បីជ្រាបដោយន័យដែលខ្ញុំពោលហើយខាងដើមនោះឯង តែគប្បីជ្រាបវាចាប្រកបយ៉ាងនេះថា សង្ឃរតនៈ ពោល គឺព្រះនិព្វានរបស់កិក្ខុខីណាស្រពទាំងឡាយ ដោយប្រការតាមដែលបានពោលហើយនេះជារតនៈដ៏ប្រណីត អាជ្ញានៃគាថានេះ អមនុស្សទាំងឡាយ ក្នុងមួយសែនកោដិចក្រវាល បានទទួលហើយ ។

ក្នុងទីបំផុតនៃទេសនា សួស្តីមានហើយដល់រាជត្រកូល ឧបទ្រវៈទាំងពួងស្ងប់ហើយ សត្វ ៨៤០០០ បានត្រាស់ដឹងធម៌ ។

កាលនោះ សក្កទេវរាជទ្រង់ត្រិះរិះថា ព្រះមានព្រះភាគ ទ្រង់អាស្រ័យគុណព្រះរតនត្រ័យប្រកបសច្ចវាចា ធ្វើនូវសួស្តីដល់អ្នកនគរហើយ សូម្បីអញ ក៏គប្បីអាស្រ័យគុណព្រះរតនត្រ័យ ពោលនូវវត្ថុណាមួយ ដើម្បីសួស្តីដល់អ្នកនគរ ទើបត្រាស់ ៣ គាថាចុងក្រោយថា

**យានីធ ភូតានិ** ដូច្នេះជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំង ៣ នោះដូចតទៅនេះ

ព្រោះហេតុដែលព្រះពុទ្ធ បានទទួលឈ្មោះថា ព្រះតថាគត ព្រោះទ្រង់ដល់នូវប្រយោជន៍ ដូចបុគ្គលទាំងឡាយដែលខ្វល់ខ្វាយដើម្បីជាប្រយោជន៍

និងសេចក្ដីសុខដល់សត្វលោកគប្បីដល់ ព្រោះទ្រង់យាងទៅដោយប្រការដែលសត្វលោកទាំងឡាយ ដើម្បីប្រយោជន៍ដល់សត្វលោកទាំងនេះគប្បីទៅ ព្រោះទ្រង់ជ្រាបដល់វត្ថុដែលសត្វលោកទាំងឡាយ ដើម្បីប្រយោជន៍ដល់សត្វលោកទាំងនេះគប្បីជ្រាប ព្រោះទ្រង់ដឹងដោយប្រការដែលជនទាំងនេះ គប្បីដឹង ព្រោះទ្រង់យាងទៅយ៉ាងនេះ ព្រោះព្រះមានព្រះភាគ ដែលទេវតា និងមនុស្សទាំងឡាយបូជាពន់ពេក ដោយវត្ថុ មានផ្កា និងគ្រឿងក្រអូបជាដើម ដែលជាឧបករណ៍កើតខាងក្រៅ និងដោយបដិបត្តិ មានបដិបត្តិធម៌ សមគួរដល់ធម៌ជាដើម ដែលកើតក្នុងខ្លួន ព្រោះដូច្នោះ ទើបសក្កទេវរាជ ទ្រង់ប្រមូលបរិស័ទទាំងអស់ មួយអន្លើដោយព្រះអង្គឯង ត្រាស់ថា

**តថាគតំ ទេវមនុស្សបូជិតំ ពុទ្ធំ នមស្សាម សុវត្ថិ ហោតុ** យើងទាំងឡាយ សូមនមស្ការនូវព្រះពុទ្ធ ទ្រង់បានត្រាស់មកហើយដូចគ្នា ។

ព្រោះក្នុងចំណែកធម៌ មគ្គធម៌ដែលបុគ្គលគប្បីដល់បានដោយកម្លាំងនៃសមថៈ និងវិបស្សនាទាំងគូ យ៉ាងណា និព្វានធម៌ដែលព្រះអរិយបុគ្គលកាត់នូវធម៌ដែលជាចំណែកនៃកិលេស ក៏ដល់បាន ដូច្នោះ ព្រះធម៌ដែលបុគ្គលគប្បីដល់ គឺចាក់ធ្លុះហើយដោយបញ្ញាឯណា និព្វានធម៌ដែលព្រះមានព្រះភាគជាដើមទ្រង់សម្រេចហើយ រមែងសម្រេចបាន ព្រោះកម្ចាត់ទុក្ខទាំងពួងបានដូច្នោះ ព្រោះហេតុនោះ ទើបបណ្ឌិតហៅថា **តថាគត** ។

ម្យ៉ាងទៀត ព្រោះហេតុដែលព្រះសង្ឃ លោកហៅថា **តថាគត** ដូចគ្នា

ព្រោះលោកដល់នូវភាពជាព្រះសង្ឃបាន ដោយមគ្គនោះៗ ដូចគ្នា និងបុគ្គល បដិបត្តិដើម្បីជាប្រយោជន៍ដល់ខ្ទនទីងគប្បីដល់ ព្រោះដូច្នោះ ទើបសក្កទេវរាជ ត្រាស់ ២ គាថាដ៏សេសថា យើងទាំងឡាយ សូមនមស្ការនូវព្រះធម៌ ដែល មានមកហើយដូចគ្នា ដែលទេវតា និងមនុស្សបូជាហើយ សូមសួស្តីកើតមាន ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

សក្កទេវរាជ កាលត្រាស់ ៣ គាថានេះ យ៉ាងនេះហើយ ទ្រង់ធ្វើ ប្រទក្សិណព្រះមានព្រះភាគ ហើយយាងទៅកាន់ទេវនគរ មួយអន្លើដោយ ទេវបរិស័ទ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងរតនសូត្រនោះឯង ក្នុងថ្ងៃទី ២ សត្វ ៨៤០០០ ក៏បានសម្រេចធម៌ទៀត ព្រះមានព្រះភាគទ្រង់សម្តែងយ៉ាង នេះ រហូតដល់ថ្ងៃទី ៧ ការសម្រេចធម៌ មានដល់សត្វ ៨៤០០០ រាល់ៗ ថ្ងៃ យ៉ាងនេះឯង ។

ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងក្រុងវេសាលីអស់កន្លះខែ ហើយ ទ្រង់ប្រកាសថា តថាគតនឹងទៅកាន់ក្រុងរាជគ្រឹះ បន្ទាប់អំពីនោះ ព្រះរាជា ទាំងឡាយ ក៏បានជូនដំណើរព្រះសាស្តាដល់ឆ្នេរស្ទឹងគង្គាអស់កាល ៣ ថ្ងៃ មួយអន្លើដោយគ្រឿងសក្ការៈ ដែលរៀបចំថ្វាយទ្វេគុណនៃព្រះបាទពិម្ពិសារ នាគរាជទាំងឡាយដែលកើតក្នុងស្ទឹងគង្គាគិតគ្នាថា ពួកមនុស្សធ្វើសក្ការៈដល់ ព្រះតថាគត ពួកយើងមិនចេះធ្វើឬ ទើបនាំគ្នានិម្មិតទូកទាំងឡាយដែលសម្រេច ដោយមាស ប្រាក់ និងកែវមណី ឲ្យក្រាលបល្ល័ង្កទាំងឡាយ ដែលសម្រេច

ដោយមាស ប្រាក់ និងកែវមណីដូចគ្នា បានធ្វើទឹកឲ្យជរជាសទៅដោយផ្កាឈូក ដែលមាន ៥ ពណ៌ ហើយចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលថា សូមទ្រង់អនុគ្រោះពួកខ្ញុំទាំងឡាយ ព្រះមានព្រះភាគទ្រង់ទទួលនិមន្តន៍ហើយ កាលទ្រង់ទទួលនិមន្តន៍ហើយ ក៏យាងចុះលើទូករតនៈ ភិក្ខុ ៥០០ រូប ក៏ចុះកាន់ទូករៀងៗ អង្គ នាគរាជទាំងឡាយបាននិមន្តន៍ព្រះសាស្តា និងភិក្ខុសង្ឃ ឲ្យចូលទៅកាន់នាគពិភព ។

បានឮថា ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដល់នាគបរិស័ទអស់រាត្រីទាំងមូល ក្នុងនាគពិភពនោះ ក្នុងថ្ងៃទី ២ នាគរាជទាំងឡាយ បានថ្វាយមហាទានដោយខាទនីយ និងភោជនីយដែលជាទិព្វ ព្រះមានព្រះភាគ ទ្រង់អនុមោទនាហើយ យាងចេញអំពីនាគពិភព ភុម្មទេវតាគិតថា ពួកមនុស្សទាំងឡាយ និងនាគទាំងឡាយ ធ្វើសក្ការៈដល់ព្រះតថាគត ពួកយើងមិនចេះធ្វើឬ ដូច្នេះហើយ ទើបលើកស្វេតច្ឆត្រត្រង់ព្រៃ ត្រង់គុម្ពឈើ ដើមឈើ និងភ្នំជាដើម ដោយឧបាយនោះឯង មហាសក្ការៈកើតឡើងហើយ ដរាបដល់អកនិដ្ឋកព្រហ្ម ។ សូម្បីព្រះបាទពិម្ពិសារក៏បានធ្វើសក្ការៈទ្វេគុណ ជាងសក្ការៈដែលស្តេចលិច្ឆវីទាំងឡាយធ្វើ ក្នុងកាលដែលព្រះមានព្រះភាគយាងមក ព្រះរាជាបាននាំព្រះមានព្រះភាគទៅកាន់នគររាជគ្រឹះ អស់កាល ៥ ថ្ងៃ ដោយន័យដែលពោលហើយខាងដើមនោះឯង ។

ព្រះមានព្រះភាគ កាលយាងដល់ក្រុងរាជគ្រឹះដោយលំដាប់ ភិក្ខុទាំង-

ឡាយដែលប្រជុំគ្នាក្នុងរោងមូលខាងក្រោយកត្ត កើតនូវការសន្ទនាក្នុងចន្លោះឡើងថា ឱ ! អានុភាពរបស់ព្រះពុទ្ធមានព្រះភាគ ភូមិភាគ ៨ យោជន៍អំពីត្រើយអាយ និងត្រើយនាយនៃស្ទឹងគង្គា ដែលព្រះរាជា និងមហាជន ធ្វើនូវផែនដីដែលជាទីទាប និងទីខ្ពស់ឲ្យស្មើគ្នា រោយនូវខ្សាច់ ហើយក្រាលដោយផ្កា ទឹកក្នុងស្ទឹងគង្គាប្រមាណមួយយោជន៍ ក៏ដេរដាសទៅដោយផ្កាឈូកចម្រុះពណ៌ ទេវតាទាំងឡាយ លើកឆត្រដល់អនិដ្ឋកកព ឧទ្ទិសចំពោះព្រះពុទ្ធអង្គ ។

ព្រះមានព្រះភាគ ទ្រង់ជ្រាបការប្រព្រឹត្តិទៅនោះ ទ្រង់យាងចេញអំពីព្រះគន្ធកុដិ ទៅកាន់រោងមូលដោយបាដិហារ្យដ៏សមគួរក្នុងខណៈនោះ គង់លើបវរពុទ្ធាសនៈ ដែលគេក្រាលហើយ ព្រះមានព្រះភាគ កាលទ្រង់គង់ហើយ បានត្រាស់ដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ ភិក្ខុទាំងឡាយក៏ក្រាបទូលរឿងនោះឲ្យទ្រង់ជ្រាប ។ ព្រះមានព្រះភាគត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ការបូជាពិសេសនេះ មិនបានកើតឡើងដោយពុទ្ធានុភាពរបស់តថាគតឡើយ មិនមែនកើតឡើងដោយអានុភាពរបស់នាគ ទេវតា និងព្រហ្មឡើយ ដោយពិត ការបូជាពិសេសនេះ កើតឡើងដោយអានុភាពនៃបរិច្ចាគ មានប្រមាណតិចតួច ភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមិនដឹងនូវបរិច្ចាគប្រមាណតិចតួចនោះ ខ្ញុំព្រះអង្គទាំងឡាយ សូមព្រះវរោកាស សូមទ្រង់ត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គទាំងឡាយ ដោយប្រការ

ដែលខ្ញុំព្រះអង្គទាំងឡាយគប្បីដឹងរឿងនោះ ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមក មានព្រាហ្មណ៍ម្នាក់ឈ្មោះសង្ខៈ ក្នុងនគរតក្កសិលា មាណពឈ្មោះសុសិមៈជាកូនរបស់ព្រាហ្មណ៍នោះ មានអាយុ ១៦ ឆ្នាំ ថ្ងៃមួយ បានចូលទៅរកឪពុក ធ្វើអញ្ជលីកម្ម ហើយឈរក្នុងចំណែកម្ខាង ។ បិតានិយាយនឹងបុត្តនោះថា នែបាសុសិមៈ តើឯងមានរឿងអ្វី មាណពពោលថា បពិត្រលោកឪពុក ខ្ញុំត្រូវការសិក្សាសិប្បវិជ្ជាត្រង់នគរពារាណសី ។

ឪពុកពោលថា អើសុសិមៈ បើដូច្នោះ ចូរទៅចុះ សម្លាញ់របស់ឪពុកជាព្រាហ្មណ៍ឈ្មោះនោះ ចូរបាទៅកាន់សម្នាក់របស់ព្រាហ្មណ៍នោះហើយ រៀនសិប្បៈចុះ ហើយប្រគល់ទ្រព្យ ១០០០ កហាបណៈ ។ សុសិមមាណពកាន់យកទ្រព្យ ១០០០ កហាបណៈនោះហើយ លាមាតាបិតា ទៅកាន់នគរពារាណសីដោយលំដាប់ ចូលទៅរកអាចារ្យដោយវិធីប្រកបដោយមារយាទរៀបរយ ថ្វាយបង្គំហើយ ណែនាំខ្លួន អាចារ្យដឹងថា កុមារនេះជាកូនសម្លាញ់របស់ខ្លួន ទើបទទួលមាណពនោះសព្វយ៉ាង មាណពនោះបន្ទោបង់នូវការនឿយហត់ក្នុងការដើរផ្លូវឆ្ងាយហើយ បានប្រគល់កហាបណៈ ១០០០ ទៀបជើងអាចារ្យ សូមឱកាសរៀនសិប្បវិជ្ជា អាចារ្យឲ្យឱកាសហើយ ក៏ឲ្យសិក្សាមាណពនោះរៀនចងចាំទុកផង រៀនបានច្រើនផង ជំនាញក្នុងសិប្បៈដែលរៀនហើយ មិនភ្លេចភ្លាំង ដូចខ្លាញ់ដែលដាក់ក្នុងភាជន៍មាស ដូច្នោះ បាន

រៀនសិប្បវិជ្ជាដែលមនុស្សទូទៅរៀនអស់ ១២ ឆ្នាំ ក្នុងកាលត្រឹមតែ ២-៣ ខែប៉ុណ្ណោះ កាលធ្វើការស្វាធ្យាយ ឃើញតែខាងដើម និងត្រង់កណ្តាលនៃសិប្បៈនោះ តែមិនឃើញទីបំផុត កាលចូលទៅរកអាចារ្យ សាកសួរថា ខ្ញុំឃើញខាងដើម និងកណ្តាលប៉ុណ្ណោះ នៃសិប្បៈនោះ តែមិនឃើញទីបំផុត ។ អាចារ្យពោលថា នែបា សូម្បីខ្ញុំ ក៏មិនឃើញដូចគ្នា ទើបមាណពសាកសួរថា បពិត្រលោកអាចារ្យ កាលបើដូច្នោះ នរណាហ្ន៎ ដឹងនូវទីបំផុតនៃសិប្បៈនេះបាន ។ អាចារ្យឆ្លើយថា នែបា នៅឯព្រៃឥសិបតនៈ មានពួកឥសីរស់នៅ ឥសីទាំងនោះគប្បីដឹង ។ មាណពពោលថា បពិត្រលោកអាចារ្យ ខ្ញុំនឹងចូលទៅរកឥសីទាំងនោះ ហើយសាកសួរ ។ អាចារ្យឆ្លើយថា នែបា ចូរបាសាកសួរតាមសប្បាយចុះ ។ មាណពនោះ ទៅកាន់ព្រៃឥសិបតនៈ ចូលទៅរកព្រះបច្ចេកពុទ្ធទាំងឡាយ ហើយសាកសួរថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយ ដឹងខាងដើម កណ្តាល និងទីបំផុតនៃសិប្បៈឬ ។ ព្រះបច្ចេកពុទ្ធទាំងឡាយឆ្លើយថា អើមាណព មែនហើយ ពួកអាត្មាដឹង មាណពសាកសួរថា បពិត្រលោកម្ចាស់ៗ ឲ្យខ្ញុំសិក្សាផងបានដែរឬ ព្រះបច្ចេកពុទ្ធទាំងឡាយតបថា អើមាណព តែអ្នកត្រូវបួសសិន ព្រោះអ្នកដែលមិនបួសមិនអាចសិក្សាបានទេ ។ មាណពទទួលថា សាធុលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយឲ្យខ្ញុំបួសចុះ លោកម្ចាស់ទាំងឡាយ ធ្វើវត្ថុដែលលោកម្ចាស់ទាំងឡាយប្រាថ្នាហើយ សូមឲ្យខ្ញុំដឹងទីបំផុតនៃសិប្បៈចុះ ។

ព្រះបច្ចេកពុទ្ធទាំងនោះ ឲ្យមាណពនោះបួសហើយ ក៏មិនអាចទូន្មានក្នុងកម្មដ្ឋានបាន ព្រះបច្ចេកពុទ្ធទាំងនោះ ឲ្យសិក្សាអភិសមាចារិកវត្ត ដោយន័យជាដើមថា ចូរអ្នកស្លៀកយ៉ាងនេះ អ្នកគប្បីដណ្តប់យ៉ាងនេះ សុសីមៈនោះសិក្សាត្រង់ព្រៃឥសិបតនៈនោះ បានត្រាស់ដឹងនូវបច្ចេកពោធិញ្ញាណក្នុងកាលមិនយូរឡើយ ព្រោះខ្លួនសម្បូរដោយឧបនិស្ស័យ ទើបលោកប្រាកដក្នុងនគរពារាណសីទាំងមូលថា ព្រះបច្ចេកពុទ្ធសុសិមៈកើតឡើងហើយ លោកដល់នូវភាពដ៏ប្រសើរដោយលាភ និងយស មានបរិវារដល់ព្រម ព្រះបច្ចេកពុទ្ធសុសិមៈនោះ មិនយូរឡើយ ក៏បរិនិព្វាន ព្រោះលោកធ្វើកម្មជាហេតុឲ្យមានអាយុខ្លីមក ។ ព្រះបច្ចេកពុទ្ធទាំងឡាយ និងពួកមហាជនធ្វើនូវសរីរកិច្ចរបស់ព្រះបច្ចេកពុទ្ធសុសិមៈនោះ កាន់យកហើយនូវព្រះធាតុទាំងឡាយ ប្រតិស្ឋានក្នុងព្រះស្តូប ត្រង់ទ្វារនគរ ។

កាលនោះឯង សង្ខព្រាហ្មណ៍គិតថា កូនរបស់អញទៅយូរហើយ អញមិនដឹងដំណឹងរបស់កូននោះ ដូច្នេះ ចង់ជួបកូនក៏ចេញអំពីតក្កសិលា ទៅដល់ពារាណសីដោយលំដាប់ ឃើញពួកមហាជនប្រជុំគ្នា ក៏ត្រិះរិះថា ក្នុងបណ្តាពួកជនជាច្រើន គង់មាននរណាម្នាក់ដឹងការប្រព្រឹត្តិទៅនៃកូនរបស់អញខ្លះជាមិនខាន ដូច្នេះហើយ ទើបចូលទៅក្នុងទីនោះ សួរថា មាណពឈ្មោះសុសិមៈមកក្នុងទីនេះមានដែរឬ អ្នកទាំងឡាយដឹងការប្រព្រឹត្តិទៅរបស់មាណពនោះខ្លះដែរឬ មហាជនឆ្លើយថា អើព្រាហ្មណ៍ យើងទាំងឡាយដឹង សុសិមមាណព

ជាអ្នកចប់ត្រៃវេទក្នុងសម្នាក់របស់ព្រាហ្មណ៍ ក្នុងនគរនេះ បួសក្នុងសម្នាក់ព្រះបច្ចេកពុទ្ធទាំងឡាយ សម្រេចជាព្រះបច្ចេកពុទ្ធ បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ស្តូបនេះ មហាជនបានប្រតិស្ឋានដើម្បីសុសិមបច្ចេកពុទ្ធអង្គនោះ ។

សង្ខព្រាហ្មណ៍យកដៃវាយផែនដី យំខ្សឹកខ្សួល ទៅកាន់លានចេតិយនោះ ដកស្មៅទាំងឡាយ ហើយយកសំពត់ដណ្តប់កើបខ្សាច់មក ហើយរោយត្រង់លានព្រះចេតិយរបស់ព្រះបច្ចេកពុទ្ធ ស្រោចដោយទឹកដែលដាក់ក្នុងឃ្នោករបស់ខ្លួន ហើយធ្វើការបូជាដោយផ្កាទាំងឡាយ យកសំពត់ដណ្តប់ធ្វើជាទង់ជ្វាលាលើកឡើង ចងឆត្ររបស់ខ្លួនបាំងព្រះស្តូប ហើយចៀសចេញទៅ ។

ព្រះមានព្រះភាគ កាលទ្រង់នាំអតីតនិទានមកយ៉ាងនេះហើយ គ្រាទ្រង់បន្តអនុសន្ធិជាតកនោះឲ្យជាប់គ្នាក្នុងហេតុការណ៍បច្ចុប្បន្ន ទើបត្រាស់ធម្មកថាដល់ភិក្ខុទាំងឡាយថា ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយមិនគប្បីឃើញសេចក្តីនោះយ៉ាងនេះថា សង្ខព្រាហ្មណ៍ក្នុងសម័យនោះជាអ្នកដទៃ តថាគតនេះឯងជាសង្ខព្រាហ្មណ៍ តថាគតបានដកស្មៅត្រង់លានព្រះចេតិយរបស់ព្រះបច្ចេកពុទ្ធឈ្មោះសុសិមៈ ដោយអានិសង្សនៃកម្មរបស់តថាគតនោះ ជនទាំងឡាយបានធ្វើផ្លូវប្រមាណ ៨ យោជន៍ឲ្យប្រាសចាកដង្គត់ និងបន្លា ហើយធ្វើផ្ទៃដីឲ្យស្មើស្អាត តថាគតបានរោយខ្សាច់ត្រង់លានព្រះចេតិយនោះ ដោយផលដែលហូរចេញអំពីកម្មនោះ ជនទាំងឡាយបានរោយខ្សាច់ក្នុងផ្លូវប្រមាណ ៨ យោជន៍

តថាគតបានធ្វើការបូជាដោយផ្កាព្រៃ ត្រង់ព្រះចេតិយរបស់ព្រះបច្ចេកពុទ្ធនោះ ដោយផលដែលហូរចេញអំពីកម្មរបស់តថាគតនោះ ជនទាំងឡាយបានធ្វើនូវការក្រាលផ្កាដោយផ្កាច្រើនប្រភេទ ទាំងលើគោក ទាំងក្នុងទឹកប្រមាណ ៨ យោជន៍ តថាគតបានធ្វើការប្រោះព្រំនូវផែនដីនោះដោយទឹក ត្រង់លានព្រះចេតិយ ដោយទឹកក្នុងឃ្លោក ដោយអានិសង្សនៃកម្មរបស់តថាគតនោះ ទើបភ្លៀងបោក្ខរព័ស្សធ្លាក់ចុះក្នុងនគរវេសាលី តថាគតបានលើកទង់ និងចងឆត្រត្រង់ចេតិយរបស់ព្រះបច្ចេកពុទ្ធនោះ ដោយផលដែលហូរចេញនៃកម្មរបស់តថាគតនោះ មនុស្ស និងទេវតាទាំងឡាយ បានលើកទង់ជ្វាលា និងលើកស្វេតច្ឆត្រឡើង រហូតដល់អកនិដ្ឋកភព ម្នាលភិក្ខុទាំងឡាយ ការបូជាពិសេសដើម្បីតថាគតនេះ មិនមែនកើតឡើងដោយពុទ្ធានុភាព មិនមែនកើតឡើងដោយនាគានុភាព ទេវានុភាព និងព្រហ្មានុភាពឡើយ តែកើតឡើងដោយអានុភាពនៃបរិច្ចាគដែលមានប្រមាណតិចតួច ដូចពោលមកនេះឯង ។

ក្នុងទីបំផុតនៃព្រះធម្មទេសនា ព្រះមានព្រះភាគបានត្រាស់គាថានេះថា

**មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ**
**ចជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ។**

បើឃើញសេចក្តីសុខដ៏ធំទូលាយ ព្រោះលះបង់ សុខល្មម
ប្រមាណ អ្នកមានប្រាជ្ញា កាលឃើញសុខធំទូលាយ
គប្បីលះសុខល្មមប្រមាណចេញ ។៚

**រតនសូត្រទី ១ ចប់**

# សុត្តន្តបិដក

## អាមគន្ធសូត្រ

[ ២២ ] សប្បុរស កាលបរិភោគនូវស្រូវស្រងែ ស្រូវកន្ទុយ
ដំរី និងសណ្តែកព្រៃ បត្តមូល មូលមូល និងគវិមូល ដែល
បានមកដោយធម៌ មិនពោលពាក្យកុហក ព្រោះសេចក្តីប្រាថ្នា
នូវកាមទេ ។

បពិត្រកស្សបៈ លោកនេះ កាលបរិភោគនូវសាច់ណាមួយ
ដែលបុគ្គលធ្វើហើយដោយល្អ សម្រេចហើយដោយល្អ តាក់
តែងហើយដ៏ឧត្តម ដែលជនទាំងឡាយដទៃឲ្យហើយ កាល
បរិភោគនូវបាយស្រូវសាលី ឈ្មោះថា បរិភោគនូវវត្ថុ មាន
ក្លិនឆ្អាប ។

ម្នាលព្រហ្មពន្ធុ លោក កាលបរិភោគនូវបាយនៃស្រូវសាលី
ទាំងឡាយ ដោយសាច់នៃសត្វស្លាប ដែលបុគ្គលតាក់តែង
ល្អហើយ ពោលយ៉ាងនេះថា វត្ថុមានក្លិនឆ្អាប មិនគួរដល់
អាត្មាអញ ។

បពិត្រព្រះកស្សបៈ ខ្ញុំនឹងសួរនូវសេចក្តីនុ៎ះនឹងលោក វត្ថុមាន
ក្លិនឆ្អាបរបស់លោក មានប្រការដូចម្តេច ។ ការសម្លាប់សត្វ
វាយ កាត់ ចង លួច ពោលពាក្យកុហក បោកប្រាស់បញ្ឆោត
រៀនក្បួនឥតប្រយោជន៍ សេពកិរិយារបស់បុគ្គលដទៃ នេះ

ហៅថា វត្ថុមានក្លិនស្អាប មិនសំដៅយកការបរិភោគសាច់ទេ ។ ជនទាំងឡាយណា ក្នុងលោកនេះ មិនសង្រួមក្នុងកាមទាំង-ឡាយ ជាអ្នកប្រាថ្នា ញ៉ាមជ្រប់ក្នុងរស ប្រឡូកប្រឡល់ ដោយភាពមិនស្អាត គឺមិច្ឆាជីវៈ ជានត្ថិកទិដ្ឋិ មានកាយកម្មជាដើម មិនរាបសា ឲ្យដឹងបានដោយក្រ នេះហៅថា វត្ថុមានក្លិនស្អាប មិនសំដៅយកការបរិភោគសាច់ទេ ។ ជនទាំងឡាយណា ជាអ្នកប្រាថ្នាចំពោះវត្ថុដ៏សៅហ្មង ជាអ្នករឹងរូស ស៊ីសាច់ខ្នង ទ្រុស្តមិត្ត មិនមានអាណិត ប្រកាន់ខ្លួន មិនឲ្យទានជាប្រក្រតី មួយទៀត មិនដែលឲ្យវត្ថុអ្វីដល់អ្នកណាមួយ នេះហៅថា វត្ថុមានក្លិនស្អាប មិនសំដៅយកការបរិភោគសាច់ទេ ។

សេចក្ដីក្រោធ ស្រវឹង រឹងត្អឹង បង្កហេតុ បិទបាំងទោស ប្រណែន លើកខ្លួន ប្រកាន់ខ្លួន មើលងាយគេ ស្និទ្ធស្នាល ដោយពួកអសប្បុរស នេះហៅថា វត្ថុមានក្លិនស្អាប មិនសំដៅយកការបរិភោគសាច់ទេ ។ ពួកជនណា មានបាបជាប្រក្រតី ជំពាក់បំណុលគេ និយាយចាក់ដោតគេ កោងដោយវោហារ ទ្រុស្តសីល ក្នុងសាសនានេះ ជាជនអាក្រក់ ជនណាធ្វើអំពើអាក្រក់ ក្នុងលោកនេះ នេះហៅថា វត្ថុមានក្លិនស្អាប មិនសំដៅយកការបរិភោគសាច់ទេ ។ ពួកជនណា ក្នុងលោកនេះ ជា

អ្នកមិនសង្រួមក្នុងសត្វទាំងឡាយ កាន់យកទ្រព្យនៃបុគ្គលដទៃ ប្រកបខាងការបៀតបៀន ជាអ្នកទ្រុស្តសីល ជាព្រានសម្លាប់ដ៏សាហាវ មិនអើពើ នេះហៅថា វត្ថុមានក្លិនឆ្អាប មិនសំដៅយកការបរិភោគសាច់ទេ ។ សត្វទាំងឡាយណា ជាប់ជំពាក់ក្នុងពួកសត្វទាំងនោះ ជាអ្នកខឹង អ្នកសម្លាប់ ប្រកបក្នុងអកុសលជានិច្ច លះលោកនេះ នឹងទៅកាន់លោកងងឹត មានក្បាលសំយុងចុះទៅនរក នេះហៅថា វត្ថុមានក្លិនឆ្អាប មិន សំដៅយកការបរិភោគសាច់ទេ ។

ការមិនស៊ីត្រី និងសាច់ មិនស៊ីបាយ អាក្រាត ( កោរសក់ បួងសក់ លាបដោយភក់ ស្លៀកស្បែកខ្លាឃ្មុំ ) សេពខាងការបម្រើភ្លើង មួយទៀត អមរតបៈទាំងឡាយដ៏ច្រើន ដែលមានក្នុងលោក វេទមន្ត ការបូជាភ្លើង បូជាយញ្ញ ( មានអស្សមេធៈ ) ជាដើម និងការសេព ( នូវទីក្ដៅក្នុងគិម្ហៈ ) រដូវជាដើមទាំងនេះ ញ៉ាំងសត្វដែលមិនទាន់ឆ្លងផុតសេចក្ដីសង្ស័យឲ្យស្អាតមិនបានទេ ។ បុគ្គលណាគ្រប់គ្រងក្នុងឥន្ទ្រិយទាំង ៦ នោះ ដឹងច្បាស់ឥន្ទ្រិយទាំង ៦ ហើយគប្បីប្រព្រឹត្ត តាំងនៅក្នុងធម៌ ត្រេកអរក្នុងការទៀងត្រង់ និងសេចក្ដីទន់ភ្លន់ កន្លងផុតគ្រឿងជំពាក់ លះបង់ទុក្ខទាំងអស់ មានប្រាជ្ញា មិនជាប់

នៅក្នុងអារម្មណ៍ ដែលខ្លួនឃើញដែលឮ ។

ព្រះមានព្រះភាគ បានត្រាស់សេចក្តីនេះរឿយៗ ដូច្នេះហើយ តិស្សព្រាហ្មណ៍ អ្នកដល់នូវត្រើយនៃមន្ត ក៏ដឹងនូវសេចក្តីនោះ ព្រះមុនីជាអ្នកមិនមានក្តិនក្តាប គឺកិលេស មិនអាស្រ័យតណ្ហា និងទិដ្ឋិ ឥតអ្នកណាមួយ ដឹកនាំឲ្យអាក្រក់បាន ទ្រង់ប្រកាសដោយគាថាទាំងឡាយដ៏វិចិត្រ ។ ព្រាហ្មណ៍បានស្តាប់បទសុភាសិត ដែលមិនមានក្តិនក្តាប ជាគ្រឿងបន្ទោបង់នូវទុក្ខទាំងពួងរបស់ព្រះពុទ្ធហើយ ក៏មានចិត្តឱនលំទោន ថ្វាយបង្គំព្រះតថាគត សូមបព្វជ្ជាក្នុងទីនេះឯង ។

**អាមគន្ធសូត្រទី ២ ចប់**

# អដ្ឋកថា

## អាមគន្ធសូត្រ

[ ២២ ] អាមគន្ធសូត្រទី ២ មានពាក្យផ្ដើមថា **សាមាកចិង្គូលកចីនកានិ** ៥ ជាដើម ។ សួរថា សូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា សូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះថា

ព្រះមានព្រះភាគ កាលទ្រង់មិនទាន់កើតឡើង ព្រាហ្មណ៍ឈ្មោះអាមគន្ធៈ ចូលទៅកាន់ភ្នំហិមពាន បួសជាតាបស មួយអន្លើដោយមាណព ៥០០ នាក់ បានសាងអាស្រមត្រង់ញកភ្នំ មានដំឡូង និងផ្លែឈើក្នុងព្រៃជាអាហារ នៅត្រង់ញកភ្នំនោះ តាបសមិនបានបរិភោគត្រី និងសាច់ឡើយ កាលនោះរោគស្គមលឿង ក៏កើតឡើងដល់តាបសទាំងនោះ ដែលមិនបានបរិភោគរបស់ជូរ និងប្រៃជាដើម ។ បន្ទាប់អំពីនោះ តាបសទាំងនោះ ក៏និយាយគ្នាថា យើងនឹងទៅកាន់ទឹកដីមនុស្ស ដើម្បីបរិភោគរបស់ជូរ និងប្រៃ ដូច្នេះហើយ ទើបធ្វើដំណើរទៅកាន់បច្ចន្តគាម ។ ក្នុងបច្ចន្តគាមនោះ មនុស្សទាំងឡាយឃើញតាបសហើយ ក៏ជ្រះថ្លាក្នុងតាបសទាំងនោះ និមន្តឲ្យឆាន់អាហារ មនុស្សទាំងឡាយបានប្រគេនគ្រែ តាំង ភាជន៍សម្រាប់បរិភោគ និងប្រេងសម្រាប់លាបជើងជាដើមដល់តាបសនោះ ដែលធ្វើភត្តកិច្ចស្រេចហើយ បង្ហាញទីលំនៅ ដោយពោលថា បពិត្រលោកម្ចាស់ទាំងឡាយ សូមលោកម្ចាស់ទាំងឡាយ នៅក្នុងទីនេះឯង លោកម្ចាស់ទាំងឡាយកុំបីអផ្សុក ដូច្នេះហើយ ក៏នាំគ្នាចៀសចេញទៅ ក្នុងថ្ងៃទី ២ ពួកមនុស្ស បានថ្វាយទានដល់

តាបសទាំងនោះ ហើយបានថ្វាយទានមួយថ្ងៃមួយស្រុក តាមលំដាប់ផ្ទះទៀត តាបសទាំងឡាយនៅក្នុងទីនោះ អស់ ៤ ខែ មានរាងកាយរឹងប៉ឹង ព្រោះបានបរិភោគសេដូវ និងប្រៃ ទើបប្រាប់ដល់មនុស្សទាំងឡាយថា អ្នកទាំងឡាយ ពួកអាត្មានឹងទៅ ។ មនុស្សទាំងឡាយបានប្រគេនប្រេង និងអង្ករជាដើមដល់តាបសទាំងនោះ ។ តាបសទាំងនោះបានកាន់យកប្រេង និងអង្ករជាដើមនោះ បានទៅកាន់អាស្រមរបស់ខ្លួននោះឯង ។ តាបសទាំងនោះបានមកកាន់ស្រុកនោះរាល់ៗ ឆ្នាំ ដូចធ្លាប់បដិបត្តិមក សូម្បីពួកមនុស្សដឹងថាតាបសទាំងនោះនាំគ្នាមក ទើបត្រៀមអង្ករជាដើម ដើម្បីថ្វាយទាន បានថ្វាយទានដល់តាបសទាំងនោះ ដែលមកហើយដូចសព្វមួយដង ។

កាលនោះ ព្រះមានព្រះភាគកើតឡើងហើយក្នុងលោក ទ្រង់សម្តែងធម្មចក្រដ៏បវរ ហើយយាងទៅកាន់នគរសាវត្ថីដោយលំដាប់ គង់នៅត្រង់នគរសាវត្ថីនោះ ទ្រង់ឃើញឧបនិស្សយសម្បត្តិរបស់តាបសទាំងនោះ ទ្រង់យាងចេញអំពីសាវត្ថី មានពួកភិក្ខុចោមរោម យាងចារិកទៅដល់ស្រុកនោះតាមលំដាប់ មនុស្សទាំងឡាយឃើញព្រះមានព្រះភាគហើយ បានថ្វាយមហាទាន ព្រះមានព្រះភាគទ្រង់សម្តែងធម៌ដល់មនុស្សទាំងនោះ ដោយព្រះធម្មទេសនានោះ មនុស្សពួកខ្លះបានជាសោតាបន្ន ពួកខ្លះបានជាសកទាគាមី និងអនាគាមី ពួកខ្លះបួសហើយ សម្រេចអរហត្ត ។ ព្រះមានព្រះភាគ បានយាងត្រឡប់មកកាន់ក្រុងសាវត្ថីវិញ ។ កាលនោះ តាបសទាំងនោះបានមក

កាន់ស្រុកនោះ ពួកមនុស្សទាំងឡាយឃើញពួកតាបសហើយ មិនបានធ្វើកោលាហលដូចសព្វដង តាបសទាំងឡាយសួរពួកមនុស្សថា នែអ្នកទាំង-ឡាយ ព្រោះហេតុអ្វី ទើបមនុស្សទាំងនេះ មិនដូចក្នុងកាលមុន ស្រុកនេះត្រូវរាជអាជ្ញាឬហ្ន៎ ឬត្រូវបៀតបៀនដោយទុព្ភិក្ខភ័យ ឬមានបព្វជិតណាមួយសម្បូរដោយគុណមានសីលជាដើមច្រើនជាងពួកយើង មកដល់ស្រុកភូមិនេះ ។

មនុស្សទាំងនោះប្រាប់ថា លោកម្ចាស់ ស្រុកនេះត្រូវរាជអាជ្ញាក៏មិនមែនត្រូវប្រទូស្តដោយទុព្ភិក្ខភ័យក៏មិនមែន តែព្រះពុទ្ធទ្រង់កើតឡើងក្នុងលោក ព្រះមានព្រះភាគអង្គនោះ ទ្រង់សម្តែងធម៌ដើម្បីជាប្រយោជន៍ដល់ជនច្រើន បានយាងមកក្នុងស្រុកនេះ ។ អាមគន្ធតាបសបានស្តាប់ពាក្យនោះហើយ ទើបពោលថា គហបតីទាំងឡាយ ពួកអ្នកពោលថា **ពុទ្ធោ** ដូច្នេះឬ ។

មនុស្សទាំងឡាយក៏ពោលអស់វារៈ ៣ ដងថា បពិត្រលោកម្ចាស់ ពួកខ្ញុំពោលថា **ពុទ្ធោ** ដូច្នេះ អាមគន្ធតាបសត្រេកអរ បន្លឺវាចា សម្តែងនូវការត្រេកអរថា ពាក្យថា **ពុទ្ធោ** នេះ ជាសំឡេងដែលរកបានដោយក្រក្នុងលោក ដូច្នេះ ទើបសួរថា ព្រះសម្ពុទ្ធអង្គនោះ ទ្រង់សោយកុិនធ្លាបឬហ្ន៎ ឬមិនសោយកុិនធ្លាបទេ ។

ពួកមនុស្សសួរថា បពិត្រលោកម្ចាស់ អ្វីជាកុិនធ្លាប អាមគន្ធតាបសពោលថា នែគហបតីទាំងឡាយ ត្រី និងសាច់ ឈ្មោះថា កុិនធ្លាប ។ ពួកមនុស្សពោលថា បពិត្រលោកម្ចាស់ ព្រះមានព្រះភាគសោយត្រី និងសាច់ ។

តាបសស្តាប់ពាក្យនោះហើយ កើតវិប្បដិសារៈថា បុគ្គលនោះជាព្រះពុទ្ធ ឬមិនមែនព្រះពុទ្ធហ្ន៎ ។ តាបសនោះគិតទៀតថា ឈ្មោះថា ការប្រាកដឡើងនៃព្រះមានព្រះភាគទាំងឡាយ បុគ្គលបានដោយលំបាក អញទៅគាល់ព្រះអង្គហើយសាកសួរ ទើបដឹងបាន ។

បន្ទាប់អំពីនោះ តាបសនោះ ក៏បានទៅកាន់ទីដែលព្រះពុទ្ធគង់នៅ សួរផ្លូវនោះ ជាមួយមនុស្សទាំងឡាយ ជាអ្នកស៊ុះស្មាដូចមេគោការកូន បានទៅដល់ក្រុងសាវត្ថី ដោយសម្រាកមួយយប់ក្នុងទីគ្រប់កន្លែង ចូលទៅកាន់វត្តជេតវ័ននោះឯង មួយអន្លើដោយបរិស័ទរបស់ខ្លួន ។ ព្រះមានព្រះភាគ ទ្រង់គង់លើអាសនៈដើម្បីសម្តែងធម៌ ក្នុងសម័យនោះ តាបសទាំងឡាយចូលទៅគាល់ព្រះមានព្រះភាគ មិនថ្វាយបង្គំ អង្គុយក្នុងចំណែកម្ខាង ។ ព្រះមានព្រះភាគប្រាស្រ័យសម្តែងនូវការត្រេកអរជាមួយតាបសទាំងនោះ ដោយន័យថា ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយល្មមអត់ធន់បានឬ ដូច្នេះជាដើម ។ តាបសទាំងនោះបានក្រាបទូលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គទាំងឡាយល្មមអត់ធន់បាន ដូច្នេះជាដើម លំដាប់នោះ អាមគន្ធឥសីបានទូលសួរព្រះមានព្រះភាគថា បពិត្រព្រះគោតម ទ្រង់សោយក្លិនឆ្អាប ឬមិនសោយ ។ ព្រះមានព្រះភាគត្រាស់សួរថា ម្នាលព្រាហ្មណ៍ ឈ្មោះថា ក្លិនឆ្អាបនោះដូចម្តេច តាបសទូលថា បពិត្រព្រះគោតម ត្រី និងសាច់ ឈ្មោះថា ក្លិនឆ្អាប ព្រះមានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ ត្រី និងសាច់ មិនមែនក្លិន

ធ្លាបទេ កិលេសដ៏លាមកជាអកុសលធម៌ ឈ្មោះថា ក្លិនធ្លាប ហើយត្រាស់ថា ម្នាលព្រាហ្មណ៍ មិនមែនតែអ្នកទេ ដែលសួរដល់ក្លិនធ្លាប ក្នុងកាលឥឡូវនេះ សូម្បីក្នុងអតីត ព្រាហ្មណ៍ឈ្មោះតិស្សៈ ក៏បានសួរដល់ក្លិនធ្លាបនឹងព្រះមានព្រះភាគព្រះនាមកស្សបៈហើយដូចគ្នា ។ តិស្សព្រាហ្មណ៍បានទូលសួរហើយយ៉ាងនេះ ព្រះមានព្រះភាគ ទ្រង់បានព្យាករណ៍ហើយយ៉ាងនេះ ដូច្នេះហើយ ទ្រង់បាននាំមកនូវគាថាដែលតិស្សព្រាហ្មណ៍ពោល និងដែលព្រះកស្សបទសពលត្រាស់ហើយនោះឯង កាលឲ្យអាមគន្ធព្រាហ្មណ៍ដឹងនូវគាថាទាំងនេះ ទើបត្រាស់ថា **សមាកចិង្គូលកចីនកានិ ច** ដូច្នេះជាដើម ។

នេះ គឺហេតុកើតឡើងនៃសូត្រនេះ ក្នុងទីនេះ ត្រឹមប៉ុណ្ណោះ តែក្នុងអតីតកាល មានអត្ថុប្បត្តិហេតុដូច្នេះ ។

បានឮថា ព្រះពោធិសត្វព្រះនាមកស្សបៈ បំពេញបារមី ៨ អសង្ខេយ្យនិង ១ សែនកប្ប បដិសន្ធិក្នុងគភ៌របស់ព្រាហ្មណីឈ្មោះធនវតី ជាភរិយាធំរបស់ព្រហ្មទត្តព្រាហ្មណ៍ ក្នុងនគរពារាណសី សូម្បីអគ្គសាវក ក៏ច្យុតអំពីទេវលោកក្នុងថ្ងៃនោះដូចគ្នា កើតក្នុងផ្ទៃភរិយាធំនៃព្រាហ្មណ៍ ដែលជាអនុបុរោហិត បដិសន្ធិ និងការប្រសូតិចាកគភ៌របស់ព្រះពោធិសត្វ និងអគ្គសាវកទាំង ២ នោះ មានហើយក្នុងថ្ងៃតែមួយនោះឯង ដោយប្រការដូច្នេះ ។ ញាតិទាំងឡាយបានដាក់ឈ្មោះបុត្ររបស់ព្រាហ្មណ៍ម្នាក់ថា កស្សបៈ បុត្ររបស់ព្រាហ្មណ៍ម្នាក់ទៀតថា តិស្សៈ ក្នុងថ្ងៃជាមួយគ្នានោះឯង ។ កុមារទាំង ២

នោះជាសម្លាញ់លេងដីជាមួយគ្នា ដល់នូវការចម្រើនវ័យដោយលំដាប់ ។ បិតារបស់តិស្សៈបានប្រាប់កូនប្រុសថា នែបា សម្លាញ់របស់បាឈ្មោះកស្សបៈនេះ ចេញបួសហើយ នឹងបានជាព្រះពុទ្ធ កូនឯងចូរបួសក្នុងសម្នាក់របស់ព្រះពុទ្ធព្រះនាមកស្សបៈនោះហើយ នឹងរលាស់ខ្លួនចេញចាកភពបាន ។ តិស្សៈនោះទទួលថា សាធុ ហើយក៏ទៅកាន់សម្នាក់របស់ព្រះពោធិសត្វពោលថា នែសម្លាញ់ យើងទាំង ២ នឹងបួសជាមួយគ្នា ព្រះពោធិសត្វទទួលថា សាធុ ។ បន្ទាប់ពីនោះ ក្នុងកាលសម្លាញ់ទាំង ២ ចម្រើនវ័យដោយលំដាប់ តិស្សៈនិយាយនឹងព្រះពោធិសត្វថា នែសម្លាញ់ មកយើងនឹងបួសជាមួយគ្នា ។ ព្រះពោធិសត្វមិនបានចេញបួស ។ តិស្សៈគិតថា ញាណរបស់សម្លាញ់អញមិនទាន់ចាស់ក្លាដោយជុំវិញ ដូច្នេះហើយ ខ្លួនឯងក៏ចេញបួសជាឥសី ធ្វើអាស្រមក្នុងព្រៃ ត្រង់ជើងភ្នំ ។ សម័យក្រោយមក ព្រះពោធិសត្វ ទាំងដែលតាំងនៅក្នុងផ្ទះនោះឯង កំណត់អានាបានស្សតិ ធ្វើឈាន ៤ និងអភិញ្ញាឲ្យកើតឡើង ហើយយាងទៅកាន់ទីជិតគល់ពោធិព្រឹក្ស មួយអន្លើដោយប្រាសាទ ហើយអធិដ្ឋានថា ចូរប្រាសាទទៅកាន់កន្លែងវិញចុះ ប្រាសាទនោះក៏ទៅតាំងត្រង់កន្លែងដើម ។ បានឮថា ព្រះពោធិសត្វ ដែលមិនបានបួសមិនអាចចូលដល់គល់ពោធិព្រឹក្សបាន ព្រោះដូច្នោះ ទើបព្រះពោធិសត្វបួសហើយចូលកាន់គល់ពោធិព្រឹក្ស អង្គុយធ្វើសេចក្តីព្យាយាម អស់ ៧ ថ្ងៃ ធ្វើឲ្យជាក់ច្បាស់នូវសម្មាសម្ពោធិញ្ញាណក្នុងកាល ៧ ថ្ងៃប៉ុណ្ណោះ ។

ក្នុងកាលនោះ ត្រង់ព្រៃឥសិបតនៈ មានបព្វជិតរហូត ២ ម៉ឺនរូប គ្រានោះ ព្រះមានព្រះភាគព្រះនាមកស្សបៈ ត្រាស់ហៅបព្វជិតទាំងនោះមកហើយ ទ្រង់សម្តែងធម្មចក្ក ក្នុងកាលចប់សូត្រនោះឯង បព្វជិតគ្រប់រូបក៏បានជាព្រះអរហន្ត ។ បានឮថា ព្រះមានព្រះភាគអង្គនោះមានភិក្ខុ ២ ម៉ឺនរូបជាបរិវារ គង់នៅត្រង់ព្រៃឥសិបតនៈនោះឯង ព្រះបាទកាសីព្រះនាមកិកិ ទ្រង់ឧបដ្ឋាកដោយបច្ច័យ ៤ ។

ថ្ងៃមួយ បុរសអ្នកនគរពារាណសីម្នាក់ ស្វែងរកវត្ថុទាំងឡាយ មានខ្ទឹមចន្ទន៍ជាដើមត្រង់ភ្នំ ក៏ទៅដល់អាស្រមរបស់តិស្សតាបស ធ្វើអញ្ជលីដល់តាបសនោះ ហើយឈរក្នុងចំណែកម្ខាង ។ តាបសឃើញបុរសនោះហើយសួរថា អ្នកមកអំពីទីណា បុរសនោះឆ្លើយថា ខ្ញុំមកពីនគរពារាណសី តាបសសួរថា ការប្រព្រឹត្តទៅក្នុងនគរពារាណសីនោះដូចម្តេចខ្លះ បុរសនោះឆ្លើយថា បពិត្រលោកម្ចាស់ ព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ កើតឡើងហើយ ក្នុងនគរពារាណសីនោះ ។ តាបសបានស្តាប់ពាក្យដែលឮបានដោយកម្រ ក៏កើតបីតិ ហើយសួរថា ព្រះសម្ពុទ្ធអង្គនោះសោយក្លិនឆ្អាប ឬមិនសោយ ។ បុរសនោះសួរថា ក្លិនឆ្អាប គឺអ្វី តាបសឆ្លើយថា ក្លិនឆ្អាប គឺត្រី និងសាច់ ។

បុរសនោះឆ្លើយថា បពិត្រលោកម្ចាស់ ព្រះមានព្រះភាគទ្រង់សោយត្រី និងសាច់ ។ តាបសស្តាប់ពាក្យនោះហើយ ក៏កើតវិប្បដិសារៈ ត្រិះរិះថា អញនឹងទៅទូលសួរព្រះមានព្រះភាគអង្គនោះ បើទ្រង់ត្រាស់ថា តថាគតបរិភោគ

ក្និទ្ធាប អញនឹងឃាត់ព្រះអង្គថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីនោះមិនសមគួរដល់ជាតិ និងត្រកូលរបស់ព្រះអង្គ ដូច្នេះហើយ គិតថា អញបួសក្នុងសម្នាក់របស់ព្រះពុទ្ធអង្គនោះ នឹងធ្វើការរលាស់ខ្លួនចេញចាកភពបាន ដូច្នេះហើយ ទើបកាន់យកឧបករណ៍ គឺបរិក្ខារដែលស្រាលៗ ទៅកាន់នគរពារាណសីក្នុងវេលាល្ងាច ដោយការសម្រាកមួយរាត្រីក្នុងទីទាំងពួង បានចូលទៅកាន់ព្រៃឥសិបតនៈនោះឯង សូម្បីព្រះសាស្តាក៏គង់លើអាសនៈ ដើម្បីសម្តែងព្រះធម្មទេសនាក្នុងសម័យនោះឯង ។ តាបសចូលទៅគាល់ព្រះមានព្រះភាគ ហើយមិនថ្វាយបង្គំ ជាអ្នកនៅស្ងៀម បានឈរក្នុងចំណែកម្ខាង ។ ព្រះមានព្រះភាគទ្រង់ឃើញតាបសនោះហើយ ត្រាស់បដិសណ្ឋារៈ ដោយន័យដែលខ្ញុំពោលហើយខាងដើមនោះឯង ។ តាបសពោលពាក្យទាំងឡាយជាដើមថា បពិត្រព្រះមានព្រះភាគព្រះនាមកស្សបៈដ៏ចម្រើន ទ្រង់ល្មមអត់ធន់បានដែរឬ ដូច្នេះហើយ អង្គុយក្នុងចំណែកម្ខាង ទូលសួរព្រះមានព្រះភាគថា បពិត្រព្រះកស្សបៈដ៏ចម្រើន ទ្រង់សោយក្និទ្ធាប ឬមិនសោយទេ ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតមិនបរិភោគក្និទ្ធាបឡើយ តាបសក្រាបទូលថា សាធុ សាធុ ព្រះកស្សបៈដ៏ចម្រើន បើទ្រង់មិនសោយសាកសពរបស់សត្វដទៃ ទ្រង់ធ្វើបានល្អហើយ សេចក្តីនោះសមគួរដល់ជាតិត្រកូល និងគោត្ររបស់ព្រះអង្គ ។

បន្ទាប់អំពីនោះ ព្រះសាស្តាទ្រង់ព្រះតម្រិះថា តថាគតពោលថា តថាគត

មិនបរិភោគក្ងិនធ្លាប ដូច្នេះ សំដៅដល់ក្លិនធ្លាប គឺកិលេសទាំងឡាយ តែព្រាហ្មណ៍សំដៅយកត្រី និងសាច់ ធ្វើម្តេចហ្ន៎ តថាគតមិនគប្បីចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ក្នុងថ្ងៃស្អែកនេះ គប្បីបរិភោគបិណ្ឌបាតដែលគេនាំមកអំពីព្រះរាជវាំងរបស់ព្រះបាទកិកិ គាថាប្រារព្ធក្លិនធ្លាបនឹងប្រព្រឹត្តទៅ បន្ទាប់អំពីនោះ តថាគតនឹងឲ្យព្រាហ្មណ៍យល់បានដោយព្រះធម្មទេសនា ទ្រង់គិតដូច្នេះហើយ ក្នុងថ្ងៃទី ២ ទ្រង់ធ្វើបរិកម្មសរីរៈអំពីព្រលឹម យាងចូលទៅកាន់ព្រះគន្ធកុដិ ។ ភិក្ខុទាំងឡាយ ឃើញព្រះគន្ធកុដិបិទ ក៏ដឹងថា ថ្ងៃនេះ ព្រះមានព្រះភាគមិនបំណងនឹងយាងទៅ មួយអន្លើដោយភិក្ខុទាំងឡាយ ទើបធ្វើប្រទក្សិណព្រះគន្ធកុដិ ហើយចូលទៅដើម្បីបិណ្ឌបាត សូម្បីព្រះមានព្រះភាគក៏ចេញអំពីព្រះគន្ធកុដិ ហើយគង់លើអាសនៈដែលគេក្រាល ។ ឯតាបសស្ងោរស្លឹកឈើបរិភោគហើយ អង្គុយក្នុងសម្នាក់របស់ព្រះមានព្រះភាគ ព្រះបាទកាសិករាជព្រះនាមកិកិ ឃើញភិក្ខុទាំងឡាយបិណ្ឌបាត ទើបត្រាស់សួរថា បពិត្រលោកម្ចាស់ ព្រះសាស្តាយាងទៅណា ទ្រង់បានស្តាប់ថា ព្រះសាស្តាគង់នៅក្នុងវិហារ ទើបទ្រង់បញ្ជូនភោជនដែលដល់ព្រមដោយរសផ្សេងៗ សម្បូរដោយសាច់ដល់ព្រះមានព្រះភាគ ។

អមាត្យទាំងឡាយទៅកាន់វិហារ ក្រាបទូលដល់ព្រះមានព្រះភាគ ថ្វាយទក្ខិណោទក កាលនឹងអង្គាស បានថ្វាយយាគូដែលដល់ព្រមដោយសាច់ច្រើនមុខ តាបសឃើញហើយ គិតថា ព្រះសាស្តាសោយ ឬមិនសោយហ្ន៎

ព្រះមានព្រះភាគ កាលតាបសកំពុងមើលនោះឯង ទ្រង់ក៏សោយបបរ ដាក់ដុំសាច់ចូលក្នុងព្រះឱស្ឋ តាបសឃើញហើយក៏ក្រោធ កាលព្រះមានព្រះភាគទ្រង់ហុតបបរស្រេចហើយ អមាត្យទាំងឡាយក៏ថ្វាយភោជន ដែលប្រកបដោយសម្លដែលមានរសផ្សេងៗ ទៀត តាបសឃើញព្រះមានព្រះភាគទទួលភោជននោះសោយ ក៏រឹងរឹតតែក្រោធ ពោលថា ព្រះមានព្រះភាគ ឆាន់ ត្រីនិងសាច់ពិត តែត្រាស់ថា តថាគតមិនឆាន់ ។

គ្រានោះ តាបសបានចូលទៅរកព្រះមានព្រះភាគ ដែលទ្រង់ធ្វើកត្តកិច្ចហើយ ទ្រង់លាងព្រះហស្ត និងព្រះបាទ ប្រថាប់គង់ទូលថា បពិត្រព្រះកស្សបៈដ៏ចម្រើន ទ្រង់ពោលពាក្យកុហក សេចក្តីនោះមិនមែនជាកិច្ចរបស់បណ្ឌិត ព្រោះព្រះមានព្រះភាគទាំងឡាយ តិះដៀលមុសាវាទហើយ សូម្បីពួកឥសីទាំងនោះ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយមូលផលាផលក្នុងព្រៃត្រង់ជើងភ្នំ ឥសីទាំងនោះក៏មិនពោលកុហក កាលពោលគុណរបស់ឥសីទាំងឡាយដោយគាថា ទើបពោលថា **សាមាកចិង្គូលកចីនកានិ ច** ជាដើម ។

បណ្តាបទទាំងនោះ តិណ្ណជាតិ និងធញ្ញជាតិ ដែលជាវត្ថុដែលបុគ្គលគួរកម្ចាត់ គឺបកសម្បក ឬបេះយកតែគ្រួរទាំងឡាយកាន់យក ឈ្មោះថា **សាមាកៈ** ( ស្រងែ ) ក្នុងគាថានោះ ។ ម្យ៉ាងទៀត ស្ពួយមានស្មែង មានសណ្ឋានដូចផ្កាកណវេរៈ ( ផ្កាយីថោ )[១] ឈ្មោះថា ចិង្គូលក សណ្តែកខៀវ

---

១- ក្នុងកណវេរជាតក ពាក្យថា កណវេរៈ លោកប្រែថា ផ្កាច្បារ ។

ដែលគេដាំហើយ កើតឡើងត្រង់ដើមភ្នំក្នុងព្រៃ ឈ្មោះថា **ចីឯកាធិ**។ ស្លឹកឈើណាមួយ ឈ្មោះថា **បត្តបួលំ**។ ដំឡូងណាមួយ ឈ្មោះថា **មូលបួលំ**។ ផ្លែឈើ និងផ្លែវល្លិណាមួយ ឈ្មោះថា **គរិបួលំ** ម្យ៉ាងទៀត ដំឡូង លោកកាន់យកដោយសព្ទថា **មូល**។ ផ្លែឈើ និងផ្លែវល្លិ លោកកាន់យកដោយសព្ទថា **ផល**។ មើមក្រចាប់ និងមើមឬសជាដើម ដែលកើតក្នុងទឹក លោកកាន់យកដោយសព្ទថា **គរិបួល**។

ពីរបទថា **ធម្មេន លទ្ធំ** សេចក្តីថា លះនូវមិច្ឆាជីវៈ មានភាពជាទូតអ្នកទទួលបម្រើ និងការនាំដំណឹងជាដើម ហើយបានមកដោយការស្វែងរកក្នុងព្រៃ ។

ព្រះអរិយៈទាំងឡាយដែលជាអ្នកស្ងប់ ឈ្មោះថា **សតំ** បទថា **អស-មានា** បានដល់ បរិភោគ ។

ដោយបាទព្រះគាថាថា **ន កាមកាមា អលិកំ ភណន្តិ** ឥសីរមែងសម្តែងដល់ការតិះដៀលចំពោះព្រះមានព្រះភាគ ដោយការសរសើរឥសីទាំងឡាយថា ឥសីទាំងឡាយនោះ មិនប្រកាន់ថាជារបស់ខ្លួន មិនហួងហែងបរិភោគនូវស្រូវផ្សេងជាដើមទាំងនេះយ៉ាងនេះ រមែងមិនពោលផ្តេសផ្តាស ព្រោះប្រាថ្នាកាម គឺប្រាថ្នាកាម ក៏មិនពោលកុហក ដូចទ្រង់ដែលប្រាថ្នាកាមទាំងឡាយ ដែលមានរសឆ្ងាញ់ជាដើម សោយនូវក្លិនឆ្អាបនោះឯង ក៏នៅត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតមិនបរិភោគក្លិនឆ្អាបឡើយ ឈ្មោះថា ពោលនូវ

ពាក្យមិនពិត គឺពាក្យឡេះឡោះ ដូច្នេះ ។

ព្រាហ្មណ៍ កាលតិះដៀលព្រះមានព្រះភាគ ដោយការអាងពាក្យសរសើរឥសីទាំងឡាយយ៉ាងនេះហើយ ឥឡូវនេះ កាលសម្ដែងការតិះដៀលតាមខ្លួនបំណង ទើបតិះដៀលព្រះមានព្រះភាគ ដោយត្រង់ៗ ថា **យេសមាសោ** ជាដើម ។

**៩** អក្ខរៈ ក្នុងគាថានោះ ជាការក្លាប់បទ តែអត្ថមានដូចតទៅនេះ ដូចសាច់ប្រចៀច ឬសាច់ទទាណាមួយ ដែលធ្វើល្អហើយ ដោយការបរិកម្មខាងដើម មានការលាង និងការហាន់ជាដើមសម្រេចល្អហើយ ដោយការបរិកម្ម ខាងក្រោយមានការចម្អិន និងការអាំងជាដើម ដែលជនដទៃជាអ្នកប្រាថ្នានូវធម៌សម្គាល់ថា បុគ្គលនេះមិនមែនមាតា មិនមែនបិតារបស់អញ តែបុគ្គលនេះជាទក្ខិណេយ្យបុគ្គល ដូច្នេះ បានប្រគេន ឈ្មោះថា តាក់តែងល្អហើយក្នុងការធ្វើសក្ការៈ ។

ឈ្មោះថា ប្រណីត គឺតាក់តែងរៀបរយ គឺប្រណីត ព្រោះជាភោជនមានរសដ៏ប្រសើរ ព្រោះជាភោជនមានឱជៈ ព្រោះជាភោជនដែលអាចនាំមកនូវកម្លាំង និងសម្រួលនូវសន្ធាក់ ទ្រង់សោយ គឺឲ្យនាំមក គឺទ្រង់សោយសាច់ណាមួយក៏មិនមែន ដោយពិត ទ្រង់សោយស្រូវសាលីនេះ បានដល់ បាយនៃស្រូវសាលីដែលបកសម្បកហើយ ក៏ឈ្មោះថា សោយក្តិនភ្លាប តាបសហៅព្រះមានព្រះភាគ ដោយអាងគោត្រថា បពិត្រកស្សបៈ ទ្រង់សោយនូវ

សាច់ប្រភេទណាមួយ និងសោយនូវស្រូវសាលីនេះ ទ្រង់ឈ្មោះថា សោយនូវភិក្ខុ ដូច្នេះ ។

តាបសកាលតិះដៀលព្រះមានព្រះភាគ ព្រោះអាហារយ៉ាងនេះហើយ ឥឡូវនេះ កាលលើកមុសាវាទឡើងតិះដៀល ទើបពោលថា **ន អាមគន្ធោ ។បេ។ សុសង្ខតេហិ។**

អត្ថនៃគាថានោះថា តាបសកាលពោលបរិកាសថា បពិត្រព្រះមានព្រះភាគ ទ្រង់ជាផៅពង្សនៃព្រហ្ម ជាអ្នកវៀរចាកគុណរបស់ព្រាហ្មណ៍ បពិត្រព្រហ្មពន្ធុ ទ្រង់កាលខ្ញុំព្រះអង្គទូលសួរក្នុងកាលមុនហើយ ទ្រង់ក៏បានត្រាស់យ៉ាងនេះថា គឺទ្រង់ត្រាស់ដោយចំណែកមួយយ៉ាងនេះថា វត្ថុមានក្លិនឆ្អាបមិនគួរដល់តថាគត ដូច្នេះ ។

បទថា **សាលីនមន្នំ** បានដល់ បាយនៃស្រូវសាលី ។ បទថា **បរិ-ភុញ្ជមានោ** បានដល់ បរិភោគ ។

បាទគាថាថា **សកុន្តមំសេហិ សុសង្ខតេហិ** សេចក្ដីថា តាបសពោលដល់សាច់បក្សីដែលព្រះរាជានាំមកថ្វាយដល់ព្រះមានព្រះភាគក្នុងកាលនោះ ។ តាបសកាលពោលយ៉ាងនេះឯង ទើបឆ្មៀងមើលព្រះវរកាយរបស់ព្រះមានព្រះភាគខាងក្រោមតាំងពីចុងជើងដល់ចុងសក់ខាងលើ ទើបឃើញការដល់ព្រមដោយព្រះលក្ខណៈដ៏ប្រសើរ ៣២ ប្រការ និងអនុព្យញ្ជនៈ ៨០ រួមទាំងបានឃើញការរោមរោមនៃព្រះរស្មី ដែលផ្សាយចេញទៅប្រមាណមួយព្យាម

ទើបគិតថា បុគ្គលមានកាយប្រដាប់ដោយមហាបុរិសលក្ខណៈបែបនេះ មិនគួរនឹងពោលកុហក ឯព្រះឧណ្ណាលោមនេះ ដែលកើតឡើងក្នុងរវាងចិញ្ចើមពណ៌សទន់ដូចសំឡី និងរណ្ដៅពេមទាំងឡាយជាច្រើន កើតឡើងដល់បុរសនេះ ព្រោះអានិសង្សដែលហូរចេញអំពីសច្ចវាចាក្នុងអន្តរកពនោះឯង បុរសនេះ និយាយកុហកក្នុងកាលឥឡូវនេះបានដូចម្ដេច ក្លិនឆ្អាបរបស់ព្រះមានព្រះភាគ ជារបស់ជទៃពិត ទ្រង់ត្រាស់ពាក្យនេះ សំដៅដល់ក្លិនឆ្អាបណាថា ម្នាលព្រាហ្មណ៍ តថាគតមិនបរិភោគក្លិនឆ្អាបឡើយ បើដូច្នោះ អញគប្បីសួរដល់ក្លិននោះ ដូច្នេះហើយ ជាអ្នកមានមានះក្រៃលែងកើតឡើងហើយ កាលនឹងចរចាដោយអំណាចគោត្តនោះឯង ទើបពោលគាថាដ៏សេសថា

> បពិត្រព្រះកស្សបៈ ខ្ញុំនឹងសួរនូវសេចក្ដីនុ៎ះនឹងលោក វត្ថុមាន
> ក្លិនឆ្អាបរបស់លោក មានប្រការដូចម្ដេច ដូច្នេះ ។

សម័យនោះ ព្រះមានព្រះភាគ កាលទ្រង់ឆ្លើយក្លិនឆ្អាបដល់ព្រាហ្មណ៍នោះ ទើបត្រាស់ថា **បាណាតិបាតោ** ដូច្នេះ ។

ការសម្លាប់សត្វមានជីវិត ឈ្មោះថា **បាណាតិបាត** ក្នុងគាថានោះ ។ ក្នុងគាថាថា **វធឆេទពន្ធនំ** នេះ មានអធិប្បាយថា ការវាយដំសត្វទាំងឡាយដោយដំបងជាដើម ឈ្មោះថា **វធ** ការកាត់ដៃ និងជើងជាដើម ឈ្មោះថា **ឆេទ** ការចងដោយខ្សែជាដើម ឈ្មោះថា **ពន្ធន**។

ការលួច និងការពោលកុហក ឈ្មោះថា **ថេយ្យមុសាវាទោ**។ ការ

ឲ្យនូវបំណាំងកើតឡើងដោយន័យជាដើមថា អញនឹងឲ្យ អញនឹងធ្វើ ដូច្នេះហើយ ក៏ធ្វើឲ្យអស់បំណាំងវិញ ឈ្មោះថា **និកតី** ។ ការឲ្យអ្នកដទៃកាន់យកនូវវត្ថុ មិនមែនមាស ថាជាមាសជាដើម ឈ្មោះថា **វញ្ចនានិ** ។

ការរៀនគម្ពីរជាអនេក ដែលមិនមានប្រយោជន៍ ឈ្មោះថា **អជ្ឈេនកុត្តំ** ។

ការប្រព្រឹត្តខុសក្នុងកិរិយា ដែលអ្នកដទៃហួងហែង ឈ្មោះថា **បរទារសេវនា** ។

បាទព្រះគាថាថា **ឯសាមគន្ធោ ន ហិ មំសភោជនំ** សេចក្តីថា ការប្រព្រឹត្តដោយអំណាចអកុសលធម៌ មានបាណាតិបាតជាដើមនេះ ឈ្មោះថា **អាមគន្ធ** គឺក្លិនឆ្អាប សេចក្តីថា ក្លិនស្អុយ ជាក្លិនដូចសាកសព សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជាទីមិនពេញចិត្ត ព្រោះប្រឡូកប្រឡំដោយរបស់មិនស្អាត គឺកិលេស ព្រោះជារបស់ដែលសប្បុរសទាំងឡាយ ខ្ពើមរអើម ព្រោះនាំមកនូវភាពជាក្លិនស្អុយក្រៃលែង ។

សត្វទាំងឡាយណា ដែលមានកិលេសកើតឡើងហើយ ដោយក្លិនឆ្អាបទាំងឡាយណា សត្វទាំងឡាយនោះ ឈ្មោះថា ជាអ្នកមានក្លិនស្អុយក្រៃលែងជាងក្លិនឆ្អាបទាំងឡាយនោះ សូម្បីសរីរៈដែលស្លាប់ហើយរបស់បុគ្គលដែលអស់កិលេសទាំងឡាយ ក៏មិនរាប់ថា ជាក្លិនស្អុយ ព្រោះដូច្នោះ ក្លិននេះ មានក្លិនបាណាតិបាតជាដើម ទើបចាត់ជាក្លិនឆ្អាប ឯសាច់ និងភោជនដែលបុគ្គលបរិភោគដោយមិនបានឃើញ មិនបានឮ និងមិនបានរង្កៀស ឈ្មោះថា ជា

អាហារមិនមានទោស ព្រោះហេតុនោះ ទើបសាច់ និងភោជន មិនមែនជាកិនិទ្ធាបឡើយ ។

ព្រះមានព្រះភាគ កាលទ្រង់វិសជ្ជនាកិនិទ្ធាបដោយន័យមួយ ដោយទេសនាដែលជាធម្មាធិដ្ឋានយ៉ាងនេះហើយ ឥឡូវនេះ ព្រោះហេតុដែលសត្វនោះៗ ប្រកបដោយកិនិទ្ធាបទាំងឡាយនោះៗ សត្វមួយប៉ុណ្ណោះ នឹងប្រកបដោយកិនិទ្ធាបសព្វយ៉ាងក៏មិនមែន ហើយកិនិទ្ធាបសព្វយ៉ាងនឹងប្រកបជាមួយសត្វមួយប៉ុណ្ណោះក៏មិនមែន ដូច្នោះ ដើម្បីទ្រង់ប្រកាសកិនិទ្ធាបនោះៗ ដល់សត្វទាំងនោះ កាលទ្រង់វិសជ្ជនាកិនិទ្ធាបដោយទេសនា ដែលជាបុគ្គលាធិដ្ឋានដោយន័យថា ជនទាំងឡាយណា ក្នុងលោកនេះ មិនសង្រួមក្នុងកាមទាំងឡាយ ដូច្នេះជាដើម ទើបទ្រង់ភាសិត ២ គាថា ។

ក្នុងបាទគាថានោះ គាថាថា **យេ ឥធ កាមេសុ អសញ្ញតា ជនា** សេចក្តីថា បុថុជ្ជនពួកឯណានីមួយក្នុងលោកនេះ មិនសង្រួម ព្រោះទម្លាយនូវការសង្រួមហើយ ក្នុងកាមទាំងឡាយ ពោល គឺការសេពកាម ព្រោះទម្លាយនូវការសង្រួមដោយមិនធ្វើ វៀរនូវព្រំដែនក្នុងជនទាំងឡាយ មានមាតា និងម្តាយមីងជាដើម ។

ពីរបទថា **រសេសុ គិទ្ធា** សេចក្តីថា ត្រេកអរ ជាប់ជំពាក់ ងប់ជ្រប់លិចលង់ ក្នុងរសទាំងឡាយ ដែលគប្បីដឹងបានដោយជិវ្ហាវិញ្ញាណ ជាអ្នកមានប្រក្រតីឃើញថា មិនមានទោស មិនមានបញ្ញាជាគ្រឿងរលាស់ចេញ

បរិភោគរសទាំងឡាយ ។

បទថា **អសុចិកមិស្សិតា** សេចក្តីថា គ្របដណ្តប់ដោយរបស់មិនស្អាត ពោល គឺមិច្ឆាជីវៈ មានប្រការផ្សេងៗ ដើម្បីជាប្រយោជន៍ដល់ការបានរស ព្រោះការជាប់ក្នុងរសនោះ ។

បទថា **នត្ថិកទិដ្ឋី** សេចក្តីថា ប្រកបដោយមិច្ឆាទិដ្ឋិ ១០ យ៉ាង ដូចមិច្ឆាទិដ្ឋិថា ទានដែលឲ្យហើយ មិនមានផលជាដើម ។

បទថា **វិសមា** សេចក្តីថា ប្រកបដោយកាយកម្មជាដើមដែលមិនស្មើ បទថា **ទុរន្នយា** សេចក្តីថា ជាបុគ្គលដែលអ្នកដទៃទូន្មានបានលំបាក បានដល់ ជាបុគ្គលប្រកបដោយការមិនលះបង់ គឺប្រកាន់មាំក្នុងមិច្ឆាទិដ្ឋិរបស់ខ្លួន ។

បទថា **ឯសាមគន្ធោ** សេចក្តីថា គប្បីជ្រាបក្លិនឆ្អាប ដែលព្រះមានព្រះភាគសម្តែងចំពោះបុគ្គលដោយគាថានេះថា មាន ៦ ប្រភេទ ដោយអត្ថដែលទ្រង់ត្រាស់ខាងដើមដទៃទៀត គឺការមិនសង្រួមក្នុងកាម ១ ការជាប់ក្នុងរស ១ អាជីវវិបត្តិ ១ នត្ថិកទិដ្ឋិ ១ ជាអ្នកមិនស្មើមានកាយទុច្ចរិតជាដើម ១ ភាពជាអ្នកទូន្មានបានលំបាក ១ ។

បទថា **ន ហិ មំសភោជនំ** សេចក្តីថា សាច់ និងភោជនមិនមែនជាក្លិនឆ្អាបឡើយ ដោយអត្ថតាមដែលពោលហើយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ២ ដូចតទៅនេះ ពីរបទថា **យេ លូខសា** សេចក្តីថា ជនពួកណាសៅហ្មង មិនមានរស អធិប្បាយថា ប្រកបខ្លួនក្នុង

អត្តកិលមថានុយោគ បទថា **ធារុណា** បានដល់ គ្រោតគ្រាត រឹង គឺប្រកប ដោយភាពជាបុគ្គលប្រដៅក្រ ។

បទថា **បិដ្ឋិមំសិកា** សេចក្តីថា ចំពោះមុខក៏ពោលពីរោះ ហើយ ក៏និយាយតិះដៀលក្នុងទីកំបាំង ពិតហើយ ជនទាំងឡាយនេះមិនអាចនឹងមើល មុខបាន ហាក់បីដូចជាស៊ីសាច់ខ្នងរបស់ជនទាំងឡាយក្នុងទីកំបាំង ព្រោះ ហេតុនោះ ទើបលោកហៅថា ចំពោះមុខល្អ កំបាំងមុខអាក្រក់ ។

បទថា **មិត្តទុព្ភិនោ** គឺទ្រុស្តមិត្ត មានពាក្យអធិប្បាយថា បដិបត្តិខុស ចំពោះមិត្តទាំងឡាយដែលឲ្យនូវការស្និទ្ធស្នាលក្នុងរឿងកិរិយា ទ្រព្យ និងជីវិត ក្នុងទីនោះៗ ។

បទថា **និក្ករុណា** សេចក្តីថា ប្រាសចាកការអាណិតអាសូរ គឺត្រូវឲ្យ សត្វទាំងឡាយវិនាស ។

បទថា **អតិមានិនោ** បានដល់ ប្រកបដោយការប្រកាន់ខ្លួនក្រៃលែង ដូចព្រះមានព្រះភាគត្រាស់ថា

> បុគ្គលពួកខ្លះ ក្នុងលោកនេះ តម្កើងមានះឲ្យប្រព្រឹត្តទៅដោយ ជាតិក្តី ។បេ។ ដោយវត្ថុណាមួយក្តី ការមើលងាយគេ ។បេ។ ភាពដូចជាទង់ ការលើកកម្ពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះណា ... ដូច្នេះ ។

បទថា **អទានសីលា** គឺមានប្រក្រតីមិនឲ្យ បានដល់ មានចិត្តបង្អៀន

ទៅដើម្បីមិនឲ្យ អធិប្បាយថា មិនត្រេកអរក្នុងការចែករំលែក ។

ត្រើនបទថា **ឧ ច ទេន្តិ កស្សចិ** សេចក្តីថា ព្រោះហេតុដែលមានប្រក្រតីមិនឲ្យនោះ សូម្បីជាបុគ្គលត្រូវសូម ក៏មិនព្រមឲ្យអ្វីដល់បុគ្គលណាម្នាក់ គឺដូចគ្នានឹងមនុស្សក្នុងត្រកូលអទិន្នបុព្វកព្រាហ្មណ៍ រមែងកើតជានិជ្ឈាមតណ្ហិកប្រេតក្នុងសម្បរាយភព ។

អាចារ្យពួកខ្លះពោលថា **អាធានសីលា** ដូច្នេះក៏មាន ។ សេចក្តីថា ជាអ្នកមានប្រក្រតីទទួលតែម្យ៉ាង តែក៏មិនព្រមឲ្យរបស់អ្វីមួយ ដល់បុគ្គលម្នាក់ណា ។

បាទគាថាថា **ឯសាមគន្ធោ ឧ ហិ មំសភោជនំ** សេចក្តីថា អ្នកសិក្សាគប្បីជ្រាបថា ក្លិនឆ្អាបដែលព្រះមានព្រះភាគ ទ្រង់សម្តែងចំពោះបុគ្គលទាំង-ឡាយដោយគាថានេះ មាន ៨ ប្រភេទ ដោយអត្ថតាមដែលព្រះមានព្រះភាគត្រាស់ហើយខាងដើមទៀត គឺជាអ្នកមានរសសៅហ្មង ១ ភាពជាអ្នករឹងរូស ១ ចំពោះមុខល្អ កំបាំងមុខអាក្រក់ ១ ភាពជាអ្នកទ្រុស្តមិត្ត ១ ការខ្វះភាពអាណិតអាសូរ ១ ការប្រកាន់ខ្លួន ១ មានប្រក្រតីមិនឲ្យ ១ មិនដែលឲ្យវត្ថុអ្វីដល់អ្នកណាម្នាក់ ១ ថាជាក្លិនឆ្អាប សាច់ និងភោជន មិនមែនជាក្លិនឆ្អាបឡើយ ។

ព្រះមានព្រះភាគ កាលត្រាស់ ២ គាថា ដោយទេសនាជាបុគ្គលាធិ-ដ្ឋានយ៉ាងនេះហើយ ទ្រង់បានជ្រាបដល់ការអនុវត្តតាមអធ្យាស្រ័យរបស់តាបស

នោះទៀត ទើបត្រាស់ ១ គាថាទៀត ដែលជាធម្មាធិដ្ឋាន ។

ក្នុងគាថានោះ សេចក្តីក្រោធ អ្នកសិក្សាគប្បីជ្រាបដោយន័យដែលខ្ញុំបានពោលហើយក្នុងឧរគសូត្រ ។ ការស្រវឹងនៃចិត្ត មានប្រភេទដូចព្រះមានព្រះភាគត្រាស់ក្នុងវិភង្គ ដោយន័យថា សេចក្តីស្រវឹងព្រោះជាតិ សេចក្តីស្រវឹងព្រោះគោត្ត សេចក្តីស្រវឹងព្រោះការមិនមានរោគជាដើម ឈ្មោះថា **មទោ**។

ភាពជាអ្នករឹងត្អឹង ឈ្មោះថា **ថម្ភោ**។

ការតាំងខ្លួនជាសត្រូវក្នុងផ្លូវដែលខុស បានដល់ ការតាំងខ្លួនខុសចាកព្រះតម្រាស់ ដែលព្រះមានព្រះភាគ ត្រាស់ដោយន័យប្រកបដោយធម៌ ឈ្មោះថា **បច្ចុបដ្ឋាបនា** ។

ការបិទបាំងនូវបាបដែលខ្លួនធ្វើ ដែលព្រះមានព្រះភាគចែកក្នុងគម្ពីរវិភង្គ ដោយន័យជាដើមថា បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ឈ្មោះថា **មាយា** ។

ការប្រចណែនក្នុងលាភសក្ការៈរបស់អ្នកដទៃជាដើម ឈ្មោះថា **ឧស្សុយា**។ ពាក្យដែលបុគ្គលលើកឡើង មានពាក្យអធិប្បាយថា ការលើកខ្លួនឡើង ឈ្មោះថា **ភស្សសមុស្សយោ** ។ ការប្រកាន់ខ្លួនដែលព្រះមានព្រះភាគទ្រង់ចែកក្នុងគម្ពីរវិភង្គថា បុគ្គលពួកខ្លះ ក្នុងលោកនេះ កាលមុនតម្កល់ខ្លួនថា ស្មើនឹងជនដទៃ កាលជាខាងក្រោយមក តម្កល់ខ្លួនថា ប្រសើរ

ជាងជនដទៃវិញ មិនតម្កល់ខ្លួនថា ថោកទាបជាងជនដទៃ ដោយជាតិក្តី ។បេ។ ដោយវត្ថុណាមួយក្តី ការប្រកាន់ អាការប្រកាន់ ភាពនៃសេចក្តីប្រកាន់ ការធ្វើងធ្មៃ អាការព្រហើន ភាពដូចជាទង់ ... ឈ្មោះថា **មានាតិមានោ។**

ការសេពគប់នឹងអសប្បុរសទាំងឡាយ ឈ្មោះថា **អសព្ភិ សន្ថវោ។**

បាទព្រះគាថាថា **ឯសាមគន្ធោ ន ហិ មំសភោជនំ** សេចក្តីថា គំនរអកុសល ៩ យ៉ាង មានសេចក្តីក្រោធជាដើម គប្បីជ្រាបថា ជាក្លិនឆ្អាប ដោយអត្ថតាមដែលពោលហើយខាងដើមនោះឯង សាច់ និងភោជន មិនឈ្មោះថា ជាក្លិនឆ្អាបឡើយ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងក្លិនឆ្អាប ៩ យ៉ាង ដោយទេសនាដែលជាធម្មាធិដ្ឋានយ៉ាងនេះហើយ កាលទ្រង់វិសជ្ជនានូវក្លិនឆ្អាបដោយទេសនាដែលជាបុគ្គលាធិដ្ឋាន មានន័យតាមដែលខ្ញុំពោលហើយខាងដើមនោះឯង ក៏ទ្រង់ភាសិត ៣ គាថា ។

បណ្តាបទទាំងនោះ ពីរបទថា **យេ ចាបសីលា** សេចក្តីថា ជនណាប្រាកដក្នុងលោកថា មានប្រក្រតីប្រព្រឹត្តអាក្រក់ ព្រោះជាអ្នកមានការប្រព្រឹត្តិអាក្រក់ ។

ការខ្ចីបុល ហើយសម្លាប់ម្ចាស់បំណុល ព្រោះមិនសងទ្រព្យនោះ និងការពោលពាក្យញុះញង់ តាមន័យដែលពោលហើយក្នុងវិសេសសូត្រ ឈ្មោះថា **ឥណឃាតសូចកា ។**

បាទគាថាថា **វោហារកូដា ឥធ ទាជិរូបិកា** សេចក្តីថា ជនទាំងឡាយ តាំងនៅហើយ ក្នុងឋានៈដែលតាំងនៅក្នុងធម៌ ជាអ្នកកាត់ក្តី ទទួលសំណូក ហើយធ្វើម្ចាស់ទ្រព្យឲ្យចាញ់ ឈ្មោះថា **វោហារកូដា** ព្រោះប្រកបដោយ វោហារដែលកោង ឈ្មោះថា **ទាជិរូបិកា** ព្រោះបោកបញ្ឆោតលើបុគ្គល ដែលតាំងនៅក្នុងធម៌ ។

ម្យ៉ាងទៀត បទថា **ឥធ** បានដល់ ក្នុងសាសនានេះ ។ បទថា **ទាជិ-រូបិកា** បានដល់ ពួកមនុស្សទ្រុស្តសីល ។

ពិតហើយ ព្រោះបុគ្គលទ្រុស្តសីលទាំងនោះ មានការសង្រួមឥរិយាបថ ឲ្យស្អាតរៀបរយជាដើម ដែលប្រៀបដូចជាមួយនឹងបុគ្គលមានសីល ដូច្នោះ ទើបឈ្មោះថា **ទាជិរូបិកា** ។

បាទគាថាថា **ឥរាធមា យេធ ករោន្តិ កិព្វិសំ** សេចក្តីថា ជនឯណា ជាបុគ្គលថោកថយក្នុងលោកនេះ រមែងធ្វើនូវកម្មគ្រោតគ្រាត ពោល គឺ បដិបត្តិខុសក្នុងមាតា និងបិតាទាំងឡាយ និងក្នុងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ជាដើម ។

បាទគាថាថា **ឯសាមគន្ធោ ន ហិ មំសភោជនំ** សេចក្តីថា កិនបែប នេះដែលព្រះមានព្រះភាគទ្រង់សម្តែងដោយគាថានេះ ដែលតាំងនៅហើយក្នុង បុគ្គលអ្នកសិក្សា គប្បីជ្រាបក្លិនឆ្អាបដទៃ ៦ ប្រភេទទៀត ដោយអត្ថដែល ខ្ញុំពោលហើយខាងដើម គឺភាពជាអ្នកមានប្រក្រតីប្រព្រឹត្តអាក្រក់ ១ ជំពាក់

បំណុល ១ និយាយចាក់ដោត ១ កាត់ក្តីកោង ១ បោកបញ្ឆោត ១ ធ្វើនូវអំពើគ្រោតគ្រាត ១ ថាជាកិច្ចទិន្នាប សាច់ និងភោជន មិនមែនជាកិច្ចទិន្នាបឡើយ ដូច្នេះ ។

បាទគាថាថា **យេ ឥធ បាណេសុ អសំយតា ជនា** សេចក្តីថា ជនណាក្នុងលោកនេះ សម្លាប់សត្វ ១០០ ខ្លះ ១០០០ ខ្លះ ប្រព្រឹត្តនូវការចងបាន ឈ្មោះថា **អសំយតា** ព្រោះមិនធ្វើសូម្បីត្រឹមតែសេចក្តីករុណា ក្នុងសត្វទាំងឡាយ ។

បាទគាថាថា **បរេ សមាទាយ វិហេសមុយ្យុតា** សេចក្តីថា កាន់យកទ្រព្យ ឬជីវិតដែលជារបស់បុគ្គលដទៃ បន្ទាប់ពីនោះ ក៏ប្រកបការបៀតបៀនដោយការប្រើបាតដៃ ដុំដី និងដំបងចំពោះជនទាំងឡាយដែលអង្វរ ឬឃាត់ថា លោកទាំងឡាយ កុំធ្វើយ៉ាងនេះ ដូច្នេះ ។

ម្យ៉ាងទៀត ចាប់សត្វទាំងឡាយបានហើយ កំណត់យ៉ាងនេះថា អញនឹងសម្លាប់ ១០ ក្នុងថ្ងៃនេះ សម្លាប់ ២០ ក្នុងថ្ងៃនេះ ដូច្នេះហើយ ក៏ធ្វើការបៀតបៀនសត្វទាំងនោះ ដោយការសម្លាប់ និងការចងជាដើម ។

បទថា **ទុស្សីលលុទ្ទា** សេចក្តីថា ឈ្មោះថា **ទុស្សីល** ព្រោះប្រព្រឹត្តអាក្រក់ និងឈ្មោះថា **លុទ្ទា** ព្រោះជាអ្នកមានការងារគ្រោតគ្រាត និងជាអ្នកមានបាតដៃប្រឡាក់ឈាម ។ ជនទាំងឡាយដែលមានកម្មដ៏លាមក មានអ្នកប្រមង់ព្រានម្រឹគ ព្រានបក្សីជាដើម ព្រះមានព្រះភាគទ្រង់បំណាងយកក្នុង

គាថានេះ ។

បទថា **ជរុសា** បានដល់ មានវាចាគ្រោតគ្រាត ។ បទថា **អធានភា** បានដល់ ជាអ្នកវៀរចាកនូវការអើពើយ៉ាងនេះថា ពួកយើងនឹងមិនធ្វើក្នុងឥឡូវនេះ ពួកយើងនឹងវៀរចាកបាបបែបនេះ ។

បាទគាថាថា **ឯសាមគន្ធោ ន ហិ មំសភោជនំ** សេចក្ដីថា ក្លិននេះដែលព្រះមានព្រះភាគ ទ្រង់សម្ដែងដោយគាថានេះ ដែលតាំងនៅហើយក្នុងបុគ្គល ទាំងដែលខ្ញុំពោលហើយ និងមិនទាន់បានពោល ដោយកាលមុនជាដើមថា ការសម្លាប់ ការវាយ ការកាត់ និងការចងជាដើម ។ បណ្ឌិតគប្បីជ្រាបក្លិនឆ្អាប ៦ ប្រភេទ គឺការមិនសង្រួមក្នុងសត្វទាំងឡាយ ១ ការបៀតបៀនសត្វដទៃ ១ ភាពជាអ្នកទ្រុស្តសីល ១ ភាពជាអ្នកឃោរឃៅ ១ ភាពជាបុគ្គលគ្រោតគ្រាត ១ ភាពជាបុគ្គលមិនអើពើ ១ សាច់ និងភោជន មិនឈ្មោះថា ជាក្លិនឆ្អាបឡើយ សមដូចពាក្យដែលលោកពោលខាងដើមថា សេចក្ដីនោះ លោកមិនបានពោលទៀត ដោយហេតុទាំងឡាយយ៉ាងនេះថា ដើម្បីប្រាប្ធានឹងស្ដាប់ ដើម្បីការកំណត់ ដើម្បីធ្វើឲ្យមាំទាំ ។ ដោយហេតុនោះឯង ទើបលោកពោលដល់អត្ថនេះខាងមុខ ព្រះមានព្រះភាគដល់ត្រើយនៃមន្ត បានត្រាស់អត្ថនេះយ៉ាងនេះរឿយៗ ឈ្មោះថា ឲ្យអ្នកដទៃជ្រាបអត្ថនោះ ។

បាទគាថាថា **ឯតេសុ គិទ្ធា វិរុទ្ធាតិចាតិនោ** សេចក្តីថា ត្រេកត្រអាលហើយ ដោយតម្រេកក្នុងសត្វទាំងនោះ ក្រោធហើយដោយទោសៈ មិនឃើញទោសដោយមោហៈ និងសម្លាប់សត្វដោយការប្រព្រឹត្តិខុសក្នុងសត្វទាំងឡាយរឿយៗ ។ ម្យ៉ាងទៀត រាគៈ ទោសៈ និងមោហៈ ពោល គឺតម្រេក សេចក្តីក្រោធ និងការសម្លាប់សត្វពួកណា ជនទាំងឡាយ ត្រេកត្រអាល ក្រោធ និងសម្លាប់សត្វដោយរាគៈ ទោសៈ និងមោហៈទាំងនោះ តាមដែលកិលេសនោះ កើតឡើងក្នុងបាបកម្មទាំងឡាយ ដែលលោកពោលហើយដោយន័យថា ការសម្លាប់ ការវាយ ការកាត់ និងការចង ។

បទថា **និច្ចុយ្យុតា** សេចក្តីថា ប្រកបក្នុងអកុសលកម្មជានិច្ច គឺជួនកាលពិចារណាហើយ ក៏មិនវៀរ ។ បទថា **បេច្ច** បានដល់ ទៅអំពីលោកនេះ កាន់លោកដទៃ ។

បាទគាថាថា **តមំ វជន្តិ មេ បតន្តិ សត្តា និរយំ អវំសិរា** សេចក្តីថា ជនពួកណាទៅកាន់ទីងងឹត ពោល គឺលោកន្តរិកនរក ដែលងងឹតអន្ធការ ឬដោយត្រកូលមានត្រកូលទាបថោកជាដើម និងសត្វពួកណា មានក្បាលសំយុងចុះ បានដល់ មានក្បាលធ្លាក់ចុះទៅកាន់នរក មានអវីចីនរកជាដើម ។

បទថា **ឯសាមគន្ធោ** សេចក្តីថា ក្លិនឆ្អាប ៣ យ៉ាង ដោយអត្ថ តាមដែលខ្ញុំពោលហើយ ដែលជាមូលនៃក្លិនឆ្អាបទាំងពួង មានតម្រេក សេចក្តីក្រោធ និងការសម្លាប់សត្វ ព្រោះជាហេតុឲ្យសត្វទាំងនោះទៅកាន់ទីងងឹត និងធ្លាក់នរក នេះឈ្មោះថា ក្លិនឆ្អាប ។

បទថា **ន ហិ មំសភោជនំ** សេចក្តីថា សាច់ និងភោជន មិនឈ្មោះថា ក្លិនឆ្អាបឡើយ ។

ព្រះមានព្រះភាគ កាលទ្រង់វិសជ្ជនាក្លិនឆ្អាបដោយបរមត្ថ និងទ្រង់ប្រកាសថា ក្លិនឆ្អាបជាផ្លូវនៃទុគ្គតិយ៉ាងនេះហើយ ឥឡូវនេះ តាបសមានការសម្គាល់ក្នុងត្រី សាច់ និងភោជនណាថា ជាក្លិនឆ្អាប និងមានសេចក្តីសម្គាល់ថា ជាផ្លូវនៃទុគ្គតិ ជាអ្នកប្រាថ្នាសេចក្តីបរិសុទ្ធិ ដោយការមិនបរិភោគត្រីសាច់ និងភោជននោះ ទើបមិនព្រមបរិភោគត្រីសាច់ និងភោជននោះ កាលទ្រង់សម្តែងភាពដែលសាច់ និងភោជននោះ និងភោជនដទៃៗ បែបនោះ មិនអាចជម្រះខ្លួនឲ្យបរិសុទ្ធបាន ទើបត្រាស់គាថាទី ៦ ថា **ន មច្ឆមំសំ** ជាដើម ។

ក្នុងគាថានោះ អ្នកសិក្សាគប្បីនាំយកពាក្យចុងក្រោយ គឺបទថា **ន សោធេតិ មច្ចំ អវិតិណ្ណកង្ខំ** មកភ្ជាប់ជាមួយគ្រប់បទយ៉ាងនេះថា ការមិនបរិភោគត្រី និងសាច់ មិនបានធ្វើសត្វដែលមិនទាន់ឆ្លងសេចក្តីសង្ស័យបានឲ្យបរិសុទ្ធបានឡើយ ការបួងសួង ការបូជាយញ្ញ និងការសេពឧតុ មិនបានញុំាងសត្វដែលមិនទាន់ឆ្លងសេចក្តីសង្ស័យឲ្យបរិសុទ្ធបានឡើយ ក្នុងសេចក្តីនេះ បើមានពាក្យសួរថា បុរាណាចារ្យទាំងឡាយពោលយ៉ាងនេះថា ពាក្យថា **ន មច្ឆមំសំ** បានដល់ ត្រី និងសាច់ ដែលបុគ្គលមិនបរិភោគ ក៏ធ្វើឲ្យបរិសុទ្ធមិនបានឡើយ ការមិនបរិភោគត្រី និងសាច់ ក៏មិនអាចធ្វើសត្វឲ្យបរិសុទ្ធបានដូចគ្នា ដូច្នេះជាដើម ។ ព្រោះថា ការពោលយ៉ាងនេះ គប្បីល្អជាង គឺយល់

ឆាយជាង សូម្បីព្រះបាលីក៏មានថា **ន មច្ឆមំសានំ អនាសកត្តំ** សន្ធិជា **ន មច្ឆមំសានាសកត្តំ** បានដល់ ភាពជាអ្នកមិនបរិភោគ ត្រី និងសាច់ រមែងមិនធ្វើសត្វឲ្យបរិសុទ្ធបាន កាលបើដូច្នេះ ភាពជាអ្នកមិនបរិភោគបាត់ទៅណា ។ ឆ្លើយថា ពាក្យនោះ មិនបាត់ទៅណាឡើយ តែព្រះលោកសង្គ្រោះចូលដោយការធ្វើរកិលេស ដើម្បីភាពជាទេវតា ព្រោះថា ការទូន្មានខ្លួន ក្រៅអំពីដែលពោលហើយទាំងអស់ រមែងដល់នូវការសង្គ្រោះក្នុងពាក្យនេះថា **យេ វាបិ លោកេ អមរា ពហូ តបា ។**

ភាពជាបុគ្គលអាក្រាតកាយ ឈ្មោះថា **នគ្គិយំ ។** ភាពជាបុគ្គលក្បាលត្រងោល ឈ្មោះថា **មុណ្ឌិយំ ។** ការចងជដា និងការប្រឡាក់ប្រឡូសដោយធូលី ឈ្មោះថា **ជដាជល្លំ ។** ក្រចក និងស្បែកខ្លា ឈ្មោះថា **ខរាជិនានិ ។** ការបម្រើភ្លើង ឈ្មោះថា **អគ្គិហោតស្សុបសេវនា ។** ការសៅហ្មងផ្លូវកាយដែលប្រព្រឹត្តទៅហើយ ដើម្បីសេចក្តីប្រាថ្នាភាពជាទេវតា ឈ្មោះថា **អមរា ។** បទថា **ពហូ** បានដល់ ជាច្រើន មានការអង្គុយប្រហោងជាដើម ។ ការធ្វើរកិលេសតាមកាយ ឈ្មោះថា **តបា ។** វេទទាំងឡាយ ឈ្មោះថា **មន្តា ។** កម្មគឺការបូជាភ្លើង ឈ្មោះថា **អាហុតី ។** យញ្ញដែលឈ្មោះថា **អស្សមេធ** ជាដើម និងការសេពឧតុ ឈ្មោះថា **យញ្ញមុតូបសេវនា ។**

ការសេពនូវទីក្តៅក្នុងរដូវក្តៅ ការសេពរុក្ខមូលក្នុងរដូវភ្លៀង ការសេពគឺការចូលទៅកាន់ជលាល័យក្នុងរដូវរងា ឈ្មោះថា **ឧតូបសេវនា ។**

បាទគាថាថា **ន សោធេតិ មច្ចំ អវិតិណ្ណកង្ខំ** បានដល់ រមែងមិនធ្វើសត្វដែលឆ្លងនូវសេចក្ដីសង្ស័យមិនទាន់បានឲ្យបរិសុទ្ធ ដោយការបរិសុទ្ធិចាកកិលេស ឬដោយការបរិសុទ្ធិចាកភព ព្រោះកាលនៅមានមន្ទិល គឺសេចក្ដីសង្ស័យ សត្វក៏ជាបុគ្គលបរិសុទ្ធមិនបាន ហើយខ្លួនលោកផ្ទាល់ក៏ឈ្មោះថានៅមានសេចក្ដីសង្ស័យនោះឯង ។

ក្នុងគាថានេះ មានពាក្យអធិប្បាយថា ពាក្យថា **អវិតិណ្ណកង្ខំ** នេះ គប្បីជាពាក្យដែលព្រះមានព្រះភាគ ត្រាស់ក្នុងការកើតសេចក្ដីសង្ស័យដល់តាបសថា ផ្លូវនៃសេចក្ដីបរិសុទ្ធិមិនគប្បីមាន ព្រោះហេតុមានការមិនបរិភោគត្រី និងសាច់ជាដើមឬហ្ន៎ ព្រោះបានស្ដាប់នូវពាក្យទាំងឡាយ មានពាក្យជាដើមថា **ន មច្ឆមំសំ** សេចក្ដីសង្ស័យក្នុងព្រះមានព្រះភាគឯណា កើតឡើងដល់តាបសនោះ ព្រោះបានស្ដាប់មកថា ព្រះមានព្រះភាគអង្គនោះ សោយត្រី និងសាច់ ដូច្នេះ ពាក្យនេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគ ត្រាស់សំដៅដល់សេចក្ដីសង្ស័យនោះ ។

ព្រះមានព្រះភាគ កាលត្រាស់បទសម្ដែងនូវភាពដែលបុគ្គលមិនអាចធ្វើខ្លួនឲ្យបរិសុទ្ធដោយមិនបរិភោគសាច់ជាដើមយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងព្រះធម៌ដែលអាចធ្វើសត្វឲ្យបរិសុទ្ធបាន ទើបត្រាស់គាថានេះថា **សោតេសុ គុត្តោ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **សោតេសុ** បានដល់ ក្នុងឥន្ទ្រិយ ៦ ។

បទថា **គុត្តោ** បានដល់ ប្រកបដោយការរក្សា គឺការសង្រួមឥន្ទ្រិយ ។ ព្រះមានព្រះភាគទ្រង់សម្តែងសីល មានឥន្ទ្រិយសំវរៈជាបរិវារដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

បទថា **វិទិតិន្ទ្រិយោ ចរេ** សេចក្តីថា ជ្រាបឥន្ទ្រិយទាំង ៦ ដោយញាតបរិញ្ញា ធ្វើឲ្យប្រាកដហើយ គប្បីប្រព្រឹត្តឲ្យ អធិប្បាយថា គប្បីប្រព្រឹត្តទៅ ព្រះមានព្រះភាគទ្រង់សម្តែងការកំណត់នាមរូប នៃបុគ្គលដែលមានសីលបរិសុទ្ធហើយ ដោយហេតុមានប្រមាណប៉ុណ្ណេះ ។

បទថា **ធម្មេ ឋិតោ** បានដល់ តាំងនៅក្នុងធម៌ គឺអរិយសច្ច ៤ ដែលគប្បីសម្រេចបានដោយអរិយមគ្គ ដោយពាក្យថា **ធម្មេ ឋិតោ** នេះ ព្រះមានព្រះភាគទ្រង់សម្តែងដល់ភូមិនៃព្រះសោតាបន្ន ។

បទថា **អជ្ជវមទ្ទវេ រតោ** បានដល់ ត្រេកអរហើយ ក្នុងភាពជាមនុស្សត្រង់ និងក្នុងភាពជាមនុស្សទន់ភ្លន់ ។ ដោយពាក្យថា **អជ្ជវមទ្ទវេ រតោ** នេះ ព្រះមានព្រះភាគទ្រង់សម្តែងដល់ភូមិរបស់ព្រះសកទាគាមី ត្បិតថា សកទាគាមិបុគ្គល ត្រេកអរហើយក្នុងការស្មោះត្រង់ និងការទន់ភ្លន់ ព្រោះលោកធ្វើរាគៈ និងទោសៈ ដែលធ្វើនូវការវៀចនៃកាយជាដើម និងធ្វើនូវការរឹងត្អឹងនៃចិត្តឲ្យស្រាលចុះ ។

បទថា **សង្គាតិគោ** បានដល់ ឆ្លងផុតនូវគ្រឿងជាប់ជំពាក់ គឺរាគៈ និងទោសៈបាន ដោយបទថា **សង្គាតិគោ** នេះ ព្រះមានព្រះភាគទ្រង់សម្តែងនូវ

ភូមិនៃព្រះអនាគាមី ។

បទថា **សព្វទុក្ខប្បហីនោ** សេចក្តីថា ឈ្មោះថា លះទុក្ខទាំងពួងបាន ព្រោះលះហេតុនៃទុក្ខក្នុងវដ្តៈទាំងមូលបាន ដោយពាក្យថា **សព្វទុក្ខប្បហីនោ** នេះ ព្រះមានព្រះភាគទ្រង់សម្តែងអរហត្តភូមិ ។

បាទព្រះគាថាថា **ន លិម្បតិ ទិដ្ឋសុតេសុ ធីរោ** សេចក្តីថា បុគ្គលនោះសម្រេចហើយនូវអរហត្តដោយលំដាប់យ៉ាងនេះ ឈ្មោះថា ជាអ្នកប្រាជ្ញ ព្រោះដល់ព្រមដោយសេចក្តីព្យាយាម រមែងមិនជាប់ក្នុងធម៌ទាំងឡាយ ដែលខ្លួនឃើញ និងស្តាប់ហើយ ដោយការជាប់ជំពាក់ណាមួយ ។

ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនាដែលជាបុគ្គលាធិដ្ឋានតែម្យ៉ាង ក៏មិនមែន តែទ្រង់បញ្ចប់ដោយកំពូល គឺអរហត្តនោះឯងថា បុគ្គលនោះរមែងមិនជាប់ក្នុងធម៌ទាំងឡាយ ដែលឃើញផង ដែលឮផង និងក្នុងធម៌ទាំងឡាយដែលខ្លួនជ្រាប និងបានដឹង ទើបជាបុគ្គលដល់ហើយនូវសេចក្តីបរិសុទ្ធិយ៉ាងក្រៃលែងដោយពិត ។

បន្ទាប់អំពីនេះទៅ ព្រះធម្មសង្គីតិកាចារ្យបានពោល ២ គាថាថា **ឥច្ចេ-តមត្ថំ** ដូច្នេះជាដើម ។

អ្នកសិក្សា គប្បីជ្រាបអត្ថនៃគាថានោះដូចតទៅនេះ ព្រះមានព្រះភាគទ្រង់ព្រះនាមកស្សបៈ បានត្រាស់ប្រាប់ គឺត្រាស់អត្ថនេះឲ្យពិស្តារ ដោយទេសនាដែលជាធម្មាធិដ្ឋាន និងជាបុគ្គលាធិដ្ឋាន ដោយគាថាជាអនេករឿយៗ

រហូតធ្វើឲ្យតាបសនោះជ្រាបច្បាស់ដូចពណ៌នាមក ដូច្នេះ ។

បទទាំងឡាយថា **តំ វេទគុំ មន្តចារគូ** សេចក្តីថា តិស្សព្រាហ្មណ៍នោះ ជាអ្នកដល់នូវត្រើយនៃមន្ត គឺដល់នូវត្រើយនៃវេទ បានជ្រាប គឺបានដឹងនូវអត្ថនោះ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះព្រះមុនីទ្រង់ប្រកាសដោយគាថាទាំងឡាយដែលពីរោះដោយអត្ថផង ដោយបទផង ដោយក្រសែនៃទេសនា ។

សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា ព្រះមុនីជាអ្នកមិនមានក្តិនក្តាប គឺកិលេស មិនអាស្រ័យតណ្ហា និងទិដ្ឋិ ឥតអ្នកណាមួយដឹកនាំឲ្យអាក្រក់បាន ដែលឈ្មោះថា ជាអ្នកមិនមានក្តិនក្តាប ព្រោះមិនមានកិលេសដែលជាក្តិនក្តាប ដែលឈ្មោះថា មិនអាស្រ័យតណ្ហា និងទិដ្ឋិ ក៏ព្រោះមិនមានតណ្ហា-និស្ស័យ និងទិដ្ឋិនិស្ស័យ ឈ្មោះថា ឥតអ្នកណាម្នាក់ដឹកនាំឲ្យអាក្រក់បាន ព្រោះបុគ្គលណាម្នាក់ មិនអាចដឹកនាំបាន ដោយអំណាចនៃទិដ្ឋិខាងក្រៅថា របស់នេះប្រសើរជាង របស់នេះប្រសើរ ដូច្នេះជាដើម ។

តិស្សព្រាហ្មណ៍ស្តាប់បទសុភាសិត គឺព្រះធម្មទេសនាដែលត្រាស់ដោយប្រពៃហើយ របស់ព្រះមានព្រះភាគអង្គនោះ ទ្រង់ប្រកាសហើយយ៉ាងនេះ ជាអ្នកមានចិត្តទន់ភ្លន់ ជាអ្នកមានចិត្តឱនលំទោន ថ្វាយបង្គំព្រះមានព្រះភាគដែលមិនមានក្តិនក្តាប មិនមានគ្រឿងជាប់ជំពាក់ គឺកិលេស បន្ទោបង់នូវសេចក្តីទុក្ខទាំងពួងចេញបាន បន្ទោបង់នូវសេចក្តីទុក្ខក្នុងវដ្តៈទាំងពួងបាន ហើយថ្វាយ

បង្គំបាទារបស់ព្រះមានព្រះភាគ ដោយបញ្ចង្គប្រតិស្ឋាន ។

បាទគាថាថា **តត្ថេវ បព្វជ្ជមរោចយិត្ថ** មានពាក្យអធិប្បាយថា តិស្ស-តាបសបានទូលសូម គឺបានទូលអង្វរសូមនូវបព្វជ្ជានឹងព្រះមានព្រះភាគ ព្រះនាមកស្សបៈអង្គនោះ ក្នុងអាសនៈនោះឯង ។

ព្រះមានព្រះភាគ បានត្រាស់នឹងតិស្សតាបសនោះថា ចូរអ្នកមកជាភិក្ខុចុះ ដូច្នេះ តាបសនោះជាអ្នកប្រកបដោយបរិក្ខារ ៨ ក្នុងរំពេចនោះឯង ដូចជាព្រះថេរៈដែលមានវស្សាមួយរយ មកតាមអាកាស ថ្វាយបង្គំព្រះមានព្រះភាគ ដោយកាលកន្លងទៅត្រឹមពីរបីថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចសាវក-បារមីញាណ បានជាអគ្គសាវក ឈ្មោះថា តិស្សៈ ។ ឯទុតិយសាវកឈ្មោះថា ភារទ្វាជៈ ។ ទើបព្រះមានព្រះភាគកស្សបៈអង្គនោះ មានគូនៃសាវក ដែលមានឈ្មោះថា តិស្សៈ និងភារទ្វាជៈ ដោយប្រការដូច្នេះ ។

ឯព្រះមានព្រះភាគនៃយើង ទ្រង់នាំ ១៤ គាថា ដែលតិស្សព្រាហ្មណ៍ពោលខាងដើម ៣ គាថា ដែលព្រះមានព្រះភាគព្រះនាមកស្សបៈត្រាស់ត្រង់កណ្តាល ៩ គាថា និងដែលព្រះសង្គីតិកាចារ្យទាំងឡាយពោលក្នុងទីបំផុត ២ គាថា ក្នុងកាលនោះ ទ្រង់ធ្វើឲ្យបរិបូណ៌ហើយ ទ្រង់ព្យាករក្ខិនធ្លាបដល់ពួកតាបស ៥០០ មានអាចារ្យជាប្រធាន ដែលឈ្មោះថា អាមគន្ធសូត្រនេះ ។

អាមគន្ធព្រាហ្មណ៍នោះ កាលស្តាប់ព្រះធម្មទេសនានោះហើយ ក៏មានចិត្តទន់ភ្លន់ដូចពោលហើយនោះឯង ថ្វាយបង្គំព្រះបាទារបស់ព្រះសាស្តា សូម

បួស មួយអន្លើដោយបរិស័ទរបស់ខ្លួន ព្រះសាស្ដាត្រាស់ថា អ្នកទាំងឡាយ ចូរមកជាភិក្ខុចុះ តាមសទាំងនោះដល់នូវភាពជាឯហិភិក្ខុដូច្នោះឯង ហាក់បីដូច ព្រះថេរៈដែលមានវស្សា ១០០ មកតាមអាកាសថ្វាយបង្គំព្រះមានព្រះភាគ ក្នុងកាលពីរបីថ្ងៃប៉ុណ្ណោះ ព្រះថេរៈទាំងនោះក៏បានតាំងនៅក្នុងអរហត្ត ដែល ជាអគ្គបុគ្គល ដូច្នេះ ។ល។

## អដ្ឋកថាអាមគន្ធសូត្រទី ២ ចប់

# សុត្តន្តបិដក

## ហិរិសូត្រ ទី ៣

[ ២៣ ] បណ្ឌិតបុរស គប្បីដឹងនូវបុគ្គលនោះ ដែលមិនមានសេចក្ដីអៀនខ្មាស មិនមានសេចក្ដីខ្ពើមរអើម និយាយថា ខ្ញុំជាសម្លាញ់ ( របស់អ្នក ) មិនអើពើនឹងការងារទាំងឡាយ ( របស់សម្លាញ់ ) ដែលខ្លួនអាចធ្វើបានថា បុគ្គលនោះ មិនមែនជាមិត្តរបស់អញទេ ។

បុគ្គលណា ពោលវាចាជាទីស្រឡាញ់ ដែលខ្លួនមិនប្រព្រឹត្តតាមចំពោះមិត្ត បណ្ឌិតទាំងឡាយ កំណត់ដឹង ( នូវបុគ្គលនោះ ) ថា គ្រាន់តែជាអ្នកនិយាយ តែមិនធ្វើ ។

បុគ្គលណា មិនប្រមាទសព្វកាល មានសេចក្ដីរង្កៀស ក្នុងការបែកបាក់គ្នា ជាអ្នកឃើញរឿយៗ នូវទោស បុគ្គលនោះ មិនហៅថា មិត្តទេ លុះតែបុគ្គលណា ដែលបុគ្គលដទៃបំបែកមិនបាន ដេកនៅ ( ឥតរង្កៀស ) ក្នុងមិត្តណា បុគ្គលនោះឯង ទើបហៅថា ជាមិត្ត ។

បុគ្គលជាអ្នកប្រាថ្នានូវផល កាលនាំមកនូវធុរៈ ជារបស់បុរស រមែងញ៉ាំងឋានៈ គឺព្យាយាម ជាទីធ្វើឲ្យកើតបាមោជ្ជ នាំមកនូវសេចក្ដីសរសើរ ជាសុខ ឲ្យចម្រើន បុគ្គលក្រេបផឹកនូវរស នៃសេចក្ដីស្ងប់រម្ងាប់ផង នូវរសនៃព្រះនិព្វាន ជាទីចូល

ទៅរម្ងាប់ផង ផឹកនូវរសនៃបីតិ ដែលកើតអំពីអរិយធម៌ហើយ
រមែងជាអ្នកមិនមានសេចក្ដីក្រវល់ក្រវាយ មិនមានបាប ។

ហិរិសូត្រទី ៣ ចប់

# អដ្ឋកថា

## ហិរិសូត្រ

[ ២៣ ] ក្នុងហិរិសូត្រទី ៣ មានពាក្យផ្ដើមថា **ហិរិន្តរន្តំ** ដូច្នេះ ។

សួរថា អត្ថុប្បត្តិហេតុនៃសូត្រនេះដូចម្ដេច ។ ឆ្លើយថា ព្រះសូត្រនេះមានអត្ថុប្បត្តិហេតុដូចតទៅនេះ

កាលព្រះមានព្រះភាគនៃយើងទាំងឡាយមិនទាន់កើតឡើង ព្រាហ្មណមហាសាលម្នាក់ ក្នុងក្រុងសាវត្ថី ជាអ្នកស្ដុកស្ដម្ភ មានទ្រព្យ ៨០ កោដិ ព្រាហ្មណ៍នោះ មានកូនម្នាក់ជាទីស្រឡាញ់ពេញចិត្ត គាត់ចិញ្ចឹមកូនប្រុសនោះឲ្យធំធាត់ ដោយគ្រឿងឧបភោគបរិភោគច្រើនប្រការ ដូចជាចិញ្ចឹមទេវកុមារដូច្នោះ មិនទាន់បានប្រគល់ទ្រព្យនោះដល់កូន ក៏បានស្លាប់ទៅ មួយអន្លើនឹងព្រាហ្មណីជាភរិយា ។

បន្ទាប់អំពីនោះ អំណឹះតតអំពីមាតាបិតារបស់មាណពនោះ អ្នករក្សាឃ្លាំង ក៏បើកឃ្លាំងទ្រព្យ ដើម្បីប្រគល់ទ្រព្យសម្បត្តិ ដោយពោលថា បពិត្រ

លោកម្ចាស់ ទ្រព្យនេះ ជាចំណែកមាតាបិតារបស់លោក ទ្រព្យនេះ ជាចំណែករបស់ជីដូន និងជីតា ទ្រព្យនេះ ជាទ្រព្យ ៧ ត្រកូលតគ្នាមក ដូច្នេះ មាណពឃើញទ្រព្យហើយ គិតថា ទ្រព្យនេះនៅសល់ ចំណែកជនដែលសន្សំទ្រព្យនេះ មិនប្រាកដសោះ ជនទាំងនោះធ្លាក់ក្នុងអំណាចនៃមច្ចុ កាលទៅ ក៏មិនបាននាំអ្វីទៅអំពីលោកនេះ ជនទាំងនោះ លះភោគសម្បត្តិទាំងឡាយ ទៅបរលោកយ៉ាងនេះ វៀរសុចរិតហើយ អ្នកណាក៏មិនអាចនាំអ្វីជាប់ខ្លួនទៅបាន បើដូច្នោះ អញនឹងបរិច្ចាគទ្រព្យនេះ ហើយកាន់យកទ្រព្យ គឺសុចរិត ដែលអញអាចនាំជាប់ខ្លួនទៅបាន ។ សេដ្ឋីបុត្ត កាលលះទ្រព្យមួយថ្ងៃមួយសែន ក៏ត្រិះរិះទៀតថា ទ្រព្យនេះក៏នៅគ្រប់គ្រាន់ ប្រយោជន៍អ្វីដោយបរិច្ចាគដែលមានប្រមាណតិចតួចយ៉ាងនេះ កាលបើដូច្នោះ អញនឹងឲ្យមហាទាន ហើយក្រាបទូលដល់ព្រះរាជាថា បពិត្រមហារាជ ទូលបង្គំមានទ្រព្យក្នុងផ្ទះប៉ុណ្ណេះ ទូលបង្គំប្រាថ្នានឹងឲ្យមហាទានដោយទ្រព្យនោះ ទូលបង្គំសូមឱកាស សូមទ្រង់ឲ្យគេប្រកាសក្នុងព្រះនគរ ។ ព្រះរាជាត្រាស់ឲ្យធ្វើយ៉ាងនោះ ព្រាហ្មណ៍នោះបានដាក់ភាជន៍ទាំងឡាយរបស់ពួកជនដែលមកហើយឲ្យពេញ ហើយបានបរិច្ចាគទ្រព្យទាំងអស់ អស់កាល ៧ ថ្ងៃ កាលបរិច្ចាគហើយ ទើបបានត្រិះរិះថា បុគ្គលដែលធ្វើមហាបរិច្ចាគយ៉ាងនេះហើយ នៅគ្រប់គ្រងផ្ទះ មិនសមគួរ បើដូច្នោះ អញនឹងបួស ទើបប្រាប់រឿងនេះដល់បរិវារជន ។ ជនជាបរិវារពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំគិតថា ទ្រព្យអស់ទៅ

ហើយ ពួកខ្ញុំនឹងសន្សំទ្រព្យដោយឧបាយផ្សេងៗ ដោយប្រើពេលបន្តិចបន្តួចប៉ុណ្ណោះ ហើយឃាត់ព្រាហ្មណ៍នោះដោយប្រការផ្សេងៗ ព្រាហ្មណ៍នោះ មិនអើពើក្នុងសំណូមពររបស់បរិវារជនទាំងនោះ បានចេញបួសជាតាបស ។ ក្នុងតាបសទាំងនោះ តាបសមាន ៨ ពួក គឺសបុត្តកភរិយ ១ ឧញ្ឆាចារិកា ១ សម្បត្តកាលិក ១ អនគ្គិបក្កិក ១ អសាមបាកិក ១ ទន្តលុយ្យក ១ បវត្តផលិក ១ វណ្ដមុត្តក ១ ។

ក្នុងតាបស ៨ ពួកនោះ តាបសទាំងឡាយ មានកេណិយជដិលជាដើម ដែលចេញបួសទាំងប្រពន្ធ ទាំងកូន ហើយចិញ្ចឹមជីវិតដោយខេត្តកម្ម និងពាណិជកម្ម ឈ្មោះថា **សបុត្តកភរិយ**។

តាបសទាំងឡាយដែលសាងអាស្រមត្រង់ទ្វារព្រះនគរ ហើយឲ្យកុមារទាំងឡាយ មានកូនស្តេច និងកូនព្រាហ្មណ៍ជាដើមសិក្សានូវសិប្បៈ មិនបានទទួលមាសប្រាក់ កាន់យកតែរបស់ដែលជាកប្បិយៈ មានល្ង និងអង្ករជាដើម ឈ្មោះថា **ឧញ្ឆាចារិកា**។ តាបសឧញ្ឆាចារិកនេះ ប្រសើរជាងតាបសដែលជាសបុត្តកភរិយ ។

ពួកតាបសដែលទទួលអាហារ ក្នុងកាលនៃអាហារប៉ុណ្ណោះចិញ្ចឹមជីវិត ឈ្មោះថា **សម្បត្តកាលិក**។ តាបសប្រភេទសម្បត្តកាលិកនេះ ប្រសើរជាងពួកតាបសដែលជាឧញ្ឆាចារិក ។

ពួកតាបសដែលទំពាស៊ីស្លឹកឈើ និងផ្លែឈើដែលមិនចម្អិនដោយភ្លើង

ចិញ្ចឹមជីវិត ឈ្មោះថា **អនគ្គិបក្កិក**។ តាបសពួកអនគ្គិបក្កិកនេះប្រសើរជាង ពួកតាបសសម្បត្តកាលិក ។

ពួកតាបសដែលកាន់ដុំថ្មប៉ុនប្រអប់ដៃ ឬកាន់កាំបិត និងសស្ត្រាណា មួយជាដើម ត្រាច់ទៅ ទំពាស៊ីសម្បកឈើដែលជួបចំពោះមុខ ក្នុងកាលដែល ខ្វះស្រេកឃ្លាន អធិដ្ឋានអង្គនៃឧបោសថ ហើយចម្រើនព្រហ្មវិហារ ៤ ឈ្មោះថា **អស្មមុដ្ឋិក** ។ តាបសប្រភេទអស្សមុដ្ឋិកនេះ ប្រសើរជាងពួក តាបសអនគ្គិបក្កិក ។

ពួកតាបសដែលមិនកាន់យកដុំថ្មប៉ុនប្រអប់ដៃដែលក្ដាប់ជាដើម ប្រើធ្មេញ កកេរសម្បកឈើដែលជួបក្នុងកាលដែលស្រេកឃ្លាន អធិដ្ឋានអង្គឧបោសថ ចម្រើនព្រហ្មវិហារ ឈ្មោះថា **ទន្តលុយ្យក** ។ តាបសប្រភេទទន្តលុយ្យក នេះប្រសើរជាងពួកតាបសអស្សមុដ្ឋិក ។

ពួកតាបសដែលអាស្រ័យស្រះកើតឯង គឺស្រះធម្មជាតិ ឬអាស្រ័យ ដងព្រៃរស់នៅ ឫសឈើឯណា មានឫសនៃកិង្សុះ គឺឫសឈូកជាដើមដែល មាននៅក្នុងស្រះនោះ ឬឈើឯណាដែលមានក្នុងកាល មានផ្កាក្នុងព្រៃ ឬផ្លែ ឈើឯណា ដែលមានក្នុងដងព្រៃ ក្នុងកាលមានផ្លែ ក៏ទំពាស៊ីផ្កា និងផ្លែនោះ ឯង កាលផ្កា និងផ្លែមិនមាន ក៏ទំពាស៊ីក្រម៉ានៃដើមឈើក្នុងព្រៃនោះ មិនទៅ កាន់ទីដទៃ ព្រោះអាហារឡើយ អធិដ្ឋានអង្គឧបោសថ ចម្រើនព្រហ្មវិហារ ឈ្មោះថា **បវត្តផលិក**។ ពួកតាបសប្រភេទបវត្តផលិកនេះ ប្រសើរជាងពួក

តាបសទន្តលុយក្រ ។

ពួកតាបសដែលទំពាស៊ីស្លឹកឈើដែលជ្រុះលើផែនដីតែម្យ៉ាង ឈ្មោះថា **វណ្ណមុត្តក** ។ ពាក្យដ៏សេដ្ឋចគ្នានឹងបទមុននោះឯង តាបសប្រភេទវណ្ណមុត្តក នេះ ប្រសើរជាងតាបសទាំងពួង ។

ឯព្រាហ្មណកុលបុត្តនេះ គិតថា អញនឹងបួស ក្នុងបណ្តាបព្វជ្ជាដ៏ប្រសើរ ក្នុងតាបសបព្វជ្ជាទាំងឡាយ ដូច្នេះហើយ ក៏បព្វជ្ជាជាវណ្ណមុត្តកបព្វជ្ជានោះ ឯង បានធ្វើអាស្រមរំលងជួរភ្នំទី ២ ទី ៣ ក្នុងហិមវន្តប្បទេស ។

សម័យនោះ ព្រះមានព្រះភាគទ្រង់កើតឡើងក្នុងលោក ទ្រង់សម្តែង ធម្មចក្កដ៏ប្រសើរ យាងទៅកាន់ក្រុងសាវត្ថីដោយលំដាប់ គង់នៅក្នុងជេត-វនារាមរបស់អនាថបិណ្ឌិក ក្នុងក្រុងសាវត្ថី ។

គ្រានោះឯង បុរសអ្នកក្រុងសាវត្ថីម្នាក់ស្វែងរកខ្លឹមចន្ទន៍ជាដើមត្រង់ភ្នំ បានទៅដល់អាស្រមរបស់តាបសនោះ ថ្វាយបង្គំតាបសហើយ ឈរនៅក្នុង ចំណែកម្ខាង តាបសនោះឃើញបុរសនោះហើយ ក៏សួរថា តើអ្នកមកអំពី ណា បុរសនោះប្រាប់ថា ខ្ញុំមកពីក្រុងសាវត្ថី ។ តាបសសួរថា ក្នុងក្រុងសាវត្ថី នោះ តើមានហេតុការណ៍អ្វីកើតឡើងដែរឬទេ បុរសនោះឆ្លើយថា បពិត្រលោក ម្ចាស់ មនុស្សទាំងឡាយក្នុងក្រុងសាវត្ថីនោះ ជាអ្នកមិនប្រមាទ នាំគ្នាធ្វើនូវ បុណ្យទាំងឡាយ មានការឲ្យទានជាដើម ។

តាបសសួរថា ពួកមនុស្សទាំងនោះ ស្តាប់ពាក្យប្រៀនប្រដៅអ្នកណា

បុរសនោះឆ្លើយថា របស់ព្រះមានព្រះភាគសម្មាសម្ពុទ្ធ ។ តាបសកាន់កាំង ដោយការបានឮពាក្យថា **ពុទ្ធ** ទើបសួរថា អើបុរសដ៏ចម្រើន អ្នកពោលថា **ពុទ្ធោ** ដូច្នេះឬ តាបសបានសួរអស់វារៈ ៣ ដង ដូចខ្ញុំបានពោលហើយ ក្នុងអាមគន្ធសូត្រនោះឯង ទើបត្រេកអរថា សំឡេងថា **ពុទ្ធោ** នោះឯង ឮ បានដោយក្រ ដូច្នេះហើយ ជាអ្នកប្រាថ្នាទៅកាន់សម្នាក់របស់ព្រះមានព្រះភាគ ទើបត្រិះរិះថា ការទៅកាន់សម្នាក់របស់ព្រះមានព្រះភាគ ដោយដៃទទេមិនគួរ ឡើយ អញគប្បីយកអ្វីទៅហ្ន៎ តាបសក៏ត្រិះរិះទៀតថា ធម្មតាព្រះពុទ្ធទាំង-ឡាយ ទ្រង់មិនធូន់ក្នុងអាមិសឡើយ ណ្ហើយចុះ អញនឹងយកធម្មបណ្ណាការទៅ ដូច្នេះហើយ ទើបចងប្រស្នា ៤ ប្រការ គឺមិត្តដូចម្តេចមិនគួរសេពគប់ ១ មិត្ត ដូចម្តេចគួរសេពគប់ ១ សេចក្តីព្យាយាមដូចម្តេចគួរប្រកប ១ រសអ្វី ក្រៃលែងជាងរសទាំងឡាយ ១ ។

តាបសនោះចងបញ្ហានោះហើយ មានមុខទៅកាន់មជ្ឈិមប្រទេស ដល់ នគរសាវត្ថីដោយលំដាប់ ចូលទៅកាន់វត្តជេតពន ។ ព្រះមានព្រះភាគ ទ្រង់ ក៏គង់លើអាសនៈដើម្បីសម្តែងព្រះធម្មទេសនា ក្នុងសម័យនោះឯង តាបស ឃើញព្រះមានព្រះភាគហើយ មិនថ្វាយបង្គំ ឈរនៅក្នុងចំណែកម្ខាង ព្រះ មានព្រះភាគត្រាស់ពាក្យដែលគួរជាទីត្រេកអរ ដោយន័យថា ម្នាលឥសី អ្នក ល្មមអត់ធន់បានដែរឬ ដូច្នេះជាដើម តាបសក៏សម្តែងសេចក្តីត្រេកអរតប ដោយន័យជាដើមថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គល្មមអត់ធន់បាន ដូច្នេះហើយ

ទើបគិតថា បើបុរសនេះជាព្រះពុទ្ធសោត កាលអញទូលសួរបញ្ហាដោយចិត្ត ទ្រង់នឹងឆ្លើយដោយវាចា ដូច្នេះហើយ ទើបសួរបញ្ហាទាំងនោះ នឹងព្រះមានព្រះភាគដោយចិត្តប៉ុណ្ណោះ ព្រះមានព្រះភាគកាលព្រាហ្មណ៍ទូលសួរហើយ ក៏ឆ្លើយបឋមបញ្ហាមុន ដោយផ្តើមថា **ហិរិន្តរន្តំ** ជាដើម ហើយត្រាស់គាថា ២ គាថាកន្លះ ។

អត្ថនៃព្រះគាថានោះ អ្នកសិក្សាគប្បីជ្រាបដូច្នេះ បទថា **ហិរិន្តរន្តំ** សេចក្តីថា បុគ្គលឈានកន្លងនូវការខ្មាស គឺមិនមានហិរិ បានដល់ មិនមានការខ្មាស ។

បទថា **វិជិគុច្ឆមានំ** បានដល់ ឃើញថា មិនស្អាត បុគ្គលមិនមានហិរិ រមែងខ្ពើមហិរិ រមែងឃើញដូចជារបស់មិនស្អាត ព្រោះហេតុនោះ ទើបបុគ្គលមិនគប់រក គឺមិនចូលទៅអង្គុយជិតនូវបុគ្គលដែលមិនមានហិរិនោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **វិជិគុច្ឆមានំ។**

បាទព្រះគាថាថា **សខាហមស្មិ ឥតិ ភាសមានំ** សេចក្តីថា បុគ្គលពោលដោយន័យជាដើមយ៉ាងនេះថា នែសម្លាញ់ ខ្ញុំជាសម្លាញ់របស់អ្នក ប្រាថ្នាប្រយោជន៍ដល់អ្នក សូម្បីជីវិតរបស់ខ្ញុំក៏លះដើម្បីអ្នកបាន ដូច្នេះ ។

បាទព្រះគាថាថា **សយ្ហានិ កម្មានិ អនាទិយន្តំ** សេចក្តីថា សូម្បីពោលយ៉ាងនេះហើយ ក៏មិនអើពើ គឺមិនតាំងចិត្តដើម្បីធ្វើការងាររបស់មិត្តនៃខ្លួន គឺកម្មទាំងឡាយរបស់មិត្ត ។

ម្យ៉ាងទៀត សេចក្តីថា មិនធ្វើត្រឹមតែការអើពើក្នុងការងារនោះដោយចិត្ត តែដោយពិតសម្តែងនូវការវិនាស ក្នុងកិច្ចទាំងឡាយ ដែលកើតឡើងប៉ុណ្ណោះ ។

បាទព្រះគាថាថា **នេសោ មមន្តិ ឥតិ នំ វិជញ្ញា** សេចក្តីថា បុរសដែលជាបណ្ឌិត គប្បីជ្រាបនូវបុគ្គលនោះ គឺបុគ្គលបែបនោះ យ៉ាងនេះថា បុគ្គលបែបនេះជាមិត្តក្លែងក្លាយ បុគ្គលបែបនេះមិនមែនមិត្តរបស់អញឡើយ ។

បទថា **អននុយំ** សេចក្តីថា មិត្តក្លែងក្លាយនោះ រមែងពោលថា ខ្ញុំនឹងឲ្យ នឹងធ្វើប្រយោជន៍ឯណា ក៏មិនបានជាប់តាមប្រយោជន៍ គឺមិនធ្វើតាមពាក្យនិយាយ ។

បទទាំងឡាយថា **បិយំ វាចំ យោ មិត្តេសុ បកុព្វតិ** សេចក្តីថា មិត្តណាប្រាស្រ័យដល់វត្ថុដែលកន្លងទៅហើយ និងមិនទាន់មកដល់ ឈ្មោះថា សង្គ្រោះនូវវត្ថុដែលមិនជាប្រយោជន៍ ឈ្មោះថា ញ៉ាំងវាចាដែលជាទីស្រឡាញ់ ឲ្យប្រព្រឹត្តទៅក្នុងមិត្រទាំងឡាយ ដោយហេតុត្រឹមតែស្រមោលនៃតួអក្សរប៉ុណ្ណោះ ។

គាថា ២ បាទថា **អករោន្តំ ភាសមានំ បរិជានន្តិ បណ្ឌិតា** សេចក្តីថា បណ្ឌិតទាំងឡាយកំណត់ដឹងបុគ្គលនោះ គឺបុគ្គលបែបនោះ ដែលមិនធ្វើតាមពាក្យដែលខ្លួនពោល ពោលដោយវាចាតែម្យ៉ាង យ៉ាងនេះថា បុគ្គលនេះឈ្មោះថា មានវាចាក្រៃលែង គឺល្អតែមាត់ មិនមែនមិត្ត ជាមិត្តក្លែងក្លាយ

ដូច្នេះ ។

បទទាំងឡាយថា **ន សោ មិត្តោ យោ សទា អប្បមត្តោ ភេទាសង្កី រន្ធមេវានុបស្សី** សេចក្តីថា បុគ្គលណាបំណងតែការប្រេះឆាប៉ុណ្ណោះ មិនប្រមាទសព្វកាល ដោយមារយាទដែលរៀបរយ គឺដោយវាចាពីរោះដែលខ្លួនធ្វើ រមែងស្វែងរកនូវទោសប៉ុណ្ណោះ យ៉ាងនេះថា វត្ថុណាដែលបុគ្គលធ្វើហើយ ដោយមិនមានស្មារតី ដោយមិនមានមសិការ ដោយមិនបានធ្វើ ដោយការមិនដឹង បុគ្គលនោះ នឹងតិះដៀលអាត្មាអញកាលណា កាលនោះ អញនឹងឆ្លើយតបបុគ្គលនោះ ដោយការធ្វើនោះ ដូច្នេះ មិត្តនោះ មិនគួរគប់រក ។

ព្រះមានព្រះភាគ កាលទ្រង់វិសជ្ជនាបញ្ហាទី ១ ថា មិនគួរគប់មិត្តប្រភេទណា យ៉ាងនេះហើយ កាលទ្រង់វិសជ្ជនាបញ្ហាទី ២ ទើបត្រាស់កន្លះគាថានេះថា **យស្មឹ ច សេតិ។**

អត្ថនៃគាថានោះថា ឯកូនដេកលើទ្រូងរបស់ឪពុក មិនមានសេចក្តីវង្វៀសសង្ស័យក្នុងហេតុទាំងឡាយថា កាលអញដេកលើទ្រូងឪពុកអញនេះ គប្បីមានសេចក្តីទុក្ខ ឬការមិនសប្បាយចិត្ត ទើបអស់សេចក្តីសង្ស័យ ហើយដេក យ៉ាងណា ដោយការទុកចិត្តចំពោះមិត្ត មិត្តធ្វើនូវការស្និទ្ធស្នាល ទុកចិត្តក្នុងភរិយា ទ្រព្យ និងជីវិតជាដើម អស់សេចក្តីសង្ស័យ ដោយភាពជាមិត្ត ដូច្នោះដូចគ្នា មិត្តណាដែលអ្នកដទៃពោលហេតុបបរយាបពាន់ ក៏មិនបែកគ្នា មិត្តនោះឯងគួរគប់រក ។ កាលព្រះមានព្រះភាគទ្រង់វិសជ្ជនាបញ្ហា

ទី ២ ថា មិត្តដូចម្តេចគួរគប់រក ដូច្នេះហើយ ដើម្បីទ្រង់វិសជ្ជនាបញ្ហាទី ៣ ទើបត្រាស់គាថាថា **ចាមុជ្ជការណំ** ជាដើម ។

អត្ថនៃគាថានោះថា ឈ្មោះថា **ចាមុជ្ជការណំ** ព្រោះអត្ថថា ធ្វើនូវការត្រេកអរ ។ ហេតុ ឈ្មោះថា **ឋានំ** ( សេចក្តីព្យាយាម ) ។ សួរថា ហេតុនោះ គឺអ្វី ឆ្លើយថា ហេតុនោះ គឺសេចក្តីព្យាយាម ។ ពិតហើយ សេចក្តីព្យាយាម លោកហៅថា ជាហេតុធ្វើនូវបាមោជ្ជ ព្រោះញុំាងនូវបីតិ បាមោជ្ជ និងសេចក្តីសុខ ដែលអាស្រ័យធម៌ឲ្យកើតឡើង ដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យដែលសាស្តាជាសព្វញ្ញូ ពោលត្រឹមត្រូវថា បុគ្គលណាមានព្យាយាមប្រារព្ធ បុគ្គលនោះ តែងនៅជាសុខ ដូច្នេះ ។ វត្ថុណានាំមកនូវសេចក្តីសរសើរ ដោយហេតុណា ហេតុនោះ ឈ្មោះថា **បសំសា-វហានំ** ។

ផលានិសង្សដែលប្រាថ្នា រមែងញុំាងផលដែលជាសុខឲ្យចម្រើន គឺឲ្យវឌ្ឍនាដោយឧបចារៈនៃផល ព្រោះនាំមកនូវទិព្វសុខ និងមនុស្សសុខ តាំងអំពីខាងដើម និងនាំមកនូវនិព្វានសុខក្នុងទីបំផុត ។

បាទព្រះគាថាថា **វហេន្តោ បោរិសំ ធុរំ** សេចក្តីថា កាន់យកនូវការៈដែលសមគួរដល់បុរស ឈ្មោះថា ធ្វើឋានៈ ពោល គឺសេចក្តីព្យាយាមដែលជាសម្មប្បធានឲ្យចម្រើន ។

ព្រះមានព្រះភាគ កាលទ្រង់វិសជ្ជនាបញ្ហាទី ៣ យ៉ាងនេះថា ការ

ព្យាយាមដូចម្តេចគួរប្រកប ដើម្បីទ្រង់វិសជ្ជនាបញ្ហាទី ៤ ទើបត្រាស់ថា **បវិវេករសំ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **បវិវេកោ** សេចក្តីថា ផលដ៏ប្រសើរ លោកហៅថា រសនៃវិវេកនោះ ព្រោះកើតអំពីការស្ងាត់ចាកកិលេស ផលដ៏ប្រសើរដែលសម្បយុត្តដោយវិវេកនោះ ឈ្មោះថា សុខ ព្រោះអត្ថថា ជាទីត្រេកអរនៃចិត្ត ។

បទថា **ឧបសមស្ស** ជាដើម សេចក្តីថា ផលដ៏ប្រសើរនោះឯង ឈ្មោះថា រសនៃធម្មបីតិ ព្រោះកើតឡើងហើយក្នុងទីបំផុតនៃការស្ងប់កិលេស ឬព្រោះជាអារម្មណ៍នៃការស្ងប់ ពោល គឺព្រះនិព្វាន ព្រោះហេតុនោះ បុគ្គលផឹកហើយនូវផលដ៏ប្រសើរនោះឯង គឺនូវរសនៃវិវេកនោះ និងរសនៃសេចក្តីស្ងប់នោះ ព្រោះជារសនៃបីតិដែលកើតឡើងហើយអំពីអរិយធម៌ ឬកើតឡើងហើយក្នុងធម៌ ពោល គឺព្រះនិព្វាន ឈ្មោះថា ផឹកនូវរសនៃធម្មបីតិ ជាអ្នកមិនមានការក្រវល់ក្រវាយ មិនមានបាប ដែលផឹកហើយ ក៏អស់នូវការក្រវល់ក្រវាយ ព្រោះមិនមានការក្រវល់ក្រវាយនៃកិលេស សូម្បីផឹក ក៏ឈ្មោះថា មិនមានបាប ព្រោះខ្ជួនលះបាបបានហើយ ព្រោះហេតុនោះ ផលដ៏ប្រសើរ គឺរសនៃវិវេកនោះ ទើបប្រសើរជាងរសទាំងឡាយ ។

តែអាចារ្យពួកខ្លះប្រកបថា ធម៌ទាំងនេះ គឺធម៌ ៣ យ៉ាង មានរសនៃវិវេកជាដើមនោះឯង ដោយអំណាចនៃឈាន និព្វាន និងបច្ចវេក្ខណៈ និង

ដោយអំណាចនៃកាយវិវេក ចិត្តវិវេក និងឧបធិវិវេក ។ បទមុននោះឯងជាបទល្អ ។

ព្រះមានព្រះភាគ កាលទ្រង់វិសជ្ជនាបញ្ហាទី ៤ យ៉ាងនេះ ឈ្មោះថាញុំាងទេសនាឲ្យចប់ដោយកំពូល គឺអរហត្ត ។

ក្នុងទីបំផុតនៃទេសនា ព្រាហ្មណ៍បានបព្វជ្ជាក្នុងសម្នាក់របស់ព្រះមានព្រះភាគ អស់ថ្ងៃបន្តិចបន្តួចប៉ុណ្ណោះ ក៏បានជាព្រះអរហន្ត សម្រេចបដិសម្ភិទាដូច្នេះឯង ។៚

## អដ្ឋកថា ហិរិសូត្រទី ៣ ចប់

# សុត្តន្តបិដក

## មង្គលសូត្រ

[ ២៤ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។

គ្រានោះឯង ទេវតាអង្គ ១ កាលវេលារាត្រីបឋមយាម កន្លងទៅហើយ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនជុំវិញទាំងអស់ឲ្យភ្លឺស្វាង ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរនៅក្នុងទីសមគួរ ។ លុះទេវតានោះ ឈរក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគ ដោយគាថាដូច្នេះថា

[ ២៥ ] ទេវតា និងមនុស្សទាំងឡាយជាច្រើន ប្រាថ្នានូវសួស្តី បានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គ ទ្រង់សំដែងនូវមង្គលដ៏ឧត្តម ។

( ព្រះមានព្រះភាគទ្រង់សំដែងថា ) ការមិនសេពគប់បុគ្គលពាលទាំងឡាយ ១ ការសេពគប់បណ្ឌិតទាំងឡាយ ១ ការបូជា ដល់បុគ្គលដែលគួរបូជាទាំងឡាយ ១ ( ទាំង ៣ ) នេះ ជាមង្គលដ៏ឧត្តម ។

ការនៅក្នុងប្រទេសដ៏សមគួរ ១ ភាពនៃបុគ្គលបានធ្វើបុណ្យទុក

ក្នុងកាលមុន ១ ការតម្កល់ខ្លួនដោយប្រពៃ ១ ( ទាំង ៣ ) នេះ ជាមង្គលដ៏ឧត្តម ។

ពាហុសច្ចៈ ១ សិល្បសាស្ត្រ ១ វិន័យដែលសិក្សាដោយប្រពៃ ១ វាចាដែលពោលត្រឹមត្រូវ ១ ( ទាំង ៤ ) នេះ ជាមង្គលដ៏ឧត្តម ។

ការបម្រើមាតាបិតា ១ សេចក្តីសង្គ្រោះបុត្ត និងភរិយា ១ ការងារទាំងឡាយមិនច្របូកច្របល់ ១ ( ទាំង ៣ ) នេះ ជាមង្គលដ៏ឧត្តម ។

ទាន ១ ការប្រព្រឹត្តិធម៌ ១ ការសង្គ្រោះពួកញាតិ ១ ការងារមិនមានទោស ១ ( ទាំង ៤ ) នេះ ជាមង្គលដ៏ឧត្តម ។

ការមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប ១ សេចក្តីសង្រួមចាកកិរិយាផឹកទឹកស្រវឹង ១ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ ១ ( ទាំង ៣ ) នេះ ជាមង្គលដ៏ឧត្តម ។

សេចក្តីគោរព ចំពោះបុគ្គលដែលគួរគោរព ១ ការប្រព្រឹត្តិបន្ទាបខ្លួន ១ សេចក្តីត្រេកអរចំពោះរបស់ដែលមាន ១ ភាពនៃបុគ្គលអ្នកដឹងឧបការគុណ ដែលអ្នកដទៃធ្វើដល់ខ្លួន ១ ការស្តាប់ធម៌តាមកាល ១ ( ទាំង ៥ ) នេះ ជាមង្គលដ៏ឧត្តម ។

សេចក្តីអត់ធន់ ១ ភាពនៃបុគ្គលដែលប្រដៅងាយ ១ ការបាន

ឃើញបានជួបសមណៈទាំងឡាយ ១ ធម្មសាកច្ឆាតាមកាល ១ ( ទាំង ៤ ) នេះ ជាមង្គលដ៏ឧត្តម ។

សេចក្តីព្យាយាមដុតបាបធម៌ ១ ការប្រព្រឹត្តិនូវធម៌ដ៏ប្រសើរ ១ ការឃើញនូវអរិយសច្ចទាំងឡាយ ១ ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ១ ( ទាំង ៤ ) នេះ ជាមង្គលដ៏ឧត្តម ។

ចិត្តនៃបុគ្គលណា ដែលលោកធម៌ពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ ១ មិនមានសេចក្តីសោក ១ មានធូលី គឺរាគៈទៅប្រាសហើយ ១ ចិត្តក្សេមក្សាន្ត ១ ( ទាំង ៤ ) នេះ ជាមង្គលដ៏ឧត្តម ។

ទេវតា និងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយ ប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសួស្តីក្នុងទីទាំងពួង ( ម្នាលទេវតា អ្នកចូរប្រកាន់ជឿថា ) មង្គលទាំង ៣៨ ប្រការ មានការមិនសេពគប់នូវបុគ្គលពាលជាដើមនោះ របស់ទេវតា និងមនុស្សទាំងអម្បាលណោះ ជាមង្គលដ៏ឧត្តម ។

## មង្គលសូត្រទី ៤ ចប់

# អដ្ឋកថា

## មង្គលសូត្រ

[ ២៤ ] ក្នុងមង្គលសូត្រទី ៤ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ ។

សួរថា សូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា សូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះ

បានឮថា ក្នុងជម្ពូទ្វីប មហាជនប្រជុំគ្នាក្នុងទីទាំងឡាយ មានទ្វារនគរ សណ្ឋាគារ និងទីប្រជុំជាដើមក្នុងទីនោះៗ សូម្បីឲ្យប្រាក់ និងមាសហើយ ក៏បបួលគ្នានិងគ្នា ពោលពាហិរកថា មានរឿងលួចនាងសិតាជាដើម មានប្រការផ្សេងៗ រឿងនីមួយៗ ទម្រាំចប់ ក៏ត្រូវប្រើពេលអស់ ៤ ខែ ក្នុងទីប្រជុំនោះ មង្គលកថាក៏តាំងឡើងថា អ្វីហ្ន៎ ឈ្មោះថា មង្គល វត្ថុដែលឃើញហើយឬឈ្មោះថា មង្គល វត្ថុដែលស្ដាប់ហើយឬ ដែលឈ្មោះថា មង្គល វត្ថុដែលជ្រាបហើយឬ ឈ្មោះថា មង្គល តើអ្នកណាហ្ន៎ ស្គាល់នូវមង្គល ។

គ្រានោះ បុរសម្នាក់ឈ្មោះទិដ្ឋមង្គលិកពោលឡើងថា ខ្ញុំស្គាល់មង្គល របស់ដែលឃើញ ឈ្មោះថា ជាមង្គលក្នុងលោក រូបដែលសន្មតថាជាមង្គលក្រៃលែង ឈ្មោះថា វត្ថុដែលឃើញហើយ គឺបុគ្គលខ្លះក្នុងលោកនេះ ភ្ញាក់អំពីព្រលឹម ឃើញសត្វត្រចៀកកាំខ្លះ ឃើញដើមល្ពៅជំទង់ខ្លះ ស្រីមានទម្ងន់ខ្លះ កុមារទាំងឡាយដែលប្រដាប់តាក់តែងហើយខ្លះ ក្អមទឹកដែលពេញខ្លះ ត្រីឆ្អិនស្រស់ខ្លះ សេះអាជានេយ្យខ្លះ គោឧសភខ្លះ មេគោខ្លះ គោពណ៌ក្រហមខ្លះ ឬឃើញរូបដទៃណា ដែលគេសន្មតថា ជាមង្គលក្រៃលែងបែបនេះ នេះ

គេហៅថា ទិដ្ឋិមង្គល ។

ពាក្យរបស់បុរសនោះ មនុស្សពួកខ្លះក៏ទទួល មនុស្សពួកខ្លះក៏មិនទទួល ជនពួកណាមិនទទួល ជនទាំងនោះ ក៏ប្រកែកជាមួយនាយទិដ្ឋមង្គលិកនោះ ។

គ្រានោះ បុរសម្នាក់ឈ្មោះសុតមង្គលិក ពោលថា នែអ្នកដ៏ចម្រើន ឈ្មោះថា ចក្ខុនេះ ឃើញរូបដែលស្អាតខ្លះ មិនស្អាតខ្លះ ឃើញរូបដែលល្អខ្លះ មិនល្អខ្លះ ដែលគាប់ចិត្តខ្លះ ដែលមិនគាប់ចិត្តខ្លះ បើរូបដែលភ្នែកនោះឃើញហើយ គប្បីជាមង្គលសោត សូម្បីរូបគ្រប់ប្រភេទ ក៏គប្បីជាមង្គល ដូច្នោះ រូបដែលឃើញហើយ ទើបមិនមែនជាមង្គល តែសំឡេងដែលស្តាប់ហើយឯណោះទេតើ ទើបជាមង្គល ព្រោះថា សំឡេង គេសន្មតថា ជាមង្គលក្រៃលែង ឈ្មោះថា វត្ថុដែលស្តាប់ហើយ គឺបុគ្គលខ្លះ ក្នុងលោកនេះ ក្រោកអំពីព្រលឹមហើយ រមែងស្តាប់នូវសំឡេងថា **វឌ្ឍ** គឺចម្រើនខ្លះ **វឌ្ឍមាន** កំពុងចម្រើនខ្លះ **បុណ្ណា** គឺពេញខ្លះ **បុស្ស** គឺសខ្លះ **សុមនា** គឺផ្កាម្លិះខ្លះ **សិរិ** គឺសិរីខ្លះ **សិរិវឌ្ឍន** គឺចម្រើនដោយសិរីខ្លះ ឬសំឡេងដែលសម្មតថាជាមង្គលដ៏ក្រៃលែងឯណានីមួយ បែបនេះថា ថ្ងៃនេះឫក្សល្អ យាមល្អ ថ្ងៃល្អ មង្គលល្អ ឬស្តាប់សំឡេងដែលគេសន្មតថា ជាមង្គលក្រៃលែងឯណានីមួយ បែបនេះ នេះគេហៅថា សុតមង្គល ។ ពាក្យរបស់សុតមង្គលិកនោះ មនុស្សពួកខ្លះក៏ព្រមទទួល ពួកខ្លះក៏មិនព្រមទទួល មនុស្សពួកណាមិនព្រមទទួល មនុស្សទាំងនោះ ក៏ប្រកែកជាមួយនាយសុតមង្គលិកនោះ ។

សម័យនោះ បុរសម្នាក់ឈ្មោះមុតមង្គលិក ពោលថា លោកដ៏ចម្រើន វត្ថុដែលបានស្តាប់នេះ បុគ្គលរមែងបានស្តាប់របស់ដែលល្អខ្លះ មិនល្អខ្លះ គាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះ បើរបស់ដែលបានស្តាប់នោះជាមង្គលសោត គ្រប់សំឡេង ដែលបានស្តាប់ទាំងអស់សុទ្ធតែជាមង្គល ព្រោះដូច្នោះ របស់ដែលបានឮ មិនមែនជាមង្គលឡើយ តែការដែលជ្រាប ឈ្មោះថា មង្គល ក្លិន រស ផោដ្ឋព្វៈ ដែលសន្មតថា ជាមង្គលក្រៃលែង ឈ្មោះថា វត្ថុដែលបានជ្រាប ជាមង្គល គឺបុគ្គលពួកខ្លះ ក្នុងលោកនេះ ភ្ញាក់អំពីព្រលឹម ហិតនូវក្លិនផ្កា មានក្លិនផ្កាឈូកខ្លះ ទំពាឈើស្ទន់ពណ៌សខ្លះ ស្ទាបផែនដីខ្លះ ស្ទាបស្រូវពណ៌ខៀវខ្លះ ស្ទាបលាមកគោស្រស់ខ្លះ ប៉ះពាល់អណ្តើកខ្លះ ប៉ះពាល់រទេះដែលផ្ទុកល្ងខ្លះ ផ្កាខ្លះ ផ្លែឈើខ្លះ ឬរមែងលាបរាងកាយដោយដីពណ៌សស្លៀកសំពត់សាជកពណ៌ស ជួតក្បាលពណ៌ស ឬហិតនូវក្លិន ភ្លក្សនូវរស ពាល់ត្រូវផោដ្ឋព្វៈដទៃណាមួយ ដែលគេសន្មតថា ជាមង្គលក្រៃលែងបែបនេះ នេះហៅថា មុតមង្គល ។ ពាក្យរបស់នាយមុតមង្គលិកនោះ ពួកខ្លះកាន់យក ពួកខ្លះ ក៏មិនកាន់យក ។

ក្នុងបណ្តាអ្នកទាំងនោះ នាយទិដ្ឋមង្គលិកមិនអាចឲ្យនាយសុតមង្គលិក និងនាយមុតមង្គលិកយល់ស្របបាន នាយសុតមង្គលិក ក៏មិនអាចឲ្យនាយទិដ្ឋមង្គលិក និងនាយមុតមង្គលិកយល់ស្របបាន នាយមុតមង្គលិក ក៏មិនអាចឲ្យនាយទិដ្ឋមង្គលិក និងនាយសុតមង្គលិកយល់ស្របបានដូចគ្នា ។ បណ្តា

មនុស្សទាំងនេះ មនុស្សពួកណាកាន់យកពាក្យរបស់នាយទិដ្ឋមង្គលិក មនុស្សទាំងនោះ ក៏នាំគ្នាសន្និដ្ឋានថា របស់ដែលឃើញហើយប៉ុណ្ណោះជាមង្គល ។ មនុស្សពួកណាជឿពាក្យរបស់នាយសុតមង្គលិក និងនាយមុតមង្គលិក មនុស្សទាំងនោះក៏សន្និដ្ឋានថា របស់ដែលស្តាប់ហើយប៉ុណ្ណោះ ជាមង្គល និងរបស់ដែលបានជ្រាបហើយប៉ុណ្ណោះ ជាមង្គល ពាក្យប្រារព្ធមង្គលនេះ ប្រាកដទូទៅក្នុងជម្ពូទ្វីបទាំងមូល ដោយប្រការដូច្នេះ ។

គ្រានោះ មនុស្សទាំងឡាយក្នុងជម្ពូទ្វីប ប្រមូលផ្តុំគ្នាជាពួកៗ គិតនូវមង្គលទាំងឡាយថា អ្វីហ្ន៎ ជាមង្គល សូម្បីអារក្ខទេវតាទាំងឡាយដែលថែរក្សាពួកមនុស្ស បានស្តាប់ពាក្យនោះហើយ ក៏គិតមង្គលដូចគ្នា ។ ភុម្មទេវតាដែលជាសម្លាញ់របស់ទេវតាទាំងនោះក៏មាន កាលភុម្មទេវតាស្តាប់ពាក្យរបស់អារក្ខទេវតាទាំងនោះហើយ ក៏គិតមង្គលទាំងឡាយដូចគ្នា អាកាសដ្ឋទេវតាដែលជាមិត្តរបស់ភុម្មទេវតាទាំងនោះក៏មាន ។ ទេវតាជាន់ចាតុម្មហារាជិកា ជាសម្លាញ់របស់អាកាសដ្ឋទេវតាក៏មាន ដោយឧបាយនេះឯង អកនិដ្ឋកទេវតាដែលជាសម្លាញ់របស់សុទស្សីទេវតាក៏មាន ។ កាលនោះ ទោះអកនិដ្ឋកទេវតាស្តាប់ពាក្យរបស់សុទស្សីទេវតានោះហើយ ក៏ផ្តុំគ្នាជាពួកៗ គិតនូវមង្គលទាំងឡាយ ការគិតនូវមង្គលកើតឡើងក្នុងទីគ្រប់កន្លែង រហូតដល់ ១ ម៉ឺនចក្រវាល ដោយប្រការដូច្នេះ ។ ការគិតរឿងមង្គលនោះ ដែលកើតឡើងហើយ សូម្បីអ្នកគិតទាំងឡាយ វិនិច្ឆ័យថា របស់នេះជាមង្គល របស់នេះជាមង្គល ក៏មិន

ចុះសម្រេចគ្នាបាន នាំគ្នាគិតរហូតអស់ ១២ ឆ្នាំ ពួកមនុស្ស និងពួកទេវតាមួយអន្លើដោយព្រហ្មទាំងពួង វៀរតែអរិយសាវកទាំងឡាយ បែកគ្នាជា ៣ ពួក គឺពួកទិដ្ឋមង្គលិក ១ ពួកសុតមង្គិក ១ ពួកមុតមង្គលិក ១ មិនមានអ្នកណាសូម្បីតែម្នាក់ ដែលឈ្មោះថា ដល់នូវការសម្រេចចិត្តបានតាមពិតថា ធម៌នេះប៉ុណ្ណោះ ជាមង្គល មង្គលកោលាហល កើតឡើងហើយក្នុងលោកដោយប្រការដូច្នេះ ។

ឈ្មោះថា កោលាហលមាន ៥ យ៉ាង គឺកប្បកោលាហល ១ ចក្កវត្តិ-កោលាហល ១ ពុទ្ធកោលាហល ១ មង្គលកោលាហល ១ មោនេយ្យ-កោលាហល ១ ។

ក្នុងបណ្តាកោលាហលទាំងនោះ ពួកទេវតាជាន់កាមាវចរមានរាងកាយទទឹក រំសាយសក់ មានទឹកភ្នែកជោកមុខ ស្លៀកសំពត់ពណ៌ក្រហម យកដៃជូតទឹកភ្នែក កាន់យកកេទប្លែកៗ ក្រៃលែង ដើរប្រាប់ក្នុងពួកមនុស្សថា ក្នុងកាលកន្លងទៅមួយសែនឆ្នាំ កប្បនឹងអស់ លោកធាតុនឹងវិនាស មហាសមុទ្រនឹងរីងស្ងួត មហាប្រឹថពី និងភ្នំសិនេរុរាជ ក៏នឹងវិនាស ការវិនាសនៃលោកនឹងមានដល់ព្រហ្មលោក នៃអ្នកនិទ្ទុក្ខទាំងឡាយ អ្នកទាំងឡាយ ចូរចម្រើនមេត្តា ករុណា មុទិតា និងឧបេក្ខាចុះ អ្នកទាំងឡាយ ចូរចិញ្ចឹមមាតាបិតាចុះ ចូរប្រព្រឹត្តកោតក្រែងក្នុងត្រកូលរៀមច្បង ចូរភ្ញាក់រឭក កុំប្រមាទ នេះហៅថា **កប្បកោលាហល** ។

ទេវតាជាន់កាមាវចរនោះឯង ត្រាច់ប្រាប់ក្នុងដែនដីមនុស្សថា ដោយកាលកន្លងទៅ ១០០ ឆ្នាំ ស្តេចចក្រពត្តិនឹងកើតឡើងក្នុងលោក នេះឈ្មោះថា **ចក្កវត្តិកោលាហល។**

ឯទេវតាជាន់សុទ្ធាវាស ប្រដាប់ដោយអាករណៈ ធ្វើសំពត់ជូតក្បាលសម្រាប់ព្រហ្ម ដាក់លើក្បាល កើតបីតិ និងសោមនស្សរឭកដល់ពុទ្ធគុណ ត្រាច់ប្រាប់ក្នុងដែនដីមនុស្សថា ក្នុងកាលកន្លងទៅ ១០០០ ឆ្នាំ ព្រះពុទ្ធនឹងកើតឡើងក្នុងលោក នេះឈ្មោះថា **ពុទ្ធកោលាហល។**

ពួកទេវតាជាន់សុទ្ធាវាសនោះឯងដឹងវារៈចិត្តរបស់មនុស្សហើយ ក៏ទៅក្នុងដែនដីមនុស្សថា ដោយកាលកន្លងទៅ ១២ ឆ្នាំ ព្រះសម្មាសម្ពុទ្ធនឹងត្រាស់មង្គល នេះឈ្មោះថា **មង្គលកោលាហល។**

ទេវតាជាន់សុទ្ធាវាសនោះឯង ត្រាច់ប្រាប់ក្នុងដែនដីមនុស្សថា ដោយកាលកន្លងទៅ ៧ ឆ្នាំ ភិក្ខុមួយរូបនឹងជួបជាមួយព្រះមានព្រះភាគ ហើយទូលសួរមោនេយ្យប្បដិបទា នេះឈ្មោះថា **មោនេយ្យកោលាហល។**

ក្នុងបណ្តាកោលាហលទាំង ៥ ប្រការនេះ មង្គលកោលាហលនេះ កើតឡើងហើយក្នុងលោក កាលពួកទេវតា និងមនុស្សទាំងឡាយ បែកគ្នាជា ៣ ពួក ដោយអំណាចនៃទិដ្ឋមង្គលជាដើម កាលនោះ កាលទេវតាទាំងឡាយ និងមនុស្សទាំងឡាយពិចារណាហើយ មិនឃើញនូវមង្គលទាំងឡាយ អស់កាល ១២ ឆ្នាំ ទេវតាទាំងឡាយជាន់តាវត្តិង្ស ក៏មកប្រជុំព្រមគ្នាហើយ គិត

គ្នាយ៉ាងនេះថា នែអ្នកនិទ្ទិក្ខទាំងឡាយ ម្ចាស់ផ្ទះប្រសើរជាងពួកជនក្នុងផ្ទះ មេស្រុក រមែងប្រសើរជាងជនទាំងឡាយក្នុងស្រុក ព្រះរាជា រមែងប្រសើរជាងពួកមនុស្សទាំងឡាយ យ៉ាងណា សូមបីសក្កទេវរាជក៏យ៉ាងនោះដូចគ្នា រមែងជាបុគ្គលប្រសើរ គឺជាអធិបតីនៃទេវលោកទាំង ២ ដោយបុណ្យ និងតេជះ ដោយភាពជាធំ និងដោយបញ្ញា បើដូច្នោះ ពួកយើងគប្បីប្រាប់សេចក្តីនេះ ដល់សក្កៈទេវរាជដូច្នោះដូចគ្នា ។ ទេវតាទាំងនោះ នាំគ្នាទៅកាន់សម្នាក់របស់សក្កទេវរាជ ថ្វាយបង្គំសក្កទេវរាជ ដែលមានព្រះវរកាយប្រកបដោយសិរី ប្រដាប់ដោយគ្រឿងអាភរណៈ ចោមរោមដោយពួកទេពអប្សរ ២ កោដិកន្លះ ប្រថាប់គង់ហើយ លើទែនបណ្ឌុកម្ពលសិលាអាសនៈ ត្រង់គល់បារិច្ឆត្តក ឈរក្នុងទីសមគួរ នាចំណែកម្ខាង ហើយបានក្រាបទូលសេចក្តីនេះថា បពិត្រព្រះអង្គនិទ្ទិក្ខ សូមទ្រង់ជ្រាបចុះថា ឥឡូវនេះ មង្គលប្បញ្ហាបានកើតឡើងហើយ ទេវតា និងមនុស្សមួយពួកពោលថា វត្ថុដែលឃើញហើយ ជាមង្គល មួយពួកពោលថា វត្ថុដែលឮហើយ ជាមង្គល មួយពួកទៀតពោលថា វត្ថុដែលបានជ្រាបហើយ ជាមង្គល ក្នុងបណ្តាជនទាំង ៣ ពួកនោះ ពួកខ្ញុំ និងពួកដទៃ ក៏ចូលគ្នាមិនបាន ខ្ញុំសូមឱកាសសូមទ្រង់ព្យាករមង្គលប្បញ្ហា ដល់ពួកខ្ញុំតាមសេចក្តីពិតចុះ ។

ទេវរាជសូម្បីដោយប្រក្រតី ទ្រង់មានបញ្ញាត្រាស់សួរថា មង្គលកថានេះ កើតឡើងក្នុងទីណា ទេវតាទាំងឡាយក៏ទូលថា បពិត្រព្រះអង្គ ពួកខ្ញុំឮ

មង្គលបញ្ហានេះរបស់ទេវតាជាន់ចាតុម្មហារាជ បន្ទាប់អំពីនោះ ទេវតាទាំង-ឡាយក៏ទូលថា ពួកទេវតាជាន់ចាតុម្មហារាជិកាទាំងឡាយ បានស្តាប់បញ្ហានៃពួកអាកាសដ្ឋទេវតាៗ ក៏បានស្តាប់បញ្ហារបស់ពួកកុម្មទេវតាៗ ក៏បានស្តាប់បញ្ហារបស់ពួកអារក្ខទេវតាៗ ក៏ពោលថា បញ្ហាតាំងឡើងក្នុងមនុស្សលោកដូច្នេះ ។

គ្រានោះ សក្កទេវរាជក៏ត្រាស់សួរថា ព្រះសម្មាសម្ពុទ្ធ ខណៈនេះ គង់នៅឯណា ។ ពួកទេវតាទាំងឡាយក្រាបទូលថា បពិត្រទេវៈ ព្រះមានព្រះភាគគង់នៅក្នុងមនុស្សលោក ។ សក្កទេវរាជសួរថា មានអ្នកណាបានទូលសួរបញ្ហានេះជាមួយព្រះមានព្រះភាគហើយឬ ពួកទេវតាទាំងឡាយក្រាបទូលថា បពិត្រទេវៈ មិនទាន់មានអ្នកណាទូលសួរឡើយ សក្កទេវរាជត្រាស់ថា អ្នកនិទ្ទុក្ខទាំងឡាយ ហេតុអ្វី ក៏ពួកអ្នករំលងព្រះមានព្រះភាគអង្គនោះ ដែលសម្តែងមង្គលមិនមានសេសសល់ មកសម្គាល់យើងថា ជាបុគ្គលគួរសួរ ឈ្មោះថា បោះបង់ភ្លើង ហើយមកផ្លុំអំពិលអំពែកឲ្យឆេះ នៃអ្នកនិទ្ទុក្ខទាំងឡាយ ចូរពួកអ្នកទៅសួរព្រះមានព្រះភាគអង្គនោះ ពួកអ្នកនឹងបាននូវការឆ្លើយបញ្ហាដ៏មានសិរីយ៉ាងពិតប្រាកដ ។

សក្កទេវរាជ ក៏បានប្រាប់ទេវបុត្តមួយអង្គថា ចូរអ្នកសាកសួរព្រះមានព្រះភាគ ទេវបុត្តអង្គនោះ ប្រដាប់ដោយគ្រឿងអលង្ការតាមសមគួរ ខណៈនោះ រុងរឿងដូចផ្លេកបន្ទោរ មានពួកទេវតាចោមរោម មកកាន់ជេតពនមហា-

វិហារ ថ្វាយបង្គំព្រះមានព្រះភាគ ឈរក្នុងចំណែកម្ខាង កាលនឹងទូលសួរមង្គលបញ្ហា ទើបពោលដោយគាថា ។ ព្រះមានព្រះភាគ កាលទ្រង់ស្រាយប្រស្នារបស់ទេវបុត្តនោះ ទើបបានត្រាស់ព្រះសូត្រនេះ ។

អត្ថនៃពាក្យទាំងឡាយ មានពាក្យថា **ឯវម្មេ សុតំ** ជាដើម ក្នុងព្រះសូត្រនោះ ដោយសង្ខេប ខ្ញុំបានពោលហើយក្នុងអដ្ឋកថានៃកសិភារទ្វាជសូត្រ ឯជនទាំងឡាយប្រាថ្នាសេចក្តីពិស្តារ គប្បីកាន់យកអត្ថដោយន័យដែលខ្ញុំពោលហើយ ក្នុងអដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនី ។

ក្នុងកសិភារទ្វាជសូត្រ លោកពោលថា ព្រះមានព្រះភាគ គង់នៅក្នុងស្រុកព្រាហ្មណ៍ ឈ្មោះឯកនាឡា ក្នុងទក្ខិណាគិរីជនបទ ក្នុងដែនមគធៈ តែក្នុងមង្គលសូត្រនេះ លោកពោលថា ព្រះមានព្រះភាគគង់នៅក្នុងវត្តជេតពនអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ក្នុងនគរសាវត្ថី ខ្ញុំនឹងពណ៌នាបទដែលមិនធ្លាប់ពណ៌នាក្នុងមង្គលសូត្រនេះ ផ្តើមអំពីបទថា **សាវត្ថិយំ** ជាដើមតទៅ ។

បទថា **សាវត្ថិយំ** បានដល់ ក្នុងនគរមានឈ្មោះយ៉ាងនោះ ។

បានឮមកថា នគរនោះ បានជាលំនៅរបស់ឥសីឈ្មោះសាវត្ថៈ នគរនោះ អ្នកស្រុកហៅថា **សាវត្ថី** ដោយអំណាចជាឥត្ថីលិង្គ ដូចលំនៅរបស់ឥសី ឈ្មោះថា **កុសុម្ព** អ្នកស្រុកហៅថា **កោសម្ពី** លំនៅឥសី ឈ្មោះ **កាកណ្ឌ** អ្នកស្រុកហៅថា **កាកណ្ឌី** ដូច្នោះ ។ តែបុរាណាចារ្យទាំងឡាយពណ៌នាថា ព្រោះហេតុដែលជនទាំងឡាយ សួរដល់ក្រុមរទេះ ដែលមករួមគ្នា

ក្នុងទីនោះថា **កឹ ភណ្ឌមត្ថិ** មានទំនិញអ្វីខ្លះ ទើបជនទាំងឡាយឆ្លើយថា **សព្វមត្ថិ** មានទំនិញសព្វយ៉ាង ព្រោះហេតុនោះ ទើបទីនោះ ហៅថា **សាវត្ថី** សំដៅយកពាក្យនោះ ។ ក្នុងនគរសាវត្ថីនោះ ។ ដោយពាក្យថា **សាវត្ថិយំ** នេះ ព្រះអានន្ទត្ថេរសម្ដែងដល់គោចរគ្រាមនៃនគរនោះ ។

ព្រះរាជកុមារព្រះនាមជេត មាននៅក្នុងទីនោះ ទើបទីនោះ ឈ្មោះថា **ជេតវន** ព្រោះជាព្រៃរបស់ព្រះរាជកុមារជេតនោះ ទាក់ទងនឹងកុមារជេតនោះ ដាំឈើទាំងនោះ ឲ្យធំចម្រើន ។ ក្នុងជេតពននោះ ។ គហបតីឈ្មោះអនាថ-បិណ្ឌិក ព្រោះអត្ថថា ជាអ្នកមានដុំបាយសម្រាប់មនុស្សអនាថាទាំងឡាយ ។ នៃអនាថបិណ្ឌិកសេដ្ឋីនោះ ។ អធិប្បាយថា ក្នុងអារាមដែលគហបតីឈ្មោះ អនាថបិណ្ឌិកសាងសម្រេចដោយបរិច្ចាគទ្រព្យ ៥៤ កោដិ ។ ដោយពាក្យថា **អនាថបិណ្ឌិកស្ស អារាមេ** នេះ ព្រះអានន្ទសម្ដែងដល់ទីលំនៅដែលសមគួរដល់បព្វជិតនៃអារាមនោះ ។

សព្ទថា **អថ** ប្រើក្នុងអត្ថថា មិនកំណត់កាល ។

សព្ទថា **ខោ** ជានិបាត ចុះក្នុងអត្ថថា សម្ដែងដល់រវាងនៃអធិការ ។ ដោយពាក្យថា **អថ ខោ** នោះ ព្រះអានន្ទសម្ដែងដល់ពេលដែលមិនកំណត់នោះឯងថា ក្នុងរវាងអធិការនេះ រឿងនេះកើតឡើងហើយដល់ព្រះមានព្រះភាគក្នុងវិហារនោះ ។ សួរថា រឿងនោះ គឺអ្វី ឆ្លើយថា រឿងនោះ គឺទេវតាមួយអង្គជាដើម កើតឡើងហើយ ក្នុងរវាងនៃអធិការ ។

ក្នុងបណ្ដាពាក្យទាំង ២ នោះ ពាក្យថា **អញ្ញតរា** ជាការសម្ដែងដល់វត្ថុដែលមិនបានកំណត់ពិតប្រាកដ ពិតហើយ ទេវតាអង្គនោះ មិនប្រាកដឈ្មោះ និងគោត្ត ព្រោះដូច្នោះ ទើបព្រះអានន្ទពោលថា **អញ្ញតរា** ប្រែថា ទេវតាមួយអង្គ ។ ទេវតា គឺទេវៈនោះឯង ។ ពាក្យថា **ទេវតា** នេះ ជាសាធារណៈ គឺទាំងទេវតាស្រី និងទេវតាប្រុស តែក្នុងព្រះសូត្រនេះ ជាទេវតាប្រុសប៉ុណ្ណោះ ។ ទេវបុត្តអង្គនោះ ។ តែលោកពោលថា **ទេវតា** ដូច្នេះ ព្រោះហេតុអ្វី ឆ្លើយថា ទេវបុត្ត លោកហៅថា **ទេវតា** ក៏ដោយអំណាចនៃសាធារណនាម ។

**អភិក្កន្ត** សព្ទ ក្នុងពាក្យនេះថា **អភិក្កន្តាយ រត្តិយា** ប្រាកដក្នុងអត្ថថា ១យ គឺអស់ទៅ **សុន្ទរ** គឺល្អ **អភិរូប** គឺស្អាត **អព្ភានុមោទនា** គឺគួរសរសើរជាដើម ។

បណ្ដាពាក្យទាំងនោះ **អភិក្កន្ត** សព្ទនេះ ប្រាកដក្នុងអត្ថថា អស់ទៅ ដូចក្នុងប្រយោគជាដើមថា **អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បឋមោ យាមោ ចិរនិសិន្នោ ភិក្ខុសង្ឃោ ឧទ្ទិសតុ ភន្តេ ភគវា ភិក្ខូនំ ចាតិមោក្ខន្តិ** បពិត្រព្រះអង្គដ៏ចម្រើន វេលារាត្រីអស់ហើយ បឋមយាមកន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់សម្ដែងបាតិមោក្ខ ដល់ភិក្ខុទាំងឡាយ ។

**អភិក្កន្ត** សព្ទ ប្រាកដក្នុងអត្ថថា ល្អ ដូចក្នុងប្រយោគជាដើមថា **អយំ**

**ឥមេសំ ចតុន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច** បណ្តាបុគ្គលទាំង ៤ ពួកនេះ បុគ្គលនេះ ចាត់ថា ល្អជាងផង ប្រសើរជាងផង ។

**អភិក្កន្ត** សព្ទ ប្រាកដក□ងអត□ថា សា□ត ដូចក្នុងប្រយោគជាដើមថា **កោ មេ វន្ទតិ បាទានិ ឥទ្ធិយា យសសា ជលំ អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា** អ្នកណាហ្ន៎ រុងរឿងដោយឫទ្ធិ និងយស មានសម្បុរស្អាត ញុំាងទិសទាំងពួងឲ្យភ្លឺ មកថ្វាយបង្គំបាទានៃតថាគត ។

**អភិក្កន្ត** សព្ទ ប្រាកដក្នុងអត្ថថា គួរសរសើរ ដូចក្នុងប្រយោគទាំង-ឡាយយ៉ាងនេះថា **អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម** បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ ។

តែក្នុងមង្គលសូត្រនេះ **អភិក្កន្ត** សព្ទ ប្រើក្នុងអត្ថថា **ខយ** ព្រោះហេតុនោះ កាលរាត្រីកន្លងហើយ អធិប្បាយថា កាលរាត្រីអស់ហើយ ។

**អភិក្កន្ត** សព្ទ ក្នុងពាក្យថា **អភិក្កន្តវណ្ណា** នេះ ប្រើក្នុងអត្ថថា ស្អាត ។

ឯ **វណ្ណ** សព្ទ ប្រាកដក្នុងអត្ថថា **ឆវិ** គឺពណ៌សម្បុរ **ថុតិ** គឺការសរសើរ **កុលវគ្គ** គឺវង្សត្រកូល **ការណ** គឺហេតុ **សណ្ឋាន** គឺទ្រង់ទ្រាយ **បមាណ** គឺប្រមាណ **រូបាយតន** គឺវណ្ណរូបជាដើម ។

ក្នុងបណ្តាអត្ថទាំងនោះ **វណ្ណ** សព្ទ ប្រាកដក្នុងអត្ថថា ពណ៌សម្បុរ ដូចក្នុងប្រយោគជាដើមថា **សុវណ្ណវណ្ណោសិ ភគវា** ព្រះមានព្រះភាគ មានសម្បុរដូចជាមាស ។

វណ្ណ សព្ទ ប្រាកដក្នុងអត្ថថា ការសរសើរ ដូចក្នុងប្រយោគជាដើមថា **កទា សញ្ញូឡ្ហា បនតេ គហបតិ ឥមេ សមណស្ស គោតមស្ស វណ្ណា** ម្នាលគហបតី ចុះគុណរបស់ព្រះសមណគោតមទាំងអម្បាលនេះ អ្នកប្រមូលមកអំពីកាលណា ។

វណ្ណ សព្ទ ប្រាកដក្នុងអត្ថថា វង្សត្រកូល ដូចក្នុងប្រយោគជាដើមថា **ចត្តារោ មេ ភោ គោតម វណ្ណា** ព្រះគោតមដ៏ចម្រើន វណ្ណៈ ( ត្រកូល ) ទាំងឡាយ ៤ នេះ ។

វណ្ណ សព្ទ ប្រាកដក្នុងអត្ថថា ហេតុដូចក្នុងប្រយោគជាដើមថា

**អថ កេន នុ វណ្ណេន គន្ធត្ថេនោតិ វុច្ចតិ** ចុះហេតុដូចម្តេច បាន ជាអ្នកនិយាយថា អាត្មាលួចក្លិន ។

វណ្ណ សព្ទ ប្រាកដក្នុងអត្ថថា សណ្ឋាន ដូចក្នុងប្រយោគជាដើមថា **មហន្តំ ហត្ថិរាជវណ្ណំ អភិនិម្មិនិត្វា** ទើបនិម្មិតសណ្ឋានជាស្តេចដំរីមួយធំ ។

វណ្ណ សព្ទ ប្រាកដក្នុងអត្ថថា ប្រមាណ ដូចក្នុងប្រយោគជាដើមថា **តយោ បត្តស្ស វណ្ណា** ប្រមាណនៃបាត្រ មាន ៣ យ៉ាង ។

វណ្ណ សព្ទ ប្រាកដក្នុងអត្ថថា អាយតនៈ គឺពណ៌ ដូចក្នុងប្រយោគ ជាដើមថា **វណ្ណោ គន្ធោ រសោ ឱជា** រូប ក្លិន រស ឱជា ។

តែក្នុងមង្គលសូត្រនេះ **វណ្ណ** សព្ទនោះ គប្បីឃើញថា ប្រាកដក្នុងអត្ថថា ពណ៌សម្បុរ ព្រោះហេតុនោះ អធិប្បាយថា ទេវបុត្តនោះ ជាអ្នកមាន

*ពណ៌សម្បុរល្អក្រៃលែង មានពណ៌សម្បុរស្អាត ។*

**កេវល** *សព្ទ ក្នុងពាក្យថា* **កេវលកប្បំ** *នេះ មានអត្ថជាអនេក គឺ មានអត្ថថា* **អនវសេស** *គឺមិនមានចំណែកសេសសល់* **យេភុយ្យ** *គឺដោយច្រើន* **អព្យាមិស្ស** *គឺមិនលាយឡំ* **អនតិរេក** *គឺមិនច្រើន* **ទឡ្ហត្ថ** *គឺមាំទាំ* **វិសំយោគ** *គឺបែកចាកគ្នាជាដើម ។*

*ពិតហើយ* **កេវល** *សព្ទនោះ មានអត្ថថា មិនមានចំណែកសល់ ដូចក្នុងប្រយោគជាដើមថា* **កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ** *ទ្រង់ប្រកាសព្រហ្មចរិយៈ ដ៏ពេញបរិបូណ៌បរិសុទ្ធទាំងអស់ ។*

**កេវល** *សព្ទនោះ មានអត្ថថា ប្រព្រឹត្តទៅដោយច្រើន ដូចក្នុងប្រយោគជាដើមថា* **កេវលកប្បា ច អង្គមគធា បហូតំ ខាទនីយំ ភោជនីយំ អាទាយ អភិក្កមិតុកាមា ហោន្តិ** *ព្រោះថា ជនអ្នកនៅក្នុងដែនអង្គៈ និងមគធៈទាំងអស់នោះ ប្រាថ្នានឹងនាំយកខាទនីយភោជនីយាហារ មានប្រមាណច្រើន ចូលមកបូជា ។*

**កេវល** *សព្ទ មានអត្ថថា មិនលាយឡំ ដូចក្នុងប្រយោគជាដើមថា* **កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ** *សេចក្តីកើតឡើងនៃកងទុក្ខសុទ្ធៗ ទាំងអស់នេះ រមែងមានយ៉ាងនេះឯង ។*

**កេវល** *សព្ទ មានអត្ថថា មិនមែនច្រើន ដូចក្នុងប្រយោគជាដើមថា* **កេវលំ សទ្ធាមត្តកំ នូន អយមាយស្មា** *ព្រោះអាស្រ័យនូវគុណធម៌ ត្រឹម*

តែសទ្ទាម្ពាន់ដោយពិត ។

**កេវល** សព្ទ មកក្នុងអត្ថថា មាំទាំ ដូចក្នុងប្រយោគជាដើមថា **កេវលកប្បំ សង្ឃភេទាយ ឋិតោ** សទិសក្រាកិរិយារបស់មនុស្សដ៏មានអាយុ ឈ្មោះវាហិយៈ នៅតែទទូចដើម្បីបំបែកឃ្លាំងមុតមាំ ។

**កេវល** សព្ទ មកក្នុងអត្ថថា ការបែកគ្នា ដូចក្នុងប្រយោគជាដើមថា **កេវលី វុសិតវា ឧត្តមបុរិសោតិ វុច្ចតិ** មានភិក្ខុទាំងឡាយ ភិក្ខុនោះអង្គ ៥ ប្រកបដោយអង្គ ៥ ហៅថា ជាឧត្តមបុរស ។

តែក្នុងមង្គលសូត្រនេះ **កេវល** សព្ទ លោកបំណងយក **អនវសេស** គឺមិនមានចំណែកសេសសល់ ។

៦ **កប្ប** សព្ទនេះ មានអត្ថជាអនេក ដូចជា **អភិសទ្ទហាន** គឺការកាន់យក **វោហារ** គឺវោហារ **កាល** គឺកាល **បញ្ញត្តិ** គឺបញ្ញត្តិ **ឆេទន** គឺការកាត់ **វិកប្ប** គឺការកំណត់ **លេស** គឺលេស **សមន្តភាវ** គឺដោយជុំវិញជាដើម ។

ពិតហើយ **កប្ប** សព្ទ មានអត្ថថា ជឿកាន់យក ដូចក្នុងប្រយោគជាដើមថា **ឱកប្បនិយមេតំ ភោតោ គោតមស្ស យថា តំ អរហតោ សម្មាសម្ពុទ្ធស្ស** ពាក្យរបស់ព្រះគោតមដ៏ចម្រើន ដែលជាអរហន្តសម្មាសម្ពុទ្ធនេះ ជាពាក្យគួរជឿពិតហើយ ។

**កប្ប** សព្ទ មកក្នុងអត្ថថា វោហារ ដូចក្នុងប្រយោគជាដើមថា **អនុ-**

**ជានាមិ ភិក្ខវេ បញ្ចហិ សមណកប្បេហិ ផលំ បរិភុញ្ជិតុំ** *ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបរិភោគផ្លែឈើ ដោយសមណកប្ប ៥ យ៉ាង ។*

**កប្ប** *សព្ទ មកក្នុងអត្ថថា កាល ដូចក្នុងប្រយោគជាដើមថា* **យេន សុទំ និច្ចកប្បំ វិហរាមិ** *តថាគតនោះឯង តែងនៅអស់កាលជានិច្ច ។*

**កប្ប** *សព្ទ មកក្នុងអត្ថថា បញ្ញត្តិ ដូចក្នុងប្រយោគជាដើមថា* **ឥច្ចាយស្មា កប្បោ** *កប្បមាណពដ៏មានអាយុទូលសួរថា ។*

**កប្ប** *សព្ទ មកក្នុងអត្ថថា ការកាត់ ដូចក្នុងប្រយោគជាដើមថា* **អលង្កតោ មាល្យធរោ សុវត្ថោ សុកុណ្ឌលី កប្បិតកេសមស្សុ** *អង្គមាន ខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា ស្លៀកដណ្ដប់ល្អ មានប្រដាប់ត្រចៀកល្អ មានសក់និងពុកចង្កា កាត់ល្មមហើយ ។*

**កប្ប** *សព្ទ មកក្នុងអត្ថថា កំណត់ ដូចក្នុងប្រយោគជាដើមថា* **កប្បតិ ទ្វង្គុលកប្បោ** *កំណត់ដោយស្រមោលព្រះអាទិត្យជ្រេទៅ ប្រមាណពីរធ្នាប់អង្គុល ។*

**កប្ប** *សព្ទ មកក្នុងអត្ថថា លេស ដូចក្នុងប្រយោគជាដើមថា* **អត្ថិ កប្បោ និបជ្ជិតុំ** *បើដូច្នោះ អាត្មាអញដេកសិន ។*

**កប្ប** *សព្ទ មកក្នុងអត្ថថា ដោយជុំវិញ ដូចក្នុងប្រយោគជាដើមថា* **កេវលកប្បំ វេឡុវនំ ឱភាសេត្វា** *ញ៉ាំងវត្តវេឡុវ័នឲ្យភ្លឺស្វាងដោយជុំវិញ ។*

តែក្នុងមង្គលសូត្រនេះ **កប្ប** សព្ទ លោកបំណងយកសមន្តភាវៈ ។ ព្រោះហេតុនោះ ក្នុងពាក្យថា **កេវលកប្បំ ជេតវនំ** នេះ គប្បីឃើញអត្ថយ៉ាងនេះថា ញ៉ាំងវត្តជេតពនទាំងមូលឲ្យភ្លឺដោយជុំវិញ ។

បទថា **ឱភាសេត្វា** សេចក្ដីថា ផ្សាយទៅហើយ ដោយពន្លឺភ្លឺស្វាង អធិប្បាយថា ធ្វើហើយឲ្យភ្លឺដូចគ្នាតែមួយ គឺឲ្យរុងរឿងតែមួយ ដូចព្រះចន្ទ និងព្រះអាទិត្យ ដូច្នោះ ។

បទថា **យេន** ក្នុងបទថា **យេន ភគវា តេនុបសង្កមិ** ជាតតិយាវិភត្តិ ប្រើក្នុងអត្ថសត្តមីវិភត្តិ ។

បណ្ឌិតគប្បីឃើញអត្ថក្នុងពាក្យថា ព្រះដ៏មានព្រះភាគគង់នៅក្នុងទីណា ក៏ចូលទៅគាល់ហើយនូវព្រះមានព្រះភាគក្នុងទីនោះ ។ ម្យ៉ាងទៀត គប្បីឃើញអត្ថក្នុងពាក្យថា ទេវតា និងមនុស្សទាំងឡាយ គប្បីចូលគាល់ព្រះមានព្រះភាគ ដោយហេតុណា ទេវបុត្តក៏ចូលគាល់ដោយហេតុនោះ ដូច្នេះ ។

សួរថា ទេវតា និងមនុស្សទាំងឡាយ គប្បីចូលទៅគាល់ព្រះមានព្រះភាគ ដោយហេតុអ្វី ឆ្លើយថា ចូលទៅគាល់ហើយ មានពាក្យអធិប្បាយថា ចូលទៅរកដោយបំណងសម្រេចគុណវិសេស មានប្រការផ្សេងៗ ដូចឈើធំដែលចេញផ្លែជានិច្ច ដែលពួកបក្សីទាំងឡាយចូលទៅរក ដោយបំណងនឹងបរិភោគផ្លែដែលឆ្ងាញ់ ដូច្នោះ ។ បទថា **ឧបសង្កមិត្វា** ជាការសម្ដែងដល់ការអស់នៃការចូលទៅគាល់ ម្យ៉ាងទៀត ទេវតានោះទៅហើយយ៉ាងនេះ មាន

អធិប្បាយថា កាន់ទីជិតជាងនោះ គឺជិតព្រះមានព្រះភាគ ។

បទថា **ភគវន្តំ អភិវាទេត្វា** សេចក្តីថា ថ្វាយបង្គំ គឺនមស្ការព្រះមានព្រះភាគ ។

បទថា **ឯកមន្តំ** ជាពាក្យសម្តែងដល់នបុំសកលិង្គ មានអធិប្បាយថា ក្នុងឱកាសម្ខាង គឺក្នុងចំណែកម្ខាង ។ ម្យ៉ាងទៀត បទថា **ឯកមន្តំ** ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថនៃសត្តមីវិភត្តិ ។

បទថា **អដ្ឋាសិ** ជាការបដិសេធឥរិយាបថដទៃ មានការអង្គុយជាដើម អធិប្បាយថា សម្រេចការឈរ បានដល់ ជាអ្នកឈរហើយ ។

សួរថា ទេវតានោះឈរដូចម្តេច ទើបឈ្មោះថា ឈរក្នុងចំណែកម្ខាង ឆ្លើយថា ព្រោះឈរវៀរទោស ៨ យ៉ាង គឺមិនឈរខាងក្រោយ ១ មិនឈរទល់មុខ ១ មិនឈរជិតពេក ១ មិនឈរឆ្ងាយពេក ១ មិនឈរចំពោះមុខ ១ មិនឈរលើខ្យល់ ១ មិនឈរក្នុងទីទាប ១ មិនឈរខ្ពស់ជាង ១ ឈ្មោះថា ឈរក្នុងចំណែកម្ខាង ។

សួរថា ទេវបុត្តនេះឈរប៉ុណ្ណោះ មិនអង្គុយ ព្រោះហេតុអ្វី ឆ្លើយថា ព្រោះទេវតាទាំងឡាយបំណងនឹងត្រឡប់ អធិប្បាយថា ពិតហើយ ទេវតាទាំងឡាយ អាស្រ័យអំណាចប្រយោជន៍ណាមួយប៉ុណ្ណោះ ទើបមកកាន់មនុស្សលោក ដែលប្រៀបដូចបង្គន់ពេញដោយរបស់មិនស្អាត ដោយប្រក្រតីមនុស្សលោកជាវត្ថុបដិកូលដល់ទេវតាទាំងនោះ ព្រោះជាទីដែលមានក្លិនស្អុយ

ក្នុងចម្ងាយ ១០០ យោជន៍ ទើបពួកទេវតាមិនត្រេកអរក្នុងមនុស្សលោក ព្រោះហេតុនោះ ទេវតានោះនាំធុរៈដែលខ្លួនមកស្រេចហើយ ក៏មិនព្រមអង្គុយ ព្រោះត្រូវការត្រឡប់ ជនទាំងឡាយ រមែងអង្គុយដើម្បីបន្ទោបង់នូវការហត់នឿយនៃឥរិយាបថ ដែលកើតអំពីការធ្វើដំណើរជាដើមឯណា ការនឿយហត់នោះនៃទេវតាទាំងឡាយ រមែងមិនមាន ព្រោះហេតុនោះ ទើបទេវតាមិនព្រមអង្គុយ ។ ម្យ៉ាងទៀត មហាសាវកទាំងឡាយពួកណា ឈរចោមរោមព្រះមានព្រះភាគហើយ ទេវតាក៏រាប់អានមហាសាវកទាំងនោះ ទើបមិនអង្គុយ ។ ម្យ៉ាងទៀត ទេវតាមិនព្រមអង្គុយ ព្រោះគោរពក្នុងព្រះពុទ្ធ ដ្បិតថា ទេវតាទាំងឡាយ កាលអង្គុយ អាសនៈនឹងកើតឡើង ទេវតាមិនប្រាថ្នាអាសនៈនោះ ទើបមិនគិតដើម្បីអង្គុយ បានឈរក្នុងចំណែកម្ខាង ។

បទថា **ឯកមន្តំ ឋិតា ខោ សា ទេវតា** សេចក្តីថា ទេវតានោះឈរក្នុងចំណែកម្ខាងនោះឯង ដោយហេតុទាំងនេះយ៉ាងនេះ ។

បទថា **ភគវន្តំ គាថាយ អជ្ឈភាសិ** អធិប្បាយថា បានទូលហើយនឹងព្រះមានព្រះភាគ ដោយពាក្យដែលនិយមអក្ខរបទ គឺដោយគាថា ។

បណ្តាបទទាំងនោះ បទថា **ពហូ** ជាការសម្តែងការរាប់ដែលមិនពិតប្រាកដ មានពាក្យដែលលោកអធិប្បាយថា ដោយពាក្យថា **ពហូ** នោះ តែងមានច្រើនរយ ច្រើនពាន់ ច្រើនសែន ។

សត្វលោកដែលឈ្មោះថា **ទេវ** ព្រោះអត្ថថា រមែងលេង អធិប្បាយ

ថា ទេវតាទាំងឡាយ រមែងលេងដោយកាមគុណ ៥ ឬលេងដោយពន្លឺ និង សិរីរបស់ខ្លួនម្យ៉ាងទៀត ទេវតាមាន ៣ ពួក ដោយអំណាចសម្មតិទេព ឧបបត្តិទេព និងវិសុទ្ធិទេព សមដូចព្រះសង្គីតិកាចារ្យពោលថា ត្រង់ពាក្យថា ទេវតា បានដល់ ពួកទេព ៣ គឺសម្មតិទេព ១ ឧបបត្តិទេព ១ វិសុទ្ធិទេព ១ ។ ពួកព្រះរាជា ព្រះរាជកុមារ និងព្រះទេវី លោកហៅថា សម្មតិទេព ។ ពួកទេពស្ថិតនៅក្នុងចាតុម្មហារាជិកា ។បេ។ និងពួកទេពជាពួកនៃព្រហ្ម ជាពួកទេពដែលស្ថិតនៅខាងលើពួកទេពទាំងនុ៎ះ លោកហៅថា ឧបបត្តិទេព ។ ពួកព្រះអរហន្តខីណាស្រព លោកហៅថា វិសុទ្ធិទេព[១] ។

ក្នុងបណ្តាទេវៈ ៣ ពួកនោះ ឧបបត្តិទេព លោកបំណងយកក្នុងសូត្រនេះ ។

សត្វលោក ដែលឈ្មោះថា **មនុស្ស** ព្រោះជាផៅពង្សនៃព្រះបាទមនូ ពួកបុរាណាចារ្យទាំងឡាយពោលថា ដែលឈ្មោះថា **មនុស្ស** ព្រោះជាអ្នកមានចិត្តខ្ពស់ ។

មនុស្សមាន ៤ ពួក គឺ មនុស្សអ្នកជម្ពូទ្វីប ១ អ្នកអមរគោយានទ្វីប ១ អ្នកឧត្តរកុរុទ្វីប ១ អ្នកបុព្វវិទេហទ្វីប ១ មនុស្សអ្នកជម្ពូទ្វីប បំណងយកក្នុងសូត្រនេះ ។

សត្វទាំងឡាយ រមែងដល់នូវសេចក្តីចម្រើនដោយហេតុទាំងនេះ ហេតុ

---

១- សេចក្តីពិស្តារ មានក្នុងបិ. ៦៧ ទំ. ១៨២ ។

នោះ ទើបហេតុទាំងនេះ ឈ្មោះថា **មង្គល** អធិប្បាយថា រមែងដល់នូវការសម្រេច គឺសេចក្ដីចម្រើន ។

ពាក្យថា **ចិន្តយុំ** បានដល់ គិតគ្នាហើយ ។ បទថា **អាកង្ខមានា** បានដល់ ប្រាថ្នា គឺត្រូវការ និងសង្ឃឹម ។ បទថា **សោត្ថានំ** បានដល់ សួស្ដី មានពាក្យដែលលោកពោលថា ការមាននៃធម៌ទាំងឡាយដ៏វិចិត្រ គឺ ល្អ ស្អាត ដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ និងសម្បរាយភពទាំងឡាយ ។

បទថា **ព្រូហិ** បានដល់ សូម សម្ដែង ប្រកាស ប្រាប់ បើក ផ្ទារ បែក ធ្វើឲ្យច្បាស់ ។ បទថា **មង្គលំ** បានដល់ ហេតុនៃសេចក្ដីសម្រេច គឺ ហេតុនៃសេចក្ដីចម្រើន បានដល់ ហេតុនៃ សម្បត្តិទាំងពួង ។ បទថា **ឧត្តមំ** បានដល់ ប្រសើរ គឺលើសលន់ បានដល់ នាំមកនូវប្រយោជន៍ដល់លោកទាំងពួង នេះ គឺអធិប្បាយតាមលំដាប់បទនៃគាថា ឯការសរុបអត្ថ មានដូចតទៅនេះ

ទេវបុត្រនោះ ឃើញទេវតាទាំងឡាយ ក្នុងម៉ឺនចក្រវាលប្រជុំគ្នា ក្នុងចក្រវាលយើងនេះ ដើម្បីស្ដាប់មង្គលបញ្ហា ដែលនិម្មិតអត្តភាពតូចៗ ប្រមាណប៉ុនចុងរោមទ្រាយ ជា ១០ អង្គខ្លះ ២០ អង្គខ្លះ ៣០ អង្គខ្លះ ៤០ អង្គខ្លះ ៥០ អង្គខ្លះ ៦០ អង្គខ្លះ ៧០ អង្គខ្លះ ៨០ អង្គខ្លះ ឈរចោមរោមព្រះមានព្រះភាគ ដែលគង់លើបវរពុទ្ធាសនៈដែលក្រាលហើយ រុងរឿងកន្លងបង់នូវទេវតា មារ ព្រហ្មទាំងពួង ដោយសិរី និងតេជះ ទេវតាជ្រាបនូវការ

គិតរបស់ពួកមនុស្សអ្នកជម្ពូទ្វីបទាំងមូល ដែលមិនបានមកក្នុងសម័យនោះ ដោយចិត្ត ដើម្បីដកនូវសរ គឺសេចក្តីសង្ស័យរបស់ទេវតា និងមនុស្ស ទាំងពួង ទើបទូលថា ទេវតា និងមនុស្សជាច្រើន ទន្ទឹងនូវសួស្តី គឺប្រាថ្នានូវ មង្គលនៃខ្លួន ទើបនាំគ្នាគិតមង្គលទាំងឡាយ បពិត្រព្រះមានព្រះភាគ ព្រះអង្គ ដែលយើងខ្ញុំទូលសួរហើយ តាមសេចក្តីអនុមតិរបស់ទេវតាទាំងនោះ និង ដោយសេចក្តីអនុគ្រោះរបស់មនុស្សទាំងឡាយ សូមត្រាស់ប្រាប់នូវមង្គលដ៏ ឧត្តម គឺសូមទ្រង់អាស្រ័យសេចក្តីអនុគ្រោះចំពោះខ្ញុំព្រះអង្គទាំងឡាយ សូម ត្រាស់ប្រាប់នូវឧត្តមមង្គល ដើម្បីនាំមកនូវប្រយោជន៍ និងសេចក្តីសុខដោយ ចំណែកមួយ ដល់យើងខ្ញុំទាំងឡាយចុះ ។

## អធិប្បាយគាថាទី ១

ព្រះមានព្រះភាគ ទ្រង់ស្តាប់ពាក្យរបស់ទេវបុត្តនោះហើយ ទើបត្រាស់ ថា **អសេវនា ច ពាលានំ** ដូច្នេះជាដើម ។

ការមិនសេពគប់ គឺមិនចូលទៅអង្គុយជិត ឈ្មោះថា **អសេវនា** ក្នុង គាថានោះ ។ ក្នុងពាក្យថា **ពាលានំ** មានវិគ្គហៈថា ជនទាំងឡាយណាត្រឹម តែរស់នៅ ហេតុនោះ ជនទាំងនោះ ឈ្មោះថា **បុគ្គលពាល** ។

សួរថា រមែងរស់នៅដូចម្តេច ឆ្លើយថា រមែងរស់នៅត្រឹមតែដកដង្ហើម ចូលចេញ អធិប្បាយថា មិនរស់នៅដោយបញ្ញា ។ នូវបុគ្គលពាលទាំង-ឡាយនោះ ។

ក្នុងពាក្យថា **បណ្ឌិតានំ** មានវិគ្គហៈថា ជនទាំងឡាយណា ប្រព្រឹត្តទៅដោយបញ្ញា ហេតុនោះ ជនទាំងនោះ ឈ្មោះថា បណ្ឌិត អធិប្បាយថា ជនទាំងឡាយ រមែងប្រព្រឹត្តទៅដោយញាណគតិក្នុងប្រយោជន៍ទាំងឡាយ ទាំងដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ទាំងដែលប្រព្រឹត្តទៅក្នុងសម្បរាយកព ។ នូវបណ្ឌិតទាំងឡាយនោះ ។

ការសេពគប់ គឺការចូលទៅអង្គុយជិត បានដល់ ការមានបុគ្គលនោះជាសម្លាញ់ ការមានបុគ្គលនោះជាមិត្ត ឈ្មោះថា **សេវនា**។

ការធ្វើសក្ការៈ ធ្វើនូវការគោរព ការរាប់អាន និងការក្រាបថ្វាយបង្គំ ឈ្មោះថា **បូជា** ។ បទថា **បូជនេយ្យានំ** បានដល់ បុគ្គលគួរដល់ការបូជា ។ បទថា **ឯតម្មង្គលមុត្តមំ** សេចក្តីថា ព្រះមានព្រះភាគទ្រង់រួបរួមការធ្វើទាំងអស់ គឺការមិនគប់រកបុគ្គលពាល ១ ការគប់រកបណ្ឌិត ១ ការបូជាបុគ្គលដែលគួរបូជា ១ ចូលគ្នាហើយ ត្រាស់ថា **ឯតម្មង្គលមុត្តមំ** ។ មានពាក្យលោកអធិប្បាយថា ក្នុងពាក្យដែលអ្នកសួរថា សូមព្រះអង្គទ្រង់សម្តែងនូវមង្គលដ៏ឧត្តមនេះ លោកកាន់យកថា នេះជាមង្គលដ៏ឧត្តម ដូច្នេះ នេះគឺការអធិប្បាយនៃគាថានេះ ។ ឯការអធិប្បាយអត្ថនៃព្រះគាថានេះ អ្នកសិក្សាគប្បីជ្រាបយ៉ាងនេះថា

ព្រះមានព្រះភាគ កាលទ្រង់ស្តាប់ពាក្យរបស់ទេវបុត្តយ៉ាងនេះហើយ ទើបត្រាស់គាថានេះថា **អសេវនា ច ពាលានំ** ការមិនសេពគប់បុគ្គលពាល

ទាំងឡាយ ដូច្នេះ ។

ក្នុងសេចក្ដីនេះ មានកថា ៤ ប្រការ គឺបុច្ឆិតកថា ១ អបុច្ឆិតកថា ១ សានុសន្ធិកថា ១ អននុសន្ធិកថា ១ ។

ក្នុងគាថាទាំង ៤ ប្រការនោះ ពាក្យដែលព្រះមានព្រះភាគ កាលបុគ្គលទូលសួរក្នុងបញ្ហាទាំងឡាយយ៉ាងនេះថា បពិត្រព្រះគោតម ទ្រង់មានព្រះបញ្ញាដូចផែនដី ខ្ញុំសូមក្រាបទូលសួរព្រះអង្គ បុគ្គលដែលចេញចាកផ្ទះចូលមកកាន់ផ្នួសក្ដី ឬពួកឧបាសកមានផ្ទះក្ដី ប្រតិបត្តិដូចម្ដេច ទើបហៅថាសាវកល្អ និងថា បពិត្រព្រះអង្គនិទ្ទុក្ខ ព្រះអង្គឆ្លងនូវអន្ទង់ ដោយហេតុដូចម្ដេចហ្ន៎ ដូច្នេះហើយ ត្រាស់តប ឈ្មោះថា **បុច្ឆិតកថា។**

ពាក្យដែលទ្រង់មិនមានបុគ្គលទូលសួរ បញ្ហាទាំងឡាយមានយ៉ាងនេះថា ពួកជនពាលដទៃ ពោលនូវវត្ថុកាមណាថាជាសុខ ព្រះអរិយៈទាំងឡាយពោលនូវវត្ថុកាមនោះថាជាទុក្ខ ដូច្នេះ ត្រាស់ហើយ ដោយអំណាចអជ្ឈាស្រ័យរបស់ព្រះអង្គ ឈ្មោះថា **អបុច្ឆិតកថា។**

ព្រះតម្រាស់របស់ព្រះមានព្រះភាគទាំងឡាយ ឈ្មោះថា **សានុសន្ធិកថា** ព្រោះព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ តថាគតសម្ដែងធម៌សមតាមហេតុ ។

អននុសន្ធិកថា គឺពាក្យពោលដោយមិនមានហេតុផល មិនមាននៅក្នុងសាសនានេះ ។

បណ្តាគាថាទាំងឡាយនេះ មង្គលកថានេះ ឈ្មោះថា **បុច្ឆិតកថា** ព្រោះព្រះមានព្រះភាគ ដែលទេវបុត្តទូលសួរហើយ បានត្រាស់ដូចពណ៌នាមកនេះ ។

អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងបុច្ឆិតកថាដូចតទៅ

ក្នុងបណ្តាបុគ្គលទាំងឡាយ ដែលគួរសេពគប់ និងមិនគួរសេពគប់ ព្រះមានព្រះភាគត្រាស់ប្រាប់ដល់បុគ្គលដែលមិនគួរសេពគប់មុនហើយ ទើបត្រាស់ប្រាប់ដល់បុគ្គលដែលគួរសេពគប់ក្នុងគ្រាឯក្រោយ ប្រៀបដូចបុរសអ្នកឈ្លាសក្នុងផ្លូវ និងមិនមែនផ្លូវ កាលមានបុគ្គលសួរដល់ផ្លូវ ទើបបានប្រាប់ផ្លូវដែលគួរលះបង់មុនហើយ ប្រាប់ផ្លូវដែលគួរកាន់យកក្នុងកាលជាក្រោយថា ក្នុងទីឈ្មោះនោះ មានផ្លូវបែកជា ២ ក្នុងបណ្តាផ្លូវទាំង ២ នោះ ចូរអ្នកលះបង់ផ្លូវឆ្វេង កាន់យកផ្លូវស្តាំ ដូច្នេះ ។

ព្រះមានព្រះភាគ ដូចគ្នានឹងបុគ្គលអ្នកឈ្លាសក្នុងផ្លូវ សមដូចព្រះធម្មសង្គាហកាចារ្យពោលថា ម្នាលតិស្សៈ ពាក្យថា បុរសស្ទាត់ក្នុងផ្លូវនុ៎ះ ជាឈ្មោះរបស់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ដ្បិតថា ជាអ្នកឈ្លាសក្នុងលោកនេះ ឈ្លាសក្នុងលោកខាងមុខ ឈ្លាសក្នុងទីនៅរបស់មារ ឈ្លាសក្នុងទីដែលមិនមែនជាទីនៅរបស់មារ ឈ្លាសក្នុងទីនៅរបស់មច្ចុ ឈ្លាសក្នុងទីដែលមិនមែនជាទីនៅរបស់មច្ចុ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលត្រាស់ប្រាប់ដល់បុគ្គលដែលមិនគួរសេពជាមុន ទើបត្រាស់ថា **អសេវនា ច ពាលានំ** កាលត្រាស់ប្រាប់បុគ្គលដែលគួរសេព ទើបត្រាស់ថា **បណ្ឌិតានញ្ច សេវនា ។**

ដឿតថា ដំបូង ពួកបុគ្គលពាល ដូចផ្លូវដែលគួរវៀរ ដែលបុគ្គលមិនគួរសេពគប់ គឺមិនគួរចូលទៅអង្គុយជិត បន្ទាប់អំពីនោះ បណ្ឌិតទាំងឡាយ ដូចផ្លូវដែលគួរកាន់យក គួរសេពគប់ គួរចូលទៅអង្គុយជិត ។ សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ កាលត្រាស់មង្គល បានត្រាស់ដល់ការមិនសេពគប់បុគ្គលពាលមុន ត្រាស់ដល់ការសេពគប់បណ្ឌិតទាំងឡាយ ក្នុងកាលខាងក្រោយ ឆ្លើយថា ព្រោះទេវតា និងមនុស្សទាំងឡាយ កាន់យកហើយនូវការឃើញដែលជាមង្គលនេះ ក្នុងមង្គលទាំងឡាយ មានទិដ្ឋមង្គលជាដើម ដោយការសេពគប់ជាមួយបុគ្គលពាល ហើយមង្គលទិដ្ឋិនេះ ក៏ជាអពមង្គល ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់តិះដៀលនូវការប្រឡូកប្រឡំជាមួយនឹងអកល្យាណមិត្ត ដែលកាច់បំបាក់នូវប្រយោជន៍ក្នុងលោកនេះ ក្នុងលោកដទៃនោះ កាលទ្រង់សរសើរការសេពគប់កល្យាណមិត្ត ដែលធ្វើប្រយោជន៍ក្នុងលោកទាំង ២ ឲ្យសម្រេច ទើបបានត្រាស់ការមិនសេពគប់បុគ្គលពាលជាមុន និងត្រាស់ការសេពគប់បណ្ឌិតក្នុងកាលជាក្រោយ ដល់ទេវតា និងមនុស្សទាំងនោះ ។

ក្នុងបុគ្គលពាល និងបណ្ឌិតទាំងពីរនោះ សត្វទាំងឡាយណា ដែលប្រកបហើយ ដោយអកុសលកម្មបថ ១០ មានបាណាតិបាតជាដើម ឈ្មោះថា បុគ្គលពាល ។ បុគ្គលពាលទាំងនោះ បណ្ឌិតគប្បីជ្រាបបាន ដោយអាការ ៣ យ៉ាង សមដូចព្រះមានព្រះភាគត្រាស់ក្នុងព្រះសូត្រថា ម្នាលភិក្ខុទាំងឡាយ

ពាលលក្ខណៈ ... របស់បុគ្គលពាលនេះ មាន ៣ យ៉ាង ។

ម្យ៉ាងទៀត ជនទាំងនេះ គឺគ្រូទាំង ៦ មានបូរណកស្សបៈជាដើម ជនទាំងឡាយ មានទេវទត្ត កោកាលិកៈ កដមោរកតិស្សៈ ខណ្ឌទេវីបុត្ត សមុទ្ទត្តៈ និងនាងចិញ្ចមាណវិកាជាដើម ព្រះភាតារបស់ព្រះបាទទីឃវិទៈ ក្នុងអតីតកាល និងសត្វដែលមានសភាពបែបនេះ គប្បីជ្រាបថា ជាបុគ្គលពាល ។ ជនទាំងនោះ រមែងធ្វើខ្លួនឯង និងជនទាំងឡាយ ដែលធ្វើតាមពាក្យរបស់ខ្លួន ឲ្យដល់នូវការវិនាស ដោយខ្លួនដែលកាន់យកខុស ដូចផ្ទះដែលត្រូវភ្លើងឆេះទូទៅហើយ ដូច្នោះ ដូចព្រះភាតារបស់ព្រះបាទទីឃវិទៈ មានអត្តភាពប្រមាណ ៦០ យោជន៍ ដេកផ្ងារធ្លាក់ទៅ ត្រូវភ្លើងឆេះក្នុងមហានរកអស់ ៤ ពុទ្ធន្តរ និងដូចត្រកូល ៥០០ គាប់ចិត្តក្នុងទិដ្ឋិរបស់ព្រះរាជាអង្គនោះ ដល់នូវភាពជាសម្លាញ់របស់ព្រះអង្គនោះឯង ឆេះក្នុងមហានរក សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ ភ្លើងតែឆេះរាលអំពីផ្ទះបបុស ឬផ្ទះស្មៅ មកឆេះផ្ទះកំពូលទាំងឡាយ ដែលគេលាបទាំងខាងក្នុង ទាំងខាងក្រៅ មិនមានខ្យល់ចូល មានសន្ទះទ្វារដ៏ជិតស្និទ្ធ មានបង្អួចបិទជិតបាន ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភ័យទាំងឡាយណាមួយកើតឡើង ភ័យទាំងអស់នោះ តែងកើតឡើងអំពីជនពាល មិនមែនកើតអំពីបណ្ឌិតទេ ឧបទ្រពទាំង-

ឡាយណាមួយ ។បេ។ ឧបសគ្គទាំងឡាយណាមួយ កើតឡើង ឧបសគ្គទាំងអស់នោះ តែងកើតអំពីជនពាល មិនមែនកើតអំពីបណ្ឌិតទេ ក៏ដូច្នោះដែរ ម្នាលភិក្ខុទាំងឡាយ ជនពាលប្រកបដោយភ័យដ៏ពន្លឹក បណ្ឌិតមិនមានភ័យដ៏ពន្លឹកទេ ជនពាលប្រកបដោយឧបទ្រព បណ្ឌិតមិនមានឧបទ្រពទេ ជនពាល ប្រកបដោយឧបសគ្គ បណ្ឌិតមិនមានឧបសគ្គទេ ដូច្នេះ ។

ម្យ៉ាងទៀត បុគ្គលពាល ដូចគ្នានឹងត្រីស្អុយ បុគ្គលដែលគប់រកបុគ្គលពាលនោះ ដូចគ្នានឹងស្លឹកឈើដែលខ្ចប់ត្រីស្អុយ រមែងដល់នូវភាពជាអ្នកដែលវិញ្ញូជនទាំងឡាយគប្បីលះចោល និងដល់នូវភាពជាបុគ្គលដែលវិញ្ញូជនទាំងឡាយគប្បីរង្កៀស សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា

នរជនណាខ្ចប់ត្រីស្អុយ ដោយចុងស្បូវ ស្បូវក៏មានក្លិនស្អុយផ្សាយចេញទៅ យ៉ាងណាមិញ ការសេពគប់នឹងបុគ្គលពាលក៏យ៉ាងនោះដែរ ដូច្នេះ ។

អកិត្តិបណ្ឌិត កាលសក្កទេវរាជប្រទានពរ ក៏បានពោលយ៉ាងនេះថា

អាត្មាសូមកុំឲ្យជួបនឹងមនុស្សពាល សូមកុំឲ្យឮដំណឹងមនុស្សពាល សូមកុំឲ្យនៅរួមនឹងមនុស្សពាល សូមកុំឲ្យបានធ្វើ ទាំងកុំឲ្យពេញចិត្តនឹងការចរចាទៅមក នឹងមនុស្សពាល ដូច្នេះ ។

សក្កទេវរាជត្រាស់សួរថា

មនុស្សពាលបានធ្វើអ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វី បានជាលោកមិនប្រាថ្នាជួបមនុស្សពាល ដូច្នេះ ។

អកិត្តិតាបសឆ្លើយថា

បុគ្គលពាល រមែងណែនាំនូវអំពើមិនគួរណែនាំ រមែងប្រកបក្នុងកិច្ចមិនមែនជាធុរៈ ការណែនាំទៅរកអាក្រក់ ជាការប្រសើរ ( របស់បុគ្គលពាលនោះ ) បុគ្គលពាល បើទុកជាគេនិយាយត្រូវ ក៏នៅតែខឹង បុគ្គលពាល រមែងមិនដឹងច្បាប់អ្វីទេ ការមិនជួបប្រទះនឹងបុគ្គលពាលនោះ ជាការប្រពៃ ។

ព្រះមានព្រះភាគ កាលទ្រង់តិះដៀលការសេពគប់បុគ្គលពាល ដោយប្រការទាំងពួងយ៉ាងនេះហើយ ទើបត្រាស់ថា ការមិនគប់បុគ្គលពាល ជាមង្គល ឥឡូវនេះ កាលត្រាស់សរសើរការសេពគប់បណ្ឌិត ទើបត្រាស់ថា ការសេពគប់បណ្ឌិតទាំងឡាយ ដូច្នេះ ។

ក្នុងបុគ្គលពាល និងបណ្ឌិតទាំងនោះ សត្វទាំងឡាយណាដែលប្រកបដោយកុសលកម្មបថ ១០ មានការវៀរចាកការសម្លាប់សត្វជាដើម ឈ្មោះថាបណ្ឌិត ។ បណ្ឌិតទាំងឡាយនោះ គប្បីជ្រាបដោយអាការ ៣ យ៉ាង ដែលត្រាស់ក្នុងព្រះសូត្រថា ម្នាលភិក្ខុទាំងឡាយ បណ្ឌិតលក្ខណៈ ... របស់

បុគ្គលជាបណ្ឌិតនេះ មាន ៣ យ៉ាង ។

ម្យ៉ាងទៀត ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះអសីតិមហាសាវក រួមទាំងសាវករបស់ព្រះតថាគត និងជនទាំងឡាយ មានសុនេត្តតាបស មហាគោវិន្ទព្រាហ្មណ៍ វិធុរបណ្ឌិត សរភង្គតាបស មហោសថបណ្ឌិត សុត-សោមបណ្ឌិត ព្រះបាទនិមិរាជ អយោឃរកុមារ និងអកិត្តិបណ្ឌិតជាដើម គប្បីជ្រាបថា ជាបណ្ឌិត ។

បណ្ឌិតទាំងនោះ ជាអ្នកអាចកម្ចាត់ភ័យឧបទ្រព និងឧបសគ្គទាំងពួងរបស់ខ្លួន ដែលធ្វើតាមពាក្យរបស់ខ្លួន ដូចការរក្សាក្នុងពេលមានភ័យ ដូចប្រទីបក្នុងទីងងឹត និងដូចការបានបាយ និងទឹកជាដើម ក្នុងពេលត្រូវសេចក្តីទុក្ខដែលកើតអំពីសេចក្តីស្រេកឃ្លានជាដើមគ្របសង្កត់ ដូច្នោះ ។

ពិតហើយ ទេវតា និងមនុស្សទាំងឡាយរាប់មិនអស់ មិនមានប្រមាណអាស្រ័យព្រះតថាគតហើយ ដល់នូវការអស់ទៅនៃអាសវៈ ពួកខ្លះ តាំងនៅក្នុងព្រហ្មលោក ពួកខ្លះ កើតហើយក្នុងទេវលោក ត្រកូល ៨ ម៉ឺន ធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះសារីបុត្តត្ថេរ ឧបដ្ឋាកព្រះថេរៈដោយបច្ច័យ ៤ កើតហើយក្នុងស្ថានសួគ៌ ត្រកូលទាំងឡាយធ្វើចិត្តឲ្យជ្រះថ្លាហើយ ក្នុងមហាសាវកទាំងពួងមានព្រះមហាមោគ្គល្លាន និងព្រះមហាកស្សបៈជាដើម ក៏កើតក្នុងស្ថានសួគ៌យ៉ាងនោះ ជនទាំងឡាយពួកខ្លះ ដែលជាសាវករបស់សុនេត្តសាស្តាប៉ុណ្ណោះកើតហើយក្នុងព្រហ្មលោក ពួកខ្លះ ដល់នូវភាពជាសម្លាញ់នៃទេវតាទាំងឡាយ

ក្នុងជាន់បរនិម្មិតវសវត្តី ។បេ។ ពួកខ្លះ ដល់ហើយនូវភាពជាសម្លាញ់នៃគហបតីមហាសាល សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភ័យមិនមានមកអំពីបណ្ឌិត ឧបទ្រពមិនមានមកអំពីបណ្ឌិត ឧប-សគ្គមិនមានមកអំពីបណ្ឌិតទេ ... ដូច្នេះ ។ មួយប្រការទៀត បណ្ឌិតដូចគ្នានឹងកណ្ដៈនៃគ្រឿងប្រអូប មានក្រស្នា និងផ្កាជាដើម បុគ្គលដែលសេពគប់នូវបណ្ឌិតនោះ ដូចគ្នានឹងស្លឹកឈើដែលខ្ចប់គ្រឿងក្រអូប មានក្រស្នា និងផ្កាជាដើម រមែងដល់នូវភាពជាបុគ្គលដែលវិញ្ញូជនទាំងឡាយគប្បីសរសើរ និងភាពជាបុគ្គលជាទីត្រេកអរនៃវិញ្ញូជនទាំងឡាយ សមដូចព្រះមានព្រះភាគត្រាស់ក្នុង ( ឥតិវុត្តក ) ថា

នរជនណាខ្ចប់ត្រីស្អុយ ដោយចុងស្បូវ ស្បូវក៏មានក្លិនស្អុយ
ផ្សាយចេញទៅ យ៉ាងណាមិញ ការសេពគប់នឹងបុគ្គលពាល
ក៏យ៉ាងនោះដែរ ។ នរជនណា ខ្ចប់ខ្លឹមក្រស្នាដោយស្លឹកឈើ
ស្លឹកឈើ ក៏មានក្លិនក្រអូបផ្សាយទៅ យ៉ាងណាមិញ ការ
សេពនឹងអ្នកប្រាជ្ញក៏យ៉ាងនោះដែរ ដូច្នេះ ។

សូម្បីអកិត្តិបណ្ឌិតកាលសក្កទេវរាជប្រទានពរក៏បានពោលយ៉ាងនេះថា

អាត្មាសូមឲ្យជួបប្រទះអ្នកប្រាជ្ញ សូមឲ្យស្ដាប់អ្នកប្រាជ្ញ សូម
ឲ្យនៅរួមជាមួយនឹងអ្នកប្រាជ្ញ សូមឲ្យបានធ្វើ ទាំងសូមឲ្យបាន
ចូលចិត្តនឹងការចរចាទៅមក ជាមួយនឹងអ្នកប្រាជ្ញនោះ ដូច្នេះ ។

សក្កទេវរាជត្រាស់សួរថា

អ្នកប្រាជ្ញបានធ្វើប្រយោជន៍អ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វី បានជាលោកចង់ជួបប្រទះអ្នកប្រាជ្ញ ដូច្នេះ ។

អកិត្តិតាបសឆ្លើយថា

អ្នកប្រាជ្ញ រមែងណែនាំនូវហេតុដែលគួរដឹកនាំ រមែងមិនប្រកបក្នុងកិច្ចដែលមិនមែនជាធុរៈ ការដឹកនាំល្អ ជាការប្រសើរ ( របស់អ្នកប្រាជ្ញនោះ ) អ្នកប្រាជ្ញ បើគេនិយាយត្រូវហើយ រមែងមិនក្រោធ អ្នកប្រាជ្ញនោះ រមែងចេះដឹងច្បាប់ ការសេពគប់ជាមួយនឹងអ្នកប្រាជ្ញនោះ ជាការប្រពៃ ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់សរសើរការសេពគប់បណ្ឌិត ដោយប្រការទាំងពួង ទើបត្រាស់ថា ការសេពគប់បណ្ឌិតទាំងឡាយ ជាមង្គល ដូចបានពណ៌នាមកដូច្នេះ ឥឡូវនេះ កាលទ្រង់សរសើរនូវការបូជាបូជនីយបុគ្គលទាំងឡាយដែលចូលដល់ហើយនូវការៈដែលគួរបូជាដោយលំដាប់ ដោយការមិនសេពបុគ្គលពាលទាំងឡាយ និងដោយការសេពគប់បណ្ឌិតទាំងឡាយនោះ ទើបត្រាស់ថា **បូជា ច បូជនេយ្យានំ ឯតម្មង្គលមុត្តមំ** ។

ព្រះមានព្រះភាគទាំងឡាយ ឈ្មោះថា **ពុទ្ធ** ព្រោះវៀរចាកទោសទាំងពួង និងព្រោះប្រកបដោយព្រះគុណទាំងពួង ព្រះបច្ចេកពុទ្ធ និងព្រះអរិយ-

សាវកទាំងឡាយ ដែលមកខាងក្រោយអំពីព្រះពុទ្ធទាំងឡាយនោះ ឈ្មោះថា **បូជនេយ្យបុគ្គល** ក្នុងគាថានោះ ព្រោះថា ការបូជាទក្ខិណេយ្យបុគ្គលទាំងនោះ សូម្បីតិចតួច ក៏ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខអស់កាលយូរ ក្នុងសេចក្ដីនេះ មានសុមនមាលាការជាដើមជាឧទាហរណ៍ ។ ក្នុងរឿងការបូជាបុគ្គលដែលគួរបូជានាំសេចក្ដីសុខមកឲ្យអស់កាលយូរនោះ ខ្ញុំនឹងលើករឿងមួយមកជាគំរូ ។

បានឮមកថា ព្រហាមថ្ងៃមួយ ព្រះមានព្រះភាគ ស្លៀកស្បង់រៀបរយហើយ កាន់យកបាត្រ និងចីវរ យាងចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត កាលនោះ នាយសុមនមាលាការកាន់យកផ្កាទាំងឡាយ ដើម្បីទៅថ្វាយព្រះរាជាដែលជាធំ ក្នុងដែនមគធៈ ។ កំពុងដើរទៅ បានឃើញព្រះមានព្រះភាគដែលញ៉ាំងអ្នកដទៃឲ្យជ្រះថ្លា ជាបុគ្គលគួរជ្រះថ្លា ប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ និងអនុព្យញ្ជនៈ ៨០ ទ្រង់រុងរឿងដោយពុទ្ធសិរី យាងដល់ទ្វារនគរ ។

សុមនមាលាការនោះ កាលឃើញហើយ ក៏មានការគិតយ៉ាងនេះថា ព្រះរាជាទ្រង់ទទួលផ្កាទាំងឡាយហើយ គប្បីឲ្យទ្រព្យ ១០០ កហាបណៈ ឬ ១០០០ កហាបណៈដល់អញ ទ្រព្យនេះ ជាសេចក្ដីសុខចំពោះក្នុងលោកនេះ តែការបូជាព្រះមានព្រះភាគ មានផលប្រមាណមិនបាន រាប់មិនបាន រមែងនាំសេចក្ដីសុខមកអស់កាលយូរ ណ្ហើយចុះ អញនឹងបូជាព្រះមានព្រះភាគ ។

នាយសុមនមាលាការនោះ មានចិត្តជ្រះថ្លា កាន់ផ្កាក្នុងដៃ បាចទៅហើយចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគ ផ្កាទាំងឡាយអណ្តែតទៅក្នុងអាកាស បានជាពិតានផ្កា តាំងនៅហើយខាងលើព្រះមានព្រះភាគ ។ នាយមាលាការឃើញអានុភាពនោះហើយ មានចិត្តជ្រះថ្លាក្រៃលែង បានបាចផ្កាទៅមួយក្តាប់ទៀត ផ្កាទាំងនោះ ក៏ក្លាយជាក្រោះផ្កា តាំងនៅហើយ ។ នាយមាលាការបាចផ្កាទៅអស់ ៨ ក្តាប់ ដោយអាការយ៉ាងនេះ ផ្កាទាំងនោះ ទៅជាផ្ទះកំពូល ។ ព្រះមានព្រះភាគ បានគង់នៅហើយខាងក្នុងផ្ទះកំពូល ពួកមហាជនប្រជុំគ្នាហើយ ព្រះមានព្រះភាគ កាលទ្រង់សរសើរមាលាការ ទ្រង់ក៏ធ្វើការញញឹមឲ្យប្រាកដ ។ ព្រះអានន្ទគិតថា ព្រះពុទ្ធទាំងឡាយ រមែងមិនធ្វើការញញឹមឲ្យប្រាកដដោយមិនមានហេតុ មិនមានបច្ច័យ ដូច្នេះហើយ ទើបទូលសួរដល់ហេតុដែលទ្រង់ញញឹម ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ មាលាការនេះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ អស់មួយសែនកប្ប ដោយអនុភាពនៃការបូជានេះ ក្នុងទីបំផុត នឹងបានជាព្រះបច្ចេកពុទ្ធឈ្មោះសុមនិស្សរៈ ។

ក្នុងទីបំផុតនៃព្រះវាចា ដើម្បីសម្តែងព្រះធម្មទេសនា ទើបព្រះមានព្រះភាគ ត្រាស់ក្នុង ( គាថាធម្មបទ ) នេះថា

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយ ឬដល់នូវ
សេចក្តីពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា កម្ម

ដែលគេធ្វើហើយនោះឯង ឈ្មោះថា ជាកម្មល្អដូច្នេះ ។

ក្នុងបំផុតនៃគាថា សត្វទាំងឡាយ ៨៤០០០ ត្រាស់ដឹងធម៌ ។

ការបូជានូវបូជនេយ្យបុគ្គលទាំងនោះ សូម្បីតិចតួចយ៉ាងនេះ ក៏គប្បីដឹងថា រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីសុខអស់កាលយូរ ការបូជានោះជាអាមិសបូជាប៉ុណ្ណោះ នឹងពោលទៅថ្វីដល់បដិបត្តិបូជា ព្រោះកុលបុត្តពួកណាតែងបូជាព្រះមានព្រះភាគដោយការដល់រតនៈ និងដោយការទទួលសិក្ខាបទដោយការសមាទានអដ្ឋឧបោសថ និងដោយគុណទាំងឡាយរបស់ខ្លួន មានបារិសុទ្ធិសីល ៤ ជាដើម អ្នកណានឹងពណ៌នាផលនៃការបូជារបស់កុលបុត្តទាំងនោះបាន ។ ជនទាំងឡាយនោះ លោកពោលថា រមែងបូជាព្រះតថាគតដោយការបូជាយ៉ាងក្រៃលែង ដូចលោកពោលក្នុងមហាបរិនិព្វានសូត្រថា

> ម្នាលអានន្ទ បុគ្គលណាមួយ ទោះបីភិក្ខុក្ដី ភិក្ខុនីក្ដី ឧបាសកក្ដី ឧបាសិកាក្ដី ជាអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្ដីកោតក្រែង ប្រព្រឹត្តតាមធម៌ បុគ្គលនោះ ឈ្មោះថាធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត ដោយគ្រឿងបូជាដ៏ឧត្ដម ដូច្នេះ ។

សូម្បីការបូជាព្រះបច្ចេកពុទ្ធ និងអរិយសាវកទាំងឡាយ គប្បីជ្រាបថានាំប្រយោជន៍សុខមកឲ្យដោយទំនងតែមួយនឹងការបូជានេះ ។

ម្យ៉ាងទៀត គប្បីជ្រាបបុគ្គលដែលគួរបូជាក្នុងសេចក្ដីនេះថា សម្រាប់

គ្រហស្ថទាំងឡាយ បងប្រុសក្តី បងស្រីក្តី ឈ្មោះថា បុគ្គលដែលគួរបូជានៃប្អូនប្រុសស្រី មាតាបិតាជាបុគ្គលដែលគួរបូជា សម្រាប់បុត្ត ប្តី ម៉ែក្មេក ឪពុកក្មេក ជាបុគ្គលគួរបូជាសម្រាប់ស្ត្រីនៅក្នុងត្រកូលទាំងឡាយ ដ្បិតថា ការបូជានូវបុគ្គលទាំងនោះ ឈ្មោះថា ជាមង្គលដូចគ្នា ព្រោះការបូជានោះលោករាប់ថា ជាកុសលធម៌ និងព្រោះការបូជានោះជាហេតុចម្រើននៃអាយុជាដើម សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា

សត្វទាំងនោះ ក៏ជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍ និងជាអ្នកប្រព្រឹត្តកោតក្រែងត្រកូលរៀមច្បង ប្រព្រឹត្តសមាទាន នូវកុសលធម៌នេះ ក៏បានចម្រើនអាយុ ចម្រើនពណ៌សម្បុរឡើងវិញ ដូច្នេះជាដើម ។

ដោយព្រះគាថានេះ ព្រះមានព្រះភាគត្រាស់ ៣ មង្គល គឺការមិនសេពគប់បុគ្គលពាលទាំងឡាយ ១ ការសេពគប់បុគ្គលដែលជាបណ្ឌិតទាំងឡាយ ១ ការបូជាបុគ្គលដែលគួរបូជាទាំងឡាយ ១ ដោយប្រការដូច្នេះ ។

ក្នុងមង្គល ៣ ប្រការនោះ ការមិនសេពគប់បុគ្គលពាលទាំងឡាយ គប្បីជ្រាបថា ជាមង្គល ព្រោះការពារអន្តរាយ មានភ័យទាក់ទងអំពីការសេពគប់បុគ្គលពាលជាបច្ច័យជាដើមបាន និងព្រោះជាហេតុនៃប្រយោជន៍ក្នុងលោកទាំង ២ ការគប់រកបណ្ឌិតទាំងឡាយ និងការបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុនៃនិព្វាន និងសុគតិ

ដោយន័យដែលខ្ញុំបានពោលហើយ ដោយពណ៌នាផល និងសម្បត្តិនៃការបូជានោះ ។ បន្ទាប់អំពីនេះទៅ ខ្ញុំមិនបានសម្តែងមាតិកាឡើយ កំណត់មង្គលបានក្នុងទីណា នឹងពណ៌នាភាពជាមង្គលក្នុងទីនោះ ។

**គាថាទី ១ ចប់**

# អធិប្បាយគាថាទី ២

ព្រះមានព្រះភាគ ដែលទេវតាទូលអារាធនាដើម្បីត្រាស់មង្គលថា សូមប្រាប់នូវមង្គលដ៏ឧត្តម ដូច្នេះ ក៏ត្រាស់ដល់ ៣ មង្គល ដោយ ១ គាថា ដូចបុរសមានចិត្តទូលាយ គេសូមតិច ក៏ឲ្យច្រើន ដូច្នោះ ព្រោះទ្រង់ប្រាថ្នាឲ្យទេវតាទាំងឡាយបានស្តាប់ក្រៃលែងជាងនោះ និងព្រោះមង្គលមានច្រើនយ៉ាង ទើបទ្រង់ផ្តើមត្រាស់ដល់មង្គលទាំងឡាយជាអនេកទៀត ដោយគាថាទាំងឡាយថា **បដិរូបទេសវាសោ ច** ដូច្នេះជាដើម ព្រោះភាពដែលព្រះអង្គជាអ្នកប្រាថ្នានឹងដឹកនាំសត្វទាំងឡាយនោះក្នុងវត្ថុដែលជាមង្គល និងជាប្រយោជន៍នោះៗ ។

ក្នុងគាថាទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១ មុន ។ បទថា **បដិរូបោ** ប្រែថា សមគួរ ។ ស្រុកក្តី និគមក្តី នគរក្តី ជនបទក្តី ឬឱកាសដែលជាលំនៅរបស់សត្វទាំងឡាយណាមួយ ឈ្មោះថា **ទេសៈ** ។

ការនៅក្នុងប្រទេសនោះ ឈ្មោះថា **វាសៈ** ។

បទថា **បុព្វេ** បានដល់ កាលមុន គឺក្នុងជាតិទាំងឡាយ ដែលកន្លងមក

ហើយ ភាពជាបុគ្គលមានកុសលសន្សំហើយ ឈ្មោះថា **កតបុញ្ញតា**។

ចិត្ត ឬអត្តភាពទាំងមូល ហៅថា **អត្តា** ។

ការតាំងសេចក្តីប្រាថ្នា អធិប្បាយថា ការប្រកប គឺការតម្កល់ខ្លួននោះដោយប្រពៃ ឈ្មោះថា **សម្មាបណិធិ** ។

ពាក្យដ៏សេស មានន័យដូចខ្ញុំពោលហើយនោះឯង ដូច្នេះ ។ នេះ គឺពណ៌នាចំពោះបទក្នុងគាថានេះ ឯពណ៌នាអត្ថ គប្បីជ្រាបដូចតទៅនេះ

ដែលឈ្មោះថា **បដិរូបទេស** បានដល់ ប្រទេសណាដែលបរិស័ទទាំង ៤ ត្រាច់ទៅ ប្រទេសដែលបុញ្ញកិរិយាវត្ថុទាំងឡាយ មានទានជាដើមរមែងប្រព្រឹត្តទៅ ប្រទេសដែលនវង្គសត្ថុសាសនៈរុងរឿង ការនៅក្នុងបដិរូបទេសនោះ ព្រះមានព្រះភាគត្រាស់ថា ជាមង្គល ព្រោះជាបច្ច័យនៃការបំពេញបុណ្យរបស់សត្វទាំងឡាយ ក្នុងសេចក្តីនេះ មានរឿងអ្នកប្រមង់នៅក្នុងកោះសីហឡជាឧទាហរណ៍ ។

ម្យ៉ាងទៀត ឈ្មោះថា **បដិរូបទេស** បានដល់ ប្រទេស គឺមណ្ឌលពោធិព្រឹក្ស ជាទីត្រាស់ដឹងនៃព្រះមានព្រះភាគ ប្រទេសដែលព្រះមានព្រះភាគទ្រង់សម្តែងធម្មចក្ក ប្រទេស គឺមណ្ឌលនៃដើមគណ្ឌម្ពព្រឹក្ស ដែលព្រះមានព្រះភាគទ្រង់ធ្វើយមកប្បាដិហារ្យ ទ្រង់ទម្លាយនូវសេចក្តីស្រើងរបស់តិរ្ថិយទាំងពួងក្នុងកណ្តាលបរិស័ទ ដែលមកប្រជុំគ្នាក្នុងផ្ទៃដី ១២ យោជន៍ ប្រទេសដែលទ្រង់ចុះអំពីទេវលោក ត្រង់សង្កស្សនគរ ឬប្រទេសដទៃណា ដែលជាទី

គង់នៅរបស់ព្រះមានព្រះភាគ មាននគរសាវត្ថី និងនគររាជគ្រឹះជាដើម ការនៅក្នុងបដិរូបទេសនោះ ព្រះមានព្រះភាគត្រាស់ថា ជាមង្គល ព្រោះជាបច្ច័យឲ្យបានអនុត្តរិយៈ ៦ ប្រការ ។

ម្យ៉ាងទៀត ក្នុងទិសខាងកើត មាននិគមឈ្មោះកជង្គល ខាងនាយកជង្គលនិគមនោះ មាននិគមឈ្មោះមហាសាលា ខាងនាយនិគមឈ្មោះមហាសាលានោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសអាគ្នេយ៍ មានស្ទឹងឈ្មោះសល្លវតី ខាងនាយស្ទឹងសល្លវតីនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងត្បូង មាននិគមឈ្មោះសេតកណ្ណិក ខាងនាយសេតកណ្ណិកនិគមនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងលិចមានស្រុកព្រាហ្មណ៍ ឈ្មោះថូនគ្រាម ខាងនាយស្រុកថូនគ្រាមនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងជើង មានភ្នំឈ្មោះឧសីរធជៈ ខាងនាយភ្នំនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមក ជាមជ្ឈិមជនបទ ។

មជ្ឈិមប្រទេសនេះ បណ្តោយ ៣០០ យោជន៍ ទទឹង ២៥០ យោជន៍ វាស់ដោយជុំវិញបាន ៩០០ យោជន៍ មជ្ឈិមប្រទេសនេះ ឈ្មោះថា **បដិរូបទេស** ។

ស្តេចចក្រពត្តិ ដែលជាឥស្សរិយាធិបតីនៃទ្វីបធំ ៤ និងទ្វីបតូច ២០០០

ក៏ទ្រង់កើតក្នុងមជ្ឈិមប្រទេសនេះ ព្រះមហាសាវកទាំងឡាយ មានព្រះសារីបុត្ត និងព្រះមោគ្គល្លានជាដើម ដែលបំពេញបារមីមួយអសង្ខេយ្យ និងមួយសែនកប្ប ក៏កើតឡើងក្នុងមជ្ឈិមប្រទេសនេះ ព្រះបច្ចេកពុទ្ធទាំងឡាយ បំពេញបារមីពីរអសង្ខេយ្យ និងមួយសែនកប្ប ក៏កើតឡើងក្នុងមជ្ឈិមប្រទេសនេះ ព្រះសម្ពុទ្ធទាំងឡាយបំពេញបារមី ៤ អសង្ខេយ្យ ៨ អសង្ខេយ្យ ១៦ អសង្ខេយ្យ និង ១ សែនកប្ប ក៏កើតឡើងក្នុងមជ្ឈិមប្រទេសនេះ ។

ក្នុងមជ្ឈិមប្រទេសនេះ សត្វទាំងឡាយទទួលឱវាទរបស់ស្តេចចក្រពត្តិ ហើយតាំងនៅក្នុងបញ្ចសីល មានស្ថានសួគ៌ជាទីទៅខាងមុខ តាំងនៅក្នុងឱវាទនៃព្រះបច្ចេកពុទ្ធទាំងឡាយក៏ដូចគ្នា តែតាំងនៅក្នុងឱវាទរបស់ព្រះសម្ពុទ្ធ និងសាវកទាំងឡាយហើយ មានស្ថានសួគ៌ជាទីទៅខាងមុខផង មាននិព្វានជាទីទៅខាងមុខផង ព្រោះដូច្នេះ ការនៅក្នុងបដិរូបទេសនោះ ព្រះមានព្រះភាគត្រាស់ថា ជាមង្គល ព្រោះជាបច្ច័យនៃសម្បត្តិទាំងឡាយផង ។

ការសន្សំកុសល ប្រារព្ធព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រពទាំងឡាយ ក្នុងជាតិដែលកន្លងមកហើយ ឈ្មោះថា **បុព្វេកតបុញ្ញតា** សូម្បីបុព្វេកតបុញ្ញតានោះ ក៏ឈ្មោះថា ជាមង្គល ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះពាក្យអធិប្បាយថា បុគ្គលរមែងសម្រេចអរហត្តក្នុងទីបំផុតនៃគាថា ប្រកបដោយបទ ៤ ដែលលោកសម្តែងហើយ ចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ និងចំពោះមុខព្រះបច្ចេកពុទ្ធ ដែល

ខ្លួនស្តាប់ហើយ ចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធទាំងឡាយ ឬចំពោះមុខពុទ្ធ-សាវក ។

មនុស្សណា បានសន្សំបុណ្យក្នុងកាលមុន ជាអ្នកមានមូលនៃកុសលក្រាស់ហើយ អ្នកនោះត្រឹមតែស្តាប់ទេសនាហើយ រមែងអស់ទៅនូវអាសវៈបាន ដោយកុសលមូលនោះឯង ដូចព្រះបាទមហាកប្បិន និងអគ្គមហេសីរបស់ព្រះអង្គ ដោយហេតុនោះ ព្រះមានព្រះភាគ ទ្រង់ក៏ត្រាស់ថា ភាពនៃបុគ្គលបានធ្វើបុណ្យទុកក្នុងកាលមុន ជាមង្គល ។

ខ្ញុំនឹងពោលដល់ការតម្កល់ខ្លួនដោយប្រពៃតទៅ គឺបុគ្គលខ្លះ ក្នុងលោកនេះ ធ្វើខ្លួនឲ្យតាំងនៅក្នុងសីល ធ្វើខ្លួនដែលមិនមានសទ្ធា ឲ្យតាំងនៅក្នុងសទ្ធាសម្បទា ធ្វើខ្លួនដែលជាបុគ្គលកំណាញ់ ឲ្យតាំងនៅក្នុងចាគសម្បទា នេះហៅថា **អត្តសម្មាបណិធិ** ។ ការតម្កល់ខ្លួនប្រពៃនេះ រាប់ថា ជាមង្គល សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជាហេតុឲ្យលះនូវពៀរដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងសម្បរាយភព និងឲ្យសម្រេចអានិសង្សផ្សេងៗ ។

ដោយគាថានេះ ព្រះមានព្រះភាគត្រាស់នូវមង្គល ៣ ប៉ុណ្ណោះ គឺការនៅក្នុងបទេសដ៏សមគួរ ១ ការធ្វើបុណ្យទុកក្នុងកាលមុន ១ ការតម្កល់ខ្លួនទុកប្រពៃ ១ ដូចពណ៌នាមក ដូច្នេះ ការដែលធម៌ទាំងឡាយនោះជាមង្គល ខ្ញុំអធិប្បាយជាក់ច្បាស់ហើយ ក្នុងមង្គលនោះៗ ឯង ដូច្នេះ ។

**គាថាទី ២ ចប់**

# អធិប្បាយគាថាទី ៣

ឥឡូវនេះ អ្នកសិក្សាគប្បីជ្រាបអធិប្បាយត្រង់មង្គលថា **ពាហុសច្ចញ្ច** ជាដើមដូចតទៅនេះ ភាពជាអ្នកបានស្ដាប់មកច្រើន ឈ្មោះថា **ពាហុសច្ចំ** ភាពជាអ្នកឈ្លាសក្នុងហត្ថកម្មណាមួយ ឈ្មោះថា **សិប្បំ** ការទូន្មានកាយ វាចា និងចិត្ត ឈ្មោះថា **វិនយោ**។ បទថា **សុសិក្ខិតោ** បានដល់ សិក្សាហើយដោយល្អ ។ បទថា **សុភាសិតា** បានដល់ ពោលហើយដោយល្អ ។ បទថា **យា** ជាការសម្ដែងដល់ពាក្យដែលមិនពិតប្រាកដ ។ ពាក្យដែលបន្ទឹចេញពាក្យដែលជាផ្លូវ ឈ្មោះថា **វាចា**។ ពាក្យដ៏សេស មានន័យដូចខ្ញុំបានពោលហើយនោះឯង នេះគឺពណ៌នាចំពោះបទក្នុងគាថានេះ ឯពណ៌នាអត្ថ អ្នកសិក្សាគប្បីជ្រាបដូច្នេះថា

ដែលឈ្មោះថា **ពាហុសច្ចំ** បានដល់ ទ្រទ្រង់ទុកនូវពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ដែលលោកពណ៌នាដោយន័យថា ជាពហូសូត ទ្រទ្រង់សុតៈ មិនភ្លេចសន្សំទុកនូវសុតៈ ដូច្នេះជាដើម និងព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ ... មានច្រើនដល់បុគ្គលពួកខ្លះក្នុងលោកនេះជាដើម ។ ពាហុសច្ចៈនោះ ព្រះមានព្រះភាគត្រាស់ថា ជាមង្គល ព្រោះជាហេតុឲ្យលះអកុសលធម៌ និងសម្រេចកុសល-ធម៌ និងព្រោះជាហេតុធ្វើឲ្យជាក់ច្បាស់នូវបរមត្ថសច្ចដោយលំដាប់ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ អរិយសាវក មានការចេះដឹងទុកជាអាវុធ

រមែងលះបង់នូវអកុសល ចម្រើននូវកុសល លះបង់នូវអំពើមានទោស ចម្រើននូវអំពើមិនមានទោស រមែងរក្សាខ្លួនឲ្យបរិសុទ្ធ ដូច្នេះ ។

ព្រះមានព្រះភាគត្រាស់ក្នុងកីដាគិរិសូត្រថា

កាលបើចងចាំធម៌ ( នោះ ) ហើយ ទើបពិចារណារកសេចក្តី លុះពិចារណារកសេចក្តីនៃធម៌នោះហើយ ធម៌ទាំងឡាយ តែងគួរដល់កិរិយាលៃលកមើល កាលបើមានការលៃលកមើលហើយ ឆន្ទៈក៏កើតឡើង បុគ្គលនោះ លុះមានឆន្ទៈកើតហើយ ទើបព្យាយាម លុះព្យាយាមហើយ រមែងស្ទង់មើល លុះស្ទង់មើលហើយ រមែងតម្កល់ទុក មានចិត្តបញ្ជូនទៅ ( កាន់ព្រះនិព្វាន ) ធ្វើឲ្យជាក់ច្បាស់នូវបរមសច្ចដោយនាមកាយ ទាំងបានចាក់ធ្លុះ ឃើញច្បាស់នូវបរមសច្ចនោះដោយប្រាជ្ញា ដូច្នេះ ។

ម្យ៉ាងទៀត សូម្បីពហុសច្ចៈរបស់យាវាសដែលមិនមានទោស គប្បីជ្រាបថា ជាមង្គល ព្រោះនាំប្រយោជន៍ និងសុខក្នុងលោកទាំងពីរមកឲ្យ ។

ឈ្មោះថា សិប្បៈ មាន ២ គឺអគារិយសិប្បៈ ១ អនាគារិយសិប្បៈ ១ ក្នុងសិប្បៈ ២ យ៉ាងនោះ អគារិយសិប្បៈ បានដល់ ការងារដែលវៀរចាកការបៀតបៀនសត្វដទៃ វៀរចាកអកុសល មានការងារជាងកែវ និង

ជាងមាសជាដើម អគារិយសិប្បៈនោះ ឈ្មោះថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍ក្នុងលោកនេះ ឯការធ្វើសមណបរិក្ខារ មានការវាស់ និងការដេរចីវរជាដើម ឈ្មោះថា អនាគារិយសិប្បៈ សិប្បៈដែលព្រះមានព្រះភាគទ្រង់ពណ៌នាក្នុងទីនោះៗ ដោយន័យថា អំពើណាដ៏ខ្ពស់ និងទាប ដែលពួកសព្រហ្មចារីបុគ្គល ត្រូវសួរគ្នីគ្នាហើយទើបធ្វើ ភិក្ខុជាអ្នកឈ្លាសវៃ ... ដូច្នេះ និងដែលព្រះមានព្រះភាគត្រាស់ថា នេះគឺនាថករណធម៌ ដូច្នេះ គប្បីជ្រាបថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍ និងសេចក្ដីសុខក្នុងលោកទាំង ២ មកឲ្យខ្លួន និងជនដទៃ ។

ដែលឈ្មោះថា **វិន័យ** មាន ២ យ៉ាង គឺអគារិយវិន័យ ១ អនាគារិយវិន័យ ១ ក្នុងវិន័យ ២ យ៉ាងនោះ ការវៀរអកុសលកម្មបថ ១០ ឈ្មោះថា **អគារិយវិន័យ** វិន័យនោះ ឈ្មោះថា ដែលបុគ្គលគប្បីសិក្សាល្អហើយ ដោយការមិនត្រូវទោស គឺសង្កិលេសក្នុងវិន័យនោះ ដោយការកំណត់គុណនៃការប្រព្រឹត្ត ឈ្មោះថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍ និងសេចក្ដីសុខក្នុងលោកទាំង ២ ។

ឯការមិនត្រូវអាបត្តិ ៧ កង ឈ្មោះថា អនាគារិយវិន័យ សូម្បីតែអនាគារិយវិន័យនោះ ឈ្មោះថា ភិក្ខុសិក្សាល្អហើយ ដោយន័យដែលពោលហើយនោះឯង ។ម្យ៉ាងទៀត បារិសុទ្ធិសីល ៤ ឈ្មោះថា **អនាគារិយវិន័យ** ។ អនាគារិយវិន័យនោះ ដែលភិក្ខុសិក្សាដោយប្រការដែលខ្លួនតាំង

នៅក្នុងអនាគារិយវិន័យនោះហើយ សម្រេចអរហត្ត ឈ្មោះថា សិក្សាល្អហើយ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុឲ្យសម្រេចលោកិយសុខ និងលោកុត្តរសុខ ។

វាចាដែលវៀរចាកទោស មានមុសាវាទជាដើម ឈ្មោះថា វាចាសុភាសិត សមដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វាចាប្រកបដោយអង្គ ៤ ឈ្មោះថា សុភាសិត ដូច្នេះ ។ ម្យ៉ាងទៀត វាចាដែលមិនផ្តេសផ្តាស ឈ្មោះថា វាចាសុភាសិតដូចគ្នា ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) ថា

ពួកសប្បុរស ពោលសុភាសិត ជាពាក្យខ្ពង់ខ្ពស់ ( ទី ១ ) ពោលពាក្យជាធម៌ មិនពោលពាក្យមិនជាធម៌ នោះជាទី ២ ពោលពាក្យជាទីស្រឡាញ់ មិនពោលពាក្យមិនជាទីស្រឡាញ់ នោះជាទី ៣ ពោលពាក្យពិត មិនពោលពាក្យកុហក នោះជាទី ៤ ដូច្នេះ ។

វាចាសុភាសិតនេះ គប្បីជ្រាបថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍ និងសេចក្តីសុខក្នុងលោកទាំង ២ ព្រោះវាចាសុភាសិតនេះ ទាក់ទងក្នុងវិន័យនេះឯង ព្រោះហេតុនោះ កុំសង្គ្រោះវាចាសុភាសិតនេះ ដោយ **វិនយ** សព្ទ សង្គ្រោះតែវិន័យប៉ុណ្ណោះ ដោយ **វិនយ** សព្ទ ។

ម្យ៉ាងទៀត នឹងមានប្រយោជន៍អ្វី ដោយសេចក្តីលំបាកនេះ វាចាជា

គ្រឿងសម្ដែងព្រះធម៌ដល់មនុស្សដទៃ ក៏គប្បីជ្រាបថា ជាវាចាសុភាសិតក្នុងទីនេះ ពិតហើយ វាចាសុភាសិតនោះ ព្រះមានព្រះភាគត្រាស់ថា ជាមង្គល ព្រោះជាបច្ច័យឲ្យសត្វទាំងឡាយបានសម្រេចប្រយោជន៍ និងសេចក្ដីសុខក្នុងលោកទាំង ២ និងព្រះនិព្វាន ដូចការនៅក្នុងប្រទេសដ៏សមគួរដូច្នោះ ដូចព្រះវង្គីសត្ថេរពោលថា

> ព្រះពុទ្ធទ្រង់ពោលវាចាណា ដ៏ក្សេមសាន្តដើម្បីដល់នូវព្រះនិព្វាន នឹងធ្វើនូវទីបំផុតទុក្ខបាន វាចានោះឯង ជាវាចាដ៏ខ្ពង់ខ្ពស់ជាងវាចាទាំងឡាយ ។

ដោយព្រះគាថានេះ ព្រះមានព្រះភាគត្រាស់មង្គល ៤ ប្រការ គឺភាពជាពហូសូត ១ សិប្បៈ ១ វិន័យដែលសិក្សាល្អហើយ ១ វាចាសុភាសិត ១ ដោយប្រការដូច្នេះ ភាវៈនៃធម៌ទាំងនោះ ជាមង្គល ខ្ញុំបានអធិប្បាយឲ្យជាក់ច្បាស់ក្នុងមង្គលនោះៗ ហើយ ដូច្នេះឯង ។

**គាថាទី ៣ ចប់**

# អធិប្បាយគាថាទី ៤

ឥឡូវនេះ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៤ នេះថា **មាតាបិតុឧបដ្ឋានំ** ដូច្នេះជាដើម ដូចតទៅនេះ

មាតាផង បិតាផង ព្រោះដូច្នោះ ទើបឈ្មោះថា **មាតាបិតុ** ។

ការបម្រើ ឈ្មោះថា **ឧបដ្ឋានំ** ។ បុត្តទាំងឡាយផង ភរិយាទាំងឡាយផង ព្រោះហេតុនោះ ទើបឈ្មោះថា **បុត្តទារស្ស** ។

ការសង្គ្រោះ ឈ្មោះថា **សង្គហោ** ។ ការងារទាំងឡាយ ដែលមិនប្របូកប្របល់ ព្រោះហេតុនោះ ទើបឈ្មោះថា **អនាកុលា**។

ការធ្វើទាំងឡាយនោះឯង ឈ្មោះថា **កម្មន្តា** ។ ពាក្យដ៏សេសមានន័យដូចខ្ញុំពោលហើយនោះឯង នេះគឺពណ៌នាចំពោះបទ ឯពណ៌នាអត្ថ អ្នកសិក្សាគប្បីជ្រាបដូចតទៅនេះ

ស្រីអ្នកឲ្យកើត លោកហៅថា **មាតា** ឯបិតាក៏ដូចគ្នា ។

ការធ្វើឧបការៈដោយការលាងជើង ការគក់ប្រដាប់ ការអប់ ការងូតនិងការឲ្យបច្ច័យ ៤ ឈ្មោះថា **ឧបដ្ឋាន** ។

គប្បីជ្រាបអធិប្បាយក្នុងការបម្រើនោះ ដូចតទៅនេះ ព្រោះមាតាបិតាជាអ្នកមានឧបការៈច្រើន ប្រាថ្នានូវប្រយោជន៍អនុគ្រោះបុត្តទាំងឡាយ ដែលលោកឃើញនូវបុត្តទាំងនោះលេងខាងក្រៅ មានខ្លួនប្រឡាក់ធូលីដើរមកហើយក៏ជូតជីឲ្យ ឱបថើបត្រង់ក្បាល ញុំាងសេចក្តីស្រឡាញ់ឲ្យកើត ។ កូនទាំង-ឡាយ ចិញ្ចឹមមាតាបិតា ដោយទូលលើក្បាលអស់ ១០០ ឆ្នាំ ក៏មិនអាចតបស្នង សងនូវឧបការគុណនៃការទំនុកបម្រុងនោះបានឡើយ ព្រោះលោកទាំង ២ ជាបុគ្គលចិញ្ចឹមឲ្យកូនឃើញនូវលោកនេះ ជាអ្នកស្មើនឹងព្រះព្រហ្មជាបុព្វាចារ្យ ទើបការទំនុកបម្រុងនូវមាតាបិតាទាំង ២ នោះ នាំមកនូវការ

សរសើរក្នុងលោកនេះ លះលោកនេះទៅហើយ ក៏នាំសេចក្ដីសុខក្នុងស្ថានសួគ៌មកឲ្យ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ជាមង្គល សមដូចព្រះមានព្រះភាគត្រាស់ក្នុង ( ខុទ្ទកនិកាយ ឥតិវុត្តក ) ថា

មាតាបិតាទាំងឡាយ ដែលហៅថា ព្រហ្មក្ដី បុព្វាចារ្យក្ដី អាហុនេយ្យៈក្ដី ( សុទ្ធតែ ) ជាអ្នកអនុគ្រោះដល់ពួកសត្វ គឺកូន ៗ ព្រោះហេតុនោះឯង អ្នកប្រាជ្ញ គួរនមស្ការ គួរធ្វើសក្ការៈដល់មាតាបិតាទាំងនោះ ដោយបាយ ទឹក សំពត់ គ្រឿងដេក គ្រឿងអប់ គ្រឿងផ្ងូតទឹក និងទឹកសម្រាប់លាងជើង ។ ព្រោះការដែលបានទំនុកបម្រុងមាតាបិតានោះហើយ បានជាអ្នកប្រាជ្ញទាំងឡាយសរសើរនូវបុគ្គលនោះ ក្នុងលោកនេះឯង បុគ្គលនោះ លុះលះលោកនេះទៅហើយ រមែងរីករាយក្នុងស្ថានសួគ៌ ដូច្នេះ ។

ម្យ៉ាងទៀត ការបម្រើមាន ៥ យ៉ាង មានការចិញ្ចឹម ការធ្វើកិច្ច និងការតាំងវង្សត្រកូលជាដើម ការបម្រើនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុនៃប្រយោជន៍ក្នុងបច្ចុប្បន្ន ៥ យ៉ាង មានការឃាត់ចាកបាបជាដើម សមដូចព្រះមានព្រះភាគត្រាស់ក្នុង ( សិង្គាលកសូត្រ ) ថា

ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត កូនត្រូវទំនុកបម្រុង ដោយស្ថានទាំងឡាយ ៥ យ៉ាង គឺកូនត្រូវតាំងចិត្តថា អាត្មាអញ មាតាបិតាបានចិញ្ចឹមរក្សាមកហើយ នឹងចិញ្ចឹមមាតា

បិតាវិញ ១ នឹងជួយធ្វើការងាររបស់មាតាបិតា ១ ទាំងតម្កល់វង្សត្រកូល ១ ប្រតិបត្តិឲ្យជាអ្នកសមគួរទទួលទ្រព្យមត៌កបាន ១ មួយទៀត ឧទ្ទិសទក្ខិណាទានដល់មាតាបិតាដែលធ្វើកាលកិរិយាទៅកាន់បរលោកហើយ ១ ។ ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត ដែលកូនទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាងនេះឯង ហើយរមែងអនុគ្រោះកូនដោយស្ថានទាំងឡាយ ៥ យ៉ាងវិញដូច្នេះ គឺហាមឃាត់កូនចាកអំពើអាក្រក់ ១ ឲ្យកូនតម្កល់នៅតែក្នុងអំពើល្អ ១ ឲ្យកូនរៀនសូត្រសិល្បសាស្ត្រ ១ ដណ្ដឹងភរិយាស្វាមីសមគួរឲ្យ ១ ចែកទ្រព្យឲ្យកូនក្នុងសម័យគួរ ១ ដូច្នេះ ។

ម្យ៉ាងទៀត បុគ្គលណាទំនុកបម្រុងមាតា និងបិតា ដោយការឲ្យកើតការជ្រះថ្លាក្នុងព្រះរតនត្រ័យ ដោយការឲ្យសមាទានសីល ឬដោយឲ្យបព្វជ្ជា បុគ្គលនេះ ចាត់ថា ជាកំពូលនៃជនទាំងឡាយ ដែលទំនុកបម្រុងមាតាបិតាក្នុងលោកនេះ ។

ការទំនុកបម្រុងមាតាបិតារបស់បុគ្គលនោះ ជាការតបស្នងចំពោះឧបការគុណ ដែលមាតា និងបិតាធ្វើ ព្រះមានព្រះភាគត្រាស់ហៅថា ជាមង្គល ព្រោះជាហេតុនៃប្រយោជន៍ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងប្រព្រឹត្តទៅក្នុងសម្បរាយភព មិនមែនតិច ។

ក្នុងពាក្យថា **បុត្តទារស្ស** នេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

បុត្តទាំងឡាយក្តី ធីតាទាំងឡាយក្តី ដែលកើតហើយរបស់ខ្លួន រមែងដល់នូវការរាប់ថាជាកូនទាំងអស់ ។ ករិយាណាមួយ ក្នុងបណ្តាករិយា ២០ ពួក ឈ្មោះថា **ទារ**។

កូនទាំងឡាយផង ទារៈទាំងឡាយផង ឈ្មោះថា **បុត្តទារា**។ នូវបុត្តនិងករិយានោះ ។ ការធ្វើឧបការៈ ដោយឋានៈទាំងឡាយ មានការសរសើរជាដើម ឈ្មោះថា **សង្គហៈ** ការធ្វើឧបការៈនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុនៃប្រយោជន៍ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន មានភាពជាអ្នកចាត់ចែងការងារល្អជាដើម សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគ ទ្រង់សង្គ្រោះ បុត្ត និងករិយា ដោយ **ភរិយា** សព្ទ ដែលទ្រង់សម្តែងក្នុង ( សង្គាលកសូត្រ ) នេះថា បុត្ត និងករិយា គប្បីជ្រាបថា ជាទិសខាងលិច ហើយត្រាស់ថា

> ម្នាលគហបតិបុត្ត ករិយាជាទិសខាងលិច ស្វាមីត្រូវទំនុកបម្រុង ដោយស្ថានទាំងឡាយ ៥ យ៉ាង គឺដោយការរាប់អានជាករិយា ពេញទី ១ ដោយមិនមើលងាយ ១ ដោយមិនប្រព្រឹត្តក្បត់ចិត្ត ១ ដោយប្រគល់ឲ្យជាធំ ( ក្នុងការផ្ទះ ) ១ ដោយការឲ្យគ្រឿងតែងខ្លួន ១ ដូច្នេះ ។

ម្នាលគហបតិបុត្ត ភរិយាជាទិសខាងលិច ដែលស្វាមីទំនុកបម្រុង ដោយស្ថានទាំងឡាយ ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះ ស្វាមីដោយស្ថានទាំងឡាយ ៥ យ៉ាងវិញ គឺចាត់ចែងការងារ ដោយល្អ ១ សង្គ្រោះជនជាញាតិទាំងពីរខាងដោយល្អ ១ មិន ប្រព្រឹត្តក្បត់ចិត្ត ១ ថែទាំទ្រព្យដែលស្វាមីរកបានមក ១ ឈ្លាស មិនខ្ជិលច្រអូស ក្នុងកិច្ចការសព្វគ្រប់ ១ ដូច្នេះ ។

ម្យ៉ាងទៀត ន័យដទៃមានដូចតទៅ ការសង្គ្រោះដោយទាន បិយវាចា និងអត្ថចរិយា ដែលប្រកបដោយធម៌ ឈ្មោះថា **សង្គហៈ** គឺការឲ្យនូវស្បៀង ក្នុងថ្ងៃឧបោសថទាំងឡាយ ការឲ្យមើលបក្ខត្តឫក្សក្នុងថ្ងៃនក្ខត្តឫក្សទាំងឡាយ ការធ្វើមង្គលក្នុងថ្ងៃមង្គលទាំងឡាយ ការទូន្មានក្នុងប្រយោជន៍ទាំងឡាយ ដែល ប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងសម្បរាយភព ការសង្គ្រោះនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុនៃប្រយោជន៍ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និង សម្បរាយភព ដោយន័យមុននោះឯង និងព្រោះជាហេតុនៃភាពជាបុគ្គល ដែលទេវតាទាំងឡាយគប្បីថ្វាយបង្គំ ។ សមដូចពាក្យដែលសក្កទេវរាជត្រាស់ ក្នុង ( សំយុត្តកនិកាយ សគាថវគ្គ ) ថា

ពួកគ្រហស្ថណា ជាអ្នកធ្វើបុណ្យ ជាឧបាសកមានសីល
ចិញ្ចឹមកូន ប្រពន្ធ ដោយធម៌ ម្នាលមាតលិ ខ្ញុំក៏ថ្វាយ
បង្គំចំពោះពួកគ្រហស្ថនោះដែរ ។

ការងារទាំងឡាយ មានខេត្តកម្ម គោរក្ខកម្ម និងពាណិជកម្មជាដើម

គប្បីវៀរចាកការងារដែលច្របូកច្របល់ មានការធ្វើពេលវេលាឲ្យកន្លងទៅ ការធ្វើដែលមិនសមគួរធ្វើ និងការធ្វើធូរថយជាដើម ព្រោះប្រកបដោយភាពជាអ្នកដឹងកាល ព្រោះមានប្រក្រតីធ្វើសមគួរ ព្រោះមិនខ្ជិលច្រអូស ព្រោះដល់ព្រមដោយភាពឧស្សាហ៍ និងសេចក្តីព្យាយាម ព្រោះជាការងារដែលមិនវិនាស ឈ្មោះថា **អនាកុលា** ។ ការងារដែលមិនច្របូកច្របល់នេះ ដែលបុគ្គលប្រកបហើយយ៉ាងនេះ ព្រោះការឈ្លាសរបស់ខ្លួនឯង បុត្រភរិយា ឬទាសៈ និងកម្មករទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា ជាមង្គល ព្រោះហេតុនៃការបានទ្រព្យ ស្រូវ និងសេចក្តីចម្រើន ក្នុងបច្ចុប្បន្ននោះឯង សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ថា

បុគ្គលមានការងារសមតាមកាល មានធុរៈ ( មិនទម្លាក់ចោល ) ជាអ្នកតស៊ូ រមែងបាននូវទ្រព្យ ។

បុគ្គលដេកក្នុងវេលាថ្ងៃជាប្រក្រតី មិនក្រោកឡើងពីយប់ជាប្រក្រតី ជាអ្នកស្រវឹងជានិច្ច ជាអ្នកលេងល្បែង មិនអាចនឹងគ្រប់គ្រងផ្ទះសម្បែងបាន ។

ប្រយោជន៍ទាំងឡាយ តែងកន្លងហួសមនុស្សដែលលះបង់ចោលនូវការងារ ដោយពោលអាងថា វេលានេះ ត្រជាក់ណាស់ ក្តៅណាស់ ល្ងាចណាស់ ។

ជនណាមួយ ធ្វើនូវកិច្ចការរបស់បុរស មិនអើពើនូវត្រជាក់

និងក្តៅ ក្រៃលែង ជាងស្មៅ ( ទៅទៀត ) ជននោះ
រមែងមិនសាបសូន្យចាកសេចក្តីសុខឡើយ ដូច្នេះ ។
អ្នកប្រាជ្ញ បរិបូណ៌ដោយសីល តែងរុងរឿង ដូចជាភ្លើង
ដែលភ្លឺ ដូច្នោះឯង កាលបុគ្គលសន្សំទ្រព្យ រមែងធ្វើទ្រព្យ
ឲ្យជាគំនរ ដូចជាឃ្មុំ ដូច្នោះឯង ។

ដោយគាថានេះ ព្រះមានព្រះភាគត្រាស់មង្គល ៤ ប្រការនេះ គឺការបម្រើមាតា ១ ការបម្រើបិតា ១ ការសង្គ្រោះបុត្ត និងភរិយា ១ ការងារទាំងឡាយដែលមិនច្របូកច្របល់ ១ ។

ម្យ៉ាងទៀត គាថានេះ មាន ៥ មង្គល ព្រោះញែកការសង្គ្រោះបុត្ត និងភរិយាចេញជា ២ ។ ម្យ៉ាងទៀត មាន ៣ មង្គល ព្រោះសរុបការទំនុកបម្រុងមាតាបិតាចូលគ្នាតែមួយ ។ ចំណែកធម៌ទាំងនោះ ជាមង្គល ខ្ញុំបានអធិប្បាយជាក់ច្បាស់ ក្នុងមង្គលនោះៗ ឯង ។

**គាថាទី ៤ ចប់**

# អធិប្បាយគាថាទី ៥

ឥឡូវនេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងគាថានេះថា **ទានញ្ច** ដូច្នេះជាដើមដូចតទៅនេះ

ដែលឈ្មោះថា **ទាន** ព្រោះអត្ថថា របស់ជាគ្រឿងឲ្យ មានពាក្យ

អធិប្បាយថា ទ្រព្យរបស់ខ្លួនដែលបុគ្គលរមែងប្រគល់ឲ្យដល់អ្នកដទៃ ។

ការប្រព្រឹត្តិធម៌ ឬការប្រព្រឹត្តិដែលមិនប្រាសចាកធម៌ ឈ្មោះថា **ធម្ម-ចរិយា** ។

ជនទាំងឡាយនេះ ដែលយើងទាំងឡាយស្គាល់ ព្រោះហេតុនោះ ទើបជនទាំងឡាយនោះ ឈ្មោះថា **ញាតិ** ។

ការងារទាំងឡាយ ដែលមិនមានទោស ឈ្មោះថា **អនវជ្ជានិ** ។ មានពាក្យអធិប្បាយថា ការងារទាំងឡាយដែលបណ្ឌិតមិនតិះដៀល គឺមិននិន្ទាពាក្យដ៏សេស មានន័យដូចខ្ញុំបានពោលនោះឯង នេះគឺពណ៌នាបទដោយចំពោះ ។ ឯពណ៌នាអត្ថទាំងឡាយ អ្នកសិក្សាគប្បីជ្រាបដូចតទៅនេះ

ចេតនាជាគ្រឿងបរិច្ចាគទានវត្ថុ ១០ យ៉ាង មាន **អន្នំ** ជាដើម ដែលមានការត្រេកអរជាខាងដើម ឧទ្ទិសចំពោះអ្នកដទៃ ឈ្មោះថា **ទាន** ។

មួយវិញទៀត អលោភៈដែលសម្បយុត្តដោយចេតនានោះ ឈ្មោះថា **ទាន** ដ្បិតថា បុគ្គលរមែងប្រគល់ឲ្យនូវវត្ថុនោះដល់អ្នកដទៃ ដោយអលោភៈនោះ ព្រោះហេតុនោះ ទើបលោកពោលថា ឈ្មោះថា **ទាន** ព្រោះអត្ថថា វត្ថុជាគ្រឿងឲ្យ ។ ទាននោះ ព្រះមានព្រះភាគត្រាស់ថា ជាមង្គល ព្រោះហេតុឲ្យបានសម្រេចផលវិសេសទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងសម្ប-រាយភព មានភាពជាទីស្រឡាញ់របស់មហាជនជាដើម ។ ក្នុងសេចក្តីនេះគប្បីរឭកដល់ព្រះសូត្រទាំងឡាយយ៉ាងនេះថា

ម្នាលសីហៈ ទាយកអ្នកម្ចាស់ទាន ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើន ដូច្នេះជាដើម ។

ម្យ៉ាងទៀត ឈ្មោះថា **ទាន** មាន ២ យ៉ាង គឺអាមិសទាន និងធម្មទាន ។ ក្នុងទាន ២ យ៉ាងនោះ អាមិសទាន មានប្រការដូចខ្ញុំពោលហើយនោះឯង ។

ការសម្ដែងធម៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសហើយ ជាទីអស់ទុក្ខនាំសេចក្ដីសុខមកឲ្យក្នុងលោកនេះ និងលោកខាងមុខ ព្រោះប្រាថ្នាប្រយោជន៍ដល់បុគ្គលដទៃ ឈ្មោះថា **ធម្មទាន** ។ ក្នុងបណ្ដាទាន ២ យ៉ាងនេះ ធម្មទានប៉ុណ្ណោះ រាប់ថា ប្រសើរ ដូចព្រះមានព្រះភាគត្រាស់ថា

ធម្មទាន ឈ្នះអាមិសទានទាំងពួង ធម្មរសឈ្នះរសទាំងពួង
សេចក្ដីត្រេកអរក្នុងធម៌ ឈ្នះសេចក្ដីត្រេកអរទាំងពួង ការ
អស់តណ្ហា ឈ្នះទុក្ខទាំងពួង ដូច្នេះ ។

ក្នុងទានទាំង ២ យ៉ាងនេះ អាមិសទាន ជាមង្គល ខ្ញុំបានពោលមកហើយនោះឯង ឯធម្មទាន ហៅថា ជាមង្គល ព្រោះជាទីតាំងនៃគុណទាំងឡាយ មានភាពជាអ្នកស្គាល់អត្ថជាដើម ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុសម្ដែងធម៌តាមដែលបានស្ដាប់មក តាមដែលបានរៀនមក ដល់អ្នកដទៃដោយពិស្ដារ ដោយប្រការណាមួយ បុគ្គលនោះ ជាអ្នកដឹងច្បាស់នូវអត្ថ និងដឹងច្បាស់នូវធម៌ក្នុងធម៌នោះៗ ដោយ

ប្រការនោះៗ ដូច្នេះជាដើម ។

ការប្រព្រឹត្តិកុសលកម្មបថ ១០ ឈ្មោះថា **ធម្មចរិយា** ដូចព្រះមានព្រះភាគត្រាស់ថា ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ដោយកាយមាន ៣ ប្រការ ដូច្នេះជាដើម ។ ការប្រព្រឹត្តិធម៌នោះគប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុឲ្យកើតក្នុងស្ថានសួគ៌ ។

សមដូចព្រះមានព្រះភាគត្រាស់ថា

ម្នាលគហបតីទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ បែកធ្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ ចូលទៅកាន់សុគតិ សួគ៌ ទេវលោក យ៉ាងនេះ ព្រោះហេតុតែកិរិយាប្រព្រឹត្តស្មើ ពោលគឺ ប្រព្រឹត្តតាមធម៌យ៉ាងនេះឯងដូច្នេះ ។

ជនទាំងឡាយ ដែលមានការទាក់ទងគ្នាខាងមាតា និងបិតា រហូតដល់ ៧ ជួរគោត្ត ឈ្មោះថា **ញាតិ**។

ការសង្គ្រោះនូវញាតិទាំងនោះ ដែលវិនាសភោគៈ ឬវិនាសព្រោះជំងឺតម្កាត់គ្របសង្កត់ ហើយនាំមកកាន់សម្នាក់របស់ខ្លួនដោយវត្ថុទាំងឡាយ មានអាហារ សំពត់ ទ្រព្យ និងស្រូវជាដើមតាមកម្លាំង ហៅថា ជាមង្គល ព្រោះជាហេតុនៃការសម្រេចគុណវិសេស ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន មានការសរសើរជាដើម និងការសម្រេចគុណវិសេស ដែលប្រព្រឹត្តទៅក្នុងសម្ប-

វាយកត មានការទៅកាន់ស្ថានសួគ៌ជាដើម ។

ការងារទាំងឡាយ មានការសមាទានឧបោសថសីល ការធ្វើនូវការខ្វល់ខ្វាយ ការដាំឈើផ្កា ឈើផ្លែ និងដើមឈើជាម្លប់ ការសាងស្ពានជាដើម ឈ្មោះថា ការងារមិនមានទោស ។ ពិតហើយ ការងារដែលមិនមានទោសទាំងនោះ ហៅថា ជាមង្គល ព្រោះជាហេតុនៃការសម្រេចប្រយោជន៍ និងសេចក្ដីសុខច្រើនប្រការ ក្នុងសេចក្ដីនេះ គប្បីរឭកដល់សូត្រទាំងឡាយ ( ដែលត្រាស់ក្នុងអង្គុត្តរនិកាយ អដ្ឋកនិបាត ) ថា

ម្នាលវិសាខា ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រី ឬបុរសពួកខ្លះក្នុងលោកនេះ ចាំរក្សានូវឧបោសថប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកចាតុម្មហារាជិកទេវតា ដូច្នេះ ។

គាថានេះ ព្រះមានព្រះភាគត្រាស់មង្គល ៤ គឺទាន ១ ធម្មចរិយា ១ ការសង្គ្រោះញាតិទាំងឡាយ ១ ការងារទាំងឡាយដែលមិនមានទោស ១ ដូចពណ៌នាមកនេះ ។

ភាវៈដែលធម៌ទាំងនោះ ជាមង្គល ខ្ញុំបានអធិប្បាយជាក់ច្បាស់ហើយក្នុងមង្គលនោះៗ ឯង ។

**គាថាទី ៥ ចប់**

# អធិប្បាយគាថាទី ៦

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានេះថា **អារតី វិរតី** ជាដើមដូចតទៅនេះ

ការវៀរ ឈ្មោះថា **អារតី** ការវៀរចាក ឈ្មោះថា **វិរតី**។ មួយាងទៀត សត្វទាំងឡាយរមែងវៀរចាកបាបដោយចេតនានេះ ហេតុនោះ ចេតនានេះ ឈ្មោះថា **វិរតិ**។

បទថា **ចាចា** បានដល់ ចាកអកុសល ។ ដែលឈ្មោះ **មជ្ជំ** ព្រោះអត្ថថា ជាទីតាំងនៃសេចក្តីស្រវឹង ការផឹកនូវមជ្ជៈ ឈ្មោះថា **មជ្ជបានំ** ។ វៀរចាកការផឹកទឹកស្រវឹងនោះ ។ ការសង្រួម ឈ្មោះថា **សំយមោ** ការមិនប្រមាទឈ្មោះថា **អប្បមាទោ**។ បទថា **ធម្មេសុ** បានដល់ ក្នុងកុសលធម៌ទាំងឡាយ ។ ពាក្យដ៏សេស មានន័យដូចខ្ញុំពោលហើយនោះឯង នេះគឺពណ៌នាចំពោះបទ ។ ឯពណ៌នាអត្ថ គប្បីជ្រាបដូចតទៅនេះ

ការមិនត្រេកអរដោយចិត្តរបស់បុគ្គល ដែលមានប្រក្រតីឃើញទោសក្នុងបាប ឈ្មោះថា **អារតិ** ។ ការវៀរដោយកាយ និងដោយវាចា ដោយអំណាចនៃកម្ម និងទ្វារ ឈ្មោះថា **វិរតិ**។

ឈ្មោះថា **វិរតិ** នោះ មាន ៣ យ៉ាង គឺសម្បត្តវិរតិ ១ សមាទានវិរតិ ១ សមុច្ឆេទវិរតិ ១ ។

ក្នុងវិរតិ ៣ យ៉ាងនោះ ការវៀររបស់កុលបុត្តចាកវត្ថុដែលជួបប្រទះ ព្រោះអាស្រ័យជាតិ ត្រកូល ឬគោត្តរបស់ខ្លួន ដោយន័យថា ការដែល

អាត្មាអញគប្បីសម្លាប់សត្វ គប្បីកាន់យកទ្រព្យដែលគេមិនបានឲ្យ នេះមិនគួរ ឈ្មោះថា **សម្បត្តវិរតិ ។** ឯកុលបុត្ត មិនប្រព្រឹត្តកន្លងសិក្ខាបទ មានបាណាតិបាតជាដើម ចាប់តាំងអំពីការប្រព្រឹត្តិទៅនៃវិរតិ ដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃការសមាទានសិក្ខាបទ ឈ្មោះថា **សមាទានវិរតិ ។**

ពៀរ ៥ ប្រការរបស់ព្រះអរិយសាវក ស្ងប់រម្ងាប់ទៅ ចាប់តាំងអំពីការប្រព្រឹត្តិទៅនៃវិរតិ ដែលសម្បយុត្តដោយអរិយមគ្គ ឈ្មោះថា **សមុច្ឆេទវិរតិ។**

អកុសល ៤ យ៉ាងនោះ ពោល គឺកម្មកិលេស ដែលព្រះមានព្រះភាគត្រាស់ពិស្តារយ៉ាងនេះថា ម្នាលគហបតីបុត្ត កម្មកិលេស គឺបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ និងមុសាវាទ ដូច្នេះ ដែលព្រះធម្មសង្គាហកាចារ្យ ប្រមូលចងក្រងដោយគាថា ( ក្នុងទីឃនិកាយ បាដិក្កវគ្គ ) យ៉ាងនេះថា

ការសម្លាប់សត្វ ១ លួចទ្រព្យគេ ១ និយាយកុហក ១ សេពភរិយាបុគ្គលដទៃ ១ ហៅថា ( កម្មកិលេស ) បណ្ឌិតទាំងឡាយ មិនសរសើរឡើយ ដូច្នេះ ។

អកុសលទាំង ៤ ប្រការនោះ ឈ្មោះថា **បាប។**

ការវៀរចាកបាបនោះ ។ ការវៀរ និងការវៀរចាកទាំងអស់នេះ ហៅថា ជាមង្គល ព្រោះជាហេតុនៃការសម្រេចគុណវិសេសច្រើនប្រការ មានការលះពៀរ និងភ័យដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងសម្បរាយភពជាដើម ។

ក្នុងសេចក្តីនេះ គប្បីរឭកដល់ព្រះសូត្រទាំងឡាយយ៉ាងនេះថា ម្នាលគហបតី អរិយសាវកដែលជាអ្នកវៀរចាកនូវការសម្លាប់សត្វ ដូច្នេះ ។

ខ្ញុំនឹងពោលដល់ការសង្រួមចាកការផឹកទឹកស្រវឹងតទៅ ពាក្យថា **មជ្ជ-បានា ច សំយមោ** នេះ ជាឈ្មោះនៃការវៀរចាកការផឹកនូវទឹកស្រវឹង គឺសុរាមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ ។ ព្រោះបុគ្គលផឹកទឹកស្រវឹងជាប្រក្រតី រមែងមិនដឹងអត្ថ រមែងមិនដឹងធម៌ រមែងធ្វើអន្តរាយដល់មាតានិងបិតា ធ្វើអន្តរាយដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវករបស់ព្រះតថាគត រមែងត្រូវតិះដៀលក្នុងបច្ចុប្បន្ន ចូលដល់ទុគ្គតិក្នុងសម្បរាយភព ដល់នូវការឆ្កួតក្នុងភពតទៅ ។ ឯការវៀរចាកនូវការផឹកទឹកស្រវឹង រមែងសម្រេចនូវការរម្ងាប់ទោសទាំងនោះបាន និងសម្រេចការដល់ព្រមនៃគុណ ដែលផ្ទុយគ្នានឹងទោសដែលពោលហើយនោះ ។ ព្រោះហេតុនោះ ការសង្រួមចាកការផឹកទឹកស្រវឹងនេះ គប្បីជ្រាបថា ជាមង្គល ។

ដោយអត្ថ ការមិននៅប្រាសចាកសតិក្នុងកុសលធម៌ទាំងឡាយ គប្បីជ្រាបដោយន័យផ្ទុយគ្នានឹងសេចក្តីប្រមាទ ដែលព្រះមានព្រះភាគត្រាស់ហើយក្នុងគម្ពីរវិភង្គថា

ការធ្វើដោយមិនគោរព ការធ្វើមិនឲ្យរឿយៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តិទំរន់ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ការមិនតាំងមាំ ការមិន

ប្រកបរឿយៗ ការធ្វេសប្រហែស ក្នុងការចម្រើន នូវពួកធម៌ជាកុសល ការធ្វេសប្រហែស អាការធ្វេសប្រហែស ភាពនៃសេចក្តីធ្វេសប្រហែស មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រមាទ ។

ការមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយនោះ ព្រះមានព្រះភាគត្រាស់ថា ការមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយ ជាមង្គល ព្រោះហេតុនៃការសម្រេចកុសលធម៌ច្រើនប្រការ ឬព្រោះជាហេតុនៃការសម្រេចអមតធម៌ ។ ក្នុងសេចក្តីនោះ គប្បីរឭកដល់ឱវាទរបស់ព្រះសាស្តាថា ភិក្ខុជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស ... ដូច្នេះ ។ និងថា សេចក្តីមិនប្រមាទជាផ្លូវមិនស្លាប់ ដូច្នេះ ។

ក្នុងគាថានេះ ព្រះមានព្រះភាគត្រាស់ ៣ មង្គល គឺការវៀរចាកបាប ១ ការសង្រួមក្នុងការផឹកទឹកស្រវឹង ១ សេចក្តីមិនប្រមាទក្នុងកុសលធម៌ទាំង-ឡាយ ១ ដូចពណ៌នាមក ដូច្នេះ ។

ភាវៈដែលធម៌ទាំងនោះ ជាមង្គល ខ្ញុំបានអធិប្បាយជាក់ច្បាស់ហើយក្នុងមង្គលនោះៗ ឯង ដូច្នេះ ។

**គាថាទី ៦ ចប់**

# អធិប្បាយគាថា ៧

*ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានេះថា* **គារវោ** *ច ជាដើមដូចតទៅនេះ*

*សេចក្តីគោរព ឈ្មោះថា* **គារវោ** *ការប្រព្រឹត្តិបន្ទាបខ្លួន ឈ្មោះថា* **និវាតោ** ។ *សេចក្តីសន្តោស ឈ្មោះថា* **សន្តុដ្ឋី** ។ *ការដឹងឧបការៈដែលអ្នកដទៃធ្វើហើយ ឈ្មោះថា* **កតញ្ញុតា** ។

*បទថា* **កាលេន** *បានដល់ ដោយខណៈ គឺដោយសម័យ ។ ការស្តាប់ធម៌ ឈ្មោះថា* **ធម្មស្សវនំ** *ពាក្យដ៏សេស ខ្ញុំបានពោលហើយនោះឯង ។ នេះ គឺពណ៌នាចំពោះបទ ឯពណ៌នាសេចក្តី គប្បីជ្រាបដូចតទៅនេះ*

*ការធ្វើសេចក្តីគោរព ការធ្វើឲ្យធ្ងន់ ភាពជាបុគ្គលមានគារវៈតាមសមគួរក្នុងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ សាវ័ករបស់ព្រះតថាគត អាចារ្យ ឧបជ្ឈាយ៍ មាតា បិតា បងប្រុស បងស្រីជាដើម ដែលគួរដល់ការធ្វើសេចក្តីគោរព ឈ្មោះថា* **គារវោ** *ព្រោះគារវៈនោះ ជាហេតុនៃការទៅកាន់សុគតិភពជាដើម ដូចព្រះតម្រាស់ត្រាស់ ( ក្នុងចូឡកម្មវិភង្គសូត្រ ) ថា*

*ធ្វើសេចក្តីគោរព ដល់បុគ្គលដែលគួរគោរព រាប់អានបុគ្គលដែលគួររាប់អាន បូជាដល់បុគ្គលដែលគួរបូជា ។ ព្រោះអំពើនោះដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក បើបុគ្គលនោះ ទម្លាយរាងកាយបន្ទាប់*

អំពីសេចក្ដីស្លាប់ទៅ មិនទៅកើតក្នុងសុគតិទេវលោកទេ បើបាន ត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណាៗ រមែងជាអ្នកមាន ត្រកូលខ្ពង់ខ្ពស់ ដូច្នេះ ។

នឹងដូចព្រះមានព្រះភាគត្រាស់ថា ធម៌ ៧ ប្រការ តើដូចម្ដេចខ្លះ ។ គឺសេចក្ដីគោរពព្រះសាស្ដា ១ ... ធម៌ ៧ ប្រការនេះឯង តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ដូច្នេះ ។ ព្រោះហេតុនោះ សេចក្ដីគោរព ទើប ព្រះមានព្រះភាគត្រាស់ថា ជាមង្គល ។

ភាវៈជាអ្នកឱនលំទោន គឺភាពជាអ្នកមានការប្រព្រឹត្តិបន្ទាបខ្លួន ឈ្មោះ ថា **និវាតោ** ។ បុគ្គលប្រកបដោយភាពជាអ្នកប្រព្រឹត្តបន្ទាបខ្លួនណា នាំនូវ មានះចេញហើយ ត្រូវនាំការរឹងត្អឹងចេញហើយ ជាបុគ្គលស្មើដោយសំពត់ ជូតជើង ជាអ្នកស្មើដោយគោស្នែងបាក់ និងជាអ្នកស្មើដោយពស់ដែលមាន ចង្កូមដកហើយ ជាអ្នកមានវាចាពីរោះស្ដាប់ បុគ្គលនេះ ឈ្មោះថា **និវាតោ**។ និវាតនោះ ព្រះមានព្រះភាគត្រាស់ថា ជាមង្គល ព្រោះជាហេតុនៃការបាននូវ គុណ មានយសជាដើម ។ សមដូចព្រះតម្រាស់ថា មានកិរិយាប្រព្រឹត្តឱន លំទោនជាប្រក្រតី មិនរឹងត្អឹង បុគ្គលមានសភាពដូច្នោះ រមែងបានយស ដូច្នេះ ។

សេចក្ដីពេញចិត្តដោយបច្ច័យតាមមាន តាមបាន ឈ្មោះថា **សន្តុដ្ឋី** ។ ការសន្ដោសនោះមាន ១២ យ៉ាង គឺក្នុងចីវរមាន ៣ យ៉ាង គឺយថាលាភ-

សន្តោស ១ យថាពលសន្តោស ១ យថាសារុប្បសន្តោស ១ ។ សូម្បីក្នុងបិណ្ឌបាតជាដើម ក៏មានបីៗ ដូចគ្នា ។

ពណ៌នាប្រភេទនៃសន្តោសនោះ មានដូចតទៅនេះថា

ភិក្ខុក្នុងធម្មវិន័យនេះ បាននូវចីវរល្អក្តី មិនល្អក្តី លោកញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរនោះឯង មិនប្រាថ្នាចីវរដទៃ កាលបានចីវរមកទៀត ក៏មិនទទួល នេះឈ្មោះថា យថាលាភសន្តោសក្នុងចីវររបស់ភិក្ខុនោះ តែបើភិក្ខុនោះមានជំងឺ កាលគ្រងចីវរធ្ងន់ រមែងលំបាក លោកក៏ដូរចីវរនោះនឹងភិក្ខុដែលជាសភាគគ្នា ហើយញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរដែលស្រាល ក៏ចាត់ថា សន្តោសដូចគ្នា នេះឈ្មោះថា យថាលាភសន្តោស ក្នុងចីវររបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត ជាអ្នកមានប្រក្រតីបានបច្ច័យប្រណីត ភិក្ខុរូបនោះបានចីវរដែលមានតម្លៃច្រើនណាមួយ ក្នុងបណ្តាបច្ច័យទាំងឡាយ មានបាត្រនិងចីវរជាដើមហើយ គិតថា ចីវរមានតម្លៃច្រើននេះ សមគួរដល់ព្រះថេរៈទាំងឡាយដែលបួសមកយូរ ឬជាពហុសូត ដូច្នេះហើយ ទើបប្រគេនចីវរនោះដល់ព្រះថេរៈទាំងនោះ ខ្លួនឯងកាន់យកចីវរដែលមិនមានម្ចាស់អំពីគំនរសំរាម ឬចាកទីណាមួយ ធ្វើជាសង្ឃាដី ទ្រទ្រង់នូវសំពត់នោះ ក៏រាប់ថាជាអ្នកសន្តោសដូចគ្នា នេះឈ្មោះថា យថាសារុប្បសន្តោសក្នុងចីវររបស់ភិក្ខុនោះ ។

ភិក្ខុក្នុងធម្មវិន័យនេះ បានបិណ្ឌបាត ទោះសៅហ្មងក្តី ប្រណីតក្តី លោកញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយបិណ្ឌបាតនោះឯង មិនត្រូវការបិណ្ឌបាតដទៃ ទោះបីបានក៏មិនទទួល នេះឈ្មោះថា យថាលាភសន្តោសក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។

តែបើភិក្ខុជាអ្នកអាពាធ ឆាន់បិណ្ឌបាតហើយ ដល់នូវការមានជំងឺ ភិក្ខុនោះក៏ឲ្យបិណ្ឌបាតដល់ភិក្ខុដែលជាសភាគ ហើយឆាន់នូវសប្បិ ទធិ ទឹកឃ្មុំ និងទឹកដោះជាដើមអំពីដៃរបស់ភិក្ខុនោះ ហើយប្រព្រឹត្តសមណធម៌ ក៏រាប់ថាជាបុគ្គលសន្តោសនោះឯង នេះឈ្មោះថា យថាពលសន្តោស ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត បានបណីតបិណ្ឌបាត គិតថា បិណ្ឌបាតនេះសមគួរដល់ព្រះថេរៈទាំងឡាយដែលបួសយូរ និងដល់សព្រហ្មចារីទាំងឡាយដទៃដែលវៀរចាកបិណ្ឌបាតដែលប្រណីតហើយ មិនអាចឲ្យអត្តភាពប្រព្រឹត្តទៅបាន ដូច្នេះហើយ ទើបប្រគេនបណីតបិណ្ឌបាតនោះដល់ព្រះថេរៈ ឬដល់ភិក្ខុទាំងនោះ ខ្លួនត្រាច់បិណ្ឌបាត ឆាន់អាហារដែលលាយគ្នា ក៏រាប់ថា ជាអ្នកសន្តោសនោះឯង នេះឈ្មោះថា យថាសារុប្បសន្តោស ក្នុងបិណ្ឌបាតរបស់ភិក្ខុនេះ ។

សេនាសនៈដល់លំដាប់ភិក្ខុក្នុងធម្មវិន័យនេះ លោកក៏ពេញចិត្ត ក្នុងសេនាសនៈនោះឯង មិនទទួលសេនាសនៈដទៃដែលមកដល់ខ្លួន ទោះបីជា

សេនាសនៈល្អ នេះឈ្មោះថា យថាលាភសន្តោស ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។

បើលោកអាពាធនៅក្នុងសេនាសនៈ ដែលមិនមានខ្យល់ រមែងក្តៅក្រៃលែង ដោយរោគប្រមាត់ជាដើម លោកក៏ឲ្យសេនាសនៈដល់ភិក្ខុដែលស្និទ្ធស្នាល នៅក្នុងសេនាសនៈដែលមានខ្យល់ និងភាពត្រជាក់ ដែលជាលំដាប់សម្រាប់ភិក្ខុនោះ ប្រព្រឹត្តសមណធម៌ នេះក៏ជាបុគ្គលសន្តោសនោះឯង នេះឈ្មោះថា យថាពលសន្តោស ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត មិនព្រមទទួលសេនាសនៈដែលល្អ សូម្បីមកដល់ភិក្ខុនោះ លោកគិតថា សេនាសនៈដែលល្អ ជាទីតាំងនៃសេចក្តីប្រមាទ កាលភិក្ខុនោះអង្គុយក្នុងសេនាសនៈដែលល្អនោះ ថីនមិទ្ធៈរមែងគ្របសង្កត់ កាលលោកត្រូវថីនមិទ្ធៈគ្របសង្កត់ ភ្ញាក់ឡើង កាមវិតក្កក៏ផ្សាយឡើង ភិក្ខុនោះបដិសេធសេនាសនៈដែលល្អនោះ ហើយនៅក្នុងសេនាសនៈណាមួយ ដែលនៅក្នុងទីវាល គល់ឈើ និងពំនូកចំបើងជាដើម ក៏រាប់ថា ជាអ្នកសន្តោសនោះឯង នេះឈ្មោះថា យថាសារុប្បសន្តោសក្នុងសេនាសនៈរបស់ភិក្ខុនោះ ។

ភិក្ខុក្នុងធម្មវិន័យនេះ បានទូវភេសជ្ជៈ ទោះជាផ្លែសម៉ក្តី ផ្លែកន្ទួតព្រៃក្តី ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភេសជ្ជៈនោះឯង មិនប្រាថ្នានូវសប្បិ ទឹកឃ្មុំ និងទឹកអំពៅជាដើមដែលភិក្ខុដទៃបានមកហើយ ទោះបីបានច្រើន ក៏មិនទទួល នេះឈ្មោះថា យថាលាភសន្តោសក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។

បើភិក្ខុជាអ្នកអាពាធត្រូវការប្រេង តែបានទឹកអំពៅមក លោកបានឲ្យទឹកអំពៅនោះដល់ភិក្ខុដែលជាសភាគហើយ ធ្វើថ្នាំដោយប្រេងដែលបានមកអំពីដៃរបស់ភិក្ខុនោះ ប្រព្រឹត្តសមណធម៌ ក៏រាប់ថា ជាអ្នកសន្តោសនោះឯងនេះឈ្មោះថា យថាលាភសន្តោសក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត ដាក់ចំណិតសម៉ៃដែលត្រាំដោយទឹកនោមក្នុងភាជនៈមួយ កាលភិក្ខុដទៃនិយាយថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ត្រូវការសូមកាន់យកមធុរស ៤ យ៉ាង ក្នុងភាជនៈមួយ បើព្យាធិរបស់ភិក្ខុនោះអាចស្ងប់ដោយភេសជ្ជៈណាមួយ ក្នុងបណ្តាភេសជ្ជៈ ២ យ៉ាងនោះ សម៉ៃត្រាំដោយទឹកនោមប៉ុណ្ណោះ បណ្ឌិតទាំងឡាយ មានព្រះសម្ពុទ្ធជាដើមសរសើរហើយ ភិក្ខុនេះក៏គិតថា ព្រះមានព្រះភាគត្រាស់ថា បព្វជ្ជាអាស្រ័យថ្នាំត្រាំដោយទឹកមូត្រ អ្នកគប្បីធ្វើឧស្សាហ៍ក្នុងថ្នាំដែលត្រាំដោយទឹកមូត្រនោះ ដរាបដល់អស់ជីវិត ទើបឃាត់ភេសជ្ជៈដែលជាមធុរសទាំង ៤ ហើយធ្វើថ្នាំដោយសម៉ៃដែលត្រាំដោយទឹកមូត្រ រាប់ថា ជាអ្នកសន្តោសក្រៃលែង នេះឈ្មោះថា យថាសារុប្បសន្តោស ក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។

សន្តោសទាំងអស់ មានប្រភេទដូចពោលមកហើយនេះ លោកហៅថា **សន្តុដ្ឋី។** សន្តុដ្ឋីនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុនៃការលះបាបធម៌ទាំងឡាយ មានសេចក្តីប្រាថ្នាច្រើន សេចក្តីប្រាថ្នាលាមក ការចង់ធំជាដើម និងការសម្រេចគុណធម៌ ព្រោះជាហេតុនៃសុគតិ ព្រោះជាហេតុនៃការសន្សំ

អរិយមគ្គ និងព្រោះជាហេតុនៃការត្រាច់ទៅឆាយស្រួលក្នុងទិសទាំង ៤ ជាដើម ។ សមដូចលោកពោល ( ក្នុងខគ្គវិសាណសូត្រ ) ថា

បុគ្គលជាអ្នកនៅជាសុខក្នុងទិសទាំង ៤ មិនលំបាក ត្រេកអរដោយបរិក្ខារតាមមាន តាមបាន ... ដូច្នេះ ។

ការដឹងឧបការគុណ ដែលបុគ្គលណាមួយបានធ្វើ ទោះតិច ឬច្រើនដោយការរឭកដល់រឿយៗ ឈ្មោះថា **កតញ្ញុតា** ។ ម្យ៉ាងទៀត បុណ្យទាំងឡាយនោះឯង ឈ្មោះថា មានឧបការៈដល់សត្វទាំងឡាយ ព្រោះការពារនូវអន្តរាយចាកទុក្ខ មានទុក្ខក្នុងនរកជាដើម ព្រោះហេតុនោះ ការរឭកដល់ឧបការៈនៃបុណ្យប៉ុណ្ណោះ គប្បីជ្រាបថា **កតញ្ញុតា** ។

ការៈនៃបុគ្គលកតញ្ញូនោះ ព្រះមានព្រះភាគត្រាស់ថា ជាមង្គល ព្រោះជាហេតុនៃការសម្រេចគុណវិសេស មានប្រការផ្សេងៗ មានភាពជាបុគ្គលដែលសប្បុរសទាំងឡាយគប្បីសរសើរជាដើម សមដូចព្រះតម្រាស់ថា

បុគ្គលជាបុព្វការី ១ បុគ្គលជាកតញ្ញូកតវេទី ១ បុគ្គល ២ ពួកនេះ រកបានដោយក្រក្នុងលោក ដូច្នេះ ។

ក្នុងកាលណា ចិត្តសហគតៈដោយឧទ្ធច្ចៈ ឬត្រូវកាមវិតក្កណានីមួយមានកាមវិតក្កជាដើមគ្របសង្កត់ ការស្តាប់ធម៌ ដើម្បីបន្ទោបង់នូវកាមវិតក្កជាដើមនោះ ក្នុងកាលនោះ ឈ្មោះថា **កាលេន ធម្មស្សវនំ** ។ អាចារ្យពួកដទៃពោលថា ការស្តាប់ធម៌ រៀងរាល់ថ្ងៃទី ៥ នៃសប្តាហ៍ ឈ្មោះថា ស្តាប់

ធម៌តាមកាល ដូចព្រះអនុរុទ្ធទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត យើងខ្ញុំព្រះអង្គតែងអង្គុយប្រជុំគ្នាដោយធម្មីកថាពេញមួយយប់ រាល់ថ្ងៃទី ៥ ដូច្នេះ ។ ម្យ៉ាងទៀត ក្នុងកាលណា បុគ្គលចូលទៅរកកល្យាណមិត្តទាំងឡាយហើយ អាចស្តាប់ធម៌ដែលបន្ទោបង់សេចក្តីសង្ស័យរបស់ខ្លួនបាន ការស្តាប់ធម៌ក្នុងកាលនោះ គប្បីជ្រាបថា ជាការស្តាប់ធម៌តាមកាល ដូចព្រះតម្រាស់ថា បានចូលទៅសាកសួរពិគ្រោះនឹងគ្រូ ឬសព្រហ្មចារីបុគ្គលទាំងនោះតាមកាលដ៏គួរ ... ដូច្នេះ ។ ការស្តាប់ធម៌តាមកាលនោះ ឈ្មោះថា ជាមង្គល ព្រោះជាហេតុឲ្យសម្រេចនូវគុណវិសេស មានប្រការផ្សេងៗ មានការលះនីវរណៈ ការឃើញអានិសង្ស ៤ ប្រការ និងការអស់អាសវៈជាដើម សមដូចពាក្យព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវកធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ផ្ចង់ចិត្តទាំងអស់ ផ្ទៀងសោតប្បសាទស្តាប់ធម៌ សម័យនោះនីវរណធម៌ទាំង ៥ មិនមានដល់ភិក្ខុនោះឡើយ ដូច្នេះ ។ និងព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ អានិសង្សទាំងឡាយ ៤ ប្រការនៃធម៌ ដែលចូលទៅកាន់ត្រចៀករឿយៗ ជាធម៌ដែលបុគ្គលចាំស្ទាត់ រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះដោយទិដ្ឋិ គឺបញ្ញា រមែងកើតប្រាកដ ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ កាល ( នៃកុសលធម៌ ) ៤ យ៉ាងនេះ កាលបើបុគ្គលចម្រើនដោយប្រពៃ ឲ្យប្រព្រឹត្តទៅដោយប្រពៃ រមែងឲ្យដល់នូវការអស់ទៅ

នៃអាសវៈដោយលំដាប់ ។ កាល ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺការស្តាប់ធម៌តាមកាល ១ ... ដូច្នេះ ។

ក្នុងគាថានេះ ព្រះមានព្រះភាគត្រាស់ ៥ មង្គល គឺសេចក្តីគោរព ១ ការបន្ទាបខ្លួន ១ សន្តោស ១ កតញ្ញូ ១ ស្តាប់ធម៌តាមកាល ១ ដូចពណ៌នាមក ដូច្នេះ ។

ភាវៈនៃធម៌ទាំងនោះជាមង្គល ខ្ញុំបានអធិប្បាយឲ្យជាក់ច្បាស់ហើយក្នុងមង្គលនោះឯង ។

**គាថាទី ៧ ចប់**

## អធិប្បាយគាថាទី ៨

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងមង្គលថា **ខន្តិ** ជាដើមដូចតទៅ

ការអត់ធន់ ឈ្មោះថា **ខន្តិ**។ ការប្រដៅបានដោយងាយ ព្រោះជាអ្នកមានប្រក្រតីទទួលដោយដៃស្តាំ គឺគោរព មានក្នុងបុគ្គលនេះ ព្រោះហេតុនេះ បុគ្គលនេះ ឈ្មោះថា **សុវចៈ**។ កម្មរបស់បុគ្គលដែលប្រដៅងាយនោះ ឈ្មោះថា **សោវចស្ស** ភាវៈនៃ **សោវចស្ស** នោះ ឈ្មោះថា **សោវចស្សតា** ។

ឈ្មោះថា **សមណា** ក៏ព្រោះស្ងប់រម្ងាប់កិលេស ។ ការមើល ឈ្មោះថា **ទស្សន** ការសន្ទនាធម៌ ឈ្មោះថា **ធម្មសាកច្ឆា** ពាក្យដ៏សេស មានន័យដូចខ្ញុំបានពោលហើយនោះឯង នេះគឺពណ៌នាចំពោះបទ ឯពណ៌នាអត្ថ

គប្បីជ្រាបដូចតទៅនេះ

អធិវាសនខន្តី ឈ្មោះថា **ខន្តិ។** ភិក្ខុប្រកបហើយដោយខន្តី ជាអ្នកមិនញាប់ញ័រ ហាក់បីដូចមិនបានឮ និងហាក់ដូចមិនបានឃើញ ក្នុងកាលបុគ្គលជេរដោយអក្កោសវត្ថុ ១០ ឬបៀតបៀនដោយកម្មទាំងឡាយ មានការសម្លាប់ និងការចងជាដើម ដូចខន្តិវាទីតាបស ដូច្នោះ ដូចព្រះតម្រាស់ថា

សមណៈជាអ្នកសម្តែងនូវខន្តី មានហើយក្នុងអតីតកាល ព្រះបាទកាសី ទ្រង់ត្រាស់ឲ្យចោរឃាតកបុរស សម្លាប់សមណៈនោះ អ្នកតាំងនៅក្នុងខន្តី ដូច្នេះ ។

ភិក្ខុរមែងមនសិការដោយភាពជាបុគ្គលអ្នកធ្វើថាល្អ ដូចព្រះបុណ្ណត្ថេរ ព្រោះមិនប្រកាន់ទោសក្រៃលែងជាងនោះ ដូចលោកពោល ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា

បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងជេរគំរាមខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនោះយ៉ាងនេះថា ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះ ជាមនុស្សល្អ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះ ល្អណាស់ហ្ន៎ ដោយហេតុមនុស្សទាំងនេះ មិនប្រហារអាត្មាអញដោយបាតដៃ ដូច្នេះ ។

អធិវាសនខន្តីដែលភិក្ខុប្រកបហើយ ជាបុគ្គលដែលឥសីទាំងឡាយ

សរសើរ ដូចសរភង្គឥសីពោលថា

បុគ្គលសម្លាប់សេចក្ដីក្រោធ រមែងមិនក្រៀមក្រំក្នុងកាល
ណាមួយឡើយ ឥសីទាំងឡាយ រមែងសរសើរនូវការ
លះបង់នូវសេចក្ដីលុបគុណគេ បុគ្គលគប្បីអត់ធន់ចំពោះ
ពាក្យអាក្រក់ ដែលបុគ្គលទាំងពួងពោលហើយ ពួក
សប្បុរស ពោលនូវសេចក្ដីអត់ធន់នុ៎ះ ថាជាគុណជាតិ
ដ៏ឧត្ដម ដូច្នេះ ។

អ្នកណាមានកម្លាំង ជាអ្នកស្ងប់ ហើយអត់ឱនចំពោះបុគ្គលមានកម្លាំងខ្សោយ បណ្ឌិតទាំងឡាយសរសើរបុគ្គលនោះថា មានសេចក្ដីអត់ទ្រាំដ៏ក្រៃលែង ព្រោះថា បុគ្គលមានកម្លាំងថយ តែងអត់ឱនជានិច្ច ដូច្នេះ ។

បុគ្គលមានការអត់ធន់ សូម្បីព្រះពុទ្ធទាំងឡាយក៏សរសើរ ដូចព្រះ-តម្រាស់ថា

បុគ្គលណា មិនប្រទូស្ដ អត់សង្កត់ពាក្យជេរផង ការបៀត
បៀន និងការចងផងបាន ទើបតថាគតហៅបុគ្គលដែលមាន
ខន្តិជាពល មានខន្តិជាវេហ៍ពលនោះឯង ថាជាព្រាហ្មណ៍ ។

ខន្តីនេះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុឲ្យបានទទួលនូវគុណទាំងឡាយដែលលោកពណ៌នាក្នុងទីនេះប៉ុណ្ណោះ និងគុណទាំងឡាយដទៃ ។ ការមិនដល់នូវការរាយមាយ ឬភាពជាអ្នកនៅស្ងៀម ឬមិនគិតដល់គុណ និង

ទោស ក្នុងកាលខ្លួនត្រូវអ្នកដទៃទូន្មានប្រកបដោយធម៌ ធ្វើនូវការអើពើគោរព និងឱនលំទោនក្រៃលែង ហើយពោលថា សាធុ ដូច្នេះ ឈ្មោះថា **សោវចស្សតា**។ ភាពជាអ្នកប្រដៅងាយនោះ ព្រះមានព្រះភាគត្រាស់ថា ជាមង្គល ព្រោះជាហេតុឲ្យបាននូវឱវាទ និងអនុសាសនីអំពីសម្នាក់របស់សព្រហ្មចារីទាំងឡាយ និងព្រោះជាហេតុឲ្យបានលះនូវទោស និងដល់នូវគុណ ។

ការចូលទៅរក ការឧបដ្ឋាក ការរឭកដល់ ការស្តាប់ និងការឃើញបព្វជិតទាំងឡាយដែលមានកិលេសស្ងប់ហើយ ជាអ្នកអប់រំកាយ វាចា ចិត្ត និងបញ្ញា ហើយជាអ្នកប្រកបដោយការទូន្មាន និងការស្ងប់ដ៏ឧត្តម ឈ្មោះថា **សមណានញ្ច ទស្សនំ** ការចូលទៅរកទាំងអស់ជាដើម លោកពោលថា **ទស្សនំ** ព្រោះមិនបានសម្តែងដល់វត្ថុដែលថោកថយ សេចក្តីនេះ គប្បីជ្រាបថា ជាមង្គល សួរថា ព្រោះអ្វី ឆ្លើយថា ព្រោះមានឧបការៈច្រើន ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការជួបប្រទះ ( ឃើញ ) នូវភិក្ខុទាំងនោះថា មានឧបការៈច្រើន ដូច្នេះជាដើម ព្រោះកុលបុត្តប្រាថ្នានូវប្រយោជន៍ ឃើញភិក្ខុទាំងឡាយដែលទ្រទ្រង់នូវសីលមកដល់ទ្វារផ្ទះ បើទេយ្យធម៌មាន គប្បីទទួលដោយទេយ្យធម៌ តាមកម្លាំង បើទេយ្យធម៌មិនមាន គប្បីថ្វាយបង្គំ ដោយបញ្ចង្គប្រតិស្ឋាន បើការថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាននោះ ប្រព្រឹត្តទៅមិនបាន គប្បីផ្គងអញ្ជលីនមស្ការ កាលផ្គងអញ្ជលីនោះ ប្រព្រឹត្តទៅមិនបាន គប្បីអង្គុយសម្លឹងដោយ

ចិត្តជ្រះថ្លា ដោយភ្នែកទាំង ២ ដែលប្រកបដោយសេចក្តីស្រឡាញ់ ព្រោះថា ដោយបុណ្យ មានការសម្លឹងមើលយ៉ាងនេះជាហេតុ រោគភ្នែកក្តី ទោសក្តី បាយភ្នែកក្តី កន្ទុយថ្ងៃនក្នុងភ្នែកក្តី រមែងមិនមានអស់ពាន់ជាតិជាអនេក បុគ្គលនោះនឹងមានចក្ខុថ្លូវផង់ ប្រកបដោយសិរី មាន ៥ ពណ៌ ដូចគ្នានឹងបន្ទួចកែវមណីដែលបិទក្នុងវិមានកែវ ជាអ្នកមានប្រក្រតីបាននូវសម្បត្តិសព្វយ៉ាង ទាំងក្នុងទេវលោក ទាំងក្នុងមនុស្សលោក អស់សែនកប្ប កើតជាមនុស្ស ក៏ជាមនុស្សមានបញ្ញា គប្បីសោយវិបាកសម្បត្តិបែបនោះ ដោយគុណដែលកើតពីការឃើញសមណៈ ដែលប្រព្រឹត្តទៅដោយប្រពៃ នេះមិនគួរអស្ចារ្យទេ តែការដែលបណ្ឌិតទាំងឡាយ ពោលសរសើរវិបាកសម្បត្តិនៃការឃើញសមណៈ ដែលកើតអំពីហេតុត្រឹមតែសទ្ធាតែម្យ៉ាងប៉ុណ្ណោះ របស់សត្តិរច្ឆានទាំងឡាយយ៉ាងនេះថា

ទីទុយឈ្មោះកោសិយៈនេះ មានភ្នែកមូល អាស្រ័យភ្នំវេទិយកៈ រស់នៅអស់កាលយូរ ប្រកបដោយសេចក្តីសុខ បានឃើញព្រះពុទ្ធដ៏ប្រសើរ ដែលទ្រង់ក្រោកឡើងតាមកាល ទីទុយនោះ ធ្វើចិត្តឲ្យជ្រះថ្លាក្នុងតថាគត ក្នុងភិក្ខុសង្ឃដ៏ប្រសើរ មិនទៅកាន់ទុគ្គតិអស់មួយសែនកប្ប ។ ទីទុយនោះឃ្លាតចាកទេវលោកហើយ កាលកុសលកម្មជាស់តឿន នឹងបានជាព្រះបច្ចេកពុទ្ធប្រាកដនាមសោមនស្ស មានញាណមិនមានទីបំផុត នេះទើបគួរអស្ចារ្យ ។

ឈ្មោះថា **កាលេន ធម្មសាកច្ឆា** ខ្ញុំនឹងពោលតទៅ ក្នុងពេលព្រលប់

ឬក្នុងពេលទៀបភ្លឺ ភិក្ខុអ្នកជំនាញខាងព្រះសូត្រ ២ រូប សន្ទនាព្រះសូត្រ ជើងវិន័យ ២ រូប សន្ទនាព្រះវិន័យ ជើងអភិធម្ម ២ រូប សន្ទនាអភិធម្ម ជើងជាតក ២ រូប សន្ទនាជាតក ជើងអដ្ឋកថា ២ រូប សន្ទនាអដ្ឋកថា ឬ ភិក្ខុទាំងឡាយរមែងសន្ទនាគ្នាក្នុងកាលនោះៗ ដើម្បីជម្រះចិត្តដែលរួញរា រាយមាយ និងចិត្តដែលត្រូវសេចក្ដីសង្ស័យគ្របសង្កត់ នេះឈ្មោះថា **កាលេន ធម្មសាកច្ឆា** ។ ការសន្ទនាធម៌តាមកាលនោះ លោកហៅថា ជាមង្គល ព្រោះជាហេតុនៃគុណទាំងឡាយ មានភាពជាអ្នកឈ្លាសក្នុងអាគម ( បរិយត្តិ ) ជាដើម ។

ព្រះគាថានេះ ព្រះមានព្រះភាគត្រាស់ ៤ មង្គល គឺខន្តី ១ សោវចស្សតា ១ ការឃើញសមណៈទាំងឡាយ ១ ធម្មសាកច្ឆាតាមកាល ១ ដូចពណ៌នាមក ដូច្នេះ ភាវៈដែលធម៌ទាំងនោះជាមង្គល ខ្ញុំបានអធិប្បាយមកជាក់ច្បាស់ហើយ ក្នុងមង្គលនោះៗ ។

**គាថាទី ៨ ចប់**

# អធិប្បាយគាថាទី ៩

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថា មានបទថា **តបោ ច** ជាដើម ដូចតទៅនេះថា ធម៌ដែលឈ្មោះថា **តប** ព្រោះអត្ថថា ដុតនូវបាបធម៌ទាំង-ឡាយ ។ ការប្រព្រឹត្តិដ៏ប្រសើរ ព្រោះហេតុនោះ ទើបឈ្មោះថា ព្រហ្មចរិយៈ ។

ម្យ៉ាងទៀត ការប្រព្រឹត្តិរបស់ព្រហ្មទាំងឡាយ ឈ្មោះថា **ព្រហ្មចរិយ** មាន ពាក្យអធិប្បាយថា ការប្រព្រឹត្តដ៏ប្រសើរ ។ ការឃើញអរិយសច្ចទាំងឡាយ ឈ្មោះថា **អរិយសច្ចានទស្សនំ** អាចារ្យពួកខ្លះពោលថា **អរិយសច្ចា-និទស្សនំ** ដូច្នេះក៏មាន សេចក្តីនេះ មិនល្អ ។

ដែលឈ្មោះថា **និព្វាន** ព្រោះចេញចាកកិលេសជាគ្រឿងរួបរឹតដែលឈ្មោះថា **វាន**។ ការធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា **សច្ចិកិរិយា**។

ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ឈ្មោះថា **និព្វានសច្ចិកិរិយា**។

ពាក្យដ៏សេស មានន័យដូចខ្ញុំពោលហើយនោះឯង នេះគឺពណ៌នាចំពោះបទ ឯពណ៌នាអត្ថ អ្នកសិក្សាគប្បីជ្រាបដូចតទៅនេះ

ការសង្រួមឥន្ទ្រិយដោយដុតអកុសលធម៌ទាំងឡាយ មានអភិជ្ឈា និងទោមនស្សជាដើម ឬសេចក្តីព្យាយាមដែលដុតរោលការខ្ជិលច្រអូស ឈ្មោះថា **តប** ។ បុគ្គលដែលប្រកបដោយតបៈនោះ ហៅថា **អាតាបី** ។

តបៈនេះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុឲ្យលះនូវអភិជ្ឈាជាដើមចោលបាន និងជាហេតុឲ្យបានឈានជាដើម ។

ឈ្មោះថា **ព្រហ្មចរិយ** ជាឈ្មោះនៃមេថុនវិរតិ សមណធម៌ សាសនា និងមគ្គ ។

ពិតហើយ មេថុនវិរតិ ហៅថា ព្រហ្មចរិយៈ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **អព្រហ្មចរិយំ បហាយ ព្រហ្មចារី ហោតិ** លះបង់នូវ

អព្រហ្មចរិយៈ គឺធម៌មិនប្រសើរ ហើយប្រព្រឹត្តតែធម៌ដ៏ប្រសើរ ដូច្នេះ ។

សមណធម៌ ហៅថា ព្រហ្មចរិយៈ ដូចក្នុងប្រយោគជាដើម មានយ៉ាងនេះថា **ភគវតិ នោ អាវុសោ ព្រហ្មចរិយំ វុស្សតីតិ** ម្នាលអាវុសោ លោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគរបស់យើងដែរឬ ។

សាសនា ហៅថា ព្រហ្មចរិយៈ ដូចក្នុងប្រយោគជាដើមថា **ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ឥទំ ព្រហ្មចរិយំ ន ឥទ្ធញ្ចេវ ភវិស្សតិ ផីតញ្ច វិត្ថារិកំ ពាហុជញ្ញំ** ម្នាលមារមានចិត្តបាប ព្រហ្មចារ្យរបស់តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា ដូច្នេះ ។

មគ្គ ហៅថា ព្រហ្មចរិយៈ ដូចក្នុងប្រយោគជាដើមថា **អយមេវ ខោ ភិក្ខុ អរិយោ អដ្ឋង្គិកោ មគ្គោ ព្រហ្មចរិយំ សេយ្យថីទំ សម្មាទិដ្ឋិ ។** ម្នាលភិក្ខុ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ហៅថា ព្រហ្មចរិយៈ មគ្គទាំង ៨ តើដូចម្តេច គឺសម្មាទិដ្ឋិ ១ ដូច្នេះ ។ តែក្នុងព្រះសូត្រនេះ ពាក្យទាំងពួងដ៏សេសក៏ប្រើបាន ព្រោះកាន់យកមគ្គជាខាងមុខ ក្នុងការឃើញអរិយសច្ច ព្រហ្មចរិយៈនេះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុនៃការសម្រេចគុណវិសេស មានប្រការផ្សេងៗ ក្រៃលែងឡើង ។

ការឃើញមគ្គ ដោយអំណាចនៃការសម្រេចអរិយសច្ច ៤ មានអត្ថ

ដែលព្រះមានព្រះភាគត្រាស់ហើយ ក្នុងកុមារបញ្ហា ឈ្មោះថា **អរិយ-សច្ចាន ទស្សនំ** ការឃើញអរិយសច្ចនោះ លោកពោលថា ជាមង្គល ព្រោះជាហេតុ ឲ្យឆ្លងផុតចាកទុក្ខក្នុងសង្សារបាន ។

ឈ្មោះថា **និព្វានសច្ឆិកិរិយា** ខ្ញុំនឹងបានពោលតទៅក្នុងមង្គលសូត្រនេះ ពាក្យថា **អរហត្តផល** ព្រះមានព្រះភាគទ្រង់បំណងយកថា ជាព្រះនិព្វាន ព្រោះអរហត្តផលនោះ ហៅថា **និព្វាន** ព្រោះចេញចាកតណ្ហាដែលហៅថា **វាន** ព្រោះជោតក្រងនូវគតិ ៥ ។ ការសម្រេច ឬការពិចារណាព្រះនិព្វាននោះ ហៅថា **សច្ឆិកិរិយា** ។ តែការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានក្រៅអំពីនេះ សម្រេចបាន ក៏ដោយការឃើញអរិយសច្ចប៉ុណ្ណោះ ព្រោះហេតុនោះ ទើបព្រះនិព្វាននេះ មិនបំណងយកក្នុងមង្គលនេះ ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននេះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុឲ្យនៅជាសុខក្នុងបច្ចុប្បន្ន ដូចពណ៌នាមក ដូច្នេះ ។

ដោយព្រះគាថានេះ ព្រះមានព្រះភាគត្រាស់ ៤ មង្គល គឺតប: ១ ព្រហ្មចរិយ: ១ ការឃើញអរិយសច្ច ១ ការធ្វើនិព្វានឲ្យជាក់ច្បាស់ ១ ដូចពណ៌នាមក ដូច្នេះ ភាវៈដែលធម៌ទាំងនោះ ជាមង្គល ខ្ញុំបានអធិប្បាយជាក់ច្បាស់ហើយ ក្នុងមង្គលនោះៗ ដូច្នេះ ។

**គាថាទី ៩ ចប់**

# អធិប្បាយគាថាទី ១០

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងមង្គលថា **ផុដ្ឋស្ស លោកធម្មេហិ** ជាដើមដូចតទៅនេះ

បទថា **ផុដ្ឋស្ស** បានដល់ សម្ផស្ស គឺពាល់ត្រូវ បានដល់ ដល់ព្រម ។ ធម៌ទាំងឡាយក្នុងលោក ឈ្មោះថា **លោកធម៌** មានពាក្យអធិប្បាយថា លោកនៅប្រព្រឹត្តទៅដរាបណា ធម៌ទាំងឡាយ ក៏មិនវិលត្រឡប់ដរាបនោះ ។

**មនោ មានស** ឈ្មោះថា **ចិត្ត**។ បទថា **យស្ស** បានដល់ នវកភិក្ខុ មជ្ឈិមភិក្ខុ ឬថេរៈ ។ បទថា **ន កម្បតិ** បានដល់ មិនញាប់ញ័រ មិនឃ្លៀងឃ្លាត ។ បទថា **អសោកំ** បានដល់ មិនសោក គឺដកនូវសរ គឺសេចក្តីសោកចេញបាន ។ បទថា **វិរជំ** បានដល់ ប្រាសចាករាគៈ គឺកម្ចាត់រាគៈបានហើយ ។ បទថា **ខេមំ** បានដល់ មិនមានភ័យ គឺគ្មានឧបទ្រវ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។ នេះជាពណ៌នាចំពោះបទ ឯពណ៌នាអត្ថ គប្បីជ្រាបដូចតទៅនេះ

ចិត្តរបស់បុគ្គលណា ដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយ មិនញាប់ញ័រ គឺចិត្តរបស់បុគ្គលណា ដែលលោកធម៌ទាំង ៨ មានលាភជាដើមពាល់ត្រូវហើយ គឺគ្របសង្កត់ហើយ រមែងមិនញាប់ញ័រ បានដល់ មិនឃ្លៀងឃ្លាត មិនកក្រើករំពើក ចិត្តរបស់បុគ្គលនោះ បុគ្គលណាម្នាក់ មិនគប្បីឲ្យញាប់ញ័របាន គប្បីជ្រាបថា ជាមង្គល ព្រោះនាំលោកុត្តរមគ្គមកឲ្យ ។ សួរថា ចិត្តរបស់បុគ្គលណា ត្រូវលោកធម៌ទាំងនេះពាល់ត្រូវហើយ មិនញាប់ញ័រ

ធ្វើយថា ចិត្តនៃព្រះអរហន្តខីណាស្រពរមែងមិនញាប់ញ័រ មិនមែនចិត្តអ្នកណាដទៃឡើយ សមដូចព្រះមានព្រះភាគត្រាស់ក្នុង ( អង្គុត្តរនិកាយ ឆក្កនិបាត ) ថា

ថ្មភ្នំតាន់សុទ្ធ រមែងមិនកម្រើកដោយខ្យល់ យ៉ាងណា អារម្មណ៍ទាំងឡាយ គឺរូប សំឡេង ក្លិន រស ផស្សៈ ទាំងអស់ ជាទីប្រាថ្នាក្តី មិនជាទីប្រាថ្នាក្តី ក៏ធ្វើចិត្តរបស់អ្នកខ្ជាប់ខ្ជួន ជាចិត្តនឹងធឹង រួចស្រឡះចាកកិលេស ឲ្យញាប់ញ័រមិនបាន ទាំងលោកក៏ពិចារណាឃើញនូវការកើតឡើង និងការរលត់ទៅនៃចិត្តនោះ ក៏យ៉ាងនោះដែរ ។

ចិត្តរបស់ព្រះខីណាស្រពប៉ុណ្ណោះ ឈ្មោះថា **អសោកំ** គឺមិនសោកពិតហើយ ចិត្តរបស់ព្រះខីណាស្រពប៉ុណ្ណោះ ឈ្មោះថា មិនសោយសោក ព្រោះមិនមានសេចក្តីសោក ដែលលោកហៅដោយន័យថា សេចក្តីជ្រប់ស្រពោន អាការនៃចិត្តជ្រប់ស្រពោន ភាពនៃចិត្តសង្រេងសង្រែ សេចក្តីស្ងួតស្ងប់ សេចក្តីស្ងួតស្ងប់ខាំង សេចក្តីក្រៀមក្រំនៃចិត្ត ... ដូច្នេះ ។

អាចារ្យពួកខ្លះ ហៅចិត្តដែលមិនសោកស្តាយនេះថា ជាព្រះនិព្វាន ។ ចិត្តដែលមិនសោកនោះ លោកមិនភ្ជាប់ជាមួយបទមុន ( ចិត្តដែលត្រូវលោកធម៌ ) ដូចពាក្យថា ចិត្តមិនសោយសោក ជាចិត្តរបស់ព្រះខីណាស្រព យ៉ាងណា សូម្បីពាក្យថា ចិត្តដែលប្រាសចាកធូលី ចិត្តក្សេម ក៏ជាចិត្តរបស់ព្រះ

ខីណាស្រពដូចគ្នា ដូច្នោះ ព្រោះថា ចិត្តរបស់ព្រះខីណាស្រពនោះ ឈ្មោះថា ប្រាសចាកធូលី ព្រោះជាចិត្តប្រាសចាកធូលី គឺរាគៈ ទោសៈ និងមោហៈ និងឈ្មោះថា ក្សេម ព្រោះជាចិត្តដែលផុតចាកយោគៈទាំង ៤ ព្រោះចិត្តរបស់ព្រះខីណាស្រពនោះមាន ៣ យ៉ាង គឺ **អសោកំ វិរជំ ខេមំ** ដោយអំណាចដែលលោកកាន់យកក្នុងបវត្តិក្ខណៈនោះៗ សម្តែងដោយអាការនោះៗ គប្បីជ្រាបថា ជាមង្គល ព្រោះនាំមកនូវភាពជាកំពូលក្នុងលោក មានភាពដែលខន្ធមិនប្រព្រឹត្តទៅទៀតជាដើម និងនាំមកនូវភាពជាអាហុនេយ្យបុគ្គលជាដើម ។

ដោយព្រះគាថានេះ ព្រះមានព្រះភាគត្រាស់មង្គល ៤ ប្រការ គឺភាពដែលចិត្តមិនញាប់ញ័រដោយលោកធម៌ប្រាំបី ១ ចិត្តមិនសោយសោក ១ ចិត្តប្រាសចាកធូលី ១ ចិត្តក្សេម ១ ដូចពណ៌នាមក ដូច្នេះ សេចក្តីនៃធម៌ទាំងនេះជាមង្គល ខ្ញុំបានអធិប្បាយជាក់ច្បាស់ហើយ ក្នុងមង្គលនោះឯង ដូច្នេះ ។

**គាថាទី ១០ ចប់**

## អធិប្បាយគាថាទី ១១

ព្រះមានព្រះភាគត្រាស់មង្គល ៣៨ ប្រការ ដោយ ១០ គាថាថា **អសេវនា ច ពាលានំ** ដូច្នេះជាដើម ដូចពណ៌នាមក ដូច្នេះហើយ ឥឡូវនេះ កាលទ្រង់សរសើរមង្គលដែលទ្រង់ត្រាស់យ៉ាងនេះ ទើបបានត្រាស់គាថាចុងក្រោយថា **ឯតាទិសានិ កត្វាន** ដូច្នេះជាដើម ។

ពណ៌នាអត្ថនៃគាថាចុងក្រោយនោះ មានដូចតទៅនេះ

ពាក្យថា **ឯតាទិសានិ** សេចក្តីថា មង្គលទាំងឡាយ មានការមិនសេពគប់បុគ្គលពាលជាដើមនេះ គឺមានប្រការដូចខ្ញុំពោលមកហើយ ។ បទថា **កត្វាន** បានដល់ ធ្វើហើយ ។ ពិតហើយ ៣ បទ គឺ **កត្វាន កត្វា ករិត្វា** អត្ថក៏មិនប្លែកទេ ។

បទថា **សព្វត្ថមបរាជិតា** សេចក្តីថា ជាបុគ្គលដែលសត្រូវណាមួយក្នុងសត្រូវទាំង ៤ មានខន្ធមារ កិលេសមារ អភិសង្ខារមារ និងទេវបុត្តមារ ឲ្យចាញ់មិនបាន អធិប្បាយថា ធ្វើមារទាំង ៤ ប្រភេទនោះឲ្យបាក់បបខ្ទបខ្ទាប ។ ម អក្ខរៈ ក្នុងពាក្យថា **សព្វត្ថមបរាជិតា** នេះ គប្បីជ្រាបថា គ្រាន់តែជាសន្ធិ គឺការភ្ជាប់បទប៉ុណ្ណោះ ។

បាទគាថាថា **សព្វត្ថ សោត្ថឹ គច្ឆន្តិ** សេចក្តីថា បុគ្គលធ្វើតាមមង្គលទាំងនេះហើយ ជាបុគ្គលដែលមារទាំង ៤ ឲ្យចាញ់មិនបាន រមែងដល់នូវសួស្តីក្នុងទីទាំងពួង គឺក្នុងលោកនេះ និងក្នុងលោកខាងមុខ និងក្នុងទីទាំងឡាយមានផ្លូវដើរចង្ក្រមជាដើម មានពាក្យអធិប្បាយថា អាសវៈ ការសម្លាប់ និងការក្តៅក្រហាយណា គប្បីកើតឡើងចាកការសេពគប់បុគ្គលពាលជាដើម ជនទាំងឡាយនោះ រមែងដល់នូវសួស្តី ព្រោះមិនមានអាសវៈ ការសម្លាប់ និងការក្តៅក្រហាយទាំងនោះ ឈ្មោះថា ជាអ្នកមិនមានឧបទ្រវ មិនមានឧបសគ្គមានសេចក្តីក្សេម មិនមានភ័យ រមែងដល់នូវសួស្តីបាន ។ **អនុនាសិក** គឺ

និគ្គហិត ក្នុងពាក្យថា **សព្វត្ថ សោត្ថឹ គច្ឆន្តិ** នេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ដើម្បីការងាយស្រួលក្នុងការចងគាថា ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនា ដោយបាទគាថានេះថា **តន្តេសំ មង្គលមុត្តមំ**។

សួរថា ព្រះមានព្រះភាគទ្រង់បញ្ចប់ទេសនាដូចម្ដេច ឆ្លើយថា ទ្រង់បញ្ចប់ទេសនាដោយពុទ្ធបំណងយ៉ាងនេះថា ម្នាលទេវបុត្ត ព្រោះជនណាធ្វើតាមមង្គលនេះយ៉ាងនេះ ជននោះ រមែងដល់នូវសួស្ដីក្នុងទីទាំងពួង ដូច្នោះទើបលោកកាន់យកមង្គលទាំង ៣៨ ប្រការ មានការមិនសេពគប់បុគ្គលពាលជាដើម ជាមង្គលដ៏ឧត្តម គឺប្រសើរបំផុត បានដល់ ប្រសើរសម្រាប់ជនទាំងឡាយនោះ ដែលធ្វើតាមមង្គលទាំងនេះ ។ ក្នុងទីបំផុតនៃទេសនាដែលព្រះមានព្រះភាគទ្រង់បញ្ចប់ហើយយ៉ាងនេះ ទេវតាប្រមាណមួយសែនកោដិសម្រេចអរហត្ត បុគ្គលដែលសម្រេចជាព្រះសោតាបន្ន សកទាគាមី អនាគាមី រាប់ចំនួនមិនអស់ឡើយ ។

បន្ទាប់អំពីនោះ ក្នុងថ្ងៃទី ២ ព្រះមានព្រះភាគត្រាស់ហៅព្រះអានន្ទត្ថេរមកហើយត្រាស់ថា ម្នាលអានន្ទ យប់មិញនេះ ទេវតាមួយអង្គមករកតថាគតសួរមង្គលបញ្ហា កាលបើដូច្នេះ តថាគតក៏ពោលមង្គល ៣៨ ដល់ទេវតានោះ ម្នាលអានន្ទ ចូរអ្នករៀនមង្គលនេះ កាលរៀនមង្គលបរិយាយនេះហើយ ចូរប្រាប់ដល់ភិក្ខុទាំងឡាយ ព្រះថេរៈរៀនហើយ ក៏បានប្រាប់ភិក្ខុទាំងឡាយ ។ មង្គលសូត្រនេះ អាចារ្យទាំងឡាយនាំតៗ គ្នាមកដល់សព្វថ្ងៃនេះ ព្រហ្មចរិយៈ

គប្បីជ្រាបថា ទេវតា និងមនុស្សទាំងឡាយប្រកាសល្អហើយ ទាំងជាអ្នកបរិបូណ៌ សាយកាយទូលំទូលាយ មានមនុស្សស្គាល់ច្រើន ជាបែបផែនដោយប្រការដូច្នេះ ។

ឥឡូវនេះ ដើម្បីការឈ្លាសក្នុងការអប់រំញាណ ក្នុងមង្គលនេះ ទើបមានយោជនាចាប់តាំងអំពីដើមដូចតទៅនេះ

សត្វទាំងឡាយណា ប្រាថ្នាសេចក្ដីសុខក្នុងលោកនេះ លោកខាងមុខ និងលោកុត្តរសុខ លះនូវការសេពគប់បុគ្គលពាល អាស្រ័យបណ្ឌិតទាំងឡាយ បូជានូវបុគ្គលទាំងឡាយដែលគួរបូជា ការនៅក្នុងប្រទេសដ៏សមគួរ និងភាពជាអ្នកមានបុណ្យធ្វើទុកហើយក្នុងកាលមុនដាស់តឿន ក្នុងការសន្សំនូវកុសល ទើបតម្កល់ខ្លួនទុកប្រពៃ មានអត្តភាពប្រដាប់ហើយដោយពាហុសច្ចៈ សិប្បៈ និងវិន័យ ពោលនូវវាចាដែលជាសុភាសិត ដែលសម គួរដល់វិន័យ ខ្លួនមិនទាន់លះភាពជាគ្រហស្ថដរាបណា ក៏ជម្រះបំណុលចាស់ ចិញ្ចឹមមាតាបិតាដរាបនោះ បុលបំណុលថ្មី ដោយការសង្គ្រោះបុត្ត និងភរិយា សម្រេចនូវសម្បត្តិ មានទ្រព្យ និងស្រូវជាដើម ដោយភាពជាអ្នកមានការងារមិនប្របូកប្របល់ កាន់យកសារៈនៃភោគៈ ដោយការឲ្យទាន និងសារៈនៃជីវិតដោយការប្រព្រឹត្តិធម៌ ធ្វើនូវប្រយោជន៍ដល់ជនរបស់ខ្លួន ដោយសង្គ្រោះញាតិ និងធ្វើប្រយោជន៍ដល់ជនដទៃ ដោយការប្រកបការងារដែលប្រាសចាកទោស វៀរបង់នូវការបៀតបៀនអ្នកដទៃ ដោយការវៀរចាកបាប និងការបៀតបៀន

ខ្លួន ដោយសង្រួមចាកការផឹកទឹកស្រវឹង ចម្រើននូវធម៌ចំណែកកុសលទាំង-ឡាយ ដោយសេចក្ដីមិនប្រមាទក្នុងធម៌ទាំងឡាយ លះនូវយរាវាសភេទ ដោយភាពជាអ្នកឈ្លាសក្នុងកុសលធម៌ ដែលខ្លួនចម្រើនហើយ ស្ងប់ស្ងៀមតាំងនៅហើយក្នុងភាពជាបព្វជិត ក៏ត្រេកអរដល់ព្រមដោយវត្ត ដោយសេចក្ដីគោរព និងការឱនលំទោនក្នុងទក្ខិណេយ្យបុគ្គលទាំងឡាយ មានព្រះពុទ្ធ ពុទ្ធ-សាវក ឧបជ្ឈាយ៍ និងអាចារ្យជាដើម លះនូវការជាប់ក្នុងបច្ច័យ ដោយសេចក្ដីសន្ដោស តាំងនៅក្នុងសប្បុរសភូមិ ដោយកតញ្ញូ លះចិត្តដែលរួញរាដោយការស្ដាប់ធម៌ គ្របសង្កត់អន្តរាយទាំងពួង ដោយការអត់ធន់ ធ្វើខ្លួនឲ្យមានទីពឹង ដោយភាពជាអ្នកប្រដៅងាយ ឃើញនូវការប្រកបសេចក្ដីព្យាយាមក្នុងបដិបត្តិ ដោយការឃើញសមណៈ បន្ទោបង់នូវសេចក្ដីសង្ស័យក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃសេចក្ដីសង្ស័យចេញបាន ដោយការសន្ទនាធម៌ ធ្វើសីលឲ្យបរិសុទ្ធបរិបូណ៌ ដោយការសង្រួមឥន្ទ្រិយ និងតបៈ ធ្វើចិត្តឲ្យបរិសុទ្ធបរិបូណ៌ដោយព្រហ្មចរិយៈ គឺសមណធម៌ ធ្វើវិសុទ្ធិ ៤ ដ៏សេសអំពីនោះឲ្យបរិបូណ៌ ( ទិដ្ឋិ កង្ខា មគ្គា បដិបទា ) សម្រេចនូវញាណទស្សន-វិសុទ្ធិ ដែលជាបរិយាយនៃអរិយសច្ចទស្សនៈ ដោយបដិបទានេះ រមែងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ពោល គឺអរហត្តផល ។ កាលធ្វើឲ្យជាក់ច្បាស់ហើយ ក៏ជាអ្នកមានចិត្តមិនញាប់ញ័រដោយលោកធម៌ ៨ ដូចភ្នំសិនេរុ មិនញាប់ញ័រព្រោះខ្យល់ និងភ្លៀង ដូច្នោះ ទើបជាបុគ្គលមិនសោយសោក មាន

ចិត្តប្រាសចាកធូលី មានចិត្តក្សេម បុគ្គលពួកណា ជាអ្នកមានចិត្តក្សេម បុគ្គលទាំងនោះ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង រមែងដល់នូវសួស្តីក្នុងទីបំផុតគ្រប់អន្ទើ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

**ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា**
**សព្វត្ថ សោត្ថិំ គច្ឆន្តិ តន្តេសំ មង្គលមុត្តមំ។**

ទេវតា និងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសួស្តីក្នុងទីទាំងពួង ( ម្នាលទេវតា អ្នកចូរប្រកាន់ជឿថា ) មង្គលទាំង ៣៨ ប្រការ មានការមិនសេពគប់នូវបុគ្គលពាលជាដើមនោះ របស់ទេវតា និងមនុស្សទាំងអម្បាលណោះ ជាមង្គលដ៏ឧត្តម ដូច្នេះ ។៚

**អដ្ឋកថា មង្គលសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## សូចិលោមសូត្រទី ៥

[ ២៦ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់លើគ្រែថ្ម ជាលំនៅនៃសូចិលោមយក្ខ ទៀបគយាគ្រាម ។ សម័យនោះឯង ខរយក្ខ និងសូចិលោមយក្ខ នាំគ្នាដើរទៅជិតព្រះមានព្រះភាគ ។ លំដាប់នោះ ខរយក្ខបាននិយាយនឹងសូចិលោមយក្ខថា នុ៎ះព្រះសមណៈ ។ សូចិលោមយក្ខឆ្លើយថា នុ៎ះមិនមែនព្រះសមណៈទេ នុ៎ះគ្រាន់តែប្រហែលនឹងព្រះសមណៈ ចាំខ្ញុំសង្កេតឲ្យដឹងថា ជាព្រះសមណៈ ឬប្រហែលនឹងព្រះសមណៈសិន ។ វេលានោះ សូចិលោមយក្ខ ក៏ចូលទៅជិតព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បន្ទន់កាយទៅរកព្រះមានព្រះភាគ ។ ចំណែកព្រះមានព្រះភាគ ឆាកព្រះកាយចេញ ។ លំដាប់នោះ សូចិលោមយក្ខ ទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះសមណៈ ខ្លាចខ្ញុំឬ ។ ម្នាលអាវុសោ តថាគតមិនខ្លាចអ្នកទេ តែសម្ផស្សរបស់អ្នកឯងអាក្រក់ ។

ព្រះសមណៈ យើងនឹងសួរប្រស្នាចំពោះលោក បើលោកមិនឆ្លើយប្រាប់យើង យើងនឹងធ្វើចិត្តរបស់លោកឲ្យរវើរវាយ ឬនឹងហែកហឫទ័យលោក ឬក៏នឹងចាប់ជើងបោះទៅត្រើយម្ខាងទន្លេគង្គា ។ ម្នាលអាវុសោ បុគ្គលណាគប្បីញ៉ាំងចិត្តតថាគត ឲ្យរាយមាយក្តី ហែកហឫទ័យតថាគតក្តី គប្បីចាប់ជើងតថាគត គ្រវីបោះទៅត្រើយម្ខាងទន្លេគង្គាក្តី តថាគតមិនឃើញបុគ្គលនោះទោះបីក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ

ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ឡើយ ម្នាលអាវុសោ មួយទៀត អ្នកប្រាថ្នា ( នឹងសួរ ) ប្រស្នាណា ចូរសួរប្រស្នានោះមកចុះ ។ លំដាប់នោះ សូចិលោមយក្ខ បានពោលទៅនឹងព្រះមានព្រះភាគ ដោយគាថាដូច្នេះថា

[ ២៧ ] រាគៈ និងទោសៈ មានអ្វីជាហេតុ សេចក្តីមិនត្រេកអរ សេចក្តីត្រេកអរ និងការព្រឺរោម កើតមកអំពីអ្វី មនោវិតក្ក កើតមកអំពីអ្វី ដែលគួរលះបង់ចោល ដូចជាពួកក្មេងលែងក្អែកចោល ។

រាគៈ ទោសៈ មានអត្តភាពនេះជាហេតុ សេចក្តីមិនត្រេកអរ សេចក្តីត្រេកអរ និងការព្រឺរោម កើតមកអំពីអត្តភាពនេះ មនោវិតក្ក កើតមកអំពីអត្តភាពនេះ ដែលគេលះបង់ចោល ដូចជាពួកក្មេងលែងក្អែកចោល ។

កិលេសទាំងឡាយ កើតមកអំពីសេចក្តីស្នេហា គឺតណ្ហា ក៏កើតអំពីខ្លួន ដូចជាពួរជ្រៃដែលកើតអំពីដើមជ្រៃ កិលេសដ៏ច្រើនជាប់ជំពាក់ក្នុងវត្ថុកាមទាំងឡាយ ដូចជាពួរឈើ ចាក់ស្រេះក្នុងព្រៃ ។

ពួកជនណា ដឹងនូវកិលេសនោះ ថាកើតអំពីហេតុណា ពួកជននោះ តែងបន្ទោបង់នូវហេតុនោះចេញ ម្នាលយក្ខ ចូរអ្នក

ស្តាប់ចុះ ពួកជនទាំងនោះ តែងឆ្លងនូវអន្លង់នេះ ដែលគេឆ្លង
បានដោយក្រ ដែលខ្លួនមិនធ្លាប់ឆ្លង ដើម្បីដល់ព្រះនិព្វាន
ដែលជាទីមិនកើតទៀត ។

សូចិលោមសូត្រទី ៥ ចប់

# អដ្ឋកថា

## សូចិលោមសូត្រ

[ ២៦ ] ក្នុងសូចិលោមសូត្រទី ៥ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

សួរថា សូត្រនេះកើតឡើងដូចម្តេច ឆ្លើយថា អត្ថុប្បត្តិហេតុរបស់សូត្រនេះ មានជាក់ច្បាស់ ដោយន័យដែលខ្ញុំពោលក្នុងពណ៌នាអត្ថ ក្នុងបទថា **គយាយំ វិហរតិ ដង្កិតមញ្ចេ សូចិលោមស្ស យក្ខស្ស ភវនេ** នេះ ។ គប្បីជ្រាបវិនិច្ឆ័យថា **គយា** គឺអ្វី គ្រែដែលមានមៅគ្រែ គឺអ្វី ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគគង់នៅត្រង់ភពរបស់យក្ខនោះ ខ្ញុំនឹងពោលឆ្លើយតទៅ

ស្រុកក្តី កំពង់ទឹកក្តី លោកហៅថា **គយា** ស្រុក និងកំពង់ទាំង ២ នោះ ក៏សមគួរក្នុងព្រះសូត្រនេះ ព្រោះថា ព្រះមានព្រះភាគសូម្បីគង់នៅក្នុងប្រទេស មិនឆ្ងាយអំពីស្រុកគយា លោកក៏ហៅថា **គយាយំ វិហរតិ** ។

ក្នុងទីជិត គឺទីមិនឆ្ងាយ បានដល់ ទីជិតទ្វារនៃស្រុកនោះ មានគ្រែដែលមានមេគ្រែនោះតាំងនៅ ព្រះមានព្រះភាគគង់នៅត្រង់កំពង់គយា លោកក៏ហៅថា **គយាយំ វិហរតិ** ហើយត្រង់កំពង់គយានោះ មានគ្រែដែលមានមេគ្រែនោះតាំងនៅ ។

គ្រែថ្មដែលគេលើកថ្មមួយបន្ទះដាក់លើជុំថ្ម ៤ ជុំ ហៅថា **ដង្កិតមញ្ច** ព្រះមានព្រះភាគទ្រង់អាស្រ័យ **ដង្កិតមញ្ច** នោះ ដែលជាភពរបស់យក្ខ ដូចភពរបស់អាឡវកយក្ខ ។

ម្យ៉ាងទៀត ព្រោះហេតុដែលព្រះមានព្រះភាគ ទ្រង់ចេញអំពីសមាបត្តិដែលប្រកបដោយព្រះមហាករុណា ក្នុងកាលទៀបភ្លឺថ្ងៃនោះ ទ្រង់ប្រមើលមើលសត្វលោក ដោយពុទ្ធចក្ខុ ទ្រង់បានឃើញឧបនិស្ស័យនៃសោតាបត្តិផលរបស់យក្ខទាំង ២ គឺសូចិលោមយក្ខ និងខរយក្ខ ដូច្នោះ ទើបទ្រង់កាន់បាត្រនិងចីវរខាងក្នុងអរុណនោះឯង យាងមកកាន់បទេសដែលជាកំពង់នោះ ជាទីកន្លែងស្មោកគ្រោក ជាទីហូរចេញនូវរបស់មិនស្អាត មានប្រការផ្សេងៗ មានទឹកមាត់ និងទឹកសម្បោរជាដើម របស់មហាជនដែលមកប្រជុំគ្នាអំពីទិសផ្សេងៗ ហើយគង់លើគ្រែ ដែលមានមេគ្រែនោះ ដែលជាភពរបស់សូចិលោមយក្ខ ព្រោះហេតុនោះ ទើបព្រះអានន្ទត្ថេរពោលថា សម័យមួយ ព្រះមានព្រះភាគគង់លើគ្រែ ដែលមានមេគ្រែក្នុងភពរបស់សូចិលោមយក្ខ ជិតស្រុកគយា ឬជិតកំពង់គយា ។

បទថា **តេន ខោ បន សមយេន** សេចក្ដីថា សម័យណា ព្រះមានព្រះភាគគង់នៅត្រង់គពរបស់សូចិលោមយក្ខនោះ សម័យនោះ ខរយក្ខ និងសូចិលោមយក្ខបានឈានចូលទៅក្នុងទីមិនឆ្ងាយអំពីព្រះមានព្រះភាគ ។

សួរថា ព្រោះហេតុអ្វី ទើបយក្ខទាំង ២ ឈានចូលទៅ ខ្ញុំនឹងពោលដូចតទៅនេះ

បណ្ដាយក្ខទាំង ២ នោះ នឹងបានពោលដល់យក្ខមួយមុន គឺក្នុងអតីត-កាល បុរសម្នាក់ មិនបានប្រាប់ឡើយ កាន់យកប្រេងរបស់សង្ឃ ទៅលាបសរីរៈរបស់ខ្លួន ព្រោះកម្មនោះ ទើបគេឆេះក្នុងនរក ហើយមកកើតក្នុងកំណើតយក្ខត្រង់ប្រាំងនៃស្រះបោក្ខរណី ក្នុងស្រុកគយា យក្ខនោះមានអវយវៈចម្លែកដោយវិបាក ដោយសេសសល់វិបាកនៃកម្មនោះ ស្បែករបស់យក្ខនោះ មានសម្ផស្សគ្រោតគ្រាត ដូចគ្នានឹងអំបែងក្បឿង កាលណាយក្ខនោះបំណាងធ្វើឲ្យអ្នកដទៃខ្លាច គេក៏ពង្រីកស្បែកដែលដូចគ្នានឹងអំបែង ធ្វើឲ្យខ្លាច យក្ខនោះបានឈ្មោះថា ខរយក្ខ ព្រោះមានសម្ផស្សគ្រោតគ្រាតនោះឯង ដោយប្រការដូច្នេះ ។

ឯសូចិលោមយក្ខ ក្នុងសម័យព្រះមានព្រះភាគព្រះនាមកស្សបៈ ជាឧបាសកទៅវត្តស្ដាប់ធម៌ មួយខែ ៨ ដង ថ្ងៃមួយ កាលអ្នកស្រុកប្រកាសការស្ដាប់ធម៌ គាត់លេងត្រង់ស្រែរបស់ខ្លួន ក្បែរទ្វារសង្ឃារាម បានឮនូវសំឡេងឃោសនាហើយ ក៏គិតថា បើអញងូតទឹកសោត នាំឲ្យយឺតយូរ ដូច្នេះ

ក៏ចូលទៅកាន់រោងឧបោសថទាំងរាងកាយស្មោកគ្រោកនោះឯង ហើយក៏ដេក លក់លើកម្រាលដែលមានតម្លៃច្រើន ដោយការមិនអើពើ ។ អាចារ្យខាង សំយុត្តនិកាយពោលថា យក្ខនេះ ជាភិក្ខុនោះឯង មិនមែនឧបាសកឡើយ ។ ដោយកម្មនោះ និងដោយកម្មដទៃទៀត ទើបគេឆេះក្នុងនរក ដោយសេស សល់ផលកម្ម ក៏មកកើតក្នុងកំណើតយក្ខ ត្រង់មាត់ស្រះបោក្ខរណី មានរូប គួរខ្ពើម ។ កាយរបស់សូចិលោមយក្ខនោះ មានរោមរឹង យក្ខនោះធ្វើសត្វ ទាំងឡាយឲ្យខ្លាច ដូចចាក់ដោយរោម ដូច្នោះ ទើបយក្ខនោះបានឈ្មោះថា សូចិលោមយក្ខ ព្រោះមានរោមរឹងដូចម្ជុលនោះឯង ដោយប្រការដូច្នេះ ។ យក្ខទាំង ២ នោះ ចេញអំពីភពរបស់ខ្លួន ដើម្បីទៅរកស៊ី មិនបានមួយសន្ទុះ ក៏ត្រឡប់មកដោយផ្លូវ ដែលខ្លួនទៅនោះឯង មកដល់ទិសាភាគក្រៅអំពីនេះ បានឈានចូលទៅក្នុងទីមិនឆ្ងាយអំពីព្រះមានព្រះភាគ ។

ក្នុងបទថា **អថ ខោ ខរោ** ជាដើម មានវិនិច្ឆ័យដូចតទៅនេះ

សួរថា ព្រោះហេតុអ្វី ទើបយក្ខទាំង ២ ពោលយ៉ាងនេះ ឆ្លើយថា ខរយក្ខបានឃើញអាការរបស់សមណៈ ហើយពោលនឹងសូចិលោមយក្ខ ឯ សូចិលោមយក្ខ ជាអ្នកមានទិដ្ឋិយ៉ាងនេះថា អ្នកណាខ្លាច អ្នកនោះមិនមែន ជាសមណៈឡើយ គ្រាន់តែជាសមណៈប្លម គ្រាន់តែជាសមណៈក្លែងក្លាយ ព្រោះហេតុនោះ កាលមើលងាយព្រះមានព្រះភាគ ក៏ពោលដោយអង់អាចថា បុរសនេះ មិនមែនជាសមណៈ ជាសមណៈប្លម កាលប្រាថ្នានឹងសាកល្បង

ទើបពោលថា **យាវ ជាឆាមិ** ជាដើម ។

ពាក្យដែលលោកពោលយ៉ាងនេះថា **អថ ខោ** ជាដើម ដែលលោកពោលចាប់តាំងអំពីពាក្យនេះថា **សូចិលោមោ យក្ខោ** រហូតដល់ពាក្យថា **អបិច ខោ តេ សមណ បញ្ហំ បុច្ឆិស្សាមិ** មានអត្ថងាយយល់ហើយ ព្រោះថាក្នុងពាក្យនោះ គប្បីជ្រាបសម្ពន្ធយ៉ាងនេះត្រឹមតែម៉្យាងថា បទថា **ភគវតោ កាយំ** សំដៅដល់ បង្អោនកាយរបស់ខ្លួនចូលទៅរកព្រះមានព្រះភាគ បន្ទាប់អំពីនោះ សូចិលោមយក្ខ ឃើញព្រះមានព្រះភាគមិនញាប់ញ័រ ទើបពោលថា ព្រះសមណៈ យើងនឹងសួរប្រស្នាចំពោះលោក ដូច្នេះជាដើម ។

សួរថា ព្រោះហេតុអ្វី ទើបសូចិលោមយក្ខសួរប្រស្នា ឆ្លើយថា ព្រោះសូចិលោមយក្ខនោះគិតថា សមណៈនេះជាមនុស្ស រមែងមិនខ្លាចអញ ដោយសម្ផស្សដែលជារបស់អមនុស្ស គ្រោតគ្រាតយ៉ាងនេះ ណ្ហើយចុះ អញនឹងសាកសួរសមណៈនេះ ក្នុងបញ្ហាដែលជាពុទ្ធវិស័យ សមណៈនេះ នឹងឆ្លើយមិនបានក្នុងបញ្ហានេះដោយពិត បន្ទាប់អំពីនោះ អញនឹងបៀតបៀនសមណៈនេះយ៉ាងនេះ ដូច្នេះហើយ ទើបសួរបញ្ហា ។ ព្រះមានព្រះភាគទ្រង់ស្តាប់បញ្ហានោះហើយ ត្រាស់ថា **ន ខ្វាហំ តំ អាវុសោ** ជាដើម ពាក្យទាំងពួងនោះបណ្ឌិតគប្បីជ្រាបដោយអាការគ្រប់យ៉ាង តាមន័យដែលខ្ញុំពោលហើយ ក្នុងអាឡវកសូត្រនោះឯង ។

[ ២៧ ] គ្រានោះ សូចិលោមយក្ខបានពោលជាមួយនឹងព្រះមាន

ព្រះភាគដោយគាថាថា **រាគោ ច ទោសោ ច** ជាដើម ។

ក្នុងបណ្ដាពាក្យទាំងនោះ រាគៈ និងទោសៈ មានន័យដូចខ្ញុំបានពោលហើយនោះឯង ។

បទថា **កុតោនិទានា** បានដល់ មានអ្វីជានិទាន គឺមានអ្វីជាហេតុ គប្បីជ្រាប **តា** អាទេស **តោ** បច្ច័យ នៃសត្តមីវិភត្តិ ប្រើក្នុងអត្ថនៃបឋមាវិភត្តិ ( ក្នុងពាក្យថា **កុតោនិទានា** ) ក្នុងសមាស មិនមានការលុប **តោ** បច្ច័យនោះទេ ។

ម្យ៉ាងទៀត ពាក្យថា **និទានា** បានដល់ កើតហើយ អធិប្បាយថា កើតឡើងហើយ ព្រោះដូច្នោះ ទើបមានពាក្យអធិប្បាយថា កើតហើយអំពីណា គឺកើត បានដល់ កើតឡើងហើយអំពីណា ។ ក្នុងពាក្យថា **អរតី រតី លោមហំសោ កុតោជា** សេចក្ដីថា សូចិលោមយក្ខសួរថា ធម៌ទាំង ៣ ប្រការនេះ គឺការមិនពេញចិត្ត ដែលលោកចែកយ៉ាងនេះថា ការមិនត្រេកអរ អាការមិនត្រេកអរ សេចក្ដីមិនត្រេកអរចំពោះអាការមិនត្រេកអរ ចំពោះការអផ្សុក សេចក្ដីសោប់សល់ ក្នុងសេនាសនៈដ៏ស្ងាត់ក្ដី ក្នុងធម៌ទាំងឡាយជាកុសលដ៏លើសលុបណាមួយក្ដី ១ ការត្រេកអរក្នុងកាមគុណទាំងប្រាំ ១ ការតក់ស្លុតនៃចិត្តដែលដល់នូវការរាប់ថា ព្រឺរោមព្រឺស្បែក ព្រោះជាទីតាំងនៃការខ្លាច ១ កើតអំពីអ្វី ។

បទថា **កុតោ សមុដ្ឋាយ** បានដល់ កើតអំពីអ្វី ។ បទថា **មនោ**

សំដៅដល់ កុសលចិត្ត ។ វិតក្ក ៩ យ៉ាង មានកាមវិតក្កជាដើម ដែលលោកពោលក្នុងឧរគសូត្រ ឈ្មោះថា **វិតក្កា** ។ ដោយបាទគាថាថា **កុមារកា ធង្ខមិវោស្សជន្តិ** សូចិលោមយក្ខសួរថា ពួកក្មេងអ្នកស្រុកលេងយកអំបោះចងជើងក្អែក ហើយលែងទៅ បានដល់ បោះទៅ យ៉ាងណា អកុសល-វិតក្កកើតឡើងអំពីណា រមែងឈមចុះកាន់អកុសលចិត្ត ដូច្នោះ ។

កាលនោះ ព្រះមានព្រះភាគ កាលទ្រង់ឆ្លើយបញ្ហារបស់សូចិលោមយក្ខនោះ ទើបត្រាស់គាថាទី ២ ថា **រាគោ ច** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **ឥតោ** ព្រះមានព្រះភាគត្រាស់សំដៅដល់អត្តភាព ។ ពិតហើយ រាគៈ និងទោសៈ កើតអំពីអត្តភាព ការមិនត្រេកអរ ការត្រេកអរ និងការព្រឺរោមព្រឺស្បែក ក៏កើតអំពីអត្តភាព ឯអកុសលវិតក្កមានកាមវិតក្កជាដើម ក៏តាំងឡើងអំពីអត្តភាពដូចគ្នា ហើយឈមចុះក្នុងចិត្តគឺអកុសល ព្រះមានព្រះភាគទ្រង់បដិសេធដល់ហេតុ មានបកតិជាដើមដទៃនោះ ដោយពាក្យថា អត្តភាពនោះ ទើបត្រាស់ថា កើតហើយអំពីអត្តភាពនេះ កើតឡើងអំពីអត្តភាពនេះ តាំងឡើងព្រមហើយអំពីអត្តភាពនេះ ។ ឯការសម្រេចនៃសព្ទ ក្នុងពាក្យថា **ឥតោ សមុដ្ឋាយ មនោ វិតក្កា** ជាដើមនេះ គប្បីជ្រាបដោយន័យដែលខ្ញុំពោលហើយក្នុងគាថាទី ១ ។

ព្រះមានព្រះភាគ កាលទ្រង់វិសជ្ជនាបញ្ហាទាំងនេះយ៉ាងនេះហើយ កាលទ្រង់ញ៉ាំងអត្ថឲ្យសម្រេចដូចពោលថា មានអត្តភាពជាហេតុកើត កើតអំពី

អត្តភាព តាំងឡើងអំពីអត្តភាព ក្នុងពាក្យទាំងឡាយ មានពាក្យថា **ឥតោ-និទានា** ជាដើម ទើបត្រាស់ថា **ស្នេហជា អត្តសម្ភូតា** ជាដើម ។

កិលេសទាំងពួង មានរាគៈជាដើម មានវិតក្កជាបរិយោសាន កើតដោយការជាប់ជំពាក់ ដោយអំណាចតណ្ហា កាលកើតឡើងយ៉ាងនោះ ឈ្មោះថា កើតហើយក្នុងខ្លួន ដែលជាបរិយាយនៃអត្តភាព មានឧបាទានក្ខន្ធ ៥ ជាដើម ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ស្នេហជា អត្តសម្ភូតា** ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ធ្វើឧបមា ធ្វើបញ្ចាំងអត្ថនោះ ទើបត្រាស់ថា **និគ្រោធស្សេវ ខន្ធជា** ។ ពួកទាំងឡាយ កើតហើយអំពីដើមទាំងឡាយក្នុងដើមជ្រៃនោះ ឈ្មោះថា កើតហើយអំពីដើម ។

បទថា **ខន្ធជា** ជាឈ្មោះរបស់ពួកនៃជ្រៃទាំងឡាយ ។ សួរថា លោកពោលអធិប្បាយដូចម្ដេច ឆ្លើយថា លោកពោលអធិប្បាយថា ពួកនៃជ្រៃទាំងឡាយ ឈ្មោះថា កើតហើយអំពីដើមរបស់ជ្រៃ ។ កាលពួកស្រូបយករសដែលកើតអំពីទឹកមាន ក៏រមែងកើតឡើងបាន កាលកើតឡើង រមែងចម្រើនឡើងក្នុងប្រភេទនៃមែកទាំងឡាយនោះ ត្រង់ដើមជ្រៃនោះឯង យ៉ាងណា កិលេសទាំងឡាយ មានរាគៈជាដើម ក៏ដូច្នោះដូចគ្នា កាលសេចក្ដីស្នេហាគឺតណ្ហាខាងក្នុងមាន ក៏កើតឡើងបាន កាលកើតឡើងក៏រមែងចម្រើនឡើងក្នុងទ្វារ អារម្មណ៍ និងវត្ថុទាំងឡាយ មានចក្ខុជាដើមនោះ ក្នុងអត្តភាពនោះឯង ។ ព្រោះហេតុនោះ ពាក្យថា កិលេសទាំងឡាយ មានរាគៈជាដើមនោះ

កើតអំពីអត្តភាព កើតចាកអត្តភាព និងមានអត្តភាពជាសមុដ្ឋាននេះ បណ្ឌិតគប្បីជ្រាបដូចពណ៌នាមក ដូច្នេះ ។

ឯក្នុងកន្ទះគាថាដ៏សេស មានពណ៌នាអត្ថ ដែលអធិប្បាយរួមទាំងអស់ដូចតទៅនេះ កិលេសទាំងឡាយដ៏ច្រើន កើតហើយក្នុងខ្លួនយ៉ាងនេះ ផ្សាយទៅហើយក្នុងកាមទាំងឡាយ គឺកិលេសទាំងអស់នេះ ដោយប្រការទាំងពួង គឺរាគៈកើតឡើងក្នុងខ្លួន ដោយអំណាចនៃកាមគុណ ៥ ក្តី ទោសៈដែលកើតឡើងក្នុងខ្លួន ដោយអំណាចនៃអាឃាតវត្ថុជាដើមក្តី កិលេសទាំងឡាយ មានការមិនពេញចិត្តជាដើម ដែលកើតឡើងក្នុងខ្លួន ដោយអំណាចប្រភេទនៃកិលេសនោះឯងក្តី មានច្រើន គឺមានជាអនេក ផ្សាយទៅហើយ គឺកើតហើយជាប់ហើយ ជាប់ជំពាក់ហើយ ជាប់ជំពាក់តាំងនៅហើយ ដោយប្រការនោះៗក្នុងវត្ថុទាំងឡាយនោះៗ ដោយអំណាចនៃវត្ថុ ទ្វារ និងអារម្មណ៍ជាដើម ។

សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា ដូចពួរជ្រៃគ្របដណ្តប់ហើយក្នុងព្រៃ ធម្មតាពួរនៃជ្រៃទាំងឡាយ ដែលគ្របដណ្តប់ហើយក្នុងព្រៃ រមែងជាវល្លិដែលរួបរឹត គឺតោង ចាប់យក រួបរឹតត្រង់ដើមជ្រៃទាំងឡាយ មានមែកតូចនិងមែកធំជាដើម តាំងនៅហើយ យ៉ាងណា សត្វទាំងឡាយណា ដឹងច្បាស់នូវពួកកិលេសនោះ ដែលផ្សាយទៅក្នុងវត្ថុកាមទាំងឡាយ ដែលមានច្រើនប្រភេទយ៉ាងនេះ កើតអំពីហេតុអ្វី ម្នាលយក្ខ ចូរអ្នកស្តាប់ សត្វនោះ តែងបន្ទោបង់នូវពួកកិលេសនោះចេញបាន ។

បណ្តាបទទាំងនោះ បទថា **យតោនិទានំ** ជាការសម្តែងដល់ទបុំ-សកលិង្គ ដោយពាក្យថា **យតោ និទានំ** នោះ ព្រះមានព្រះភាគទ្រង់សម្តែង អ្វី ។ សត្វពួកណា រមែងដឹងពួកនៃកិលេសនោះយ៉ាងនេះថា កើតអំពីហេតុណា សត្វទាំងនោះ ដឹងនូវពួកនៃកិលេសនោះថា រមែងកើតឡើងក្នុងអត្តភាព ដែលជាប់ជំពាក់ហើយ ដោយជ័រ គឺតណ្ហា ហើយជម្រះជ័រ គឺតណ្ហានោះចេញ ដោយភ្លើង គឺភាវនាញាណ មានអាទីនវានុបស្សនាជាដើម រមែងបន្ទោបង់ បានដល់ រមែងលះ គឺរមែងធ្វើឲ្យអស់ ម្នាលយក្ខ ចូរអ្នកស្តាប់សុភាសិតរបស់តថាគតនោះ ។ ក្នុងបទថា **យតោនិទានំ** នេះ ព្រះមានព្រះភាគទ្រង់សម្តែងការកំណត់ដឹងទុក្ខ ដោយការដឹងច្បាស់នូវអត្តភាព និងការលះសមុទយៈ ដោយបន្ទោបង់ពួកកិលេស មានរាគៈជាដើម ដែលជាជ័រ គឺតណ្ហា សត្វពួកណា រមែងបន្ទោបង់នូវពួកកិលេសនោះបាន សត្វទាំងនោះឈ្មោះថា រមែងឆ្លងផុតឱឃៈដែលឆ្លងបានដោយកម្រ គឺដែលខ្វនមិនធ្លាប់ឆ្លង ។ ព្រះមានព្រះភាគ ទ្រង់សម្តែងមគ្គភាវនា និងការធ្វើនិរោធឲ្យជាក់ច្បាស់ អធិប្បាយថា សត្វពួកណា រមែងបន្ទោបង់នូវពួកនៃកិលេសនោះបាន សត្វទាំងនោះ ឈ្មោះថា អប់រំមគ្គដោយពិត ព្រោះថា បើវៀរចាកមគ្គភាវនាហើយ ការបន្ទោបង់កិលេសនឹងមិនមាន ហើយសត្វពួកណា រមែងអប់រំមគ្គ សត្វទាំងនោះ ឈ្មោះថា រមែងឆ្លងឱឃៈទាំង ៤ យ៉ាង មានកាមោឃៈជាដើម ដែលឆ្លងបានដោយកម្រនេះបាន ដោយញាណបកតិ ។ ពិតហើយ ការឆ្លង

ឱឃៈនឹងមាន ក៏ព្រោះមគ្គភាវនា ។

បទថា **អតិណ្ណបុព្វំ** បានដល់ ដែលខ្លួនមិនធ្លាប់ឆ្លង ដោយហោច ក្នុងការយល់សប្តិអស់កាលដ៏យូរមកនេះ ។

បទថា **អបុនព្ភវាយ** បានដល់ ដើម្បីព្រះនិព្វាន ។

យក្ខដែលជាសម្លាញ់ទាំង ២ នោះ ស្តាប់ពាក្យដែលសម្តែងសច្ចៈ ៤ ប្រការនេះដូច្នេះ ឈមចុះទៅដោយលំដាប់ ដោយបញ្ញាដែលខ្លួនអប់រំល្អ ហើយ ដូចពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ កាលស្តាប់ហើយ រមែងទ្រទ្រង់ចាំបាន រមែងចូលទៅពិចារណាអត្ថនៃធម៌ ដែលខ្លួនទ្រទ្រង់ហើយ ដូច្នេះ ក៏តាំងនៅក្នុងសោតាបត្តិផល ក្នុងទីបំផុតនៃគាថានោះឯង ជាអ្នកជ្រះថ្លា ជាអ្នកមានពណ៌សម្បុរដូចមាស ប្រដាប់ដោយអលង្ការដែលជាទិព្វ គួរជ្រះថ្លា ។ល។

## អដ្ឋកថា សូចិលោមសូត្រទី ៥ ចប់

# ក្បាលទី ៣៧

# សុត្តន្តបិដក ចាលីប្រែ -៥៤

សន្ទឹកចង្អុលប្រាប់មាតិកា

| មាតិកា | | លេខទំព័រ |
|---|---|---|

## ឧរគវគ្គទី ១


ឧរគសូត្រទី ១ ...... ...... ...... ...... ១
អដ្ឋកថាឧរគសូត្រ ...... ...... ...... ...... ៦
អត្ថរបស់អន្តរសព្ទ ...... ...... ...... ...... ៤៧
ធនិយសូត្រទី ២ ...... ...... ...... ...... ៦០
អដ្ឋកថាធនិយសូត្រ ...... ...... ...... ...... ៦៤
អត្ថរបស់ព្រហ្មចរិយសព្ទ ...... ...... ...... ...... ១០០
ខគ្គវិសាណសូត្រទី ៣ ...... ...... ...... ...... ១០៩
អដ្ឋកថាខគ្គវិសាណសូត្រ ...... ...... ...... ...... ១១៨
គាថាទី ១ ...... ...... ...... ...... ១១៨
គាថាទី ២ ...... ...... ...... ...... ១៥៧
គាថាទី ៣ ...... ...... ...... ...... ១៦៦
គាថាទី ៤ ...... ...... ...... ...... ១៧១
គាថាទី ៥ ...... ...... ...... ...... ១៧៤
គាថាទី ៦ ...... ...... ...... ...... ១៨៦
គាថាទី ៧ ...... ...... ...... ...... ១៨៩
គាថាទី ៨ ...... ...... ...... ...... ១៩១
គាថាទី ៩ ...... ...... ...... ...... ១៩៦

| | | |
|---|---|---|
| គាថាទី ១០ | ...... ...... ...... ...... | ១៩៩ |
| គាថាទី ១១-១២ | ...... ...... ...... ...... | ២០៣ |
| គាថាទី ១៣ | ...... ...... ...... ...... | ២០៨ |
| គាថាទី ១៤ | ...... ...... ...... ...... | ២១១ |
| គាថាទី ១៥ | ...... ...... ...... ...... | ២១៣ |
| គាថាទី ១៦ | ...... ...... ...... ...... | ២១៧ |
| គាថាទី ១៧ | ...... ...... ...... ...... | ២២០ |
| គាថាទី ១៨ | ...... ...... ...... ...... | ២២៣ |
| គាថាទី ១៩ | ...... ...... ...... ...... | ២២៤ |
| គាថាទី ២០ | ...... ...... ...... ...... | ២២៨ |
| គាថាទី ២១ | ...... ...... ...... ...... | ២៣៣ |
| គាថាទី ២២ | ...... ...... ...... ...... | ២៣៥ |
| គាថាទី ២៣ | ...... ...... ...... ...... | ២៣៩ |
| គាថាទី ២៤ | ...... ...... ...... ...... | ២៤២ |
| គាថាទី ២៥ | ...... ...... ...... ...... | ២៤៥ |
| គាថាទី ២៦ | ...... ...... ...... ...... | ២៤៨ |
| គាថាទី ២៧ | ...... ...... ...... ...... | ២៤៩ |
| គាថាទី ២៨ | ...... ...... ...... ...... | ២៥២ |
| គាថាទី ២៩ | ...... ...... ...... ...... | ២៥៤ |
| គាថាទី ៣០ | ...... ...... ...... ...... | ២៥៧ |
| គាថាទី ៣១ | ...... ...... ...... ...... | ២៥៩ |
| គាថាទី ៣២ | ...... ...... ...... ...... | ២៦១ |
| គាថាទី ៣៣ | ...... ...... ...... ...... | ២៦៣ |

| | | |
|---|---|---|
| គាថាទី ៣៤ | ...... ...... ...... ...... | ២៦៥ |
| គាថាទី ៣៥ | ...... ...... ...... ...... | ២៧១ |
| គាថាទី ៣៦ | ...... ...... ...... ...... | ២៧២ |
| គាថាទី ៣៧ | ...... ...... ...... ...... | ២៧៥ |
| គាថាទី ៣៨ | ...... ...... ...... ...... | ២៧៩ |
| គាថាទី ៣៩ | ...... ...... ...... ...... | ២៨២ |
| គាថាទី ៤០ | ...... ...... ...... ...... | ២៨៤ |
| គាថាទី ៤១ | ...... ...... ...... ...... | ២៨៦ |
| កសិភារទ្វាជសូត្រទី ៤ | ...... ...... ...... ...... | ២៩០ |
| អដ្ឋកថាកសិភារទ្វាជសូត្រ | ...... ...... ...... ...... | ២៩៥ |
| ចុន្ទសូត្រទី ៥ | ...... ...... ...... ...... | ៣៤៩ |
| អដ្ឋកថាចុន្ទសូត្រ | ...... ...... ...... ...... | ៣៥១ |
| បរាភវសូត្រទី ៦ | ...... ...... ...... ...... | ៣៦៩ |
| អដ្ឋកថាបរាភវសូត្រ | ...... ...... ...... ...... | ៣៧៣ |
| វសលសូត្រទី ៧ | ...... ...... ...... ...... | ៣៨៩ |
| អដ្ឋកថាវសលសូត្រ | ...... ...... ...... ...... | ៣៩៦ |
| អត្ថរបស់សាធុសព្ទ | ...... ...... ...... ...... | ៤០០ |
| មេត្តសូត្រទី ៨ | ...... ...... ...... ...... | ៤៣៦ |
| អដ្ឋកថា មេត្តសូត្រ | ...... ...... ...... ...... | ៤៣៨ |
| ហេមវតសូត្រទី ៩ | ...... ...... ...... ...... | ៤៧៦ |
| អដ្ឋកថាហេមវតសូត្រ | ...... ...... ...... ...... | ៤៨១ |
| អាឡវកសូត្រទី ១០ | ...... ...... ...... ...... | ៥២៧ |
| អដ្ឋកថាអាឡវកសូត្រ | ...... ...... ...... ...... | ៥៣១ |

អត្ថរបស់សច្ចសព្ទ ...... ...... ...... ...... ៥៥៨
អត្ថរបស់អត្ថសព្ទ ...... ...... ...... ...... ៥៧០
វិជយសូត្រទី ១១ ...... ...... ...... ...... ៥៧៧
អដ្ឋកថាវិជយសូត្រ ...... ...... ...... ...... ៥៧៩
មុនិសូត្រទី ១២ ...... ...... ...... ...... ៦០៤
អដ្ឋកថាមុនិសូត្រ ...... ...... ...... ...... ៦០៨
រតនសូត្រទី ១ ...... ...... ...... ...... ៦៥១
អដ្ឋកថារតនសូត្រ ...... ...... ...... ...... ៦៥៧
អាមគន្ធសូត្រទី ២ ...... ...... ...... ...... ៧៤០
អដ្ឋកថាអាមគន្ធសូត្រ ...... ...... ...... ...... ៧៤៤
ហិរិសូត្រទី ៣ ...... ...... ...... ...... ៧៧៧
អដ្ឋកថាហិរិសូត្រ ...... ...... ...... ...... ៧៧៨
មង្គលសូត្រទី ៤ ...... ...... ...... ...... ៧៩០
អដ្ឋកថាមង្គលសូត្រ ...... ...... ...... ...... ៧៩៣
អត្ថរបស់អភិក្កន្តសព្ទជាដើម ...... ...... ...... ...... ៨០៣
សូចិលោមសូត្រទី ៥ ...... ...... ...... ...... ៨៧៩
អដ្ឋកថាសូចិលោមសូត្រ ...... ...... ...... ...... ៨៨១